# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៥១

បាលីប្រែ ៦២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# ជាតកដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ ជាតក

# ឯកាទសមភាគ

# ៥១

# បាលីប្រែ ៦២



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥៧

# សុត្តន្តបិដក ខុទ្ទកនិកាយ

# ជាតក

# បកិណ្ណកសមភាគ

## មហានិបាត ជាតក

## តេមិយជាតក

[ ១ ] *( ទេវតាពោលថា ) អ្នកកុំប្រកាសនូវភាពជាអ្នកប្រាជ្ញ ចូរឲ្យជនទាំងពួងដឹងថាជាមនុស្សល្ងង់ ជនទាំងអស់ ចូរមើលងាយអ្នកចុះ សេចក្តីចម្រើននឹងមានដល់អ្នក ដោយវិធីយ៉ាងនេះ ។*

[ ២ ] *( ព្រះមហាសត្វត្រាស់ថា ) បពិត្រទេវតា អ្នកនិយាយពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកនោះ បពិត្រទេវតា អ្នក ឈ្មោះថា ប្រាថ្នានូវសេចក្តីចម្រើនដល់ខ្ញុំ បពិត្រទេវតា អ្នក ឈ្មោះថា ប្រាថ្នានូវប្រយោជន៍ ( ដល់ខ្ញុំ ) ។*

[ ៣ ] *( ព្រះមហាសត្វ ) នែនាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្តៅ តើព្រោះហេតុអ្វី ម្នាលសម្លាញ់ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅ ។*

[ ៤ ] *( នាយសារថី ) ព្រះរាជបុត្តកើតមកហើយ គជង ខ្វិន*

ផង ដូចជាឥតចិត្ត ឯខ្ញុំនោះ ព្រះរាជាទ្រង់ត្រាស់ប្រើមកហើយថា អ្នកត្រូវជីកកប់កូនអញក្នុងព្រៃចុះ ។

[ ៥ ] ( ព្រះមហាសត្វ ) ខ្ញុំមិនថ្លង់ មិនគ មិនខ្វិនទេ មិនមែនវិកលវិការទេ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថាធ្វើខុសធម៌ អ្នកចូរមើលភ្លៅ និងដើមដៃខ្ញុំ ទាំងចូរស្តាប់សម្តីខ្ញុំ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសធម៌ ។

[ ៦ ] ( នាយសារថី ) អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាបុរិន្ទទ-សក្កទេវរាជ អ្នកជាអ្វី ទាំងជាកូនអ្នកណា យើងនឹងស្គាល់អ្នកបាន ដោយប្រការដូចម្តេច ។

[ ៧ ] ( ព្រះមហាសត្វ ) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាបុរិន្ទទសក្កទេវរាជទេ អ្នកកប់បុគ្គលណាក្នុងរណ្តៅ បុគ្គលនោះ គឺខ្ញុំជាកូនរបស់ព្រះបាទកាសិកៈ អ្នករស់នៅដោយស្រួល ( ព្រោះអាស្រ័យ ) នូវព្រះរាជាណា ខ្ញុំជាកូនរបស់ព្រះរាជានោះ នែនាយសារថី បើអ្នកនឹងកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ បុគ្គលគប្បីអង្គុយ ឬដេកក្រោមម្លប់ឈើណា មិនគប្បីកាច់បំបាក់មែកឈើនោះទេ ព្រោះថា អ្នកទ្រុស្តមិត្តជាមនុស្សលាមក នែនាយសារថី ព្រះរាជាទុកដូចជាដើមឈើ ខ្លួនខ្ញុំទុកដូចជាមែកឈើដែរ អ្នកឯងទុកដូចបុរសដែលចូលទៅជ្រកក្រោមម្លប់ឈើ ដូច្នោះ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ

អ្នក ឈ្មោះថា ធ្វើខុសធម៌ ។

[ ៨ ] បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ បុគ្គលនោះ បើចេញផុតអំពីផ្ទះរបស់ខ្លួនហើយ ជាអ្នកមានភក្ខាហារច្រើន ជនច្រើននាក់ តែងចិញ្ចឹមជីវិត ( អាស្រ័យ ) បុគ្គលនោះ ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ បុគ្គលនោះទៅកាន់ជនបទ និគម រាជធានីណាៗ គេតែងបូជាក្នុងទីទាំងអស់នោះ ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ ពួកចោរមិនកំហែង បុគ្គលនោះ សត្វក៏មិនមើលងាយបុគ្គលនោះ បុគ្គលនោះ រមែងកន្លងនូវសត្រូវទាំងអស់ ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ បុគ្គលនោះមិនខឹង មកកាន់ផ្ទះរបស់ខ្លួន ជាអ្នកគេទទួលរីករាយក្នុងរោងសម្រាប់ប្រជុំ ជាបុគ្គលឧត្តមរបស់ពួកញាតិ ។ បុគ្គលធ្វើសក្ការៈចំពោះ ( មិត្ត ) រមែងត្រូវមិត្តធ្វើសក្ការៈវិញ ជាអ្នកគោរព ( មិត្ត ) រមែងបានសេចក្តីគោរពវិញ បុគ្គលមិនប្រទូស្តមិត្ត រមែងពេញដោយគុណ និងកិត្តិសព្ទ ។ បុគ្គលអ្នកបូជាមិត្ត រមែងបានការបូជាវិញ ជាអ្នកសំពះមិត្ត រមែងបានការសំពះតបវិញ បុគ្គលមិនប្រទូស្តមិត្ត រមែងដល់នូវយសបរិវារ និងកិត្តិសព្ទ ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ បុគ្គលនោះ រមែងរុងរឿងដូចភ្លើង រុងរឿងដូចទេវតា ជាអ្នកមិនលះបង់ចាកសិរីឡើយ ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ គោទាំងឡាយ របស់បុគ្គល

នោះ សម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះសាបព្រោះក្នុងស្រែ រមែងដុះដាល បុគ្គលនោះ រមែងបរិភោគផ្លែនៃពូជទាំងឡាយ ដែលខ្លួនសាបព្រោះហើយ ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ បុគ្គលនោះ សូម្បីធ្លាក់ទៅក្នុងជ្រោះក្តី អំពីភ្នំក្តី អំពីដើមឈើក្តី ធ្លាក់ហើយរមែងបានទីពឹង ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ សត្រូវទាំងឡាយ គ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់ មិនអាចគ្របសង្កត់ដើមជ្រៃ ដែលមានឫស និងពួរដុះហើយ ។

[ ៩ ] ( នាយសារថី ) បពិត្រព្រះរាជបុត្ត សូមទ្រង់ស្តេចមកទូលព្រះបង្គំជាខ្ញុំ នឹងនាំទ្រង់ទៅកាន់ដំណាក់របស់ព្រះអង្គ សូមទ្រង់សោយរាជ្យចុះ សេចក្តីចម្រើននឹងមានដល់ទ្រង់ ទ្រង់នឹងធ្វើអ្វីក្នុងព្រៃ ។

[ ១០ ] ( ព្រះមហាសត្វ ) នែនាយសារថី រាជសម្បត្តិណាដែលខ្ញុំគប្បីបានដោយអធម្មចរិយៈ ខ្ញុំមិនត្រូវការដោយរាជសម្បត្តិនោះ ឬដោយជនជាញាតិ ឬក៏ដោយទ្រព្យទេ ។

[ ១១ ] ( នាយសារថី ) បពិត្រព្រះរាជបុត្ត សូមទ្រង់ស្តេចទៅអំពីទីនេះ ហើយញុំាងទូលព្រះបង្គំជាខ្ញុំ ឲ្យបាននូវរង្វាន់ជាទីត្រេកអរ បពិត្រព្រះរាជបុត្ត កាលបើព្រះអង្គស្តេចទៅហើយ ព្រះរាជបិតា និងព្រះមាតា គប្បីប្រទាន ( រង្វាន់ ) ដល់ទូលព្រះបង្គំជាខ្ញុំ ។

បពិត្រព្រះរាជបុត្ត កាលទ្រង់ស្តេចទៅហើយ ពួកស្រីស្នំ និង រាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ជនទាំងអម្បាលនោះ មានចិត្តត្រេកអរ គប្បីឲ្យ ( រង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ) ។ បពិត្រព្រះរាជបុត្ត កាលទ្រង់ស្តេចទៅហើយ ពួកហ្មដំរី ពួកពល រក្សាព្រះអង្គ ពួកពលរថ ពួកថ្មើរជើង ជនទាំងអម្បាលនោះ មានចិត្តត្រេកអរ គប្បីឲ្យ ( រង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ) ។ បពិត្រព្រះរាជបុត្ត កាលទ្រង់ស្តេចទៅ ពួកអ្នកជនបទ និងពួក អ្នកនិគម មានធញ្ញាហារច្រើន មកប្រជុំគ្នា គប្បីឲ្យគ្រឿង បណ្ណាការទាំងឡាយ ដល់ទូលព្រះបង្គំជាខ្ញុំ ។

[ ១២ ] ( ព្រះមហាសត្វ ... ) ខ្ញុំដែលព្រះបិតាមាតា អ្នកដែន អ្នកនិគម និងពួករាជកុមារទាំងពួង បានលះបោលហើយ ផ្ទះរបស់ ខ្លួនខ្ញុំមិនមានទេ ខ្ញុំដែលព្រះមាតាបានអនុញ្ញាត ឲ្យទទួលរាជ្យ ៧ ថ្ងៃហើយ ខ្ញុំដែលព្រះបិតា លះបោលស្រឡះហើយ ខ្ញុំនឹង បួសនៅក្នុងព្រៃតែម្នាក់ឯង មិនប្រាថ្នានូវកាមទាំងឡាយឡើយ ។

[ ១៣ ] សេចក្តីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំ កាលមិន ប្រញាប់ប្រញាល់ ( អស់ ១៦ ឆ្នាំ ) ខ្ញុំជាអ្នកមានព្រហ្ម- ចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹង

មានភ័យអំពីណា ។

[ ១៤ ] ( នាយសារថី ... ) ទ្រង់នោះ មានព្រះបន្ទូលពីរោះ មានព្រះបន្ទូលក្បោះក្បាយយ៉ាងនេះ ហេតុអ្វីបានជាទ្រង់មិនមានព្រះបន្ទូលក្នុងសម្នាក់នៃព្រះបិតាព្រះមាតា ក្នុងពេលនោះ ។

[ ១៥ ] ( ព្រះមហាសត្វ ... ) ខ្ញុំមិនមែនខ្វិន ព្រោះមិនមានសទ្ធាក់ទេ ខ្ញុំមិនមែនថ្លង់ ព្រោះមិនមានសោតប្រសាទទេ ខ្ញុំមិនមែនគ ព្រោះមិនមានជិវ្ហាប្រសាទទេ អ្នកកុំសម្គាល់ខ្ញុំថា ជាមនុស្សគឡើយ ។ ខ្ញុំរឭកឃើញនូវជាតិមុន ជាជាតិដែលខ្ញុំបានសោយរាជ្យ លុះខ្ញុំសោយរាជ្យក្នុងជាតិនោះហើយ ក៏ធ្លាក់នរកគួរស្ញើប ។ ខ្ញុំសោយរាជ្យក្នុងជាតិនោះអស់ ២០ ឆ្នាំ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ ។ ខ្ញុំខ្លាចរាជ្យនោះ កុំឲ្យព្រះមាតាបិតា អភិសេកខ្ញុំក្នុងរាជ្យ ព្រោះហេតុនោះ បានជាខ្ញុំមិននិយាយក្នុងសម្នាក់នៃព្រះបិតាមាតា ក្នុងកាលនោះ ។ ព្រះរាជបិតា បានឲ្យខ្ញុំអង្គុយលើព្រះឧរុ ហើយទ្រង់វិនិច្ឆ័យក្ដីថា អ្នកទាំងឡាយ ចូរសម្លាប់ចោរ ១ នាក់ ចូរចងចោរ ១ នាក់ ( ធ្វើចោរ ១ នាក់ ) ឲ្យប្រឡាក់ដោយទឹកក្បុង ។ ចូរដោតចោរ ១ នាក់ លើឈើស្រួច ព្រះរាជបិតាត្រាស់បង្គាប់មហាជន ដោយប្រការដូច្នេះ លុះខ្ញុំស្ដាប់នូវវាចាដ៏អាក្រក់នោះ ដែលព្រះរាជបិតាទ្រង់ត្រាស់ហើយ ។ ខ្ញុំមិនគរទេ តែមានភេទដូចបុគ្គលគរ ខ្ញុំមិនខ្វិនទេ តែសន្មតថាដូចជាខ្វិន ខ្ញុំបាននៅជ្រមុជ

ជ្រមុលក្នុងមូត្រ និងករីសរបស់ខ្លួន ។ ជីវិត ( របស់សត្វ ) លំបាកផង តិចផង ជីវិតនោះ ប្រកបដោយទុក្ខ បុគ្គលណា អាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរ ដោយហេតុណា នីមួយ ។ បុគ្គលណា អាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរ ដោយហេតុណានីមួយ ព្រោះមិនបានបញ្ញាផង ព្រោះមិនឃើញធម៌ផង ។ សេចក្ដីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំកាល មិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមាន ព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យ អំពីណា ។

[ ១៦ ] ( នាយសារថី ) បពិត្រព្រះរាជបុត្ត ទូលព្រះបង្គំជាខ្ញុំ នឹងបួស ក្នុងសម្នាក់ព្រះអង្គ បពិត្រព្រះរាជបុត្តដ៏ចម្រើន សូមទ្រង់ត្រាស់ហៅទូលព្រះបង្គំជាខ្ញុំ ( ឲ្យបួសផង ) ទូលព្រះបង្គំជាខ្ញុំ ពេញចិត្តនឹងបព្វជ្ជាដែរ ។

[ ១៧ ] ( ព្រះមហាសត្វ ) នែ នាយសារថី អ្នកចូរប្រគល់នូវរថ ហើយជាអ្នកមិនមានបំណុល សឹមមកចុះ ព្រោះថា បព្វជ្ជា ( រមែងសម្រេច ) ដល់បុគ្គលមិនមានបំណុល បព្វជ្ជាកម្មនេះ ពួកឥសីសរសើរហើយ ។

[ ១៨ ] ( នាយសារថី ) សេចក្តីចម្រើនចូរមានដល់ទ្រង់ ពាក្យណាដែលទ្រង់បានថ្លែងហើយ ទូលព្រះបង្គំជាខ្ញុំ នឹងធ្វើតាមពាក្យនោះ ទ្រង់ដែលទូលព្រះបង្គំជាខ្ញុំ អង្វរហើយ គួរធ្វើតាមពាក្យរបស់ទូលព្រះបង្គំជាខ្ញុំនោះផង ។ សូមទ្រង់ស្តេចគង់នៅក្នុងទីនេះដរាបដល់ទូលព្រះបង្គំជាខ្ញុំ នាំព្រះរាជាមកដល់ ព្រះបិតារបស់ទ្រង់ទតឃើញហើយ សមជាមានព្រះហឫទ័យ ត្រេកអររីករាយ ។

[ ១៩ ] ( ព្រះមហាសត្វ ) នៃនាយសារថី អ្នកនិយាយពាក្យណានឹងខ្ញុំៗ នឹងធ្វើតាមពាក្យរបស់អ្នកនោះ ឯខ្ញុំមានបំណងដើម្បីជួបព្រះបិតារបស់ខ្ញុំ ដែលទ្រង់ស្តេចយាងមកក្នុងទីនេះដែរ ។ ម្នាលសម្លាញ់ អ្នកទៅហើយចូរមកវិញ ចូរត្រឡប់ទៅសិនចុះ អ្នកប្រាប់នូវសេចក្តីសុខដល់ញាតិទាំងឡាយ អ្នកដែលខ្ញុំប្រាប់ហើយគប្បីក្រាបទូលនូវការថ្វាយបង្គំចំពោះព្រះមាតាបិតា ។

[ ២០ ] ( អភិសម្ពុទ្ធគាថា ) នាយសារថីចាប់ព្រះបាទា នៃព្រះមហាសត្វនោះ ហើយក៏ធ្វើប្រទក្សិណព្រះមហាសត្វនោះ រួចឡើងជិះរថ បរចូលទៅកាន់រាជទ្វារ ។

[ ២១ ] ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរដោយព្រះអស្សុ ទ្រង់ព្រះកន្សែង មៀងមើលទៅនាយសារថីនោះ ដែលមកវិញតែឯង ដោយគិតថា នាយសារថីនេះ សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ ។ កូនរបស់អញចម្រើនផែនដី

នាយសារថី កប់ក្នុងផែនដីដោយពិត ពួកសត្រូវរមែងត្រេកអរ ដោយពិត ពួកជនមានពៀរ ត្រេកអរហើយដោយពិត ព្រោះ ឃើញនាយសារថី សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ ។ ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរ ដោយ ព្រះអស្សុ ទ្រង់ព្រះកន្សែង សួរទៅនាយសារថីនោះ ដែលមក វិញតែម្នាក់ឯងថា កូនរបស់ខ្ញុំនោះ ជាមនុស្សគនប្អី ជាមនុស្ស ខ្វិនប្អី កាលអ្នកកប់ក្នុងផែនដី ក្នុងកាលនោះ កូនរបស់ខ្ញុំពិលាប ដែរឬ ម្នាលនាយសារថី អ្នកចូរប្រាប់នូវរឿងនោះដល់ខ្ញុំ ។ ( កូន របស់ខ្ញុំនោះ ) ជាមនុស្សគ ជាមនុស្សខ្វិន កាលអ្នកកប់ក្នុងផែនដី បានកម្រើកដៃ និងជើងដូចម្តេចដែរ ( ម្នាលនាយសារថី ) អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់រឿងនោះ ។

[ ២២ ] ( នាយសារថី ) បពិត្រព្រះនាងជាម្ចាស់ ( បើ ) ព្រះ នាងឲ្យអភ័យដល់ទូលព្រះបង្គំជាខ្ញុំ ហេតុណាដែលខ្ញុំបានឮហើយ ឬបានឃើញហើយ ក្នុងសម្នាក់នៃព្រះរាជបុត្ត ទូលព្រះបង្គំជាខ្ញុំនឹង ក្រាបទូលនូវហេតុនោះ ដល់ព្រះនាង ។

[ ២៣ ] ( ព្រះរាជទេវី ) ម្នាលសារថីសម្លាញ់ ខ្ញុំឲ្យអភ័យដល់ អ្នក ហេតុណាដែលអ្នកបានឮហើយ ឬបានឃើញហើយ ក្នុងសម្នាក់ នៃព្រះរាជបុត្ត អ្នកកុំភិតភ័យ ចូរប្រាប់នូវហេតុនោះចុះ ។

[ ២៤ ] ( នាយសារថី ) ព្រះរាជបុត្តនោះ មិនមែនគទេ ព្រះរាជបុត្តនោះ មិនមែនខ្វិនទេ ឯព្រះរាជបុត្តនោះ មានព្រះបន្ទូលក្បោះក្បាយ បានឮថា ព្រះរាជបុត្តនោះ ទ្រង់ខ្លាចរាជ្យ ទើបបានជាធ្វើនូវពុតត្បុតច្រើនយ៉ាង ។ ព្រះរាជបុត្តនោះ ទ្រង់រឭកឃើញនូវជាតិមុន ជាជាតិដែលបានទ្រង់សោយរាជ្យ លុះសោយរាជ្យក្នុងទីនោះហើយ ធ្លាក់នរកគួរស្ញែង ។ ព្រះរាជបុត្តនោះ បានសោយរាជ្យក្នុងទីនោះ អស់ ២០ ឆ្នាំគត់ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ ។ ព្រះរាជបុត្តនោះ ទ្រង់ខ្លាចរាជ្យនោះហើយ ( ក៏តាំងព្រះរាជហឫទ័យថា ) ព្រះរាជមាតាបិតា កុំអភិសេកអញក្នុងរាជ្យ ព្រោះហេតុនោះ ទើបព្រះរាជបុត្ត មិនមានបន្ទូលក្នុងសម្នាក់នៃព្រះបិតា និងព្រះមាតា ក្នុងកាលនោះ ។ ព្រះរាជបុត្តនោះ បរិបូណ៌ដោយអវយវៈតូចធំ មានកម្ពស់ និងទំហំ ( ដ៏ស៊ីប់សួន ) មានព្រះបន្ទូលដ៏ក្បោះក្បាយ មានបញ្ញា ទ្រង់ឋិតនៅក្នុងផ្លូវសួគ៌ ។ បើព្រះនាងមានប្រាថ្នាដើម្បីឃើញព្រះរាជបុត្ត ជាកូនបង្កើតរបស់ព្រះនាង សូមព្រះនាងយាងទៅចុះ គេមិយកុមារគង់នៅក្នុងទីណា ទូលព្រះបង្គំជាខ្ញុំ នឹងនាំព្រះនាងឲ្យដល់ទីនោះ ។

[ ២៥ ] ( ព្រះបាទកាសិកៈ ) នាយសារថីទាំងឡាយ ចូរទឹមសេះក្នុងរថ អ្នកទាំងឡាយ ចូរចងជង្គន់នាដំរី ស័ង្ខ និងស្គរ ចូរលាន់សំឡេងឡើង ស្គរមានមុខតែម្ខាង ចូរលាន់សំឡេងឡើង ។ ស្គរដែលគេពាសល្អហើយ ចូរបន្លឺសំឡេង ស្គរមានសំឡេងពីរោះ

ចូរលាន់សំឡេងឡើង ទាំងពួកអ្នកនិគម ចូរទៅតាមយើងចុះ យើងនឹងទៅឲ្យឱវាទ ដល់កូនរបស់យើង ។ ពួកស្រីស្នំ និង រាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង ។ ពួកហ្មដំរី ពួកពល សេះ ពួកពលរថ ពួកពលថ្មើរជើង ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង ។ អ្នកជនបទមកប្រជុំគ្នា ទាំងអ្នកនិគមក៏មកប្រជុំគ្នា ហើយចូរទឹមនូវយានឲ្យឆាប់ យើង នឹងទៅឲ្យឱវាទ ដល់កូនរបស់យើង ។

[ ២៦ ] ( អភិសម្ពុទ្ធគាថា ) ឯពួកនាយសារថី ( បាននាំយក ) នូវសេះសិន្ធពទាំងឡាយ ជាពាហនៈមានសម្ទុះដ៏លឿន ដែលទឹម ហើយ ចូលមកកាន់រាជទ្វារ ( ក្រាបបង្គំទូលថា ) បពិត្រព្រះ សម្មតិទេព សេះទាំងឡាយនេះ ទូលព្រះបង្គំជាខ្ញុំបានទឹមរួចហើយ ។

[ ២៧ ] ( ព្រះរាជា ) ពួកសេះធាត់ៗ រមែងសាបសូន្យចាក សម្ទុះ ពួកសេះស្គមៗ រមែងសាបសូន្យចាកកម្លាំង អ្នកទាំងឡាយ ត្រូវវៀរបង់នូវពួកសេះស្គម និងសេះធាត់ចេញ ហើយទឹមតែពួក សេះ ដែលប្រកប ( ដោយវ័យ សម្បុរ សម្ទុះ កម្លាំង ) វិញ ។

[ ២៨ ] លំដាប់នោះ ព្រះរាជា ទ្រង់ប្រញាប់ប្រញាល់ ឡើងគង់ រថដែលនាយសារថីទឹមហើយ ទ្រង់ត្រាស់ទៅនឹងស្រ្តីស្នំថា នាង ទាំងអស់គ្នា ចូរទៅតាមយើងចុះ ។ នាងទាំងឡាយ ចូរប្រដាប់

ដោយមាសទាំងឡាយ ហើយកាន់យកនូវផ្លិត ម្កុដ ព្រះខ័ន ស្វេតច្ឆត្រ និងស្បែកជើង រួចឡើងជិះរថមក ។ បន្ទាប់ពីនោះមក ព្រះរាជាបានឲ្យនាយសារថីដើរមុខ ហើយទ្រង់ស្តេចយាងទៅ តេមិយកុមារនៅក្នុងទីណា ក៏យាងទៅក្នុងទីនោះយ៉ាងឆាប់ ។

[ ២៩ ] តេមិយៈ ទតឃើញព្រះបិតានោះ កំពុងស្តេចយាងមក ហាក់ដូចជារុងរឿងដោយតេជៈ ដែលពួកអមាត្យ អ្នកកាន់ព្រះខ័ន ហែរហមហើយ ទើបត្រាស់សួរព្រះបិតានោះថា បពិត្រព្រះបិតា ព្រះអង្គមានសេចក្តីសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះអង្គមិនមានព្រះអាពាធទេឬ រាជកញ្ញាទាំងអស់ ជាព្រះមាតារបស់ខ្ញុំ មិនមានរោគទេឬ ។

[ ៣០ ] ( ព្រះវរបិតា ) នែកូន ខ្ញុំសុខសប្បាយទេ នែកូន ខ្ញុំមិនមានជំងឺតម្កាត់ទេ រាជកញ្ញាទាំងអស់ ជាមាតារបស់អ្នក មិនមានរោគទេ ។

[ ៣១ ] ( មហាសត្វ ) បពិត្រព្រះបិតា ព្រះអង្គមិនសោយទឹកស្រវឹងទេឬ សុរាមិនពេញព្រះហឫទ័យរបស់ព្រះអង្គទេឬ ព្រះហឫទ័យរបស់ព្រះអង្គ ត្រេកអរក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទានដែរឬ ។

[ ៣២ ] ( ព្រះវរបិតា ) នែកូន ខ្ញុំមិនផឹកទឹកស្រវឹងទេ មួយទៀត សុរាមិនពេញចិត្តខ្ញុំទេ ឯចិត្តរបស់ខ្ញុំ តែងត្រេកអរក្នុងសច្ចៈ ក្នុង

ធម៌ និងក្នុងទាន ។

[ ៣៣ ] ( មហាសត្វ ) យានរបស់ព្រះអង្គ មិនខូចទេឬ វាហនៈរបស់ព្រះអង្គ តែងប្រព្រឹត្តទៅបានដែរឬ ព្យាធិទាំងឡាយ ជាគ្រឿងដុតកម្តៅសរីរៈ មិនមានដល់ព្រះអង្គទេឬ ។

[ ៣៤ ] ( ព្រះវរបិតា ) ឯយានរបស់ខ្ញុំ ឥតមានខូចទេ វាហនៈរបស់ខ្ញុំ ក៏ប្រព្រឹត្តទៅបានដោយស្រួល ព្យាធិទាំងឡាយជាគ្រឿងដុតកម្តៅសរីរៈ មិនមានដល់ខ្ញុំទេ ។

[ ៣៥ ] ( មហាសត្វ ) ជនបទនៅទីប្រទល់ដែន របស់ព្រះអង្គ ( ស្រុក និងនិគម ) របស់ព្រះអង្គទាំងមូល ដែលតាំងនៅកណ្តាលផែនដី ជាស្រុកសម្បូរដែរឬ ឃ្លាំង និងជង្រុក ព្រះអង្គបានតម្កល់ទុកស្រួលបួលទេឬ ។

[ ៣៦ ] ( ព្រះវរបិតា ) ជនបទនៅទីប្រទល់ដែនរបស់ខ្ញុំ ( ស្រុក និងនិគម ) ទាំងមូលរបស់ខ្ញុំ ដែលតាំងនៅកណ្តាលដែន ជាស្រុកសម្បូរ ឃ្លាំង និងជង្រុកទាំងអស់ ខ្ញុំបានតម្កល់ទុកស្រួលបួលហើយ ។

[ ៣៧ ] ( មហាសត្វ ) បពិត្រមហារាជ ព្រះអង្គស្តេចយាងមកល្អហើយ មួយទៀត ព្រះអង្គស្តេចមកមិនមែនអាក្រក់ទេ រាជ-បុរស ចូររៀបចំបល្ល័ង្កជាទីគង់របស់ព្រះរាជា ។

[ ៣៨ ] ព្រះអង្គគង់លើកម្រាលស្លឹកឈើ ដែលគេតែងតាំងហើយ

សូមព្រះអង្គយកទឹកអំពីទីនេះ លាងព្រះបាទារបស់ព្រះអង្គចុះ ។

[ ៣៩ ] បពិត្រព្រះរាជា ស្លឹកនេះដែលអាត្មាភាពចម្អិនហើយ ជារបស់មិនមានរសប្រៃ បពិត្រមហារាជ សូមព្រះអង្គស្តេចសោយចុះ ព្រះអង្គទើបស្តេចយាងមកដល់ ទុកជាភ្ញៀវរបស់អាត្មាភាព ។

[ ៤០ ] ( ព្រះវរបិតា ) ខ្ញុំមិនបរិភោគស្លឹកនេះទេ ព្រោះស្លឹកឈើនេះ មិនមែនជាភោជនរបស់ខ្ញុំ ខ្ញុំបរិភោគតែបាយនៃស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត ។

[ ៤១ ] សេចក្តីអស្ចារ្យកើតប្រាកដដល់ខ្ញុំ ព្រោះឃើញ ( លោក ) នៅស្ងាត់តែម្នាក់ឯង កាលលោកបរិភោគភោជនបែបនេះ សម្បុរនៅតែស្រស់ថ្លា ដោយហេតុដូចម្តេច ។

[ ៤២ ] ( មហាសត្វ ) បពិត្រព្រះរាជា អាត្មាភាពម្នាក់ឯងសឹងលើកម្រាលស្លឹក ដែលតាំងទុកហើយ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាពស្រស់ថ្លា ដោយដំណេកម្នាក់ឯងនោះ ។ ពួកអ្នករក្សាព្រះរាជា ដែលសៀតព្រះខ័ន មិនប្រាកដដល់អាត្មាភាពទេ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាពថ្លាស្រស់ ដោយដំណេកម្នាក់ឯងនោះ ។ អាត្មាភាពមិនតាមសោកនឹងអារម្មណ៍ ដែលកន្លងហើយ មិនប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយវត្ថុដែលលើកឡើងចំពោះមុខ ហេតុនោះ បានជាវណ្ណៈរបស់អាត្មាភាព រមែងថ្លាស្រស់ ។ ជនពាល

ទាំងឡាយ តែងរីងស្ងួត ព្រោះសេចក្តីប្រាថ្នាអារម្មណ៍ដែលមិនទាន់មកដល់ ព្រោះសេចក្តីតាមសោកស្តាយអារម្មណ៍ដែលកន្លងទៅហើយ នេះដូចជាដើមបបុសមានសម្បុរខៀវ ដែលគេដកហាលថ្ងៃ ដូច្នោះ ។

[ ៤៣ ] ( ព្រះវរបិតា ) នែកូន ខ្ញុំនឹងឲ្យនូវពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកជនពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ មួយទៀត ខ្ញុំឲ្យនូវស្រីស្នំដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន ចូរអ្នកគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ អ្នកជាព្រះរាជារបស់យើង ។ ស្ត្រីរបាំជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង បានសិក្សា ( ក្នុងកិច្ចស្ត្រី ) ញុំាងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។ ខ្ញុំនឹងនាំយករាជកញ្ញា ដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃ ដល់អ្នក អ្នកចូរញុំាងកូនទាំងឡាយ ឲ្យកើតក្នុងស្ត្រីទាំងនោះ ហើយសឹមបួសក្នុងកាលជាខាងក្រោយ ។ អ្នកនៅក្មេងកំលោះ ប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យ សេចក្តីចម្រើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។

[ ៤៤ ] ( មហាសត្វ ) បុគ្គលនៅកំលោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីជាកំលោះ ព្រោះថា បព្វជ្ជារបស់បុគ្គលនៅកំលោះនេះ ពួកឥសីទាំងឡាយសរសើរ

ហើយ ។ បុគ្គលនៅកំលោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីនៅកំលោះ អាត្មាភាពនឹងប្រព្រឹត្តព្រហ្មចរិយធម៌ អាត្មាភាពមិនត្រូវការដោយរាជ្យទេ ។ បពិត្រព្រះមាតា និងបិតា អាត្មាភាពឃើញនរជននៅក្មេង ទើបនឹងចេះនិយាយ ជាកូនជាទីស្រឡាញ់ ដែលមាតាបិតាបានដោយលំបាក មិនទាន់ចាស់គ្រាំគ្រាហើយស្លាប់ ។ អាត្មាភាពឃើញនាងកុមារី មានសម្បុរដូចមាស ដែលមច្ចុរាជចាប់ដកក្រយជីវិតហើយ ដូចជាដកនូវទំពាំងឬស្សីដ៏ខ្ចី ។ នរជនទាំងឡាយ ឬនាងនារីទាំងឡាយ សូម្បីនៅក្មេងក៏តែងស្លាប់ តើសត្វណា គប្បីទុកចិត្តក្នុងជីវិតនោះថា អាត្មាអញនៅក្មេងដូច្នេះ ។ អាយុនៃកុមារណា មានប្រមាណតិច ដោយការកន្លងទៅនៃយប់ និងថ្ងៃ ភាពនៃខ្លួនជាកុមារក្នុងវ័យនោះ នឹងធ្វើដូចម្តេចកើត ដូចទីមានទឹកតិចរបស់ត្រីទាំងឡាយ ។ សត្វលោក ត្រូវសត្រូវបៀតបៀនជានិច្ចផង ត្រូវសត្រូវរួបរឹតជានិច្ចផង កាលយប់ និងថ្ងៃទាំងឡាយ មិនកន្លងទៅទទេទទេ តើព្រះអង្គ នឹងអភិសេកអាត្មាភាព ក្នុងរាជ្យដូចម្តេច ។

[ ៤៥ ] ( ព្រះរាជា ) សត្វលោកនេះ ត្រូវសត្រូវអ្វីបៀតបៀនផង ត្រូវសត្រូវអ្វីរួបរឹតផង ធម្មជាតដូចម្តេចមិនកន្លងទៅទទេ ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវដំណើរនោះ ។

[ ៤៦ ] ( ព្រះមហាសត្វ ) សត្វលោក ត្រូវមច្ចុបៀតបៀនផង ត្រូវជរារួបរឹតផង រាត្រីទាំងឡាយ រមែងកន្លងទៅមិនទទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។ កាលតម្បាញ ដែលបុគ្គលត្បាញរបស់ណាៗ ដែលបុគ្គលនឹងត្បាញ របស់ដែលត្រូវត្បាញ ( នោះៗ ) ជារបស់នៅសល់តិច យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញកាលហូរទៅ មិនត្រឡប់ថយក្រោយវិញ យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ កាលកន្លងទៅ មិនត្រឡប់វិញ យ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញ គប្បីបន្សាត់ទៅ នូវដើមឈើទាំងឡាយ ដែលដុះក្បែរច្រាំង យ៉ាងណាមិញ សត្វទាំងអស់ ត្រូវជរា និងមរណៈបន្សាត់ទៅ ក៏យ៉ាងនោះដែរ ។

[ ៤៧ ] ( ព្រះវរបិតា ) នែកូន ខ្ញុំនឹងឲ្យពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកពលពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ មួយទៀត យើងនឹងឲ្យស្ត្រីស្នំដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូនអ្នកចូរគ្រប់គ្រងពួកស្ត្រីទាំងនោះចុះ ។ អ្នកនឹងជារាជារបស់យើង ស្ត្រីរបាំជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង សិក្សា ( ក្នុងកិច្ចរបស់ស្ត្រី ) នឹងញុំាងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។ យើងនឹងនាំយកនូវរាជកញ្ញា ដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃដល់អ្នក អ្នកញុំាងកូនទាំងឡាយ ឲ្យកើតក្នុងពួកនាង

កញ្ញាទាំងនោះ ហើយសឹមបួសក្នុងកាលជាខាងក្រោយចុះ ។ អ្នកនៅក្មេងកំលោះ ប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យចុះ សេចក្តីចម្រើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។ នែកូន ខ្ញុំនឹងឲ្យឃ្លាំង ជង្រុក វាហនៈ ពល និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ អ្នកដែលក្រុមនៃរាជកញ្ញា មានចំណែកដ៏ល្អចោមរោមហើយ មានពួកនៃខ្ញុំស្រ្តីហែហមហើយ ចូរសោយរាជ្យចុះ សេចក្តីចម្រើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។

[ ៤៨ ] ( ព្រះមហាសត្វ ) ប្រយោជន៍អ្វី ដោយទ្រព្យដល់អាត្មាភាព ព្រោះទ្រព្យតែងអស់ទៅ ប្រយោជន៍អ្វី ដោយភរិយា ព្រោះភរិយាក៏គង់ស្លាប់ ប្រយោជន៍អ្វី ដោយវ័យដែលគ្រាំគ្រា ជាវ័យត្រូវជរាគ្របសង្កត់ហើយ ។ ក្នុងលោកសន្និវាសនេះ នៅមានសេចក្តីត្រេកអរអ្វី ការលេងសើចអ្វី ការរីករាយអ្វី ការស្វែងរកទ្រព្យអ្វី អាត្មាភាពត្រូវការអ្វី ដោយកូន និងប្រពន្ធ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះចាកចំណងហើយ ។ អាត្មាភាពដឹងច្បាស់យ៉ាងនេះថា មច្ចុមិនធ្វេសប្រហែសចំពោះអញឡើយ អាត្មាភាពនោះ ត្រូវសេចក្តីស្លាប់គ្របសង្កត់ហើយ នៅមានសេចក្តីត្រេកអរដូចម្តេច ការស្វែងរកទ្រព្យដូចម្តេចទៀត ។ ផ្លែឈើទុំទាំងឡាយ តែងមានភ័យអំពីការជ្រុះជានិច្ច យ៉ាងណាមិញ សត្វ

ទាំងឡាយ កើតមកហើយ តែងមានភ័យអំពីសេចក្តីស្លាប់ជានិច្ច យ៉ាងនោះដែរ ។ ជនជាច្រើន ពួកខ្លះ ដែលគេឃើញក្នុងវេលាព្រឹក តែគេមិនឃើញក្នុងវេលាល្ងាច ជនជាច្រើនពួកខ្លះ ដែលគេឃើញក្នុងវេលាល្ងាច តែគេមិនឃើញក្នុងវេលាព្រឹក ។ សេចក្តីព្យាយាមក្នុងកុសល គេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក ដ្បិតការបណ្តោះបណ្តៃ អំពីសេចក្តីស្លាប់ដែលមានសេនាច្រើននោះ មិនមានដល់យើងទេ ។ ពួកចោរទាំងឡាយ តែងប្រាថ្នាទ្រព្យ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះហើយអំពីចំណង បពិត្រព្រះរាជា សូមព្រះអង្គមក សូមព្រះអង្គត្រឡប់ព្រះហឫទ័យទៅវិញចុះ អាត្មាភាពមិនត្រូវការដោយរាជ្យទេ ។

## តេមិយជាតកទី ១ ចប់

# អដ្ឋកថា

# មហានិបាត

## តេមិយជាតក

[ ១-៤៨ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនេក្ខម្មបារមី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **មា បណ្ឌិច្ចយំ វិភាវយ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភា ពណ៌នាពីនេក្ខម្មបារមីរបស់ព្រះដ៏មានព្រះភាគ ព្រះសាស្តាទ្រង់ស្តាប់រឿងនោះដោយទិព្វសោត យាងចេញអំពីព្រះគន្ធកុដិ មកកាន់ធម្មសភា ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកទាំងឡាយប្រជុំចរចាគ្នាដល់រឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមានបារមីចាស់ក្លាហើយ លះរាជសម្បត្តិចេញ ដើម្បីស្វែងរកគុណធំក្នុងឥឡូវនេះ មិនជាអស្ចារ្យឡើយ ក្នុងកាលមុន ញាណមិនទាន់ចាស់ក្លា តថាគតកំពុងបំពេញបារមី បានលះនូវរាជសម្បត្តិ ចេញដើម្បីគុណដ៏ក្រៃលែងនោះ ទើបគួរអស្ចារ្យ ត្រាស់ដូច្នេះហើយ ទ្រង់ក៏តុណ្ហីភាព ភិក្ខុទាំងនោះ បានក្រាបទូលអារាធនាឲ្យទ្រង់និទានរឿងនោះ ទើបទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅ*

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រះរាជាព្រះនាមកាសិករាជ គ្រងរាជសម្បត្តិដោយធម៌ក្នុងនគរពារាណសី ទ្រង់មានស្នំប្រមាណ ១ ម៉ឺន ៦ ពាន់នាក់ បណ្ដាស្នំទាំងនោះ ស្នំសូម្បីតែម្នាក់ក៏មិនមានបុត្រ ឬធីតាឡើយ កាលនោះ អ្នកនគរនាំគ្នាពោលថា ព្រះរាជារបស់ពួកយើង មិនមានព្រះឱរសសូម្បីតែមួយអង្គ ដែលនឹងបន្តវង្ស ទើបប្រជុំគ្នាត្រង់លានព្រះរាជវាំង ដោយន័យដែលពោលមកហើយ ក្នុងកុសរាជជាតកនោះឯង ក្រាបទូលព្រះរាជាថា បពិត្រសម្មតិទេព សូមទ្រង់ប្រាថ្នាព្រះឱរសចុះ ព្រះរាជាទ្រង់ស្ដាប់ពាក្យអ្នកនគរនោះហើយ ត្រាស់ហៅស្រីស្នំទាំង ១ ម៉ឺន ៦ ពាន់ មកក្នុងខណៈនោះហើយ មានព្រះតម្រាស់ថា នាងទាំងឡាយ ចូរប្រាថ្នាកូន ។ ស្រីស្នំទាំងនោះធ្វើកិច្ច មានអង្វរ និងទំនុកបម្រុងទេវតាទាំងឡាយ មានព្រះចន្ទជាដើម សូម្បីប្រាថ្នា ក៏មិនបានឱរស ឬធីតាឡើយ ។

ចំណែកអគ្គមហេសីរបស់ព្រះបាទកាសិករាជ ជាបុត្រីរបស់ស្ដេចមទ្ទរាជ ព្រះនាមចន្ទាទេវី ជាអ្នកសម្បូរដោយសីលាចារវត្ត ព្រះរាជាទ្រង់មានព្រះតម្រាស់ថា នែនាងដ៏ចម្រើន សូម្បីនាងក៏ចូរប្រាថ្នាព្រះឱរស ព្រះទេវីបានស្ដាប់ព្រះតម្រាស់របស់ព្រះស្វាមីហើយ ព្រះនាងទូលទទួលថា សាធុ ហើយទើបសមាទានឧបោសថ ក្នុងថ្ងៃ ១៥ កើត ដោះនូវអាករណៈសព្វយ៉ាង ផ្ទុំលើគ្រែតូច ព្រះនាងអាវជ្ជនាការដល់សីលរបស់ព្រះនាង បានធ្វើសច្ចកិរិយាថា បើខ្ញុំរក្សាសីលមិនដាច់ សូមព្រះរាជបុត្រកើតឡើងដោយសច្ចវាចានេះ ។

ដោយតេជានុភាពនៃសីលរបស់ព្រះនាងចន្ទាទេវីនោះ បណ្ឌុកម្ពលសិលា

អាសនៈរបស់សក្កទេវរាជ ក៏សម្តែងអាការក្តៅ ។ សក្កទេវរាជ កាលទ្រង់អាវជ្ជនាការ ក៏ទ្រង់ជ្រាបហេតុនោះថា ព្រះនាងចន្ទាទេវីប្រាថ្នាឱរស អញនឹងឲ្យឱរសដល់ព្រះនាង ហើយទ្រង់ពិចារណាដល់ឱរស ដែលសមគួរដល់ព្រះនាង ទ្រង់ឃើញព្រះពោធិសត្វ ។ កាលនោះ ព្រះពោធិសត្វគ្រងរាជសម្បត្តិក្នុងក្រុងពារាណសីបាន ២០ ឆ្នាំ ទ្រង់ចុតិអំពីមនុស្សលោកនោះ ទៅកើតក្នុងឧស្សទនរក សោយទុក្ខក្នុងនរកនោះ អស់ ៨ ម៉ឺនឆ្នាំ ឃ្លាតចាកនរកនោះកើតក្នុងឋានតាវត្តិង្ស តាំងនៅក្នុងតាវត្តិង្សនោះដរាបដល់អស់អាយុ ឃ្លាតចាកតាវត្តិង្សនោះ បំណងនឹងទៅកាន់ទេវលោកជាន់ខ្ពស់ កាលនោះ សក្កទេវរាជបានទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ត្រាស់ថា បពិត្រលោកនិទុក្ខ កាលអ្នកកើតក្នុងមនុស្សលោក បារមីទាំងឡាយរបស់អ្នកនឹងពេញបរិបូណ៌ សេចក្តីចម្រើននឹងមានដល់អ្នក និងដល់ព្រះជនក ព្រះជននីរបស់អ្នក ព្រោះថាអគ្គមហេសីរបស់ព្រះបាទកាសិករាជ ព្រះនាមចន្ទាទេវីប្រាថ្នាឱរស ចូរអ្នកកើតក្នុងព្រះគភ៌របស់ព្រះនាងនោះ ហើយសក្កទេវរាជទ្រង់កាន់យកនូវបដិញ្ញារបស់ព្រះពោធិសត្វនោះ និងរបស់ទេវបុត្រទាំងឡាយ ប្រមាណ ៥០០ អង្គដែលនឹងចុតិ ហើយយាងត្រឡប់ទៅកាន់ទីប្រថាប់របស់ព្រះអង្គនោះឯង ព្រះពោធិសត្វនោះ ទទួលពាក្យថា សាធុ ហើយចុតិ មួយអន្លើដោយទេវបុត្រ ៥០០ អង្គ ឯខ្លួនព្រះអង្គ បដិសន្ធិក្នុងគភ៌របស់ព្រះនាងចន្ទាទេវី ចំណែកទេវបុត្រ ៥០០ អង្គក្រៅអំពីនេះ បានបដិសន្ធិក្នុងគភ៌របស់ភរិយាអមាត្យទាំងឡាយ ។ កាលនោះ ព្រះគភ៌របស់ព្រះនាងចន្ទាទេវី ហាក់ដូចពេញទៅ

ដោយកែវវជិរៈ ព្រះនាងជ្រាបថា តាំងព្រះគភ៌ ទើបក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់ជ្រាបដូច្នោះ ទើបបានព្រះរាជទានគព្ភបរិហារដល់ព្រះនាង ។ ព្រះនាងទ្រង់គភ៌គ្រប់កំណត់ហើយ ក៏ប្រសូតព្រះឱរសដែលសម្បូរដោយបុញ្ញ-លក្ខណៈដ៏ឧត្តម ភរិយារបស់អមាត្យទាំងឡាយ ក៏ប្រសូតកុមារ ៥០០ ក្នុងផ្ទះអមាត្យ ក្នុងថ្ងៃនោះដូចគ្នា ខណៈនោះ ព្រះរាជាប្រថាប់នៅក្នុងទីដែលទ្រង់ចេញ ចោមរោមទៅដោយពួកអមាត្យរាជបរិពារ ។ លំដាប់នោះ ភ្នាក់ងារទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា ព្រះរាជឱរសរបស់ទ្រង់ប្រសូតហើយ ។ ព្រះបាទកាសិករាជ ទ្រង់បានស្តាប់ពាក្យរបស់ភ្នាក់ងារទាំងនោះ ទ្រង់មាននូវសេចក្តីស្រឡាញ់ក្នុងឱរសជាដំបូងកើតឡើង មុតព្រះឆវីផ្ទុះរហូតដល់ខួរក្នុងឆ្អឹង តាំងនៅ កើតបីតិជ្រួតជ្រាបក្នុងព្រះសរីរៈ សូម្បីហទយៈរបស់អមាត្យរាជបរិវារទាំងឡាយ ក៏ត្រជាក់ត្រជុំគ្រប់គ្នា ។ ព្រះរាជាត្រាស់សួរពួកអមាត្យថា អ្នកទាំងឡាយ ត្រេកអរឬ កាលកូនប្រុសរបស់យើងកើត អមាត្យទាំងនោះក្រាបទូលថា ទ្រង់ត្រាស់ប្ញីព្រះអង្គ កាលមុន ពួកទូលបង្គំឥតទីពឹងឥឡូវនេះ ពួកទូលបង្គំមានទីពឹង បាននូវម្ចាស់ហើយ ។ ព្រះបាទកាសិករាជទ្រង់បានស្តាប់ពាក្យរបស់ពួកអមាត្យ ក៏កើតបីតិសោមនស្ស ទើបត្រាស់ហៅគុត្តមហាសេនាបតីមកត្រាស់ថា នែគុត្តមហាសេនាបតីដ៏ចម្រើន កូនប្រុសរបស់យើងគួរបានបរិវារ ចូរអ្នកទៅពិនិត្យមើលថា ក្នុងផ្ទះអមាត្យមានទារកកើតក្នុងថ្ងៃនេះប៉ុន្មាន មហាសេនាបតីទទួលព្រះរាជបញ្ជាហើយ ទៅពិនិត្យមើល ឃើញទារកក្នុងផ្ទះរបស់អមាត្យ ៥០០ នាក់ ទើបក្រាបទូលឲ្យទ្រង់

ជ្រាប ព្រះរាជាបានស្តាប់ពាក្យអមាត្យទាំងនោះ ក៏កើតបីតិ ត្រាស់ឲ្យព្រះរាជទានគ្រឿងប្រដាប់សម្រាប់កុមារដល់ទារកទាំង ៥០០ និងឲ្យព្រះរាជទានស្រីស្នំ ៥០០ នាក់ តែសម្រាប់ព្រះមហាសត្វ ព្រះរាជទានស្រីស្នំ ៦៤ នាក់ សុទ្ធតែជាស្រីដែលមិនមានទោស មានខ្ពស់ពេកជាដើម ដោះមិនសណ្តាយ ទឹកដោះមានរសផ្អែម ។ សួរថា ព្រោះហេតុអ្វី ទើបវៀរស្រីស្នំដែលមានទោសបែបនោះ ឆ្លើយថា ព្រោះកាលទារកអង្គុយបៅដោះ ស្ត្រីដែលខ្ពស់ពេក ទារកនឹងដកកវែងទៅ កាលទារកអង្គុយបៅដោះស្ត្រីដែលទាបពេក ក របស់ទារកនឹងរួញខ្លី កាលទារកនោះបៅដោះស្ត្រីដែលស្គមពេក ជើងទាំងពីររបស់ទារកនោះ នឹងរួមចូលគ្នា បើទារកអង្គុយបៅដោះស្ត្រីដែលធាត់ពេក ជើងទាំងពីររបស់ទារកនឹងកន្ទែក ស្ត្រីដែលមានសម្បុរខ្មៅពេក ទឹកដោះត្រជាក់ពេក ស្ត្រីដែលមានសម្បុរសពេក ទឹកដោះក្តៅខ្លាំង កាលទារកបៅដោះស្ត្រីដែលមានដោះសណ្តាយ ច្រមុះនឹងក្រពឹត ស្ត្រីដែលកើតរោគហឺតមានទឹកដោះជូរពេក ស្ត្រីដែលកើតរោគរីងរៃ ទឹកដោះនឹងមានរសវិការផ្សេងៗ មានហឺរជាដើម ព្រោះហេតុនោះ ព្រះបាទកាសិករាជទ្រង់វៀរទោសទាំងពួងទាំងនោះ ព្រះរាជទានស្រីស្នំ ៦៤ នាក់ ដែលវៀរចាកទោស មានខ្ពស់ពេកជាដើម ដោះមិនសណ្តាយ ទឹកដោះមានរសផ្អែម ទ្រង់ធ្វើសក្ការៈធំបានព្រះរាជទានពរដល់ព្រះនាងចន្ទាទេវី ព្រះនាងទទួលពរហើយ ថ្វាយទុកសិន ។ ក្នុងថ្ងៃថ្វាយព្រះនាមព្រះពោធិសត្វ ព្រះបាទកាសិករាជ ទ្រង់ធ្វើសក្ការៈច្រើនដល់ពួកព្រាហ្មណ៍ដែលចេះលក្ខណព្យាករណ៍ ហើយត្រាស់សួរដល់អន្តរាយរបស់ព្រះមហាសត្វ ព្រាហ្មណ៍ចេះលក្ខណព្យាករណ៍ទាំងនោះ

ឃើញលក្ខណៈរបស់ព្រះពោធិសត្វ ទើបក្រាបទូលថា ព្រះឱរសរបស់ព្រះអង្គ សម្បូរដោយបុញ្ញលក្ខណៈដ៏ឧត្តម កុំថាឡើយទ្វីបមួយ ព្រះឱរសរបស់ព្រះអង្គ អាចគ្រងរាជសម្បត្តិក្នុងមហាទ្វីបទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ គឺជាស្តេចចក្រពត្តិ អន្តរាយណាមួយនឹងមិនប្រាកដដល់ព្រះឱរសឡើយ ព្រះបាទកាសិករាជ ទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍ទាំងនោះ ក៏ត្រេកអរក្នុងព្រះហឫទ័យ កាលថ្វាយនាមព្រះរាជកុមារ បានថ្វាយនាមថា តេមិយកុមារ ព្រោះក្នុងថ្ងៃដែលកុមារប្រសូត ភ្លៀងធ្លាក់ពេញកាសិករដ្ឋ និងព្រោះព្រះរាជកុមារប្រសូត ហាក់ដូចជាញ៉ាំងព្រះហឫទ័យនៃព្រះរាជា និងចិត្តនៃពួកអមាត្យ និងមហាជនឲ្យត្រជាក់ត្រជុំ ។ លំដាប់នោះ ស្រីស្នំទាំងឡាយញ៉ាំងព្រះពោធិសត្វដែលមានព្រះជន្មបាន ១ ខែ ឲ្យតាក់តែងព្រះកាយហើយ នាំឡើងទៅគាល់ព្រះរាជបិតា ព្រះរាជាទតឃើញព្រះបិយោរស ទ្រង់ឱបក្រសោប ថើបត្រង់ព្រះសិរសាហើយ ឲ្យប្រថាប់លើភ្លៅ ទ្រង់ត្រេកអរជាមួយព្រះរាជកុមារ ។ ខណៈនោះ ពួករាជបុរសនាំចោរ ៤ នាក់ មកខាងមុខព្រះទីន័ង ព្រះរាជាទតឃើញចោរទាំងនោះហើយ មានព្រះតម្រាស់ឲ្យដាក់អាជ្ញាដល់ចោរទាំងនោះ ឲ្យយកផ្តៅទាំងបន្លាវាយចោរម្នាក់ ១ ពាន់រំពាត់ ឲ្យចងចោរម្នាក់ដោយច្រវាក់ហើយបញ្ចូលទៅក្នុងគុក ឲ្យយកលំពែងចាក់សរីរៈចោរម្នាក់ យកលំពែងដោតត្បាងចោរម្នាក់ ។

កាលនោះ ព្រះមហាសត្វទ្រង់ស្តាប់ព្រះតម្រាស់របស់ព្រះបិតា ទ្រង់ខ្លាចផង តក់ស្លុតផង ទ្រង់ចិន្តនាការថា ឱ បិតារបស់អញអាស្រ័យរាជសម្បត្តិ

ធ្វើកម្មធ្ងន់ក្រៃលែង ដែលនាំទៅកាន់នរក ។ ស្អែកឡើង ក៏លៀង និងស្នំ ទាំងឡាយ ឲ្យព្រះមហាសត្វផ្ទំលើព្រះទែនដែលប្រកបដោយសិរី ដែលតាក់តែងហើយខាងក្រោមស្វេតច្ឆត្រ ព្រះពោធិសត្វផ្ទំបន្តិច ភ្ញាក់ពីបន្ទំ បើកព្រះនេត្រទាំងពីរទតស្វេតច្ឆត្រ ឃើញនូវសិរីរាជសម្បត្តិដ៏ធំក្រៃលែង លំដាប់នោះ ការខ្លាចដ៏ក្រៃលែងបានកើតឡើងដល់ព្រះពោធិសត្វ ទ្រង់ខ្លាចផង តក់ស្លុតផង ជាប្រក្រតី ហើយទ្រង់ព្រះតម្រិះថា អញមកអំពីណា មកកាន់ព្រះរាជមន្ទីរនេះ កាលទ្រង់ពិចារណា ក៏ទ្រង់ជ្រាប ដោយទ្រង់រឭកជាតិបានថា មកអំពីទេវលោក កាលទ្រង់ពិចារណាហួសនោះទៅទៀត ក៏ឃើញថា ទៅឆេះក្នុងឧស្សទនរក កាលទ្រង់ពិចារណាបន្តពីនោះទៅទៀត ក៏ទ្រង់ជ្រាបថា ទ្រង់ជាព្រះរាជាក្នុងនគរនេះឯង កាលព្រះពោធិសត្វពិចារណាថា អញបានគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ២០ ឆ្នាំ ហើយឆេះក្នុងឧស្សទនរក ៨ ម៉ឺនឆ្នាំ ឥឡូវនេះ អញកើតក្នុងព្រះរាជវាំង ដូចផ្ទះចោរនេះទៀត ម្សិលមិញនេះ កាលគេនាំចោរ ៤ នាក់មក បិតារបស់អញបានពោលផរុសវាចាបែបនោះ ដែលជាហេតុឲ្យធ្លាក់នរក បើអញគ្រងរាជសម្បត្តិ គង់កើតក្នុងនរកសោយទុក្ខធំទៀត ដូច្នេះ ក៏កើតនូវសេចក្តីខ្លាចដ៏ខ្លាំង ព្រះសរីរៈមានពណ៌ដូចមាសរបស់ព្រះពោធិសត្វ បានរីងស្ងួត មានវណ្ណៈសៅហ្មងដូចផ្កាឈូកដែលប្របាច់ដោយដៃដូច្នោះ ទ្រង់ផ្ទំចិន្តនាការថា ធ្វើយ៉ាងណា ទើបអញផុតចាកព្រះរាជមន្ទីរ ដូចផ្ទះចោរនេះបាន ។

គ្រានោះ ទេពធីតាដែលអាស្រ័យត្រង់ស្វេតច្ឆត្រ ធ្លាប់ជាមាតាព្រះ

ពោធិសត្វ ក្នុងអត្តភាពចន្លោះមួយអត្តភាព លួងលោមព្រះពោធិសត្វឲ្យសប្បាយព្រះហឫទ័យ ហើយពោលថា នែបាតេមិយៈ បាកុំសោកឡើយ កុំគិត កុំខ្វាចឡើយ បើបាចង់ផុតចាករាជមន្ទីរនេះ បាមិនខ្វិន ក៏ចូរធ្វើដូចជាមនុស្សខ្វិន បាមិនថ្លង់ ក៏ចូរធ្វើដូចជាមនុស្សថ្លង់ បាមិនគ ក៏ចូរធ្វើដូចជាមនុស្សគចុះ ចូរបាអធិដ្ឋានអង្គ ៣ នេះ ដូច្នេះហើយ កុំប្រកាសភាពដែលបាជាមនុស្សឈ្លាសវៃ ទេពធីតាពោលហើយ បានពោលបឋមគាថាដូច្នេះថា

អ្នកកុំប្រកាសនូវភាពជាអ្នកប្រាជ្ញ ចូរឲ្យជនទាំងពួងដឹងថា ជាមនុស្សល្ងង់ ជនទាំងអស់ចូរមើលងាយអ្នកចុះ សេចក្តីចម្រើននឹងមានដល់អ្នក ដោយវិធីយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា បណ្ឌិច្ចយំ** សេចក្តីថា ចូរកុំប្រកាសភាពជាបណ្ឌិតរបស់ខ្លួន ម្យ៉ាងទៀត បាឋៈថា **បណ្ឌិច្ចំ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នានោះឯង ។ បទថា **ពាលមតោ** បានដល់ ស្គាល់ថាជាមនុស្សល្ងង់ ។ បទថា **សព្វបាណភិនំ** បានដល់ ដែលសត្វទាំងពួង គឺជនទាំងឡាយ ។ បទថា **សព្វោ តញ្ជនោ** បានដល់ ទាំងជនខាងក្នុង និងជនខាងក្រៅទាំងអស់ ។ បទថា **ឱចិនាយតុ** បានដល់ ទោះជាគេមាក់ងាយ គឺចូរមើលងាយថា ចូរពួកអ្នកនាំមនុស្សកាឡកិណីនេះចេញទៅ ។

ព្រះពោធិសត្វ ត្រឡប់បាននូវការកក់ក្តៅព្រោះពាក្យរបស់ទេពធីតានោះ ទើបពោលគាថាទី ២ ថា

បពិត្រទេវតា អ្នកនិយាយពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកនោះ បពិត្រទេវតា អ្នក ឈ្មោះថា ប្រាថ្នានូវសេចក្ដីចម្រើនដល់ខ្ញុំ បពិត្រទេវតា អ្នក ឈ្មោះថា ប្រាថ្នានូវប្រយោជន៍ ( ដល់ខ្ញុំ ) ដូច្នេះ ។

កាលពោលគាថានេះហើយ ព្រះពោធិសត្វបានអធិដ្ឋានអង្គទាំង ៣ នោះ ទេពធីតានោះក៏អន្តរធានទៅ ។

លំដាប់នោះ ព្រះបាទកាសិករាជមានព្រះតម្រិះថា កូនរបស់អញគួរបានកុមារ ៥០០ ទាំងនោះជាបរិវារដើម្បីជាទីពេញចិត្ត ទើបត្រាស់ឲ្យកុមារទាំង ៥០០ នោះ អង្គុយក្នុងសម្នាក់របស់ព្រះពោធិសត្វ ទារកទាំងនោះយំទារបៅដោះ ចំណែកព្រះមហាសត្វ ត្រូវសេចក្ដីខាចក្នុងនរកគំរាម ទ្រង់ត្រិះរិះថា ចាប់ពីថ្ងៃនេះទៅ កាយរបស់អញ ចូរក្រៀមស្ងួតស្លាប់ទៅចុះប្រសើរជាង ត្រិះរិះដូច្នេះហើយ ទើបមិនយំ ស្រីស្នំទាំងឡាយក្រាបទូលព្រឹត្តិការណ៍នោះ ដល់ព្រះនាងចន្ទាទេវី ព្រះនាងក៏ក្រាបទូលដល់ព្រះរាជាៗត្រាស់ឲ្យហៅពួកព្រាហ្មណ៍ដែលទាយនិមិត្តមកត្រាស់សួរ ព្រាហ្មណ៍ទាំងឡាយបានក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ស្រីស្នំគួរថ្វាយទឹកដោះនោះដល់ព្រះរាជកុមារឲ្យហួសកាលប្រក្រតី កាលបើធ្វើយ៉ាងនេះ ព្រះកុមារនឹងយំចាប់ដោះសោយឯង ។ ចាប់តាំងពីនោះមក ស្រីស្នំទាំងឡាយ កាលថ្វាយទឹកដោះដល់ព្រះពោធិសត្វ ក៏ធ្វើហួសកាលតាមប្រក្រតី ជួនកាល ថ្វាយរំលងពេលម្ដង ជួនកាល មិនថ្វាយអស់មួយថ្ងៃ ព្រះពោធិសត្វត្រូវសេចក្ដី

ខ្វាចក្នុងនរកគំរាម សូម្បីព្រះកាយក្រៀមស្វិត ក៏ទ្រង់មិនយំទារទឹកដោះឡើយ ។ លំដាប់នោះ ព្រះនាងចន្ទាទេវីឃើញ ព្រះពោធិសត្វមិនយំ ទ្រង់ត្រិះរិះថា កូនរបស់អញឃ្លាន ទើបឲ្យបៅ ព្រះសុដនរបស់ព្រះនាងឯង ។ ដូនកាល ស្រីស្នំទាំងឡាយឲ្យទឹកដោះ ពួកទារកដទៃក៏នាំគ្នាយំ មិនដេកក្នុងពេលដែល មិនបានបៅ តែព្រះពោធិសត្វ មិនយំ មិនកន្ទក់កន្ទេញ មិនផ្ទំ មិនលាព្រះ ហស្ត និងព្រះបាទ មិនបន្លឺវាចា កាលនោះស្នំទាំងឡាយ គិតគ្នាថា ធម្មតាដៃ និងជើងរបស់មនុស្សខ្វិន មិនដូច្នេះឡើយ ចុងចង្ការបស់មនុស្សគក៏មិនយ៉ាង នេះ ត្រចៀករបស់មនុស្សថ្លង់ក៏មិនយ៉ាងនេះ នឹងត្រូវមានហេតុក្នុងព្រះ រាជកុមារនេះ ពួកយើងនឹងសាកល្បងព្រះរាជកុមារ ទើបមិនថ្វាយទឹកដោះដល់ ព្រះពោធិសត្វនោះអស់មួយថ្ងៃ ដោយបំណងថានឹងសាកល្បងព្រះរាជកុមារ ដោយរឿងបៅដោះជាមុន ព្រះពោធិសត្វ សូម្បីក្រៀមស្ងួត ក៏ទ្រង់មិនយំ សោយទឹកដោះ កាលនោះ ព្រះជននីរបស់ព្រះពោធិសត្វត្រាស់ឲ្យស្រីស្នំ ថ្វាយទឹកដោះដោយព្រះរាជសវនីយ៍ថា កូនខ្ញុំឃ្លាន ចូរឲ្យទឹកដោះដល់កូនខ្ញុំ ស្នំទាំងនោះសូម្បីសាកល្បងមិនថ្វាយទឹកដោះក្នុងចន្លោះៗ យ៉ាងនេះ អស់កាល មួយឆ្នាំ ក៏មិនឃើញការខុសប្លែករបស់ព្រះពោធិសត្វ ។ លំដាប់នោះ ពួក អមាត្យក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ធម្មតាទារកអាយុមួយខួប ចូលចិត្តបរិភោគនំ និងរបស់ទំពា ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយ នំនិងរបស់ទំពា ក្រាបទូលដូច្នេះហើយ ឲ្យកុមារទាំង ៥០០ អង្គុយជិតព្រះ រាជកុមារ យកនំ និងរបស់ទំពាផ្សេងៗ ដាក់ក្បែរព្រះមហាសត្វ ពោលថា ចូរ

អ្នកទាំងឡាយកាន់យកនំ និងរបស់ទំពាទាំងនោះតាមគាប់ចិត្ត ហើយនាំគ្នាលួចមើល ពួកទារកដ៏សេសឈ្លោះគ្នា ដណ្ដើមគ្នានិងគ្នាកាន់យកនំ និងរបស់ទំពាមកទំពាស៊ី ចំណែកព្រះមហាសត្វទ្រង់ទូន្មានព្រះអង្គថា នែតេមិយៈ បើអ្នកបំណងនរក ក៏ចូរត្រូវការនំ និងរបស់ទំពា បើអ្នកខ្លាចភ័យក្នុងនរក មិនគប្បីទតមើលនំ និងរបស់ទំពាឡើយ ។ សូម្បីការសាកល្បងដោយនំ និងរបស់ទំពាក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនឃើញការខុសប្លែករបស់ព្រះពោធិសត្វ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជធម្មតាទារក ២ ឆ្នាំ ចូលចិត្តផ្លែឈើតូចធំ ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយផ្លែឈើ ក្រាបទូលដូច្នេះហើយ នាំផ្លែឈើតូចធំផ្សេងៗ ចូលទៅដាក់ក្បែរព្រះពោធិសត្វ ហើយពោលថា ចូរអ្នកទាំងឡាយកាន់យកផ្លែឈើតូចធំទាំងនោះតាមគាប់ចិត្តចុះ ហើយនាំគ្នាលបមើល ពួកទារកដ៏សេសវាយគ្នានិងគ្នា កាន់យកផ្លែឈើទាំងនោះបរិភោគ ចំណែកព្រះពោធិសត្វទូន្មានខ្លួនថា នែបាតេមិយៈ បើឯងចង់ទៅនរក ក៏ចូរត្រូវការផ្លែឈើតូចធំទាំងឡាយ ជាបុគ្គលត្រូវភ័យក្នុងនរកគំរាម មិនយកភ្នែកមើលផ្លែឈើតូចធំឡើយ សូម្បីពិសោធដោយផ្លែឈើតូចធំក្នុងចន្លោះៗ យ៉ាងនេះ អស់មួយឆ្នាំ ក៏មិនឃើញការខុសប្លែករបស់ព្រះពោធិសត្វ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជធម្មតាទារក ៣ ឆ្នាំ ចូលចិត្តរបស់លេង ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារ

ដោយរបស់លេង ក្រាបទូលដូច្នេះហើយ ទើបឲ្យធ្វើរូបដំរីជាដើម សម្រេចដោយមាសជាដើម ដាក់ក្បែរៗ ព្រះពោធិសត្វ ពួកទារកដ៏សេសដណ្តើមគ្នាកាន់យក ចំណែកព្រះមហាសត្វ មិនយកភ្នែកមើលឡើយ សូម្បីពិសោធដោយរបស់លេងបណ្តើរៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនឃើញការខុសប្លែកអ្វីរបស់ព្រះពោធិសត្វឡើយ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាទារក ៤ ឆ្នាំ ចូលចិត្តភោជនាហារ ពួកទូលបង្គំនឹងសាកល្បងព្រះរាជ-កុមារដោយភោជនាហារ ក្រាបទូលដូច្នេះហើយ ទើបបង្អោនភោជនាហារផ្សេងៗ ថ្វាយដល់ព្រះមហាសត្វ សូម្បីពួកទារកដ៏សេសក៏ធ្វើជាពំនូតៗ បរិភោគ ឯព្រះមហាសត្វ ទ្រង់ទូន្មានខ្លួនថា នែបាតេមិយៈ អត្តភាពរបស់ឯង មិនបានភោជនបរិភោគរាប់មិនអស់ ទ្រង់ខ្លាចភ័យក្នុងនរក មិនបានយកភ្នែកមើលនូវភោជនាហារនោះ ។ លំដាប់នោះ ព្រះជននីរបស់ព្រះពោធិសត្វ ហាក់ដូចជាបុគ្គលមានហឫទ័យបែកធ្លាយ ឲ្យព្រះឱរសសោយភោជនាហារ ដោយដៃឯងសូម្បីការសាកល្បងដោយភោជនាហារ ក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនឃើញការខុសប្លែករបស់ព្រះពោធិសត្វឡើយ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាទារក ៥ ឆ្នាំរមែងខ្លាចភ្លើង ទូលបង្គំនឹងពិសោធកុមារដោយភ្លើង ។ ក្រាបទូលដូច្នេះហើយ ឲ្យធ្វើផ្ទះធំ មានទ្វារច្រើន គ្រង់លានព្រះរាជវាំង ប្រក់ដោយស្លឹកត្នោត ឲ្យព្រះមហាសត្វ ដែលចោមរោមដោយពួកទារកដ៏សេស

អន្ទុយត្រង់កណ្ដាលទារកទាំងនោះហើយដុតភ្លើង ទារកដ៏សេសឃើញអណ្ដាតភ្លើងឆេះសន្ធោសន្ធៅ ភ័យផង ខ្លាចផង នាំគ្នាស្រែកឃំរត់ទៅ ចំណែកព្រះមហាសត្វទ្រង់ព្រះតម្រិះថា កម្ដៅនៃភ្លើងនេះគង់ល្អជាងឆេះដោយភ្លើងនរក ព្រះមហាសត្វមិនបានតក់ស្លុតឡើយ ដូចព្រះមហាថេរៈចូលនិរោធសមាបត្តិ ដូច្នោះ កាលភ្លើងឆេះរាលមក អមាត្យទាំងឡាយ ក៏បីព្រះពោធិសត្វចេញទៅ សូម្បីពិសោធដោយភ្លើងបណ្ដើរយ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនឃើញការខុសប្លែករបស់ព្រះពោធិសត្វឡើយ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាទារក ៦ ឆ្នាំ រមែងខ្លាចដំរីចុះប្រេង ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយដំរីចុះប្រេង ក្រាបទូលដូច្នេះហើយ ឲ្យទូន្មានដំរីមួយយ៉ាងល្អ ឲ្យព្រះពោធិសត្វចោមរោមដោយពួកទារកដ៏សេស អន្ទុយត្រង់លានព្រះរាជវាំង ហើយលែងដំរី ដំរីនោះបន្លឺសំឡេងដូចសត្វក្រៀល យកប្រមោយបោកផែនដីសម្ដែងភ័យមក ពួកទារកដ៏សេសឃើញដំរីចុះប្រេង ក៏នាំគ្នាខ្លាចមរណភ័យទើបរត់ទៅកាន់ទិសផ្សេងៗ ចំណែកព្រះមហាសត្វឃើញដំរីចុះប្រេងមក ទ្រង់គិតថា អញស្លាប់ដោយភ្លុកដំរីចុះប្រេងដ៏កាច ប្រសើរជាងឆេះក្នុងនរកដ៏ពន្លឹក ព្រះមហាសត្វត្រូវភ័យក្នុងនរកគំរាម ប្រថាប់គង់ត្រង់នោះឯង មិនបានកម្រើកឡើយ ។ លំដាប់នោះ ដំរីដែលគេបង្ហឹកល្អហើយនោះ ស្ទុះចូលមកចាប់ព្រះមហាសត្វដូចចាប់បាច់ផ្កា រត់ទៅរត់មក ធ្វើឲ្យព្រះមហាសត្វលំបាកក្រៃលែង មហាជនទទួលព្រះមហាសត្វអំពីប្រមោយដំរីហើយ នាំចេញទៅ សូម្បីសាក

ល្បងដោយដំរីចុះប្រេងបណ្តើរៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនឃើញការខុសប្លែករបស់ព្រះពោធិសត្វ ។

ព្រះរាជាត្រាស់សួរពួករាជបុរសថា ពួកលោកក្នុងពេលមក ហើយទទួលកុមារនាំចេញទៅ ព្រះរាជកុមារកម្រើកដៃកម្រើកជើងខ្លះដែរឬ ពួករាជបុរសទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ មិនកម្រើកឡើយ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើដូចម្តេច ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជធម្មតាក្មេង ៧ ឆ្នាំ រមែងខ្លាចពស់ ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយពស់ ក្រាបទូលដូច្នេះហើយ ទើបឲ្យព្រះមហាសត្វ និងពួកទារកដ៏សេសអង្គុយត្រង់លានព្រះរាជវាំង លែងពស់ទាំងឡាយ ដែលកាច់ចង្កូមហើយដេរមាត់ហើយ ក្នុងកាលដែលព្រះពោធិសត្វប្រថាប់គង់ ចោមរោមទៅដោយពួកទារកដ៏សេសៗ ទាំងឡាយ ឃើញពស់សាហាវទាំងនោះក៏ស្រែក ហើយរត់ទៅ ចំណែកព្រះមហាសត្វ ទ្រង់ពិចារណាភ័យក្នុងនរក ទ្រង់ត្រិះរិះថាការវិនាសទៅក្នុងមាត់របស់ពស់កាច ល្អជាងស្លាប់ក្នុងនរកដ៏ពន្លឹក ដូច្នេះហើយ ទើបទ្រង់នៅស្ងៀមដូចព្រះថេរៈចូលនិរោធសមាបត្តិ កាលពស់ទាំងឡាយលូនមករួតព្រះកាយរបស់ព្រះមហាសត្វ បើកពពារលើសីសៈរបស់ព្រះមហាសត្វ សូម្បីក្នុងកាលនោះ ព្រះមហាសត្វមិនបានញាប់ញ័រឡើយ ការសាកល្បងដោយពស់បណ្តើរៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបានឃើញការខុសប្លែករបស់ព្រះមហាសត្វ ។ ព្រះរាជាត្រាស់សួរពួករាជបុរសថា ពួក

អ្នកក្នុងកាលដែលមក ហើយទទួលព្រះរាជកុមារនាំចេញទៅ ព្រះរាជកុមារកម្រើកដៃ ឬជើងខ្លះដែរឬ រាជបុរសទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ មិនកម្រើកឡើយ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើដូចម្តេច ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាទារក ៨ ឆ្នាំចូលចិត្តមហោស្រពច្រៀងរាំ ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយមហោស្រព ក្រាបទូលដូច្នេះហើយ ឲ្យព្រះរាជកុមារប្រថាប់គង់ក្នុងលានព្រះរាជវាំងជាមួយទារក ៥០០ នាក់ ហើយសម្តែងមហោស្រពច្រៀងរាំ ពួកទារកដ៏សេសឃើញមហោស្រពហើយនាំគ្នាពោលថា ល្អ ល្អ នាំគ្នាសើចសប្បាយ ចំណែកព្រះមហាសត្វទ្រង់ពិចារណាភ័យក្នុងនរកថា ពេលដែលអញកើតក្នុងនរក ការត្រេកអរ ឬសោមនស្សមិនមាន សូម្បីត្រឹមមួយជួរខណៈ ទើបអង្គុយស្ងៀម មិនយកភ្នែកមើលអ្វីឡើយ ។ ការពិសោធដោយមហោស្រព រាំច្រៀងក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបានឃើញការខុសប្លែករបស់ព្រះពោធិសត្វ ព្រះរាជាត្រាស់សួរពួករាជបុរសថា ពួកអ្នកក្នុងកាលដែលមក ហើយទទួលព្រះរាជកុមារនាំចេញទៅ ព្រះរាជកុមារកម្រើកដៃ ឬជើងខ្លះដែរឬ ពួករាជបុរសទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ មិនកម្រើកឡើយ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើដូចម្តេច ។

បន្ទាប់អំពីនោះ គណៈអាមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាទារកអាយុ ៩ ឆ្នាំ រមែងខ្លាចសស្ត្រា ពួកទូលបង្គំនឹងសាកល្បងព្រះ

រាជកុមារដោយសន្ត្រា ទើបឲ្យព្រះមហាសត្វប្រថាប់គង់ក្នុងលានព្រះរាជវាំង ជាមួយទារក ៥០០ ក្នុងពេលដែលទារក ៥០០ កំពុងលេង បុរសម្នាក់កាន់ដាវ មានពណ៌ដូចកែវផលិក គ្រវីចុះឡើងស្រែកសន្ធាប់ ទះដៃលោតមក បញ្ចេញនូវអាកប្បកិរិយាសម្លុតថា បានឮថា ព្រះរាជឱរសមួយអង្គរបស់ព្រះបាទកាសិករាជ ជាមនុស្សកាឡកិណី នៅឯណា យើងនឹងយកដាវកាត់ក្បាលរបស់គេ រត់ចូលមកពោលយ៉ាងនេះ ពួកទារកដ៏សេសឃើញដូច្នោះ ខ្លាចផង តក់ស្លុតផង ស្រែកយំទ្រហឹងរត់ទៅក្នុងទិសផ្សេងៗ ។ ចំណែកព្រះពោធិសត្វ ទ្រង់ពិចារណាភ័យក្នុងនរក ទ្រង់ឃើញថា ការវិនាសក្នុងមុខដាវដ៏មុត ល្អជាងស្លាប់ក្នុងឧស្សទនរក ដូច្នេះ ប្រថាប់ដូចជាទ្រង់មិនជ្រាប ។ លំដាប់នោះ បុរសនោះ យកដាវទល់ត្រង់សីសៈ ហើយពោលនឹងព្រះមហាសត្វថា យើងនឹងកាត់ក្បាលអ្នក សូម្បីធ្វើឲ្យព្រះមហាសត្វខ្លាច ក៏មិនអាចឲ្យមហាសត្វខ្លាចបាន ក៏ចៀសចេញទៅ ។ សូម្បីសាកល្បងដោយដាវក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបានឃើញការខុសប្លែករបស់ព្រះពោធិសត្វ ព្រះរាជាត្រាស់សួរពួករាជបុរសយ៉ាងនេះថា ពួកអ្នកក្នុងកាលដែលមក ហើយទទួលព្រះរាជកុមារនាំចេញទៅ ព្រះរាជកុមារកម្រើកដៃ ឬជើងខ្លះដែរឬ ពួករាជបុរសក្រាបទូលថា បពិត្រព្រះអង្គ មិនកម្រើកឡើយ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើដូចម្តេច ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាទារកអាយុ ១០ ឆ្នាំ រមែងខ្លាចសំឡេង គួរប្រើសំឡេងពិសោធព្រះ

រាជកុមារថា តើត្រចៀកថ្លង់ដែរឬទេ ក្រាបទូលដូច្នេះហើយ ទើបឲ្យបាំងវាំងនន ធ្វើនូវប្រហោង ៤ ទិស ឲ្យមនុស្សផ្លុំស័ង្ខអង្គុយខាងក្រោមទីបន្ទំ មិនឲ្យព្រះពោធិសត្វឃើញ ឲ្យផ្លុំស័ង្ខព្រមគ្នា ឲ្យមានសំឡេងព្រមគ្នា ស្រីស្នំទាំងឡាយឲ្យព្រះមហាសត្វផ្ទំលើទីបន្ទំ អមាត្យ ៤ នាក់ ឈរក្នុងទិសទាំង ៤ មើលនូវឥរិយាបថរបស់ព្រះពោធិសត្វតាមចន្លោះវាំងនន មិនបានឃើញវិការនៃព្រះហស្ត និងព្រះបាទ ឬត្រឹមតែការកម្រើក ដោយការភ្ញាក់សតិរបស់ព្រះមហាសត្វឡើយ ។ ព្រះរាជាត្រាស់សួរពួករាជបុរសថា កូនរបស់យើងកម្រើកដៃជើងខ្លះដែរឬទេ ពួករាជបុរសទាំងនោះក្រាបទូលថា មិនបានកម្រើកឡើយព្រះអង្គ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើដូចម្តេច ការពិសោធន៍ដោយស័ង្ខក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ មិនបានឃើញការខុសប្លែករបស់ព្រះពោធិសត្វឡើយ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ជម្មតាទារក ១១ ឆ្នាំ រមែងខ្លាចសំឡេងស្គរ គួរសាកល្បងព្រះរាជកុមារដោយសំឡេងស្គរ ។ អមាត្យទាំងឡាយ សូម្បីពិសោធដោយសំឡេងស្គរក្នុងចន្លោះៗ យ៉ាងនោះឯង អស់កាលមួយឆ្នាំ ក៏មិនបានឃើញការខុសប្លែករបស់ព្រះពោធិសត្វ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ជម្មតាទារកអាយុ ១២ ឆ្នាំ រមែងខ្លាចភ្លើងប្រទីប ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយប្រទីប ក្រាបទូលដូច្នេះហើយ ឲ្យព្រះមហាសត្វផ្ទំក្នុងទីងងឹត

ពេលរាត្រី គិតថា ព្រះរាជកុមារកម្រើកដៃ ឬកម្រើកជើងដែរឬហ្ន៎ ធ្វើប្រទីបឲ្យឆេះសន្ធោសន្ធៅក្នុងផ្ទាំងទាំងឡាយ ឲ្យពន្លត់ប្រទីបដទៃៗ ឲ្យព្រះពោធិសត្វផ្ទំបន្តិចក្នុងទីងងឹត ហើយលើកផ្ទាំងប្រទីបទាំងឡាយឡើង ធ្វើឲ្យភ្លឺព្រមគ្នា ពិចារណាមើលឥរិយាបថរបស់ព្រះពោធិសត្វ ក៏មិនបានឃើញត្រឹមតែការកម្រើកកាយរបស់ព្រះមហាសត្វឡើយ ។ សូម្បីសាកល្បងដោយប្រទីបក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបានឃើញត្រឹមតែការកម្រើកណាមួយរបស់ព្រះពោធិសត្វឡើយ ព្រះរាជាត្រាស់សួរពួករាជបុរសថា កូនរបស់យើង កម្រើកដៃ ឬជើងខ្លះដែរឬ រាជបុរសទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ មិនកម្រើកឡើយ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើដូចម្តេច ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជធម្មតាទារក ១៣ ឆ្នាំ រមែងខ្លាចរុយ ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយទឹកអំពៅ ក្រាបទូលដូច្នេះហើយ ទើបយកទឹកអំពៅលាបពេញសរីរៈរបស់ព្រះពោធិសត្វ ហើយឲ្យផ្ទំក្នុងទីដែលមានរុយអែអុក រុយទាំងនោះក៏រោមព្រះសរីរៈទាំងមូលរបស់ព្រះពោធិសត្វ បឺតទឹកអំពៅ ដូចចាក់ដោយម្ជុលដ៏ច្រើន ព្រះពោធិសត្វត្រិះរិះថា អញស្លាប់ក្នុងមាត់របស់រុយទាំងឡាយប្រសើរជាងស្លាប់ក្នុងអវិចីនរក ហើយអត់សង្កត់នូវទុក្ខវេទនា មិនកម្រើកឡើយ ដូចព្រះមហាថេរៈចូលនិរោធសមាបត្តិ ដូច្នោះ សូម្បីការសាកល្បងដោយទឹកអំពៅក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបានឃើញ

ត្រឹមតែការកម្រើករបស់ព្រះពោធិសត្វឡើយ ព្រះរាជាត្រាស់សួរពួករាជ-បុរសថា កូនរបស់យើងកម្រើកដៃ ឬកម្រើកជើងខ្លះដែរឬ រាជបុរសទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ មិនកម្រើកឡើយ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើដូចម្តេច ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ កាលទារកមានអាយុ ១៤ ឆ្នាំជាមនុស្សធំហើយ ឥឡូវនេះ កុមារនេះជាមនុស្សធំ ប្រាជ្ញារបស់ស្អាត ស្អុយខ្ទើមរបស់ស្មោកគ្រោក ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយរបស់ស្មោកគ្រោក ក្រាបទូលដូច្នេះហើយ តាំងអំពីនោះមក មិនស្រេចស្រង់ព្រះពោធិសត្វ មិនឲ្យលើកឲ្យបន្ទោបង់ មិនជួយឲ្យក្រោកអំពីទីបន្ទំ ព្រះពោធិសត្វ ក៏ត្រូវបន្ទោបង់ឧច្ចារបស្សាវៈពាសពេញក្នុងទីនោះឯង ព្រោះក្លិនស្អុយ កាលនោះ ដូចជាកាលសម្តែងព្រះអជ្ឈាស្រ័យខាងក្នុងនៃព្រះពោធិសត្វចេញមកខាងក្រៅ រុយទាំងឡាយ ក៏មកចោមរោមស៊ីព្រះសរីរៈរបស់ព្រះពោធិសត្វ គ្រានោះ ព្រះជនកព្រះជននី ប្រថាប់គង់ក្បែរព្រះពោធិសត្វត្រាស់យ៉ាងនេះថា នែបាតេមិយៈ ឥឡូវនេះ បាធំហើយ អ្នកណាគេនឹងបម្រើបាជានិច្ច បាមិនខ្មាសទេឬ បាដេកធ្វើអ្វី ក្រោកឡើងជម្រះរាងកាយចុះ ហើយត្រាស់ជេរ ។ ព្រះពោធិសត្វ សូម្បីនៅក្នុងគំនរលាមកបដិកូលយ៉ាងនោះ ក៏ទ្រង់ដាក់អារម្មណ៍ជាកណ្តាល ទ្រង់ពិចារណាឃើញក្លិនស្អុយរបស់គូថនរក ដែលអាចផ្សាយឡើងក្នុងចិត្តរបស់បុគ្គលដែលឈរក្នុងទីបំផុត ១០០ យោជន៍ ព្រោះក្លិនស្អុយ ។ សូម្បីពិសោធដោយរបស់ស្មោកគ្រោក

ក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបានឃើញការខុសប្លែករបស់ព្រះពោធិសត្វ ។

បន្ទាប់អំពីនោះ គណៈអមាត្យក្រាបទូលព្រះរាជាថា បពិត្រមហារាជ ធម្មតាទារកអាយុ ១៥ ឆ្នាំ រមែងខ្លាចនូវកម្តៅ ពួកទូលបង្គំនឹងពិសោធព្រះរាជកុមារដោយរងើកភ្លើង លំដាប់នោះ អមាត្យទាំងឡាយ បានដាក់អំបែងដែលពេញដោយរងើកភ្លើង ក្រោមព្រះទែនរបស់ព្រះពោធិសត្វ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ព្រះរាជកុមារត្រូវកម្តៅបៀតបៀន ហើយសោយទុក្ខវេទនាកាលអត់ធន់នូវទុក្ខវេទនាមិនបាន ក៏សម្តែងនូវការកម្រើកព្រះហស្ត ឬព្រះបាទខ្លះ ស្រីស្នំទាំងឡាយឲ្យព្រះមហាសត្វផ្ទំលើព្រះទែនហើយចេញមក ។ ព្រះមហាសត្វត្រូវក្តៅបៀតបៀន អណ្តាតភ្លើងប្រាកដដូចឆេះពេញសរីរៈរបស់ព្រះមហាសត្វ សូម្បីព្រះមហាសត្វក៏ទ្រង់ទូន្មានខ្លួនថា នែតេមិយកុមារ កម្តៅក្នុងអវិចីមហានរក ផ្សាយទៅក្នុងទី ១០០ យោជន៍ ទម្លាយនូវភ្នែករបស់បណ្តាសត្វដែលនៅក្នុងទី ១០០ យោជន៍បាន កម្តៅនៃភ្លើងនេះ ប្រសើរជាងកម្តៅក្នុងនរកនោះរាប់រយដង រាប់ពាន់ដង រាប់សែនដង ដូច្នេះហើយ ទ្រង់អត់សង្កត់នូវកម្តៅនោះ មិនញាប់ញ័រឡើយ ដូចបុគ្គលចូលនិរោធសមាបត្តិ ។ លំដាប់នោះ ព្រះជនកព្រះជននីរបស់ព្រះពោធិសត្វ ទតឃើញព្រះពោធិសត្វត្រូវសេចក្តីទុក្ខបៀតបៀន ព្រះហឫទ័យស្ទើរបែក ទើបវៃកមហាជនចូលទៅនាំព្រះពោធិសត្វចេញអំពីកម្តៅរបស់ភ្លើង ហើយត្រាស់អង្វរព្រះពោធិសត្វថា នែបាតេមិយៈ ពួកយើងដឹងថា បាមិនមែនជាមនុស្សខ្វិនជាដើមឡើយ ព្រោះ

មនុស្សពិការ មិនមានដៃ ជើង មាត់ និងរន្ធត្រចៀកយ៉ាងនេះ បាជាកូនដែលពួកយើងប្រាថ្នា ទើបបាន បាកុំឲ្យពួកយើងវិនាសឡើយ ចូរបាដោះពួកយើងអំពីការនិន្ទាពីសម្នាក់ព្រះរាជាពេញជម្ពូទ្វីបចុះ សូម្បីព្រះជនកព្រះជននីអង្វរយ៉ាងនេះ ព្រះពោធិសត្វផ្ងំស្ងៀម ដូចមិនបានឮព្រះវាចានោះ លំដាប់នោះ ព្រះជនកព្រះជននីរបស់ព្រះពោធិសត្វ ក៏ទ្រង់ព្រះកន្សែង ហើយចៀសចេញទៅ ជួនកាល ព្រះជនករបស់ព្រះពោធិសត្វតែមួយព្រះអង្គឯង ចូលទៅអង្វរព្រះពោធិសត្វ ជួនកាល ព្រះជននីតែមួយព្រះអង្គឯង ចូលទៅអង្វរព្រះពោធិសត្វ ជួនកាល ចូលទៅទាំងពីរអង្គ អង្វរជាមួយគ្នា ។ សូម្បីពិសោធដោយរងើកភ្លើងក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបានឃើញការខុសប្លែករបស់ព្រះពោធិសត្វ ។

លំដាប់នោះ កាលព្រះពោធិសត្វព្រះជន្មបាន ១៦ វស្សា ពួកអមាត្យព្រាហ្មណ៍ជាដើម គិតគ្នាថា ព្រះរាជកុមារខ្វិនក្តី គក្តី ថ្លង់ក្តី ចូរលើកទុកចុះ កាលវ័យប្រែប្រួលទៅ បុគ្គលដែលឈ្មោះថា មិនតម្រេកក្នុងអារម្មណ៍ដែលគួរតម្រេក មិនមាន ឈ្មោះថា មិនមើលក្នុងអារម្មណ៍ដែលគួរមើល មិនមាន ឈ្មោះថា មិនត្រេកអរក្នុងអារម្មណ៍ដែលគួរត្រេកអរ មិនមាន កាលដល់ពេលហើយ តម្រេកនេះ រមែងមានជាធម្មតា ដូចការរីករបស់ផ្កា ដូច្នោះ ពួកយើងនឹងឲ្យស្រីស្នំបម្រើព្រះរាជកុមារ ពិសោធព្រះរាជកុមារ ដោយស្រីស្នំទាំងនោះ ។ លំដាប់នោះ ព្រះបាទកាសិករាជ ទ្រង់មានព្រះតម្រាស់ឲ្យអ្នករបាំ ដែលទ្រទ្រង់នូវរូបដ៏ឧត្តម សម្បូរដោយលម្អដូចទេពអប្សរ ត្រាស់នឹង

ស្រីទាំងឡាយថា បណ្តានាងទាំងឡាយ ស្រីណា អាចធ្វើឲ្យព្រះរាជកុមារ ត្រេកអរ ឬចងដោយអំណាចកិលេសបាន ស្រីនោះ នឹងបានជាអគ្គមហេសី របស់ព្រះរាជកុមារនោះ ។ ស្រីស្នំទាំងឡាយ ស្រង់ព្រះរាជកុមារដោយទឹក ក្រអូប តាក់តែងព្រះរាជកុមារដូចទេវបុត្រ ឲ្យផ្ទំលើព្រះសិរីសេយ្យាសនៈ ដែលតាក់តែងល្អហើយ ក្នុងបន្ទប់ដ៏មានសិរី ដូចគ្នានឹងទេវវិមាន ធ្វើឲ្យជា ទីវង្វេង ព្រោះក្លិនក្រអូបដ៏កំពូលខាងក្នុងបន្ទប់ ដោយគ្រឿងក្រអូប កម្រងផ្កា កម្រងបុប្ផជាតិ និងលម្អិតផ្សេងក្រអូប និងគ្រឿងអប់ជាដើម ហើយចៀស ចេញទៅ ។ លំដាប់នោះ ស្រីទាំងនោះ នាំគ្នាចោមរោមព្រះពោធិសត្វ ព្យាយាមឲ្យព្រះពោធិសត្វអភិរម្យដោយការរាំច្រៀង ប្រគំដ៏ពាក្យពីរោះជាដើម មានប្រការផ្សេងៗ ព្រោះភាពដែលព្រះពោធិសត្វ ជាអ្នកសម្បូរដោយប្រាជ្ញា ទ្រង់មិនសម្លឹងមើលស្រីទាំងនោះ ទ្រង់អធិដ្ឋានថា ស្រីទាំងនោះ កុំបីពាល់ ត្រូវសរីរៈរបស់អញ ហើយទ្រង់អត់នូវដង្ហើម កាលនោះ សរីរៈរបស់ព្រះ ពោធិសត្វក៏រឹង ស្រីទាំងនោះ កាលមិនបានពាល់ត្រូវសរីរៈរបស់ព្រះពោធិសត្វ គិតថា ព្រះរាជកុមារនេះមានសរីរៈរឹង មិនមែនជាមនុស្ស គង់ជាយក្ខ ភ័យ ផង ខ្លាចផង មិនអាចតម្កល់ខ្លួនបាន ហើយនាំគ្នាគេចទៅ សូម្បីការពិសោធ ដោយស្រីទាំងឡាយ ក្នុងចន្លោះៗ យ៉ាងនេះ អស់កាលមួយឆ្នាំ ក៏មិនបាន ឃើញការខុសប្លែករបស់ព្រះពោធិសត្វ ពួកអមាត្យ ព្រាហ្មណ៍ ព្រះរាជា សូម្បីសាកល្បងដោយការពិសោធធំៗ ១៦ ដង និងដោយការសាកល្បង តូចៗ ជាច្រើនដង អស់ ១៦ ឆ្នាំ យ៉ាងនេះ ក៏មិនអាចចាប់កំហុសរបស់

ព្រះពោធិសត្វបាន ព្រះរាជាត្រាស់សួរស្រីស្នំទាំងឡាយថា នៃនាងទាំងឡាយ កូនរបស់យើងសើចជាមួយពួកនាងដែរឬទេ ស្រីទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ មិនបានសើចឡើយ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ស្រីទាំងនោះហើយ ទ្រង់ក្តៅក្រហាយព្រះហឫទ័យ ព្រោះហេតុនោះ ទ្រង់ត្រាស់ឲ្យហៅពួកព្រាហ្មណ៍ដែលទាយលក្ខណៈមកត្រាស់ថា នៃអ្នកដ៏ចម្រើនទាំងឡាយ កាលកុមារប្រសូត ពួកអ្នកប្រាប់យើងថា ព្រះរាជកុមារនេះ សម្បូរដោយបុញ្ញលក្ខណៈដ៏ឧត្តម ឯអន្តរាយមិនមានដល់ព្រះរាជកុមារនេះ ឥឡូវនេះកុមារនោះ ខ្វិនផង គផង ថ្លង់ផង ពាក្យសម្តីរបស់ពួកលោកធ្វើឲ្យយើងមិនត្រេកអរឡើយ ។ លំដាប់នោះ ព្រាហ្មណ៍ទាំងឡាយក្រាបទូលព្រះរាជាថា បពិត្រមហារាជ ឈ្មោះថា និមិត្តដែលអាចារ្យទាំងឡាយរបស់ពួកទូលបង្គំមិនឃើញ មិនមាន ម្យ៉ាងទៀត ព្រះរាជកុមារនេះ ជាឱរសដែលរាជត្រកូលទាំងឡាយប្រាថ្នា ទើបបានមក បើពួកទូលបង្គំក្រាបទូលថា ជាកាឡកិណីទោមនស្សគប្បីមានដល់ព្រះអង្គ ព្រោះហេតុនោះ ទើបពួកទូលបង្គំមិនក្រាបទូល ព្រះរាជាត្រាស់សួរថា ឥឡូវនេះ គួរធ្វើដូចម្តេច ព្រាហ្មណ៍ទាំងនោះក្រាបទូលថា បពិត្រមហារាជ បើព្រះរាជកុមារនៅក្នុងព្រះរាជវាំងនេះ អន្តរាយ ៣ យ៉ាងនឹងប្រាកដ គឺអន្តរាយនៃជីវិត ១ អន្តរាយនៃស្វេតច្ឆត្រ ១ អន្តរាយនៃអគ្គមហេសី ១ ព្រោះដូច្នោះ ទ្រង់យឺតយូរមិនបាន សូមទ្រង់ទឹមរថអពមង្គល ដោយសេះអពមង្គល ឲ្យព្រះរាជកុមារផ្ទំលើរថនោះ នាំចេញតាមទ្វារទៅទិសខាងលិច កប់ចោលក្នុងព្រៃស្មសាន ។ ព្រះរាជាទ្រង់ស្តាប់

ពាក្យព្រាហ្មណ៍ទាំងនោះ ទ្រង់ខ្លាចកយន្តរាយ ទើបឲ្យធ្វើយ៉ាងនោះ កាល នោះ ព្រះនាងចន្ទាទេវីបានស្តាប់នូវព្រឹត្តិហេតុនោះ ទើបប្រញាប់យាងចូល គាល់ព្រះរាជា តែមួយព្រះអង្គឯង ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រ ព្រះសម្មតិទេព ទ្រង់បានព្រះរាជទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់ទទួលហើយ ផ្ញើ ទុកនឹងព្រះអង្គ សូមទ្រង់ព្រះរាជទានពរនោះដល់ខ្ញុំម្ចាស់ក្នុងកាលឥឡូវនេះ ព្រះរាជាត្រាស់ថា ចូរនាងទទួលចុះ ព្រះនាងក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ព្រះរាជទានរាជសម្បត្តិដល់បុត្រខ្ញុំម្ចាស់ចុះ ព្រះរាជាត្រាស់ថា មិន បាន ព្រះទេវីទូលសួរថា ព្រោះហេតុអ្វី ក៏ត្រាស់ថា កូនរបស់យើងជា កាឡកិណី ព្រះទេវីទូលថា បពិត្រព្រះអង្គ បើមិនព្រះរាជទានមួយជីវិត សូមព្រះរាជទានរាជសម្បត្តិ ៧ ឆ្នាំ ព្រះរាជាត្រាស់ថា មិនបាន ព្រះទេវីទូល ថា បើដូច្នេះ សូមព្រះរាជទានរាជសម្បត្តិ ៦ ឆ្នាំ ព្រះរាជាត្រាស់ថា មិនបាន ព្រះទេវីទូលថា បើដូច្នោះ សូមព្រះរាជទានរាជសម្បត្តិ ៥ ឆ្នាំ ព្រះរាជា ត្រាស់ថា មិនបាន ព្រះនាងចន្ទាទេវីទូលសូមរាជសម្បត្តិបន្ថយចុះជាលំដាប់ គឺ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែ រហូតដល់ ៧ ថ្ងៃ ព្រះរាជាក៏ទ្រង់អនុញ្ញាត ទើបព្រះ នាងឲ្យតាក់តែងព្រះឱរស ហើយអភិសេកថា រាជសម្បត្តិនេះ ជារបស់ តេមិយកុមារ ឲ្យប្រកាសពេញព្រះនគរ ឲ្យប្រដាប់ព្រះនគរទាំងមូល ឲ្យព្រះ រាជឱរសប្រថាប់លើកដំរី ឲ្យលើកស្វេតច្ឆត្រលើព្រះសិរសារបស់ព្រះរាជ- ឱរស ធ្វើប្រទក្សិណព្រះនគរ ឲ្យព្រះរាជឱរសយាងមកផ្ទំលើព្រះទែនដ៏មាន

សិរី ត្រាស់អង្វរអស់យប់ និងថ្ងៃរហូតដល់ថ្ងៃទី ៥ ថា បាតេមិយៈ ម៉ែដេក មិនលក់ ទ្រហោយំអស់ ១៦ ឆ្នាំ ព្រោះកូន ភ្នែករបស់ម៉ែទាំងពីរជាមដោយ ទឹកភ្នែក បេះដូងរបស់ម៉ែស្ទើរប្រេះបែកដោយសេចក្តីសោក ម្តាយដឹងថា បា មិនមែនខ្វិនជាដើមឡើយ បាកុំធ្វើឲ្យម្តាយឥតទីពឹងឡើយ ។ កាលដល់ថ្ងៃទី ៦ ព្រះរាជាត្រាស់ឲ្យហៅនាយសារថីឈ្មោះសុនន្ទៈមកត្រាស់ថា នែសុនន្ទ សារថី ស្អែកនេះ ឯងចូរទឹមសេះអពមង្គលមួយគូ ដោយរថអពមង្គល ក្នុងពេលព្រលឹមនោះឯង ឲ្យព្រះរាជកុមារដេកលើរថនោះ នាំចេញតាមទ្វារ ទិសខាងលិច ប្រកាសថា មនុស្សកាឡកិណី ហើយចូរជីករណ្តៅ ៤ ជ្រុង ត្រង់ព្រៃខ្មោច ដាក់ព្រះកុមារក្នុងរណ្តៅនោះ ហើយយកត្បូងចបវាយក្បាល ឲ្យស្លាប់ លុបដីអំពីខាងលើ ពូនដីធ្វើជាផ្នូរ ងូតទឹក ហើយសឹមត្រឡប់មក នាយសារថីទទួលព្រះរាជតម្រាស់ថា សាធុ ។ ព្រះទេវី បានស្តាប់ដូច្នោះ ហឫទ័យរបស់ព្រះនាងស្ទើរបែកធ្លាយ យាងទៅកាន់សម្នាក់ព្រះរាជឱរស អង្វរ ព្រះរាជកុមារអស់រាត្រីថា បាតេមិយៈ ព្រះបាទកាសិករាជ បិតារបស់បា មានព្រះរាជតម្រាស់ឲ្យកប់បាក្នុងព្រៃខ្មោច ក្នុងព្រឹកស្អែកនេះ បានឹងស្លាប់ក្នុង ព្រឹកស្អែកនេះ ។ ព្រះមហាសត្វបានស្តាប់ដូច្នោះ ក៏មានព្រះហឫទ័យត្រេកអរ ទ្រង់ត្រិះរិះថា តេមិយៈ សេចក្តីព្យាយាមដែលអ្នកធ្វើមក ១៦ ឆ្នាំ មានោរថ របស់អ្នកដល់ទីបំផុត ក្នុងថ្ងៃស្អែកនេះ កាលព្រះមហាសត្វត្រិះរិះយ៉ាងនេះ បីតិក៏កើតក្នុងព្រះសរីរៈ ។ ចំណែកព្រះហឫទ័យរបស់ព្រះមាតាព្រះមហាសត្វ ត្រូវទុក្ខបៀតបៀនហាក់ដូចបែកធ្លាយ ។ ក្នុងកាលនោះ ព្រះមហាសត្វក៏ត្រិះរិះ

ថា បើអញនិយាយ មនោរថរបស់អញក៏នឹងមិនដល់ទីបំផុត ដូច្នេះ ទើបមិនត្រាស់ជាមួយព្រះជននីនោះ ។ លំដាប់នោះ កាលរាត្រីអស់ហើយ ព្រះទេវីទ្រង់ស្រង់ព្រះមហាសត្វ តាក់តែងព្រះកាយឲ្យ ហើយដាក់ឲ្យអង្គុយលើភ្លៅ ហើយប្រថាប់គង់ឱបព្រះមហាសត្វ ។ កាលនោះ សុនន្ទសារថីទឹមរថអំពីព្រហាមនោះ ដោយអានុភាពរបស់ព្រះមហាសត្វ ទេវតាបណ្ដាលចិត្តឲ្យទឹមសេះមង្គល បញ្ឈរទៀបព្រះរាជទ្វារ ឡើងកាន់ព្រះរាជនិវេសន៍ ចូលកាន់បន្ទប់ដ៏មានសិរី ថ្វាយបង្គំព្រះទេវីហើយ ក្រាបទូលថា បពិត្រព្រះទេវី សូមព្រះនាងកុំពិរោធនឹងទូលបង្គំៗ ទទួលព្រះរាជបញ្ជាមកទេ ក្រាបទូលដូច្នេះហើយ យកខ្នងដៃកៀសព្រះនាងដែលកំពុងឱបព្រះរាជឱរសឲ្យឃ្លាតទៅ ចាប់បីព្រះរាជកុមារដូចបីបាច់ផ្កា ចុះអំពីប្រាសាទ ។ កាលនោះ ព្រះនាងចន្ទាទេវីរំសាយព្រះកេសា គក់ទ្រូង បរិទេវនាការជាមួយពួកស្នំក្នុងប្រាសាទ ។

លំដាប់នោះ ព្រះមហាសត្វទតឃើញព្រះមាតាទ្រង់ព្រះកន្សែង ទ្រង់ហាក់ដូចជាមានព្រះហទយៈបែកធ្លាយជា ៧ ចម្រៀក ទ្រង់ត្រិះរិះថា ប្រសិនបើអញមិននិយាយជាមួយព្រះជននី ព្រះជននីរបស់អញ នឹងមានព្រះហឫទ័យបែកធ្លាយ ក្ស័យព្រះជន្ម ទើបទ្រង់ប្រាថ្នានឹងនិយាយ តែទ្រង់ត្រិះរិះថា បើអញនិយាយជាមួយនឹងព្រះមាតា សេចក្ដីព្យាយាមដែលអញធ្វើមកអស់ ១៦ ឆ្នាំ ក៏នឹងឥតប្រយោជន៍ទទេ តែបើមិននិយាយ អញនឹងបានជាប្រយោជន៍ដល់ខ្លួនឯង ដល់ព្រះជនកព្រះជននី និងដល់មហាជន ទ្រង់ត្រិះរិះដូច្នេះ ទើបទ្រង់អត់សង្កត់នូវសេចក្ដីសោកបាន មិនត្រាស់ជាមួយព្រះជននីឡើយ ។

លំដាប់នោះ សុនន្ទសារថីឲ្យព្រះមហាសត្វឡើងរថហើយគិតថា អញនឹងបររថទៅកាន់ទិសខាងលិច ដោយអានុភាពនៃមហាសត្វ ត្រូវទេវតាបណ្ដាលចិត្ត ឲ្យបររថតម្រង់ទៅទិសខាងកើត កាលនោះ កង់រថប៉ះធរណីទ្វារ ព្រះមហាសត្វបានស្ដាប់សំឡេងនោះ ទ្រង់ត្រិះរិះថា មនោរថរបស់អញដល់ទីបំផុតហើយ មានព្រះហឫទ័យត្រេកអរក្រៃលែង ។ រថស្ទុះចេញអំពីព្រះនគរអស់ផ្លូវចម្ងាយ ៣ យោជន៍ ដល់ព្រៃស្មាប់ ត្រង់ទីនោះប្រាកដដល់នាយសារថីដូចជាព្រៃខ្មោច នាយសារថីកំណត់ថា ទីនេះជាសុក ទើបបញ្ឈររថចេញអំពីផ្លូវ ចុះអំពីរថ ដោះនូវគ្រឿងតែងកាយរបស់ព្រះមហាសត្វ ខ្ចប់កាន់ យកចបចាប់ផ្ដើមជីករណ្ដៅ ៤ ជ្រុង ក្នុងទីមិនឆ្ងាយអំពីរថ បន្ទាប់អំពីនោះ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា កាលនេះ ជាកាលដែលត្រូវព្យាយាមរបស់អញ អញព្យាយាមអស់ ១៦ ឆ្នាំ មិនកម្រើកដៃ និងជើង កម្លាំងរបស់អញមានដែរឬហ្ន៎ ដូច្នេះហើយ ក្រោកឡើងប្របាច់ដៃស្ដាំដោយដៃឆ្វេង ប្របាច់ដៃឆ្វេងដោយដៃស្ដាំ ប្របាច់ជើងទាំងពីរដោយដៃទាំងពីរ មានចិត្តគិតចុះអំពីរថ ខណៈនោះ ផែនដីក៏កំពុងឡើងត្រង់ទីប្រតិស្ឋានព្រះបាទនៃព្រះមហាសត្វដូចពំនូកចូលីដែលពេញដោយខ្យល់ប៉ោងឡើង ដូច្នោះ ។ ព្រះមហាសត្វចុះអំពីរថ ទ្រង់យាងទៅមកបន្តិចបន្តួច ក៏ទ្រង់ជ្រាបថា អញមានកម្លាំង ដែលដើរចម្ងាយមួយរយយោជន៍ក្នុងមួយថ្ងៃ កាលទ្រង់ពិចារណាកម្លាំងថា បើសារថីប្រទូស្តអញ កម្លាំងរបស់អញ ដែលតតាំងជាមួយសារថី មានឬហ្ន៎ ទើបទ្រង់ចាប់ទីបំផុតនៃរថលើកឡើង ប្រដាប់ឈរ គ្រវីនូវរថនោះ ដូចចាប់រទេះ

ដែលជាគ្រឿងលេងរបស់ពួកកូនក្មេង ដូច្នោះ កាលទ្រង់កំណត់ថា កម្លាំង ដែលត្រូវតតាំងជាមួយនាយសារថីរបស់ព្រះអគ្គ មាន ទើបទ្រង់បំណងចង់ បានគ្រឿងប្រដាប់កាយ ខណៈនោះ ភពរបស់សក្កទេវរាជក៏សម្ដែងអាការក្ដៅ សក្កទេវរាជទ្រង់អាវជ្ជនាការ ក៏ជ្រាបហេតុនោះ ទ្រង់ត្រិះរិះថា សេចក្ដីប្រាថ្នា របស់តេមិយកុមារដល់ទីបំផុតហើយ ឥឡូវនេះ លោកត្រូវការគ្រឿងប្រដាប់ គ្រឿងប្រដាប់របស់មនុស្ស លោកត្រូវការធ្វើអ្វី អញនឹងឲ្យតេមិយកុមារ ប្រដាប់ដោយគ្រឿងអលង្ការដែលជាទិព្វ ទើបហៅវិស្សកម្មទេវបុត្រ មកប្រគល់ គ្រឿងអលង្ការទិព្វហើយ ទ្រង់បញ្ជូនទៅដោយត្រាស់ថា នែបា ចូរអ្នកទៅចុះ ចូរបាប្រដាប់តេមិយកុមាររាជឱរស របស់ព្រះបាទកាសិករាជដោយគ្រឿង អលង្ការដែលជាទិព្វ វិស្សកម្មទេវបុត្រស្ដាប់ពាក្យរបស់សក្កទេវរាជ ទទួល ព្រះរាជឱង្ការហើយ មកកាន់មនុស្សលោក ចូលទៅកាន់សម្នាក់ព្រះមហាសត្វ ជួតព្រះសិរសាព្រះមហាសត្វដោយសំពត់ទិព្វ ១ ម៉ឺនជុំ ប្រដាប់ព្រះមហាសត្វ ដូចសក្កទេវរាជ ដោយគ្រឿងប្រដាប់ដែលជាទិព្វ និងរបស់មនុស្ស ហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។ ព្រះមហាសត្វ យាងទៅកាន់ទីជីករណ្ដៅ របស់នាយសារថី ដោយសក្កលីលា ប្រថាប់ឈរត្រង់មាត់រណ្ដៅ កាលនឹង ត្រាស់សួរនាយសារថីនោះ បានត្រាស់គាថាទី ៣ ថា

នែនាយសារថី អ្នកប្រញាប់ប្រញាល់ ជីករណ្ដៅ តើព្រោះហេតុ
អ្វី ម្នាលសម្លាញ់ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់មកចុះ អ្នកនឹង
ធ្វើនូវអ្វីដោយរណ្ដៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាសុំ** បានដល់ រណ្ដៅ ៤ ជ្រុង ។ នាយសារថីបានស្ដាប់ដូច្នោះ ជីករណ្ដៅមិនបានងើបមើល ពោលគាថាទី ៤ ថា

ព្រះរាជបុត្តកើតមកហើយ គផង ខ្វិនផង ដូចជាឥតចិត្ត ឯខ្ញុំនោះ
ព្រះរាជាទ្រង់ត្រាស់ប្រើមកហើយថា អ្នកត្រូវជីកកប់កូនអញក្នុង
ព្រៃចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បក្ខោ** បានដល់ ជាមនុស្សខ្វិន ។ ដោយបទថា **មូគោ** នោះឯង សំដៅដល់ ភាពជាមនុស្សថ្លង់របស់តេមិយកុមារ ព្រោះមនុស្សថ្លង់ មិនអាចពោលតបបាន ។ បទថា **អចេតសោ** សេចក្ដីថា ដូចមិនមានចិត្ត សារថីពោលយ៉ាងនេះ ព្រោះតេមិយកុមារមិននិយាយអស់ ១៦ ឆ្នាំ ។ បទថា **សមជ្ឈិដ្ឋោ** សេចក្ដីថា ព្រះរាជាមានព្រះតម្រាស់បញ្ជូនទៅហើយ ។ បទថា **និក្ខណំ វនេ** សេចក្ដីថា គប្បីកប់ក្នុងព្រៃ ។

លំដាប់នោះ ព្រះមហាសត្វពោលនឹងនាយសារថីថា

ខ្ញុំមិនថ្លង់ មិនគ មិនខ្វិនទេ មិនមែនវិកលវិការទេ នែនាយសារថី
បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ អ្នកចូរមើលភ្លៅ
និងដើមដៃខ្ញុំ ទាំងចូរស្ដាប់សម្ដីខ្ញុំ នែនាយសារថី បើអ្នកកប់ខ្ញុំ
ក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពធិរោ** សេចក្ដីថា ព្រះមហាសត្វត្រាស់យ៉ាងនេះដើម្បីសំដែងថា នែនាយសារថីសម្លាញ់ បើព្រះរាជាមានព្រះតម្រាស់ឲ្យកប់ព្រះឱរសនេះយ៉ាងនោះ តែយើងមិនមានសភាពដូច្នោះឡើយ ។ បទថា

**បង្គុលោ** បានដល់ មានឥន្ទ្រិយវិកលវិការ ។ បទថា **មញ្ចេ តុំ និក្ខណាំ វនេ** សេចក្ដីថា បើអ្នកកប់យើងដែលវៀរចាកភាពជាមនុស្សថ្លង់ជាដើម បែបនេះ ក្នុងព្រៃ អ្នកគប្បីធ្វើវត្ថុដែលមិនជាធម៌ គេមិយកុមារនោះ ឃើញនាយសារថីស្ដាប់គាថាដំបូងហើយ មិនសម្លឹងមើលទ្រង់ឡើយ ទ្រង់ត្រិះរិះថា អញនឹងសម្ដែងដល់នាយសារថីនេះថា យើងមិនថ្លង់ មិនគ មិនខ្វិន គាក់តែងសរីរៈហើយ ទើបត្រាស់គាថានេះថា ឱរូ ជាដើម គាថានោះ មានអត្ថថា នែសារថីសម្លាញ់ ចូរអ្នកមើលភ្លៅទាំងពីររបស់យើង គឺរបស់ខ្ញុំ ដែលដូចគ្នានឹងដើមចេកមាស ដើមដៃទាំងពីររបស់យើង គឺរបស់ខ្ញុំ មានពណ៌ដូចត្រួយចេកមាស និងចូរស្ដាប់ពាក្យដ៏ពីរោះរបស់យើង បន្ទាប់អំពីនោះ នាយសារថីគិតថា បុគ្គលនេះជានរណាហ្ន៎ មកសរសើរតែខ្លួនប៉ុណ្ណោះ ឈប់ជីករណ្ដៅហើយងើបមុខមើល បានឃើញរូបសម្បត្តិរបស់មហាសត្វ កាលមិនស្គាល់ព្រះមហាសត្វថា បុរសនេះជាមនុស្ស ឬជាទេវតាហ្ន៎ ទើបពោលគាថានេះថា

អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាបុរិន្ទទសក្កទេវរាជ អ្នកជាអ្វី
ទាំងជាកូនអ្នកណា យើងនឹងស្គាល់អ្នកបានដោយប្រការដូចម្ដេច
ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វ កាលនឹងបង្ហាញខ្លួនឲ្យជាក់ច្បាស់ និងសម្ដែងធម៌ ទើបត្រាស់គាថាដូច្នេះថា

ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាបុរិន្ទទសក្កទេវរាជ
ទេ អ្នកកប់បុគ្គលណាក្នុងរណ្ដៅ បុគ្គលនោះ គឺខ្ញុំជាកូនរបស់ព្រះ

បាទកាសិកៈ អ្នករស់នៅដោយស្រួល ( ព្រោះអាស្រ័យ ) នូវព្រះរាជាណា ខ្ញុំជាកូនរបស់ព្រះរាជានោះ នៃនាយសារថី បើអ្នកនឹងកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ បុគ្គលគប្បីអង្គុយឬដេកក្រោមម្លប់ឈើណា មិនគប្បីកាច់បំបាក់មែកឈើនោះទេ ព្រោះថា អ្នកទ្រុស្តមិត្ត ជាមនុស្សលាមក នៃនាយសារថី ព្រះរាជាទុកដូចជាដើមឈើ ខ្លួនខ្ញុំ ទុកដូចជាមែកឈើដែរ អ្នកឯងទុកដូចបុរសដែលចូលទៅជ្រកក្រោមម្លប់ឈើ ដូច្នោះ នៃនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នក ឈ្មោះថា ធ្វើខុសធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆិហាញ្ញសិ** បានដល់ នឹងប្រហារ ព្រះមហាសត្វសម្តែងថា អ្នកជីករណ្តៅ បំណងនឹងកប់បុគ្គលណាក្នុងរណ្តៅនេះ យើង គឺបុគ្គលនោះ កាលព្រះមហាសត្វត្រាស់ថា យើងជាឱរស នាយសារថីក៏នៅមិនជឿនោះឯង តែដឹងបានដោយមធុរកថារបស់ព្រះមហាសត្វនោះ ទើបឈរស្តាប់ធម៌ ។ បទថា **មិត្តទុព្ភោ** បានដល់ អ្នកសម្លាប់មិត្ត គឺបៀតបៀនមិត្តទាំងឡាយ ។ បទថា **រុក្ខស្ស** សេចក្តីថា បុគ្គលកាច់នូវឫសដើម ផ្លែ ស្លឹក ឬលំពង់របស់ដើមឈើ ដែលមានម្លប់ដល់ខ្លួន ដែលខ្លួនបានប្រើប្រាស់ រមែងជាអ្នកសម្លាប់មិត្ត គឺបៀតបៀនមិត្ត ។ បទថា **ធាបកោ** បានដល់ ជាបុគ្គលលាមក នឹងពោលថ្មីដល់ការសម្លាប់មនុស្ស ។ ដោយបទថា **ធាយ្យបគោ** ព្រះមហាសត្វត្រាស់ថា នៃសារថី អ្នកអាស្រ័យព្រះរាជាចិញ្ចឹមជីវិត ដូចមនុស្សចូលទៅកាន់ម្លប់របស់ដើមឈើ ដើម្បីប្រើប្រាស់

ដូច្នោះ កាលព្រះពោធិសត្វត្រាស់យ៉ាងនេះ នាយសារថីក៏មិនជឿនោះឯង លំដាប់នោះ ព្រះមហាសត្វទ្រង់ត្រិះរិះថា អញនឹងធ្វើឲ្យសារថីនេះជឿ ទ្រង់ធ្វើព្រៃឲ្យលាន់ឮដោយសំឡេងសាធុការរបស់ពួកទេវតា និងដោយពាក្យឃោសនារបស់ព្រះអង្គ កាលត្រាស់គាថាបូជាមិត្ត ១០ ប្រការ ទើបត្រាស់ថា

បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ បុគ្គលនោះ បើចេញផុតអំពីផ្ទះរបស់ខ្លួនហើយ ជាអ្នកមានកក្ខាហារច្រើន ជនច្រើននាក់ តែងចិញ្ចឹមជីវិត ( អាស្រ័យ ) បុគ្គលនោះ ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ បុគ្គលនោះ ទៅកាន់ជនបទ និគម រាជធានីណាៗ គេតែងបូជាក្នុងទីទាំងអស់នោះ ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ ពួកចោរមិនគំហែង បុគ្គលនោះ សត្វក៏មិនមើលងាយបុគ្គលនោះ បុគ្គលនោះ រមែងកន្លងនូវសត្រូវទាំងអស់ ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្តទាំងឡាយ បុគ្គលនោះ មិនខឹង មកកាន់ផ្ទះរបស់ខ្លួន ជាអ្នកគេទទួលរីករាយក្នុងរោងសម្រាប់ប្រជុំ ជាបុគ្គលឧត្តមរបស់ពួកញាតិ ។ បុគ្គលធ្វើសក្ការៈចំពោះ ( មិត្ត ) រមែងត្រូវមិត្តធ្វើសក្ការៈវិញ ជាអ្នកគោរព ( មិត្ត ) រមែងបានសេចក្តីគោរពវិញ បុគ្គលមិនប្រទូស្តមិត្ត រមែងពេញដោយគុណ និងកិត្តិសព្ទ ។ បុគ្គលអ្នកបូជាមិត្ត រមែងបានការបូជាវិញ ជាអ្នកសំពះមិត្ត រមែងបានការសំពះតបវិញ

បុគ្គលមិនប្រទូស្តមិត្ត រមែងដល់នូវយសបរិវារ និងកិត្តិសព្ទ ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ បុគ្គលនោះ រមែងរុងរឿង ដូចភ្លើង រុងរឿងដូចទេវតា ជាអ្នកមិនលះបង់ចាកសិរីឡើយ ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ គោទាំងឡាយរបស់បុគ្គលនោះ សម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះ សាបព្រោះក្នុងស្រែ រមែងដុះដាល បុគ្គលនោះ រមែងបរិភោគផ្លែនៃពូជទាំងឡាយ ដែលខ្លួនសាបព្រោះហើយ ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ បុគ្គលនោះ សូម្បីធ្លាក់ទៅក្នុងជ្រោះក្តី អំពីភ្នំក្តី អំពីដើមឈើក្តី ធ្លាក់ហើយ រមែងបានទីពឹង ។ បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ សត្រូវទាំងឡាយ គ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់ មិនអាចគ្របសង្កត់ដើមជ្រៃ ដែលមានឫស និងពួរដុះហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុតព្ភក្ខោ** បានដល់ បានភិក្ខាហារមកងាយ ។ បទថា **សកម្ហា** បានដល់ ចេញអំពីផ្ទះរបស់ខ្លួន ម្យ៉ាងទៀតបាឋៈ ក៏យ៉ាងនេះឯង ។ បទថា **ន ទុព្ភតិ** បានដល់ មិនប្រទូស្ត ។ បទថា **សព្វត្ថ បូជិតោ ហោតិ** នេះ គប្បីពណ៌នាដោយរឿងព្រះសីវលី ។ បទថា **នាស្ស ចោរា បសហន្តិ** សេចក្តីថា ពួកចោរមិនអាចធ្វើការសង្កត់សង្កិនពាក្យនេះ គប្បីសម្តែងដោយរឿងសង្កិច្ចសាមណេរ ។ បទថា **នាតិមញ្ញតិ ខត្តិយោ** នេះ គប្បីសម្តែងដោយរឿងជោតិកសេដ្ឋី ។ បទថា **តរតិ** បានដល់

រមែងធ្ងន់ គឺឈានកន្ទួន ។ បទថា **សយំ ឯតិ** សេចក្តីថា ជាអ្នកទ្រុស្តមិត្ត សូម្បីមកផ្ទះរបស់ខ្លួន ក៏មានចិត្តខឹងក្រោធមក តែបុគ្គលមិនទ្រុស្តមិត្ត រមែងមិនក្រោធ មកកាន់ផ្ទះរបស់ខ្លួន ។ បទថា **បដិឆន្ទិតោ** សេចក្តីថា រមែងពោលគុណកថារបស់បុគ្គលមិនទ្រុស្តមិត្ត ក្នុងទីប្រជុំរបស់ជនច្រើន ដែលមិនប្រទូស្តមិត្តនោះ រមែងជាបុគ្គលត្រេកអរដោយហេតុនោះ ។ បទថា **សក្កត្វា សក្កតោ ហោតិ** សេចក្តីថា សក្ការៈដែលធ្វើដល់អ្នកដទៃហើយ ខ្លួនឯងជាបុគ្គលដែលអ្នកដទៃធ្វើសក្ការៈដូចគ្នា ។ បទថា **គរុ ហោតិ សគារវោ** សេចក្តីថា មានសេចក្តីគោរពក្នុងអ្នកដទៃទាំងឡាយ សូម្បីខ្លួនឯង ក៏ជាបុគ្គលដែលអ្នកដទៃទាំងឡាយគោរព ។ បទថា **វណ្ណកិត្តិភតោ ហោតិ** សេចក្តីថា បានទទួលនូវការលើកតម្កើង និងការសរសើរ គឺលើកតម្កើងនូវគុណ និងសេចក្តីសរសើរ ដើរប្រកាស ។ បទថា **បូជកោ** សេចក្តីថា ជាអ្នកបូជាមិត្តទាំងឡាយ សូម្បីខ្លួនឯង ក៏រមែងបាននូវការបូជា ។ បទថា **វន្ទកោ** សេចក្តីថា បុគ្គលថ្វាយបង្គំកល្យាណមិត្តទាំងឡាយ មានព្រះពុទ្ធជាដើម រមែងបានថ្វាយបង្គំតបក្នុងកពថ្មី ។ បទថា **យសោកិត្តឹ** សេចក្តីថា រមែងដល់នូវឥស្សរិយយស និងបរិវារយស និងសំឡេងសរសើរគុណ គប្បីពោលដល់រឿងរបស់ចិត្តគហបតីដោយគាថានេះ ។ បទថា **បជ្ជលតិ** សេចក្តីថា រមែងរុងរឿងដោយឥស្សរិយយស និងបរិវារយស ។ ក្នុងបទថា **សិរិយា អជ្ជហិតោ ហោតិ** នេះ គួរពោលរឿងរបស់អនាថបិណ្ឌិកសេដ្ឋី ។ បទថា **អស្នាតិ** បានដល់ រមែងបរិភោគប្រើប្រាស់ ។ បទថា **បតិដ្ឋំ លភតិ** គប្បី

សម្ដែងដោយចុល្លបទុមជាតក ។ បទថា **វិរូឡ្ហមូលសន្តានំ** បានដល់ មានឫស និងពួរចម្រើន ។ ក្នុងបទថា **អមិត្តា ឆប្បសហាន្តិ** នេះ គប្បីពោលរឿងចោរចូលផ្ទះមាតារបស់ព្រះសោណត្ថេរក្នុងកុរឃរនគរ ។

សុនន្ទសារថីបានស្ដាប់ដូច្នោះ សូម្បីព្រះមហាសត្វទ្រង់សម្ដែងធម្មកថាមានប្រមាណប៉ុណ្ណោះ ក៏ចាំព្រះអង្គមិនបាន ឈប់ជីករណ្ដៅ ដោយគិតថា បុរសនេះ ជាអ្នកណាហ្ន៎ ហើយក្រោកឡើងដើរទៅក្បែររថ មិនឃើញព្រះមហាសត្វ និងគ្រឿងប្រដាប់ ទើបត្រឡប់មកមើលម្ដងទៀត ក៏ចាំបាន ហើយក្រាបចុះទៀបបាទានៃព្រះមហាសត្វ ផ្គងអញ្ជលីទូលព្រះគាថានេះថា

បពិត្រព្រះរាជបុត្ត សូមទ្រង់ស្ដេចមក ទូលព្រះបង្គំជាខ្ញុំ នឹងនាំទ្រង់ទៅកាន់ដំណាក់របស់ព្រះអង្គ សូមទ្រង់សោយរាជ្យចុះ សេចក្ដីចម្រើននឹងមានដល់ទ្រង់ ទ្រង់នឹងធ្វើអ្វីក្នុងព្រៃ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វក៏ត្រាស់នឹងសារថីថា

នែនាយសារថី រាជសម្បត្តិណា ដែលខ្ញុំគប្បីបានដោយអធម្មចរិយៈ ខ្ញុំមិនត្រូវការដោយរាជសម្បត្តិនោះ ឬដោយជនជាញាតិ ឬក៏ដោយទ្រព្យទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អលំ** ជាពាក្យបដិសេធ ។ នាយសារថីក្រាបទូលថា

បពិត្រព្រះរាជបុត្ត សូមទ្រង់ស្ដេចទៅអំពីទីនេះ ហើយញុំាងទូលព្រះបង្គំជាខ្ញុំ ឲ្យបាននូវរង្វាន់ជាទីត្រេកអរ បពិត្រព្រះរាជបុត្ត កាល

បើព្រះអង្គស្តេចទៅហើយ ព្រះរាជបិតា និងព្រះមាតា គប្បីប្រទាន ( រង្វាន់ ) ដល់ទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះរាជបុត្ត កាលទ្រង់ស្តេចទៅហើយ ពួកស្រីស្នំ និងរាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ជនទាំងអម្បាលនោះ មានចិត្តត្រេកអរ គប្បីឲ្យ ( រង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ) ។ បពិត្រព្រះរាជបុត្ត កាលទ្រង់ស្តេចទៅហើយ ពួកហ្មដំរី ពួកពលរក្សាព្រះអង្គ ពួកពលរថ ពួកថ្មើរជើង ជនទាំងអម្បាលនោះ មានចិត្តត្រេកអរ គប្បីឲ្យ ( រង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ) ។ បពិត្រព្រះរាជបុត្ត កាលទ្រង់ស្តេចទៅ ពួកអ្នកជនបទ និងពួកអ្នកនិគម មានធញ្ញាហារច្រើន មកប្រជុំគ្នា គប្បីឲ្យគ្រឿងបណ្ណាការទាំងឡាយ ដល់ទូលព្រះបង្គំជាខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុណ្ណបត្តំ** បានដល់ រង្វាន់ជាគ្រឿងត្រេកអរ គឺរបស់ឲ្យដែលគួរត្រេកអរ ។ បទថា **ទជ្ជុំ** សេចក្តីថា គប្បីឲ្យរង្វាន់ជាគ្រឿងត្រេកអរ ដែលធ្វើនូវបំណងរបស់ខ្ញុំឲ្យបរិបូណ៌ដូចភ្លៀង គឺរតនៈ ៧ ប្រការ ដូច្នោះ នាយសារថីគិតថា ទោះជាយ៉ាងណា ព្រះរាជកុមារនេះពិតជាត្រឡប់កាលអនុគ្រោះអញទើបពោលពាក្យនេះ ។ បទថា **វេសិយានា** ប្រែថា ឈ្មួញ ។ បទថា **ឧបាយនានិ** ប្រែថា គ្រឿងបណ្ណាការ ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះហើយ ក៏ត្រាស់ថា

ខ្ញុំ ដែលព្រះបិតាមាតា អ្នកដែន អ្នកនិគម និងពួករាជកុមារទាំង

ពួង បានលះចោលហើយ ផ្ទះរបស់ខ្លួនខ្ញុំមិនមានទេ ខ្ញុំ ដែលព្រះមាតាបានអនុញ្ញាតឲ្យទទួលរាជ្យ ៧ ថ្ងៃហើយ ខ្ញុំ ដែលព្រះបិតាលះចោលស្រឡះហើយ ខ្ញុំនឹងបួសនៅក្នុងព្រៃតែម្នាក់ឯង មិនប្រាថ្នានូវកាមទាំងឡាយឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បិតុ មាតុ ច** ប្រែថា ដែលព្រះជនក និងព្រះជននី ។ បទថា **ចត្តោ** ប្រែថា លះបង់ហើយ សូម្បីក្នុងបទក្រៅអំពីនេះក៏មានន័យដូចគ្នា ។ បទថា **មត្យា** សេចក្ដីថា នែនាយសារថីសម្លាញ់ យើងឈ្មោះថា ព្រះជននី ទ្រង់ទទួលពរឲ្យគ្រងរាជសម្បត្តិ ៧ ថ្ងៃ ទ្រង់អនុញ្ញាតហើយ ។ បទថា **សព្វត្តោ** បានដល់ លះហើយដោយល្អ ។ បទថា **បព្វជិតោ** សេចក្ដីថា ចេញដើម្បីបួសក្នុងព្រៃ ។

កាលព្រះមហាសត្វ ត្រាស់នូវគុណធម៌របស់ព្រះអង្គយ៉ាងនេះ បីតិក៏កើតឡើងហើយ បន្ទាប់អំពីនោះ កាលទ្រង់បន្លឺព្រះឧទានដោយកម្លាំងបីតិទើបត្រាស់ថា

សេចក្ដីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ( អស់ ១៦ ឆ្នាំ ) ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យអំពីណា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ផលាសាវ** សេចក្ដីថា ព្រះមហាសត្វត្រាស់យ៉ាងនេះ ដើម្បីសម្ដែងថា ផលនៃការប្រាថ្នារបស់យើង ដែលមិនប្រញាប់ប្រញាល់ ១៦ ឆ្នាំ ទើបសម្រេច ។ បទថា **វិបក្កព្រហ្មចរិយោស្មិ** បានដល់ មានការប្រាថ្នាដល់ទីបំផុតហើយ ។ បទថា **សម្មទត្ថោ វិបច្ចតិ** សេចក្ដីថា ប្រភេទគុណវិសេស មានឈានជាដើម ដែលជាកិច្ចគប្បីធ្វើ រមែងសម្រេចដោយប្រពៃ គឺដោយឧបាយ ដោយហេតុ ។

នាយសារថីក្រាបទូលថា

ទ្រង់នោះ មានព្រះបន្ទូលពីរោះ មានព្រះបន្ទូលក្បោះក្បាយយ៉ាងនេះ ហេតុអ្វី បានជាទ្រង់មិនមានព្រះបន្ទូលក្នុងសម្នាក់នៃព្រះបិតា ព្រះមាតា ក្នុងពេលនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វគ្គុករោ** បានដល់ មានព្រះតម្រាស់ពីរោះ គឺមានព្រះតម្រាស់ក្បោះក្បាយ ។ បន្ទាប់អំពីនោះ ព្រះមហាសត្វក៏ត្រាស់ថា

ខ្ញុំមិនមែនខ្វិន ព្រោះមិនមានសន្ទាក់ទេ ខ្ញុំមិនមែនថ្លង់ ព្រោះមិនមានសោតប្រសាទទេ ខ្ញុំមិនមែនគ ព្រោះមិនមានជិវ្ហាប្រសាទទេ អ្នកកុំសម្គាល់ខ្ញុំថា ជាមនុស្សគឡើយ ។ ខ្ញុំរឭកឃើញនូវជាតិមុន ជាជាតិដែលខ្ញុំបានសោយរាជ្យ លុះខ្ញុំសោយរាជ្យ ក្នុងជាតិនោះហើយ ក៏ធ្លាក់នរកគួរស្បើប ។ ខ្ញុំសោយរាជ្យក្នុងជាតិនោះ អស់ ២០ ឆ្នាំ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ ។ ខ្ញុំខ្លាចរាជនោះ កុំឲ្យព្រះមាតាបិតា អភិសេកខ្ញុំក្នុងរាជ្យ ព្រោះហេតុនោះ បានជាខ្ញុំមិន

និយាយក្នុងសម្នាក់នៃព្រះបិតាមាតា ក្នុងកាលនោះ ។ ព្រះរាជ-បិតា បានឲ្យខ្ញុំអង្គុយលើព្រះឧរុ ហើយទ្រង់វិនិច្ឆ័យក្តីថា អ្នកទាំងឡាយ ចូរសម្លាប់ចោរ ១ នាក់ ចូរចងចោរ ១ នាក់ ( ធ្វើចោរ ១ នាក់ ) ឲ្យប្រឡាក់ដោយទឹកក្បួង ។ ចូរដោតចោរ ១ នាក់លើឈើស្រួច ព្រះរាជបិតាត្រាស់បង្គាប់មហាជន ដោយប្រការដូច្នេះ លុះខ្ញុំស្តាប់នូវវាចាដ៏អាក្រក់នោះ ដែលព្រះរាជបិតា ទ្រង់ត្រាស់ហើយ ។ ខ្ញុំមិនគទេ តែមានភេទដូចបុគ្គលគរ ខ្ញុំមិនខ្វិនទេ តែសន្មតថា ដូចជាខ្វិន ខ្ញុំបាននៅជ្រមុជជ្រមុល ក្នុងមូត្រ និងករីសរបស់ខ្លួន ។ ជីវិត ( របស់សត្វ ) លំបាកផង តិចផង ជីវិតនោះ ប្រកបដោយទុក្ខ បុគ្គលណា អាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរ ដោយហេតុណានីមួយ ។ បុគ្គលណា អាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរ ដោយហេតុណានីមួយ ព្រោះមិនបានបញ្ញាផង ព្រោះមិនឃើញធម៌ផង ។ សេចក្តីប្រាថ្នាជាផលតែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្ម-ចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យអំពីណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសទ្ធិតា** បានដល់ ព្រោះមិនមានតំណ

គឺមិនមានទីត ។ បទថា **អសោតតា** បានដល់ ព្រោះមិនមានសោត: ។ បទថា **អដ្ឋិវត្តា** សេចក្តីថា យើងនោះមិនគរ ព្រោះមិនមានអណ្តាតសម្រាប់គ្រលាស់ទៅមកនៃវាចាក៏ទេ ។ បទថា **យត្ថ** សេចក្តីថា បានសោយរាជសម្បត្តិក្នុងក្រុងពារាណសីនោះឯង ក្នុងជាតិណាមួយ ។ បទថា **ចាបត្តំ** សេចក្តីថា ព្រះមហាសត្វត្រាស់ដល់អំពើអាក្រក់ថា ព្រះអង្គបានធ្លាក់មកហើយ ។ បទថា **រជ្ជាភិសេចយុំ** បានដល់ គប្បីអភិសេកក្នុងរាជសម្បត្តិ ។ បទថា **និសីទេត្វា** សេចក្តីថា ឲ្យអង្គុយហើយ ។ បទថា **អត្តានុសាសតិ** សេចក្តីថា ត្រាស់បញ្ជានូវទោសកំហុស ។ បទថា **ទារាបតច្ចិកំ** សេចក្តីថា ចូរយកលំពែងចាក់ ហើយស្រោចដោយទឹកក្បួង ។ បទថា **ឧព្វេជ** បានដល់ ចូរលើកឡើង គឺចូរដោត ។ បទថា **ឥច្ចស្ស អនុសាសតិ** សេចក្តីថា ត្រាស់ដល់មហាជនទាំងនោះយ៉ាងនេះ ។ បទថា **តាយាហំ** សេចក្តីថា យើងបានស្តាប់ព្រះវាចាទាំងនោះ ។ បទថា **បក្ខសម្មតោ** សេចក្តីថា បានជាបុគ្គលដែលជនទាំងឡាយយល់ថា ជាមនុស្សខ្វិន គឺដូចមនុស្សខ្វិន ។ បទថា **អច្ឆាហំ** សេចក្តីថា នៅហើយ គឺយើងនៅហើយ ។ បទថា **សំបរិប្លុតោ** សេចក្តីថា ជាអ្នកបម្រះនទៀល គឺលិចចុះហើយ ។ បទថា **កសិរំ** បានដល់ ជាទុក្ខ ។ បទថា **បរិត្តំ** បានដល់ តិចតួច ពាក្យនេះ មានអធិប្បាយថា នៃសារបើសម្លាញ់ ជីវិតរបស់សត្វទាំងឡាយជាទុក្ខ បើតាំងនៅយូរ ក៏គួរប្រាថ្នាតិចតួច បើសប្បាយក៏គួរប្រាថ្នា តែជីវិតនេះ លំបាកផង តិចផង តិចតួចផងប្រកប គឺចូលទៅទ្រទ្រង់នូវទុក្ខ ដោយសេចក្តីទុក្ខក្នុងវដ្ដ:ទាំងមូលនោះឯង គឺ

ត្រូវជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាស ញាំញី ។ បទថា **កោចមំ** កាត់បទជា **កោ ឥមំ** ។ បទថា **វេរំ** បានដល់ ពៀរ ៥ យ៉ាង មានបាណាតិបាតជាដើម ។ បទថា **កេនចិ** បានដល់ ដោយហេតុណាមួយ ។ បទថា **កយិរាថ** បានដល់ គប្បីធ្វើ ។ បទថា **បញ្ញាយ** បានដល់ ដោយវិបស្សនាបញ្ញា ។ បទថា **ធម្មស្ស** សេចក្ដីថា ព្រោះមិនឃើញសោតាបត្តិមគ្គ ។

ព្រះមហាសត្វ ត្រាស់ឧទានគាថាដដែលទៀត ដើម្បីប្រកាសនូវបំណងដែលទ្រង់មិនយាងត្រឡប់ទៅព្រះនគរដោយដាច់ខាត ។

សុនន្ទសារថីបានស្ដាប់ដូច្នោះ គិតថា ព្រះរាជកុមារនេះ លះបង់នូវសិរីរាជសម្បត្តិបែបនេះ ដូចបោលនូវសាកសព មិនទម្លាយនូវអធិដ្ឋានរបស់ខ្លួន ចូលទៅកាន់ព្រៃដោយបំណងថានឹងបួស អញត្រូវការអ្វីដោយជីវិតដែលមិនសមប្រកបនេះ អញក៏នឹងបួសជាមួយព្រះរាជកុមារនេះ គិតដូច្នេះហើយ ទើបពោលគាថាដូច្នេះថា

បពិត្រព្រះរាជបុត្ត ទូលព្រះបង្គំជាខ្ញុំ នឹងបួសក្នុងសម្នាក់ព្រះអង្គ
បពិត្រព្រះរាជបុត្តដ៏ចម្រើន សូមទ្រង់ត្រាស់ហៅទូលព្រះបង្គំជាខ្ញុំ
( ឲ្យបួសផង ) ទូលព្រះបង្គំជាខ្ញុំ ពេញចិត្តនឹងបព្វជ្ជាដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តវន្តិកេ** បានដល់ ក្នុងសម្នាក់របស់ទ្រង់ ។ បទថា **អវ្ហាយស្សុ** សេចក្ដីថា សូមទ្រង់ហៅខ្ញុំថា ចូរឯងមកបួសចុះ ។

នាយសារថីទូលអង្វរយ៉ាងនេះ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា បើអញឲ្យនាយសារថីបួសក្នុងកាលឥឡូវនេះ ព្រះបិតា និងព្រះមាតារបស់អញ ក៏មិនយាងមកក្នុងទីនេះ បើដូច្នេះ ការសោបសូន្យនឹងមានដល់លោកទាំងពីរ សេះ រថ និងគ្រឿងប្រដាប់ទាំងនេះ ក៏នឹងវិនាស សូម្បីពាក្យនិន្ទា ក៏កើតដល់អញថា សារថីនោះ ត្រូវព្រះរាជកុមារជាយក្ខស៊ីហើយ ទ្រង់ពិចារណាដើម្បីដោះនូវការនិន្ទារបស់ព្រះអង្គ និងពិចារណាដល់សេចក្តីចម្រើននៃព្រះជនក និងព្រះជននី កាលទ្រង់បង្ហាញសេះ រថ និងគ្រឿងប្រដាប់ ធ្វើឲ្យជាបំណុលដល់សារថីនោះ ទើបត្រាស់គាថានេះថា

នៃនាយសារថី អ្នកចូរប្រគល់នូវរថ ហើយជាអ្នកមិនមាន
បំណុល សឹមមកចុះ ព្រោះថា បព្វជ្ជា ( រមែងសម្រេច ) ដល់
បុគ្គលមិនមានបំណុល បព្វជ្ជាកម្មនេះ ពួកឥសីសរសើរហើយ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតំ** បានដល់ ធ្វើនូវបព្វជ្ជានោះ ។ បទថា **ឥសីភិ វណ្ណិតំ** សេចក្តីថា លោកអ្នកស្វែងរកគុណធំ មានព្រះពុទ្ធជាដើមសរសើរហើយ ។

នាយសារថីបានស្តាប់ដូច្នេះ គិតថា បើអញទៅកាន់នគរ បើព្រះរាជ-កុមារនេះគប្បីយាងទៅកាន់ទីដទៃ ព្រះរាជបិតាទ្រង់បានស្តាប់ដំណឹងនេះហើយយាងមក ត្រាស់ថា ចូរបង្ហាញកូនរបស់យើង មិនបានទតឃើញព្រះរាជ-កុមារនេះ ទ្រង់នឹងដាក់រាជទណ្ឌដល់អញ ព្រោះដូច្នោះ អញពោលគុណរបស់ខ្លួនដល់ព្រះរាជកុមារនេះ នឹងកាន់យកពាក្យប្តេជ្ញា កុំឲ្យទ្រង់យាងទៅទី

ដទៃ គិតដូច្នេះហើយ ទើបពោល ២ គាថាថា

សេចក្តីចម្រើនចូរមានដល់ទ្រង់ ពាក្យណា ដែលទ្រង់បានថ្លែងហើយ ទូលព្រះបង្គំជាខ្ញុំ នឹងធ្វើតាមពាក្យនោះ ទ្រង់ដែលទូលព្រះបង្គំជាខ្ញុំអង្វរហើយ គួរធ្វើតាមពាក្យរបស់ទូលព្រះបង្គំជាខ្ញុំនោះផង ។ សូមទ្រង់ស្តេចគង់នៅក្នុងទីនេះ ដរាបដល់ទូលព្រះបង្គំជាខ្ញុំ នាំព្រះរាជាមកដល់ ព្រះបិតារបស់ទ្រង់ ទតឃើញហើយ សមជាមានព្រះហឫទ័យ ត្រេកអររីករាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ** សេចក្តីថា សូមព្រះអង្គទ្រង់មានសេចក្តីចម្រើន ព្រះតម្រាស់ណាដែលទ្រង់ត្រាស់ហើយដល់ខ្ញុំ ខ្ញុំបានធ្វើតាមព្រះតម្រាស់នោះហើយ កាលខ្ញុំអង្វរហើយ គួរព្រះអង្គធ្វើតាមពាក្យនោះប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ ព្រះមហាសត្វក៏ត្រាស់ថា

នែនាយសារថី អ្នកនិយាយពាក្យណានឹងខ្ញុំៗ នឹងធ្វើតាមពាក្យរបស់អ្នកនោះ ឯខ្ញុំ មានបំណងដើម្បីជួបព្រះបិតារបស់ខ្ញុំ ដែលទ្រង់ស្តេចយាងមកក្នុងទីនេះដែរ ។ ម្នាលសម្លាញ់ អ្នកទៅហើយចូរមកវិញ ចូរត្រឡប់ទៅសិនចុះ អ្នកប្រាប់នូវសេចក្តីសុខ ដល់ញាតិទាំងឡាយ អ្នកដែលខ្ញុំប្រាប់ហើយ គប្បីក្រាបទូលនូវការថ្វាយបង្គំ ចំពោះព្រះមាតាបិតា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ករោមិ តេ តំ** សេចក្តីថា ខ្ញុំធ្វើតាមពាក្យនោះរបស់អ្នក ។ បទថា **ឯហិ សម្ម និវត្តស្សុ** សេចក្តីថា នែនាយសារថី

សម្លាញ់ ចូរអ្នកទៅក្នុងទីនោះ ចូរប្រញាប់ត្រឡប់ទៅអំពីទីនេះ ។ បទថា **វុត្តោ វជ្ជាសិ** សេចក្តីថា អ្នកជាបុគ្គលដែលខ្ញុំប្រើហើយ គប្បីក្រាបទូលការថ្វាយបង្គំរបស់ខ្ញុំថា តេមិយកុមារព្រះរាជបុត្ររបស់ព្រះអង្គ សូមថ្វាយបង្គំព្រះយុគលបាទរបស់ព្រះអង្គ ។

កាលត្រាស់ដូច្នេះហើយ ព្រះមហាសត្វបានបង្អោនព្រះកាយ ដូចដើមចេកមាស បែរព្រះភក្ត្រទៅកាន់នគរពារាណសី ថ្វាយបង្គំព្រះបិតា និងព្រះមាតាដោយបញ្ចង្គប្រតិស្ឋាន ហើយបានប្រទានរាជសាសន៍ដល់សារថី ។

សារថីទទួលបណ្តាំហើយ ធ្វើប្រទក្សិណព្រះរាជកុមារ ថ្វាយបង្គំទៀបព្រះយុគលបាទ ឡើងរថបរតម្រង់ទៅកាន់ក្រុងពារាណសី ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថិធម៌ឯណា ពុំទាន់ប្រាកដបទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ទ្រង់មានព្រះបន្ទូលដូច្នេះថា

> នាយសារថីចាប់ព្រះបាទា នៃព្រះមហាសត្វនោះ ហើយក៏ធ្វើ
> ប្រទក្សិណព្រះមហាសត្វនោះ រួចឡើងជិះរថ បរចូលទៅកាន់
> រាជទ្វារ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្ស** ជាដើម សេចក្តីថា ម្នាលភិក្ខុទាំងឡាយ នាយសារថីនោះចាប់ត្រង់ព្រះបាទទាំងគូ របស់ព្រះរាជកុមារនោះ ធ្វើនូវប្រទក្សិណ ហើយឡើងរថចូលទៅកាន់ទ្វារព្រះរាជវាំង ។

ក្នុងខណៈនោះ ព្រះនាងចន្ទាទេវីបើកបង្អួច ឃើញការមករបស់នាយ

សារថី ប្រាថ្នាចង់ដឹងថា ការប្រព្រឹត្តទៅរបស់កូនយើងដូចម្ដេចហ្ន៎ លុះទត ឃើញនាយសារថីត្រឡប់មកម្នាក់ឯង ព្រះហឫទ័យក៏ដូចជាបែកធ្លាយទៅ ព្រះនាងយំសោកហើយ ។ ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរ ដោយព្រះអស្សុ ទ្រង់ព្រះកន្សែង មៀងមើលទៅនាយសារថីនោះ ដែលមកវិញតែឯង ដោយគិតថា នាយសារថីនេះ សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ ។ កូនរបស់អញ ចម្រើនផែនដី នាយសារថី កប់ក្នុងផែនដីដោយពិត ពួកសត្រូវរមែងត្រេកអរដោយពិត ពួកជនមានពៀរ ត្រេកអរហើយដោយពិត ព្រោះឃើញនាយសារថី សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ ។ ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរ ដោយព្រះអស្សុ ទ្រង់ព្រះកន្សែង សួរទៅនាយសារថីនោះ ដែលមកវិញតែម្នាក់ឯងថា កូនរបស់ខ្ញុំនោះ ជាមនុស្សគបឬអ្វី ជាមនុស្សខ្វិនឬអ្វី កាលអ្នកកប់ក្នុងផែនដី ក្នុងកាលនោះ កូនរបស់ខ្ញុំពិលាបដែរឬ ម្នាលនាយសារថី អ្នកចូរប្រាប់នូវរឿងនោះដល់ខ្ញុំ ។ ( កូនរបស់ខ្ញុំនោះ ) ជាមនុស្សគ ជាមនុស្សខ្វិន កាលអ្នកកប់ក្នុងផែនដី បានកម្រើកដៃ និងជើងដូចម្ដេចដែរ ( ម្នាលនាយសារថី ) អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់រឿងនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មាតា** បានដល់ ព្រះជននីរបស់តេមិយ-កុមារពោធិសត្វ ។ បទថា **បថព្យា ភូមិវឌ្ឍនោ** សេចក្ដីថា កូនរបស់យើងត្រូវកប់ក្នុងផែនដីចម្រើនផែនដីដោយពិត ។ បទថា **ភោគន្តិ ធំ បរិបុច្ឆតិ** សេចក្ដីថា ព្រះនាងចន្ទាទេវីត្រាស់សាកសួរនាយសារថី ដែលជាអ្នកបញ្ឈប់រថក្នុងទិសមគ្គរ នាចំណែកម្ខាងហើយ ទើបឡើងប្រាសាទ ថ្វាយបង្គំព្រះនាងហើយឈរក្នុងទិសមគ្គរនាចំណែកម្ខាង ។ បទថា **កិន្នុ** សេចក្ដីថា កូនរបស់យើងគ ខ្វិនពិតឬ ។ បទថា **តទា** សេចក្ដីថា ក្នុងពេលដែលឯងកប់ក្នុងរណ្ដៅហើយ យកត្បូងចបវាយក្បាល ។ បទថា **និហញ្ញមានោ ភូមិយា** សេចក្ដីថា កាលឯងកប់ក្នុងផែនដី កូនយើងនិយាយអ្វីខ្លះ ។ បទថា **តំ មេ អក្ខាហិ** សេចក្ដីថា ចូរឯងប្រាប់រឿងទាំងអស់នោះកុំឲ្យឃ្លៀងឃ្លាតឡើយ ។ បទថា **វិវដ្ដយិ** សេចក្ដីថា កូនរបស់យើង គេកម្រើកដៃ និងជើង និយាយនឹងឯងថា ចៀសចេញទៅសារថី លោកកុំសម្លាប់ខ្ញុំ ដូច្នេះដែរឬទេ ។

លំដាប់នោះ នាយសុនន្ទសារថីក្រាបទូលព្រះនាងថា

បពិត្រព្រះនាងជាម្ចាស់ ( បើ ) ព្រះនាងឲ្យអភ័យដល់ទូលព្រះ
បង្គំជាខ្ញុំ ហេតុណា ដែលខ្ញុំបានឮហើយ ឬបានឃើញហើយ ក្នុង
សម្នាក់នៃព្រះរាជបុត្ត ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលនូវហេតុនោះ
ដល់ព្រះនាង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទជ្ជាសិ** សេចក្ដីថា បើព្រះនាងព្រះរាជ-ទាននូវអភ័យ ។ នាយសុនន្ទសារថីគិតថា បើអញក្រាបទូលថា ព្រះឱរស

របស់ព្រះនាងមិនគ មិនខ្វិន មិនថ្លង់ មានព្រះតម្រាស់ពីរោះ ជាធម្មតជិត ដូច្នេះ ព្រះរាជាគប្បីត្រិះរិះថា បើយ៉ាងនេះ ហេតុអ្វីទើបឯងមិននាំកូនអញមក គប្បីព្រះពិរោធ ដាក់អាជ្ញាដល់អញពិត អញត្រូវសូមព្រះរាជទានអភ័យជាមុន ទើបក្រាបទូលពាក្យនេះ ។

លំដាប់នោះ ព្រះនាងចន្ទាទេវីក៏ត្រាស់នឹងនាយសារថីនោះថា

ម្នាលសារថីសម្លាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ហេតុណា ដែលអ្នកបានឮហើយ ឬបានឃើញហើយ ក្នុងសម្នាក់នៃព្រះរាជបុត្ត អ្នកកុំភិតភ័យ ចូរប្រាប់នូវហេតុនោះចុះ ដូច្នេះ ។

បន្ទាប់អំពីនោះ នាយសារថីក៏ក្រាបទូលថា

ព្រះរាជបុត្តនោះ មិនមែនគទេ ព្រះរាជបុត្តនោះ មិនមែនខ្វិនទេ ឯព្រះរាជបុត្តនោះ មានព្រះបន្ទូលក្បោះក្បាយ បានឮថា ព្រះរាជ-បុត្តនោះ ទ្រង់ខ្លាចរាជ្យ ទើបបានជាធ្វើនូវពុតត្បុតច្រើនយ៉ាង ។ ព្រះរាជបុត្តនោះ ទ្រង់រឭកឃើញនូវជាតិមុន ជាជាតិដែលបានទ្រង់សោយរាជ្យ លុះសោយរាជ្យក្នុងទីនោះហើយ ធ្លាក់នរកគួរស្ញែង ។ ព្រះរាជបុត្តនោះ បានសោយរាជ្យក្នុងទីនោះ អស់ ២០ ឆ្នាំគត់ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ ។ ព្រះរាជបុត្តនោះ ទ្រង់ខ្លាចរាជ្យនោះហើយ ( ក៏តាំងព្រះរាជហឫទ័យថា ) ព្រះរាជ-មាតាបិតា កុំអភិសេកអញក្នុងរាជ្យ ព្រោះហេតុនោះ ទើបព្រះរាជបុត្ត មិនមានបន្ទូលក្នុងសម្នាក់នៃព្រះបិតា និងព្រះមាតា ក្នុង

កាលនោះ ។ ព្រះរាជបុត្តនោះ បរិបូណ៌ដោយអវយវៈតូចធំ មាន
កម្ពស់ និងទំហំ ( ដ៏សមសួន ) មានព្រះបន្ទូលដ៏ក្បោះក្បាយ
មានបញ្ញា ទ្រង់បិតនៅក្នុងផ្លូវសួគ៌ ។ បើព្រះនាងមានប្រាថ្នា
ដើម្បីឃើញព្រះរាជបុត្ត ជាកូនបង្កើតរបស់ព្រះនាង សូមព្រះនាង
យាងទៅចុះ តេមិយកុមារគង់នៅក្នុងទីណា ទូលព្រះបង្គំជាខ្ញុំ នឹង
នាំព្រះនាងឲ្យដល់ទីនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិសដ្ឋវចនោ** បានដល់ មានព្រះតម្រាស់បរិសុទ្ធ ។ បទថា **អកការ អាលយេ ពហូ** សេចក្តីថា បានធ្វើនូវការបោកបញ្ឆោតព្រះនាងជាច្រើន ។ បទថា **បញ្ញោ** បានដល់ មានបញ្ញា ។ បទថា **សចេ ត្វំ** សេចក្តីថា នាយសារថី ធ្វើព្រះរាជាឲ្យជាធុរៈ ក្រាបទូលយ៉ាងនេះ នឹងក្សត្រទាំងពីរអង្គនោះ ។ បទថា **យត្ថ សម្មតិ** សេចក្តីថា នាយសារថី ក្រាបទូលថា ព្រះឱរសរបស់ទ្រង់ សន្សំជាមួយទូលបង្គំជាប្រថាប់ក្នុងទីណា ទូលបង្គំ នឹងនាំទ្រង់ទៅក្នុងទីនោះ សូមទ្រង់ប្រញាប់ប្រញាល់ កុំបង្អែបង្អង់ឡើយ ។

ចំណែកតេមិយកុមារ កាលបញ្ជូននាយសារថីទៅហើយ ប្រាថ្នានឹងបួស កាលនោះ សក្កទេវរាជ ទ្រង់ជ្រាបព្រះហឫទ័យរបស់ព្រះរាជកុមារ ទើបត្រាស់បញ្ជាវិស្សកម្មទេវបុត្រថា នែវិស្សកម្ម តេមិយកុមារប្រាថ្នានឹងបួស ចូរអ្នកសាងនូវបណ្ណសាលា និងគ្រឿងបរិក្ខារនៃបព្វជិតដល់ព្រះរាជកុមារនោះ ។ វិស្សកម្មទេវបុត្រទទួលទេវបញ្ជាហើយ ចុះអំពីឋានសួគ៌ និម្មិតអាស្រមក្នុង

ដងព្រៃទំហំ ៣ យោជន៍ និម្មិតទីសម្រាកពេលយប់ និងពេលថ្ងៃ និងស្រះបោក្ខរណី ធ្វើទីនោះ ឲ្យសម្បូរដោយដើមឈើដែលមានផ្លែមិនចាំកាល និម្មិតទីចង្ក្រមប្រមាណ ២៤ ហត្ថ ក្នុងទីជិតបណ្ណសាលា រោយនូវខ្សាច់មានពណ៌ដូចកែវផលិកក្នុងទីចង្ក្រម និងនិម្មិតគ្រឿងបរិក្ខារសម្រាប់បព្វជិតគ្រប់យ៉ាង ហើយចារឹកអក្សរត្រង់ជញ្ជាំងថា កុលបុត្រណាម្នាក់ ប្រាថ្នានឹងបួស ក៏ចូរកាន់យកគ្រឿងបរិក្ខារសម្រាប់បព្វជិតទាំងនេះបួសចុះ ហើយឲ្យម្រឹគ និងបក្សីក្បែរអាស្រមគេចទៅ ហើយត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។

ខណៈនោះ មហាសត្វទតឃើញអាស្រមបទនោះ ទ្រង់អានអក្សរហើយទ្រង់ជ្រាបថា សក្កទេវរាជទ្រង់ប្រទានឲ្យ ទើបចូលបណ្ណសាលា ដោះព្រះភូសារបស់ព្រះអង្គ ស្លៀកសំពត់សម្បកឈើពណ៌ក្រហម ដណ្ដប់សំពត់នោះមួយផ្ទាំង ធ្វើស្បែកខ្លាធៀងស្មាម្ខាង ចងនូវមណ្ឌលជដា លើកដងរែកដាក់លើស្មា កាន់ឈើច្រត់ ចេញអំពីបណ្ណសាលា កាលឲ្យសិរីនៃបព្វជិតកើតឡើង ទើបយាងចង្ក្រមទៅមក ទ្រង់បន្លឺឧទានឡើងថា បព្វជ្ជាដែលអញបានហើយ ជាសុខ ជាសុខក្រៃលែងហ្ន៎ ហើយយាងចូលបណ្ណសាលា គង់លើគម្រាលដែលក្រាលដោយស្លឹកឈើ ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើត យាងចេញអំពីបណ្ណសាលាក្នុងពេលល្ងាច បេះស្លឹកតន្ត្រៀបក្ដាមដែលកើតត្រង់ចុងទីចង្ក្រម ស្ងោរស្រុសដោយភាជនៈដែលសក្កៈប្រទាន ដោយទឹកក្ដៅដែលមិនមានរសប្រៃ មិនមានរសជូរ មិនហឹរ សោយដូចបរិភោគអមតរស ចម្រើននូវព្រហ្មវិហារ ៤ សម្រេចឥរិយាបថក្នុងទីនោះ ។

ចំណែកព្រះបាទកាសិករាជ ទ្រង់ស្តាប់ពាក្យរបស់សុនន្ទសារថី ទើបត្រាស់ឲ្យហៅមហាសេនាគុត្ត ប្រញាប់ប្រញាល់ឲ្យធ្វើការត្រៀមដំណើរដោយព្រះតម្រាស់ថា

នាយសារថីទាំងឡាយ ចូរទឹមសេះក្នុងរថ អ្នកទាំងឡាយ ចូរចងជន្លន់នាដំរី ស័ង្ខ និងស្គរ ចូរលាន់សំឡេងឡើង ស្គរមានមុខតែម្ខាង ចូរលាន់សំឡេងឡើង ។ ស្គរដែលគេពាសល្អហើយ ចូរបន្លឺសំឡេង ស្គរមានសំឡេងពីរោះ ចូរលាន់សំឡេងឡើង ទាំងពួកអ្នកនិគម ចូរទៅតាមយើងចុះ យើងនឹងទៅឲ្យឱវាទ ដល់កូនរបស់យើង ។ ពួកស្រីស្នំ និងរាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទ ដល់កូនរបស់យើង ។ ពួកហ្មដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទ ដល់កូនរបស់យើង ។ អ្នកជនបទមកប្រជុំគ្នា ទាំងអ្នកនិគមក៏មកប្រជុំគ្នា ហើយចូរទឹមនូវយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទ ដល់កូនរបស់យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទីរយន្តុ** បានដល់ ចូរប្រគំ ។ បទថា **នទន្តុ** បានដល់ ចូរបន្លឺសំឡេង ។ បទថា **ឯកបោក្ខរា** បានដល់ ស្គរដែលមានស្បែកពាសតែម្ខាង ។ បទថា **សន្នទ្ធា** បានដល់ ពាសយ៉ាងល្អ ។ បទថា **វគ្គូ** បានដល់ មានសំឡេងពីរោះ ។ បទថា **គច្ឆំ** បានដល់ នឹងទៅ ។

បទថា **បុត្តនិវាទកោ** សេចក្តីថា យើងនឹងទៅប្រៀនប្រដៅ គឺឲ្យឱវាទដល់កូនប្រុស ព្រះបាទកាសិករាជត្រាស់យ៉ាងនេះ ដោយមានរាជបំណងថា យើងនឹងទៅដើម្បីទូន្មានតេមិយកុមារ ឲ្យកាន់យកពាក្យរបស់យើង ហើយអភិសេកក្នុងគំនររតនៈ ក្នុងទីនោះឯង ហើយនាំមក ។ បទថា **ធេគមា** បានដល់ ពួកជនមានទ្រព្យ ។ បទថា **សមាគតា** សេចក្តីថា ចូរប្រជុំគ្នាតាមយើងមក ។

នាយសារថីទាំងឡាយ ដែលព្រះរាជាត្រាស់យ៉ាងនេះហើយ ក៏ទឹមនូវសេះ ចតរថទុកត្រង់ទ្វារព្រះរាជវាំង ហើយក្រាបទូលឲ្យព្រះរាជាជ្រាប ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វិអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់បែងច្បាស់ លុះព្រះបានត្រាស់ហើយ ទ្រង់មានព្រះបន្ទូលដូច្នេះថា

ឯពួកនាយសារថី ( បាននាំយក ) នូវសេះសិន្ធពទាំងឡាយ
ជាពាហនៈ មានសម្ទុះដ៏លឿន ដែលទឹមហើយ ចូលមកកាន់
រាជទ្វារ ( ក្រាបបង្គំទូលថា ) បពិត្រព្រះសម្មតិទេព សេះទាំង
ឡាយនេះ ទូលព្រះបង្គំជាខ្ញុំបានទឹមរួចហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិន្ធវេ** បានដល់ សេះដែលកើតត្រង់កំពង់ឈ្មោះសិន្ធុ ។ បទថា **សីឃពាហនេ** សេចក្តីថា ដឹកសេះទាំងឡាយ ដែលដល់ព្រមដោយសម្ទុះ ។ បទថា **សារថី** ប្រែថា នាយសារថីទាំងឡាយ ។ បទថា **យុត្តេ** បានដល់ ទឹមត្រង់រថទាំងឡាយ ។ បទថា **ឧបាគញ្ចុំ** សេចក្តី

ថា នាយសារថីទាំងនោះ ដឹកសេះទាំងឡាយដែលទឹមទុកត្រង់រថទាំងឡាយមក កាលមកហើយ បានក្រាបទូលថា សេះទាំងពីរពួកនេះ ទឹមហើយ ។

បន្ទាប់អំពីនោះ ព្រះរាជាត្រាស់ថា

ពួកសេះធាត់ៗ រមែងសាបសូន្យចាកសម្បុះ ពួកសេះស្គមៗ រមែងសាបសូន្យចាកកម្លាំង អ្នកទាំងឡាយ ត្រូវវៀរបង់នូវពួកសេះស្គម និងសេះធាត់ចេញ ហើយទឹមតែពួកសេះ ដែលប្រកប ( ដោយវ័យ សម្បុរ សម្បុះ កម្លាំង ) វិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិសេ ថូលេ វិវជ្ជិត្វា** សេចក្ដីថា ពួកអ្នកកុំកាន់យកសេះស្គម និងសេះធាត់ ។ បទថា **សំសដ្ឋា យោជិតា ហយា** សេចក្ដីថា ទឹមនូវសេះដែលប្រកបដោយវ័យ ពណ៌សម្បុរ ការវាងវៃ និងកម្លាំង ។

លំដាប់នោះ ព្រះរាជាកាលយាងទៅកាន់សម្នាក់ព្រះរាជឱរស ទើបត្រាស់ឲ្យប្រជុំវណ្ណៈទាំង ៤ សេនាទាំង ១៨ និងពលនិកាយទាំងអស់ ប្រជុំគ្នា ៣ ថ្ងៃ ក្នុងថ្ងៃទី ៤ ព្រះបាទកាសិករាជ ក៏ចេញអំពីព្រះនគរ មួយអន្លើដោយសេនា ឲ្យយកទ្រព្យដែលល្អមយកទៅបានទៅផង ទ្រង់យាងដល់អាស្រមរបស់តេមិយរាជឥសី ទ្រង់ត្រេកអរនឹងព្រះរាជឥសី ដែលជាព្រះរាជឱរស ទ្រង់ធ្វើបដិសណ្ឋារៈហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ទ្រង់មានព្រះ

បន្ទូលដូច្នេះថា

លំដាប់នោះ ព្រះរាជា ទ្រង់ប្រញាប់ប្រញាល់ឡើងគង់រថ ដែលនាយសារថីទឹមហើយ ទ្រង់ត្រាស់ទៅនឹងស្ត្រីស្នំថា នាងទាំងអស់គ្នា ចូរទៅតាមយើងចុះ ។ នាងទាំងឡាយ ចូរប្រដាប់ដោយមាសទាំងឡាយ ហើយកាន់យកនូវផ្ចិត ម្កុដ ព្រះខ័ន ស្វេតច្ឆត្រ និងស្បែកជើង រួចឡើងជិះរថមក ។ បន្ទាប់ពីនោះមក ព្រះរាជា បានឲ្យនាយសារថីដើរមុខ ហើយទ្រង់ស្តេចយាងទៅ តេមិយកុមារនៅក្នុងទីណា ក៏យាងទៅក្នុងទីនោះ យ៉ាងឆាប់ ។

តេមិយៈ ទតឃើញព្រះបិតានោះ កំពុងស្តេចយាងមក ហាក់ដូចជារុងរឿងដោយតេជះ ដែលពួកអាមាត្យ អ្នកកាន់ព្រះខ័នហែរហមហើយ ទើបត្រាស់សួរព្រះបិតានោះថា បពិត្រព្រះបិតា ព្រះអង្គមានសេចក្តីសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះអង្គមិនមានព្រះអាពាធទេឬ រាជកញ្ញាទាំងអស់ ជាព្រះមាតារបស់ខ្ញុំមិនមានរោគទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

នែកូន ខ្ញុំសុខសប្បាយទេ នែកូន ខ្ញុំមិនមានជំងឺតម្កាត់ទេ រាជកញ្ញាទាំងអស់ ជាមាតារបស់អ្នក មិនមានរោគទេ ដូច្នេះ ។

លំដាប់នោះ ព្រះពោធិសត្វទូលសួរព្រះរាជាថា

បពិត្រព្រះបិតា ព្រះអង្គមិនសោយទឹកស្រវឹងទេឬ សុរាមិនពេញ

ព្រះហឫទ័យរបស់ព្រះអង្គទេឬ ព្រះហឫទ័យរបស់ព្រះអង្គ ត្រេកអរក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទានដែរឬ ដូច្នេះ ។

លំដាប់នោះ ព្រះរាជាត្រាស់តបថា

នែកូន ខ្ញុំមិនផឹកទឹកស្រវឹងទេ មួយទៀត សុរាមិនពេញចិត្តខ្ញុំទេ ឯចិត្តរបស់ខ្ញុំ តែងត្រេកអរក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទាន ដូច្នេះ ។

ព្រះមហាសត្វទូលសួរថា

យានរបស់ព្រះអង្គ មិនខូចទេឬ វាហនៈរបស់ព្រះអង្គ តែងប្រព្រឹត្តទៅបានដែរឬ ព្យាធិទាំងឡាយ ជាគ្រឿងដុតកម្តៅសរីរៈមិនមានដល់ព្រះអង្គទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

ឯយានរបស់ខ្ញុំឥតមានខូចទេ វាហនៈរបស់ខ្ញុំ ក៏ប្រព្រឹត្តទៅបានដោយស្រួល ព្យាធិទាំងឡាយជាគ្រឿងដុតកម្តៅសរីរៈ មិនមានដល់ខ្ញុំទេ ដូច្នេះ ។

ព្រះមហាសត្វទូលសួរថា

ជនបទនៅទីប្រទល់ដែន របស់ព្រះអង្គ ( ស្រុក និងនិគម ) របស់ព្រះអង្គទាំងមូល ដែលតាំងនៅកណ្តាលផែនដី ជាស្រុកសម្បូរដែរឬ ឃ្លាំង និងជង្រុក ព្រះអង្គបានតម្កល់ទុកស្រួលបួលទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

ជនបទនៅទីប្រទល់ដែន របស់ព្រះអង្គ ( ស្រុក និងនិគម ) របស់ព្រះអង្គទាំងមូល ដែលតាំងនៅកណ្ដាលផែនដី ជាស្រុកសម្បូរដែរឬ ឃ្លាំង និងជង្រុក ព្រះអង្គបានតម្កល់ ទុកស្រួលបួលទេឬ ដូច្នេះ ។

ព្រះមហាសត្វទូលសួរថា

បពិត្រមហារាជ ព្រះអង្គស្ដេចយាងមក ល្អហើយ មួយទៀត ព្រះអង្គស្ដេចមកមិនមែនអាក្រក់ទេ រាជបុរស ចូររៀបចំបល្ល័ង្ក ជាទីគង់របស់ព្រះរាជា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទាជី រថមារុយ្ហ** សេចក្ដីថា ជញ្ជូនស្បែកជើងឡើងរថ ព្រះរាជាត្រាស់ថា ពួកនាងចូរយកគ្រឿងរាជកកុធភណ្ឌ ៥ យ៉ាងទៅផង ដើម្បីអភិសេកកូនយើងក្នុងទីនោះឯង ដូច្នេះ ទើបត្រាស់បទទាំង ៣ នេះ ។ បទថា **សុវណ្ណាហិ អលង្កតា** ព្រះរាជាត្រាស់សំដៅយកទ្រនាប់ជើង ។ បទថា **ឧទាគញ្ឆិ** បានដល់ បានយាងចូលទៅហើយសួរថា ក្នុងពេលណា ឆ្លើយថា ក្នុងពេលដែលព្រះមហាសត្វទ្រង់ស្មោរស្លឹកតង្កៀបក្ដាម ពន្ទត់ភ្លើងហើយប្រថាប់គង់ ។ បទថា **ជលន្តមិវ តេជសា** បានដល់ រុងរឿងដោយតេជានុភាពនៃព្រះរាជា ។ បទថា **ខគ្គសំឃបរិព្យូឡ្ហំ** សេចក្ដីថា ចោមរោមទៅដោយពួកអមាត្យដែលមានផាសុក ដោយពោលពាក្យសម្ដី ។ បទថា **ឯតមព្រវិ** សេចក្ដីថា តេមិយឥសីទទួលព្រះបាទកាសិករាជ ដែលស្នាក់នៅក្នុងកងទ័ពខាងក្រៅ យាងមកបណ្ណសាលាដោយ

ព្រះបាទ ថ្វាយបង្គំព្រះអង្គហើយ ប្រថាប់គង់ បានត្រាស់ពាក្យនេះ ។

តេមិយរាជឥសី ត្រាស់សួរដល់ការមិនមានរោគប៉ុណ្ណោះ ដោយបទទាំង ពីរថា **កុសលំ អនាមយំ ។** បទថា **កច្ចិ អមជ្ជបោ តាត** សេចក្តីថា តេមិយរាជឥសី ទូលសួរព្រះបាទកាសិករាជថា ទ្រង់មិនជាអ្នកសោយទឹកចំណ្ណ ខ្លះទេឬ ។ បាឋៈថា **អប្បមជ្ជោ** ដូច្នេះក៏មាន សេចក្តីថា មិនប្រមាទក្នុង កុសលកម្មទាំងឡាយ ។ បទថា **សុរមប្បិយំ** សេចក្តីថា ការផឹកនូវសុរា មិនជាទីស្រឡាញ់របស់ព្រះអង្គ ។ បាឋៈថា **សុរមប្បិយា** ដូច្នេះក៏មាន សេចក្តី ថា សុរាមិនជាទីស្រឡាញ់របស់ព្រះអង្គទេឬ ។ បទថា **ធម្មេ** បានដល់ ទសពិធរាជធម៌ ។ បទថា **យោគ្គំ** សេចក្តីថា ពាហនៈ មានសេះ និងគោ ជាដើម គួរទឹមក្នុងយានទាំងឡាយ ។ បទថា **កច្ចិ វហាតិ** សេចក្តីថា មិន មានរោគ នាំទៅបានដែរឬ ។ បទថា **វាហនំ** បានដល់ ពាហនៈទាំងអស់ មានដំរីជាដើម ។ បទថា **សរីរស្សុបតាបិយា** បានដល់ ចូលទៅដុតរោល សរីរៈ ។ បទថា **អន្តា** បានដល់ បច្ចន្តជនបទ ។ បទថា **ជីតា** បានដល់ ស្តុកស្តម្ភ មានកិច្ចការកបានងាយ នៅជាមួយគ្នាយ៉ាងកុះករ ។ បទថា **មជ្ឈេ** ច បានដល់ កណ្តាលរដ្ឋ ។ បទថា **ពហាលា** សេចក្តីថា អ្នកគាម និងអ្នក និគម នៅជាមួយគ្នាជាពួក ជាក្រុម ។ បទថា **បដិសណ្ឋិតំ** សេចក្តីថា បិទ បាំងហើយ គឺគ្រប់គ្រងល្អ ឬសម្បូរ ។ បទថា **និសក្កតិ** សេចក្តីថា ព្រះ មហាសត្វត្រាស់ថា ចូររៀបចំបល្ល័ង្ក ដែលជាទីព្រះរាជាប្រថាប់គង់ ព្រះរាជា មិនប្រថាប់គង់លើព្រះបល្ល័ង្ក ដោយសេចក្តីគោរពក្នុងព្រះមហាសត្វ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា បើព្រះរាជាមិនប្រថាប់គង់លើបល្ល័ង្ក ចូរអ្នកទាំងឡាយ ក្រាលកម្រាលស្លឹកឈើ ថ្វាយទ្រង់ចុះ កាលអញ្ជើញព្រះរាជាឲ្យប្រថាប់គង់លើកម្រាលដែលក្រាលហើយនោះ ទើបត្រាស់គាថាដូច្នេះថា

ព្រះអង្គគង់លើកម្រាលស្លឹកឈើ ដែលគេតែងតាំងហើយ សូមព្រះអង្គយកទឹកអំពីទីនេះ លាងព្រះបាទារបស់ព្រះអង្គចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និយតេ** បានដល់ រៀបចំយ៉ាងល្អ ព្រះមហាសត្វ បង្ហាញទឹកសម្រាប់បរិភោគដោយបទថា **ឯតេ្ដា** ។

ដោយការគោរពចំពោះមហាសត្វ ព្រះរាជាមិនប្រថាប់គង់លើកម្រាលស្លឹកឈើឡើយ ប្រថាប់គង់ត្រង់ផែនដី ព្រះមហាសត្វយាងចូលកាន់បណ្ណសាលា នាំយកស្លឹកតង្កៀបក្ដាមនោះចេញមក យាងព្រះរាជាឲ្យទ្រង់សោយ ទើបត្រាស់គាថាដូច្នេះថា

បពិត្រព្រះរាជា ស្លឹកនេះ ដែលអាត្មាភាពចម្អិនហើយ ជារបស់មិនមានរសប្រៃ បពិត្រមហារាជ សូមព្រះអង្គស្ដេចសោយចុះ ព្រះអង្គទើបស្ដេចយាងមកដល់ ទុកជាភ្ញៀវរបស់អាត្មាភាព ដូច្នេះ ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងមហាសត្វថា

ខ្ញុំមិនបរិភោគស្លឹកនេះទេ ព្រោះស្លឹកឈើនេះ មិនមែនជាភោជនរបស់ខ្ញុំ ខ្ញុំបរិភោគតែបាយនៃស្រូវសាលី ដែលលាយដោយ

សាច់ដ៏ស្អាត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆចាហំ** ជាដើម ជាពាក្យដែលព្រះរាជាត្រាស់ហាម ។

កាលទ្រង់ត្រាស់ឃាត់ហើយ ព្រះរាជាទ្រង់សរសើរភោជនរបស់ព្រះអង្គ ទ្រង់ក៏ច្បិចយកស្ទឹកតង្កៀបក្តាមបន្តិចដាក់លើបាតដៃ ដោយទ្រង់គោរពក្នុងព្រះមហាសត្វ ហើយត្រាស់សួរថា នែបា បាសោយភោជនយ៉ាងនេះឬ មហាសត្វទទួលថា បពិត្រព្រះអង្គ ពិតហើយ ព្រះរាជាប្រថាប់គន់ត្រាស់វាចាជាទីស្រឡាញ់ ជាមួយព្រះឱរស ។

ខណៈនោះ ព្រះនាងចន្ទាទេវី ចោមរោមដោយពួកស្រីស្នំយាងមក ទ្រង់ចាប់ព្រះបាទទាំងពីររបស់ព្រះឱរសជាទីស្រឡាញ់ ព្រះនាងថ្ងាយបង្គំហើយ ព្រះកន្សែង មានព្រះនេត្រទាំងពីរពេញដោយអស្សុជល ប្រថាប់គន់ក្នុងទីសមគួរមួយកន្លែង ។ លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះនាងថា នែនាង ចូរនាងមើលភោជនាហារកូនរបស់នាង ហើយទ្រង់ចាប់យកនូវស្ទឹកតង្កៀបក្តាមបន្តិច ដាក់ក្នុងព្រះហស្តរបស់ព្រះនាង ហើយប្រទានដល់ស្រីស្នំដទៃៗ ម្នាក់បន្តិចៗ ស្រីស្នំទាំងនោះពោលថា ទ្រង់សោយភោជនបែបនេះឬ ហើយយកនូវស្ទឹកតង្កៀបក្តាមនោះ មកដាក់លើក្បាលរៀងៗ ខ្លួន ហើយពោលថា ព្រះរាជកុមារ ធ្វើនូវវត្ថុដែលគេធ្វើបានដោយលំបាកក្រៃលែង ហើយនមស្ការ លំដាប់នោះ ព្រះរាជាត្រាស់នឹងមហាសត្វថា កូនជាទីស្រឡាញ់ រឿងនេះ ប្រាកដជាអស្ចារ្យដល់ឪពុក ហើយត្រាស់គាថាយ៉ាងនេះថា

សេចក្ដីអស្ចារ្យកើតប្រាកដដល់ខ្ញុំ ព្រោះឃើញ ( លោក ) នៅស្ងាត់តែម្នាក់ឯង កាលលោកបរិភោគភោជនបែបនេះ សម្បុរនៅតែស្រស់ថ្លា ដោយហេតុដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកកំ** សេចក្ដីថា កូនជាស្រឡាញ់ ការអស្ចារ្យប្រាកដដល់ឪពុក ព្រោះបានឃើញកូនក្នុងទីស្ងាត់តែម្នាក់ឯង ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភោជននេះ ។ បទថា **ឯធិសំ** សេចក្ដីថា ព្រះរាជាត្រាស់សួរព្រះមហាសត្វថា អ្នកបរិភោគភោជនមិនមានរសប្រៃ មិនជូរ មិនមានផ្សំរស ផ្សំទឹកបែបនេះ ហេតុអ្វីទើបមានពណ៌សម្បុរផូរផង់ ។

លំដាប់នោះ ព្រះមហាសត្វកាលក្រាបទូលដល់ព្រះរាជា ទើបត្រាស់ថា បពិត្រព្រះរាជា អាត្មាភាពម្នាក់ឯង សិងលើកម្រាលស្លឹក ដែលតាំងទុកហើយ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាពស្រស់ថ្លា ដោយដំណេកម្នាក់ឯងនោះ ។ ពួកអ្នករក្សាព្រះរាជា ដែលសៀតព្រះខ័ន មិនប្រាកដដល់អាត្មាភាពទេ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាព ថ្លាស្រស់ដោយដំណេកម្នាក់ឯងនោះ ។ អាត្មាភាព មិនតាមសោកនឹងអារម្មណ៍ដែលកន្លងហើយ មិនប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលលើកឡើងចំពោះមុខ ហេតុនោះ បានជាវណ្ណៈរបស់អាត្មាភាព រមែងថ្លាស្រស់ ។ ជនពាលទាំងឡាយ តែងរីងស្ងួត ព្រោះសេចក្ដីប្រាថ្នាអារម្មណ៍ដែលមិនទាន់មកដល់ ព្រោះ

សេចក្ដីតាមសោកស្ដាយអារម្មណ៍ ដែលកន្លងទៅហើយនេះ ដូច ជាដើមបបុសមានសម្បុរខៀវ ដែលគេដកហាលថ្ងៃដូច្នោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆេត្តំ សពន្ធា** បានដល់ អ្នកសៀតព្រះខ័ន ។ បទថា **រាជរក្ខា** បានដល់ កងរក្សាព្រះរាជា ។ បទថា **ឆប្បជប្បាមិ** បានដល់ មិនត្រូវការ ។ បទថា **ហរិតោ** បានដល់ មានពណ៌ខៀវស្រស់ ។ បទថា **លុតោ** សេចក្ដីថា ហាក់បីដូចដើមបបុស ដែលដកហាលថ្ងៃ ។

លំដាប់នោះ ព្រះរាជាមានព្រះតម្រិះថា យើងនឹងអភិសេកកូនរបស់យើងក្នុងទីនេះឯង ហើយនាំត្រឡប់ទៅព្រះនគរ កាលយាងព្រះមហាសត្វឲ្យគ្រងរាជសម្បត្តិ ទើបត្រាស់ថា

នែកូន ខ្ញុំនឹងឲ្យនូវពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកជនពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ មួយទៀត ខ្ញុំឲ្យនូវស្រីស្នំ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន ចូរអ្នកគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ អ្នកជាព្រះរាជារបស់យើង ។ ស្ត្រីរបាំជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង បានសិក្សា ( ក្នុងកិច្ចស្ត្រី ) ញុំាងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។ ខ្ញុំនឹងនាំយករាជកញ្ញាដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃដល់អ្នក អ្នកចូរញុំាងកូនទាំងឡាយ ឲ្យកើតក្នុងស្ត្រីទាំងនោះហើយ សឹមបួសក្នុងកាលជាខាងក្រោយ ។ អ្នកនៅក្មេងកំលោះ ប្រកបដោយបឋម-

វ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យ សេចក្ដីចម្រើននឹង
មានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហត្ថានីកំ** សេចក្ដីថា ហ្វូងដំរីធំ ចាប់ពី ១០ ដំរីឡើងទៅ ឈ្មោះថា ពលដំរី ឯពលរថក៏យ៉ាងនោះ ។ បទថា **ចម្មិនោ** បានដល់ កងទាហានមិនខ្លាចស្លាប់ ពាក់ជោយក្រោះ ។ បទថា **កុសលា** បានដល់ ជាអ្នកឈ្លាស ។ បទថា **សិក្ខិតា** សេចក្ដីថា ជាអ្នកបានទទួលការសិក្សាល្អក្នុងកិច្ចរបស់ស្រីដទៃៗ ។ បទថា **ចាតុរិត្ថិយោ** បានដល់ ស្រីស្អាត មានមន្ទស្នេហ៍ ៤ នាក់ ម្យ៉ាងទៀត ស្រីអ្នកក្រុង ៤ នាក់ ម្យ៉ាងទៀត ស្រីអ្នករបាំ ៤ នាក់ ។ បទថា **បដិបាទ្ទូហិ តេ កញ្ញា** សេចក្ដីថា នៃកូន ឪពុកនឹងនាំរាជកញ្ញាដទៃៗ អំពីព្រះរាជាដទៃមកឲ្យកូន ។ បទថា **យុវា** បានដល់ ដល់នូវភាពជាកំលោះ ។ បទថា **ទហរោ** បានដល់ កំលោះ ។ បទថា **បឋមុប្បត្តិតោ** សេចក្ដីថា កើតឡើង គឺផ្ដើមដោយបឋមវ័យ ។ បទថា **សុសូ** សេចក្ដីថា នៅកំលោះ មានសក់ខ្មៅស្រិល ។

តាំងអំពីនេះទៅ ជាធម្មកថារបស់ព្រះមហាសត្វ ដែលសម្ដែងធម្មកថាថ្វាយព្រះរាជាដូច្នេះថា

បុគ្គលនៅកំលោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្ត
ព្រហ្មចរិយធម៌ គប្បីជាកំលោះ ព្រោះថា បព្វជ្ជារបស់បុគ្គលនៅ
កំលោះនេះ ពួកឥសីទាំងឡាយសរសើរហើយ ។ បុគ្គលនៅ
កំលោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្ម-

ចរិយធម៌ គប្បីនៅកំលោះ អាត្មាភាពនឹងប្រព្រឹត្តព្រហ្មចរិយធម៌ អាត្មាភាពមិនត្រូវការដោយរាជ្យទេ ។ បពិត្រព្រះមាតា និងបិតា អាត្មាភាពឃើញនរជននៅក្មេង ទើបនឹងចេះនិយាយ ជាកូនជាទីស្រឡាញ់ ដែលមាតាបិតាបានដោយលំបាក មិនទាន់ចាស់គ្រាំគ្រា ហើយស្លាប់ ។ អាត្មាភាពឃើញនាងកុមារី មានសម្បុរដូចមាស ដែលមច្ចុរាជចាប់ដកក្សយជីវិតហើយ ដូចជាដកនូវទំពាំងឫស្សីដ៏ខ្ចី ។ នរជនទាំងឡាយ ឬនាងនារីទាំងឡាយ សូម្បីនៅក្មេង ក៏តែងស្លាប់ តើសត្វណា គប្បីទុកចិត្តក្នុងជីវិតនោះថា អាត្មាអញនៅក្មេង ដូច្នេះ ។ អាយុនៃកុមារណា មានប្រមាណតិច ដោយការកន្លងទៅនៃយប់ និងថ្ងៃ ភាពនៃខ្លួនជាកុមារក្នុងវ័យនោះ នឹងធ្វើដូចម្តេចកើត ដូចទីមានទឹកតិចរបស់ត្រីទាំងឡាយ ។ សត្វលោក ត្រូវសត្រូវបៀតបៀនជានិច្ចផង ត្រូវសត្រូវរួបរឹតជានិច្ចផង កាលយប់ និងថ្ងៃទាំងឡាយ មិនកន្លងទៅទទេទេ តើព្រះអង្គនឹងអភិសេកអាត្មាភាព ក្នុងរាជ្យដូចម្តេច ដូច្នេះ ។

ព្រះរាជាត្រាស់សួរថា

សត្វលោកនេះ ត្រូវសត្រូវអ្វីបៀតបៀនផង ត្រូវសត្រូវអ្វីរួបរឹតផង ចម្មជាតដូចម្តេចមិនកន្លងទៅទទេ ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវដំណើរនោះ ដូច្នេះ ។

ព្រះមហាសត្វត្រាស់ថា

សត្វលោក ត្រូវមច្ចុបៀតបៀនផង ត្រូវជរារួបរឹតផង រាត្រីទាំងឡាយ រមែងកន្លងទៅមិនទទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។ កាលតម្បាញ ដែលបុគ្គលត្បាញរបស់ណាៗ ដែលបុគ្គលនឹងត្បាញ របស់ដែលត្រូវត្បាញ ( នោះៗ ) ជារបស់នៅសល់តិច យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញ កាលហូរទៅ មិនត្រឡប់ថយក្រោយវិញ យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ កាលកន្លងទៅ មិនត្រឡប់វិញ យ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញគប្បីបន្សាត់ទៅ នូវដើមឈើទាំងឡាយ ដែលដុះក្បែរច្រាំង យ៉ាងណាមិញ សត្វទាំងអស់ ត្រូវជរា និងមរណៈបន្សាត់ទៅ ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្រហ្មចារី យុវា សិយា** សេចក្ដីថា អ្នកប្រព្រឹត្តព្រហ្មចរិយៈ គួរជាបុគ្គលនៅកំលោះនោះឯង ។ បទថា **ឥសីភិ វណ្ណិតំ** សេចក្ដីថា អ្នកស្វែងរកគុណទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ គឺលើកតម្កើងហើយ ។ បទថា **រជ្ជេនមត្ថិកោ** សេចក្ដីថា អាត្មាមិនត្រូវការរាជសម្បត្តិ ។ បទថា **អម្មតាត វទន្តំ** បានដល់ ដែលនរៈហៅថា ម៉ែពុក ។ បទថា **បលុត្តំ** សេចក្ដីថា ត្រូវសេចក្ដីស្លាប់ដកឡើងដោយខានមិនបាន ។ បទថា **យស្ស រត្យា វិវសានេ** សេចក្ដីថា មហាបពិត្រ តាំងអំពីកាលដែលកុមារបដិសន្ធិក្នុងគភ៌មាតា អាយុក៏តិចចុះរឿយៗ ព្រោះយប់ និង

ថ្ងៃកន្លងទៅ ។ បទថា **កោមារិកំ តហឹ** សេចក្តីថា ក្នុងវ័យនោះ ភាពជាកំលោះ នឹងធ្វើអ្វីបាន ។ បទថា **កេនមត្ថាហតោ** សេចក្តីថា លោកនេះត្រូវអ្វីគ្របសង្កត់ ព្រះរាជាទ្រង់មិនជ្រាបអត្ថរបស់ពាក្យដែលពោលសង្ខេប ទើបត្រាស់សេចក្តីនេះ ។ បទថា **រត្យោ** បានដល់ រាត្រីទាំងឡាយ មហាបពិត្រ រាត្រីទាំងឡាយ រមែងធ្វើអាយុ វណ្ណៈ និងពលរបស់សត្វទាំងនេះឲ្យអស់ទៅ ប្រព្រឹត្តទៅ ដូច្នោះ គប្បីជ្រាបថា វត្ថុដែលមិនជាប្រយោជន៍ប្រព្រឹត្តទៅ ។ បទថា **យំ យទេវោបវុយ្ហតិ** សេចក្តីថា ក្នុងសំពត់ដែលកំពុងត្បាញ កាលធ្វើចំណែកដែលសល់ ដែលគប្បីត្រូវត្បាញនោះឲ្យពេញរមែងសល់តិច យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏ដូច្នោះ ។ បទថា **ន បរិវត្តតិ** សេចក្តីថា ទឹកដែលហូរទៅរឿយៗ ក្នុងខណៈនោះ រមែងមិនហូរទៅកាន់ទីខ្ពស់ ។ បទថា **វហេ រុក្ខេ បក្កូលជេ** សេចក្តីថា គប្បីក្ជួចដើមឈើទាំងឡាយ ដែលកើតត្រង់ច្រាំងទៅ ។

ព្រះរាជា ទ្រង់ស្តាប់ធម្មកថារបស់ព្រះមហាសត្វហើយ ទ្រង់មិនជាប់ជំពាក់ដោយការគ្រប់គ្រងផ្ទះ មានព្រះរាជបំណងនឹងបួស ត្រាស់ថា អញនឹងមិនទៅកាន់ព្រះនគរវិញឡើយ នឹងបួសក្នុងទីនេះឯង បើកូនរបស់អញទៅព្រះនគរ អញនឹងឲ្យស្វេតច្ឆត្រ ដូច្នេះ ដើម្បីទ្រង់សាកល្បងព្រះមហាសត្វ ទើបយាងដោយរាជសម្បត្តិទៀតថា

នែកូន ខ្ញុំនឹងឲ្យពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកពលពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរ

ដល់អ្នក ។ មួយទៀត យើងនឹងឲ្យស្ត្រីស្នំ ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន អ្នកចូរគ្រប់គ្រង ពួកស្ត្រីទាំងនោះចុះ ។ អ្នកនឹងជារាជារបស់យើង ស្ត្រីរបាំជាអ្នក ឈ្លាសក្នុងការរាំ និងច្រៀង សិក្សា ( ក្នុងកិច្ចរបស់ស្ត្រី ) នឹង ញុំាងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។ យើងនឹងនាំ យកនូវរាជកញ្ញា ដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជា ដទៃដល់អ្នក អ្នកញុំាងកូនទាំងឡាយ ឲ្យកើតក្នុងពួកនាងកញ្ញា ទាំងនោះហើយ សឹមបួសក្នុងកាលជាខាងក្រោយចុះ ។ អ្នកនៅ ក្មេងកំលោះ ប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរ សោយរាជ្យចុះ សេចក្តីចម្រើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុង ព្រៃ ។ នែកូន ខ្ញុំនឹងឲ្យឃ្លាំង ជង្រុក វាហនៈ ពល និងនិវេស-នដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ អ្នកដែលក្រុមនៃរាជ-កញ្ញា មានចំណែកដ៏ល្អចោមរោមហើយ មានពួកនៃខ្ញុំស្ត្រីហែហម ហើយ ចូរសោយរាជ្យចុះ សេចក្តីចម្រើននឹងមានដល់អ្នក អ្នកនឹង ធ្វើអ្វីក្នុងព្រៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គោមណ្ឌលបរិព្យូឡ្ហោ** សេចក្តីថា មាន ពួករាជកញ្ញាស្រស់ស្អាតចោមរោមជារង្វង់ ។

លំដាប់នោះ ព្រះមហាសត្វ កាលប្រកាសភាពដែលព្រះអង្គមិនត្រូវ ការរាជសម្បត្តិ ទើបត្រាស់ថា

ប្រយោជន៍អ្វី ដោយទ្រព្យដល់អាត្មាភាព ព្រោះទ្រព្យ តែងអស់ទៅ ប្រយោជន៍អ្វី ដោយភរិយា ព្រោះភរិយាក៏គង់ស្លាប់ ប្រយោជន៍អ្វី ដោយវ័យដែលគ្រាំគ្រា ជាវ័យត្រូវជរាគ្របសង្កត់ហើយ ។ ក្នុងលោកសន្និវាសនេះ នៅមានសេចក្ដីត្រេកអរអ្វី ការលេងសើចអ្វី ការរីករាយអ្វី ការស្វែងរកទ្រព្យអ្វី អាត្មាភាពត្រូវការអ្វី ដោយកូន និងប្រពន្ធ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះចាកចំណងហើយ ។ អាត្មាភាពដឹងច្បាស់យ៉ាងនេះថា មច្ចុមិនធ្វេសប្រហែសចំពោះអញឡើយ អាត្មាភាពនោះ ត្រូវសេចក្ដីស្លាប់គ្របសង្កត់ហើយ នៅមានសេចក្ដីត្រេកអរដូចម្ដេច ការស្វែងរកទ្រព្យដូចម្ដេចទៀត ។ ផ្លែឈើទុំទាំងឡាយ តែងមានភ័យអំពីការជ្រុះជានិច្ច យ៉ាងណាមិញ សត្វទាំងឡាយ កើតមកហើយ តែងមានភ័យអំពីសេចក្ដីស្លាប់ជានិច្ច យ៉ាងនោះដែរ ។ ជនជាច្រើនពួកខ្លះ ដែលគេឃើញក្នុងវេលាព្រឹក តែគេមិនឃើញក្នុងវេលាល្ងាច ជនជាច្រើនពួកខ្លះ ដែលគេឃើញក្នុងវេលាល្ងាច តែគេមិនឃើញក្នុងវេលាព្រឹក ។ សេចក្ដីព្យាយាមក្នុងកុសល គេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណា គប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក ដ្បិតការបណ្ដោះបណ្ដែអំពីសេចក្ដីស្លាប់ ដែលមានសេនាច្រើននោះ មិនមានដល់យើងទេ ។ ពួកចោរទាំងឡាយ តែងប្រាថ្នាទ្រព្យ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះហើយ អំពីចំណង បពិត្រ

ព្រះរាជា សូមព្រះអង្គមក សូមព្រះអង្គត្រឡប់ព្រះហឫទ័យ ទៅវិញចុះ អាត្មាភាពមិនត្រូវការដោយរាជ្យទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទិយេជ** សេចក្ដីថា មហាបពិត្រ ទ្រង់និមន្តអាត្មាភាពព្រោះទ្រព្យធ្វើអ្វី ទ្រព្យអស់ទៅ លះបង់នូវបុគ្គលក៏មាន បុគ្គលរមែងលះបង់នូវទ្រព្យទៅក៏មាន វត្ថុទាំងពួង រមែងដល់នូវការអស់ទៅទាំងអស់ ព្រះអង្គទ្រង់និមន្តអាត្មាដោយទ្រព្យធ្វើអ្វី ។ បទថា **កឹ ករិយាយ មរិស្សតិ** សេចក្ដីថា កាលអាត្មាភាពកំពុងតាំងនៅ ករិយាក៏នឹងស្លាប់ កាលករិយានោះកំពុងតាំងនៅ អាត្មាភាពក៏នឹងស្លាប់ ទ្រង់នឹងធ្វើអ្វីដោយករិយានោះ ។ បទថា **ជិណ្ណោន** សេចក្ដីថា ដែលជរាចោមរោមគ្របសង្កត់ ។ បទថា **តត្ថ** សេចក្ដីថា ក្នុងលោកសន្និវាសដែលមានជរា និងមរណៈជាធម្មតា ។ បទថា **កា នន្ទិ** សេចក្ដីថា នឹងត្រេកអរធ្វើអ្វី ។ បទថា **កា ខិឌ្ឌា** សេចក្ដីថា នឹងលេងធ្វើអ្វី ។ បទថា **កា រតិ** សេចក្ដីថា នឹងត្រេកអរក្នុងកាមតណ្ហាធ្វើអ្វី ។ បទថា **ពន្ធនា** សេចក្ដីថា ព្រោះសង្កត់បានដោយឈាន ព្រះមហាសត្វកាលត្រាស់យ៉ាងនេះថា មហាបពិត្រ អាត្មាជាអ្នកផុតហើយចាកចំណង គឺកាមឬចាកគ្រឿងចង គឺតណ្ហា ។ បទថា **មច្ចុ មេ** សេចក្ដីថា មច្ចុរាជមិនប្រមាទក្នុងយើង ។ បទថា **នប្បមជ្ជសិ** សេចក្ដីថា ជាបុគ្គលមិនប្រមាទដើម្បីនឹងសម្លាប់អាត្មាជានិច្ចឡើយ ។ បទថា **យោហំ** សេចក្ដីថា អាត្មាជ្រាបយ៉ាងនេះ ។ បទថា **អន្តកេនាធិបន្នស្ស** សេចក្ដីថា កាលអាត្មាត្រូវសេចក្ដីស្លាប់គ្របសង្កត់ គឺឈានចុះហើយ នឹងត្រេកអរស្វែងរកទ្រព្យធ្វើអ្វី ។ បទថា **និច្ចំ**

សេចក្តីថា ភ័យអំពីមរណៈ រមែងកើតឡើងក្នុងកាលទាំងពួង ចាប់តាំងអំពីកាលដែលជាកលលៈ ។ បទថា **អាតប្បំ** បានដល់ សេចក្តីព្យាយាមក្នុងកុសលកម្ម ។ បទថា **កិច្ចំ** បានដល់ គប្បីធ្វើ ។ បទថា **កោ ជញ្ញា មរណំ សុវេ** សេចក្តីថា អ្នកណាដឹងថា នឹងស្លាប់ក្នុងថ្ងៃស្អែកនេះ ឬខានស្អែកនេះ ។ បទថា **សង្គរំ** បានដល់ កំណត់ ។ បទថា **មហាសេនេន** សេចក្តីថា អ្នកមានសេនាច្រើន មានមហាភ័យ ២៥ កម្មករណៈ ៣២ និងរោគ ៩៦ ជាដើម ។ បទថា **ចោរា ធនស្ស បត្ថេន្តិ** សេចក្តីថា ចោរទាំងឡាយកាលលះបង់ជីវិតដើម្បីទ្រព្យ ឈ្មោះថា ប្រាថ្នាទ្រព្យ ។ បទថា **រាជ មុញ្ចាមិ** សេចក្តីថា មហាបពិត្រ អាត្មាផុតហើយចាកចំណង ពោល គឺសេចក្តីប្រាថ្នាទ្រព្យ អាត្មាមិនត្រូវការទ្រព្យ ។ បទថា **និវត្តស្សុ** សេចក្តីថា សូមមហាបពិត្រទ្រង់បែរព្រះហឫទ័យតាមពាក្យរបស់អាត្មា សូមមហាបពិត្រលះរាជសម្បត្តិ ទ្រង់ផ្នួស ធ្វើនេក្ខម្មគុណឲ្យជាទីពឹង មិនល្អឬ ម្យ៉ាងទៀត មហាបពិត្រកុំមានព្រះរាជតម្រិះដល់រឿង ដែលមហាបពិត្រមានព្រះរាជតម្រិះនោះថា នឹងឲ្យកូនរបស់យើងតាំងនៅក្នុងរាជសម្បត្តិ អាត្មាមិនត្រូវការរាជសម្បត្តិទេ ។

ព្រះធម្មទេសនារបស់ព្រះមហាសត្វ ឈ្មោះថា យថានុសន្ធិ ចប់ដោយប្រការដូច្នេះ ។

ស្រីស្នំ ១៦០០០ នាក់ និងមហាជន មានពួកអមាត្យជាដើម រាប់តាំងអំពីព្រះរាជា និងព្រះនាងចន្ទាទេវីជាដើម បានស្តាប់ព្រះធម្មទេសនារបស់ព្រះមហាសត្វនោះហើយ មានបំណងនឹងបព្វជ្ជាក្នុងពេលនោះ កាលនោះ ព្រះរាជា

ឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា ជនណាមួយប្រាថ្នាបួសក្នុងសម្នាក់របស់កូនយើង ជននោះៗ ចូរបួសចុះ និងត្រាស់ឲ្យបើកទ្វារឃ្លាំងមាសជាដើម ហើយឲ្យចារឹកបន្ទះមាសទុកត្រង់សសរប្រាសាទថា ឆ្នាំងកំណាប់ទ្រព្យធំ មានក្នុងទីនោះផង ក្នុងទីនោះផង អ្នកដែលត្រូវការ ចូរកាន់យកចុះ ចំណែកអ្នកនគរទាំងឡាយ លះចោលរានផ្សារដែលលក់ដូរ និងលះបង់នូវផ្ទះដែលបើកទ្វារ ទៅកាន់សម្នាក់ព្រះរាជាៗ ទ្រង់បួសក្នុងសម្នាក់ព្រះមហាសត្វ មួយអន្លើដោយមហាជន អាស្រមដ្ឋាន ៣ យោជន៍ ដែលសក្កទេវរាជទ្រង់ថ្វាយ បានពេញទាំងអស់ ព្រះមហាសត្វទ្រង់ពិចារណាបណ្ណសាលាទាំងឡាយ ទ្រង់ប្រគល់បណ្ណសាលាទាំងឡាយត្រង់កណ្ដាលដល់ពួកស្ត្រី ព្រោះហេតុអ្វី ព្រោះស្ត្រីទាំងនេះជាអ្នកខ្លាច ព្រះមហាសត្វទ្រង់ពិចារណាហើយ ទ្រង់ប្រគល់បណ្ណសាលាខាងក្រៅៗ ដល់ពួកបុរស ក្នុងថ្ងៃរក្សាឧបោសថ បព្វជិតស្រីប្រុសទាំងអស់ បេះផ្លែឈើត្រង់ដើមឈើដែលមានផ្លែទាំងឡាយ ដែលវិស្សុកម្មនិម្មិត ដែលជ្រុះត្រង់ផែនដី យកមកបរិភោគ ហើយចម្រើនសមណធម៌ ។ បណ្ដាបព្វជិតទាំងនោះ បុគ្គលណា ត្រិះរិះនូវកាមវិតក្ក ព្យាបាទវិតក្ក ឬវិហិង្សាវិតក្ក ព្រះមហាសត្វទ្រង់ជ្រាបវារចិត្តនៃបុគ្គលនោះ ទ្រង់ប្រថាប់គង់សម្ដែងធម៌ទូន្មានក្នុងអាកាស បព្វជិតទាំងអស់នោះ ស្ដាប់ឱវាទនោះហើយធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតរួសរាន់នោះឯង ក្នុងកាលនោះ ស្ដេចសាមន្តរាជមួយអង្គ បានដំណឹងថា បានឮថា ព្រះបាទកាសិករាជទ្រង់ផ្នួសហើយ ទ្រង់គិតថា អញនឹងដណ្ដើមយករាជសម្បត្តិក្នុងក្រុងពារាណសី

ទើបយាងចេញអំពីព្រះនគរ ដល់ក្រុងពារាណសី ទ្រង់ចូលកាន់ព្រះនគរ ទត ឃើញព្រះនគរតាក់តែង ទើបយាងឡើងកាន់ព្រះរាជនិវេសន៍ ទតមើលរតនៈដ៏ប្រសើរ ៧ ប្រការ ក៏ទ្រង់ចិន្តនាការថា ភ័យឯណានីមួយ គប្បីមានព្រោះអាស្រ័យទ្រព្យនេះ ត្រាស់ឲ្យហៅពួកអ្នកលេងសុរាមកត្រាស់សួរថា នែបាអ្នកផឹកសុរាទាំងឡាយ ក្នុងព្រះនគរនេះ មានភ័យកើតឡើងដល់ព្រះរាជាដែលជាម្ចាស់របស់ពួកអ្នកឬ អ្នកលេងទូលថា មិនមានទេ ព្រះអង្គ ។ ក្សត្រសាមន្តរាជត្រាស់សួរថា ព្រោះហេតុអ្វី ក៏ទូលថា បពិត្រព្រះអង្គ តេមិយរាជកុមារជាឱរសរបស់ព្រះរាជាពួកទូលបង្គំ ទ្រង់ឃើញថា នឹងគ្រប់គ្រងរាជសម្បត្តិក្នុងក្រុងពារាណសីធ្វើអ្វី មិនគ ក៏ក្លែងធ្វើជាគ យាងចេញអំពីព្រះនគរនេះ ចូលទៅកាន់ព្រៃ បួសជាឥសី ព្រោះហេតុនោះ ព្រះរាជារបស់ទូលបង្គំ មួយអន្លើដោយមហាជន ក៏បានយាងចេញអំពីព្រះនគរនេះទៅកាន់សម្នាក់របស់តេមិយកុមារ ទ្រង់បួសហើយ ។ ស្តេចសាមន្តរាជត្រាស់សួរថា ព្រះរាជារបស់ពួកអ្នកយាងចេញតាមទ្វារណា កាលជនទាំងនោះក្រាបទូលថា យាងចេញតាមទ្វារទិសខាងកើត ក៏យាងចេញតាមទ្វារនោះដូចគ្នា បានទៅតាមឆ្នេរស្ទឹង ។

ព្រះមហាសត្វទ្រង់ដឹងថា ស្តេចសាមន្តរាជយាងមក ទើបទ្រង់ចេញទៅទទួល ប្រថាប់គង់ក្នុងអាកាសសម្តែងធម៌ដល់ព្រះបាទសាមន្តរាជនោះ ព្រះរាជាសាមន្តរាជនោះ ដល់ព្រមដោយបរិស័ទ ទ្រង់ស្តាប់ធម៌ហើយ ទ្រង់បួសក្នុងសម្នាក់របស់ព្រះមហាសត្វនោះ សូម្បីព្រះរាជាដទៃៗ ៣ អង្គទៀត ក៏ទ្រង់

លះបង់រាជសម្បត្តិ បួសហើយយ៉ាងនោះដូចគ្នា ដោយប្រការដូច្នេះ ប្រទេសត្រង់នោះបានជាមហាសមាគម ដីរទាំងឡាយក៏ក្លាយជាដីរព្រៃ សេះទាំងឡាយក៏ក្លាយជាសេះព្រៃ រថទាំងឡាយ ក៏ទ្រុឌទ្រោមទៅក្នុងព្រៃនោះឯង កណ្ឌៈជាគ្រឿងប្រើប្រាស់ និងកហាបណៈទាំងឡាយ ក៏រត់រាយដូចខ្សាច់ ក្បែរអាស្រមដ្ឋាន បព្វជិតទាំងអស់នោះធ្វើនូវសមាបត្តិ ៨ ឲ្យកើតក្នុងទីនោះឯង កាលអស់ជីវិត មានព្រហ្មលោកជាទីទៅខាងមុខ ដីរ និងសេះទាំងឡាយដែលជាសត្វតិរច្ឆាន ញុំាងចិត្តឲ្យជ្រះថ្លាក្នុងពួកឥសីទាំងឡាយ បានកើតក្នុងស្ថានសួគ៌ជាន់កាមាវចរ ៦ ជាន់ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតលះរាជសម្បត្តិចេញបួស សូម្បីក្នុងកាលមុន តថាគតក៏បានលះរាជសម្បត្តិចេញបួសដូចគ្នា ដូច្នេះហើយ ទ្រង់ប្រកាសអរិយសច្ចទាំង ៤ ហើយប្រជុំជាតកថា ទេពធីតាដែលស្ថិតត្រង់ស្វេតច្ឆត្រក្នុងកាលនោះ បានមកជាឧប្បលវណ្ណាភិក្ខុនីក្នុងកាលឥឡូវនេះ សុនន្ទសារថីក្នុងកាលនោះ បានជាសារីបុត្ត សក្កៈក្នុងកាលនោះ បានមកជាអនុរុទ្ធ ព្រះជនក និងព្រះជននីក្នុងកាលនោះ បានមកជាត្រកូលមហារាជ បរិស័ទក្រៅពីនេះ ក្នុងកាលនោះ បានជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកបណ្ឌិតដែលធ្វើគ ធ្វើខ្វិន ក្នុងកាលនោះ គឺតថាគតសម្មាសម្ពុទ្ធនេះឯង ។ល។

**អដ្ឋកថា តេមិយជាតក ចប់**

# សុត្តន្តបិដក

## មហាជនកជាតក

[ ៤៩ ] ( នាងទេវធីតាឈ្មោះមណីមេខលាសួរថា ) បុគ្គលណានេះ កាលមិនឃើញត្រើយ ក៏ព្យាយាម ( ហែល ) ក្នុងកណ្តាលសមុទ្ទ អ្នកដឹងនូវអំណាច នៃប្រយោជន៍ដូចម្តេច ក៏ព្យាយាមក្រៃពេកម៉្លេះ ។

[ ៥០ ] ( ព្រះមហាសត្វត្រាស់តបថា ) ម្នាលទេវតា ខ្ញុំពិចារណានូវវត្តនៃសត្វលោក និងអានិសង្សនៃសេចក្តីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំសូម្បីមិនឃើញត្រើយ ក៏នៅតែព្យាយាម ក្នុងកណ្តាលសមុទ្ទ ។

[ ៥១ ] ( នាងមណីមេខលា ) អ្នកមិនឃើញត្រើយនៃសមុទ្ទដ៏ជ្រៅប្រមាណមិនបាន ការព្យាយាមតាមកម្លាំង បុរសរបស់អ្នកជាព្យាយាមសោះសូន្យទទេ អ្នកមិនដល់នូវត្រើយទេ មុខជានឹងស្លាប់ ។

[ ៥២ ] ( ព្រះមហាសត្វ ) បុគ្គលធ្វើនូវកិច្ចរបស់បុរស ទើបជាអ្នកមិនមានបំណុល ( ក្នុងរវាង ) ពួកញាតិ ពួកទេវតា និងពួកបិតា ( ព្រហ្ម ) ទាំងមិនក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ។

[ ៥៣ ] ( នាងមណីមេខលា ) ការងារណា មិនគប្បីសម្រេច ( ដោយសេចក្តីព្យាយាមទេ ) ការងារនោះ ជារបស់ឥតផល មានសេចក្តីលំបាកជាកម្រៃ សេចក្តីស្លាប់ រមែងសម្រេចដល់បុគ្គល

ណា បុគ្គលនោះ មានប្រយោជន៍ដូចម្តេច ដោយសេចក្តីព្យាយាម ក្នុងការងារនោះ ។

[ ៥៤ ] ( ព្រះមហាសត្វ ) ម្នាលទេវតា បុគ្គលណាដឹងច្បាស់ថា ការងារមិនគប្បីសម្រេចដោយពិត ហើយមិនរក្សាជីវិតរបស់ខ្លួន បុគ្គលនោះ បើបន្ថយសេចក្តីព្យាយាម គង់ដឹង ( នូវផលនៃសេចក្តីខ្ជិលនោះមិនខាន ) ។ ម្នាលទេវតា បុគ្គលពួកខ្លះក្នុងលោកនេះ ( កាលឃើញ ) នូវផលនៃសេចក្តីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះសម្រេចខ្លះ មិនសម្រេចខ្លះ ។ ម្នាលទេវតា ក្រែងអ្នកបានឃើញផលនៃកម្ម ដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ជនទាំងឡាយដទៃលិចលង់ហើយ ខ្ញុំនៅឆ្លងទាំងបានឃើញនាង ដែលឋិតនៅក្នុងទីជិតនៃខ្ញុំ ។ ខ្ញុំនោះនឹងព្យាយាមតាមសមគួរ ដល់សេចក្តីអង់អាច និងសមគួរដល់កម្លាំង ខ្ញុំកាលទៅដល់ត្រើយនៃសមុទ្ទ នឹងធ្វើនូវសេចក្តីព្យាយាម ដែលបុរសគប្បីធ្វើ ។

[ ៥៥ ] ( នាងមណីមេខលា ) កាលមហាសមុទ្រមានអន្លង់ទឹកដ៏ជ្រៅ ប្រមាណមិនបាន ប្រព្រឹត្តទៅយ៉ាងនេះ អ្នកណាប្រកបដោយសេចក្តីព្យាយាមដោយធម៌ រមែងមិនលិចដោយកម្ម គឺសេចក្តីព្យាយាម ចិត្តរបស់អ្នកត្រេកអរក្នុងទីណា អ្នកនោះ ចូរទៅក្នុងទីនោះចុះ ។

[ ៥៦ ] ( ព្រះបាទបោលជនក ) កំណប់ធំ ១៦ នេះ គឺកំណប់ត្រង់ទីព្រះអាទិត្យរះ កំណប់ត្រង់ទីព្រះអាទិត្យលិច កំណប់ខាងក្នុង កំណប់ខាងក្រៅ កំណប់មិនមែនខាងក្នុង មិនមែនខាងក្រៅ កំណប់ធំត្រង់ទីសម្រាប់ឡើង កំណប់ត្រង់ទីសម្រាប់ចុះ កំណប់ត្រង់សាលព្រឹក្សធំទាំងបួន កំណប់ត្រង់ទីមួយយោជន៍ជុំវិញ កំណប់ធំត្រង់ចុងភ្លុកដំរីទាំងពីរ កំណប់ត្រង់ចុងកន្ទុយ កំណប់ក្នុងទឹក កំណប់ធំត្រង់ចុងឈើសហស្សថាមគ្គ បល្ល័ង្កបួនជ្រុង នឹងញាំងនាងសីវលីរាជទេវីឲ្យត្រេកអរ ។

[ ៥៧ ] ( ព្រះបាទមហាជនក ) បុរសជាបណ្ឌិតត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួនឯង យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។ បុរសជាបណ្ឌិតត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន ( ដែលទេវតា ) ស្រង់អំពីទឹកមកដាក់លើគោក ។ បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។ បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន ( ដែលទេវតា ) ស្រង់អំពីទឹកមកដាក់លើគោក ។ នរជនមានប្រាជ្ញា សូម្បីសេចក្តីទុក្ខប៉ះពាល់ហើយ មិនគប្បីកាត់សេចក្តីប្រាថ្នា ដើម្បីដល់នូវសេចក្តីសុខទេ ព្រោះថា ការប៉ះពាល់

ដ៏ច្រើនឥតប្រយោជន៍ក៏មាន មានប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងដល់នូវសេចក្ដីស្លាប់ ។ ហេតុដែលបុគ្គលមិនបានគិតសម្រេចក៏មាន ហេតុដែលបុគ្គលគិតហើយ វិនាសទៅក៏មាន ព្រោះភោគៈទាំងឡាយ របស់ស្ត្រី ឬបុរស មិនមែនសម្រេចដោយការគិតទេ ។

[ ៥៨ ] ( មហាជន ) ម្នាលគ្នាយើងដ៏ចម្រើន ព្រះរាជាត្រួតនូវផែនដីទាំងមូល ជាម្ចាស់ក្នុងទិសមិនដូចអំពីដើមសោះ ថ្ងៃនេះមិនទ្រង់ក្រសាលរបាំ មិនទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះចម្រៀង មិនទតម្រឹគ មិនទតឧទ្យាន មិនទតហង្ស ទ្រង់គង់នៅស្ងៀម ហាក់ដូចមនុស្សគ មិនទ្រង់កាត់សេចក្ដី ។

[ ៥៩ ] ( ព្រះបាទមហាជនក ) ព្រះបច្ចេកពុទ្ធទាំងឡាយ ទាំងក្មេង ទាំងចាស់ អ្នកប្រាថ្នាសេចក្ដីសុខ មានសេចក្ដីស្ងប់ស្ងាត់ជាប្រក្រតី ប្រាសចាកចំណង គឺកិលេស គង់នៅក្នុងអារាមនៃបុគ្គលណាហ្ន៎ ក្នុងថ្ងៃនេះ ។ អ្នកប្រាជ្ញទាំងឡាយណា បានកន្លងនូវតណ្ហា ជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ នៅក្នុងលោក ដែលកំពុងខ្វល់ខ្វាយ ខ្ញុំសូមថ្វាយបង្គំអ្នកប្រាជ្ញទាំងនោះ ជាអ្នកស្វែងរកនូវគុណដ៏ធំ ។ អ្នកប្រាជ្ញទាំងឡាយនោះ កាត់ទម្លាយនូវតម្បាញជាបណ្ដាញដ៏មាំរបស់មច្ចុ ដែលមានមាយាចេញទៅរួច បុគ្គលណា គប្បីញុំាងយើងឲ្យដល់នូវគតិ ( លម្អាន ) នៃអ្នកប្រាជ្ញទាំងនោះបាន ។

[ ៦០ ] កាលណា អញនឹងលះនគរមិថិលា ជាក្រុងសម្បូណ៌ ដែលជាងចែកហើយ ( ដោយហាន មានរាជនិវេសន៍ជាដើម ) វាស់ហើយដោយចំណែក ( នៃទ្វារ និងថ្នល់ ) ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ទូលាយ មានពន្លឺដោយជុំវិញ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង និងខ្លោងទ្វារដ៏ច្រើន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានប៉ម និងស៊ុមទ្វារដ៏មាំមួន ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដែលគេចែកល្អ មានផ្លូវធំ ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរានផ្សារដែលគេចែកដោយល្អ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដ៏កុះករដោយគោ សេះ និងរថ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃសួន

ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃឧទ្យាន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃប្រាសាទដ៏ប្រសើរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង ៣ ជាន់ ពេញដោយរាជវង្សានុវង្ស ដែលព្រះបាទវិទេហៈ ព្រះនាមសោមនស្ស មានយសទ្រង់សាងទុក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់ដែនវិទេហៈ ជាដែនសម្បូណ៌ បរិបូណ៌ដោយការសន្សំ ( នូវធញ្ញាហារជាដើម ) ដែលរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដែនវិទេហៈ ជាដែនសម្បូណ៌ ដែលបច្ចាមិត្តផ្ចាញ់មិនបាន ជាដែនរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ដែលជាទីរីករាយ ដែលជាងចែកវាស់ដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ជាទីរីករាយ ដែលបូកដោយកំបោរ និងដី

ហើយបួស ការលះបង់ នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវខានក្នុងបុរី ជាទីរីករាយ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលជាងថែកហើយ វាស់ហើយដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលបូកដោយកំបោរ និងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលមានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលលាបល្អហើយ ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវគ្រែមាសទាំងឡាយ មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវបល្ល័ង្កកែវមណី មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវសំពត់អំបោះ និងសំពត់សូត្រ សំពត់ទាំងឡាយដែល

កើតអំពីដែនខោមៈ និងកើតអំពីដែនកោទុម្ពរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាក្រពាកយំទ្រហឹង ដេរដាសដោយចន្ទុលណីទាំងឡាយផង ដោយឈូក និងព្រលិតទាំងឡាយផង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវហ្វូងដំរីមាតង្គៈ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ មានខ្សែជង្គន់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរី មានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវហ្វូងសេះ អាជានេយ្យអំពីជាតិ ជាសេះសិន្ធព ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ ជាវាហនៈលឿន ដែលអ្នកបង្ហាត់សេះកាន់សែ្វ និងធ្នូ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួករថប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួករថមាសប្រដាប់

ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានជ្ជ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថប្រាក់ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានជ្ជ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមសេះប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានជ្ជ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមឱដ្ឋប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានជ្ជ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមគោប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាង

ដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានជ្ជ និងខែល ក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមកែះប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានជ្ជ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមពពែប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានជ្ជ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមម្រឹគប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានជ្ជ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះដំរី ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្បៀវក្លា មានលំពែងស្នែងក្របី និងកន្ត្រៃក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាល

ណាអញនឹងលះបង់នូវពួកអ្នកជិះសេះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ែ និងធ្នូ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះរថ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងព្រួញក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកខ្មាន់ធ្នូ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកព្រះរាជបុត្រ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអរិយជន គឺព្រាហ្មណ៍ដែលមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្តប់ដោយសំពត់ ដែលបានមកអំពីដែនកាសីដ៏ឧត្តម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអាមាត្យ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់

ខែលមានពណ៌លឿង ជាអ្នកក្បៀវក្លា មានរបៀបដើរខាងមុខ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ជាអ្នកសង្រួមល្អ មានចង្កេះរៀវ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវស្រីស្នំ ៧០០ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវភាជន៍មាស មានទម្ងន់ ១០០ បល្ល: ប្រកបដោយស្នាមចម្លាក់ ១០០ ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាហ្វូងដំរីមាតង្គ:របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង មានខ្សែជង្គង់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីមានលំពែងស្នែងក្របី និងកង្វេរក្នុងដៃឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាហ្វូងសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការ ទាំងពួង ជាសេះអាជានេយ្យដោយជាតិ ជាសេះសិន្ធពជាវាហនៈដ៏លឿន ដែលពួកអ្នករក្សាសេះកាន់សែ្ង និងធ្នូឡើងជិះ

ហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេច ក្នុងកាលណាហ្ន៎ ។ កាលណាពួករថរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានដួ និងខែលក្នុងដៃឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថមាសរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានដួ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថប្រាក់របស់អញ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានដួ និងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមសេះរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានដួ និងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាល

ណាហ្ន៎ ។ កាលណារថទឹមឧដ្ឋរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូនិងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថទឹមគោរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមកែះរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមពពែរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមម្រឹគរបស់អញប្រដាប់ហើយ

មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអ្នកជិះដីរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របី និងកន្ទ្រើក្នុងដៃ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអ្នកជិះសេះរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ែ និងធ្នូ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអ្នកជិះរថរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកខ្មាន់ធ្នូរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករាជបុត្ររបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំង

ពួន កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអរិយជន គឺព្រាហ្មណ៍អ្នកមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវសំពត់ដ៏ឧត្តម ដែលបានមកអំពីដែនកាសី នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអាមាត្យរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ជាស្ត្រីសង្រួមល្អ មានចង្កេះរៀវ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងបានទៅជាអ្នកកោរក្បាល ឃ្លុំសង្ឃាដិ កាន់បាត្រត្រាច់ចរទៅបិណ្ឌបាត ដំណើរនោះនឹងសម្រេច

ក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងទ្រទ្រង់នូវសង្ឃាដិនៃសំពត់បង្សុកូលទាំងឡាយ ដែលគេចោលក្នុងផ្លូវធំ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញ កាលដែលមេឃបង្អុរភ្លៀងចុះអស់ ៧ ថ្ងៃហើយ នឹងត្រាច់ទៅបិណ្ឌបាតទាំងចីវរទទឹក ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងចេញទៅអំពីដើមឈើមួយ ទៅកាន់ដើមឈើមួយ អំពីព្រៃមួយទៅកាន់ព្រៃមួយ រហូតថ្ងៃ និងយប់ទាំងអស់ ត្រាច់ទៅ ឥតអាឡោះអាល័យ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងលះបង់នូវភ័យគួរខ្លាច ហើយមិនមានគ្នាជាគម្រប់ពីរនាក់ ដើរទៅលើជ្រោះភ្នំទាំងឡាយ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញធ្វើចិត្តឲ្យត្រង់ ដូចជាបុគ្គលដេញពិណ អាចដេញខ្សែទាំង ៧ ឲ្យជាទីរីករាយចិត្តបាន ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងកាត់នូវកាមសំយោជន៍ជាទិព្វ ទាំងជារបស់មនុស្សបាន ដូចជាជាងរថ កាលកាត់នូវស្បែកជើង ដូច្នោះ ។

[ ៦១ ] ( អភិសម្ពុទ្ធគាថា ) ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ព្រោះហេតុអ្វី ។ ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្រ្តីសង្រួមល្អ មានចង្កេះរៀវ ផ្គងដើមដៃទួញ

យំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ព្រោះហេតុអ្វី ។ ពួកស្រី ស្នំទាំង ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ព្រោះហេតុអ្វី ។ ព្រះរាជាទ្រង់លះនូវសម្ប័ទ បានលះបង់ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ព្រះអង្គត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវសម្ប័ទ បានលះបង់ពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រួមល្អ មានចង្កេះរៀវ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវសម្ប័ទ បានលះបង់ពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវភាជន៍មាស មានទម្ងន់មួយរយបល្ល: ប្រកបដោយស្នាមចម្លាក់មួយរយ បានកាន់យកនូវបាត្រដី ការកាន់នូវបាត្រដីនោះ ទុកជាអភិសេកទី ២ ។

[ ៦២ ] ( ព្រះនាងសីវលីទេវី ) ឃ្លាំងទាំងឡាយ គឺឃ្លាំងប្រាក់ ឃ្លាំងមាស ឃ្លាំងកែវមុក្តា ឃ្លាំងកែវពិទូរ្យ ឃ្លាំងកែវមណី ឃ្លាំងស័ង្ខ ឃ្លាំងកែវមុក្តាដ៏ច្រើន ឃ្លាំងសំពត់ ឃ្លាំងខ្លឹមចន្ទន៍ក្រហម ឃ្លាំងស្បែកខ្លាឃ្មុំ ឃ្លាំងរបស់ធ្វើពីភ្លុក ឃ្លាំងទង់ដែង និងឃ្លាំងដែកខ្មៅដ៏ច្រើន ជាឃ្លាំងដែលរាជបុរសរៀបចំដោយចំណែក ត្រូវ

ភ្លើងឆេះ មានអណ្តាតភ្លើងស្មើគ្នាគួរខ្លាច បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យទ្រព្យរបស់ព្រះអង្គនោះវិនាស ។

[ ៦៣ ] ( ព្រះរាជា ) កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើក្រុងមិថិលាត្រូវភ្លើងឆេះ ភ្លើងមិនមែនឆេះ នូវទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ ។

[ ៦៤ ] ( ព្រះនាងសីវលីទេវី ) ចោរក្នុងដងព្រៃកើតឡើងហើយ បំផ្លាញដែនរបស់ព្រះអង្គ បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យដែននេះវិនាស ។

[ ៦៥ ] ( ព្រះរាជា ) កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើដែនត្រូវពួកចោរប្លន់ ចោរមិនបានយកទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ កង្វល់មិនមានដល់យើងណា យើងនោះ ឈ្មោះថា រស់នៅជាសុខ យើងជាអ្នកមានបីតិជាអាហារដូចពួកអាភស្សរទេវតា ។

[ ៦៦ ] ( នារទតាបស ) សំឡេងគឹកកងនៃជនច្រើននេះ តើព្រោះហេតុអ្វី ស្រ្តីនោះជាអ្វី លេងជាមួយក្នុងព្រៃ ដូចក្នុងស្រុក បពិត្រសមណៈ ខ្ញុំសួរលោកថា មហាជនទាំងប្រជុំគ្នាដើម្បីអ្វី ។

[ ៦៧ ] ( ព្រះរាជា ) ខ្ញុំកាលលះបង់នូវមហាជន ហើយចេញទៅ បានជាមហាជនប្រជុំគ្នាក្នុងទីនេះ ខ្ញុំកន្លងនូវដែន គឺកិលេស

ហើយទៅបួស ដើម្បីបាននូវមោនធម៌ ( ពោល គឺញាណរបស់អនាគារិយៈ ) មុនី ខ្ញុំកាលទៅកាន់ទីប្រឡូកប្រឡំ ដោយសេចក្តីរីករាយទាំងឡាយ អ្នកដឹង ទើបសួរឬ ( ឬមិនដឹង ) ។

[ ៦៨ ] ( នារទតាបស ) ព្រះអង្គ កាលទ្រទ្រង់នូវសរីរៈនេះ កុំសម្គាល់ថា អញឆ្លងកិលេសហើយដូច្នេះ កម្ម ( គឺកិលេស ) នេះ បុគ្គលមិនគប្បីឆ្លងបានទេ ព្រោះថា សេចក្តីអន្តរាយមានច្រើន ។

[ ៦៩ ] ( ព្រះរាជា ) ខ្ញុំណាមិនប្រាថ្នា នូវកាមទាំងឡាយក្នុងមនុស្សលោក ដែលបុគ្គលឃើញហើយ មិនប្រាថ្នានូវកាមទាំងឡាយក្នុងទេវលោក ដែលបុគ្គលមិនឃើញហើយ សេចក្តីអន្តរាយដូចម្តេចហ្ន៎ នឹងមានដល់ខ្ញុំនោះ មានកិរិយាទៅយ៉ាងនេះ ។

[ ៧០ ] ( នារទតាបស ) ដ្បិតថា សេចក្តីអន្តរាយ តាំងឡើងច្រើន គឺការដេកលក់ សេចក្តីខ្ជិល ការមើតពត់ សេចក្តីអផ្សុក ការពុលបាយ តាំងនៅក្នុងសរីរៈ រមែងកើត ( ក្នុងសរីរៈវិញ ) ។

[ ៧១ ] ( ព្រះរាជា ) បពិត្រព្រាហ្មណ៍ លោកដ៏ចម្រើនប្រៀនប្រដៅខ្ញុំល្អណាស់ បពិត្រព្រាហ្មណ៍ ខ្ញុំសួរលោក បពិត្រលោកនិទ៌ុក្ខ លោកជាអ្វី ។

[ ៧២ ] ( នារទតាបស ) ជនទាំងឡាយ ស្គាល់អាត្មាភាពដោយនាមថា នារទៈ ដោយគោត្រថា កស្សបៈ ដូច្នេះ អាត្មាភាពមកក្នុងសម្នាក់ព្រះអង្គដ៏ចម្រើន ដោយដឹងច្បាស់ថា សមាគមដោយ

សប្បុរសទាំងឡាយ ជាកិច្ចញ៉ាំងប្រយោជន៍ឲ្យសម្រេច ។ សេចក្តីត្រេកអរ ( ក្នុងបព្វជ្ជា ) ទាំងអស់ និងព្រហ្មវិហារ ចូរកើតដល់ព្រះអង្គនោះចុះ បរិកម្ម និងឈានណា ការខ្វះខាត ( ដោយសីល និងឈាន ) ណា ព្រះអង្គចូរបំពេញនូវការខ្វះខាតនោះចុះ ព្រះអង្គ ( ចូរប្រកប ) ដោយអធិវាសនខន្តី និងឧបសមៈ ។ ព្រះអង្គចូររំសាយចោលនូវសេចក្តីមើលងាយ និងសេចក្តីក្រអឺតក្រអោង ចូរធ្វើគោរពនូវកុសលកម្ម នូវវិជ្ជា និងធម៌ ។

[ ៧៣ ] ( មិគាជិនតាបស ) បពិត្រព្រះជនក ព្រះអង្គលះបង់ដំរីសេះ ពួកអ្នកនគរ និងជនបទជាច្រើន ហើយទ្រង់ព្រះផ្នួស ដល់នូវសេចក្តីត្រេកអរទីងអំបែង បពិត្រព្រះជនក ពួកអ្នកជនបទ មិត្តអាមាត្យ និងព្រះញាតិ បានធ្វើនូវការទ្រុស្ត ចំពោះព្រះអង្គខ្លះដែរឬ ព្រោះហេតុអ្វី ក៏ព្រះអង្គពេញព្រះហឫទ័យ ទីងអំបែងរបស់ព្រះអង្គនោះ ។

[ ៧៤ ] ( ព្រះមហាជនក ) បពិត្រមិគាជិនៈ ក្នុងកាលណាមក ខ្ញុំមិនដែលផ្ចាញ់ នូវញាតិណាមួយ ដោយអធម៌ជាដាច់ខាត ទាំងពួកញាតិ ក៏មិនដែលផ្ចាញ់ខ្ញុំដោយអធម៌ដែរ ។

[ ៧៥ ] បពិត្រមិគាជិនៈ ខ្ញុំបានឃើញនូវប្រវេណី នៃសត្វលោក ដែលកិលេសកំពុងទំពាស៊ី ធ្វើឲ្យដូចជាភក់ បុថុជ្ជនលិចចុះហើយក្នុងកិលេសវត្ថុណា សត្វទាំងឡាយ តែងបៀតបៀនគ្នាផង តែង

ជាប់ក្នុងកិលេសវត្ថុនោះផង ហើយក៏ធ្វើនូវពួកបុថុជ្ជនទាំងនេះ ឲ្យជាគ្រឿងប្រៀបធៀប ទើបបួសជាភិក្ខុ ។

[ ៧៦ ] ( មិគាជិនតាបស ) បពិត្រព្រះអង្គប្រសើរក្នុងរថ បុគ្គលមានជោគណា ជាសាស្តារបស់ព្រះអង្គ ពាក្យដ៏ពីរោះនេះ ជាពាក្យរបស់បុគ្គលណា ព្រោះថា អ្នកប្រាជ្ញទាំងឡាយ មិនវៀរនូវតាបសអ្នកសម្រេចអភិញ្ញា ឬនូវព្រះបច្ចេកពុទ្ធ ដែលប្រកបដោយវិជ្ជា ហើយពោលនូវសមណៈថា អ្នកមានវត្តជាគ្រឿងកន្លងនូវទុក្ខទេ ។

[ ៧៧ ] ( ព្រះមហាជនក ) បពិត្រមិគាជិនៈ ខ្ញុំមិនដែលចូលទៅគោរពសមណៈ និងព្រាហ្មណ៍ណាមួយ ដោយជាប់ខាត ក្នុងកាលណាម្តងឡើយ ។ បពិត្រមិគាជិនៈ ខ្ញុំកាលទៅ ដោយអានុភាពដ៏ធំរុងរឿងដោយសិរី កាលចម្រៀងដែលបុគ្គលកំពុងច្រៀង កាលតន្ត្រីមានសំឡេងដ៏ពីរោះ ដែលបុគ្គលកំពុងប្រគំ បានឃើញស្វាយមានផ្លែខាងក្រៅកំពែង ដែលពួកមនុស្សអ្នកត្រូវការផ្លែ បេះជិតឧទ្យានដែលគឹកកង ដោយការប្រគំតន្ត្រី ជាឧទ្យានប្រកបដោយសូរ ប្រគំដ៏ពីរោះ បពិត្រមិគាជិនៈ ខ្ញុំនោះ បានលះបង់សិរីនោះ ហើយចុះ ( អំពីដំរី ) ចូលទៅកាន់គល់ស្វាយ ដែលមានផ្លែ និងមិនមានផ្លែ បានឃើញស្វាយមានផ្លែ ដែលបុគ្គលបៀតបៀនហើយកម្ចាត់ហើយ ធ្វើមិនឲ្យមានស្លឹក និងស្វាយ ១ ដើមក្រៅនេះ មានពន្លឺខៀវ ជាទីរីករាយនៃចិត្ត សត្រូវទាំងឡាយ អាចសម្លាប់យើង

ដែលជាឥស្សរៈ មានបន្ទាច្រើនដោយពិត ដូចដើមស្វាយដែលមានផ្លែ ដែលបុគ្គលសម្លាប់ហើយ ខ្លាដំបងត្រូវគេសម្លាប់ព្រោះស្បែក ដំរីត្រូវគេសម្លាប់ព្រោះភ្លុក បុគ្គលអ្នកមានទ្រព្យ ត្រូវគេសម្លាប់ព្រោះទ្រព្យ តើនរណា នឹងសម្លាប់បុគ្គលអ្នកមិនមានផ្ទះ មិនមានសន្ថវៈ ដើមស្វាយមានផ្លែ និងមិនមានផ្លែទាំងពីរនោះ ជាសាស្តារបស់ខ្ញុំ ។

[ ៧៨ ] ( នាងសីវលី ) ជនទាំងពួង គឺសេនាដំរី ពលសេះ ពលរថ ពលថ្មើរជើង បានឮថា ព្រះរាជាទ្រង់ផ្នួសហើយ ក៏តក់ស្លុតសូមព្រះអង្គ លួងលោមនូវប្រជុំជន ហើយតាំងទុកនូវការរក្សារូបតាំងព្រះរាជឱរស ក្នុងរាជ្យសម្បត្តិ ហើយសឹមទ្រង់ព្រះផ្នួសក្នុងកាលជាខាងក្រោយចុះ ។

[ ៧៩ ] ( ព្រះមហាជនក ) ពួកអ្នកជនបទ មិត្ត អាមាត្យ និងញាតិទាំងឡាយ ដែលយើងលះបង់ហើយ កូនរបស់អ្នកដែនវិទេហៈ ឈ្មោះទីឃាវុកុមារ អ្នកញុំាងដែនឲ្យចម្រើន ម្នាលបជាបតិ កូននោះ នឹងសោយរាជ្យ ក្នុងក្រុងមិថិលាចុះ ។

[ ៨០ ] នាងចូរមកនេះ ពាក្យណាដែលអាត្មាពេញចិត្ត អាត្មានឹងប្រាប់នូវពាក្យនោះ នាងនឹងទៅកាន់ទុគ្គតិ ដោយកាយ វាចា ចិត្តណា នាងឯងកាលសោយរាជ្យ ( ឈ្មោះថាធ្វើ ) នូវបាបទុច្ចរិតដ៏ច្រើនដោយកាយ វាចា ចិត្តនោះ អាត្មានឹងញុំាងអត្តភាព ឲ្យ

ប្រព្រឹត្តទៅដោយដុំបាយ ដែលបុគ្គលដទៃឲ្យហើយ ដែលបុគ្គលដទៃសម្រេចហើយ ( នេះ ) ជាបវេណីរបស់អ្នកប្រាជ្ញ ។

[ ៨១ ] ( នាងសីវលី ) បុគ្គលណា មិនបរិភោគអាហារក្នុងកាលនៃភត្តជាគម្រប់ ៤ បុគ្គលនោះ គប្បីស្លាប់ ដោយសេចក្តីស្រេកឃ្លាន ដូចបុគ្គលដល់នូវសេចក្តីស្លាប់ដ៏ពិត មានសភាពជាកុលបុត្តមិនគប្បីបរិភោគដុំបាយ ដែលប្រឡាក់ដោយធូលី មិនស្អាតទេ ឬការបរិភោគនោះមិនល្អទេ មិនប្រសើរទេ បពិត្រមហាជនក ព្រះអង្គសោយនូវដុំបាយ ដែលសល់អំពីឆ្កែ ។

[ ៨២ ] ( ព្រះរាជា ) ម្នាលសីវលី វត្ថុណាដែលគ្រហស្ថ ឬសុនខលះបង់ហើយ វត្ថុនោះមិនមែនជាអាត្មា មិនគួរធាន់ទេ ភោគៈទាំងឡាយណានីមួយក្នុងលោកនេះ ដែលបានដោយធម៌ ភោគៈទាំងអស់នោះ លោកពោលថា ជាអាហារមិនមានទោស ។

[ ៨៣ ] ( ព្រះរាជា ) ម្នាលនាងកុមារិកា ជាក្មេងដេកជិតមាតានៅឡើយ មានគ្រឿងប្រដាប់ មិនឃ្លាតអំពីខ្លួនជានិច្ច ដៃម្ខាងរបស់នាងលាន់ឮសំឡេង ដៃម្ខាងមិនលាន់ឮសំឡេង តើព្រោះហេតុអ្វី ។

[ ៨៤ ] ( នាងកុមារិកា ) បពិត្រសមណៈ កងពីរដែលពាក់នឹងដៃរបស់ខ្ញុំនេះ ខ្ទប់គ្នាហើយ សំឡេងក៏កើតឡើង នោះជាគតិនៃកងទាំងពីរ បពិត្រសមណៈ កង ១ ដែលពាក់នឹងដៃរបស់ខ្ញុំនេះ កងនោះ មិនមានកងឯទៀតជាគម្រប់ពីរ ទើបមិនលាន់ឮសំឡេង

ដូចអរិយបុគ្គលជាអ្នកស្ងប់ស្ងៀម ឯបុគ្គលមានគ្នាជាគម្រប់ពីរនាក់ រមែងដល់នូវការជជែកគ្នា បុគ្គល ១ នាក់ នឹងជជែកជាមួយនឹងបុគ្គលណាកើត ព្រះអង្គនោះ ជាអ្នកប្រាថ្នានូវឋានសួគ៌ សូមទ្រង់ពេញចិត្តនឹងភាពនៃបុគ្គលម្នាក់ឯងចុះ ។

[ ៨៥ ] ( ព្រះរាជា ) ម្នាលនាងសីវលី នាងឮគាថា ដែលនាងកុមារិកាពោលហើយឬទេ នាងកុមារិកាតិះដៀលនូវអាត្មា ដូចជាអ្នកបម្រើ ទុំះឯង ជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវ តែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់ផ្លូវ ១ អាត្មានឹងកាន់ផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថាជាប្រពន្ធទៀតដែរ ។ ( អភិសម្ពុទ្ធគាថា ) ព្រះរាជា និងនាងសីវលី កាលពោលនូវពាក្យនេះហើយ ក៏ចូលទៅកាន់ថូណនគរ ។ កាលជិតវេលាភត្ត ព្រះរាជា ( ក៏ឈរ ) ជិតទ្វារនៃជាងព្រួញ ជាងព្រួញនោះ ធ្មេចភ្នែកម្ខាង សម្លឹងមើលដងព្រួញវៀចមួយ ដែលធ្វើឲ្យត្រង់ ដោយភ្នែកម្ខាង ជិតខ្លោងទ្វារនោះ ។

[ ៨៦ ] ( ព្រះរាជា ) ម្នាលជាងព្រួញ អ្នកចូរស្តាប់ពាក្យអាត្មា អ្នកធ្មេចភ្នែកម្ខាង សម្លឹងមើលដងព្រួញវៀច អ្នកមើលយ៉ាងនេះស្រួលឬ ។

[ ៨៧ ] ( ជាងព្រួញ ) បពិត្រសមណៈ ទីប្រាកដដូចជាទូលាយ

ដោយភ្នែកពីរ កិច្ចដោយការៈនៃព្រួញត្រង់ រមែងមិនសម្រេច ព្រោះមិនឃើញ នូវទីវៀចខាងមុខ ។ កាលបុគ្គលធ្មេចភ្នែកម្ខាង សម្លឹងមើលទីវៀច ដោយភ្នែកម្ខាង កិច្ចដោយភាពនៃព្រួញត្រង់ រមែងសម្រេច ព្រោះឃើញទីវៀចខាងមុខ ។ បុគ្គលជាគម្រប់ពីរ រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់ឯង នឹងជជែកគ្នាជាមួយនឹង អ្នកណាកើត កាលព្រះអង្គនោះ ប្រាថ្នានូវឋានសួគ៌ សូមពេញព្រះ ហឫទ័យ នឹងភាពនៃបុគ្គលម្នាក់ឯងចុះ ។

[ ៨៨ ] ( ព្រះរាជា ... ) នៃនាងសីវលី នាងពួគាថាដែលជាង ព្រួញពោលហើយឬទេ ជាងព្រួញតិះដៀលអាត្មា ដូចជាអ្នកបម្រើ ទុំះជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវ តែងដើរទៅ បណ្ដាផ្លូវទាំងពីរនោះ នាងចូរកាន់ យកផ្លូវ ១ អាត្មានឹងកាន់យកផ្លូវ ១ ជាទៀត នាងកុំហៅអាត្មា ថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថា ជាភរិយារបស់អាត្មា ដែរ ម្នាលនាងសីវលី នាងចូរនៅម្នាក់ឯងចុះ ដូចស្មៅយាប្លងដែល អាត្មាដកហើយ ។

## មហាជនកជាតកទី ២ ចប់

# អដ្ឋកថា

## មហាជនកជាតក

[ ៤៩-៨៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាភិនេក្ខម្មបារមី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោ យំ មជ្ឈេ សមុទ្ទស្មឹ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយពណ៌នាមហាភិនេក្ខម្មបារមីរបស់ព្រះតថាគត ក្នុងធម្មសភា ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតចេញស្វែងរកគុណធំ សូម្បីក្នុងកាលមុន កាលជាពោធិសត្វ តថាគតក៏ចេញស្វែងរកគុណធំដូចគ្នា ត្រាស់ដូច្នេះហើយ ទ្រង់ក៏តុណ្ហីភាព ភិក្ខុទាំងនោះក្រាបទូលអារាធនាឲ្យទ្រង់សម្តែង ទើបទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅ

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រះរាជាព្រះនាមមហាជនក គ្រងរាជសម្បត្តិក្នុងក្រុងមិថិលា ដែនវិទេហ: ព្រះបាទមហាជនកនោះ មានព្រះរាជឱរស ២ អង្គ គឺអរិដ្ឋជនក ១ អង្គ បោលជនក ១ អង្គ ក្នុងក្សត្រទាំងពីរអង្គនោះ ព្រះរាជាព្រះរាជទានតំណែងឧបរាជដល់ព្រះរាជឱរសបង ប្រទានតំណែងសេនាបតីដល់ព្រះរាជឱរសប្អូន ។ ក្នុងកាលតមក ព្រះមហាជនកទ្រង់សោយទិវង្គត អរិដ្ឋជនកក៏បានឡើងគ្រងរាជសម្បត្តិ ទ្រង់តាំងព្រះបោល-

ជនក ដែលជាកនិដ្ឋភាតាជាឧបរាជ ។ អមាត្យម្នាក់ជាអ្នកជិតស្និទ្ធជាមួយព្រះរាជា ចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គ ព្រះឧបរាជប្រាថ្នានឹងផ្តាច់ព្រះជន្មព្រះអង្គ ព្រះអរិដ្ឋជនកទ្រង់ស្តាប់ពាក្យនោះរឿយៗ ក៏ទម្លាយសេចក្តីស្នេហាជាមួយព្រះអនុជ ធ្វើព្រះបោលជនកមហាឧបរាជដោយចំណងឃុំទុកក្នុងទីមួយកន្លែង ក្នុងព្រះដំណាក់មួយខ្នង ក្បែរព្រះរាជនិវេសន៍ មានអ្នកយាមរក្សា បោលជនកកុមារទ្រង់តាំងសច្ចាធិដ្ឋានថា បើខ្ញុំបក្កៀវវេរាចំពោះព្រះជេដ្ឋា ចំណងកុំបីរបូតអំពីដៃ និងជើងរបស់ខ្ញុំឡើយ ទ្វារក៏កុំរបើក បើខ្ញុំមិនបានបង្កនូវពៀរវេរាចំពោះព្រះជេដ្ឋា ចំណងចូររបូតអំពីដៃ និងជើងរបស់ខ្ញុំ ទ្វារក៏ចូររបើក ។ គ្រឿងចងក៏បាក់ជាកំណាត់ៗ ទ្វារក៏របើក បន្ទាប់អំពីនោះ ព្រះបោលជនកក៏យាងចេញទៅកាន់បច្ចន្តគ្រាមមួយកន្លែង ប្រថាប់នៅត្រង់បច្ចន្តគ្រាមនោះ អ្នកបច្ចន្តគ្រាមចំណាំទ្រង់បាន ក៏ទំនុកបម្រុង ។ កាលនោះ អរិដ្ឋជនកមិនអាចចាប់ព្រះអង្គបាន ព្រះបោលជនកនោះ បានធ្វើបច្ចន្តជនបទឲ្យនៅក្នុងអំណាចដោយលំដាប់ ជាអ្នកមានបរិវារច្រើន ទ្រង់គិតថា កាលមុនយើងមិនបានបង្កនូវពៀរវេរាចំពោះព្រះជេដ្ឋារបស់យើង តែឥឡូវនេះ យើងនឹងបង្កពៀរវេរា ទ្រង់ឲ្យប្រជុំពួកពលនិកាយ ចោមរោមដោយពួកមហាជន ចេញអំពីបច្ចន្តគ្រាម ដល់ក្រុងមិថិលាដោយលំដាប់ ឲ្យបោះជំរំទ័ពខាងក្រៅព្រះនគរ កាលនោះ ពួកទាហានអ្នកមិថិលានគរជ្រាបថា ព្រះបោលជនកយាងមក ក៏ជញ្ជូនយុទ្ធបករណ៍ មានពាហនដំរីជាដើម មកកាន់សម្នាក់របស់ព្រះបោលជនកនោះដោយច្រើន សូម្បីអ្នកនគរដទៃៗ ក៏នាំគ្នា

ចូលផងដែរ ព្រះបោលជនកបញ្ជូនសាសន៍ទៅថ្វាយព្រះជេដ្ឋាថា ក្នុងកាលមុន ខ្ញុំមិនបានបង្កៀរជាមួយទ្រង់ តែឥឡូវនេះ ខ្ញុំនឹងបង្កៀរ ទ្រង់ប្រទានស្វេតច្ឆត្រដល់ខ្ញុំ ឬក៏ច្បាំង ព្រះរាជាអរិដ្ឋជនកទ្រង់ស្តាប់ដូច្នោះ ប្រាថ្នានឹងច្បាំង ទើបត្រាស់ហៅអគ្គមហេសីមកត្រាស់ថា នែនាង ការច្បាំងឈ្នះ ឬចាញ់មិនអាចដឹងបាន បើយើងមានអន្តរាយ នាងគប្បីរក្សាគភ៌ឲ្យល្អ ត្រាស់ដូច្នេះហើយ ទ្រង់លើកទ័ពចេញអំពីព្រះនគរ កាលនោះ ទាហានរបស់ព្រះបាទបោលជនក ញុំាំងព្រះអរិដ្ឋជនករាជឲ្យសោយទិវង្គត ក្នុងទីលានចម្បាំង អ្នកនគរទាំងឡាយដឹងថា ព្រះរាជាសោយទិវង្គតហើយ ក៏កើតកោលាហលទូទៅ ចំណែកព្រះទេវីទ្រង់ជ្រាបថា ព្រះរាជស្វាមីសោយទិវង្គតហើយ ក៏ទុកដាក់វត្ថុរបស់ដែលសំខាន់ មានមាសជាដើមដាក់ក្នុងល្អី យកសំពត់ចាស់ៗបិទបាំង ហើយដាក់អង្ករខាងលើ ដណ្តប់ព្រះកូសាចាស់សៅហ្មង គៀសព្រះកាយចេញទៅ ដាក់ល្អីលើក្បាល ចេញអំពីព្រះនគរអំពីព្រលឹម មិនមានអ្នកណាស្គាល់ព្រះនាងបាន ។ ព្រះនាងចេញតាមទ្វារទិសឧត្តរ មិនស្គាល់ផ្លូវ ព្រោះមិនធ្លាប់ទៅកាន់ទីណាមួយ មិនអាចកំណត់ទិស ទើបប្រថាប់គង់ត្រង់សាលាមួយកន្លែង រង់ចាំសួរថា មានអ្នកណាទៅកាន់នគរកាលចម្បាកៈដែរឬទេ ព្រោះព្រះនាងទ្រង់ធ្លាប់ឮថា មាននគរឈ្មោះកាលចម្បាកៈប៉ុណ្ណោះ ។ សត្វក្នុងគភ៌របស់ព្រះទេវីនោះ មិនមែនជាសត្វសាមញ្ញ តែជាមហាសត្វមានបារមីពេញហើយមកកើត ដោយតេជានុភាពនៃមហាសត្វនោះ បណ្តាលឲ្យសក្កពិភពបញ្ចេញអាការក្តៅ ។ សក្កទេវរាជទ្រង់អាវជ្ជនាការ ក៏ទ្រង់ជ្រាប

ហេតុនោះ ទ្រង់ត្រិះរិះថា សត្វដែលកើតក្នុងព្រះគភ៌របស់ព្រះទេវី មានបុណ្យច្រើន អញគួរទៅក្នុងទីនោះ ទើបនិម្មិតរថមានគ្រឿងបិទបាំង រៀបចំគ្រែតាំងក្នុងរទេះនោះ និម្មិតខ្លួនដូចមនុស្សចាស់ បររថទៅឈប់ត្រង់ទ្វារសាលាដែលព្រះទេវីប្រថាប់ ទូលសួរព្រះទេវីថា មាននរណាចង់ទៅនគរកាលចម្បាកៈដែរឬទេ ព្រះទេវីបានស្តាប់ដូច្នោះ ទើបត្រាស់ថា បពិត្រលោកឪពុក ខ្ញុំនឹងទៅ សក្កទេវរាជត្រាស់ថា បើដូច្នោះ ចូរនាងឡើងលើរទេះចុះ ព្រះទេវីយាងមកត្រាស់ថា បពិត្រលោកឪពុក ខ្ញុំមានគភ៌ចាស់ខែមិនអាចឡើងរទេះបាន សូមដើរតាមក្រោយលោកឪពុកទៅប៉ុណ្ណោះ តែសូមលោកឪពុកជួយទទួលយកល្អីរបស់ខ្ញុំនេះដាក់លើរទេះផងចុះ ។ សក្កទេវរាជត្រាស់ថា នែនាង នាងនិយាយអ្វី បុគ្គលដែលចេះបររទេះដូចខ្ញុំមិនមានទេ នាងកុំខ្លាចឡើយ សូមនាងឡើងអង្គុយលើរទេះចុះ ។ ដោយអានុភាពនៃព្រះឱរសរបស់ព្រះនាង កាលដែលព្រះទេវីឡើងរទេះ ផែនដីក៏ទល់ឡើងដូចពេញដោយខ្យល់ដូច្នោះ ទាល់គ្នានឹងទូករទេះ ព្រះទេវីឡើងផ្ទំលើសិរីសេយ្យាសនៈ ព្រះនាងជ្រាបបានថា នេះជាទេវតា គ្រាន់តែគិតប៉ុណ្ណោះព្រះនាងក៏លង់លក់ ព្រោះបានទីបន្ទំដែលជាទិព្វ ។

កាលនោះ សក្កទេវរាជទ្រង់បររថដល់ស្ទឹងមួយកន្លែង ដែលមានចម្ងាយ ៣០ យោជន៍ ទើបដាស់ព្រះទេវីត្រាស់ថា នែនាង ចូរនាងចុះអំពីរទេះនេះងូតទឹកក្នុងស្ទឹង ចូរស្លៀកដណ្តប់សំពត់មួយគូដែលដាក់លើសិរសានោះ ចូរនាងចាប់យករបស់បរិភោគ ដែលមានក្នុងរទេះនោះមកបរិភោគចុះ ។ ព្រះទេវីធ្វើតាមយ៉ាងនោះ ហើយក៏ផ្ទំបន្តទៅទៀត លុះដល់កាលចម្បាកនគរ ជូន

ជាពេលល្ងាច ទតឃើញទ្វារត្រង់សំយាបកំពែងព្រះនគរ ទើបត្រាស់សួរសក្កៈថា បពិត្រលោកឪពុក នគរនេះ ឈ្មោះអ្វី សក្កទេវរាជឆ្លើយថា នគរនេះ ឈ្មោះកាលចម្បាកៈ ព្រះទេវីប្រកែកថា បពិត្រលោកឪពុក លោកនិយាយអ្វី នគរកាលចម្បាកៈ នៅឆ្ងាយអំពីនគររបស់ពួកយើង ដល់ទៅ ៦០ យោជន៍មិនមែនឬ សក្កទេវរាជត្រាស់ថា ត្រូវហើយ តែតាស្គាល់ផ្លូវត្រង់ ។ កាលនោះ សក្កៈឲ្យព្រះទេវីចុះអំពីរទេះ ក្នុងទីក្បែរទ្វារ នាទិសទក្សិណ ត្រាស់ប្រាប់ថា ផ្ទះរបស់តានៅខាងមុខ តែចូរនាងចូលទៅកាន់នគរនេះ ត្រាស់ដូច្នេះហើយ យាងទៅដូចទៅខាងមុខ ហើយក៏អន្តរធាន ទៅកាន់ទីប្រថាប់របស់ព្រះអង្គ ឯព្រះទេវីប្រថាប់គង់ត្រង់សាលាមួយកន្លែង ។

ខណៈនោះ មានព្រាហ្មណ៍អ្នករាយមន្តម្នាក់ ជាអ្នកស្រុកកាលចម្បាកៈ ជាអាចារ្យទិសាបាមោក្ខ មានមាណព ៥០០ ចោមរោម ដើរទៅដើម្បីងូតទឹក សម្លឹងមើលមកអំពីចម្ងាយឃើញព្រះទេវីនោះ មានរូបល្អក្រៃលែង សម្បុរដោយលម្អដ៏លើស ប្រថាប់គង់ក្នុងសាលានោះ ដោយអានុភាពនៃព្រះមហាសត្វ ដែលកើតក្នុងព្រះគភ៌របស់ព្រះទេវី គ្រាន់តែឃើញប៉ុណ្ណោះ ក៏កើតនូវសេចក្ដីស្រឡាញ់ដូចជាប្អូនស្រីរបស់ខ្លួន ទើបឲ្យមាណពឈរចាំខាងក្រៅ ចូលទៅក្នុងសាលាតែម្នាក់ឯងសួរថា នែប្អូនស្រី នាងជាអ្នកស្រុកណា ព្រះទេវីឆ្លើយថា បពិត្របងប្រុស ខ្ញុំជាអគ្គមហេសីរបស់អរិដ្ឋជនករាជ ក្រុងមិថិលា ព្រាហ្មណ៍សួរថា នាងមកទីនេះធ្វើអ្វី ព្រះទេវីត្រាស់ឆ្លើយថា អរិដ្ឋជនករាជត្រូវព្រះបោលជនកផ្តាច់ព្រះជន្ម កាលបើយ៉ាងនេះ ខ្ញុំខ្លាចភ័យទើបគេចមក

ដោយគិតថា នឹងរក្សាគភ៌ ។ ព្រាហ្មណ៍សួរថា ក្នុងព្រះនគរនេះមានអ្នកណា ជាញាតិរបស់នាងឬ ព្រះទេវីត្រាស់ឆ្លើយថា មិនមានទេ ព្រាហ្មណ៍ពោលថា បើដូច្នោះ នាងកុំកង្វល់ឡើយ ខ្ញុំឧទិច្ចព្រាហ្មណមហាសាល ជាអាចារ្យ ទិសាបាមោក្ខ ខ្ញុំនឹងតាំងនាងជាប្អូនស្រី បដិបត្តិមើលថែនាង ចូរនាងពោល នឹងខ្ញុំថា បងប្រុស បងប្រុស ហើយចាប់ត្រង់ជើងទាំងពីររបស់ខ្ញុំ ហើយយំ ចុះ ព្រះទេវីទទួលហើយបន្លឺសំឡេងខ្លាំង ចាប់ត្រង់ជើងទាំងពីររបស់ព្រាហ្មណ៍ ព្រាហ្មណ៍ក៏យំដូចគ្នា កាលនោះ ពួកអន្តេវាសិកបានឮសំឡេងរបស់ព្រាហ្មណ៍ ទើបនាំគ្នាចូលទៅកាន់សាលា សួរថា បពិត្រលោកអាចារ្យ មានរឿងអ្វីកើត ឡើងដល់លោកឬ ព្រាហ្មណ៍ពោលថា បាទាំងឡាយ ស្រីនេះ ជាប្អូនស្រី របស់ខ្ញុំ ព្រាត់អំពីខ្ញុំតាំងអំពីកាលឈ្មោះនោះ ពួកអន្តេវាសិកពោលថា ចាប់ តាំងអំពីលោកទាំងពីរបានជួបគ្នាហើយ សូមកុំវិតក្កឡើយ ព្រាហ្មណ៍បានឲ្យ នាំយានដែលបិទបាំងមក ឲ្យព្រះទេវីប្រថាប់ក្នុងយាននោះ ពោលនឹងពួក មាណពថា ចូរអ្នកទាំងឡាយប្រាប់ព្រាហ្មណីថា ស្រីនេះ ជាប្អូនស្រីរបស់ យើង ហើយចូរប្រាប់ព្រាហ្មណីដើម្បីធ្វើកិច្ចទាំងពួងដល់នាង ពោលដូច្នេះ ហើយ ក៏បញ្ជូនព្រះទេវីទៅកាន់ផ្ទះ ។ លំដាប់នោះ ព្រាហ្មណីឲ្យនាងស្រង់ ដោយទឹកក្តៅ ហើយរៀបចំព្រះបន្ទំឲ្យផ្ទំ ។ ព្រាហ្មណ៍ងូតទឹកហើយ ក៏ត្រឡប់ មកកាន់ផ្ទះ ឲ្យអញ្ជើញព្រះនាងមកក្នុងពេលបរិភោគអាហារ ដោយពាក្យថា ចូរអញ្ជើញប្អូនស្រីរបស់យើងមក ហើយបរិភោគរួមគ្នាជាមួយព្រះនាង បាន ប្រណិប័តន៍ព្រះនាងក្នុងនិវេសន៍របស់ខ្លួន មិនយូរប៉ុន្មាន ព្រះនាងក៏ប្រសូត

ព្រះឱរស មានពណ៌ដូចមាស ព្រះទេវីថ្វាយព្រះនាមព្រះឱរស ដូចព្រះនាម ព្រះអយ្យកាថា មហាជនកកុមារ ព្រះកុមារនោះ ទ្រង់ចម្រើនវ័យ ក៏លេង ជាមួយពួកក្មេងៗ ពួកក្មេងណាធាធៅ ឲ្យព្រះរាជកុមារខឹង ព្រះរាជកុមារ ក៏ចាប់ក្មេងទាំងនោះហើយវាយ ដោយទ្រង់មានកម្លាំងច្រើន និងដោយ ខត្តិយមានះ ព្រោះទ្រង់កើតក្នុងត្រកូលស្តេច ដែលមិនលាយឡំដោយពូជ ពង្សដទៃ ពួកក្មេងទាំងនោះក៏ស្រែកយំដោយសំឡេងខ្លាំង កាលត្រូវសួរថា អ្នកណាវាយ ក៏ប្រាប់ថា កូនស្រីមេម៉ាយវាយ ព្រះរាជកុមារគិតថា ពួកក្មេង ថាអញជាកូនស្រីមេម៉ាយរឿយៗ ណ្ហើយចុះ អញនឹងសួរមាតារបស់អញ ថ្ងៃមួយ ទើបព្រះរាជកុមារទូលសួរព្រះមាតាថា បពិត្រអ្នកម៉ែ អ្នកណាជា ឪពុករបស់ខ្ញុំ ព្រះនាងត្រាស់លួងលោមព្រះរាជកុមារថា ព្រាហ្មណ៍ជាឪពុក របស់កូន ។ ស្អែកឡើង ព្រះរាជកុមារក៏វាយក្មេងទាំងឡាយ កាលក្មេងទាំង ឡាយពោលថា កូនស្រីមេម៉ាយវាយ ទើបត្រាស់ថា ព្រាហ្មណ៍ជាបិតារបស់ យើងមិនមែនឬ កាលពួកក្មេងសួរថា ព្រាហ្មណ៍ជាអ្វីនឹងឯង ទើបទ្រង់គិតថា ក្មេងទាំងនេះពោលថា ព្រាហ្មណ៍ជាអ្វីនឹងឯង មាតារបស់អញមិនប្រាប់ហេតុ ការណ៍នេះតាមសេចក្តីពិត លោកមិនប្រាប់ដល់អញតាមចិត្តរបស់លោក លើកទុកចុះ អញនឹងធ្វើឲ្យលោកប្រាប់ឲ្យខាងតែបាន កាលព្រះរាជកុមារបៅ ដោះព្រះមាតា ទើបខាំដោះព្រះមាតា ត្រាស់ថា បពិត្រអ្នកម៉ែ សូមម៉ែប្រាប់ លោកឪពុកដល់ខ្ញុំ បើមិនប្រាប់ខ្ញុំនឹងខាំដោះម៉ែឲ្យដាច់ ព្រះនាងមិនអាច បញ្ឆោតព្រះឱរសបាន ទើបប្រាប់ថា នែបា ឯងជារាជបុត្តរបស់ព្រះបាទអរិដ្ឋ-

មហាជនក ក្នុងនគរមិថិលា បិតារបស់បាត្រូវព្រះបោលជនកផ្ដាច់ព្រះជន្ម មាតាតាំងចិត្តរក្សាបុត្ត ទើបមកកាន់នគរនេះ ព្រាហ្មណ៍នេះ ទុកម៉ែក្នុងនាទីជាប្អូនស្រី បដិបត្តិម៉ែ តាំងអំពីនោះមក សូម្បីអ្នកណាថាជាកូនស្រីមេម៉ាយ ព្រះរាជកុមារក៏មិនខឹង ។ ព្រះរាជកុមាររៀនចប់ត្រៃវេទ និងសិល្បសាស្ត្រទាំងពួង ក្នុងវ៉ាង ១៦ ឆ្នាំ កាលព្រះជន្មបាន ១៦ ឆ្នាំ ជាអ្នកទ្រទ្រង់នូវព្រះរូបឆោមលោមពណ៌ដ៏ឧត្តម ទ្រង់គិតថា អញនឹងយករាជសម្បត្តិដែលជារបស់បិតា ទើបទូលសួរព្រះមាតាថា បពិត្រព្រះមាតា ទ្រព្យណាមួយដែលព្រះមាតាមាន មានខ្លះដែរឬទេ ខ្ញុំនឹងជួញដូរ ឲ្យទ្រព្យកើតឡើងហើយ នឹងយករាជសម្បត្តិដែលជារបស់ព្រះបិតា ព្រះនាងត្រាស់តបថា នែកូន ម៉ែមិនបានមកដៃទទេទេ វត្ថុដែលជាសារៈរបស់យើងមាន ៣ យ៉ាង គឺកែវមណីកែវមុក្តា និងកែវវជិរៈ ក្នុងរបស់ ៣ យ៉ាងនោះ របស់នីមួយៗ ល្មមជាកម្លាំងអាចយករាជសម្បត្តិបាន ចូរបាទទួលកែវ ៣ យ៉ាងនោះ ហើយរកឧបាយយករាជសម្បត្តិចុះ កុំធ្វើការជួញដូរឡើយ ព្រះរាជកុមារទូលថា បពិត្រព្រះមាតា សូមព្រះមាតាប្រទានទ្រព្យនោះពាក់កណ្ដាលដល់ខ្ញុំ ខ្ញុំនឹងយកទៅកាន់សុវណ្ណភូមិ នាំទ្រព្យជាច្រើនមក ហើយយករាជសម្បត្តិដែលជារបស់បិតា ។ ទូលដូច្នេះហើយ ឲ្យព្រះមាតាប្រទានទ្រព្យពាក់កណ្ដាល ចំណាយជាមុខទំនិញ ហើយឡើងសំពៅ មួយអន្លើដោយពួកពាណិជ ធ្វើដំណើរមកកាន់សុវណ្ណភូមិ ហើយត្រឡប់មកថ្វាយបង្គំលាព្រះមាតា ទូលថា បពិត្រព្រះមាតា ខ្ញុំនឹងទៅកាន់សុវណ្ណភូមិ ព្រះនាងត្រាស់ឃាត់ថា នែកូន ឈ្មោះថា

មហាសមុទ្រ សម្រេចប្រយោជន៍តិច មានអន្តរាយច្រើន កូនកុំទៅឡើយ ទ្រព្យរបស់បាមានច្រើន ល្មមសម្រេចនូវប្រយោជន៍យកពជសម្បត្តិហើយ ព្រះរាជកុមារទូលថា ខ្ញុំនឹងទៅពិត ទូលលាព្រះមាតា ថ្វាយបង្គំធ្វើប្រទក្សិណ ហើយឡើងសំពៅទៅ ។ ក្នុងថ្ងៃនោះ រោគក៏កើតឡើងក្នុងព្រះសរីរៈរបស់ព្រះបាទបោលជនករាជ ផ្ទំហើយ ទ្រង់ក្រោកឡើងមិនរួច ។ ពួកពាណិជប្រមាណ ៧០០ ឡើងសំពៅទៅ សំពៅទៅបាន ៧០០ យោជន៍ក្នុងពេល ៧ ថ្ងៃ សំពៅស្ទុះទៅដោយកម្លាំងរលកដ៏ខ្លាំងក្លា មិនអាចទ្រទ្រង់ខ្លួនបាន បន្ទះក្តារក៏បែកដោយកម្លាំងរលក ទឹកចូលមកអំពីទីនោះៗ សំពៅក៏លិចក្នុងកណ្តាលមហាសមុទ្រ មហាជនខ្លាចមរណភ័យ ស្រែកទ្រហោយំ ថ្វាយបង្គំទេវតាទាំងឡាយ តែព្រះមហាសត្វទ្រង់មិនសោយសោកឡើយ ទ្រង់មិនកន្ទក់កន្ទេញ មិនថ្វាយបង្គំទេវតាទាំងឡាយ ទ្រង់ជ្រាបថា ទូកនឹងលិច ទើបបរិភោគស្ករ និងសប្បិរហូតពេញពោះ ហើយជ្រលក់សំពត់សាច់អិល ២ ផ្ទាំង ដោយប្រេងឲ្យសើម ទ្រង់ស្លៀកសំពត់យ៉ាងខ្ជាប់ខ្ជួន ប្រថាប់ឈរលើសសរក្តោង ក្នុងវេលាដែលសំពៅលិច ទ្រង់ឡើងលើចុងសសរក្តោង មហាជនបានជាចំណីរបស់ត្រី និងអណ្តើក ទឹកដោយជុំវិញមានពណ៌ដូចឈាម ព្រះមហាសត្វឈរត្រង់កំពូលសសរក្តោង ទ្រង់កំណត់ទិសថា មិថិលានគរនៅក្នុងទិសនេះ ក៏លោតពីចុងសសរក្តោង រំលងផុតហ្វូងត្រី និងអណ្តើក ទៅធ្លាក់ក្នុងទីបំផុត ១ ឧសភៈ ព្រោះទ្រង់មានកម្លាំងច្រើន ។ ព្រះបាទបោលជនករាជ ក៏សោយទិវង្គតក្នុងថ្ងៃនោះដូចគ្នា ។ ចាប់តាំងអំពីនោះ

ព្រះមហាសត្វអណ្ដែតទៅនៅក្នុងរលក ដែលមានពណ៌ដូចកែវមណី ដូចកំណាត់ដើមចេកមាស ហែលឆ្លងមហាសមុទ្រ ដោយកម្លាំងដើមដៃ ។

ព្រះមហាសត្វទ្រង់ហែលឆ្លងមហាសមុទ្រអស់ ៧ ថ្ងៃ ដូចហែលឆ្លងមួយថ្ងៃ ។ ព្រះពោធិសត្វសង្កេតពេលវេលាថា ថ្ងៃនេះ គឺជាថ្ងៃ ១៥ កើត ទើបខ្ពុរព្រះឱសដោយទឹកប្រៃ ទ្រង់សមាទានឧបោសថសីល ។ ក្នុងកាលនោះ ស្ដេចចតុលោកបាល ប្រគល់ឲ្យទេពធីតាឈ្មោះមណីមេខលា ជាអ្នកថែរក្សាមហាសមុទ្រថា ចូររក្សាសត្វទាំងឡាយ ដែលប្រកបដោយគុណ មានបម្រើមាតាជាដើម ជាអ្នកមិនសមគួរនឹងស្លាប់ក្នុងមហាសមុទ្រ នាងមណីមេខលាមិនបានពិនិត្យមើលមហាសមុទ្រអស់កាល ៧ ថ្ងៃ បានឮថា នាងសោយទិព្វសម្បត្តិភ្លេចស្មារតីមិនបានពិនិត្យមើល អាចារ្យពួកខ្លះពោលថា ទេពធីតាទៅកាន់ទេវសមាគម ។ នាងរឭកបានថា ថ្ងៃនេះជាថ្ងៃទី ៧ ដែលអញមិនបានពិនិត្យមើលមហាសមុទ្រ តើមានហេតុអ្វីខ្លះឬហ្ន៎ កាលនាងពិនិត្យមើលឃើញព្រះមហាសត្វ ទើបគិតថា បើមហាជនកកុមារ ស្លាប់ក្នុងមហាសមុទ្រ អញនឹងមិនបានចូលទេវសមាគម គិតដូច្នេះហើយ តាក់តែងព្រះសរីរៈឋិតនៅក្នុងអាកាស មិនឆ្ងាយអំពីព្រះមហាសត្វ កាលពិសោធព្រះមហាសត្វ ទើបពោលបឋមគាថានេះថា

> បុគ្គលណានេះ កាលមិនឃើញត្រើយ ក៏ព្យាយាម ( ហែល )
> ក្នុងកណ្ដាលសមុទ្ទ អ្នកដឹងនូវអំណាចនៃប្រយោជន៍ដូចម្ដេច ក៏
> ព្យាយាមក្រៃពេកម៉្លេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អបស្សន្តីរំ** បានដល់ មិនឃើញត្រើយឡើយ ។ បទថា **អាយុហោ** បានដល់ ធ្វើនូវសេចក្ដីព្យាយាម ។

កាលនោះ មហាសត្វទ្រង់ព្រះតម្រិះថា អញហែលឆ្លងមហាសមុទ្របាន ៧ ថ្ងៃ ថ្ងៃនេះ អញមិនធ្លាប់ឃើញសម្មាញ់ជាគម្រប់ពីរបស់អញឡើយ បុគ្គលណាហ្ន៎មកពោលជាមួយអញ កាលសម្លឹងមើលក្នុងអាកាស ក៏ទតឃើញនាងមណីមេខលា ទើបត្រាស់គាថាទី ២ ថា

ម្នាលទេវតា ខ្ញុំពិចារណា នូវវត្តនៃសត្វលោក និងអានិសង្សនៃ
សេចក្ដីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំសូម្បីមិនឃើញត្រើយ ក៏
នៅតែព្យាយាម ក្នុងកណ្ដាលសមុទ្ទ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និសម្ម វត្តំ លោកស្ស** សេចក្ដីថា ខ្ញុំបានពិចារណា គឺពិចារណាវត្ត បដិបទារបស់លោក ។ បទថា **វាយមស្ស ច** សេចក្ដីថា ព្រះមហាសត្វសម្ដែងសេចក្ដីថា ខ្ញុំបានពិចារណា គឺឃើញអានិសង្សនៃសេចក្ដីព្យាយាម ។ បទថា **តស្មា** សេចក្ដីថា ព្រោះខ្ញុំពិចារណា គឺដឹងថាឈ្មោះថា សេចក្ដីព្យាយាមរបស់បុរស មិនឥតអំពើឡើយ រមែងឲ្យតាំងនៅក្នុងសេចក្ដីសុខដូច្នោះ សូម្បីមើលមិនឃើញត្រើយ ក៏ត្រូវតែព្យាយាម គឺធ្វើសេចក្ដីព្យាយាម អធិប្បាយថា ខ្ញុំមិនពិចារណាដល់សេចក្ដីនោះបានដូចម្ដេច ។

នាងមណីមេខលា ប្រាថ្នានឹងស្ដាប់ធម្មកថារបស់ព្រះមហាសត្វ ទើបពោលគាថាបន្ដថា

អ្នកមិនឃើញត្រើយនៃសមុទ្ទ ដ៏ជ្រៅ ប្រមាណមិនបាន ការ

ព្យាយាមតាមកម្លាំងបុរសរបស់អ្នក ជាព្យាយាមសោះសូន្យទទេ
អ្នកមិនដល់នូវត្រើយទេ មុខជានឹងស្លាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អប្បត្វា វ** សេចក្តីថា មិនទាន់ដល់ត្រើយឡើយ អ្នកក៏នឹងស្លាប់ ។

គ្រានោះ ព្រះមហាសត្វត្រាស់នឹងនាងមណីមេខលាថា នាងពោលអ្វីយ៉ាងនោះ ខ្ញុំធ្វើសេចក្តីព្យាយាម សូម្បីស្លាប់ក៏ផុតចាកពាក្យនិន្ទា ត្រាស់យ៉ាងនេះហើយ ទើបពោលគាថាដូច្នេះថា

បុគ្គលធ្វើនូវកិច្ចរបស់បុរស ទើបជាអ្នកមិនមានបំណុល ( ក្នុងវាង ) ពួកញាតិ ពួកទេវតា និងពួកបិតា ( ព្រហ្ម ) ទាំងមិនក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនណោ** សេចក្តីថា នៃទេវតា បុគ្គលកាលធ្វើសេចក្តីព្យាយាម ទោះបីស្លាប់ ក៏ជាអ្នកមិនមានបំណុល គឺមិនត្រូវតិះដៀលក្នុងវាងញាតិទាំងឡាយ ទេវតាទាំងឡាយ និងព្រហ្មទាំងឡាយ ។ លំដាប់នោះ ទេវតាពោលនឹងព្រះមហាសត្វថា

ការងារណា មិនគប្បីសម្រេច ( ដោយសេចក្តីព្យាយាមទេ ) ការងារនោះ ជារបស់ឥតផល មានសេចក្តីលំបាកជាកម្រៃ សេចក្តីស្លាប់ រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះ មានប្រយោជន៍ដូចម្តេច ដោយសេចក្តីព្យាយាមក្នុងការងារនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបារណេយ្យំ** សេចក្តីថា មិនគប្បីដល់

គោលដៅដោយសេចក្តីព្យាយាម ។ បទថា **មច្ចុ យស្សាភិនិប្បតំ** សេចក្តីថា ការធ្វើនូវសេចក្តីព្យាយាមក្នុងឋានៈ ដែលមិនសមគួរណា របូតមច្ចុ គឺការស្លាប់នោះឯងប្រាកដឡើង សេចក្តីព្យាយាមក្នុងឋានៈដែលមិនសមគួរនោះ នឹងមានប្រយោជន៍អ្វី ។ កាលនាងមណីមេខលាពោលយ៉ាងនេះហើយ ព្រះមហាសត្វ កាលនឹងធ្វើនាងមណីមេខលាឲ្យទាល់ក្នុងពាក្យសម្តី ទើបត្រាស់គាថាបន្តថា

ម្នាលទេវតា បុគ្គលណាដឹងច្បាស់ថា ការងារមិនគប្បីសម្រេចដោយពិត ហើយមិនរក្សាជីវិតរបស់ខ្លួន បុគ្គលនោះ បើបន្ធយសេចក្តីព្យាយាមគង់ដឹង ( នូវផលនៃសេចក្តីខ្ជិលនោះមិនខាន ) ។ ម្នាលទេវតា បុគ្គលពួកខ្លះ ក្នុងលោកនេះ ( កាលឃើញ ) នូវផលនៃសេចក្តីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះ សម្រេចខ្លះ មិនសម្រេចខ្លះ ។ ម្នាលទេវតា ក្រែងអ្នកបានឃើញផលនៃកម្ម ដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ជនទាំងឡាយដទៃលិចលង់ហើយ ខ្ញុំនៅឆ្លង ទាំងបានឃើញនាងដែលឋិតនៅក្នុងទីជិតនៃខ្ញុំ ។ ខ្ញុំនោះ នឹងព្យាយាមតាមសមគួរ ដល់សេចក្តីអង់អាច និងសមគួរដល់កម្លាំង ខ្ញុំកាលទៅដល់ត្រើយនៃសមុទ្ទ នឹងធ្វើនូវសេចក្តីព្យាយាម ដែលបុរសគប្បីធ្វើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អច្ចន្តំ** សេចក្តីថា បុគ្គលណាដឹងច្បាស់នូវការងារនេះថា ធ្វើនូវសេចក្តីព្យាយាមក៏មិនអាចឲ្យសម្រេចបាន មិនរំលង

ទៅបានពិតៗ ដូច្នេះ មិននាំដីរកាច និងដីរចុះប្រេងជាដើមចេញទៅ ឈ្មោះថា មិនរក្សាជីវិតរបស់ខ្លួន ។ បទថា **ជញ្ញា សោ យទិ ហាបយេ** សេចក្តីថា បើបុគ្គលនោះ លះនូវសេចក្តីព្យាយាមក្នុងឋានៈដូច្នោះចោល ក៏គប្បីដឹងផល នៃការខ្ជិលច្រអូសនោះ ពាក្យដែលលោកពោលនោះៗ ឥតប្រយោជន៍ ។ ព្រះមហាសត្វទ្រង់ចង្អុលបង្ហាញ ដូច្នេះ បទដែលរចនាក្នុងបាលីថា **ជញ្ញា សោ យទិ ហាបយេ** នោះ មិនមានក្នុងអដ្ឋកថា ។ បទថា **អធិប្បាយផលំ** សេចក្តីថា បុគ្គលខ្លះ ឃើញផលនៃបំណងរបស់ខ្លួន ប្រកបការងារ មានកសិកម្ម និងពាណិជ្ជកម្មជាដើម ។ បទថា **ឥានិ ឥជ្ឈន្តិ វា ន វា** សេចក្តីថា ព្រះមហាសត្វសម្តែងសេចក្តីថា កាលបុគ្គលធ្វើនូវសេចក្តីព្យាយាមផ្លូវកាយ និងសេចក្តីព្យាយាមផ្លូវចិត្តថា យើងនឹងទៅក្នុងទីនេះ នឹងរៀនរបស់នេះ ការងារទាំងនោះរមែងសម្រេចពិតប្រាកដនោះឯង ព្រោះដូច្នោះ ទើបគួរធ្វើនូវសេចក្តីព្យាយាមពិត ។ បទថា **សន្នា អញ្ញេ តរាមហំ** សេចក្តីថា អ្នកដទៃៗ លិច គឺលិចចុះក្នុងមហាសមុទ្រ គឺកាលមិនធ្វើសេចក្តីព្យាយាម ក៏ក្លាយជាចំណីត្រី និងអណ្តើកអស់ ខ្ញុំម្នាក់ប៉ុណ្ណោះកំពុងហែលឆ្លង ។ បទថា **តញ្ច បស្សាមិ សន្តិកេ** សេចក្តីថា ចូរនាងមើលផលនៃសេចក្តីព្យាយាមរបស់យើងនេះ យើងមិនធ្លាប់ឃើញទេវតា ដោយអត្តភាពនេះឡើយ យើងនោះក៏បានឃើញនាងមកស្ថិតនៅក្បែរៗ ខ្ញុំ ដោយអត្តភាពទិព្វនេះ ។ បទថា **យថាសត្តិ យថាពលំ** សេចក្តីថា សមគួរដល់សតិ និងកម្លាំងរបស់ខ្លួន ។ បទថា **កស្សំ** បានដល់ នឹងធ្វើ ។

ទេវតាបានស្តាប់វាចាដែលមាំទាំរបស់ព្រះមហាសត្វនោះ កាលសរសើរព្រះមហាសត្វ ទើបពោលគាថាដូច្នេះថា

កាលមហាសមុទ្រ មានអន្លង់ទឹកដ៏ជ្រៅ ប្រមាណមិនបាន ប្រព្រឹត្តទៅយ៉ាងនេះ អ្នកណា ប្រកបដោយសេចក្តីព្យាយាមដោយធម៌ រមែងមិនលិចដោយកម្ម គឺសេចក្តីព្យាយាម ចិត្តរបស់អ្នកត្រេកអរក្នុងទីណា អ្នកនោះ ចូរទៅក្នុងទីនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវំ គតេ** សេចក្តីថា ក្នុងអន្លង់ទឹកដែលប្រមាណមិនបានបែបនេះ គឺក្នុងមហាសមុទ្រជ្រៅផង ធំផង ។ បទថា **ធម្ម-វាយាមសម្បន្នោ** សេចក្តីថា ប្រកបដោយសេចក្តីព្យាយាមតាមធម៌ ។ បទថា **កម្មុនា នាវសីទសិ** សេចក្តីថា អ្នកមិនលិចចុះដោយកិច្ច គឺសេចក្តីព្យាយាមរបស់បុរសរបស់ខ្លួន ។ បទថា **យត្ថ តេ** សេចក្តីថា ចិត្តរបស់អ្នកត្រេកអរក្នុងទីណា ចូរអ្នកទៅក្នុងទីនោះចុះ ។

កាលពោលយ៉ាងនេះហើយ នាងមណីមេខលាបានសួរថា បពិត្របណ្ឌិតអ្នកមានសេចក្តីព្យាយាមច្រើន ខ្ញុំនឹងនាំអ្នកទៅក្នុងទីណា កាលព្រះមហាសត្វត្រាស់ថា មិថិលានគរ ទើបនាងត្រកងព្រះមហាសត្វឡើង ដូចមនុស្សលើកនូវបាច់ផ្កា ប្រើដើមដៃទាំងពីរផ្គងឲ្យដេកទៀបទ្រូង នាំហោះទៅក្នុងអាកាស ដូចម្តាយបីកូនជាទីស្រឡាញ់ ដូច្នោះ ព្រះមហាសត្វមានសរីរៈសៅហ្មងដោយទឹកប្រៃអស់ ៧ ថ្ងៃ បាននូវសម្ផស្សទិព្វក៏ផ្ទំលក់ លំដាប់នោះ នាងមណី-មេខលា នាំព្រះមហាសត្វដល់មិថិលានគរ ឲ្យផ្ទំផ្អៀងខាងស្តាំ លើផ្ទាំងថ្ម

ដែលជាមង្គល ក្នុងអម្ពវនឧទ្យាន ប្រគល់ឲ្យពួកទេវតាដែលនៅក្នុងឧទ្យាន រក្សានូវព្រះមហាសត្វ ហើយទៅកាន់លំនៅរបស់ខ្លួន ។

ក្នុងកាលនោះ ព្រះបាទបោលជនករាជ មិនមានព្រះរាជឱរស មានតែព្រះរាជធីតាមួយអង្គ ព្រះនាមសីវលីទេវី ជាស្រីមានប្រាជ្ញា អមាត្យទាំងឡាយ បានទូលសួរព្រះបាទបោលជនករាជ កាលផ្ទំលើព្រះទែនមរណ-មញ្ចាសនៈថា បពិត្រមហារាជ កាលទ្រង់សោយទិវង្គតហើយ ពួកទូលបង្គំនឹងថ្វាយរាជសម្បត្តិដល់អ្នកណា ព្រះរាជាត្រាស់ថា អ្នកទាំងឡាយ ចូរប្រគល់រាជសម្បត្តិឲ្យដល់អ្នកណាដែលញុំាងព្រះនាងសីវលីទេវី ធីតារបស់យើងឲ្យត្រេកអរ ឬបុរសណាដែលដឹងក្បាលដំណេកនៃបល្ល័ង្ក ៤ ជ្រុង ឬបុរសណាអាចលើកធ្នូសហស្សថាមឡើងបាន ឬបុគ្គលណាអាចនាំមហាកំណប់ទាំង ១៦ កន្លែងមកបាន អ្នកទាំងឡាយ ចូរប្រគល់រាជសម្បត្តិឲ្យដល់បុគ្គលនោះ អមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ត្រាស់ឧទានបញ្ហានៃកំណប់ទ្រព្យទាំងនោះ ដល់ពួកទូលបង្គំចុះ ។

ព្រះរាជា ទើបត្រាស់ឧទានបញ្ហារបស់វត្ថុដទៃៗ មួយអន្លើដោយកំណប់ទ្រព្យទាំងឡាយថា

កំណប់ធំ ១៦ នេះ គឺកំណប់ត្រង់ទីព្រះអាទិត្យរះ កំណប់ត្រង់ទីព្រះអាទិត្យលិច កំណប់ខាងក្នុង កំណប់ខាងក្រៅ កំណប់មិនមែនខាងក្នុង មិនមែនខាងក្រៅ កំណប់ធំត្រង់ទីសម្រាប់ឡើង កំណប់ត្រង់ទីសម្រាប់ចុះ កំណប់ត្រង់សាលព្រឹក្សធំទាំងបួន

កំណាប់ត្រង់ទីមួយយោជន៍ជុំវិញ កំណាប់ធំត្រង់ចុងក្តុកដីរទាំងពីរ កំណាប់ត្រង់ចុងកន្ទុយ កំណាប់ក្នុងទឹក កំណាប់ធំត្រង់ចុងឈើ សហស្សថាមធ្ជ បល្ល័ង្កបួនជ្រុង នឹងញ៉ាំងនាងសិវលីរាជទេវី ឲ្យត្រេកអរ ដូច្នេះ ។

កាលព្រះបាទបោលជនករាជសោយទិវង្គត ថ្វាយព្រះភ្លើងព្រះបរមសព ស្រេចហើយ អមាត្យទាំងឡាយ បានប្រជុំប្រឹក្សាគ្នាក្នុងថ្ងៃទី ៧ ដល់រឿង ដែលព្រះរាជាត្រាស់ថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នកដែលអាចឲ្យព្រះរាជធីតា របស់ទ្រង់ត្រេកអរ អ្នកណាហ្ន៎ អាចឲ្យព្រះរាជធីតាត្រេកអរ អមាត្យទាំងនោះ ក៏ឃើញថា សេនាបតីដែលជាអ្នកជិតស្និទ្ធនៃព្រះរាជា ប្រហែលជាអាច ទើប បញ្ជូនដំណឹងដល់សេនាបតីនោះឲ្យជ្រាប សេនាបតីនោះ បានស្តាប់ដំណឹង ទទួលថា សាធុ ហើយទៅកាន់ទ្វារព្រះរាជវាំងដើម្បីរាជសម្បត្តិ ឲ្យទូលនូវ ភាពដែលខ្លួនមក ដល់ព្រះរាជធីតាៗ ជ្រាបថា សេនាបតីនោះមក ព្រះនាង បំណងសាកល្បងសេនាបតីថា តើជាអ្នកមានបញ្ញា ទ្រទ្រង់នូវសិរីនៃស្វេត- ច្ឆត្របានដែរឬទេ ទើបត្រាស់ថា ចូរមកដោយរហ័ស សេនាបតីបានស្តាប់ ដំណឹងនោះហើយ បំណងឲ្យព្រះរាជធីតាប្រោសប្រាណ ទើបមកដោយរហ័ស តាំងអំពីជើងជណ្តើរ ទៅឈរត្រង់ទីជិតព្រះរាជធីតា លំដាប់នោះ ព្រះរាជធីតា កាលពិសោធសេនាបតីនោះ ទើបត្រាស់ថា ចូររត់ទៅឲ្យរហ័ស ក្នុងព្រះ ដំណាក់ សេនាបតីគិតថា នឹងញ៉ាំងព្រះរាជធីតាឲ្យត្រេកអរ ទើបរត់ទៅ ដោយរហ័ស ព្រះរាជធីតាត្រាស់នឹងសេនាបតីនោះថា ចូររត់មកវិញឲ្យរហ័ស

សេនាបតីក៏រត់មកវិញដោយរហ័ស ព្រះរាជធីតាជ្រាបថា សេនាបតីនោះមិនមានបញ្ញា ទើបត្រាស់ថា ចូរមកប្រាប់ជើងឲ្យយើង សេនាបតីក៏អង្គុយចុះប្រាប់ព្រះបាទរបស់ព្រះរាជធីតា ដើម្បីឲ្យព្រះនាងសព្វព្រះហឫទ័យ គ្រានោះព្រះរាជធីតាក៏យកជើងធាក់សេនាបតីនោះត្រង់ទ្រូងឲ្យដួលផ្ងារ ហើយប្រទានសញ្ញាដល់ខ្ញុំបម្រើទាំងឡាយ ដោយព្រះតម្រាស់ថា ចូរវាយបុរសអាប់ឥតប្រាជ្ញា អន្ធពាលនេះ អូសកចេញទៅ ពួកអ្នកបម្រើទាំងឡាយក៏ធ្វើតាមបញ្ជាសេនាបតី កាលត្រូវគេសួរថា បពិត្រលោកសេនាបតី តើដូចម្តេចទៅហើយក៏ឆ្លើយថា ពួកអ្នកកុំសួរឡើយ ព្រះរាជធីតានេះមិនមែនស្រីមនុស្ស ជាយក្ខិនី បន្ទាប់អំពីនោះ អមាត្យអ្នករក្សាឃ្លាំង ទៅដើម្បីឲ្យព្រះរាជធីតាត្រេកអរ ព្រះរាជធីតាក៏ឲ្យបានទទួលនូវការខ្មាសដូចគ្នានឹងសេនាបតី បានញុំាងជនទាំងពួង គឺសេដ្ឋី ភ្នាក់ងារនាហ្មឺន ភ្នាក់ងារមន្ត្រី ឲ្យទទួលនូវការខ្មាសដូចគ្នា ៗ គ្រានោះ មហាជនប្រឹក្សាគ្នាហើយ ពោលថា មិនមានអ្នកអាចឲ្យព្រះរាជធីតាប្រោសប្រាណ ចូរអ្នកទាំងឡាយប្រគល់រាជសម្បត្តិ ដល់អ្នកអាចលើកធ្នូដែលមានកម្លាំងបុរសមួយពាន់ បុគ្គលណាម្នាក់ ក៏មិនអាចលើកធ្នូនោះឡើង ៗ បន្ទាប់អំពីនោះ ទើបមហាជនពោលថា អ្នកទាំងឡាយចូរប្រគល់រាជសម្បត្តិដល់អ្នកស្គាល់ក្បាលដំណោកនៃបល្ល័ង្ក ៤ ជ្រុង ក៏មិនមានអ្នកណាស្គាល់ទៀត បន្ទាប់អំពីនោះ មហាជនក៏ពោលថា អ្នកទាំងឡាយចូរប្រគល់រាជសម្បត្តិដល់អ្នកអាចនាំកំណប់ទ្រព្យ ១៦ កន្លែងយកមកបាន ក៏មិនមានអ្នកណាអាចទៀត បន្ទាប់អំពីនោះ សេនាមាត្យទាំងឡាយ ប្រឹក្សាគ្នា

ថា យើងទាំងឡាយមិនអាចរក្សាដែន ដែលគ្មានព្រះរាជាបាន គប្បីធ្វើដូចម្តេចហ្ន៎ លំដាប់នោះ បុរោហិតក៏ពោលនឹងសេនាមាត្យទាំងនោះថា ពួកអ្នកកុំវិតក្កឡើយ យើងគួរផ្សងបុស្សរថទៅ ព្រោះព្រះរាជាដែលរកបានដោយបុស្សរថ ជាអ្នកអាចគ្រប់គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ពួកសេនាមាត្យក៏យល់ឃើញព្រមគ្នា ទើបតាក់តែងព្រះនគរ ហើយឲ្យទឹមសេះ ៤ ដែលមានពណ៌ដូចផ្កាកុមុទ ដោយរាជរថដែលជាមង្គល ក្រាលនូវកម្រាលដ៏វិចិត្រខាងលើ ឲ្យប្រតិស្ឋានបញ្ចរាជកកុធភណ្ឌ ចោមរោមដោយចតុរង្គសេនា ជនទាំងឡាយប្រគំគ្រឿងតន្ត្រីខាងមុខរាជរថ ដែលមានព្រះរាជាជាម្ចាស់ ប្រគំខាងក្រោយរថ បើមិនមានព្រះរាជា ព្រោះដូច្នោះ ទើបបុរោហិតពោលថា ចូរអ្នកទាំងឡាយ ប្រគំតន្ត្រីខាងក្រោយរាជរថ ហើយពាក់នូវខ្សែស្បែកត្រង់ទឹមជន្ទួញ កុណ្ឌីមាស ហើយប្រាប់រាជរថថា បុគ្គលណាមានបុណ្យដែលត្រូវបានរាជសម្បត្តិ ចូរអ្នកទៅកាន់សម្នាក់របស់បុគ្គលនោះ ហើយលែងរាជរថនោះទៅ លំដាប់នោះ រាជរថក៏ធ្វើប្រទក្សិណជុំវិញព្រះរាជនិវេសន៍ ហើយឡើងកាន់មហាវិថី ស្ទុះទៅដោយរហ័ស ជនទាំងឡាយ មានសេនាបតីជាដើមនឹកផ្សងថា សូមបុស្សរថមកកាន់សម្នាក់អញ រថនោះ ក៏ស្ទុះទៅហួសគេហដ្ឋានរបស់ជនទាំងពួង ប្រទក្សិណព្រះនគរហើយ ចេញទៅតាមទ្វារទិសខាងកើត បែរមុខទៅកាន់ព្រះរាជឧទ្យាន ។ កាលនោះ ជនទាំងឡាយឃើញរាជរថស្ទុះទៅដោយរហ័ស ទើបពោលថា អ្នកទាំងឡាយ ចូរញ៉ាំងរាជរថនោះឲ្យត្រឡប់ បុរោហិតឃាត់ថា កុំឲ្យត្រឡប់ឡើយ ទោះបីស្ទុះទៅ

អស់មួយរយយោជន៍ ក៏កុំឲ្យត្រឡប់ ។ រាជរថចូលទៅកាន់រាជឧទ្យាន ធ្វើប្រទក្សិណាផ្ទាំងសិលាមង្គលហើយ ឈប់ត្រៀមទទួលការយាងឡើង បុរោហិតឃើញមហាសត្វផ្ទំ ទើបហៅពួកអមាត្យមកពោលថា បុរសម្នាក់ដេកលើសិលាមង្គលប្រាកដ តែពួកយើងមិនដឹងថា បុរសនោះមានបញ្ញាសមគួរដល់ស្វេតច្ឆត្រឬទេ បើគេមានបញ្ញានឹងមិនក្រោក មិនសម្លឹងមើល បើជាបុគ្គលកាឡកិណី នឹងភ័យខ្លាច ក្រោកឡើងក្រទីក្រទា សម្លឹងមើល ហើយរត់ទៅ អ្នកទាំងឡាយ ចូរប្រគំតន្ត្រីឡើងដោយរហ័ស ជនទាំងពួងក៏ប្រគំតន្ត្រីក្នុងខណៈនោះ សំឡេងតន្ត្រីទាំងនោះ ហាក់ដូចជាកងរំពងពេញផ្ទៃសមុទ្រ ព្រះមហាសត្វភ្ញាក់ដោយសំឡេងនោះ បើកព្រះសិរសាទតឃើញមហាជនហើយទ្រង់ចិន្តនាការថា ស្វេតច្ឆត្រនឹងធ្លាក់មកដល់អញ ដូច្នេះហើយ ទទូរក្បាលដេកទៀត ប្រែព្រះកាយផ្ទំទៅខាងឆ្វេង បុរោហិតបើកព្រះបាទនៃព្រះមហាសត្វត្រួតមើលព្រះលក្ខណៈហើយ ពោលថា កុំថាតែទ្វីបមួយប៉ុណ្ណោះឡើយ បុរសនេះ អាចគ្រប់គ្រងរាជសម្បត្តិ ក្នុងមហាទ្វីបទាំង ៤ បាន ពោលដូច្នេះហើយ ឲ្យប្រគំតន្ត្រីទៀត ។ លំដាប់នោះ ព្រះមហាសត្វទ្រង់បើកព្រះភក្ត្រម្តងទៀត បែរព្រះកាយផ្ទំខាងស្តាំ ទតឃើញមហាជន បុរោហិតឲ្យបរិស័ទថយចេញទៅ ហើយផ្គងអញ្ជលីឱនមុខ ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ក្រោកឡើងចុះ រាជសម្បត្តិមកដល់ព្រះអង្គហើយ លំដាប់នោះ ព្រះមហាសត្វត្រាស់សួរបុរោហិតថា ព្រះរាជារបស់ពួកអ្នកយាងទៅណា កាលបុរោហិតក្រាបទូលថា ទ្រង់សោយទិវង្គត ទើបត្រាស់សួរថា ព្រះរាជឱរស

ឬព្រះរាជកាតារបស់ព្រះរាជានោះមិនមានទេឬ បុរោហិតក្រាបទូលថា បពិត្រព្រះអង្គ មិនមានទេ មានតែព្រះរាជធីតាមួយអង្គប៉ុណ្ណោះ លំដាប់នោះ ព្រះមហាសត្វទ្រង់ស្តាប់ពាក្យរបស់បុរោហិតនោះហើយ ទើបត្រាស់ថា បើយ៉ាងនោះ ជាការល្អហើយ យើងនឹងគ្រប់គ្រងរាជសម្បត្តិ ត្រាស់ដូច្នោះហើយ ទ្រង់ក្រោកឡើងប្រថាប់គង់ពត់ភ្នែនលើផ្ទាំងមង្គលសិលា បន្ទាប់អំពីនោះ ជនទាំងឡាយ មានអមាត្យ និងបុរោហិតជាដើម ក៏ថ្វាយអភិសេកព្រះមហាសត្វក្នុងទីនោះឯង ព្រះមហាសត្វទ្រង់បានព្រះនាមថា មហាជនករាជ ទ្រង់យាងឡើងកាន់រាជរថដ៏ប្រសើរ ចូលព្រះនគរដោយសិរីរាជសម្បត្តិដ៏ធំ ចូលកាន់ព្រះរាជនិវេសន៍ ទ្រង់ពិចារណាថា តំណែងនោះៗ ចូរមានដល់ជននោះៗ មានសេនាបតីជាដើម ហើយឡើងព្រះទីន័ងខាងក្នុង ។

ចំណែកព្រះរាជធីតា ត្រាស់នឹងរាជបុរសម្នាក់ ដើម្បីសាកល្បងព្រះមហាសត្វដោយសញ្ញាដែលមានអំពីមុនថា ចូរអ្នកទៅគាល់ព្រះរាជាក្រាបទូលថា ព្រះនាងសីវលីត្រាស់ឲ្យយាងទៅ សូមទ្រង់ប្រញាប់យាងទៅ អមាត្យនោះក៏ទៅក្រាបទូលព្រះរាជាដូច្នោះ ព្រះរាជាទ្រង់មិនស្តាប់ពាក្យនោះ ទ្រង់ធ្វើដូចជាមិនបានឮ ត្រាស់សរសើរប្រាសាទជាដើមថា ប្រាសាទនេះល្អដូច្នេះ ព្រោះភាពដែលទ្រង់ជាបណ្ឌិត រាជបុរសនោះ មិនអាចឲ្យព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទើបត្រឡប់មកទូលព្រះរាជធីតាថា បពិត្រព្រះនាង ព្រះរាជាមិនស្តាប់ពាក្យរបស់ព្រះនាងទេ រវល់តែមើលប្រាសាទ មិនដាក់ចិត្តក្នុងវាចារបស់ព្រះនាង ដូចបុគ្គលមិនដាក់ចិត្តក្នុងដើមស្មៅដូច្នោះ ព្រះរាជធីតាទ្រង់ត្រិះរិះថា

បុរសនេះមានអធ្យាស្រ័យធំ បញ្ជូនបុរសឲ្យយានមកទៀត អស់ ២-៣ ដង សូម្បីព្រះរាជាក៏យានទៅដោយប្រក្រតី តាមការពេញចិត្តរបស់ព្រះអង្គ ឡើងកាន់ប្រាសាទ ដូចស្តេចរាជសីហ៍ដើរចេញអំពីគុហាដូច្នោះ កាលយានចូលជិតមក ព្រះនាងសីវលីទេវីរាជធីតាមិនអាចតម្កល់ព្រះកាយបានដោយអានុភាពនៃព្រះមហាសត្វ ទើបយានមកថ្វាយឲ្យកៀកព្រះសូរង ព្រះមហាសត្វទ្រង់កៀកកព្រះរាជធីតាឡើងកាន់ព្រះទីន័ង ប្រថាប់លើរាជបល្ល័ង្ក ខាងក្រោមមហាស្វេតច្ឆត្រ ត្រាស់ហៅអមាត្យទាំងឡាយមកត្រាស់សួរថា នែអមាត្យទាំងឡាយ កាលព្រះរាជារបស់ពួកអ្នកទ្រង់សោយទិវង្គត បានត្រាស់អ្វីខ្លះ កាលអមាត្យទាំងឡាយក្រាបទូលថា បានត្រាស់ដែរ ទើបត្រាស់ឲ្យពួកអមាត្យទូលថ្វាយ អមាត្យទាំងឡាយក្រាបទូលថា ព្រះរាជារបស់យើងទាំងឡាយបានត្រាស់ដូច្នេះថា

ឲ្យប្រគល់រាជសម្បត្តិដល់បុគ្គលដែលធ្វើឲ្យព្រះរាជធីតា ព្រះនាមសីវលីត្រេកអរ ព្រះរាជាត្រាស់ថា ព្រះនាងសីវលីរាជធីតាយានមកឲ្យយើងកៀកករបស់ព្រះនាងហើយ សេចក្តីនេះ ឈ្មោះថា យើងបានឲ្យព្រះរាជធីតាប្រោសប្រាណហើយ ចូរអ្នកទាំងឡាយពោលសេចក្តីដទៃចុះ ។ អមាត្យទាំងឡាយទូលបន្តថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នកអាចដឹងក្បាលដំណេក នៃបល្ល័ង្ក ៤ ជ្រុង ថានៅខាងណា ។

ព្រះមហាសត្វទ្រង់ត្រិះរិះថា សេចក្តីនេះដឹងបានលំបាក តែអាចដឹងបានដោយឧបាយ ទើបទ្រង់ដោះស្នៀតសក់អំពីសិរសា ប្រទានដល់ព្រះនាងសីវលី

មានព្រះតម្រាស់ថា ចូរនាងទុកស្នៀតសក់នេះ ព្រះនាងសីវលីរាជធីតាទទួលស្នៀតសក់ ហើយទុកខាងក្បាលដំណេកនៃបល្ល័ង្កនោះ អាចារ្យពួកខ្លះពោលថា ព្រះមហាសត្វប្រទានព្រះខ័នឲ្យព្រះរាជធីតា ព្រះមហាសត្វទ្រង់ជ្រាបថា ខាងនេះជាក្បាលដំណេកដោយសញ្ញានោះ ទ្រង់ធ្វើជាមិនបានឮពាក្យនោះ ទើបត្រាស់សួរថា លោកពោលថ្វី កាលពួកអមាត្យក្រាបទូលដដែលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ការដឹងក្បាលដំណេករបស់បល្ល័ង្ក ៤ ជ្រុង មិនជាអស្ចារ្យទេ ខាងនេះជាក្បាលដំណេក អ្នកទាំងឡាយចូរពោលប្រការបន្តទៀតចុះ អមាត្យទាំងឡាយទូលថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នកដែលលើកធ្នូសហស្សថាមឡើងបាន ។ ព្រះមហាសត្វត្រាស់ឲ្យនាំធ្នូនោះមក ហើយប្រថាប់នារាជបល្ល័ង្កនោះឯង ទ្រង់លើកសហស្សថាមធ្នូឡើង ដូចទ្រង់លើកឧបករណ៍ថ្ពេចសម្ពីរបស់ស្រីទាំងឡាយ ដូច្នោះហើយ ឲ្យប្រាប់សេចក្ដីបន្តទៅទៀត ។ អមាត្យទាំងឡាយទូលថា ឲ្យប្រគល់រាជសម្បត្តិដល់អ្នកនាំកំណប់ទ្រព្យ ១៦ កន្លែង យកមកបាន ។ ព្រះមហាសត្វត្រាស់សួរថា បញ្ហាណាមួយទាក់ទងនឹងកំណប់ទ្រព្យនោះមានដែរឬទេ កាលពួកអមាត្យក្រាបទូលបញ្ហាដែលទាក់ទងនឹងកំណប់ថា មានកំណប់ទ្រព្យត្រង់ព្រះអាទិត្យរះជាដើម ។ ព្រះមហាសត្វទ្រង់ស្តាប់បញ្ហានោះហើយ ឯសេចក្ដីប្រាកដដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត កំពុងអណ្តែតក្នុងលម្ហ ដូច្នោះ ទើបព្រះមហាសត្វត្រាស់ថា ថ្ងៃនេះអស់ពេលហើយ ស្អែកនេះ សឹមជីកកំណប់ទ្រព្យក្នុងទីទាំងឡាយនោះៗ ។ ស្អែកឡើង ព្រះមហាសត្វឲ្យប្រជុំពួកអមាត្យ ហើយត្រាស់សួរថា ព្រះរាជា

របស់ពួកអ្នក និមន្តព្រះបច្ចេកពុទ្ធឲ្យមកឆាន់ដែរឬទេ ក៏ក្រាបទូលថា ធ្លាប់និមន្តមកឆាន់ដែរ ព្រះមហាសត្វត្រិះរិះថា ព្រះអាទិត្យមិនមែនព្រះអាទិត្យដែលមើលឃើញនេះឡើយ ព្រះអាទិត្យ សំដៅយកព្រះបច្ចេកពុទ្ធ ព្រោះមានគុណដូចព្រះអាទិត្យ កំណប់ទ្រព្យគង់មានក្នុងទីទទួលព្រះបច្ចេកពុទ្ធទាំងនោះ ព្រះមហាសត្វក៏ត្រាស់សួរថា កាលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ព្រះរាជាទៅទទួលត្រង់ណា កាលអមាត្យទូលថា ត្រង់ទីឈ្មោះនោះ ក៏ត្រាស់ឲ្យជីកក្នុងទីនោះ នាំកំណប់ទ្រព្យមកបាន ទើបត្រាស់សួរបន្តថា កាលទ្រង់បញ្ជូនព្រះបច្ចេកពុទ្ធត្រឡប់ ទ្រង់ប្រថាប់ឈរត្រង់ណា កាលទ្រង់ជ្រាបថាទីណាហើយ ក៏ឲ្យជីកទីនោះ នាំកំណប់ទ្រព្យមកបាន ។

មហាជនក៏ស្រែកហ៊ោកញ្ជ្រៀវថ្វាយសាធុការ ហើយសរសើរព្រះបញ្ញាសោមនស្សថា ជនទាំងឡាយជីកក្នុងទីព្រះអាទិត្យរះ ព្រោះបញ្ហាពោលថា ទីព្រះអាទិត្យរះ និងជីកក្នុងទីព្រះអាទិត្យលិច ព្រោះបញ្ហាពោលថា ទីដែលព្រះអាទិត្យលិច តែកំណប់ទ្រព្យមានក្នុងទីនេះឯង ឱ អស្ចារ្យហ្ន៎ ចម្លែកហ្ន៎ ។

ព្រះមហាសត្វត្រាស់ឲ្យនាំកំណប់ទ្រព្យ មកអំពីខាងក្នុងធរណីទ្វារ នៃទ្វារធំរបស់ព្រះរាជដ្ឋានបាន ព្រោះបញ្ហាថា កំណប់ទ្រព្យខាងក្នុង ។ ឲ្យជីកនាំកំណប់ទ្រព្យមកអំពីខាងក្រៅធរណីទ្វារ នៃទ្វារធំរបស់ព្រះរាជដ្ឋានបាន ព្រោះបញ្ហាថា កំណប់ទ្រព្យខាងក្រៅ ។ ឲ្យជីកនាំកំណប់ទ្រព្យមកអំពីខាងក្រោមធរណីទ្វារ នៃទ្វារធំរបស់ព្រះរាជដ្ឋានបាន ព្រោះបញ្ហាថា កំណប់ទ្រព្យមិនមែនខាងក្នុង មិនមែនខាងក្រៅ ។ ឲ្យជីកនាំកំណប់ទ្រព្យមកអំពីទីក្រោម

ពោះដំរី ក្នុងពេលទ្រង់ឡើងហត្ថីមង្គលបាន ព្រោះបញ្ហាថា កំណប់ទ្រព្យក្នុងទីឡើង ឲ្យជីកកំណប់ទ្រព្យក្នុងទីដែលទ្រង់ចុះអំពីកដំរីបាន ព្រោះបញ្ហាថា កំណប់ទ្រព្យក្នុងទីចុះ ឲ្យជីកកំណប់ទ្រព្យទាំង ៤ ផ្ទាំង មកអំពីក្រោមជើងរាំងទាំង ៤ កន្លែង ដែលជាជើងព្រះទែនបន្ទំដ៏មានសិរីអំពីផែនដីបាន ព្រោះបញ្ហាថា កំណប់ទ្រព្យត្រង់ជើងរាំងទាំង ៤ ឲ្យជីកនាំផ្ទាំងទ្រព្យទាំងឡាយមកអំពីទីប្រមាណ ១ ជួរទឹមដោយជុំវិញ ព្រះសិរីសេយ្យាសនៈ ដោយការរាប់មួយជួរទឹមរថប្រមាណមួយយោជន៍បាន ព្រោះបញ្ហាថា កំណប់ទ្រព្យក្នុងទីមួយយោជន៍ដោយជុំវិញ ឲ្យជីកកំណប់ទ្រព្យទាំងពីរ ក្នុងទីដែលមង្គលហត្ថី គឺត្រង់ចុងភ្លុកទាំងពីររបស់ដំរីនោះមកបាន ព្រោះបញ្ហាថា កំណប់ទ្រព្យជំត្រង់ចុងភ្លុកដំរីទាំងពីរ ឲ្យជីកកំណប់ទ្រព្យក្នុងទីដែលមង្គលហត្ថីឈរ ត្រង់ចុងកន្ទុយរបស់ដំរីនោះមកបាន ព្រោះបញ្ហាថា កំណប់ទ្រព្យត្រង់ចុងកន្ទុយ ។ ឲ្យបាចទឹកក្នុងស្រះមង្គលបោក្ខរណីបង្ហាញកំណប់ទ្រព្យ ព្រោះបញ្ហាថា កំណប់ទ្រព្យក្នុងទឹក ។ ឲ្យជីកផ្ទាំងទ្រព្យមកអំពីខាងក្រោមស្រមោលម្ចប់រាំង ដែលមានបរិមណ្ឌលក្នុងពេលថ្ងៃត្រង់ ត្រង់គល់រាំងធំក្នុងព្រះរាជឧទ្យានបាន ព្រោះបញ្ហាថា កំណប់ទ្រព្យជំត្រង់ចុងឈើ ព្រះរាជាឲ្យនាំមហាកំណប់ទាំង ១៦ មកបានហើយ ត្រាស់សួរថា បញ្ហាដទៃនៅមានដែរឬ អមាត្យទាំងឡាយក្រាបទូលថា មិនមានឡើយ មហាជននាំគ្នាត្រេកអរពោលថា ឱអស្ចារ្យ ព្រះរាជាអង្គនេះ ជាបណ្ឌិតដោយពិត ។

លំដាប់នោះ ព្រះរាជាត្រិះរិះថា អញនឹងបរិច្ចាគទ្រព្យនេះ ក្នុងទានមុខ

ទើបឲ្យសាងរោងទាន ៦ កន្លែង គឺកណ្ដាលព្រះនគរ ១ ត្រង់ទ្វារនគរទាំង ៤ និងត្រង់ទ្វារព្រះរាជនិវេសន៍ ១ ហើយផ្ដើមឲ្យទាន ព្រះរាជាឲ្យយាងព្រះមាតា និងព្រាហ្មណ៍មកអំពីកាលចម្បាកនគរ ទ្រង់ធ្វើសក្ការធំ កាលព្រះមហាសត្វតាំងនៅក្នុងរាជសម្បត្តិ ក្នុងកាលទ្រង់ជាតរុណរាជកុមារ អ្នកវិទេហរដ្ឋទាំងមូលក៏ត្រេកអរ កាលបានឃើញព្រះអង្គ ដោយគិតថា ព្រះរាជឱរសព្រះបាទអរិដ្ឋជនករាជ ព្រះនាមមហាជនករាជ គ្រងនូវរាជសម្បត្តិ ជាបណ្ឌិតរាជា ជាអ្នកឈ្លាសក្នុងឧបាយ យើងទាំងឡាយមិនឃើញព្រះអង្គ បន្ទាប់អំពីនោះមក មហាជននាំគ្រឿងបណ្ណាការមកថ្វាយ មានមហោស្រពធំក្នុងព្រះនគរ លាតនូវកម្រាលដែលធ្វើដោយដៃជាដើម ក្នុងព្រះរាជនិវេសន៍ សំយុងកម្រងផ្កា និងគ្រឿងក្រអូបជាដើម រោយនូវលាជធ្វើគ្រឿងឧបករណ៍ផ្កា គ្រឿងអប់ និងផ្សេងក្រអូប តម្កល់ទឹក និងភោជនាហារមានប្រការផ្សេងៗ ក្នុងភាជនប្រាក់ ភាជនមាសដើម្បីជាគ្រឿងរាជបណ្ណាការថ្វាយព្រះមហាសត្វ ឈរចោមរោមក្នុងទីនោះៗ ពួកអមាត្យចូលគាល់ក្នុងបារាំ ១ ពួកព្រាហ្មណ៍ចូលគាល់ក្នុងបារាំ ១ ពួកសេដ្ឋីជាដើមក្នុងបារាំ ១ ពួកស្រីស្នំដែលប្រកបដោយរូបសម្បត្តិក្នុងបារាំ ១ ពួកព្រាហ្មណ៍ទាំងឡាយ ក៏នាំគ្នាស្វាធ្យាយមន្ត ដើម្បីឲ្យនូវសួស្តី ពួកពោលជយមង្គលដោយមាត់ ក៏ពោលព្រមគ្នា ថ្វាយជយមង្គលកងរំពង ពួកជនអ្នកជំនាញក្នុងការច្រៀងជាដើម ក៏ច្រៀងថ្វាយ ពួកជនអ្នកប្រគំតន្ត្រី ក៏ប្រគំដោយតន្ត្រីរាប់រយបែប គគ្រឹកគគ្រេង ព្រះរាជនិវេសនដ្ឋាន ក៏បន្ទឺជាសំឡេងតែមួយ ដូចផ្ទៃមហាសមុទ្រដែលត្រូវខ្យល់បក់

នាំមកអំពីក្ដីយុគន្ធរជួច្នោះ ទីដែលព្រះមហាសត្វទតហើយ ក៏ញាប់ញ័រទូទៅ ។

ព្រះមហាសត្វ ប្រថាប់គង់នៅក្នុងព្រះរាជអាសនៈ ខាងក្រោមមហាស្វេតច្ឆត្រ ទតសិរីវិលាសដ៏ធំ ដូចសិរីរបស់សក្កទេវរាជ ទ្រង់រឭកដល់សេចក្ដីព្យាយាមដែលទ្រង់ធ្វើក្នុងមហាសមុទ្រ កាលទ្រង់រឭកដល់សេចក្ដីព្យាយាមនោះ ទើបទ្រង់មានសិការថា ឈ្មោះថា សេចក្ដីព្យាយាម គួរតែធ្វើពិត បើអញមិនបានធ្វើសេចក្ដីព្យាយាមក្នុងមហាសមុទ្រ អញក៏មិនបានសម្បត្តិនេះ កាលទ្រង់រឭកដល់សេចក្ដីព្យាយាមនោះ ក៏កើតបីតិសោមនស្សជ្រួតជ្រាប ទ្រង់ក៏បន្លឺព្រះឧទានដោយកម្លាំងបីតិថា

បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួនឯង យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។ បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន ( ដែលទេវតា ) ស្រង់អំពីទឹកមកដាក់លើគោក ។ បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។ បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន ( ដែលទេវតា ) ស្រង់អំពីទឹកមកដាក់លើគោក ។ នរជនមានប្រាជ្ញាសូម្បីសេចក្ដីទុក្ខប៉ះពាល់ហើយ មិនគប្បីកាត់សេចក្ដីប្រាថ្នា ដើម្បីដល់នូវសេចក្ដីសុខទេ ព្រោះថា ការប៉ះពាល់ដ៏ច្រើនឥតប្រយោជន៍

ក៏មាន មានប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងដល់នូវសេចក្ដីស្លាប់ ។ ហេតុដែលបុគ្គលមិនបានគិតសម្រេចក៏មាន ហេតុដែលបុគ្គលគិតហើយ វិនាសទៅក៏មាន ព្រោះភោគៈទាំងឡាយរបស់ស្ត្រី ឬបុរស មិនមែនសម្រេចដោយការគិតទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាសីសេថេវ** សេចក្ដីថា មិនកាត់នូវសេចក្ដីប្រាថ្នា ធ្វើនូវសេចក្ដីសង្ឃឹមក្នុងការងាររបស់ខ្លួនរឿយៗ ទៅ ។ ក្នុងបទថា **ន និព្វិន្ទេយ្យ** សេចក្ដីថា មិនគប្បីធ្វើសេចក្ដីព្យាយាម កុំនឿយណាយ គឺមិនខ្ជិលច្រអូស ។ បទថា **យថា ឥច្ឆឹ** សេចក្ដីថា យើងបានជាព្រះរាជាដូចប្រាថ្នានោះឯង ។ បទថា **ឧត្ថតំ** បានដល់ នាំចូលទៅជិត គឺនាំចូលទៅហើយ ។ បទថា **ទុក្ខូបនីតោបិ** សេចក្ដីថា សូម្បីទុក្ខផ្លូវកាយ និងផ្លូវចិត្តពាល់ត្រូវហើយ ។ បទថា **អហិតា ហិតា ច** សេចក្ដីថា ទុក្ខសម្ផស្ស ឈ្មោះថាមិនជាប្រយោជន៍ សុខសម្ផស្ស ឈ្មោះថា ជាប្រយោជន៍ ។ បទថា **អវិ-តក្កិតាភោ** បានដល់ មិនត្រិះរិះ គឺមិនគិត លោកអធិប្បាយថា បណ្ដាផស្សៈទាំងនោះ ពួកសត្វដែលផស្សៈមិនមានប្រយោជន៍ពាល់ត្រូវ មិនគិតថា សូម្បីផស្សៈដែលមានប្រយោជន៍ក៏មាន បុគ្គលធ្វើសេចក្ដីព្យាយាម រមែងសម្រេចផស្សៈនោះ មិនគិតដូច្នេះ ទើបមិនធ្វើសេចក្ដីព្យាយាម សត្វទាំងនោះ មិនត្រិះរិះ គឺមិនគិតសេចក្ដីនេះ ទើបមិនបាននូវសម្ផស្សដែលមានប្រយោជន៍ រមែងចូលដល់មច្ចុ គឺដល់នូវសេចក្ដីស្លាប់ ព្រោះដូច្នោះ ឈ្មោះថា សេចក្ដីព្យាយាមគួរធ្វើពិត ។ បទថា **អចិន្តិតម្បិ** សេចក្ដីថា សូម្បីវត្ថុដែលសត្វទាំងនេះ

*មិនបានគិត ក៏រមែងមាន ។ បទថា* **ចិន្តិតម្បិ វិនស្សតិ** *សេចក្តីថា រឿង ដែលយើងគ្រប់គ្រងរាជសម្បត្តិ ដោយមិនបានច្បាំងនេះ យើងមិនបានគិត រឿងដែលយើងជញ្ជូនទ្រព្យអំពីសុវណ្ណភូមិ ដើម្បីមកច្បាំង ហើយគ្រងរាជ-សម្បត្តិនេះ យើងគិត តែរឿងទាំងពីរនោះ រឿងដែលយើងគិត ក៏វិនាសទៅ រឿងដែលយើងមិនបានគិត ក៏កើតឡើង ។ បទថា* **ន ហិ ចិន្តាមយា ភោគា** *សេចក្តីថា ព្រោះថា ភោគៈរបស់សត្វទាំងឡាយ ឈ្មោះថា សម្រេចដោយ ការគិត ក៏មិនមែន ព្រោះមិនបានសម្រេច ដោយការគិត ដូច្នោះ គួរធ្វើនូវ សេចក្តីព្យាយាមនោះឯង ព្រោះវត្ថុដែលមិនបានគិត រមែងមានដល់អ្នកមាន សេចក្តីព្យាយាម ។*

*តាំងអំពីនោះមក ព្រះមហាសត្វទ្រង់បំពេញទសពិធរាជធម៌ ទ្រង់គ្រង រាជសម្បត្តិដោយធម៌ ទ្រង់ផ្គត់ផ្គង់ព្រះបច្ចេកពុទ្ធទាំងឡាយ ក្នុងកាលតមក ព្រះ នាងសីវលីទេវី ប្រសូតព្រះរាជបុត្រដែលសម្បូរដោយលក្ខណៈស្តុកស្តម្ភ និង ភាពជាអ្នកមានបុណ្យ ព្រះមាតាបិតាថ្វាយព្រះនាមថាទីឃាវុរាជកុមារ ។ កាល ទីឃាវុរាជកុមារទ្រង់ចម្រើនវ័យ ព្រះរាជាប្រទានជាឧបរាជ ព្រះរាជាទ្រង់បាន គ្រងរាជសម្បត្តិអស់ ៧ ពាន់ឆ្នាំ ។*

*ថ្ងៃមួយ កាលនាយឧទ្យានបាល នាំផ្លែឈើតូចធំផ្សេងៗ និងផ្កាផ្សេងៗ មកថ្វាយ ព្រះមហាជនករាជទ្រង់ទតឃើញរបស់ទាំងនោះ ទ្រង់ត្រេកអរ ទ្រង់ សរសើរនាយឧទ្យានបាលនោះ ត្រាស់ថា នែឧទ្យានបាល យើងប្រាថ្នានឹង ឃើញឧទ្យាន ចូរអ្នកតាក់តែងឧទ្យាន នាយឧទ្យានបាលទទួលរាជតម្រាស់*

ហើយ ធ្វើតាមព្រះរាជបញ្ជា ហើយក្រាបទូលឲ្យទ្រង់ជ្រាប ។ ព្រះមហាសត្វ ប្រថាប់គង់លើកដំរី ចេញអំពីព្រះនគរដោយរាជបរិវារដ៏ច្រើន ដល់ទ្វារព្រះរាជឧទ្យាន ក្នុងទីជិតទ្វារព្រះរាជឧទ្យាននោះ មានដើមស្វាយ ២ ដើម មានស្លឹកខៀវស្រងាត់ មួយដើមមិនមានផ្លែ មួយដើមមានផ្លែ ផ្លែនោះមានរសផ្អែមពន់ពេក បុគ្គលណាម្នាក់មិនអាចបេះផ្លែអំពីដើមនោះ ព្រោះផ្លែមានរសជាតិក៏ប្រសើរ ព្រះរាជាមិនទាន់បានសោយ ព្រះមហាសត្វប្រថាប់ឈរលើកដំរីទ្រង់បេះយកផ្លែមួយសោយ ផ្លែស្វាយនោះ គ្រាន់តែប៉ះចុងព្រះជិវ្ហារបស់ព្រះរាជា ប្រាកដដូចទិព្វឱជា ព្រះមហាសត្វទ្រង់គិតថា អញនឹងបរិភោគឲ្យច្រើនក្នុងពេលត្រឡប់ ហើយយាងចូលទៅកាន់ព្រះរាជឧទ្យាន ជនដទៃៗ មានឧបរាជជាដើម រហូតដល់អ្នកឃ្វាលដំរី អ្នកឃ្វាលសេះ ដឹងថា ព្រះរាជាសោយផ្លែស្វាយ មានរសដ៏ប្រសើរហើយ ក៏បេះយកផ្លែមកបរិភោគដូចគ្នា ចំណែកអ្នកដែលមិនទាន់បានផ្លែនោះ ក៏ទម្លាយមែកស្វាយដោយដំបង ធ្វើឲ្យជាឈើមិនមានស្លឹក សល់តែដើម និងមែក ស្វាយមួយដើមទៀត តាំងនៅយ៉ាងល្អ ដូចភ្នំកែវមណី ព្រះរាជាយាងចេញអំពីព្រះរាជឧទ្យាន ទតឃើញដូច្នោះ ទើបត្រាស់សួរពួកអមាត្យថា តើមានរឿងអ្វីហ្ន៎ ពួកអមាត្យក្រាបទូលថា មហាជនជ្រាបថា ទ្រង់សោយផ្លែឈើមានរសដ៏ប្រសើរហើយ ជនទាំងអស់ ក៏ដណ្តើមគ្នាបរិភោគនូវផ្លែស្វាយនេះ ព្រះរាជាត្រាស់សួរថា ស្លឹក និងពណ៌សម្បុររបស់ដើមឈើនេះ អស់ទៅហើយ ស្លឹក និងវណ្ណៈរបស់ដើមឈើដទៃ ក៏មិនអស់ទៅ ព្រោះហេតុអ្វី អមាត្យទាំងឡាយក្រាបទូលថា ស្លឹក

និងពណ៌សម្បុររបស់ដើមមួយទៀត មិនអស់ទៅ ព្រោះមិនមានផ្លែ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទ្រង់ដល់នូវសេចក្តីសង្វេគ ទ្រង់ត្រិះរិះថា ដើមនេះ មានពណ៌ខៀវ តាំងនៅហើយ ព្រោះមិនមានផ្លែ តែដើមនេះ ត្រូវបាក់ដល់គល់ ព្រោះមានផ្លែ សូម្បីសម្បត្តិក៏ដូចគ្នានឹងឈើមានផ្លែ បព្វជ្ជាដូចគ្នានឹងឈើមិនមានផ្លែ ភ័យរមែងមានដល់បុគ្គលមានកង្វល់ រមែងមិនមានដល់បុគ្គលដែលមិនមានកង្វល់ ឯយើងនឹងមិនដូចដើមឈើមានផ្លែ នឹងដូចដើមឈើដែលឥតផ្លែ យើងនឹងលះរាជសម្បត្តិចេញបួស ទ្រង់អធិដ្ឋានព្រះហឫទ័យយាងចូលកាន់ព្រះនគរ ឡើងប្រាសាទប្រថាប់ត្រង់ទ្វារប្រាសាទ ឲ្យហៅសេនាបតីមក ត្រាស់ថា ចាប់តាំងអំពីថ្ងៃនេះ ជនដទៃក្រៅអំពីអ្នកបដិបត្តិយើងម្នាក់ ដែលជាអ្នកនាំព្រះក្រយាហារមក និងជាអ្នកថ្វាយទឹកខ្ពុរព្រះឱស្ឋ និងឈើស្ទន់ អ្នកដទៃកុំមករកយើងឡើយ អ្នកទាំងឡាយ ចូរកាន់តាមពួកអមាត្យ ដែលជាអ្នកវិនិច្ឆ័យអំពីបុរាណ ពោលរាជកិច្ចតាំងអំពីថ្ងៃនេះទៅ យើងនឹងចម្រើនសមណធម៌ក្នុងព្រះរាជដំណាក់ខាងលើ កាលត្រាស់ដូច្នេះហើយ ទ្រង់ឡើងកាន់ប្រាសាទ ចម្រើនសមណធម៌មួយអង្គឯងប៉ុណ្ណោះ ។ កាលកន្លងទៅយ៉ាងនេះ មហាជនប្រជុំគ្នាត្រង់លានព្រះរាជវាំង មិនឃើញព្រះមហាសត្វ ក៏ពោលថា ព្រះរាជារបស់ពួកយើងមិនដូចមុន ហើយពោល ២ គាថាថា

ម្នាលគ្នាយើងដ៏ចម្រើន ព្រះរាជាត្រួតត្រានូវផែនដីទាំងមូល ជាម្ចាស់ក្នុងទិស មិនដូចអំពីដើមសោះ ថ្ងៃនេះ មិនទ្រង់ក្រសាលរបាំ មិនទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះចម្រៀង មិនទតម្រឹគ មិន

ទតឧទ្យាន មិនទតហង្ស ទ្រង់គង់នៅស្ងៀម ហាក់ដូចមនុស្សគ
មិនទ្រង់កាត់សេចក្តី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិគេ** ជាពាក្យពោលសរុបដល់សត្វទាំងពួង អធិប្បាយថា ក្នុងកាលមុនទ្រង់ឲ្យដីរីជល់គ្នា ទ្រង់ឲ្យពពែជល់គ្នា ទ្រង់ឲ្យពួកម្រឹគជល់គ្នា ថ្ងៃនេះ ទ្រង់មិនទតសត្វទាំងនោះ ។ បទថា **ឧយ្យានេ** សេចក្តីថា ទ្រង់មិនទតកីឡាក្នុងព្រះរាជឧទ្យាន ។ បទថា **ហំសេ** សេចក្តីថា មិនទតហ្វូងហង្ស ក្នុងស្រះបោក្ខរណី ក្នុងព្រះរាជឧទ្យាន ដែលដេរដាសទៅដោយផ្កាឈូក ៥ ពណ៌ ។ បទថា **មូគោវ** សេចក្តីថា បានឮថា ពួកជនទាំងនោះ សួរអ្នកបម្រើព្រះស្ងោយថា ព្រះរាជាទ្រង់ប្រឹក្សាសេចក្តីណាមួយ ជាមួយពួកលោកដែរឬទេ ជនទាំងនោះពោលថា ទ្រង់មិនប្រឹក្សាឡើយ ព្រោះហេតុនោះ ទើបពោលយ៉ាងនេះ ។

ព្រះរាជាទ្រង់មានព្រះហឫទ័យ មិនជាប់ជំពាក់ក្នុងកាមទាំងឡាយ បង្អោនព្រះហឫទ័យទៅកាន់វិវេក ទ្រង់រឭកដល់ពួកព្រះបច្ចេកពុទ្ធ ដែលជាអ្នកស្និទ្ធស្នាលក្នុងរាជត្រកូល ទ្រង់ត្រិះរិះថា អ្នកណាហ្ន៎ នឹងប្រាប់ទីលំនៅរបស់ព្រះបច្ចេកពុទ្ធដែលប្រកបដោយគុណ មានសីលជាដើម ជាអ្នកមិនកង្វល់ទាំងនោះដល់យើង ហើយទ្រង់បន្លឺឧទាន ៣ គាថាថា

ព្រះបច្ចេកពុទ្ធទាំងឡាយ ទាំងក្មេង ទាំងចាស់ អ្នកប្រាថ្នាសេចក្តី
សុខ មានសេចក្តីស្ងប់ស្ងាត់ជាប្រក្រតី ប្រាសចាកចំណង គឺ
កិលេស គង់នៅក្នុងអារាមនៃបុគ្គលណាហ្ន៎ ក្នុងថ្ងៃនេះ ។ អ្នក

ប្រាជ្ញទាំងឡាយណា បានកន្លងនូវតណ្ហា ជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ នៅក្នុងលោក ដែលកំពុងខ្វល់ខ្វាយ ខ្ញុំសូមថ្វាយបង្គំអ្នកប្រាជ្ញទាំងនោះ ជាអ្នកស្វែងរកនូវគុណដ៏ធំ ។ អ្នកប្រាជ្ញទាំងឡាយនោះ កាត់ទម្លាយនូវតម្បាញ ជាបណ្តាញដ៏មាំរបស់មច្ចុ ដែលមានមាយាចេញទៅរួច បុគ្គលណា គប្បីញុំាងយើងឲ្យដល់នូវគតិ ( លម្អាន ) នៃអ្នកប្រាជ្ញទាំងនោះបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុខកាមា** បានដល់ ជាអ្នកប្រាថ្នាសេចក្តីសុខ គឺព្រះនិព្វាន ។ បទថា **រហោសីលា** សេចក្តីថា មានសីលដែលបិទបាំងហើយ គឺប្រកាសនូវគុណដែលមិនមានទីបំផុត ។ បទថា **វគ្គពន្ធា** បានដល់ចំណង គឺកិលេស ។ បទថា **ឧទារតា** បានដល់ ទៅប្រាសហើយ ។ បទថា **ទហរា វុឌ្ឍា ច** បានដល់ ក្មេងក្តី ចាស់ក្តី ។ បទថា **អច្ឆរេ** បានដល់ រមែងនៅ កាលព្រះរាជាទ្រង់ព្រួកដល់គុណរបស់ព្រះបច្ចេកពុទ្ធទាំងនោះ កើតបីតិឡើងយ៉ាងខ្លាំងក្លា ។ កាលនោះ ព្រះរាជាទ្រង់ក្រោកចាកបល្ល័ង្ក បើកបង្អួចទិសខាងជើង បែរព្រះភក្រ្តទៅទិសឧត្តរ ទ្រង់ប្រតិស្ឋានអញ្ជលីលើសិរសា កាលទ្រង់នមស្ការព្រះបច្ចេកពុទ្ធទាំងឡាយ ដែលប្រកបដោយគុណដ៏ឧត្តមបែបនេះ ទើបត្រាស់ថា **អតិក្កន្តវនថា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អតិក្កន្តវនថា** បានដល់ លះតណ្ហាបានហើយ ។ បទថា **មហេសិនំ** បានដល់ ជាអ្នកស្វែងរកគុណធំ មានសីលក្ខន្ធជាដើមដ៏ច្រើនតាំងនៅ ។ បទថា **ឧស្សុក្កម្ហិ** បានដល់ ជាអ្នកខ្វល់ខ្វាយចាក

ភាគៈជាដើម ។ បទថា **មច្ចុនោ ជាលំ** បានដល់ សំណាញ់ គឺតណ្ហា ដែលកិលេសមារសន្ទឹង ។ បទថា **តន្តំ មាយាវិនោ** សេចក្ដីថា ជាអ្នកមានមាយាក្រៃលែងទាំងឡាយកម្ចាត់ គឺទម្លាយដោយញាណរបស់ខ្លួនហើយទៅ ។ បទថា **កោ តេសំ គតិ មាបយេ** សេចក្ដីថា អ្នកណាគប្បីឲ្យយើងដល់ គឺនាំយើងទៅកាន់និវាសនដ្ឋានរបស់ព្រះបច្ចេកពុទ្ធទាំងនោះ ។

កាលព្រះមហាសត្វទ្រង់ចម្រើនសមណធម៌ លើប្រាសាទនោះឯង ពេលវេលាកន្លងទៅ ៤ ខែ ។ គ្រានោះ ព្រះហឫទ័យរបស់ព្រះអង្គបានបង្អោនទៅក្នុងបព្វជ្ជាយ៉ាងក្រៃលែង ព្រះរាជនិវេសន៍ប្រាកដដូចលោកន្តរនរក ភពទាំង ៣ ប្រាកដដល់ព្រះអង្គដូចរណ្ដៅលាមកដែលត្រូវភ្លើងឆេះ ព្រះមហាសត្វមានព្រះហឫទ័យប្រាថ្នាចំពោះបព្វជ្ជា ទ្រង់ព្រះចិន្តានាការថា កាលណាហ្ន៎ យើងលះក្រុងមិថិលា ដែលប្រដាប់តាក់តែងដូចភពរបស់សក្កទេវរាជនេះ ហើយទៅកាន់ហិមវន្តប្បទេស ទ្រទ្រង់នូវភេទបព្វជិតនឹងមានដល់យើង ទ្រង់គិតដូច្នេះហើយ ទ្រង់ពណ៌នាក្រុងមិថិលាថា

កាលណាអញនឹងលះនគរមិថិលា ជាក្រុងសម្បូណ៌ ដែលជាងថែកហើយ ( ដោយឋាន មានរាជនិវេសន៍ជាដើម ) វាស់ហើយដោយចំណែក ( នៃទ្វារ និងថ្នល់ ) ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ទូលាយ មានពន្លឺដោយជុំវិញ ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណា

អញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង និងខ្លោងទ្វារដ៏ច្រើន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានប៉ម និងស៊ុមទ្វារដ៏មាំមួន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដែលគេចែកល្អ មានផ្លូវធំ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរានផ្សារដែលគេចែកដោយល្អ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដ៏កុះករដោយគោ សេះ និងរថ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃសួន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃឧទ្យាន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃប្រាសាទដ៏ប្រសើរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹង

លះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង ៣ ជាន់ពេញដោយរាជវង្សានុវង្ស ដែលព្រះបាទវិទេហៈ ព្រះនាមសោមនស្ស មានយសទ្រង់សាងទុក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់ដែនវិទេហៈ ជាដែនសម្បូណ៌ បរិបូណ៌ដោយការសន្សំ ( នូវធញ្ញាហារជាដើម ) ដែលរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដែនវិទេហៈ ជាដែនសម្បូណ៌ ដែលបច្ចាមិត្តផ្ចាញ់មិនបាន ជាដែនរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ដែលជាទីរីករាយ ដែលជាងចែកវាស់ដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ជាទីរីករាយ ដែលបូកដោយកំបោរ និងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ជាទីរីករាយ មានក្លិនក្រអូបជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលជាងចែកហើយ វាស់ហើយដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណា

អញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលបូកដោយកំបោរ និងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលមានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលលាបល្អហើយ ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវគ្រែមាសទាំងឡាយ មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវបល្ល័ង្កកែវមណី មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវសំពត់អំបោះ និងសំពត់សូត្រ សំពត់ទាំងឡាយដែលកើតអំពីដែនខោមៈ និងកើតអំពីដែនកោទុម្ពរ ហើយបួស ការលះបង់នោះនឹង សម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាក្រពាកយំទ្រហឹង ដេរដាសដោយចន្ទលណីទាំងឡាយផង ដោយឈូកនិងព្រលិតទាំងឡាយផង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវហ្វូងដំរី

មាតង្គ: ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ មានខ្សែ ជង្គន់មាស មានគ្រឿងស្អាងដោយបណ្ដាញមាស ដែលហ្មដំរីមាន លំពែងស្ទែងក្របី និងកង្វេរក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវហ្វូងសេះអាជានេយ្យអំពីជាតិ ជាសេះសិន្ធព ដែល ស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ ជាវាហនៈលឿន ដែល អ្នកបង្ហាត់សេះកាន់សែ្វ និងធ្នូ ឡើងជិះហើយ ហើយបួស ការ លះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹង លះបង់នូវពួករថប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំង ដោយស្បែកខ្លាដំបង និងខ្លាធំស្អិតស្អាងដោយគ្រឿងអលង្ការទាំង ពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាល ណាអញនឹងលះបង់នូវពួករថមាសប្រដាប់ហើយ មានទង់លើក ហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និង ខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹង សម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថប្រាក់ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លា ដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួក

នាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវរថទឹមសេះប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមឧសុភប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមគោប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមកែះប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដែលនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណា

ហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមពាំពែប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមម្រឹគប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាជំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះដំរី ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ ហើយបួស ការលះបង់នោះ នឹង សម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះសេះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ែ និងធ្នូ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះរថ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងព្រួញក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុង

កាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកខ្មាន់ធ្នូ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកព្រះរាជបុត្រ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអរិយជន គឺព្រាហ្មណ៍ ដែលមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្ដប់ដោយសំពត់ ដែលបានមកអំពីដែនកាសីដ៏ឧត្ដម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអាមាត្យ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ជាអ្នកសង្រួមល្អ មានចង្កេះរៀវ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុង

កាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវស្រីស្នំ ៧០០ ជាស្រ្តីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវភាជន៍មាស មានទម្ងន់ ១០០ បល្វៈ ប្រកបដោយស្នាមចម្លាក់ ១០០ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាហ្វូងដំរីមាតង្គៈរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង មានខ្សែដង្កន់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរី មានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាហ្វូងសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាសេះអាជានេយ្យដោយជាតិ ជាសេះសិន្ធព ជាវាហនៈដ៏លឿន ដែលពួកអ្នករក្សាសេះកាន់ស៊ើ និងធ្នូ ឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថមាសរបស់អញ

ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថប្រាក់របស់អញ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមសេះរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមឱដ្ឋរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុង ដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថទឹមគោរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លា

ដំបង និងខ្វាជំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខ្សែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមកែះរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្វាជំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខ្សែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមពពែរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្វាជំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខ្សែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមម្រឹគរបស់អញប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្វាជំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខ្សែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអ្នកជិះដំរីរបស់អញស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខ្សែលមានពណ៌ខៀវជាអ្នកក្មៀវក្លា មានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ នឹងមិន

ទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអ្នកជិះសេះរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ែ និងធ្នូ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអ្នកជិះរថរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកខ្មាន់ធ្នូរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករាជ-បុត្ររបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកអរិយជន គឺព្រាហ្មណ៍ អ្នកមានសំពត់មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវសំពត់ដ៏ឧត្តម ដែលបានមកអំពីដែនកាសី នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កាលណាពួកអាមាត្យរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ជាស្ត្រីសង្រួមល្អ មានចង្កេះរៀវ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងបានទៅជាអ្នកកោរក្បាល ឃ្លុំសង្ឃាដិ កាន់បាត្រត្រាច់ចរទៅបិណ្ឌបាត ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងទ្រទ្រង់នូវសង្ឃាដិនៃសំពត់បង្សុកូលទាំងឡាយ ដែលគេបោលក្នុងផ្លូវធំ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញ កាលដែលមេឃបង្អុរភ្លៀងចុះអស់ ៧ ថ្ងៃហើយ នឹងត្រាច់ទៅបិណ្ឌបាតទាំងចីវរទទឹក ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងចេញទៅអំពីដើមឈើមួយ ទៅកាន់ដើមឈើ

មួយ អំពីព្រៃមួយ ទៅកាន់ព្រៃមួយ រហូតថ្ងៃ និងយប់ទាំងអស់ ត្រាច់ទៅឥតអាឡោះអាល័យ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងលះបង់នូវភ័យគួរខ្លាច ហើយមិនមានគ្នា ជាគម្រប់ពីរនាក់ ដើរទៅលើជ្រោះភ្នំទាំងឡាយ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញធ្វើចិត្តឲ្យត្រង់ ដូចជាបុគ្គលដេញពិណ អាចដេញខ្សែទាំង ៧ ឲ្យជាទីរីករាយចិត្តបាន ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងកាត់នូវកាមសំយោជន៍ជាទិព្វ ទាំងជារបស់មនុស្សបាន ដូចជាជាងរថកាលកាត់នូវស្បែកជើងដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កទា** ជាបទកំណត់ពេលវេលា ។ បទថា **ដីតំ** សេចក្តីថា ផ្សាយ គឺពេញដោយគ្រឿងប្រដាប់ជាដើម ។ បទថា **វិភត្តំ ភាគសោ មិតំ** សេចក្តីថា ដែលនាយជាងសាងព្រះនគរដ៏ឈ្លាស ចែកស្ថានទីព្រះរាជនិវេសន៍ជាដើម ជាចំណែកទ្វារ និងថ្នល់ ។ បទថា **តំ កទា សុ ភវិស្សតិ** សេចក្តីថា ការលះនូវនគរបែបនេះចេញបួសនោះ នឹងមានក្នុងកាលណា ។ បទថា **សព្វតោ បភំ** សេចក្តីថា ប្រកបដោយពន្លឺនៃគ្រឿងប្រដាប់ដោយជុំវិញ ។ បទថា **ពហុទាការតោរណំ** សេចក្តីថា ប្រកបដោយកំពែងដ៏ក្រាស់ និងខ្លោងទ្វារ ។ បទថា **ឧទ្ធាលមដ្ដាលកោដ្ឋកំ** សេចក្តីថា ប្រកបដោយប៉ម និងខ្លោងទ្វារយ៉ាងមាំទាំ ។ បទថា **បីឡិតំ** សេចក្តីថា ពពាក់ពពូន ។ បទថា **តិបុរំ** សេចក្តីថា ប្រកបដោយកំពែង ៣ ជាន់ គឺ

កំពែង ៣ ជាន់ ម្យ៉ាងទៀត សេចក្ដីថា ព័ទ្ធដោយរបង ៣ ជាន់ ។ បទថា **ភាជពន្ធនី** សេចក្ដីថា ជានគរពេញទៅដោយញាតិវង្សព្ទុវង្ស ៣ តំណនោះឯង ។ បទថា **សោមនស្សេន** សេចក្ដីថា ព្រះបាទវិទេហរាជ មានព្រះនាមយ៉ាងនេះ ។ បទថា **និច្ចិតេ** បានដល់ សន្សំនូវធញ្ញាហារជាដើមដ៏សម្បូណ៌ ។ បទថា **អជេយ្យេ** បានដល់ ពួកបច្ចាមិត្តយកឈ្នះមិនបាន ។ បទថា **ចន្ទន-ផោសិតេ** បានដល់ ប្រោះព្រំដោយចន្ទន៍ក្រហម ។ បទថា **ខោមកោទុម្ពរានិ** បានដល់ សំពត់ដែលកើតក្នុងខោមរដ្ឋ និងកោទុម្ពរដ្ឋ ។ បទថា **ហត្ថិគុម្ពេ** បានដល់ ហ្វូងដំរី ។ បទថា **ហេមកប្បនិវាសសេ** បានដល់ ប្រកបដោយរបស់សម្រេចរូប ពោល គឺគ្រឿងប្រដាប់សិរសា សម្រេចហើយដោយមាសនិងបណ្ដាញមាស ។ បទថា **គាមណីយេភិ** បានដល់ ពួកហត្ថាចារ្យ ។ បទថា **អាជានីយេវ ជាតិយា** បានដល់ ហ្វូងសេះទាំងឡាយបែបនោះ ឈ្មោះអាជានេយ្យ ព្រោះដឹងហេតុ និងមិនមែនហេតុ មានជាតិ ព្រោះសម្បូណ៌ដោយជាតិ ។ បទថា **គាមណីយេភិ** បានដល់ ពួកអស្សាចារ្យ ។ បទថា **ឥន្ទិយា ចាបធារិភិ** បានដល់ ទ្រទ្រង់នូវដាវ និងបំពង់ព្រួញ ។ បទថា **រថសេនិយោ** បានដល់ ពួករថ ។ បទថា **សន្នទ្ធេ** បានដល់ ពាក់នូវក្រោះដោយល្អ ។ បទថា **ទីបេ អថោបិ វេយ្យគ្ឃេ** បានដល់ ស្រោបដោយស្បែកខ្លាដំបង និងខ្លាធំ ។ បទថា **គាមណីយេភិ** បានដល់ ពួករថាចារ្យ ។ បទថា **សណ្ឋាទេ** បានដល់ រថប្រាក់ទឹមដោយពពែ ទឹមដោយកែះ ទឹមដោយម្រឹគ ដើម្បីភាពល្អស្អាត ។ បទថា **អរិយគណោ** បានដល់ ពួកព្រាហ្មណ៍

បានឮថា ព្រាហ្មណ៍ទាំងនោះ ជាអ្នកមានអាចារៈប្រសើរក្នុងពេលនោះ ព្រោះហេតុនោះ ទើបមហាសត្វពោលដល់ព្រាហ្មណ៍ទាំងនោះយ៉ាងនេះ ។ បទថា **ហរិចន្ទនលិត្តង្គ** បានដល់ មានសរីរៈលាបដោយចន្ទន៍ក្រហម ព្រះមហាសត្វពោលថា **សត្តសតា** សំដៅយកកិរិយាជាទីស្រឡាញ់ប៉ុណ្ណោះ ។ បទថា **សុសញ្ញា** បានដល់ សង្រួមហើយដោយល្អ ។ បទថា **អស្សវា** បានដល់ ធ្វើតាមពាក្យសម្តី ។ បទថា **សតបលំ** បានដល់ ធ្វើដោយមាសទម្ងន់ ១០០ បល្លៈ ។ បទថា **កំសំ** បានដល់ ថាស ។ បទថា **សតរាជិកំ** បានដល់ ប្រកបដោយក្បាច់ក្បូរខាងក្រោយ ១០០ ក្បាច់ ។ បទថា **យន្តុំ មំ** សេចក្តីថា ជាអ្នកជាប់តាមទាំងឡាយ កាលណានឹងមិនជាប់តាមអាត្មាអញដែលទៅកាន់ដងព្រៃម្នាក់ឯងប៉ុណ្ណោះ ។ បទថា **សត្តាហំ មេឃេ** បានដល់ កាលភ្លៀងតាំងឡើង ៧ ថ្ងៃ សេចក្តីថា ពេលភ្លៀងធ្លាក់ ៧ ថ្ងៃ ។ បទថា **សព្វណ្ហំ** បានដល់ ទាំងយប់ ទាំងថ្ងៃ ។ បទថា **វីណារុជ្ឈកោ** បានដល់ ដែលលេងពិណ ។ បទថា **កាមសំយោជនេ** បានដល់ គ្រឿងប្រកប គឺកាម ។ បទថា **ទិព្វេ** បានដល់ ជារបស់ទិព្វ ។ បទថា **មានុសេ** បានដល់ ជារបស់មនុស្ស ។

បានឮថា ព្រះមហាសត្វកើតក្នុងកាលដែលមនុស្សមានអាយុ ១ ម៉ឺនឆ្នាំ សោយរាជសម្បត្តិ ៧០០០ ឆ្នាំ ទ្រង់បានចេញបួសក្នុងកាលព្រះជន្មាយុនៅសេសសល់ប្រមាណ ៣ ពាន់ឆ្នាំ កាលទ្រង់ផ្នួសបាននៅក្នុងយាវាសវិស័យ ៤ ខែ ចាប់តាំងពីកាលដែលបានទតឃើញដើមស្វាយត្រង់ទ្វារព្រះរាជឧទ្យាន

ទ្រង់ត្រិះរិះថា ភេទនៃបព្វជិតប្រសើរជាងភេទនៃព្រះរាជានេះ អញនឹងបួស ទើបត្រាស់បញ្ជារាជបុរសអ្នកបម្រើដោយសម្ងាត់ថា ចូរអ្នកនាំសំពត់ជ្រលក់ទឹកអម្ចត់ និងបាត្រដីមកអំពីរានផ្សារ កុំឲ្យនរណាដឹង រាជបុរសនោះបានធ្វើតាមព្រះតម្រាស់ ព្រះរាជាឲ្យហៅភ្នាក់ងារកូសាមាលាមកហើយ ដាក់ព្រះកេសា និងព្រះមស្សុ ព្រះរាជទានស្រុកសួយដល់កូសាមាលាហើយ ឲ្យត្រឡប់ទៅ ទ្រង់ស្លៀកសំពត់កាសាវៈមួយផ្ទាំង ទ្រង់ដណ្តប់មួយផ្ទាំង មួយផ្ទាំងទៀត ពាក់ត្រង់ស្មា ពាក់បាត្រដីត្រង់ចង្កួយស្មា ទ្រទ្រង់នូវឈើច្រត់សម្រាប់មនុស្សចាស់ ពេលនោះ ទ្រង់ចង្ក្រមទៅមកក្នុងប្រាសាទ ដោយបច្ចេកពុទ្ធលីលា អស់ថ្ងៃបន្តិចបន្តួច ទ្រង់បន្លឺឧទានថា ឱ បព្វជ្ជាជាសុខហ្ន៎ ជាសុខយ៉ាងក្រៃលែង ជាសុខដ៏ប្រសើរ ។ ព្រះមហាសត្វទ្រង់ប្រថាប់ក្នុងប្រាសាទនោះឯងអស់ថ្ងៃនោះ លុះស្អែកឡើង ទ្រង់យាងចុះអំពីប្រាសាទក្នុងពេលព្រះអាទិត្យរះ កាលនោះ ព្រះនាងសីវលីទេវី ត្រាស់ហៅស្ត្រីអ្នកស្និទ្ធស្នាល ៧០០ នោះមកត្រាស់ថា ពួកយើងមិនបានឃើញព្រះរាជារបស់យើងទាំងឡាយ ៤ ខែហើយ ថ្ងៃនេះ យើងទាំងឡាយនឹងនាំគ្នាទៅគាល់ទ្រង់ អ្នកទាំងឡាយគប្បីតាក់តែងដោយគ្រឿងអលង្ការទាំងពួង សម្តែងអាកប្បកិរិយាត្រេកអរ និយាយម្រិកម្រ៉ក់ដោយមាយាស្ត្រីជាដើម តាមកម្លាំងព្យាយាមចងព្រះរាជាដោយចំណង គឺកិលេស សូម្បីព្រះទេវី ក៏ព្រះនាងប្រដាប់តាក់តែងព្រះកាយ ហើយឡើងកាន់ប្រាសាទជាមួយស្ត្រីទាំងនោះ ដោយត្រិះរិះថានឹងគាល់ព្រះរាជា សូម្បីទតឃើញព្រះរាជាកំពុងចុះ ក៏ព្រះនាងមិនស្គាល់

ថ្វាយបង្គំព្រះរាជាហើយ ប្រថាប់នៅក្នុងចំណែកម្ខាង ព្រោះព្រះនាងសម្គាល់ថា បព្វជិតនេះ ជាព្រះបច្ចេកពុទ្ធមកថ្វាយឱវាទដល់ព្រះរាជា ចំណែកព្រះមហាសត្វចុះអំពីប្រាសាទ ។ ព្រះទេវីកាលឡើងទៅកាន់ប្រាសាទ ទតឃើញព្រះកេសាព្រះរាជា ដែលមានពណ៌ដូចស្វាបកំភេមលើព្រះសិរីសេយ្យាសនៈ និងកញ្ចប់គ្រឿងអាភរណៈ ទើបត្រាស់ថា បព្វជិតនោះមិនមែនព្រះបច្ចេកពុទ្ធ គឺជាព្រះរាជស្វាមីជាទីស្រឡាញ់របស់ពួកយើង មកអ្នកទាំងឡាយ យើងទាំងឡាយនឹងទូលឲ្យទ្រង់ត្រឡប់ ទើបយាងចុះអំពីប្រាសាទទាន់ព្រះរាជាត្រង់មុខលានព្រះរាជវាំង លុះដល់ ទើបរំសាយកេសាលើខ្នង មួយអន្លើដោយស្ត្រីទាំងនោះ ផ្គងដើមដៃក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ធ្វើយ៉ាងនេះព្រោះហេតុអ្វី ព្រះនាងខ្សឹកខ្សួលយាងតាមព្រះរាជា គួរអាណិតក្រៃលែង ។

កាលនោះ ព្រះនគរទាំងមូល ក៏រំជើបរំជួល ចំណែកអ្នកនគរទាំងនោះពោលថា បានឮថា ព្រះរាជារបស់ពួកយើងទ្រង់បួសហើយ ពួកយើងនឹងបានព្រះរាជា ដែលតាំងនៅក្នុងយុត្តិធម៌បែបនេះអំពីណា ហើយទ្រហោយំដើរតាមព្រះរាជាទៅ ។

ព្រះសាស្តា កាលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសំឡេងខ្សឹកខ្សួល របស់ស្ត្រីទាំងនោះ និងភាពដែលព្រះរាជាទ្រង់លះស្រី ដែលកំពុងយំនោះយាងទៅ ព្រោះហេតុការណ៍នោះ ទើបត្រាស់ថា

ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿង
អលង្ការទាំងពួង ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួក

ខ្ញុំម្ចាស់ព្រោះហេតុអ្វី ។ ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រួមល្អ មានចង្កេះរៀវ ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះបោលពួកខ្ញុំម្ចាស់ព្រោះហេតុអ្វី ។ ពួកស្រីស្នំទាំង ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះបោលពួកខ្ញុំម្ចាស់ព្រោះហេតុអ្វី ។ ព្រះរាជាទ្រង់លះនូវសម្បទ បានលះបង់ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ព្រះអង្គត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវសម្បទ បានលះបង់ពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រួមល្អ មានចង្កេះរៀវ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវសម្បទ បានលះបង់ពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវភាជន៍មាស មានទម្ងន់មួយរយបលៈ ប្រកបដោយស្នាមចម្លាក់មួយរយ បានកាន់យកនូវបាត្រដី ការកាន់នូវបាត្រដីនោះ ទុកជាអភិសេកទី ២ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បគ្គយ្ហ** បានដល់ លើកឡើងហើយ ។ បទថា **សម្បទាំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទមហាជនករាជនោះទ្រង់លះបង់នូវស្រីស្នំ ៧០០ នោះ ដែលកំពុងយំរៀបរាប់ថា ទ្រង់លះពួកខ្ញុំម្ចាស់ យាងទៅតែម្នាក់ឯងធ្វើអ្វី ខ្ញុំម្ចាស់ទាំងឡាយមានកំហុសអ្វីឬ ទ្រង់

បែរមុខគេចទៅ ដូចត្រូវចោទថា សូមទ្រង់យាងចេញបួស ។ បទថា **តំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនោះ ទ្រង់ឱបបាត្រដីនោះ ឲ្យជាអភិសេកលើកទី ២ យាងចេញ ។

ព្រះនាងសីវលីទេវី យំសោក ក៏មិនអាចញ៉ាំងព្រះរាជាឲ្យយាងត្រឡប់បាន ព្រះនាងគិតថា មានឧបាយមួយ ទើបឲ្យហៅមហាសេនាគុត្តមកគាល់ ហើយត្រាស់ថា ចូរអ្នកទៅដុតភ្លើង គឺផ្ទះចាស់ៗ សាលាចាស់ៗ ក្នុងចំណែកទិសខាងមុខដែលព្រះរាជាយាងទៅ ចូរប្រមូលស្មៅ និងស្លឹកឈើនាំមកបំពក់ឲ្យមានផ្សែងច្រើនក្នុងទីនោះៗ មហាសេនាគុត្តបានធ្វើយ៉ាងនោះ ព្រះនាងសីវលីទេវី យាងទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទៀបព្រះយុគលបាទ ក្រាបទូលភាពដែលភ្លើងឆេះក្រុងមិថិលា ២ គាថាថា

ឃ្លាំងទាំងឡាយ គឺឃ្លាំងប្រាក់ ឃ្លាំងមាស ឃ្លាំងកែវមុក្តា ឃ្លាំងកែវពិទូរ្យ ឃ្លាំងកែវមណី ឃ្លាំងស័ង្ខ ឃ្លាំងកែវមុក្តាដ៏ច្រើន ឃ្លាំងសំពត់ ឃ្លាំងខ្លឹមចន្ទន៍ក្រហម ឃ្លាំងស្បែកខ្លាឃ្មុំ ឃ្លាំងរបស់ធ្វើពីភ្លុក ឃ្លាំងទង់ដែង និងឃ្លាំងដែកខ្មៅដ៏ច្រើន ជាឃ្លាំងដែលរាជបុរសរៀបចំដោយចំណែក ត្រូវភ្លើងឆេះ មានអណ្តាតភ្លើងស្មើគ្នាគួរខ្លាច បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យទ្រព្យរបស់ព្រះអង្គនោះវិនាស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភស្មា** បានដល់ គួរខ្លាច ។ បទថា **អគ្គិសាមាជាធា** សេចក្តីថា ផ្ទះទាំងឡាយរបស់មនុស្សនោះៗ កាលភ្លើងឆេះ

ភ្លើងរុងរឿងដោយអណ្តាតស្មើគ្នានោះឯង ។ បទថា **កោសា** បានដល់ ឃ្លាំង ប្រាក់ជាដើមនោះឯង ។ បទថា **ភាគសោ** សេចក្តីថា ព្រះនាងសីវលី ក្រាបទូលថា បពិត្រព្រះអង្គ ឃ្លាំងរបស់យើងទាំងឡាយនោះ បែងចែកជា ចំណែកៗ ត្រូវភ្លើងឆេះអស់ ។ បទថា **លោហំ** បានដល់ ទង់ដែងជាដើម ។ បទថា **មា តេ តំ វិនស្សា ធនំ** សេចក្តីថា សូមទ្រព្យរបស់ព្រះអង្គនោះ កុំបីវិនាសឡើយ អធិប្បាយថា មកចុះ សូមទ្រង់លត់នូវភ្លើងនោះ ទ្រង់នឹង យាងទៅខាងក្រោយ ទ្រង់នឹងត្រូវគេនិន្ទាថា ទ្រង់ចេញទៅដោយមិនសម្លឹង មើលព្រះនគរដែលភ្លើងកំពុងឆេះ ទ្រង់នឹងមានវិប្បដិសារៈព្រោះការខ្មាសនោះ មកចុះ សូមទ្រង់ត្រាស់ឲ្យពួកអាមាត្យលត់ភ្លើងចុះ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់នឹងព្រះនាងសីវលីថា នែព្រះទេវី នាងត្រាស់អ្វីយ៉ាងនោះ ការកង្វល់ដោយរបស់ពួកណាមាន ការកង្វល់នោះ ដោយរបស់ទាំងនោះ ភ្លើងដុតបំផ្លាញ តែយើងមិនកង្វល់ឡើយ កាល ទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់គាថាដូច្នេះថា

កង្វល់មិនមានដល់យើងណា យើងនោះ ឈ្មោះថា រស់នៅជា
សុខ កាលបើក្រុងមិថិលាត្រូវភ្លើងឆេះ ភ្លើងមិនមែនឆេះ នូវ
ទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្ថិ កិញ្ចនំ** សេចក្តីថា ការកង្វល់ ពោល គឺកិលេសគ្រឿងកង្វល់ទាំងឡាយណារបស់យើងមិនមាន យើងទាំងឡាយ នោះ មានជីវិតជាសុខ សុខប្រពៃហ្ន៎ ព្រោះមិនមានសេចក្តីកង្វល់នោះ ដោយ

ហេតុនោះ ព្រះមហាសត្វក៏ត្រាស់ថា កាលក្រុងមិថិលាត្រូវភ្លើងឆេះ គ្មានរបស់ណាមួយរបស់យើងមិនបានឆេះឡើយ សេចក្តីថា យើងមិនឃើញរបស់ផ្ទាល់ខ្លួនរបស់យើង សូម្បីបន្តិចបន្តួច ត្រូវភ្លើងឆេះឡើយ ។

កាលត្រាស់យ៉ាងនេះហើយ ព្រះមហាសត្វបានយាងចេញតាមទ្វារទិសឧត្តរ ស្រីស្នំទាំង ៧០០ នោះ ក៏ចេញតាមព្រះរាជាទៅ ព្រះនាងសីវលីគិតរកឧបាយណាមួយ ទើបត្រាស់បញ្ជាអមាត្យទាំងឡាយថា ចូរពួកអ្នកសម្តែងហេតុការណ៍ឲ្យដូចជាចោរសម្លាប់អ្នកស្រុក និងប្លន់ដែន អមាត្យបានចាត់ការតាមព្រះតម្រាស់ ខណៈនោះ មនុស្សទាំងឡាយ ក៏បង្ហាញពួកបុគ្គលដែលកាន់អាវុធរត់មកអំពីទីនោះៗ ហាក់បីដូចជាត្រូវប្លន់ ស្រោចនូវទឹកល័ក្តលើសរីរៈ ហាក់បីដូចត្រូវប្រហារ ឲ្យដេកលើបន្ទះក្តារ ហាក់បីដូចជាស្លាប់ ត្រូវទឹកបន្សាត់ទៅចំពោះព្រះរាជា មហាជនទូលព្រះរាជាថា បពិត្រមហារាជ ពួកចោរប្លន់ដែន សម្លាប់ប្រជានុរាស្ត្ររបស់ព្រះអង្គ ទាំងដែលទ្រង់គង់ព្រះជន្មសូម្បីព្រះទេវី ក៏ថ្វាយបង្គំព្រះរាជា ត្រាស់គាថាដើម្បីឲ្យទ្រង់យាងត្រឡប់ថា

ចោរក្នុងដងព្រៃ កើតឡើងហើយ បំផ្លាញដែនរបស់ព្រះអង្គ
បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ
កុំឲ្យដែននេះវិនាស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អដវិយោ** សេចក្តីថា បពិត្រមហារាជ កាលទ្រង់តម្កល់ព្រះជន្មនៅនោះឯង ចោរព្រៃកើតឡើងហើយ ។ បទថា **រដ្ឋំ** សេចក្តីថា ពួកចោរទម្លាយដែនរបស់ព្រះអង្គ ដែលធម៌រក្សាហើយបែបនោះ

សូមទ្រង់យាងមក សូមទ្រង់ត្រឡប់ចុះ ដែនរបស់ទ្រង់កុំបីវិនាសឡើយ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ មានព្រះតម្រិះថា កាលយើងនៅមានជីវិត នឹងមិនកើតចោរប្លន់ទម្លាយនូវដែនឡើយ នេះនឹងជាការធ្វើរបស់ព្រះនាងសីវលី កាលទ្រង់ធ្វើព្រះនាងឲ្យទញ់ទាល់នូវពាក្យសម្តី ទើបត្រាស់ថា

កង្វល់មិនមានដល់យើងណា យើងនោះ ឈ្មោះថា រស់នៅជាសុខ កាលបើដែនត្រូវពួកចោរប្លន់ ចោរមិនបានយកទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ កង្វល់មិនមានដល់យើងណា យើងនោះ ឈ្មោះថា រស់នៅជាសុខ យើងជាអ្នកមានបីតិជាអាហារ ដូចពួកអាភស្សរទេវតា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិលុម្បមានម្ហិ** បានដល់ ត្រូវពួកចោរប្លន់ ។ បទថា **អាភស្សរា យថា** សេចក្តីថា ព្រហ្មទាំងនោះ ជាអ្នកមានបីតិជាភក្ខាញុំាងកាលវេលាឲ្យកន្លងទៅដោយសេចក្តីសុខក្នុងសមាបត្តិ យ៉ាងណា យើងនឹងញុំាងកាលវេលាឲ្យកន្លងទៅយ៉ាងនោះ ។

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ មហាជនក៏នៅតែទៅតាមព្រះអង្គនោះឯង ព្រះមហាសត្វមានព្រះតម្រិះថា មហាជនទាំងនេះមិនប្រាថ្នាត្រឡប់អញនឹងឲ្យមហាជននោះត្រឡប់ កាលទ្រង់ធ្វើដំណើរទៅបានកន្លះគាវុត ទ្រង់ក៏ឈប់សម្រាក ប្រថាប់ឈរក្នុងផ្លូវធំ ត្រាស់សួរអមាត្យទាំងឡាយថា រាជ-សម្បត្តិនេះជារបស់អ្នកណា អមាត្យទាំងឡាយក្រាបទូលថា ជារបស់ព្រះអង្គព្រះរាជាត្រាស់ថា បើយ៉ាងនោះ អ្នកទាំងឡាយ ចូរដាក់រាជទណ្ឌដល់បុគ្គល

ណាដែលធ្វើស្នាមគំនូសនេះឲ្យរលប់ ត្រាស់ដូច្នេះហើយ ទ្រង់យកឈើច្រត់ធ្វើឲ្យមានស្នាមទទឹងផ្លូវ បុគ្គលណាម្នាក់ក៏មិនហ៊ានធ្វើស្នាមគំនូស ដែលព្រះរាជាអ្នកមានតេជានុភាព ទ្រង់បានគូសឲ្យរលប់ឡើយ មហាជនធ្វើស្នាមគំនូសលើក្បាលយំសោក ព្រះនាងសីវលីក៏ទ្រង់មិនអាចធ្វើស្នាមគំនូសឲ្យរលប់បាន ទតឃើញព្រះរាជាបែរខ្នងយាងទៅ មិនអាចអត់ធន់នូវសេចក្តីសោកបាន ក៏ផ្តួលព្រះឱរ្ស បម្រះនទៀលទៅមក រំលងស្នាមគំនូសនោះទៅ មហាជនយល់ថា ម្ចាស់របស់គំនូសបានទម្លាយនូវស្នាមគំនូសហើយ ទើបនាំគ្នាតាមព្រះរាជាទៅ តាមមាគ៌ាដែលព្រះទេវីទៅនោះឯង ព្រះមហាសត្វបែរព្រះភក្ត្រទៅកាន់ហិមវន្តប្បទេសនាទិសឧត្តរ ចំណែកព្រះនាងសីវលីទេវី ក៏នាំពលសេនាពាហនៈទាំងពួង តាមព្រះរាជាទៅដែរ ព្រះរាជាទ្រង់មិនអាចឲ្យមហាជនត្រឡប់បាន ទ្រង់យាងទៅអស់ផ្លូវប្រមាណ ៦០ យោជន៍ ។

ក្នុងកាលនោះ មានតាបសមួយរូបឈ្មោះនារទៈ នៅត្រង់សុវណ្ណគុហាក្នុងហិមវន្តប្បទេស ឲ្យកាលវេលាកន្លងទៅដោយសុខ ដែលកើតអំពីឈានដែលសម្បយុត្តដោយអភិញ្ញា ៥ រំលង ៧ ថ្ងៃ ក៏ចេញអំពីសុខដែលកើតអំពីឈាន បន្លឺឧទានថា ឱ សុខហ្ន៎ សុខក្រៃលែងហ្ន៎ ហើយរំពឹងមើលសត្វលោកដោយទិព្វចក្ខុថា អ្នកណាហ្ន៎ក្នុងជម្ពូទ្វីប ស្វែងរកសេចក្តីសុខនេះ មានដែរឬទេហ្ន៎ ឃើញព្រះមហាជនកដែលជាបណ្តូលពុទ្ធង្កុរ ទើបគិតថា មហាជនកនេះ ជាព្រះរាជាចេញមហាភិនេស្រ្កមណ៍ មិនអាចញុំាងមហាជន និងពួករាជបរិវារ មានព្រះនាងសីវលីទេវីជាប្រធាន ឲ្យត្រឡប់ទៅនគរបាន រាជ-

បរិវារនោះ គប្បីធ្វើអន្តរាយដល់ព្រះអង្គ អញនឹងថ្វាយឱវាទដល់ព្រះអង្គ ដើម្បីឲ្យទ្រង់សមាទានមាំក្រៃលែងដោយប្រមាណ ទើបទៅដោយកម្លាំងឫទ្ធិ ស្ថិតនៅក្នុងអាកាសចំពោះព្រះភក្ត្រព្រះរាជា ពោលនូវគាថា ឲ្យទ្រង់កើតនូវឧស្សាហ៍ថា

សំឡេងគឹកកងនៃជនច្រើននេះ តើព្រោះហេតុអ្វី ស្ត្រីនោះជាអ្វី
លេងជាមួយក្នុងព្រៃ ដូចក្នុងស្រុក បពិត្រសមណៈ ខ្ញុំសួរលោក
ថា មហាជនទុំះ ប្រជុំគ្នាដើម្បីអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិម្ហេសោ** សេចក្តីថា គឹកកងនៃប្រជុំជនធំមានហ្វូងដំរីជាដើមនេះ ព្រោះហេតុអ្វី ។ បទថា **កាន្ុ គាមេវ កីឡិយា** សេចក្តីថា ទុំះនរណាហ្ន៎ មកជាមួយអ្នក ហាក់បីដូចលេងកីឡាជាមួយគ្នាក្នុងស្រុក ។ បទថា **កាត្ថេសោ** បានដល់ មហាជននេះ មកដើម្បីអ្វី ។ បទថា **អភិសដោ** សេចក្តីថា មហាជនប្រជុំគ្នា ចោមរោមអ្នកមក នារទតាបសសួរដូច្នេះ ។ ព្រះរាជាត្រាស់តបថា

ខ្ញុំកាលលះបង់នូវមហាជន ហើយចេញទៅ បានជាមហាជន
ប្រជុំគ្នាក្នុងទីនេះ ខ្ញុំកន្លងនូវដែន គឺកិលេស ហើយទៅបួស ដើម្បី
បាននូវមោនធម៌ ( ពោល គឺញាណរបស់អនាគារិយៈ ) មុនី
ខ្ញុំកាលទៅកាន់ទីប្រឡូកប្រឡំ ដោយសេចក្តីរីករាយទាំងឡាយ
អ្នកដឹង ទើបសួរឬ ( ឬមិនដឹង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មមំ** សេចក្តីថា ខ្ញុំលះជនទៅ ទើបខ្ញុំនោះ

ជាអ្នកលះទៅ ។ បទថា **ឋត្ត** សេចក្តីថា មហាជននេះ ចោមរោមហើយ គឺ ជាប់តាមមកក្នុងទីនេះ ។ បទថា **សីមាតិក្កមធំ យន្តំ** សេចក្តីថា ហេតុអ្វីទើប អ្នកសួរខ្ញុំដែលជាអ្នកកន្លងដែន គឺកិលេសទៅ គឺបួសដើម្បីដល់នូវមោនធម៌ ពោល គឺញាណរបស់មុនី ដែលជាអនាគារិយៈ គឺអ្នកមិនមានផ្ទះ ។ បទថា **មិស្សំ ឆន្ទីហិ គច្ឆន្តំ** សេចក្តីថា អ្នកដឹងឬ ឬមិនដឹងថាខ្ញុំបួសហើយ ទើបសួរ ខ្ញុំដែលមិនទាន់លះសេចក្តីត្រេកអរ លាយឡំដោយសេចក្តីត្រេកអរទាំងឡាយ ដែលកើតឡើងក្នុងខណៈនោះៗ ទៅ គឺអ្នកមិនបានស្តាប់ដំណឹងខ្លះទេឬថា បានឮថា ព្រះមហាជនកលះបង់វិទេហរដ្ឋបួស ។

លំដាប់នោះ នារទតាបសពោលគាថាទៀត ដើម្បីឲ្យមហាសត្វ សមាទានមាំថា

ព្រះអង្គ កាលទ្រទ្រង់នូវសរីរៈនេះ កុំសម្គាល់ថា អញឆ្លង
កិលេសហើយ ដូច្នេះ កម្ម ( គឺកិលេស ) នេះ បុគ្គលមិនគប្បី
ឆ្លងបានទេ ព្រោះថា សេចក្តីអន្តរាយមានច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាស្សុ តិណ្ណោ អមញ្ញិត្ថោ** សេចក្តីថា អ្នកទ្រទ្រង់នូវសរីរៈនេះ គឺទ្រទ្រង់នូវបព្វជិតបរិក្ខារ និងសំពត់កាសាវៈ កុំ យល់ថា អញឆ្លងហើយ គឺឈានកន្លងហើយនូវដែននៃកិលេសដោយហេតុ ត្រឹមតែភេទ គឺបព្វជិតនេះ ។ បទថា **អតីរណេយ្យមិទំ** សេចក្តីថា ឈ្មោះ ថា កិលេសនេះ មិនមែនឆ្លងបានដោយហេតុមានប្រមាណប៉ុណ្ណោះឡើយ ។ បទថា **ពហូ ហិ បរិបន្ថយោ** សេចក្តីថា ព្រោះថា អន្តរាយ គឺកិលេសរបស់

ទ្រង់ ដែលរាកាំងនូវស្ថានសួគ៌ មានច្រើន ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា

ខ្ញុំណា មិនប្រាថ្នានូវកាមទាំងឡាយ ក្នុងមនុស្សលោក ដែលបុគ្គលឃើញហើយ មិនប្រាថ្នានូវកាមទាំងឡាយ ក្នុងទេវលោក ដែលបុគ្គលមិនឃើញហើយ សេចក្តីអន្តរាយដូចម្តេចហ្ន៎ នឹងមានដល់ខ្ញុំនោះ មានកិរិយាទៅយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ នេវ ទិដ្ឋេ នាទិដ្ឋេ** សេចក្តីថា ខ្ញុំមិនប្រាថ្នានូវកាមទាំងឡាយក្នុងមនុស្សលោក ដែលបុគ្គលឃើញហើយក៏មិនមែន ក្នុងទេវលោកដែលបុគ្គលមិនឃើញហើយក៏មិនមែន អន្តរាយអ្វីហ្ន៎ គប្បីមានដល់ខ្ញុំនោះ ដែលជាអ្នកមានប្រក្រតីម្នាក់ឯងយ៉ាងនេះ ព្រះមហាសត្វត្រាស់ដូច្នេះ ។

លំដាប់នោះ នារទតាបសកាលសម្តែងអន្តរាយទាំងឡាយ ដល់ព្រះមហាសត្វ ទើបពោលគាថាដូច្នេះថា

ដ្បិតថា សេចក្តីអន្តរាយ តាំងឡើងច្រើន គឺការដេកលក់ សេចក្តីខ្ជិល ការមិតពត់ សេចក្តីអផ្សុក ការពុលបាយ តាំងនៅក្នុងសរីរៈ រមែងកើត ( ក្នុងសរីរៈវិញ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និទ្ទា** បានដល់ ដេកលក់ដូចស្វា ។ បទថា **តន្ទិ** បានដល់ ខ្ជិលប្រអូស ។ បទថា **អរតិ** បានដល់ មិនត្រេកអរ គឺអផ្សុក ។ បទថា **ភត្តសម្មទោ** បានដល់ ការស្រវឹងក្នុងភត្តាហារ លោក

អធិប្បាយដូច្នេះថា នៃសមណៈ ទ្រង់មានព្រះរូបគួរជ្រះថ្លា មានពណ៌សម្បុរដូចមាស កាលទ្រង់ត្រាស់ថា អាត្មាលះរាជសម្បត្តិចេញបួស មនុស្សទាំងឡាយនឹងថ្វាយបិណ្ឌបាត ដែលជាបណីតឱជាដល់ទ្រង់ ទ្រង់ទទួលល្មមពេញបាត្រ សោយល្មមសមគួរហើយ ចូលកាន់បណ្ណសាលា ផ្ទំក្នុងទីដែលក្រាលដោយស្លឹកឈើលក់ស្រមុក ភ្ញាក់ក្នុងចន្លោះៗ ប្រែប្រួលទៅមក ទ្រង់លាព្រះហស្ត និងព្រះបាទ ក្រោកឡើងចាប់ស្អួចីវរ ខ្ជិលច្រអូស មិនចាប់អំបោសបោសអាស្រម មិននាំទឹកផឹកមក ផ្ទំលក់ទៀត ត្រិះរិះដល់កាមវិតក្ក កាលនោះ ក៏មិនពេញព្រះហឫទ័យក្នុងបព្វជ្ជា ការក្រវល់ក្រវាយព្រោះកត្តាហារនឹងមានដល់ព្រះអង្គ ដោយប្រការដូច្នេះ ។ បទថា **អាវសន្តិ សរីរដ្ឋា** សេចក្តីថា អន្តរាយទាំងនេះ មានប្រមាណប៉ុណ្ណេះ តាំងនៅក្នុងសរីរៈរបស់ទ្រង់ អាស្រ័យនៅ គឺកើតក្នុងសរីរៈរបស់ទ្រង់នោះឯង នារទតាបសសម្តែងដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វកាលសរសើរនារទតាបសនោះ ទើបត្រាស់គាថាដូច្នេះថា

បពិត្រព្រាហ្មណ៍ លោកដ៏ចម្រើនប្រៀនប្រដៅខ្ញុំល្អណាស់
បពិត្រព្រាហ្មណ៍ ខ្ញុំសួរលោក បពិត្រលោកនិទ្ទុក្ខ លោកជាអ្វី
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្រាហ្មណ អនុសាសសិ** សេចក្តីថា បពិត្រព្រាហ្មណ៍ លោកប្រៀនប្រដៅខ្ញុំល្អណាស់ ។ លំដាប់នោះ នារទតាបស

ពោលថា

ជនទាំងឡាយ ស្គាល់អាត្មភាព ដោយនាមថា នារទៈ ដោយគោត្រថា កស្សបៈ ដូច្នេះ អាត្មាភាពមកក្នុងសម្នាក់ព្រះអង្គដ៏ចម្រើន ដោយដឹងច្បាស់ថា សមាគមដោយសប្បុរសទាំងឡាយ ជាកិច្ចញុំាងប្រយោជន៍ឲ្យសម្រេច ។ សេចក្តីត្រេកអរ ( ក្នុងបព្វជ្ជា ) ទាំងអស់ និងព្រហ្មវិហារ ចូរកើតដល់ព្រះអង្គនោះចុះ បរិកម្ម និងឈានណា ការខ្វះខាត ( ដោយសីល និងឈាន ) ណា ព្រះអង្គចូរបំពេញនូវការខ្វះខាតនោះចុះ ព្រះអង្គ ( ចូរប្រកប ) ដោយអធិវាសនក្ខន្តិ និងឧបសមៈ ។ ព្រះអង្គចូររំសាយចោលនូវសេចក្តីមើលងាយ និងសេចក្តីក្រអឺតក្រអោង ចូរធ្វើគោរពនូវកុសលកម្ម នូវវិជ្ជា និងធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិទូ** សេចក្តីថា ជនទាំងឡាយ ស្គាល់អាត្មាដោយឈ្មោះ និងគោត្រថា កស្សបៈ ។ បទថា **សត្តិ** សេចក្តីថា ឈ្មោះថាសមាគមជាមួយបណ្ឌិតទាំងឡាយ ជាការញុំាងប្រយោជន៍ឲ្យសម្រេច ព្រោះហេតុនោះទើបអាត្មាមក ។ បទថា **អាណន្ទោ** សេចក្តីថា ការត្រេកត្រអាល គឺការត្រេកអរ ចូរសេចក្តីពេញចិត្តក្នុងបព្វជ្ជានេះមានដល់ទ្រង់ កុំនឿយណាយឡើយ ។ បទថា **វិហារោ** បានដល់ ព្រហ្មវិហារធម៌ ៤ យ៉ាង ។ បទថា **ឧបវត្តតុ** បានដល់ ចូរកើតឡើង ។ បទថា **យទូនំ** សេចក្តីថា កិច្ចដោយសីល ដោយកសិណបរិកម្ម ដោយឈាននោះ គង់នៅធូរថយ ចូរទ្រង់ញុំាង

កិច្ចនោះឲ្យបរិបូណ៌ដោយគុណ មានសីលជាដើមនេះ ។ បទថា **ខន្តិយា ឧបសមេន ច** សេចក្តីថា ទ្រង់កុំបីមានមានះថា អញជាព្រះរាជបព្វជិត ចូរជាបុគ្គលប្រកបដោយអធិវាសនក្ខន្តី និងការស្ងប់រម្ងាប់កិលេស ។ បទថា **បសារយ** សេចក្តីថា កុំលើកខ្លួន កុំប្រកាន់ខ្លួន គឺចូរលះបង់នូវមានះ ។ បទថា **សន្នតញ្ច ឧន្នតញ្ច** សេចក្តីថា ចូរប្រាសចាកនូវមានះដែលប្រព្រឹត្តទៅដោយន័យជាដើមថា អញមានជាតិត្រកូល និងអតិមានះ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា អញសម្បូរដោយជាតិ ។ បទថា **កម្មំ** បានដល់ កុសលកម្មបថ ១០ ។ បទថា **វិជ្ជំ** បានដល់ ញាណដែលប្រព្រឹត្តទៅក្នុងអភិញ្ញា ៥ និងសមាបត្តិ ៨ ។ បទថា **ធម្មំ** បានដល់ សមណធម៌ ពោលគឺកសិណបរិកម្ម ។ បទថា **សក្កត្វាន បរិព្វជ** សេចក្តីថា ចូរធ្វើដោយគោរពនូវគុណធម៌ទាំងនោះ ប្រព្រឹត្តទៅ ឬចូរធ្វើដោយគោរពនូវគុណធម៌ទាំងនេះ សមាទានឲ្យមាំ បំពេញព្រហ្មចរិយៈ គឺចូររក្សាបព្វជ្ជា កុំបីនឿយណាយឡើយ ។

នារទតាបសនោះ ថ្វាយឱវាទដល់មហាសត្វយ៉ាងនេះហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនតាមអាកាស ។

កាលនារទតាបសទៅហើយ មានតាបសមួយរូបទៀត ឈ្មោះមិគាជិនៈ ចេញអំពីសមាបត្តិ ត្រួតមើលលោកសន្និវាស ឃើញព្រះមហាសត្វ ទើបមកហើយដូចគ្នា ដោយគិតថា អញនឹងថ្វាយឱវាទដល់ព្រះមហាសត្វ ដើម្បីប្រយោជន៍ឲ្យមហាជនត្រឡប់ទៅព្រះនគរ ទើបស្ថិតនៅក្នុងអាកាស បង្ហាញ

ខ្ជួនឲ្យប្រាកដ ហើយពោលថា

បពិត្រព្រះជនក ព្រះអង្គលះបង់ដីរ សេះ ពួកអ្នកនគរ និង ជនបទជាច្រើន ហើយទ្រង់ព្រះផ្នួស ដល់នូវសេចក្ដីត្រេកអរនឹងអំបែង បពិត្រព្រះជនក ពួកអ្នកជនបទ មិត្ត អាមាត្យ និងព្រះញាតិ បានធ្វើនូវការទ្រុស្ត ចំពោះព្រះអង្គខ្លះដែរឬ ព្រោះហេតុអ្វីក៏ព្រះអង្គពេញព្រះហឫទ័យ នឹងអំបែងរបស់ព្រះអង្គនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កថាលេ** ក្នុងគាថានោះ លោកពោលសំដៅដល់បាត្រដី មានពាក្យអធិប្បាយថា កាលមិគាជិនតាបសសួរដល់ហេតុនៃបព្វជ្ជា ទើបពោលយ៉ាងនេះថា បពិត្រមហាជនក ទ្រង់លះនូវភាពជាធំបែបនេះបួសហើយ ទ្រង់ត្រេកអរក្នុងបាត្រដីនេះ ។ បទថា **ទុភី** សេចក្ដីថា ពួកគេទាំងនោះ បានធ្វើនូវកំហុសអ្វីក្នុងរវាងទ្រង់ដែរឬ ព្រោះហេតុអ្វី ទើបទ្រង់លះនូវឥស្សរិយសុខបែបនេះ មកពេញព្រះហឫទ័យបាត្រដីប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ ព្រះមហាសត្វត្រាស់ថា

បពិត្រមិគាជិនៈ ក្នុងកាលណាមក ខ្ញុំមិនដែលផ្ចាញ់ នូវញាតិណាមួយ ដោយអធម៌ជាដាច់ខាត ទាំងពួកញាតិ ក៏មិនដែលផ្ចាញ់ខ្ញុំដោយអធម៌ដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន មិគាជិន** បានដល់ បពិត្រមិគាជិនៈដ៏ចម្រើន ។ បទថា **ជាតុច្ចេ** ប្រែថា ដោយចំណែកមួយនោះឯង ។ បទថា **អហំ កញ្ចិ កុទាចនំ** សេចក្ដីថា ខ្ញុំមិនបានផ្ចាញ់នូវញាតិណាមួយ ក្នុងកាល

ណាមួយដោយអធម៌ សូម្បីញាតិទាំងនោះ ក៏មិនបានផ្ចាញ់នូវខ្ញុំដោយអធម៌ អធិប្បាយថា មិនមានញាតិណា បានធ្វើនូវកំហុសក្នុងខ្ញុំឡើយ ដោយប្រការដូច្នេះ ។

ព្រះមហាសត្វទ្រង់ឃាត់នូវបញ្ហា នៃមិគាជិនតាបសនោះយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងហេតុនៃការបួស ទើបត្រាស់ថា

បពិត្រមិគាជិនៈ ខ្ញុំបានឃើញនូវប្រវេណី នៃសត្វលោក ដែលកិលេសកំពុងទំពាស៊ី ធ្វើឲ្យដូចជាភក់ បុថុជ្ជនលិចចុះហើយ ក្នុងកិលេសវត្ថុណា សត្វទាំងឡាយ តែងបៀតបៀនគ្នាផង តែងជាប់ក្នុងកិលេសវត្ថុនោះផង ហើយក៏ធ្វើនូវពួកបុថុជ្ជនទាំងនេះ ឲ្យជាគ្រឿងប្រៀបធៀប ទើបបួសជាភិក្ខុ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លោកវត្តន្តំ** សេចក្តីថា ខ្ញុំបានឃើញវត្ត គឺបវេណីរបស់សត្វលោកល្វង់ខ្វៅ ប្រព្រឹត្តទៅតាមវដ្តៈ ព្រោះឃើញដូច្នោះ ទើបខ្ញុំបួស ព្រះមហាសត្វទ្រង់សម្តែង ដូច្នេះ ។ បទថា **ខជ្ជន្តំ កទ្ទមីកតំ** សេចក្តីថា ឃើញសត្វលោកត្រូវកិលេសទំពាស៊ី ត្រូវកិលេសទាំងនោះឯងធ្វើឲ្យដូចជាភក់ ។ បទថា **យត្ថ សន្នោ** សេចក្តីថា បុថុជ្ជនលិចចុះ គឺជាប់ជំពាក់ គឺលិចចុះក្នុងកិលេសវត្ថុណា សត្វទាំងឡាយជាច្រើន ជាប់ជំពាក់ក្នុងកិលេស-វត្ថុនោះ រមែងត្រូវសម្លាប់ខ្លះ រមែងជាប់ក្នុងគ្រឿងចង មានប្រវាក់ និងពន្ធនាគារជាដើមខ្លះ ។ បទថា **ឯតាហំ** សេចក្តីថា បើខ្ញុំជាប់ក្នុងកិលេសវត្ថុនេះ ខ្ញុំក៏នឹងត្រូវសម្លាប់ ត្រូវចងដូចសត្វទាំងនោះ ដូច្នោះ ទើបធ្វើហេតុការណ៍

នោះឯងឲ្យជាឧបមានៃខ្លួនហើយ បួសជាភិក្ខុ ទើបព្រះមហាសត្វហៅតាបស នោះថា មិគាជិនៈ ព្រះមហាសត្វទ្រង់ជ្រាបឈ្មោះរបស់តាបសនោះបានដូចម្តេច ទ្រង់ជ្រាប ព្រោះទ្រង់សួរមុន ក្នុងពេលបដិសណ្ឋារៈ ។

តាបសប្រាថ្នានឹងស្តាប់ហេតុការណ៍នោះដោយពិស្តារ ទើបពោលគាថាដូច្នេះថា

បពិត្រព្រះអង្គប្រសើរក្នុងរថ បុគ្គលមានជោគណា ជាសាស្តា
របស់ព្រះអង្គ ពាក្យដ៏ពីរោះនេះ ជាពាក្យរបស់បុគ្គលណា ព្រោះ
ថា អ្នកប្រាជ្ញទាំងឡាយ មិនរៀននូវតាបស អ្នកសម្រេចអភិញ្ញា
ឬនូវព្រះបច្ចេកពុទ្ធ ដែលប្រកបដោយវិជ្ជា ហើយពោលនូវ
សមណៈថា អ្នកមានវត្ត ជាគ្រឿងកន្លងនូវទុក្ខទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កស្សេតំ** សេចក្តីថា ពាក្យដ៏ស្អាតនេះ គឺដែលលោកពោល ជាពាក្យរបស់អ្នកណា ។ បទថា **កប្បំ** បានដល់ តាបសជាកម្មវាទី ជាអ្នកមានអភិញ្ញាសមាបត្តិ ដែលសម្រេចប្រព្រឹត្តទៅហើយ ។ បទថា **វិជ្ជំ** បានដល់ ព្រះបច្ចេកពុទ្ធដែលប្រកបដោយវិជ្ជា គឺអាសវក្ខយញ្ញាណ លោកអធិប្បាយដូច្នេះ ។ មិគាជិនតាបស ហៅព្រះបាទមហាជនករាជថា **រថេសភ** អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលដែលប្រព្រឹត្តវត្ត ដោយប្រការដែលឈានកន្លងនូវទុក្ខថាជាសមណៈ ដោយប្រាប់ គឺរៀនឱវាទកប្បសមណៈ និងវិជ្ជាសមណៈក៏មិនមែន បុគ្គលស្តាប់ពាក្យរបស់លោកទាំងនោះហើយ ទើបអាចបដិបត្តិយ៉ាងនេះបាន ដូច្នោះ ទើបពោលថា អ្នកណាហ្ន៎ ជាអ្នកចែកអត្ថ

ទូន្មានព្រះអង្គ ។

លំដាប់នោះ មហាសត្វពោលនឹងតាបសនោះថា

បពិត្រមិគាជិនៈ ខ្ញុំមិនដែលចូលទៅគោរពសមណៈ និងព្រាហ្មណ៍ណាមួយដោយដាច់ខាត ក្នុងកាលណាម្តងឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សក្កត្វា** បានដល់ បូជាដើម្បីការសួរនូវគុណនៃបព្វជ្ជា ។ បទថា **អនុចារិសឹ** សេចក្តីថា ព្រះមហាសត្វត្រាស់ថា ខ្ញុំមិនធ្លាប់ចូលជិតអ្នកណា មិនសួរសមណៈណាឡើយ ព្រោះព្រះមហាសត្វសូម្បីស្តាប់ធម៌ ក្នុងសម្នាក់របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏មិនសួរគុណនៃបព្វជ្ជា ដោយចំពោះក្នុងកាលណាឡើយ ដូច្នោះ ទើបត្រាស់យ៉ាងនេះ ។

កាលត្រាស់យ៉ាងនេះហើយ ទើបព្រះមហាសត្វត្រាស់គាថា ដើម្បីទ្រង់សម្តែងហេតុដែលទ្រង់បួស តាំងអំពីដើមថា

បពិត្រមិគាជិនៈ ខ្ញុំកាលទៅដោយអានុភាពដ៏ធំរុងរឿង ដោយសិរីកាលចម្រៀងដែលបុគ្គលកំពុងច្រៀង កាលតន្ត្រីមានសំឡេងដ៏ពីរោះ ដែលបុគ្គលកំពុងប្រគំ បានឃើញស្វាយ មានផ្លែខាងក្រៅកំពែង ដែលពួកមនុស្សអ្នកត្រូវការផ្លែ បេះជិតឧទ្យានដែលគឹកកងដោយការប្រគំតន្ត្រី ជាឧទ្យានប្រកបដោយសូរប្រគំដ៏ពីរោះ បពិត្រមិគាជិនៈ ខ្ញុំនោះ បានលះបង់សិរីនោះ ហើយចុះ ( អំពីដំរី ) ចូលទៅកាន់គល់ស្វាយ ដែលមានផ្លែ និងមិនមានផ្លែ បានឃើញស្វាយមានផ្លែ ដែលបុគ្គលបៀតបៀនហើយ កម្ចាត់

ហើយ ធ្វើមិនឲ្យមានស្ទឹក និងស្វាយ ១ ដើមក្រៅនេះ មាន ពន្លឺខៀវ ជាទីរីករាយនៃចិត្ត សត្រូវទាំងឡាយអាចសម្លាប់យើង ដែលជាឥស្សរៈ មានបន្ទាប្រើនដោយពិត ដូចដើមស្វាយដែលមាន ផ្លែ ដែលបុគ្គលសម្លាប់ហើយ ខ្លាដំបងត្រូវគេសម្លាប់ព្រោះស្បែក ដំរីត្រូវគេសម្លាប់ព្រោះភ្លុក បុគ្គលអ្នកមានទ្រព្យ ត្រូវគេសម្លាប់ ព្រោះទ្រព្យ តើនរណា នឹងសម្លាប់បុគ្គលអ្នកមិនមានផ្ទះ មិនមាន សន្ថវៈ ដើមស្វាយមានផ្លែ និងមិនមានផ្លែទាំងពីរនោះ ជាសាស្តា របស់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វគ្គុសុ** សេចក្តីថា កាលតន្ត្រីមានសំឡេង ពីរោះ ដែលបុគ្គលប្រគំ ។ បទថា **តូរិយតាលិតសង្ឃុដ្ឋេ** សេចក្តីថា ក្នុង ព្រះរាជឧទ្យានដែលកងរំពងដោយសំឡេងតន្ត្រីទាំងឡាយ ។ បទថា **សម្មា-តាលសមាហិតេ** សេចក្តីថា ប្រកបដោយអ្នកចម្រៀង និងអ្នកប្រគំទាំងឡាយ ។ បទថា **សមិគាជិន** សេចក្តីថា បពិត្រមិគាជិនៈ ខ្ញុំនោះ បានឃើញហើយ ។ បទថា **ផលឹ អម្ពំ** សេចក្តីថា ស្វាយមានផ្លែ គឺដើមស្វាយដែលចេញផ្លែ ។ បទថា **តិរោច្ឆទំ** សេចក្តីថា បានឃើញដើមស្វាយខាងក្រៅកំពែង គឺកើត អាស្រ័យខាងក្រៅកំពែង ដែលតាំងនៅខាងក្នុងព្រះរាជឧទ្យាននោះឯង ។ បទថា **តុទមានំ** បានដល់ ត្រូវគេវែង ( បេះ ) ។ បទថា **ឱរោហិត្វា** សេចក្តីថា ចុះអំពីកដំរី ។ បទថា **វិឆលីកតំ** បានដល់ ធ្វើឲ្យប្រាសចាកស្ទឹកមិនមាន មែក ។ បទថា **ឃរមេវ** បានដល់ ខ្ញុំនោះឯង ។ បទថា **ផលី** បានដល់

សម្បូរដោយផ្លែ ។ បទថា **អជិនម្ហិ** បានដល់ ដើម្បីស្បែក គឺមានស្បែកជាហេតុ ។ បទថា **ឧរេន្ទហិ** សេចក្តីថា ត្រូវសម្លាប់ព្រោះភ្លុកទាំងពីររបស់ខ្លួន គឺត្រូវសម្លាប់ព្រោះភ្លុកជាហេតុ ។ បទថា **ហន្តិ** បានដល់ ត្រូវប្រហារ ។ បទថា **អនិកេតមសន្ថវំ** សេចក្តីថា បុគ្គលណា ឈ្មោះថា **អនិកេត** ព្រោះលះនូវផ្ទះបួស ឈ្មោះថា **អសន្ថវ** ព្រោះមិនមានសន្ថវៈ គឺតណ្ហាដែលជាវត្ថុនៃសង្ខារទាំងឡាយ អធិប្បាយថា អ្នកណានឹងសម្លាប់បុគ្គលនោះ ដែលមិនមានផ្ទះ មិនមានសន្ថវៈ ។ បទថា **តេ សត្ថារោ** សេចក្តីថា ព្រះមហាសត្វពោលថា ដើមឈើពីរដើមនោះ ជាសាស្តារបស់ខ្ញុំ ។

មិគាជិនតាបសបានស្តាប់ដូច្នោះហើយ ទើបថ្វាយឱវាទដល់ព្រះរាជាថា សូមទ្រង់ជាអ្នកមិនប្រមាទចុះ ហើយត្រឡប់ទៅកាន់លំនៅរបស់ខ្លួននោះឯង ។ កាលមិគាជិនតាបសទៅហើយ ព្រះនាងសីវលីទេវីក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះរាជា ក្រាបទូលថា

> ជនទាំងពួង គឺសេនាជំរំ ពលសេះ ពលរថ ពលថ្មើរជើង
> បានឮថា ព្រះរាជាទ្រង់ផ្នួសហើយ ក៏តក់ស្លុត សូមព្រះអង្គ
> លួងលោមនូវប្រជុំជន ហើយតាំងទុកនូវការរក្សា រួចតាំងព្រះ
> រាជឱរសក្នុងរាជសម្បត្តិ ហើយសឹមទ្រង់ព្រះផ្នួស ក្នុងកាលជា
> ខាងក្រោយចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បព្វជិតោ** បានដល់ ខ្លាច គឺតក់ស្លុត ។ បទថា **បដិច្ចនំ** សេចក្តីថា តាំងនៅកងរក្សាឃុំគ្រងមហាជនដែលតក់ស្លុតថា

ព្រះរាជាទ្រង់មិនបានសម្លឹងមើលពួកយើងដែលត្រូវភ្លើងឆេះផង ត្រូវប្លន់ផង ។ បទថា **បុត្តំ** សេចក្តីថា សូមទ្រង់អភិសេកព្រះឱរស គឺទីឃាវុកុមារក្នុងរាជសម្បត្តិហើយ សឹមទ្រង់ផ្នួសក្នុងកាលជាខាងក្រោយចុះ ។

លំដាប់នោះ ព្រះពោធិសត្វត្រាស់ថា

ពួកអ្នកជនបទ មិត្តអាមាត្យ និងញាតិទាំងឡាយ ដែលយើង
លះបង់ហើយ កូនរបស់អ្នកដែនវិទេហៈ ឈ្មោះទីឃាវុកុមារ អ្នក
ញុំាងដែនឲ្យចម្រើន ម្នាលបជាបតិ កូននោះ នឹងសោយរាជ្យ
ក្នុងក្រុងមិថិលាចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តិ បុត្តា** សេចក្តីថា ម្នាលសីវលីទេវី ធម្មតាសមណៈទាំងឡាយ រមែងមិនមានបុត្រ តែទីឃាវុកុមារ ជាបុត្ររបស់អ្នកវិទេហរដ្ឋ អ្នកវិទេហរដ្ឋទាំងនោះ នឹងឲ្យគ្រងរាជសម្បត្តិ ព្រះមហាសត្វត្រាស់ហៅព្រះទេវីថា **បជាបតិ** ។

លំដាប់នោះ ព្រះនាងសីវលីទេវីក្រាបទូលមហាសត្វថា បពិត្រព្រះអង្គទ្រង់ផ្នួសហើយ ខ្ញុំម្ចាស់នឹងធ្វើអ្វី ព្រះមហាសត្វក៏ត្រាស់នឹងព្រះនាងថា នែទេវី អាត្មាឲ្យនាងសិក្សាតាម ចូរនាងធ្វើតាមពាក្យរបស់អាត្មា ហើយត្រាស់ថា

នាងចូរមកនេះ ពាក្យណា ដែលអាត្មាពេញចិត្ត អាត្មានឹងប្រាប់
នូវពាក្យនោះ នាងនឹងទៅកាន់ទុគ្គតិ ដោយកាយ វាចា ចិត្តណា
នាងឯងកាលសោយរាជ្យ ( ឈ្មោះថា ធ្វើ ) នូវបាបទុច្ចរិត ដ៏

ច្រើនដោយកាយ វាចា ចិត្តនោះ អាត្មានឹងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយងុំបាយ ដែលបុគ្គលជរទៃឲ្យហើយ ដែលបុគ្គលជរទៃសម្រេចហើយ ( នេះ ) ជាបវេណីរបស់អ្នកប្រាជ្ញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ត្វំ** សេចក្ដីថា នាងឲ្យលើកស្វេតច្ឆត្រឡើងដល់ព្រះរាជឱរស ទូន្មានទូវរឿងរាជសម្បត្តិដោយគិតថា កូនរបស់អញជាព្រះរាជា នឹងជាអ្នកធ្វើបាបច្រើន ។ បទថា **គច្ឆសិ** សេចក្ដីថា នាងនឹងទៅកាន់ទុគ្គតិ ដោយបាបជាច្រើន ដែលធ្វើដោយកាយជាដើមណា ។ បទថា **ស ធីរធម្មោ** សេចក្ដីថា ការប្រព្រឹត្តដែលគប្បីញ៉ាំងជីវិត ឲ្យប្រព្រឹត្តទៅដោយដុំបាយ ដែលបានមកដោយកម្លាំងស្មងនេះ ជាទំនៀមរបស់អ្នកប្រាជ្ញទាំងឡាយ ។

ព្រះមហាសត្វបានប្រទានឱវាទដល់ព្រះនាង ដោយប្រការដូច្នេះ កាលក្សត្រទាំងពីរត្រាស់ឆ្លើយឆ្លងគ្នា និងយាងទៅ ព្រះអាទិត្យក៏អស្ដង្គត ព្រះទេវីមានព្រះសវនីយ៍ ឲ្យបោះនូវជំរំក្នុងទីដែលសមគួរ ព្រះមហាសត្វទ្រង់សម្រាកត្រង់គល់ឈើមួយកន្លែង ប្រថាប់ក្នុងទីនោះអស់រាត្រី ស្អែកឡើង ទ្រង់ធ្វើសរីរកិច្ច ហើយយាងទៅតាមមាគ៌ា ចំណែកព្រះទេវីត្រាស់ឲ្យសេនាតាមទៅអំពីក្រោយ ហើយយាងទៅពីក្រោយព្រះមហាសត្វ ជនទាំងពីរយាងដល់នគរក្នុងពេលកិច្ចាហារ ខណៈនោះ មានបុរសម្នាក់នៅខាងក្នុងនគរ ដាក់សាច់មួយដុំធំ ត្រង់ជញ្ជាំងសម្រាប់លក់សាច់ ដោតនូវប្រទួច អាំងលើរងើកភ្លើងឲ្យឆ្អិនហើយ ដាក់ត្រង់ក្ដារដើម្បីឲ្យត្រជាក់ បានឈរ កាលបុរសនោះបញ្ចូ

ចិត្តទៅកាន់ទីដទៃ ឆ្កែមួយពាំដុំសាច់នោះគេចទៅ បុរសនោះដឹងហើយ ដេញតាមឆ្កែនោះ ទៅដល់ខាងក្រៅទ្វារនគរទិសទក្សិណ អស់អាល័យ និងត្រឡប់ចូលស្រុក ព្រះរាជា និងព្រះទេវីយាងមកអំពីខាងមុខសុនខ តាមផ្លូវបែកជាពីរ សុនខនោះក៏ទម្លាក់ដុំសាច់ រត់គេចទៅដោយសេចក្តីភ័យខ្លាច ព្រះមហា-សត្វទតឃើញដុំសាច់នោះ ទ្រង់ចិន្តនាការថា ឆ្កែនេះ បោលដុំសាច់នេះមិនសម្លឹងមើល រត់ទៅ សូម្បីអ្នកដទៃជាម្ចាស់ក៏មិនប្រាកដ អាហារបែបនេះមិនមានទោស ឈ្មោះថា បំសុកូលបិណ្ឌបាត អញនឹងបរិភោគដុំសាច់នោះ ទើបទ្រង់នាំបាត្រដីចេញមកកាន់យកដុំសាច់នោះ បោសនូវធូលីដែលប្រឡាក់ហើយ ដាក់ក្នុងបាត្រ យាងទៅកាន់ទីដែលមានទឹកបរិបូណ៌ ទ្រង់ពិចារណាហើយ ផ្តើមសោយនូវដុំសាច់នោះ ។ លំដាប់នោះព្រះទេវីទ្រង់ព្រះតម្រិះថា បើព្រះរាជានេះមានបំណងនឹងរាជសម្បត្តិ មិនគប្បីសោយដុំសាច់បែបនេះ ដែលគួរខ្ពើម ប្រឡាក់ធូលី ជារបស់សល់ពីសុនខ ឥឡូវនេះ ទ្រង់មិនមែនព្រះរាជស្វាមីរបស់អញឡើយ ត្រិះរិះដូច្នេះហើយ ក្រាបទូលថា បពិត្រមហារាជ កោតតែព្រះអង្គសោយសាច់ដែលគួរខ្ពើមបែបនេះទៅបាន ព្រះមហាសត្វត្រាស់ថា នែទេវី នាងមិនស្គាល់ភាពវិសេសរបស់បិណ្ឌបាតនេះ ព្រោះល្ងង់ខ្លៅ ត្រាស់ដូច្នេះហើយ ទ្រង់ពិចារណាទីដែលដុំសាច់នោះតាំងនៅ សោយដុំសាច់នោះ ដូចសោយអម្រឹតរស ខ្ពុរព្រះឱស ជម្រះព្រះហស្ត និងព្រះបាទហើយ ។ កាលនោះ ព្រះទេវី កាលតិះដៀលព្រះរាជា ទើបត្រាស់ថា

បុគ្គលណា មិនបរិភោគអាហារក្នុងកាលនៃភត្ត ជាគម្រប់ ៤

បុគ្គលនោះ គប្បីស្លាប់ ដោយសេចក្តីស្រេកឃ្លាន ដូចបុគ្គលដល់នូវសេចក្តីស្លាប់ដ៏ពិត មានសភាពជាកុលបុត្ត មិនគប្បីបរិភោគដុំបាយ ដែលប្រឡាក់ដោយធូលី មិនស្អាតទេ ឬការបរិភោគនោះមិនល្អទេ មិនប្រសើរទេ បពិត្រមហាជនក ព្រះអង្គសោយនូវដុំបាយ ដែលសល់អំពីឆ្កែ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈជ្ជមារិវ** សេចក្តីថា ទៀបនឹងស្លាប់ ។ បទថា **លុលិតំ** បានដល់ ប្រឡាក់ធូលី ។ បទថា **អធរិយំ** បានដល់ មិនល្អ ។ **ន** អក្ខរៈ ក្នុងបទថា **ន សេវេ** ត្រឹមតែជានិបាត ចុះក្នុងអត្ថសួរឆ្លើយ មានពាក្យអធិប្បាយថា សូម្បីមិនបានបរិភោគអាហារ ៤ ពេល ឬនឹងស្លាប់ដោយការអត់អាហារ កាលបើយ៉ាងនោះ បុគ្គលឈ្លាសវៃ រមែងមិនព្រមបរិភោគអាហារបែបនោះឡើយ គឺមិនបរិភោគអាហារដូចទ្រង់ ។ បទថា **តយិទំ** ប្រែថា នេះ ។ ព្រះមហាសត្វត្រាស់តបថា

ម្នាលសីវលី វត្ថុណាដែលគ្រហស្ថ ឬសុនខលះបង់ហើយ វត្ថុនោះ មិនមែនជាអាត្មាមិនគួរឆាន់ទេ ភោគៈទាំងឡាយណានីមួយក្នុងលោកនេះ ដែលបានដោយធម៌ ភោគៈទាំងអស់នោះ លោកពោលថា ជាអាហារមិនមានទោស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភក្ខោ** សេចក្តីថា បិណ្ឌបាតនោះ មិនឈ្មោះថាជាភក្ខាហាររបស់អាត្មាក៏មិនមែន ។ បទថា **យំ ហោតិ** សេចក្តីថា របស់ណាដែលគ្រហស្ថ ឬឆ្កែលះបង់ហើយ របស់នោះ ឈ្មោះថា បង្សុកូល

ជារបស់មិនមានទោស ព្រោះមិនមានម្ចាស់ ។ បទថា **យេ កេចិ** សេចក្តីថា ព្រោះដូច្នោះ គោគៈពួកណានីមួយដទៃ ដែលបានមកដោយធម៌ ។ បទថា **សព្វោ សោ ភក្ខោ អនវយោ** សេចក្តីថា មិនមានទោស គឺសូម្បីមានមនុស្ស មើលរឿយៗ ក៏មិនខ្វះខាត បរិបូណ៌ដោយគុណមិនមានទោស តែលាភ ដែលបានមកមិនប្រកបដោយធម៌ ទោះមានតម្លៃរាប់សែន ក៏គួរខ្ពើមនោះឯង ។

កាលក្សត្រពីរអង្គសន្ទនាគ្នាយ៉ាងនេះ ទ្រង់ក៏យាងដល់ទ្វារព្រះនគរ កាល ទារកទាំងឡាយកំពុងលេងក្នុងនគរនោះ មានទារិកាម្នាក់យកចង្អេរតូចអុំខ្សាច់ លេង កងដៃមួយពាក់ត្រង់កដៃម្ខាងរបស់នាង កងដៃពីរ ពាក់ត្រង់កដៃម្ខាង កងដៃពីរនោះទង្គិចគ្នាមានសំឡេង កងដៃមួយទៀតមិនមានសំឡេង ព្រះរាជា ទ្រង់ជ្រាបហេតុនោះ ទើបមានព្រះតម្រិះថា ឥឡូវនេះ ព្រះនាងសីវលីមក តាមក្រោយអញ ឈ្មោះថា ស្ត្រី រមែងជាមន្ទិលរបស់បព្វជិត ជនទាំង ឡាយឃើញនាងមកតាមអញ នឹងតិះដៀលថា បព្វជិតនេះ សូម្បីបួសហើយ ក៏មិនអាចលះភរិយាបាន បើកុមារីនេះឈ្លាសវៃ នឹងពោលដល់ហេតុឲ្យនាង សីវលីត្រឡប់ អញនឹងស្តាប់ពាក្យរបស់កុមារីនេះ ហើយបញ្ជូននាងសីវលី ត្រឡប់ មានព្រះតម្រិះដូច្នេះហើយ យាងទៅក្បែរកុមារីនោះ កាលនឹងសួរ ទើបត្រាស់គាថានេះថា

ម្នាលនាងកុមារិកា ជាក្មេងដេកជិតមាតានៅឡើយ មានគ្រឿង
ប្រដាប់ មិនឃ្លាតអំពីខ្លួនជានិច្ច ដៃម្ខាងរបស់នាងលាន់ឮសំឡេង
ដៃម្ខាងមិនលាន់ឮសំឡេង តើព្រោះហេតុអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧបសេនិយេ** សេចក្ដីថា ចូលទៅជេកក្បែរមាតា ។ បទថា **និគ្គលមណ្ឌិតេ** សេចក្ដីថា ព្រះមហាសត្វត្រាស់ថា មានប្រក្រតីប្រដាប់ដោយគ្រឿងប្រដាប់ដ៏កំពូល ។ បទថា **ជនតិ** បានដល់ មានសំឡេងខ្លាំង ។ កុមារិកាពោលថា

បពិត្រសមណៈ កងពីរដែលពាក់នឹងដៃរបស់ខ្ញុំនេះ ខ្ទប់គ្នាហើយ សំឡេងក៏កើតឡើង នោះជាគតិនៃកងទាំងពីរ បពិត្រសមណៈ កង ១ ដែលពាក់នឹងដៃរបស់ខ្ញុំនេះ កងនោះ មិនមានកងឯទៀតជាគម្រប់ពីរ ទើបមិនលាន់ឮសំឡេង ដូចអរិយបុគ្គលជាអ្នកស្ងប់ស្ងៀម ឯបុគ្គលមានគ្នាជាគម្រប់ពីរនាក់ រមែងដល់នូវការជជែកគ្នា បុគ្គល ១ នាក់ នឹងជជែកជាមួយនឹងបុគ្គលណាកើត ព្រះអង្គនោះ ជាអ្នកប្រាថ្នានូវស្ថានសួគ៌ សូមទ្រង់ពេញចិត្តនឹងភាពនៃបុគ្គលម្នាក់ឯងចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុតិយា** បានដល់ កងពីរ ។ បទថា **សង្ឃាដា** សេចក្ដីថា ព្រោះខ្ទប់គ្នា គឺប៉ះទង្គិចគ្នា ។ បទថា **គតិ** បានដល់ សេចក្ដីសម្រេច ព្រោះថា កងទីពីរ រមែងមានការសម្រេចបែបនេះ ។ បទថា **សោ** បានដល់ កងនោះ ។ បទថា **មុនិភូតោវ** សេចក្ដីថា ដូចព្រះអរិយបុគ្គលដែលលះនូវកិលេសអស់ហើយតាំងនៅ ។ បទថា **វិវាទប្បត្តោ** សេចក្ដីថា បពិត្រសមណៈ ឈ្មោះថា បុគ្គលជាគម្រប់ពីរ រមែងវិវាទគ្នា គឺឈ្លោះគ្នា ប្រកាន់ផ្សេងៗ គ្នា ។ បទថា **កេនេកោ** សេចក្ដីថា បុគ្គលម្នាក់ឯង នឹងឈ្លោះជាមួយអ្នកណា ។

បទថា **ឯកត្ថមុបរោចតំ** សេចក្តីថា សូមលោកគាប់ចិត្តជាបុគ្គលម្នាក់ឯងចុះ កាលពោលយ៉ាងនេះហើយ កុមារិកានោះ បានពោលយ៉ាងនេះទៀត គឺពោលទូន្មានមហាសត្វថា បពិត្រសមណៈ ធម្មតាអ្នកបួសទាំងឡាយ រមែងមិននាំប្អូនស្រីដើរទៅឡើយ តែហេតុអ្វី ទើបលោកនាំកិរិយា ដែលទ្រទ្រង់នូវរូបដ៏ឧត្តមនេះត្រាច់ទៅ កិរិយានេះនឹងធ្វើអន្តរាយដល់លោក សូមលោកនាំកិរិយានេះចេញទៅតែម្នាក់ឯងប៉ុណ្ណោះ បំពេញសមណធម៌ឲ្យសមគួរចុះ ។

ព្រះមហាសត្វបានស្តាប់ពាក្យរបស់កុមារិកានោះហើយ ទ្រង់បានហេតុឧបការៈ កាលត្រាស់ជាមួយព្រះទេវី ទើបត្រាស់ថា

ម្នាលនាងសីវលី នាងឮគាថា ដែលនាងកុមារិកាពោលហើយឬទេ នាងកុមារិកាតិះដៀលនូវអាត្មា ដូចជាអ្នកបម្រើ នោះឯងជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវ តែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់ផ្លូវ ១ អាត្មានឹងកាន់ផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថា ជាប្រពន្ធទៀតដែរដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុមារិយា** បានដល់ កុមារិកាពោលហើយ ។ បទថា **បេសិយា** សេចក្តីថា បើអញនៅគ្រប់គ្រងរាជសម្បត្តិ កុមារិកានេះ ក៏ជាអ្នកបម្រើ គឺធ្វើតាមពាក្យបញ្ជារបស់អញ សូម្បីតែក្រឡេកមើលអញ ក៏មិនអាច តែឥឡូវនេះ នាងតិះដៀល គឺពោលទូន្មានអញដូច

*អ្នកបម្រើ និងដូចទាសៈរបស់ខ្លួនថា* **ឩតិយសេ្ស សា គតិ** *ដូច្នេះ ។ បទថា* **អនុចិណ្ណា** *បានដល់ កើតតាមគ្នាទៅ ។ បទថា* **បថាវិហិ** *បានដល់ អ្នកធ្វើដំណើរ ។ បទថា* **ឯកំ** *សេចក្តីថា ចូរនាងកាន់យកផ្លូវមួយ ដែលជាទីគាប់ចិត្តរបស់នាង ចំណែកអាត្មា ក៏នឹងកាន់យកផ្លូវមួយដ៏សេស អំពីផ្លូវដែលនាងកាន់យក ។ បទថា* **មា ច មំ ត្វំ** *សេចក្តីថា នៃនាងសីវលី តាំងអំពីនេះទៅ នាងកុំហៅអាត្មាថាជាស្វាមីរបស់នាងទៀត អាត្មាក៏នឹងមិនហៅនាងថា ជាមហេសីដូចគ្នា ។*

*ព្រះនាងសីវលីទេវី ទ្រង់បានស្តាប់ព្រះតម្រាស់របស់ព្រះមហាសត្វហើយ ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ជាក្សត្រដ៏ខ្ពង់ខ្ពស់ ចូរកាន់យកផ្លូវខាងស្តាំ ចំណែកខ្ញុំម្ចាស់ជាស្ត្រី ជាតិថោកថយ នឹងកាន់យកផ្លូវខាងឆ្វេង ក្រាបទូលដូច្នេះហើយ ថ្វាយបង្គំព្រះមហាសត្វ ហើយយាងទៅបានបន្តិច មិនអាចអត់សង្កត់សេចក្តីសោកបាន ក៏យាងមកវិញ ទៅជាមួយព្រះរាជាចូលថូណនគរជាមួយគ្នា ។*

**តមត្ថំ បកាសេន្តោ សត្ថា ឧបឌ្ឍគាថមាហ** *វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់បែងច្បាស់ លុះព្រះបានត្រាស់ហើយ ទ្រង់ត្រាស់កន្លះគាថាដូច្នេះថា*

*ព្រះរាជា និងនាងសីវលី កាលពោលនូវពាក្យនេះហើយ ក៏ចូលទៅកាន់ថូណនគរ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **ឩគរមុបាគមុំ** *សេចក្តីថា យាងចូលទៅ*

ហើយកាន់នគរ ។ កាលទ្រង់ចូលទៅហើយ ព្រះមហាសត្វត្រាច់បិណ្ឌបាត យាងដល់ទ្វារផ្ទះរបស់ជាងពត់ព្រួញ សូម្បីព្រះនាងសីវលីទេវីក៏យាងទៅតាមអំពីខាងក្រោយ ប្រថាប់ក្នុងទីសមគួរនាចំណែកម្ខាង ។ សម័យនោះ ជាងព្រួញ កំពុងរោលព្រួញលើអំបែងរងើកភ្លើង នាំយកបាយម៉ានលាបនូវព្រួញ បិទភ្នែកម្ខាង សម្លឹងមើលដោយភ្នែកម្ខាង ពត់ព្រួញឲ្យត្រង់ ព្រះមហាសត្វកាលទតឃើញដូច្នោះ មានព្រះតម្រិះថា បើជាងព្រួញនេះជាមនុស្សឈ្លាសវៃ នឹងពោលហេតុណាមួយដល់អញ អញនឹងសាកសួរគេមើល ទើបចូលទៅរកជាងព្រួញ ហើយត្រាស់សួរ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដបទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសានូវបាទព្រះគាថាដូច្នេះថា

កាលជិតវេលាភត្ត ព្រះរាជា ( ក៏ឈរ ) ជិតទ្វារនៃជាងព្រួញ
ជាងព្រួញនោះ ធ្មេចភ្នែកម្ខាង សម្លឹងមើលដងព្រួញវៀចមួយ
ដែលធ្វើឲ្យត្រង់ ដោយភ្នែកម្ខាង ជិតខ្លោងទ្វារនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោដ្ឋកេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយព្រះរាជាអង្គនោះ កាលជិតដល់ពេលសោយរបស់ព្រះអង្គ បានប្រថាប់ឈរត្រង់ខ្លោងទ្វាររបស់ជាងព្រួញ ។ បទថា **តត្រ ច** បានដល់ ជិតខ្លោងទ្វារនោះ ។ បទថា **និគ្គយ្ហ** បានដល់ បិទភ្នែកហើយ ។ បទថា **ជិម្ហមេកេន** សេចក្តីថា ប្រើភ្នែកម្ខាងសម្លឹងមើលព្រួញដែលវៀច ។

លំដាប់នោះ ព្រះមហាសត្វបានត្រាស់នឹងជាងព្រួញនោះថា

ម្នាលជាងព្រួញ អ្នកចូរស្តាប់ពាក្យអាត្មា អ្នកធ្មេចភ្នែកម្ខាង សម្ងឹងមើលដងព្រួញវៀច អ្នកមើលយ៉ាងនេះស្រួលឬ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា នែជាងព្រួញសម្លាញ់ អ្នកបិទភ្នែកម្ខាង សម្ងឹងមើលព្រួញដែលវៀចដោយភ្នែកម្ខាង ដោយប្រការណា អ្នកឃើញការសម្រេចប្រយោជន៍ដោយប្រការនោះឬ ។

លំដាប់នោះ កាលជាងព្រួញទូលព្រះមហាសត្វនោះ ទើបពោលថា

បពិត្រសមណៈ ទីប្រាកដដូចជាទូលាយ ដោយភ្នែកពីរ កិច្ចដោយភាវៈនៃព្រួញត្រង់ រមែងមិនសម្រេច ព្រោះមិនឃើញនូវទីវៀចខាងមុខ ។ កាលបុគ្គលធ្មេចភ្នែកម្ខាង សម្ងឹងមើលទីវៀចដោយភ្នែកម្ខាង កិច្ចដោយភាពនៃព្រួញត្រង់ រមែងសម្រេច ព្រោះឃើញទីវៀចខាងមុខ ។ បុគ្គលជាគម្រប់ពីរ រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់ឯង នឹងជជែកគ្នាជាមួយនឹងអ្នកណាកើត កាលព្រះអង្គនោះ ប្រាថ្នានូវស្ថានសួគ៌ សូមពេញព្រះហឫទ័យនឹងភាពនៃបុគ្គលម្នាក់ឯងចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិសាលំ វិយ** សេចក្តីថា ប្រាកដដូចជាទូលាយពេក ។ បទថា **អប្បត្វា បរមំ លិង្គំ** សេចក្តីថា មិនដល់នូវទីវៀចខាងមុខ ។ បទថា **ឧជុភាវាយ** បានដល់ មិនត្រង់ មានពាក្យអធិប្បាយថា កាលការទូលាយប្រាកដ ក៏នឹងមិនដល់ទីត្រង់ខាងមុខ កាលមិនដល់ គឺមិន

ប្រាកដ កិច្ចដោយការត្រង់នឹងមិនសម្រេច គឺមិនដល់ព្រម ។ បទថា **សម្បត្វា** សេចក្តីថា ដល់ គឺឃើញដោយចក្ខុ ។ បទថា **វិវាទបត្តោ** សេចក្តីថា កាលបើកន្លែកទាំងពីរ ទីដែលវៀច រមែងមិនប្រាកដ គឺទីដែលវៀចប្រាកដជាត្រង់ ទីដែលត្រង់ប្រាកដជាវៀច ការវិវាទ រមែងមានដោយប្រការដូច្នេះ យ៉ាងណា សូម្បីសមណៈមានពីររូបក៏ដូច្នោះ រមែងវិវាទគ្នា គឺឈ្លោះគ្នា ប្រកាន់ផ្សេងៗគ្នា ។ បទថា **កោនេកោ** សេចក្តីថា បុគ្គលម្នាក់ឯងនឹងវិវាទជាមួយអ្នកណា ។ បទថា **ឯកត្តមុបកោចតំ** សេចក្តីថា សូមលោកពេញចិត្តក្នុងភាពជាបុគ្គលម្នាក់ឯង ធម្មតាសមណៈទាំងឡាយ រមែងមិននាំសូម្បីប្អូនស្រីត្រាច់ទៅឡើយ ហេតុអ្វី ទើបលោកនាំកិរិយាដែលមានរូបស្អាតត្រាច់ទៅ កិរិយានេះ នឹងធ្វើអន្តរាយដល់លោក សូមលោកនាំកិរិយានេះចេញទៅ បំពេញសមណធម៌ម្នាក់ឯងប៉ុណ្ណោះ ឲ្យសមគួរចុះ ជាងព្រួញពោលទូន្មានមហាសត្វ ដោយប្រការដូច្នេះ ចំណែកជាងព្រួញ ថ្វាយឱវាទដល់ព្រះមហាសត្វយ៉ាងនេះហើយ ក៏ស្ងៀមនៅ ព្រះមហាសត្វត្រាច់បិណ្ឌបាត បានកត្តាហារដែលលាយគ្នាហើយ យាងចេញអំពីព្រះនគរ ប្រថាប់គង់សោយក្នុងទីដែលមានទឹកបរិបូណ៌ ទ្រង់សោយព្រះក្រយាហារស្រេចហើយ ខ្ពុរព្រះឱស្ឋ លាងបាត្រដាក់ចូលស្ពាក ហើយ ត្រាស់ហៅព្រះនាងសីវលីមកត្រាស់ថា

នែនាងសីវលី នាងឮគាថាដែលជាងព្រួញពោលហើយឬទេ ជាងព្រួញតិះដៀលអាត្មា ដូចជាអ្នកបម្រើ នោះជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវ

តែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់យកផ្លូវ ១ អាត្មានឹងកាន់យកផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មា ថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាង ថាជាភរិយារបស់អាត្មាដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុណាសិ** សេចក្តីថា នាងស្តាប់គាថាឬព្រះមហាសត្វត្រាស់ថា **បេសិយា មំ** នេះ ទ្រង់សំដៅដល់ឱវាទរបស់ជាងព្រួញនោះឯង ។

បានឮថា ព្រះនាងសីវលីទេវីនោះ សូម្បីត្រូវព្រះមហាសត្វត្រាស់ថា នាងកុំហៅអាត្មាថាជាព្រះស្វាមីរបស់នាងដូច្នេះ ក៏នៅតែយាងតាមព្រះមហាសត្វនោះឯង ព្រះរាជាក៏មិនអាចឲ្យព្រះនាងសីវលីនោះ យាងត្រឡប់បាន សូម្បីមហាជនក៏យាងតាមទ្រង់ទៅនោះឯង តែដល់ទីនោះ មានព្រៃមួយកន្លែងដែលនៅមិនឆ្ងាយ លំដាប់នោះ ព្រះមហាសត្វទតឃើញជន្ទព្រៃខៀវស្រងាត់ មានព្រះរាជបំណងឲ្យព្រះនាងត្រឡប់ កាលយាងទៅ បានទតឃើញស្មៅជំណេកទន្សាយក្នុងទីក្បែរផ្លូវ ហើយទ្រង់ដកស្មៅជំណេកទន្សាយនោះ ត្រាស់ហៅព្រះទេវីមកត្រាស់ថា នែសីវលីដ៏ចម្រើន ចូរនាងមើលស្មៅជំណេកទន្សាយនេះ ស្មៅជំណេកទន្សាយនេះ មិនអាចជាប់គ្នាត្រង់គុម្ពនេះបានទៀតយ៉ាងណា ការនៅរួមជាមួយនាងរបស់អាត្មា ក៏មិនអាចជាប់តគ្នាបានទៀតដូច្នោះហើយ ទ្រង់ត្រាស់កន្លះគាថាដូច្នេះថា

ម្នាលនាងសីវលី នាងចូរនៅម្នាក់ឯងចុះ ដូចស្មៅយាប្លងដែល
អាត្មាដកហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកា** សេចក្ដីថា នៃនាងសីវលីដ៏ចម្រើន ស្មៅជំណោកទន្សាយដែលជាប់គ្នាពីមុន អាត្មាដកហើយ មិនអាចតគ្នាឲ្យជាប់តទៅទៀត យ៉ាងណា ការនៅរួមគ្នារបស់នាង និងអាត្មា ក៏មិនអាចធ្វើបានដូច្នោះ ព្រោះហេតុនោះ យើងនឹងនៅតែម្នាក់ឯង សូម្បីនាងក៏នៅតែម្នាក់ឯងដូចគ្នា ព្រះមហាសត្វបានប្រទានឱវាទដល់ព្រះនាងសីវលីទេវី ដោយប្រការដូច្នេះ ។

ព្រះនាងបានស្ដាប់ព្រះតម្រាស់របស់ព្រះមហាសត្វហើយ ត្រាស់ថា ចាប់អំពីនេះទៅ ខ្ញុំមិនបាននៅរួមជាមួយព្រះមហាជនកនរិន្ទរាជទៀត ព្រះនាងមិនអាចអត់សង្កត់សេចក្ដីសោក ផ្គងដើមដៃទាំងពីរបរិទេវនាការដោយអនេក-បរិយាយ ដល់នូវវិសញ្ញីភាព ដួលចុះត្រង់ផ្លូវធ្លារ ព្រះមហាសត្វទ្រង់ជ្រាបថាព្រះនាងសន្លប់ ក៏ឈានព្រះបាទយាងចូលកាន់ព្រៃ ខណៈនោះ ពួកអមាត្យយកទឹកមកប្រស់សរីរៈព្រះទេវីនោះ នាំគ្នាថ្វាយការងារត្រង់ព្រះហស្ត និងព្រះបាទ ព្រះនាងមានស្មារតីក្រោកឡើង ត្រាស់សួរថា ព្រះរាជាយាងទៅខាងណា ពួកអមាត្យទូលសួរថា ព្រះនាងទ្រង់មិនជ្រាបទេឬ ព្រះនាងត្រាស់ឲ្យដើររក ជនទាំងនោះ នាំគ្នារត់ទៅខាងនោះខាងនេះ ក៏មិនអាចជួបព្រះរាជា ព្រះនាងទ្រង់បរិទេវនាការជាអនេក ហើយឲ្យសាងចេតិយត្រង់ទីដែលព្រះរាជាប្រថាប់ឈរ បូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ហើយយាងត្រឡប់ទៅកាន់ក្រុងមិថិលា ចំណែកព្រះមហាសត្វយាងចូលព្រៃហិមពាន្ត ធ្វើអភិញ្ញា និងសមាបត្តិឲ្យកើតខាងក្នុង ៧ ថ្ងៃ មិនបានយាងមកកាន់ដែនដីមនុស្សទៀត

ទេ ។ ចំណែកព្រះនាងសីវលី បានយាងត្រឡប់ហើយ ឲ្យសាងព្រះចេតិយជាច្រើនកន្លែង ក្នុងទីដែលព្រះមហាសត្វត្រាស់ជាមួយជាងព្រួញ ត្រាស់ជាមួយកុមារី ទីសោយសាច់ដែលសុនខទម្លាក់ចោល ទីត្រាស់ជាមួយមិគាជិនតាបស និងជាមួយនារទតាបស គ្រប់តំបន់ហើយ បូជាដោយគ្រឿងក្រអូបនិងផ្កាជាដើម ទ្រង់ចោមរោមទៅដោយសេនានិករ ក្រោយមក ទើបយាងទៅដល់មិថិលានគរ ព្រះនាងអភិសេកព្រះឱរសក្នុងឧទ្យានអម្ពវ័ន ទ្រង់បញ្ចូនព្រះរាជឱរស ដែលពួកសេនាចោមរោម ហើយចូលព្រះនគរ ហើយព្រះនាងទ្រង់ផ្នួសជាតាបសិនី ប្រថាប់នៅក្នុងព្រះរាជឧទ្យាននោះ ព្រះនាងធ្វើកសិណ-បរិកម្ម បានសម្រេចនូវឈាន មានឈានមិនសាបសូន្យ មានព្រហ្មលោកជាទីទៅខាងមុខ ក្នុងទីបំផុតនៃព្រះជន្មាយុ ។ ចំណែកព្រះមហាសត្វ មានឈានមិនសាបសូន្យ ក៏ចូលដល់ព្រហ្មលោកដូចគ្នា ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតចេញមហាភិនេស្រ្កមណ៍ សូម្បីក្នុងកាលមុន តថាគតក៏ចេញមហាភិនេស្រ្កមណ៍ដូចគ្នា ហើយទ្រង់សមោធានជាតកថា សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធក្នុងកាលឥឡូវនេះ ព្រាហ្មណទិសាបាមោក្ខក្នុងកាលនោះ បានមកជាកស្សបៈ មណីមេខលាទេពធីតាអ្នករក្សាសមុទ្រក្នុង

កាលនោះ បានមកជាឧប្បលវណ្ណាភិក្ខុនី នារទតាបសក្នុងកាលនោះ បានមកជាសារីបុត្ត មិគាជនតាបសក្នុងកាលនោះ បានមកជាមោគ្គល្លាន កុមារិកាក្នុងកាលនោះ បានមកជាខេមាភិក្ខុនី ជាងព្រួញក្នុងកាលនោះ បានមកជាអានន្ទ រាជបរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ សីវលីទេវីក្នុងកាលនោះ បានមកជារាហុលមាតា ទីឃាវុកាមារក្នុងកាលនោះ បានមកជារាហុល ព្រះមាតាបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជ ចំណែកមហាជនកនរិន្ទរាជក្នុងកាលនោះ គឺតថាគតសម្មាសម្ពុទ្ធនេះឯង ។ល។

## អដ្ឋកថា មហាជនកជាតក ចប់

# សុត្តន្តបិដក

## សុវណ្ណសាមជាតក

[ ៨៩ ] ( សុវណ្ណសាមបណ្ឌិតសួរថា ) នរណាហ្ន៎ បាញ់ខ្ញុំជាអ្នកជងទឹក ភ្លេចស្មារតី ដោយព្រួញ ជនណាជាក្សត្រ ឬជាព្រាហ្មណ៍ ឬជាវេស្សៈ បាញ់ខ្ញុំហើយពួន ។ សាច់ទាំងឡាយរបស់ខ្ញុំ មិនមែនជារបស់គួរទំពាស៊ីទេ សេចក្តីត្រូវការដោយស្បែក មិនមានទេ កាលបើដូច្នេះ តើអ្នកសម្គាល់នូវខ្ញុំថា គួរបាញ់ដោយហេតុដូចម្តេច ។ អ្នកជាអ្វី ជាបុត្តរបស់អ្នកណា យើងស្គាល់អ្នកដូចម្តេចបាន ម្នាលសម្លាញ់ អ្នកខ្ញុំសួរហើយ ចូរប្រាប់ម្តេចក៏បានជាអ្នកបាញ់ខ្ញុំហើយពួន ។

[ ៩០ ] ( ព្រះបាទបិលយក្ខត្រាស់ថា ) ខ្ញុំជាព្រះរាជារបស់ពួកអ្នកកាសី គេស្គាល់ខ្ញុំថាឈ្មោះបិលយក្ខ ខ្ញុំលះបង់នូវដែន មកត្រាច់ស្វែងរកម្រឹគ ព្រោះលោភ ( ក្នុងសាច់ ) ។ មួយវិញទៀតខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ ជាអ្នកមានឈ្មោះល្បីល្បាញ ថាជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំបាន សូម្បីដំរីដែលមកត្រង់មុខ ព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ ។ ចុះអ្នកជាអ្វី ជាបុត្តរបស់អ្នកណា ដូចម្តេចទើបយើងស្គាល់អ្នកបាន សូមអ្នកប្រាប់នូវនាម និងគោត្តរបស់បិតាផង របស់ខ្លួនផង ។

[ ៩១ ] ( ព្រះមហាសត្វ ... ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ ( ជាកូនរបស់ឥសី ) ជាបុត្តរបស់នាយនេសាទ ពួកញាតិហៅទូលបង្គំ

ជាខ្ញុំ កំពុងរស់នៅជាសាមៈ ថ្ងៃនេះទូលបង្គំជាខ្ញុំនោះដល់ ( មាត់មច្ចុរាជ ) ហើយដេកនៅយ៉ាងនេះ ។ ខ្ញុំដែលព្រះអង្គបាញ់ហើយ ហាក់ដូចម្រឹគ ដែលព្រានព្រៃបាញ់ហើយ ដោយព្រួញធំ ប្រកប ដោយថ្នាំពិសដូច្នោះ បពិត្រព្រះរាជា សូមទ្រង់ទតចុះ ទូលបង្គំជាខ្ញុំ ដេកត្រាំនៅក្នុងឈាមរបស់ខ្លួន ។ សូមទ្រង់ទតព្រួញដែលមុត ធ្លាយទៅខាងឆ្វេង ទូលបង្គំជាខ្ញុំខ្ពុរឈាម ទូលបង្គំជាខ្ញុំចាប់ពើត ណាស់ បានជាសួរព្រះអង្គរឿយៗ ម្តេចក៏ទ្រង់បាញ់ទូលបង្គំជាខ្ញុំ ហើយពួន ។ ខ្លាដំបងគេសម្លាប់ព្រោះតែស្បែក ដំរីគេសម្លាប់ ព្រោះភ្លុកទាំងឡាយ កាលបើដូច្នោះ តើព្រះអង្គសម្គាល់នូវទូល បង្គំជាខ្ញុំថា គួរបាញ់ដោយហេតុដូចម្តេច ។

[ ៩២ ] ( ព្រះបាទបិលយក្ខ និយាយកុហកថា ) ម្រឹគមកប្រាកដ ចំមុខព្រួញរបស់ខ្ញុំហើយ ឃើញអ្នកហើយក៏ផ្អើលទៅ ម្នាលសាមៈ ព្រោះហេតុនោះ បានជាខ្ញុំមានសេចក្តីក្រោធ គ្របសង្កត់ ។

[ ៩៣ ] ( ព្រះមហាសត្វ ... ) តាំងពីកាលដែលខ្ញុំ រឭកឃើញ នូវខ្លួន តាំងពីកាលដែលខ្ញុំ ដល់នូវភាពជាអ្នកដឹងក្តី ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល ( ឃើញ ) ទូលបង្គំជាខ្ញុំ ហើយតក់ស្លុតទេ តាំងពីកាលដែលខ្ញុំ ស្លៀកដណ្តប់សំពត់សម្បក ឈើ តាំងពីកាលដែលខ្ញុំ ដល់នូវវ័យដ៏ចម្រើន ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល ( ឃើញ ) នូវខ្ញុំហើយ

តក់ស្លុតទេ ។ បពិត្រព្រះរាជា កិន្នរទាំងឡាយ ដែលជាសត្វខ្លាច ( នៅ ) នាភ្នំគន្ធមាទន៍ ( មិនដែលឃើញខ្ញុំហើយ តក់ស្លុតទេ ) យើងទាំងឡាយ តែងរីករាយជាមួយគ្នា ទៅកាន់ភ្នំ និងព្រៃ កាលបើដូច្នោះ ម្រឹគទាំងឡាយ ( ឃើញ ) នូវទូលបង្គំជាខ្ញុំហើយ តក់ស្លុតដោយហេតុដូចម្តេច ។

[ ៩៤ ] ( ព្រះបាទបិលយក្ខ ) ម្នាលសាមៈ ម្រឹគមិនមែនផ្អើលនឹងអ្នកទេ ខ្ញុំនឹងនិយាយកុហកធ្វើអ្វី ខ្ញុំមានសេចក្តីក្រោធ និងសេចក្តីលោភគ្របសង្កត់ហើយ ទើបបាញ់អ្នកនឹងព្រួញនោះ ។ ម្នាលសាមៈ អ្នកមកអំពីប្រទេសណា ឬនរណាប្រើមកថា អ្នកដងទឹកចូរទៅកាន់ស្ទឹងដូច្នេះ បានជាអ្នកមកកាន់ស្ទឹង មិគសម្មតៈ ( នេះ ) ។

[ ៩៥ ] ( មហាសត្វ ) មាតាបិតា របស់ទូលបង្គំជាខ្ញុំខ្វាក់ ទូលបង្គំជាខ្ញុំ តែងចិញ្ចឹមគាត់ក្នុងព្រៃធំ ទូលបង្គំជាខ្ញុំ ជាអ្នកដងទឹក ដើម្បីអ្នកមានគុណទាំងឡាយ បានជាមកកាន់ស្ទឹងមិគសម្មតៈ ( នេះ ) ។

[ ៩៦ ] ( ព្រះមហាសត្វពិលាបថា ) មាតាបិតាទាំងឡាយនោះ មានត្រឹមតែភោជន កាលបើយ៉ាងនេះ ( ជីវិតនឹងប្រព្រឹត្តទៅ ) ត្រឹម ៦ ថ្ងៃ ព្រោះគាត់ខ្វាក់ មុខជានឹងស្លាប់ដោយឥតទឹកពុំខាន ។ ទុក្ខនេះ មិនមែនជាទុក្ខ របស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះ បុរសត្រូវតែបាន ត្រង់ដែលទូលបង្គំជាខ្ញុំ ខានឃើញមាតា ដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែង របស់ទូលបង្គំជាខ្ញុំ

ជាងទុក្ខនេះ ( ទៅទៀត ) ។ ទុក្ខនេះ មិនមែនជាទុក្ខ របស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះ បុរសត្រូវតែបាន ត្រង់ដែលទូលបង្គំជាខ្ញុំមានឃើញបិតា ដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែង របស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ ( ទៅទៀត ) ។ ឱម្ល៉េះ សមមាតានៅកំព្រា ទួញយំទាំងអធ្រាត្រ និងទីបំផុតនៃរាត្រីអស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួតទៅ ដូចជាស្ទឹង ( ក្នុងគិម្ហរដូវ ) ពុំខាន ។ ឱម្ល៉េះ សមបិតា នៅកំព្រា ទួញយំទាំងអធ្រាត្រ និងទីបំផុតនៃរាត្រី អស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួត ដូចជាស្ទឹងពុំខាន ។ បពិត្រព្រះរាជា មួយវិញទៀត ( ខ្ញុំតែងភ្ញាក់ក្នុងមួយយប់ពីរបីដង ) ដើម្បីបម្រើបាទាដោយព្យាយាម និងដើម្បីគក់ប្រេបាច់ ម្ល៉េះសមគាត់នឹងដើរ ចប្រប់ក្នុងព្រៃធំ ដង្ហើយហៅថា អឺ បាសាមៈ ដូច្នេះ ពុំខានឡើយ ។ បើទូលបង្គំជាខ្ញុំខានឃើញជនទាំងទាំងពីរនាក់ ដោយហេតុណា ហេតុនោះឯង ទុកជាសរទីពីរ ដែលញាំងហឫទ័យ របស់ទូលបង្គំជាខ្ញុំ ឲ្យញាប់ញ័រ មុខជាជីវិតទូលបង្គំជាខ្ញុំ នឹងវិនាសពុំខាន ។

[ ៩៧ ] ( ព្រះបាទបិលយក្ខ ) ម្នាលសាមៈ ជាអ្នកមានរូបល្អគួរឲ្យគយគន់ អ្នកកុំទួញយំខ្លាំងឡើយ ខ្ញុំនឹងជាអ្នកធ្វើការងារបចិញ្ចឹមនូវជនទាំងឡាយនោះ ក្នុងព្រៃធំ ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃ ក្នុងសិល្បធ្នូស្រាប់ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់

នូវផ្លូវដ៏មាំ ខ្ញុំជាអ្នកធ្វើការងារ ចិញ្ចឹមនូវជនទាំងឡាយនោះ ក្នុងព្រៃធំ ។ ខ្ញុំនឹងជាអ្នកធ្វើការងារ ស្វែងរកវំពានៃម្រឹគ និងមើមឈើផ្លែឈើទាំងឡាយក្នុងព្រៃ ហើយនឹងចិញ្ចឹម នូវជនទាំងឡាយនោះក្នុងព្រៃធំ ។ ម្នាលសាមៈ មាតាបិតារបស់អ្នក នៅក្នុងព្រៃណាព្រៃនោះដូចម្តេច អ្នកបានចិញ្ចឹម នូវមាតាបិតាយ៉ាងណា ខ្ញុំក៏នឹងចិញ្ចឹមនូវគាត់យ៉ាងនោះដែរ ។

[ ៩៨ ] ( ព្រះមហាសត្ត ) បពិត្រព្រះរាជា ផ្លូវចុះតែជើងម្នាក់នេះនៅខាងក្បាលដំណេកទូលបង្គំជាខ្ញុំ ព្រះអង្គយាងទៅអំពីទីនេះតែកន្លះយោសៈ ( នឹងឃើញ ) ខ្ទមជាទីនៅរបស់មាតាបិតា ទូលបង្គំជាខ្ញុំនោះ ព្រះអង្គយាងទៅអំពីទីនេះ សូមទ្រង់ចិញ្ចឹមនូវគាត់ក្នុងទីនោះផង ។

[ ៩៩ ] បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះរាជា ទ្រង់មានសេចក្តីចម្រើនក្នុងដែនកាសី ទូលបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះអង្គ មាតាបិតាទាំងឡាយរបស់ទូលបង្គំជាខ្ញុំ ជាមនុស្សខ្វាក់ សូមទ្រង់ចិញ្ចឹមនូវគាត់ ក្នុងព្រៃធំឲ្យទាន ។ ទូលបង្គំជាខ្ញុំ សូមផ្គងអញ្ជលីចំពោះព្រះអង្គ បពិត្រព្រះរាជាជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះអង្គទូលបង្គំជាខ្ញុំសូមផ្តាំទុក សូមទ្រង់ជម្រាបនូវការថ្វាយបង្គំ ចំពោះមាតាបិតា របស់ទូលបង្គំជាខ្ញុំផង ។

[ ១០០ ] ( អភិសម្ពុទ្ធគាថា ) សាមៈ កំលោះ អ្នកមានរូបល្អគួរពិតពិលរមិលមើលនោះ លុះពោលនូវពាក្យនេះរួចហើយ ក៏ជ្រប់សន្ទប់ដោយកម្លាំងពិស ។

[ ១០១ ] ព្រះរាជាអង្គនោះ ទ្រង់ព្រះកន្សែង រៀបរាប់នូវពាក្យដែលប្រកបដោយសេចក្តីករុណា មានប្រមាណច្រើនថា អាត្មាអញបានយល់ថា អញមិនចាស់ មិនស្លាប់ ថ្ងៃនេះ អញឃើញនូវសុវណ្ណសាមនេះ ធ្វើកាលកិរិយាហើយ ទើបដឹងនូវហេតុនោះ ពីដើមមិនដឹងជាការមក នៃសេចក្តីស្លាប់ មិនមែនមិនមាន ដូច្នេះ ។ សាមៈ ដែលជោកដោយថ្នាំពិស កំពុងចរចាជាមួយនឹងអញ ( ក្នុងកាលអម្បាញ់មិញនេះ ) ឥឡូវនេះ គាត់លែងនិយាយពាក្យតិចតួច ក្នុងកាលប្រព្រឹត្តទៅយ៉ាងនេះ ក្នុងថ្ងៃនេះ អាត្មាអញ មុខជានឹងទៅកាន់នរកពុំខាន អាត្មាអញ ឥតមានសេចក្តីសង្ស័យ ក្នុងដំណើរនេះទេ ។ ព្រោះថា អំពើបាបដែលអាត្មាអញធ្វើទុកហើយក្នុងគ្រានោះ នឹងជាទោសឲ្យផលលាមក អស់កាលជាអង្វែង ( បើ ) ក្នុងស្រុក គង់មានពួកអ្នកតិះដៀលអញនោះថា ព្រះអង្គជាអ្នកធ្វើនូវអំពើអាក្រក់ដូច្នេះ តែក្នុងអរញ្ញប្រទេស ដែលឥតមនុស្ស តើអ្នកណាតិះដៀលអញបាន បើក្នុងស្រុក ពួកមាណពប្រជុំគ្នា ហើយចោទប្រកាន់នូវអំពើទាំងឡាយ ( របស់អញ ) តែក្នុងអរញ្ញប្រទេស ដែលឥតមនុស្ស តើអ្នកណានឹងចោទប្រកាន់អញ ។

[ ១០២ ] ទេវតានោះ បាត់អំពីក្អមទន្ធមាទន៍ ហើយពោលនូវគាថាទាំងឡាយនេះ ដោយអនុគ្រោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គទ្រង់បានធ្វើនូវបាបជាទម្ងន់ ដែលជាអំពើអាក្រក់ ជនទាំង ៣ នាក់ គឺមាតា បិតា និងបុត្ត ជាអ្នកមិនប្រទូស្ត ទ្រង់បានសម្លាប់ហើយ ដោយព្រួញតែមួយ ។ សូមទ្រង់មក សុគតិ-កព និងគប្បីមានដល់ព្រះអង្គយ៉ាងណា ខ្ញុំនឹងពន្យល់ព្រះអង្គយ៉ាងនោះ សូមទ្រង់ចិញ្ចឹមនូវជនខ្វាក់ ទាំងពីរនាក់នោះឯងដោយធម៌ ខ្ញុំយល់ថា សុគតិគប្បីមាន ។

[ ១០៣ ] ព្រះរាជាអង្គនោះ ទ្រង់ពិលាបរៀបរាប់ ប្រកបដោយសេចក្ដីករុណា មានប្រមាណច្រើន ហើយកណ្ដៀតក្អមទឹក យាងឆ្ពោះទៅទិសទក្សិណ ។

[ ១០៤ ] ( ទុក្កូលបណ្ឌិត ... ) សូរជើងនរណាទុំះហ្ន៎ ដែលដើរមកនេះ ពិតជាសូរជើងមនុស្ស តែសូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិទ្រ្ទ អ្នកជាអ្វីហ្នឹង ។ ដ្បិតសាមៈតែងដើរថ្នមៗ លើកដាក់ជើងស្រាលៗ សូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិទ្រ្ទ អ្នកជាអ្វីហ្នឹង ។

[ ១០៥ ] ( ព្រះបាទបិលយក្ខ ... ) ខ្ញុំជាព្រះរាជា របស់ពួកអ្នកដែនកាសី គេស្គាល់ខ្ញុំថាបិលយក្ខ ខ្ញុំលះបង់នូវដែន ត្រាច់ស្វែងរកម្រឹគ ព្រោះលោភ ( សាច់ ) ។ មួយទៀត ខ្ញុំជាអ្នកឈ្លាសវៃ

ក្នុងសិល្បផ្ទ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវផ្ទដ៏មាំបាន សូមរ្បីដ៏រីមកចំមុខព្រញរបស់ខ្ញុំហើយ មិនគប្បីរួចទេ ។

[ ១០៦ ] ( ទុកូលបណ្ឌិត ... ) បពិត្រមហារាជ ព្រះរាជដំណើរមក របស់ព្រះអង្គល្អហើយ ព្រះដំណើរមករបស់ព្រះអង្គ មិនអាក្រក់ទេ ព្រះអង្គជាធំទ្រង់យានមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូលចុះ ។ បពិត្រព្រះរាជា ផលាផល គឺផ្លែទន្លាប់ មាក់ប៉ែន ស្រគំ ស៊ីងមានរសផ្អែមដូចទឹកឃ្មុំ អាត្មាភាពប្រមូលមកទុក ក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផលមានរសឆ្ងាញ់ៗ ។ នេះទឹកត្រជាក់សម្រាប់សោយ ដែលដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ បើទ្រង់សព្វព្រះហឫទ័យ ទ្រង់ ( ដង ) អំពីទីនេះ សោយចុះ ។

[ ១០៧ ] ( ព្រះរាជា ... ) អ្នកទាំងពីរជាមនុស្សខ្វាក់ មិនអាចឃើញ ( អ្វី ) ក្នុងព្រៃទេ ចុះនរណា ប្រមូលនូវផលាផលមកជូនអ្នក អាហារដែល ( បាន ) ដោយប្រពៃនេះ ប្រាកដដល់ខ្ញុំ ដូចជាអាហាររបស់មនុស្សមិនខ្វាក់ ។

[ ១០៨ ] ( ទុកូលបណ្ឌិត ... ) សាមៈកំលោះនៅក្មេង មិនខ្ពស់មិនទាបពេក ជាមនុស្សមានរូបល្អគួរគយគន់ មានសក់វែងខ្មៅទាំងមានចុងទន់ល្វន់ ។ សាមៈនោះឯង តែងស្វែងរកផលាផលជាអ្នកដងទឹក បានកាន់យកក្អមទឹកអំពីទីនេះ ទៅកាន់ស្ទឹងប្រហែល

ជាជិតមកដល់ហើយ ។

[ ១០៩ ] ( ព្រះបាទបិលយក្ខ ... ) សាមៈជាអ្នកបម្រើអ្នក អ្នកនិយាយសំដៅកុមារ ឈ្មោះសាមៈណា ដែលមានរូបគួរគយគន់ សាមៈនោះខ្ញុំសម្លាប់ហើយ ។ សាមៈដែលមានសក់វែង ពណ៌ខ្មៅ ចុងទន់ល្មន់ ( ឥឡូវនេះ ) ខ្ញុំសម្លាប់ដួលដេក លើសក់ទាំងនោះ ប្រឡាក់ហើយដោយឈាម ។

[ ១១០ ] ( នាងបារិកា ) បពិត្រទុកូល អ្នកប្រឹក្សាជាមួយនរណា ដែលបាននិយាយថា ខ្ញុំសម្លាប់សាមៈហើយ បេះដូងខ្ញុំញ័រចំប្រប់ ព្រោះឮថាសាមៈស្លាប់ហើយ ។ ហឫទ័យខ្ញុំញាប់ញ័រ ហាក់ដូចត្រួយពោធិបាយខ្ចី ដែលមានខ្យល់ប៉ះទង្គិច ព្រោះឮថា សាមៈស្លាប់ហើយ ។

[ ១១១ ] ( ទុកូលបណ្ឌិត ... ) ម្នាលនាងបារិកា នេះជាព្រះរាជាជាធំក្នុងដែនកាសី ព្រះអង្គបាញ់សាមៈដោយព្រួញ ក្បែរស្ទឹងមិគសម្មតៈ ដោយសេចក្តីក្រោធ យើងកុំចង់ឲ្យមានបាប ដល់ព្រះអង្គឡើយ ។

[ ១១២ ] ( នាងបារិកា ... ) បុត្តដែលចិញ្ចឹមយើង ផងនឹតផងល់ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់ យើងរកបានដោយកម្រ ចិត្តមិនគប្បីរំជួលក្នុងបុរស អ្នកសម្លាប់កូនប្រុសតែមួយនោះ ដូចម្តេចបាន ។

[ ១១៣ ] ( ទុកូលបណ្ឌិត ...) បុត្តដែលចិញ្ចឹមយើង ផងនឹតផងល់

ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់ យើងរកបានដោយកម្រ បណ្ឌិតទាំងឡាយសរសើរសេចក្តីមិនក្រោធ ចំពោះបុរស អ្នកសម្លាប់នូវបុត្តតែមួយនោះ ។

[ ១១៤ ] ( ព្រះបាទបិលយក្ខ ... ) អ្នកទាំងពីរកុំគប្បីខ្សឹកខ្សួលខ្លាំង ចំពោះខ្ញុំអ្នកពោលថា សាមៈខ្ញុំសម្លាប់ហើយ ខ្ញុំនឹងជាអ្នកធ្វើការងារចិញ្ចឹម ( អ្នកទាំងពីរ ) ក្នុងព្រៃធំ ។ ព្រោះខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំ ខ្ញុំនឹងធ្វើការងារចិញ្ចឹម ( អ្នក ) ក្នុងព្រៃធំ ។ ខ្ញុំនឹងធ្វើការងារ ស្វែងរកសំពាម្រឹគទាំងឡាយ ទាំងមើមឈើ ផ្លែឈើ ហើយចិញ្ចឹម ( អ្នក ) ក្នុងព្រៃធំ ។

[ ១១៥ ] ( ជនទាំងពីរ ... ) បពិត្រមហារាជ នេះមិនមែនជាទំនៀមទេ កិរិយាធ្វើនូវអំពើ ( របស់ព្រះអង្គ ) នេះ មិនសមគួរដល់យើងឡើយ ព្រះអង្គជាព្រះរាជារបស់យើងៗ សូមថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ ។

[ ១១៦ ] ( ព្រះរាជា ... ) បពិត្រអ្នកនេសាទ អ្នកពោលនូវធម៌ អ្នកធ្វើនូវសេចក្តីគោរព ( ចំពោះខ្ញុំ ) អ្នកទុកជាបិតារបស់ខ្ញុំ បពិត្រនាងបារិកា នាងទុកជាមាតារបស់ខ្ញុំ ។

[ ១១៧ ] ( ជនទាំងពីរ ... ) បពិត្រព្រះរាជា ជាធំក្នុងដែនកាសីទូលបង្គំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ ទ្រង់ចម្រើនក្នុងដែន

កាសី ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ ទូលបង្គំទាំងឡាយ សូមប្រណម្យអញ្ជលីចំពោះព្រះអង្គ សូមព្រះអង្គនាំទូលបង្គំ ទៅដល់សាមៈ ។ ទូលបង្គំទាំងឡាយ នឹងប្របាច់ជើង ស្ទាបមុខល្អគួរមើលរបស់សាមៈនោះ ត្រៀមរង់ចាំនូវសេចក្តីស្លាប់ប៉ុណ្ណោះ ។

[ ១១៨ ] ( ព្រះបាទបិលយក្ខ ... ) សាមៈដែលស្លាប់ហើយ ដួលដេកដូចជាព្រះចន្ទ្រ ធ្លាក់មកលើប្រឹថពី ក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។ សាមៈដែលស្លាប់ហើយ ដួលដេកដូចជាព្រះអាទិត្យ ធ្លាក់មកលើប្រឹថពីក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។ សាមៈដែលស្លាប់ហើយ ដួលដេកប្រឡាក់ប្រឡូសដោយអាចម៍ដី នៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។ សាមៈដែលស្លាប់ហើយ ដួលដេកនៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ( ព្រោះហេតុនោះ ) អ្នកទាំងឡាយ ចូរនៅតែក្នុងអាស្រមនេះហើយ ។

[ ១១៩ ] ( ជនទាំងពីរនាក់ ... ) បើទុកណាជាទីនោះ ( មានម្រឹគសាហាវ ) រយ ពាន់ ម៉ឺនក្តី ទូលបង្គំទាំងពីរនាក់ ឥតមាន

សេចក្តីភិតភ័យតិចតួច ព្រោះសត្វសាហាវទាំងឡាយ ក្នុងព្រៃទេ ។

[ ១២០ ] ( អភិសម្ពុទ្ធគាថា ... ) គ្រានោះ ព្រះរាជាជាធំក្នុងដែនកាសី នាំជនខ្វាក់ ( ទាំងពីរ ) ដឹកដៃទៅក្នុងព្រៃធំ ត្រង់កន្លែងដែលសាមៈស្លាប់ ។

[ ១២១ ] មាតាបិតាឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ហាក់ដូចព្រះចន្ទ្រដែលធ្លាក់មកលើប្រឹថពី ។ ឃើញនូវសាមៈជាបុត្តដួលប្រឡាក់ប្រឡូស ដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ដូចព្រះអាទិត្យ ដែលធ្លាក់មកលើប្រឹថពី ។ ឃើញនូវសាមៈជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ក៏យំរាប់រៀបគួរឲ្យអាណិត ។ ឃើញនូវសាមៈជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ហើយផ្គងដើមដៃ យំទន្ទឹះខ្សឹកខ្សួលថា ហៃបាដ៏ចម្រើន ( ការស្លាប់នេះ ) មានសភាពមិនគួរទេ ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាឯងជាមនុស្សស្រវឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈ ថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱបាសាមៈ មានរូបល្អគួរឲ្យក្រឡេកមើល បាជាមនុស្សភ្លើតភ្លើនខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈ ថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱបាសាមៈ អ្នកមានរូបល្អគួរឲ្យក្រឡេក

មើល បាឯងទីងខ្ទាំង បានជាក្នុងកាលដែលដល់នូវមរណៈ ក្នុងថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱបាសាមៈ មានរូបល្អគួរឲ្យក្រឡេកមើល បាឯងដេកលក់ស៊ប់ បានជាក្នុងកាលដែលដល់នូវមរណៈ ក្នុងថ្ងៃនេះ បាឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱសាមៈ មានរូបល្អគួរឲ្យក្រឡេកមើល បាជាបុគ្គលតូចចិត្តខ្ទាំង បានជាក្នុងកាលដែលដល់នូវមរណៈ ក្នុងថ្ងៃនេះ បាឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឥឡូវនេះ នរណានឹងរៀបចំជដាដ៏សៅហ្មង ប្រឡាក់ប្រឡូសដោយអាចម៍ដី ព្រោះសាមៈ ជាអ្នកបម្រើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ ។ នរណានឹងកាន់អំបោស បោសអាស្រមដើម្បីយើង ព្រោះសាមៈ ជាអ្នកបម្រើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ ។ ឥឡូវនេះ នរណានឹងផ្ងូត ( យើង ) ដោយទឹកត្រជាក់ ទឹកក្តៅ ព្រោះសាមៈជាអ្នកបម្រើយើងងងឹតងងល់នេះធ្វើមរណកាលហើយ ។ ឥឡូវនេះ នរណានឹងឲ្យយើងបរិភោគមើមឈើ ផ្លែឈើ ព្រោះសាមៈជាអ្នកបម្រើយើងងងឹតងងល់នេះធ្វើមរណកាលហើយ ។

[ ១២២ ] មាតាឃើញសាមៈជាបុត្ត ជួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្តីសោកព្រោះកូនបៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះជាអ្នកប្រព្រឹត្តធម៌ដោយ

សច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុនសាមៈនេះ ជាអ្នកពោលនូវពាក្យសត្យ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះជាអ្នកបម្រើមាតា និងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំ ជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលបិតារបស់អ្នកផង បានធ្វើហើយដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ។

[ ១២៣ ] បិតាឃើញសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្ដីសោកព្រោះកូនបៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះជាអ្នកប្រព្រឹត្តធម៌ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការ

ពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុនសាមៈ ជាអ្នកពោលនូវពាក្យសត្យ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកចិញ្ចឹមមាតា និងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាបុគ្គលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលមាតារបស់អ្នកផង បានធ្វើហើយដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ។

[ ១២៤ ] ទេវតានោះ បាត់អំពីភ្នំគន្ធមាទន៍ បានពោលនូវពាក្យសច្ចៈនេះ ដោយសេចក្តីអនុគ្រោះសាមៈថា ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍អស់កាលជាយូរអង្វែងហើយ ឥតមាននរណាដទៃដែលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំ ជាងសាមៈទេ ដោយការពោលសច្ចៈនុ៎ះ សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ។ នៅ

ភ្នំគន្ធមាទន៍ សព្វព្រៃព្រឹក្សាទាំងឡាយ សុទ្ធសឹងមានក្លិនក្រអូប ដោយការពោលសច្ចៈនេះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ។ កាលបើជនទាំងនោះ កំពុងចរចារៀបរាប់នូវពាក្យប្រកបដោយសេចក្ដីករុណា មានប្រមាណច្រើន សាមៈជាមនុស្សកំលោះ មានរូបល្អគួរឲ្យរមិលមើល ក៏ក្រោកឡើងភ្លាម ។

[ ១២៥ ] ( មហាសត្វ ... ) ខ្ញុំឈ្មោះសាមៈ សេចក្ដីចម្រើនចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងដោយសួស្ដីហើយ សូមលោកទាំងឡាយ កុំខ្សឹកខ្សួលខ្លាំងឡើយ សូមលោកទាំងឡាយចរចាចំពោះខ្ញុំដោយពាក្យពីរោះ ។

[ ១២៦ ] បពិត្រមហារាជ ព្រះរាជដំណើររបស់ព្រះអង្គមកល្អហើយ ទ្រង់យាងមកមិនអាក្រក់ទេ ព្រះអង្គជាធំទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូល ។ បពិត្រមហារាជ ផលាផលមានផ្លែទន្លាប់ មាក់ប្រ៉ែន ស្រគំ សឹងមានរសផ្អែមដូចទឹកឃ្មុំ ទូលបង្គំជាខ្ញុំប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផល ដែលមានរសឆ្ងាញ់ៗ ។ បពិត្រមហារាជ ទឹកសម្រាប់សោយដ៏ត្រជាក់ ទូលបង្គំជាខ្ញុំបាននាំមកអំពីជ្រោះភ្នំ បើព្រះអង្គមានសេចក្ដីត្រូវការ សូមទ្រង់ជងអំពីទីនោះសោយចុះ ។

[ ១២៧ ] ( ព្រះបាទបិលយក្ខ... ) ខ្ញុំវង្វេងកាន់កាំងស្មារតី ងងឹត

ផងលស់សព្វទិសានុទិស ព្រោះបានឃើញសាមៈនោះធ្វើមរណកាលហើយ ម្នាលសាមៈ អ្នកដូចម្តេចក៏រស់ឡើងវិញ ។

[ ១២៨ ] ( មហាសត្ត ... ) បពិត្រមហារាជ ( សត្វលោក ) តែងសម្គាល់នូវបុរសដែលមានវេទនាធ្ងន់តែនៅរស់ ឬមានសេចក្តីត្រិះរិះក្នុងចិត្ត ធ្លាក់ចុះក្នុងភវង្គ ដែលនៅរស់ថាស្លាប់ ។ បពិត្រមហារាជ ម្យ៉ាងទៀត ( សត្វលោក ) តែងសម្គាល់នូវបុរសដែលមានវេទនាធ្ងន់តែនៅរស់ ឬចូលនិរោធ នៅរស់នោះថាស្លាប់ហើយ ។

[ ១២៩ ] សត្វណាតែងចិញ្ចឹមនូវមាតា និងបិតាដោយធម៌ ទេវតាទាំងឡាយតែងរក្សានូវសត្វអ្នកចិញ្ចឹមមាតាបិតានោះ ។ សត្វណា តែងចិញ្ចឹមមាតា និងបិតាដោយធម៌ បណ្ឌិតទាំងឡាយក្នុងលោកនេះឯង តែងសរសើរនូវសត្វនោះ សត្វនោះលុះលះបង់លោកនេះទៅ រមែងរីករាយក្នុងស្ថានសួគ៌ ។

[ ១៣០ ] ( ព្រះបាទបិលយក្ខ... ) ខ្ញុំរឹងរឹតតែវង្វេង ភាន់ភាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ម្នាលសាមៈ ខ្ញុំសូមយកអ្នកជាទីពឹង អ្នកចូរជាទីពឹងរបស់ខ្ញុំ ។

[ ១៣១ ] ( ព្រះមហាសត្ត ... ) បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមាតា និងបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះបុត្រ និងភរិយា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមិត្ត និងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសត្វពាហនៈ និងពល បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះស្រុក និងនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះអ្នកដែន និងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសមណៈ និងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះម្រឹគ និងបក្សី បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ធម៌ដែលប្រព្រឹត្តល្អហើយ

តែងនាំមកនូវសុខ បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រព្រះមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ( ព្រោះ ) ទេវតាឥន្ទព្រហ្មដែលបានដល់នូវស្ថានសួគ៌ ក៏ព្រោះធម៌ដែលខ្លួនប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ ។

## សុវណ្ណសាមជាតកទី ៣ ចប់

# អដ្ឋកថា

## សុវណ្ណសាមជាតក

[ ៨៩-១៣១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប អ្នកចិញ្ចឹមមាតា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោ នុ មំ ឧសុនា វិជ្ឈិ** ដូច្នេះជាដើម ។

បានឮមកថា ក្នុងក្រុងសាវត្ថី មានកុលបុត្រម្នាក់ ជាបុត្រទោលរបស់ត្រកូលសេដ្ឋីមួយមានទ្រព្យសម្បត្តិ ១៨ កោដិ កុលបុត្រនោះជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា ។ ថ្ងៃមួយ ឡើងលើប្រាសាទបើកសីហបញ្ជរសម្លឹងមើលមកមហាវិថី ឃើញមហាជនកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម ទៅកាន់វត្តជេតពន ដើម្បីស្តាប់ព្រះធម្មទេសនា ទើបគិតថា អញនឹងទៅជាមួយជនទាំងនោះដែរ ទើបឲ្យមនុស្សកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើមទៅកាន់វិហារ ថ្វាយសំពត់ ភេសជ្ជៈ និងទឹកធាន់ជាដើមដល់ព្រះសង្ឃ បូជាព្រះសាស្តាដោយគ្រឿងក្រអូប និងផ្កាជាដើម ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ស្តាប់ព្រះធម្មទេសនាហើយ ឃើញទោសក្នុងកាមទាំងឡាយ កំណត់អានិសង្សនៃបព្វជ្ជា កាលបរិស័ទក្រោកទៅហើយ ទើបថ្វាយបង្គំព្រះមានព្រះភាគ ទូលសូមបព្វជ្ជា ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងកុលបុត្រនោះយ៉ាងនេះថា ព្រះតថាគតទាំងឡាយ មិនញុំាងបុត្រដែលមាតាបិតាមិនអនុញ្ញាតឲ្យបព្វជ្ជាឡើយ កុលបុត្របានស្តាប់ព្រះតម្រាស់នោះ ទើបថ្វាយបង្គំព្រះដ៏មានព្រះភាគ ត្រឡប់ទៅគេហដ្ឋាន សំពះមាតាបិតាដោយសេចក្តីគោរព ពោលយ៉ាងនេះថា បពិត្រលោកឪពុក អ្នកម្តាយ ខ្ញុំនឹង

បួសក្នុងសម្នាក់ព្រះតថាគត លំដាប់នោះ មាតាបិតារបស់កុលបុត្រនោះ បាន ស្តាប់ពាក្យរបស់គេហើយ បេះដូងហាក់បែកសញ្ជែកជា ៧ ភាគ ព្រោះមាន កូនតែមួយ ញាប់ញ័រដោយសេចក្តីស្នេហាក្នុងបុត្រ បានពោលយ៉ាងនេះថា នែបា ឯងជាកូនជាទីស្រឡាញ់ ជាពន្លកនៃត្រកូល ជាកែវភ្នែក ជាជីវិតនៃ យើងទាំងពីរ ពុក និងម៉ែវៀរចាកឯងហើយ នឹងមានជីវិតបានដូចម្តេច ជីវិត របស់យើងទាំងពីរ ជាប់ទាក់ទងនឹងឯង យើងទាំងពីរក៏ចាស់ជរាហើយ នឹង ស្លាប់ក្នុងថ្ងៃនេះ ស្អែកនេះ ឬខានស្អែកនេះ ឯងលះបង់យើងទាំងពីរទៅទៀត ឬ ធម្មតាបព្វជ្ជា បុគ្គលធ្វើបានលំបាកក្រៃលែង បើត្រូវការត្រជាក់ រមែងបាន ក្តៅ បើត្រូវការក្តៅ រមែងបានត្រជាក់ ព្រោះហេតុនោះ កូនកុំបួសឡើយ ។ កុលបុត្របានស្តាប់ពាក្យរបស់មាតាបិតា ដូច្នោះ ក៏មានសេចក្តីទុក្ខទោមនស្ស អង្គុយឱនមុខស្រុបសៅ មិនបរិភោគអាហារអស់ ៧ ថ្ងៃ លំដាប់នោះ មាតា បិតារបស់កុលបុត្រនោះ គិតគ្នាយ៉ាងនេះថា បើកូនរបស់យើងមិនបានទទួល អនុញ្ញាតឲ្យបួស ក៏នឹងស្លាប់ យើងនឹងមិនបានឃើញគេទៀតឡើយ បើកូន របស់យើងរស់ដោយភេទអ្នកបួស យើងនឹងគង់បានឃើញតទៅទៀត កាល គិតឃើញយ៉ាងនេះហើយ ទើបអនុញ្ញាតថា នែបា កូនជាទីស្រឡាញ់ យើង អនុញ្ញាតឲ្យឯងបួស ចូរឯងបួសចុះ កុលបុត្របានស្តាប់ដូច្នោះ ក៏មានចិត្ត ត្រេកអរ បន្ទន់សរីរៈ ក្រាបទៀបបាតជើងមាតាបិតា លាចេញអំពីក្រុងសាវត្ថី ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តាទូលសូមបព្វជ្ជា ។ ព្រះសាស្តាត្រាស់ ឲ្យភិក្ខុមួយរូប បំបួសកុលបុត្រនោះជាសាមណេរ ។ សាមណេរនោះ ចាប់

ពីបួសហើយ លាភសក្ការៈកើតឡើងជាច្រើន សាមណេរនោះ បានញុំាង អាចារ្យ និងឧបជ្ឈាយ៍ឲ្យត្រេកអរ ឧបសម្បទាជាភិក្ខុហើយ រៀនធម៌បាន ៥ វស្សា ក៏ត្រិះរិះថា អញនៅក្នុងទីនេះប្រឡូកប្រឡំដោយពួកញាតិជាដើម មិនសមគួរដល់អញឡើយ ជាអ្នកប្រាថ្នាបំពេញវិបស្សនាធុរៈ ទើបរៀនកម្មដ្ឋាន ក្នុងសម្នាក់ឧបជ្ឈាយ៍ ចេញអំពីវិហារជេតពន ទៅកាន់បច្ចន្តគ្រាមមួយកន្លែង នៅក្នុងព្រៃអាស្រ័យបច្ចន្តគ្រាមនោះ ។ ភិក្ខុនោះ ចម្រើនវិបស្សនាក្នុងទីនោះ សូម្បីព្យាយាមអស់ ១២ ឆ្នាំ ក៏មិនអាចញុំាងធម្មវិសេសឲ្យកើត ។ ចំណែក មាតាបិតារបស់ភិក្ខុនោះ ក្នុងកាលកន្លងមកក៏ធ្លាក់ខ្លួនក្រីក្រ ព្រោះថា ពួកជន ដែលប្រកបកសិកម្ម ឬពាណិជ្ជកម្មរបស់ជនទាំងពីរនោះគិតថា បុត្រ ឬបងប្អូនដែលនឹងទារបំណុលហើយទទួលយកទ្រព្យ មិនមានក្នុងត្រកូលនេះ ទើបពួកជនទាំងនោះកាន់យកទ្រព្យតាមកម្លាំងរៀងៗ ខ្លួន គេចទៅតាមគាប់ចិត្ត សូម្បីទាសកម្មករក្នុងផ្ទះជាដើម ក៏កាន់យកប្រាក់មាសជាដើមគេចទៅ ។ គ្រាតមក ជនទាំងពីរក៏ជួបនូវទុក្ខលំបាកពន់ពេក មិនបានសូម្បីការស្រោចទឹកក្នុងដៃ ត្រូវលក់ផ្ទះ មិនមានផ្ទះ ដល់នូវភាពជាបុគ្គលគួរករុណាក្រៃលែង ស្លៀកកន្ទប កាន់អំបែង ដើរសូមទានក្នុងទីនោះៗ ។ ក្នុងកាលនោះ ភិក្ខុមួយរូបចេញអំពីវត្តជេតពន ទៅដល់លំនៅរបស់បុត្រសេដ្ឋីអនាថានោះ ភិក្ខុសេដ្ឋីបុត្រនោះ ធ្វើអាគន្តុកវត្តដល់ភិក្ខុនោះហើយ អង្គុយជាសុខ ហើយទើបសួរថា លោកម្ចាស់និមន្តមកអំពីណា អាគន្តុកភិក្ខុប្រាប់ថា មកពីវត្តជេតពន ទើបសួរដល់ភាពផាសុកនៃព្រះសាស្តា និងព្រះមហាសាវកជាដើម ហើយសួរដល់

ដំណឹងមាតាបិតាថា បពិត្រលោកម្ចាស់ ត្រកូលសេដ្ឋីឈ្មោះនោះ ក្នុងក្រុងសាវត្ថី សុខសប្បាយទេឬ អាគន្តុកភិក្ខុឆ្លើយថា អាវុសោ លោកកុំសួរដល់ត្រកូលនោះឡើយ លោកក៏សួរទៀតថា មានរឿងអ្វីឬ ភិក្ខុនោះឆ្លើយថា បានឮថា ត្រកូលនោះមានកូនម្នាក់ គេបួសក្នុងសាសនា ចាប់តាំងពីបួសហើយ ត្រកូលនោះក៏វិនាសទៅ ឥឡូវនេះ សេដ្ឋីទាំងពីរជាមនុស្សកំព្រា គួរករុណាក្រៃលែង កាន់អំបែង ដើរសូមទាន ។ ភិក្ខុសេដ្ឋីបុត្របានស្តាប់ពាក្យរបស់អាគន្តុកភិក្ខុហើយ មិនអាចតម្កល់ខ្លួនបាន មានទឹកភ្នែកជោកមុខ ព្រះថេរៈឃើញដូច្នេះ ទើបពោលថា អាវុសោយំធ្វើអ្វី ភិក្ខុជាសេដ្ឋីបុត្រឆ្លើយថា បពិត្រលោកម្ចាស់ ជនទាំងពីរនោះជាមាតាបិតារបស់ខ្ញុំ ខ្ញុំជាកូនរបស់លោកទាំងពីរនោះ ព្រះថេរៈក៏ពោលថា ឪពុកម្តាយរបស់លោក ដល់នូវសេចក្តីវិនាសព្រោះអាស្រ័យលោក ចូរលោកទៅបដិបត្តិមាតាបិតានោះ ភិក្ខុសេដ្ឋីបុត្រគិតថា សូម្បីអញព្យាយាមអស់ ១២ ឆ្នាំ ក៏មិនអាចញ៉ាំងមគ្គ និងផលឲ្យកើត អញជាអភព្វបុគ្គល ប្រយោជន៍អ្វីដោយបព្វជ្ជា អញនឹងសឹកទៅជាគ្រហស្ថចិញ្ចឹមឪពុកម្តាយ ឲ្យទាន នឹងមានស្ថានសួគ៌ជាទីទៅខាងមុខ គិតដូច្នេះហើយ ប្រគល់ទីលំនៅក្នុងព្រៃដល់ព្រះថេរៈ ថ្វាយបង្គំព្រះថេរៈហើយស្អែកឡើង ក៏ចេញអំពីព្រៃទៅដោយលំដាប់ ដល់វិហារមួយកន្លែង ជិតវត្តជេតពន មិនឆ្ងាយអំពីក្រុងសាវត្ថី មានផ្លូវបែកជាពីរ ផ្លូវមួយទៅកាន់វត្តជេតពន ផ្លូវមួយទៅក្រុងសាវត្ថី ភិក្ខុនោះឈប់នៅត្រង់នោះ គិតថា អញទៅរកឪពុកម្តាយមុន ឬទៅគាល់ព្រះសាស្តាមុន ក៏គិតបានថា អញមិនបានជួប

មាតាបិតាមកយូរហើយក៏ពិត តែចាប់អំពីពេលនេះ អញមិនងាយបានគាល់ព្រះសម្មាសម្ពុទ្ធ ថ្ងៃនេះ អញនឹងគាល់ព្រះសម្មាសម្ពុទ្ធហើយស្តាប់ធម៌ ស្អែកឡើងសឹមទៅរកមាតាបិតាអំពីព្រលឹម គិតដូច្នេះហើយ លះមាគ៌ាទៅកាន់ក្រុងសាវត្ថី ហើយចូលទៅកាន់ផ្លូវដែលទៅកាន់វត្តជេតពន ដល់វត្តជេតពនក្នុងពេលល្ងាច ។

ថ្ងៃនោះ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក ក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃភិក្ខុ ដែលជាបុត្រនៃត្រកូលនេះ ទើបទ្រង់ពណ៌នាគុណមាតាបិតាដោយមាតុបោសកសូត្រ ក្នុងពេលដែលភិក្ខុនោះមកដល់ ។ ភិក្ខុនោះឈរខាងចុងបរិស័ទ ស្តាប់ធម្មកថាដ៏ពីរោះ ទើបគិតថា អញគិតថានឹងសឹកទៅជាគ្រហស្ថ អាចបដិបត្តិមាតាបិតា តែព្រះសាស្តាត្រាស់ថា សូម្បីបព្វជិតក៏ធ្វើនូវឧបការៈដល់មាតាបិតាបាន បើអញមិនមកគាល់ព្រះសាស្តាមុនហើយទៅ ម៉្លេះសមសាបសូន្យចាកបព្វជ្ជាបែបនេះ ឥឡូវនេះ អញមិនចាំបាច់សឹកជាគ្រហស្ថ នៅជាបព្វជិតនេះឯង នឹងទំនុកបម្រុងមាតាបិតា ភិក្ខុនោះក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយចេញអំពីវត្តជេតពន ទៅកាន់រោងស្លាកទទួលភត្តាហារ និងយាគូដែលបានដោយស្លាក ជាភិក្ខុអ្នកនៅព្រៃអស់ ១២ ឆ្នាំ បានដូចជាដល់នូវភាពជាបុគ្គលចាលចាញ់ហើយ ភិក្ខុនោះចូលទៅក្នុងក្រុងសាវត្ថីអំពីព្រឹកនោះឯង គិតថា អញនឹងទទួលយាគូមុន ឬទៅរកមាតាបិតាមុន ហើយគិតថា ការមានដៃទទេ ចូលទៅកាន់សម្នាក់មនុស្សកំព្រាមិនសមគួរ ទើបកាន់យកបបរទៅកាន់ផ្ទះចាស់របស់មាតាបិតាទាំងនោះ បាន

ឃើញមាតាបិតាដើរសូមបបរ ហើយចូលអាស្រ័យសំយាបផ្ទះរបស់អ្នកដទៃ អន្តុយ ភិក្ខុនោះចូលទៅក្បែរហើយ ឃើញមាតាបិតាដែលដល់នូវភាពជាមនុស្សកំព្រាតោកយ៉ាក ក៏មានសេចក្តីសោកកើតឡើង មានទឹកភ្នែកជោកមុខ ឈរក្នុងទីក្បែរៗ មាតាបិតាទាំងពីរនោះ មាតាបិតាឃើញលោកហើយមិនស្គាល់ មាតារបស់ភិក្ខុនោះសម្គាល់ថា ភិក្ខុឈរដើម្បីបិណ្ឌបាតទើបពោលថា បពិត្រលោកម្ចាស់ របស់ទំពា របស់ឆាន់ដែលគួរប្រគេនលោកម្ចាស់មិនមាន សូមនិមន្តប្រោសសត្វឯមុខចុះ ។ ភិក្ខុនោះ បានស្តាប់ពាក្យរបស់មាតា ក៏មានសេចក្តីសោកជាកម្លាំង មានទឹកភ្នែកជោកមុខ ឈរត្រង់ទីនោះឯង ព្រោះបានទទួលនូវសេចក្តីសោក សូម្បីមាតាពោលបែបនោះអស់វារៈ ២-៣ ដង ក៏នៅតែឈរនោះឯង លំដាប់នោះ បិតារបស់ភិក្ខុនោះពោលនឹងមាតាថា ចូរនាងទៅមើល នុ៎ះជាកូនរបស់យើងទាំងពីរទេដឹង នាងក្រោកឡើងហើយ ទៅជិតភិក្ខុនោះឯង សម្លឹងមើល ក៏ស្គាល់ ទើបក្រាបចុះបរិទេវនាការទៀបបាទានៃភិក្ខុដែលជាបុត្រ បិតាក៏ទៅដែរ អន្ទុយយំក្នុងទីនោះដូចគ្នា គួរករុណាក្រៃលែង ចំណែកភិក្ខុនោះ ឃើញមាតាបិតា មិនអាចតម្កល់កាយបានក៏យំ ភិក្ខុនោះអត់សង្កត់នូវសេចក្តីសោកហើយ ពោលថាលោកទាំងពីរកុំគិតថ្វីឡើយ អាត្មានឹងចិញ្ចឹមលោកទាំងពីរ ឲ្យរស់នៅជាសុខញ៉ាំងមាតាបិតាឲ្យកក់ក្តៅហើយ ឲ្យបរិភោគបបរ ឲ្យអន្តុយសម្រាកក្នុងទីសមគួរមួយកន្លែង នាំភិក្ខាហារមកទៀត ឲ្យមាតាបិតាបរិភោគហើយ ទើបស្វែងរកដើម្បីខ្លួន ទៅកាន់សម្នាក់មាតាបិតា សួររឿងកត្តាហារទៀត បានទទួល

ចម្លើយថា មិនបរិភោគ ទើបឆាន់ខ្លួនឯង ហើយឲ្យមាតាបិតានៅក្នុងទីគួរមួយកន្លែង ភិក្ខុនោះបានបដិបត្តិមាតាបិតាទាំងពីរដោយទំនងនេះ តាំងអំពីនោះមក ស្ងួរីកត្តដែលកើតក្នុងបក្ខជាដើមដែលខ្លួនបានមក ក៏ឲ្យដល់មាតាបិតា ខ្លួនឯងត្រាច់ភិក្ខាចារបានមកក៏បរិភោគ បើមិនបានក៏មិនបរិភោគ បានសំពត់ចំណាំវស្សាក៏ដោយ សំពត់ឯណាមួយក៏ដោយ ដែលជាអតិរេកលាភ ក៏ឲ្យដល់មាតាបិតា បោកគក់ជ្រលក់សំពត់ចាស់ៗ ដែលមាតាបិតាស្លៀកដណ្ដប់ហើយ ដេរប៉ះស្លៀកដណ្ដប់ខ្លួនឯង ថ្ងៃដែលភិក្ខុនោះបានអាហារ មានតិច ថ្ងៃដែលអត់អាហារ មានច្រើន ស្បង់ចីវររបស់ភិក្ខុនោះសៅហ្មងដល់កម្រិត ភិក្ខុនោះបដិបត្តិមាតាបិតា តមក ក៏មានរូបកាយស្គាំងស្គម មិនផូរផង់ មានសម្បុរលឿង មានខ្លួនរវាមដោយសរសៃ កាលនោះ ពួកភិក្ខុដែលជាមិត្ត ឃើញភិក្ខុនោះ ទើបសួរថា អាវុសោ ពីមុនសរីរៈសម្បុររបស់លោកស្រស់ផូរផង់ តែឥឡូវនេះ លោកស្គាំងស្គមសៅហ្មង មិនផូរផង់ កាយក៏លឿងទៅៗ មានខ្លួនរវាមដោយសរសៃ ព្យាធិកើតឡើងដល់លោកឬ ភិក្ខុនោះឆ្លើយថា អាវុសោ ខ្ញុំមិនមានព្យាធិ តែមានកង្វល់ ហើយប្រាប់ព្រឹត្តិហេតុនោះ ភិក្ខុទាំងនោះក៏ពោលថា អាវុសោ ព្រះសាស្ដាមិនប្រទានអនុញ្ញាតដើម្បីញ៉ាំងរបស់ដែលគេឲ្យដោយសទ្ធាឲ្យធ្លាក់ទៅ លោកកាន់យករបស់ដែលគេឲ្យដោយសទ្ធា មកឲ្យដល់ពួកគ្រហស្ថ ធ្វើកិច្ចមិនសមគួរ ភិក្ខុនោះបានស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះ ក៏ខ្មាស បោះបង់មាតាបិតុបដ្ឋានកិច្ចចោល ភិក្ខុទាំងនោះក៏នៅមិនពេញចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណោះ ទើបនាំគ្នាទៅគាល់ព្រះដ៏

មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុឈ្មោះនោះ ញុំាងរបស់ដែលគេឲ្យដោយសទ្ធាឲ្យធ្លាក់ចុះ ចិញ្ចឹមគ្រហស្ថ ។ ព្រះសាស្តាទ្រង់ហៅភិក្ខុនោះមក ត្រាស់សួរថា នែភិក្ខុ បានឮថា អ្នកកាន់យកសទ្ធាទេយ្យទៅចិញ្ចឹមគ្រហស្ថពិតឬ កាលភិក្ខុនោះក្រាបទូលទទួលថា ករុណាព្រះអង្គ កាលទ្រង់ប្រាថ្នានឹងសរសើរការធ្វើរបស់ភិក្ខុនោះ និងទ្រង់ប្រាថ្នាបុព្វចរិយារបស់ព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកចិញ្ចឹមពួកគ្រហស្ថ ចិញ្ចឹមគ្រហស្ថពួកណា ភិក្ខុនោះក្រាបទូលថា គឺចិញ្ចឹមមាតាបិតារបស់ខ្ញុំព្រះអង្គ ដើម្បីញុំាងឧស្សាហ៍ឲ្យកើតដល់ភិក្ខុនោះ ព្រះសាស្តាទ្រង់បានប្រទានសាធុការ ៣ ដងថា សាធុ សាធុ សាធុ ហើយត្រាស់ថា អ្នកតាំងនៅក្នុងផ្លូវដែលតថាគតដើរហើយ សូម្បីតថាគត កាលប្រព្រឹត្តបុព្វចរិយា ក៏បានចិញ្ចឹមមាតាបិតាដូចគ្នា ភិក្ខុនោះត្រឡប់បាននូវការត្រេកអរ កាលនោះ កាលភិក្ខុនោះក្រាបទូលអារាធនាឲ្យទ្រង់ប្រកាសបុព្វចរិយា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ក្នុងទីមិនឆ្ងាយអំពីក្រុងពារាណសី មានស្រុកព្រាននេសាទមួយ ត្រង់ឆ្នេរស្ទឹងខាងអាយ និងមានស្រុកព្រាននេសាទមួយទៀត នៅត្រើយខាងនាយនៃស្ទឹង ក្នុងស្រុកនីមួយៗ មានត្រកូលប្រមាណ ៥០០ នាយនេសាទដែលជាធំក្នុងស្រុកទាំងពីរ ជាសម្លាញ់នឹងគ្នាតាំងពីនៅកំលោះ គេបានធ្វើកតិកាសញ្ញាដល់គ្នាយ៉ាងនេះថា បើម្ខាងមានធីតា ម្ខាងមានបុត្រ គេនឹងធ្វើអាវាហវិវាហមង្គលដល់បុត្រធីតាទាំងនោះ លំដាប់នោះ ក្នុងផ្ទះរបស់នាយនេសាទដែលជាធំ ក្នុងស្រុកត្រើយអាយ ប្រសូតបានកូនប្រុស

មាតាបិតាឲ្យឈ្មោះថា ទុកូលកុមារ ព្រោះកុមារនោះ ញាតិទាំងឡាយទទួលដោយទុកូលកន្ត្រ ក្នុងខណៈប្រសូត ក្នុងផ្ទះរបស់នាយនេសាទដែលជាធំម្ខាងទៀត ប្រសូតបានកូនស្រី មាតាបិតាឲ្យឈ្មោះថា បារិកាកុមារី ព្រោះនាងកើតត្រង់ត្រើយនាយ កុមារកុមារីទាំងពីរ មានរូបល្អគួរជ្រះថ្លា មានពណ៌សម្បុរដូចមាស សូម្បីកើតក្នុងត្រកូលព្រាន ក៏មិនធ្វើបាណាតិបាត ។

ក្នុងកាលតមក កាលទុកូលកុមារមានអាយុ ១៦ ឆ្នាំ មាតាបិតាពោលថា នឹងនាំកុមារិកាមកដើម្បីកុមារនោះ តែទុកូលកុមារចុតិអំពីព្រហ្មលោក ជាសត្វបរិសុទ្ធ ទើបបិទត្រចៀកទាំងពីរពោលថា បពិត្រលោកឪពុកអ្នកម្តាយ ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះ សូមកុំពោលយ៉ាងនេះ មាតាបិតាពោលអស់ ២-៣ ដងក៏មិនប្រាថ្នា ចំណែកបារិកាកុមារី សូម្បីមាតាបិតាពោលថា នែនាង កូនប្រុសរបស់សម្លាញ់យើងមាន គេមានរូបស្អាតគួរជ្រះថ្លា មានពណ៌សម្បុរដូចមាស យើងនឹងឲ្យកូនឯងដល់គេ នាងបារិកាក៏ឃាត់ដូចគ្នា ហើយបិទត្រចៀកទាំងពីរ ព្រោះនាងមកអំពីព្រហ្មលោក ជាសត្វបរិសុទ្ធ ។

ក្នុងកាលនោះ ទុកូលកុមារ បញ្ជូនដំណឹងត្រឡប់ទៅដល់នាងបារិកាថា បើបារិកាមានសេចក្តីត្រូវការដោយមេថុនធម្ម ចូរទៅកាន់ផ្ទះរបស់បុគ្គលដទៃ ខ្ញុំមិនមានសេចក្តីពេញចិត្តក្នុងមេថុនធម្ម សូម្បីនាងបារិកាក៏បញ្ជូនសំបុត្រទៅដល់ទុកូលកុមារដូចគ្នា តែមាតាបិតាក៏នៅតែធ្វើអាវាហវិវាហមង្គល ដល់កុមារកុមារីទាំងពីរ ដែលមិនប្រាថ្នាក្នុងរឿងបវេណីឡើយ ជនទាំងពីរ មិនបានឈានចុះកាន់សមុទ្រ គឺកិលេស នៅជាមួយគ្នាដូចមហាព្រហ្មពីរអង្គ

ដូច្នោះ ចំណែកទុកូលកុមារ មិនសម្លាប់ត្រី ឬម្រឹគ ដោយហោចសូម្បីម្រឹគ ដែលបុគ្គលនាំមក ក៏មិនលក់ដូរ ។ លំដាប់នោះ មាតាបិតាពោលថា នែបា ឯងកើតក្នុងត្រកូលព្រាន មិនប្រាថ្នាគ្រប់គ្រងផ្ទះ មិនធ្វើការសម្លាប់សត្វ ឯងនឹងធ្វើអ្វី ទុកូលកុមារពោលយ៉ាងនេះថា បពិត្រលោកឪពុកអ្នកម្តាយ បើលោកទាំងពីរអនុញ្ញាត យើងទាំងពីរនឹងបួស មាតាបិតាបានស្តាប់ដូច្នោះ ទើបអនុញ្ញាតថា បើដូច្នោះ ចូរឯងទាំងពីរបួសចុះ ទុកូលកុមារ និងបារិកាកុមារី ត្រេកអរក្រៃលែង ថ្វាយបង្គំមាតាបិតាហើយ ចេញអំពីផ្ទះ ចូលកាន់ហិមវន្តប្បទេស ឆ្លងស្ទឹងគង្គាដោយលំដាប់ លះនូវស្ទឹងគង្គា មានមុខឆ្ពោះទៅកាន់ស្ទឹងមិគសម្មតា ដែលហូរមកអំពីហិមវន្តប្បទេសជួបគ្នានឹងស្ទឹងគង្គា ។

ខណៈនោះ ពិភពនៃសក្កទេវរាជសម្តែងនូវអាការក្តៅ សក្កទេវរាជទ្រង់អាវជ្ជនាការ ទ្រង់ជ្រាបហេតុនោះ ទើបត្រាស់ហៅវិស្សកម្មទេវបុត្រមកត្រាស់ថា នែវិស្សកម្ម មហាបុរសទាំងពីរ ចេញអំពីផ្ទះប្រាថ្នានឹងបួសជាឥសី ចូលកាន់ហិមវន្តប្បទេស គួរអ្នកទាំងពីរបាននូវលំនៅ ចូរអ្នកនិម្មិតបណ្ណសាលា និងបព្វជិតបរិក្ខារដើម្បីជនទាំងពីរល្មមហៅគ្នាឮ តាមឆ្នេរស្ទឹងមិគសម្មតា រួចត្រឡប់មក ។ វិស្សកម្មទេវបុត្រទទួលទេវបញ្ជាហើយ ចាត់ចែងកិច្ចទាំងពួង ដោយន័យដែលពោលហើយ ក្នុងមូគបក្ខជាតក ( តេមិយជាតក ) ដេញម្រឹគ និងបក្សីដែលមានសំឡេងមិនជាទីពេញចិត្តឲ្យគេចទៅ ហើយនិម្មិតផ្លូវដើរតែម្នាក់ឯង ស្រេចហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន កុមារកុមារី ទាំងពីរឃើញផ្លូវនោះ ក៏ដើរទៅតាមផ្លូវនោះ ដល់អាស្រមបទ ទុកូលបណ្ឌិត

ចូលកាន់បណ្ណសាលា ឃើញបព្វជិតបរិក្ខារ ក៏ជ្រាបថា សក្កទេវរាជប្រទាន ដល់អញ ទើបដោះនូវសំពត់សាដក ស្លៀកនូវសំពត់សម្បកឈើពណ៌ក្រហមមួយផ្ទាំង ដណ្តប់មួយផ្ទាំង ពាក់ស្បែកខ្លាលើស្មា ចងនូវមណ្ឌលជដា ទ្រទ្រង់នូវភេទឥសី ហើយឲ្យនាងបារិកាបួសជាតបស្សិនី ឥសីទាំងពីរអង្គនោះ បម្រើនមេត្តាជាន់កាមាវចរ អាស្រ័យក្នុងទីនោះ សូម្បីហ្វូងម្រឹគ និងបក្សីទាំងពួង ក៏ត្រឡប់បាននូវមេត្តាចិត្តចំពោះគ្នានិងគ្នា ដោយអានុភាពមេត្តានៃតាបស តបស្សិនីទាំងពីរនោះ ។ បណ្តាសត្វទាំងនោះ មិនមានសត្វណាមួយបៀតបៀននូវគ្នានិងគ្នាឡើយ ។ ចំណែកបារិកាតបស្សិនីក្រោកឡើងអំពីព្រឹក តម្កល់ទឹកផឹក និងរបស់ឆាន់ ហើយបោសអាស្រមបទ ធ្វើកិច្ចទាំងពួង តាបស និងតបស្សិនីទាំងពីរនោះ នាំផ្លែឈើតូចធំមកឆាន់ ហើយចូលកាន់បណ្ណសាលារៀងៗខ្លួន ចម្រើនសមណធម៌ សម្រេចការនៅក្នុងទីនោះឯង ។

សក្កទេវរាជយាងមកកាន់ទីបម្រើនៃមុនីទាំងពីរនោះ ថ្ងៃមួយ ទ្រង់បានពិចារណាឃើញអន្តរាយនៃព្រះមុនីទាំងនោះថា ភ្នែកទាំងពីររបស់ជនទាំងពីរនេះនឹងត្រូវខ្វាក់ ទើបចុះមកអំពីទេវលោក ចូលទៅរកទុកូលបណ្ឌិត នមស្ការហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ត្រាស់យ៉ាងនេះថា បពិត្រលោកម្ចាស់ អន្តរាយនឹងប្រាកដដល់លោកទាំងពីរ លោកទាំងពីរគួរបានបុត្រសម្រាប់បដិបត្តិ សូមលោកទាំងពីរសេពលោកធម៌ ។ ទុកូលបណ្ឌិតបានស្តាប់ពាក្យរបស់សក្កទេវរាជ ទើបពោលថា នែសក្កៈ ទ្រង់ត្រាស់អ្វី យើងទាំង ២ នៅកណ្តាលផ្ទះគង់មិនសេពលោកធម៌ យើងទាំងពីរលះនូវលោកធម៌នេះ ខ្ទើម

រអើមដូចគំនរលាមកដែលពេញដោយដង្កូវ ឥឡូវនេះ យើងទាំងពីរ ចូលព្រៃបួសជាឥសី នឹងធ្វើកម្មបែបនេះដូចម្ដេចកើត សក្កទេវរាជត្រាស់ថា បពិត្រលោកម្ចាស់ បើលោកម្ចាស់មិនធ្វើយ៉ាងនោះ គ្រាន់តែយកដៃស្ទាបផ្ចិតបារិកា-តាបសិនី ក្នុងវេលាដែលនាងមានរដូវក៏បាន ។ ទុកូលបណ្ឌិតទទួលថា បើយ៉ាងនេះអាចធ្វើបាន ។ សក្កទេវរាជ ថ្វាយបង្គំទុកូលតាបស ហើយត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ចំណែកទុកូលបណ្ឌិត ក៏ប្រាប់នាងបារិកាឲ្យដឹងខ្លួន ហើយយកដៃស្ទាបផ្ចិតនាង ក្នុងកាលដែលនាងមានរដូវ ។

ក្នុងកាលនោះ ព្រះពោធិសត្វចុតិអំពីទេវលោក បដិសន្ធិក្នុងផ្ទៃរបស់បារិកាតបស្សិនី លុះកន្លងទៅ ១០ ខែ នាងក៏ប្រសូតបុត្រមានពណ៌ដូចមាស ដោយហេតុនោះឯង ទើបមាតាបិតាដាក់ឈ្មោះកុមារនោះថា សុវណ្ណសាម-កុមារ ពេលដែលបារិកាតបស្សិនីទៅព្រៃដើម្បីរកមើមឈើ ផ្លែឈើ កិន្នរីទាំងឡាយដែលនៅក្នុងបព៌ត បានធ្វើកិច្ចជាអ្នកបម្រើ តាបស តបស្សិនីទាំងពីរ ងូតទឹកព្រះពោធិសត្វហើយ ឲ្យដេកក្នុងបណ្ណសាលា ហើយនាំគ្នាទៅរកផ្លែឈើតូចធំ ក្នុងខណៈនោះ កិន្នរីទាំងឡាយពកុមារនោះទៅងូតទឹកត្រង់ញកភ្នំជាដើម ហើយឡើងកាន់កំពូលភ្នំប្រដាប់ដោយផ្កាផ្សេងៗ ហើយបុកហរតាល និងមនោសិលាជាដើមឲ្យជាលម្អិត លាបត្រង់ថ្ងាស ហើយនាំមកឲ្យដេកត្រង់បណ្ណសាលា ។ ចំណែកនាងបារិកា ត្រឡប់មកឲ្យកូនបៅដោះ ។ ក្នុងកាលតមក មាតាបិតារក្សាបុត្រនោះរហូតអាយុបាន ១៦ ឆ្នាំ ឲ្យអង្គុយក្នុងបណ្ណសាលា ខ្លួនឯងនាំគ្នាទៅព្រៃដើម្បីរកមើមឈើ និងផ្លែឈើ លំដាប់

នោះ មហាសត្វគិតថា អន្តរាយណាមួយ អាចមានដល់មាតាបិតារបស់អញ ក្នុងពេលណាមួយ ទើបទ្រង់សង្កេតផ្លូវដែលមាតាបិតាទៅ ។ ថ្ងៃមួយ កាល តាបស និងតបស្វិនី នាំមូលផលាផលក្នុងព្រៃ ត្រឡប់មកក្នុងពេលល្ងាច ដល់ទីជិតអាស្រមបទ មហាមេឃក៏តាំងឡើង ភ្លៀកក៏ធ្លាក់ ជនទាំងពីរក៏ចូល ទៅកាន់គល់ឈើមួយកន្លែង ឈរលើកំពូលជំបូក អាសិរពិសមានក្នុងជំបូក នោះ ទឹកភ្លៀងលាយជាមួយក្លិនញើសចេញអំពីសរីរៈរបស់ជនទាំងពីរនោះ ក៏ហូរចូលទៅក្នុងប្រមុះរបស់អាសិរពិសនោះ អាសិរពិសក្រោធ ព្រួសខ្យល់ ក្នុងប្រមុះចេញមក ខ្យល់ក្នុងប្រមុះនោះ ត្រូវភ្នែកទាំងពីររបស់តាបស និង តបស្វិនីនោះ ជនទាំងពីរក៏ខ្វាក់មិនឃើញគ្នានិងគ្នាព្រោះខ្យល់នោះ ទុកូល-បណ្ឌិតហៅនាងបារិកាមកប្រាប់ថា បារិកា ភ្នែកទាំងពីររបស់ខ្ញុំងងឹត ខ្ញុំមើល មិនឃើញនាង សូម្បីនាងបារិកា ក៏ពោលយ៉ាងនោះដូចគ្នា ជនទាំងពីរមើល មិនឃើញផ្លូវ ក៏ឈរយំដោយយល់ថា ឥឡូវនេះ ជីវិតរបស់យើងទាំងពីរ មិនមាន ។

តាបស និងតបស្វិនីទាំងពីរនោះមានបុព្វកម្មដូចម្តេច បានឮថា ជន ទាំងពីរនោះ ក្នុងកាលមុន កើតក្នុងត្រកូលពេទ្យ កាលនោះ ពេទ្យនោះរក្សា រោគក្នុងភ្នែករបស់បុរសអ្នកមានទ្រព្យច្រើនម្នាក់ បុរសនោះជាភ្នែកហើយ មិន ឲ្យថ្លៃព្យាបាលដល់ពេទ្យនោះ ពេទ្យខឹងក្រោធ ទៅកាន់ផ្ទះប្រាប់ដល់ភរិយា របស់ខ្លួនថា នៃនាង ខ្ញុំរក្សារោគក្នុងភ្នែករបស់បុរសនោះជាហើយ ឥឡូវនេះ គេមិនឲ្យទ្រព្យថ្លៃរក្សានោះដល់ខ្ញុំ យើងធ្វើដូចម្តេចហ្ន៎ ចំណែកភរិយាបាន

ស្តាប់ស្វាមីហើយ ក៏ក្រោធ ទើបពោលថា យើងមិនត្រូវការទ្រព្យដែលមានរបស់វា សូមលោកផ្សំថ្នាំឲ្យវាបន្តក់ ធ្វើភ្នែកទាំងពីរឲ្យខ្វាក់ចុះ ស្វាមីក៏យល់ស្រប ទើបចេញអំពីផ្ទះ ទៅរកបុរសនោះ បានធ្វើតាមនោះ បុរសដែលមានទ្រព្យច្រើននោះ មិនយូរប៉ុន្មាន ចក្ខុក៏ងងឹតទៅ ជនទាំងពីរខ្វាក់ភ្នែកដោយបាបកម្មនេះ ។

លំដាប់នោះ មហាសត្វគិតថា មាតាបិតារបស់អញ ក្នុងថ្ងៃដទៃៗ ធ្លាប់ត្រឡប់មកក្នុងវេលានេះ ឥឡូវនេះ អញមិនដឹងរឿងរបស់ជនទាំងពីរនោះ ទើបដើរបញ្ច្រាស់ផ្លូវស្រែកហៅ ជនទាំងពីរចាំសំឡេងកូនបានក៏បង្អោកតបហើយពោលហាមដោយសេចក្តីស្រឡាញ់ក្នុងកូនថា មានអន្តរាយក្នុងទីនេះ កូនកុំចូលមកឡើយ ។ ព្រះមហាសត្វឆ្លើយនឹងជនទាំងពីរថា បើដូច្នោះ សូមលោកទាំងពីរ ចាប់ចុងឈើច្រត់នេះមកចុះ ហើយហុចឈើវែងឲ្យជនទាំងពីរចាប់ ឥសីទាំងពីរចាប់ឈើច្រត់ហើយក៏មករកបុត្រ មហាសត្វសួរថា ភ្នែកទាំងពីររបស់លោកងងឹតទៅព្រោះហេតុអ្វី មាតាបិតាទាំងពីរក៏ពោលឲ្យមហាសត្វជាកូនស្តាប់ថា កូនជាទីស្រឡាញ់ កាលភ្លៀងធ្លាក់ យើងទាំងពីរឈរលើកំពូលដំបូកត្រង់គល់ឈើនេះ ភ្នែករបស់យើងទាំងពីរខ្វាក់ដោយហេតុនោះ ។ ព្រះមហាសត្វបានស្តាប់ពាក្យរបស់មាតាបិតា ដឹងថា មានអាសិរពិសក្នុងដំបូកនោះ អាសិរពិសនោះខឹងក្រោធ បញ្ចេញខ្យល់ក្នុងច្រមុះចេញមក ។ ព្រះមហាសត្វឃើញមាតាបិតាហើយ ក៏ស្រែកយំ យំហើយក៏សើច មាតាបិតាក៏សួរថា ហេតុអ្វីទើបយំហើយសើច ព្រះមហាសត្វឆ្លើយ

ថា ខ្ញុំយំដោយទោមនស្សថា ចក្ខុរបស់លោកទាំងពីរ វិនាសទៅក្នុងពេលដែលខ្ញុំនៅក្មេង តែខ្ញុំសើច ព្រោះសប្បាយចិត្តថា ខ្ញុំនឹងបានបដិបត្តិលោកទាំងពីរក្នុងឥឡូវនេះ សូមលោកទាំងពីរកុំគិតច្រើឡើយ ខ្ញុំនឹងបដិបត្តិលោកទាំងពីរឲ្យនៅជាផាសុក ។ ព្រះមហាសត្វលួងលោមឲ្យមាតាបិតាទាំងពីរធូរស្បើយចិត្ត ហើយនាំមកកាន់អាស្រមបទ ចងខ្សែជាស្ពានក្នុងទីទាំងពួង សម្រាប់មាតាបិតាទាំងពីរនោះ គឺត្រង់ទីសម្រាកពេលយប់ ត្រង់ទីសម្រាកពេលថ្ងៃ ត្រង់ទីចង្ក្រម ត្រង់បណ្ណសាលា ត្រង់ទីបន្ទោបង់ឧច្ចារបស្សាវៈ ។ ចាប់តាំងពីនោះមក ឲ្យមាតាបិតានៅក្នុងអាស្រមបទ នាំមូលផលាផលក្នុងព្រៃមកឯង តម្កល់ទុកក្នុងបណ្ណសាលា បោសទីលំនៅរបស់មាតាបិតាអំពីព្រលឹម ថ្វាយបង្គំមាតាបិតា ហើយកាន់ក្អមទៅកាន់មិគសម្មតានទីដងទឹកមក រៀបចំរបស់ឆាន់ជូនទូវឈើស្ទន់ និងទឹកខ្ពុរមាត់ជាដើម ឲ្យនូវផលាផលដែលមានរសឆ្ងាញ់ កាលមាតាបិតាបរិភោគ ខ្ពុរមាត់ហើយ ទើបខ្លួនឯងបរិភោគផលាផលដែលសល់ សម្រេចកិច្ចបរិភោគហើយ ថ្វាយបង្គំមាតាបិតា មានហ្វូងម្រឹគចោមរោមចូលទៅកាន់ព្រៃ ដើម្បីរកផ្លែឈើ ពួកកិន្នរត្រង់ជើងភ្នំ ចោមរោមព្រះពោធិសត្វ ជួយបេះផ្លែឈើឲ្យព្រះពោធិសត្វ ពេលល្ងាច ក៏ត្រឡប់មកកាន់អាស្រម ហើយយកក្អមដងទឹកមកតម្កល់ទុក ដាំទឹកឲ្យក្តៅហើយ ងូតនិងលាងជើងមាតាបិតាតាមអធ្យាស្រ័យ នាំអំបែងរងើកភ្លើងមកឲ្យអាំង ជូតជើងរបស់មាតាបិតា កាលមាតាបិតាអង្គុយហើយ ក៏ឲ្យបរិភោគផលាផលចំណែកខ្លួនឯង កាលមាតាបិតាបរិភោគហើយ ទុកដាក់ផលាផលដែលសល់

ក្នុងអាស្រមបទ ព្រះពោធិសត្វបដិបត្តិមាតាបិតា ដោយទំនងនេះឯង ។

សម័យនោះ ព្រះរាជាព្រះនាមបិលយក្ខរាជ សោយរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់ល្មោភក្នុងសាច់ម្រឹគ ទើបប្រគល់រាជសម្បត្តិឲ្យព្រះមាតាគ្រប់គ្រង សៀតនូវបញ្ចាវុធចូលកាន់ហិមវន្តប្បទេស ទ្រង់សម្លាប់ម្រឹគទាំងឡាយសោយសាច់ យាងដល់មិគសម្មតានទី ដល់កំពង់ដែលសុវណ្ណសាមពោធិសត្វដងទឹកដោយលំដាប់ ទតឃើញស្នាមជើងម្រឹគ ក៏ទ្រង់កាច់មែកឈើដែលមានពណ៌ខៀវ ដើម្បីបិទបាំងខ្លួន ត្រៀមព្រួញដែលលាបដោយថ្នាំពិសប្រថាប់គង់ត្រៀមខ្លួនក្នុងគុម្ពឈើនោះ ។ ចំណែកព្រះមហាសត្វ នាំផ្លែឈើមកក្នុងពេលល្ងាច ទុកក្នុងអាស្រមបទ ថ្វាយបង្គំមាតាបិតា លាទៅដងទឹកកាន់ក្អមដែលមានហ្វូងម្រឹគចោមរោម ឲ្យម្រឹគពីរដើរទន្ទឹមគ្នា ដាក់ក្អមទឹកផឹកលើខ្នងម្រឹគទាំងពីរ យកដៃកាន់មាត់ក្អមទៅកាន់កំពង់ទឹក ចំណែកព្រះរាជាប្រថាប់នៅក្នុងគុម្ពឈើ ទតឃើញព្រះពោធិសត្វដើរមកគិតថា អញត្រាច់មកក្នុងហិមវន្តប្បទេសអស់កាលមានប្រមាណប៉ុណ្ណេះ មិនធ្លាប់ឃើញមនុស្ស បុរសនេះជាទេវតា ឬជានាគហ្ន៎ បើអញចូលទៅសាកសួរបុរសនេះ បើជាទេវតាក៏នឹងហោះទៅកាន់អាកាស បើជានាគនឹងមុជផែនដីទៅ តែអញនឹងត្រាច់ទៅក្នុងហិមវន្តប្បទេស អស់កាលទាំងពួងក៏មិនមែន បើអញត្រឡប់ទៅពារាណសីអមាត្យទាំងឡាយនឹងសួរអញ ក្នុងកាលដែលអញត្រាច់ទៅក្នុងហិមវន្តប្បទេសនោះថា កាលព្រះអង្គយាងទៅក្នុងហិមវន្តប្បទេស បានទតឃើញអ្វីអស្ចារ្យខ្លះ អញនឹងពោលថា ធ្លាប់ឃើញសត្វបែបនេះ គេនឹងសួរអញថា

សត្វនោះជាសត្វអ្វី បើអញធ្វើយថា មិនស្គាល់ គេនឹងតិះដៀលអញ ព្រោះហេតុនោះ អញនឹងបាញ់បុរសនេះ ធ្វើឲ្យខ្សោយកម្លាំង ហើយសឹមសួរ ។ លំដាប់នោះ កាលហ្វូងម្រឹគនោះផឹកទឹកហើយ ឡើងមកមុន ព្រះពោធិសត្វក៏ចុះសន្សឹមៗ ដូចព្រះថេរៈដែលមានវត្តរៀនហើយ ងូតទឹករម្ងាប់នូវសេចក្តីក្រវល់ក្រវាយហើយ ឡើងអំពីទឹក ស្លៀកសំពត់សម្បកឈើ ដែលមានពណ៌ក្រហមមួយផ្ទាំង ដណ្តប់មួយផ្ទាំង យកស្បែកខ្លាពាក់ឆៀងស្មា លើកក្អមទឹកឡើងជូតទឹកហើយ ដាក់លើស្មាឆ្វេង ក្នុងកាលនោះ ព្រះរាជាគិតថា ឥឡូវនេះ ជាសម័យដែលត្រូវបាញ់ ទើបលើកសរដែលលាបដោយថ្នាំពិសនោះឡើង បាញ់ព្រះពោធិសត្វពីខាងស្តាំ ធ្លុះទៅខាងឆ្វេង ពួកម្រឹគដឹងមហាសត្វត្រូវបាញ់ ភិតភ័យក៏រត់ទៅ ចំណែកសុវណ្ណសាមបណ្ឌិត សូម្បីត្រូវបាញ់ ក៏ផ្គងក្អមទឹកទុកដោយប្រក្រតី ទប់ស្មារតីដាក់ក្អមចុះ ប្រមូលខ្សាច់តម្កល់ក្អមទឹក កំណត់ទិស បែរក្បាលទៅកាន់ទិសាភាគ ដែលជាលំនៅរបស់មាតាបិតា ដូចបដិមាមាស ដេកលើផ្ទូកខ្សាច់មានពណ៌ដូចប្រាក់ តាំងសតិពោលថា ឈ្មោះថា បុគ្គលដែលមានពៀររបស់ខ្ញុំក្នុងហិមវន្តប្បទេសនេះមិនមាន បុគ្គលដែលមានពៀរនៃមាតាបិតារបស់ខ្ញុំក៏មិនមាន ពោលដូច្នេះហើយ ក៏ខ្ទុរឈាមចេញពីមាត់ មិនឃើញព្រះរាជាឡើយ កាលសួរ ទើបពោលគាថាទី ១ ថា

នរណាហ្ន៎ បាញ់ខ្ញុំ ជាអ្នកដងទឹក ភ្លេចស្មារតី ដោយព្រួញ ជនណា ជាក្សត្រ ឬជាព្រាហ្មណ៍ ឬជាវេស្សៈ បាញ់ខ្ញុំ ហើយពួន

ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បមត្តំ** សេចក្តីថា ជាអ្នកមិនមានស្មារតីក្នុងការបម្រើនមេត្តា ពាក្យនេះ ព្រះពោធិសត្វពោលសំដៅសេចក្តីថា បានធ្វើខ្លួនជាអ្នកប្រមាទក្នុងខណៈនោះ ។ បទថា **វិទ្ធា** សេចក្តីថា បាញ់ហើយពួនក្នុងទីនេះ ជននោះ ឈ្មោះអ្វីហ្ន៎ ជាក្សត្រ ឬព្រាហ្មណ៍ ឬវេស្សៈ ប្រើព្រួញលាបដោយថ្នាំពិស បាញ់ខ្ញុំដែលកំពុងដងទឹក ត្រង់មិគសម្មតានទី គឺជនឈ្មោះអ្វីហ្ន៎ បាញ់ខ្ញុំហើយពួន គឺបិទបាំងខ្លួនក្នុងគុម្ពឈើ ។

កាលពោលយ៉ាងនេះហើយ ដើម្បីសម្តែងភាពដែលសាច់ក្នុងសរីរៈរបស់ខ្លួន ឃើញថា មិនមែនជាអាហារ ទើបពោលគាថាទី ២ ថា

សាច់ទាំងឡាយរបស់ខ្ញុំ មិនមែនជារបស់គួរទំពាស៊ីទេ សេចក្តីត្រូវការដោយស្បែក មិនមានទេ កាលបើដូច្នេះ តើអ្នកសម្គាល់នូវខ្ញុំថា គួរបាញ់ដោយហេតុដូចម្តេច ដូច្នេះ ។

ក្នុងគាថានោះ មានសេចក្តីថា មាណពដ៏ចម្រើន សាច់របស់ខ្ញុំ គឺសាច់ក្នុងខ្លួនរបស់ខ្ញុំ បរិភោគមិនកើត គឺមនុស្សទាំងឡាយមិនគប្បីបរិភោគ ស្បែករបស់ខ្ញុំ គឺស្បែកក្នុងសរីរៈរបស់ខ្ញុំ មិនមានប្រយោជន៍ដល់មនុស្សទាំងឡាយ កាលបើដូច្នេះ គឺកាលយ៉ាងនេះ បុរសនេះយល់ថា ខ្ញុំជាបុគ្គលគួរបាញ់ គឺគួរចាក់ គឺបាញ់ខ្ញុំដោយមិនពិចារណា ដោយហេតុអ្វី ។

កាលពោលគាថាទី ២ ហើយ សួរដល់ឈ្មោះជាដើម ព្រះពោធិសត្វក៏ពោលគាថាដូច្នេះថា

អ្នកជាអ្វី ជាបុត្តរបស់អ្នកណា យើងស្គាល់អ្នកដូចម្តេចបាន ម្នាលសម្លាញ់ អ្នកខ្ញុំសួរហើយ ចូរប្រាប់ ម្តេចក៏បានជាអ្នកបាញ់ខ្ញុំហើយពួន ដូច្នេះ ។

កាលពោលយ៉ាងនេះហើយ ក៏បាននៅស្ងៀម ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទ្រង់ត្រិះរិះថា បុរសនេះសូម្បីត្រូវអញបាញ់ដោយព្រួញ លាបដោយថ្នាំពិសដួលហើយក៏មិនជេរ មិនផ្តាសាអញ ហៅនូវអញដោយពាក្យជាទីស្រឡាញ់ ដូចបុគ្គលកាត់នូវបេះដូង អញនឹងចូលទៅរក ក៏យាងទៅប្រថាប់ឈរក្នុងទីជិតព្រះពោធិសត្វ ហើយត្រាស់ថា

ខ្ញុំជាព្រះរាជារបស់ពួកអ្នកកាសី គេស្គាល់ខ្ញុំថា ឈ្មោះបិលយក្ខ ខ្ញុំលះបង់នូវដែន មកត្រាច់ស្វែងរកម្រឹគ ព្រោះលោភ ( ក្នុងសាច់ ) ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ ជាអ្នកមានឈ្មោះល្បីល្បាញ ថាជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំបាន សូម្បីដំរីដែលមកត្រង់មុខព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រាជាហមស្មិ** សេចក្តីថា បានឮថា ព្រះបាទបិលយក្ខនោះ មានព្រះតម្រិះយ៉ាងនេះថា ទេវតាក្តី នាគក្តី រមែងពោលនូវភាសាមនុស្សបានទាំងអស់ អញមិនស្គាល់បុរសនេះថាជាទេវតា នាគ ឬជាមនុស្ស បើគេខឹងក្រោធនឹងធ្វើឲ្យអញវិនាសបាន បើពោលដល់អញថាជាព្រះរាជា បុគ្គលណាមួយមិនខ្លាច មិនមាន ព្រោះហេតុនោះ ដើម្បីឲ្យដឹងថាទ្រង់ជាព្រះរាជា ទើបត្រាស់ជាមុនថា **រាជហមស្មិ** ដូច្នេះ ។ នៃមាណពដ៏

ចម្រើន យើងជាព្រះរាជារបស់អ្នកកាសី គឺរបស់ជនដែលនៅក្នុងកាសិករដ្ឋ ។ បទថា **មំ** បានដល់ មហាជនស្គាល់យើងដោយឈ្មោះថាព្រះបាទបិលយក្ខ ។ បទថា **វិទូ** បានដល់ ស្គាល់ គឺហៅ ។ បទថា **លោភា** សេចក្ដីថា ប្រគល់រាជសម្បត្តិដល់ព្រះមាតា ព្រោះលោភក្នុងសាច់ម្រឹគ ។ បទថា **មិគមេសំ** បានដល់ ស្វែងរក គឺរំពៃរកពួកម្រឹគ ។ បទថា **ចរាមហំ** សេចក្ដីថា អញត្រាច់ទៅក្នុងព្រៃម្នាក់ឯងប៉ុណ្ណោះ ព្រះរាជាបំណងនឹងសម្ដែងកម្លាំងរបស់ព្រះអង្គ ទើបត្រាស់គាថាទី ២ ។

បណ្ដាបទទាំងនោះ បទថា **ឥស្សត្ថេ** បានដល់ ក្នុងសិប្បធ្នូ ។ បទថា **ទឡ្ហធម្មោ** សេចក្ដីថា ជាអ្នកអាចលើក និងដាក់នូវធ្នូដ៏ធ្ងន់ គឺធ្នូទម្ងន់កម្លាំងបុរសមួយពាន់ទើបលើកបាន បានឮល្បីសុសសាយ គឺប្រាកដទូទៅពេញជម្ពូទ្វីប ។ បទថា **អាគតោ ឧសុបាតគំ** សេចក្ដីថា ដំរីដែលមានកម្លាំង សុះមកក្នុងមុខព្រួញរបស់យើង ក៏ឈានមិនលើសពីរ ៧ ជំហាន ។

ព្រះរាជាទ្រង់សរសើរកម្លាំងរបស់ព្រះអង្គដូច្នេះហើយ កាលសួរឈ្មោះនិងគោត្ររបស់ព្រះពោធិសត្វ ទើបត្រាស់ថា

ចុះអ្នកជាអ្វី ជាបុត្តរបស់អ្នកណា ដូចម្ដេច ទើបយើងស្គាល់អ្នកបាន សូមអ្នកប្រាប់នូវនាម និងគោត្ត របស់បិតាផង របស់ខ្លួនផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បវេទយ** បានដល់ គប្បីប្រាប់ ។

មហាសត្វបានស្ដាប់ដូច្នោះហើយ ត្រិះរិះថា បើអញប្រាប់ថាអញជាទេវតា

នាគ យក្ខ កិន្នរ ឬជាក្សត្រជាដើមណាមួយ ព្រះរាជានេះរមែងជឿពាក្យរបស់អញ អញគួរពោលតាមពិតប៉ុណ្ណោះ ត្រិះរិះដូច្នេះហើយ ទើបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ ( ជា កូនរបស់ឥសី ) ជាបុត្តរបស់នាយនេសាទ ពួកញាតិហៅទូលបង្គំជាខ្ញុំ កំពុងរស់នៅថាសាមៈ ថ្ងៃនេះ ទូលបង្គំជាខ្ញុំនោះ ដល់ ( មាត់មច្ចុរាជ ) ហើយដេកនៅយ៉ាងនេះ ។ ខ្ញុំដែលព្រះអង្គបាញ់ហើយ ហាក់ដូចម្រឹគ ដែលព្រានព្រៃបាញ់ហើយ ដោយព្រួញធំ ប្រកបដោយថ្នាំពិស ដូច្នោះ បពិត្រព្រះរាជា សូមទ្រង់ទតចុះ ទូលបង្គំជាខ្ញុំ ដេកត្រាំនៅក្នុងឈាមរបស់ខ្លួន ។ សូមទ្រង់ទតព្រួញដែលមុតធ្លាយទៅខាងឆ្វេង ទូលបង្គំជាខ្ញុំខ្ទរឈាម ទូលបង្គំជាខ្ញុំចាប់ពើតណាស់ បានជាសួរព្រះអង្គរឿយៗ ម្ដេចក៏ទ្រង់បាញ់ទូលបង្គំជាខ្ញុំហើយពួន ។ ខ្លាដំបងគេសម្លាប់ព្រោះតែស្បែក ដំរីគេសម្លាប់ព្រោះភ្លុកទាំងឡាយ កាលបើដូច្នោះ តើព្រះអង្គសម្គាល់នូវទូលបង្គំជាខ្ញុំថា គួរបាញ់ដោយហេតុដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភទ្ទន្តេ** សេចក្ដីថា បពិត្រមហារាជដ៏ចម្រើន ទូលបង្គំជាកូនឥសីដែលជាបុត្រអ្នកនេសាទ ។ បទថា **ជីវន្តំ** សេចក្ដីថា ញាតិទាំងឡាយ កាលហៅទូលបង្គំដែលមានជីវិតអំពីកាលមុននេះថា មកចុះសាមៈ ទៅចុះសាមៈ ក៏បានហៅថា សាមៈ ។ បទថា **ស្វាជ្ជេវង្គតោ** សេចក្ដីថា ថ្ងៃនេះ ទូលបង្គំនោះទៅ គឺដល់ គឺចូលទៅក្នុងមាត់នៃមរណៈហើយយ៉ាងនេះ ។

បទថា **សយេ** បានដល់ ដេក ម្រឹគត្រូវព្រានព្រៃបាញ់ដោយព្រួញធំ ដែលលាបដោយថ្នាំពិស យ៉ាងណា ទូលបង្គំក៏ដូច្នោះ គឺជាអ្នកត្រូវទ្រង់បាញ់យ៉ាងនោះ ។ បទថា **បរិប្ផុតោ** សេចក្តីថា ដេកត្រាំ គឺសូមទ្រង់ទតខ្ញុំដែលដេកបែបនេះ ។ បទថា **បដិវាមគតំ** សេចក្តីថា ចូលអំពីខាងស្តាំ ហើយធ្លុះទៅខាងឆ្វេង ។ បទថា **បស្ស** បានដល់ សូមទតនូវទូលបង្គំ ។ បទថា **ឋិម្ហាមិ** បានដល់ ខ្ជាក់ ព្រះមហាសត្វតម្កល់ស្មារតីមាំ មិនញាប់ញ័រ ខ្ជាក់នូវលោហិតត្រាស់ហើយដោយប្រការដូច្នេះ ។ បទថា **អាតុរោ** សេចក្តីថា ខ្ញុំឈឺខ្លាំងសូមទូលសួរទ្រង់ ។ បទថា **និលីយសិ** សេចក្តីថា ប្រថាប់គង់ក្នុងគុម្ពឈើមួយកន្លែង ។ បទថា **វិទ្ធេយ្យំ** បានដល់ គួរបាញ់ ។ បទថា **អមញ្ញថ** សេចក្តីថា បានយល់ថាជាម្រឹគ ។

ព្រះរាជា បានស្តាប់ពាក្យរបស់មហាសត្វហើយ មិនត្រាស់ប្រាប់តាមសេចក្តីពិត កាលពោលពាក្យកុហក ទើបត្រាស់ថា

ម្រឹគមកប្រាកដ ចំមុខព្រួញរបស់ខ្ញុំហើយ ឃើញអ្នកហើយក៏ផ្អើលទៅ ម្នាលសាមៈ ព្រោះហេតុនោះ បានជាខ្ញុំមានសេចក្តីក្រោធគ្របសង្កត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្រិដ្ឋ** បានដល់ គេចទៅ ។ បទថា **អាវិសិ** បានដល់ គ្របសង្កត់ ព្រះរាជាទ្រង់សម្តែងថា សេចក្តីក្រោធ កើតឡើងដល់យើងព្រោះហេតុនោះ ។

លំដាប់នោះ មហាសត្វទូលព្រះរាជាថា បពិត្រព្រះរាជាជាធំ ទ្រង់ត្រាស់

អ្វី ឈ្មោះថា ម្រឹគដែលឃើញខ្ញុំហើយ គេចទៅ មិនមានក្នុងហិមវន្តប្បទេស នេះ ហើយទូលថា

តាំងពីកាលដែលខ្ញុំរឭកឃើញនូវខ្លួន តាំងពីកាលដែលខ្ញុំដល់នូវភាពជាអ្នកដឹងក្តី ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល ( ឃើញ ) ទូលបង្គំជាខ្ញុំហើយ តក់ស្លុតទេ តាំងពីកាលដែលខ្ញុំស្លៀកដណ្តប់សំពត់សម្បកឈើ តាំងពីកាលដែលខ្ញុំដល់នូវវ័យដ៏ចម្រើន ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល ( ឃើញ ) នូវខ្ញុំហើយ តក់ស្លុតទេ ។ បពិត្រព្រះរាជា កិន្នរទាំងឡាយ ដែលជាសត្វខ្លាច ( នៅ ) នាភ្នំគន្ធមាទន៍ ( មិនដែលឃើញខ្ញុំហើយ តក់ស្លុតទេ ) យើងទាំងឡាយតែងរីករាយជាមួយគ្នា ទៅកាន់ភ្នំ និងព្រៃ កាលបើដូច្នោះ ម្រឹគទាំងឡាយ ( ឃើញ ) នូវទូលបង្គំជាខ្ញុំហើយ តក់ស្លុតដោយហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន មំ មិគា** សេចក្តីថា ធម្មតាម្រឹគទាំងឡាយឃើញទូលបង្គំហើយ មិនតក់ស្លុត ។ បទថា **សាបទានិ** បានដល់ពាលម្រឹគ ។ បទថា **យតោ និធឹ** សេចក្តីថា ចាប់តាំងពីកាលដែលខ្ញុំស្លៀកគឺទ្រទ្រង់សំពត់សម្បកឈើ ។ បទថា **ភីរូ កឹបុរិសា រាជ** សេចក្តីថា បពិត្រព្រះរាជាជាធំ ម្រឹគទាំងឡាយចូរលើកទុកចុះ ធម្មតាកិន្នរទាំងឡាយ ជាសត្វដែលខ្លាចក្រៃលែង កិន្នរពួកណាដែលនៅត្រង់ភ្នំគន្ធមាទន៍នេះ កិន្នរទាំងនោះ

ឃើញខ្ញុំហើយ មិនតក់ស្លុត ពួកខ្ញុំត្រេកអរនូវគ្នានិងគ្នាទៅតាមព្រៃ ចូលក្នុងព្រៃដោយពិត ។ បទថា **ឧត្រាសន្តិ មិគា មមំ** សេចក្តីថា ព្រះមហាសត្វសម្តែងសេចក្តីថា ព្រោះហេតុអ្វី ទើបទ្រង់ឲ្យខ្ញុំជឿថា ម្រឹគទាំងឡាយឃើញខ្ញុំហើយភ័យខ្លាច ព្រះរាជាបានស្តាប់ដូច្នោះហើយ ទ្រង់បានត្រិះរិះថា អញបាញ់សុវណ្ណសាមដែលឥតកំហុសនេះហើយ នៅពោលមុសាវាទទៀត អញនឹងពោលពាក្យពិតប៉ុណ្ណោះ ដូច្នេះហើយ ទើបត្រាស់ថា

ម្នាលសាមៈ ម្រឹគមិនមែនផ្អើលនឹងអ្នកទេ ខ្ញុំនឹងនិយាយកុហកធ្វើអ្វី ខ្ញុំមានសេចក្តីក្រោធ និងសេចក្តីលោភគ្របសង្កត់ហើយ ទើបបាញ់អ្នកនឹងព្រួញនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន តំ តស** សេចក្តីថា ម្រឹគឃើញអ្នកហើយមិនគិតភ័យទេ ។ បទថា **កិន្នាហំ** សេចក្តីថា ខ្ញុំពោលពាក្យកុហកក្នុងសម្នាក់របស់អ្នក ដែលមានទស្សនៈល្អយ៉ាងនេះ ។ បទថា **កោធលោភាភិភូតាហំ** សេចក្តីថា ខ្ញុំជាបុគ្គលដែលសេចក្តីក្រោធ និងសេចក្តីលោភគ្របសង្កត់ហើយ កាលម្រឹគទាំងឡាយ ចុះមុនហើយនោះឯង ខ្ញុំនុ៎ះនឹងបាញ់ម្រឹគទាំងឡាយព្រោះសេចក្តីក្រោធ ។ ព្រះរាជាឈរលើកធ្នូ ក្រោយមក ឃើញព្រះពោធិសត្វមិនដឹងថា ព្រះពោធិសត្វនោះជាអ្នកណា ក្នុងបណ្តាទេវតាជាដើម នឹងសួរព្រះពោធិសត្វនោះ ព្រះរាជាញ៉ាំងសេចក្តីលោភឲ្យកើតឡើង ដោយប្រការដូច្នេះទើបត្រាស់យ៉ាងនេះ ។

កាលត្រាស់យ៉ាងនេះហើយ ព្រះរាជាត្រិះរិះថា សុវណ្ណសាមនេះ មិន

មែនអាស្រ័យនៅក្នុងព្រៃនេះតែម្នាក់ឯងប៉ុណ្ណោះឡើយ ញាតិរបស់គេគប្បីមានពិត អញនឹងសួរមើល ទើបត្រាស់គាថាបន្តថា

ម្នាលសាមៈ អ្នកមកអំពីប្រទេសណា ឬនរណាប្រើមកថា អ្នកដងទឹក ចូរទៅកាន់ស្ទឹង ដូច្នេះ បានជាអ្នកមកកាន់ស្ទឹងមិគ-សម្មតៈ ( នេះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ ព្រះរាជាហៅពោធិសត្វដោយបទថា **សាម ។** បទថា **អាគម្ម** សេចក្ដីថា មកអំពីប្រទេសណាមកកាន់ព្រៃនេះ ។ បទថា **កស្ស វា បហិតោ** សេចក្ដីថា អ្នកត្រូវអ្នកណាបញ្ជូនទៅដោយពាក្យថា ចូរទៅកាន់ស្ទឹង ដងទឹកនាំមកឲ្យពួកយើង ដូច្នេះ ទើបមកកាន់ស្ទឹងមិគសម្មតានេះ ។

ព្រះពោធិសត្វ បានស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ទុក្ខវេទនាពាល់ត្រូវជាច្រើន ខ្ទរខ្ទូវឈាម ហើយពោលគាថាដូច្នេះថា

មាតាបិតា របស់ទូលបង្គំជាខ្ញុំខ្វាក់ ទូលបង្គំជាខ្ញុំ តែងចិញ្ចឹមគាត់ក្នុងព្រៃធំ ទូលបង្គំជាខ្ញុំ ជាអ្នកដងទឹក ដើម្បីអ្នកមានគុណទាំងឡាយ បានជាមកកាន់ស្ទឹងមិគសម្មតៈ ( នេះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភរាមិ** សេចក្ដីថា នាំនូវមូលផលាផលជាដើមមកចិញ្ចឹម ។ កាលពោលយ៉ាងនេះហើយ ក៏យំរៀបរាប់ប្រារព្ធដល់មាតាបិតាថា

មាតាបិតាទាំងឡាយនោះ មានត្រឹមតែភោជន កាលបើយ៉ាងនេះ ( ជីវិតនឹងប្រព្រឹត្តទៅ ) ត្រឹម ៦ ថ្ងៃ ព្រោះគាត់ខ្វាក់ មុខជានឹង

ស្លាប់ ដោយឥតទឹកពុំមាន ។ ទុក្ខនេះ មិនមែនជាទុក្ខ របស់ទូល បង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះ បុរសត្រូវតែបាន ត្រង់ ដែលទូលបង្គំជាខ្ញុំមានឃើញមាតា ដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ ( ទៅទៀត ) ។ ទុក្ខនេះ មិនមែនជាទុក្ខរបស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខ នេះ បុរសត្រូវតែបាន ត្រង់ដែលទូលបង្គំជាខ្ញុំមានឃើញបិតា ដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ ( ទៅទៀត ) ។ ឱម៉្លេះ សមមាតានៅកំព្រា ទួញយំ ទាំងអធ្រាត្រ និងទីបំផុតនៃរាត្រី អស់កាលជាយូរអង្វែង មុខជា នឹងរីងស្ងួតទៅ ដូចជាស្ទឹង ( ក្នុងគិម្ហរដូវ ) ពុំខាន ។ ឱម៉្លេះ សមបិតានៅកំព្រា ទួញយំទាំងអធ្រាត្រ និងទីបំផុតនៃរាត្រី អស់ កាលជាយូរអង្វែង មុខជានឹងរីងស្ងួត ដូចជាស្ទឹងពុំខាន ។ បពិត្រ ព្រះរាជា មួយវិញទៀត ( ខ្ញុំតែងភ្ញាក់ក្នុងមួយយប់ពីរបីដង ) ដើម្បីបម្រើបាទាដោយព្យាយាម និងដើម្បីគក់ប្រាប់ ម៉្លេះសមគាត់ នឹងដើរចប្រប់ក្នុងព្រៃធំ ដង្ហោយហៅថា អើបាសាម: ដូច្នេះពុំខាន ឡើយ ។ បើទូលបង្គំជាខ្ញុំ ខានឃើញជនទាំងទាំងពីរនាក់ ដោយ ហេតុណា ហេតុនោះឯង ទុកជាសរទីពីរ ដែលញាំងហឫទ័យ របស់ទូលបង្គំជាខ្ញុំឲ្យញាប់ញ័រ មុខជាជីវិតទូលបង្គំជាខ្ញុំ នឹងវិនាស ពុំខាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឩសាមត្តំ** បានដល់ ល្មមជាអាហារ បានឮថា ពាក្យថា **ឩសា** ជាឈ្មោះរបស់ភោជនាហារ សេចក្ដីថា មាតាបិតាទាំងពីរនោះ នៅមានភោជនាហារ ។ បទថា **អជ សាហាស្ស ជីវិតំ** សេចក្ដីថា មានជីវិតនៅបានប្រមាណ ៦ ថ្ងៃ ។ ព្រះមហាសត្វពោលពាក្យនេះ សំដៅដល់ផ្លែឈើដែលនាំមកហើយ ។ ម្យ៉ាងទៀត បទថា **ឩសា** បានដល់ កម្ដៅ ដោយបទនោះ ព្រះមហាសត្វសម្ដែងសេចក្ដីនេះថា ក្នុងរាងកាយរបស់មាតាបិតាទាំងពីរនោះ លុះតែមានកម្ដៅ កាលបើដូច្នោះ ទើបមានជីវិតបាន ៦ ថ្ងៃ ដោយផ្លែឈើដែលខ្ញុំនាំមក ។ បទថា **មរិស្សរេ** បានដល់ នឹងស្លាប់ បពិត្រព្រះរាជាជាធំ សេចក្ដីទុក្ខព្រោះទ្រង់បាញ់ខ្ញុំនេះ ជាសេចក្ដីទុក្ខពិត តែមិនជាទុក្ខរបស់ខ្ញុំ ព្រោះហេតុអ្វីទើបពោលយ៉ាងនេះ ។ បទថា **បុម្មុនា** បានដល់ ដែលបុរស សេចក្ដីថា សេចក្ដីទុក្ខបែបនេះ ដែលបុរសបានជួបទាំងអស់ ព្រោះសេចក្ដីទុក្ខដែលខ្ញុំមិនបានឃើញអ្នកម្ដាយបារិកានោះ ជាសេចក្ដីទុក្ខរបស់ខ្ញុំ ក្រៃលែងជាងសេចក្ដីទុក្ខ ព្រោះត្រូវទ្រង់បាញ់នេះ ១ រយដង ១ ពាន់ដង ១ សែនដង ។ បទថា **ចិរំ រត្តាយ រុច្ឆតិ** សេចក្ដីថា នឹងយំអស់រាត្រីយូរ ។ បទថា **អឌ្ឍរត្តេ** បានដល់ ក្នុងសម័យពាក់កណ្ដាលរាត្រី ។ បទថា **រត្តេ វា** បានដល់ ក្នុងទីបំផុតនៃរាត្រី ។ បទថា **អវសុស្សតិ** បានដល់ នឹងរីងស្ងួត អធិប្បាយថា នឹងរីងស្ងួតដូចស្ទឹងតូចក្នុងរដូវប្រាំង ។ បទថា **ឧដ្ឋានចានចរិយាយ** សេចក្ដីថា បពិត្រព្រះរាជាជាធំ ខ្ញុំក្រោកឡើងមួយយប់ ២-៣ ដង ឬមួយថ្ងៃ ២-៣ ដង បដិបត្តិបម្រើមាតាបិតាទាំងពីរនោះ គក់

ប្របាច់ដៃជើងរបស់លោកទាំងពីរនោះ ដោយសេចក្តីព្យាយាមរបស់ខ្ញុំ ឥឡូវនេះ អ្នកទាំងពីរមានភ្នែកងងឹត មិនឃើញខ្ញុំនឹងក្រោកឡើងដើម្បីបដិបត្តិនោះៗ នឹងកន្ទក់កន្ទេញថា អឺបាសាមៈ អឺបាសាមៈ នឹងត្រូវបន្ទាមុត ត្រាប់ទៅក្នុងហិមវន្តប្បទេសនេះ ។ បទថា **ទុតិយំ** សេចក្តីថា ត្រូវសរ គឺសេចក្តីសោកព្រោះមិនបានឃើញមាតាបិតាទាំងពីរនោះ ដែលជាសេចក្តីទុក្ខទីពីរនេះ ជាសេចក្តីទុក្ខក្រៃលែង ជាងទុក្ខដែលត្រូវព្រួញលាបដោយថ្នាំពិសបាញ់រាប់រយ រាប់ពាន់ រាប់សែនដង ។

ព្រះរាជាទ្រង់ស្តាប់ទំនួញរបស់ព្រះពោធិសត្វនោះ ទ្រង់ត្រិះរិះថា បុរសនេះជាអ្នកប្រព្រឹត្តព្រហ្មចរិយៈតាំងនៅក្នុងធម៌ បដិបត្តិមាតាបិតាដ៏កំពូល ឥឡូវនេះ បានទទួលសេចក្តីទុក្ខបែបនេះ គង់កន្ទក់កន្ទេញដល់មាតាបិតា អញបានធ្វើខុសក្នុងបុរសដែលសម្បូរដោយគុណបែបនេះ អញគួរលួងលោមបុរសនេះយ៉ាងណាល្អហ្ន៎ ហើយទ្រង់សន្និដ្ឋានថា ក្នុងពេលដែលអញធ្លាក់នរក រាជសម្បត្តិនឹងធ្វើអ្វីបាន អញនឹងបដិបត្តិមាតាបិតារបស់បុរសនេះ ដោយទំនងដែលបុរសនេះបដិបត្តិហើយ ការស្លាប់របស់បុរសនេះ នឹងដូចជាមិនស្លាប់ ដោយប្រការដូច្នេះ ទើបត្រាស់ថា

ម្នាលសាមៈ ជាអ្នកមានរូបល្អគួរឲ្យគយគន់ អ្នកកុំទួញយំខ្លាំងឡើយ ខ្ញុំនឹងជាអ្នកធ្វើការងារ ចិញ្ចឹមទូវជនទាំងឡាយនោះ ក្នុងព្រៃធំ ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃ ក្នុងសិល្បធ្នូស្រាប់ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំ ខ្ញុំជាអ្នកធ្វើ

ការងារ ចិញ្ចឹមនូវជនទាំងឡាយនោះ ក្នុងព្រៃធំ ។ ខ្ញុំនឹងជាអ្នកធ្វើការងារ ស្វែងរកសំពានៃម្រឹគ និងមើមឈើ ផ្លែឈើទាំងឡាយក្នុងព្រៃហើយ នឹងចិញ្ចឹមនូវជនទាំងឡាយនោះ ក្នុងព្រៃធំ ។ ម្នាលសាមៈ មាតាបិតារបស់អ្នក នៅក្នុងព្រៃណា ព្រៃនោះដូចម្តេច អ្នកបានចិញ្ចឹមនូវមាតាបិតាយ៉ាងណា ខ្ញុំក៏នឹងចិញ្ចឹមនូវគាត់យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភរិស្សន្តេ** សេចក្តីថា ខ្ញុំនឹងចិញ្ចឹមមាតាបិតាទាំងនោះរបស់អ្នក ។ បទថា **មិគានំ** បានដល់ រាជសីហ៍ ខ្លាធំ ខ្លាដំបងនិងម្រឹគជាដើម ។ បទថា **វិឃាសមន្វេសំ** សេចក្តីថា ស្វែងរក គឺស្វែងរកនូវអាហារ ។ ព្រះរាជាត្រាស់ថា ខ្ញុំជាអ្នកឈ្លាសក្នុងសិប្បធ្នូ នឹងសម្លាប់ម្រឹគជាត់ៗ ចិញ្ចឹមមាតាបិតារបស់អ្នកដោយសាច់ដែលឆ្ងាញ់ដូច្នេះ កាលព្រះពោធិសត្វទូលថា បពិត្រព្រះរាជាជាធំ សូមទ្រង់កុំធ្វើនូវការសម្លាប់សត្វព្រោះហេតុពួកខ្ញុំឡើយដូច្នេះ ទើបត្រាស់យ៉ាងនេះ ។ បទថា **យថា តេ** សេចក្តីថា អ្នកបានចិញ្ចឹមលោកទាំងពីរយ៉ាងណា ខ្ញុំនឹងចិញ្ចឹមលោកទាំងពីរយ៉ាងនោះដូចគ្នា ។

លំដាប់នោះ ព្រះមហាសត្វបានស្តាប់ព្រះវាចារបស់ព្រះរាជានោះហើយទើបទូលថា សាធុ បើយ៉ាងនោះ សូមទ្រង់ចិញ្ចឹមមាតាបិតារបស់ខ្ញុំព្រះអង្គចុះ ។ កាលប្រាប់ផ្លូវឲ្យទ្រង់ជ្រាប ទើបទូលថា

បពិត្រព្រះរាជា ផ្លូវចុះតែជើងម្នាក់នេះ នៅខាងក្បាលដំណេក

ទូលបង្គំជាខ្ញុំ ព្រះអង្គយាងទៅអំពីទីនេះ តែកន្ទះយោសៈ ( ទើង
ឃើញ ) ខ្ទមជាទីនៅរបស់មាតាបិតាទូលបង្គំជាខ្ញុំនោះ ព្រះអង្គ
យាងទៅអំពីទីនេះ សូមទ្រង់ចិញ្ចឹមនូវគាត់ក្នុងទីនោះផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯកបទី** បានដល់ ផ្លូវដើរចំពោះម្នាក់ឯង ។ បទថា **ឧស្សីសកេ** បានដល់ ត្រង់ក្បាលរបស់ខ្ញុំនេះ ។ បទថា **អឌ្ឍយោសំ** បានដល់ រវាងពាក់កណ្តាលសំឡេងដែលស្រែកខ្លាំង ។

ព្រះមហាសត្វប្រាប់ផ្លូវដល់ព្រះរាជាយ៉ាងនេះហើយ អត់សង្កត់នូវវេទនាបែបនោះបាន ដោយសេចក្តីស្រឡាញ់ក្នុងបិតា មាតាជាកម្លាំង ផ្គងអញ្ជលីទូលអង្វរដើម្បីឲ្យចិញ្ចឹមមាតាបិតា បានទូលយ៉ាងនេះទៀតថា

បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំ
ព្រះអង្គ បពិត្រព្រះរាជា ទ្រង់មានសេចក្តីចម្រើនក្នុងដែនកាសី
ទូលបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះអង្គ មាតាបិតាទាំងឡាយ របស់
ទូលបង្គំជាខ្ញុំ ជាមនុស្សខ្វាក់ សូមទ្រង់ចិញ្ចឹមនូវគាត់ ក្នុងព្រៃ
ធំឲ្យទាន ។ ទូលបង្គំជាខ្ញុំ សូមផ្គងអញ្ជលីចំពោះព្រះអង្គ បពិត្រ
ព្រះរាជាជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះអង្គ
ទូលបង្គំជាខ្ញុំសូមផ្តាំទុក សូមទ្រង់ជម្រាបនូវការថ្វាយបង្គំចំពោះ
មាតាបិតា របស់ទូលបង្គំជាខ្ញុំផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វុត្តោ វជ្ជាសិ** សេចក្តីថា មហាសត្វទូលថា បពិត្រព្រះរាជាជាធំ ទ្រង់ដែលខ្ញុំក្រាបទូលហើយ សូមប្រាប់នូវការក្រាប

ថ្វាយបង្គំឲ្យមាតាបិតាជ្រាបយ៉ាងនេះថា សាមកូនរបស់លោកទាំងពីរ ត្រូវខ្ញុំបាញ់ដោយព្រួញដែលលាបដោយថ្នាំពិស ត្រង់មាត់ស្ទឹង ដេកផ្អៀងខាងស្តាំលើផ្នែរខ្សាច់ដែលមានពណ៌ដូចប្រាក់ ផ្គងអញ្ជលីដល់លោក ក្រាបថ្វាយបាតជើងទាំងពីររបស់លោក ។

ព្រះរាជា ទ្រង់ទទួលពាក្យព្រះមហាសត្វ បញ្ជូនការថ្វាយបង្គំមាតាបិតាហើយក៏ដល់នូវវិសញ្ញី គឺសន្លប់ ។ **តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាទូវព្រះគាថាដូច្នេះថា

សាមៈកំលោះ អ្នកមានរូបល្អ គួរពិតពិលរមិលមើលនោះ លុះពោលនូវពាក្យនេះរួចហើយ ក៏ជ្រប់សន្លប់ដោយកម្លាំងពិស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមប្បត្ថ** បានដល់ ជាអ្នកដល់នូវវិសញ្ញី ។

ព្រះមហាសត្វកាលពោលបានប៉ុណ្ណោះក៏រលត់អស្សាសៈ មិនបានពោលបន្តទៀតឡើយ ក្នុងកាលនោះ ពាក្យដែលប្រព្រឹត្តទៅព្រោះអាស្រ័យហទយ-រូប ដែលបន្តនៃចិត្តរបស់ព្រះពោធិសត្វនោះ ដាច់ហើយព្រោះកម្លាំងនៃពិសជ្រួតជ្រាប មាត់របស់ព្រះពោធិសត្វក៏បិទ ភ្នែកក៏បិទ ដៃជើងក៏រឹង រាងកាយទាំងមូលជោកដោយឈាម លំដាប់នោះ ព្រះរាជាទ្រង់គិតថា សុវណ្ណសាមនេះ ពោលនឹងអញអំបាញ់មិញនេះ កើតអ្វីទៅហ្ន៎ ទើបទ្រង់ពិចារណាមើលខ្យល់អស្សាសបស្សាសៈរបស់ព្រះពោធិសត្វ ខ្យល់អស្សាសបស្សាសៈរលត់ហើយ សរីរៈក៏រឹងហើយ ព្រះរាជាទតឃើញហេតុនោះ ទ្រង់ជ្រាបថា

ឥឡូវនេះ សុវណ្ណសាមស្លាប់ហើយ រលត់ហើយ ទ្រង់មិនអាចអត់សង្កត់នូវសេចក្តីសោកបាន ក៏ដាក់ព្រះហស្តលើសិរសា ស្រែកយំដោយសំឡេងខ្លាំង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះរាជាអង្គនោះ ទ្រង់ព្រះកន្សែង រៀបរាប់នូវពាក្យដែលប្រកបដោយសេចក្តីករុណា មានប្រមាណច្រើនថា អាត្មាអញ បានយល់ថា អញមិនចាស់ មិនស្លាប់ ថ្ងៃនេះ អញឃើញនូវសុវណ្ណសាមនេះ ធ្វើកាលកិរិយាហើយ ទើបដឹងនូវហេតុនោះ ពីដើម មិនដឹងជាការមកនៃសេចក្តីស្លាប់ មិនមែនមិនមាន ដូច្នេះ ។ សាមៈដែលដោតដោយថ្នាំពិស កំពុងចរចាជាមួយនឹងអញ ( ក្នុងកាលអម្បាញ់មិញនេះ ) ឥឡូវនេះ គាត់លែងនិយាយពាក្យតិចតួចក្នុងកាលប្រព្រឹត្តទៅយ៉ាងនេះ ក្នុងថ្ងៃនេះ អាត្មាអញ មុខជានឹងទៅកាន់នរកពុំខាន អាត្មាអញ ឥតមានសេចក្តីសង្ស័យ ក្នុងដំណើរនេះទេ ។ ព្រោះថា អំពើបាបដែលអាត្មាអញ ធ្វើទុកហើយក្នុងគ្រានោះ នឹងជាទោសឲ្យផលលាមក អស់កាលជាអង្វែង ( បើ ) ក្នុងស្រុក គង់មានពួកអ្នកតិះដៀលអញនោះថា ព្រះអង្គជាអ្នកធ្វើនូវអំពើអាក្រក់ដូច្នេះ តែក្នុងអរញ្ញប្រទេស ដែលឥតមនុស្ស តើអ្នកណាតិះដៀលអញបាន បើក្នុងស្រុក ពួកមាណពប្រជុំគ្នាហើយ

ចោទប្រកាន់នូវអំពើទាំងឡាយ (របស់អញ) តែក្នុងអរញ្ញប្រទេស ដែលឥតមនុស្ស តើអ្នកណានឹងចោទប្រកាន់អញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាសី** សេចក្តីថា យើងមាននូវសេចក្តីសម្គាល់ថា នឹងមិនចាស់ មិនស្លាប់ មកអស់កាលប្រមាណប៉ុណ្ណោះ ។ បទថា **អជ្ជេតំ** សេចក្តីថា ថ្ងៃនេះ អញបានឃើញសាមបណ្ឌិតនេះធ្វើកាលកិរិយា ទើបដឹងថា ខ្លួនអញក្តី សត្វដទៃៗក្តី ត្រូវចាស់ ត្រូវស្លាប់ទាំងអស់ ។ បទថា **នត្ថិ មច្ចុស្ស នាគមោ** សេចក្តីថា ព្រះរាជាទ្រង់យំរៀបរាប់ថា ការមកនៃមច្ចុនោះ អញដឹងក្នុងថ្ងៃនេះឯង កាលមុនអំពីនេះអញមិនដឹងឡើយ ។ បទថា **ស្វាជ្ជេវ ឆ្ពតេ កាលេ** សេចក្តីថា ព្រះរាជាទ្រង់សម្តែងថា សាមបណ្ឌិតណាត្រូវព្រួញ ដែលលាបដោយថ្នាំពិសជ្រាបហើយ ចរចានឹងអញអំបាញ់មិញនេះឯង សាមបណ្ឌិតនោះ កាលមរណកាលទៅ គឺប្រព្រឹត្តទៅយ៉ាងនេះ ក្នុងថ្ងៃនេះ មិនពោលអ្វីឡើយ សូម្បីតែពាក្យតិចតួច ។ បទថា **តទា ហិ** សេចក្តីថា អញជាអ្នកបាញ់សាមបណ្ឌិតក្នុងខណៈនោះ បានធ្វើនូវបាបកម្មហើយ ។ បទថា **ចិរំ រត្តាយ កិព្វិសំ** សេចក្តីថា បាបនោះ ខ្លាំងក្លាពេកណាស់ អាចធ្វើឲ្យក្តៅក្រហាយអស់រាត្រីដ៏យូរ ។ បទថា **តស្ស** សេចក្តីថា តិះដៀលអញនោះឯង ដែលជាអ្នកធ្វើកម្មបែបនេះ ។ បទថា **វត្តារោ** សេចក្តីថា រមែងតិះដៀល សួរថា តិះដៀលទីណា ឆ្លើយថា តិះដៀលក្នុងស្រុក ។ សួរថា តិះដៀលដូចម្តេច ឆ្លើយថា តិះដៀលថា ជាអ្នកធ្វើកម្មជោកទាប ។

ព្រះរាជាទ្រង់យាំរៀបរាប់ក្នុងព្រៃ ដែលឥតមនុស្សនេះ នរណាហ្ន៎ គួរតិះដៀលអញ បើមាន គប្បីពោលនឹងអញ ។ បទថា **សារយន្តិ** បានដល់ក្នុងស្រុក ឬក្នុងនិគមជាដើម ។ បទថា **សង្គច្ច មាណវា** សេចក្តីថា មនុស្សទាំងឡាយប្រជុំគ្នាក្នុងទីនោះៗ នឹងញ៉ាំងគ្នានិងគ្នាឲ្យរឭកដល់កម្មទាំងឡាយ នឹងចោទយ៉ាងនេះថា នែបុរសសម្លាប់មនុស្ស អ្នកឯងធ្វើកម្មទារុណ អ្នកឯងត្រូវបានទទួលទោសយ៉ាងនោះ តែក្នុងព្រៃមិនមានមនុស្សនេះ អ្នកណានឹងញ៉ាំងព្រះរាជានេះឲ្យរឭកដល់កម្ម ព្រះរាជាទ្រង់ចោទខ្លួនឯង ខ្សឹកខ្សួលយ៉ាងនេះ ដោយប្រការដូច្នេះ ។

កាលនោះ ទេពធីតាឈ្មោះពសុន្ធរី នៅត្រង់ភ្នំគន្ធមាទន៍ ធ្លាប់ជាមាតារបស់មហាសត្វក្នុងអត្តភាពទី ៧ ពិចារណាមើលព្រះពោធិសត្វជានិច្ច ដោយសេចក្តីស្នេហាក្នុងបុត្រ ថ្ងៃនោះ នាងសោយទិព្វសម្បត្តិ មិនបានពិចារណាមើលមហាសត្វ អាចារ្យខ្លះពោលថា នាងទៅកាន់ទេវសមាគមដូច្នេះក៏មាន ។ ក្នុងកាលដែលមហាសត្វសន្លប់ នាងពិចារណាមើលថា ការប្រព្រឹត្តទៅរបស់កូនអញយ៉ាងដូចម្តេចហ្ន៎ បានឃើញថា ព្រះបាទបិលយក្ខនេះបាញ់កូនរបស់អញ ដោយព្រួញដែលលាបដោយថ្នាំពិស ឲ្យដួលត្រង់ច្នេរខ្សាច់ មាត់ស្ទឹងមិគសម្មតា ទ្រហោយំដោយសំឡេងខ្លាំង គិតថា បើអញមិនទៅក្នុងទីនោះ សុវណ្ណសាមបុត្ររបស់អញនឹងវិនាស សូម្បីហទយៈរបស់ព្រះរាជាក៏នឹងបែក មាតាបិតារបស់សាមនឹងអត់អាហារ មិនមានទឹកផឹក នឹងក្រៀមស្ងួតស្លាប់ តែបើអញទៅ ព្រះរាជានឹងកាន់យកក្អមទឹកផឹកទៅកាន់សម្នាក់មាតាបិតារបស់

សាមនោះ កាលយាងទៅហើយ នឹងត្រាស់ថា បុត្ររបស់លោកទាំងពីរ ខ្ញុំសម្លាប់ហើយ កាលទ្រង់ស្តាប់ពាក្យរបស់លោកទាំងពីរនោះហើយ នឹងនាំលោកទាំងពីរនោះ ទៅកាន់សម្នាក់របស់សុវណ្ណសាមដែលជាបុត្រ កាលបើដូច្នេះ តាបស និងតបស្សិនីទាំងពីរ មួយអន្លើដោយអញ នឹងធ្វើសច្ចកិរិយា ពិសរបស់សុវណ្ណសាមក៏នឹងវិនាស កូនរបស់អញនឹងមានជីវិតមកវិញ ភ្នែកទាំងពីររបស់មាតាបិតាសុវណ្ណសាម នឹងមើលឃើញជាប្រក្រតី ព្រះរាជាបានស្តាប់ធម្មទេសនារបស់សុវណ្ណសាម ទ្រង់ត្រឡប់ទៅព្រះនគរ បរិច្ចាគទាន គ្រងរាជសម្បត្តិដោយធម៌ មានស្ថានសួគ៌ជាទីទៅខាងមុខ ព្រោះហេតុនោះ អញនឹងទៅក្នុងទីនោះ ។ ទើបទេពធីតានោះ ទៅស្ថិតនៅក្នុងអាកាស ដោយមិនប្រាកដកាយ ត្រង់ប្រាំងមិគសម្មតានទី ពោលនឹងព្រះបាទបិលយក្ខរាជ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាធនូវព្រះគាថាដូច្នេះថា

ទេវតានោះ បាត់អំពីភ្នំគន្ធមាទន៍ ហើយពោលនូវគាថាទាំងឡាយនេះ ដោយអនុគ្រោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គទ្រង់បានធ្វើនូវបាបជាទម្ងន់ ដែលជាអំពើអាក្រក់ ជនទាំង ៣ នាក់ គឺមាតាបិតា និងបុត្ត ជាអ្នកមិនប្រទូស្ត ទ្រង់បានសម្លាប់ហើយ ដោយព្រួញតែមួយ ។ សូមទ្រង់មក សុគតិកព នឹងគប្បី

មានដល់ព្រះអង្គយ៉ាងណា ខ្ញុំនឹងពន្យល់ព្រះអង្គយ៉ាងនោះ សូម ទ្រង់ចិញ្ចឹមនូវជនខ្វាក់ទាំងពីរនាក់នោះឯង ដោយធម៌ ខ្ញុំយល់ថា សុគតិគប្បីមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រញ្ញោ** បានដល់ ព្រះរាជានោះឯង ។ បទថា **អាគុំ ករិ** សេចក្តីថា បពិត្រព្រះរាជាជាធំ ព្រះអង្គទ្រង់ធ្វើកំហុសច្រើន គឺបាបច្រើន ។ បទថា **ទុក្កដំ** សេចក្តីថា សេចក្តីអាក្រក់ណា ដែលទ្រង់ធ្វើហើយមាន ព្រះអង្គបានធ្វើហើយនូវអំពើអាក្រក់នោះ ដែលកម្មដ៏លាមក ។ បទថា **អទូសកា** បានដល់ ជាអ្នកមិនមានទោស គឺជាអ្នកមិនប្រទូស្ត ។ បទថា **បិតាបុត្តា** សេចក្តីថា ជនទាំង ៣ នេះ គឺមាតា ១ បិតា ១ បុត្រ ១ ទ្រង់សម្លាប់ដោយព្រួញមួយ ដ្បិតថា កាលទ្រង់សម្លាប់សុវណ្ណសាមនោះ សូម្បីមាតាបិតារបស់សុវណ្ណសាម ដែលប្រតិព័ទ្ធសុវណ្ណសាមនោះ ឈ្មោះថា ទ្រង់សម្លាប់ដូចគ្នា ។ បទថា **អនុសិក្ខាមិ** សេចក្តីថា នឹងឲ្យសិក្សា គឺនឹងប្រៀនប្រដៅ ។ បទថា **ឋោស** សេចក្តីថា ចូរតាំងនៅក្នុងឋានៈសុវណ្ណសាម ញុំាងសេចក្តីស្នេហាឲ្យកើតឡើង ចិញ្ចឹមមាតាបិតាទាំងពីរដែលខ្វាក់នោះឲ្យដូចសុវណ្ណសាម ។ បទថា **មញ្ញេហំ សុគតី សិយា** សេចក្តីថា ខ្ញុំយល់ថា ព្រះអង្គគប្បីទៅកាន់សុគតិប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យទេពធីតាហើយ ទ្រង់ជឿថា អញចិញ្ចឹមមាតាបិតារបស់សុវណ្ណសាមហើយ នឹងទៅកាន់សុគតិ ទ្រង់ត្រិះរិះថា អញត្រូវការរាជសម្បត្តិធ្វើអ្វី អញនឹងចិញ្ចឹមលោកទាំងពីរនោះ ទ្រង់តាំងព្រះហឫទ័យមាំ

ទ្រង់កន្ទក់កន្ទេញជាកម្លាំង ទ្រង់ធ្វើសេចក្តីសោកឲ្យស្រោកស្រាន្ត យល់ថា សុវណ្ណសាមពោធិសត្វអស់ជីវិតហើយ ទើបទ្រង់បូជាសរីរៈរបស់ព្រះពោធិ-សត្វនោះ ដោយបុប្ផជាតិផ្សេងៗ ប្រោះព្រំដោយទឹក ធ្វើប្រទក្សិណ ៣ ជុំ ទ្រង់ក្រាបក្នុងឋានៈទាំង ៤ ហើយ កាន់យកក្អមទឹកដែលព្រះពោធិសត្វដង ពេញហើយ ដល់នូវទោមនស្ស បែរមុខទៅទិសទក្សិណយាងទៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាថិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះ បន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

ព្រះរាជាអង្គនោះ ទ្រង់ពិលាបរៀបរាប់ ប្រកបដោយសេចក្តី
ករុណា មានប្រមាណច្រើន ហើយកណ្តៀតក្អមទឹក យាងត្ពោះ
ទៅទិសទក្សិណ ដូច្នេះ ។

ដោយប្រក្រតី ព្រះរាជាទ្រង់មានកម្លាំងច្រើន ទ្រង់កាន់ក្អមទឹកចូល ទៅកាន់អាស្រមបទ ដល់ទ្វារសាលារបស់ទុកូលបណ្ឌិត ដូចបុគ្គលទន្ទិចនូវ អាស្រមឲ្យរង្គើ ទុកូលបណ្ឌិតអង្គុយខាងក្នុង បានស្តាប់សូរជើងរបស់ស្តេច បិលយក្ខ ក៏នឹកក្នុងចិត្តថា នេះមិនមែនជាសូរជើងសុវណ្ណសាម កូនរបស់ អញ សូរជើងអ្នកណាហ្ន៎ កាលសួរ ទើបពោល ២ គាថាថា

សូរជើងនរណាទុ៎ះហ្ន៎ ដែលដើរមកនេះ ពិតជាសូរជើងមនុស្ស
តែសូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិទ្ទុក្ខ អ្នក
ជាអ្វីហ្ន៎ង ។ ដ្បិតសាមៈ តែងដើរថ្នមៗ លើកដាក់ជើងស្រាលៗ

សូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិទ្ទិក្ខ អ្នក
ជាអ្វីហ្នឹង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មនុស្សស្សេវ** សេចក្តីថា សូរជើងដែលមកនេះ មិនមែនរបស់រាជសីហ៍ ខ្លាធំ ខ្លាដំបង យក្ខ និងកិន្នរជាដើម ជាសូរជើងរបស់មនុស្សពិត តែមិនមែនរបស់សាមៈ ។ បទថា **សន្តំ ហិ** បានដល់ស្ងាត់ ។ បទថា **វដ្ឌតិ** បានដល់ ឈានទៅ ។ បទថា **ហញ្ញតិ** បានដល់ ទទេ ។

ព្រះរាជាបានស្តាប់សំណួរនោះ ទ្រង់ត្រិះរិះថា បើអញមិនប្រាប់ភាពដែលអញជាព្រះរាជា ប្រាប់ថា អញសម្លាប់បុត្ររបស់លោកហើយ លោកទាំងពីរនឹងក្រោធអញ ពោលពាក្យគ្រោតគ្រាតនឹងអញ កាលបើដូច្នេះ ការក្រោធក្នុងលោកទាំងពីរនេះនឹងកើតឡើងដល់អញ កាលការក្រោធកើតឡើង អញនឹងបៀតបៀនលោកទាំងពីរនោះ កម្មនោះ នឹងជាអកុសលរបស់អញ តែបើអញប្រាប់ថាជាព្រះរាជា ឈ្មោះថា អ្នកមិនកោតខ្លាច មិនមាន ព្រោះដូច្នោះ អញប្រាប់ភាពជាព្រះរាជាមុន ទ្រង់ត្រិះរិះដូច្នេះហើយ ទ្រង់ដាក់ក្អមទឹកត្រង់រោងទឹក ហើយប្រថាប់ឈរត្រង់ទ្វារបណ្ណសាលា កាលនឹងសម្តែងខ្លួនឲ្យឥសីស្គាល់ ទើបត្រាស់ថា

ខ្ញុំជាព្រះរាជា របស់ពួកអ្នកដែនកាសី គេស្គាល់ខ្ញុំថា បិលយក្ខ
ខ្ញុំលះបង់នូវដែន ត្រាច់ស្វែងរកម្រឹគ ព្រោះល្មោភ ( សាច់ ) ។
មួយទៀត ខ្ញុំជាអ្នកឈ្លាសវៃ ក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញ

ថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំបាន សូម្បីដំរីមកចំមុខព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ ដូច្នេះ ។

ទុកូលបណ្ឌិត កាលធ្វើបដិសណ្ឋារៈជាមួយព្រះរាជា ក៏ទូលថា

បពិត្រមហារាជ ព្រះរាជដំណើរមក របស់ព្រះអង្គល្អហើយ ព្រះដំណើរមករបស់ព្រះអង្គ មិនអាក្រក់ទេ ព្រះអង្គជាធំ ទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូលចុះ ។ បពិត្រព្រះរាជា ផលាផល គឺផ្លែទន្លាប់ មាក់ប៉ែន ស្រគំ សីង មានរសផ្អែមដូចទឹកឃ្មុំ អាត្មាភាពប្រមូលមកទុក ក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផល មានរសឆ្ងាញ់ៗ ។ នេះទឹកត្រជាក់សម្រាប់សោយ ដែលដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ បើទ្រង់សព្វព្រះហឫទ័យ ទ្រង់ ( ដង ) អំពីទីនេះសោយចុះ ដូច្នេះ ។

អត្ថរបស់គាថានោះ ក៏បានពោលហើយក្នុងសត្តិគុម្ពជាតក តែក្នុងទីនេះ បទថា **គិរិគព្ភរា** លោកពោលសំដៅយក មិគសម្មតានទី ព្រោះមិគ-សម្មតានទីនោះ ហូរមកអំពីភ្នំ ទើបឈ្មោះថា កើតអំពីជ្រោះភ្នំ ។

កាលតាបសធ្វើបដិសណ្ឋារៈយ៉ាងនេះហើយ ព្រះរាជាគិតថា អញមិនគួរប្រាប់ថា អញសម្លាប់កូនរបស់លោកឡើយ ធ្វើជាមិនដឹង និយាយរឿងដទៃៗ សិន ហើយសឹមប្រាប់ ទ្រង់ត្រិះរិះដូច្នេះហើយ ទើបត្រាស់ថា

អ្នកទាំងពីរជាមនុស្សខ្វាក់ មិនអាចឃើញ ( អ្វី ) ក្នុងព្រៃទេ ចុះនរណា ប្រមូលនូវផលាផលមកជូនអ្នក អាហារដែល ( បាន )

ដោយប្រពៃនេះ ប្រាកដដល់ខ្ញុំ ដូចជាអាហាររបស់មនុស្សមិនខ្វាក់ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាលំ** សេចក្តីថា លោកទាំងពីរខ្វាក់ មិនអាចមើលអ្វីក្នុងព្រៃនេះបាន ។ បទថា **កោ នុ វោ ផលមាហរិ** សេចក្តីថា អ្នកណាហ្ន៎នាំផ្លែឈើតូចធំមកដើម្បីលោកទាំងពីរ ។ បទថា **និវាបោ** សេចក្តីថា ការបេះ គឺការសន្សំផ្លែឈើតូចធំដែលបរិសុទ្ធល្អ ដែលគួរទទួលទានបានធ្វើយ៉ាងរៀបរយ គឺដោយន័យ ដោយឧបាយ ដោយហេតុនេះ ។ បទថា **អនន្ធស្សេវ** សេចក្តីថា រមែងប្រាកដ គឺចូលទៅតាំងទុកដល់ខ្ញុំ ដូចមនុស្សភ្នែកល្អធ្វើ ។

ទុកូលបណ្ឌិតបានស្តាប់ដូច្នោះ ដើម្បីសម្តែងថា មូលផលាផលខ្លួនមិនបាននាំមក តែកូនរបស់ខ្លួននាំមក ទើបពោល ២ គាថាថា

សាមៈកំលោះនៅក្មេង មិនខ្ពស់ មិនទាបពេក ជាមនុស្សមានរូបល្អគួរគយគន់ មានសក់វែងខ្មៅ ទាំងមានចុងទន់ល្វន់ ។ សាមៈនោះឯង តែងស្វែងរកផលាផល ជាអ្នកដងទឹក បានកាន់យកក្អមទឹកអំពីទីនេះ ទៅកាន់ស្ទឹង ប្រហែលជាជិតមកដល់ហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នាតិព្រហា** សេចក្តីថា មិនខ្ពស់ពេក មិនទាបពេក ។ បទថា **សុនគ្គវេល្លិតា** សេចក្តីថា មានចុងងន់ឡើងដូចចុងកាំបិតសម្រាប់ចិញ្ច្រាំសាច់ ។ បទថា **កមណ្ឌលុំ** បានដល់ ក្អម ។ បទថា **ឆ**

**ធុរមាគតោ** សេចក្តីថា ឥឡូវនេះ សុវណ្ណសាមនឹងមកជិតហើយ គឺនឹងមកហើយក្នុងទីជិត ។

ព្រះរាជាទ្រង់បានស្តាប់ដូច្នោះហើយ ទើបត្រាស់ថា

សាមៈជាអ្នកបម្រើអ្នក អ្នកនិយាយសំដៅកុមារ ឈ្មោះសាមៈ
ណា ដែលមានរូបគួរគេយគន់ សាមៈនោះ ខ្ញុំសម្លាប់ហើយ ។
សាមៈដែលមានសក់វែង ពណ៌ខ្មៅ ចុងទន់ល្វន់ ( ឥឡូវនេះ )
ខ្ញុំសម្លាប់ដួលដេក លើសក់ទាំងនោះ ប្រឡាក់ហើយដោយឈាម
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អវធិ** សេចក្តីថា ខ្ញុំបាញ់ដោយព្រួញសម្រាប់បាញ់ម្រឹគឲ្យស្លាប់ហើយ ។ បទថា **បវេធេឋ** បានដល់ ពោលដល់ ។ បទថា **សេតិ** សេចក្តីថា ដេកលើផ្ទៃខ្សាច់ត្រង់ផ្ទៃស្ទឹងមិគសម្មតានទី ។

បណ្ណសាលារបស់បារិកាតបស្វិនីដែលនៅជិតបណ្ណសាលារបស់ទុកូល-បណ្ឌិត នាងអង្គុយក្នុងបណ្ណសាលានោះ បានស្តាប់ព្រះតម្រាស់របស់ព្រះរាជា ក៏ប្រាថ្នានឹងដឹងហេតុការណ៍នោះ ហើយចេញអំពីបណ្ណសាលារបស់ខ្លួន ទៅកាន់សម្នាក់ទុកូលបណ្ឌិត តាមសញ្ញាខ្សែសម្រាប់ស្ទាវទៅ ហើយពោលថា

បពិត្រទុកូល អ្នកប្រឹក្សាជាមួយនរណា ដែលបាននិយាយថា
ខ្ញុំសម្លាប់សាមៈហើយ បេះដូងខ្ញុំញ័រចំប្រប់ ព្រោះឮថា សាមៈ
ស្លាប់ហើយ ។ ហឫទ័យខ្ញុំញាប់ញ័រ ហាក់ដូចត្រួយពោធិបាយខ្ចី
ដែលមានខ្យល់ប៉ះទង្គិច ព្រោះឮថា សាមៈស្លាប់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វាធិធា** សេចក្តីថា អ្នកពោលថា ខ្ញុំសម្លាប់សាមកុមារហើយ ។ បទថា **បវាលំ** បានដល់ ត្រួយខ្ចី ។ បទថា **មាលុ-តេរិតំ** សេចក្តីថា ត្រូវខ្យល់បក់ឲ្យរញ្ជួយ ។

លំដាប់នោះ ទុកូលបណ្ឌិត កាលនឹងទូន្មាននាងបារិកាតបស្វិនីនោះ ទើបពោលថា

ម្នាលនាងបារិកា នេះជាព្រះរាជា ជាធំក្នុងដែនកាសី ព្រះអង្គបាញ់
សាមៈដោយព្រួញ ក្បែរស្ទឹងមិគសម្មតៈ ដោយសេចក្តីក្រោធ
យើងកុំចង់ឲ្យមានបាប ដល់ព្រះអង្គឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិគសម្មតេ** សេចក្តីថា ត្រង់ឆ្នេរខ្សាច់នាមាត់ស្ទឹងមិគសម្មតានទី ។ បទថា **កោធសា** សេចក្តីថា ដោយសេចក្តីក្រោធ ដែលកើតឡើងក្នុងម្រឹគទាំងឡាយ ។ បទថា **មា ធាបមិច្ឆិម្ហា** សេចក្តីថា យើងទាំងពីរ កុំប្រាថ្នាបាបចំពោះទ្រង់ឡើយ ។ បារិកាតបស្វិនីពោលថា

បុត្តដែលចិញ្ចឹមយើង ងងឹតងងល់ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់
យើងរកបានដោយកម្រ ចិត្តមិនគប្បីរំជួលក្នុងបុរសអ្នកសម្លាប់កូន
ប្រុសតែមួយនោះ ដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃាតម្ហិ** ប្រែថា ក្នុងបុគ្គលដែលសម្លាប់ ។ ទុកូលបណ្ឌិតពោលថា

បុត្តដែលចិញ្ចឹមយើង ងងឹតងងល់ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់

យើងរកបានដោយកម្រ បណ្ឌិតទាំងឡាយ សរសើរសេចក្ដីមិនក្រោធ ចំពោះបុរសអ្នកសម្លាប់នូវបុត្តតែមួយនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អក្កោធំ** សេចក្ដីថា បណ្ឌិតទាំងឡាយរមែងសរសើរ គឺពោលដល់បុគ្គលដែលមិនក្រោធនោះថា ឈ្មោះថា សេចក្ដីក្រោធ រមែងធ្វើឲ្យធ្លាក់នរក ដូច្នោះ មិនគប្បីធ្វើនូវសេចក្ដីក្រោធនោះ គប្បីធ្វើការមិនក្រោធក្នុងបុគ្គលដែលសម្លាប់បុត្រប៉ុណ្ណោះ ។

កាលពោលយ៉ាងនេះហើយ តាបស និងតបស្សិនីទាំងពីរ ក៏គក់ទ្រូងដោយដៃទាំងទ្វេ ពណ៌នាគុណរបស់មហាសត្វ យំសោកដោយច្រើន ។

លំដាប់នោះ ព្រះបាទបិលយក្ខរាជ កាលទ្រង់លួងលោមយកចិត្តតាបស និងតបស្សិនីទាំងពីរនោះ ទើបត្រាស់ថា

អ្នកទាំងពីរកុំគប្បីខ្សឹកខ្សួលខ្លាំង ចំពោះខ្ញុំអ្នកពោលថា សាមៈ ខ្ញុំសម្លាប់ហើយ ខ្ញុំនឹងជាអ្នកធ្វើការងារចិញ្ចឹម ( អ្នកទាំងពីរ ) ក្នុងព្រៃធំ ។ ព្រោះខ្ញុំជាអ្នកឈ្លាសវៃ ក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំ ខ្ញុំនឹងធ្វើការងារចិញ្ចឹម ( អ្នក ) ក្នុងព្រៃធំ ។ ខ្ញុំនឹងធ្វើការងារ ស្វែងរកវំពាម្រឹគទាំងឡាយ ទាំងមើមឈើ ផ្លែឈើ ហើយចិញ្ចឹម ( អ្នក ) ក្នុងព្រៃធំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាធិណា** សេចក្ដីថា លោកទាំងពីរកុំពោលពាក្យជាដើមថា បុត្រដែលដល់ព្រមដោយគុណយ៉ាងនេះរបស់អញ ត្រូវអ្នកពោលជាមួយខ្ញុំថា សម្លាប់សាមកុមារហើយដូច្នេះ សម្លាប់ហើយ ឥឡូវនេះ

អ្នកណានឹងចិញ្ចឹមពួកយើង ដូច្នេះ កុំកន្ទក់កន្ទេញច្រើនឡើយ ខ្ញុំនឹងធ្វើការងារដល់លោកទាំងពីរ ចិញ្ចឹមលោកទាំងពីរដូចសាមកុមារ កាលត្រាស់យ៉ាងនេះហើយ ព្រះរាជាបានលួងលោមជនទាំងពីរនោះថា សូមលោកទាំងពីរកុំគិតថ្វីឡើយ ខ្ញុំមិនត្រូវការរាជសម្បត្តិ ខ្ញុំនឹងចិញ្ចឹមលោកទាំងពីរដរាបដល់អស់ជីវិតលំដាប់នោះ តាបស និងតបស្សិនីទាំងពីរនោះ សន្ទនាជាមួយព្រះរាជាថា

បពិត្រមហារាជ នេះមិនមែនជាទំនៀមទេ កិរិយាធ្វើនូវអំពើ

( របស់ព្រះអង្គ ) នេះ មិនសមគួរដល់យើងឡើយ ព្រះអង្គជា

ព្រះរាជារបស់យើងៗ សូមថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មោ** បានដល់ សភាព ឬហេតុការណ៍ ។ បទថា **នេតំ អម្ហេសុ កប្បតិ** សេចក្ដីថា ការធ្វើនូវការងាររបស់ព្រះអង្គនោះមិនគួរ គឺមិនស្អាត មិនសមគួរក្នុងអាត្មាទាំងពីរ ។ បទថា **ឯតេ វន្ទាម តេ** សេចក្ដីថា តាបស តបស្សិនីទាំងពីរនោះ តាំងនៅក្នុងភេទបព្វជិត ទូលព្រះរាជាដូច្នេះ ព្រោះសេចក្ដីសោកក្នុងបុត្រគ្របសង្កត់ និងព្រោះមិនមានមានះ ។ តាបស និងតបស្សិនីពោលយ៉ាងនេះ ដើម្បីឲ្យកើតការស្និទ្ធស្នាលដល់ព្រះរាជា ។

ព្រះរាជាបានស្ដាប់ដូច្នោះ ទ្រង់ត្រេកអរពន់ពេក ទ្រង់ព្រះតម្រិះថា ឱគួរអស្ចារ្យ សូម្បីពាក្យគ្រោតគ្រាតរបស់ឥសីទាំងពីរនេះ ក៏មិនមានដល់អញដែលធ្វើនូវការប្រទូស្តដល់ម៉្លេះ បែរជាលើកតម្កើងអញទៀតផង ទើបត្រាស់ដូច្នេះថា

បពិត្រអ្នកនេសាទ អ្នកពោលនូវធម៌ អ្នកធ្វើនូវសេចក្តីគោរព ( ចំពោះខ្ញុំ ) អ្នកទុកជាបិតារបស់ខ្ញុំ បពិត្រនាងបារិកា នាងទុកជាមាតារបស់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តយា** សេចក្តីថា កាលពោលជាបុគ្គលៗ ក៏ពោលយ៉ាងនេះ ។ បទថា **បិតា** ជាដើម សេចក្តីថា បពិត្រលោកឪពុកទុកូលបណ្ឌិត តាំងអំពីថ្ងៃនេះទៅ សូមលោកតាំងនៅក្នុងឋានៈជាបិតារបស់ខ្ញុំ បពិត្រអ្នកម៉ែបារិកា សូម្បីលោកក៏ចូរនៅក្នុងឋានៈនៃមាតា ខ្ញុំនឹងតាំងនៅក្នុងឋានៈនៃសាមកុមារបុត្ររបស់លោក ធ្វើកិច្ចគ្រប់យ៉ាង មានលាងជើងជាដើម សូមលោកទាំងពីរកុំកំណត់ខ្ញុំថាខ្ញុំជាព្រះរាជា ចូរកំណត់ថាជាសាមកុមារចុះ ។

តាបស និងតបស្វិនីទាំងពីរ ផ្គងអញ្ជលីទូលអង្វរថា សូមថ្វាយព្រះពរមហាបពិត្រ ទ្រង់មិនមានកិច្ចដែលធ្វើការងារចំពោះអាត្មាទាំងពីរ តែសូមទ្រង់កាន់ចុងឈើច្រត់របស់អាត្មាទាំងពីរ ទៅបង្ហាញខ្លួនសុវណ្ណសាមចុះ ទើបពោល ២ គាថាថា

បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ ទ្រង់ចម្រើនក្នុងដែនកាសី ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ ទូលបង្គំទាំងឡាយ សូមប្រណម្យអញ្ជលីចំពោះព្រះអង្គ សូមព្រះអង្គនាំទូលបង្គំទៅដល់សាមៈ ។ ទូលបង្គំទាំងឡាយ នឹងប្របាច់ជើង ស្នាមមុខល្អគួរមើល របស់សាមៈនោះ ត្រៀមរង់ចាំនូវសេចក្តីស្លាប់ប៉ុណ្ណោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាវ សាមានុធាបយ** សេចក្តីថា សូមនាំអាត្មាទាំងពីរទៅកាន់ទីដែលសាមកុមារនៅ ។ បទថា **កុជនស្ស៊ំ** សេចក្តីថា សាមកុមារស្អាតគួរមើល មានរូបគួរជ្រះថ្លា ។ បទថា **សំសុម្ភមានា** បានដល់ វាយ[១] ។ បទថា **កាលមាគមយាមសេ** សេចក្តីថា នឹងធ្វើ គឺនឹងដល់កាលកិរិយា ។

កាលលោកទាំងនោះសន្ទនាគ្នាយ៉ាងនេះ ព្រះអាទិត្យក៏អស្តង្គត លំដាប់នោះ ព្រះរាជាទ្រង់ត្រិះរិះថា បើអញនាំឥសីទាំងពីរដែលមានភ្នែកខ្វាក់ទៅក្នុងសម្នាក់របស់សាមក្នុងកាលឥឡូវនេះ ហទយៈរបស់ឥសីទាំងពីរនឹងបែក ព្រោះឃើញសាមនោះ អញក៏ឈ្មោះថា ដេកក្នុងនរក ក្នុងកាលដែលលោកទាំងបីធ្វើកាលកិរិយា ដោយប្រការដូច្នេះ ព្រោះដូច្នោះ អញនឹងមិនឲ្យឥសីទាំងពីរនោះទៅ ត្រិះរិះដូច្នេះហើយ ទើបត្រាស់ ៤ គាថាថា

សាមៈដែលស្លាប់ហើយ ដួលដេកដូចជាព្រះចន្ទ្រ ធ្លាក់មកលើប្រឹថពី ក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។

សាមៈដែលស្លាប់ហើយ ដួលដេកដូចជាព្រះអាទិត្យ ធ្លាក់មកលើប្រឹថពីក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។

សាមៈដែលស្លាប់ហើយ ដួលដេកប្រឡាក់ប្រឡូសដោយអាចម៍ដី

---

១- បិដកខ្មែរ ប្រែថា ត្រៀមរង់ចាំ ។

នៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាស
ដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។ សាមៈ
ដែលស្លាប់ហើយ ដួលដេកនៅក្នុងព្រៃណា ព្រៃនោះឯង ជា
ព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូច
ជាទីបំផុតនៃអាកាស ( ព្រោះហេតុនោះ ) អ្នកទាំងឡាយ ចូរនៅ
តែក្នុងអាស្រមនេះហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្រហា** បានដល់ ខ្ពស់ក្រៃលែង ។ បទថា **អាកាសន្តំ** សេចក្ដីថា ព្រៃនោះឯង ឃើញគ្នាទូទៅ គឺជីងគ្រប់គ្នា ហាក់បីដូចទីបំផុតនៃអាកាស ។ ម្យ៉ាងទៀត បទថា **អាកាសន្តំ** សេចក្ដីថា ធ្វើឲ្យកើតជាស្នាម គឺប្រាកដ ។ បទថា **ឆមា** បានដល់ លើផែនដី គឺប្រឹថពី ។ បាឋៈថា **ឆមំ** ដូច្នេះក៏មាន សេចក្ដីថា ដូចដួលចុះលើផែនដី ។ បទថា **បរិ-កុណ្ឌិតោ** សេចក្ដីថា ប្រឡាក់ប្រឡូស គឺជាប់ស្អេកស្អះ ។

លំដាប់នោះ ឥសីទាំងពីរបានពោលគាថាដើម្បីសម្ដែងថា ខ្លួនមិនខ្លាចពាលម្រឹគទាំងឡាយឡើយថា

បើទុកណាជាទីនោះ ( មានម្រឹគសាហាវ ) រយ ពាន់ ម៉ឺនក្ដី
ទូលបង្គំទាំងពីរនាក់ ឥតមានសេចក្ដីភិតភ័យតិចតួច ព្រោះសត្វ
សាហាវទាំងឡាយក្នុងព្រៃទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោចិ** សេចក្ដីថា ព្រៃនេះសូម្បីជាប្រទេសមួយក្នុងទីណាៗ អាត្មាទាំងពីរមិនមានការខ្លាចក្នុងពាលម្រឹគទាំងឡាយឡើយ ។

លំដាប់នោះ ព្រះរាជាកាលមិនអាចឃាត់ឥសីទាំងពីរនោះ ក៏ទ្រង់ដឹកដៃនាំទៅកាន់សម្នាក់សុវណ្ណសាមនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាចិធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូច្យសានូវព្រះគាថាដូច្នេះថា

គ្រានោះ ព្រះរាជាជាធំក្នុងដែនកាសី នាំជនខ្វាក់ ( ទាំងពីរ )

ដឹកដៃទៅក្នុងព្រៃធំ ត្រង់កន្លែងដែលសាមៈស្លាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តតោ** សេចក្ដីថា ក្នុងសម័យនោះ ។ បទថា **អន្ធានំ** បានដល់ ឥសីទាំងពីរដែលមានភ្នែកខ្វាក់ ។ បទថា **អហុ** ប្រែថា បានមានហើយ ។ បទថា **យត្ថ** សេចក្ដីថា ព្រះបាទកាសី នាំឥសីទាំងពីរទៅកាន់ទីដែលសាមដេក ។

កាលទ្រង់នាំទៅហើយ ប្រថាប់ឈរក្នុងទីជិតសុវណ្ណសាម រួចត្រាស់ថា នេះកូនរបស់លោកទាំងពីរ លំដាប់នោះ ឥសីជាបិតារបស់ព្រះពោធិសត្វលើកក្បាលឡើងដាក់លើភ្លៅ តបស្សិនីជាមាតាក៏លើកជើងឡើងដាក់លើភ្លៅរបស់ខ្លួន អង្គុយទ្រហោយំ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាចិធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូច្យសានូវព្រះគាថាដូច្នេះថា

មាតាបិតាឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូស ដោយ

អាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ហាក់ដូចព្រះចន្ទ្រ ដែលធ្លាក់មកលើប្រឹថពី ។ ឃើញនូវសាមៈ ជាបុត្តជួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ដូចព្រះអាទិត្យដែលធ្លាក់មកលើប្រឹថពី ។ ឃើញនូវសាមៈ ជាបុត្តជួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ក៏យំរាប់រៀបគួរឲ្យអាណិត ។ ឃើញនូវសាមៈ ជាបុត្តជួលប្រឡាក់ប្រឡូសដោយអាចម៍ដី ហើយផ្គងដើមដៃ យំទន្ទឹះខ្សឹកខ្សួលថា ហៃបាដ៏ចម្រើន ( ការស្លាប់នេះ ) មានសភាពមិនគួរទេ ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាឯងជាមនុស្សស្រវឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱបាសាមៈ មានរូបល្អគួរឲ្យក្រឡេកមើល បាជាមនុស្សភ្លើតភ្លើនខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱបាសាមៈ អ្នកមានរូបល្អ គួរឲ្យក្រឡេកមើល បាឯងខឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាឯងដេកលក់ស៊ប់ បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឥតនិយាយរកយើងបន្តិចបន្តួចសោះ ។ ឱសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាជាបុគ្គលតូច

ចិត្តខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឥត និយាយរកយើងបន្តិចបន្តួចសោះ ។ ឥឡូវនេះ នរណានឹងរៀប ចំជដាដ៏សៅហ្មង ប្រឡាក់ប្រឡូសដោយអាចម៍ដី ព្រោះសាមៈ ជាអ្នកបម្រើយើងងនឹតងងល់នេះ ធ្វើមរណកាលហើយ ។ នរណា នឹងកាន់អម្បោស បោសអាស្រមដើម្បីយើង ព្រោះសាមៈជាអ្នក បម្រើយើងងនឹតងងល់នេះ ធ្វើមរណកាលហើយ ។ ឥឡូវនេះ នរណានឹងផ្ងូត ( យើង ) ដោយទឹកត្រជាក់ ទឹកក្តៅ ព្រោះ សាមៈជាអ្នកបម្រើយើងងនឹតងងល់នេះ ធ្វើមរណកាលហើយ ។ ឥឡូវនេះ នរណានឹងឲ្យយើងបរិភោគមើមឈើ ផ្លែឈើ ព្រោះ សាមៈជាអ្នកបម្រើយើងងនឹតងងល់នេះ ធ្វើមរណកាលហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបវិទ្ធំ** សេចក្តីថា ទុកចោលដោយឥត ប្រយោជន៍ ។ បទថា **អជ្ជេវ កិរ ភោ ឥតិ** សេចក្តីថា បានឮថា ភាពយុត្តិ- ធម៌កំពុងប្រព្រឹត្តទៅក្នុងលោកនេះ ក្នុងថ្ងៃនេះ ។ បទថា **បមត្តោ** សេចក្តីថា ស្រវឹង គឺដល់នូវសេចក្តីប្រមាទ ដូចផឹកនូវសុរាខ្លាំង ។ បទថា **បតិត្តោ** បានដល់ ប្រកាន់ខ្លួន ។ បទថា **វិមនោ** សេចក្តីថា ជាអ្នកលេង ឥសីទាំងពីរ ពោលរវើរវាយផ្តេសផ្តាស ។ បទថា **ជដំ** បានដល់ ផ្នួងសក់របស់យើង ទាំងពីរដែលសៅហ្មង ។ បទថា **វលិនំ បំសុគតំ** សេចក្តីថា នឹងប្រឡាក់ មន្ទិលក្នុងកាលណា ។ បទថា **កោនានិ** សេចក្តីថា ឥឡូវនេះ អ្នកណានឹង

រៀបផ្នួងសក់ឲ្យត្រង់ គឺធ្វើនូវការសម្អាត ហើយធ្វើឲ្យត្រង់ក្នុងកាលនោះ ។

លំដាប់នោះ តបស្វិនីជាមាតារបស់ព្រះពោធិសត្វ កាលរវើរវាយខ្លាំង ក៏យកដៃរីតទ្រូងរបស់ព្រះពោធិសត្វ ពិចារណានូវកម្តៅ គិតថា ការក្តៅត្រង់ទ្រូងរបស់កូនអញនៅប្រព្រឹត្តទៅ កូនរបស់អញសន្លប់ដោយកម្លាំងពិស អញនឹងធ្វើសច្ចកិរិយាដល់កូនរបស់អញ ដើម្បីបន្សាត់បង់នូវពិស គិតដូច្នេះហើយ បានធ្វើសច្ចកិរិយា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួព្យសានូវព្រះគាថាដូច្នេះថា

មាតាឃើញសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្តីសោកព្រោះកូនបៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុនសាមៈនេះ ជាអ្នកពោលនូវពាក្យសត្យ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាអ្នកបម្រើមាតា និងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាប

រលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះជាអ្នកប្រព្រឹត្ត កោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលបិតារបស់អ្នកផង បានធ្វើហើយដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេន សច្ចេន** បានដល់ ដោយសេចក្ដីពិតណា គឺដោយសភាវៈណា ។ បទថា **ធម្មចារី** បានដល់ អ្នកប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ ។ បទថា **សច្ចវាទី** សេចក្ដីថា មិនពោលមុសាវាទ សូម្បីត្រឹមតែការសើចលេង ។ បទថា **មាតាបេត្តិភរោ** សេចក្ដីថា ជាអ្នកមិនខ្ជិលច្រអូស បម្រើមាតាបិតាអស់យប់ និងថ្ងៃ ។ បទថា **កុលេ ជេដ្ឋាបចាយិកោ** សេចក្ដីថា ជាអ្នកធ្វើនូវសក្ការៈដល់បិតាជាដើម ដែលចម្រើនបំផុត ។

កាលមាតាធ្វើសច្ចកិរិយាដោយគាថា ៧ យ៉ាងនេះ សាមកុមារក៏ប្រែខ្លួនលំដាប់នោះ បិតាគិតថា កូនរបស់អញនៅមានជីវិត អញនឹងធ្វើសច្ចកិរិយាដែរ ទើបធ្វើសច្ចកិរិយាយ៉ាងនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទ

ព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួបស្យសានូវព្រះគាថាដូច្នេះថា

បិតាឃើញសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្ដីសោកព្រោះកូនបៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈជាអ្នកពោលនូវពាក្យសត្យ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកចិញ្ចឹមមាតា និងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាបុគ្គលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលមាតារបស់អ្នកផង បានធ្វើហើយ

ដោយកុសលទាំងអស់នោះ សូមពិសរបស់សាមៈសាបរលាប
ទៅ ដូច្នេះ ។

កាលបិតាធ្វើសច្ចកិរិយាយ៉ាងនេះ មហាសត្វ ក៏ប្រែខ្លួនទៅម្ខាងទៀត លំដាប់នោះ ទេពធីតាឈ្មោះពសុន្ធរី បានធ្វើសច្ចកិរិយាជាលំដាប់ទី ៣ ដល់ព្រះមហាសត្វនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសានូវព្រះគាថាដូច្នេះថា

ទេវតានោះ បាត់អំពីភ្នំគន្ធមាទន៍ បានពោលនូវពាក្យសច្ចៈនេះ
ដោយសេចក្តីអនុគ្រោះសាមៈថា ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍
អស់កាលជាយូរអង្វែងហើយ ឥតមាននរណាដទៃ ដែលជាទី
ស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងសាមៈទេ ដោយការពោល
សច្ចៈនុ៎ះ សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ។ នៅភ្នំគន្ធ-
មាទន៍ សព្វព្រៃព្រឹក្សាទាំងឡាយ សុទ្ធសឹងមានក្លិនក្រអូប ដោយ
ការពោលសច្ចៈនេះ សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ។
កាលបើជនទាំងនោះ កំពុងចរចារៀបរាប់នូវពាក្យប្រកបដោយ
សេចក្តីករុណា មានប្រមាណច្រើន សាមៈជាមនុស្សកំលោះ
មានរូបល្អ គួរឲ្យរមិលមើល ក៏ក្រោកឡើងភ្លាម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បព្វត្យាហំ** កាត់បទជា **បព្វតេ អហំ**

សេចក្តីថា យើងនៅត្រង់បពិត ។ បទថា **សព្វេ វនា គន្ធមយា** បានដល់ សម្រេចហើយ ដោយដើមឈើមានក្លិនក្រអូបត្រង់ភ្នំនោះ មិនមានដើមឈើណាមួយ ដែលមិនមានក្លិនក្រអូបឡើយ ។ បទថា **តេសំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលឥសីទាំងពីរនោះកំពុងរៀបរាប់នោះឯង សាមកុមារបានក្រោកឡើងដោយរួសរាន់ក្នុងកាលដែលទេពធីតាធ្វើសច្ចកិរិយាចប់ការឈឺចាប់របស់សាមកុមារនោះ បានសាបរលាបទៅ ដូចទឹករមៀលធ្លាក់ចុះអំពីស្លឹកឈូក មិនប្រាកដស្នាមរបួសដែលបាញ់ថា ត្រូវបាញ់ត្រង់នេះ ត្រូវបាញ់ក្នុងទីនេះ ។

អស្ចារ្យទាំងពួង គឺព្រះមហាសត្វជាសះស្បើយរោគ ឥសីជាមាតាបិតាក៏មានភ្នែកឃើញជាប្រក្រតី អរុណក៏រះឡើង ជនទាំង ៤ ក៏ប្រាកដត្រង់អាស្រមដោយអានុភាពរបស់ទេវតា មានឡើងក្នុងពេលតែមួយ មាតាបិតាទាំងពីរបានទូវភ្នែកល្អជាប្រក្រតីហើយ ត្រេកអរពន់ពេកថា កូនសាមបានជាសះស្បើយ លំដាប់នោះ សាមបណ្ឌិតបានពោលនឹងជនទាំងនោះ ដោយគាថានេះថា

ខ្ញុំឈ្មោះសាម: សេចក្តីចម្រើន ចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងដោយសួស្តីហើយ សូមលោកទាំងឡាយ កុំខ្សឹកខ្សួលខ្លាំងឡើយ សូមលោកទាំងឡាយ ចរចាចំពោះខ្ញុំ ដោយពាក្យពីរោះ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វឃើញព្រះរាជា កាលនឹងធ្វើបដិសណ្ឋារៈ

ទើបពោលគាថាទាំងនេះថា

បពិត្រមហារាជ ព្រះរាជដំណើររបស់ព្រះអង្គមកល្អហើយ ទ្រង់យាងមកមិនអាក្រក់ទេ ព្រះអង្គជាធំទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូល ។ បពិត្រមហារាជ ផលាផល មានផ្លែទន្លាប់ មាក់ប្រ៉ែន ស្រគំ សឹងមានរសផ្អែមដូចទឹកឃ្មុំ ទូលបង្គំជាខ្ញុំប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផល ដែលមានរសឆ្ងាញ់ៗ ។ បពិត្រមហារាជ ទឹកសម្រាប់សោយដ៏ត្រជាក់ ទូលបង្គំជាខ្ញុំបាននាំមកអំពីជ្រោះភ្នំ បើព្រះអង្គមានសេចក្តីត្រូវការ សូមទ្រង់ដងអំពីទីនោះសោយចុះ ដូច្នេះ ។

ចំណែកព្រះរាជាទតឃើញអស្ចារ្យនោះ ទើបត្រាស់ថា

ខ្ញុំវង្វេងកាន់កាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ព្រោះបានឃើញសាមៈនោះ ធ្វើមរណកាលហើយ ម្នាលសាមៈ អ្នកដូចម្តេច ក៏រស់ឡើងវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បេតំ** សេចក្តីថា បានឃើញសាមបណ្ឌិតធ្វើកាលកិរិយាហើយ ។ បទថា **កោ នុ តំ** សេចក្តីថា ព្រះរាជាត្រាស់សួរថា អ្នកជីវិតខ្ញុំនមកបានដូចម្តេចហ្ន៎ ។

ចំណែកសាមបណ្ឌិតត្រិះរិះថា ព្រះរាជាទ្រង់កំណត់អញថាស្លាប់ហើយ អញនឹងប្រកាសភាពដែលអញមិនទាន់ស្លាប់ដល់ទ្រង់ ទើបទូលថា

បពិត្រមហារាជ ( សត្វលោក ) តែងសម្គាល់នូវបុរសដែល
មានវេទនាធ្ងន់ តែនៅរស់ ឬមានសេចក្តីត្រិះរិះក្នុងចិត្ត ធ្លាក់ចុះក្នុង
ករណ្តដែលនៅរស់ថាស្លាប់ ។ បពិត្រមហារាជ ម្យ៉ាងទៀត ( សត្វ
លោក ) តែងសម្គាល់នូវបុរស ដែលមានវេទនាធ្ងន់ តែនៅរស់
ឬចូលនិរោធ នៅរស់នោះ ថាស្លាប់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ ជីវំ** បានដល់ ជាអ្នករស់នៅពិតៗ ។
បទថា **ឧបនីតមនសង្កប្បំ** បានដល់ មានចិត្តវារៈ ឈមចុះក្នុងករណ្ត ។
បទថា **ជីវន្តំ** បានដល់ នៅមានជីវិតពិតៗ ។ បទថា **មញ្ញតេ** សេចក្តីថា
លោកនេះ រមែងសម្គាល់ថា បុគ្គលនេះស្លាប់ហើយ ។ បទថា **និរោធគតំ**
សេចក្តីថា សាមបណ្ឌិតពោលថា លោករមែងសម្គាល់នូវបុគ្គល ដែលនៅ
មានជីវិត មានអស្សាសបស្សាសៈដល់នូវការរលត់រម្ងាប់ហើយ រស់នៅ
ពិតៗ ដូចខ្ញុំថា ស្លាប់ហើយយ៉ាងនេះ ។

កាលទូលយ៉ាងនេះហើយ ព្រះមហាសត្វបំណងនឹងប្រកបព្រះរាជាក្នុង
ប្រយោជន៍ កាលសម្តែងនូវធម៌ ទើបពោល ២ គាថាថា

សត្វណា តែងចិញ្ចឹមនូវមាតា និងបិតាដោយធម៌ ទេវតាទាំង
ឡាយ តែងរក្សានូវសត្វអ្នកចិញ្ចឹមមាតាបិតានោះ ។ សត្វណា
តែងចិញ្ចឹមមាតា និងបិតាដោយធម៌ បណ្ឌិតទាំងឡាយ ក្នុង
លោកនេះឯង តែងសរសើរនូវសត្វនោះ សត្វនោះ លុះលះបង់
លោកនេះទៅ រមែងរីករាយក្នុងស្ថានសួគ៌ ដូច្នេះ ។

ព្រះរាជាបានស្តាប់ពាក្យនោះហើយ ទ្រង់ត្រិះរិះថា គួរអស្ចារ្យហ្ន៎ សូម្បីទេវតាទាំងឡាយ ក៏ព្យាបាលរោគដែលកើតឡើងដល់បុគ្គលអ្នកចិញ្ចឹមមាតាបិតា សាមបណ្ឌិតនេះ ល្អល្អះពន់ពេក ទ្រង់ត្រិះរិះដូច្នេះហើយ ផ្គងអញ្ជលីត្រាស់ថា

ខ្ញុំរឹងរឹតតែវង្វេង កាន់កាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ម្នាលសាមៈ ខ្ញុំសូមយកអ្នកជាទីពឹង អ្នកចូរជាទីពឹងរបស់ខ្ញុំដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភិយ្យោ** សេចក្តីថា ព្រោះខ្ញុំបានធ្វើខុសក្នុងបុគ្គលដែលមានសីលបរិសុទ្ធ សម្បូណ៌ដោយគុណដូចអ្នកដូច្នេះ ទើបខ្ញុំវង្វេងពន់ពេក ។ បទថា **ត្វញ្ច មេ សរណំ ភវ** សេចក្តីថា ខ្ញុំសូមដល់អ្នកជាសរណៈ សូមអ្នកជាសរណៈ គឺចូរជាទីពឹងរបស់ខ្ញុំ ខ្ញុំសូមដល់នូវសរណៈ គឺសូមអ្នកធ្វើខ្ញុំឲ្យទៅទេវលោក ។

លំដាប់នោះ ព្រះមហាសត្វទូលព្រះរាជាថា បពិត្រមហារាជ បើទ្រង់មានបំណងទៅកាន់ទេវលោក មានបំណងបរិភោគទិព្វសម្បត្តិធំ សូមទ្រង់ប្រព្រឹត្តទសពិធរាជធម៌ទាំងនេះចុះ កាលនឹងថ្វាយឱវាទដល់ព្រះរាជា ទើបពោលគាថា ដោយការប្រព្រឹត្តទសពិធរាជធម៌ថា

បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមាតានិងបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ

សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះបុត្រ និងភរិយា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមិត្ត និងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះសត្វពាហនៈ និងពល បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះស្រុក និងនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះអ្នកដែន និងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះសមណៈ និងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះម្រឹគ និងបក្សី បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ធម៌ដែលប្រព្រឹត្តល្អហើយ តែងនាំមកនូវសុខ

បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅ
កាន់ស្ថានសួគ៌ ។ បពិត្រព្រះមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌
( ព្រោះ ) ទេវតា ឥន្ទ ព្រហ្ម ដែលបានដល់នូវស្ថានសួគ៌
ក៏ព្រោះធម៌ ដែលខ្លួនប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា ព្រះអង្គ
កុំប្រហែសធ្វេសនឹងធម៌ឡើយ ដូច្នេះ ។

សេចក្តីនៃគាថាទាំងនេះ មានពោលដោយពិស្តារហើយ ក្នុងតេស-
កុណជាតកនោះឯង ។

ព្រះមហាសត្វសម្តែងធម៌ថ្វាយព្រះរាជាយ៉ាងនេះហើយ កាលថ្វាយឱវាទ
ឲ្យក្រៃលែងឡើង បានថ្វាយបញ្ចសីល ព្រះរាជាទ្រង់ទទួលឱវាទរបស់ព្រះ
មហាសត្វនោះដោយសិរសា ទ្រង់ថ្វាយបង្គំព្រះពោធិសត្វ សូមខមាទោសព្រះ
ពោធិសត្វហើយ យាងត្រឡប់មកក្រុងពារាណសី ទ្រង់បំពេញព្រះរាជកុសល
មានទានជាដើម ទ្រង់រក្សាបញ្ចសីល គ្រងរាជសម្បត្តិដោយធម៌ ដោយស្មើ
ក្នុងទីបំផុតនៃព្រះជន្ម មានស្ថានសួគ៌ជាទីទៅខាងមុខ ។ ចំណែកព្រះពោធិសត្វ
បដិបត្តិមាតាបិតា ញុំាងអភិញ្ញា និងសមាបត្តិឲ្យកើត មួយអន្លើដោយមាតា
បិតាមានឈានមិនសាបសូន្យ ក្នុងទីបំផុតនៃអាយុ បានចូលដល់ព្រហ្មលោក
មួយអន្លើដោយមាតាបិតានោះឯង ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយត្រាស់ថា ម្នាល
ភិក្ខុទាំងឡាយ ឈ្មោះថា ការចិញ្ចឹមមាតាបិតា ជាវង្សរបស់បណ្ឌិតទាំង
ឡាយ ត្រាស់ដូច្នេះហើយ ទ្រង់ប្រកាសអរិយសច្ច ៤ ក្នុងកាលចប់

អរិយសច្ច ភិក្ខុនោះសម្រេចសោតាបត្តិផល ហើយទ្រង់សមោធានជាតកថា ព្រះបាទបិលយក្ខក្នុងកាលនោះ បានមកជាភិក្ខុឈ្មោះអានន្ទក្នុងកាលឥឡូវនេះ ពសុន្ធរីទេពធីតាក្នុងកាលនោះ បានមកជាភិក្ខុនីឈ្មោះឧប្បលវណ្ណា សក្កទេវរាជក្នុងកាលនោះ បានមកជាភិក្ខុឈ្មោះអនុរុទ្ធ ទុកូលបណ្ឌិតដែលជាបិតាក្នុងកាលនោះ បានមកជាភិក្ខុឈ្មោះមហាកស្សបៈ នាងបារិកាដែលជាមាតាក្នុងកាលនោះ បានមកជាភិក្ខុនីឈ្មោះភទ្ទកាបិលានី សុវណ្ណសាមបណ្ឌិតក្នុងកាលនោះ គឺតថាគតសម្មាសម្ពុទ្ធនេះឯង ។

# សុត្តន្តបិដក

## នេមិរាជជាតក

[ ១៣២ ] *( អភិសម្ពុទ្ធគាថា ) ក្នុងកាលដែលព្រះបាទនេមិជាបណ្ឌិត អ្នកត្រូវការដោយកុសល ជាព្រះរាជាអ្នកទូន្មាននូវសត្រូវ ទ្រង់តែងឲ្យទានដល់ជន អ្នកនៅក្នុងដែនវិទេហៈទាំងឡាយគ្រប់គ្នាគ្រានោះ ( មនុស្ស និងទេវតាទាំងឡាយ តែងសរសើរថា ) ឱអស្ចារ្យណាស់ អ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាជាគ្រឿងពិចារណាកើតឡើងក្នុងលោកហើយ ។ កាលព្រះរាជាអង្គនោះ ទ្រង់ឲ្យទាននោះ សេចក្ដីត្រិះរិះកើតឡើងថា ទានក្ដី ព្រហ្មចរិយៈក្ដី កុសលណាហ្ន៎ មានផលច្រើនជាង ។*

[ ១៣៣ ] *ទេវរាជឈ្មោះមឃវៈ ជាទេវកុញ្ជរ ជាសហស្សនេត្របានជ្រាបព្រះតម្រិះរបស់ព្រះរាជានោះ ហើយមកប្រាកដ ( ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ) កម្ចាត់បង់នូវងងឹតដោយវណ្ណៈ ។ ព្រះបាទនេមិរាជ ជាធំជាងមនុស្ស ទ្រង់ព្រឺព្រះលោមា បានសួរទេវរាជឈ្មោះវាសវៈថា អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាសក្កបុរិន្ទទៈ ។ រស្មីប្រាកដដូច្នោះ ខ្ញុំពុំដែលឃើញ ទាំងមិនធ្លាប់ឮឡើយ បពិត្រអ្នកដ៏ចម្រើន អ្នកចូរប្រាប់ខ្ញុំ ធ្វើម្ដេចយើងស្គាល់អ្នកបាន ។ ទេវរាជឈ្មោះវាសវៈជ្រាបថា ព្រះបាទនេមិព្រឺព្រះលោមាហើយ ទើបឆ្លើយថា ខ្ញុំជាព្រះឥន្ទ ជាធំជាងទេវតា មកកាន់សម្នាក់ព្រះអង្គ បពិត្រព្រះអង្គជាធំជាមនុស្ស ទ្រង់កុំព្រឺព្រះ*

លោមាឡើយ ព្រះអង្គមានសេចក្ដីប្រាថ្នា ដើម្បីសួរនូវប្រស្នាណា សូមទ្រង់សួរចុះ ។ ចំណែកព្រះបាទនេមិរាជអង្គនោះ លុះព្រះឥន្ទ្រាធិរាជធ្វើឱកាសហើយ ក៏ទ្រង់ត្រាស់សួរនូវទេវរាជឈ្មោះវាសវៈថា បពិត្រទេវរាជ ជាឥស្សរៈជាងសព្វសត្វទាំងឡាយ ខ្ញុំសូមសួរព្រះអង្គថា ទានក្ដី ព្រហ្មចរិយៈក្ដី កុសលណា មានផលច្រើនជាង ។ ព្រះវាសវៈនោះ ដែលព្រះបាទនេមិ ជានរទេពសួរហើយ ក៏ឆ្លើយតបព្រះបាទនេមិវិញ ព្រះវាសវៈនោះប្រាប់នូវផលនៃព្រហ្មចរិយៈ បានទូលព្រះបាទនេមិដែលមិនជ្រាបថា បុគ្គលកើតក្នុងត្រកូលក្សត្រ ដោយព្រហ្មចរិយៈថោកទាប ដល់នូវភាពជាទេវតា ដោយព្រហ្មចរិយៈជាកណ្ដាល បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់ ។ ពួកអ្នកបួសប្រព្រឹត្តតបៈទាំងឡាយ ទៅកើតក្នុងពួកព្រហ្មណា ពួកព្រហ្មទាំងនុ៎ះ បុគ្គលអ្នកប្រកបក្នុងការសូមណាមួយ មិនងាយបានសោះទេ ។

[ ១៣៤ ] ព្រះបាទទុទីបៈ ១ ព្រះបាទសាគរៈ ១ ព្រះបាទសេលៈ ១ ព្រះបាទមុចលិន្ទ ១ ព្រះបាទភគីរសៈ ១ ព្រះបាទឧសិន្នរៈ ១ ព្រះបាទអត្ថកៈ ១ ព្រះបាទអស្សកៈ ១ ព្រះបាទបុថុជ្ជនៈ ១ ។ ព្រះរាជាទាំងឡាយអង្គនេះក្ដី ព្រះរាជាទាំងឡាយដទៃក្ដី ពួកក្សត្រពួកព្រាហ្មណ៍ជាច្រើនក្ដី ដែលបូជានូវគ្រឿងយញ្ញយ៉ាងច្រើន មិនប្រព្រឹត្តកន្លងនូវបេតភាព ( កាមាវចរភូមិ ) ឡើយ ។

[ ១៣៥ ] ជនទាំងឡាយណា មិនមានគូ ជាបុគ្គលម្នាក់ឯង រមែងមិនត្រេកអរ ( ត្រេកអរតែក្នុងការនៅប្រឡូកប្រឡំដោយពួក ) ជនទាំងឡាយណា មិនមានបីតិដែលកើតអំពីវិវេកទេ ជនទាំងឡាយនោះ ទុកជាមានភោគៈស្មើដោយព្រះឥន្ទក៏ដោយចុះ ជនទាំងឡាយនោះ ក៏ឈ្មោះថា ជាបុគ្គលកម្សត់ មានសេចក្តីសុខ ព្រោះកិរិយាអាស្រ័យនូវបុគ្គលដទៃដោយពិត ។

[ ១៣៦ ] ឥសី ៧ អង្គនេះ គឺឥសីឈ្មោះយាមហនុ ១ សោមយាគៈ ១ មនោជវៈ ១ សមុទ្ទៈ ១ មាឃៈ ១ ភរតៈ ១ ឥសីឈ្មោះកាលបុរក្ខិតៈ ១ និងឥសីទាំងឡាយ ៤ អង្គ គឺឥសីឈ្មោះអង្គីរសៈ ១ កស្សបៈ ១ កីសវច្ឆៈ ១ អកត្តិ ១ ជាអនាគារបុគ្គល មានតបធម៌បានកន្លង ( កាមាវចរភូមិ ) ដោយពិត ។

[ ១៣៧ ] នៅប្រទេសហិមវន្តខាងជើង មានស្ទឹងឈ្មោះសីទា មានជម្រៅដ៏ជ្រៅ អ្នកផងឆ្លងបានដោយកម្រ ( ទាំងពីរខាងច្នេរស្ទឹងនោះ ) មានភ្នំមាស ពណ៌ដូចភ្លើងខៀវ រុងរឿងសព្វៗ កាល ។ ( ទៀបច្នេរនៃស្ទឹងនោះ ) សឹងមានដើមក្រស្នា លូតលាស់ទន្ទឹងទន្គោល មានទាំងរុក្ខជាតិផ្សេងៗ មានគុម្ពលូតលាស់ ( អំពីជើងបព៌ត ) ក្នុងកាលមុន មានពួកឥសីចាស់ៗ មួយម៉ឺនអង្គ នៅក្នុងទីនោះឯង ។ ខ្ញុំជាបុគ្គលប្រសើរដោយការឲ្យ និងការប្រព្រឹត្តវត្ត

ដោយការសង្រួម និងការទូន្មាន ( នូវឥន្ទ្រិយ ) ហើយប្រព្រឹត្ត ( ម្នាក់ឯង ) លះបង់ ( ពួក ) ជាអ្នកមានចិត្តតាំងមាំ ។ ខ្ញុំមិនរិះគន់នូវជនអ្នកមានជាតិទាប និងមានជាតិខ្ពស់ នមស្ការចំពោះជនអ្នកមានចិត្តត្រង់ មិនមានកំណត់កាលវេលាឡើយ ព្រោះថាសត្វទាំងឡាយ មានកម្មជាផៅពង្ស ។ វណ្ណៈទាំងអស់ អ្នកមិនតាំងនៅក្នុងធម៌ រមែងធ្លាក់ចុះក្នុងនរកជាខាងក្រោម វណ្ណៈទាំងអស់ បានប្រព្រឹត្តធម៌ដ៏ឧត្តមហើយ រមែងបរិសុទ្ធ ។

[ ១៣៨ ] មឃទេវរាជ សុជម្បតិទ្រង់ពោលពាក្យនេះ ទ្រង់ប្រៀនប្រដៅព្រះបាទនេមិជាធំក្នុងដែនវិទេហៈ រួចហើយ ទ្រង់ចៀសចេញទៅកាន់ពួកទេវតាក្នុងស្ថានសួគ៌ ។

[ ១៣៩ ] ( ព្រះឥន្ទ ... ) ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយទាំងប៉ុន្មានដែលបានមកប្រជុំគ្នាហើយក្នុងទីនេះ ចូរចាំស្តាប់នូវគុណខ្ពស់ និងទាប មានប្រមាណច្រើននេះរបស់មនុស្សទាំងឡាយ អ្នកប្រកបដោយធម៌ ។ ដូចជាព្រះបាទនេមិអង្គនេះ ជាបណ្ឌិត ជាអ្នកត្រូវការដោយកុសល ជាព្រះរាជាទូន្មាននូវសត្រូវ បានឲ្យទានដល់អ្នកដែនវិទេហៈទាំងឡាយគ្រប់ៗ គ្នា ។ កាលដែលព្រះរាជាអង្គនោះ កំពុងឲ្យនូវទាននោះ សេចក្តីត្រិះរិះកើតឡើងថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណា មានផលច្រើនជាង ។

[ ១៤០ ] ( មហាជន ... ) ឱហ្ន៎ សេចក្តីព្រឺរោម មិនធ្លាប់កើតមាន ក៏កើតឡើងហើយក្នុងលោក រថទិព្វកើតប្រាកដហើយដល់ព្រះបាទវិទេហៈមានយស ។

[ ១៤១ ] ( អភិសម្ពុទ្ធគាថា ) មាតលិទេវបុត្រ អ្នកមានឫទ្ធិច្រើន ជាទេវសារថី បានអញ្ជើញព្រះបាទវិទេហៈអ្នកគ្រប់គ្រងក្រុងមិថិលាថា ។ បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងមក ទ្រង់ស្តេចឡើងកាន់រថនេះ ដ្បិតទេវតាទាំងឡាយនៅស្ថានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ ចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយនោះ តែងរឭក ( ព្រះអង្គ ) កំពុងនៅប្រជុំក្នុងធម្មសភាឈ្មោះសុធម្មា ។

[ ១៤២ ] លំដាប់នោះ ព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលា ទ្រង់ម្ទីម្ទាក្រោកចាកអាសនៈ បែរព្រះភក្ត្រឡើងកាន់រថ ។ មាតលិទេវបុត្រទូលសួរព្រះបាទនេមិរាជនុ៎ះ ដែលស្តេចឡើងកាន់រថទិព្វហើយដូច្នេះថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណា តាមផ្លូវដែលសត្វមានបាបកម្ម ឬតាមផ្លូវដែលសត្វមានបុញ្ញកម្ម ។

[ ១៤៣ ] ( ព្រះបាទនេមិ ... ) ម្នាលមាតលិទេវសារថី អ្នកចូរនាំខ្ញុំទៅតាមផ្លូវទាំងពីរ គឺផ្លូវដែលសត្វមានបាបកម្មផង ផ្លូវដែលសត្វមានបុញ្ញកម្មផង ។

[ ១៤៤ ] ( មាតលិ ... ) បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណាមុន តាមផ្លូវដែលសត្វមានបាបកម្មមុនឬ ឬតាមផ្លូវដែលសត្វមានបុញ្ញកម្មមុន ។

[ ១៤៥ ] ( ព្រះបាទនេមិ ... ) ខ្ញុំចង់ឃើញនរកជាទីនៅនៃសត្វអ្នកមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញស្ថាននៃសត្វ អ្នកមានកម្មលាមក និងគតិនៃសត្វទ្រុស្តសីលទាំងឡាយមុន ។

[ ១៤៦ ] ( អភិសម្ពុទ្ធគាថា ) មាតលិទេវសារថី បង្ហាញព្រះរាជានូវស្ទឹងឈ្មោះវេតរណី ដែលសត្វឆ្លងបានដោយកម្រ ប្រកបព្រមដោយទឹកផ្សាប្រៃកំពុងពុះ ក្តៅដូចអណ្តាតភ្លើង ។

[ ១៤៧ ] ព្រះបាទនេមិ ទ្រង់ឃើញសត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី ជាទីឆ្លងឡើងបានដោយកម្រក្រៃលែង ហើយត្រាស់សួរមាតលិទេវសារថីថា ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ( សត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី ) ម្នាលមាតលិទេវសារថីខ្ញុំសួរអ្នក សត្វទាំងឡាយនេះ ធ្លាក់ទៅកាន់ស្ទឹងវេតរណី តើពួកសត្វនេះ បានធ្វើបាបកម្មអ្វី ។

[ ១៤៨ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករផលនៃបាបកម្មទាំងឡាយដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកសត្វណា មានកម្លាំង មានធម៌ដ៏លាមក បៀតបៀនប្រទេចផ្តាសា នូវពួកសត្វដែលមានកម្លាំង

ខ្សោយក្នុងជីវលោក ពួកសត្វមានកម្មលាមកនោះ រមែងវេទនាបាប ពួកសត្វទាំងនោះឯង រមែងធ្លាក់ទៅកាន់ស៊ឹងវេតរណី ។

[ ១៤៩ ] ( ព្រះបាទនេមិ ... ) ពួកឆ្កែព្រៃសម្បុរក្រហម និងពពាល ពួកត្មាត ពួកក្អែក ជាសត្វគួរខ្លាច តែងទំពាស៊ី ( សត្វនរកដែលវាប្រទះឃើញ ) ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថីខ្ញុំសួរអ្នក ហ្វូងក្អែកតែងជញ្ជែងស៊ី នូវសត្វទាំងឡាយនេះ តើសត្វទាំងឡាយនេះបានធ្វើបាបដូចម្តេច ។

[ ១៥០ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃកម្មដែលខ្លួនដឹង ទូលព្រះរាជា ដែលមិនទ្រង់ជ្រាបថា សត្វទាំងឡាយណានីមួយ មានសេចក្តីកំណាញ់កំណាញ់ស្វិតស្វាញ មានធម៌លាមកពេក ជាអ្នកជេរប្រទេចបៀតបៀន ប្រទូស្តសមណព្រាហ្មណ៍ សត្វអ្នកមានអំពើលាមកទាំងនោះ រមែងវេទនាបាប ទើបហ្វូងក្អែកជញ្ជែងស៊ីសត្វទាំងឡាយនោះ ។

[ ១៥១ ] ( ព្រះរាជា ... ) សត្វនរកទាំងឡាយ មានសរីរៈឆេះសន្ធោសន្ធៅ ដើរលើផែនដីដែក ថែមទាំងនាយនិរយបាលសំពងដោយដំបងដែកទាំងឡាយ ដែលភ្លើងឆេះ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថីខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលវាយដោយដំបង ដួលដេកនេះ តើពួកសត្វ

ទាំងនេះ បានធ្វើបាបដូចម្តេច ។

[ ១៥២ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលបាបកម្មដែលខ្លួនដឹង ទូលព្រះរាជា ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយមានបាបធម៌ពេញបន្ទុក បៀតបៀនប្រទេចផ្តាសានូវបុរសស្ត្រី ដែលឥតបាបធម៌ក្នុងជីវលោក ឈ្មោះថាជាអ្នកមានបាបធម៌ពេញបន្ទុក ជនអ្នកមានកម្មលាមកទាំងនោះរមែងរងបាប ជនទាំងឡាយនោះឯងហើយ ដែលនាយនិរយបាលបៀតបៀនដោយដំបង ដួលដេកនៅ ។

[ ១៥៣ ] ( ព្រះរាជា ... ) ពួកសត្វនរកដទៃ មានខ្លួនឆេះជុំវិញកំពុងទួញយំ ( ធ្លាក់ទៅ ) កាន់រណ្តៅរងើកភ្លើងហើយថ្ងូរ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយ ដែលធ្លាក់ទៅកាន់រណ្តៅរងើកភ្លើងហើយថ្ងូរ តើពួកសត្វទាំងឡាយនេះ បានធ្វើបាបដូចម្តេច ។

[ ១៥៤ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ពោលអាងសាក្សី ( កោង ) ក្នុងហេតុនៃទ្រព្យរបស់ប្រជុំជន ហើយញុំាងទ្រព្យជាបំណុលនោះឲ្យវិនាស បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ ញុំាងពួកជនឲ្យវិនាសហើយ ជនទាំងឡាយ អ្នកមានកម្មដ៏លាមកនោះ

រមែងវេងបាប ទើបជនទាំងឡាយនោះឯង ( ធ្លាក់ទៅ ) កាន់រណ្តៅរងើកភ្លើង ហើយថ្ងូរ ដូច្នេះ ។

[ ១៥៥ ] ( ព្រះរាជា ... ) ខ្ទះទង់ដែងធំ មានភ្លើងឆេះសន្ធោសន្ធៅ ឡោលប្រាលឆ្អៅ ប្រាកដជាក់ស្តែង ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថីខ្ញុំសួរអ្នក ពួកសត្វទាំងនេះ ( មានក្បាលសំយុងចុះ ) ធ្លាក់ទៅកាន់ខ្ទះ ពេញដោយទឹកទង់ដែង តើពួកសត្វទាំងនេះ ធ្វើបាបដូចម្តេច ។

[ ១៥៦ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណាមានធម៌ដ៏លាមកពេក បៀតបៀនប្រទេចផ្តាសា នូវសមណៈ ឬព្រាហ្មណ៍អ្នកមានសីល ជនអ្នកមានកម្មដ៏លាមកទាំងឡាយនោះ តែងវេងនូវបាប ជនទាំងនោះ ( មានក្បាលសំយុងចុះ ) ធ្លាក់ទៅកាន់ខ្ទះពេញដោយទឹកទង់ដែង ។

[ ១៥៧ ] ( ព្រះរាជា ... ) ពួកនាយនិរយបាលត្របែងកនៃសត្វនរក ហើយកាប់ពន្លះបោះទៅក្នុងទឹកក្តៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថីខ្ញុំសួរអ្នក ចុះពួកសត្វដែលមានក្បាលដាច់ ហើយដេកនៅនេះ តើសត្វពួកនេះបានធ្វើបាបដូចម្តេច ។

[ ១៥៨ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោក មានបាបធម៌ពេញបន្ទុក តែងចាប់បៀតបៀននូវសត្វស្លាបទាំងឡាយ បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះបៀតបៀនហើយនូវសត្វស្លាប ពួកជនអ្នកមានកម្មលាមកនោះរមែងរងនូវបាប ជនទាំងឡាយនោះ មានក្បាលដាច់ ហើយដេកនៅ ដូច្នេះ ។

[ ១៥៩ ] ( ព្រះរាជា ... ) ស្ទឹងនេះមានទឹកច្រើន មានច្រាំងមិនជ្រៅ មានកំពង់ល្អរាបទាបហូរទៅ សត្វដែលមានសេចក្ដីស្រេកឃ្លានគ្របសង្កត់ហើយតែងផឹក ស្រាប់តែទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាម ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថីខ្ញុំសួរអ្នក ចុះទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាមវិញ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្ដេច ។

[ ១៦០ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ។ ជនទាំងឡាយណា អ្នកមានកិច្ចការមិនបរិសុទ្ធ លាយនូវស្រូវសុទ្ធដោយអង្កាម ឲ្យដល់អ្នកទិញ បានជា

ទឹកដែលជនទាំងឡាយនោះ កំពុងមានសេចក្តីក្តៅបៀតបៀន មានសេចក្តីស្រេកឃ្លានគ្របសង្កត់ ហើយផឹកទៅក្លាយជាអង្កាមវិញ ។

[ ១៦១ ] ( ព្រះរាជា ... ) នាយនិរយបាលទាំងឡាយ ចាក់នូវសរីរៈទាំងពីរខាងនៃសត្វនរក ដែលកំពុងកន្ទក់កន្ទេញដោយព្រួញទាំងឡាយក៏មាន ដោយលំពែងទាំងឡាយក៏មាន ដោយលំពែងស្នែងក្របីទាំងឡាយក៏មាន ម្នាលទេពបម្រើ សេចក្តីភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលបៀតបៀនហើយ ដោយលំពែង ដេកនៅដូច្នេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

[ ១៦២ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ។ ជនទាំងឡាយណា ក្នុងជីវលោក ជាអ្នកមានកម្មមិនល្អ លួចយកស្រូវ ទ្រព្យ ប្រាក់មាស ទាំងសត្វចិញ្ចឹម ពពែ ចៀម និងក្របី ដែលគេមិនឲ្យហើយធ្វើនូវការចិញ្ចឹមជីវិត ជនអ្នកមានកម្មដ៏លាមកទាំងនោះរមែងរងនូវបាប ទើបពួកជនទាំងនោះ ត្រូវនាយនិរយបាលបៀតបៀនហើយ ដោយលំពែង ដេកនៅដូច្នេះ ។

[ ១៦៣ ] ( ព្រះរាជា ... ) ហេតុអ្វីសត្វនរកទាំងឡាយនេះ មួយពួក ត្រូវនាយនិរយបាលចងកអូស ពួកដទៃត្រូវនាយនិរយបាល

ចិញ្ច្រាំ ពួកដទៃទៀតត្រូវនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទីដួលដេកនៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថីខ្ញុំសួរអ្នក ជនទាំងឡាយដែលនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ហើយដួលដេកនៅ តើពួកជនទាំងនោះ បានធ្វើនូវបាបដូចម្តេច ។

[ ១៦៤ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទាន់ជ្រាបថា ជនទាំងឡាយណា ជាអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក សម្លាប់ត្រី សម្លាប់សត្វចិញ្ចឹម គឺក្របី ពពែ និងចៀម ហើយដាក់លក់ពួដ៏ភានផ្សារលក់សាច់ ជនអ្នកមានកម្មអាក្រក់ទាំងនោះ តែងវេងបាប បានជាជនទាំងនោះ ត្រូវនាយនិរយបាលធ្វើខ្ទេចខ្ទី ហើយដេកនៅ ។

[ ១៦៥ ] ( ព្រះរាជា ... ) អន្លង់នេះ ពេញពោរដោយមូត្រ និងករីស មានក្លិនអាក្រក់ មិនស្អាត ស្អុយផ្សាយទៅ ពួកជនអ្នកមានសេចក្តីស្រេកឃ្លាន គ្របសង្កត់ហើយ ស៊ី ( នូវមូត្រ និងករីសនេះ ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនអ្នកបរិភោគនូវមូត្រ និងករីសនេះ តើពួកជនទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

[ ១៦៦ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិន

ទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ជាអ្នកបង្កសេចក្តីទុក្ខ អ្នកបៀតបៀនមិត្តសម្លាញ់ អ្នកតាំងនៅក្នុងការបៀតបៀននូវជនដទៃសព្វៗ កាល ពួកជនទាំងឡាយ មានអំពើលាមកនោះ រមែងរងបាប ជនពាលទាំងឡាយ ជាអ្នកទ្រុស្តមិត្តនោះ តែងស៊ីអាហារចាស់ ។

[ ១៦៧ ] ( ព្រះរាជា ... ) អន្ទង់នេះ ពេញពោរទៅដោយឈាមនិងខ្ទុះ មានក្លិនអាក្រក់ មិនស្អាត ស្អុយផ្សាយទៅ ពួកសត្វដែលត្រូវកម្តៅបៀតបៀនហើយ ផឹក ( ឈាម និងខ្ទុះនោះ ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេពសារថី ខ្ញុំសួរអ្នក ពួកជនដែលមានឈាម និងខ្ទុះជាអាហារនេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

[ ១៦៨ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជា ដែលមិនជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ សម្លាប់ព្រះអរហន្ត គឺមាតា ឬបិតា ឈ្មោះថា បារាជិក ( ក្នុងភាពជាគ្រហស្ថ ) ពួកជនអ្នកមានអំពើលាមកនោះ តែងរងបាប ជនទាំងនោះ មានឈាម និងខ្ទុះជាអាហារ ។

[ ១៦៩ ] ( ព្រះរាជា ... ) អ្នកចូរមើលនូវសត្វនរក មានអណ្តាតមុតដោយសន្ទូច បីដូចស្បែកដែលគេខ្ទារដោយកង្វេរ ញាប់ញ័រ

ដូចត្រី ដែលជនបោះទៅលើគោក ព្រោះហេតុអ្វីហ្ន៎ បានជាសត្វនរក ទាំងនេះ យំបង្អៀរទឹកមាត់ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះ ឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលស៊ីសន្ទូច ដេកនៅ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

[ ១៧០ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា មនុស្សទាំងឡាយណានីមួយ ស្ថិតនៅក្នុង តំណែង ជាអ្នកកាត់ថ្លៃទំនិញ ញុំាងទំនិញដែលមានថ្លៃ ឲ្យសាប- សូន្យចាកថ្លៃ ( បន្ថោកទំនិញគេ ) ប្រកបដោយអំពើកោង ធ្វើ អំពើកោង ព្រោះហេតុចង់បានទ្រព្យ បីដូចជាសន្ទូច ដែលគេបិទ បាំង ( ដោយនុយ ) ដើម្បីសម្លាប់ត្រី ។ ទីពឹងរបស់អ្នក ធ្វើនូវ អំពើកោង ជាបុគ្គលដែលកម្មរបស់ខ្លួន រួបរឹតហើយ មិនមានទេ ពួកជនអ្នកមានអំពើលាមកនោះ តែងវេងបាប បានជាពួកជនទាំង នោះ ជាអ្នកស៊ីសន្ទូច ដេកនៅ ។

[ ១៧១ ] ( ព្រះរាជា ... ) ពួកស្ត្រីទាំងនេះ មានខ្លួនដាច់ខ្ទេចខ្ទី មានជាតិអាក្រក់ មានខ្លួនប្រឡាក់ពាសពេញ ដោយឈាម និង ខ្ទុះ មានខ្លួនដាច់រយេះរយាយ បីដូចគោទាំងឡាយ ដែលគេពន្ទះ ក្នុងទីសម្លាប់ ផ្គងដើមដៃទាំងឡាយ យំកន្ទក់កន្ទេញ ពួកស្ត្រីទាំង នោះ ( មានខ្លួនត្រឹមបង្កេះ ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោ

សន្ធៅ មានក្អួរមៀលកិនសព្វៗ កាល ។ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិជាទេវសារថី ខ្ញុំសួរអ្នក ពួកស្ត្រីដែល ( មានខ្លួនត្រឹមចង្កេះ ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានក្អួរមៀលកិនសព្វៗ កាល តើពួកស្ត្រីទាំងនេះបានធ្វើបាបដូចម្តេច ។

[ ១៧២ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពួកស្ត្រីមានត្រកូល ក្នុងជីវលោកនេះ មានអំពើមិនបរិសុទ្ធ បានប្រព្រឹត្តនូវអំពើជារបស់អសប្បុរស ពួកស្ត្រីទាំងនោះ មានសភាពជាអ្នកលេង លះបង់ស្វាមីហើយ ត្រាច់ទៅរកបុរសដទៃ ព្រោះហេតុតែកាមគុណ និងល្បែងពាល ពួកស្ត្រីទាំងនោះ ក្នុងជីវលោក លុះញុំាងបុរសដទៃ ឲ្យត្រេកត្រអាលទើបមានភ្លើងឆេះសន្ធោសន្ធៅ មានក្អួរមៀលកិន ដូច្នេះ ។

[ ១៧៣ ] ( ព្រះរាជា ... ) ព្រោះហេតុអ្វី បានជាសត្វនរកមួយពួកទៀតនេះ ត្រូវនាយនិរយបាលចាប់ជើង ដោយមានក្បាលសំយុងចុះ ហើយទម្លាក់ទៅក្នុងរណ្តៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះដែលមានក្បាលសំយុងចុះ នាយនិរយបាល ទម្លាក់ទៅក្នុងរណ្តៅនរក តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្តេច ។

[ ១៧៤ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ អ្នកមានអំពើជារបស់អសប្បុរស ប្រព្រឹត្តកន្លងនូវប្រពន្ធទាំងឡាយ នៃជនដទៃ សត្វទាំងឡាយ ប្រាកដដូច្នោះនោះ ឈ្មោះថា ជាអ្នកលួចនូវរបស់ដ៏ថ្លៃថ្លា បានជាសត្វទាំងនោះ ( មានក្បាលសំយុងចុះ ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅ ។ សត្វទាំងឡាយនោះ តែងរងនូវទុក្ខវេទនា ក្នុងនរកទាំងឡាយនោះ អស់ប្រជុំនៃឆ្នាំដ៏ច្រើន ព្រោះថា ទីពឹងទាំងឡាយ របស់បុគ្គលអ្នកធ្វើបាប ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយ មិនមានទេ ពួកសត្វអ្នកមានអំពើលាមកនោះ រមែងរងនូវបាប ទើបបានជាពួកជនទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅ ។

[ ១៧៥ ] ( ព្រះរាជា ... ) ពួកសត្វទាំងឡាយនេះ ខ្ពស់ និងទាបផ្សេងៗ គ្នា ជាអ្នកត្រជាក់ត្រដួស មានរូបគួរខ្លាចពន់ពេក ប្រាកដនៅក្នុងនរកទាំងឡាយ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានសេចក្ដីទុក្ខវេទនាក្លៀវក្លា ខ្លាចផ្សា ក្ដៅក្រហាយក្រៃលែងនេះ តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្ដេច ។

[ ១៧៦ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏

ព្យាករនូវផលបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែល មិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ មានទិដ្ឋិ លាមកក្រៃលែង តែងធ្វើអំពើដ៏ស្មុគ្រ ព្រោះមោហៈ ទាំងបបួល អ្នកដទៃ ( ឲ្យយល់ ) ក្នុងទិដ្ឋិទាំងឡាយនោះផង ជនទាំងឡាយ នោះ មានទិដ្ឋិបាប រមែងរងបាប ទើបបានជាពួកជនទាំងនោះ រង ទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សា ក្តៅក្រហាយក្រៃលែង ។

[ ១៧៧ ] បពិត្រព្រះរាជា ទីលំនៅរបស់សត្វ អ្នកមានបាបកម្ម ទាំងឡាយ ស្ថានរបស់សត្វ អ្នកមានអំពើអាក្រក់ទាំងឡាយ និង គតិរបស់សត្វ អ្នកទ្រុស្តសីលទាំងឡាយ ព្រះអង្គទ្រង់បានជ្រាប ហើយ បពិត្រព្រះរាជា អ្នកស្វែងរកគុណដ៏ធំ សូមទ្រង់ស្តេចទៅ ក្នុងសម្នាក់ទេវរាជឥឡូវនេះ ។

[ ១៧៨ ] ( ព្រះបាទនេមិ ... ) វិមាននេះ មានកំពូលប្រាំ ដែល យើងឃើញប្រាកដ មាននាងនារីមានអានុភាពធំ ប្រដាប់ដោយ កម្រងផ្កា សម្តែងនូវទេវឫទ្ធិ មានប្រការផ្សេងៗ នៅកណ្តាល ជំណោកក្នុងវិមាននោះ ម្នាលទេពបម្រើ សេចក្តីរីករាយមានប្រាកដ ដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក នារីដែល បានដល់ស្ថានសួគ៌ហើយ រីករាយក្នុងវិមាន តើនារីនេះ បានធ្វើ កុសលដូចម្តេច ។

[ ១៧៩ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏

ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះ
រាជានោះ ដែលមិនទ្រង់ជ្រាបថា ពិរណី ដែលទ្រង់ធ្លាប់ជ្រាបហើយ
ជាទាសីកើតហើយ ក្នុងផ្ទៃនៃទាសី ក្នុងផ្ទះនៃព្រាហ្មណ៍ ក្នុងជីវ-
លោក នាងពិរណីនោះដឹងថា ភិក្ខុជាភ្ញៀវ មានកាលដល់ហើយ
( ហើយក៏អង្គាសចង្ហាន់ប្រគេនភិក្ខុនោះ ) ហាក់ដូចជាមាតា ដែល
ត្រេកអរចំពោះបុត្ររបស់ខ្លួន នាងជាអ្នកសង្រួម ជាអ្នកចែកទាន
ទើបនាងរីករាយក្នុងវិមាន ។

[ ១៨០ ] ( ព្រះបាទនេមិ ... ) វិមានមាសទាំង ៧ ដែលបុញ្ញកម្ម
តាក់តែងហើយ មានពន្លឺរុងរឿងផ្សព្វផ្សាយទៅ មានទេវបុត្រមាន
ឫទ្ធិច្រើន ប្រដាប់ហើយដោយអាភរណៈគ្រប់បែប មានពួកនាង
ទេពធីតាចោមរោមហើយ ដើរប្រទក្សិណាដោយជុំវិញ ក្នុងវិមាន
ទាំង ៧ នោះ ។

ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាល
មាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តនេះ បានធ្វើនូវកុសល
ដូចម្តេច ទើបដល់នូវស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

[ ១៨១ ] មាតលិទេពសារថី ដែលព្រះបាទនេមិសួរហើយ ក៏
ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះ
រាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តនេះ ជាគហបតីឈ្មោះ
សោណទិន្ន ជាម្ចាស់នៃទាន ( ក្នុងដែនកាសី ) គាត់បានសាងកុដិ

សម្រាប់នៅ ៧ ខ្នង ឧទ្ទិសចំពោះបព្វជិត ។ គាត់បានបម្រើភិក្ខុទាំងឡាយ ដែលអាស្រ័យនៅក្នុងកុដិនោះដោយគោរព បានប្រគេនចីវរសម្រាប់ស្លៀកដណ្ដប់ផង ភត្តាហារផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះលោកអ្នកមានចិត្តត្រង់ទាំងឡាយ ដោយចិត្តជ្រះថ្លា ។ គាត់រក្សាឧបោសថប្រកបដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយបក្ខផង គាត់ជាអ្នកសង្រួម ក្នុងសីលទាំងឡាយសព្វៗ កាលជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគាត់រីករាយក្នុងវិមាន ។

[ ១៨២ ] ( ព្រះរាជា ... ) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការនៃកែវផលិក ពាសពេញដោយពួកនារីដ៏ប្រសើរ រុងរឿងដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និងច្រៀងទាំងពីរ ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្ដីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើនារីទាំងនេះ បានធ្វើកុសលកម្មដូចម្ដេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

[ ១៨៣ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកនារីណានីមួយ ក្នុង

ជីវលោកនេះ មានសីល ជាឧបាសិកា ត្រេកអរក្នុងទាន មាន
ចិត្តជ្រះថ្លាជានិច្ច តាំងនៅក្នុងសច្ចធម៌ មិនប្រហែសធ្វេសក្នុង
ឧបោសថ ជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនារីទាំង
នោះ រីករាយក្នុងវិមាន ។

[ ១៨៤ ] ( ព្រះរាជា ... ) វិមាននេះ ដែលបុញ្ញកម្មនិម្មិត
ហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការនៃកែវពៃទូរ្យ ប្រកប
ដោយភូមិភាគ ចែកវាស់ដោយចំណែក ។ ( ក្នុងវិមាននេះ )
មានសូរសំឡេងទិព្វលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង
និងប្រគំគួរស្តាប់ ជាទីរីករាយនៃចិត្ត ។ សំឡេងដែល
ប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែល
ឃើញ ទាំងមិនដែលឮឡើយ ទើបតែបានដឹង ។ ម្នាលទេព
បម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះបានឃើញ ម្នាល
មាតលិទេវសារថី ខ្ញុំសួរអ្នក តើពួកទេវបុត្តទាំងនេះ ធ្វើ
កុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុង
វិមាន ។

[ ១៨៥ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏
ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះ
រាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា មានសីល
ជាឧបាសក ក្នុងជីវលោកនេះ បានកសាងសួនច្បារ ស្រះ អណ្តូង

ទឹក និងស្ពាន ប្រតិបត្តិព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយគោរព ព្រមទាំងបានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមាន ចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ ជនទាំងឡាយនោះ បានរក្សា ឧបោសថ ប្រកបដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយបក្ខផង សង្រួមក្នុង សីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ និងជាអ្នក ចែកទាន ទើបជនទាំងឡាយនោះ រីករាយក្នុងវិមាន ។

[ ១៨៦ ] ( ព្រះរាជា ... ) វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អ ហើយ រុងរឿងដោយជញ្ជាំង ជាវិការនៃកែវផលិក ដេរដាសដោយ ពួកនាងនារីដ៏ប្រសើរ ចម្រើនដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និងច្រៀង ទាំងពីរយ៉ាង មានស្ទឹង ប្រកបដោយរុក្ខជាតិ មានផ្កាផ្សេងៗ ហូរព័ទ្ធជុំវិញ ម្នាលទេព បម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាល មាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តនេះ បានធ្វើនូវកុសល- កម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

[ ១៨៧ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះ រាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនុ៎ះ ជាគហបតី ជា

ម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្ដូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះពួកព្រះអរហន្ត អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន ។

[ ១៨៨ ] ( ព្រះរាជា ... ) វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការនៃកែវផលិក ដេរដាសដោយពួកនារីដ៏ប្រសើរ ចម្រើនដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយការច្រៀង និងការរាំទាំងពីរយ៉ាង មានស្ទឹងប្រកបដោយឈើ មានផ្កាផ្សេងៗ ហួរព័ទ្ធជុំវិញ មានឈើទាំងឡាយជាច្រើន គឺដើមកែស ក្ទិដ្ឋ ស្វាយ សាលព្រឹក្ស ព្រីង ទន្លាប់ មាក់ប៉ែន សុទ្ធសឹងមានផ្លែជានិច្ច ។

ម្នាលទេពបម្រើ សេចក្ដីត្រេកអរ មានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្តអង្គនេះ បានធ្វើកុសលកម្មដូចម្ដេច ទើបដល់ស្ថានសួគ៌ រីករាយ

ក្នុងវិមាន ។

[ ១៨៩ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូងទឹក បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលជាអ្នកមានចិត្តត្រជាក់ដោយគោរព បានថ្វាយនូវចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា គហបតីនោះ បានទាំងរក្សាឧបោសថប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន ។

[ ១៩០ ] ( ព្រះរាជា ... ) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយដ៏រុងរឿងដោយជញ្ជាំង ជាវិការនៃកែវពៃទូរ្យ ប្រកបដោយភូមិភាគ ចែកវាស់ដោយចំណែក ( ក្នុងវិមាននោះ ) មានសូរសព្ទជាទិព្វលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំគួរស្តាប់ជាទីរីករាយនៃចិត្ត ។ សំឡេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ

ទើបតែនឹងបានដឹង ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

[ ១៩១ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងពារាណសី បានកសាងសួនច្បារ ស្រះអណ្តូងទឹក និងស្ពាន បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានបច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ ទេវបុត្តនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបទេវបុត្តនោះ រីករាយក្នុងវិមាន ។

[ ១៩២ ] ( ព្រះរាជា ... ) វិមាននេះ ជាវិការនៃមាស ដែលបុញ្ញកម្មនិម្មិតហើយ ដូចព្រះអាទិត្យទើបរះឡើង មានពណ៌ក្រហម

មានមណ្ឌលធំ ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្តអង្គនេះបានធ្វើកុសលកម្មដូចម្តេច ទើបដល់នូវស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

[ ១៩៣ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងសាវត្ថី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ ជាអ្នកមានចិត្តត្រជាក់ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា ។ គហបតីនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន ។

[ ១៩៤ ] ( ព្រះរាជា ... ) វិមានទាំងឡាយនេះ ជាវិការនៃមាសមានប្រមាណច្រើន ដែលបុញ្ញកម្មនិម្មិតហើយ តាំងនៅក្នុងអាកាស

មានពន្លឺដ៏រុងរឿង ដូចជាផ្ទៃកបន្ទោរក្នុងចន្លោះនៃមេឃ ក្នុងវិមានទាំងឡាយនោះ មានពួកទេវតាមានឫទ្ធិច្រើន សឹងប្រដាប់ដោយគ្រឿងអាភរណៈគ្រប់បែប មានពួកនាងទេពអប្សរចោមរោម ហើយប្រទក្សិណ វិលវង់ដោយជុំវិញ ។

ម្នាលទេពបម្រើ សេចក្ដីត្រេកអរ មានប្រាកដដល់ ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកទេវបុត្តទាំងនេះ បានធ្វើកុសលកម្មដូចម្ដេច ទើបដល់នូវស្ថានសួគ៌ រីករាយក្នុងវិមាន ។

[ ១៩៥ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពួកទេវបុត្តទាំងនោះ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ តាំងនៅស៊ប់ ដោយសទ្ធាក្នុងព្រះសទ្ធម្ម ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសទុកល្អហើយ បានធ្វើតាមនូវពុទ្ធវចនៈ របស់ព្រះសាស្ដា បពិត្រព្រះរាជា ស្ថានទាំងឡាយ ដែលទ្រង់ក្រឡេកឃើញហើយ គឺជាស្ថានរបស់ទេវបុត្តទាំងឡាយនោះ ។

[ ១៩៦ ] បពិត្រមហារាជ ស្ថានរបស់សត្វ អ្នកមានបាបកម្មទ្រង់បានជ្រាបហើយ ព្រោះទ្រង់ទតឃើញនូវលំនៅ ( របស់សត្វ ) ទាំងស្ថានរបស់សត្វ អ្នកមានកល្យាណកម្ម ក៏ទ្រង់ជ្រាបហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកកុសលធម៌ ឥឡូវនេះ សូមទ្រង់

យាងទៅក្នុងសម្នាក់នៃទេវរាជ ។

[ ១៩៧ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទនេមិមហារាជ ទ្រង់ស្ថិតនៅលើទិព្វយាន មានសេះជាវាហនៈ ដែលទឹមដោយសេះសិន្ធព ១ ពាន់ កាលស្ដេចកំពុងយាងទៅ ទ្រង់ក្រឡេកឃើញភ្នំទាំងឡាយក្នុងចន្លោះសីទន្តរសមុទ្ទ លុះទ្រង់ទតឃើញហើយ ទ្រង់ត្រាស់ហៅទេវសារថីសួរថា ភ្នំទាំងនោះ តើឈ្មោះអ្វីខ្លះ ។

[ ១៩៨ ] ( មាតលិ ... ) ភ្នំធំៗ ទាំងឡាយនេះ ក្នុងសមុទ្ទសីទន្តរ គឺភ្នំសុទស្សនៈ ១ ករវិក ១ ឥសិន្ធរ ១ យុគន្ធរ ១ នេមិន្ធរ ១ វិនតក ១ អស្សកណ្ណ ១ ជាភ្នំមានកំពូលខ្ពស់ឡើងតាមលំដាប់រៀងគ្នា បពិត្រមហារាជ ភ្នំដែលទ្រង់ក្រឡេកឃើញ សឹងជាលំនៅនៃមហារាជទាំងឡាយ ។

[ ១៩៩ ] ( ព្រះរាជា ... ) ( ទ្វារ ) មានរូបជាអនេក ដ៏រុងរឿងវិចិត្រ ដោយរតនវត្ថុផ្សេងៗ ដ៏ដេរដាសដោយរូបទាំងឡាយប្រហែលរូបព្រះឥន្ទ្រ បីដូចជា ( ព្រៃធំ ) ដែលពួកខ្លាធំចាំនៅហើយ ។

ម្នាលទេពបម្រើ សេចក្ដីត្រេកអរ មានដល់ខ្ញុំ ព្រោះឃើញ
ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅថាទ្វារនេះឈ្មោះ
អ្វី ទើបជាទីរីករាយនៃចិត្ត ប្រាកដអំពីចម្ងាយ ។

[ ២០០ ] មាតលិទេពសារថី ដែលព្រះបាទនេមិសួរហើយ ក៏

ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទ្វារនេះឈ្មោះចិត្តកូដ ជាទីចេញចូលនៃទេវរាជ ( ជាទ្វារនៃទេពនគរ ដែលតាំងនៅត្រង់ទីបំផុតនៃភ្នំព្រះសុមេរុ ) ជាភ្នំគួរឲ្យចង់មើលប្រាកដ ( ទ្វារនេះ ) មានរូបជាអនេក ដ៏រុងរឿង វិចិត្រដោយរតនវត្ថុផ្សេងៗ ប្រាកដជាទ្វារដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា ( ព្រៃធំ ) ដែលពួកខ្លារក្សាហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅតាមទ្វារនុ៎ះ សូមទ្រង់ជាន់នូវផែនដីទិព្វ ដ៏រាបស្មើ ។

[ ២០១ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទនេមិមហារាជ ទ្រង់ស្ថិតនៅលើទិព្វយាន មានសេះជាវាហនៈ ដែលទឹមដោយសេះសិន្ធព ១ ពាន់ ទ្រង់យាងទៅ បានទតឃើញនូវទេវសភា ( ត្រាស់សួរថា ) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដោយជញ្ជាំងជាវិការនៃកែវពៃទូរ្យ ឃើញច្បាស់ដូចអាកាស មានពន្លឺខៀវក្នុងសរទកាល ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅវិមាននុ៎ះឈ្មោះអ្វី ។

[ ២០២ ] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះ

រាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវសភា ដែលព្រះអង្គទតឃើញនុ៎ះឯង គេហៅថាសុធម្មា ( ទេវសភានុ៎ះ ) រុងរឿងដោយកែវពៃទូរ្យដ៏វិចិត្រ ដែលបុញ្ញានុភាពនិម្មិត ដោយប្រពៃតាំងនៅ សសរមានជ្រុងប្រាំបី ដែលបុញ្ញកម្មតាក់តែងល្អ សុទ្ធសឹងជាវិការនៃកែវពៃទូរ្យទាំងអស់ ពួកទេវតានៅជាន់តាវត្តិង្សគ្រប់អង្គ សឹងមានព្រះឥន្ទ្រជាប្រមុខ តែងប្រជុំគ្នា គិតគូរសេចក្តីចម្រើនរបស់ទេវតានិងមនុស្សទាំងឡាយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅកាន់ទីអនុមោទនារបស់ទេវតាទាំងឡាយ តាមទ្វារនេះ ។

[ ២០៣ ] ( អភិសម្ពុទ្ធគាថា ) ពួកទេពនិករ បានឃើញព្រះរាជានោះ ស្តេចយាងមកដល់ហើយ ត្រេកអរទទួលថា បពិត្រមហារាជដំណើរដែលព្រះអង្គយាងមកនេះ ប្រពៃហើយ មិនមែនទ្រង់យាងមកអាក្រក់ទេ បពិត្រព្រះរាជា ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរឥឡូវនេះ សូមព្រះអង្គគង់ក្នុងទីជិតនៃទេវរាជចុះ ។ សក្កទេវរាជទ្រង់ត្រេកអរទទួលព្រះបាទវិទេហៈ គ្រប់គ្រងក្រុងមិថិលានោះ ព្រះបាទវាសវៈ អញ្ជើញព្រះអង្គ ដោយកាមទាំងឡាយផង ដោយអាសនៈផងថា ព្រះអង្គស្តេចមកដល់លំនៅ នៃទេវតាទាំងឡាយជាដំណើរប្រពៃណាស់ ព្រះរាជា ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងទេវលោកទាំងឡាយ ជាទីញុំាងសេចក្តី

ប្រាថ្នាទាំងពួងឲ្យសម្រេច សូមព្រះអង្គបរិភោគកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្ស ក្នុងតាវត្តិង្សទេវលោកចុះ ។

[ ២០៤ ] ( ព្រះបាទនេមិ ... ) វត្ថុណា ដែលបានដោយអ្នកដទៃឲ្យជាបច្ច័យ ដូចជាយានជារបស់សូមគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនុ៎ះ ក៏មានឧបមេយ្យយ៉ាងនេះឯង ។ ខ្ញុំឥតចង់បានវត្ថុ ដែលបានមក ដោយអ្នកដទៃឲ្យជាបច្ច័យនោះទេ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯងនោះ ទើបជាទ្រព្យសម្រេចដល់ខ្ញុំ ។ ខ្ញុំឯង នឹងត្រឡប់ទៅធ្វើកុសល ដែលបុគ្គលធ្វើហើយ រមែងដល់សេចក្តីសុខ មិនក្តៅក្រហាយខាងក្រោយ ឲ្យមានប្រមាណច្រើន ដោយការឲ្យផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមឥន្ទ្រិយផង ដោយការទូន្មាននូវឥន្ទ្រិយផង ក្នុងពួកមនុស្ស ។

[ ២០៥ ] មាតលិជាទេវសារថី ដ៏ចម្រើន ជាអ្នកមានឧបការៈច្រើនដល់យើង ព្រោះបានបង្ហាញនូវស្ថាន នៃសត្វអ្នកមានបុញ្ញកម្ម និងស្ថាននៃសត្វ អ្នកមានបាបកម្មទាំងឡាយ ។

[ ២០៦ ] ព្រះបាទនេមិ ទ្រង់ជាឥស្សរៈក្នុងដែនវិទេហៈ គ្រប់គ្រងក្រុងមិថិលា ទ្រង់បានពោលដូច្នេះហើយ ( ទើបទ្រង់លាសក្កទេវរាជ ត្រឡប់មកមនុស្សវិញ ) ទ្រង់បានបូជាយញ្ញដ៏ច្រើន ហើយទ្រង់ចូលទៅរកការសង្រួម ( បព្វជ្ជា ) ។

**នេមិរាជជាតកទី ៤ ចប់**

# អដ្ឋកថា

## នេមិរាជជាតក

[ ១៣២-២០៦ ] *ព្រះសាស្ដា កាលគង់នៅក្នុងព្រះរាជឧទ្យានអម្ពវ័ន របស់មឃទេវរាជ ទ្រង់អាស្រ័យនគរមិថិលា ជាទីកិក្ខាចារ ទ្រង់ប្រារព្ធនូវការញញឹមឲ្យប្រាកដ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **អច្ឆេរំ វត លោកស្មឹ** *ដូច្នេះជាដើម ។*

*រឿងមានសេចក្ដីសង្ខេបដូច្នេះថា ថ្ងៃមួយ ព្រះសាស្ដា មួយអន្លើដោយភិក្ខុជាច្រើន ទ្រង់ចារិកទៅក្នុងអម្ពវ័ននោះក្នុងពេលល្ងាច ទតឃើញប្រទេសមួយជារម្មណីយដ្ឋាន ទ្រង់ប្រាថ្នានឹងត្រាស់បុព្វចរិយារបស់ព្រះអង្គ ទើបទ្រង់ញញឹម ព្រះអានន្ទត្ថេរក្រាបទូលសួរហេតុដែលទ្រង់ញញឹម ទើបទ្រង់មានព្រះពុទ្ធតម្រាស់ថា ម្នាលអានន្ទ ភូមិប្រទេសនេះតថាគតធ្លាប់អាស្រ័យនៅ ចម្រើនឈានក្នុងកាលដែលតថាគតកើតជាមឃទេវរាជ ត្រាស់ដូច្នេះហើយ ទ្រង់ក៏នៅស្ងៀម ភិក្ខុទាំងឡាយក្រាបទូលអារាធនាដើម្បីឲ្យទ្រង់សម្ដែង ទើបប្រថាប់គង់លើបវរពុទ្ធាសនៈដែលក្រាល ហើយទ្រង់នាំអតីតនិទានមកសាធកៈតទៅ*

*ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ក្នុងក្រុងមិថិលាដែនវិទេហរដ្ឋ មានក្សត្រព្រះនាមមឃទេវរាជ ទ្រង់នៅលេងជារាជកុមារអស់ ៨៤០០០ ឆ្នាំ ទ្រង់ធ្វើជាឧបរាជ ៨៤០០០ ឆ្នាំ ទ្រង់សោយរាជ្យជាព្រះរាជាធិរាជបាន ៨៤០០០ ឆ្នាំ មានព្រះរាជតម្រាស់នឹងជាងកោរកាត់ថា កាលណាអ្នកឃើញសក់ស្កូវក្នុងសីសៈរបស់យើង ចូរប្រាប់យើងក្នុងកាលនោះ ។ ក្នុងកាលតមក ភ្នាក់ងារកូសាមាលា បានឃើញព្រះកេសាស្កូវ ទើបក្រាបទូលដល់ព្រះរាជា ទ្រង់ត្រាស់*

ឲ្យជកដោយសណ្ឋាសមាសដាក់លើបាតព្រះហស្ត ទតមើលព្រះកេសា ទ្រង់ពិចារណាឃើញមរណៈ ហាក់ដូចជាមកជាប់ត្រង់ថ្ងាស មានព្រះតម្រិះថា ឥឡូវនេះ ជាកាលដែលអញនឹងបួស ទើបព្រះរាជទានស្រុកសួយដល់ជាងកោរកាត់ ហើយត្រាស់ហៅព្រះជេដ្ឋោរសមក មានព្រះតម្រាស់ថា ចូរបាគ្រងរាជសម្បត្តិ បិតានឹងចេញបួស ព្រះរាជឱរសទូលសួរដល់ហេតុដែលព្រះរាជាទ្រង់ផ្នួស កាលនឹងត្រាស់ប្រាប់ហេតុដល់ព្រះរាជឱរស ទើបត្រាស់គាថានេះថា

សក់ទាំងឡាយនេះ នាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញ
ហើយ ទេវទូត កើតប្រាកដហើយ ( នេះ ) ជាសម័យនៃ
ផ្នួសរបស់អញ ដូច្នេះ ។

កាលត្រាស់ដូច្នេះហើយ ក៏អភិសេកព្រះរាជឱរសច្បងនោះក្នុងរាជសម្បត្តិ ហើយព្រះរាជទានឱវាទថា បើបាឃើញសក់ស្កូវយ៉ាងនេះហើយ គប្បីបួស ត្រាស់ដូច្នេះហើយ ទ្រង់ចេញអំពីព្រះនគរ ទ្រង់បួសជាឥសីចម្រើនព្រហ្មវិហារ ៤ អស់ ៨៤០០០ ឆ្នាំ កើតក្នុងព្រហ្មលោក ។ ព្រះរាជឱរសរបស់ព្រះបាទមឃទេវរាជ ក៏ទ្រង់បួសដោយឧបាយនោះឯង មានព្រហ្មលោកជាទីទៅខាងមុខ ។ ក្សត្រដែលជាព្រះរាជឱរសរបស់ព្រះរាជា ជាលំដាប់លំដោយមកចំនួន ៨៣៩៩៨ អង្គ ទតឃើញសរសៃសក់ស្កូវលើសិរសាហើយ ចេញបួសក្នុងព្រះរាជឧទ្យានអម្ពវ័ននេះ ចម្រើនព្រហ្មវិហារ ៤ កើតក្នុងព្រហ្មលោក បណ្ដាស្ដេចទាំងនោះ ក្សត្រមានឈ្មោះថា មឃទេវៈ កើតក្នុងព្រហ្មលោកមុនក្សត្រ

ទាំងពួង ស្ថិតនៅក្នុងព្រហ្មលោកនោះឯងសម្លឹងមើលវង្សរបស់ព្រះអង្គ ឃើញក្សត្រ ៨៣៩៩៨ អង្គបួសហើយ ក៏មានព្រះហឫទ័យត្រេកអរ ពិចារណាថា ខាងមុខអំពីនេះ វង្សរបស់អញនឹងប្រព្រឹត្តទៅ ឬមិនប្រព្រឹត្តទៅហ្ន៎ ក៏ទ្រង់ជ្រាបថា នឹងមិនប្រព្រឹត្តទៅ ទើបទ្រង់គិតថា អញនេះឯង នឹងបន្តវង្សរបស់អញ ក៏ចុតិអំពីព្រហ្មលោក មកបដិសន្ធិក្នុងព្រះគភ៌ នៃអគ្គមហេសីរបស់ព្រះរាជា ក្នុងក្រុងមិថិលា លុះកន្លងទៅ ១០ ខែក៏ប្រសូតចាកព្រះគភ៌របស់ព្រះមាតា ព្រះរាជាត្រាស់ហៅព្រាហ្មណ៍ទាំងឡាយ ដែលចេះទស្សន៍ទាយមកសួរហេតុការណ៍ ក្នុងថ្ងៃថ្វាយព្រះនាមព្រះរាជកុមារ ព្រាហ្មណ៍ទាំងនោះពិនិត្យពិច័យមើលនូវលក្ខណៈ ហើយក្រាបទូលថា ព្រះរាជកុមារនេះ នឹងបន្តវង្សរបស់ព្រះអង្គ កើតហើយ ព្រោះថា វង្សរបស់ព្រះអង្គ ជាវង្សបព្វជិត បន្តអំពីព្រះកុមារនេះទៅខាងមុខនឹងមិនមាន ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ មានព្រះតម្រិះថា ព្រះរាជឱរសនេះ មកកើតបន្តវង្សរបស់អញ ដូចកង់រថដូច្នោះ អញនឹងថ្វាយនាមព្រះឱរសនេះថា នេមិកុមារ ទ្រង់ត្រិះរិះដូច្នេះហើយ ទើបព្រះរាជទានព្រះនាមព្រះរាជឱរសថា នេមិកុមារ ព្រះនេមិកុមារនោះ ជាអ្នកត្រេកអរក្នុងការឲ្យទាន រក្សាសីល និងឧបោសថកម្ម តាំងពីនៅក្មេង ។ គ្រានោះ ព្រះរាជាដែលជាព្រះជនករបស់នេមិរាជកុមារ ទតឃើញសរសៃសក់លើព្រះសិរសាស្កូវ ក៏ព្រះរាជទានស្រុកសួយដល់ភ្នាក់ងារកូសាមាលា រួចប្រគល់រាជសម្បត្តិដល់ព្រះរាជឱរស ទ្រង់បួសក្នុងព្រះរាជឧទ្យានអម្ពវ័ននោះឯង ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ដោយន័យខាងដើមនោះឯង ។

ចំណែកព្រះបាទនេមិរាជ ទ្រង់ឲ្យសាងសាលាទាន ៥ កន្លែង គឺត្រង់ទ្វារនគរ ៤ កន្លែង ត្រង់កណ្ដាលនគរមួយកន្លែង ញុំាងមហាទានឲ្យប្រព្រឹត្តទៅដោយភាពជាអ្នកមានអធ្យាស្រ័យក្នុងទាន ព្រះរាជទានទ្រព្យត្រង់រោងទានមួយកន្លែង ១ សែន ទ្រង់បរិច្ចាគទ្រព្យមួយថ្ងៃ ៥ សែនកហាបណៈរាល់ៗថ្ងៃ ទ្រទ្រង់នូវបញ្ចសីលជានិច្ច ទ្រង់សមាទានឧបោសថរាល់បក្ខ ហើយទ្រង់ដឹកនាំមហាជនក្នុងការបំពេញបុណ្យ មានឲ្យទានជាដើម ទ្រង់សម្ដែងធម៌ទូន្មានឲ្យជ្រាបផ្លូវសួគ៌ គំរាមមហាជនឲ្យខ្លាចនរក ប្រជុំជនតាំងនៅក្នុងឱវាទរបស់ព្រះអង្គ បំពេញបុណ្យ មានឲ្យទានជាដើម ចុតិចាកអត្តភាពនោះហើយកើតក្នុងទេវលោក ទេវលោកក៏ពេញ នរកហាក់ដូចទទេ ។ កាលនោះ ពួកទេវតាក្នុងតាវត្តិង្សពិភព ប្រជុំគ្នាក្នុងទេវស្ថានឈ្មោះសុធម្មា ពោលសរសើរគុណរបស់មហាសត្វថា ឱព្រះបាទនេមិរាជ ជាអាចារ្យរបស់ពួកយើង ពួកយើងទាំងឡាយ អាស្រ័យទ្រង់ ទើបបានសោយទិព្វសម្បត្តិបែបនេះ សូម្បីពុទ្ធញាណក៏មិនបានកំណត់ សូម្បីក្នុងមនុស្សលោក មហាជនក៏សរសើរគុណរបស់ព្រះមហាសត្វ គុណកថាផ្សាយទូទៅ ដូចប្រេងដែលនៅលើផ្ទៃមហាសមុទ្រ ដូច្នោះ ។

ព្រះសាស្ដា កាលត្រាស់ដល់ភិក្ខុសង្ឃ ទ្រង់ធ្វើសេចក្ដីនោះឲ្យជាក់ច្បាស់ ទើបត្រាស់ថា

ក្នុងកាលដែលព្រះបាទនេមិជាបណ្ឌិត អ្នកត្រូវការដោយកុសល
ជាព្រះរាជាអ្នកទូន្មាននូវសត្រូវ ទ្រង់តែងឲ្យទាន ដល់ជនអ្នកនៅ

ក្នុងដែនវិទេហៈទាំងឡាយគ្រប់គ្នា គ្រានោះ ( មនុស្ស និងទេវតា ទាំងឡាយ តែងសរសើរថា ) ឱ អស្ចារ្យណាស់ អ្នកប្រាជ្ញ ទាំងឡាយ មានប្រាជ្ញាជាគ្រឿងពិចារណា កើតឡើងក្នុងលោក ហើយ ។ កាលព្រះរាជាអង្គនោះ ទ្រង់ឲ្យទាននោះ សេចក្តីត្រិះរិះ កើតឡើងថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាហ្ន៎ មានផល ច្រើនជាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទា អហុ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលណាព្រះបាទនេមិរាជជាបណ្ឌិត មានព្រះបំណងដោយកុសល ដើម្បីព្រះ អង្គផង ដើម្បីមហាជនផង កាលនោះ ទេវតា និងមនុស្សទាំងឡាយបាន ពោលគុណរបស់ព្រះបាទនេមិរាជនោះយ៉ាងនេះថា គួរអស្ចារ្យហ្ន៎ ដែលព្រះ ពុទ្ធញាណមិនទាន់កើតឡើង ក៏មានបុគ្គលឈ្លាសវៃ អាចញ៉ាំងពុទ្ធកិច្ចឲ្យ សម្រេចដល់មហាជនបែបនេះ កើតឡើងក្នុងលោក ។ បាឋៈថា **យថា អហុ** ដូច្នេះក៏មាន បាឋៈនោះ មានសេចក្តីថា ព្រះបាទនេមិរាជជាបណ្ឌិត មាន បំណងដោយកុសលប៉ុណ្ណោះ យ៉ាងណា បុគ្គលឈ្លាសវៃទាំងឡាយក៏ដូច្នោះ រមែងកើតឡើង ញ៉ាំងពុទ្ធកិច្ចឲ្យសម្រេចដល់មហាជន ការកើតឡើងរបស់ បុគ្គលឈ្លាសវៃទាំងនោះ គួរអស្ចារ្យក្នុងលោកហ្ន៎ ។ ព្រះសាស្តា ទ្រង់កើត អស្ចារ្យឯង ទើបត្រាស់យ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **សព្វ-វិទេហានំ** បានដល់ អ្នកវិទេហរដ្ឋទាំងពួង ។ បទថា **កតមំ សុ** សេចក្តីថា ទាន និងព្រហ្មចរិយៈពីរយ៉ាងនេះ មួយណាមានផលច្រើនហ្ន៎ ។

បានឮថា ស្តេចនេមិរាជនោះ ទ្រង់សមាទានឧបោសថសីលក្នុងថ្ងៃឧបោសថទី ១៥ ទ្រង់ដោះរាជាករណៈទាំងពួង ផ្ទំលើព្រះទែនដ៏មានសិរី ឈានចុះកាន់និទ្រាអស់ ២ យាម ភ្ញាក់ពីបន្ទំក្នុងបច្ឆិមយាម ទ្រង់គង់ពត់ភ្នែនត្រិះរិះថា អញឲ្យទានមិនមានប្រមាណដល់ប្រជុំជន និងរក្សាសីល ផលនៃទានមានច្រើន ឬផលនៃព្រហ្មចរិយវាស មានផលច្រើនជាងហ្ន៎ ទ្រង់ត្រិះរិះដូច្នោះក៏មិនអាចកាត់សេចក្តីសង្ស័យទ្រង់បាន ។

ខណៈនោះ ពិភពនៃសក្កទេវរាជ ក៏សម្តែងអាការក្តៅ សក្កទេវរាជទ្រង់អាវជ្ជនាការហេតុនោះ ទ្រង់ក៏ឃើញព្រះបាទនេមិរាជ កំពុងបរិវិតក្កយ៉ាងនោះ ទើបគិតថា អញនឹងកាត់សេចក្តីសង្ស័យរបស់ព្រះរាជា ទើបយាងមកដោយរួសរាន់តែមួយព្រះអង្គឯង ធ្វើសកលរាជនិវេសន៍ ឲ្យមានរស្មីឱភាសដូចគ្នាតែមួយ ចូលកាន់ទីបន្ទំដ៏មានសិរី ផ្សាយរស្មីស្ថិតនៅក្នុងអាកាស ទ្រង់ព្យាករណ៍បញ្ហា ដែលព្រះបាទនេមិរាជត្រាស់សួរ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

> ទេវរាជឈ្មោះមឃវៈ ជាទេវកុញ្ជរ ជាសហស្សនេត្រ បានជ្រាបព្រះតម្រិះរបស់ព្រះរាជានោះ ហើយមកប្រាកដ ( ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ) កម្ចាត់បង់នូវងងឹតដោយវណ្ណៈ ។ ព្រះបាទនេមិរាជ ជាធំជាងមនុស្ស ទ្រង់ព្រឺព្រះលោមា បានសួរទេវរាជ

ឈ្មោះវាសវៈថា អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាសក្កបុរិន្ទទៈ ។ រស្មីប្រាកដដូច្នោះ ខ្ញុំពុំដែលឃើញ ទាំងមិនធ្លាប់ឮឡើយ បពិត្រអ្នកដ៏ចម្រើន អ្នកចូរប្រាប់ខ្ញុំ ធ្វើម្តេចយើងស្គាល់អ្នកបាន ។ ទេវរាជឈ្មោះវាសវៈជ្រាបថា ព្រះបាទនេមិ ព្រឺព្រះលោមាហើយ ទើបឆ្លើយថា ខ្ញុំជាព្រះឥន្ទ ជាធំជាងទេវតាមកកាន់សម្នាក់ព្រះអង្គ បពិត្រព្រះអង្គជាធំជាមនុស្ស ទ្រង់កុំព្រឺព្រះលោមាឡើយ ព្រះអង្គមានសេចក្តីប្រាថ្នាដើម្បីសួរនូវប្រស្នាណា សូមទ្រង់សួរចុះ ។ ចំណែកព្រះបាទនេមិរាជអង្គនោះ លុះព្រះឥន្ទ្រាធិរាជ ធ្វើឱកាសហើយ ក៏ទ្រង់ត្រាស់សួរនូវទេវរាជឈ្មោះវាសវៈថា បពិត្រទេវរាជជាឥស្សរៈជាងសព្វសត្វទាំងឡាយ ខ្ញុំសូមសួរព្រះអង្គថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាមានផលច្រើនជាង ។ ព្រះវាសវៈនោះ ដែលព្រះបាទនេមិ ជានរទេពសួរហើយ ក៏ឆ្លើយតបព្រះបាទនេមិវិញ ព្រះវាសវៈនោះប្រាប់នូវផលនៃព្រហ្មចរិយៈ បានទូលព្រះបាទនេមិដែលមិនជ្រាបថា បុគ្គលកើតក្នុងត្រកូលក្សត្រដោយព្រហ្មចរិយៈថោកទាប ដល់នូវភាពជាទេវតាដោយព្រហ្មចរិយៈជាកណ្តាល បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់ ។ ពួកអ្នកបួសប្រព្រឹត្តតបៈទាំងឡាយ ទៅកើតក្នុងពួក ព្រហ្មណាពួកព្រហ្មទាំងនុ៎ះ បុគ្គលអ្នកប្រកបក្នុងការសូម ណាមួយមិនងាយបានសោះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សលោមហដ្ឋោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទនេមិរាជនោះទតឃើញពន្លឺ ទើបទ្រង់សម្លឹងទៅក្នុងអាកាស ទតឃើញសក្កទេវរាជនោះ ប្រដាប់ដោយទិព្វាភរណៈ មានព្រះលោមជាតិព្រឺព្រោះភ័យខ្លាច ទើបត្រាស់ថា អ្នកជាទេវតាឬ ដូច្នេះជាដើម ។ បទថា **អលោមហដ្ឋោ** សេចក្តីថា ទ្រង់កុំខ្លាច ទ្រង់កុំមានព្រះលោមជាតិព្រឺឡើយ សូមសួរចុះ មហារាជ ។ បទថា **វាសវំ អវចា** សេចក្តីថា ទ្រង់មានព្រះហឫទ័យត្រេកអរ បានត្រាស់ហើយ ។ បទថា **ជានំ អក្ខាសិជានតោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជនោះ ទ្រង់ជ្រាបវិបាកនៃព្រហ្មចរិយៈដែលទ្រង់ឃើញ ប្រចក្សដោយព្រះអង្គឯងក្នុងអតីតភព ទើបត្រាស់ប្រាប់ដល់ស្តេចនេមិរាជ ដែលទ្រង់មិនដឹង ។

ក្នុងបទថា **ហីនេន** ជាដើម មានវិនិច្ឆ័យថា ក្នុងលទ្ធិតិរ្ថិយដោយច្រើន សីលត្រឹមតែជាមេថុនវិរតិ ឈ្មោះថា ព្រហ្មចរិយៈយ៉ាងទាប អ្នកបំពេញរមែងកើតក្នុងខត្តិយត្រកូលដោយព្រហ្មចរិយៈយ៉ាងទាបនោះ ការបានឧបចារ-ឈាន ឈ្មោះថា ព្រហ្មចរិយៈជាកណ្តាល អ្នកបំពេញរមែងកើតជាទេវតាដោយព្រហ្មចរិយៈជាកណ្តាលនោះ ការឲ្យសមាបត្តិ ៨ កើត ឈ្មោះថា ព្រហ្មចរិយៈយ៉ាងខ្ពស់ អ្នកបំពេញ រមែងកើតក្នុងព្រហ្មលោកដោយព្រហ្ម-ចរិយៈយ៉ាងខ្ពស់នោះ ជនខាងក្រៅពុទ្ធសាសនា ពោលព្រហ្មចរិយៈយ៉ាងខ្ពស់នោះ ថាជានិព្វាន អ្នកបំពេញ រមែងបរិសុទ្ធដោយព្រហ្មចរិយៈនោះ ។

ក្នុងព្រះពុទ្ធសាសនានេះ ភិក្ខុអ្នកមានសីលបរិសុទ្ធ ប្រាថ្នាទេវនិកាយ

ណាមួយ ព្រហ្មចរិយៈរបស់ភិក្ខុនោះឈ្មោះថាទាប ព្រោះចេតនាទាប លោករមែងកើតក្នុងទេវលោកតាមផលដែលលោកប្រាថ្នានោះ ការដែលភិក្ខុមានសីលបរិសុទ្ធ ញុំាងសមាបត្តិ ៨ ឲ្យកើត ឈ្មោះថាព្រហ្មចរិយៈយ៉ាងកណ្ដាល លោករមែងកើតក្នុងព្រហ្មលោក ដោយព្រហ្មចរិយៈយ៉ាងកណ្ដាលនោះ កាលដែលភិក្ខុមានសីលបរិសុទ្ធ ចម្រើនវិបស្សនា ញុំាងអរហត្តមគ្គឲ្យកើត ឈ្មោះថាព្រហ្មចរិយៈយ៉ាងខ្ពស់ លោករមែងបរិសុទ្ធដោយព្រហ្មចរិយៈដ៏ឧត្តមនោះ ។

បទថា **កាយា** បានដល់ ពួកព្រហ្ម ។ បទថា **យាចយោគេន** បានដល់ ដោយការសំណូមពរ ឬដោយការអង្វរ អធិប្បាយថា ដោយប្រកបការបូជាយញ្ញ បទនេះ ជាឈ្មោះរបស់បុគ្គលអ្នកឲ្យនោះឯង សូម្បីដោយប្រការទាំងពីរ ។ បទថា **តបស្សិនោ** បានដល់ ជាអ្នកអាស្រ័យតបធម៌ ។

សក្កទេវរាជត្រាស់សរសើរថា បពិត្រមហារាជ ការប្រព្រឹត្តព្រហ្មចរិយៈមានគុណ មានផលច្រើនជាងទានរយដង ពាន់ដង សែនដង ដោយប្រការដូច្នេះ កាលទ្រង់សម្ដែងការនៅដោយព្រហ្មចរិយៈ ជាគុណមានផលច្រើនដោយគាថាទាំងនេះហើយ ឥឡូវនេះ ទ្រង់នឹងសម្ដែងព្រះរាជាទាំងឡាយក្នុងអតីតដែលបរិច្ចាគទានហើយ មិនអាចឈានចុះកាន់កាមាវចរបាន ទើបត្រាស់ថា

ព្រះបាទទុទីបៈ ១ ព្រះបាទសាគរៈ ១ ព្រះបាទសេលៈ ១ ព្រះបាទមុចលិន្ទ ១ ព្រះបាទភគីរសៈ ១ ព្រះបាទឧសិន្នរៈ ១ ព្រះបាទអដ្ឋកៈ ១ ព្រះបាទអស្សកៈ ១ ព្រះបាទបុថុជ្ជនៈ ១ ។ ព្រះរាជាទាំងឡាយអន្តនេះក្តី ព្រះរាជាទាំងឡាយដទៃក្តី ពួកក្សត្រ

ពួកព្រាហ្មណ៍ជាច្រើនក្តី ដែលបូជានូវគ្រឿងយញ្ញយ៉ាងច្រើន មិន
ប្រព្រឹត្តកន្លងនូវបេតភាព ( កាមាវចរភូមិ ) ឡើយ ដូច្នេះ ។

គាថានោះមានអត្ថថា នៃមហារាជ ព្រះរាជាព្រះនាមថា ទុទីបរាជក្នុងក្រុងពារាណសីក្នុងកាលមុន ទ្រង់បរិច្ចាគទានច្រើនសោយទិវង្គតហើយ កើតក្នុងស្ថានសួគ៌ជាន់កាមាវចរនោះឯង ព្រះរាជា ៨ អង្គ មានព្រះបាទសាគររាជជាដើមក៏ដូចគ្នា ឯព្រះរាជាដែលជាមហាក្សត្រ និងព្រាហ្មណ៍ដទៃៗ ទាំងនេះជាច្រើន បានបូជាយញ្ញដ៏ច្រើន បរិច្ចាគទានមានប្រការមិនមែនតិច ក៏មិនកន្លងផុតនូវការលះលោកនេះ ពោល គឺកាមាវចរភូមិទៅបាន ពិតហើយ ពួកទេវតាជាន់កាមាវចរ ហៅថា បេតៈ ព្រោះសម្រេចទៅបាន ដោយអាស្រ័យអ្នកដទៃ ព្រោះហេតុនៃកិលេសវត្ថុ មានរូបជាដើម ទើបទ្រង់ត្រាស់ថា

ជនទាំងឡាយណា មិនមានគូ ជាបុគ្គលម្នាក់ឯង រមែងមិន
ត្រេកអរ ( ត្រេកអរតែក្នុងការនៅប្រឡូកប្រឡំដោយពួក ) ជន
ទាំងឡាយណា មិនមានបីតិ ដែលកើតអំពីវិវេកទេ ជនទាំង
ឡាយនោះ ទុកជាមានភោគៈ ស្មើដោយព្រះឥន្ទ ក៏ដោយចុះ ជន
ទាំងឡាយនោះ ក៏ឈ្មោះថា ជាបុគ្គលកម្សត់ មានសេចក្តីសុខ
ព្រោះកិរិយាអាស្រ័យនូវបុគ្គលដទៃដោយពិត ដូច្នេះ ។

សក្កទេវរាជទ្រង់សម្តែងភាពដែលផលនៃព្រហ្មចរិយៈនោះឯង ជារបស់ច្រើនជាងផលនៃទានយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងតាបសអ្នកឈានកន្លងនូវបេតភព ដោយការនៅប្រព្រឹត្តព្រហ្មចរិយៈកើតក្នុងព្រហ្ម-

លោក ទើបត្រាស់ថា

ឥសី ៧ អង្គនេះ គឺឥសីឈ្មោះយាមហនុ ១ សោមយាគៈ ១ មនោជវៈ ១ សមុទ្ទៈ ១ មាឃៈ ១ ភរតៈ ១ ឥសីឈ្មោះ កាលបុរក្ខិតៈ ១ និងឥសីទាំងឡាយ ៤ អង្គ គឺឥសីឈ្មោះ អង្គីរសៈ ១ កស្សបៈ ១ កីសវច្ឆៈ ១ អកត្តិ ១ ជាអនាគារ- បុគ្គលមានតបធម៌បានកន្លង ( កាមាវចរភូមិ ) ដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតិវត្តឹសុ** បានដល់ ឈានកន្លងកាមា- វចរភព ។ បទថា **តបស្សិនោ** សេចក្តីថា អាស្រ័យតបៈ គឺសីល និងតបៈ គឺសមាបត្តិ ៨ ។ បទថា **សត្តិសយោ** លោកពោលសំដៅយកឥសីជាបងប្អូន នឹងគ្នា ៧ នាក់ មានយាមហនុជាដើម ឥសីទាំងនេះ និងឥសី ៤ នាក់ មានអង្គីរសឥសីជាដើម រួមជា ១១ នាក់ ។

សក្កទេវរាជត្រាស់សរសើរព្រហ្មចរិយវាសៈ ថាមានផលច្រើន តាម ដែលបានស្តាប់មកយ៉ាងនេះជាបឋម ឥឡូវនេះ កាលទ្រង់នាំរឿងដែលធ្លាប់ ឃើញ ដោយព្រះអង្គឯងមក ទើបត្រាស់ថា

នៅប្រទេសហិមវន្តខាងជើង មានស្ទឹងឈ្មោះសីទា មានជម្រៅ ដ៏ជ្រៅ អ្នកផងធ្លងបានដោយកម្រ ( ទាំងពីរខាងច្នេរស្ទឹងនោះ ) មានភ្នំមាស ពណ៌ដូចភ្លើងខៀវ រុងរឿងសព្វៗ កាល ។ ( ទៀប ច្នេរនៃស្ទឹងនោះ ) សឹងមានដើមក្រស្នា លូតលាស់ទន្ទឹមទន្ទោល មានទាំងរុក្ខជាតិផ្សេងៗ មានគុម្ពលូតលាស់ ( អំពីជើងបពិត )

ក្នុងកាលមុន មានពួកឥសីចាស់ៗ មួយម៉ឺនអង្គ នៅក្នុងទីនោះ ឯង ។ ខ្ញុំជាបុគ្គលប្រសើរដោយការឲ្យ និងការប្រព្រឹត្តវត្ត ដោយការសង្រួម និងការទូន្មាន ( នូវឥន្ទ្រិយ ) ហើយប្រព្រឹត្ត ( ម្នាក់ឯង ) លះបង់ ( ពួក ) ជាអ្នកមានចិត្តតាំងមាំ ។ ខ្ញុំមិនរិះគន់នូវជនអ្នកមានជាតិទាប និងមានជាតិខ្ពស់ នមស្ការចំពោះជនអ្នកមានចិត្តត្រង់ មិនមានកំណត់កាលវេលាឡើយ ព្រោះថា សត្វទាំងឡាយ មានកម្មជាផៅពង្ស ។ វណ្ណៈទាំងអស់ អ្នកមិនតាំងនៅក្នុងធម៌ រមែងធ្លាក់ចុះក្នុងនរកជាខាងក្រោម វណ្ណៈទាំងអស់បានប្រព្រឹត្តធម៌ដ៏ឧត្តមហើយ រមែងបរិសុទ្ធ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្តរេន** សេចក្តីថា នែមហារាជ ក្នុងអតីតកាល មានស្ទឹងឈ្មោះសីទា ហូរមករវាងសុវណ្ណបព៌តទាំងពីរ ក្នុងហិមវន្តប្បទេស ដោយទិសឧត្តរ ជាស្ទឹងជ្រៅ យាន មានទូកជាដើមឆ្លងបានលំបាក ព្រោះហេតុអ្វី ព្រោះស្ទឹងនោះមានទឹកល្អិតក្រៃលែង ( ទឹកឥតសរសៃ ) សូម្បីតែអង្កាំកន្ទុយក្ងោក ធ្លាក់ក្នុងទឹកនោះ ក៏មិនអណ្តែត លិចចុះដល់បាតដីនោះឯង ព្រោះជាទឹកល្អិត ដោយហេតុនោះឯង ទើបទឹកស្ទឹងនេះមានឈ្មោះថា **សីទា** ឯកញ្ចនបព៌តនោះ នៅជិតឆ្នេរស្ទឹងនោះ ដែលមានពណ៌ដូចភ្លើងឆេះដើមបបុស គឺរុងរឿងសព្វកាល ។ បទថា **បរុឡ្ហកច្ឆា តគ្គរា** សេចក្តីថា ឆ្នេរស្ទឹងនោះមានដើមក្រស្នា ស្អាត ជាក្រស្នាមានក្លិនក្រអូប ។ បទថា **បរុឡ្ហកច្ឆា វនា នគា** សេចក្តីថា ព្រៃផ្សេងៗ ក្នុងទីនោះ ដុះលូតលាស់

ដោយពួកឈើ អធិប្បាយថា គ្របដណ្ដប់ទៅដោយព្រឹក្សជាតិ ដែលមានផ្កានិងផ្លែ ។ បទថា **តត្រាសុំ** សេចក្ដីថា មានឥសី ១ ម៉ឺន អាស្រ័យនៅក្នុងភូមិភាគដែលគួរត្រេកអរនោះ លោកទាំងនោះ សុទ្ធតែបានអភិញ្ញា ៥ សមាបត្តិ ៨ បណ្ដាឥសីទាំងនោះ លុះដល់ពេលភិក្ខាចារ ពួកខ្លះ ទៅឧត្តរកុរុទ្វីប ពួកខ្លះ ទៅនាំផ្លែមហាជម្ពូមក ពួកខ្លះ នាំផ្លែតូចធំដែលមានរសផ្អែម ក្នុងហិមវន្តប្បទេសមកឆាន់ ពួកខ្លះ ទៅកាន់នគរនោះៗ ក្នុងផ្ទៃជម្ពូទ្វីប ឥសីសូម្បីតែម្នាក់ ដែលត្រូវតណ្ហាក្នុងរសគ្របសង្កត់ក៏មិនមាន ឥសីទាំងនោះ ញុំាងកាលវេលាឲ្យកន្លងទៅដោយសុខក្នុងឈានប៉ុណ្ណោះ ។

ក្នុងកាលនោះ មានតាបសមួយរូបមកកាន់នគរពារាណសីតាមអាកាស ស្លៀកដណ្ដប់រៀបរយ ត្រាច់បិណ្ឌបាតដល់ទ្វារផ្ទះរបស់បុរោហិតៗ នោះជ្រះថ្លាក្នុងសេចក្ដីស្ងប់របស់លោក នាំលោកមកកាន់លំនៅរបស់ខ្លួន ឲ្យឆាន់ហើយ បដិបត្តិ ២-៣ ថ្ងៃ កាលកើតនូវការស្និទ្ធស្នាល ទើបសួរថា លោកម្ចាស់នៅឯណា លោកឆ្លើយថា នៅក្នុងទីឈ្មោះនោះ បុរោហិតសួរថា លោកម្ចាស់នៅទីនោះមួយអង្គឯង ឬឥសីដទៃៗ មានដែរ លោកឆ្លើយថា អ្នកនិយាយអ្វី ឥសីរាប់ម៉ឺននៅក្នុងទីនោះ សុទ្ធតែជាអ្នកបានអភិញ្ញា ៥ សមាបត្តិ ៨ ទាំងអស់ បុរោហិតបានស្ដាប់គុណរបស់ឥសីទាំងនោះ អំពីតាបសរូបនោះ ចិត្តក៏បង្អោនទៅក្នុងបព្វជ្ជា ទើបពោលនឹងតាបសនោះថា សូមលោកម្ចាស់មេត្តានាំខ្ញុំទៅបួសក្នុងទីនោះចុះ ឥសីពោលថា អ្នកជារាជបុរស អាត្មាមិនអាចឲ្យបួសបានទេ បុរោហិតក៏ពោលថា បើយ៉ាងនោះ ថ្ងៃនេះ ខ្ញុំនឹងទូលលា

ព្រះរាជា ស្អែកនេះ សូមលោកម្ចាស់មកទីនេះ តាបសទទួលពាក្យហើយ ។ ចំណែកបុរោហិត បរិភោគអាហារព្រឹកហើយ ចូលគាល់ព្រះរាជា ក្រាបទូលថា ទូលបង្គំប្រាថ្នានឹងបួស ព្រះរាជាត្រាស់សួរថា លោកអាចារ្យនឹងបួសដោយហេតុអ្វី បុរោហិតក្រាបទូលថា ដោយឃើញទោសក្នុងកាមទាំងឡាយ ឃើញនូវអានិសង្សក្នុងនេក្ខម្មៈ ព្រះរាជាទ្រង់អនុញ្ញាតថា បើដូច្នោះ ចូរអ្នកបួសចុះ សូម្បីបួសហើយ ក៏ចូរមកសួរសុខទុក្ខយើងខ្លះ បុរោហិតទទួលព្រះរាជឱង្ការហើយ ថ្វាយបង្គំត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន ផ្តាំផ្ញើបុត្រកិរិយា ប្រគល់សម្បត្តិទាំងពួង កាន់យកបព្វជិតបរិក្ខារដើម្បីខ្លួន អង្គុយរង់ចាំតាបសមក ចំណែកតាបសមកតាមអាកាស ចូលខាងក្នុងព្រះនគរ ហើយមកកាន់ផ្ទះបុរោហិតៗ នោះ បានអង្គាសតាបសនោះដោយគោរព ហើយប្រាប់ថា ខ្ញុំគប្បីបដិបត្តិដូចម្តេច តាបសនោះនាំបុរោហិតទៅក្រៅនគរ យកដៃចាប់នាំទៅកាន់លំនៅរបស់ខ្លួន ដោយអានុភាពរបស់ខ្លួន ឲ្យបួសហើយ ។ ស្អែកឡើងឲ្យព្រាហ្មណ៍ដែលបួសហើយ ស្នាក់នៅក្នុងទីនោះ នាំភត្តាហារមកឲ្យបរិភោគ ហើយប្រាប់កសិណបរិកម្ម តាបសដែលបួសថ្មីនោះ ធ្វើអភិញ្ញា និងសមាបត្តិ ៨ ឲ្យកើតដោយថ្ងៃកន្លងទៅបន្តិចបន្តួច ក៏ត្រាច់បិណ្ឌបាតមកឆាន់បានខ្លួនឯង ។

ក្នុងកាលតមក តាបសនោះគិតថា អញបានថ្វាយបដិញ្ញាដើម្បីទៅគាល់ព្រះរាជា អញនឹងទៅតាមពាក្យបដិញ្ញា ទើបថ្វាយបង្គំតាបសទាំងឡាយ ទៅកាន់ក្រុងពារាណសីតាមអាកាស ត្រាច់បិណ្ឌបាត លុះដល់ទ្វារព្រះរាជវាំង ព្រះបាទពារាណសីទតឃើញឥសីនោះ ទ្រង់ចាំបាន និមន្តឲ្យចូលកាន់ព្រះរាជ-

និវេសន៍ ទ្រង់ធ្វើសក្ការៈហើយ ត្រាស់សួរថា លោកម្ចាស់នៅឯណា ឥសីទូលតបថា អាត្មានៅត្រង់ប្រាំងស្ទឹងសីទា ក្នុងចន្លោះកញ្ចនបព៌ត ក្នុងហិមវន្តប្បទេស ទាទិសខាងជើង ព្រះរាជាត្រាស់សួរថា លោកម្ចាស់នៅក្នុងទីនោះមួយអង្គឯង ឬមានតាបសដទៃៗ នៅក្នុងទីនោះដែរ ឥសីនោះទូលថា ទ្រង់ត្រាស់អ្វី តាបសរាប់ម៉ឺនរូបនៅក្នុងទីនោះ ហើយលោកទាំងនោះ សុទ្ធតែបានអភិញ្ញា ៥ និងសមាបត្តិ ៨ ទាំងអស់ ព្រះរាជាទ្រង់ស្តាប់គុណសម្បត្តិនៃតាបសទាំងនោះ បំណាងនឹងថ្វាយភិក្ខាដល់តាបសទាំងនោះ ទើបត្រាស់នឹងតាបសទាំងនោះថា ខ្ញុំប្រាថ្នានឹងថ្វាយភិក្ខាដល់ឥសីទាំងនោះ សូមលោកម្ចាស់នាំលោកទាំងនោះមកក្នុងទីនេះ តាបសទូលថា ឥសីទាំងនោះមិនត្រេកអរក្នុងរសដែលគប្បីដឹងដោយអណ្តាត អាត្មាមិនអាចនាំមកក្នុងទីនេះបានឡើយ ព្រះបាទពារាណសីត្រាស់ថា ខ្ញុំអាស្រ័យលោកម្ចាស់ ឲ្យឥសីទាំងនោះបរិភោគ សូមលោកម្ចាស់ប្រាប់ឧបាយដល់ខ្ញុំ តាបសទូលថា បើទ្រង់បំណាងថ្វាយទានដល់ឥសីទាំងនោះ សូមទ្រង់ចេញអំពីនគរនេះ ទៅស្នាក់នៅត្រង់ឆ្នេរស្ទឹងសីទា ហើយទ្រង់ថ្វាយទានដល់លោកទាំងនោះ ព្រះរាជាទទួលពាក្យ ឲ្យគេកាន់ឧបករណ៍ទាំងពួង យាងចេញអំពីព្រះនគរ មួយអន្លើដោយចតុរង្គសេនាដល់ទីបំផុតនៃអាណាខេត្តរបស់ព្រះអង្គ ។ លំដាប់នោះ ទើបតាបសនាំព្រះរាជាទៅត្រង់ប្រាំងសីទានទី មួយអន្លើដោយសេនា ដោយអានុភាពរបស់ខ្លួនបានបោះជំរំត្រង់ឆ្នេរស្ទឹង តឿនព្រះរាជាមិនឲ្យប្រមាទ ហើយហោះទៅកាន់លំនៅរបស់ខ្លួន ត្រឡប់មកក្នុងថ្ងៃស្អែក ។ លំដាប់នោះ ព្រះរាជាបានឲ្យតាបស

ទាំងនោះឆាន់ដោយគោរព ហើយត្រាស់ថា ស្អែកនេះ សូមលោកម្ចាស់ទាំង ១ ម៉ឺនរូបនិមន្តមកក្នុងទីនេះ តាបសនោះ ទទួលព្រះរាជតម្រាស់ហើយ ត្រឡប់ទៅ ស្អែកឡើង ក្នុងពេលភិក្ខាចារ ប្រាប់ដល់ឥសីទាំងឡាយថា លោកនិរទុក្ខ ស្តេចពារាណសី មានបំណងចង់ប្រគេនភិក្ខាដល់លោកទាំងឡាយ ទ្រង់យាងមកប្រថាប់ទៀបឆ្នេរស្ទឹងសីទានទី ទ្រង់អារាធនាលោកទាំងឡាយ សូមលោកទាំងឡាយទៅកាន់ជំរំព្រះរាជា ដើម្បីទទួលភិក្ខាដោយអនុគ្រោះ ឥសីទាំងនោះទទួលពាក្យ ទើបហោះមកចុះក្បែរព្រះពន្លារបស់ព្រះរាជា ។ លំដាប់នោះ ព្រះរាជារាក់ទាក់ពួកឥសីទាំងនោះ ហើយអារាធនាឲ្យចូលក្នុងជំរំ និមន្តឲ្យគង់លើអាសនៈដែលបានរៀបចំ អង្គាសពួកឥសីឲ្យឆ្អែតស្កប់ស្កល់ ដោយអាហារដ៏ប្រណីត ទ្រង់ជ្រះថ្លាក្នុងឥរិយាបថរបស់ឥសីទាំងនោះ ទើបនិមន្តឲ្យឆាន់ក្នុងថ្ងៃស្អែកទៀត បានថ្វាយទានដល់តាបស ១ ម៉ឺនរូបដោយឧបាយនេះអស់ ១ ម៉ឺនឆ្នាំ កាលទ្រង់ថ្វាយ បានឲ្យគេសាងនគរក្នុងទីនោះឯង ឲ្យធ្វើនូវកសិកម្ម ។ បពិត្រមហារាជ ស្តេចពារាណសីក្នុងកាលនោះ មិនគឺអ្នកឯណា គឺខ្ញុំនេះឯង ខ្ញុំជាបុគ្គលប្រសើរដោយទានក្នុងកាលនោះដោយពិត ព្រោះថា កាលនោះ ខ្ញុំនេះឯង ជាអ្នកប្រសើរដោយទាន បានបរិច្ចាគទាននោះ ក៏មិនអាចឈានកន្លងនូវបេតលោកនេះ កើតក្នុងព្រហ្ម-លោកបានឡើយ តែឥសីទាំងនោះ បរិភោគទានដែលខ្ញុំបរិច្ចាគ ឈានកន្លងកាមាវចរភព កើតក្នុងព្រហ្មលោក ព្រហ្មចរិយវាស ជាគុណជាតិមានផលា-និសង្សច្រើនយ៉ាងណា សូមទ្រង់ជ្រាបយ៉ាងនោះ ដោយឧទាហរណ៍ដែល

សម្តែងមកហើយនេះ ។ សក្កទេវរាជប្រកាសភាពដែលទ្រង់ជាអ្នកប្រសើរ ដោយទានយ៉ាងនេះហើយ ប្រកាសគុណធម៌នៃឥសីទាំងនោះ ដោយ ៣ បទ ក្រៅអំពីនេះ ។

បណ្តាបទទាំងនោះ បទថា **សញ្ញមេន** បានដល់ ដោយសីល ។ បទថា **ទមេន** បានដល់ ដោយការទូន្មានឥន្ទ្រិយ ។ បទថា **អនុត្តរំ** សេចក្តីថា ប្រព្រឹត្តវត្តសមាទានដ៏ឧត្តមជានិច្ច ទាក់ទងដោយគុណទាំងនេះ ។ បទថា **បរិព្វជា** សេចក្តីថា ខ្ចាត់ខ្ចាយ គឺបន្សាត់ទៅ គឺលះនូវពួកគណៈ ត្រាច់ទៅនោះឯង គឺដល់នូវភាពជាបុគ្គលម្នាក់ឯង ។ បទថា **សមាហិតេ** បានដល់ ជាអ្នកមានចិត្តតាំងមាំដោយឧបចារសមាធិ និងអប្បនាសមាធិ ។ ស្តេចសក្កៈទ្រង់សម្តែងថា ខ្ញុំទំនុកបម្រុងតាបសដែលមានតបៈបែបនេះ ។ បទថា **អហាមុជ្ជគតំ** សេចក្តីថា នៃមហារាជ ឥសីទាំង ១ ម៉ឺនរូបនោះ ជាអ្នកប្រព្រឹត្តត្រង់ ព្រោះមិនមានការវៀចផ្លូវកាយជាដើម សូម្បីត្រឹមតែមួយរូប ខ្ញុំមិនបានជ្រើសរើសដោយជាតិថា មានជាតិថោកថយ ឬសម្បូណ៌ដោយជាតិជាដើម មានចិត្តជ្រះថ្លាក្នុងគុណសម្បត្តិរបស់លោកទាំងនោះ នមស្ការលោកទាំងនោះអស់កាលជានិច្ច គឺនមស្ការសព្វកាលជានិច្ចនោះឯង សក្កទេវរាជត្រាស់ដូច្នេះ ។ ព្រោះហេតុអ្វី ព្រោះសត្វមានកម្មជាផៅពង្ស អធិប្បាយថា ព្រោះថា ឈ្មោះថាសត្វទាំងឡាយនេះ មានកម្មជាផៅពង្ស មានកម្មជាទីអាស្រ័យ ។ បទថា **សព្វេ វណ្ណា** គប្បីជ្រាបដោយហេតុនោះឯង ។

កាលត្រាស់យ៉ាងនេះហើយ សក្កទេវរាជទ្រង់ទូន្មានព្រះបាទនេមិរាជ

នោះថា បពិត្រមហារាជ ព្រហ្មចរិយវាស ជាធម៌មានផលច្រើនជាងទាន ដោយពិត តែទោះជាយ៉ាងនោះ ធម៌ទាំងពីរនោះ ក៏ជាមហាបុរិសវិតក្ក ព្រោះ ដូច្នោះ សូមទ្រង់កុំប្រមាទក្នុងធម៌ទាំងពីរ សូមទ្រង់បរិច្ចាគទានផង រក្សា សីលផង ត្រាស់ដូច្នេះហើយ ទើបយាងទៅកាន់សក្កដ្ឋានរបស់ទ្រង់នោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទ ព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល សូត្យសានូវព្រះគាថាដូច្នេះថា

មឃទេវរាជ សុជម្បតិទ្រង់ពោលពាក្យនេះ ទ្រង់ប្រៀនប្រដៅ
ព្រះបាទនេមិជាធំក្នុងដែនវិទេហៈ រួចហើយ ទ្រង់ចៀសចេញទៅ
កាន់ពួកទេវតាក្នុងស្ថានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបក្កមិ** ប្រែថា ចៀសចេញទៅហើយ អធិប្បាយថា សក្កទេវរាជបង្ហាញខ្លួនដល់ពួកទេវតាពីរពួក គង់ក្នុងទេវសភា ឈ្មោះសុធម្មា ។

លំដាប់នោះ ពួកទេវតាបានទូលសួរសក្កទេវរាជថា បពិត្រមហារាជ ទ្រង់មិនប្រាកដ ទ្រង់យាងទៅណាហ្ន៎ សក្កទេវរាជឆ្លើយថា លោកនិទុក្ខទាំង ឡាយ សេចក្តីងឿងឆ្ងល់មួយកើតឡើងដល់ព្រះបាទនេមិរាជ ក្រុងមិថិលា ខ្ញុំ ក៏ទៅពោលបញ្ហា ធ្វើឲ្យទ្រង់អស់សង្ស័យ ហើយត្រឡប់មក ។

កាលត្រាស់យ៉ាងនេះហើយ សក្កទេវរាជ ដើម្បីត្រាស់ហេតុនេះ ដោយគាថាទៀត ទើបត្រាស់ថា

ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយទាំងប៉ុន្មាន ដែលបានមកប្រជុំគ្នាហើយក្នុងទីនេះ ចូរចាំ ស្តាប់នូវគុណខ្ពស់ និងទាបមានប្រមាណច្រើននេះរបស់មនុស្សទាំងឡាយ អ្នកប្រកបដោយធម៌ ។ ដូចជាព្រះបាទនេមិអង្គនេះ ជាបណ្ឌិត ជាអ្នកត្រូវការដោយកុសល ជាព្រះរាជាទូន្មាននូវសត្រូវ បានឲ្យទានដល់អ្នកដែនវិទេហៈទាំងឡាយគ្រប់ៗ គ្នា ។ កាលដែលព្រះរាជាអង្គនោះកំពុងឲ្យនូវទាននោះ សេចក្តីត្រិះរិះកើតឡើងថា ទានក្តី ព្រហ្ម-ចរិយៈក្តី កុសលណា មានផលច្រើនជាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥមំ** សេចក្តីថា ចូរអ្នកទាំងឡាយតាំងចិត្តស្តាប់ គឺចូរស្តាប់នូវគុណ ដែលគួរពណ៌នា ខ្ពស់ដោយអំណាចសីល ទាបដោយអំណាចទានជាច្រើននេះ របស់ពួកមនុស្សទាំងឡាយដែលប្រកបដោយធម៌ គឺជាអ្នកមានកល្យាណធម៌ដែលខ្ញុំពោល ។ បទថា **យថា អយំ** សេចក្តីថា ព្រះបាទនេមិរាជនេះ ជាបណ្ឌិត គឺជាបណ្ឌិតយ៉ាងពិតប្រាកដ ។

សក្កទេវរាជត្រាស់គុណដែលគួរពណ៌នារបស់ព្រះបាទនេមិរាជ ដោយមិនខ្វះខាត ដោយប្រការដូច្នេះ ។

ពួកទេវតាបានស្តាប់ពាក្យរបស់សក្កៈដូច្នេះ ប្រាថ្នានឹងឃើញព្រះបាទនេមិរាជ ទើបទូលថា បពិត្រមហារាជ ព្រះបាទនេមិរាជជាអាចារ្យរបស់ពួកខ្ញុំ ពួកខ្ញុំតាំងនៅក្នុងឱវាទរបស់ព្រះអង្គ អាស្រ័យព្រះអង្គទើបបាននូវទិព្វសម្បត្តិនេះ ពួកទូលបង្គំប្រាថ្នានឹងឃើញព្រះអង្គ សូមទ្រង់យាងព្រះបាទនេមិរាជមក

សក្កទេវរាជទ្រង់ទទួលពាក្យ ទើបមានទេវបញ្ជាដល់មាតលិទេវសារថីថា ចូរអ្នកទឹមវេជយន្តរថ ទៅកាន់ក្រុងមិថិលា យាងព្រះបាទនេមិរាជឡើងទិព្វយាន នាំទ្រង់មកទេវស្ថាននេះ ។ មាតលិទេវបុត្រទទួលទេវោង្ការហើយ ទឹមរថដែលជាទិព្វបរចេញទៅ កាលសក្កទេវរាជត្រាស់នឹងទេវតាទាំងឡាយ ត្រាស់ហៅមាតលិសារថីមកត្រាស់បញ្ជា កាលមាតលិទេវសារថីទឹមវេជយន្តរាជរថ កន្លងទៅបានមួយខែ ដោយកំណត់ថ្ងៃរបស់មនុស្ស ។ កាលព្រះបាទនេមិរាជទ្រង់រក្សាឧបោសថសីលក្នុងថ្ងៃពេញបូណ៌មី បើកបង្អួចទិសខាងកើត ប្រថាប់គង់ក្នុងជំណាក់ គណៈអមាត្យចោមរោម ទ្រង់ពិចារណានូវសីល វេជយន្តរាជរថនោះ ប្រាកដព្រមជាមួយចន្ទមណ្ឌល ដែលរះឡើងពីទិសខាង កើតនៃចក្កវាឡ ។ ជនទាំងឡាយ បរិភោគអាហារល្ងាចហើយ អង្គុយត្រង់ទ្វារផ្ទះរៀងៗខ្លួន និយាយគ្នាដល់ពាក្យដែលឲ្យកើតសេចក្ដីសុខថា ថ្ងៃនេះ ព្រះចន្ទរះពីរ ។ លំដាប់នោះ ទេវរថនោះក៏ប្រាកដដល់មហាជនដែលកំពុងសន្ទនាមហាជនពោលថា នុ៎ះមិនមែនជាព្រះចន្ទ គឺជារថ កាលវេជយន្តរថទឹមដោយសេះសិន្ធពមួយពាន់ មានមាតលិទេវបុត្រជាអ្នកបរ ប្រាកដហើយក្នុងខណៈនោះ ទើបគិតគ្នាថា ទិព្វយាននេះមកដើម្បីអ្នកណាហ្ន៎ ក៏យល់ឃើញថាមិនមែនដើម្បីអ្នកដទៃ ព្រះរាជារបស់ពួកយើង ជាធម្មិករាជ ប្រហែលសក្កទេវរាជបញ្ជូនមកដើម្បីព្រះរាជានោះឯង ទេវរថនេះ សមគួរដល់ព្រះរាជារបស់ពួកយើងដោយពិត ឃើញដូច្នេះហើយ ក៏ត្រេកអរពោលគាថាដូច្នេះថា

ឱហ្ន៎ សេចក្ដីព្រឺរោមមិនធ្លាប់កើតមាន ក៏កើតឡើងហើយក្នុង

លោក រថទិព្វកើតប្រាកដហើយ ដល់ព្រះបាទវិទេហៈមានយស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អព្ភុតោ** បានដល់ មិនធ្លាប់មានហើយ ម្យ៉ាងទៀត បានដល់ អស្ចារ្យ មហាជនពោលយ៉ាងនេះដោយការក្រាក់ផ្អើល ។

កាលមហាជនពោលយ៉ាងនេះ មាតលិទេវបុត្រមកដោយរហ័ស ត្រឡប់រថ ទល់រថខាងក្រោយត្រង់សីហបញ្ជរ រៀបចំឲ្យព្រះរាជាយាងឡើង បានយាងព្រះបាទនេមិរាជឡើងរថ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

មាតលិទេវបុត្រ អ្នកមានឫទ្ធិច្រើន ជាទេវសារថី បានអញ្ជើញព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលាថា ។ បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងមក ទ្រង់ស្ដេចឡើងកាន់រថនេះ ដ្បិតទេវតាទាំងឡាយ នៅស្ថានតាវត្តិង្ស ព្រមទាំងព្រះឥន្ទចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយនោះ តែងរឭក ( ព្រះអង្គ ) កំពុងនៅប្រជុំក្នុងធម្មសភាឈ្មោះសុធម្មា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មិថិលគ្គហំ** សេចក្ដីថា ជាអ្នកមានប្រាសាទប្រតិស្ឋានក្នុងក្រុងមិថិលា ទ្រង់សង្គ្រោះអ្នកមិថិលាដោយសង្គហវត្ថុ ៤ ។ បទថា **សមច្ឆរេ** សេចក្ដីថា អង្គុយពោលសរសើរគុណរបស់ព្រះអង្គ ។

ព្រះបាទនេមិរាជបានស្ដាប់ពាក្យនោះ មានព្រះតម្រិះថា អញនឹងបាន ឃើញទេវលោកដែលមិនធ្លាប់ឃើញ មាតលិទេវបុត្រនឹងសង្គ្រោះអញ អញ នឹងទៅ ត្រាស់ហៅស្រីស្នំ និងមហាជនមកត្រាស់ថា អញនឹងទៅមិនយូរ ឡើយ អ្នកទាំងឡាយកុំប្រមាទ ចូរធ្វើបុណ្យទាំងឡាយ មានការឲ្យទាន ជាដើម ត្រាស់ដូច្នេះហើយ យាងឡើងទិព្វរថ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះ បន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះ ព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលា ទ្រង់មីម្នា
ក្រោកចាកអាសនៈ បែរព្រះភក្ត្រឡើងកាន់រថ ។ មាតលិទេវបុត្រ
ទូលសួរព្រះបាទនេមិរាជនុ៎ះ ដែលស្ដេចឡើងកាន់រថទិព្វហើយ
ដូច្នេះថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំ
នាំព្រះអង្គទៅតាមផ្លូវណា តាមផ្លូវដែលសត្វមានបាបកម្ម ឬតាម
ផ្លូវដែលសត្វមានបុញ្ញកម្ម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បមុខោ** សេចក្ដីថា ជាបុគ្គលឧត្តម ឬជា ប្រមុខ ទ្រង់បែរខ្នងចំពោះមហាជនហើយ យាងឡើង ។ បទថា **យេន វា** សេចក្ដីថា បណ្ដាផ្លូវទាំងនេះ គឺផ្លូវដែលបុគ្គលទៅហើយ អាចឃើញលំនៅ របស់ពួកសត្វដែលធ្វើបាប ១ ផ្លូវដែលបុគ្គលទៅហើយ អាចឃើញលំនៅ របស់ពួកសត្វដែលធ្វើបុណ្យ ១ ទ្រង់ឲ្យខ្ញុំនាំទៅផ្លូវណាមុន មាតលិសារថីនោះ

សូម្បីសក្កៈមិនបានបញ្ជាយ៉ាងនេះ ក៏ទូលដើម្បីសម្តែងដល់ភាពវិសេសនៃភាពជាទូតរបស់ខ្លួន ។

លំដាប់នោះ ព្រះរាជាមានព្រះតម្រិះថា ទីទាំងពីរ យើងមិនធ្លាប់ឃើញ យើងនឹងមើលទាំងពីរកន្លែង ទើបត្រាស់ថា

ម្នាលមាតលិទេវសារថី អ្នកចូរនាំខ្ញុំទៅតាមផ្លូវទាំងពីរ គឺផ្លូវដែលសត្វមានបាបកម្មផង ផ្លូវដែលសត្វមានបុញ្ញកម្មផង ដូច្នេះ ។

លំដាប់នោះ មាតលិទេវបុត្រទូលថា ខ្ញុំមិនអាចបង្ហាញទីទាំងពីរក្នុងខណៈតែមួយបានឡើយ ទើបទូលសួរទ្រង់ កាលនឹងទូលសួរ ទើបពោលគាថាដូច្នេះថា

បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណាមុន តាមផ្លូវដែលសត្វមានបាបកម្មមុនឬ ឬតាមផ្លូវដែលសត្វមានបុញ្ញកម្មមុន ដូច្នេះ ។

លំដាប់នោះ ព្រះរាជាមានព្រះតម្រិះថា អញនឹងទៅទេវលោកពិត តែនឹងមើលនរកសិន ទើបត្រាស់គាថាបន្តថា

ខ្ញុំចង់ឃើញនរកជាទីនៅនៃសត្វ អ្នកមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញស្ថាននៃសត្វ អ្នកមានកម្មលាមក និងគតិនៃសត្វទ្រុស្តសីលទាំងឡាយមុន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុស្សីលានំ** បានដល់ របស់គ្រហស្ថទ្រុស្តសីល របស់សមណៈទ្រុស្តសីល ដែលធ្វើបាបដោយអំណាចអកុសល-

កម្មបថ ១០ ។ បទថា **យា គតិ** សេចក្ដីថា យើងនឹងមើលទីកើតរបស់អ្នកទ្រុស្តសីលទាំងនោះ ។

លំដាប់នោះ មាតលិទេវសារថី បានបង្ហាញស្ទឹងឈ្មោះវេតរណីដល់ព្រះបាទនេមិរាជមុន ។

**គមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

មាតលិទេវសារថី បង្ហាញព្រះរាជានូវស្ទឹងឈ្មោះវេតរណី ដែលសត្វឆ្លងបានដោយកម្រ ប្រកបព្រមដោយទឹកផ្សាប្រៃ កំពុងពុះក្ដៅ ដូចអណ្ដាតភ្លើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វេតរណឹ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ មាតលិទេវសារថី បានស្ដាប់ព្រះរាជតម្រាស់របស់ព្រះបាទនេមិរាជ ទើបបររថតម្រង់ទៅនរក បង្ហាញស្ទឹងវេតរណីដែលតាំងឡើងដោយឧតុ ដោយកម្មជាបច្ច័យមុន នាយនិរយបាលទាំងឡាយក្នុងនរកនោះកាន់សស្ត្រាវុធ មានដាវ កាំបិត ច្បូក លំពែង និងដំបងជាដើមដែលឆេះរន្ទាលប្រាលឆ្អៅ ប្រហារសត្វនរកទាំងឡាយ សត្វនរកទាំងនោះ អត់ធន់នូវទុក្ខនោះមិនបាន ក៏លោតចូលក្នុងវេតរណី ។

វេតរណីនទីនោះ ដេរដាសដោយវល្លិ៍មានបន្លា មុតដូចធ្មេញរណារប្រមាណប៉ុនចុងលំពែង មានភ្លើងឆេះសន្ធោសន្ធៅខាងលើ សត្វនរកទាំង

នោះត្រូវនៅក្នុងវេតរណីច្រើនពាន់ឆ្នាំ ដាច់ជាកំណាត់តូចធំ ព្រោះវល្លិ៍ដែលមានបន្លាមានមុខមុតដូចកាំបិតកោរ មានភ្លើងឆេះ មានលំពែងឆេះ ប្រមាណប៉ុនដើមត្នោត ឆេះដោយភ្លើង តាំងឡើងខាងក្នុងវល្លិ៍ទាំងនោះ សត្វនរកទាំងឡាយ ញុំាងកាលឲ្យកន្លងទៅអស់កាលដ៏យូរ ធ្លាក់អំពីវល្លិ៍ ក៏ជង់ត្រង់មុខលំពែង មានរាងកាយត្រូវលំពែងមុត ជាប់ក្នុងលំពែង ដែលឆេះដោយភ្លើងអស់កាលយូរ ដូចត្រីដែលគេដោតក្នុងឈើស្រួច ដាក់លើភ្លើង លំពែងទាំងឡាយឆេះជាភ្លើង សត្វនរកទាំងឡាយ ក៏ឆេះជាភ្លើង ខាងក្រោមលំពែងទាំងឡាយ មានស្លឹកឈូកដែកមុតដូចកាំបិតកោរ ឆេះដោយភ្លើងនៅលើផ្ទៃទឹក សត្វនរកទាំងនោះ រើខ្លួនរបូតពីចុងលំពែងទាំងឡាយ ក៏រអិលទៅលើស្លឹកឈូកដែក សោយនូវទុក្ខវេទនាអស់កាលយូរ បន្ទាប់អំពីនោះ សត្វនរកទាំងនោះ ក៏របេមរះ ហើយក៏រអិលធ្លាក់ក្នុងទឹកក្រុត សូម្បីទឹកក្រុតនោះ ក៏ឆេះជាអណ្តាតភ្លើង សត្វនរកទាំងឡាយ មានខ្លួនក្រហមដូចភ្លើង សូម្បីផ្ទៃស្រក៏តាំងឡើង ឯផ្ទៃទឹកខាងក្រោមដេរដាសដោយគ្រឿងប្រហារសុទ្ធតែមុតៗ សត្វនរកទាំងនោះ លិចចូលក្នុងទឹក ដោយគិតថា ខាងក្នុងទឹកជាអ្វីហ្ន៎ ក៏មុជចុះទៅប៉ះនឹងគ្រឿងប្រហារ មុតដាច់ជាកំណាត់តូចធំ សត្វនរកទាំងនោះ មិនអាចអត់ទ្រាំនូវទុក្ខធំនោះ ក៏ស្រែកគួរខ្លាច ។ សត្វនរកទាំងនោះ ជួនកាល ហូរទៅក្រោម ជួនកាល ហូរបញ្ច្រាស់ ។ លំដាប់នោះ នាយនិរយបាលដែលនៅត្រង់ច្រាំង ក៏បាញ់ដោយព្រួញ កាំបិត ច្បូក លំពែង ទម្លុះសត្វនរកទាំងនោះដូចត្រី សត្វនរកទាំងនោះដល់នូវទុក្ខវេទនា ស្រែកយំគ្រលួច លំដាប់នោះ

នាយនិរយបាលក៏យកសន្ទូចដែកដែលឆេះដោយភ្លើង ថ្ពក់សត្វនរកទាំងនោះអូសឡើងមក អូសឡើងមកឲ្យដេកលើផែនដីដែក ដែលឆេះដោយភ្លើងរន្ទាលប្រាល់ឆ្អៅ ហើយបង្ហារមាត់ច្រកនូវដុំដែក ដែលឆេះសន្ធោសន្ធៅ ។ ព្រះបាទនេមិរាជបានឃើញសត្វនរកទាំងនោះ ត្រូវទុក្ខធំបៀតបៀន ក្នុងវេតរណីនទី ក៏តក់ស្លុត ត្រាស់សួរមាតលិទេវសារថីថា សត្វទាំងនេះ បានធ្វើកម្មដូចម្តេច មាតលិទេវសារថីក៏ក្រាបទូលព្យាករណ៍ ឲ្យទ្រង់ជ្រាប ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាន្ធព្រះគាថាដូច្នេះថា

ព្រះបាទនេមិ ទ្រង់ឃើញសត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី ជាទីឆ្លងឡើងបានដោយកម្រក្រៃលែង ហើយត្រាស់សួរមាតលិទេវសារថីថា ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ( សត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី ) ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយនេះ ធ្លាក់ទៅកាន់ស្ទឹងវេតរណី តើពួកសត្វនេះបានធ្វើបាបកម្មអ្វី ។

មាតលិទេវសារថីដែលព្រះបាទនេមិសួរហើយ ក៏ព្យាករផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកសត្វណាមានកម្លាំង មានធម៌ដ៏លាមកបៀតបៀនប្រទេចផ្តាសា នូវពួកសត្វដែលមានកម្លាំងខ្សោយ ក្នុង

ជីវលោក ពួកសត្វមានកម្មលាមកនោះ រមែងរងបាប ពួកសត្វទាំងនោះឯង រមែងធ្លាក់ទៅកាន់ស្ទឹងវេតរណី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិន្ទតិ** សេចក្ដីថា ខ្ញុំមិនមានឥស្សរៈដល់ខ្លួន ដូចមានសេចក្ដីខ្លាច ។ បទថា **ទិស្វា** សេចក្ដីថា ឃើញពួកសត្វដែលធ្លាក់ គឺឃើញសត្វនរកទាំងនោះ ធ្លាក់ក្នុងស្ទឹងវេតរណី ។

បទថា **ជានំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ មាតលិទេវសារថីនោះដឹងឯង ទើបទូលប្រាប់ដល់ព្រះបាទនេមិរាជ ដែលទ្រង់មិនជ្រាប ។ បទថា **ទុព្វលេ** បានដល់ វៀរចាកកម្លាំងរាងកាយ កម្លាំងភោគៈ និងកម្លាំងអំណាច ។ បទថា **ពលវន្តោ** បានដល់ ប្រកបដោយកម្លាំងទាំងនោះ ។ បទថា **ហឹសេន្តិ** បានដល់ ធ្វើឲ្យលំបាក មានប្រហារដោយបាតដៃជាដើម ។ បទថា **រោសេន្តិ** បានដល់ ជេរដោយប្រការផ្សេងៗ ។ បទថា **បសវេត្វា** សេចក្ដីថា ឲ្យកើត គឺធ្វើ ។

មាតលិទេវសារថី ទូលព្យាករបញ្ហាដល់ព្រះបាទនេមិរាជយ៉ាងនេះហើយ កាលព្រះបាទនេមិរាជ បានទតឃើញវេតរណីនរកហើយ ក៏ធ្វើប្រទេសនោះឲ្យអន្តរធានទៅ ហើយបររថទៅខាងមុខ សម្ដែងទីដែលសត្វ មានឆ្កែជាដើមទំពាស៊ី ព្រះបាទនេមិរាជទតឃើញទីនោះហើយ ក៏ភ័យខ្លាច ត្រាស់សួរបញ្ហា បានទូលព្យាករហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួរសាទូវព្រះគាថាដូច្នេះថា

ពួកក្អែកព្រៃសម្បុរក្រហម និងពពាល ពួកត្មាត ពួកក្អែក ជាសត្វគួរខ្លាច តែងទំពាស៊ី ( សត្វនរកដែលវាប្រទះឃើញ ) ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិ-ទេវសារថី ខ្ញុំសួរអ្នក ហ្វូងក្អែកតែងជញ្ជែងស៊ី នូវសត្វទាំងឡាយនេះ តើសត្វទាំងឡាយនេះ បានធ្វើបាបដូចម្តេច ។

មាតលិទេវសារថីដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃកម្មដែលខ្លួនដឹង ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា សត្វទាំងឡាយណានីមួយ មានសេចក្តីកំណាញ់ កំណាញ់ស្វិតស្វាញ មានធម៌លាមកពេក ជាអ្នកជេរប្រទេចបៀតបៀន ប្រទូស្តសមណព្រាហ្មណ៍ សត្វអ្នកមានអំពើលាមកទាំងនោះ រមែងរងបាប ទើបហ្វូងក្អែកជញ្ជែងស៊ីសត្វទាំងឡាយនោះ ដូច្នេះ ។

បញ្ហាដទៃក្រៅអំពីនេះ និងការព្យាករណ៍ ក៏មានន័យដូច្នេះឯង ។

បណ្តាបទទាំងនោះ បទថា **សាមា** បានដល់ មានពណ៌ក្រហម ។ បទថា **សោណា** ប្រែថា ឆ្កែ ។ បទថា **សវលា** សេចក្តីថា មានពណ៌ពពាល និងមានពណ៌ស ខ្មៅ លឿង លោកសំដែងឆ្កែ ៥ ពណ៌យ៉ាងនេះ បានឮថា ឆ្កែទាំងនោះមានខ្លួនធំប៉ុនៗ ដំរី ដេញតាមសត្វនរក ដែលរត់លើផែនដីដែកឆេះដោយភ្លើង ដូចដេញម្រឹគ ខាំសាច់ជាចម្រៀកៗ ញ៉ាំងសរីរៈទំហំ ៣

គាវុតរបស់សត្វនរក ឲ្យដួលលើផែនដីដែកដែលឆេះដោយភ្លើង យកជើងមុខទាំងពីរ ជាន់ត្រង់ទ្រូងរបស់សត្វនរកដែលកំពុងស្រែក ត្របាក់ស៊ីសាច់ ឲ្យសល់តែរាងឆ្អឹង នៃសត្វដែលមានបាបធម៌ ។ បទថា **គិជ្ឈា** បានដល់ ហ្វូងត្មាត ដែលមានចំពុះជាលោហៈ មានខ្លួនធំប៉ុនៗ រទេះដឹកទំនិញ ត្មាតទាំងនោះចោះទម្លុះឆ្អឹងរបស់សត្វនរកដោយចំពុះ ដូចគ្នានឹងចុងដែកស្ទាន ទំពាស៊ីខួរក្នុងឆ្អឹង ។ បទថា **កាកោលសង្ឃា** បានដល់ ហ្វូងក្អែក មានចំពុះ ជាលោហៈគួរខ្លាចក្រៃលែង ទំពាស៊ីសត្វនរកដែលវាឃើញហើយ ។ បទថា **យេមេ ជនេ** សេចក្តីថា សួរថា សត្វនរកទាំងនេះដែលត្រូវក្អែកទំពាស៊ី បានធ្វើបាបកម្មអ្វី ។ បទថា **មច្ឆរិនោ** បានដល់ មិនឲ្យអ្វីដល់អ្នកដទៃឈ្មោះថាកំណាញ់ ។ បទថា **កទរិយា** បានដល់ រឹងត្អឹង និងកំណាញ់ហាមអ្នកដទៃដែលកំពុងបរិច្ចាគទាន ។ បទថា **សមណព្រាហ្មណានំ** បានដល់ អ្នកស្ងប់រម្ងាប់បាប បន្សាត់បាបហើយ ។

បន្ទាប់អំពីនោះ មាតលិទេវសារថីញុំាងបទេសនោះឲ្យអន្តរធាន បររថទៅខាងមុខទៀត ។ សត្វនរកទាំងឡាយជាន់ផែនដីដែក ៩ យោជន៍ដែលឆេះរន្ទាល នាយនិរយបាលដេញតាមទៅ ប្រហារស្មងដោយដំបងដែកដែលឆេះដោយភ្លើង ប្រមាណប៉ុនដើមត្នោត ឲ្យដួលចុះវាយដោយដំបងដែកនោះឲ្យបែកខ្ទិចខ្ទីជាលម្អិតតូចធំ ។ ព្រះបាទនេមិរាជទតឃើញដូច្នោះ ទ្រង់តក់ស្លុតកាលត្រាស់សួរមាតលិទេវសារថី ទើបត្រាស់គាថាដូច្នេះថា

សត្វនរកទាំងឡាយ មានសរីរៈ ឆេះសន្ធោសន្ធៅ ដើរលើផែនដី

ដែក ថែមទាំងនាយនិរយបាលសំពង ដោយដំបងដែកទាំងឡាយ ដែលភ្លើងឆេះ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាល វាយដោយដំបង ដួលដេកនេះ តើពួកសត្វទាំងនេះ បានធ្វើបាប ដូចម្ដេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល បាបកម្មដែលខ្លួនដឹង ទូលព្រះរាជា ដែលមិនទ្រង់ជ្រាបថា ជន ទាំងឡាយមានបាបធម៌ពេញបន្ទុក បៀតបៀនប្រទេច ផ្ដាសានូវ បុរសស្ត្រី ដែលឥតបាបធម៌ ក្នុងជីវលោក ឈ្មោះថា ជាអ្នក មានបាបធម៌ពេញបន្ទុក ជនអ្នកមានកម្មលាមកទាំងនោះ រមែង រងបាប ជនទាំងឡាយនោះឯងហើយ ដែលនាយនិរយបាល បៀតបៀន ដោយដំបងដួលដេកនៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សញ្ជោតិភូតា** បានដល់ មានសរីរៈឆេះ សន្ធោសន្ធៅ ។ បទថា **បឋវី** សេចក្ដីថា ឈាន គឺជាន់ផែនដីដែក ៩ យោជន៍ ដែលឆេះសន្ធោសន្ធៅ ។ បទថា **ខន្ធេហិ ច ចោទយន្តិ** សេចក្ដីថា ពួកសត្វ នរក មានរាងកាយឆេះសន្ធោសន្ធៅ ត្រូវនាយនិរយបាលដេញតាមប្រហារ ត្រង់ស្មងទាំងពីរ ដោយដំបងដែកដែលឆេះដោយភ្លើង ប៉ុនដើមត្នោតឲ្យដួល ហើយ បោមពោមវាយដោយដំបងដែកទាំងនោះឯង ឲ្យដាច់ជាចម្រៀកតូចធំ ដូចវាយគោដែលមិនចូលក្រោល ដូច្នោះ ។ បទថា **សុចាបធម្មិនោ** បានដល់

ជាអ្នកមានបាបធម៌ពេញបន្ទុកសម្រាប់ខ្លួន ។ បទថា **អចាបជម្មំ** បានដល់ សម្បូរដោយគុណ មានសីល និងអាចារៈជាដើម ឬប្រាសចាកកំហុស ។

មាតលិទេវសារថី បររថទៅខាងមុខទៀត នាយនិរយបាលទាំងឡាយ ចាក់សត្វនរកដោយអាវុធដែលឆេះសន្ធោសន្ធៅ សត្វនរកទាំងនោះក៏ធ្លាក់ក្នុង រណ្តៅរងើកភ្លើង កាលសត្វនរកនោះលិចក្នុងរណ្តៅរងើកភ្លើងត្រឹមចង្កេះ ពួក នាយនិរយបាល ក៏យកល្អីដែកធំដួសរងើកភ្លើង ស្រោចលើក្បាលសត្វនរក ទាំងនោះ សត្វនរកទាំងនោះមិនអាចទ្រាំនឹងរងើកភ្លើងបាន ក៏ទ្រហោយំ មាន ភ្លើងឆេះកាយបម្រះននៀល ព្រះបាទនេមិរាជទតឃើញដូច្នោះ ទើបត្រាស់ ព្រះគាថាដូច្នេះថា

ពួកសត្វនរកដទៃ មានខ្លួនឆេះជុំវិញ កំពុងទួញយំ ( ធ្លាក់ទៅ ) កាន់រណ្តៅរងើកភ្លើងហើយថ្ងូរ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយ ដែលធ្លាក់ទៅកាន់រណ្តៅរងើកភ្លើង ហើយថ្ងូរ តើពួកសត្វទាំង ឡាយនេះ បានធ្វើបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជា ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ពោលអាងសាក្សី ( កោង ) ក្នុង ហេតុនៃទ្រព្យរបស់ប្រជុំជន ហើយញុំាងទ្រព្យជាបំណុលនោះឲ្យ វិនាស បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ ញុំាងពួក

ជនឲ្យវិនាសហើយ ជនទាំងឡាយអ្នកមានកម្មដ៏លាមកនោះ រមែង
រងបាប ទើបជនទាំងឡាយនោះឯង ( ធ្លាក់ទៅ ) កាន់រណ្តៅ
រងើកភ្លើង ហើយថ្ងូរ ដូច្នេះ

បណ្តាបទទាំងនោះ បទថា **អង្គារកាសុំ** សេចក្តីថា នែសម្លាញ់មាតលី
ហេតុអ្វី សត្វទាំងនេះ ត្រូវនាយនិរយបាលចោមរោមចាក់ដោយអាវុធ ដែល
ឆេះសន្ធោសន្ធៅ ដូចកៀងគោបញ្ចូលក្រោល ធ្លាក់ក្នុងរណ្តៅរងើកភ្លើង នាយ
និរយបាលទាំងឡាយ កាន់យកល្អីដែកធំ ដួសរងើកភ្លើងចាក់លើក្បាលសត្វ
នរកទាំងនោះ ដែលកំពុងលិចក្នុងរណ្តៅរងើកភ្លើងត្រឹមចង្កេះ កាលនោះ ពួក
សត្វមិនអាចអត់ទ្រាំនឹងរងើកភ្លើងទាំងឡាយបានក៏ស្រែក មានកាយឆេះទូទៅ
យំបម្រះនទៀល អធិប្បាយថា រោយ គឺរោយរងើកភ្លើងលើក្បាលរបស់សត្វ
នរក ដោយកម្លាំងនៃកម្មខ្លះ ដោយខ្លួនឯងខ្លះ ។ បទថា **បូគាយ ធនស្ស**
សេចក្តីថា ហេតុនៃទ្រព្យដែលជារបស់ប្រជុំជនដែលខ្លួនរៃអង្គាស កាលមាន
ឱកាសថា ពួកយើងនឹងថ្វាយទានខ្លះ នឹងធ្វើការបូជាខ្លះ នឹងសាងវិហារខ្លះ ។
បទថា **ជាបយន្តិ** សេចក្តីថា ចាយទ្រព្យនោះតាមគាប់ចិត្ត សូកសំណូកអ្នកធំ
សាងសាក្សីកោងថា ពួកយើងធ្វើការខ្វល់ខ្វាយក្នុងទីនោះប៉ុណ្ណោះ ក្នុងទីនោះ
ប៉ុណ្ណោះ ធ្វើទ្រព្យឲ្យវិនាស គឺធ្វើឲ្យអន្តរធានទៅ ។

មាតលិទេវសារថីបររថទៅខាងមុខ ពួកសត្វត្រូវនិរយបាលមានរូបគួរ
ខ្លាច ចាប់ជើងឡើងលើក្បាលចុះក្រោម ទម្លាក់ទៅក្នុងឆ្នាំងលោហៈដែលក្តៅ
ព្រះបាទនេមិរាជទតឃើញ ទើបត្រាស់ថា

ខ្ទះទង់ដែងធំ មានភ្លើងឆេះសន្ធោសន្ធៅ ឆ្នោលប្រាលឆ្អៅ ប្រាកដ ជាក់ស្តែង ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាល មាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ ( មានក្បាល សំយុងចុះ ) ធ្លាក់ទៅកាន់ខ្ទះ ពេញដោយទឹកទង់ដែង តើពួក សត្វទាំងនេះ ធ្វើបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា មានធម៌ដ៏លាមកពេក បៀតបៀនប្រទេច ផ្តាសា នូវសមណៈ ឬព្រាហ្មណ៍ អ្នកមាន សីល ជនអ្នកមានកម្មដ៏លាមកទាំងឡាយនោះ តែងវេងនូវបាប ជនទាំងនោះ ( មានក្បាលសំយុងចុះ ) ធ្លាក់ទៅកាន់ខ្ទះ ពេញ ដោយទឹកទង់ដែង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បធិត្តា** បានដល់ ដែលភ្លើងឆេះទូទៅហើយ ។ បទថា **មហាតី** សេចក្តីថា ប្រមាណប៉ុនភ្នំតាំងនៅអស់កប្ប ពេញទៅដោយ ទឹកលោហៈ ។ បទថា **អវំសិរា** សេចក្តីថា សត្វទាំងនោះ ត្រូវនិរយបាល ចាប់ជើងឡើងលើ ក្បាលចុះក្រោម ទម្លាក់ក្នុងលោហកុម្ភីនោះ ។ បទថា **សីលវន្តំ** បានដល់ ជាអ្នកមានសីល គឺដល់ព្រមដោយគុណ និងអាចារៈ ។

មាតលិទេវសារថីបររថទៅខាងមុខ នាយនិរយបាលយកខ្សែដែកដែល ឆេះដោយភ្លើងចងកសត្វនរកឲ្យឱនមុខ ទាញឡើងមកកាត់ត្រង់ក ឲ្យជ្រមុជ

ក្នុងទឹកក្តៅ ហើយវាយ ។ ព្រះបាទនេមិរាជទតឃើញដូច្នោះ ទើបត្រាស់គាថាដូច្នេះថា

ពួកនាយនិរយបាលត្របែងកនៃសត្វនរក ហើយកាប់ពន្លះបោះទៅ ក្នុងទឹកក្តៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាល មាតលិទេវសារថី ខ្ញុំសួរអ្នក ចុះពួកសត្វដែលមានក្បាលដាច់ ហើយដេកនៅនេះ តើសត្វពួកនេះ បានធ្វើបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោក មាន បាបធម៌ពេញបន្ទុក តែងចាប់បៀតបៀននូវសត្វស្លាបទាំងឡាយ បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ បៀតបៀនហើយ នូវសត្វស្លាប ពួកជនអ្នកមានកម្មលាមកនោះ រមែងរងនូវបាប ជនទាំងឡាយនោះ មានក្បាលដាច់ ហើយដេកនៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លុញ្ចន្តិ** បានដល់ កើចកន្ត្រាក់ ។ បទថា **អថ វេឋយិត្វា** សេចក្តីថា យកខ្សែដែកដែលឆេះដោយភ្លើង ចងកឲ្យឱនមុខ ។ បទថា **ឧណ្ហោទកស្មឹ** បានដល់ ក្នុងទឹកលោហៈ ដែលតាំងមកអស់កប្ប ។ បទថា **បកិលេទយិត្វា** បានដល់ ឲ្យជ្រមុជ គឺបោះទៅ អធិប្បាយថា នៃ មាតលីសម្លាញ់ នាយនិរយបាលទាំងនេះ យកខ្សែដែកត្បែងករបស់សត្វពួក ណា ហើយបង្អោនខ្លួនដែលមានប្រមាណ ៣ គាវុត ឲ្យឱនចុះ ហើយកាត់ក

ដោយដំបងដែកដែលឆេះដោយភ្លើង ហើយបោះទៅក្នុងថ្នាំងលោហៈដែលឆេះសន្ធោសន្ធៅ ហើយនាំគ្នាត្រេកអរ កាលករបស់សត្វនរកដាច់ហើយ ក៏មានកដទៃមួយអន្ទើដោយក្បាល កើតឡើងដល់សត្វនរកនោះទៀត សត្វទាំងនេះបានធ្វើបាបកម្មអ្វី ការខ្លាចបានកើតឡើងដល់យើង ព្រោះឃើញសត្វទាំងនោះ ។ បទថា **បក្ខី គហេត្វាន វិហេឋយន្តិ** សេចក្តីថា បពិត្រមហារាជ សត្វពួកណា កាលនៅក្នុងមនុស្សលោក ចាប់បក្សីបានមក កាត់ស្លាប ចងក សម្លាប់បរិភោគខ្លះ លក់ដូរខ្លះ សត្វទាំងនោះមានក្បាលដាច់ដេកក្នុងទីនេះ ។

មាតលិទេវសារថីបររថទៅទៀត បានឮថា ក្នុងប្រទេសនោះមានស្ទឹងមានទឹកត្រជាក់គួរត្រេកអរ ហូរទៅដោយប្រក្រតី សត្វនរកមិនអាចអត់ធន់នឹងការស្រេកឃ្លានព្រោះកម្តៅដោយភ្លើង ទើបដើរជាន់ផែនដីដែកដែលឆេះដោយភ្លើងចុះកាន់ស្ទឹងនោះ រំពេចនោះឯង ច្រាំងទាំងពីរក៏ឆេះសន្ធោសន្ធៅ ទឹកគួរផឹកក៏ក្លាយជាអង្កាម និងស្លឹកឈើឆេះជាភ្លើង សត្វនរកមិនអាចអត់ធន់នូវការស្រេក ក៏ទំពាស៊ីអង្កាម និងស្លឹកឈើដែលឆេះដោយភ្លើងជំនួសទឹកផឹក អង្កាម និងស្លឹកឈើទាំងនោះ ក៏ដុតសរីរៈទាំងមូល ហើយធ្លាយទៅខាងក្រោម សត្វនរកមិនអាចអត់សង្កត់នូវទុក្ខនោះ ក៏ផ្គងដើមដៃទាំងពីរស្រែកគ្រលួច ព្រះបាទនេមិរាជទតឃើញដូច្នោះ ក៏ត្រាស់ថា

ស្ទឹងនេះមានទឹកច្រើន មានច្រាំងមិនជ្រៅ មានកំពង់ល្អរាបទាប
ហូរទៅ សត្វដែលមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ តែង
ផឹក ស្រាប់តែទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជា

អង្កាម ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាមវិញ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្ដេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា អ្នកមានកិច្ចការមិនបរិសុទ្ធ លាយនូវស្រូវសុទ្ធដោយអង្កាម ឲ្យដល់អ្នកទិញ បានជាទឹកដែលជនទាំងឡាយនោះ កំពុងមានសេចក្ដីក្ដៅបៀតបៀន មានសេចក្ដីស្រេកឃ្លានគ្របសង្កត់ហើយផឹកទៅ ក្លាយជាអង្កាមវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនិខាតកូលា** បានដល់ មានច្រាំងមិនជ្រៅ ។ បទថា **សុបត្ថតិត្ថា** បានដល់ ប្រកបដោយកំពង់ទឹកល្អ ។ បទថា **ថុស ហោតិ** សេចក្ដីថា ស្រូវក្លាយជាអង្កាម ។ បទថា **ចានិ** បានដល់ ទឹកផឹក បានឮថា ក្នុងប្រទេសនោះ មានទឹកថ្លាគួរជាទីត្រេកអរហូរជាប្រក្រតី សត្វនរកក្ដៅព្រោះកម្ដៅនៃភ្លើង មិនអាចអត់ធន់នឹងការស្រេកបាន ទើបដើរជាន់ផែនដីដែក ដែលឆេះសន្ធោសន្ធៅចុះកាន់ស្ទឹងនោះ រំពេចនោះឯង ច្រាំងទាំងសងខាង ក៏ឆេះទូទៅ ទឹកគួរផឹក ក៏ក្លាយជាអង្កាម និងស្លឹកឈើ ឆេះសន្ធោសន្ធៅ សត្វនរកមិនអាចអត់ធន់នឹងការស្រេក ក៏ទំពាស៊ីអង្កាម និងស្លឹកឈើដែលឆេះនោះ អង្កាម និងស្លឹកឈើនោះ ក៏ដុតសរីរៈទាំងមូលរបស់

សត្វទាំងនោះ ឆេះសន្ធោសន្ធៅទូទៅ ហើយធ្លាយមកចំណែកខាងក្រោម សត្វនរកទាំងនោះ មិនអាចអត់សង្កត់សេចក្តីទុក្ខនោះ ក៏ផ្គងនូវដើមដៃទាំងពីរ ទ្រហោយំ ។ បទថា **សុទ្ធធញ្ញំ** ក្នុងគាថានោះ បានដល់ ធុញ្ញជាតិបរិសុទ្ធ ៧ យ៉ាង មានស្រូវជាដើម ។ បទថា **បលាសេន មិស្សំ** សេចក្តីថា យកស្លឹកឈើខ្លះ អង្កាមខ្លះ ខ្សាច់ និងដីជាដើមខ្លះផ្សំគ្នា ។ បទថា **អសុទ្ធកម្មា** បានដល់ មានកាយកម្ម វចីកម្ម មនោកម្មសៅហ្មង ។ បទថា **កយិនោ** សេចក្តីថា ពោលថា ខ្ញុំនឹងឲ្យស្រូវដែលល្អដល់អ្នក ទទួលប្រាក់អំពីដៃរបស់អ្នកវិញហើយ ឲ្យស្រូវមិនល្អបែបនេះ ។

មាតលិទេវសារថីបររថបន្តទៅ នាយនិរយបាលទាំងឡាយ ចោមរោមសត្វនរកក្នុងនិរយាបាយនោះ ដូចនាយព្រាន ចោមរោមម្រឹគក្នុងព្រៃ ហើយចាក់ថ្លឹងជំនីរទាំងសងខាងរបស់សត្វនរកទាំងនោះ ដោយអាវុធផ្សេងៗ មានគ្រឿងប្រហារ គឺព្រួញជាដើម រាងកាយរបស់សត្វនរកទាំងនោះ ប្រាកដជារបស់ធ្លុះធ្លាយដូចជាស្លឹកឈើចាស់ ដូច្នោះ ។ ព្រះបាទនេមិរាជទតឃើញដូច្នោះ កាលត្រាស់សួរមាតលិទេវសារថី ទើបត្រាស់គាថាដូច្នេះថា

នាយនិរយបាលទាំងឡាយ ចាក់នូវសរីរៈទាំងពីរខាងនៃសត្វនរក
ដែលកំពុងកន្ទក់កន្ទេញ ដោយព្រួញទាំងឡាយក៏មាន ដោយ
លំពែងទាំងឡាយក៏មាន ដោយលំពែងស្នែងក្របីទាំងឡាយ
ក៏មាន ម្នាលទេពបម្រើ សេចក្តីភ័យមានដល់ខ្ញុំ ព្រោះឃើញ
ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាល

បៀតបៀនហើយដោយលំពែង ដេកនៅ ដូច្នេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោក ជាអ្នកមានកម្មមិនល្អ លួចយកស្រូវ ទ្រព្យ ប្រាក់ មាស ទាំងសត្វចិញ្ចឹម ពពែ ចៀម និងក្របី ដែលគេមិនឲ្យ ហើយធ្វើនូវការចិញ្ចឹមជីវិត ជនអ្នកមានកម្មដ៏លាមកទាំងនោះ រមែងវេទនូវបាប ទើបពួកជនទាំងនោះ ត្រូវនាយនិរយបាលបៀតបៀនហើយ ដោយលំពែង ដេកនៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧភយានិ** បានដល់ ចំហៀងទាំងសងខាង ។ បទថា **តុទន្តិ** បានដល់ រមែងចាក់ ។ បទថា **កន្ទតំ** បានដល់ ទ្រហោយំ នាយនិរយបាលឃោរឃៅ ចោមរោមចាក់ផ្អឹងជំនីរទាំងសងខាងដោយអាវុធផ្សេងៗ មានព្រួញជាដើម ដូចនាយព្រានចោមរោមម្រឹគក្នុងព្រៃ សរីរៈប្រាកដជាប្រហោងដូចស្នឹកឈើចាស់ ។ បទថា **អទិន្នមាទាយ** បានដល់ សវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យដែលជារបស់អ្នកដទៃ សត្វនរកទាំងនោះកាន់យកទ្រព្យនោះ ដោយការកាត់ទីតជាដើម និងដោយការបញ្ឆោតមានប្រការផ្សេងៗ ចិញ្ចឹមជីវិត ។

មាតលិទេវសារថី បររថបន្តទៅទៀត បង្ហាញនិរយបាលដទៃទៀត នាយ

និរយបាលចងកសត្វនរកនោះដោយខ្សែធំដែលឆេះដោយភ្លើង កញ្ឆក់ឲ្យដួល លើផែនដីដែលឆេះសន្ធោសន្ធៅ វាយដោយអាវុធផ្សេងៗ ។ ព្រះបាទនេមិរាជ កាលត្រាស់សួរមាតលិទេវសារថីដល់ហេតុនោះ ទើបត្រាស់គាថាដូច្នេះថា

ហេតុអ្វី សត្វនរកទាំងឡាយនេះ មួយពួកត្រូវនាយនិរយបាល ចងកអូស ពួកដទៃ ត្រូវនាយនិរយបាលចិញ្ច្រាំ ពួកដទៃទៀត ត្រូវនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទីដួលដេកនៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ជនទាំងឡាយដែលនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ហើយដួលដេក នៅ តើពួកជនទាំងនោះ បានធ្វើនូវបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ ជ្រាបថា ជនទាំងឡាយណា ជាអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក សម្លាប់ត្រី សម្លាប់សត្វចិញ្ចឹម គឺក្របី ពពែ និងចៀម ហើយ ដាក់លក់ក្នុងទីពានផ្សារលក់សាច់ ជនអ្នកមានកម្មអាក្រក់ទាំងនោះ តែងវេងបាប បានជាជនទាំងនោះ ត្រូវនាយនិរយបាលធ្វើខ្ទេចខ្ទី ហើយដេកនៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គីវាយ ពទ្ធា** សេចក្តីថា ពួកសត្វនរក ត្រូវនាយនិរយបាលចងកដោយខ្សែដែកធំឆេះដោយភ្លើង កន្ត្រាក់មកឲ្យដួល លើផែនដីដែក វាយដោយអាវុធផ្សេងៗ ដែលសុទ្ធតែឆេះដោយភ្លើង ព្រះបាទ

នេមិរាជ ទតឃើញសត្វនរកទាំងនោះទើបត្រាស់សួរ ។ បទថា **អញ្ញោ វិកន្តា** សេចក្ដីថា សត្វនរកដទៃត្រូវកាត់ជាកំណាត់ៗ ។ បទថា **វិលកតា** សេចក្ដីថា សត្វនរកដទៃត្រូវនិរយបាល ចាប់ឲ្យដេកលើផែនដីដែកដែលឆេះទ្រលោម យកកាំបិតចៀរសាច់ ចិញ្ច្រាំធ្វើជាដុំៗ ដេកនៅ ។ បទថា **មច្ឆិកា** បានដល់សម្លាប់ត្រី ។ បទថា **បសុំ** បានដល់ មេគោ ។ បទថា **សូណេសុ បសាយើសុ** សេចក្ដីថា ទុកក្នុងរានសម្លាប់សត្វលក់សាច់ ដើម្បីប្រយោជន៍ដល់ការលក់ដូរចិញ្ចឹមជីវិត ។

មាតលិទេវសារថី បររថបន្តទៅ បង្ហាញនិរយបាលដទៃទៀត ស្ដេចនេមិរាជទតឃើញសត្វនរកទាំងនោះស៊ីមូត្រ និងលាមក កាលត្រាស់សួរមាតលិទេវសារថី ទើបត្រាស់ថា

អន្លង់នេះ ពេញពោរដោយមូត្រ និងករីស មានក្លិនអាក្រក់ មិនស្អាត ស្អុយផ្សាយទៅ ពួកជនអ្នកមានសេចក្ដីស្រេកឃ្លាន គ្របសង្កត់ហើយ ស៊ី ( នូវមូត្រ និងករីសនេះ ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនអ្នកបរិភោគនូវមូត្រ និងករីសនេះ តើពួកជនទាំងនេះបានធ្វើនូវបាបដូចម្ដេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ជាអ្នកបង្កសេចក្ដីទុក្ខ អ្នក

បៀតបៀនមិត្តសម្លាញ់ អ្នកតាំងនៅក្នុងការបៀតបៀន នូវជនដទៃ សព្វៗ កាល ពួកជនទាំងឡាយ មានអំពើលាមកនោះ រមែងរងបាប ជនពាលទាំងឡាយ ជាអ្នកទ្រុស្តមិត្តនោះ តែងស៊ីអាហារចាស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខុទ្ទាបរេតា មនុជា អនេត្តិ** សេចក្តីថា សត្វនរកទាំងនេះ ដែលសេចក្តីឃ្លានគ្របសង្កត់ មិនអាចអត់ធន់សេចក្តីឃ្លានបាន ទើបធ្វើលាមកដែលតាំងនៅអស់កប្ប ក្តៅគគុក ពោរពេញដោយផ្សែងចេះទ្រលោមជាដុំៗ ហើយទំពាស៊ី ។ បទថា **ការណិកា** បានដល់ គំនរទុក្ខ ។ បទថា **វិហេសិកា** បានដល់ ដែលបៀតបៀនមិត្តសម្លាញ់ជាដើម ។ បទថា **មិត្តទ្ទុនោ** សេចក្តីថា សត្វពួកណាជាពាលទំពាស៊ី គឺបរិភោគបាយ ត្រីអាហារ ក្នុងផ្ទះរបស់បុគ្គលទាំងនោះ អង្គុយ ដេកលើអាសនៈដែលគេក្រាលជាកូនឈ្នួល នៅលួចមាសកៈ និងកហាបណៈទៀត សត្វទាំងនោះ ជាអ្នកទ្រុស្តមិត្ត ជាបុគ្គលពាល ទើបទំពាស៊ីនូវលាមកបែបនេះ ។

មាតលិទេវសារថីបររថទៅក្នុងនរកដទៃៗ សត្វនរកទាំងនេះដែលសេចក្តីឃ្លានពាល់ត្រូវ ក៏មិនអាចអត់ទ្រាំនឹងសេចក្តីឃ្លានបាន ទើបធ្វើឈាម និងខ្ទុះជាដុំៗ ទំពាស៊ី ព្រះបាទនេមិរាជទតឃើញដូច្នោះ ទើបត្រាស់គាថាដូច្នេះថា

អន្លង់នេះ ពេញពោរទៅដោយឈាម និងខ្ទុះ មានក្លិនអាក្រក់
មិនស្អាត ស្អុយផ្សាយទៅ ពួកសត្វដែលត្រូវកម្តៅបៀតបៀន
ហើយផឹក ( ឈាម និងខ្ទុះនោះ ) ម្នាលទេពបម្រើ ភ័យមានដល់

ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេពសារថី ខ្ញុំសួរអ្នក ពួកជនដែលមានឈាម និងខ្ទុះជាអាហារនេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជា ដែលមិនជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ សម្លាប់ព្រះអរហន្ត គឺមាតា ឬបិតា ឈ្មោះថា បារជិក ( ក្នុងកាលជាគ្រហស្ថ ) ពួកជនអ្នកមានអំពើលាមកនោះ តែងវេងបាប ជនទាំងនោះ មានឈាម និងខ្ទុះជាអាហារ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យម្ហាភិតត្តា** បានដល់ ត្រូវកម្តៅបៀតបៀន ។ បទថា **ធារាជិកា** សេចក្តីថា ជាអ្នកចាលចាញ់ គឺសម្លាប់មាតាបិតាត្រូវបារាជិកក្នុងកាលជាគ្រហស្ថនោះឯង ។ បទថា **អរហន្តេ** បានដល់ ជាអ្នកសមគួរដល់ការបូជាពិសេស ។ បទថា **ហនន្តិ** សេចក្តីថា សម្លាប់មាតាបិតាជាអ្នកធ្វើកម្ម ដែលគេធ្វើបានដោយលំបាក ម្យ៉ាងទៀត បទថា **អរហន្តេ** លោកសង្គ្រោះយកពុទ្ធសាវកទាំងឡាយផងដែរ ។

មាតលិទេវសារថីបរវថទៅ នាយនិរយបាលត្រង់ឧស្សូទនរកដទៃទៀត យកសន្ទូចដែកដែលឆេះដោយភ្លើងប៉ុនដើមត្នោត ថ្ពក់អណ្តាតសត្វនរកទាញមក ឲ្យសត្វនរកដួលលើផែនដីដែកដែលឆេះដោយភ្លើងឲ្យដេកផ្ងារ យកតម្លក់ដែកថ្ពក់សន្ទឹងនូវស្បែកដូចសន្ទឹងស្បែកគោដូច្នោះ សត្វនរកទាំងនោះ

បម្រះនទៀលដូចត្រីដែលបម្រះនៅលើគោក មិនអាចអត់ធន់នូវទុក្ខនោះបាន ស្រែកថ្ងូរ មានទឹកមាត់ហូរ ព្រះបាទនេមិរាជ កាលសម្តែងដល់មាតលិ-ទេវសារថីនោះ បានត្រាស់ថា

អ្នកចូរមើលនូវសត្វនរក មានអណ្តាតមុតដោយសន្ទូច បីដូចស្បែកដែលគេខ្វារដោយកន្ទេរ ញាប់ញ័រ ដូចត្រីដែលជនបោះទៅលើគោក ព្រោះហេតុអ្វីហ្ន៎ បានជាសត្វនរកទាំងនេះ យំបង្ហៀរទឹកមាត់ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលស៊ីសន្ទូច ដេកនៅ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា មនុស្សទាំងឡាយណានីមួយ ស្ថិតនៅក្នុងតំណែង ជាអ្នកកាត់ថ្លៃទំនិញ ញ៉ាំងទំនិញដែលមានថ្លៃ ឲ្យសាបសូន្យចាកថ្លៃ ( បន្ទាកទំនិញគេ ) ប្រកបដោយអំពើកោង ធ្វើអំពើកោង ព្រោះហេតុចង់បានទ្រព្យ បីដូចជាសន្ទូចដែលគេបិទបាំង ( ដោយនុយ ) ដើម្បីសម្លាប់ត្រី ។ ទីពឹងរបស់អ្នកធ្វើនូវអំពើកោង ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយ មិនមានទេ ពួកជនអ្នកមានអំពើលាមកនោះ តែងវេងបាប បានជាពួកជនទាំងនោះ ជាអ្នកស៊ីសន្ទូចដេកនៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិមេតេ** សេចក្ដីថា ព្រោះហេតុអ្វី សត្វនរកទាំងនោះ ។ បទថា **វណ្ណយន្តា** បានដល់ លេបនូវសន្ទូច ។ បទថា **សណ្ឋានគតា** សេចក្ដីថា បុគ្គលដល់នូវតំណែង គឺតាំងនៅក្នុងតំណែងជាអ្នកវាយតម្លៃទំនិញ ។ បទថា **អគ្ឃេន អគ្ឃំ** សេចក្ដីថា ទទួលតម្លៃទំនិញនោះៗ ជាសំណូក ហើយបន្ថយតម្លៃវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យនោះៗ មានដំរី សេះ ប្រាក់ មាសជាដើម ។ បទថា **កយំ** សេចក្ដីថា កាលបន្ថយតម្លៃនោះៗ រមែងបន្ថយតម្លៃដែលទិញមក អំពីតម្លៃនោះដល់អ្នកទិញទាំងឡាយ កាលគួរឲ្យ ១០០ ក៏ឲ្យត្រឹមតែ ៥០ កាលគួរឲ្យ ៥០ ក៏ឲ្យត្រឹមតែ ២៥ ចំណែកបុគ្គលដែលទិញក្រៅអំពីនេះ ក៏ចែកជាមួយអ្នកវាយតម្លៃនោះកាន់យកតម្លៃនោះ ។ បទថា **កូដេន កូដំ** បានដល់ ការកោងនោះៗ មានកោងដោយជញ្ជីងជាដើម ។ បទថា **ធនលោភហេតុ** សេចក្ដីថា ធ្វើនូវការកោងនោះ ព្រោះហេតុលោភក្នុងទ្រព្យ ។ បទថា **ឆន្នំ យថា វារិចរំ វធាយ** សេចក្ដីថា សត្វទាំងនោះ សូម្បីធ្វើការងារនោះ ក៏បិទបាំងការកោងដែលមនុស្សធ្វើយ៉ាងនោះ ដោយវាចាទន់ភ្លន់ មនុស្សចូលទៅជិតត្រីដែលហែលក្នុងទឹក ដើម្បីសម្លាប់ យកនុយស្រោបផ្លែសន្ទូចសម្លាប់ត្រីនោះ យ៉ាងណា ការបិទបាំងធ្វើនូវការងារនោះ ក៏ដូច្នោះ ។ បទថា **ន ហិ កូដការិស្ស** សេចក្ដីថា ព្រោះថា ឈ្មោះថា ការការពារ រមែងមិនមានដល់បុគ្គលដែលធ្វើការកោង សូម្បីសម្គាល់ថា កម្មរបស់អញដែលបិទបាំងនោះ មិនមានអ្នកណាដឹង ។ បទថា **សកេហិ កម្មេហិ បុរិក្ខិតស្ស** សេចក្ដីថា បុគ្គលនោះ ត្រូវ

កម្មរបស់ខ្លួនរក្សា ក៏មិនបាននូវទីពឹង ។

មាតលិទេវសារថីបររថបន្តទៅទៀត សត្វនរកក្នុងនរកនោះនៅក្នុងរណ្តៅធំ ដែលពេញដោយរងើកភ្លើង បានឮថា សត្វនរកទាំងនោះ ត្រូវនិរយបាលកាន់អាវុធផ្សេងៗ ចាក់សត្វនរកនោះ ដូចនាយគោបាលចាក់គោដែលមិនចូលក្រោលដូច្នោះ នាយនិរយបាលចាប់សត្វនរកទាំងនោះ យកជើងឡើងលើបោះទៅក្នុងនរកនោះ ព្រះបាទនេមិរាជទតឃើញសត្វនរក ធ្លាក់ក្នុងនរកយ៉ាងនោះកាលនឹងត្រាស់សួរមាតលិទេវសារថី ទើបត្រាស់គាថាដូច្នេះថា

ពួកស្ត្រីទាំងនេះ មានខ្លួនដាច់ខ្ទេចខ្ទី មានជាតិអាក្រក់ មានខ្លួនប្រឡាក់ពាសពេញដោយឈាម និងខ្ទុះ មានខ្លួនដាច់រយះរយាយ បីដូចគោទាំងឡាយ ដែលគេពន្លះក្នុងទីសម្លាប់ ផ្គងដើមដៃទាំងឡាយ យំកន្ទក់កន្ទេញ ពួកស្ត្រីទាំងនោះ ( មានខ្លួនត្រឹមចង្កេះ ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានក្អំរមៀលកិនសព្វៗ កាល ។ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញម្នាលមាតលិជាទេវសារថី ខ្ញុំសួរអ្នក ពួកស្ត្រីដែល ( មានខ្លួនត្រឹមចង្កេះ ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានក្អំរមៀលកិនសព្វៗ កាល តើពួកស្ត្រីទាំងនេះ បានធ្វើបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់

ជ្រាបថា ពួកស្ត្រីមានត្រកូល ក្នុងជីវលោកនេះ មានអំពើមិន បរិសុទ្ធ បានប្រព្រឹត្តនូវអំពើជារបស់អសប្បុរស ពួកស្ត្រីទាំងនោះ មានសភាពជាអ្នកលេង លះបង់ស្វាមីហើយ ត្រាច់ទៅរកបុរស ដទៃ ព្រោះហេតុតែកាមគុណ និងល្បែងពាល ពួកស្ត្រីទាំងនោះ ក្នុងជីវលោក លុះញុំាងបុរសដទៃឲ្យត្រេកត្រអាល ទើបមានភ្លើង ឆេះសន្ធោសន្ធៅ មានក្អែករមៀលកិន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នារិ** បានដល់ ស្រីទាំងឡាយ ។ បទថា **សម្បរិភិន្នគត្តា** សេចក្តីថា មានខ្លួនបែក គឺមានសរីរៈដាច់ជុំវិញ ។ បទថា **ឧុជច្ចា** បានដល់ មានជាតិថោកថយ គឺមានរូបប្លែកៗ អធិប្បាយថា គួរខ្ពើម ។ បទថា **វិកន្តា** សេចក្តីថា មានខ្លួនប្រឡាក់ដោយខ្ទុះ និងឈាម ដូចគោទាំង ឡាយដែលមានក្បាលដាច់ ។ បទថា **សេតា ឆិទាតា** សេចក្តីថា លិចចុះក្នុង ផែនដីដែកដែលឆេះសន្ធោសន្ធៅជានិច្ច លិចត្រឹមចង្កេះ ដូចគេដាក់ ។ បទថា **ខជ្ជាតិវត្តន្តិ** សេចក្តីថា នែមាតលិសម្លាញ់ ក្អែកទាំងនេះរមៀលកិនស្រីទាំងនោះ បានឮថា ពេលស្រីទាំងនោះលិចត្រឹមចង្កេះយ៉ាងនេះ ក្អែកដែលឆេះសន្ធោ សន្ធៅតាំងឡើងពីទិសខាងកើត ដូចសំឡេងផ្គរលាន់ ហាក់បីដូចសង្កត់សរីរៈ ឲ្យបែកល្អិតទៅ កាលក្អែកនោះរមៀលទៅតាំងនៅទិសខាងលិច សរីរៈរបស់ស្រី ទាំងនោះក៏ប្រាកដឡើងទៀត ស្រីទាំងនោះមិនអាចអត់ធន់នូវទុក្ខនោះបាន ទើប ផ្គងដើមដៃទ្រហោយំ សូម្បីក្អែកដែលតាំងឡើងពីទិសខាងជើងជាដើម ក៏មាន ន័យដូចគ្នានេះឯង ក្អែកទាំងពីរនោះ តាំងឡើងលើសរីរៈរបស់ស្រីទាំងនោះ ដូច

គាបអំពៅ ឈាមហូរខ្ចាយទៅ ជួនកាល ៣ ក្អំ ជួនកាល ៤ ក្អំ តាំង ឡើងលើសរីរៈរបស់ស្រីទាំងនោះ ព្រោះហេតុនោះ ទើបលោកពោលថា **ខន្ធាតិវត្តន្តិ** ។ បទថា **កោលិត្ថិយាយោ** បានដល់ ជាកុលធីតា តាំងនៅ ក្នុងត្រកូល ។ បទថា **អសតំ អចារុំ** សេចក្ដីថា បានធ្វើកម្មដែលមិនសង្រួម ។ បទថា **ធុត្តរូបា** សេចក្ដីថា ជាស្រីមិនល្អ គឺជាស្រីអាក្រក់ មានជាតិជាអ្នក លេង ។ បទថា **បតិ វិប្បហាយ** សេចក្ដីថា លះបង់នូវស្វាមីរបស់ខ្លួន ចោល ។ បទថា **អចារុំ** បានដល់ គប់រកបុរសដទៃ ។ បទថា **រតិខិឌ្ឌហេតុ** សេចក្ដីថា ព្រោះកាមគុណ ៥ និងព្រោះដើម្បីលេង ។ បទថា **រមាបយិត្វា** សេចក្ដីថា ញុំាងចិត្តរបស់ខ្លួនឲ្យត្រេកអរជាមួយបុរសដទៃ កើតឡើងក្នុង ទីនេះ អធិប្បាយថា កាលបើដូច្នោះ ទើបក្អំមានភ្លើងឆេះសន្ធោសន្ធៅទាំងនេះ កិនសរីរៈរបស់ស្រីទាំងនោះ ដោយអាការយ៉ាងនេះ ។

មាតលិទេវសារថីបររថបន្តទៅ សត្វនរកទាំងនោះ តាំងនៅក្នុងរណ្ដៅធំ ពេញដោយរងើកភ្លើង ឆេះសន្ធោសន្ធៅ បានឮថា សត្វនរកទាំងនោះ ត្រូវ នាយនិរយបាល កាន់អាវុធផ្សេងៗ ចាក់ ដូចនាយគោបាលចាក់គោដែលមិន ចូលក្រោល ចូលដល់នរកនោះដោយប្រការដូច្នេះ ។ លំដាប់នោះ និរយបាល ចាប់សត្វនរកទាំងនោះឲ្យមានជើងឡើងលើ ទម្លាក់ក្នុងរណ្ដៅធំ ព្រះបាទនេមិ- រាជទតឃើញសត្វនរក ធ្លាក់ក្នុងនរកយ៉ាងនោះ កាលត្រាស់សួរមាតលិ- ទេវសារថី ទើបត្រាស់គាថាដូច្នេះថា

ព្រោះហេតុអ្វី បានជាសត្វនរកមួយពួកទៀតនេះ ត្រូវនាយនិរយ-

បាលចាប់ជើង ដោយមានក្បាលសំយុងចុះ ហើយទម្លាក់ទៅក្នុងរណ្ដៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ ដែលមានក្បាលសំយុងចុះ នាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅនរក តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្ដេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ អ្នកមានអំពើជារបស់អសប្បុរស ប្រព្រឹត្តកន្ទងនូវប្រពន្ធទាំងឡាយនៃជនដទៃ សត្វទាំងឡាយប្រាកដដូច្នោះនោះ ឈ្មោះថា ជាអ្នកលួចនូវរបស់ដ៏ថ្លៃថ្លា បានជាសត្វទាំងនោះ ( មានក្បាលសំយុងចុះ ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅ ។ សត្វទាំងឡាយនោះ តែងរងនូវទុក្ខវេទនា ក្នុងនរកទាំងឡាយនោះ អស់ប្រជុំនៃឆ្នាំដ៏ច្រើន ព្រោះថា ទីពឹងទាំងឡាយ របស់បុគ្គលអ្នកធ្វើបាប ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយ មិនមានទេ ពួកសត្វអ្នកមានអំពើលាមកនោះ រមែងរងនូវបាប ទើបបានជាពួកជនទាំងនោះ ( មានក្បាលសំយុងចុះ ) ត្រូវនាយនិរយបាល ទម្លាក់ទៅក្នុងរណ្ដៅដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆរកេ** បានដល់ រណ្ដៅធំដែលពេញដោយ

រងើកសន្ទោសន្ទៅ បានឮថា សត្វនរកទាំងនោះត្រូវនាយនិរយបាលកាន់អាវុធផ្សេងៗ កាប់ ចាក់ វាយដូចនាយគោបាលចាក់គោទាំងឡាយ ដែលមិនចូលក្រោលដូច្នោះ ចូលដល់នរកនោះបែបនេះ លំដាប់នោះ នាយនិរយបាលទាំងឡាយធ្វើសត្វនរកទាំងនោះ ឲ្យមានជើងឡើងលើក្បាលចុះក្រោម ហើយបោះក្នុងរណ្តៅធំនោះ ព្រះបាទនេមិរាជទតឃើញសត្វនរក កំពុងធ្លាក់យ៉ាងនោះ កាលនឹងត្រាស់សួរ ទើបត្រាស់យ៉ាងនេះ ។ បទថា **ឧត្តមភណ្ឌថេណា** បានដល់ អ្នកលួចកណ្ឌៈដ៏ប្រសើរ ដែលមនុស្សទាំងឡាយគប្បីស្រឡាញ់ កាលទូលយ៉ាងនេះហើយ មាតលិទេវសារថី បានញុំាងនរកទាំងនោះឲ្យអន្តរធានទៅ បររថបន្តទៅទៀត សម្តែងនរកដែលជាទីឆេះនៃពួកមិច្ឆាទិដ្ឋិ បានព្យាករសេចក្តីដែលព្រះបាទនេមិរាជត្រាស់សួរថា

ពួកសត្វទាំងឡាយនេះ ខ្ពស់ និងទាប ផ្សេងៗ គ្នា ជាអ្នកត្រដាបត្រដួស មានរូបគួរខ្លាចពន់ពេក ប្រាកដនៅក្នុងនរកទាំងឡាយ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានសេចក្តីទុក្ខវេទនាក្លៀវក្លា ខ្លាចផ្សា ក្តៅក្រហាយក្រៃលែងនេះ តើពួកសត្វទាំងនេះបានធ្វើបាបដូចម្តេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ មានទិដ្ឋិលាមកក្រៃលែង

តែងធ្វើអំពើដ៏ស្មិទ្ធ ព្រោះមោហៈ ទាំងបបួលអ្នកដទៃ ( ឲ្យយល់ ) ក្នុងទិដ្ឋិទាំងឡាយនោះផង ជនទាំងឡាយនោះ មានទិដ្ឋិបាប រមែងរងបាប ទើបបានជាពួកជនទាំងនោះ រងទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សា ក្តៅក្រហាយក្រៃលែង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧច្ចាវចាមេ** បានដល់ សត្វនរកទាំងនេះ ខ្ពស់ និងទាប អធិប្បាយថា ទាំងតូច និងធំ ។ បទថា **ឧបក្កមា** បានដល់ ជាអ្នកប្រកបដោយហេតុការណ៍ ។ បទថា **សុទាបធិដ្ឋិនោ** សេចក្តីថា ជាអ្នកមានធម៌ដ៏លាមកពេញបន្ទុកដោយទិដ្ឋិ មានវត្ថុ ១០ គឺទានមិនមានផល ការបូជាមិនមានផល យញ្ញមិនមានផល ផលវិបាកនៃកម្មដែលធ្វើល្អ ធ្វើអាក្រក់មិនមាន មាតាមិនមាន បិតាមិនមាន សមណព្រាហ្មណ៍មិនមាន សត្វដែលជាឱបបាតិកៈមិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន ។ បទថា **វិស្សាសកម្មានិ** សេចក្តីថា ជាអ្នកអាស្រ័យកម្មដែលធ្វើដោយការស្និទ្ធស្នាល ធ្វើកម្មលាមកមានបែបផ្សេងៗ ដោយមិច្ឆាទិដ្ឋិនោះ ។ បទថា **តេមេ** សេចក្តីថា ជនទាំងនេះ រមែងសោយទុក្ខបែបនេះ ។

មាតលិទេវសារថី ទូលប្រាប់នរកដែលឆេះរបស់ពួកមិច្ឆាទិដ្ឋិទាំងឡាយ ដល់ព្រះបាទនេមិរាជ ដោយប្រការដូច្នេះ ។

ពួកទេវតាក្នុងទេវលោក ក៏បានអង្គុយប្រជុំគ្នាក្នុងទេវសភា ឈ្មោះថាសុធម្មានោះឯង រង់ចាំព្រះបាទនេមិរាជយាងមក ។ ចំណែកសក្កទេវរាជទ្រង់ពិចារណាថា ហេតុអ្វីទើបមាតលិសារថីយឺតយូរ ក៏ជ្រាបហេតុនោះ ទើបទ្រង់ចិន្តនាការថា មាតលិទេវបុត្របង្ហាញនរកទាំងឡាយថា សត្វកើតក្នុងនរកនោះ

ព្រោះធ្វើកម្មនោះដូច្នេះ ដើម្បីសម្តែងភាពជាទូតពិសេសរបស់ខ្លួន តែជន្មាយុរបស់ព្រះបាទនេមិរាជនៅសល់តិច នឹងគប្បីអស់ទៅ ជន្មាយុនោះមិនគប្បីដល់ទីបំផុតនៃការសម្តែងនរក ទ្រង់ត្រិះរិះដូច្នេះហើយ ទើបទ្រង់បញ្ជូនទេវបុត្រមួយអង្គ ដែលមានសម្ទុះរហ័ស ដោយទេវបញ្ជាថា ចូរអ្នកប្រាប់ដល់មាតលីថា សូមយានព្រះបាទនេមិរាជមកដោយរហ័ស ទេវបុត្រនោះ ក៏មកប្រាប់ដោយរហ័ស មាតលិទេវសារថីបានស្តាប់ពាក្យរបស់ទេវបុត្រនោះហើយ ទើបទូលព្រះបាទនេមិរាជថា យើងដំអក់មិនបាន ហើយសម្តែងនរកជាច្រើនក្នុង ៤ ទិសព្រមគ្នានោះឯង ដល់ព្រះបាទនេមិរាជ ពោលគាថាដូច្នេះថា

បពិត្រព្រះរាជា ទីលំនៅរបស់សត្វ អ្នកមានបាបកម្មទាំងឡាយ
ស្ថានរបស់សត្វ អ្នកមានអំពើអាក្រក់ទាំងឡាយ និងគតិរបស់
សត្វអ្នកទ្រុស្តសីលទាំងឡាយ ព្រះអង្គទ្រង់បានជ្រាបហើយ
បពិត្រព្រះរាជា អ្នកស្វែងរកគុណដ៏ធំ សូមទ្រង់ស្តេចទៅក្នុង
សម្នាក់ទេវរាជឥឡូវនេះ ដូច្នេះ ។

គាថានោះមានសេចក្តីថា បពិត្រមហារាជ ទ្រង់ជ្រាបលំនៅរបស់សត្វដែលមានកម្មគ្រោតគ្រាត ព្រោះបានទតនិរយបាលដែលជាលំនៅរបស់ពួកសត្វនរក ដែលមានកម្មលាមកនេះ ។ បទថា **ទុស្សីលានញ្ច យា គតិ** សេចក្តីថា សេចក្តីសម្រេចនោះរបស់ព្រះអង្គ ក៏ទ្រង់ជ្រាបហើយ ឥឡូវនេះសូមទ្រង់យានឡើងទៅមើលទិព្វសម្បត្តិ ក្នុងសម្នាក់របស់សក្កទេវរាជចុះ ។

**និរយកណ្ឌ ចប់**

កាលទូលយ៉ាងនេះហើយ មាតលិទេវសារថី ក៏បររថសំដៅទៅកាន់ទេវលោក ព្រះបាទនេមិរាជ កាលយាងទៅកាន់ទេវលោក ទតឃើញវិមានដែលប្រតិស្ឋានក្នុងអាកាសរបស់ទេពធីតាព្រះនាមពិរណី មានកំពូល ៥ សម្រេចហើយដោយកែវមណីទំហំ ១២ យោជន៍ ប្រដាប់ដោយអលង្ការទាំងពួង សម្បូរដោយឧទ្យាន និងស្រះបោក្ខរណី មានដើមកប្បព្រឹក្សព័ទ្ធជុំវិញ និងទតឃើញទេពធីតានោះ អង្គុយលើសេយ្យាសនៈ ខាងក្នុងកូដាគារ ពួកអប្សរមួយពាន់ចោមរោម បើកមណីសីហបញ្ជរមើលមកក្រៅ ទើបត្រាស់គាថាសួរមាតលិទេវសារថីៗ ក៏ព្យាករដល់ព្រះអង្គ ។

វិមាននេះ មានកំពូល ៥ ដែលយើងឃើញប្រាកដ មាននាងនារី
មានអានុភាពធំ ប្រដាប់ដោយកម្រងផ្កា សម្ដែងនូវទេវឫទ្ធិ មាន
ប្រការផ្សេងៗ នៅកណ្ដាលជំណោកក្នុងវិមាននោះ ម្នាលទេពបម្រើ
សេចក្ដីរីករាយ មានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិ-
ទេវសារថី ខ្ញុំសួរអ្នក នារីដែលបានដល់ស្ថានសួគ៌ ហើយរីករាយ
ក្នុងវិមាន តើនារីនេះ បានធ្វើកុសលដូចម្ដេច ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល
នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ
ដែលមិនទ្រង់ជ្រាបថា ពិរណី ដែលទ្រង់ធ្លាប់ជ្រាបហើយ ជាទាសី
កើតហើយ ក្នុងផ្ទៃនៃទាសី ក្នុងផ្ទះនៃព្រាហ្មណ៍ ក្នុងជីវលោក
នាងពិរណីនោះដឹងថា ភិក្ខុជាភ្ញៀវ មានកាលដល់ហើយ (ហើយ

ក៏អង្គាសចង្ហាន់ប្រគេនភិក្ខុនោះ ) ហាក់ដូចជាមាតាដែលត្រេកអរ ចំពោះបុត្តរបស់ខ្លួន នាងជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនាងរីករាយក្នុងវិមាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បញ្ចថូបំ** សេចក្ដីថា ប្រកបដោយកំពូល ៥ ។ បទថា **មាលាបិលន្ធា** សេចក្ដីថា ប្រដាប់ដោយសព្វាភរណៈ មានគ្រឿងប្រដាប់ និងកម្រងផ្កាជាដើម ។ បទថា **តត្ថច្ឆតី** សេចក្ដីថា នៅក្នុងវិមាននោះ ។ បទថា **ឧច្ចាវចំ ឥទ្ធិ វិកុព្វមានា** សេចក្ដីថា សម្ដែងទេវឫទ្ធិមានប្រការផ្សេងៗ ។ បទថា **ទិស្វា** សេចក្ដីថា ខ្ញុំជាអ្នកឃើញការប្រព្រឹត្តទៅនោះតាំងនៅ ។ បទថា **វិត្តី** បានដល់ សេចក្ដីត្រេកអរ ។ បទថា **វិន្ទតិ** បានដល់ រមែងបានចំពោះ អធិប្បាយថា យើងមានការត្រេកអរ ហាក់ដូចជារបស់មាន គឺដែលសេចក្ដីត្រេកអរគ្របសង្កត់ហើយ ។ បទថា **អាមាយទាសី** សេចក្ដីថា ជាទាសីកើតក្នុងគភ៌របស់ទាសីក្នុងផ្ទះ ។ បទថា **អហុ ព្រាហ្មណស្ស** សេចក្ដីថា ទេពធីតានោះ បានជាទាសីរបស់ព្រាហ្មណ៍ម្នាក់ក្នុងកាលនៃព្រះកស្សបទសពល ។ បទថា **សា បត្តកាលំ** សេចក្ដីថា ព្រាហ្មណ៍នោះ បានបរិច្ចាគសាលាកភត្ត ៨ ដល់សង្ឃ ព្រាហ្មណ៍នោះទៅផ្ទះហៅកិរិយាមកប្រាប់ថា នែនាងដ៏ចម្រើន ស្អែកនេះ ចូរនាងក្រោកឡើងអំពីព្រលឹម រៀបចំសាលាកភត្ត ៨ ធ្វើឲ្យមានតម្លៃ ១ កហាបណៈ សម្រាប់ភិក្ខុមួយរូបៗ ព្រាហ្មណ៍បដិសេធថា នែអ្នក ឈ្មោះថាភិក្ខុទាំងឡាយជាអ្នកលេងខ្ញុំមិនអាច ធីតាទាំងឡាយរបស់ព្រាហ្មណ៍នោះ ក៏បដិសេធយ៉ាងនោះដូចគ្នា

ព្រាហ្មណ៍ពោលនឹងទាសីថា នាងអាចដែរឬទេ ទាសីនោះទទួលថា អាច ហើយរៀបចំបបរ ខាទនីយៈ និងកត្តាហារជាដើមដោយគោរព បាន សាលាកកត្តហើយ ដឹងច្បាស់នូវភ្ញៀវ ដែលបានកាលដែលមកហើយ និមន្ត ឲ្យគង់លើអាសនៈដែលក្រាល ដែលលាបដោយគោម័យស្រស់ ធ្វើផ្កាដទៃ ខាងមុខក្នុងផ្ទះ ។ បទថា **មាតាវ បុត្តំ** សេចក្តីថា ទាសីនោះត្រេកអរ ក្រៃលែង អស់កាលជានិច្ច អន្តាសដោយគោរព បានប្រគេនរបស់ណាមួយ ដែលជារបស់ខ្លួន ដូចមាតាត្រេកអរក្រៃលែងចំពោះបុត្ត ដែលបែកទៅយូរ ត្រឡប់មក ដូច្នោះ ។ បទថា **សញ្ញមា សំវិភាគា ច** សេចក្តីថា ទាសីនោះ បានជាអ្នកមានសីល និងមានចាគៈ ព្រោះហេតុនោះ ទើបត្រេកអរក្នុងវិមាន នេះដោយសីល និងចាគៈនោះ ។ ម្យ៉ាងទៀត បទថា **សញ្ញមា** សេចក្តីថា ប្រកបដោយការទូន្មានឥន្ទ្រិយ ។

កាលពោលយ៉ាងនេះហើយ មាតលិទេវសារថីបានបររថតទៅ សម្តែង ៧ វិមាន របស់ទេវបុត្រឈ្មោះសោណទិន្នៈ ព្រះបាទនេមិរាជទតឃើញវិមាន ទាំងនោះ និងសិរីសម្បត្តិរបស់សោណទិន្នទេវបុត្រនោះ ទើបត្រាស់សួរដល់ កម្ម ដែលទេវបុត្រនោះបានធ្វើហើយ សូម្បីមាតលិទេវសារថីក្រៅពីនេះ ក៏ បានទូលប្រាប់ដល់ព្រះអង្គ ។

វិមានមាសទាំង ៧ ដែលបុញ្ញកម្មតាក់តែងហើយ មានពន្លឺរុងរឿង ផ្សព្វផ្សាយទៅ មានទេវបុត្រមានឫទ្ធិច្រើន ប្រដាប់ហើយដោយ អាភរណៈគ្រប់បែប មានពួកនាងទេពធីតាចោមរោមហើយ ដើរ

ប្រទក្សិណដោយជុំវិញ ក្នុងវិមានទាំង ៧ នោះ ។

ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាលមាតលិ-ទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តនេះ បានធ្វើនូវកុសលដូចម្តេច ទើបដល់នូវស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

មាតលិទេពសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តនេះ ជាគហបតីឈ្មោះសោណទិន្ន ជាម្ចាស់នៃទាន ( ក្នុងដែនកាសី ) គាត់បានសាងកុដិសម្រាប់នៅ ៧ ខ្នង ឧទ្ទិសចំពោះបព្វជិត ។ គាត់បានបម្រើភិក្ខុទាំងឡាយ ដែលអាស្រ័យនៅក្នុងកុដិនោះដោយគោរព បានប្រគេនចីវរសម្រាប់ស្លៀកដណ្តប់ផង ភត្តាហារផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះលោកអ្នកមានចិត្តត្រង់ទាំងឡាយ ដោយចិត្តជ្រះថ្លា ។ គាត់រក្សាឧបោសថប្រកបដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយបក្ខផង គាត់ជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគាត់រីករាយក្នុងវិមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧគ្គុល្លមានា** បានដល់ រុងរឿង ។ បទថា **អាភេន្តិ** សេចក្តីថា ពន្លឺភ្លឺស្វាងដូចព្រះអាទិត្យដែលទើបនឹងរះ ។ បទថា **តត្ថ** សេចក្តីថា ក្នុងវិមានទាំង ៧ ដែលតាំងរៀងគ្នានោះ មានទេវបុត្រមួយអង្គ

ឈ្មោះសោណទិន្នៈ បពិត្រមហារាជ ទេវបុត្រអង្គនេះ កាលមុន ក្នុងកាលនៃព្រះកស្សបទសពល ជាគហបតីឈ្មោះសោណទិន្នៈ ជាទានបតី ក្នុងនិគមមួយកន្លែង ក្នុងកាសិករដ្ឋ ឲ្យគេធ្វើកុដិ ៧ ខ្នង ឧទ្ទិសដល់បព្វជិតទាំងឡាយជាអ្នកបម្រើភិក្ខុទាំងឡាយដែលនៅក្នុងកុដិនោះៗ ដោយបច្ច័យ ៤ ដោយគោរព និងធ្វើឧបោសថ សង្រួមក្នុងសីលទាំងឡាយជានិច្ច កាលចុតិចាកអត្តភាពនោះហើយ ទើបកើតក្នុងវិមាននេះ ហើយរីករាយ ។

ម្យ៉ាងទៀត បទថា **ចាដិហារិយបក្ខញ្ច** នេះ ក្នុងគាថានោះ លោកពោលសំដៅយកតិថីទី ៧ និងតិថីទី ៩ ដែលជាតិថីទទួល និងជូនដំណើរនៃអដ្ឋមីឧបោសថ និងតិថិទី ១៣ និងបាដិបទដែលជាតិថីទទួលជូនដំណើរនៃចាតុទ្ទសីឧបោសថ និងបណ្ណរសីឧបោសថ ។

កាលពោលកម្មរបស់សោណទិន្នទេវបុត្រយ៉ាងនេះហើយ មាតលិទេវសារថីក៏បររថទៅ បង្ហាញវិមានកែវផលិកដែលមានកម្ពស់ ២៥ យោជន៍ ប្រកបដោយសសរសម្រេចដោយកែវ ៧ ប្រការច្រើនរយដើម ប្រដាប់ដោយកំពូលច្រើនរយ មានកណ្ដឹងជាជួរដោយជុំវិញ មានទង់ដែលសម្រេចដោយមាស និងប្រាក់យ៉ាងល្អ ប្រដាប់ដោយឧទ្យាន និងព្រៃដ៏វិចិត្រដោយផ្កាផ្សេងៗ ប្រកបដោយស្រះបោក្ខរណី គួរត្រេកអរ មានវេទិកាជាទីត្រេកអរ ដេរដាសទៅដោយទេពអប្សរដែលឈ្លាសក្នុងការរាំ ច្រៀង និងប្រគំជាដើម ព្រះបាទនេមិរាជទតឃើញវិមានកែវផលិកនោះ មានព្រះហឫទ័យត្រេកអរ ត្រាស់សួរដល់កុសលកម្មនៃទេពអប្សរទាំងនោះ មាតលិទេវសារថីក៏បានទូលប្រាប់ដល់

ទ្រន់ដូចគ្នា ។

វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការនៃកែវផលិក ពាសពេញដោយពួកនារីដ៏ប្រសើរ រុងរឿងដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និងច្រៀងទាំងពីរ ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើនារីទាំងនេះបានធ្វើកុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកនារីណានីមួយ ក្នុងជីវលោកនេះ មានសីលជាឧបាសិកា ត្រេកអរក្នុងទាន មានចិត្តជ្រះថ្លាជានិច្ច តាំងនៅក្នុងសច្ចធម៌ មិនប្រហែសធ្វេសក្នុងឧបោសថ ជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនារីទាំងនោះ រីករាយក្នុងវិមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្យម្ហំ** ប្រែថា វិមាន មានពាក្យអធិប្បាយថា ប្រាសាទ ។ បទថា **ផលិកាសុ** បានដល់ ជញ្ជាំងកែវផលិក គឺជញ្ជាំងដែលសម្រេចដោយកែវមណីស ។ បទថា **នារីវរគណាកិណ្ណំ** បានដល់ ដេរដាសដោយពួកទេពអប្សរដ៏ប្រសើរ ។ បទថា **កូដាគារវរោចិតំ** សេចក្តីថា សន្សំ គឺរួបរួម គឺចម្រើនដោយផ្ទះកំពូលដ៏ប្រសើរទាំងឡាយ ។ បទថា

**ឧភយំ** សេចក្តីថា ស្អាតដោយការរាំ និងការច្រៀងទាំងពីរយ៉ាង ។ បទថា **យា កាចិ** នេះ លោកពោលដោយមិនកំណត់ក៏ពិត តែទោះជាយ៉ាងនោះ គប្បីជ្រាបទេពអប្សរទាំងនោះថា ជាឧបាសិកាក្នុងក្រុងពារាណសី ក្នុងកាល នៃព្រះកស្សបសម្ពុទ្ធ បានរួមគ្នាជាគណៈធ្វើបុណ្យទាំងឡាយ ដែលមាន ប្រការដូចពោលហើយខាងដើមប៉ុណ្ណោះ ទើបដល់នូវសម្បត្តិនោះ ។

លំដាប់នោះ មាតលិទេវសារថីនោះ បររថទៅ បង្ហាញវិមានកែវមណី មួយដល់ព្រះបាទនេមិរាជ វិមានកែវមណីនោះ ប្រតិស្ឋានក្នុងភូមិភាគដែល រាបស្មើ បរិបូណ៌ដោយកម្ពស់ បញ្ចេញរស្មីដូចមណីបពិត គឹកកងដោយ សំឡេងច្រៀង រាំ ប្រគំ កុះករដោយទេវបុត្រជាច្រើន ព្រះបាទនេមិរាជទត ឃើញដូច្នេះ ទើបត្រាស់សួរដល់កុសលកម្មរបស់ទេវបុត្រទាំងនោះ សូម្បី មាតលិទេវសារថី ក៏បានក្រាបទូលដល់ព្រះអង្គដូចគ្នា ។

វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំង ជា វិការនៃកែវពៃទូរ្យ ប្រកបដោយភូមិភាគ ចែករំលែកដោយចំណែក ។ ( ក្នុងវិមាននេះ ) មានសូរសំឡេងទិព្វលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំគួរស្តាប់ ជាទីរីករាយនៃចិត្ត ។ សំឡេង ដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែល ឃើញ ទាំងមិនដែលឮឡើយ ទើបតែបានដឹង ។ ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះបានឃើញ ម្នាលមាតលិទេវ-សារថី ខ្ញុំសួរអ្នក តើពួកទេវបុត្តទាំងនេះ ធ្វើកុសលកម្មដូចម្តេច

ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា មានសីល ជាឧបាសក ក្នុងជីវលោកនេះ បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និង ស្ពាន ប្រតិបត្តិព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយ គោរព ព្រមទាំងបានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ ជនទាំងឡាយនោះ បានរក្សាឧបោសថ ប្រកប ដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ និងជាអ្នកចែកទាន ទើបជនទាំង ឡាយនោះ រីករាយក្នុងវិមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេឡុរិយាសុ** បានដល់ ជញ្ជាំងកែវពៃទូរ្យ ។ បទថា **ឧបេតំ ភូមិភាគេហិ** សេចក្តីថា ប្រកបដោយភូមិភាគគួរជាទីត្រេកអរ ។ បទថា **អាលម្ពរា មុទិង្គា ច** សេចក្តីថា គ្រឿងតន្ត្រីទាំងនេះ រមែងបន្លឺ សំឡេងក្នុងវិមាននេះ ។ បទថា **នច្ចគីតា សុវាទិតា** សេចក្តីថា ការរាំ និង ការច្រៀង មានប្រការផ្សេងៗ និងការប្រគំតន្ត្រីដទៃៗ រមែងប្រព្រឹត្តទៅក្នុង វិមាននេះ ។ បទថា **ឃរំ គតំ** បានដល់ ដល់នូវការៈដែលគួរត្រេកអរក្នុងចិត្ត

យ៉ាងនេះ ។ បទថា **យេ កេចិ** នេះ លោកពោលដោយមិនកំណត់ក៏ពិត តែទោះជាយ៉ាងនោះ គប្បីជ្រាបទេវបុត្រទាំងនោះ ថាជាឧបាសកអ្នកពារាណសី ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ បានរួមគ្នាជាគណៈធ្វើបុណ្យទាំងនេះ ទើបដល់នូវទិព្វសម្បត្តិនោះ ។ បទថា **បដិបាទយុំ** ក្នុងគាថានោះ សេចក្ដីថា ឲ្យដល់ គឺបានថ្វាយដល់ព្រះអរហន្តទាំងនោះ ។ បទថា **បច្ចយំ** បានដល់គិលានប្បច្ច័យ ។ បទថា **អធំសុ** សេចក្ដីថា បានថ្វាយទានមានប្រការផ្សេងៗ យ៉ាងនេះ ។

មាតលិទេវសារថីនោះ ទូលប្រាប់កម្មរបស់ទេវបុត្រទាំងនោះ ដល់ព្រះបាទនេមិរាជដោយប្រការដូច្នេះហើយ បររថតទៅបង្ហាញវិមានកែវផលិកមួយទៀត វិមានកែវផលិកនោះ ប្រដាប់ដោយកំពូលមិនមែនតិច ប្រដាប់ដោយព្រៃទាបៗ ដែលគ្របដណ្ដប់ដោយផ្កាផ្សេងៗ ចោមរោមទៅដោយស្ទឹងមានទឹកថ្លាស្អាត ខ្ទៀវខ្ទារទៅដោយហ្វូងបក្សីផ្សេងៗ មានពួកទេពអប្សរចោមរោម ជាលំនៅរបស់ទេវបុត្រអ្នកមានបុណ្យមួយអង្គនោះឯង ព្រះបាទនេមិរាជទតឃើញវិមាននោះ មានព្រះហឫទ័យត្រេកអរ ទើបត្រាស់សួរដល់កុសលកម្មរបស់ទេវបុត្រនោះ សូម្បីមាតលិទេវសារថីក៏បានទូលប្រាប់ដល់ព្រះអង្គដូចគ្នា ។

វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អហើយ រុងរឿងដោយជញ្ជាំង ជា
វិការនៃកែវផលិក ដេរដាសដោយពួកនាងនារីដ៏ប្រសើរ ចម្រើន
ដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និង
ច្រៀងទាំងពីរយ៉ាង មានស្ទឹងប្រកបដោយរុក្ខជាតិ មានផ្កាផ្សេងៗ

ហូរព័ទ្ធជុំវិញ ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តនេះ បានធ្វើនូវកុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយ ក្នុងវិមាន ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនុ៎ះ ជាគហបតី ជាម្ចាស់នៃ ទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូង ទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះពួកព្រះអរហន្ត អ្នកមានចិត្តត្រង់ ដោយ ចិត្តជ្រះថ្លា បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយ-បក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វៗ កាល ជាអ្នកសង្រួមនូវ ឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆន្នា** សេចក្តីថា ទឹកស្ទឹងមួយខ្សែហូរ ជុំវិញវិមាននោះ ។ បទថា **ទុមាយុតា** សេចក្តីថា ស្ទឹងនោះប្រកបដោយ ដើមឈើ មានផ្កាផ្សេងៗ ។ បទថា **មិថិលាយំ** សេចក្តីថា បពិត្រមហារាជ

ទេវបុត្រនេះ ជាគហបតីម្នាក់ក្នុងមិថិលានគរវិទេហរដ្ឋ ក្នុងកាលសាសនាព្រះកស្សបសម្ពុទ្ធ បានជាទានបតី គហបតីនោះ ធ្វើកុសលកម្ម មានដាំសួនច្បារជាដើម ទើបដល់នូវទិព្វសម្បត្តិបែបនេះ ។

កាលទូលប្រាប់កម្ម ដែលទេវបុត្រនោះធ្វើ ដល់ព្រះបាទនេមិរាជយ៉ាងនេះហើយ មាតលិទេវសារថីក៏បររថតទៅ បង្ហាញវិមានកែវពៃទូរ្យមួយទៀត ដែលដូចគ្នានឹងវិមានមុននោះឯង ព្រះបាទនេមិរាជទតឃើញវិមាននោះ ទើបត្រាស់សួរដល់បុព្វកម្មរបស់ទេវបុត្រ ដែលប្រកបដោយសម្បត្តិនោះ ឯមាតលិទេវសារថីក៏បានទូលដល់ព្រះអង្គដូចគ្នា

វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការនៃកែវផលិក ដេរដាសដោយពួកនារីដ៏ប្រសើរ ចម្រើនដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយការច្រៀងនិងការរាំទាំងពីរយ៉ាង មានស្ទឹងប្រកបដោយឈើ មានផ្កាផ្សេងៗហូរព័ទ្ធជុំវិញ មានឈើទាំងឡាយជាច្រើន គឺដើមកែស ក្ងិដ្ឋស្វាយ សាលព្រឹក្ស ព្រីង ទន្លាប់ មាក់ប្រ៉ែន សុទ្ធសឹងមានផ្លែជានិច្ច ។

ម្នាលទេពបម្រើ សេចក្ដីត្រេកអរ មានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្តអង្គនេះបានធ្វើកុសលកម្មដូចម្ដេច ទើបដល់ស្ថានសួគ៌ រីករាយក្នុងវិមាន ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល

នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូង ទឹក បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលជាអ្នកមានចិត្តត្រជាក់ដោយគោរព បានថ្វាយនូវចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា គហបតីនោះ បានទាំងរក្សាឧបោសថប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆឌ្ឍា** សេចក្តីថា ស្ទឹងមួយខ្សែហូរជុំវិញវិមាននោះ ។ បទថា **ទុមាយុតា** សេចក្តីថា ស្ទឹងនោះប្រកបដោយដើមឈើមានផ្កាផ្សេងៗ ។ បទថា **មិថិលាយំ** សេចក្តីថា បពិត្រមហារាជ ទេវបុត្រនេះ ជាគហបតីម្នាក់ក្នុងមិថិលានគរវិទេហរដ្ឋ ក្នុងកាលនៃព្រះកស្សបសម្ពុទ្ធ បានជាទានបតី ធ្វើបុញ្ញកម្មទាំងនេះ ទើបដល់នូវទិព្វសម្បត្តិនេះ ។

កាលមាតលិទេវសារថីនោះ ទូលប្រាប់កម្មដែលទេវបុត្រនោះធ្វើ ដល់ព្រះបាទនេមិរាជយ៉ាងនេះហើយ មាតលិទេវសារថីក៏បររថបន្តទៅទៀត បង្ហាញវិមានកែវពៃទូរ្យមួយទៀត ដូចគ្នានឹងវិមានមុននោះឯង ព្រះបាទនេមិរាជ

ត្រាស់សួរដល់កម្ម ដែលទេវបុត្រនោះសោយនូវទិព្វសម្បត្តិ ក្នុងវិមាននោះ មាតលិទេវសារថីក៏ក្រាបទូលដល់ព្រះអង្គដូចគ្នា ។

វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការនៃកែវពៃទូរ្យ ប្រកបដោយកូមិភាគ បែកវាស់ដោយចំណែក ( ក្នុងវិមាននោះ ) មានសូរសព្ទជាទិព្វលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំគួរស្តាប់ ជាទីរីករាយនៃចិត្ត ។ សំឡេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ទើបតែនឹងបានដឹង ។ ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងពារាណសី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា ។ ទេវបុត្តនោះ បានរក្សាឧបោសថប្រកបដោយ

អដ្ឋ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបទេវបុត្ត នោះ រីករាយក្នុងវិមាន ដូច្នេះ ។

មាតលិទេវសារថីនោះ ទូលប្រាប់កុសលកម្មដល់ព្រះបាទនេមិរាជយ៉ាង នេះហើយ ក៏បររថបន្តទៅទៀត សម្តែងវិមានមាស ដែលមានរស្មីដូចព្រះ អាទិត្យទើបនឹងរះ ព្រះបាទនេមិរាជឃើញសម្បត្តិរបស់ទេវបុត្រ ដែលនៅ ក្នុងវិមានមាសនោះ មានព្រះហឫទ័យត្រេកអរ ទើបត្រាស់សួរដល់កម្មដែល ទេវបុត្រនោះធ្វើ ឯមាតលិទេវសារថីក៏ក្រាបទូលដល់ព្រះអង្គដូចគ្នា ។

វិមាននេះ ជាវិការនៃមាស ដែលបុញ្ញកម្មនិម្មិតហើយ ដូចព្រះ អាទិត្យទើបរះឡើង មានពណ៌ក្រហម មានមណ្ឌលធំ ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំ ព្រោះ ឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្តអង្គនេះ បាន ធ្វើកុសលកម្មដូចម្តេច ទើបដល់នូវស្ថានសួគ៌ ហើយរីករាយ ក្នុងវិមាន ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្តអង្គនេះ ជាគហបតី ជាម្ចាស់នៃ ទាន ក្នុងក្រុងសាវត្ថី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និង

ស្ថាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ ជាអ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង ( គិលានប្បច្ច័យ ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ គហបតីនោះ បានរក្សាឧបោសថ ប្រកបដោយ អង្គ ៨ ប្រការ អស់តិថីទី ១៤ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតី នោះ រីករាយក្នុងវិមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទយមាទិច្ចោ** បានដល់ ព្រះអាទិត្យរះ ឡើងដំបូង ។ បទថា **សាវត្ថិយំ** សេចក្តីថា ទេវបុត្រនោះជាទានបតីក្នុងក្រុង សាវត្ថី ក្នុងសាសនានៃព្រះកស្សបសម្ពុទ្ធ ។

ក្នុងពេលដែលមាតលិទេវសារថី ទូលវិមានទាំងឡាយ ៨ នេះដោយ ប្រការដូច្នេះ សក្កទេវរាជទ្រង់ត្រិះរិះថា មាតលិនេះ យឺតយូរពន់ពេក ទើប បញ្ជូនទេវបុត្រដែលជាអ្នកឈ្លាសវៃដទៃទៀតទៅដោយទេវបញ្ជាថា ចូរអ្នកទៅ ប្រាប់ដល់មាតលិថា សក្កទេវរាជឲ្យហៅអ្នក ទេវបុត្រនោះក៏ទៅដោយរហ័ស ប្រាប់ដល់មាតលីឲ្យជ្រាប មាតលិទេវសារថីបានស្តាប់ពាក្យរបស់ទេវបុត្រ នោះ ត្រិះរិះថា ឥឡូវនេះ អញមិនអាចបង្អែបង្អង់បានឡើយ ទើបបង្ហាញ វិមានជាច្រើនរួមគ្នាតែម្តង ព្រះបាទនេមិរាជត្រាស់សួរដល់កម្មរបស់ទេវបុត្រ ក្នុងវិមាននោះៗ មាតលិទេវសារថីបានទូលដល់ព្រះរាជាដូចគ្នា ។

វិមានទាំងឡាយនេះ ជាវិការនៃមាស មានប្រមាណច្រើន ដែល
បុញ្ញកម្មនិម្មិតហើយ តាំងនៅក្នុងអាកាស មានពន្លឺដ៏រុងរឿង ដូច
ជាផ្លេកបន្ទោរក្នុងចន្លោះនៃមេឃ ក្នុងវិមានទាំងឡាយនោះ មាន
ពួកទេវតាមានឫទ្ធិច្រើន ស៊ឹងប្រដាប់ដោយគ្រឿងអាភរណៈគ្រប់
បែប មានពួកនាងទេពអប្សរចោមរោមហើយ ប្រទក្សិណវិលវង់
ដោយជុំវិញ ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំ ព្រោះឃើញ
ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកទេវបុត្តទាំងនេះ បានធ្វើ
កុសលកម្មដូចម្តេច ទើបដល់នូវស្ថានសួគ៌ រីករាយក្នុងវិមាន ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល
នៃបុញ្ញកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់
ជ្រាបថា ពួកទេវបុត្តទាំងនោះ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ
តាំងនៅស៊ប់ ដោយសទ្ធាក្នុងព្រះសទ្ធម្ម ដែលព្រះមានព្រះភាគ
ទ្រង់ប្រកាសទុកល្អហើយ បានធ្វើតាមនូវពុទ្ធវចនៈ របស់ព្រះ
សាស្តា បពិត្រព្រះរាជា ស្ថានទាំងឡាយ ដែលទ្រង់ក្រឡេក
ឃើញហើយ គឺជាស្ថានរបស់ទេវបុត្តទាំងឡាយនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេហាយសាមេ** សេចក្តីថា វិមានទាំងនេះ
អណ្តែតនៅក្នុងនភាកាស ព្រះបាទនេមិរាជត្រាស់ថា វិមានដែលតាំងនៅក្នុង
អាកាសទាំងនេះ តាំងនៅដោយល្អក្នុងអាកាសនោះឯង ។ បទថា **វិជ្ជុវណ្ណ-**

**ឃនន្តរេ** សេចក្តីថា ហាក់បីដូចផ្ទៃកបន្ទោរ ដែលវាសក្នុងចន្លោះពពក ។ បទថា **សុនិម្មិតាយ** សេចក្តីថា តាំងមាំដោយល្អ ព្រោះមកដោយមគ្គ មានអធិប្បាយថា បពិត្រមហារាជ ទេវបុត្រទាំងនេះបួសក្នុងសាសនារបស់ព្រះកស្សបសម្ពុទ្ធ ដែលជានេយ្យានិកធម៌ក្នុងកាលមុន ជាអ្នកមានសីលបរិសុទ្ធ បំពេញសមណធម៌ ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មិនអាចញ៉ាំងអរហត្តឲ្យកើត ចុតិអំពីអត្តភាពនោះហើយ កើតក្នុងវិមានទាំងនេះ បពិត្រព្រះរាជា ទីទាំងនេះ ជាទីដែលស្ថិតនៅរបស់សាវក ព្រះកស្សបសម្ពុទ្ធទាំងនោះ ដែលទ្រង់ទត ដូច្នេះ សូមទ្រង់ទតចុះ ។

មាតលិទេវសារថី សម្តែងវិមានដែលអណ្តែតក្នុងអាកាសដល់ព្រះបាទនេមិរាជយ៉ាងនេះហើយ កាលធ្វើនូវឧស្សាហៈដើម្បីយាងទៅកាន់សម្នាក់របស់សក្កទេវរាជ ទើបទូលថា

បពិត្រមហារាជ ស្ថានរបស់សត្វ អ្នកមានបាបកម្ម ទ្រង់
បានជ្រាបហើយ ព្រោះទ្រង់ទតឃើញនូវលំនៅ ( របស់សត្វ )
ទាំងស្ថានរបស់សត្វ អ្នកមានកល្យាណកម្ម ក៏ទ្រង់ជ្រាបហើយ
បពិត្រព្រះរាជា ទ្រង់ស្វែងរកកុសលធម៌ ឥឡូវនេះ សូមទ្រង់
យាងទៅក្នុងសម្នាក់នៃទេវរាជ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាវាសំ** សេចក្តីថា បពិត្រមហារាជ ទ្រង់ទតឃើញលំនៅរបស់សត្វនរកមុនហើយ ទ្រង់ជ្រាបលំនៅរបស់សត្វមានកម្មលាមកទាំងឡាយ ម្យ៉ាងទៀត កាលទ្រង់ទតវិមានដែលអណ្តែតក្នុងអាកាស

ទាំងនេះ ទ្រង់ជ្រាបលំនៅរបស់អ្នកមានកម្មស្អាតហើយ សូមទ្រង់ទតទិព្វ-សម្បត្តិក្នុងសម្នាក់របស់សក្កទេវរាជ ក្នុងកាលឥឡូវនេះចុះ ។

កាលទូលយ៉ាងនេះហើយ មាតលិទេវសារថីក៏បររថបន្តទៅ បង្ហាញភ្នំសត្តបរិភណ្ឌ ដែលនៅជុំវិញភ្នំសិនេរុបព៌ត ។ ព្រះសាស្ដា កាលត្រាស់ការដែលព្រះបាទនេមិរាជ ទតឃើញបព៌តទាំងនោះ ត្រាស់សួរមាតលិទេវសារថីឲ្យជាក់ច្បាស់ ទើបត្រាស់ថា

ព្រះបាទនេមិមហារាជ ទ្រង់ស្ថិតនៅលើទិព្វយាន មានសេះជាវាហនៈ ដែលទឹមដោយសេះសិន្ធព ១ ពាន់ កាលស្ដេចកំពុងយាងទៅ ទ្រង់ក្រឡេកឃើញភ្នំទាំងឡាយ ក្នុងចន្លោះសីទន្តរ-សមុទ្ទ លុះទ្រង់ទតឃើញហើយ ទ្រង់ត្រាស់ហៅទេវសារថី សួរថា ភ្នំទាំងនោះ តើឈ្មោះអ្វីខ្លះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សហស្សយុត្តំ** សេចក្ដីថា ទឹមដោយសេះសិន្ធព ១ ពាន់ ។ បទថា **ហយវាហឹ** សេចក្ដីថា សេះទាំងឡាយនាំទៅ ។ បទថា **ទិព្វយានមធិដ្ឋិតោ** សេចក្ដីថា ជាអ្នកប្រថាប់នៅលើទិព្វយានយាងទៅ ។ បទថា **អទ្ទា** បានដល់ បានទតឃើញហើយ ។ បទថា **សីទន្តរេ** បានដល់ ក្នុងចន្លោះមហាសមុទ្រសីទន្តរ ។ បានឮថា ទឹកក្នុងមហាសមុទ្ទនោះល្អិត ដោយហោចសូម្បីត្រឹមអង្កាំកន្ទុយក្ងោក ដែលបោះចូលទៅ ក៏មិនអាចអណ្ដែតបាន រមែងលិចចុះនោះឯង ដូច្នេះ ទើបមហាសមុទ្រនោះហៅថា មហាសមុទ្រសីទន្តរ ។ ក្នុងចន្លោះនៃមហាសមុទ្រសីទន្តរនោះ ។ បទថា **នគេ**

បានដល់ ភ្នំ ។ បទថា **កេ ឆាម** សេចក្ដីថា ភ្នំទាំងនេះឈ្មោះអ្វី ។

មាតលិទេវបុត្រ ត្រូវព្រះបាទនេមិរាជត្រាស់សួរយ៉ាងនេះហើយ ទើបទូលថា

ភ្នំធំៗ ទាំងឡាយនេះ ក្នុងសមុទ្ទសីទន្តរ គឺភ្នំសុទស្សនៈ ១ ករវិក ១ ឥសិន្ធរ ១ យុគន្ធរ ១ នេមិន្ធរ ១ វិនតក ១ អស្សកណ្ណ ១ ជាភ្នំមានកំពូលខ្ពស់ឡើង តាមលំដាប់ រៀងគ្នា បពិត្រមហារាជ ភ្នំដែលទ្រង់ក្រឡេកឃើញ សឹងជាលំនៅ នៃមហារាជទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុទស្សនោ** សេចក្ដីថា បពិត្រមហារាជ ភ្នំនេះឈ្មោះសុទស្សនបព៌ត នៅខាងក្រៅគេបង្អស់ បន្ទាប់អំពីភ្នំសុទស្សនៈនោះ ជាភ្នំឈ្មោះករវិក ភ្នំករវិកនោះ ខ្ពស់ជាងភ្នំសុទស្សនៈ ។ មយ៉ាងទៀត សមុទ្ទឈ្មោះសីទន្តរ នៅក្នុងចន្លោះភ្នំទាំង ២ នោះ បន្ទាប់អំពីភ្នំករវិក ជាភ្នំឈ្មោះឥសិន្ធរ ភ្នំឥសិន្ធរនោះ ខ្ពស់ជាងភ្នំករវិក មយ៉ាងទៀត សមុទ្ទឈ្មោះសីទន្តរនៅក្នុងចន្លោះភ្នំទាំង ២ នោះ ។ បន្ទាប់ពីភ្នំឥសិន្ធរ ជាភ្នំឈ្មោះយុគន្ធរ ភ្នំយុគន្ធរនោះ ខ្ពស់ជាងភ្នំឥសិន្ធរ សមុទ្ទឈ្មោះសីទន្តរ នៅក្នុងចន្លោះភ្នំទាំង ២ នោះ ។ បន្ទាប់ពីភ្នំយុគន្ធរ ជាភ្នំឈ្មោះនេមិន្ធរ ភ្នំនេមិន្ធរនោះ ខ្ពស់ជាងភ្នំយុគន្ធរ សមុទ្ទឈ្មោះសីទន្តរ នៅត្រង់ចន្លោះភ្នំទាំង ២ នោះ ។ បន្ទាប់ពីភ្នំនេមិន្ធរ ជាភ្នំឈ្មោះវិនតក ភ្នំវិនតកនោះ ខ្ពស់ជាងភ្នំនេមិន្ធរ សមុទ្រឈ្មោះសីទន្តរនៅក្នុងចន្លោះភ្នំទាំង ២ នោះ ។ បន្ទាប់ពីភ្នំវិនតក ជាភ្នំឈ្មោះអស្សកណ្ណ

ភ្នំអស្សកណ្ណ ខ្ពស់ជាភ្នំវិនតក សមុទ្រឈ្មោះសីទន្តរនៅចន្លោះភ្នំទាំង ២ នោះ ។

បទថា **អនុបុព្វសមុគ្គតា** សេចក្តីថា ភ្នំទាំង ៧ នោះ ខ្ពស់ឡើង ដោយលំដាប់ ក្នុងសមុទ្រសីទន្តរដូចកាំជណ្តើរតាំងនៅ ។ បទថា **យានិ** សេចក្តីថា បពិត្រមហារាជ សូមទ្រង់ទតភ្នំទាំងនេះ ដែលជាលំនៅរបស់ចាតុម្មហារាជ ។

មាតលិទេវសារថី សម្តែងទេវលោកជាន់ចាតុម្មហាជល់ព្រះបាទនេមិរាជ យ៉ាងនេះហើយ បររថបន្តទៅ បង្ហាញរូបឥន្ទបដិមា ដែលប្រតិស្ឋានត្រង់ទ្វារចិត្តកូដនៃតាវត្តិង្សពិភព ព្រះបាទនេមិរាជទតឃើញទ្វារនោះហើយត្រាស់សួរ មាតលិទេវសារថីក៏បានក្រាបទូលដល់ព្រះរាជាដូចគ្នា ។

( ទ្វារ ) មានរូបជាអនេក ដ៏រុងរឿង វិចិត្រដោយរតនវត្ថុផ្សេងៗ
ដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា
( ព្រៃធំ ) ដែលពួកខ្លាធំចាំនៅហើយ ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះឃើញ ម្នាល
មាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅថាទ្វារនេះឈ្មោះអ្វី ទើបជាទី
រីករាយនៃចិត្ត ប្រាកដអំពីចម្ងាយ ។

មាតលិទេពសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល
នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ
ដែលមិនទ្រង់ជ្រាបថា ទ្វារនេះ ឈ្មោះចិត្តកូដ ជាទីចេញចូលនៃ
ទេវរាជ ( ជាទ្វារនៃទេពនគរ ដែលតាំងនៅត្រង់ទីបំផុតនៃភ្នំព្រះ

សុមេរុ ) ជាភ្នំគួរឲ្យចង់មើលប្រាកដ ( ទ្វារនេះ ) មានរូបជាអនេក ដ៏រុងរឿង វិចិត្រដោយរតនវត្ថុផ្សេងៗ ប្រាកដជាទ្វារដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា ( ព្រៃធំ ) ដែលពួកខ្លារក្សាហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅតាមទ្វារនុ៎ះ សូមទ្រង់ជាន់នូវផែនដីទិព្វ ដ៏រាបស្មើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនេករូបំ** បានដល់ មានច្រើនប្រភេទ ។ បទថា **នានាចិត្តំ** បានដល់ វិចិត្រដោយរតនៈផ្សេងៗ ។ បទថា **បកាសតិ** សេចក្តីថា ទ្វារនេះ ប្រាកដឈ្មោះអ្វី ។ បទថា **អាកិណ្ណំ** សេចក្តីថា ចោមរោមហើយ ។ បទថា **ព្យគ្ឃេហេវ សុរក្ខិតំ** សេចក្តីថា ព្រៃធំ ដែលខ្លាធំ ឬរាជសីហ៍ទាំងឡាយរក្សាល្អហើយយ៉ាងណា ទ្វារនេះជាទ្វារដែលមានរូបព្រះឥន្ទនោះឯងរក្សាល្អហើយដូច្នោះ ឯរូបឥន្ទបដិមានោះ គេតម្កល់ដើម្បីប្រយោជន៍ក្នុងការរក្សា គប្បីពោលក្នុងកុលាវកជាតកក្នុងឯកនិបាត ។ បទថា **កិមភិញ្ញមាហុ** សេចក្តីថា គេហៅឈ្មោះទ្វារនេះថាអ្វី ។ បទថា **បវេសនំ** សេចក្តីថា សានយ៉ាងល្អដើម្បីប្រយោជន៍យានចេញចូល ។ បទថា **សុទស្សនស្ស** សេចក្តីថា ភ្នំសិនេរុដែលស្អាតគួរមើល ។ បទថា **ទ្វារំ ហេតំ** សេចក្តីថា ទ្វារនេះ ជាទ្វាររបស់ទេវនគរ ទំហំ ១ ម៉ឺនយោជន៍ ប្រតិស្ឋានលើកំពូលភ្នំសិនេរុ ។ បទថា **បកាសតិ** សេចក្តីថា ខ្លោងទ្វារ រមែងប្រាកដ ។ បទថា **បវិសេតេន** សេចក្តីថា សូមទ្រង់យាងចូលនគរតាមទ្វារនេះ ។ បទថា **អរុជំ**

**ភុម្មិបក្កម** សេចក្តីថា បពិត្រមហារាជ សូមទ្រង់ជាន់ទិព្វភូមិភាគ ដែលរាប ស្មើសម្រេចហើយដោយមាស ប្រាក់ និងកែវមណី មានបុព្វជាតិចម្រុះ ដោយយានទិព្វ ។

កាលទូលយ៉ាងនេះហើយ មាតលិទេវសារថីបានយាងព្រះបាទនេមិរាជ ឲ្យចូលទៅនគរ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា

ព្រះបាទនេមិមហារាជ ទ្រង់ស្ថិតនៅលើទិព្វយាន មានសេះ
ជាវាហនៈ ដែលទឹមដោយសេះសិន្ធព ១ ពាន់ ទ្រង់យាងទៅ
បានទតឃើញនូវទេវសភា ដូច្នេះ ។

ព្រះបាទនេមិរាជនោះប្រថាប់លើយានយាងទៅ បានទតឃើញទេវសភា ឈ្មោះសុធម្មា ទើបត្រាស់សួរមាតលិទេវសារថី មាតលិទេវសារថីក៏ក្រាប ទូលព្រះរាជាដូចគ្នា ។

( ត្រាស់សួរថា ) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដោយ
ជញ្ជាំងជាវិការនៃកែវពៃទូរ្យ ឃើញច្បាស់ដូចអាកាស មានពន្លឺ
ឡើងក្នុងសរទកាល ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះឃើញ ម្នាល
មាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅវិមានទុំនុះឈ្មោះអ្វី ។

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផល
នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ
ដែលមិនទ្រង់ជ្រាបថា ទេវសភា ដែលព្រះអង្គទតឃើញទុំនុះឯង គេ

ហៅថាសុធម្មា ( ទេវសភាន៍ះ ) រុងរឿងដោយកែវពៃទូរ្យ ដ៏វិចិត្រ ដែលបុញ្ញានុភាពនិម្មិតដោយប្រពៃ តាំងនៅ សសរមានប្រាំបី ដែលបុញ្ញកម្មតាក់តែងល្អ សុទ្ធសឹងជាវិការនៃកែវពៃទូរ្យទាំងអស់ ពួកទេវតានៅជាន់តាវត្តិង្សគ្រប់អង្គ សឹងមានព្រះឥន្ទ្រជាប្រមុខ តែងប្រជុំគ្នា គិតគូរសេចក្តីចម្រើនរបស់ទេវតា និងមនុស្សទាំងឡាយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅកាន់ទីអនុមោទនារបស់ទេវតាទាំងឡាយ តាមទ្វារនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធំ** ត្រឹមតែជានិបាត សេចក្តីថា បានតឃើញទេវសភា ។ បទថា **ឃសោ** បានដល់ វិមាននោះ ។ បទថា **វេឡុរិយារុចិរា** សេចក្តីថា មានកែវពៃទូរ្យដ៏ល្អ ។ បទថា **ចិត្រា** សេចក្តីថា វិចិត្រដោយរតនៈផ្សេងៗ ។ បទថា **ធារយន្តិ** សេចក្តីថា សសរទាំងឡាយ ៨ ជ្រុង ដែលធ្វើល្អហើយ ទ្រទ្រង់ទេវសភានេះ ។ បទថា **ឥន្ទុបុរោហិតា** សេចក្តីថា ពួកទេវតាក្នុងស្ថានតាវត្តិង្សនាំគ្នាចោមរោមលើកព្រះឥន្ទជាប្រធាន ប្រាថ្នាដល់សេចក្តីត្រូវការរបស់ទេវតា និងមនុស្សទាំងឡាយ ។ បទថា **បវិ-សេនេន** សេចក្តីថា សូមទ្រង់យាងចូលទៅកាន់ទី ដែលជាទីត្រេកអររបស់ពួកទេវតាដែលត្រេកអរជាមួយគ្នានិងគ្នា តាមផ្លូវនេះ ។

ចំណែកទេវតាទាំងឡាយអង្គុយរង់ចាំព្រះបាទនេមិរាជយាងមក ទេវតាទាំងនោះបានស្តាប់ថា ព្រះបាទនេមិរាជយាងមកហើយ ក៏កាន់គ្រឿងក្រអូប

និងផ្សែងក្រអូប អប់ដោយផ្កាឈើទិព្វ រង់ចាំដំណើរយានមក តាំងអំពីខ្លោងទ្វារចិត្តកូដ បូជាមហាសត្វដោយគ្រឿងក្រអូប និងបុព្វជាតិជាដើម នាំចូលកាន់ទេវសភាឈ្មោះសុធម្មា ។ ព្រះបាទនេមិរាជចុះអំពីរថ ចូលកាន់ទេវសភា ទេវតាទាំងឡាយក្នុងទីនោះ យាងឲ្យទ្រង់ប្រថាប់គង់លើទិព្វាសនៈ ។ សក្កទេវរាជយាងព្រះរាជាឲ្យប្រថាប់គង់លើទិព្វាសនៈ និងសោយទិព្វកាមសុខ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

ពួកទេពនិករ បានឃើញព្រះរាជានោះ ស្តេចយាងមកដល់ហើយ ក្រេកអរទទួលថា បពិត្រមហារាជ ដំណើរដែលព្រះអង្គយាងមកនេះ ប្រពៃហើយ មិនមែនទ្រង់យាងមកអាក្រក់ទេ បពិត្រព្រះរាជា ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គគង់ក្នុងទីជិតនៃទេវរាជចុះ ។ សក្កទេវរាជ ទ្រង់ក្រេកអរទទួលព្រះបាទវិទេហៈ គ្រប់គ្រងក្រុងមិថិលានោះ ព្រះបាទវាសវៈ អញ្ជើញព្រះអង្គ ដោយកាមទាំងឡាយផង ដោយអាសនៈផងថា ព្រះអង្គស្តេចមកដល់លំនៅនៃទេវតាទាំងឡាយ ជាដំណើរប្រពៃណាស់ ព្រះរាជា ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងទេវលោកទាំងឡាយ ជាទីញ៉ាំងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេច សូមព្រះអង្គបរិភោគកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្ស

ក្នុងតាវត្តិង្សទេវលោកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិនន្ទីសុ** សេចក្តីថា រួមគ្នាប្រព្រឹត្តជាទីស្រឡាញ់ គឺត្រេកអរទទួល ។ បទថា **សព្វកាមសមិទ្ធិសុ** បានដល់ ដែលប្រកបដោយសេចក្តីសម្រេចទិព្វកាមារម្មណ៍ទាំងពួង ។

សក្កទេវរាជយាងមហាសត្វឲ្យសោយទិព្វកាមារម្មណ៍ និងឲ្យប្រថាប់លើទិព្វាសនៈយ៉ាងនេះ ព្រះបាទនេមិរាជទ្រង់ស្តាប់ដូច្នោះ កាលឃាត់ ទើបត្រាស់ថា

វត្ថុណា ដែលបានដោយអ្នកដទៃឲ្យជាបច្ច័យ ដូចជាយានជារបស់សូមគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនុ៎ះ ក៏មានឧបមេយ្យយ៉ាងនេះឯង ។ ខ្ញុំឥតចង់បានវត្ថុ ដែលបានមកដោយអ្នកដទៃឲ្យជាបច្ច័យនោះទេ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយ ដោយខ្លួនឯង នោះទើបជាទ្រព្យសម្រេចដល់ខ្ញុំ ។ ខ្ញុំឯង នឹងត្រឡប់ទៅធ្វើកុសល ដែលបុគ្គលធ្វើហើយ រមែងដល់សេចក្តីសុខ មិនក្តៅក្រហាយខាងក្រោយ ឲ្យមានប្រមាណច្រើន ដោយការឲ្យផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមឥន្ទ្រិយផង ដោយការទូន្មាននូវឥន្ទ្រិយផង ក្នុងពួកមនុស្ស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ បរតោ ទានបច្ចយា** សេចក្តីថា វត្ថុណា ដែលបានមកព្រោះការឲ្យអំពីអ្នកដទៃ គឺរបស់អ្នកដទៃនោះជាបច្ច័យ គឺព្រោះអ្នកដទៃនោះឲ្យ វត្ថុនោះ រមែងដូចគ្នានឹងរបស់ដែលខ្ចីគេមកដូច្នោះ ខ្ញុំ

មិនប្រាថ្នារបស់នោះឡើយ ។ បទថា **សយំ កតានិ** សេចក្ដីថា បុណ្យទាំងឡាយណាដែលខ្ញុំធ្វើផ្ទាល់ខ្លួន ការធ្វើបុណ្យទាំងនោះរបស់ខ្ញុំទុំះឯង មិនសាធារណៈដល់អ្នកដទៃ ។ បទថា **អាវេណិយំ ធនំ** បានដល់ ទ្រព្យដែលជាប់តាមខ្លួនទៅបាន ។ បទថា **សមចរិយាយ** បានដល់ ដោយការប្រព្រឹត្តស្មើតាមទ្វារទាំង ៣ ។ បទថា **សញ្ញមេន** បានដល់ ដោយការសង្រួម គឺការរក្សាសីល ។ បទថា **ទមេន** បានដល់ ដោយការទូន្មានឥន្ទ្រិយ ។

ព្រះមហាសត្វទ្រង់សម្ដែងធម៌ ដោយព្រះសូរសៀងដ៏ពីរោះដល់ទេវតាទាំងឡាយយ៉ាងនេះ កាលទ្រង់ប្រថាប់នៅ ៧ ថ្ងៃ ដោយការរាប់ថ្ងៃមនុស្ស ញុំាងពួកទេវតាឲ្យត្រេកអរ ប្រថាប់នៅត្រង់កណ្ដាលពួកទេវតានោះឯង កាលទ្រង់ពណ៌នាគុណរបស់មាតលិទេវសារថី ទើបត្រាស់ថា

មាតលីជាទេវសារថីដ៏ចម្រើន ជាអ្នកមានឧបការៈច្រើនដល់យើង
ព្រោះបានបង្ហាញនូវស្ថាន នៃសត្វអ្នកមានបុញ្ញកម្ម និងស្ថាននៃ
សត្វ អ្នកមានបាបកម្មទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យោ មេ កល្យាណកម្មានំ បាបានំ បដិទស្សយិ** សេចក្ដីថា មាតលិទេវសារថីនេះ បានសម្ដែងទីដែលជាលំនៅរបស់ទេវតាទាំងឡាយ ដែលមានកម្មស្អាត និងទីរបស់សត្វនរកទាំងឡាយដែលមានកម្មមិនស្អាតដល់ខ្ញុំ ។

លំដាប់នោះ ព្រះបាទនេមិរាជយាងសក្កទេវរាជមកត្រាស់ថា បពិត្រមហារាជ ខ្ញុំប្រាថ្នាត្រឡប់ទៅមនុស្សលោក សក្កទេវរាជក៏មានព្រះរាជ-

ទេវរាជ្ញាក្រនឹងមាតលិទេវសារថីថា ចូរអ្នកនាំព្រះបាទនេមិរាជយាងត្រឡប់ទៅមិថិលានគរវិញ ។ មាតលិទេវសារថីទទួលទេវបញ្ជាហើយ បានទឹមរថ ព្រះបាទនេមិរាជ ទ្រង់ត្រេកអរនឹងពួកទេវតាហើយ ញុំាងពួកទេវតាឲ្យត្រឡប់ត្រាស់លាហើយ ក៏យាងឡើងរថ មាតលិទេវសារថីបររថទៅដល់ក្រុងមិថិលាតាមទិសខាងកើត មហាជនឃើញទិព្វរថមានចិត្តត្រេកអរថា ព្រះរាជារបស់ពួកយើងយាងត្រឡប់ហើយ ។ មាតលិទេវសារថី ធ្វើប្រទក្សិណក្រុងមិថិលាញុំាងព្រះមហាសត្វឲ្យចុះត្រង់សីហបញ្ជរនោះ ហើយទូលលាត្រឡប់ទៅកាន់លំនៅរបស់ខ្លួននោះឯង ។ ចំណែកមហាជនក៏ចោមរោមព្រះរាជា ទូលសួរថាបពិត្រព្រះអង្គ ទេវលោកដូចម្តេច ព្រះបាទនេមិរាជទ្រង់ពោលដល់សម្បត្តិរបស់ពួកទេវតា និងរបស់សក្កទេវរាជហើយ ត្រាស់ថា សូម្បីអ្នកទាំងឡាយក៏ចូរធ្វើបុណ្យ មានទានជាដើម នឹងកើតក្នុងទេវលោកដូចគ្នា ហើយទ្រង់សម្តែងធម៌ដល់មហាជន ។

ក្នុងកាលតមក ព្រះបាទនេមិរាជមហាសត្វនោះ កាលកូសាមាលាក្រាបទូលភាពដែលព្រះកេសាស្កូវកើតឡើង ទើបទ្រង់ឲ្យដកព្រះកេសាស្កូវដោយសណ្ណាសមាស ដាក់លើបាតព្រះហស្ត ទតឃើញព្រះកេសាស្កូវនោះហើយក៏តក់ស្លុត ព្រះរាជទានស្រុកសួយដល់កូសាមាលា មានបំណងទ្រង់ផ្នួស ទើបប្រគល់រាជសម្បត្តិដល់ព្រះរាជឱរស កាលព្រះរាជឱរសទូលសួរថា ទ្រង់ព្រះផ្នួស ព្រោះហេតុអ្វី កាលប្រាប់ហេតុដល់ព្រះរាជឱរស ទើបត្រាស់ថា

សក់ទាំងឡាយនេះ នាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញហើយ
ទេវទូតកើតប្រាកដហើយ ( នេះ ) ជាសម័យនៃផ្នួសរបស់
អញ ដូច្នេះ ។

ព្រះបាទនេមិរាជត្រាស់គាថានេះហើយ ក៏ធ្វើដូចជាព្រះរាជាអង្គមុនៗ ទ្រង់បួសហើយ ប្រថាប់នៅក្នុងអម្ពវ័ននោះឯង ចម្រើនព្រហ្មវិហារ ៤ មានឈានមិនសាបសូន្យ ជាអ្នកកើតក្នុងព្រហ្មលោក ព្រះសាស្តាកាលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវភាពដែលព្រះបាទនេមិរាជទ្រង់ផ្នួសហើយ ទើបត្រាស់គាថាចុងក្រោយថា

ព្រះបាទនេមិ ទ្រង់ជាឥស្សរៈក្នុងដែនវិទេហៈ គ្រប់គ្រងក្រុង
មិថិលា ទ្រង់បានពោលដូច្នេះហើយ ( ទើបទ្រង់លាសក្កទេវ-
រាជ ត្រឡប់មកមនុស្សវិញ ) ទ្រង់បានបូជាយញ្ញដ៏ច្រើន ហើយ
ទ្រង់ចូលទៅរកការសង្រួម ( បព្វជ្ជា ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទំ វត្វា** សេចក្តីថា ត្រាស់គាថានេះថា **ឧត្តមង្គរុហា មយ្ហំ** ( ស្កូវកើតដល់អញហើយ ) ដូច្នេះជាដើម ។ បទថា **បុថុយញ្ញំ យជិត្វាន** បានដល់ ថ្វាយទានជាច្រើន ។ បទថា **សញ្ញមំ អជ្ឈុបាគមិ** សេចក្តីថា ទ្រង់ចូលដល់សេចក្តីសង្រួមក្នុងសីល ចំណែកព្រះឱរសរបស់ព្រះបាទនេមិរាជនោះ ព្រះនាមកាឡារជ្ជកៈ ជាអ្នកកាត់នូវវង្សនោះ គឺសក់ស្កូវហើយ ក៏មិនបួស ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតចេញមហាភិនេស្រ្កមណ៍ សូម្បីក្នុងកាលមុន ក៏តថាគតចេញមហាភិនេស្រ្កមណ៍ដូចគ្នា ដូច្នេះហើយ ទ្រង់បានប្រកាសចតុរារិយសច្ច ប្រជុំជាតកថា សក្កទេវរាជក្នុងកាលនោះ បានមកជាភិក្ខុឈ្មោះអនុរុទ្ធក្នុងកាលឥឡូវនេះ មាតលិទេវសារថីក្នុងកាលនោះ បានមកជាភិក្ខុឈ្មោះអានន្ទ ក្សត្រ ៨៤០០០ អង្គក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯព្រះបាទនេមិរាជក្នុងកាលនោះ គឺតថាគតសម្មាសម្ពុទ្ធនេះឯង ។

## អដ្ឋកថានេមិរាជជាតក ចប់

# សុត្តន្តបិដក

## មហោសធជាតក

[ ២០៧ ] ( ព្រះបាទវិទេហៈត្រាស់ថា ) ម្នាលមហោសធ ព្រះរាជាចូឡនីព្រហ្មទត្ត ជាម្ចាស់ក្រុងបញ្ចាល យាងមកជាមួយនឹងសេនាទាំងពួង សេនារបស់ព្រះរាជាក្រុងបញ្ចាលនោះ បុគ្គលប្រមាណមិនបាន ។ ( សេនាទាំងនោះ ) មានពលជាងឈើ និងពលថ្មើរជើង អ្នកឈ្លាសក្នុងសង្គ្រាមទាំងពួង អាចនឹងលុកចូលទៅក្នុងពួក ជាសេនាមានសំឡេង ( មិនស្ងាត់ចាកសំឡេងទាំង ១០ យ៉ាង ) ញ៉ាំងគ្នានិងគ្នាឲ្យដឹង ដោយសំឡេងស្គរ និងស័ង្ខ ។ ( ពួកសេនាទាំងនោះ ) មានវិទ្យាក្នុងផ្លូវលោហធាតុ និងមានគ្រឿងប្រដាប់មានទង់ជ័យ មានមនុស្សអ្នកឡើងកាន់ពាហនៈខាងច្រើន ទាំងបរិបូណ៌ល្អ ដោយពួកមនុស្សអ្នកមានសិល្បៈ ដែលពួកយោធាដ៏ក្លៀវក្លា ( មានព្យាយាមស្មើដោយសត្វសីហៈ ) តាំងទុកដោយល្អហើយ ។ ក្នុងចំណោមសេនាទាំងនុ៎ះ មាននាយពល ១០ នាក់ ជាអ្នកឈ្លាស មានប្រាជ្ញាដូចផែនដី ច្រើនទៅប្រជុំប្រឹក្សាក្នុងទីស្ងាត់ និងមាតារបស់ព្រះរាជាជាគម្រប់ ១១ រមែងទ្រង់ប្រៀនប្រដៅសេនាក្នុងក្រុងបញ្ចាល ។ បណ្ដាជនទាំងនុ៎ះ មានក្សត្រិយ៍ ១០១ សុទ្ធតែមានយសជាចំណុះ ដែលត្រូវព្រះបាទចូឡនីព្រហ្មទត្ត ដណ្ដើមយកដែនហើយ មានសេចក្ដីភ័យអំពីមរណៈ ក៏លុះក្នុងអំណាចនៃព្រះបាទបញ្ចាល ។ ( ស្ដេច

ទាំង ១០១ នោះ ) ជាអ្នកធ្វើតាមព្រះរាជតម្រាស់ មិនមានប្រាជ្ញា ក៏ពោលពាក្យជាទីស្រឡាញ់ មិនមានប្រាជ្ញា ក៏លុះអំណាចចុះ ចូលព្រះបាទបញ្ចាល ។ មិថិលារាជធានីរបស់ពួកអ្នកវិទេហៈ ត្រូវពួកសេនានោះចោមព័ទ្ធជា ៣ ជាន់ ( ដូចជា ) ជីកគាស់ដោយជុំវិញ ។ ( ក្រុងមិថិលា ) ត្រូវសេនាចោមព័ទ្ធជុំវិញ ( ប្រាកដដោយសស្ត្រាវុធ ) ដូចជាផ្កាយដែលប្រាកដក្នុងខាងលើ ម្នាលមហោសធ អ្នកឯងចូរដឹងថា សេចក្តីរួច ( ចាកទុក្ខនេះ ) នឹងមានដល់ពួកយើង ដោយប្រការដូចម្តេច ។

[ ២០៨ ] ( ព្រះមហាសត្វក្រាបបង្គំទូលថា ) បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់សណ្តូកព្រះបាទ ( ឲ្យស្រួលចុះ ) សូមព្រះអង្គទ្រង់ក្រសាលរីករាយក្នុងកាមចុះ ព្រះបាទចូឡនីព្រហ្មទត្តមុខជានឹងលះបង់សេនាក្នុងក្រុងបញ្ចាល ហើយរត់ទៅ ។

[ ២០៩ ] ( អាចារ្យកេវដ្តព្រាហ្មណ៍ ... ) ព្រះរាជាចូឡនីប្រាជ្ញាដើម្បីធ្វើសម្ពន្ធមិត្ត ( នឹងព្រះអង្គ ) ទាំងទ្រង់ថ្វាយកែវទាំងឡាយមានស្រីកែវជាដើមដល់ព្រះអង្គ ( ចាប់ដើម ) ពីថ្ងៃនេះទៅ សូមឲ្យពួករាជទូតមានវាចាពីរោះ ពោលពាក្យជាទីស្រឡាញ់មក ( ក្នុងក្រុងមិថិលានេះបាន ) សូមឲ្យពួករាជទូតទាំងនេះ ពោលវាចាដ៏ទន់ភ្លន់ ជាវាចាគួរត្រេកអរ សូមព្រះបាទបញ្ចាល និងព្រះបាទវិទេហៈទាំងពីរអង្គនោះ រួបរួមគ្នាតែមួយ ។

[ ២១០ ] ( ព្រះបាទវិទេហៈ ... ) នែកេវដ្ដៈ អ្នកបានជួបនឹងមហោសធដែរឬ អ្នកចូរពោលសេចក្ដីនោះ អ្នកបានឲ្យមហោសធអត់ទោសហើយឬ មហោសធត្រេកអរហើយឬ ។

[ ២១១ ] ( អាចារ្យកេវដ្ដៈ ... ) បពិត្រព្រះអង្គជាធំជាងជនមហោសធហៅពេញជាបុរសថោកទាប ពុំមានសេចក្ដីស្មោះស្មើជាមនុស្សរឹងរូស ជាអសប្បុរស ពុំបានពោលសេចក្ដីអ្វីតិចតួចសោះ ដូចជាមនុស្សគ ឬដូចជាមនុស្សថ្លង់ ។

[ ២១២ ] ( ព្រះបាទវិទេហៈ ... ) ចំណែកការដែលគិតនេះ បុរសផ្ដេសផ្ដាសឃើញបានក្រណាស់ដោយពិត សេចក្ដីបរិសុទ្ធ នរជនអ្នកមានព្យាយាម មុខជានឹងឃើញ ហេតុនោះ កាយរបស់អញញាប់ញ័រ អ្នកណានឹងលះបង់នូវដែនរបស់ខ្លួន ហើយលុះក្នុងកណ្ដាប់ដៃជនដទៃវិញកើត ។

[ ២១៣ ] គំនិតរបស់យើងទាំង ៦ នាក់ ដែលជាអ្នកឈ្លាសមានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ផុតដូចផែនដី ស្មើគ្នាជាឯកច្ឆន្ទ ម្នាលមហោសធ អ្នកចូរគិតមើល ទៅ ឬកុំទៅ ឬក៏ឈប់ ។

[ ២១៤ ] ( ព្រះមហាសត្វ ... ) បពិត្រព្រះរាជា សូមព្រះអង្គទ្រង់ជ្រាបថា ព្រះបាទចូឡនីព្រហ្មទត្ត ជាអ្នកមានអានុភាពធំ មានពលច្រើន ឥឡូវប្រាថ្នាដើម្បីនឹងសម្លាប់ព្រះអង្គ ដូចនាយព្រានដែលសម្លាប់ម្រឹគដោយផ្លាក់ ។

ត្រីជាសត្វជាប់ចិត្តក្នុងនុយស្រស់ ( លេប ) ផ្លែសន្ទូចដែលគេបិទបាំងដោយសាច់ មិនដឹងសេចក្តីស្លាប់ខ្លួនយ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកជាប់ក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គដូចត្រីនោះឯង ។ បើព្រះអង្គ ស្តេចយាងទៅកាន់ក្រុងបញ្ចាល ព្រះអង្គមុខជានឹងលះបោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគដែលដើរទៅតាមផ្លូវ ( ទៀបទ្វារនៃស្រុកដែរ ) ។

[ ២១៥ ] ( ព្រះបាទវិទេហៈ ... ) យើងដែលបានពោលនូវប្រយោជន៍ដ៏ឧត្តម ក្នុងសម្នាក់នៃអ្នក ត្រឡប់ទៅជាមនុស្សល្ងង់លីលាវិញ អ្នកឯងជាអ្នកចម្រើនដោយចុងនង្គ័ល ម្តេចនឹងដឹងសេចក្តីចម្រើនដូចអ្នកដទៃកើត ។

[ ២១៦ ] អ្នកទាំងឡាយ ចូរចាប់អ្នកនេះច្របឹក ហើយឲ្យវិនាសចាកដែនរបស់អញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ ។

[ ២១៧ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ មហោសធពោធិសត្វ ក៏ចៀសចេញអំពីសម្នាក់នៃព្រះបាទវិទេហៈហើយ ទើបហៅសុវបណ្ឌិត ឈ្មោះមាធុរៈជាទូតមកប្រាប់ថា ម្នាលសម្លាញ់មានស្លាបខៀវ អ្នកចូរមកធ្វើការបម្រើអញ ដ្បិតមានសាលិកាញីមួយដែលគេចិញ្ចឹមទុកជិតទីក្រឡាបន្ទំនៃព្រះបាទបញ្ចាល ។ ឯងចូរ

ទៅសួរសាលិកានោះដោយសន្ថវកិច្ច ព្រោះវាជាសត្វឈ្លាសក្នុងកិច្ចទាំងពួង វាដឹងការណ៍អាថ៌កំបាំងទាំងពួងរបស់ជនទាំងពីរ គឺព្រះរាជា និងកោសិយព្រាហ្មណ៍ ។ មាធុរសុវបណ្ឌិតមានស្លាបខៀវនោះបានទទួលស្តាប់ថា បាទដូច្នេះហើយ ក៏ហើរទៅកាន់សម្នាក់នៃនាងសាលិកា ។ មាធុរសុវបណ្ឌិត លុះហើរទៅដល់ហើយ ទើបហៅនាងសាលិកាមានទ្រូងល្អ ពោលពាក្យពីរោះថា នែនាងមានទ្រូងល្អ នាងល្មមអត់ទ្រាំបានដែរឬ នែនាងជាវេសជាតិ នាងមិនមានជំងឺតម្កាត់ទេឬ នែនាងមានទ្រូងល្អ នាងបានលាជលាយដោយទឹកឃ្មុំដែរឬ ។

( សាលិកាញី ... ) ម្នាលសម្លាញ់ សេចក្តីសុខស្រួលមានដល់ខ្ញុំ ម្នាលសម្លាញ់ មួយទៀត ខ្ញុំមិនមានជំងឺតម្កាត់ទេ ម្នាលសុវបណ្ឌិត ទាំងលាជលាយដោយទឹកឃ្មុំ ខ្ញុំក៏បានដែរ ។ នែសម្លាញ់ អ្នកមកអំពីណាហ្ន៎ ឬអ្នកណាប្រើមក មួយវិញទៀត អ្នកជាសត្វដែលខ្ញុំមិនធ្លាប់ឃើញ មិនធ្លាប់ឮក្នុងកាលមុនអំពីកាលនេះទេ ។

[ ២១៨ ] ( សុវបណ្ឌិត ... ) ខ្ញុំគេចិញ្ចឹមទុកនូវទីបន្ទំក្នុងប្រាសាទនៃព្រះបាទសិវិ ព្រះរាជានោះទ្រង់ស្ថិតនៅក្នុងធម៌ តែងទ្រង់ដោះលែងនូវសត្វទាំងឡាយដែលជាប់ចំណង ចាកចំណងអំពីទីនោះៗ ។ មាននាងសាលិកាមួយពោលពាក្យពីរោះ ជាកិរិយារបស់ខ្ញុំ ម្នាលនាងមានទ្រូងល្អ កាលខ្ញុំកំពុងតែសម្លឹងជាប់ចិត្ត ស្រាប់តែខ្លែង

សម្លាប់នាងសាលិកានោះទៅ ។ ខ្ញុំបរិបូណ៌ដោយសេចក្តីប្រាថ្នា ចំពោះកិរិយានោះ បានជាមកក្នុងសម្នាក់នៃនាង ប្រសិនបើនាងបើកឱកាស យើងទាំងពីរនាក់ នឹងនៅក្នុងទីជាមួយគ្នា ។

[ ២១៩ ] ( សាលិកា ... ) ធម្មតាសេកឈ្មោល គួរតែប្រាថ្នារកសេកញី សាលិកាឈ្មោល គួរតែប្រាថ្នារកសាលិកាញី ចុះការនៅរួមដោយសេកឈ្មោលនឹងសាលិកាញីដូចម្តេចកើត ។

[ ២២០ ] ( សុវបណ្ឌិត ... ) បុគ្គលណា ប្រាថ្នាស្ត្រីណាក្នុងកាមសូម្បីស្ត្រីនោះ ជាចណ្ឌាលក៏ដោយ ព្រោះថា ការនៅរួមទាំងអស់ ដូចៗ គ្នា ដែលមិនដូចគ្នាក្នុងកាមមិនមានទេ ។ ព្រះមាតានៃព្រះបាទសិវិ ព្រះនាមជម្ពាវតី ( ជាចណ្ឌាលសោះ ) តែបានជាអគ្គមហេសី ជាទីស្រឡាញ់របស់ព្រះបាទវាសុទេវកណ្ហាយនគោត្រ ។ សូម្បីនាងកិន្នរីឈ្មោះរតនវតី ញុំាងតាបសឈ្មោះវច្ឆៈឲ្យប្រាថ្នាដែរ ។ មនុស្សរួមសង្វាសជាមួយនឹងមេម្រឹគក៏មាន ការនៅរួមក្នុងកាម មិនដូចគ្នាមិនមានទេ ។ នៃនាងសាលិកាពោលពាក្យពីរោះ បើដូច្នោះ យើងនឹងទៅវិញ ព្រោះពាក្យនាងនុ៎ះ ទុកជាពាក្យប្រកែក នាងមើលងាយខ្ញុំពិត ។

[ ២២១ ] ( សាលិកា ... ) នៃមាធុរសុវបណ្ឌិត សិរី រមែងមិនមានដល់អ្នកប្រញាប់ទេ អ្នកចូរឈប់នៅទីនេះ ដរាបបានឃើញព្រះរាជាសិន អ្នកនឹងបានស្តាប់សំឡេងសម្ភោរ បានឃើញ

អានុភាពព្រះរាជា ។

[ ២២២ ] ( សុវបណ្ឌិត ... ) សំឡេងអឺងកងនេះ ឮល្បីប្រាកដ ទៅជនបទខាងក្រៅថា ព្រះរាជធីតារបស់ព្រះបាទបញ្ចាល មាន វណ្ណៈដូចជាផ្កាយព្រឹក ព្រះអង្គនឹងប្រទានព្រះរាជធីតានោះដល់ព្រះ បាទវិទេហៈ ឯវិវាហមង្គលនោះក៏នឹងមានដែរ ( តើពិតឬទេ ) ។

[ ២២៣ ] ( សាលិកា ... ) នៃមាធុរៈ ការរៀបចំវិវាហមង្គល ប្រាកដដូចនេះ របស់ពួកសត្រូវ ដូចជាវិវាហមង្គលរបស់ព្រះបាទ បញ្ចាលជាមួយនឹងព្រះបាទវិទេហៈរបស់អ្នក ចូរលើកទុកចុះ ។ ព្រះរាជាដ៏ប្រសើរលើរថ របស់អ្នកក្រុងបញ្ចាល នឹងនាំព្រះបាទ វិទេហៈមក ហើយនឹងសម្លាប់ព្រះបាទវិទេហៈនោះ ក្នុងវេលានោះ ( ព្រះបាទចូឡនី ) មិនមែនជាសម្លាញ់របស់ព្រះបាទវិទេហៈ នោះទេ ។

[ ២២៤ ] ( សុវបណ្ឌិត ... ) សូមនាងអនុញ្ញាតឲ្យបងទៅត្រឹម ៧ រាត្រី ទម្រាំបងទូលព្រះបាទសិវិ និងព្រះមហោសធថា ខ្ញុំបាន នៅរួមក្នុងសម្នាក់នាងសាលិកាហើយ ។

[ ២២៥ ] ( សាលិកា ... ) អើ ! ខ្ញុំអនុញ្ញាតឲ្យអ្នកទៅត្រឹម ៧ រាត្រី បើអ្នកមិនត្រឡប់មកកាន់សម្នាក់ខ្ញុំក្នុងរវាង ៧ រាត្រីវិញទេ ខ្ញុំសម្គាល់ខ្លួនខ្ញុំថាអស់ជីវិត កាលបើខ្ញុំស្លាប់ហួសទៅហើយ ទើប អ្នកនឹងមកដល់ ។

[ ២២៦ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ មាធុរសុវបណ្ឌិតនោះ ក៏ហើរទៅប្រាប់មហោសធថា ពាក្យនេះ ជាពាក្យរបស់នាងសាលិកា ។

[ ២២៧ ] ( មហោសធ ... ) បុរសគប្បីបរិភោគនូវភោគសម្បត្តិក្នុងផ្ទះរបស់បុគ្គលណា គប្បីធ្វើប្រយោជន៍ដល់បុគ្គលនោះឯង ។

[ ២២៨ ] បពិត្រព្រះជនិន្ទ ខ្ញុំព្រះអង្គនឹងសូមទៅកាន់បុរីគួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បម្រុងព្រះអង្គមានយសធំក្នុងដែនវិទេហៈ ។ បពិត្រក្សត្រិយ៍ លុះខ្ញុំព្រះអង្គសាងនិវេសន៍ដើម្បីព្រះអង្គ មានយសធំ ក្នុងដែនវិទេហៈស្រេចហើយ នឹងបញ្ជូនទូតមកទូលព្រះអង្គក្នុងវេលាណា ព្រះអង្គគប្បីយាងទៅក្នុងវេលានោះ ។

[ ២២៩ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះឯង ព្រះមហោសធក៏បានទៅកាន់បុរី គួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បម្រុងព្រះបាទវិទេហៈមានយស ។ ព្រះមហោសធ លុះសាងនិវេសន៍ដើម្បីព្រះបាទវិទេហៈ មានយសស្រេចហើយ ទើបបញ្ជូនទូតមកទូលព្រះបាទវិទេហៈគ្រប់គ្រងមិថិលាថា បពិត្រមហារាជ និវេសន៍ខ្ញុំព្រះអង្គសាងដើម្បីព្រះអង្គហើយ សូមព្រះអង្គស្តេចមកក្នុងកាលឥឡូវនេះ ។

[ ២៣០ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះឯង ព្រះរាជា ព្រម

ដោយសេនាមានអង្គ ៤ យាងទៅដើម្បីទតបុរីដ៏ធំទូលាយដែលមហោសធបណ្ឌិតសាងទុកក្នុងដែនកបិ្បលៈ មានពាហនៈមិនមានទីបំផុត ។

[ ២៣១ ] លំដាប់នោះឯង ព្រះបាទវិទេហៈនោះ លុះស្តេចយាងទៅដល់ ( ដែនកប្បិលៈ ) ហើយ ទើបបញ្ជូនរាជសាសន៍ទៅថ្វាយព្រះបាទចូឡនីព្រហ្មទត្តថា បពិត្រមហារាជ ខ្ញុំមកដើម្បីថ្វាយបង្គំព្រះបាទទាំងឡាយរបស់ព្រះអង្គ ។ សូមព្រះអង្គទ្រង់ប្រទាននាងនារីដែលមានសព្វាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយា ( របស់ខ្ញុំ ) ក្នុងកាលឥឡូវនេះ ។

[ ២៣២ ] ( ព្រះបាទចូឡនី ... ) បពិត្រព្រះបាទវិទេហៈ ព្រះអង្គស្តេចមកល្អហើយ មួយទៀត ព្រះអង្គស្តេចមកមិនអាក្រក់ទេ សូមព្រះអង្គសាកសួររកនក្ខត្តប្ញក្សចុះ ខ្ញុំនឹងថ្វាយនាងកញ្ញា ដ៏ប្រដាប់ដោយគ្រឿងអលង្ការ ជាវិការនៃមាស មានពួកទាសីជាបរិវារព្រះអង្គ ។

[ ២៣៣ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះឯង ព្រះបាទវិទេហៈសួររកនក្ខត្តប្ញក្ស លុះសួររកនក្ខត្តប្ញក្សរួចហើយ ទើបបញ្ជូនរាជ-សាសន៍ ទៅថ្វាយព្រះបាទព្រហ្មទត្តថា សូមព្រះអង្គទ្រង់ប្រទាននារី ដែលមានសព្វាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការ

ជាវិការនៃមាស មានពួកទាសីជាបរិវារឲ្យជាកិរិយារបស់ខ្ញុំ ក្នុងកាលឥឡូវនេះ ។

[ ២៣៤ ] ( ព្រះបាទចូឡនី ... ) ខ្ញុំថ្វាយនាងនារី ដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការ ជាវិការនៃមាស មានពួកទាសីជាបរិវារឲ្យជាកិរិយារបស់ព្រះអង្គ ក្នុងកាលឥឡូវនេះ ។

[ ២៣៥ ] ( ព្រះបាទវិទេហៈ ... ) ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅ ( ត្រៀបត្រា ) គប់ភ្លើងឆេះភ្លឺសន្ធោសន្ធៅ តើពួកបណ្ឌិតសម្គាល់ដូចម្ដេច ។

[ ២៣៦ ] ( អភិសម្ពុទ្ធគាថា ) ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅ ( ត្រៀបត្រា ) គប់ភ្លើងឆេះសន្ធោសន្ធៅ នៃបណ្ឌិត ពួកសេនាទាំងនោះនឹងធ្វើអ្វីហ្ន៎ ។

[ ២៣៧ ] ( មហោសធ ... ) បពិត្រមហារាជ ព្រះបាទចូឡនីព្រហ្មទត្តមានពលច្រើន ប្រទូសរ៉ាយដល់ព្រះអង្គ រក្សាព្រះអង្គទុក នឹងសម្លាប់ព្រះអង្គអំពីព្រឹក ។

[ ២៣៨ ] ( ព្រះបាទវិទេហៈ ... ) ហឫទ័យរបស់យើងញ័ររន្ធត់ ទាំងមាត់របស់យើងក៏ស្ងោះស្ងួត យើងមិនបានសេចក្ដីរលត់ ដូចជាឈើត្រូវភ្លើងឆេះក្នុងកណ្ដាលកម្ដៅថ្ងៃ ។ ចង្ក្រានរបស់ជាងមាសឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់

យើង ក៏ឆេះតែខាងក្នុងមិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ ។

[ ២៣៩ ] ( មហោសធ ... ) បពិត្រក្សត្រ ព្រះអង្គស្រវឹង ( ដោយកាម ) ទើបប្រព្រឹត្តកន្លងការប្រឹក្សា ទម្លាយការប្រឹក្សាចោល ឥឡូវនេះ សូមឲ្យបណ្ឌិត ( ទាំង ៤ នាក់ ) ដែលជាអ្នកមានប្រាជ្ញា រក្សាព្រះអង្គចុះ ។ បពិត្រព្រះរាជា ព្រះអង្គមិនធ្វើតាមពាក្យរបស់ទូលបង្គំជាអាមាត្យ ជាអ្នកប្រាថ្នាសេចក្តីចម្រើន និងស្វែងរកប្រយោជន៍ ទ្រង់ត្រេកអរដោយបីតិដ៏សៅហ្មងរបស់ព្រះអង្គ ដូចម្រឹគជាប់អន្ទាក់ ។ ( ទូលបង្គំបានក្រាបទូលហើយថា ) ត្រីជាសត្វល្មោភក្នុងនុយស្រស់ លេបនូវផ្លែសន្ទូចដ៏វៀច ដែលគេបិទដោយសាច់ ត្រីមិនដឹងសេចក្តីស្លាប់របស់ខ្លួន យ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកល្មោភក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គ ដូចត្រីយ៉ាងនោះឯង ។ បើទ្រង់ស្តេចទៅកាន់ក្រុងបញ្ចាល ទ្រង់មុខជានឹងលះបោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគដែលដើរទៅតាមផ្លូវ ( ទៀបទ្វារនៃស្រុក ) ។ បពិត្រព្រះជនិន្ទ បុរសមានសភាពមិនថ្លៃថ្នូរ ដូចពស់នៅក្នុងថ្នក់ គប្បីចឹកបុរសមានប្រាជ្ញា មិនគប្បីធ្វើនូវមេត្រីភាពដោយបុរសនោះទេ ព្រោះថា ការគប់រកដោយបុរសអាក្រក់ រមែងនាំមកនូវសេចក្តីទុក្ខដោយពិត ។ បពិត្រព្រះជនិន្ទ បណ្ឌិតបុរស ស្គាល់នូវបុគ្គល

ណាថា អ្នកនេះមានសីល មានការចេះដឹងច្រើន ដូច្នេះ បណ្ឌិតបុរសនោះ គួរធ្វើមេត្រីភាពជាមួយនឹងបុគ្គលនោះ ព្រោះថា ការសេពគប់ដោយសប្បុរសទាំងឡាយ រមែងនាំមកនូវសេចក្តីសុខពិត ។

[ ២៤០ ] បពិត្រព្រះរាជា ព្រះអង្គជាមនុស្សល្ងង់លីលា បាននោលនូវសេចក្តីចម្រើនដ៏ឧត្តម ក្នុងសម្នាក់នៃខ្ញុំព្រះអង្គថា ខ្ញុំព្រះអង្គជាអ្នកចម្រើនដោយចុងនង្គ័ល ធ្វើម្តេចនឹងដឹងសេចក្តីចម្រើនដូចអ្នកដទៃ ។ អ្នកទាំងឡាយចូរចាប់មហោសធនេះត្រង់ក ហើយឲ្យវិនាស ចាកដែនរបស់អញចេញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ ។

[ ២៤១ ] ( ព្រះបាទវិទេហៈ ... ) ម្នាលមហោសធ បណ្ឌិតទាំងឡាយ រមែងមិនចាក់ដោតដោយទោសដែលកន្លងទៅហើយទេ អ្នកចាក់ដោតយើង ដូចគេយកជន្ទញចាក់សេះដែលចងទុកហើយធ្វើអ្វី ។ ប្រសិនបើអ្នកឃើញសេចក្តីរួចរបស់យើង ឬឃើញសេចក្តីក្សេមរបស់យើង អ្នកចូរពន្យល់យើងដោយសោត្ថិភាពនោះចុះ អ្នកចាំបាច់ចាក់ដោតយើងដោយទោស ដែលកន្លងទៅហើយធ្វើអ្វី ។

[ ២៤២ ] ( មហោសធ ... ) អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើដែលគេកែបានដោយក្រ សម្រួលវិញ

បានដោយក្រ ខ្ញុំព្រះអង្គមិនអាចនឹងដោះព្រះអង្គបានទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបចុះ ។ ដំរីទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន ដំរីបែបនោះរបស់ព្រះរាជាណា សូមឲ្យដំរីទាំងនោះ នាំព្រះរាជានោះទៅចុះ ។ សេះទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន សេះបែបនោះរបស់ព្រះរាជាណា សូមឲ្យសេះទាំងនោះ នាំព្រះរាជានោះទៅចុះ ។ បក្សីទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន បក្សីបែបនោះរបស់ព្រះរាជាណា សូមឲ្យបក្សីទាំងនោះនាំព្រះរាជានោះទៅចុះ ។ យក្ខទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន យក្ខបែបនោះរបស់ព្រះរាជាណា សូមឲ្យយក្ខទាំងនោះនាំព្រះរាជានោះទៅចុះ ។ អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ បពិត្រក្សត្រិយ៍ ខ្ញុំព្រះអង្គមិនអាចដោះព្រះអង្គទៅតាមអាកាសបានទេ ។

[ ២៤៣ ] ( អាចារ្យសេនកៈ ... ) បុរសជាអ្នកមិនឃើញត្រើយក្នុងមហាសមុទ្រ បុរសនោះបានទីពំនាក់ក្នុងប្រទេសណា គេក៏បានសេចក្តីសុខក្នុងប្រទេសនោះ ( យ៉ាងណាមិញ ) ។ បពិត្រមហោសធ អ្នកជាទីពឹងរបស់ពួកយើង និងព្រះរាជា ក៏យ៉ាងនោះដែរ ព្រោះអ្នកជាបុគ្គលប្រសើរជាងពួកយើង និងពួកមន្ត្រី សូម

អ្នកដោះពួកយើងអំពីទុក្ខ ។

[ ២៤៤ ] ( មហោសធ ... ) អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ ខ្ញុំមិនអាចនឹងដោះអ្នកបានទេ នៃសេនកៈ អ្នកចូរដឹងចុះ ។

[ ២៤៥ ] ( ព្រះបាទវិទេហៈ ... ) អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំទុំ ( ស្រាប់ហើយ ) ម្នាលអាចារ្យសេនកៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្តេចក្នុងរឿងនេះ ។

[ ២៤៦ ] ( អាចារ្យសេនកៈ ... ) ពួកយើងគួរដុតភ្លើងត្រង់ទ្វារ ឬកាន់កាំបិតសម្លាប់គ្នានិងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្ត សម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ ។

[ ២៤៧ ] ( ព្រះបាទវិទេហៈ ... ) អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំទុំ ( ស្រាប់ហើយ ) ម្នាលអាចារ្យបុក្កុសៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ។

[ ២៤៨ ] ( អាចារ្យបុក្កុសៈ ... ) ពួកយើងគួរស៊ីថ្នាំពិសឲ្យស្លាប់នឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើងឲ្យលំបាកអស់កាលយូរឡើយ ។

[ ២៤៩ ] ( ព្រះបាទវិទេហៈ ... ) អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ ( ស្រាប់ហើយ ) ម្នាលអាចារ្យកាមិន្ទៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្តេចក្នុងរឿងនេះ ។

[ ២៥០ ] ( អាចារ្យកាមិន្ទៈ ... ) ពួកយើងគប្បីយកខ្សែចងឲ្យស្លាប់ ឬលោតចុះទៅក្នុងអណ្តូង ( ឲ្យស្លាប់ ) កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ ។

[ ២៥១ ] ( ព្រះបាទវិទេហៈ ... ) អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ ( ស្រាប់ហើយ ) ម្នាលអាចារ្យទេវិន្ទៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្តេចក្នុងរឿងនេះ ។

[ ២៥២ ] ( អាចារ្យទេវិន្ទៈ ... ) ពួកយើង ( បិទទ្វារ ) ដុតភ្លើងហើយកាន់កាំបិតសម្លាប់គ្នានិងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ ( បើ ) មហោសធមិនអាចនឹងដោះពួកយើងឲ្យរួចដោយងាយទេ ។

[ ២៥៣ ] ( ព្រះបាទវិទេហៈ ... ) បុគ្គលស្វែងរកខ្លឹមនៃដើមចេករមែងមិនបាន យ៉ាងណាមិញ យើងស្វែងរក ( ឧបាយជាគ្រឿងរួចចាកទុក្ខ ) ក៏មិនបានប្រស្នានោះក៏យ៉ាងនោះដែរ ។ បុគ្គលស្វែងរកខ្លឹមនៃដើមរកា រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរកក៏

មិនបានប្រស្នានោះក៏យ៉ាងនោះដែរ ។ ការនៅនៃដីរទាំងឡាយក្នុងទីមិនមានទឹក ឈ្មោះថា នៅក្នុងទីមិនមែនប្រទេស ( យ៉ាងណាមិញ ) កាលបើយើងនៅក្នុងទីជិតនៃពួកមនុស្សអាក្រក់ល្ងង់ខ្លៅមិនចេះមិនដឹង ( ឈ្មោះថា នៅក្នុងទីមិនមែនជាប្រទេសក៏ដូច្នោះឯង ) ។ ហឫទ័យរបស់យើងញ័ររន្ធត់ ទាំងមាត់របស់យើងក៏សោះស្ងួត យើងមិនបានសេចក្តីរលត់ ដូចឈើត្រូវភ្លើងឆេះក្នុងកណ្តាលកម្តៅថ្ងៃ ។ ចង្រ្កានជាងមាសឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើង ឆេះតែខាងក្នុងមិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ ។

[ ២៥៤ ] ( អភិសម្ពុទ្ធគាថា ) វេលានោះ មហោសធជាអ្នកប្រាជ្ញ មានប្រាជ្ញាឃើញប្រយោជន៍ជាប្រក្រតីនោះ បានឃើញព្រះបាទវិទេហៈទ្រង់មានសេចក្តីទុក្ខ ទើបក្រាបបង្គំទូលថា បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះចន្ទដែលរាហូចាប់ហើយ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះអាទិត្យដែលរាហូចាប់ហើយ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះ

ដីផុងក្នុងភក់ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះពស់ដែលជាប់នៅក្នុងកំប្រោង ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះបក្សីដែលជាប់នៅក្នុងទ្រុង ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះត្រីទាំងឡាយ ដែលជាប់នៅក្នុងសំណាញ់ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គចេញ ព្រមទាំងយាន វេហ៍ពល និងពាហនៈ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដេញព្រះបាទបញ្ចាលឲ្យរត់ទៅ ដូចជាគេដេញក្អែក និងខ្វែង ដោយដុំដី ។ បុគ្គលណាមិនជួយព្រះអង្គ ដែលមានសេចក្ដីចង្អៀត ( ព្រោះមរណៈ ) ឲ្យរួចចាកទុក្ខបានទេ ប្រាជ្ញា ( របស់បុគ្គលនោះ ) មានប្រយោជន៍អ្វី ឬអាមាត្យបែបនោះ ( មានប្រយោជន៍អ្វី ) ។

[ ២៥៥ ] នែមាណពទាំងឡាយ អ្នកទាំងឡាយចូរមក ចូរក្រោកឡើង អ្នកទាំងឡាយ ចូរបើកមាត់នៃគន្លិះយន្ត ព្រះបាទវិទេហៈ

មួយអន្ទើដោយពួកអាមាត្យ នឹងស្ដេចទៅតាមឧមង្គ ។

[ ២៥៦ ] ពួកជនអ្នកធ្វើការបម្រើរបស់មហោសធបណ្ឌិត ស្ដាប់ពាក្យរបស់លោកហើយ ទើបបើកទ្វារនៃឧមង្គ និងគន្លឹះទ្វារដែលប្រកបដោយគ្រឿងយន្ត ។

[ ២៥៧ ] អាចារ្យសេនកៈដើរមុន មហោសធដើរក្រោយ ព្រះបាទវិទេហៈមានអាមាត្យហែហម ស្ដេចយាងត្រង់កណ្ដាល ។

[ ២៥៨ ] ព្រះបាទវិទេហៈ ស្ដេចទ្រង់ចេញអំពីឧមង្គ ហើយឡើងគង់លើព្រះទីន័ងនាវា មហោសធដឹងថា ព្រះរាជាឡើងគង់ហើយក៏ប្រៀនប្រដៅថា បពិត្រព្រះសម្មតិទេព ព្រះបាទចូឡនីព្រហ្មទត្តនេះ ជាព្រះបិតាក្មេករបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងជនព្រះនាងនន្ទាទេវីនេះជាព្រះមាតាក្មេករបស់ព្រះអង្គ ការប្រតិបត្តិព្រះវររាជមាតា ( របស់ព្រះអង្គ ) យ៉ាងណា ការប្រតិបត្តិព្រះមាតាក្មេកចូរមានដល់ព្រះអង្គ ក៏យ៉ាងនោះដែរ ។ ព្រះរាជបុត្របង្កើតរួមឧទរ មានព្រះមាតាជាមួយគ្នាយ៉ាងណា បពិត្រព្រះអង្គប្រសើរលើរថ បញ្ចាលចន្ទរាជកុមារព្រះអង្គគប្បីស្រឡាញ់យ៉ាងនោះដែរ ។ បពិត្រព្រះអង្គប្រសើរលើរថ ព្រះនាងបញ្ចាលចន្ទីទេវីនេះ ជាព្រះរាជបុត្រី ( របស់ព្រះបាទចូឡនីព្រហ្មទត្ត ) ដែលព្រះអង្គទ្រង់ប្រាថ្នា សូមព្រះអង្គ ធ្វើសេចក្ដីប្រាថ្នារបស់ព្រះអង្គចំពោះព្រះនាងនោះ ព្រះនាងជាករិយារបស់ព្រះអង្គហើយ ។

[ ២៥៩ ] ( ព្រះបាទវិទេហៈ ... ) ម្នាលមហោសធ អ្នកចូរប្រញាប់ប្រញាល់ឡើងជិះទូកមក នៅឈរលើច្រាំងធ្វើអ្វី យើងទាំងឡាយរួចចាកទុក្ខដោយលំបាក យើងនឹងទៅឥឡូវនេះ ។

[ ២៦០ ] ( មហោសធ ... ) បពិត្រមហារាជ ខ្ញុំព្រះអង្គដែលជានាយកនៃសេនា លះបង់ចោលនូវអង្គនៃសេនា ហើយដោះយកតែខ្លួន នេះមិនមែនជាទំនៀមទេ ។ បពិត្រព្រះសម្មតិទេពប្រសើរលើរថ ខ្ញុំព្រះអង្គនឹងដឹកនាំនូវអង្គនៃសេនា ដែលព្រះអង្គបោះបង់ចោល ក្នុងរាជនិវេសន៍ នឹងរបស់ដែលព្រះបាទព្រហ្មទត្តថ្វាយហើយ ។

[ ២៦១ ] ( ព្រះបាទវិទេហៈ ... ) ម្នាលបណ្ឌិត អ្នកឯងជាអ្នកមានសេនាតិច នឹងសង្កត់សង្កិនទប់ទល់ព្រះបាទចូឡនីព្រហ្មទត្តដែលមានសេនាច្រើនដូចម្តេចបាន អ្នកឯងជាអ្នកមានកម្លាំងខ្សោយមុខជាលំបាកដោយព្រះបាទចូឡនីព្រហ្មទត្តដែលមានកម្លាំង ។

[ ២៦២ ] ( ពោធិសត្វ ... ) បុគ្គលមានប្រាជ្ញា សូម្បីមានសេនាតិច រមែងឈ្នះបុគ្គលមិនមានប្រាជ្ញា ដែលមានសេនាច្រើន ព្រះរាជាតែមួយព្រះអង្គ ( ជាអ្នកឈ្លាសក្នុងឧបាយ ) រមែងឈ្នះព្រះរាជាទាំងឡាយ ( ជាអ្នកល្ងង់ក្នុងឧបាយ ) ដូចព្រះអាទិត្យដែលរះឡើង ( រមែងឈ្នះ ) ងងឹត ដូច្នោះឯង ។

[ ២៦៣ ] ( ព្រះបាទវិទេហៈ ... ) នែអាចារ្យសេនកៈ ការនៅ

រួមជាមួយនឹងពួកបណ្ឌិត នាំមកនូវសេចក្តីសុខស្រួលណាស់ហ្ន៎ ព្រោះថា មហោសធបានដោះពួកយើង ដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រីដែលជាប់នៅក្នុងសំណាញ់ ដូច្នោះ ។

[ ២៦៤ ] ( អាចារ្យសេនកៈ ... ) បពិត្រមហារាជ ពិតមែនហើយ បណ្ឌិតទាំងឡាយ នាំមកសេចក្តីសុខយ៉ាងនោះឯង មហោសធបានដោះពួកយើង ដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រីដែលជាប់នៅក្នុងសំណាញ់ ដូច្នោះ ។

[ ២៦៥ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទចូឡនីព្រហ្មទត្តមានកម្លាំងច្រើន ទ្រង់រក្សាអស់រាត្រីទាំងមូល កាលអរុណរះឡើង ក៏ស្តេចចូលទៅដល់ក្រុងឧបការៈ ។ ព្រះបាទចូឡនី គ្រប់គ្រងក្រុងបញ្ចាលមានកម្លាំងច្រើន ស្តេចឡើងគង់លើដំរីប្រសើរ ដ៏មានកម្លាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ បានត្រាច់ទៅ ( នឹងសេនារបស់ព្រះអង្គ ) ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់សៀតគ្រឿងក្រោះ ជាវិការនៃកែវមណី ព្រះហស្តចាប់សរ បានត្រាស់ទៅនឹងរេហ៍ពលអ្នកទទួលបម្រើ ( របស់ព្រះអង្គ ) ជាអ្នកមានសិល្បៈច្រើនដែលមកជួបជុំគ្នា ។ ( ព្រះបាទចូឡនីត្រាស់ទៅ ) នឹងពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងខ្មាន់ធ្នូដែលមានដៃដ៏ស្ទាត់ក្នុង

សិល្បៈធ្នូ អាចបាញ់រោមត្រូវ ដែលមកជួបជុំគ្នា ។

[ ២៦៦ ] ( ព្រះបាទចូឡនី ... ) អ្នកទាំងឡាយ ចូរបញ្ចូនដំរី មានភ្លុកដ៏មានកម្លាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ ចូរឲ្យដំរីទាំងឡាយញាំញីទីក្រុង ដែលព្រះបាទវិទេហៈ សាងទុកហើយ ។ ( ពួកព្រួញ ) មានសម្បុរ-ស មានមុខដូចពន្លាក មានចុងដ៏មុត អាចចាក់ទម្លាយនូវឆ្អឹង ដែលបាញ់ដោយកម្លាំងធ្នូ ឲ្យធ្លាក់ចុះព្រមគ្នា អំពីខាងនេះ ខាងនោះ ។ ពួកសេនាក្មេងៗ ក្លៀវក្លា ពាក់គ្រឿងក្រោះ មានអាវុធប្រកបដោយដងដ៏វិចិត្រ កាលបើពួកដំរីធំស្ទុះចូលមក ចូរអ្នកនាំគ្នា ( តស៊ូ ) ចំពោះមុខដំរីទាំងឡាយ ។ លំពែងទាំងឡាយ ដែលគេលាងជម្រះដោយប្រេង មានរស្មីភ្លឺផ្លេក រុងរឿង ដូចជាផ្កាយព្រឹក មានរស្មីច្រើន ។ កាលបើពួកយោធា ( របស់យើង ) មានគ្រឿងអាវុធជាកម្លាំង ទ្រទ្រង់សង្វារ គឺគ្រឿងក្រោះប្រាកដដូច្នេះ មិនបានរត់ក្នុងសង្គ្រាមទេ ព្រះបាទវិទេហៈ នឹងរួចពីដៃយើងអំពីណា បើក្រែងតែព្រះបាទវិទេហៈ នឹងធ្វើដូចបក្សី ( ទើបរួច ) ។ ពួកយោធារបស់យើងទាំងអស់ មានចំនួន ៣៩០០០ អាចកាត់ក្បាលសត្រូវ ហើយរើសយកក្បាលមួយៗ មក យើងបានដើរសព្វលើផែនដី មិនឃើញពួកយោធាណាស្មើឡើយ ។ ដំរីទាំងឡាយ មានភ្លុកប្រដាប់ហើយ មានកម្លាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ ពួកយោធានៅ

ក្មេងៗ មានសម្បុរដូចមាស រមែងល្អលើ-កនៃដីទាំងឡាយ ។ យោធាទាំងឡាយ មានគ្រឿងអលង្ការ មានពណ៌លឿង ស្បៀក សំពត់មានពណ៌លឿង ដណ្តប់សំពត់មានពណ៌លឿង រមែងល្អលើកនៃដីទាំងឡាយ ដូចទេវបុត្តទាំងឡាយ ក្នុងនន្ទវ័ន ។ ព្រះខ័នទាំងឡាយ មានសម្បុរដូចត្រីស្វាត ដែលលាងជម្រះដោយប្រេង មានរស្មីភ្លឺផ្លេក ដែលបុរសអ្នកមានព្យាយាម ធ្វើសម្រេចហើយ មានមុខស្មើ ដែលគេសំលៀងល្អហើយ ។ ព្រះខ័នទាំងឡាយមិនមានស្នឹម រុងរឿងដូចជាព្រះអាទិត្យ ស្ថិតនៅក្នុងទីពាក់កណ្តាល ដែលគេធ្វើដោយដែកថែបដ៏មាំ ដែលពួកយោធាអ្នកមានកម្លាំងជំនាញ ក្នុងវិធីប្រហារមាំកាន់យកហើយ ។ ព្រះខ័នទាំងឡាយបរិបូណ៌ដោយដងជាវិការនៃមាស ទ្រទ្រង់ដោយស្រោមមានពណ៌ក្រហម កាលបើគេគ្រវីឡើង រមែងល្អ ដូចជាផ្លេកបន្ទោរ ភ្លឺផ្លេកក្នុងចន្លោះនៃពពក ។ ពួកខ្មាន់ធ្នូអ្នកក្លៀវក្លា ពាក់គ្រឿងក្រោះ អាចប្រព្រឹត្តទៅក្នុងអាកាសបាន អ្នកឈ្លាសក្នុងការកាន់ដាវ និងខែល ជាអ្នកហាត់ក្នុងការកាន់ធ្នូដ៏ក្រៃលែង អាចកាត់នូវកនៃដីឲ្យធ្លាក់ចុះបាន ។ អ្នកឯងត្រូវពួកយោធាប្រាកដដូច្នេះព័ទ្ធហើយ អ្នកឯងមិនរួចអំពីទីនេះទេ អ្នកនឹងទៅកាន់ក្រុងមិថិលា ដោយរាជានុភាពណា យើងមិនបានឃើញរាជានុភាពនោះរបស់អ្នកទេ ។

[ ២៦៧ ] ( ព្រះពោធិសត្វ ... ) ព្រះអង្គទ្រង់ប្រញាប់ប្រញាល់

បញ្ជូនដីរីដ៏ប្រសើរមក ព្រះអង្គមានព្រះហឫទ័យ រីករាយយាងមក ហើយទ្រង់សម្គាល់ថា អាត្មាអញនឹងបានសម្រេចប្រយោជន៍ដូច្នេះឬហ្ន៎ ។ សូមព្រះអង្គដាក់ធ្នូ និងបំពង់ព្រួញនុ៎ះចេញ សូមព្រះអង្គដាក់កូនសរនោះចេញ សូមព្រះអង្គដាក់គ្រឿងក្រោះដ៏ល្អ ប្រហែលដោយកែវពៃទូរ្យ និងកែវមណីនុ៎ះចេញ ។

[ ២៦៨ ] ( ព្រះបាទចូឡនី ... ) អ្នកឯងជាអ្នកមានសម្បុរមុខស្រស់បស់ ទាំងនិយាយក៏ញញឹមញញែមជាប់ ឯការបរិបូណ៌ដោយសម្បុរបែបនេះ រមែងមានប្រាកដក្នុងមរណកាល ។

[ ២៦៩ ] ( មហោសធ ... ) បពិត្រក្សត្រជាព្រះរាជា ពាក្យដែលព្រះអង្គគំរាមហើយ ជាពាក្យសោះសូន្យទទេ ព្រះអង្គមានការប្រឹក្សាធ្លាយហើយ ឯព្រះរាជា ( របស់យើង ) ព្រះអង្គមិនងាយនឹងចាប់យកបានទេ ដូចសេះសិន្ធព និងសេះខ្ទក ។ ( ព្រះរាជាក្រុងមិថិលា ) ព្រមដោយអាមាត្យ និងរាជបរិស័ទ ឆ្លងស្ទឹងគង្គាតាំងពីថ្ងៃម្សិលទៅហើយម៉្លេះ ក្អែកស្មុះតាមរាជហង្ស នឹងធ្លាក់ចុះក្នុងពាក់កណ្ដាលផ្លូវ យ៉ាងណាមិញ ( បើព្រះអង្គនឹងតាមព្រះរាជានោះ នឹងដល់សេចក្ដីវិនាស ក្នុងពាក់កណ្ដាលផ្លូវ ក៏យ៉ាងនោះដែរ ) ។

[ ២៧០ ] ឆ្កែចចកទាំងឡាយ ជាម្រឹគថោកទាប ឃើញផ្កាចារដែលរីកក្នុងចំណែកនៃរាត្រី ក៏សម្គាល់ថា ដុំសាច់ ហើយនាំគ្នាចោមរោម ។ ( ឆ្កែចចកទាំងនោះ ) ជាម្រឹគថោកទាប កាលបើ

រាត្រីកន្លងទៅហើយ ព្រះអាទិត្យក៏រះឡើង ទើបឃើញច្បាស់ថា ជាផ្កាចាររីក ក៏ដាច់សេចក្ដីប្រាថ្នា ( រត់ទៅ ) យ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គបោមព័ទ្ធព្រះបាទវិទេហៈ នឹងដាច់សេចក្ដីប្រាថ្នាហើយ ទៅដូចពួកក្អែកចចក ( បោមរោម ) នូវផ្កាចារ ដូច្នោះដែរ ។

[ ២៧១ ] ( ព្រះបាទចូឡនី ... ) អ្នកទាំងឡាយ ចូរកាត់ដៃ និងជើង ត្រចៀក និងច្រមុះ នៃមហោសធនេះ ព្រោះវាធ្វើព្រះបាទវិទេហៈ ជាសត្រូវដែលនៅក្នុងកណ្ដាប់ដៃយើង ឲ្យរួចទៅវិញ ។ សេនាទាំងឡាយ ចូរដោតគហបតីបុត្តនេះ ដោយឈើស្រួច ហើយចម្អិនវា ដូចគេចម្អិនសាច់ដែលគួរចម្អិន ព្រោះវាធ្វើស្ដេចវិទេហៈ ជាសត្រូវដែលនៅក្នុងកណ្ដាប់ដៃយើង ឲ្យរួចទៅវិញ ។ បុគ្គលដោតសន្ទឹងស្បែកគោលើផែនដី ពុំនោះសោត ពួកស្បែកសីហៈ ឬខ្លាធំដោយកង្វេរ យ៉ាងណា ។ យើងនឹងចាក់ដោតវាដោយលំពែង យ៉ាងនោះ ព្រោះវាធ្វើព្រះបាទវិទេហៈ ជាសត្រូវដែលនៅក្នុងកណ្ដាប់ដៃយើង ឲ្យរួចទៅវិញ ។

[ ២៧២ ] ( មហោសធ ... ) បើព្រះអង្គ កាត់នូវដៃជើង ត្រចៀក និងច្រមុះ របស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( ដៃជើង ត្រចៀក និងច្រមុះ ) របស់ព្រះរាជបុត្ត ឈ្មោះបញ្ចាលចន្ទៈ យ៉ាងហ្នឹងដែរ បើព្រះអង្គ កាត់ដៃជើង ត្រចៀក និងច្រមុះ របស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( នូវដៃជើង

ត្រចៀក និងច្រមុះ ) របស់ព្រះរាជធីតាឈ្មោះបញ្ចាលចន្ទី យ៉ាង ហ្នឹងដែរ ។ បើព្រះអង្គ កាត់ដៃ និងជើង ត្រចៀក និងច្រមុះ របស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( នូវដៃជើង ត្រចៀក និងច្រមុះ ) របស់អគ្គមហេសីឈ្មោះនន្ទាទេវី យ៉ាង ហ្នឹងដែរ ។ បើព្រះអង្គកាត់ ដៃ និងជើង ត្រចៀក និងច្រមុះ របស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( នូវដៃ និង ជើង ត្រចៀក និងច្រមុះ ) របស់ព្រះរាជបុត្ត និងព្រះមហេសី របស់ព្រះអង្គ យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំដោយឈើ អណ្តោត ហើយចម្អិន ដូចគេចម្អិនសាច់ដែលគួរចម្អិន ព្រះបាទ វិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជបុត្ត ឈ្មោះបញ្ចាលចន្ទៈ ( ដោយឈើអណ្តោត ) ហើយចម្អិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គ ដោតខ្ញុំ ដោយឈើអណ្តោតហើយចម្អិន ដូចគេចម្អិនសាច់ ដែល គួរចម្អិន ព្រះបាទវិទេហៈ មុខជានឹងប្រើគេឲ្យដោតព្រះរាជធីតា ឈ្មោះបញ្ចាលចន្ទី ( ដោយឈើអណ្តោត ) ហើយចម្អិន យ៉ាង ហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្តោត ហើយចម្អិន ដូច គេចម្អិនសាច់ ដែលគួរចម្អិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យ គេដោតអគ្គមហេសី ឈ្មោះនន្ទាទេវី ( ដោយឈើអណ្តោត ) ហើយចម្អិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំ នឹងឈើអណ្តោត ហើយចម្អិន ដូចគេចម្អិនសាច់ដែលគួរចម្អិន ព្រះបាទវិទេហៈ មុខ

ជានឹងប្រើឲ្យគេជោតព្រះរាជបុត្ត និងព្រះមហេសីរបស់ព្រះអង្គ ( ដោយឈើអណ្ដាត ) ហើយចម្អិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គចាក់ជោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងជោតព្រះរាជបុត្ត ឈ្មោះបញ្ចាលចន្ទៈ ( ដោយលំពែង ) យ៉ាងហ្នឹងដែរ ។ បើព្រះអង្គចាក់ជោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ជោតព្រះរាជធីតា ឈ្មោះបញ្ចាលចន្ទី ( ដោយលំពែង ) យ៉ាងនោះដែរ ។ បើព្រះអង្គចាក់ជោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ជោតអគ្គមហេសី ឈ្មោះនន្ទាទេវី ( ដោយលំពែង ) យ៉ាងនោះដែរ ។ បើព្រះអង្គចាក់ជោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ជោតព្រះរាជបុត្ត និងព្រះមហេសីរបស់ព្រះអង្គ ( ដោយលំពែង ) យ៉ាងនោះដែរ ។ យើងទាំងពីរនាក់ គឺស្ដេចវិទេហៈ និងទូលព្រះបង្គំជាខ្ញុំ ប្រឹក្សាគ្នារួចស្រេច ក្នុងទីស្ងាត់យ៉ាងនេះហើយ ខែលស្បែកមានទម្ងន់ ១០០ បលៈ ដែលជាងស្បែកឲ្យសម្រេចហើយ ដោយសស្ត្រារបស់ជាងស្បែក រមែងជួយការពារខ្លួន ដើម្បីទប់ផងនូវកូនសរទាំងឡាយ យ៉ាងណា ។ ទូលព្រះបង្គំជាខ្ញុំ ជាអ្នកនាំសេចក្ដីសុខ មកជួយបន្ទោបង់សេចក្ដីទុក្ខ នៃព្រះបាទវិទេហៈដ៏មានយស តែងទប់ផងនូវកូនសរ គឺព្រះតម្រិះរបស់ព្រះអង្គ ដោយខែលស្បែកមានទម្ងន់ ១០០ បលៈ ( សេចក្ដីគិតរបស់ទូលព្រះបង្គំជាខ្ញុំ ក៏ដូច្នោះឯង ) ។

[ ២៧៣ ] បពិត្រមហារាជ សូមអញ្ជើញព្រះអង្គ ទតព្រះនេត្រមើលព្រះរាជវាំង របស់ព្រះអង្គដែលសូន្យឈឹងចុះ បពិត្រព្រះមហាក្សត្រិយ៍ ស្រីស្នំ និងកុមារទាំងឡាយ និងព្រះវររាជមាតារបស់ព្រះអង្គ ខ្ញុំឲ្យនាំចេញចាកឧមង្គ នាំទៅថ្វាយព្រះបាទវិទេហៈហើយ ។

[ ២៧៤ ] ( ព្រះបាទចូឡនី ... ) បើដូច្នោះ អ្នកទាំងឡាយចូរទៅឯព្រះរាជវាំងរបស់អញ ហើយពិចារណាមើលហេតុនោះ តើសមដូចពាក្យរបស់មហោសធនេះ ពិត ឬកុហកទេ ។

[ ២៧៥ ] ( ពួកអាមាត្យ ... ) បពិត្រមហារាជ មហោសធទូលយ៉ាងណា សេចក្តីនុ៎ះក៏យ៉ាងនោះឯង ព្រះរាជវាំងទាំងមូល សូន្យឈឹង ដូចស្ពានជាទីប្រជុំចុះនៃពួកក្អែក ។

[ ២៧៦ ] ( មហោសធ ... ) បពិត្រមហារាជ ព្រះនាងនារីនន្ទាទេវីព្រះសព៌ាង្គកាយដ៏ល្អ មានព្រះសោណីដ៏ល្អ ដូចដំបារមាស មានប្រក្រតីពោលពាក្យពីរោះ ដូចជាសំឡេងនៃហង្ស បានចេញទៅអំពីឧមង្គនេះហើយ ។ បពិត្រមហារាជ ព្រះនាងនារីមានសព៌ាង្គ-កាយដ៏ល្អ ទ្រទ្រង់កោសេយ្យពស្ត្រ មានសរីរៈដូចមាស មានខ្សែរឹតព្រះអង្គនោះ ក៏ល្អវិចិត្រដោយមាស ។ ព្រះនាងនារី មានព្រះបាទដ៏ក្រហមល្អ ប្រកបដោយលម្អ ( ៥ យ៉ាង ) មានខ្សែរឹតជាវិការនៃមាស និងកែវមណី មានដួងព្រះនេត្រប្រាកដស្មើដោយភ្នែកសត្វព្រាប មានសរីរៈដ៏ល្អ មានរិមព្រះឱស្ឋរលីងល្អ

ដូចជាផ្លែទន្លាប់ មានចង្កេះរៀវ ។ ព្រះនាងនារីមានចង្កេះរៀវ ដូចវល្លិ៍ទាគលតា ដែលលូតលាស់ល្អ ឬដូចក្តារហឹង ( ជាវិការនៃមាស ) ព្រះកេសរបស់ព្រះនាងនារីនោះ វែងមានចុងខ្មៅងបន្តិចដូចចុងកាំបិត ។ ព្រះនាងនន្ទាទេវី មានដួងព្រះនេត្រថ្លាយង់ ដូចជាភ្នែកនៃកូនម្រឹគ កើត ( បានមួយខួប ) ឬដូចជាអណ្តាតភ្លើងក្នុងហេមន្តរដូវ ពុំនោះសោត ដូចជាស្ទឹង ដ៏ដេរដាសដោយដើមឫស្សីតូចៗ ទាំងឡាយ ទៀបជ្រោះភ្នំ ។ ព្រះនាងនន្ទាទេវី មានព្រះឱរុល្អដូចប្រមោយដំរី មានស្តនទាំងគូ ល្អដូចផ្លែទន្លាប់ ដ៏ប្រសើរ មិនខ្ពស់ពេក មិនទាបពេក មិនមែនឥតព្រះលោមា មិនមែនមានព្រះលោមាច្រើនពេក ។ បពិត្រព្រះអង្គមានពាហនៈបរិបូណ៌ដោយសិរី ព្រះអង្គត្រេកអរដោយមរណៈនៃព្រះនាងនន្ទាទេវីដោយពិត ឯខ្ញុំព្រះអង្គ និងព្រះនាងនន្ទា នឹងទៅកាន់សម្នាក់យមរាជដោយពិត ។

[ ២៧៧ ] ( ព្រះបាទចូឡនី ... ) អ្នកបានរៀនកលមាយាជាទិព្វ ហើយបានធ្វើឧបាយ បំបាំងភ្នែកឬ បានជាអ្នកដោះលែងព្រះបាទវិទេហៈជាសត្រូវ នៅក្នុងកណ្តាប់ដៃយើងបាន ។

[ ២៧៨ ] ( មហោសធ ... ) បពិត្រមហារាជ បណ្ឌិតទាំងឡាយក្នុងលោកនេះ រមែងរៀននូវកលមាយា ជាទិព្វដោយពិត ពួកបណ្ឌិតជន អ្នកមានសេចក្តីជឹងនោះ ទើបដោះខ្លួន ( ចាកទុក្ខបាន )

ពួកយោធាក្មេងៗ អ្នកបម្រើរបស់ទូលព្រះបង្គំ ជាអ្នកឈ្លាស ជាអ្នកកាត់ផ្តាច់នូវទីត ព្រះបាទវិទេហៈ យាងទៅកាន់ក្រុងមិថិលា តាមផ្លូវដែលពួកជនទាំងនេះ ធ្វើទុកហើយ ។

[ ២៧៩ ] បពិត្រមហារាជ សូមព្រះអង្គស្តេចទតឧមង្គ ដែលពួកជាងសាងទុកល្អហើយ សូមព្រះអង្គទតឧមង្គដ៏ល្អរុងរឿង ( ដោយរបៀប ) នៃដំរី សេះ រថ និងពលថ្មើរជើង ដែលគេធ្វើឲ្យសម្រេចហើយ ដោយល្អ ។

[ ២៨០ ] ( ព្រះបាទចូឡនី ... ) ម្នាលមហោសធ ជាលាភរបស់អ្នកដែនវិទេហៈដោយពិត បណ្ឌិតទាំងឡាយ បែបដូចជាអ្នកនេះ នៅក្នុងដំណាក់ ក្នុងដែនរបស់ព្រះរាជាណា ( ជាលាភរបស់ព្រះរាជានោះពិត ) ។

[ ២៨១ ] យើងនឹងឲ្យគ្រឿងចិញ្ចឹមជីវិត និងវត្ថុគ្រឿងរក្សា គឺស្រុក និងនិគម ទាំងបាយ និងថ្លៃឈ្នួល ជាទ្វេគុណដល់អ្នក ទាំងឲ្យភោគសម្បត្តិដ៏ធំទូលាយទៀត អ្នកចូរបរិភោគ ចូររីករាយតាមប្រាថ្នាចុះ អ្នកកុំទៅរកព្រះបាទវិទេហៈឡើយ ព្រះបាទវិទេហៈនឹងធ្វើអ្វីដល់អ្នក ។

[ ២៨២ ] ( មហោសធ ... ) បពិត្រមហារាជ បុគ្គលណាលះបង់នូវបុគ្គលអ្នកចិញ្ចឹមព្រោះហេតុនៃទ្រព្យ បុគ្គលនោះ ត្រូវជនទាំងពីរ គឺខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់គង់

ព្រះជន្មាយុជរាបណា ខ្ញុំក៏មិនគប្បីនៅក្នុងដែននៃព្រះរាជាដទៃ ( ដរាបនោះ ) ។ បពិត្រមហារាជ បុគ្គលណាលះបង់នូវបុគ្គលអ្នកចិញ្ចឹមព្រោះហេតុនៃទ្រព្យ បុគ្គលនោះ ត្រូវជនទាំងពីរ គឺខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់ស្ថិតនៅជរាបណា ខ្ញុំមិនត្រូវជាបុរសរបស់បុគ្គលដទៃ ( ដរាបនោះ ) ។

[ ២៨៣ ] ( ព្រះបាទចូឡនី ... ) ម្នាលមហោសធ យើងឲ្យមាសភ្ជារ ១០០០ និងស្រុកចំនួន ៨០ ក្នុងដែនកាសីដល់អ្នក យើងឲ្យទាសី ៤០០ និងភរិយា ១០០ ដល់អ្នក អ្នកចូរនាំអង្គនៃសេនាទាំងពួងទៅ ដោយសួស្តីចុះ ។

[ ២៨៤ ] ជនទាំងឡាយ ចូរឲ្យវត្ថុផ្សេងៗ ជាទ្វេគុណ ដល់ពួកដំរី ពួកសេះជាកំណត់ ចូរញុំាងពលរថ និងពលថ្មើរជើង ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹកចុះ ។

[ ២៨៥ ] ម្នាលបណ្ឌិត អ្នកចូរនាំយកពួកដំរី ពួកសេះ ពួករថ និងពួកពលថ្មើរជើងទៅ ព្រះបាទវិទេហមហារាជ ចូរទតឃើញអ្នក ដែលទៅដល់ក្រុងមិថិលាចុះ ។

[ ២៨៦ ] ( ព្រះបាទវិទេហៈ ... ) សេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ និងសេនាថ្មើរជើងនោះ ប្រាកដជាមានច្រើន មានសភាពគួរខ្លាច តើបណ្ឌិតទាំងឡាយ សម្គាល់ដូចម្តេចហ្ន៎ ។

[ ២៨៧ ] ( អាចារ្យសេនកៈ ... ) បពិត្រមហារាជ សេចក្តីត្រេកអរ យ៉ាងខ្លាំងខ្លស់ រមែងប្រាកដដល់ព្រះអង្គ មហោសធនាំយកអង្គនៃសេនាទាំងពួងមកដល់ហើយ ដោយសួស្តី ។

[ ២៨៨ ] ( ព្រះបាទវិទេហៈ ... ) ម្នាលមហោសធ ជនទាំង ៤ នាក់ នាំមនុស្សស្លាប់ ទៅចោលក្នុងព្រៃស្មសាន ( ហើយត្រឡប់មក ) យ៉ាងណា ពួកយើងបោះបង់អ្នកចោលក្នុងដែន គប្បីលះហើយត្រឡប់មកក្នុងទីនេះ ក៏ដូច្នោះ ។ កាលបើដូច្នេះ អ្នកបេះដោះខ្លួនឲ្យរួចមក ដោយហេតុដូចម្តេច ដោយបច្ច័យដូចម្តេច ដោយដំណើរដូចម្តេច ។

[ ២៨៩ ] ( មហោសធ ... ) បពិត្រក្សត្រព្រះនាមវិទេហៈ ទូលព្រះបង្គំ បានការពារនូវសេចក្តីដោយសេចក្តី នូវការប្រឹក្សាដោយប្រឹក្សា ទូលព្រះបង្គំ បានការពារស្តេច ដូចជាសាគរការពារជម្ពូទ្វីបដូច្នោះ ។ ព្រះបាទចូឡនី បានប្រទានមាសក្តោរ ១០០០ និងស្រុកចំនួន ៨០ ក្នុងដែនកាសី ដល់ទូលព្រះបង្គំ ប្រទានទាសី ៤០០ និងភរិយា ១០០ ដល់ទូលព្រះបង្គំ ទូលព្រះបង្គំជាអ្នកនាំអង្គនៃសេនាទាំងពួងមកក្នុងទីនេះ ដោយសួស្តី ។

[ ២៩០ ] ( ព្រះបាទវិទេហៈ ... ) នែអាចារ្យសេនកៈ កាលនៅរួមជាមួយនឹងអ្នកប្រាជ្ញ នាំមកនូវសេចក្តីសុខស្រួលណាស់ហ្ន៎ មហោសធ បានដោះពួកយើង ដែលតាំងនៅក្នុងសេចក្តីវិនាស គឺ

ដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សី ដែលជាប់នៅក្នុងទ្រុង ឬដូចជាគេដោះត្រី ដែលជាប់នៅក្នុងសំណាញ់ ។

[ ២៩១ ] ( អាចារ្យសេនកៈ ... ) បពិត្រមហារាជ មែនពិត ពួកបណ្ឌិតរមែងនាំមកនូវសេចក្ដីសុខយ៉ាងនេះឯង មហោសធ បានដោះពួកយើង ដែលតាំងនៅក្នុងសេចក្ដីវិនាស គឺដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សី ដែលជាប់ក្នុងទ្រុង ឬដូចជាគេដោះត្រី ដែលជាប់ក្នុងសំណាញ់ ។

[ ២៩២ ] ( អភិសម្ពុទ្ធគាថា ... ) ពួកជនចូរដេញពិណា ចូរវាយស្គរតូច និងស្គរធំ ផ្លុំស័ង្ខ ដែលកើតក្នុងដែនមគធៈ និងទូងស្គរធំមានសំឡេងពីរោះ ។

[ ២៩៣ ] ពួកស្រីស្នំ ពួកកុមារ ពួកវេស្សៈ និងពួកព្រាហ្មណ៍ នាំបាយ និងទឹកជាច្រើន មកជូន ( មហោសធបណ្ឌិត ) ។ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត ។ ពួកអ្នកជនបទប្រជុំគ្នា ទាំងពួកអ្នកនិគមក៏មកប្រជុំគ្នា នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត ។ ជនជាច្រើន កាលបើបានឃើញបណ្ឌិតមកដល់ហើយ ក៏មានសេចក្ដីជ្រះថ្លា កាលបើបណ្ឌិតមកដល់ហើយ ការលើកឡើងនូវទង់ក៏ប្រព្រឹត្តទៅ ។

**មហោសធជាតកទី ៥ ចប់**

# អដ្ឋកថា

## មហោសថជាតក

[ ២០៧-២៩៣ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ព្រះបញ្ញាបារមីរបស់ព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **បញ្ញាលោ សព្វសេនាយ** *ដូច្នោះជាដើម ។*

*សេចក្តីសង្ខេបថា ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា កាល នឹងសរសើរព្រះបញ្ញាបារមីរបស់ព្រះតថាគត បានអង្គុយសរសើរព្រះគុណ របស់ព្រះសាស្តាថា នៃអាវុសោទាំងឡាយ ព្រះតថាគតជាអ្នកមានប្រាជ្ញាជាធំ មានបញ្ញាដ៏ក្រាស់ មានបញ្ញាដ៏ជ្រាលជ្រៅ មានបញ្ញានាំឲ្យរីករាយ មានបញ្ញា ដូចផែនដី មានបញ្ញាជាគ្រឿងស្ទុះទៅ មានបញ្ញាដ៏មុត មានបញ្ញាជាគ្រឿង ទម្លុះទម្លាយ ញាំញីនូវវាទៈនៃអ្នកដទៃ ទ្រង់ទូន្មានពួកព្រាហ្មណ៍ មានកូដទន្ត- ព្រាហ្មណ៍ជាដើម ពួកបរិព្វាជក មានសព្ភិយបរិព្វាជកជាដើម ពួកយក្ខ មាន អាឡវកយក្ខជាដើម ពួកទេវតា មានសក្កទេវរាជជាដើម ពួកព្រហ្ម មាន ពកព្រហ្មជាដើម ពួកចោរ មានចោរអង្គុលិមាលជាដើម ដោយព្រះបញ្ញា- នុភាពរបស់ព្រះអង្គ ទ្រង់ធ្វើឲ្យអស់ព្យសន៍ ទ្រង់ទូន្មានជនជាច្រើន ប្រទាន បព្វជ្ជាឲ្យតាំងនៅក្នុងមគ្គផល ព្រះសាស្តាមានបញ្ញាជាធំដូច្នេះ ។ ព្រះសាស្តា យាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួក អ្នកអង្គុយសន្ទនាគ្នា ដោយរឿងអ្វី រឿងអ្វីដែលពួកអ្នកសន្ទនាគ្នាក្នុងចន្លោះ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតមាន*

បញ្ញាច្រើន សូម្បីក្នុងអតីតកាល កាលញាណមិនទាន់ចាស់ក្លា នៅបំពេញបុព្វចរិយា ដើម្បីប្រយោជន៍ដល់ពោធិញ្ញាណនៅឡើយ ក៏ជាអ្នកមានបញ្ញាដូចគ្នា កាលត្រាស់ដូច្នេះហើយ ទ្រង់ក៏តុណ្ហីភាព ភិក្ខុទាំងនោះ ក្រាបទូលអារាធនាឲ្យទ្រង់ប្រកាសបុព្វចរិយា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រះរាជាព្រះនាមវិទេហៈ សោយរាជសម្បត្តិក្នុងក្រុងមិថិលា ដែនវិទេហៈ មានបណ្ឌិត ៤ នាក់ ឈ្មោះសេនកៈ ១ បុក្កុសៈ ១ កាមិន្ទៈ ១ ទេវិន្ទៈ ១ ជាអ្នកថ្វាយអនុសាសន៍ អត្ថ និងធម៌ដល់ព្រះបាទវិទេហរាជនោះ កាលនោះ ព្រះបាទវិទេហរាជ ទ្រង់ព្រះសុបិនក្នុងពេលទៀបភ្លឺ ក្នុងថ្ងៃព្រះពោធិសត្វបដិសន្ធិថា គ្រង់ជ្រុងលានព្រះរាជវាំងទាំង ៤ ជ្រុង មានគំនរភ្លើង ៤ គំនរ ប្រមាណប៉ុនមហាកំពែង ក្នុងកណ្តាលគំនរភ្លើងទាំង ៤ នោះ មានគំនរភ្លើងមួយប្រមាណប៉ុនអំពិលអំពែក ប្រាកដឡើងភ្លឺរន្ទាលរុងរឿងជាងគំនរភ្លើងទាំង ៤ ក្នុងខណៈនោះឯង ភ្លើងនោះប្រាកដឡើងទល់នឹងអកនិដ្ឋកព្រហ្ម ភ្លឺពេញចក្កវាឡ វត្ថុដែលជ្រុះលើផែនដី សូម្បីប៉ុនគ្រាប់ស្ពៃក៏ប្រាកដ មនុស្សលោក ទេវតា មារ ព្រហ្ម មកបូជាគំនរភ្លើងនោះដោយគ្រឿងក្រអូប និងដោយកម្រងផ្កាជាដើម មហាជនត្រាច់ទៅក្នុងរវាងអណ្តាតភ្លើងក៏មិនក្តៅសូម្បីត្រឹមតែរោម ។ ព្រះរាជាទ្រង់ព្រះសុបិននេះហើយ ទ្រង់តក់ស្លុត ក្រោកឡើងប្រថាប់គង់ ទ្រង់ចិន្តានាការរហូតដល់ថ្ងៃរះឡើងថា ហេតុការណ៍អ្វីហ្នឹគប្បីមានដល់អញ ។ បណ្ឌិតទាំង ៤ មកគាល់

អំពីព្រលឹម ទូលសួរដល់សុខក្នុងព្រះដំណេកថា បពិត្រសម្មតិទេព ទ្រង់ផ្ទំជាសុខឬ ព្រះរាជាត្រាស់តបថា លោកអាចារ្យ សេចក្ដីសុខមានដល់យើងអំពីណា យើងបានសុបិនយ៉ាងនេះ លំដាប់នោះ សេនកបណ្ឌិតទូលថា បពិត្រមហារាជ សូមទ្រង់កុំកិតភ័យ សុបិននេះជាមង្គលទេ សេចក្ដីចម្រើននឹងមានដល់ទ្រង់ កាលព្រះរាជាត្រាស់សួរថា ហេតុអ្វី ទើបទូលថា បពិត្រមហារាជ បណ្ឌិតទី ៥ ម្នាក់ទៀតនឹងកើតឡើង គ្របសង្កត់ពួកទូលបង្គំ ដែលជាបណ្ឌិតទាំង ៤ ធ្វើឲ្យអាប់រស្មី ពួកខ្ញុំទាំង ៤ ដូចគំនរភ្លើងទាំង ៤ បណ្ឌិតទី ៥ នឹងកើតឡើង ដូចគំនរភ្លើងដែលកើតឡើងទ្រង់កណ្ដាល បណ្ឌិតនោះ មិនមានបុគ្គលស្មើក្នុងលោក ព្រមទាំងទេវលោក ។ ព្រះបាទវិទេហរាជត្រាស់សួរថា បណ្ឌិតនោះនៅឯណា សេនកបណ្ឌិតទូលព្យាករ ហាក់បីដូចឃើញដោយទិព្វចក្ខុ ព្រោះកម្លាំងនៃសិប្បៈរបស់ខ្លួនថា ថ្ងៃនេះ បណ្ឌិតនោះនឹងបដិសន្ធិ ឬនឹងកើតចាកគភ៌មាតា ។ ព្រះរាជាទ្រង់ចាំទុកដល់ពាក្យនៃសេនកបណ្ឌិតនោះ តាំងអំពីនោះមក ។

ស្រុកទាំង ៤ គឺស្រុកឈ្មោះទក្ខិណយវមជ្ឈគាម ១ បច្ឆិមយវមជ្ឈគាម ១ ឧត្តរយវមជ្ឈគាម ១ បាចីនយវមជ្ឈគាម ១ មាននៅត្រង់ទ្វារទាំង ៤ នៃក្រុងមិថិលា ។ ក្នុងស្រុកទាំង ៤ នោះ សេដ្ឋីឈ្មោះសិរិវឌ្ឍកៈ នៅក្នុងស្រុកឈ្មោះបាចីនយវមជ្ឈគាម ភរិយារបស់សេដ្ឋីនោះ ឈ្មោះសុមនាទេវី ។ ថ្ងៃនោះ ព្រះមហាសត្វចុតិអំពីតាវត្តិង្ស បដិសន្ធិក្នុងគភ៌នៃនាងសុមនាទេវីក្នុងកាលដែលព្រះរាជាទ្រង់សុបិន ទេវបុត្រ ១ ពាន់អង្គទៀត ចុតិ

អំពីតាវត្តិង្សភព បដិសន្ធិក្នុងត្រកូលនៃសេដ្ឋីធំ-តូច ក្នុងស្រុកនោះឯង ។ ក្នុងកាលដែលកន្ទងមកបាន ១០ ខែ នាងសុមនាទេវីក៏ប្រសូតកូនប្រុស មានសម្បុរដូចមាស ។

ខណៈនោះ សក្កទេវរាជទតនូវមនុស្សលោក ទ្រង់ជ្រាបថា មហាសត្វប្រសូតចាកគភ៌មាតា ទ្រង់គិតថា អញគួរធ្វើព្ទង្គួរនេះ ឲ្យប្រាកដក្នុងលោកនិងទេវលោក ទើបយាងមកដោយអទិសមានកាយ មិនមានអ្នកណាឃើញទ្រង់ ។ ក្នុងពេលដែលព្រះមហាសត្វប្រសូតចាកគភ៌មាតា ក៏ដាក់ដុំឱសថមួយក្នុងដៃព្រះមហាសត្វនោះ ហើយយាងត្រឡប់ទៅកាន់ទិព្វវិមាននោះឯង ។ ព្រះមហាសត្វទទួលដុំឱសថនោះហើយក្តាប់ ។ កាលព្រះមហាសត្វប្រសូតចាកគភ៌នោះ សេចក្តីទុក្ខមិនមានដល់មាតា សូម្បីត្រឹមតែបន្តិច ប្រសូតងាយដូចទឹកដែលចេញអំពីធម្មក្រក ដូច្នោះ ។ នាងសុមនាទេវីឃើញឱសថក្នុងដៃរបស់បុត្រនោះ ក៏សួរថា បាបានអ្វីមក មហាសត្វឆ្លើយនឹងម្តាយថា បពិត្រអ្នកម៉ែ គឺថ្នាំ ហើយដាក់ទិព្វឱសថក្នុងដៃមាតា ពោលថា បពិត្រអ្នកម៉ែ សូមអ្នកឲ្យថ្នាំនេះដល់អ្នកជំងឺ ដែលឈឺដោយប្រការណាមួយ ។ នាងសុមនាទេវីត្រេកអរក្រៃលែង ក៏ប្រាប់ដល់សិរិវឌ្ឍកសេដ្ឋីដែលជាស្វាមី ឯសេដ្ឋីនោះមានជំងឺឈឺក្បាលមកអស់ ៧ ឆ្នាំ មានសេចក្តីត្រេកអរ គិតថា កុមារនេះកាលកើតអំពីគភ៌មាតា ក៏កាន់យកថ្នាំមក ទាំងនិយាយជាមួយម្តាយក្នុងខណៈដែលកើតនោះឯង ថ្នាំដែលបុគ្គលមានបុណ្យបែបនេះឲ្យ នឹងមានអានុភាពច្រើន គិតដូច្នេះហើយ ទើបកាន់យកឱសថនោះដុសលើថ្ម ហើយកាន់យក

បន្តិចលាបត្រង់ថ្ងាស រោគឈឺក្បាលដែលកើតមកអស់ ៧ ឆ្នាំ ក៏ជាសះស្បើយទៅ ដូចទឹកហូរអំពីស្លឹកឈូក ដូច្នោះ ។ លោកសេដ្ឋីមានសេចក្តីត្រេកអរថា ឱសថមានអានុភាពច្រើន ។ រឿងព្រះមហាសត្វកាន់យកថ្នាំមកក៏ប្រាកដក្នុងទីទាំងពួង បណ្តាអ្នកជំងឺទាំងពួង នាំគ្នាមកផ្ទះលោកសេដ្ឋីសូមថ្នាំ ចំណែកលោកសេដ្ឋី ក៏កាន់យកថ្នាំបន្តិចដុសលើថ្ម លាយទឹកឲ្យដល់មនុស្សទាំងពួង គ្រាន់តែយកទិព្វឱសថលាបសរីរៈប៉ុណ្ណោះ ជំងឺតម្កាត់ទាំងពួងក៏ស្ងប់ មនុស្សទាំងឡាយបានសេចក្តីសុខហើយ សរសើរថា ឱសថក្នុងផ្ទះរបស់សិរិវឌ្ឍកសេដ្ឋីមានអានុភាពច្រើន ហើយចៀសចេញទៅ ។

ក្នុងថ្ងៃដាក់ឈ្មោះព្រះមហាសត្វ សេដ្ឋីគិតថា អញមិនត្រូវការឈ្មោះបុព្វបុរស មានជីតាជាដើម មកជាឈ្មោះកូនរបស់អញឡើយ កូនរបស់អញចូរមានឈ្មោះថា ឱសថ ព្រោះកាលគេកើតកាន់យកថ្នាំមក បន្ទាប់អំពីនោះទើបដាក់ឈ្មោះព្រះមហាសត្វនោះថា មហោសថកុមារ ព្រោះអាស្រ័យពាក្យកើតឡើងថា ឱសថនេះមានគុណច្រើន ឱសថនេះមានអានុភាពច្រើន ដោយប្រការដូច្នេះ ។ លំដាប់នោះ មហាសេដ្ឋីមានគំនិតថា កូនរបស់អញមានបុណ្យច្រើន នឹងមិនកើតតែម្នាក់ឯងប៉ុណ្ណោះឡើយ ទារកទាំងឡាយដែលកើតជាមួយនឹងកូនរបស់អញនេះគប្បីមាន ទើបឲ្យរកមើល ក៏បានដំណឹងថា ជួបទារកដែលកើតក្នុងថ្ងៃតែមួយ ១ ពាន់នាក់ ទើបឲ្យនូវគ្រឿងប្រដាប់ដល់កុមារទាំងអស់ និងឲ្យស្នំ ១ ពាន់នាក់ ឲ្យធ្វើមង្គលដល់ទារកទាំងនោះ មួយអន្លើដោយព្រះពោធិសត្វនោះឯង ដោយគិតថា ទារកទាំងនេះ នឹងជាអ្នកបដិបត្តិ

ទំនុកបម្រុងបុត្ររបស់អញ ស្រីស្នំទាំងឡាយ តាក់តែងទារកហើយ នាំមកបម្រើព្រះមហាសត្វ ។ ព្រះពោធិសត្វលេងជាមួយទារកទាំងនោះ ចម្រើនវ័យ មានអាយុ ៧ ឆ្នាំ មានរូបស្អាតដូចបដិមាមាស កាលព្រះពោធិសត្វកំពុងលេងជាមួយទារកទាំងនោះត្រង់កណ្ដាលស្រុក កាលដំរីជាដើមមក ទីសម្រាប់លេងក៏ខូចខាត ទារកទាំងឡាយលំបាកក្នុងការត្រូវខ្យល់ និងកម្ដៅថ្ងៃ ។ ថ្ងៃមួយ ក្មេងទាំងនោះកំពុងលេង មហាមេឃក៏តាំងឡើង មហាសត្វមានកម្លាំងដូចដំរីសារ ឃើញមេឃតាំងឡើង ក៏រត់ចូលសាលាមួយខ្នង ទារកក្រៅអំពីនេះ ក៏រត់ទៅតាមក្រោយព្រះមហាសត្វ ទាក់ជើងគ្នាដួលចុះ បែកក្បាលជង្គង់ជាដើម ទើបព្រះពោធិសត្វគិតថា គួរធ្វើសាលាជាទីលេងក្នុងទីនេះ យើងទាំងឡាយនឹងមិនលំបាកយ៉ាងនេះ ទើបប្រាប់ដល់ទារកទាំងនោះថា ពួកយើងលំបាកដោយខ្យល់ ភ្លៀង និងកម្ដៅថ្ងៃ ពួកយើងនឹងសាងសាលាមួយខ្នងក្នុងទីនេះ ឲ្យល្មមជាទីឈរ អង្គុយ និងដេកបាន ចូរអ្នកទាំងឡាយនាំកហាបណៈ ម្នាក់ ១ កហាបណៈ ទារកទាំងនោះក៏ធ្វើតាមនោះ ព្រះមហាសត្វឲ្យហៅជាងធំមក ពោលថា បពិត្រលោកឪពុក សូមលោកធ្វើសាលាក្នុងទីនេះ ហើយឲ្យកហាបណៈមួយពាន់ដល់មេជាង ។ មេជាងទទួលកហាបណៈមួយពាន់ហើយ ពង្រាបដីឲ្យស្មើ ជីកដង្គត់ចេញ ហើយសន្ទឹងខ្សែ ព្រះមហាសត្វឃើញវិធីសន្ទឹងខ្សែរបស់មេជាង កាលនឹងប្រាប់ ទើបពោលថា លោកដ៏ចម្រើន លោកកុំសន្ទឹងយ៉ាងនេះ ចូរសន្ទឹងឲ្យល្អ មេជាងពោលថា បពិត្រកុមារ ខ្ញុំសន្ទឹងតាមសមគួរដល់សិប្បៈរបស់ខ្លួន បើធ្វើដទៃក្រៅអំពីនេះ

ខ្ញុំមិនដឹងឡើយ មហាសត្វពោលថា គ្រាន់តែប៉ុណ្ណោះក៏មិនដឹង លោកទទួលទ្រព្យរបស់ពួកយើង ធ្វើសាលាបានដូចម្តេច ចូរនាំខ្សែមក ខ្ញុំនឹងសន្ទឹងឲ្យលោក ឲ្យនាំខ្សែមកហើយក៏សន្ទឹងឯង ខ្សែដែលព្រះមហាសត្វសន្ទឹង ហាក់ដូចវិស្សុកម្មទេវបុត្រសន្ទឹង បន្ទាប់អំពីនោះ ព្រះមហាសត្វបានពោលនឹងមេជាងថា លោកអាចសន្ទឹងខ្សែបានដូច្នេះដែរឬទេ មេជាងពោលថា មិនអាចទេ មហោសថកុមារពោលថា បើដូច្នោះ លោកអាចធ្វើតាមការយល់ឃើញរបស់ខ្ញុំបានដែរឬទេ មេជាងឆ្លើយថា អាច ។ មហាសត្វក៏បែងចែកសាលាឲ្យជាចំណែកៗ គឺបន្ទប់ស្រីអនាថាប្រសូតកូន ១ បន្ទប់ បន្ទប់សម្រាប់សមណព្រាហ្មណ៍ដែលជាអាគន្តុកៈស្នាក់នៅ ១ បន្ទប់ បន្ទប់សម្រាប់គ្រហស្ថដែលជាអាគន្តុកៈ ១ បន្ទប់ បន្ទប់សម្រាប់ដាក់ទំនិញរបស់ពួកឈ្មួញដែលជាអាគន្តុកៈ ១ បន្ទប់ បន្ទប់ទាំងអស់មានទ្វារ និងយ៉មុខ ឲ្យធ្វើទីលានសម្រាប់លេង ទីវិនិច្ឆ័យ សូម្បីរោងធម៌ក៏ធ្វើយ៉ាងនោះ កាលសាលាសម្រេចដោយថ្ងៃបន្តិចបន្តួច ឲ្យហៅជាងគំនូរមកគូរឲ្យជាទីរីករាយ ឲ្យមានចិត្រកម្មទូលំទូលាយ ដោយខ្លួនជាអ្នកបញ្ជា សាលានោះ មានចំណែកប្រៀបដោយទេវសភាឈ្មោះសុធម្មា ។ បន្ទាប់ពីនោះ ព្រះមហាសត្វត្រិះរិះថា ត្រឹមប៉ុណ្ណោះសាលាមិនទាន់ស្អាតឡើយ គួរសាងស្រះបោក្ខរណីឲ្យល្អ ហើយឲ្យជីកស្រះបោក្ខរណី ហៅជាងឥដ្ឋមក ឲ្យសាងស្រះបោក្ខរណី ឲ្យមានជាន់ថ្នាក់រាប់ពាន់ ឲ្យមានកំពង់ចុះរាប់រយ តាមគំនិតរបស់ខ្លួន ស្រះបោក្ខរណីនោះ ដេរដាសដោយបទុមជាតិ ៥ ប្រភេទ ដូចជានន្ទនបោក្ខរណី ឲ្យធ្វើសួន ដាំដើមឈើ

ផ្សេងៗ មានផ្កា និងផ្លែត្រង់មាត់ស្រះនោះ ដូចឧទ្យាននន្ទនវ័ន ។ ហើយប្រើសាលានោះឯងតម្កល់ទានវត្ត ដើម្បីសមណព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌ និងអ្នកដំណើរជាដើម ។ ការធ្វើរបស់ព្រះមហាសត្វនោះ បានប្រាកដទៅក្នុងទីទាំងពួង មនុស្សជាច្រើន បានអាស្រ័យសាលានោះ ។ ព្រះមហាសត្វអង្គុយក្នុងសាលានោះ ពោលវត្ថុដែលគួរធ្វើ និងមិនគួរធ្វើ វត្ថុដែលត្រូវ និងខុសដល់បុគ្គលដែលមកហើយ ផ្ដើមតាំងនូវការវិនិច្ឆ័យសម័យនោះ បានដូចជាពុទ្ធុប្បាទកាល ។

ចំណែកព្រះបាទវិទេហរាជ កន្លងទៅបាន ៧ ឆ្នាំ ទ្រង់រឭកបានថា បណ្ឌិតទាំង ៤ ពោលដល់អញថា បណ្ឌិតទី ៥ នឹងកើតឡើងគ្របសង្កត់ពួកគេ បណ្ឌិតទី ៥ នោះ ឥឡូវនេះនៅឯណា ទ្រង់ឲ្យអមាត្យទាំង ៤ ទៅស៊ើបរកត្រង់ទ្វារទិសទាំង ៤ ឲ្យដឹងទីលំនៅរបស់បណ្ឌិតនោះ អមាត្យដែលចេញទៅតាមទ្វារដទៃៗ មិនជួបព្រះមហាសត្វ អមាត្យដែលចេញទៅតាមទ្វារទិសខាងកើត អង្គុយត្រង់សាលា គិតថា សាលានេះ បុគ្គលឈ្លាសវៃធ្វើខ្លួនឯងឬឲ្យអ្នកដទៃធ្វើ ទើបសួរមនុស្សទាំងឡាយថា សាលានេះជាងណាជាអ្នកធ្វើ មនុស្សទាំងឡាយក៏ប្រាប់ថា សាលានេះ ជាងឈើមិនបានធ្វើឯង តែធ្វើតាមគំនិតរបស់មហោសថបណ្ឌិត ដែលជាកូនរបស់សិរិវឌ្ឍកសេដ្ឋី ដោយកម្លាំងបញ្ញារបស់ខ្លួន អមាត្យសួរថា បណ្ឌិតនោះអាយុប៉ុន្មាន មនុស្សទាំងឡាយឆ្លើយថា ៧ ឆ្នាំបរិបូណ៌ អមាត្យរាប់ឆ្នាំ តាំងពីថ្ងៃដែលព្រះរាជាទ្រង់សុបិនក៏ជ្រាបថា បណ្ឌិតនោះ គឺកុមារនេះឯង ត្រូវគ្នានឹងព្រះរាជាទ្រង់ព្រះសុបិន ទើប

បញ្ជូនទូតទៅទូលព្រះរាជាថា បពិត្រព្រះអង្គ កូនប្រុសរបស់សិរិវឌ្ឍកសេដ្ឋី ក្នុងបាចីនយវមជ្ឈគាម ឈ្មោះមហោសថបណ្ឌិត អាយុបាន ៧ ឆ្នាំ ឲ្យសាងសាលា ស្រះបោក្ខរណី និងឧទ្យានយ៉ាងនេះៗ ទូលបង្គំនឹងនាំបណ្ឌិតនេះមកគាល់ទ្រង់ឬ ព្រះរាជាទ្រង់ស្តាប់ព្រឹត្តិហេតុនោះ មានព្រះហឫទ័យត្រេកអរ ត្រាស់ឲ្យហៅសេនកបណ្ឌិតមក តំណាលសេចក្តីនោះប្រាប់ ហើយត្រាស់សួរថា នែអាចារ្យសេនកៈ តើយើងនឹងធ្វើដូម្តេច យើងគួរនាំបណ្ឌិតនោះមកឬ ។ សេនកបណ្ឌិតនោះជាមនុស្សកំណាញ់ ទើបទូលថា បពិត្រមហារាជ បុគ្គលមិនឈ្មោះថាបណ្ឌិត ដោយគ្រាន់តែចេះធ្វើសាលាជាដើមប៉ុណ្ណោះទេ អ្នកណាៗ ក៏ឲ្យធ្វើបាន សេចក្តីនោះជារឿងបន្តិចបន្តួច ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់សេនកបណ្ឌិត ទ្រង់ត្រិះរិះថា ហេតុការណ៍ក្នុងសេចក្តីនេះ គប្បីមាន ហើយទ្រង់ក៏ស្ងៀម ទ្រង់បញ្ជូនទូតរបស់អមាត្យត្រឡប់ទៅ ដោយព្រះតម្រាស់ថា អមាត្យនោះ ចូរនៅក្នុងទីនោះ ពិចារណាមើលបណ្ឌិតនោះសិន អមាត្យបានស្តាប់ព្រះរាជតម្រាស់នេះ ក៏បានបន្ទង់នៅក្នុងទីនោះ ពិចារណាមើលបណ្ឌិតទៅ រួមមាតិកាសម្រាប់ពិចារណា ក្នុងរឿងនោះមានដូចតទៅ

ដុំសាច់ ១ គោ ១ គ្រឿងប្រដាប់ដែលធ្វើអំពីអំបោះ ១ ដុំអំបោះ ១ បុត្រ ១ មនុស្សទាបឈ្មោះគោឡកាឡ ១ រថ ១ កំណាត់ឈើ ១ លលាដ៍ក្បាលមនុស្ស ១ ពស់ ១ មាន់ ១ កែវមណី ១ គោឈ្មោលកើតកូន ១ បាយ ១ ទោងដែលចងដោយខ្សែ ខ្សាច់ ១ ស្រះទឹក ១ ឧទ្យាន ១ លា ១ កែវមណីក្នុងសំបុក

ក្អែក ១ ។

បណ្ដាមាតិកាទាំងនោះ ពាក្យថា ដុំសាច់ សេចក្ដីថា ថ្ងៃមួយ ព្រះពោធិសត្វទៅកាន់ទីសម្រាប់លេង មានខ្លែងមួយ ឆាបដុំសាច់ត្រង់ជ្រញ់អ្នកសម្លាប់សត្វ ហើរមកតាមអាកាស ទារកទាំងឡាយឃើញខ្លែងពាំដុំសាច់ហើរមក ក៏ដេញទៅ ដោយគិតថា ឲ្យខ្លែងទម្លាក់ដុំសាច់នោះ ក្មេងទាំងនោះរត់ទៅកាន់ទីផ្សេងៗ មើលតែខាងលើ រត់ទៅអំពីខាងក្រោយខ្លែងនោះ ក៏ជំពប់ជើងត្រង់ជន្លត់ ត្រង់ដុំថ្មជាដើម រមែងលំបាក លំដាប់នោះ មហោសថបណ្ឌិត ពោលនឹងក្មេងទាំងនោះថា យើងនឹងឲ្យខ្លែងនោះទម្លាក់ដុំសាច់ ក្មេងទាំងឡាយក៏ឲ្យព្រះមហោសថសាកល្បងមើល ទើបព្រះពោធិសត្វពោលថា បើដូច្នោះ ចូរអ្នកទាំងឡាយមើល ថាហើយ ក៏រត់តាមខាងក្រោយលឿនដូចខ្យល់ មិនមើលខាងលើ លុះឃើញស្រមោលខ្លែងក៏ទះដៃ ស្រែកដោយសំឡេងខ្លាំង ដោយតេជានុភាពនៃមហាសត្វ សំឡេងនោះហាក់ចូលទៅក្នុងពោះរបស់ខ្លែងនោះ ខ្លែងខ្លាចក៏ទម្លាក់ដុំសាច់ មហាសត្វដឹងថា ខ្លែងទម្លាក់ដុំសាច់ហើយ សម្លឹងមើលស្រមោល ទទួលយកក្នុងអាកាសមិនឲ្យធ្លាក់ដល់ដី មហាជនឃើញមហាសត្វធ្វើដូច្នោះ កើតអស្ចារ្យ បន្លឺសម្រែកហ៊ោទះដៃ ធ្វើសំឡេងខ្ទរខ្ទារទៅ អមាត្យដឹងព្រឹត្តិការណ៍នោះ ក៏បញ្ជូនទូតទៅទូលព្រះរាជាទៀតថា បពិត្រព្រះអង្គ មហោសថបណ្ឌិត បានញ៉ាំងខ្លែងឲ្យទម្លាក់ដុំសាច់ដោយឧបាយយ៉ាងនេះៗ សូមព្រះសម្មតិទេពជ្រាបព្រឹត្តិហេតុនេះ ។ ព្រះរាជាទ្រង់ស្ដាប់ដូច្នោះ ក៏ត្រាស់សួរអាចារ្យសេនកបណ្ឌិតថា លោកអាចារ្យ

សេនកៈ យើងនឹងនាំបណ្ឌិតមកឬ សេនកបណ្ឌិតគិតថា ចាប់ពីពេលដែលមហោសថកុមារមកក្នុងរាជដំណាក់នេះ ពួកយើង ៤ នាក់ នឹងអស់ស្នេ ព្រះរាជានឹងមិនជ្រាបថា ពួកយើងមាន មិនគួរឲ្យនាំមហោសថកុមារនោះមកឡើយ ព្រោះភាពជាអ្នកកំណាញ់លាភ ទើបទូលថា បពិត្រមហារាជ បុគ្គលមិនឈ្មោះថាជាបណ្ឌិត ដោយហេតុត្រឹមប៉ុណ្ណោះឡើយ សេចក្តីនោះ ជារឿងបន្តិចបន្តួច ៗ ព្រះរាជាទ្រង់មានខ្លួនជាកណ្តាល ទើបបញ្ជូនទូតនោះត្រឡប់ទៅ ដោយព្រះរាជតម្រាស់ថា ចូរពិចារណាមហោសថនោះ ក្នុងទីនោះតទៅ ។

រឿងគោ សេចក្តីថា បុរសអ្នកបាចីនយវមជ្ឈគាមម្នាក់ គិតថា កាលភ្លៀងធ្លាក់ អញនឹងភ្ជួរស្រែ ទើបទិញគោអំពីស្រុកដទៃនាំមកកាន់ផ្ទះរបស់ខ្លួនស្អែកឡើង នាំទៅកាន់ទីមានស្មៅដើម្បីឃ្វាល អង្គុយលើខ្នងគោ លុះហត់នឿយ ក៏ចុះទៅអង្គុយត្រង់គល់ឈើដេកលក់ទៅ ខណៈនោះ ចោរម្នាក់ក៏មកនាំគោគេចទៅ បុរសម្ចាស់គោភ្ញាក់ឡើង មិនឃើញគោ រកគោក្នុងទីផ្សេងៗ ឃើញចោរនោះ ក៏រត់ដេញទៅដោយសម្ទុះដ៏រហ័ស ហើយពោលថា ឯងនាំគោរបស់យើងទៅណា ចោរឆ្លើយថា ឯងនិយាយអ្វី អញនាំគោរបស់អញទៅកាន់ទីដែលត្រូវការ មហាជនមកស្តាប់ជនទាំងពីរ ទាស់ទែងគ្នាជាច្រើន មហោសថបណ្ឌិតស្តាប់សំឡេងមនុស្សទាំងឡាយ ដែលទៅតាមផ្លូវទ្វារសាលា ទើបហៅជនទាំងពីរមក ឃើញអាកប្បកិរិយារបស់ជនទាំងពីរ ក៏ដឹងថា បុគ្គលនេះជាចោរ បុគ្គលនេះជាម្ចាស់គោ តែទោះជាដឹង ក៏សួរថា អ្នកទាំងពីរទាស់ទែងគ្នាព្រោះហេតុអ្វី ម្ចាស់គោពោលថា បពិត្រលោកម្ចាស់ ខ្ញុំ

ទិញគោនេះមកអំពីមនុស្សឈ្មោះនេះ ក្នុងស្រុកឈ្មោះនោះ នាំមកផ្ទះ ហើយយកទៅឃ្វាលក្នុងទីដែលមានស្មៅ អំពីព្រលឹម បុរសនេះនាំគោរបស់ខ្ញុំគេចទៅ ព្រោះឃើញខ្ញុំប្រមាទ ក្នុងពេលនោះ ខ្ញុំសម្លឹងរកគោក្នុងទីផ្សេងៗ ឃើញបុរសនេះ ទើបដេញតាមទៅចាប់ខ្លួនមក អ្នកស្រុកនោះ ដឹងការដែលខ្ញុំទិញគោនេះមក ។ ចំណែកចោរពោលថា គោនេះ កើតក្នុងផ្ទះរបស់ខ្ញុំ បុរសនេះនិយាយកុហក ។ លំដាប់នោះ មហោសថបណ្ឌិត ក៏សួរបុរសទាំងពីរថា ខ្ញុំនឹងវិនិច្ឆ័យក្តីរបស់អ្នកទាំង ២ ដោយយុត្តិធម៌ អ្នកទាំងពីរនឹងតាំងនៅក្នុងវិនិច្ឆ័យឬ កាលមនុស្សទាំងពីរទទួលថា នឹងតាំងនៅ គិតថា គួរកាន់យកតាមគាប់ចិត្តរបស់មហាជន ទើបសួរចោរមុនថា គោទាំងនេះ អ្នកឲ្យស៊ីអ្វីឲ្យផឹកអ្វី ចោរឆ្លើយថា បពិត្របណ្ឌិត ខ្ញុំឲ្យគោផឹកបបរ ឲ្យស៊ីល្ង ម្សៅ និងនំកុម្មាស បន្ទាប់អំពីនោះ ក៏សួរម្ចាស់គោ ម្ចាស់គោឆ្លើយថា អាហារមានបបរជាដើម អ្នកក្រីក្រដូចខ្ញុំបានមកអំពីណា ខ្ញុំឲ្យស៊ីស្មៅប៉ុណ្ណោះ មហោ-សថបណ្ឌិតស្តាប់ពាក្យរបស់ជនទាំងពីរហើយ ក៏ឲ្យមនុស្សយកថាសមក ឲ្យយកស្លឹកប្រយង្គុមកបុកក្នុងត្បាល់ ប្របាច់ដោយទឹក ឲ្យគោផឹក គោក៏រើអៀងមកចេញសុទ្ធតែស្មៅ មហោសថបណ្ឌិតបង្ហាញដល់មហាជនឲ្យឃើញហើយ សួរចោរថា ឯងជាចោរ ឬមិនមែនចោរ ចោរក៏សារភាពថា ខ្លួនជាចោរ មហោសថបណ្ឌិតឲ្យឱវាទថា បើយ៉ាងនោះ ចាប់ពីពេលនេះទៅ អ្នកកុំធ្វើយ៉ាងនេះ ចំណែកបរិស័ទរបស់ព្រះពោធិសត្វ ក៏វាយចោរនោះដោយដៃនិងជើងធ្វើឲ្យខ្សោយកម្លាំង ។ លំដាប់នោះ មហោសថបណ្ឌិតបានពោល

ទូន្មាននឹងចោរនោះថា ចូរអ្នកឃើញទុក្ខរបស់អ្នកក្នុងជាតិនេះប៉ុណ្ណោះ តែក្នុងកពខាងមុខ អ្នកនឹងសោយទុក្ខធំក្នុងនរកជាដើម ចាប់ពីពេលនេះទៅ ចូរអ្នកលះបង់នូវកម្មនេះ ហើយឲ្យបញ្ចសីលដល់ចោរនោះ អមាត្យទូលព្រឹត្តិការណ៍នោះដល់ព្រះរាជាតាមសេចក្ដីពិត ព្រះរាជាត្រាស់សួរសេនកបណ្ឌិតថា លោកអាចារ្យសេនកៈ យើងគួរនាំបណ្ឌិតនោះមកឬ កាលសេនកបណ្ឌិតទូលថា បពិត្រមហារាជ គ្រាន់តែរឿងគោ អ្នកណាក៏វិនិច្ឆ័យបាន បុគ្គលមិនឈ្មោះជាបណ្ឌិត ដោយហេតុត្រឹមប៉ុណ្ណោះឡើយ សូមទ្រង់បង្អង់សិន ព្រះរាជាទ្រង់ដាក់ខ្លួនជាកណ្ដាល ទើបបញ្ជូនដំណឹងទៅយ៉ាងនោះទៀត អ្នកប្រាជ្ញគប្បីជ្រាបក្នុងវិធីប្រកបទាំងពួងយ៉ាងនេះ ខាងមុខអំពីនេះទៅ នឹងលើកត្រឹមតែមាតិការឿងប៉ុណ្ណោះមកសម្ដែង ។

រឿងគ្រឿងប្រដាប់មានសេចក្ដីថា មានស្រីក្រីក្រម្នាក់ ដោះគ្រឿងប្រដាប់ដែលធ្វើជាកង់ៗ ស្រោក់ដោយអំបោះពណ៌ផ្សេងៗ អំពីក ដាក់លើសំពត់សាដកចុះកាន់ស្រះបោក្ខរណី ដែលមហោសថបណ្ឌិតធ្វើ ដើម្បីងូតទឹក ស្រីក្មេងម្នាក់ឃើញគ្រឿងប្រដាប់នោះ កើតចិត្តលោភ កាន់យកគ្រឿងប្រដាប់ សរសើរថាគ្រឿងប្រដាប់នេះល្អណាស់ អ្នកធ្វើអស់ថ្លៃប៉ុន្មាន ខ្ញុំចង់ធ្វើខ្សែកបែបនេះតាមគួរដល់សិប្បៈរបស់ខ្លួន ពោលសរសើរដូច្នេះហើយ ក៏យកមកពាក់ត្រង់ក ហើយពោលថា ខ្ញុំនឹងពិចារណាប្រមាណនៃគ្រឿងប្រដាប់នោះសិន ស្រីជាម្ចាស់ទ្រព្យពោលថា ចូរពិចារណាមើលចុះ ព្រោះស្រីម្ចាស់ទ្រព្យ ជាអ្នកមានចិត្តត្រង់ ស្រីក្មេងកាលប្រដាប់ត្រង់កខ្លួនហើយ ក៏ចៀសចេញទៅ ចំណែក

ស្រីជាម្ចាស់ទ្រព្យឃើញដូច្នោះ ក៏ប្រញាប់ប្រញាល់ឡើងអំពីស្រះបោក្ខរណី ស្លៀកសំពត់សាដកដេញតាមទៅ ទាញសំពត់ជាប់ ពោលថា ហឯកាន់យកគ្រឿងប្រដាប់របស់អញទៅណា ចំណែកស្រីចោរឆ្លើយថា អញមិនបានយកគ្រឿងប្រដាប់របស់ហឯទេ គ្រឿងប្រដាប់ត្រង់ក ជារបស់អញទេតើ មហាជនប្រជុំគ្នាស្តាប់ជម្លោះនោះ ចំណែកមហោសថបណ្ឌិត លេងជាមួយពួកទារក បានស្តាប់សំឡេងស្រីពីរនាក់នោះ ឈ្លោះគ្នាត្រង់ទ្វារសាលា សួរថា នុ៎ះជាសំឡេងអ្វី បានស្តាប់ហេតុដែលស្រីទាំងពីរឈ្លោះគ្នាហើយក៏ហៅមក សូម្បីដឹងដោយអាការថា ស្រីនេះជាចោរ ស្រីនេះមិនមែនចោរ ក៏សួរសេចក្តីនោះហើយពោលថា នាងទាំងពីរនឹងតាំងនៅក្នុងវិនិច្ឆ័យរបស់ខ្ញុំឬ កាលស្រីទាំងពីរទទួលថា នឹងតាំងនៅ ទើបសួរស្រីចោរមុនថា នាងជ្រលក់គ្រឿងប្រដាប់នេះដោយរបស់ក្រអូបធ្វើអំពីអ្វី ស្រីចោរឆ្លើយថា ខ្ញុំជ្រលក់ដោយគ្រឿងក្រអូបគ្រប់យ៉ាង គ្រឿងក្រអូបដែលប្រកបដោយរបស់ក្រអូបទាំងពួង ឈ្មោះថាគ្រឿងក្រអូបគ្រប់យ៉ាង ។ លំដាប់នោះ មហោសថបណ្ឌិត សួរស្រីម្ចាស់ទ្រព្យថា នាងឆ្លើយថា ព្រោះខ្ញុំជាស្រីក្រីក្រ គ្រឿងក្រអូបសព្វយ៉ាងនឹងមានមកអំពីណា ខ្ញុំជ្រលក់ដោយគ្រឿងក្រអូប គឺផ្កាប្រយង្គុប៉ុណ្ណោះ ។ មហោ-សថបណ្ឌិត ឲ្យមនុស្សរបស់ខ្លួនកំណត់ពាក្យរបស់ស្រីទាំងពីរនោះ ហើយឲ្យយកភាជនៈមកត្រាំគ្រឿងប្រដាប់ក្នុងភាជនៈនោះ ឲ្យហៅអ្នកដែលពូកែស្រង់ក្លិនមកប្រាប់ថា ចូរពួកលោកហិតគ្រឿងប្រដាប់នោះ តើជាក្លិនអ្វី អ្នកស្ទាត់ជំនាញខាងក្លិន ហិតគ្រឿងប្រដាប់នោះហើយ ក៏ដឹងថា ក្លិនផ្កាប្រយង្គុ ទើប

ពោលគាថានេះ ក្នុងឯកនិបាតថា

**សព្វសំហារកោ នត្ថិ សុទ្ធំ កង្គុ បវាយតិ អលិកំ ភាសតិ យំ ធុត្តី សច្ចមាហុ មហល្លិកាតិ។**

គ្រឿងអប់ទាំងពួងគ្មានទេ សុទ្ធតែផ្កាប្រយង្គុទេតើ បក់ផ្សាយទៅ ( នោះ ) ឯស្ត្រីអ្នកលេង រមែងពោលពាក្យមិនពិត ស្ត្រីចាស់ ទើបបានពោលពាក្យពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធុត្តី** បានដល់ ស្រីចោរ ។ បទថា **អាហុ** បានដល់ ពោលហើយ ។ ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។

លំដាប់នោះ ព្រះមហាសត្វញ៉ាំងមហាជនឲ្យដឹងហេតុការណ៍នោះហើយ សួរថា នាងជាចោរឬ ហើយស្រីនោះសារភាពថាខ្លួនជាចោរ ចាប់តាំងពីពេលនោះ ភាពដែលមហាសត្វជាបណ្ឌិត ក៏ប្រាកដដល់មហាជន ។

រឿងដុំអំបោះ មានសេចក្តីថា មានស្ត្រីម្នាក់រក្សាចម្ការកប្បាស កាលយាមចម្ការ បានបេះកប្បាសដែលបរិសុទ្ធក្នុងចម្ការនោះ មកធ្វើឲ្យជាសរសៃតូចៗ ហើយយកគ្រាប់ទន្ទាប់មកដាក់ខាងក្នុង ហើយរុំអំបោះនោះអំពីខាងក្រៅ ធ្វើជាដុំក្នុងថ្នក់ កាលត្រឡប់មកផ្ទះ គិតថា អញនឹងងូតទឹកក្នុងស្រះបោក្ខរណីរបស់បណ្ឌិត ទើបដាក់ដុំអំបោះនោះលើសំពត់សាដក ហើយចុះងូតទឹក ។ មានស្រីម្នាក់ឃើញដុំអំបោះនោះ ក៏កាន់យកដោយចិត្តលោភ ទះដៃពោលថា ឱអំបោះនេះល្អ នាងធ្វើឬ ធ្វើដូចជាមើល ហើយដាក់ក្នុងថ្នក់ចៀសចេញទៅ ។ រឿងដ៏សេសគប្បីជ្រាបដោយន័យមុននោះឯង មហោសថ-

បណ្ឌិតសួរស្រីចោរមុនថា កាលនាងធ្វើអំបោះឲ្យជាដុំបានដាក់អ្វីខាងក្នុង ស្រីចោរនោះឆ្លើយថា ខ្ញុំបានដាក់ផ្លែកប្បាសនោះឯងខាងក្នុង បន្ទាប់អំពីនោះ មហោសថបណ្ឌិត ក៏សួរស្រីម្នាក់ទៀតដែលជាម្ចាស់ទ្រព្យ នាងឆ្លើយថា ដាក់គ្រាប់ទន្ទាប់ខាងក្នុង មហោសថបណ្ឌិត ឲ្យមនុស្សរបស់ខ្លួនកំណត់ពាក្យរបស់ស្រីទាំងពីរ ហើយឲ្យលាដុំអំបោះនោះចេញ ឃើញគ្រាប់ទន្ទាប់ ទើបឲ្យស្រីចោរនោះទទួលសារភាពថាជាចោរ មហាជនត្រេកអរពោលថា មហោសថបណ្ឌិតវិនិច្ឆ័យក្តីល្អ បានឲ្យសាធុការជាច្រើន ។

រឿងកូន មានសេចក្តីថា មានស្ត្រីម្នាក់ ពកូនទៅកាន់ស្រះបោក្ខរណីរបស់មហោសថបណ្ឌិត ដើម្បីលុបមុខ ឲ្យកូនងូតទឹកហើយ ដាក់ឲ្យអង្គុយលើសំពត់សាដករបស់ខ្លួន ខ្លួនឯងក៏ចុះលុបមុខ ខណៈនោះ មានយក្ខិនីម្នាក់ឃើញទារកនោះ ចង់បរិភោគ ទើបកាឡាខ្លួនជាស្ត្រីមកសួរថា នែសម្លាញ់ កូនក្មេងនេះស្អាតហ្ន៎ ជាកូនរបស់នាងឬ កាលស្ត្រីជាម្តាយទទួលថា ជាកូនរបស់ខ្លួន ទើបពោលថា ខ្ញុំនឹងឲ្យបៅដោះ កាលស្ត្រីមាតាអនុញ្ញាតហើយ ក៏ពទារកនោះឲ្យលេងបន្តិច ហើយនាំទារកនោះគេចទៅ ស្រីជាមាតាឃើញដូច្នោះ ក៏ឡើងអំពីទឹករត់ទៅដោយរហ័ស ទាញសំពត់សាដក ពោលថា ហាងនាំកូនអញទៅណា យក្ខិនីពោលថា ហាងបានកូនអំពីណា នេះជាកូនរបស់អញទេតើ ស្រីទាំង ២ ឈ្លោះគ្នា ដើរទៅដល់ទ្វារសាលា មហោសថបណ្ឌិតបានស្តាប់សំឡេងរបស់ស្រីទាំងពីរឈ្លោះគ្នា ឲ្យហៅមក សួរថា តើមានរឿងអ្វី ស្រីទាំងពីរ ក៏ប្រាប់ឲ្យជ្រាបរឿងនោះ មហោសថស្តាប់ពាក្យ

នោះហើយ សូម្បីដឹងថា ស្រីនេះ ជាយក្ខិនីដោយឥតសង្ស័យ ព្រោះមិនប៉ប្រិចភ្នែក មានភ្នែកក្រហម មិនមានស្រមោល ទើបពោលថា នាងទាំងពីរនឹងតាំងនៅក្នុងវិនិច្ឆ័យរបស់យើងឬ កាលបានទទួលពាក្យថា នឹងតាំងនៅក្នុងវិនិច្ឆ័យ ទើបគូសគំនូសលើផែនដី ឲ្យទារកដេកត្រង់កណ្តាលស្នាមគំនូស ឲ្យយក្ខិនីចាប់ដៃទារក ឲ្យស្រីជាម្តាយចាប់ជើង ហើយពោលថា ចូរនាងទាំងពីរអូសទារកយកចុះ ទារកនោះជាកូនរបស់បុគ្គលណាដែលអាចដណ្តើមយកបាន ស្រីទាំងពីរក៏អូសទារកនោះ ទារកនោះត្រូវទាញទៅដោយសេចក្តីលំបាក ក៏ស្រែកយំ ស្រីជាម្តាយស្តាប់សំឡេងនោះ បេះដូងហាក់ដូចជាបែកធ្លាយ លែងនូវកូនហើយ ឈរយំ មហោសថបណ្ឌិតសួរមហាជនថា ចិត្តរបស់ម្តាយទារកទន់ ឬចិត្តរបស់ស្រីដែលមិនមែនជាមាតាទន់ មហាជនឆ្លើយថា ចិត្តរបស់ម្តាយទន់ មហោសថបណ្ឌិតក៏សួរមហាជនថា ឥឡូវនេះ យើងគិតដូចម្តេច ស្រីដែលទាញទារកទៅហើយឈរ ជាមាតា ឬស្រីដែលលែងទារកហើយឈរ ជាមាតា មហាជនឆ្លើយថា ស្រីដែលលះបង់ទារកហើយឈរ ជាមាតា មហោសថពោលថា បើដូច្នោះ អ្នកទាំងឡាយដឹងទេថា ស្រីនេះជាអ្វីដែលលួចទារក មនុស្សទាំងឡាយឆ្លើយថា មិនដឹងទេ មហោសថក៏ពោលថា ស្រីនេះ ជាយក្ខិនី ទាញយកទារកទៅដើម្បីបរិភោគ មហាជនសួរថា តើដឹងបានដូចម្តេច មហោសថឆ្លើយថា ដឹងបានដោយឥតសង្ស័យ ព្រោះយក្ខិនីមិនប៉ប្រិចភ្នែក ភ្នែកក្រហម មិនមានស្រមោល និងប្រាសចាកសេចក្តីករុណា ។ លំដាប់នោះ ព្រះមហាសត្វសួរស្រីនោះថា នាងជានរណា

យក្ខិនីឆ្លើយថា ខ្ញុំជាយក្ខិនី មហាសត្វពោលថា នាងយកទារកនេះទៅធ្វើអ្វី យក្ខិនីឆ្លើយថា យកទៅស៊ី មហាសត្វពោលថា នែស្រីអន្ធពាល ក្នុងកាលមុននាងធ្វើបាប ទើបកើតជាយក្ខិនី ឥឡូវនេះ នៅធ្វើបាបទៀត ឱបុគ្គលអន្ធពាល ពោលដូច្នេះហើយ ឲ្យយក្ខិនីតាំងនៅក្នុងបញ្ចសីល ហើយដោះលែងទៅ ចំណែកស្រីជាមាតារបស់ទារកពោលថា សូមលោកមានអាយុវែង សរសើរមហោសថបណ្ឌិតហើយ នាំកូនចៀសចេញទៅ ។

រឿងបុរសតឿ ឈ្មោះគោឡកាឡៈ មានសេចក្ដីថា បុរសម្នាក់ឈ្មោះគោឡកាឡៈ ជាមនុស្សទាបតឿ សម្បុរខ្មៅ គាត់ធ្វើការងារ ៧ ឆ្នាំ ទើបបានភរិយាឈ្មោះទីឃតាលា ។ ថ្ងៃមួយ គោឡកាឡៈ ហៅភរិយាមកពោលថា ចូរនាងចៀនទំនំដែលគួរទំពា កាលនាងសួរថា អ្នកគិតទៅណា ទើបប្រាប់ថា យើងនឹងទៅសួរសុខទុក្ខមាតាបិតា នាងឃាត់ថា អ្នកត្រូវការអ្វីដោយមាតាបិតា គោឡកាឡៈក៏នៅតែប្រើឲ្យចៀនទំនំអស់វារៈ ៣ ដង ទើបកាន់យកស្បៀង និងរបស់ផ្ញើ ធ្វើដំណើរទៅជាមួយភរិយានោះ ក្នុងរវាងផ្លូវ បានឃើញស្ទឹងមានទឹកហូរខ្ពុលខ្លាញ់ ប្ដីប្រពន្ធទាំងពីរនោះជាមនុស្សខ្លាច មិនហ៊ានចុះ ក៏ឈរត្រង់មាត់ស្ទឹង ។ កាលនោះ មានបុរសក្រីក្រម្នាក់ ឈ្មោះទីឃបិដ្ឋិ ដើរស្រេបមកតាមមាត់ស្ទឹងដល់ទីនោះ ប្ដីប្រពន្ធឃើញបុរសនោះសួរថា ស្ទឹងនេះ ជ្រៅ ឬរាក់ ទីឃបិដ្ឋិដឹងថា ប្ដីប្រពន្ធទាំងពីរជាអ្នកខ្លាចទឹក ទើបឆ្លើយថា ទឹកនេះជ្រៅពន់ពេក ត្រីកាចក៏សម្បូរ ទើបប្ដីប្រពន្ធសួរថា នែសម្លាញ់ តើយើងនឹងទៅបានដូចម្ដេច បុរសនោះឆ្លើយថា ខ្ញុំមានសេចក្ដីស្និទ្ធ

ស្នាលជាមួយក្រពើ និងមករ ដូច្នោះ សត្វកាចទាំងនោះមិនបៀតបៀនយើង ឡើយ ជន ២ នាក់ប្តីប្រពន្ធ ពោលថា បើដូច្នោះ សូមសម្លាញ់ចម្លងយើង ទាំងពីរទៅ បុរសនោះទទួលពាក្យថា សាធុ ។ លំដាប់នោះ ប្តីប្រពន្ធទាំង ពីរក៏ឲ្យរបស់ទំពា និងរបស់បរិភោគដល់បុរសនោះៗ បរិភោគឆ្អែតហើយ ក៏ សួរថា នែសម្លាញ់ ឲ្យយើងនាំអ្នកណាទៅមុន នាយគោឡកាឡៈឆ្លើយថា ចូរ នាំកិរិយាខ្ញុំទៅមុន សឹមនាំខ្ញុំទៅឯក្រោយ បុរសនោះទទួលពាក្យថា សាធុ ឲ្យនាងទីឃតាហលាឡើងលើ-ក កាន់យកស្បៀង និងរបស់ផ្សេងទាំងអស់ ចុះ ទឹកទៅបានបន្តិចហើយ អង្គុញខ្លួនឆ្លងទៅ លំដាប់នោះ នាយគោឡកាឡៈ ឈរត្រង់មាត់ច្រាំង គិតថា ទឹកនេះជ្រៅពិត បុរសខ្ពស់គង់បែបនេះ តែអញ មិនបានការនោះឯង ចំណែកទីឃបិដ្ឋិ នាំនាងទីឃតាហលាទៅដល់កណ្តាល ស្ទឹង ក៏និយាយលែបខាយថា ខ្ញុំនឹងចិញ្ចឹមនាង នាងនឹងមានសំពត់គ្រឿង ប្រដាប់បរិបូណ៌ មានអ្នកបម្រើប្រុសស្រីចោមរោម គោឡកាឡៈកន្លើនោះ ធ្វើអ្វីដល់នាងបាន ចូរនាងធ្វើតាមពាក្យខ្ញុំ នាងទីឃតាហលាបានស្តាប់ពាក្យ របស់ទីឃបិដ្ឋិនោះ ក៏កាត់សេចក្តីស្នេហាក្នុងប្តីរបស់ខ្លួន មានចិត្តប្រតិព័ទ្ធក្នុង នាយទីឃបិដ្ឋិនោះក្នុងខណៈនោះឯង ទើបពោលឆ្លើយថា បើអ្នកមិនបោះបង់ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នក នាយទីឃបិដ្ឋិពោលថា នាងនិយាយអ្វី ខ្ញុំនឹង មើលថែនាង ជនទាំងពីរនោះ ទៅដល់ត្រើយនាយ ក៏សរសើរនូវគ្នានិងគ្នា លះបង់នូវនាយគោឡកាឡៈពោលថា សូមរង់ចាំសិនៗ ហើយទំពាស៊ីរបស់ ដែលគួរស៊ី ក្នុងទីចំពោះមុខនាយគោឡកាឡៈដែលកំពុងមើលនោះឯង ហើយ

នាំគ្នាចៀសចេញទៅ ។ នាយគោឡុកាឡុះឃើញដូច្នោះ គិតថា ជនទាំងពីរនេះប្រហែលជារួមគ្នាបោលអញ ហើយគេចទៅ រត់ទៅរត់មក ចុះទៅបានបន្តិច ក៏ឡើងមកវិញ ព្រោះសេចក្តីខ្លាច ហើយចុះម្តងទៀត ដោយសេចក្តីក្រោធក្នុងជនទាំងពីរនោះ លោតចុះដោយតាំងចិត្តថា ទោះជាស្លាប់ក៏ដោយចុះ ហើយចុះទៅកាន់ស្ទឹង ទើបដឹងថា ទឹករាក់ ក៏ឡើងអំពីស្ទឹង ដេញតាមទៅដោយរហ័ស លុះទាន់ជនទាំងពីរក៏ពោលថា នែចោរអាក្រក់ អានាំប្រពន្ធអញទៅណា ទីឃបិដ្ឋិពោលតបថា នែអាក្រិស ស្រីនេះ ជាប្រពន្ធអាពីអន្កាល់ណា ពោលដូច្នេះហើយ ក៏បណ្តេញគោឡុកាឡុះទៅ នាយគោឡុ-កាឡុះចាប់ដៃនាងទីឃតាហលាពោលថា ឈប់សិន ឈប់សិន នាងចង់ទៅណា យើងធ្វើការអស់ ៧ ឆ្នាំ ទើបបាននាងជាប្រពន្ធ កាលឈ្លោះជាមួយនាយទីឃបិដ្ឋិបណ្តើរៗ ក៏មកដល់សាលារបស់មហាសត្វ មហាជនប្រជុំគ្នា មហោសថបណ្ឌិតសួរថា នុ៎ះជាសំឡេងអ្វី បានដឹងសេចក្តីនោះហើយ ឲ្យហៅមនុស្សទាំងពីរ បានស្តាប់ពាក្យឆ្លើយឆ្លងរបស់ជនទាំងពីរហើយ ក៏ពោលថា អ្នកទាំងពីរឲ្យខ្ញុំវិនិច្ឆ័យឬ កាលមនុស្សទាំងពីរយល់ព្រម ទើបសួរនាយទីឃបិដ្ឋិមុនថា តើអ្នកឈ្មោះអ្វី ទីឃបិដ្ឋិឆ្លើយថា ខ្ញុំឈ្មោះទីឃបិដ្ឋិ មហាសត្វសួរថា ភរិយារបស់អ្នកឈ្មោះអ្វី កាលមិនទាន់ស្គាល់ឈ្មោះ ក៏ប្រាប់ឈ្មោះដទៃ មហាសត្វសួរទៀតថា មាតាបិតារបស់អ្នកឈ្មោះអ្វី ក៏ប្រាប់ឈ្មោះនោះៗ មាតាបិតារបស់ភរិយាឈ្មោះអ្វី កាលមិនទាន់ស្គាល់ ក៏ប្រាប់ឈ្មោះដទៃ ។ លំដាប់នោះ មហោសថបណ្ឌិត ឲ្យហៅមនុស្សរបស់ខ្លួនកំណត់ពាក្យ

នោះ ហើយឲ្យនាយទីឃបិដ្ឋិនោះចេញទៅ ហៅនាយគោឡកាឡៈមកសួរឈ្មោះមនុស្សទាំងពួង ដោយន័យមុននោះឯង នាយគោឡកាឡៈស្គាល់តាមសេចក្ដីពិត ក៏ប្រាប់មិនខុស ព្រះពោធិសត្វក៏ឲ្យនាំនាយគោឡកាឡៈចេញទៅ ឲ្យហៅនាងទីឃតាហលាមកសួរថា នាងឈ្មោះអ្វី ស្រីនោះឆ្លើយថា ខ្ញុំឈ្មោះទីឃតាហលា ប្ដីនាងឈ្មោះអ្វី កាលមិនទាន់ស្គាល់ ក៏ប្រាប់ឈ្មោះដទៃ មាតាបិតារបស់នាងឈ្មោះអ្វី ក៏ប្រាប់ឈ្មោះនោះៗ មាតាបិតារបស់ប្ដីនាងឈ្មោះអ្វី កាលមិនដឹង ក៏ប្រាប់ឈ្មោះដទៃ មហោសថបណ្ឌិត ហៅនាយទីឃបិដ្ឋិ និងនាយគោឡកាឡៈមកហើយ សួរមហាជនថា ពាក្យរបស់នាងទីឃតាហលាសមនឹងពាក្យទីឃបិដ្ឋិ ឬសមនឹងពាក្យគោឡកាឡៈ មហាជនឆ្លើយថា ពាក្យរបស់នាងទីឃតាហលា សមនឹងពាក្យរបស់នាយគោឡកាឡៈ មហោសថ-បណ្ឌិតក៏ពោលថា នាយគោឡកាឡៈ ជាប្ដីរបស់នាងទីឃតាហលា ទីឃបិដ្ឋិជាចោរ ។ លំដាប់នោះ មហោសថបណ្ឌិតក៏សួរនាយទីឃបិដ្ឋិថា អ្នកជាចោរឬ នាយទីឃបិដ្ឋិទទួលសារភាពថា ខ្លួនជាចោរ ។ នាយគោឡកាឡៈ បានកិរិយារបស់ខ្លួនមកវិញ ដោយការវិនិច្ឆ័យរបស់មហោសថបណ្ឌិត សរសើរមហោសថបណ្ឌិតហើយ នាំកិរិយាចៀសចេញទៅ ។ មហោសថបណ្ឌិតពោលនឹងទីឃបិដ្ឋិថា ចាប់ពីថ្ងៃនេះទៅ អ្នកកុំធ្វើកម្មបែបនេះទៀត ។

ក្នុងរឿងរថ មានសេចក្ដីថា កាលនោះ មានបុរសម្នាក់អង្គុយក្នុងរថចេញអំពីស្រុកដើម្បីលុបមុខ ខណៈនោះ សក្កទេវរាជ ទ្រង់ពិចារណាឃើញព្រះពោធិសត្វ ទើបត្រិះរិះថា អញនឹងធ្វើបញ្ញានុភាពនៃមហោសថពុទ្ធង្កូរឲ្យ

ប្រាកដ ទើបយានមកដោយភេទជាមនុស្ស ចាប់ប្រែករទេះបុរសជាម្ចាស់រទេះ សួរថា បពិត្រលោកឪពុក លោកមកដោយប្រយោជន៍អ្វី កាលបានស្តាប់ថា មកដើម្បីសូមបម្រើខ្លួន ទើបទទួលថា សាធុ ហើយក៏ចុះអំពីរទេះទៅដើម្បីធ្វើសរីរកិច្ច ខណៈនោះ សក្កទេវរាជឡើងរថបរទៅដោយរហ័ស បុរសជាម្ចាស់រថ ធ្វើសរីរកិច្ចស្រេចហើយ ចេញមកឃើញសក្កទេវរាជបំបោលរទេះ ក៏ដេញតាមទៅដោយរហ័ស ពោលថា ឈប់ ឈប់ ឯងនាំរថរបស់យើងទៅណា កាលសក្កទេវរាជឆ្លើយថា រថរបស់ឯងដទៃទេ តែនេះជារថរបស់យើង ក៏កើតជម្លោះដល់គ្នានិងគ្នាទៅដល់ទ្វារសាលា ។ មហោសថបណ្ឌិតសួរថា តើមានរឿងអ្វី ហើយក៏ហៅមនុស្សទាំងពីរនោះមក ឃើញមនុស្សទាំងពីរមកដោយអាការនោះ ក៏ដឹងច្បាស់ថា បុរសនេះជាសក្កទេវរាជព្រោះប្រាសចាកការខ្លាចក្រែង និងមិនប៉ប្រិចភ្នែក បុរសនេះជាម្ចាស់រទេះកាលបើដូច្នោះ មហោសថក៏សួរដល់ហេតុនៃវិវាទថា អ្នកទាំងពីរនឹងតាំងនៅក្នុងវិនិច្ឆ័យរបស់ខ្ញុំឬ កាលបានស្តាប់ពាក្យថា នឹងតាំងនៅ ក៏ពោលថា ខ្ញុំនឹងបររថទៅ អ្នកទាំងពីរចូរចាប់ប្រែករទេះ ម្ចាស់របស់រថនឹងមិនលែង បុគ្គលមិនមែនម្ចាស់របស់រថនឹងលែង ពោលដូច្នេះហើយ ប្រាប់បុរសម្នាក់ថា ចូរអ្នកបររថទៅ បុរសនោះបានធ្វើតាមនោះ ជនទាំងពីរចាប់ប្រែករទេះរត់តាមទៅម្ចាស់របស់រថទៅបានបន្តិចក៏ហត់ ហើយលែងរទេះ ក៏ឈរ ឯសក្កទេវរាជរត់ទៅជាមួយរទេះនោះឯង មហោសថបណ្ឌិត ប្រាប់ឲ្យបររទេះត្រឡប់ រួចប្រាប់ដល់មហាជនថា បុរសនេះទៅបានបន្តិច ក៏លែងរថ ហើយឈរ តែបុរស

នេះរត់ទៅជាមួយរទេះ ត្រឡប់មកជាមួយរទេះ សូម្បីញើសមួយតំណក់ ក៏មិនមាន ខ្យល់ដង្ហើមក៏មិនមាន មិនមានការហត់នឿយ ភ្នែកក៏មិនប៉ប្រិច បុគ្គលនេះ គឺសក្កទេវរាជ លំដាប់នោះ មហោសថបណ្ឌិតសួរថា អ្នកជាសក្កទេវរាជឬ កាលឆ្លើយថា មែន ទើបសួរថា ទ្រង់យាងមកទីនេះដើម្បីអ្វី ក៏ត្រាស់ថា ដើម្បីប្រកាសបញ្ញារបស់លោកនោះឯង ទើបពោលថា បើដូច្នោះ ទ្រង់កុំធ្វើយ៉ាងនេះទៀត សក្កទេវរាជកាលប្រកាសសក្កានុភាព ក៏ស្ថិតនៅក្នុងអាកាស ត្រាស់សរសើរមហោសថបណ្ឌិតថា អ្នកវិនិច្ឆ័យល្អហើយៗ ហើយក៏ត្រឡប់ទៅកាន់ទិព្វស្ថានរបស់ខ្លួន ។ កាលនោះ អមាត្យនោះ ទៅគាល់ព្រះបាទវិទេហរាជដោយខ្លួនឯង ថ្វាយបង្គំហើយ ក្រាបទូលថា រឿងរថ មហោ-សថកុមារវិនិច្ឆ័យយ៉ាងល្អ សូម្បីសក្កទេវរាជក៏នៅតែចាញ់ ហេតុអ្វី ក៏ទ្រង់មិនជ្រាបបុរសវិសេសបែបនេះ ។ ព្រះរាជាត្រាស់សួរអាចារ្យសេនកៈថា គួរនាំបណ្ឌិតមកឬ អាចារ្យសេនកៈ ជាមនុស្សកំណាញ់ ក៏បានទូលថា បពិត្រមហារាជ បុគ្គលមិនឈ្មោះថាបណ្ឌិត ដោយហេតុត្រឹមប៉ុណ្ណោះឡើយ សូមទ្រង់បន្អង់សិន យើងពិសោធហើយនឹងដឹង ព្រះរាជាក៏ទ្រង់តុណ្ហីភាព ។

## សត្តទារកប្បញ្ហា ចប់

រឿងកំណាត់ឈើ សេចក្ដីថា ថ្ងៃមួយ ព្រះបាទវិទេហរាជ ទ្រង់ត្រិះរិះដើម្បីសាកល្បងមហោសថបណ្ឌិត ទើបឲ្យនាំឈើគគីរមកឲ្យកាត់ ១ ចំអាមឲ្យជាងក្រឡឹងល្អហើយ បញ្ជូនទៅកាន់ស្រុកបាចីនយវមជ្ឈគាម ដោយព្រះរាជអាណត្តិថា អ្នកបាចីនយវមជ្ឈគាមចូរដឹងថា កំណាត់ឈើគគីរនេះ ខាង

នេះចុង ខាងនេះគល់ បើមិនដឹងនឹងពិន័យមួយពាន់កហាបណៈ អ្នកស្រុកប្រជុំគ្នា កាលមិនអាចដឹងបាន ទើបប្រាប់ដល់សិរិវឌ្ឍកសេដ្ឋីថា ជួនកាលមហោសថបណ្ឌិតអាចដឹង សូមលោកហៅមហោសថមកសួរ ។ មហាសេដ្ឋីឲ្យហៅមហោសថបណ្ឌិតមកអំពីទីលានកីឡា ប្រាប់សេចក្តីនោះហើយសួរថា យើងមិនអាចដឹងប្រស្នានេះ តើបាអាចដឹងបានដែរឬទេ ព្រះមហាសត្វបានស្តាប់ដូច្នោះហើយ គិតថា ព្រះរាជាមិនមែនចង់ដឹងចុង ឬគល់ឈើគគីរនេះឡើយ ទ្រង់បញ្ជូនកំណាត់ឈើគគីរនេះមក ដើម្បីល្បងប្រាជ្ញាអញ ទើបពោលថា យកមកចុះលោកឪពុក ខ្ញុំនឹងដឹងរឿងនោះ ។ លំដាប់នោះ សេដ្ឋីឲ្យយកកំណាត់ឈើគគីរមកឲ្យដល់មហោសថបណ្ឌិត ព្រះពោធិសត្វទទួលកំណាត់ឈើគគីរនោះដោយដៃប៉ុណ្ណោះ ក៏ដឹងបានថា ខាងនេះចុង ខាងនេះគល់ សូម្បីដឹងក៏ឲ្យនាំភាជនៈទឹកមកដើម្បីកំណត់ចិត្តរបស់មហាជន ហើយយកអំបោះចងត្រង់កណ្តាលកំណាត់ឈើគគីរនោះ ហើយកាន់ចុងអំបោះ ដាក់កំណាត់ឈើគគីរលើទឹក គ្រាន់តែដាក់ប៉ុណ្ណោះ គល់ក៏លិចចុះមុន ព្រោះធ្ងន់ បន្ទាប់អំពីនោះ ព្រះពោធិសត្វក៏សួរមហាជនថា ធម្មតាដើមឈើ គល់ធ្ងន់ ឬចុងធ្ងន់ កាលមហាជនឆ្លើយថា គល់ធ្ងន់ ទើបពោលថា បើដូច្នោះ ចំណែករបស់ឈើគគីរនេះ លិចចុះមុន ទើបជាគល់ ហើយប្រាប់ចុង និងគល់ដោយសញ្ញានេះ អ្នកស្រុកបញ្ជូនដំណឹងទូលដល់ព្រះរាជាថា ខាងនេះចុង ខាងនេះគល់ ព្រះរាជាទ្រង់ត្រេកអរត្រាស់សួរថា អ្នកណាដឹង អ្នកស្រុកក្រាបទូលថា មហោសថបណ្ឌិត កូនរបស់សិរិវឌ្ឍកសេដ្ឋី ទ្រង់ស្តាប់ដូច្នោះហើយ ក៏ត្រាស់

សួរថា លោកអាចារ្យសេនកៈ យើងគួរនាំមហោសថបណ្ឌិតមកបានហើយ ឬនៅ អាចារ្យសេនកៈទូលថា សូមទ្រង់បន្អង់សិន យើងនឹងសាកល្បង ដោយឧបាយដទៃទៀត ព្រះរាជាត្រាស់ថា សាធុ ។

រឿងលលាដ៍ក្បាល សេចក្តីថា ថ្ងៃមួយ ព្រះបាទវិទេហរាជឲ្យយក ក្បាលខ្មោច ២ គឺក្បាលខ្មោចមនុស្សស្រី និងក្បាលខ្មោចមនុស្សប្រុសមក ហើយបញ្ជូនទៅឲ្យអ្នកស្រុកបាចីនយវមជ្ឈគាមព្យាករ ទ្រង់ដាក់បទបញ្ញត្តិថា អ្នកស្រុកបាចីនយវមជ្ឈគាមចូរដឹងថា នេះជាលលាដ៍ក្បាលមនុស្សស្រី នេះ ជាលលាដ៍ក្បាលមនុស្សប្រុស បើមិនដឹងនឹងពិន័យមួយពាន់កហាបណៈ អ្នក ស្រុកកាលមិនដឹង ទើបសួរព្រះមហាសត្វៗ គ្រាន់តែឃើញប៉ុណ្ណោះក៏ដឹង ។ សួរថា ដឹងបានដូចម្តេច គឺថ្នេរក្នុងលលាដ៍ក្បាលរបស់មនុស្សប្រុសត្រង់ៗ ថ្នេរក្នុងលលាដ៍ក្បាលរបស់មនុស្សស្រីវៀច មហោសថបណ្ឌិតប្រាប់ថា នេះ លលាដ៍ក្បាលស្រី នេះលលាដ៍ក្បាលប្រុស ដោយការដឹងក្រៃលែងនេះ អ្នក ស្រុកក៏បញ្ជូនដំណឹងក្រាបទូលដល់ព្រះរាជាទៀត សេចក្តីដ៏សេសដូចគ្នានឹង ន័យដែលពោលខាងដើមនោះឯង ។

រឿងពស់ សេចក្តីថា ថ្ងៃមួយ ព្រះបាទវិទេហរាជ ឲ្យនាំពស់ឈ្មោល និងពស់ញីមក ទ្រង់បញ្ជូនទៅឲ្យអ្នកស្រុកបាចីនយវមជ្ឈគាម ដោយព្រះ រាជាណត្តិថា អ្នកស្រុកបាចីនយវមជ្ឈគាមចូរដឹងថា នេះពស់ឈ្មោល នេះ ពស់ញី បើមិនដឹងនឹងពិន័យមួយពាន់កហាបណៈ អ្នកស្រុកកាលមិនដឹង ទើប សួរមហោសថបណ្ឌិតៗ គ្រាន់តែឃើញប៉ុណ្ណោះក៏ដឹង ដ្បិតថា កន្ទុយរបស់

ពស់ឈ្មោលធំ កន្ទុយរបស់ពស់ញីរៀវ ក្បាលរបស់ពស់ឈ្មោលធំ ក្បាលរបស់ពស់ញីស្រួចវែង ភ្នែករបស់ពស់ឈ្មោលធំ ភ្នែករបស់ពស់ញីតូច ក្រឡារបស់ពស់ឈ្មោលជាប់គ្នា ក្រឡារបស់ពស់ញីដាច់ៗ ពីគ្នា មហោសថបណ្ឌិត ប្រាប់ដល់អ្នកស្រុកថា នេះពស់ឈ្មោល នេះពស់ញី ដោយការដឹងក្រៃលែងយ៉ាងនេះ សេចក្ដីដ៏សេសមានន័យដូចពោលហើយនោះឯង ។

រឿងមាន់ មានសេចក្ដីថា ថ្ងៃមួយ ព្រះបាទវិទេហរាជ បញ្ជូនដំណឹងទៅដល់អ្នកស្រុកបាចីនយវមជ្ឈគាមថា អ្នកបាចីនយវមជ្ឈគាម ចូរបញ្ជូនគោឈ្មោល ដែលជាគោមង្គលពណ៌សសុទ្ធ មានស្នែងដុសត្រង់ជើង មានបូកត្រង់ក្បាល ស្រែករោទ៍មួយថ្ងៃ ៣ ដងមកឲ្យយើង បើមិនបញ្ជូនមក នឹងពិន័យមួយពាន់កហាបណៈ អ្នកស្រុកទាំងនោះកាលមិនដឹង ក៏សួរមហោសថបណ្ឌិតៗ ពោលថា ព្រះរាជាឲ្យបញ្ជូនមាន់ពណ៌សទៅថ្វាយនោះឯង ព្រោះថា មាន់នោះ ឈ្មោះថា មានស្នែងត្រង់ជើង ព្រោះមានខ្នាយត្រង់ជើង ឈ្មោះថា មានបូកត្រង់ក្បាល ព្រោះមានសិរ្សត្រង់ក្បាល ឈ្មោះថា រោទ៍មួយថ្ងៃ ៣ ដង ព្រោះរងាវ ៣ ដង ព្រោះដូច្នោះ អ្នកទាំងឡាយ ចូរបញ្ជូនមាន់មានលក្ខណៈយ៉ាងនេះទៅថ្វាយ អ្នកស្រុកទាំងនោះ ក៏បញ្ជូនទៅថ្វាយដល់ព្រះរាជាៗ ទ្រង់ត្រេកអរហើយ ។

រឿងកែវមណី សេចក្ដីថា កែវមណីដែលសក្កទេវរាជប្រទានដល់ព្រះបាទកុសរាជមាន កែវមណីនោះមានប្រហោងក្នុងទី ៨ កន្លែង អំបោះចាស់របស់កែវមណីនោះដាច់ មិនមានអ្នកណាអាចនាំយកអំបោះចេញ ហើយដោត

អំបោះថ្មីចូលទៅ ថ្ងៃមួយ ព្រះបាទវិទេហៈ បានបញ្ជូនដំណឹងទៅដល់អ្នកស្រុកបាចីនយវមជ្ឈគាមថា អ្នកបាចីនយវមជ្ឈគាម ចូរយកអំបោះចេញអំពីកែវមណីនេះ ហើយចូរដោតអំបោះថ្មីជំនួស បើធ្វើមិនបាននឹងត្រូវពិន័យមួយពាន់កហាបណៈ ពួកមនុស្សមិនអាចនាំយកអំបោះចាស់ចេញ ហើយដោតអំបោះថ្មីចូលទៅបាន កាលមិនអាច ទើបប្រាប់ដល់មហោសថបណ្ឌិតៗ ពោលថា កុំវិតក្កថ្វីឡើយ ហើយឲ្យយកទឹកឃ្មុំមកលាបត្រង់រន្ធកែវមណីទាំងសងខាង ឲ្យធ្វើអំបោះរោមសត្វ យកទឹកឃ្មុំលាបចុងអំបោះនោះ ដោតអំបោះចូលទៅក្នុងប្រហោងបន្តិច ដាក់ក្នុងទីដែលមានស្រមោចក្រហមទាំងឡាយ ពួកស្រមោចនាំគ្នាចេញអំពីលំនៅរបស់វា មកស៊ីអំបោះចាស់ក្នុងកែវមណី ហើយពាំចុងអំបោះរោមសត្វថ្មីទាញចូលមក មហោសថបណ្ឌិតដឹងថា អំបោះនោះចូលទៅហើយ ក៏ឲ្យដល់អ្នកស្រុកឲ្យយកទៅថ្វាយដល់ព្រះរាជាៗ មានព្រះតម្រាស់សួរ ទ្រង់ស្តាប់ឧបាយដោតអំបោះនោះហើយ ទ្រង់ត្រេកអរ ។

រឿងគោឈ្មោលកើតកូន សេចក្តីថា បានឮថា ថ្ងៃមួយ ព្រះរាជាត្រាស់ឲ្យរាជបុរសឲ្យគោឈ្មោលដែលជាមង្គល ស៊ីនំកុម្មាសជាច្រើន រហូតប៉ោងពោះ ឲ្យលាងស្នែងទាំងពីរហើយ លាបដោយប្រេង ឲ្យយកទឹករមៀតស្រោចខ្លួន បញ្ជូនទៅកាន់អ្នកស្រុកនោះ ដោយរាជាណត្តិថា បានឮថា ពួកអ្នកជាអ្នកប្រាជ្ញ គោឈ្មោលមង្គលរបស់ព្រះរាជានេះ មានទម្ងន់ ចូរអ្នកទាំងឡាយឲ្យគោនេះកើតកូន ហើយបញ្ជូនត្រឡប់មក មួយអន្លើដោយកូនគោដែលកើត បើមិនបញ្ជូនមក នឹងត្រូវពិន័យមួយពាន់កហាបណៈ ពួកអ្នក

ស្រុកប្រឹក្សាគ្នាថា ពួកយើងមិនអាចធ្វើបានយ៉ាងនេះ ពួកយើងធ្វើដូចម្តេច ទើបសួរមហោសថបណ្ឌិតៗ គិតថា រឿងនេះ ជាប្រស្នាតទល់ ទើបសួរថា ពួកអ្នក មាននរណាម្នាក់ដែលក្លាហាន អាចទូលជាមួយព្រះរាជាបានដែរឬ អ្នកស្រុកឆ្លើយថា រឿងនោះមិនលំបាកឡើយ មហោសថបណ្ឌិតពោលថា បើដូច្នោះ ចូរហៅគេមក អ្នកស្រុកទាំងនោះ ហៅបុរសនោះមកហើយ ។ គ្រានោះ មហាសត្វពោលនឹងបុរសនោះថា ចូរអ្នករំសាយសក់របស់អ្នក ហើយយំខ្លាំងៗ មានប្រការផ្សេងៗ ចូលទៅកាន់ទ្វារព្រះរាជនិវេសន៍ អ្នកណាសួរក៏កុំនិយាយ យំរឿយៗ ទៅ បើព្រះរាជាហៅមកសួរហេតុនៃការយំ ចូរថ្វាយបង្គំ ហើយទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ឪពុករបស់ទូលបង្គំ មិនអាចកើតកូនរាប់ទាំងថ្ងៃនេះ ៧ ថ្ងៃហើយ សូមទ្រង់ជាទីពឹងរបស់ទូលបង្គំផងចុះ សូមទ្រង់ធ្វើនូវឧបាយ ដើម្បីប្រសូតបុត្រដល់ឪពុករបស់ទូលបង្គំ កាលព្រះរាជាត្រាស់ថា អ្នកនិយាយអ្វីដោយសេចក្តីនោះ នេះមិនមែនជាឋានៈឡើយ ធម្មតាមនុស្សប្រុស កើតកូនមានឬ ចូរក្រាបទូលថា បពិត្រព្រះសម្មតិទេព បើហេតុយ៉ាងនេះ មិនមាន ធ្វើម្តេចអ្នកស្រុកបាចីនយវមជ្ឈគាម អាចញុំាំងមង្គលឧសភៈឲ្យកើតកូនបាន ។ បុរសនោះទទួលពាក្យ ធ្វើតាមពាក្យប្រាប់នោះ បានទៅយ៉ាងនោះ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់បុរសនោះ ត្រាស់សួរថា បញ្ហានេះ អ្នកណាគិត បានជ្រាបថា មហោសថ ទ្រង់ក៏ត្រេកអរ ។

រឿងបាយ សេចក្តីថា ថ្ងៃមួយ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹង

សាកល្បងមហោសថ ទើបបញ្ជូនដំណឹងទៅថា បានឮថា អ្នកបាចីនយ-វមជ្ឈគាម ជាមនុស្សឈ្លាសវៃ អ្នកស្រុកនោះ ចូរចម្អិនអម្ពិលោទនៈ ( បាយជូរ ) ប្រកបដោយអង្គ ៨ មកឲ្យយើង អង្គ ៨ នោះ គឺមិនឲ្យចម្អិនដោយអង្ករ មិនឲ្យចម្អិនដោយទឹក មិនឲ្យចម្អិនដោយឆ្នាំងបាយ មិនឲ្យចម្អិនដោយចង្ក្រាន មិនឲ្យចម្អិនដោយភ្លើង មិនឲ្យចម្អិនដោយឧស មិនឲ្យស្ត្រី ឬបុរសនាំមក មិនឲ្យនាំមកតាមផ្លូវ បើបញ្ជូនមកមិនបាន នឹងត្រូវពិន័យមួយពាន់កហាបណៈ ពួកអ្នកស្រុកមិនដឹងហេតុ ទើបប្រាប់ដល់មហោសថបណ្ឌិត ។ មហោសថបណ្ឌិតពោលថា អ្នកកុំភ័យឡើយ ហើយប្រាប់ឲ្យដឹងថា ឲ្យចម្អិនដោយចុងអង្ករដែលមិនឈ្មោះថាអង្ករ ឲ្យចម្អិនដោយទឹកសន្សើម ដែលមិនឈ្មោះថាទឹកប្រក្រតី ឲ្យចម្អិនដោយភាជនៈដីថ្មី ដែលមិនឈ្មោះថាឆ្នាំងបាយ ឲ្យបោះគល់ឈើដាក់ភាជនៈចម្អិន ដែលមិនឈ្មោះថាចម្អិនដោយចង្ក្រាន ឲ្យចម្អិនដោយភ្លើងដែលកួតគ្នាកើតឡើង មិនឈ្មោះថាភ្លើងប្រក្រតី ឲ្យចម្អិនដោយស្លឹកឈើ ដែលមិនឈ្មោះថាឧស ហើយដាក់ក្នុងភាជនៈថ្មី ចងដោយអំបោះ ប្រថាប់ត្រា កុំឲ្យមនុស្សស្រី ឬបុរសយកទៅ គឺឲ្យមនុស្សខ្ទើយយកទៅ ទៅដោយផ្លូវតូច លះបង់ផ្លូវធំ ឈ្មោះថា មិនមកតាមផ្លូវ បញ្ជូនបាយបែបនេះទៅថ្វាយព្រះរាជា អ្នកស្រុកបានធ្វើតាមន័យនោះ ព្រះរាជាទតឃើញកិរិយានោះ ទើបត្រាស់សួរថា បញ្ហានេះអ្នកណាដឹង ទ្រង់ជ្រាបថា មហោសថដឹង ទ្រង់ត្រេកអរហើយ ។

រឿងទោងដែលចងដោយខ្សែដីខ្សាច់ សេចក្តីថា ក្នុងថ្ងៃនោះ ព្រះរាជា

បញ្ជូនដំណឹងទៅកាន់អ្នកស្រុកបាចីនយវមជ្ឈគាម ដើម្បីសាកល្បងមហោសថ-បណ្ឌិតថា ព្រះរាជាប្រាថ្នានឹងក្រសាលទោង ដែលចងដោយខ្សែដីខ្សាច់ ដ្បិតខ្សែដីខ្សាច់អំពីបុរាណ ក្នុងរាជត្រកូលដាច់ហើយ ឲ្យអ្នកស្រុកនោះវេញខ្សែដីខ្សាច់មួយចង្វាយបញ្ជូនមក បើមិនបញ្ជូនមកមិនបាន នឹងត្រូវពិន័យមួយពាន់កហាបណៈ អ្នកស្រុកទាំងនោះមិនដឹងហេតុ ទើបប្រាប់ដល់មហោសថបណ្ឌិត ។ មហោសថបណ្ឌិតគិតថា រឿងនេះ គឺជាប្រស្នាតទល់ ក៏និយាយលួងលោមអ្នកស្រុកកុំឲ្យភ័យខ្លាច ហៅអ្នកមានប្ញីមាត់ ២-៣ នាក់ មកប្រាប់ឲ្យទៅទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព អ្នកស្រុកមិនជ្រាបទំហំនៃខ្សែនោះ ថាតូចធំប៉ុនណា សូមទ្រង់បញ្ជូនខ្សែខ្សាច់អំពីបុរាណ ត្រឹមតែមួយចំអាម ឬ ៤ ធ្នាប់មកគ្រាន់ជាគំរូ អ្នកស្រុកឃើញទំហំនោះហើយ នឹងវេញទំហំប៉ុណ្ណោះ បើព្រះរាជាប្រាប់ដល់អ្នកទាំងឡាយថា ខ្សែខ្សាច់ក្នុងព្រះរាជដ្ឋានរបស់យើង ធ្លាប់មានមកអំពីណា ចូរអ្នកទាំងឡាយក្រាបទូលថា បពិត្រមហារាជ ខ្សែខ្សាច់ជាគំរូនោះមិនមាន អ្នកស្រុកបាចីនយវមជ្ឈគាម នឹងធ្វើបានដូចម្តេច អ្នកស្រុកទាំងនោះទៅធ្វើតាមមហោសថណែនាំ ព្រះរាជាត្រាស់សួរថា បញ្ហានេះអ្នកណាគិត ទ្រង់ជ្រាបថា មហោសថគិត ទ្រង់ក៏ត្រេកអរ ។

រឿងស្រះទឹក សេចក្តីថា ក្នុងថ្ងៃដទៃទៀត ព្រះរាជាវិទេហរាជទ្រង់បញ្ជូនដំណឹងដល់អ្នកស្រុកទាំងនោះ ដើម្បីសាកល្បងមហោសថថា ព្រះរាជាមានបំណងក្រសាលទឹក អ្នកបាចីនយវមជ្ឈគាម ចូរបញ្ជូនស្រះបោក្ខរណីដែលដេរដាសដោយឈូក ៥ ពណ៌ បើពួកអ្នកស្រុកនោះមិនបញ្ជូនមក នឹង

ត្រូវពិន័យមួយពាន់កហាបណៈ អ្នកស្រុកទាំងនោះ ប្រាប់ដល់មហោសថ-បណ្ឌិត ។ មហោសថបណ្ឌិតគិតថា រឿងនេះ ជាប្រស្នាតទល់ ទើបហៅអ្នកមានថ្វីមាត់ ២-៣ នាក់មក ប្រាប់ឲ្យនិយាយ បញ្ជូនទៅហើយប្រាប់ថា ចូរអ្នកទាំងឡាយលេងទឹកឲ្យភ្នែកក្រហម មានសក់សើម សំពត់សើម ខ្លួនប្រឡាក់ដោយភក់ កាន់ខ្សែ ដុំដី និងដំបងទៅកាន់ទ្វារព្រះរាជនិវេសន៍ ហើយក្រាបទូលភាពដែលមកឈរចាំគាល់ព្រះរាជា កាលបានឱកាសហើយ ចូលគាល់ព្រះរាជា ក្រាបទូលថា បពិត្រមហារាជ ព្រោះទ្រង់បញ្ជូនដំណឹង ទៅឲ្យអ្នកស្រុកបាចីនយវមជ្ឈគាម បញ្ជូនស្រះបោក្ខរណីមកថ្វាយ ពួកទូលបង្គំនាំស្រះបោក្ខរណីធំដែលសមគួរដល់ព្រះអង្គមក តែស្រះបោក្ខរណីនោះឃើញព្រះនគរមានកំពែង មានគូទឹក មានទ្វារ មានរបៀងក៏ខ្លាច ផ្ដាច់ខ្សែ ហើយគេចទៅព្រៃវិញ ព្រោះធ្លាប់នៅក្នុងព្រៃ ពួកទូលបង្គំវាយដោយដុំដី និងដំបងក៏មិនអាចឲ្យត្រឡប់ សូមទ្រង់ព្រះរាជទានស្រះបោក្ខរណីចាស់របស់ទ្រង់ដែលនាំមកអំពីព្រៃ ពួកទូលបង្គំនឹងចងភ្ជាប់ស្រះបោក្ខរណីថ្មី នាំមកថ្វាយ កាលព្រះរាជាត្រាស់ថា ស្រះបោក្ខរណីរបស់យើងដែលនាំមកអំពីព្រៃ មិនធ្លាប់មានក្នុងកាលណាឡើយ យើងមិនធ្លាប់បញ្ជូនស្រះបោក្ខរណីទៅ ដើម្បីចងជាមួយអ្វីនាំមកឡើយ ចូរអ្នកទាំងឡាយទូលថា បពិត្រព្រះសម្មតិទេព បើដូច្នេះ អ្នកបាចីនយវមជ្ឈគាម នឹងបញ្ជូនស្រះបោក្ខរណីមកថ្វាយបានដូចម្ដេច អ្នកស្រុកដែលទទួលពាក្យណែនាំរបស់មហោសថ ក៏ធ្វើតាមនោះគ្រប់ប្រការ ព្រះរាជាទ្រង់ជ្រាបថា មហោសថដឹងបញ្ហានេះ ទ្រង់ក៏ត្រេកអរ ។

រឿងឧទ្យាន សេចក្តីថា ថ្ងៃមួយ ទ្រង់បញ្ជូនដំណឹងទៅទៀត ដោយរាជាណត្តិថា ទ្រង់ប្រាថ្នានឹងក្រសាលឧទ្យាន តែព្រះរាជឧទ្យានចាស់ ស្វិតឈើ ដើមឈើបាក់អស់ហើយ អ្នកបាចីនយវមជ្ឈគាម ចូរបញ្ជូនឧទ្យានថ្មីដែលដេរដាសដោយតរុណរុក្ខជាតិ ដែលមានផ្ការីកល្អមកថ្វាយ បើមិនបញ្ជូនមកតាមព្រះរាជបំណាង នឹងត្រូវពិន័យមួយពាន់កហាបណៈ អ្នកស្រុកទាំងនោះមិនដឹងហេតុ ក៏ប្រាប់សេចក្តីនោះដល់មហោសថបណ្ឌិតៗ គិតថា រឿងនេះជាប្រស្នាតទល់ ទើបហៅមនុស្សទាំងឡាយមកប្រាប់ដោយន័យមុននោះឯង មនុស្សទាំងនោះធ្វើតាមពាក្យប្រាប់ ទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់សួរអាចារ្យសេនកៈថា យើងគួរនាំមហោសថបណ្ឌិតមកឬ អាចារ្យសេនកៈក្រាបទូលដោយការកំណាញ់លាភសក្ការៈថា បុគ្គលមិនឈ្មោះថាបណ្ឌិត ដោយហេតុត្រឹមតែប៉ុណ្ណោះឡើយ សូមទ្រង់បង្អង់សិន ។ ព្រះបាទវិទេហរាជបានស្តាប់ពាក្យរបស់សេនកបណ្ឌិតហើយ មានព្រះតម្រិះថា មហោសថបណ្ឌិតដោះស្រាយបញ្ហាក្នុងកាលនៅជាទារក ធ្វើរឿង ៧ ជនត្រូវចិត្តយើង ការព្យាករណ៍ប្រស្នាកំបាំង និងការតទល់ប្រស្នាបែបនេះរបស់មហោសធនោះដូចគ្នានឹងសព្វញ្ញុតញ្ញាណ អាចារ្យសេនកៈមិនឲ្យនាំបណ្ឌិតបែបនេះមកក្នុងទីនេះ អញត្រូវការអ្វីដោយអាចារ្យសេនកៈ អញនឹងនាំមហោសថបណ្ឌិតនោះមក ។ ព្រះបាទវិទេហរាជ យាងទៅកាន់ស្រុកនោះដោយបរិវារធំ កាលព្រះរាជាទ្រង់ផែលសេះមង្គលយាងទៅ ក្រចករបស់សេះប៉ះនឹងដីប្រេះក៏បែកព្រះរាជាក៏យាងត្រឡប់ចូលព្រះនគរ លំដាប់នោះ អាចារ្យសេនកៈចូលគាល់

ទូលសួរថា ទ្រង់យាងទៅស្រុកបាចីនយវមជ្ឈគាម ដើម្បីនាំមហោសថ-បណ្ឌិតមកឬ កាលបានស្តាប់ព្រះបន្ទូលថា យាងទៅ ទើបទូលថា បពិត្រមហារាជ ទ្រង់គិតថា ទូលបង្គំជាអ្នកប្រាថ្នាសេចក្តីវិនាស ទ្រង់ពិចារណាឃើញឬថា ក្នុងកាលដែលទូលបង្គំជំទាស់ទ្រង់ឲ្យទ្រង់បង្អង់សិន ចៃដន្យក្របកសេះមង្គលដែលប្រញាប់ចេញទៅ ក៏បែកតាំងអំពីដំបូង ព្រះបាទវិទេហរាជទ្រង់បានស្តាប់ពាក្យរបស់សេនកៈ ទ្រង់ក៏នៅស្ងៀម ។

ថ្ងៃមួយទៀត ព្រះបាទវិទេហរាជប្រឹក្សានឹងអាចារ្យសេនកៈថា យើងនឹងនាំមហោសថមក អាចារ្យសេនកៈក្រាបទូលថា ទ្រង់កុំយាងទៅឯងឡើយ សូមទ្រង់បញ្ជូនទូតទៅកាន់មហោសថថា កាលទ្រង់យាងទៅកាន់សម្នាក់មហោសថក្របកសេះព្រះទីន័ងក៏បែក ចូរមហោសថបញ្ជូនសេះអស្សតរ ឬសេះដែលប្រសើរជាងសេះធម្មតាមក បើមហោសថបញ្ជូនសេះអស្សតរមក ចូរមហោ-សថមកឯង តែបើបញ្ជូនតែសេះដ៏ប្រសើរមក នឹងបញ្ជូនបិតាមក បញ្ហារបស់យើងនេះ នឹងដល់ទីបំផុត ព្រះរាជាទ្រង់ឃើញប្រពៃដែរ ទើបបញ្ជូនរាជទូតទៅដូចពោលមកនោះ ។ មហោសថបណ្ឌិត បានស្តាប់ពាក្យរាជទូតគិតថា ព្រះរាជាប្រាថ្នានឹងជួបអញ និងឪពុករបស់អញ ទៅរកបិតា ថ្វាយបង្គំហើយ ពោលថា ព្រះរាជាទ្រង់ប្រាថ្នាចង់ជួបបិតា និងខ្ញុំ សូមលោកឪពុកមួយអន្ទើដោយអនុសេដ្ឋី ១ ពាន់ជាបរិវារទៅគាល់ទ្រង់មុន កាលទៅ កុំទៅដៃទទេ សូមយកប្រអប់ខ្លឹមចន្ទន៍ ដាក់សប្បិឲ្យពេញទៅផង ព្រះរាជានឹងត្រាស់បដិសណ្ឋារៈជាមួយលោកឪពុក ទ្រង់នឹងហៅឲ្យអង្គុយថា ចូរអង្គុយ

ត្រង់អាសនៈដែលសមគួរ សូមលោកឪពុកដឹងអាសនៈដែលសមគួរហើយ អង្គុយ កាលបិតាអង្គុយហើយ ខ្ញុំនឹងទៅតាមក្រោយ ព្រះរាជានឹងរាក់ទាក់ជាមួយខ្ញុំ ត្រាស់ឲ្យអង្គុយថា ចូរអង្គុយត្រង់អាសនៈសមគួរ ពេលនោះ ខ្ញុំនឹងសម្លឹងលោកឪពុក កាលខ្ញុំសម្លឹងលោកឪពុក សូមលោកឪពុកក្រោកអំពីអាសនៈដោយសញ្ញានោះ ហើយពោលថា នែបាមហោសថ ចូរកូនអង្គុយក្នុងអាសនៈនេះ បញ្ហាឯណាមួយ នឹងដល់នូវទីបំផុតក្នុងថ្ងៃនេះ ។ សិរិវឌ្ឍកសេដ្ឋីទទួលពាក្យនោះ ហើយក៏ទៅដោយន័យដែលពោលហើយនោះឯង ឲ្យទូលនូវភាពដែលខ្លួនមកឈរវង់ចាំត្រង់ទ្វារដល់ព្រះរាជា កាលបានព្រះរាជានុញ្ញាតហើយ ទើបចូលទៅគាល់ ថ្វាយបង្គំព្រះរាជា ឈរក្នុងទីសមគួរ នាចំណែកម្ខាង ព្រះរាជាទ្រង់រាក់ទាក់ ប្រាស្រ័យ ត្រាស់សួរថា នែគហបតី មហោសថកូនរបស់លោកនៅឯណា សេដ្ឋីទូលថា បពិត្រព្រះអង្គ មកតាមក្រោយ ព្រះរាជាទ្រង់ជ្រាបដូច្នេះ ទ្រង់ក៏ត្រេកអរត្រាស់ថា នែគហបតី ចូរលោកមើលអាសនៈសមគួរដល់ខ្លួនអង្គុយចុះ សេដ្ឋីក៏អង្គុយក្នុងអាសនៈដែលសមគួរដល់ខ្លួន នាចំណែកម្ខាង ។ ចំណែកព្រះពោធិសត្វ ប្រដាប់តាក់តែងខ្លួនហើយ មានកុមារមួយពាន់ចោមរោម អង្គុយលើរថដែលប្រដាប់ហើយ កាលចូលកាន់ព្រះនគរ ឃើញលាមួយនៅត្រង់ខ្នងប្រឡាយ ប្រាប់បរិវារដែលមានកម្លាំងថា ចូរអ្នកចងលាមួយត្រង់មាត់កុំឲ្យវាយំបាន និងរុំដោយកន្ទេលផែង ឲ្យដេកក្នុងកម្រាលសែងមក បរិវារទាំងនោះក៏ធ្វើតាមពាក្យប្រាប់ ព្រះពោធិសត្វចូលកាន់ព្រះនគរដោយបរិវារច្រើន មហាជនឃើញព្រះពោធិ-

សត្វមកដូច្នោះ នាំគ្នាសរសើរព្រះពោធិសត្វមិនផ្អែតផ្អន់ថា កូនសិរិវឌ្ឍកសេដ្ឋី នេះ ឈ្មោះមហោសថបណ្ឌិត កាលលោកកើតមក ក៏កាន់យកដុំឱសថមក ផង លោកចេះដឹង ដោះស្រាយនូវបញ្ហាដែលគេសាកល្បង មានប្រមាណ ប៉ុណ្ណេះបាន ។ មហោសថទៅដល់ទ្វារព្រះរាជដ្ឋាន ឲ្យក្រាបទូលដល់ព្រះរាជា ដើម្បីឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់បានដំណឹងថា មហោសថមក ទ្រង់ក៏សោមនស្ស ត្រាស់ថា មហោសថកូនរបស់យើង ចូរប្រញាប់មកចុះ មហោសថ មួយអន្លើដោយកុមារមួយពាន់ជាបរិវារ ឡើងកាន់ប្រាសាទ ថ្វាយបង្គំព្រះ រាជាហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ព្រះរាជាទតឃើញមហោសថ ទ្រង់ក៏ត្រេកអរ ត្រាស់បដិសណ្ឋារៈយ៉ាងពីរោះថា នែបណ្ឌិត ចូរអ្នកដឹង អាសនៈដែលសមគួរ ហើយអង្គុយចុះ ។ កាលនោះ មហាសត្វសម្លឹងមើល បិតា លំដាប់នោះ បិតារបស់មហោសថក៏ក្រោកចាកអាសនៈ ដោយសញ្ញា ដែលមហោសថសម្លឹងមើល ហើយពោលថា នែបណ្ឌិត ចូរកូនអង្គុយក្នុង អាសនៈនេះ មហោសថក៏អង្គុយក្នុងអាសនៈនោះ អាចារ្យសេនកៈ បុក្កុសៈ កាមិន្ទៈ ទេវិន្ទៈ និងជនដទៃដែលល្ងង់ខ្លៅ ឃើញមហោសថអង្គុយត្រង់ អាសនៈនោះ ក៏នាំគ្នាទះដៃចំអកថា មនុស្សទាំងឡាយ នាំគ្នាហៅមនុស្ស ល្ងង់ខ្លៅនេះ ថាបណ្ឌិត ការហៅបុគ្គលដែលឲ្យឪពុកក្រោកចាកអាសនៈ ហើយអង្គុយខ្លួនឯងនេះ ថាជាបណ្ឌិត មិនសមគួរឡើយ ។ ព្រះរាជាមាន ព្រះហឫទ័យសៅហ្មង ទ្រង់ទោមនស្ស លំដាប់នោះ ព្រះមហាសត្វទូលសួរ ព្រះរាជាថា ទ្រង់ទោមនស្សព្រះហឫទ័យឬ ព្រះរាជាត្រាស់តបថា អើ យើង

ទោមនស្ស ព្រោះបានស្តាប់ការប្រព្រឹត្តទៅរបស់អ្នក ក៏ជាទីត្រេកអរ តែលុះបានឃើញការប្រព្រឹត្តរបស់អ្នក ក៏កើតទោមនស្ស ព្រោះថា អ្នកឲ្យបិតារបស់អ្នកក្រោកអំពីអាសនៈ ហើយអង្គុយខ្លួនឯង មហោសថទូលសួរថា បពិត្រព្រះអង្គ ទ្រង់សម្គាល់ថា ឪពុកប្រសើរជាងកូនគ្រប់ទីទាំងពួងឬ កាលត្រាស់តបថា អើ យើងយល់យ៉ាងនោះ ទើបក្រាបទូលថា ទ្រង់ព្រះរាជទានដំណឹងនេះទៅថា ឲ្យទូលបង្គំបញ្ជូនសេះអស្សតរ ឬសេះប្រសើរជាងសេះសាមញ្ញមកថ្វាយមិនមែនឬ ក្រាបទូលដូច្នេះហើយ ក្រោកចាកអាសនៈ សម្លឹងមើលបរិវារឲ្យនាំលាដែលចងនោះមក ឲ្យដេកទៀបយុគលបាទរបស់ព្រះបាទវិទេហរាជ ហើយក្រាបទូលសួរថា លានេះ មានតម្លៃប៉ុន្មានព្រះអង្គ ព្រះរាជាត្រាស់តបថា បើវាមានឧបការៈ តម្លៃវា គឺ ៨ កហាបណៈ មហោសថទូលសួរថា សេះអស្សតរអាស្រ័យលានេះ កើតក្នុងពោះរបស់សេះសាមញ្ញ តម្លៃប៉ុន្មាន កាលព្រះរាជាត្រាស់តបថា មានតម្លៃកាត់ថ្លៃមិនបាន ដូច្នេះ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ហេតុអ្វី ទើបទ្រង់ត្រាស់ដូច្នោះ អម្បាញ់មិញ ទ្រង់ត្រាស់ថា ឪពុកប្រសើរជាងកូនក្នុងទីគ្រប់អន្លើមិនមែនឬ បើព្រះរាជតម្រាស់នោះពិត លាក៏ឧត្តមជាងសេះអស្សតររបស់ទ្រង់ សូមទ្រង់ទទួលយកលានេះចុះ បើសេះអស្សតរឧត្តមជាងលាទាំងឡាយ សូមទ្រង់ទទួលសេះអស្សតរនោះ បណ្ឌិតទាំងឡាយរបស់ព្រះអង្គ ក៏មិនដឹងហេតុមានប្រមាណប៉ុណ្ណេះ នាំគ្នាទះដៃសើច ចំអកទូលព្រះបង្គំ បណ្ឌិតទាំងឡាយរបស់ទ្រង់ បរិបូណ៌ដោយបញ្ញាទាំងនោះ ទ្រង់បានមកអំពីណា ទូល

ដូច្នេះហើយ ពោលចំអកបណ្ឌិតទាំង ៤ ហើយទូលព្រះរាជាដោយគាថាក្នុងឯកនិបាតថា

បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គរីករាយ រមែងសម្គាល់ថា បិតាប្រសើរជាងកូនយ៉ាងនេះ បើដូច្នោះ មានតែសត្វលារបស់ព្រះអង្គនេះ ប្រសើរជាងសេះអស្សតរ ព្រោះសត្វលាជាបានៃសេះអស្សតរ ដូច្នេះ ។

គាថានោះ មានសេចក្តីថា បពិត្រព្រះរាជាដ៏ប្រសើរ បើទ្រង់សម្គាល់ថា ឪពុកប្រសើរជាងកូនក្នុងសព្វអន្លើ លានេះក៏ប្រសើរជាងសេះអស្សតររបស់ទ្រង់ ព្រោះហេតុអ្វី ព្រោះលាជាបារបស់សេះអស្សតរ ។ កាលទូលយ៉ាងនេះហើយ ព្រះមហាសត្វក៏ក្រាបទូលថា បើបិតាប្រសើរជាងបុត្រទាំងឡាយ សូមទ្រង់ទទួលបិតារបស់ទូលបង្គំ បើកូនប្រសើរជាងបិតា សូមទ្រង់ទទួលទូលព្រះបង្គំ ដើម្បីប្រយោជន៍ដល់ទ្រង់ ។ ព្រះបាទវិទេហរាជទ្រង់ស្តាប់ពាក្យនោះ ទ្រង់ក៏សោមនស្ស រាជបរិស័ទទាំងឡាយ ក៏ឲ្យសាធុការថា មហោសថបណ្ឌិតពោលប្រស្នាប្រពៃហើយ សំឡេងទះដៃ និងការលើកផ្ទាំងសំពត់រាប់ពាន់បានប្រព្រឹត្តទៅហើយ បណ្ឌិតទាំង ៤ ក៏មានមុខសៅហ្មងស្រុបសៅទាំងអស់ ។

សួរថា បុគ្គលអ្នកដឹងគុណនៃមាតាបិតា ដូចព្រះពោធិសត្វ រមែងមិនមានមិនមែនឬ កាលបើដូច្នោះ ហេតុអ្វី ទើបលោកធ្វើយ៉ាងនេះ ។

ឆ្លើយថា ព្រះពោធិសត្វបានធ្វើយ៉ាងនោះ បំណងនឹងមើលងាយឪពុកក៏

មិនមែន តែព្រះរាជាបញ្ជូនដំណឹងនេះទៅថា ឲ្យបញ្ជូនសេះអស្សតរ ឬសេះដែលប្រសើរជាងសេះសាមញ្ញមកថ្វាយ ព្រោះដូច្នោះ ទើបធ្វើយ៉ាងនេះ ដើម្បីធ្វើបញ្ហានោះឲ្យជាក់ច្បាស់ ដើម្បីប្រកាសភាពដែលខ្លួនជាបណ្ឌិត និងដើម្បីធ្វើអាចារ្យទាំង ៤ មានអាចារ្យសេនកៈជាដើម ឲ្យអាប់រស្មី ។

គទ្រភបញ្ហា ចប់

ព្រះបាទវិទេហរាជទ្រង់ត្រេកអរ ចាប់ព្រះកុណ្ឌីមាស ដែលពេញដោយទឹកក្រអូប ប្រុចក្នុងដៃសិរិវឌ្ឍកសេដ្ឋី ព្រះរាជទានឲ្យគ្រប់គ្រងបាចីនយវមជ្ឈគាម ហើយត្រាស់ថា ចូរពួកសេដ្ឋី បម្រើសិរិវឌ្ឍកសេដ្ឋី ហើយបញ្ជូនគ្រឿងសព្វលង្ការ ព្រះរាជទានដល់នាងសុមនាទេវី មាតារបស់ព្រះពោធិសត្វ ទ្រង់ជ្រះថ្លាក្នុងគទ្រភបញ្ហា ទើបត្រាស់នឹងសេដ្ឋី ដើម្បីសូមព្រះពោធិសត្វ ក្នុងតំណែងជារាជបុត្រជាទីស្រឡាញ់របស់ទ្រង់ថា នែគហបតី ចូរលោកឲ្យមហោសថបណ្ឌិត មកជារាជបុត្ររបស់យើង សេដ្ឋីទូលទាស់ថា បពិត្រព្រះសម្មតិទេព មហោសថរបស់ទូលបង្គំនៅក្មេងណាស់ មកទល់ថ្ងៃនេះ មាត់មិនទាន់បាត់ធុំក្លិនទឹកដោះ ក្នុងកាលណាគេជាមនុស្សធំ សឹមនៅក្នុងរាជសម្នាក់ ។ ព្រះរាជាត្រាស់ថា ចាប់ពីថ្ងៃនេះទៅ ចូរលោកកុំហួងហែងក្នុងមហោសថឡើយ មហោសថនេះជារាជបុត្ររបស់យើង ចាប់អំពីថ្ងៃនេះទៅ យើងនឹងចិញ្ចឹមកូនរបស់លោកបាន ចូរលោកត្រឡប់ចុះ ត្រាស់ដូច្នេះហើយ បានឲ្យសេដ្ឋីត្រឡប់ទៅផ្ទះ ។ សេដ្ឋីថ្វាយបង្គំព្រះបរមក្សត្រហើយ ឱបមហោសថត្រង់ទ្រូង ថើបក្បាល ឲ្យឱវាទដល់មហោសថថា នែកូនកំពូលដួងចិត្ត អ្នក

ស្មើនឹងកែវក្អែកដ៏ប្រសើរ បាកុំធ្វើឲ្យបិតាមិនមានទីពឹង ចាប់ពីថ្ងៃនេះទៅ ចូរបាបម្រើព្រះរាជារបស់យើងទាំងឡាយ ដោយសេចក្តីមិនប្រមាទចុះ មហោសថថ្វាយបង្គំបិតាហើយ ពោលថា សូមលោកឪពុក កុំគិតថ្វីឡើយ ហើយជូនដំណើរបិតាត្រឡប់ ។

ព្រះបាទវិទេហរាជត្រាស់សួរមហោសថថា ឯងនៅខាងក្នុងរាជវាំង ឬនៅខាងក្រៅ ព្រះពោធិសត្វគិតថា បរិវាររបស់អាត្មាអញមានច្រើន អញគួរនៅខាងក្រៅព្រះរាជវាំង ទើបក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំនឹងនៅខាងក្រៅ លំដាប់នោះ ទើបព្រះរាជាព្រះរាជទានគេហដ្ឋានដ៏សមគួរ ហើយព្រះរាជទានគ្រឿងឧបភោគ បរិភោគទាំងពួង ដល់មហោសថ និងបរិវារ ។ ចាប់តាំងពីថ្ងៃនោះមក មហោសថបណ្ឌិតក៏បម្រើព្រះរាជា ព្រះរាជាទ្រង់ប្រាថ្នានឹងសាកល្បងមហោសថនោះតទៅ ។

កាលនោះ កែវមណីមាននៅក្នុងសម្បុកក្អែក ត្រង់ដើមត្នោតមួយដើមនាមាត់ច្រាំងស្រះបោក្ខរណី មិនឆ្ងាយអំពីទ្វារទិសទក្សិណនៃព្រះនគរ ស្រមោលរបស់កែវមណីនោះ ប្រាកដក្នុងស្រះបោក្ខរណី ជនទាំងឡាយទូលដល់ព្រះរាជាថា កែវមណីមានក្នុងស្រះបោក្ខរណី ព្រះរាជាត្រាស់ហៅអាចារ្យសេនកៈមកសួរថា នែលោកអាចារ្យសេនកៈ បានឮថា មណីរតនៈប្រាកដក្នុងស្រះបោក្ខរណី ធ្វើដូចម្តេចទើបកាន់យកកែវមណីនោះបាន កាលសេនកៈទូលថា គួរបាចទឹកកាន់យក ព្រះរាជាក៏ប្រគល់ការណ៍នោះ ឲ្យជាភារៈរបស់អាចារ្យសេនកៈនោះ អាចារ្យសេនកៈបានឲ្យមនុស្សជាច្រើន ប្រជុំគ្នាបាចទឹក កើបកក់ចេញអំពី

ស្រះបោក្ខរណី សូម្បីជីកដល់ដីរឹងក៏មិនឃើញកែវមណី កាលទឹកពេញស្រះបោក្ខរណី ស្រមោលកែវមណីក៏ប្រាកដទៀត អាចារ្យសេនកៈបានធ្វើយ៉ាងនោះទៀត ក៏មិនឃើញកែវមណីនោះឡើយ ។ បន្ទាប់អំពីនោះ ព្រះរាជាហៅមហោសថបណ្ឌិតមកត្រាស់ថា កែវមណីមួយប្រាកដក្នុងស្រះបោក្ខរណី អាចារ្យសេនកៈឲ្យបាចទឹក និងកកាយចេញអំពីស្រះបោក្ខរណី ជីកទាំងដី ក៏មិនឃើញកែវមណីនោះ កាលទឹកពេញស្រះបោក្ខរណី ស្រមោលកែវមណីក៏ប្រាកដទៀត តើអ្នកអាចយកកែវមណីនោះបានមកឬ មហោសថក្រាបទូលថា សេចក្ដីនោះមិនជាការលំបាកឡើយ សូមទ្រង់យាង ទូលបង្គំនឹងបង្ហាញកែវមណីនោះ ព្រះបាទវិទេហរាជបានស្ដាប់ដូច្នោះ ទ្រង់សោមនស្ស គិតថា ថ្ងៃនេះ អញនឹងឃើញកម្លាំងបញ្ញារបស់មហោសថបណ្ឌិត មួយអន្លើដោយរាជបរិវារ ទ្រង់យាងទៅកាន់មាត់ស្រះបោក្ខរណី មហាសត្វឈរត្រង់ច្រាំង សម្លឹងមើលកែវមណី ក៏ដឹងថា កែវមណីនោះមិនមានក្នុងស្រះបោក្ខរណី មាននៅលើដើមត្នោត ទើបក្រាបទូលថា កែវមណីមិនមានក្នុងស្រះបោក្ខរណីទេ កាលព្រះរាជាត្រាស់ថា កែវមណីប្រាកដក្នុងទឹកមិនមែនឬ ទើបឲ្យនាំភាជនៈដាក់ទឹកពេញមកហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ទត កែវមណីនេះ មិនប្រាកដក្នុងស្រះបោក្ខរណីតែមួយកន្លែងឡើយ ក្នុងភាជនៈទឹកក៏ប្រាកដ កាលព្រះរាជាត្រាស់សួរថា នែបណ្ឌិត តើកែវមណីនេះ មាននៅឯណា ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ស្រមោលប្រាកដក្នុងស្រះបោក្ខរណីខ្លះ ក្នុងភាជនៈទឹកខ្លះ កែវមណីមិនបាននៅក្នុងស្រះបោក្ខរណី តែកែវ

មណីមាននៅក្នុងសម្បុកក្អែក លើដើមត្នោត សូមទ្រង់ឲ្យរាជបុរសឡើងទៅយកមកថ្វាយចុះ ព្រះរាជាក៏ត្រាស់ឲ្យរាជបុរសឡើងទៅយកកែវមណីមក មហោសថបណ្ឌិត ទទួលកែវមណីអំពីរាជបុរសហើយ ដាក់ក្នុងព្រះហស្តរបស់ព្រះរាជា មហាជនបានឲ្យសាធុការដល់មហោសថបណ្ឌិត ជេរប្រទេចអាចារ្យសេនកៈ សរសើរមហោសថថា កែវមណីនៅលើដើមត្នោត សេនកៈល្ងង់ខ្លៅឲ្យមនុស្សជាច្រើនជីកបំផ្លាញស្រះបោក្ខរណី តែមហោសថបណ្ឌិត មិនធ្វើដូច្នោះឡើយ សូម្បីព្រះបាទវិទេហរាជ ក៏ទ្រង់សោមនស្ស ព្រះរាជទានកម្រងកែវមុក្តាហារ ជាគ្រឿងប្រដាប់ករបស់ទ្រង់ដល់មហោសថ ព្រះរាជទានកម្រងកែវមុក្តាវលី ដល់កុមារជាបរិវារមួយពាន់ ទ្រង់អនុញ្ញាតព្រះពោធិសត្វ មួយអន្ទើដោយបរិវារ ឲ្យបដិបត្តិរាជការដោយទំនងនេះ ។

## ប្រស្នា ១៩ ចប់

ថ្ងៃមួយ ព្រះបាទវិទេហរាជយាងទៅព្រះរាជឧទ្យាន ជាមួយមហោសថ-បណ្ឌិត កាលនោះ មានបង្កួយមួយនៅត្រង់ចុងសសរខ្លោងទ្វារ កាលឃើញព្រះរាជាយាងមក ក៏ចុះអំពីសសរក្រាបចុះត្រង់ផែនដី ព្រះរាជាទតឃើញនូវកិរិយារបស់បង្កួយនោះក៏ត្រាស់សួរថា នែបណ្ឌិត បង្កួយនេះធ្វើអ្វី មហោសថទូលតបថា បង្កួយនេះថ្វាយខ្លួន ព្រះរាជាត្រាស់ថា ការថ្វាយខ្លួនរបស់បង្កួយយ៉ាងនេះ មិនមានផលក៏មិនមែន ចូរអ្នកឲ្យភោគសម្បត្តិដល់វា ។ មហោសថក្រាបទូលថា បង្កួយនេះមិនមែនត្រូវការទ្រព្យឡើយ គួរព្រះរាជទានត្រឹមតែចំណីអាហារក៏ល្មម កាលព្រះរាជាត្រាស់សួរថា បង្កួយនេះស៊ីអ្វី ក៏ទូលថា

បក្ខីយនេះស៊ីសាច់ ព្រះរាជាត្រាស់សួរថា តើវាគួរបានតម្លៃប៉ុន្មាន មហោសថទូលថា គួរបានតម្លៃមួយកាកណិក ទើបព្រះរាជាត្រាស់នឹងរាជបុរសម្នាក់ថា រង្វាន់របស់ព្រះរាជាត្រឹមមួយកាកណិកមិនគួរ ចូរអ្នកនាំសាច់ដែលមានតម្លៃកន្លះមាសក មកឲ្យបក្ខីយស៊ីជានិច្ច រាជបុរសទទួលព្រះរាជឱង្ការ ក៏បានធ្វើដូច្នោះចាប់តាំងពីថ្ងៃនោះមក ។ ថ្ងៃមួយ ជាថ្ងៃឧបោសថ ពួកមនុស្សមិនសម្លាប់សត្វ រាជបុរសរកសាច់មិនបាន ទើបចោះប្រាក់កន្លះមាសកនោះ ដោតដោយអំបោះចងជាគ្រឿងប្រដាប់ត្រង់ករបស់បក្ខីយ ។ លំដាប់នោះ មានះក៏កើតឡើងដល់បក្ខីយនោះ ព្រោះមានអលង្ការកន្លះមាសកនោះ ។ ថ្ងៃនោះ ព្រះរាជាយាងទៅព្រះរាជឧទ្យាន បក្ខីយនោះឃើញព្រះរាជាយាងមក ក៏ធ្វើខ្លួនស្មើនឹងព្រះរាជា ដោយគិតថា ទ្រង់មានទ្រព្យច្រើនឬ យើងក៏មានច្រើនដូចគ្នា ដោយអំណាចការប្រកាន់ខ្លួន អាស្រ័យទ្រព្យកន្លះមាសកនោះ មិនចុះអំពីចុងសសរ ដេកធ្វើក្បាលផ្ងក់ៗ លើចុងសសរខ្លោងទ្វារនោះឯង ។ ព្រះបាទវិទេហរាជទតឃើញកិរិយារបស់បក្ខីយ កាលត្រាស់សួរថា នែបណ្ឌិត ថ្ងៃនេះ បក្ខីយមិនចុះមកដូចសព្វមួយដង ព្រោះហេតុអ្វីហ្ន៎ ទើបត្រាស់គាថានេះថា

កាលពីដើមបក្ខីយនេះ នៅលើខ្លោងទ្វារ មិនក្រអឺតក្រអោងទេ

ម្នាលមហោសថ អ្នកចូរដឹង ព្រោះហេតុអ្វី បានជាបក្ខីយត្រឡប់

ទៅជារបឹងរឹងរូសវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆ ឧណ្ណាមតិ** សេចក្តីថា ថ្ងៃនេះ បក្ខីយមិនចុះ ដេកធ្វើក្បាលផ្ងក់ៗ លើចុងសសរនោះឯង បក្ខីយមិនចុះមកដូចថ្ងៃមុន

ព្រោះហេតុអ្វី ។ បទថា **កេន ថទ្ធោ** សេចក្តីថា ដល់នូវការរឹងត្អឹង ដោយហេតុអ្វីហ្ន៎ ។

លំដាប់នោះ មហោសថបណ្ឌិតដឹងថា ក្នុងថ្ងៃឧបោសថមនុស្សមិនសម្លាប់សត្វ បង្កួយនេះអាស្រ័យមាសក ដែលរាជបុរសចងត្រង់ក ព្រោះរកសាច់មិនបាន ទើបការប្រកាន់ខ្លួនរបស់វាកើតឡើង ដូច្នេះហើយ ទើបទូលគាថានេះថា

បង្កួយបានរបស់ ដែលមិនធ្លាប់បាន ចំនួនកន្លះមាសក រមែង
មើលងាយព្រះបាទវិទេហៈ ដែលសោយរាជ្យ ក្នុងនគរមិថិលា
ដូច្នេះ ។

ព្រះរាជាត្រាស់ឲ្យហៅរាជបុរសនោះមកសាកសួរ ក៏បានដឹងសេចក្តីដូចព្រះមហោសថព្យាករនោះ ទ្រង់ក៏ជ្រះថ្លាក្នុងព្រះពោធិសត្វឥតឧបមា ព្រោះទ្រង់ឃើញថា អធ្យាស្រ័យរបស់បង្កួយ មហោសថមិនសាកសួររឿងអ្វីនឹងបុគ្គលណា ក៏ដឹងបានដូចសព្វញ្ញុពុទ្ធ ដឹងអធ្យាស្រ័យវេនេយ្យសត្វ ដូច្នោះ ទើបទ្រង់ព្រះរាជទានសួយត្រង់ទ្វារទាំង ៤ ដល់មហោសថបណ្ឌិត តែទ្រង់ពិរោធនឹងបង្កួយ ប្រាថ្នាឲ្យគេសម្លាប់ មហោសថទូលឃាត់ព្រះរាជាថា ធម្មតាសត្វតិរច្ឆាន មិនមានបញ្ញាឡើយ សូមទ្រង់អភ័យទោសដល់បង្កួយចុះ ។

កកណ្តកបញ្ហា ចប់

សម័យនោះ មានមាណពម្នាក់ឈ្មោះបិង្គុត្តរៈ ជាអ្នកដែនមិថិលា ទៅកាន់នគរតក្កសិលា រៀនសិប្បៈក្នុងសម្នាក់អាចារ្យទិសាបាមោក្ខចេះចប់យ៉ាងរហ័ស

មាណពនោះឲ្យទ្រព្យដែលជាគ្រឿងតបគុណហើយ លាអាចារ្យត្រឡប់ទៅផ្ទះ ។ មានទំនៀមថា បើធីតាក្នុងត្រកូលនោះជាអ្នកចម្រើនវ័យ អាចារ្យត្រូវលើកឲ្យដល់សិស្សច្បង អាចារ្យនោះមានធីតាម្នាក់ មានរូបស្អាតដូចទេពអប្សរ គ្រានោះ អាចារ្យពោលនឹងបិង្គុត្តរមាណពនោះថា យើងឲ្យកូនស្រីដល់ឯង ចូរឯងនាំទៅចុះ តែមាណពនោះជាអ្នកមិនមានបុណ្យ ជាមនុស្សកាឡកិណី ឯកុមារិកាជាអ្នកមានបុណ្យច្រើន ចិត្តរបស់បិង្គុត្តរមាណពមិនបានប្រតិព័ទ្ធ ព្រោះឃើញកុមារិកានោះ មាណពនោះ សូម្បីមិនប្រាថ្នានាងកុមារិកា ក៏ទទួលដោយគិតថា អញនឹងមិនទម្លាយពាក្យរបស់អាចារ្យ ។ ព្រាហ្មណ៍ជាអាចារ្យទិសាបាមោក្ខ បានឲ្យធីតាដល់មាណពនោះៗ ដេកក្នុងដំណេកដ៏មានសិរីដែលតាក់តែងហើយក្នុងពេលរាត្រី មានសេចក្តីខ្មាសអៀន ព្រោះកុមារីនោះឡើងមកដេកជាមួយ ក៏ចុះទៅដេកខាងក្រោម កុមារិកាក៏ចុះមកដេកក្បែរមាណពនោះ មាណពក៏ឡើងទៅលើដំណេក កុមារិកាក៏ឡើងទៅដេកក្បែរទៀត លុះកុមារិកាឡើងទៅ មាណពក៏ចុះមកដេកខាងក្រោមវិញ ឈ្មោះថាកាឡកិណី រមែងមិនរួមជាមួយសិរី កុមារិកាក៏ដេកត្រង់ទីដេក មាណពនោះក៏ដេកខាងក្រោម ញុំាងកាលវេលាឲ្យកន្លងទៅយ៉ាងនេះអស់មួយសប្តាហ៍ ក៏នាំកុមារិកានោះ ថ្វាយបង្គំអាចារ្យចេញអំពីតក្កសិលានគរ ក្នុងរវាងផ្លូវ មិនបានចរចាប្រាស្រ័យគ្នាឡើយ ជនទាំងពីរមិនមានសេចក្តីប្រាថ្នានូវគ្នានិងគ្នា បានមកដល់នគរមិថិលា ។ ចំណែកបិង្គុត្តរមាណព ឃើញដើមល្វាមួយដើមស្អេកស្កះទៅដោយផ្លែ ក្នុងទីជិតព្រះនគរ ត្រូវសេចក្តីឃ្លានបៀតបៀន ក៏ឡើង

ដើមឈើនោះទំពាស៊ីផ្លែល្វា ចំណែកកុមារិកានោះក៏ឃ្លាន ទៅត្រង់គល់ឈើពោលថា បពិត្រអ្នក ចូរទម្លាក់ផ្លែចុះមកឲ្យខ្ញុំខ្លះ មាណពឆ្លើយថា ដៃជើងរបស់នាងមិនមានឬ ចូរនាងឡើងមកបេះស៊ីឯង នាងក៏ឡើងទៅបេះបរិភោគ មាណពដឹងថា នាងឡើងមក ក៏សម្រូតចុះ រួចអូសបន្ទាមកស្រែះ ពោលថា អញផុតចាកស្រីកាឡកិណី ហើយគេចទៅ កុមារិកានោះ កាលមិនអាចចុះ ក៏អង្គុយលើដើមឈើនោះឯង ថ្ងៃនោះ ព្រះបាទវិទេហរាជ យាងប្រពាតព្រះរាជឧទ្យាន ទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាននោះហើយ កាលប្រថាប់គង់លើកដំរី យាងចូលព្រះនគរក្នុងពេលល្ងាច បានទតឃើញកុមារិកានោះ ទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធ ទើបឲ្យគេសួរថា នាងមានប្ដីហួងហែងដែរឬទេ នាងប្រាប់ថា ប្ដីរបស់នាងដែលត្រកូលរៀបចំមាន តែគេឲ្យខ្ញុំអង្គុយលើដើមឈើនេះ ហើយចៀសចេញទៅ អមាត្យក្រាបទូលសេចក្ដីនោះដល់ព្រះរាជាៗ ទ្រង់ព្រះតម្រិះថា កណ្ឌៈមិនមានម្ចាស់ ជារបស់ព្រះរាជា ទើបឲ្យដាក់នាងចុះ ហើយឲ្យឡើងកដំរី នាំទៅព្រះរាជនិវេសន៍អភិសេក ស្ថាបនាក្នុងតំណែងអគ្គមហេសី ព្រះនាងជាទីស្រឡាញ់ ជាទីពេញព្រះហឫទ័យនៃព្រះរាជា ជនទាំងឡាយកំណត់ដឹងព្រះនាមរបស់ព្រះនាងថា ឧទុម្ពរទេវី ព្រោះព្រះរាជាបានព្រះនាងមកអំពីដើមល្វា ។

ថ្ងៃមួយ នាយក្នាក់ងារ ញ៉ាំងអ្នកស្រុកក្បែរទ្វារនគរ ឲ្យជម្រះផ្លូវដើម្បីប្រយោជន៍ក្នុងការយាងរបស់ព្រះរាជា បិង្គុត្តរមាណព កាលធ្វើការស៊ីឈ្នួល ចងក្បិនយ៉ាងមាំជម្រះផ្លូវដោយចប កាលផ្លូវមិនទាន់ហើយ ព្រះរាជាប្រថាប់

លើរថព្រះទីន័ងជាមួយព្រះនាងឧទុម្ពរទេវី យាងចេញអំពីព្រះនគរ ព្រះនាងឧទុម្ពរទេវីទតឃើញបិង្គុត្តរមាណព ដែលជាមនុស្សកាឡកិណីនោះ កំពុងឆ្ការផ្លូវ ដោយនឹកក្នុងព្រះហឫទ័យថា បុរសកាឡកិណីនេះមិនអាចទ្រទ្រង់នូវសិរីដូច្នេះបាន ព្រះនាងក៏សើច ព្រះរាជាទតឃើញព្រះនាងសើច ទ្រង់ក៏ពិរោធត្រាស់សួរថា នាងសើចអ្វី ព្រះនាងក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសដែលជម្រះផ្លូវនេះ ជាប្តីមុនរបស់ខ្ញុំម្ចាស់ ញុំាងខ្ញុំម្ចាស់ឲ្យឡើងដើមល្វា យកបន្លាស្រះហើយទៅ ខ្ញុំម្ចាស់មើលបុរសនេះហើយគិតថា បុរសកាឡកិណីនេះមិនអាចទ្រទ្រង់នូវសិរីបែបនេះបានទើបសើច ព្រះរាជាត្រាស់ថា នាងនិយាយកុហក នាងប្រហែលជាឃើញអ្វីដទៃ យើងនឹងសម្លាប់នាង ត្រាស់ដូច្នេះហើយទ្រង់ចាប់ដាវ ព្រះនាងខ្លាចចំពោះរាជអាជ្ញា ទើបក្រាបទូលថា សូមទ្រង់ត្រាស់សួរនូវបណ្ឌិតទាំងឡាយសិន ទើបព្រះរាជាត្រាស់សួរអាចារ្យសេនកៈថា លោកជឿដែរឬ អាចារ្យសេនកៈទូលថា ទូលបង្គំមិនជឿ បុរសអ្វី លះស្រីបែបនេះ ព្រះនាងឧទុម្ពរទ្រង់ស្តាប់ពាក្យរបស់អាចារ្យសេនកៈ រឹងរឹតតែខ្លាចព្រះរាជ-អាជ្ញា លំដាប់នោះ ព្រះរាជាទ្រង់ត្រិះរិះថា សេនកៈ ដឹងអ្វី អញនឹងសួរមហោសថ កាលសួរមហោសថ ទើបត្រាស់ថា

ម្នាលមហោសធ ស្ត្រីដែលមានរូបល្អ តែស្ត្រីនោះ មានសីល
បុរសមិនគប្បីប្រាថ្នាស្ត្រីនោះ អ្នកជឿឬទេ ដូច្នេះ ។

បទថា **សីលវតី** ក្នុងគាថានោះ សេចក្តីថា ដល់ព្រមដោយអាចារនិងមារយាទ ។ មហោសថបណ្ឌិត បានស្តាប់ព្រះរាជតម្រាស់នោះ ទើប

ពោលគាថានេះថា

បពិត្រមហារាជ ទូលព្រះបង្គំជឿ បុរសដែលថោកទាប ( មិនត្រូវការនឹងស្ត្រីនោះទេ ) ( ព្រោះ ) សិរី និងកាឡកិណី រមែងមិនជួបប្រសព្វគ្នាក្នុងកាលណាមួយឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆ សមេន្តិ** សេចក្តីថា ចូលគ្នាមិនបាន ដូចត្រើយនាយ និងត្រើយអាយរបស់មហាសមុទ្រ ដូចអាកាស និងផែនដី ។

ព្រះរាជាជ្រាបហេតុការណ៍នោះ តាមពាក្យរបស់មហោសថ ទ្រង់ឈប់ខ្ញាល់ ទ្រង់ត្រេកអរចំពោះមហោសថ ត្រាស់ថា នែបណ្ឌិត បើមិនបានអ្នក ថ្ងៃនេះ យើងនឹងបាត់បង់ឥត្ថីរតនៈបែបនេះ តាមពាក្យរបស់សេនកៈដែលជាបុគ្គលល្ងង់ខ្លៅ ឯយើងបាននាងក៏ព្រោះអាស្រ័យអ្នក ត្រាស់សរសើរដូច្នេះហើយ ព្រះរាជទាន ១ សែនកហាបណៈ បូជាមហោសថ ។ ចំណែកព្រះទេវី ថ្វាយបង្គំព្រះរាជាហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់បានជីវិត ព្រោះអាស្រ័យមហោសថបណ្ឌិត ខ្ញុំម្ចាស់ប្រាថ្នាពរដើម្បីឲ្យមហោសថបណ្ឌិតនោះ តាំងនៅក្នុងឋានៈជាប្អូនប្រុសរបស់ខ្ញុំម្ចាស់ សូមទ្រង់ប្រទានផងចុះ ព្រះបាទវិទេហរាជ ក៏ប្រទានពរដល់ព្រះនាងថា សាធុ ចូរព្រះនាងទទួលពរដែលយើងឲ្យដល់នាង ។ ព្រះនាងក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ចាប់ពីថ្ងៃនេះទៅ ខ្ញុំម្ចាស់មិនបរិភោគអ្វីដែលមានរសឆ្ងាញ់ដោយវៀរប្អូនប្រុស ចាប់អំពីនេះទៅ ខ្ញុំម្ចាស់សូមបើកទ្វារក្នុងពេលដែលមិនមែនជាកាល បញ្ជូនរបស់មានរសឆ្ងាញ់ ទៅឲ្យប្អូនប្រុសនោះ ខ្ញុំម្ចាស់សូម

ទទួលពរនេះ ។ ព្រះបាទវិទេហរាជត្រាស់ថា សាធុ ចូរនាងទទួលពរនេះចុះ ។

**សិរិកាឡកិណ្ណិបញ្ហា ចប់**

ថ្ងៃមួយ ព្រះបាទវិទេហរាជសោយព្រះក្រយាហារព្រឹកហើយ យាងទៅមកក្នុងល្វែងប្រាសាទ កាលទតតាមបង្អួច បានឃើញពពែមួយ និងឆ្កែមួយធ្វើសេចក្ដីស្និទ្ធស្នាលគ្នា បានឮថា ពពែនោះស៊ីស្មៅក្នុងរោងដំរី ដែលគេដាក់ឲ្យដំរីៗ ក៏មិនបានស៊ី លំដាប់នោះ អ្នកចិញ្ចឹមដំរី ក៏វាយពពែនោះឲ្យចេញទៅ អ្នកចិញ្ចឹមដំរីម្នាក់ដេញតាមពពែនោះ ដែលកំពុងស្រែក រត់ទៅដោយរហ័ស យកអង្កត់ឧសគ្រវែងត្រង់ខ្នង ពពែនោះក៏បាក់ខ្នង ទទួលទុក្ខវេទនាទៅដេកក្បែរតាំង អាស្រ័យជញ្ជាំងធំក្នុងព្រះរាជគេហដ្ឋាន ថ្ងៃនោះ ឆ្កែស៊ីឆ្អឹងនិងស្បែកជាដើម ត្រង់យ៉ាំងរបស់ព្រះរាជារហូតជាត់ កាលអ្នកវិសេសរៀបចំភត្តាហារហើយ ចេញទៅខាងក្រៅដើម្បីឲ្យស្ងួតញើសក្នុងសរីរៈ ឆ្កែបានក្លិនត្រី និងសាច់ មិនអាចអត់ធន់នឹងចំណង់បាន ក៏ចូលទៅក្នុងបន្ទប់ បើកភាជនៈឲ្យធ្លាក់ហើយ ទំពាស៊ីសាច់ ចំណែកអ្នកវិសេសបានឮសំឡេងភាជនៈ ក៏ចូលទៅតាមសំឡេងភាជនៈ ឃើញឆ្កែកំពុងស៊ីសាច់ ទើបបិទទ្វារវាយឆ្កែនោះដោយដុំដី និងដំបងជាដើម ឆ្កែនោះក៏ចោលសាច់ដែលពាំនឹងមាត់ រត់គេចចេញទៅ អ្នកវិសេសដឹងថា ឆ្កែគេចចេញទៅ ក៏ដេញតាមវាយពីក្រោយដោយដំបង ឆ្កែក៏បាក់ជើងក្រោយ លើកជើងម្ខាងទៅក្នុងទីដែលពពែដេក ពពែសួរឆ្កែនោះថា សម្លាញ់លើកជើងម្ខាងមកដោយហេតុអ្វី ខ្យល់ចាក់ដោតសម្លាញ់ឬ ចំណែកឆ្កែក៏សួរថា សម្លាញ់បាក់ខ្នងកំពុងដេក ខ្យល់ចាក់ដោត

សម្លាញ់ឬ ពពែប្រាប់រឿងរបស់ខ្លួនដល់ខ្លា ខ្លាក៏ប្រាប់រឿងយ៉ាងនោះដូចគ្នា ។ លំដាប់នោះ ពពែសួរខ្លាថា សម្លាញ់ហ៊ានទៅរោងចុងភៅទៀតឬ ខ្លាប្រាប់ថា ខ្ញុំមិនហ៊ាន បើចូលទៅជីវិតខ្ញុំនឹងមិនមាន ចុះសម្លាញ់ហ៊ានទៅរោងដំរីទៀតឬ ពពែឆ្លើយថា ខ្ញុំក៏មិនហ៊ានទៅត្រង់រោងដំរីនោះ បើខ្ញុំចេសទៅ ជីវិតខ្ញុំនឹងមិនមាន សត្វទាំងពីរគិតរកឧបាយថា ឥឡូវនេះ យើងរស់នៅបានដូចម្តេចហ្ន៎ ពពែក៏ពោលនឹងខ្លាថា បើយើងទាំងពីរសហការគ្នា ឧបាយពិតជាមាន គឺតាំងអំពីនេះទៅ ចូរអ្នកទៅកាន់រោងដំរី ពួកអ្នកចិញ្ចឹមដំរី នឹងមិនចាប់ភ្លឹកក្នុងខ្លួនអ្នក ព្រោះឃើញថា សត្វនេះមិនស៊ីស្មៅ អ្នកគប្បីនាំស្មៅមកដើម្បីខ្ញុំ ចំណែកខ្ញុំនឹងទៅកាន់រោងចុងភៅ អ្នកវិសេសនឹងមិនសង្ស័យក្នុងខ្លួនខ្ញុំ ព្រោះឃើញថា សត្វនេះមិនស៊ីសាច់ ខ្ញុំនឹងនាំសាច់មកដើម្បីអ្នក សត្វទាំងពីរយល់ព្រមគ្នាថា ឧបាយនេះល្អ ទើបខ្លាទៅកាន់រោងដំរី ពាំបាច់ស្មៅយកមកដាក់ក្បែរជញ្ជាំង ចំណែកពពែទៅកាន់បន្ទប់ចុងភៅ ពាំដុំសាច់ពេញមាត់ នាំមកដាក់ក្នុងទីជិតនោះឯង ខ្លាក៏ទំពាស៊ីសាច់ ពពែក៏ទំពាស៊ីស្មៅ សត្វទាំងពីរនោះព្រមព្រៀងត្រូវគ្នា រស់នៅត្រង់ជញ្ជាំងនោះ ។ ព្រះបាទវិទេហរាជទតឃើញអាកប្បកិរិយាសត្វទាំងពីរ គឺពពែ និងខ្លានោះចងគ្នាជាសម្លាញ់ ទ្រង់ចិន្តនាការថា ហេតុការណ៍ដែលអញមិនធ្លាប់ឃើញ អញបានឃើញហើយ ក្នុងថ្ងៃនេះ ក្នុងកាលមុន សត្វទាំងពីរនេះជាសត្រូវនឹងគ្នា ឥឡូវនេះ សាមគ្គីគ្នាបានអញនឹង ចងហេតុការណ៍នេះ ធ្វើជាប្រស្នាសួរបណ្ឌិតទាំងឡាយ បណ្ឌិតណាមិនដឹងបញ្ហានេះ អញនឹងបណ្តេញបណ្ឌិតនោះចេញអំពីដែន តែអញនឹង

ធ្វើសក្ការៈដល់បណ្ឌិតអ្នកដឹង ព្រោះបណ្ឌិតដទៃដឹងយ៉ាងនេះមិនមាន តែថ្ងៃនេះអស់ពេលទៅហើយ ស្អែកនេះ អញនឹងសួរបណ្ឌិតទាំងនោះ ក្នុងពេលដែលចូលមកគាល់ ។ ស្អែកឡើង កាលបណ្ឌិតទាំងឡាយមកគាល់ហើយ កាលនឹងសួរបញ្ហា ទើបត្រាស់គាថានេះថា

តាំងពីកាលណាមក ក្នុងលោកនេះ មិនធ្លាប់មានពួកសត្វណាមានជើង ៧ យកគ្នាជាសម្លាញ់ឡើយ សត្វទាំងពីរនោះ ជាសត្រូវនឹងគ្នាទេ ( តែឥឡូវ ) ត្រឡប់ជាយកគ្នាធ្វើជាសម្លាញ់ប្រព្រឹត្តរាប់អានគ្នា តើព្រោះហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិសន្ធាយ** បានដល់ ជឿគ្នានិងគ្នាហើយព្យាយាម ។

កាលត្រាស់យ៉ាងនេះហើយ បានត្រាស់យ៉ាងនេះទៀតថា

ប្រសិនបើអ្នកទាំងឡាយ មិនអាចដោះប្រស្នាយើងនុ៎ះ ក្នុងពេលបាយព្រឹក ក្នុងថ្ងៃនេះបានទេ យើងនឹងបំបរបង់អ្នកទាំងអស់គ្នាអំពីដែន ព្រោះយើងមិនត្រូវការ នឹងពួកមនុស្សឥតប្រាជ្ញាឡើយដូច្នេះ ។

អាចារ្យសេនកៈ អង្គុយដើមអាសនៈ មហោសថបណ្ឌិតអង្គុយចុងអាសនៈ ព្រះមហាសត្វពិចារណានូវបញ្ហានោះមិនទាន់ឃើញអត្ថ ទើបគិតថា ព្រះរាជាអង្គនេះ មានបញ្ញាទាន់ខ្សោយ មិនអាចចងប្រស្នាបែបនេះបានឡើយ ទ្រង់មុខជាទតឃើញអ្វីមួយពិត ថ្ងៃមួយ កាលអញបានឱកាស នឹងនាំប្រស្នានេះមក

ទូល អាចារ្យសេនកៈ ញ៉ាំងព្រះរាជាឲ្យបន្ទន់មួយថ្ងៃ ក្នុងថ្ងៃនេះដោយឧបាយណាមួយបានឬ ជនទាំងបីក្រៅអំពីនេះពិចារណាមិនធ្លុះ ដូចចូលក្នុងបន្ទប់ងងឹត ដូច្នោះ សេនកៈសម្លឹងមើលព្រះពោធិសត្វដោយមនសិការថា ការប្រព្រឹត្តទៅរបស់មហោសថដូចម្តេចហ្ន៎ ចំណែកមហោសថក៏សម្លឹងមើលសេនកៈ សេនកៈដឹងបំណងរបស់ព្រះពោធិសត្វ ដោយអាការដែលព្រះពោធិសត្វក្រឡេកមើល ទើបគិតថា បញ្ហានោះមិនទាន់ប្រាកដដល់មហោសថ ព្រោះហេតុនោះ ទើបមហោសថត្រូវការឱកាសមួយថ្ងៃ អញនឹងញ៉ាំងមនោរថរបស់មហោសថឲ្យពេញ ទើបសើចដោយការស្និទ្ធស្នាលនឹងព្រះរាជាទូលថា ទ្រង់បណ្តេញទូលបង្គំទាំងនេះដែលមិនអាចឆ្លើយបញ្ហា ចេញអំពីដែនរបស់ទ្រង់ពិតឬ ព្រះរាជាត្រាស់ឆ្លើយថា ពិត ទើបសេនកៈទូលថា ទ្រង់កំណត់ប្រស្នានេះថា ប្រស្នានេះមានកំណួចមួយឬ ទូលបង្គំទាំងឡាយមិនអាចពោលដោះស្រាយប្រស្នានេះក្នុងថ្ងៃនេះបាន សូមទ្រង់បន្ទន់បន្តិច បញ្ហានេះ មានកំណួច ទូលបង្គំទាំងឡាយនឹងពោលកណ្តាលប្រជុំជន នឹងត្រូវអង្គុយគិតក្នុងទីមួយកន្លែង ខាងក្រោយនឹងទូលដល់ទ្រង់ សូមទ្រង់ព្រះរាជទានឱកាសដល់ពួកទូលបង្គំ សេនកៈពោលដូច្នេះ សម្លឹងមើលមហោសថ ហើយពោល ២ គាថាថា

កាលបើមានការប្រជុំ នៃមហាជនគគ្រឹកគគ្រេង កាលបើមានការ
ជួបជុំ រជើបរជួលនៃជន កើតឡើងហើយ ( យ៉ាងនេះ )
យើងខ្ញុំមានចិត្តរវើរវាយ មានចិត្តមិននឹងនៅក្នុងអារម្មណ៍តែមួយ

មិនអាចឆ្លើយប្រស្នានុ៎ះបានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សម្មសិត្វាន** សេចក្ដីថា អ្នកប្រាជ្ញទាំងនេះ មានឯកគ្គតាចិត្ត តាំងនៅក្នុងកាយវិវេក និងចិត្តវិវេក ពិចារណាប្រស្នានេះហើយ នឹងពោលសេចក្ដីនោះដល់ទ្រង់ ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់សេនកៈ ទ្រង់សោមនស្ស ត្រាស់គំរាមដូច្នេះថា សាធុ ចូរអ្នកទាំងឡាយគិត បើឆ្លើយមិនបាន យើងនឹងបណ្ដេញចោលទាំង ៤ ចេញអំពីរាជនិវេសន៍ ទើបសេនកៈពោលនឹងបណ្ឌិតក្រៅអំពីនេះថា ព្រះរាជាត្រាស់សួរបញ្ហាល្អិតសុខុម កាលពួកយើងឆ្លើយមិនរួច ភ័យធំនឹងកើតឡើង ហេតុនោះ អ្នកទាំងឡាយបរិភោគឲ្យសប្បាយ ហើយចូរពិចារណាប្រស្នានោះដោយប្រពៃ ហើយទៅកាន់ផ្ទះរៀងៗ ខ្លួន ចំណែកមហោសថ ក្រោកទៅកាន់សម្នាក់ព្រះនាងឧទុម្ពរទេវី ទូលសួរថា បពិត្រព្រះទេវី ថ្ងៃនេះ ឬម្សិលមិញនេះ ព្រះរាជាប្រថាប់នៅក្នុងទីណាយូរជាងគេ ព្រះនាងឧទុម្ពរត្រាស់ថា ម្សិលមិញនេះ ព្រះរាជាយាងទៅមកៗ ទតត្រង់បង្អួច ត្រង់រោងវែង ។ បន្ទាប់អំពីនោះ ព្រះពោធិសត្វក៏គិតថា ព្រះរាជាពិតជាបានទតឃើញហេតុអ្វីមួយ ក្នុងទីនោះ ទើបទៅកាន់ទីនោះ សម្លឹងមើលខាងក្រៅ បានឃើញកិរិយាពពែ និងឆ្កែ ក៏យល់ថា ព្រះរាជាទតឃើញសត្វទាំងពីរ ទើបទ្រង់ចងប្រស្នា ចាប់ចំណុចបានដូច្នេះហើយ ក៏ត្រឡប់ទៅកាន់គេហដ្ឋាន ចំណែកបណ្ឌិតទាំងបីគិតហើយ មិនឃើញអ្វីសោះ ទើបទៅរកអាចារ្យសេនកៈៗ ឃើញបណ្ឌិតទាំងបី ក៏សួរថា លោកឃើញប្រស្នាហើយ

ឬ កាលបានទទួលពាក្យឆ្លើយថា មិនទាន់ឃើញទេ ទើបពោលថា បើដូច្នោះ ព្រះរាជានឹងបំបរបង់ពួកលោកចេញអំពីដែន អ្នកទាំងឡាយគិតធ្វើដូចម្ដេច កាលបណ្ឌិតទាំងបីសាកសួរថា ចុះលោក គិតឃើញឬ ក៏ឆ្លើយថា ខ្ញុំក៏គិតមិនទាន់ឃើញ បណ្ឌិតទាំងបីពោលថា បើអាចារ្យគិតមិនឃើញ ពួកខ្ញុំនឹងគិតឃើញដូចម្ដេច មួយលើមិញនេះ យើងទាំងឡាយបន្លឺសីហនាទក្នុងរាជសម្នាក់ថា នឹងស្រាយប្រស្នា ហើយមកផ្ទះ ឥឡូវនេះ ព្រះរាជានឹងខ្ញាល់ បើពួកយើងឆ្លើយមិនបាន ពួកយើងនឹងធ្វើដូចម្ដេច ទើបពោលថា បញ្ហានេះ បើយើងទាំងឡាយមិនឃើញ មហោសថនឹងគិតពិចារណាបានរាប់រយ រាប់ពាន់ន័យ ព្រោះដូច្នោះ អ្នកទាំងឡាយ ចូរទៅកាន់សម្នាក់មហោសថជាមួយយើងចុះ ។ បណ្ឌិតទាំង ៤ ក៏ទៅកាន់ទ្វារគេហដ្ឋានរបស់មហោសថ ឲ្យប្រាប់ភាពដែលខ្លួនមក ហើយចូលទៅកាន់ផ្ទះ ប្រាស្រ័យគ្នាហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ហើយសួរមហោសថថា នែបណ្ឌិត អ្នកគិតប្រស្នាឃើញហើយឬ ព្រះពោធិសត្វឆ្លើយថា បើខ្ញុំគិតមិនឃើញ តើអ្នកណានឹងគិតឃើញបញ្ហានោះ ខ្ញុំគិតឃើញហើយ ។ កាលនោះ បណ្ឌិតទាំង ៤ ពោលថា បើដូច្នោះ សូមលោកប្រាប់ដល់ខ្ញុំផង មហោសថក៏ត្រិះរិះថា បើអញមិនប្រាប់ដល់បណ្ឌិតទាំង ៤ នេះ ព្រះរាជានឹងក្រោធ បណ្ដេញពួកគេចេញអំពីដែនព្រះរាជទានរតនៈ ៧ ដល់អញ មនុស្សល្ងង់ខ្លៅទាំងនេះកុំបីវិនាសឡើយ អញនឹងប្រាប់ដល់ជនទាំងនោះ ត្រិះរិះដូច្នេះហើយ ឲ្យបណ្ឌិតទាំង ៤ អង្គុយក្នុងអាសនៈទាបហើយពោលថា ចូរអ្នកទាំងឡាយព្យាករយ៉ាងនេះ ក្នុងកាល

ដែលព្រះរាជាត្រាស់សួរ ហើយឲ្យបណ្ឌិតទាំង ៤ រៀន បាលីប្រព័ន្ធគាថា ៤ តែមិនឲ្យដឹងវត្ថុដែលព្រះរាជាទតឃើញ ហើយបញ្ជូនត្រឡប់ទៅ ។ ក្នុងថ្ងៃទី ២ បណ្ឌិតទាំងនោះ ទៅកាន់រាជុបដ្ឋានអង្គុយលើអាសនៈដែលគេក្រាលហើយ ព្រះរាជាត្រាស់សួរសេនកៈថា លោកដឹងប្រស្នាហើយឬ សេនកៈក៏ក្រាបទូលថា បពិត្រមហារាជ បើទូលបង្គំមិនដឹង អ្នកដទៃណានឹងដឹង កាលព្រះរាជាឲ្យពោល ទើបពោលគាថាតាមដែលរៀនមកនោះឯងថា

សាច់ពពែជាទីពេញចិត្ត ជាទីគាប់ចិត្តរបស់កូនអាមាត្យ និងព្រះរាជបុត្រទាំងឡាយ ពួកកូនអាមាត្យ និងព្រះរាជបុត្រទាំងនោះ មិនបរិភោគសាច់ឆ្កែទេ បានជាពពែ និងឆ្កែយកគ្នាជាសម្លាញ់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧគ្គបុត្តរាជបុត្តិយានំ** សេចក្ដីថា នៃកូនអមាត្យទាំងឡាយផង នៃព្រះរាជឱរសទាំងឡាយផង ។

កាលពោលគាថាហើយ សេនកៈក៏មិនដឹងសេចក្ដីឡើយ ចំណែកព្រះបាទវិទេហរាជទ្រង់ជ្រាបសេចក្ដី ព្រោះប្រាកដដល់ទ្រង់ ព្រោះដូច្នោះ ទើបត្រាស់សួរបុក្កុសៈបន្ត ព្រោះយល់ថា សេនកៈដឹងហើយ ចំណែកបុក្កុសៈក៏ក្រាបទូលថា ទូលបង្គំមិនមែនជាបណ្ឌិតឬ ហើយពោលគាថាតាមដែលរៀនមកនោះឯងថា

ពួកជនតែងពន្ទះស្បែក ពពែសម្រាប់ក្រាលលើខ្នងសេះ ព្រោះ

ហេតុចង់ឲ្យស្រួល តែពួកជនទាំងនោះមិនក្រាលស្បែកខ្លានទេ បាន

ជាពពែ និងខ្លែយកគ្នាជាសម្លាញ់ ដូច្នេះ ។

តែសេចក្តីមិនប្រាកដដល់បុក្កុសៈឡើយ ។ ចំណែកព្រះរាជាយល់ថា បុក្កុសៈនេះដឹងអត្ថ ព្រោះប្រាកដដល់ទ្រង់ ទើបត្រាស់សួរកាមិន្ទៈបន្ត កាមិន្ទៈក៏ពោលគាថាតាមទំនងដែលរៀនមកនោះឯងថា

ពពែមានស្នែងជាវង្វង់ ឯខ្លែគ្មានស្នែងទេ ពពែស៊ីស្មៅខ្លែស៊ីសាច់

បានជាពពែ និងខ្លែយកគ្នាជាសម្លាញ់ ដូច្នេះ ។

សេចក្តីមិនប្រាកដដល់កាមិន្ទៈឡើយ ។ ព្រះរាជាយល់ថា សូម្បីកាមិន្ទៈនេះក៏ដឹងសេចក្តីនេះហើយ ទើបត្រាស់សួរទេវិន្ទៈជាបន្ត ទេវិន្ទៈក៏ពោលគាថាតាមដែលរៀនមកនោះឯងថា

ពពែស៊ីស្មៅ ស៊ីស្លឹកឈើ ឯខ្លែមិនស៊ីស្មៅ មិនស៊ីស្លឹកឈើទេ

ខ្លែខាំតែទន្សាយ និងសំពោច បានជាពពែ និងខ្លែយកគ្នាជា

សម្លាញ់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តិណាមាសិ បលាសមាសិ** សេចក្តីថា សត្វស៊ីស្មៅ និងស៊ីស្លឹកឈើ ។ បទថា **ន បលាសំ** សេចក្តីថា ខ្លែមិនស៊ីស្លឹកឈើទេ ។

សេចក្តីមិនប្រាកដដល់ទេវិន្ទៈឡើយ គ្រានោះ ព្រះរាជាយល់ថា សូម្បីទេវិន្ទៈនេះក៏ដឹង ព្រោះប្រាកដដល់ព្រះអង្គ ទើបត្រាស់សួរដល់មហោសថថា ហៃបាមហោសថ តើអ្នកដឹងប្រស្នានេះឬ មហោសថទូលថា បពិត្រមហារាជ

ចាប់ពីអវីចីដល់ភវគ្គព្រហ្ម រៀវទូលបង្គំហើយ អ្នកដទៃណានឹងដឹងប្រស្នានេះ កាលព្រះរាជាត្រាស់ឲ្យពោល ទើបក្រាបទូលថា សូមទ្រង់ស្តាប់ចុះ កាលប្រកាសភាពដែលកិច្ចនោះប្រាកដដល់ខ្លួន ទើបពោល ២ គាថាថា

សត្វជើង ៧ កន្ទះ គឺខ្លែមានជើង ៣ កន្ទះ ពពែមានជើង ៤ មាន ក្រចក ៨ បន្ទំលួចសាច់ ឯខ្លែនេះលួច ( ស្មៅ ) ឲ្យពពែនេះ ពពែនេះ លួចសាច់ឲ្យខ្លែឯនោះ ។

ពួថា ព្រះបាទវិទេហរាស្ត្រ ជាស្តេចដ៏ប្រសើរ ជាធំជាងជន ស្តេចគង់នៅលើប្រាសាទដ៏ប្រសើរ ទ្រង់ទតឃើញជាក់ច្បាស់នូវការផ្លាស់ប្តូរភោជន ដល់គ្នានិងគ្នាទុំះ របស់ខ្លែនិងពពែ ដែលដើរទៅលួចអាហារ ពេញមាត់មកឲ្យគ្នាបរិភោគ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អឌ្ឍឌ្ឍចាគោ** លោកពោលសំដៅយកជើង ៤ នៃពពែ ព្រោះភាពជាអ្នកឈ្លាសក្នុងព្យញ្ជនៈ ។ បទថា **មេណ្ឌោ** បានដល់ពពែ ។ បទថា **អឌ្ឍនក្ខោ** នេះ លោកពោលតាមដែលជើងពពែមួយ មានក្រចកពីរ ។ បទថា **អទិស្សមានកាយោ** សេចក្តីថា មិនប្រាកដកាយ ក្នុងពេលដែលនាំសាច់មក ។ បទថា **ធាទិយំ** សេចក្តីថា គ្រឿងប្រក់ គឺស្មៅ ។ បទថា **អយំ ឥមស្ស** សេចក្តីថា ខ្លែនាំស្មៅមកដើម្បីពពែ ។ បទថា **វីតិហារំ** បានដល់ នាំមកដូរគ្នា ។ បទថា **អញ្ញោញ្ញភោជនានំ** សេចក្តីថា ដូរគ្នាស៊ី ព្រោះថា ពពែនាំរបស់ស៊ីមកដើម្បីខ្លែៗ ក៏ដូរជាមួយពពែនោះ គឺខ្លែនាំមកដើម្បីពពែៗ នាំមកដើម្បីខ្លែ ។ បទថា **អទ្ទក្ខិ** សេចក្តីថា បានទតឃើញសត្វ

ទាំងពីរនោះ ដូរគ្នាបរិភោគផ្ទាល់ព្រះនេត្រ គឺប្រចក្សដល់ព្រះអង្គ ។ បទថា **ភោកុក្កុស្ស** បានដល់ ឆ្កែដែលព្រុសថា កុកុ ។ បទថា **បុណ្ណមុខស្ស** បានដល់ ពពែ អធិប្បាយថា ព្រះរាជាទតឃើញមិត្តភាពរបស់សត្វទាំងពីរនេះ ដោយព្រះអង្គឯង ។

ព្រះរាជាកាលទ្រង់មិនជ្រាប ភាពដែលអាចារ្យទាំងនោះដឹងបញ្ហាព្រោះអាស្រ័យព្រះពោធិសត្វ ទ្រង់សម្គាល់ថា បណ្ឌិតទាំង ៥ ដឹងដោយបញ្ញារៀងៗ ខ្លួន ទ្រង់សោមនស្ស ត្រាស់គាថានេះថា

យើងហៅពេញជាមានលាភ មានសភាពមិនតិចទេ ព្រោះអ្នកប្រាជ្ញទាំងឡាយបែបនេះ មាននៅក្នុងត្រកូលរបស់យើង អ្នកប្រាជ្ញទាំងនេះយល់អាថ៌ប្រស្នាដ៏ជ្រាលជ្រៅល្អិត ដោយសុភាសិតបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិវិជ្ឈន្តិ** សេចក្តីថា ពោលឆ្លើយនូវប្រស្នាដោយសុភាសិត ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អញគួរធ្វើអាការត្រេកអរដល់បណ្ឌិតទាំងនោះ ដោយសេចក្តីត្រេកអរ កាលទ្រង់ធ្វើនូវសេចក្តីត្រេកអរនោះឲ្យជាក់ច្បាស់ ទើបពោលគាថាដូច្នេះថា

យើងមានចិត្តត្រេកអរដ៏ក្រៃលែង យើងឲ្យសេះអស្សតរ និងរថមួយៗ ម្នាក់ ឲ្យស្រុកសួយដែលបរិបូណ៌មួយៗ ម្នាក់ ដល់អ្នកទាំងអស់គ្នា ជាអ្នកប្រាជ្ញព្រោះសុភាសិត ដូច្នេះ ។

កាលត្រាស់ដូច្នេះហើយ ទ្រង់បានព្រះរាជទានវត្ថុទាំងពួងនោះ ។

មេណ្ឌកបញ្ហាក្នុងទ្វាទសកនិបាត ចប់

ចំណែកព្រះរាជទេវីឧទុម្ពរ ព្រះនាងជ្រាបភាពដែលបណ្ឌិតទាំង ៤ ដឹងបញ្ហាព្រោះអាស្រ័យមហោសថ ព្រះនាងត្រិះរិះថា ព្រះរាជាប្រទានរង្វាន់ដល់បណ្ឌិតទាំង ៥ ដូចជាធ្វើសណ្តែកបាយ និងសណ្តែករាជមាសមិនឲ្យប្លែកគ្នា ទើបយាងទៅគាល់ព្រះរាជាទូលសួរថា អ្នកណាទូលបញ្ហាថ្វាយទ្រង់ ព្រះរាជាត្រាស់ថា បណ្ឌិតទាំង ៥ ព្រះនាងទូលថា បណ្ឌិតទាំង ៤ ដឹងបញ្ហារបស់ទ្រង់អាស្រ័យអ្នកណា ព្រះរាជាតបថា យើងមិនដឹង ទើបព្រះនាងឧទុម្ពរក្រាបទូលថា បណ្ឌិតទាំង ៤ នាក់នេះដឹងអ្វី មហោសថឲ្យរៀនបញ្ហា ព្រោះយល់ឃើញថា បុគ្គលល្ងង់ខ្លៅទាំងនេះកុំបីវិនាសឡើយ ទ្រង់ព្រះរាជទានរង្វាន់ដល់បណ្ឌិតទាំងពួងស្មើគ្នានោះ មិនសមគួរឡើយ គួរព្រះរាជទានដល់មហោសថឲ្យវិសេស ព្រះរាជាទ្រង់ឃើញថា មហោសថនេះមិនប្រាប់ភាពដែលបណ្ឌិតទាំង ៤ ដឹងបញ្ហាអាស្រ័យខ្លួន ក៏ទ្រង់សោមនស្ស មានបំណងនឹងធ្វើសក្ការៈឲ្យក្រៃលែងជាង ទើបទ្រង់គិតថា ចូរលើកទុកចុះ យើងនឹងសួរបញ្ហាមួយដល់បុត្ររបស់យើង នឹងធ្វើសក្ការៈធំ ក្នុងកាលដែលបុត្ររបស់យើងស្រាយប្រស្នា កាលព្រះរាជាគិតប្រស្នា ទើបទ្រង់គិតសិរិមេណ្ឌកបញ្ហា ។ ថ្ងៃមួយ ពេលបណ្ឌិតទាំង ៥ មកអង្គុយគាល់ស្រួលបួលហើយ ទ្រង់ត្រាស់នឹងអាចារ្យសេនកៈថា លោកអាចារ្យសេនកៈ យើងនឹងសួរបញ្ហា សេនកៈក្រាបទូលថា សូមទ្រង់ត្រាស់សួរចុះ ទើបព្រះរាជាត្រាស់គាថាទី ១ ក្នុង

សិរិមេណ្ឌកបញ្ហាថា

នៃសេនកៈ យើងសួរនូវសេចក្តីនុ៎ះ គឺបុគ្គលប្រកបដោយប្រាជ្ញា ប្រាសចាកសិរីសម្បត្តិ ១ បុគ្គលមានយស ប្រាសចាកប្រាជ្ញា ១ អ្នកប្រាជ្ញទាំងឡាយពោលថា បណ្តាបុគ្គលទាំងពីរនោះ បុគ្គលណា ប្រសើរជាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កតមេត្ថ សេយ្យោ** សេចក្តីថា បណ្តាជនពីរពួកនេះ បណ្ឌិតទាំងឡាយ ពោលបុគ្គលណាថាប្រសើរ បានឮថា បញ្ហានេះ បន្តមកអំពីវង្សរបស់សេនកៈ ដូច្នោះ ទើបសេនកៈក្រាបទូលឆ្លើយបញ្ហានោះបានភ្លាមថា

បពិត្រព្រះអង្គជាធំជាងជន ពួកអ្នកប្រាជ្ញ ពួកជនពាល ពួកជនអ្នកបរិបូណ៌ដោយសិល្បៈ និងពួកជនមិនមានសិល្បៈ សូម្បីជាអ្នកមានជាតិខ្ពស់ រមែងជាអ្នកធ្វើនូវការបម្រើជនអ្នកមានយស ដែលមិនមានជាតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និហីនោ** សេចក្តីថា បុគ្គលមានបញ្ញាជាបុគ្គលថោកថយ បុគ្គលជាធំនោះឯង ជាបុគ្គលប្រសើរ ។

ព្រះបាទវិទេហរាជ បានស្តាប់ពាក្យរបស់សេនកៈនោះហើយ ទ្រង់មិនត្រាស់សួរអាចារ្យទាំង ៣ ទៀតឡើយ កាលត្រាស់សួរមហោសថបណ្ឌិត

ដែលជាអ្នកមកប្តីក្នុងពួក ដែលកំពុងអង្គុយ ទើបត្រាស់ថា

ម្នាលមហោសធ អ្នកមានប្រាជ្ញា មិនថោកថយ ជាអ្នកឃើញនូវហេតុដោយសព្វគ្រប់ យើងសូមសួរអ្នក អំពីបុគ្គលពាលមានយស បណ្ឌិតគ្មានភោគៈ តើអ្នកប្រាជ្ញទាំងឡាយ ពោលថា បណ្តាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អោរលធម្មទស្សិ** សេចក្តីថា អ្នកឃើញធម៌ទាំងពួង ។

លំដាប់នោះ មហាសត្វក៏ទូលព្រះរាជាថា សូមទ្រង់ស្តាប់ចុះ ហើយក្រាបទូលថា

ពួកជនពាល តែងធ្វើនូវអំពើអាក្រក់ទាំងឡាយ ហើយសម្គាល់ថា អំពើនេះឯង ជាអំពើប្រសើរ ជាអ្នកឃើញត្រឹមតែលោកនេះ មិនឃើញនូវលោកខាងមុខទេ បុគ្គលពាល តែងកាន់យកនូវទោសក្នុងលោកទាំងពីរ ខ្ញុំព្រះអង្គបានឃើញហេតុនេះ សូមទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធមេវ** សេចក្តីថា សម្គាល់ថា ឥស្សរិយយសរបស់អញនេះប៉ុណ្ណោះក្នុងលោកនេះប្រសើរ ។ បទថា **កលិមគ្គហេសិ** សេចក្តីថា បុគ្គលពាលធ្វើបាបកម្មដោយការស្រវឹងក្នុងឥស្សរិយៈ កើតក្នុងនរកជាដើមក្នុងបរលោក មកអំពីនរកនោះ កើតជាបុគ្គលមានទុក្ខព្រោះភោជន

ក្នុងត្រកូលថោកទាបក្នុងលោកនេះ ឈ្មោះថា កាន់យកនូវការបរាជ័យក្នុងលោកទាំងពីរ ដោយប្រការដូច្នេះ ។ បទថា **ឯតម្បិ** សេចក្តីថា ទូលបង្គំឃើញហេតុនេះ ទើបពោលថា បុគ្គលសម្បូរដោយបញ្ញាប៉ុណ្ណោះជាបុគ្គលឧត្តម បុគ្គលល្ងង់ខ្លៅ ទោះបីជាធំ ក៏មិនមែនជាបុគ្គលប្រសើរ ។

កាលមហាសត្វទូលដូច្នេះ ព្រះបាទវិទេហរាជទតអាចារ្យសេនកៈត្រាស់ថា មហោសថសរសើរបុគ្គលមានបញ្ញា ថាជាបុគ្គលប្រសើរមិនមែនឬ សេនកៈទូលថា បពិត្រមហារាជ មហោសថក្មេងណាស់ មកទល់នឹងថ្ងៃនេះ មាត់របស់គេមិនទាន់បាត់ធុំក្លិនទឹកដោះផង គេនឹងដឹងអ្វី ទូលដូច្នេះហើយ ទើបពោលគាថាដូច្នេះថា

សិល្បៈនេះ រមែងមិនដល់នូវភោគសម្បត្តិទេ បុគ្គលមានផៅពង្ស ក៏មិនដល់នូវបុគ្គលមានភោគសម្បត្តិដែរ ទាំងបុគ្គលអ្នកមានឱកាសនៃសរីរៈ ( មានរូបឆោមល្អ ) ក៏មិនដល់នូវបុគ្គលមានភោគសម្បត្តិដែរ សូមទ្រង់ទតចុះ អ្នកផងតែងគប់រកនូវគោរវិន្ទសេដ្ឋី ជាមនុស្សហៀរទឹកមាត់ដល់នូវសេចក្តីសុខ ជាអ្នកសាបសូន្យចាកសិរី ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯឡម្ងគំ** បានដល់ មានទឹកមាត់ហូរចេញ ។ បទថា **គោរវិន្ទំ** សេចក្តីថា បានឮថា គោរវិន្ទៈនោះជាសេដ្ឋី មានសម្បត្តិ

៨០ កោដិ ក្នុងព្រះនគរនោះឯង មានរូបរាងខុសប្រក្រតី មិនមានកូនប្រុសស្រី មិនចេះសិប្បៈអ្វីឡើយ កាលគាត់និយាយ ទឹកមាត់ក៏ហូរតាមរង្វះមាត់ទាំងពីរ មានស្រ្តីពីរនាក់ស្អាតដូចទេពអប្សរ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់ផ្កាឧប្បលខៀវដែលរីកល្អហើយ ឈរសងខាងចាំត្រងទឹកមាត់ដោយផ្កាឧប្បលខៀវ ហើយបោះផ្កាឧប្បលតាមបង្អួច ចំណែកពួកអ្នកលេងសុរា កាលបើគេអស់ស្រា ត្រូវការដោយផ្កាឧប្បលខៀវ ក៏នាំគ្នាទៅកាន់ទ្វារផ្ទះរបស់សេដ្ឋីនោះ ហើយពោលថា បពិត្រលោកគោរវិន្ទសេដ្ឋី លោកសេដ្ឋីបានឮនូវសំឡេងរបស់អ្នកលេងទាំងនោះ ឈរត្រង់បង្អួច ពោលថា មានរឿងអ្វីបា ខណៈនោះ ទឹកមាត់ក៏ហូរអំពីមាត់របស់លោកសេដ្ឋី ស្រីពីរនាក់នោះក៏យកផ្កាឧប្បលខៀវត្រងទឹកមាត់ ហើយបោះទៅក្នុងរវាងផ្លូវ ពួកអ្នកលេងក៏រើសផ្កាឧប្បលទាំងនោះយកទៅលាងទឹក ហើយប្រដាប់ខ្លួន ចូលតៀមស្រាសេដ្ឋីនោះ ជាអ្នកសម្បូរដោយសិរីយ៉ាងនេះ សេនកៈកាលបង្ហាញសេដ្ឋីនោះជាគំរូ ទើបពោលយ៉ាងនេះ ។

ព្រះរាជាស្តាប់ដូច្នោះហើយ ពោលថា នែបាមហោសថ អ្នកពោលដោះស្រាយដូចម្តេច ។ មហោសថបណ្ឌិតក្រាបទូលថា បពិត្រព្រះសម្មតិទេព សេនកៈដឹងអ្វី សម្លឹងឃើញតែយសប៉ុណ្ណោះ មិនឃើញញញួរធំដែលនឹងធ្លាក់លើក្បាល ប្រៀបដូចក្អែកក្នុងទីដែលគេចាក់បាយ និងប្រៀបដូចសុនខ ប្រាថ្នានឹងផឹកទឹកដោះជូរ សូមទ្រង់ស្តាប់ចុះ ទូលដូច្នេះហើយ បានពោលគាថានេះថា

បុគ្គលអប្បប្រាជ្ញា បានសេចក្តីសុខហើយ រមែងស្រវឹង លុះត្រូវ

សេចក្តីទុក្ខប៉ះពាល់វិញ ក៏ដល់នូវសេចក្តីវង្វេង បុគ្គលអប្បប្រាជ្ញា ត្រូវសេចក្តីសុខ និងទុក្ខមកថ្មីប៉ះពាល់ហើយ ក៏រមែងញាប់ញ័រ ដូចជាវារិចរ ( សត្វត្រាច់ទៅក្នុងទឹក ) ដែលញាប់ញ័រក្នុងកាល ក្តៅ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមាន ប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាល មានយស មិន ប្រសើរ ។

បណ្តាបទទាំងនោះ បទថា **លទ្ធា សុខំ** សេចក្តីថា បុគ្គលល្ងង់ខ្លៅ បានឥស្សរិយសុខហើយ រមែងស្រវឹង គឺប្រមាទ បុគ្គលប្រមាទរមែងធ្វើបាប ច្រើន ។ បទថា **ទុក្ខេន** សេចក្តីថា ដែលសេចក្តីទុក្ខផ្លូវកាយ និងចិត្ត ពាល់ ត្រូវហើយ ។ បទថា **អាគន្តុនា** បានដល់ ដែលមិនបានកើតខាងក្នុង ព្រោះ ថា សូម្បីសេចក្តីសុខរបស់សត្វទាំងឡាយ ក៏ជារបស់ចរមកទាំងអស់ មិន មែនជារបស់ប្រចាំ ។

បទថា **យថា** សេចក្តីថា ដូចត្រីដែលគេលើកឡើងអំពីទឹក បោះទៅ ក្នុងទីក្តៅ រមែងបម្រះននៀល ។

ព្រះបាទវិទេហរាជ ទ្រង់ស្តាប់ដូច្នោះហើយ ទើបត្រាស់សួរសេនកៈថា លោកអាចារ្យឆ្លើយដូចម្តេច សេនកៈក្រាបទូលថា បពិត្រព្រះសម្មតិទេព មហោសថនេះដឹងអ្វី មនុស្សទាំងឡាយចូរលើកទុកចុះ បក្សីទាំងឡាយរមែង មករកតែដើមឈើដែលកើតក្នុងព្រៃ ដែលសម្បូរដោយផ្លែប៉ុណ្ណោះ ទូល ដូច្នេះហើយ បានពោលគាថានេះថា

ពួកសត្វបក្សី តែងហើរសំដៅ ទៅចោមរោមដើមឈើ ដែលមាន ផ្លែដ៏ឆ្ងាញ់ក្នុងព្រៃ យ៉ាងណា ជនជាច្រើន តែងគប់រកនូវបុគ្គល ស្តុកស្តម្ភ បរិបូណ៌ដោយទ្រព្យ និងភោគៈ ព្រោះហេតុតែ ប្រយោជន៍ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គល មានសិរី ជាបុគ្គលប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុជ្ជនោ** សេចក្តីថា មនុស្សជាច្រើន ប្រជុំគ្នាដើម្បីហេតុនៃទ្រព្យ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទើបត្រាស់ជាមួយមហោសថថា នែបា មហោសថ តើបាដោះស្រាយដូចម្តេច មហោសថបណ្ឌិតក្រាបទូលថា បពិត្រ មហារាជ សេនកៈនេះដឹងអ្វី ធំតែពោះប៉ុណ្ណោះ សូមទ្រង់ស្តាប់ចុះ ទូលដូច្នេះ ហើយ ទើបពោលគាថានេះថា

បុគ្គលពាល មានកម្លាំង រមែងបាននូវទ្រព្យ ( ព្រោះតែធ្វើ ) នូវកម្មដ៏ក្តៅក្លា មិនល្អទេ ពួកនិរយបាល តែងទាញកន្ត្រាក់នូវ បុគ្គលពាល ឥតប្រាជ្ញា ដែលកន្ទក់កន្ទេញនោះ យកទៅកាន់នរក ដ៏ក្តៅក្លា ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាល មានយស មិនប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាហសំ** សេចក្តីថា បុគ្គលល្ងង់ខ្លៅធ្វើ

នូវកម្មក្បៀវក្លាដោយភាពក្បៀវក្លា បៀតបៀនមហាជន ទើបបានទ្រព្យ កាលបើដូច្នោះ ទើបនាយនិរយបាលទាំងឡាយ អូសបុគ្គលល្ងង់ខ្លៅនោះ ដែលមិនឈ្លាស កំពុងយំនោះឯងទៅកាន់នរក ដែលមានវេទនាជាកម្លាំង ។

កាលព្រះរាជាត្រាស់សួរទៀតថា លោកអាចារ្យសេនកៈ លោកនឹងដោះស្រាយដូចម្តេច សេនកៈក៏ទូលថា បពិត្រមហារាជ សូមទ្រង់ស្តាប់ចុះ ហើយពោលគាថានេះថា

ទឹកស្ទឹងទាំងឡាយណាមួយ រមែងហូរចាក់ទៅក្នុងទន្លេគង្គា ទឹកស្ទឹងទាំងអស់នោះ រមែងលះបង់នូវនាម និងគោត្រ ទឹកទន្លេគង្គាកាលបើហូរដល់សមុទ្រ ( រមែងបានឈ្មោះថា មហាសមុទ្រ យ៉ាងណា ) បុគ្គលដែលមានប្រាជ្ញាជាគ្រឿងសម្រេច ក៏មិនប្រាកដក្នុងលោក យ៉ាងនោះដែរ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរីជាបុគ្គលប្រសើរ ។

បណ្តាបទទាំងនោះ បទថា **សន្ទន្តិ** សេចក្តីថា ជាសភាវៈអនុលោមទៅ គឺហូរទៅ ដោយហោចសូម្បីតែស្ទឹងតូចៗ ។ បទថា **ជហន្តិ** សេចក្តីថា រមែងរាប់ថា ជាស្ទឹងគង្គាទាំងអស់ រមែងលះឈ្មោះដើមរបស់ខ្លួនចោល ។ បទថា **ន ខាយតេ** សេចក្តីថា ស្ទឹងគង្គានោះ កាលហូរទៅកាន់សមុទ្រ ក៏មិនប្រាកដថាជាស្ទឹងគង្គា រមែងបានឈ្មោះថាជាមហាសមុទ្រនោះឯង សូម្បីបុគ្គលមានបញ្ញាច្រើន ចូលទៅរកបុគ្គលដែលមានឥស្សរៈហើយ រមែងមិន

ប្រាកដ គឺមិនមានអ្នកណាស្គាល់ ដូចស្ទឹងគង្គាហូរទៅកាន់សមុទ្រ ។

ព្រះរាជាត្រាស់ទៀតថា នែបាបណ្ឌិត បានឹងដោះស្រាយដូចម្តេច មហោសធក្រាបទូលថា សូមទ្រង់ស្តាប់ចុះ ហើយពោលគាថានេះថា

លោកសេនកៈ បានពោលនូវមហាសមុទ្រណា ថាជាសមុទ្រធំ ទឹកស្ទឹងទាំងឡាយ តែងហូរទៅក្នុងសមុទ្រនោះ រាប់មិនបាន អស់កាលទាំងពួង សមុទ្រនោះ មានសម្ទុះដ៏លើសលប់ជានិច្ច ក៏មែន តែថា ទឹកមហាសមុទ្រ ក៏មិនកន្លងនូវប្រាំងបានទេ ការ ប្រឹក្សារបស់មនុស្សពាល ក៏យ៉ាងនោះដែរ តាំងពីកាលណាមក បុគ្គលអ្នកមានសិរី រមែងមិនកន្លងនូវបុគ្គល មានប្រាជ្ញាបាន ឡើយ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមាន ប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិន ប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យមេតមក្ខា** សេចក្តីថា លោកប្រាប់ គឺពោលបញ្ហាណា ។ បទថា **អសង្ខ្យេយ្យំ** បានដល់ រាប់មិនអស់ ។ បទថា **វេលំ នាច្ចេតិ** សេចក្តីថា សមុទ្រនោះឯងមានកម្លាំងក្រៃលែង បង្កើតរលក ឡើងរាប់ពាន់ ក៏មិនអាចកន្លងប្រាំងទៅបាន រលកទាំងអស់ដល់ប្រាំងហើយ រមែងបែកទៅដោយពិត ។ បទថា **ឯវម្បិ** សេចក្តីថា កិច្ចដែលបុគ្គលល្ងង់ខ្លៅ បំណង រមែងមិនអាចកន្លងបុគ្គលដែលមានបញ្ញាទៅបាន កាលមកដល់ បុគ្គល មានបញ្ញានោះហើយ រមែងបែកធ្លាយទៅដូច្នោះដូចគ្នា ។ បទថា **បញ្ញំ**

**ឆាច្ចេតិ** សេចក្តីថា ធម្មតាបុគ្គលមានសិរី រមែងមិនកន្ទ្រងបុគ្គលដែលមានបញ្ញាទៅបានឡើយ អធិប្បាយថា មិនមានបុគ្គលណា ដែលកើតសេចក្តីសង្ស័យក្នុងប្រយោជន៍ និងមិនជាប្រយោជន៍ រំលងអ្នកមានបញ្ញា ទៅទៀបបាតជើងរបស់បុគ្គលល្ងង់ខ្លៅ ដែលជាឥស្សរៈ តែរមែងបានការវិនិច្ឆ័យទៀបបាតជើងរបស់បុគ្គលមានបញ្ញាប៉ុណ្ណោះ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទើបត្រាស់សួរសេនកៈថា តើអ្នកនឹងដោះស្រាយដូចម្តេច អាចារ្យសេនកៈក្រាបទូលថា សូមទ្រង់ស្តាប់ចុះ ហើយពោលគាថានេះថា

> បុគ្គលពាលមានយស ស្ថិតនៅក្នុងទីវិនិច្ឆ័យ បើទុកជាមិនព្រៀងទុក ក៏អាចប្រាប់នូវសេចក្តី ចំពោះពួកជនដទៃបាន សម្តីរបស់បុគ្គលមានយសនោះឯង រមែងលូតលាស់ ក្នុងកណ្តាលនៃពួកញាតិ អ្នកផងមិនអាចញុំាងបុគ្គលដែលមានប្រាជ្ញា តែសាបសូន្យចាកសិរី ឲ្យធ្វើការ ( អ្វី ) បានទេ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសញ្ញតោ ចេបិ** សេចក្តីថា បើបុគ្គលមានយស ជាអ្នកមិនសង្រួមកាយជាដើម គឺជាអ្នកទ្រុស្តសីល ។ បទថា **សណ្ឋានគតោ** សេចក្តីថា បុគ្គលមានយស តាំងនៅក្នុងទីវិនិច្ឆ័យ ពោលអត្ថដល់បុគ្គលដទៃ កាលបុគ្គលនោះ ដែលចោមរោមទៅដោយបរិវារធំ

ពោលមុសា ធ្វើម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យ ក្នុងរេឿងវិនិច្ឆ័យ ពាក្យរបស់បុគ្គលនោះឯង រមែងគេកាន់យក បុគ្គលអ្នកមានបញ្ញា រមែងធ្វើបុគ្គលដែលមានសិរីឲ្យធ្វើតាមពាក្យមិនបាន ហេតុនោះ បុគ្គលមានបញ្ញា ជាបុគ្គលថោកថយ បុគ្គលមានសិរី ទើបជាបុគ្គលប្រសើរ ។

កាលព្រះរាជាត្រាស់សួរមហោសថថា នែបា តើបាដោះស្រាយដូចម្តេច មហោសថបណ្ឌិតក្រាបទូលថា សូមទ្រង់ស្តាប់ចុះ សេនកៈល្ងង់ខ្លៅដឹងអ្វី សម្តីងមើលតែក្នុងលោកនេះប៉ុណ្ណោះ មិនមើលដល់បរលោក ហើយពោលគាថានេះថា

បុគ្គលពាលអប្បប្រាជ្ញា រមែងនិយាយកុហក ព្រោះហេតុនៃអ្នកដទៃ ឬខ្លួនឯង បុគ្គលពាលនោះ ត្រូវគេតិះដៀល ក្នុងកណ្តាលទីប្រជុំ ក្នុងកាលខាងក្រោយ បុគ្គលពាលនោះ រមែងទៅកាន់ទុគ្គតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលដែលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាល មានយស មិនប្រសើរ ដូច្នេះ ។

លំដាប់នោះ អាចារ្យសេនកៈពោលគាថានេះថា

បុគ្គលមានប្រាជ្ញាក្រាស់ដូចផែនដី មិនមានទីលំនៅ មិនមានទ្រព្យធន ជាបុគ្គលក្រីក្រ បើទុកជាពោលនូវសេចក្តី ( ណាមួយ ) ពាក្យសម្តីរបស់បុគ្គលដែលមានប្រាជ្ញានោះ ក៏មិនលូតលាស់ ក្នុងកណ្តាលនៃពួកញាតិ ទាំងសិរីរបស់បុគ្គលមានប្រាជ្ញា ក៏មិនមាន ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា

ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថម្ហិ ជេ** សេចក្តីថា បើពោលហេតុការណ៍ ។ បទថា **ញាតិមជ្ឈេ** បានដល់ ក្នុងកណ្តាលបរិស័ទ ។ ដោយបទថា **បញ្ញាណវតោ** នេះ អាចារ្យសេនកៈសម្តែងសេចក្តីថា បពិត្រមហារាជ ធម្មតាសិរី សូម្បីមាននៅតាមប្រក្រតី ដល់នូវភាពជាកំពូល សេចក្តីល្អនៃសិរី ក៏មិនមានដល់បុគ្គលមានបញ្ញានោះឯង ព្រោះថា បុគ្គលមានបញ្ញានោះ រមែងមិនប្រាកដក្នុងសម្នាក់របស់បុគ្គលមានសិរីនោះ ដូចអំពិលអំពែកក្នុងកាលព្រះអាទិត្យរះឡើង ដូច្នោះ ។

កាលព្រះរាជាត្រាស់សួរមហោសថទៀតថា នែបាមហោសថ តើបាដោះស្រាយដូចម្តេច មហោសថបណ្ឌិតក៏ក្រាបទូលថា សេនកៈដឹងអ្វី គាត់ឃើញតែក្នុងលោកនេះប៉ុណ្ណោះ មិនឃើញដល់បរលោក ហើយពោលគាថានេះថា

បុគ្គលអ្នកមានប្រាជ្ញា ក្រាស់ដូចផែនដី រមែងមិននិយាយពាក្យឡេះឡោះ ព្រោះហេតុនៃបុគ្គលដទៃ ឬខ្លួនឯងទេ បុគ្គលអ្នកមានប្រាជ្ញានោះ មានគេបូជាក្នុងកណ្តាលទីប្រជុំ លុះកាលខាងក្រោយ អ្នកមានប្រាជ្ញានោះ រមែងទៅកាន់សុគតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាល មានយស មិនប្រសើរទេ ដូច្នេះ ។

លំដាប់នោះ អាចារ្យសេនកៈពោលគាថានេះថា

ដំរី គោ សេះ កែវមណី កុណ្ឌល និងនារី តែងកើតមានក្នុង

ត្រកូលដ៏ស្តុកស្តម្ភ ដីរី គោ សេះជាដើមទាំងអស់នោះ ជារបស់មិនមានឫទ្ធិ ទើបជាគ្រឿងឧបភោគ ( ប្រើប្រាស់ ) របស់បុរសជាឥស្សរៈ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទ្ធស្ស** បានដល់ បុគ្គលមានឥស្សរៈ ។ បទថា **អនិទ្ធិមន្តោ** សេចក្តីថា មិនមែនតែនារីទាំងនោះប៉ុណ្ណោះទេ ដែលជាឧបភោគ ដោយពិតនោះ សត្វទាំងឡាយដែលជាអ្នកមិនមានឥស្សរៈទាំងអស់ រមែងជាឧបភោគរបស់បុគ្គលមានឥស្សរៈនោះ ។

លំដាប់នោះ មហោសថបណ្ឌិតពោលថា សេនកៈដឹងអ្វី កាលនឹងទាញយកហេតុមួយមកសម្តែង ទើបពោលគាថានេះថា

សិរី គឺឥស្សរិយយស រមែងលះបង់នូវបុគ្គលពាល ដែលមិនចេះចាត់ចែងនូវការងារ ជាអ្នកមានគំនិតអាក្រក់ ឥតប្រាជ្ញា ដូចពស់ដែលលះចោលនូវសំណាកចាស់ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាល មានយស មិនប្រសើរទេ ដូច្នេះ ។

អត្ថនៃបទថា **សិរី ជហាតិ** ក្នុងគាថានោះ គប្បីជ្រាបតាមចេតិយជាតក ។

លំដាប់នោះ កាលព្រះរាជាត្រាស់សួរសេនកៈថា តើអ្នកដោះស្រាយដូចម្តេច សេនកៈក្រាបទូលថា បពិត្រព្រះសម្មតិទេព មហោសថនេះនៅ

ក្មេង ដឹងអ្វី សូមទ្រង់ស្តាប់ចុះ ទូលដូច្នេះហើយ គិតថា អញនឹងធ្វើមហោសធឲ្យអស់បដិភាណ ទើបពោលគាថានេះថា

បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំង ៥ នាក់ សុទ្ធសឹងជាបណ្ឌិត ប្រណម្យដៃបម្រើព្រះអង្គទាំងអស់គ្នា ព្រះអង្គជាធំលើសលុប ពួកខ្ញុំព្រះអង្គ ដូចជា ទេវរាជឈ្មោះសក្កៈជាម្ចាស់នៃទេវតា ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ដូច្នេះ ។

បានឮថា ព្រះបាទវិទេហរាជ ទ្រង់ស្តាប់ពាក្យរបស់សេនកៈនេះហើយ ទ្រង់ត្រិះរិះថា ហេតុការណ៍ដែលសេនកៈលើកមកនេះល្អ កូនរបស់អញអាចនាំហេតុការណ៍ដទៃ មកទម្លាយវាទៈរបស់សេនកៈនេះបានទេហ្ន៎ ទើបត្រាស់ថា នែបណ្ឌិត តើអ្នកដោះស្រាយដូចម្តេច ។ បានឮថា កាលសេនកៈលើកហេតុការណ៍នេះមក អ្នកដទៃវៀរព្រះពោធិសត្វ ឈ្មោះថា អាចទម្លាយវាទៈនោះ មិនមាន ព្រោះដូច្នោះ មហាសត្វ កាលទម្លាយវាទៈនៃសេនកៈនោះដោយកម្លាំងញាណរបស់ខ្លួន ទើបក្រាបទូលថា បពិត្រមហារាជ សេនកៈនេះជាបុគ្គលល្ងង់ខ្លៅ នឹងដឹងអ្វី សម្លឹងមើលចំពោះយសប៉ុណ្ណោះ មិនដឹងភាពវិសេសនៃបញ្ញា សូមទ្រង់ស្តាប់ចុះ ទូលបង្គំនឹងក្រាបទូល ដូច្នេះហើយពោលគាថានេះថា

បុគ្គលពាលដែលមានយស ទុកដូចជាទាសៈ របស់បុគ្គលអ្នកមានប្រាជ្ញា នាកាលហេតុទាំងឡាយប្រាកដដូច្នោះកើតហើយ អ្នកប្រាជ្ញតាក់តែងនូវប្រស្នា ដ៏ល្អិតណា បុគ្គលពាលរមែងដល់នូវការវង្វេងក្នុងប្រស្នាដ៏ល្អិតនោះ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាល មានយស មិនប្រសើរទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អត្ថេសុ** បានដល់ កាលកិច្ចទាំងឡាយ ។ បទថា **សំវិធេតិ** បានដល់ រមែងចាត់ចែង ។

មហាសត្វសម្ដែងហេតុការណ៍របស់បញ្ញា ដោយប្រការដូច្នេះ ហាក់បីដូចបុគ្គលវិសេស ដកនូវក្អំព្រះសិនេរុ និងដូចបុគ្គលអ្នកមានឫទ្ធិ ញុំាងព្រះចន្ទឲ្យពេញវង់ ឲ្យតាំងឡើងក្នុងលម្ហ ដូច្នោះ កាលព្រះមហាសត្វសម្ដែងអានុភាពនៃបញ្ញានោះឯង ព្រះរាជាត្រាស់នឹងសេនកៈថា លោកអាចារ្យសេនកៈ លោកស្រាយប្រស្នាដូចម្ដេច លោកអាចពោលឲ្យក្រៃលែងជាងនេះឬ សេនកៈនោះញុំាងវិជ្ជាដ៏មុតដែលរៀនមកឲ្យអស់ទៅ ជាអ្នកអស់បដិភាណ ជាអ្នកខ្មាសអៀន អង្គុយសុបសៅ ដូចស្រូវដែលគេដាក់ក្នុងជង្រុក បើសេនកៈនោះគប្បីនាំហេតុការណ៍ដទៃមកសោត មហោសថគប្បីឆ្លើយ ដែលញុំាងជាតកនេះឲ្យចប់ដោយគាថាមួយពាន់ ។ មហាសត្វ កាលពណ៌នាបញ្ញានោះឯងឲ្យក្រៃលែង ដូចអន្ទង់ទឹកជ្រៅ ក្នុងកាលដែលសេនកៈនោះអស់បដិភាណនៅស្ងៀម ទើបពោលគាថានេះថា

តាមពិត ពួកសប្បុរស តែងសរសើរប្រាជ្ញាតែម្យ៉ាង ពួកមនុស្ស

តែងត្រេកអរចំពោះភោគៈ សិរីគ្រាន់តែជាទីត្រេកអររបស់ ( ពួកមនុស្សពាល ) មួយទៀត ញាណនៃអ្នកប្រាជ្ញទាំងឡាយ មិនមានអ្វីប្រៀបផ្ទឹមបានទេ តាំងពីកាលណាមក បុគ្គលអ្នកមានសិរីរមែងមិនកន្លងនូវបុគ្គលមានប្រាជ្ញាបានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សតំ** បានដល់ សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ។ បទថា **ភោគរតា** មានអត្ថដែលបណ្ឌិតគប្បីពណ៌នាតាមភិសជាតកថា បពិត្រកូតាធិបតី ព្រោះមនុស្សអន្ធពាលទាំងនោះ ត្រេកអរក្នុងភោគសម្បត្តិ ដូច្នោះ ទើបពួកជនទាំងនោះ ប្រាថ្នាសិរី ឈ្មោះថា យសនេះ បណ្ឌិតទាំងឡាយតិះដៀល បុគ្គលពាលទាំងឡាយប្រាថ្នា ។ បទថា **ពុទ្ធានំ** បានដល់ ញាណរបស់ពួកអ្នកប្រាជ្ញ ។ បទថា **កទាចិ** សេចក្ដីថា បពិត្រព្រះសម្មតិទេព ធម្មតាបុគ្គលមានសិរី រមែងមិនឈានកន្លងបុគ្គលមានបញ្ញា ក្នុងកាលណាឡើយ ។

ព្រះបាទវិទេហរាជ ទ្រង់បានស្ដាប់ពាក្យនោះ ក៏ទ្រង់សោមនស្សដោយបញ្ហាព្យាករនៃមហាសត្វ ដើម្បីនឹងទ្រង់បូជាដោយទ្រព្យ ហាក់បីដូចបុគ្គលវិសេសញ៉ាំងភ្លៀងធំឲ្យធ្លាក់ ទើបត្រាស់គាថាដូច្នេះថា

ម្នាលមហោសថ ជាអ្នកឃើញធម៌សព្វគ្រប់ យើងបានសួរនូវប្រស្នាណា អ្នកបានថ្លែងដោះស្រាយនូវប្រស្នានោះ ដល់យើង យើងត្រេកអរ ដោយការដោះស្រាយនូវប្រស្នា ( របស់អ្នក ) យើងសូមឲ្យទ្រព្យទាំងនេះ គឺគោមួយពាន់ មានគោឧសភ ( ជា

ដើម ) ផង ដំរីផង រថដែលទឹមដោយសេះអាជានេយ្យ ១០ ផង ស្រុកសួយ ១៦ ផង ដល់អ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧសភញ្ច ឆាគំ** សេចក្ដីថា យើងឲ្យដំរីដែលគួរជិះ មានខ្លួនប្រដាប់តាក់តែងហើយ ធ្វើគោឧសភរាជឲ្យជាធំ នៃគោមួយពាន់ដោយល្អ ។

## សិរិមេណ្ឌកបញ្ហាក្នុងវីសតិនិបាត ចប់

ចាប់តាំងពីពេលនោះ មហោសថពោធិសត្វ ក៏មានយសធំ ព្រះនាងឧទុម្ពរទេវី បានចាត់ចែងរឿងនោះទាំងអស់ ក្នុងកាលមហោសថមានអាយុ ១៦ ឆ្នាំ ព្រះនាងត្រិះរិះថា ប្អូនប្រុសរបស់អញជាមនុស្សធំហើយ សូម្បីយសរបស់គេក៏ធំ អញគួរធ្វើអាវាហមង្គលដល់គេ ព្រះនាងត្រិះរិះដូច្នេះហើយ បានក្រាបទូលសេចក្ដីនោះដល់ព្រះបាទវិទេហរាជ បរមក្សត្របានស្ដាប់សេចក្ដីនោះ ទើបមានព្រះរាជតម្រាស់ថា សាធុ ចូរនាងឲ្យសាមីខ្លួនជ្រាបចុះ ។ ព្រះនាងឲ្យមហោសថជ្រាបសេចក្ដី កាលមហោសថទទួលធ្វើអាវាហមង្គល ទើបមានព្រះសវនីយ៍ថា បើដូច្នេះ យើងនឹងនាំកុមារិកាមកដើម្បីអ្នក ។ គ្រានោះ មហាសត្វគិតថា កុមារិកាដែលព្រះនាងនាំមក ជួនកាល ក៏មិនគាប់ចិត្តអញ អញនឹងពិចារណាមើលឯង គិតដូច្នេះហើយ ទើបទូលថា បពិត្រព្រះរាជទេវី ទ្រង់កុំត្រាស់អ្វីដល់ព្រះរាជា ២-៣ ថ្ងៃ ទូលបង្គំនឹងស្វែងរកកុមារិកាម្នាក់ ដែលទូលបង្គំគាប់ចិត្ត ហើយនឹងទូលឲ្យព្រះនាងជ្រាប ព្រះនាងឧទុម្ពរទ្រង់អនុញ្ញាត ។ មហោសថក៏ថ្វាយបង្គំលាព្រះទេវី ទៅផ្ទះរបស់ខ្លួន

ឲ្យសញ្ញាដល់ពួកសម្លាញ់ហើយ ក្លែងខ្លួនមិនឲ្យអ្នកណាស្គាល់ កាន់យកគ្រឿងឧបករណ៍នៃជាងកាត់ដេរ ចេញអំពីទ្វារទិសឧត្តរតែម្នាក់ឯង ទៅកាន់ស្រុកឧត្តរយវមជ្ឈគាម ។

ក្នុងកាលនោះ មានត្រកូលសេដ្ឋីបុរាណមួយក្នុងស្រុកនោះ ជាត្រកូលដែលអស់ទ្រព្យ កូនស្រីរបស់ត្រកូលនោះ ឈ្មោះនាងអមរាទេវី នាងមានរូបស្អាតបរិបូណ៌ដោយលក្ខណៈសព្វយ៉ាង ជាអ្នកមានបុណ្យ ។ ថ្ងៃនោះ នាងដាំបបរអំពីព្រលឹម នាំបបរនោះទៅ ដោយគិតថា នឹងទៅកាន់ទីដែលបិតាភ្ជួរស្រែ ទើបចេញអំពីផ្ទះ ធ្វើដំណើរជួសផ្លូវជាមួយព្រះមហោសថ ព្រះមហាសត្វឃើញនាងដើរមក គិតក្នុងចិត្តថា ស្រីនេះ សម្បូរដោយលក្ខណៈល្អគ្រប់យ៉ាង បើមិនទាន់មានប្តី ស្រីនេះ ក៏គួរជាកិរិយារបស់អញ ចំណែកនាងអមរាឃើញមហោសថ ក៏គិតក្នុងចិត្តថា បើអញបានបុរសនេះ ជាប្តីសោត អញនឹងញ៉ាំងទ្រព្យសម្បត្តិឲ្យកើតយ៉ាងមាំទាំ លំដាប់នោះ ព្រះមហាសត្វគិតថា អញមិនទាន់ស្គាល់ភាពដែលស្រីនេះមានប្តី ឬមិនទាន់មាន អញនឹងសួរនាងដោយកាសា-គ បើនាងឈ្លាស ក៏នឹងដឹងសេចក្តីនៃប្រស្នារបស់អញ គិតដូច្នេះហើយ ឈរអំពីចម្ងាយក្តាប់ដៃបង្ហាញ នាងអមរាដឹងសេចក្តីថា បុរសនេះសួរអញថា មានប្តីហើយឬនៅ ទើបឈរ ហើយលាដៃបង្ហាញ មហោសថដឹងហេតុនោះហើយ ទើបចូលទៅជិតសួរថា នែនាងនាងឈ្មោះអ្វី នាងឆ្លើយថា នែអ្នក របស់ណាមិនមានក្នុងអតីត មិនមានក្នុងអនាគត មិនមានក្នុងបច្ចុប្បន្ន របស់នោះ ជាឈ្មោះរបស់ខ្ញុំ មហោសថពោល

ថា នែនាងដ៏ចម្រើន ឈ្មោះថា ការមិនស្លាប់មិនមានក្នុងលោក ដូច្នោះ នាងឈ្មោះអមរាឬ នាងអមរាឆ្លើយថា យ៉ាងនោះឯង មហោសថសួរថា នាងនាំបបរជាដើមទៅដើម្បីអ្នកណា កាលនាងអមរាឆ្លើយថា នាំទៅដើម្បីបុព្វទេវតា មហោសថពោលថា មាតាបិតា ឈ្មោះថា បុព្វទេវា ប្រហែលជានាងនាំបបរទៅឲ្យបិតារបស់នាង នាងអមរាឆ្លើយថា ត្រូវហើយ មហោសថសួរថា បិតារបស់នាងធ្វើការអ្វី នាងឆ្លើយថា បិតារបស់ខ្ញុំធ្វើរបស់មួយដោយចំណែកពីរ មហោសថពោលថា នែនាងដ៏ចម្រើន ការភ្ជួរស្រែ ឈ្មោះថា ធ្វើរបស់មួយដោយរបស់ពីរ ប្រហែលជាបិតារបស់នាងភ្ជួរស្រែ នាងអមរាឆ្លើយថា ត្រូវហើយ មហោសថសួរថា បិតារបស់នាងភ្ជួរនៅទីណា នាងអមរាឆ្លើយថា ជនទាំងឡាយទៅក្នុងទីណាម្តងហើយ ខាងក្រោយមិនត្រឡប់មក បិតារបស់ខ្ញុំ ទៅភ្ជួរស្រែក្នុងទីនោះឯង មហោសថពោលថា ព្រៃខ្មោច ឈ្មោះថា ទីដែលជនទាំងឡាយទៅម្តងមិនត្រឡប់មក ប្រហែលឪពុករបស់នាងភ្ជួរស្រែក្បែរព្រៃខ្មោច នាងអមរាឆ្លើយថា ត្រូវហើយ មហោសថសួរបន្តថា នែនាងថ្ងៃនេះ នាងត្រឡប់ទៅ ឬមិនត្រឡប់ នាងអមរាឆ្លើយថា បពិត្រអ្នក បើមកខ្ញុំនឹងមិនត្រឡប់ បើមិនមក ខ្ញុំនឹងត្រឡប់ មហោសថពោលថា នែនាងឪពុករបស់នាងប្រហែលជាភ្ជួរក្បែរស្ទឹង កាលទឹកឡើងមកនាងនឹងមិនត្រឡប់ កាលទឹកមិនមក នាងនឹងត្រឡប់ នាងអមរាឆ្លើយថា ត្រូវហើយ ជនទាំងពីរចរចាគ្នាប៉ុណ្ណេះហើយ ក្រោយមក នាងអមរាអញ្ជើញឲ្យព្រះមហោសថបរិភោគបបរ ព្រះមហាសត្វត្រិះរិះថា ការបដិសេធន៍ជាអពមង្គល ទើបទទួល

ថា នឹងបរិភោគ ទើបនាងដាក់ថ្នាំងបបរចុះ ព្រះមហាសត្វគិតថា បើនាងអមរាមិនលាងកាជនៈ មិនឲ្យទឹកលាងដៃ ឲ្យបបរ អញនឹងលះបង់នាងក្នុងទីនេះទៅ ចំណែកនាងអមរាលាងកាជនៈហើយ នាំទឹកមកដោយកាជនៈ ឲ្យទឹកលាងដៃ មិនដាក់កាជនៈទទេក្នុងដៃ មិនដាក់ថ្នាំងលើផែនដី ហើយដួសបបរដាក់ពេញកាជនៈ តែគ្រាប់បបរក្នុងកាជនៈនោះតិច លំដាប់នោះ ព្រះមហាសត្វពោលថា នែនាង ទឹកបបរច្រើនពេកឬ នាងអមរាឆ្លើយថា បពិត្រអ្នក ខ្ញុំមិនបានថែមទឹក ព្រះមហាសត្វពោលថា នាងប្រហែលជាមិនបានទឹកមកអំពីស្រែ នាងឆ្លើយថា ត្រូវហើយ ហើយនាងបែងបបរទុកឲ្យបិតា សល់អំពីនោះ ឲ្យព្រះពោធិសត្វ ។ ព្រះពោធិសត្វហុតបបរនោះហើយ ខ្ពុរមាត់ពោលថា នែនាង ខ្ញុំនឹងទៅកាន់ផ្ទះរបស់នាង ចូរនាងប្រាប់ផ្លូវដល់ខ្ញុំ នាងអមរាពោលថា សាធុ កាលនឹងប្រាប់ផ្លូវ ក៏ពោលគាថាក្នុងឯកនិបាតនេះថា

( បពិត្រអ្នកម្ចាស់ ) រានផ្សារដែលគេលក់សដូវ និងម្សូរ និងដើមរលួសមានស្លឹក ២ ជាន់ មាននៅក្នុងទិសាភាគណា ខ្ញុំកាន់បបរដោយដៃណា ខ្ញុំម្ចាស់ប្រាប់ផ្លូវដោយដៃនោះ ខ្ញុំមិនបានកាន់បបរដោយដៃណា ខ្ញុំមិនប្រាប់ផ្លូវដោយដៃនោះទេ ទិសាភាគនុ៎ះឯងហើយ ជាផ្លូវនៃយាវមជ្ឈព្រាហ្មណ៍ អ្នកចូរដឹងផ្លូវដ៏កំបាំងនោះចុះ ដូច្នេះ ។

គាថានោះ មានអត្ថថា នែអ្នក ចូរអ្នកទៅខាងក្នុងស្រុកហើយ នឹងឃើញរានលក់សដូវ ១ បន្ទាប់អំពីនោះទៅ អ្នកនឹងឃើញរានលក់ម្សូរ បន្ទាប់

អំពីពានទាំងពីរនោះ មានដើមល្ហុសផ្អុងមានស្លឹកពីរជាន់ មានផ្ការីក ដូច្នោះ ចូរអ្នកទៅតាមផ្លូវដែលមានពានលក់សដូវ ពានលក់ម្ជូរ និងដើមល្ហុសផ្អុង ដែលមានផ្ការីក ឈរក្រោមដើមល្ហុសផ្អុង កាន់យកផ្លូវខាងស្តាំ កុំកាន់យកផ្លូវខាងឆ្វេង ។ បទថា **ឯស មគ្គោ យវមជ្ឈកស្ស** សេចក្តីថា នេះជាផ្លូវទៅផ្ទះរបស់ពួកយើង ដែលតាំងនៅក្នុងស្រុកយវមជ្ឈគាម សូមអ្នកជ្រាបផ្លូវដែលបិទបាំង គឺផ្លូវដែលកំបាំងនេះ ដែលខ្ញុំពោលបិទបាំងយ៉ាងនេះ ឬផ្លូវបិទ ឬហេតុដែលបិទបាំង ។ បទថា **យេនានាធិ** ក្នុងគាថានេះ នាងពោលសំដៅយកដៃស្តាំ ដែលខ្ញុំប្រើកាន់ភាជនៈបបរ ក្រៅអំពីនេះ ជាដៃឆ្វេង នាងអមរាប្រាប់ផ្លូវដល់មហោសថយ៉ាងនេះហើយ កាន់បបរទៅឲ្យឪពុក ។

ឆន្នបថប្បញ្ហា ចប់

មហោសថពោធិសត្វទៅកាន់ផ្ទះនោះ តាមដែលនាងអមរាប្រាប់ លំដាប់នោះ ម្តាយរបស់នាងអមរាឃើញមហោសថហើយ ក៏ឲ្យព្រះមហាសត្វអង្គុយលើអាសនៈពោលថា សូមអ្នកពិសាបបរ មហោសថឆ្លើយថា បពិត្រអ្នកម៉ែ នាងអមរាទេវី បានឲ្យបបរដល់ខ្ញុំបន្តិចហើយ មាតារបស់នាងអមរាក៏ដឹងថា បុរសនេះ គង់មកដើម្បីកូនស្រីរបស់អញ ។ ព្រះពោធិសត្វ សូម្បីដឹងថា ត្រកូលនោះជាត្រកូលក្រីក្រ ក៏សួរថា បពិត្រអ្នកម៉ែ ខ្ញុំជាងកាត់ដេរ អ្នកម៉ែមានសំពត់ដែលខ្ញុំគួរដេរដែរឬទេ មាតានាងអមរាឆ្លើយថា នែអ្នក សំពត់មាន តែថ្លៃឈ្នួលមិនមានទេ មហោសថពោលថា បពិត្រអ្នកម៉ែ ខ្ញុំមិនយកថ្លៃឈ្នួលឡើយ សូមម៉ែនាំមកចុះខ្ញុំនឹងដេរឲ្យ មាតារបស់នាងអមរា ក៏នាំ

សំពត់ចាស់ៗ មកឲ្យមហោសថប៉ះ ។ ព្រះពោធិសត្វ ក៏ឲ្យសំពត់ដែលនាំមកហើយសម្រេចទាំងអស់ ព្រោះការធ្វើរបស់លោកអ្នកមានបុណ្យ រមែងសម្រេចងាយ លំដាប់នោះ មហោសថប្រាប់ដល់ម្ដាយរបស់នាងអមរាថា សូមម៉ែពោលតាមមាត់ផ្លូវឲ្យនាំសំពត់មកដេរ មាតារបស់នាងអមរាទៅប្រាប់ដល់អ្នកស្រុកទូទៅ ព្រះមហាសត្វធ្វើការដេរប៉ាក់មួយថ្ងៃប៉ុណ្ណោះ ក៏បានទ្រព្យមួយពាន់ ។ ចំណែកមាតារបស់នាងអមរា ចម្អិនបាយឲ្យមហោសថបរិភោគក្នុងពេលនោះហើយ សួរថា ពេលល្ងាចខ្ញុំនឹងចម្អិនប៉ុនណា មហោសថឆ្លើយថា ជនមានប្រមាណប៉ុនណាបរិភោគក្នុងផ្ទះនេះ សូមអ្នកម៉ែចម្អិនដោយប្រមាណនៃជនប៉ុណ្ណោះ នាងក៏ចម្អិនកត្តាហារជាច្រើន មួយអន្លើដោយសម្ល ទាំងម្ហូបក៏មិនតិច ចំណែកនាងអមរាទេវី ពេលល្ងាច យកបាច់ឧសទូលលើក្បាល កណ្ដៀតបន្លែមកអំពីព្រៃ ដាក់ឧសត្រង់ទ្វារទិសខាងកើត ហើយចូលទៅកាន់ផ្ទះតាមទ្វារទិសខាងលិច ចំណែកឪពុករបស់នាងអមរា ត្រឡប់មកផ្ទះល្ងាចជាងពីតា ។ មហោសថបរិភោគភោជនាហារ មានរសដ៏ប្រសើរ នាងអមរាឲ្យឪពុកម្ដាយបរិភោគហើយ ខ្លួនឯងបរិភោគជាក្រោយ ហើយលាងជើងមាតាបិតា និងជើងមហោសថពោធិសត្វ មហោសថសង្កេតពិនិត្យនាងអមរាក្នុងផ្ទះនោះ ២-៣ ថ្ងៃ ។ សម័យថ្ងៃមួយ កាលនឹងសាកល្បងនាងអមរា ទើបពោលថា នែអមរាទេវីដ៏ចម្រើន ចូរនាងយកអង្ករកន្ទះនាឡិដាំបបរ ធ្វើនំ និងដាំបាយដើម្បីខ្ញុំដោយអង្ករកន្ទះនាឡិនោះ នាងអមរាទទួលពាក្យ ហើយបុកអង្ករនោះ ហើយយកអង្ករដែលបាក់ ២-៣ កំណាត់បបរ

យកអង្ករដែលមិនបាក់ដាំបាយ យកចុងអង្ករកិនជាម្សៅធ្វើនំ ហើយធ្វើម្ហូប ឲ្យគួរដល់បាយ និងបបរនោះ ឲ្យបបរដល់មហោសថមុន មហោសថបាន ហុតបបរ គ្រាន់តែដល់មាត់ បបរនោះក៏ជ្រួតជ្រាបទៅកាន់សរសៃប្រសាទ ទាំង ៧ ពាន់ ដែលជាសរសៃសម្រាប់ទទួលរស មហោសថពោលដើម្បី សាកល្បងនាងអមរាថា នាងមិនចេះបបរ ធ្វើអង្ករយើងឲ្យវិនាសដើម្បី ប្រយោជន៍អ្វី ហើយព្រួសបបរ មួយអន្ទើដោយទឹកមាត់ទៅលើផែនដី នាង អមរាមិនក្រោធពោលថា បពិត្រអ្នក បើបបរមិនឆ្ងាញ់ សូមអ្នកពិសានំ ហើយឲ្យនំដល់មហោសថៗ ក៏ធ្វើអាការយ៉ាងនោះ ហើយពោលយ៉ាងនោះ ទៀត នាងអមរាក៏ពោលថា បើនំមិនឆ្ងាញ់ សូមអ្នកពិសាបាយ ហើយឲ្យ បាយដល់មហោសថៗ ក៏ធ្វើអាការយ៉ាងនោះឯង ហើយពោលដូច្នោះទៀត ធ្វើជាអាក់អន់ ប្របាច់បាយទាំងបីយ៉ាងនោះចូលគ្នាតែមួយ ហើយលាបសរីរៈ ទាំងមូល តាំងអំពីក្បាលនាង រហូតដល់ជើង ហើយដេញនាងឲ្យទៅឈរ ត្រង់ទ្វារ ចំណែកនាងអមរា មិនក្រោធឡើយ ប្រណម្យដៃពោលថា សាធុ ហើយបានធ្វើតាមនោះ មហោសថដឹងថា នាងមិនប្រកាន់ខ្លួន ទើបហៅនាងមក គ្រាន់តែបានឮពាក្យហៅប៉ុណ្ណោះ នាងក៏មកអង្គុយក្បែរមហោសថ ចំណែក មហាសត្វកាលមកអំពីផ្ទះ មិនបានមកដៃទទេ បានយកសំពត់សាដកមួយ ផ្ទាំង និងកហាបណៈមួយពាន់ដាក់ក្នុងថៃតូចមកផង ទើបយកសំពត់សាដក នោះ ចេញអំពីថៃតូច ឲ្យដល់នាងអមរា ហើយពោលថា នែនាងដ៏ចម្រើន ចូរនាងងូតទឹកជាមួយសម្លាញ់ទាំងឡាយរបស់នាង ហើយស្លៀកសំពត់សាដក

នេះមក នាងអមរាបានធ្វើតាមពាក្យប្រាប់ មហោសថឲ្យទ្រព្យដែលកើតឡើង និងទ្រព្យដែលនាំមកទាំងអស់ ដល់មាតាបិតារបស់នាង ញុំាងជនទាំងបីឲ្យត្រេកអរហើយ លាឪពុកក្មេក ម្តាយក្មេក នាំនាងអមរាត្រឡប់មកផ្ទះ ។ ព្រះមហាសត្វឲ្យឆត្រ និងស្បែកជើងដល់នាងអមរាហើយ ពោលយ៉ាងនេះថា នែនាង ចូរនាងយកឆត្របាំង ពាក់ស្បែកជើងដើរទៅ នាងអមរាទទួលរបស់ពីរយ៉ាង បិទឆត្រក្នុងពេលក្តៅ ដោយព្រះអាទិត្យក្នុងទីវាល ដើរទៅ ដោះស្បែកជើង ក្នុងទីទួល កាន់ដើរទៅ ពាក់ស្បែកជើងក្នុងពេលដល់ទីដែលមានទឹក ហើយដើរទៅ មហោសថឃើញហេតុនោះ ទើបសួរថា ហេតុអ្វីទើបនាងមិនពាក់ស្បែកជើងក្នុងទីទួល ពាក់ក្នុងទីដែលមានទឹកដើរទៅ នាងឆ្លើយនឹងមហោសថថា បពិត្រអ្នក ខ្ញុំឃើញរបស់ប្រទូស្តដល់រាងកាយ មានបន្លាជាដើមក្នុងទីទួល ខ្ញុំមិនឃើញរបស់ប្រទូស្តរាងកាយ មានត្រី អណ្តើក និងបន្លាជាដើមក្នុងទីដែលមានទឹក កាលគ្រឿងប្រទូស្តចូលទៅកាន់ជើង ខ្ញុំគប្បីសោយទុក្ខវេទនាធំ ព្រោះដូច្នោះ ទើបខ្ញុំពាក់ស្បែកជើងក្នុងទីដែលមានទឹកដើរទៅ ព្រះពោធិសត្វស្តាប់ពាក្យរបស់នាងគិតថា ទារិកានេះឈ្លាសវៃហ្ន៎ ហើយដើរទៅ លំដាប់នោះ នាងអមរាកាលចូលក្នុងព្រៃ ក៏បាំងឆត្រដើរទៅ មហោសថសួរហេតុនោះថា នែនាងដ៏ចម្រើន មនុស្សដទៃបាំងឆត្រក្នុងទីដែលមានកម្តៅថ្ងៃដើរទៅ តែនាងមិនធ្វើយ៉ាងនោះឡើយ ព្រោះហេតុអ្វី នាងឆ្លើយនឹងមហោសថថា បពិត្រអ្នក ខ្ញុំ ឈ្មោះថា ចូលទៅក្នុងព្រៃក៏ពិត តែធ្វើយ៉ាងនេះ ព្រោះខ្លាចមែកឈើ ឬកំណាត់ឈើស្ងួតធ្លាក់ចំក្បាល ព្រះពោធិសត្វបានស្តាប់ពាក្យនាងពោលដោយហេតុពីរយ៉ាងនេះ ក៏ត្រេកអរ លំដាប់នោះ

កាលព្រះពោធិសត្វដើរទៅជាមួយនាង ឃើញដើមពុទ្រា ដល់ព្រមដោយផ្លែ មួយកន្ទែង ក៏ឈប់ អង្គុយក្រោមដើមពុទ្រា ចំណែកនាងអមរា ឃើញមហាសត្វអង្គុយក្រោមដើមពុទ្រា ក៏ពោលថា បពិត្រអ្នក ចូរអ្នកឡើងបេះពុទ្រាបរិភោគ ហើយឲ្យខ្ញុំខ្លះ មហោសថឆ្លើយថា នែនាង ខ្ញុំហត់នឿយ មិនអាចឡើងបានឡើយ ចូរនាងឡើងចុះ នាងស្តាប់ពាក្យរបស់មហោសថ ក៏ឡើងដើមពុទ្រានោះ បេះផ្លែល្អៗ ចំណែកព្រះពោធិសត្វពោលនឹងនាងថា នែនាងដ៏ចម្រើន ចូរនាងឲ្យផ្លែដល់យើងខ្លះ នាងគិតថា អញនឹងមើលបុរសនេះឈ្លាស ឬល្ងង់ហ្ន៎ នឹងសាកល្បងមើល ទើបពោលយ៉ាងនេះថា បពិត្រអ្នក អ្នកចង់បរិភោគក្តៅ ឬចង់បរិភោគត្រជាក់ ព្រះពោធិសត្វសូម្បីដឹងហេតុដែលនាងសួរ ក៏ធ្វើដូចជាមិនដឹង ទើបពោលយ៉ាងនេះ ដើម្បីសាកល្បងដោយពាក្យថា នែនាងដ៏ចម្រើន ខ្ញុំត្រូវការផ្លែក្តៅ នាងក៏បេះផ្លែបោះទៅលើផែនដី ពោលថា សូមអ្នកបរិភោគចុះ ព្រះពោធិសត្វ ក៏រើសផ្លែមកបោសផ្លុំឲ្យអស់ធូលី ហើយបរិភោគ កាលសាកល្បងនាងទៀត ទើបពោលយ៉ាងនេះថា នែនាងដ៏ចម្រើន ចូរនាងឲ្យផ្លែត្រជាក់ដល់ខ្ញុំ នាងក៏បេះផ្លែពុទ្រាបោះទៅលើស្មៅ ព្រះពោធិសត្វរើសផ្លែនោះ មិនចាំបាច់បោស មិនបាច់ផ្លុំ ទំពាបរិភោគតែម្តង ដឹងថា ទារិកានេះឈ្លាសវៃ ក៏ត្រេកអរ ហើយប្រាប់ឲ្យនាងចុះអំពីដើមពុទ្រា នាងអមរាស្តាប់ពាក្យរបស់មហោសថហៅឲ្យចុះ ក៏ចុះអំពីដើមពុទ្រា កាន់ក្អមទៅកាន់ស្ទឹងដងទឹក មកឲ្យមហោសថៗ ក៏ផឹកទឹក ហើយខ្ពុរមាត់ នាងឈរក្នុងចំណែកម្ខាង ជនទាំងពីរក្រោកឡើង ដើរទៅកាន់ព្រះ

នគរ ព្រះមហាសត្វ ឲ្យនាងនៅត្រង់ផ្ទះអ្នកយាមទ្វារ ហើយប្រាប់ដល់កិរិយារបស់អ្នកយាមទ្វារឲ្យជ្រាប ដើម្បីពិសោធនាង ហើយចូលទៅកាន់គេហដ្ឋានរបស់ខ្លួន ហៅបុរសទាំងឡាយមកប្រាប់ថា យើងឲ្យស្ត្រីម្នាក់នៅត្រង់ផ្ទះនោះដែលទើបមកស្រុកនេះ អ្នកទាំងឡាយ ចូរយកទ្រព្យមួយពាន់កហាបណៈនេះទៅត្រង់ផ្ទះនោះ ពោលលែបខាយនាងសាកល្បងមើល ដូច្នេះហើយ ឲ្យកហាបណៈមួយពាន់ បញ្ជូនទៅ ។ បុរសទាំងនោះ ទៅកាន់សម្នាក់នាងអមរា ហើយបានធ្វើតាមមហោសថប្រាប់ នាងមិនប្រាថ្នា គិតថា ការប្រព្រឹត្តរបស់បុរសទាំងនេះ មិនស្មើនឹងល្អងធូលីដែលជាប់ត្រង់ជើងប្តីរបស់អញបុរសទាំងនោះក៏ត្រឡប់មកប្រាប់ដល់មហោសថ លំដាប់នោះ មហោសថបញ្ជូនបុរសទាំងនោះទៅរឿយៗ អស់វារៈ ៣ ដង ក្នុងវារៈទី ៤ ក៏ពោលថាបើដូច្នោះ អ្នកទាំងឡាយ ចូរចាប់ខ្លួននាងអូសមក បុរសទាំងនោះក៏ទៅធ្វើដូច្នោះ នាងក៏មកឃើញព្រះមហាសត្វតាំងនៅក្នុងភាពជាអ្នកមានទ្រព្យសម្បត្តិច្រើន ក៏ស្គាល់មិនបាន សម្លឹងមើលព្រះមហោសថ សើចហើយយំ មហោសថសួរដល់ហេតុទាំងពីរនោះ នាងក៏ប្រាប់ដល់មហោសថថា បពិត្រអ្នក ខ្ញុំឃើញសម្បត្តិរបស់អ្នក ក៏នឹកក្នុងចិត្តថា សម្បត្តិនេះ អ្នកមិនមែនបានមកដោយឥតហេតុ តែអ្នកនឹងធ្វើកុសលទុកក្នុងជាតិមុន ទើបបានសម្បត្តិនេះ ឱ ! ផលបុណ្យទាំងឡាយ គួរអស្ចារ្យហ្ន៎ នឹកក្នុងចិត្តដូច្នេះហើយ ក៏សើច តែកាលខ្ញុំយំ ព្រោះអាណិតលោក ព្រោះថា ឥឡូវនេះ លោកធ្វើអាក្រក់ ក្នុងវត្ថុដែលអ្នកដទៃគ្រប់គ្រង ក៏នឹងទៅកាន់នរក ។ មហោសថពិសោធនាងអមរា

ដឹងភាពដែលនាងជាស្រីបរិសុទ្ធ ទើបពោលថា អ្នកទាំងឡាយចូរទៅ ចូរនាំនាងទៅវិញ ហើយក្លែងគេទធ្វើជាងកាត់ដេរ ចូលទៅស្នាក់នៅជាមួយនាងស្អែកឡើង ក៏ចូលទៅកាន់រាជសម្នាក់ ទូលហេតុការណ៍នោះដល់ព្រះនាងឧទុម្ពរ ព្រះនាងក្រាបទូលសេចក្តីនោះដល់ព្រះបាទវិទេហរាជ ហើយតាក់តែងកាយនាងអមរាទេវីដោយគ្រឿងអលង្ការទាំងពួង ឲ្យនាងអង្គុយក្នុងរថធំ នាំមកកាន់គេហដ្ឋានរបស់មហោសថ ធ្វើនូវអាវាហមង្គល ដោយកិត្តិយសដ៏ធំក្រៃលែង ។ ព្រះរាជាទ្រង់បញ្ជូនទ្រព្យមួយពាន់កហាបណៈ ជាបណ្ណាការដល់ព្រះពោធិសត្វ អ្នកនគរទាំងមូល តាំងអំពីអ្នករក្សាទ្វារ ក៏បានរៀបចំរបស់ចងដៃមកឲ្យ ចំណែកនាងអមរាទេវី ក៏ចែករបស់ដែលព្រះរាជាប្រទានជាពីរចំណែក ដាក់ក្នុងឃ្លាំងព្រះរាជាមួយចំណែក ទទួលមួយចំណែក បានបញ្ជូនរបស់ចងដៃនៃអ្នកនគរទាំងមូល ទៅសង្គ្រោះអ្នកនគរដោយវិធីនេះ បន្ទាប់អំពីនោះ ព្រះមហាសត្វក៏បាននៅរួមជាមួយនាងអមរា បានថ្វាយអនុសាសន៍អត្ថ និងធម៌ដល់ព្រះរាជា ។

## អមរាទេវីបរិយេសនា ចប់

ថ្ងៃមួយ សេនកៈ ឃើញបុក្កុសៈ កាមិន្ទៈ និងទេវិន្ទៈទាំងបីមកកាន់សម្នាក់របស់ខ្លួន ទើបប្រឹក្សានឹងអាចារ្យទាំងនោះថា នែលោកដ៏ចម្រើនទាំងបី យើងទាំង ៤ នាក់ មិនស្មើនឹងមហោសថដែលជាកូនគហបតី ឥឡូវនេះ គេនាំប្រពន្ធឈ្លាសវៃមកឯង ពួកយើងគប្បីបំបែកគេនឹងព្រះរាជាដូចម្តេចល្អ អាចារ្យទាំងបីឆ្លើយតបនឹងអាចារ្យសេនកៈថា ខ្ញុំទាំងបីដឹងអ្វី សូមលោកគិត

មើលចុះ អាចារ្យសេនកៈពោលថា ពួកលោកកុំវិតក្កឡើយ ខ្ញុំមានឧបាយមួយ អាចារ្យទាំងបីសួរថា ឧបាយដូចម្តេច អាចារ្យសេនកៈក៏ប្រាប់ថា យើងនឹងលួចស្មៀតសក់របស់ព្រះរាជាមក ចំណែកបុក្កុសៈ ចូរលួចសុវណ្ណមាលា ចំណែកកាមិន្ទៈចូរលួចសំពត់កម្ពលមក ចំណែកទេវិន្ទៈចូរលួចបាទុកាមាស កាលលួចរាជាភរណៈទាំង ៤ យ៉ាងបានមកដូច្នេះហើយ យើងទាំង ៤ នឹងញុំាងរាជាភរណៈទាំងនោះឲ្យចូលទៅក្នុងផ្ទះរបស់មហោសថ យើងទាំង ៤ លួចរាជាភរណៈទាំង ៤ បានមកដោយឧបាយហើយ បន្ទាប់អំពីនោះ នឹងឲ្យគេចូលទៅក្នុងផ្ទះរបស់មហោសថ ធ្វើកុំឲ្យមហាជនសង្ស័យក្នុងពួកយើង អាចារ្យទាំងបីនោះទទួលថា ឧបាយនេះល្អពន់ពេក ៗ អាចារ្យសេនកៈក៏នាំចូឡាមណីដាក់ក្នុងផ្ទាំងតក្កៈ ហើយឲ្យទាសីម្នាក់នាំផ្ទាំងតក្កៈនោះទៅប្រាប់ថា ចូរនាំផ្ទាំងទឹកដោះនេះទៅលក់ កុំលក់ឲ្យដល់អ្នកដទៃ បើជនក្នុងផ្ទះរបស់មហោសថទិញ ចូរឲ្យទទេ មួយអន្ទើដោយផ្ទាំង ទាសីក៏ទៅកាន់ទ្វារផ្ទះរបស់មហោសថ ស្រែកពពាយនាយថា អ្នកទាំងឡាយ ចូរទិញទឹកដោះជូរ ដើរត្រឡប់ទៅត្រឡប់មក ត្រង់ទ្វារផ្ទះនោះ នាងអមរាទេវីឈរនៅត្រង់ទ្វារ ឃើញកិរិយារបស់ទាសីនោះ គិតថា ស្រីនេះមិនទៅកាន់ទីដទៃ ហេតុការណ៍គប្បីមានក្នុងស្រីនេះ ទើបញុំាងទាសីទាំងឡាយឲ្យចៀសចេញទៅដោយសញ្ញាដែលណាត់ទុក ហើយហៅទាសីអ្នកលក់តក្កៈនោះមកថា មកនេះនាង ខ្ញុំនឹងទិញតក្កៈ ហើយឲ្យសញ្ញាដល់ពួកទាសីរបស់ខ្លួន ក្នុងកាលដែលអ្នកលក់តក្កៈមក កាលពួកទាសីរបស់ខ្លួនមិនទាន់មក ទើបឲ្យអ្នកលក់តក្កៈនោះទៅ

ហៅមក នាងក៏លូកដៃចូលក្នុងផ្ទាំង ប៉ះចូឡាមណីនោះ ក្នុងកាលដែលអ្នកលក់តក្កៈនោះទៅ លុះអ្នកលក់ត្រឡប់មក ក៏សួរថា នាងមកអំពីសម្នាក់របស់អ្នកណា អ្នកលក់ទឹកដូរនោះតបថា បពិត្រអ្នកនាង ខ្ញុំជាទាសីរបស់អាចារ្យសេនកៈ បន្ទាប់អំពីនោះ នាងអមរាក៏សាកសួរឈ្មោះរបស់នាង និងឈ្មោះមាតាបិតារបស់នាង នាងបានតបថា ឈ្មោះនោះ ឈ្មោះនោះ ហើយសួរថា ទឹកដោះនេះ នាងលក់តម្លៃប៉ុន្មាន ក៏បានឆ្លើយថា ស្មើគ្នានឹងតម្លៃអង្ករ ៤ នាឡិ ទើបពោលថា បើដូច្នោះ ចូរនាងលក់ដល់ខ្ញុំ នាងក៏បានឆ្លើយថា បើអ្នកនាងទិញ ខ្ញុំនឹងត្រូវការអ្វីដោយតម្លៃ សូមទទួលយកទាំងផ្ទាំងចុះ ខ្ញុំមិនគិតតម្លៃឡើយ នាងអមរាពោលថា បើដូច្នោះ ជាការល្អ ហើយឲ្យអ្នកលក់តក្កៈនោះ ត្រឡប់ទៅវិញ ហើយនាងបានសរសេរលាយលក្ខណ៍អក្សរ មានសេចក្តីថា ខែនេះ ថ្ងៃនេះ អាចារ្យសេនកៈឲ្យទាសីឈ្មោះនេះ ដែលជាកូនស្រីរបស់ទាសីឈ្មោះនេះ នាំព្រះចូឡាមណីរបស់ព្រះរាជាមកលក់ឲ្យ ចំណែកបុក្កុសៈ ដាក់សុវណ្ណមាលាក្នុងប្រអប់ផ្កាម្លិះ ហើយបិទសុវណ្ណមាលានោះដោយផ្កាម្លិះបញ្ជូនទៅ ចំណែកកាមិន្ទៈ បិទបាំងសំពត់កម្ពលក្នុងកញ្ច្រែងដាក់បន្លែ ដើម្បីបិទបាំងបញ្ជូនទៅ ចំណែកទេវិន្ទៈ ដាក់បាទុកាមាសក្នុងកណ្តាប់ស្រូវដំណើប ហើយបញ្ជូនទៅ នាងអមរាទទួលវត្ថុទាំងពួងនោះ ចារឹកអក្សរដោយន័យខាងដើម ប្រាប់ដល់ព្រះមហាសត្វ ហើយបានរក្សាទុក ។ ឯបណ្ឌិតទាំង ៤ នោះ ទៅកាន់រាជសម្នាក់ទូលថា ទ្រង់មិនប្រដាប់ព្រះចូឡាមណីទេឬ ព្រះបាទវិទេហរាជត្រាស់ថា អើ យើងនឹងប្រដាប់ ចូរទៅយកមក អាចារ្យទាំង ៤ នោះទៅមើល ក៏មិនឃើញព្រះចូឡាមណី ក្នុងទីដែលទុក

និងមិនឃើញរាជាករណៈទាំង ៣ យ៉ាងក្រៅអំពីនេះ ទើបទូលព្រះញញ់ថា បពិត្រព្រះសម្មតិទេព រាជាករណៈរបស់ព្រះអង្គ ពិតជានៅក្នុងផ្ទះរបស់មហោសថៗ ប្រើរាជករណៈដោយខ្លួនឯង នឹងជាសត្រូវរបស់ព្រះអង្គ ។

លំដាប់នោះ ចារបុរសរបស់ព្រះមហោសថ បាននាំសេចក្ដីនោះមកប្រាប់ដល់មហាសត្វ មហោសថបានស្ដាប់ពាក្យរបស់ចារបុរស ក៏គិតថា អញនឹងគាល់ព្រះរាជា ទើបដឹងរឿង ទើបទៅគាល់ព្រះរាជា ព្រះរាជាពិរោធនឹងមហោសថ មិនឲ្យមហោសថចូលគាល់ ដោយទ្រង់ព្រះតម្រិះថា អ្នកណានឹងដឹងថា មានអ្វីកើតឡើង មហោសថដឹងថា ព្រះរាជាទ្រង់ព្រះពិរោធ ទើបត្រឡប់មកផ្ទះរបស់ខ្លួន ។ ព្រះរាជាត្រាស់ឲ្យចាប់មហោសថ ។ ចំណែកមហោសថបណ្ឌិត បានស្ដាប់ពាក្យរបស់ចារបុរសរបស់ខ្លួន ទើបគិតថា អញគួរគេចទៅ ទើបឲ្យសញ្ញាដល់នាងអមរា ហើយក្លែងខ្លួនចេញអំពីនគរ ទៅកាន់ទក្ខិណយវមជ្ឈគាម ធ្វើជាស្មូនឆ្នាំង ចិញ្ចឹមជីវិតក្នុងស្រុកនោះ ។ កោលាហលក៏កើតក្នុងព្រះនគរថា មហោសថបណ្ឌិតគេចទៅហើយ អាចារ្យទាំង ៤ មានសេនកៈជាដើម ដឹងថា មហោសថគេចទៅហើយ ក៏ពោលថា អ្នកទាំងឡាយ កុំវិតក្កឡើយ យើងទាំងឡាយមិនមែនជាបណ្ឌិតឬ ពោលដូច្នេះហើយ មិនញុំាងគ្នានិងគ្នាឲ្យដឹង បញ្ជូនបណ្ណាការឲ្យដល់នាងអមរា នាងអមរាទទួលបណ្ណាការដែលអាចារ្យទាំង ៤ បញ្ជូនទៅ ហើយពោលថា ចូរមកក្នុងវេលាឈ្មោះនោះ ហើយគិតថា អញនឹងឲ្យជនទាំង ៤ នាក់មករកអញ បាននូវសេចក្ដីខ្មាស ទើបហៅពួកទាសីមក ឲ្យជីករណ្ដៅមួយ ព័ទ្ធ

របងត្រង់រណ្ដៅនោះ ចាក់លាមក និងទឹកក្នុងរណ្ដៅនោះ ហើយឲ្យបិទបន្ទះក្ដារយន្តត្រង់ផ្ទៃខាងលើនៃរណ្ដៅលាមកនោះ បិទបាំងដោយកន្ទេលផែនជុំវិញប្រកបដោយគន្ធិះទាំងសងខាង រៀបចំគេហដ្ឋានឲ្យចងនូវបុប្ផជាតិជាដើម ឲ្យដូចជាទីគួរត្រេកអរ ហើយឲ្យតម្កល់ទឹក ញុំាងនូវវត្ថុទាំងពួងឲ្យសម្រេចហើយ ។ ពេលព្រលប់ថ្ងៃនោះ អាចារ្យសេនកៈតែងខ្លួន បរិភោគអាហារមានរសដ៏ប្រសើរផ្សេងៗ ហើយទៅកាន់ផ្ទះរបស់មហោសថ ឈរទៀបទ្វារឲ្យប្រាប់ដល់ការដែលខ្លួនមក ញុំាងអ្នករក្សាទ្វារឲ្យប្រាប់ដល់នាងអមរាៗ បានស្ដាប់ពាក្យសេនកៈនោះ ក៏ពោលថា មកចុះ សេនកៈក៏ទៅឈរក្បែរនាងអមរាៗ ក៏ពោលនឹងសេនកៈថា ខ្ញុំធ្លាក់ក្នុងអំណាចរបស់លោកក្នុងកាលឥឡូវនេះហើយ ការមិនផ្ទុតទឹក ហើយដេក មិនគួរ សូមលោកទៅផ្ទុតទឹកក្រអូបនេះសិន សឹមមក ។ សេនកៈទទួលពាក្យហើយ ទៅជាន់បន្ទះក្ដារគិតនឹងផ្ទុត នាងអមរាធ្វើដូចជាស្រោចទឹកឲ្យ ក្នុងកាលដែលសេនកៈឡើងឈរលើបន្ទះក្ដារ នាងក៏ជាន់ត្រង់គន្ធិះយន្ត ញុំាងសេនកៈឲ្យធ្លាក់ក្នុងរណ្ដៅលាមក ។ នាងញុំាងបុក្កុសៈដែលតែងខ្លួន បរិភោគភោជនដ៏ប្រសើរ ហើយមកក្នុងពេលល្ងាច ឲ្យធ្លាក់ក្នុងរណ្ដៅលាមកនោះ ។ បុក្កុសៈ កាលជាន់សេនកៈ ក៏សួរថា លោកជាមនុស្សឬ ក៏បានទទួលពាក្យឆ្លើយថា ខ្ញុំជាអាចារ្យសេនកៈ ចំណែកសេនកៈ ក៏សួរបុក្កុសៈថា អ្នកជាមនុស្សឬ ក៏បានទទួលពាក្យតបថា ខ្ញុំជាអាចារ្យបុក្កុសៈ ។ នាងអមរាញុំាងកាមិន្ទៈ និងទេវិន្ទៈ ទាំងពីរដែលមកតាមគ្នា ឲ្យធ្លាក់ក្នុងរណ្ដៅលាមកដោយទំនងនោះដូចគ្នា អាចារ្យ

ទាំង ៤ នាក់នោះ ឈរក្នុងរណ្ដៅលាមកត្រឹមពោះ ក្បាលជល់គ្នានិងគ្នា ក៏សួរគ្នាថា ឯងជានរណា លំដាប់នោះ អាចារ្យសេនកៈប្រាប់ថា ខ្ញុំ ៗ កាលអាចារ្យទាំង ៣ សួរថា យើងនឹងធ្វើដូចម្ដេច អាចារ្យសេនកៈក៏ឃាត់ថា អ្នកទាំងឡាយកុំឡូឡាពេក តាំងអំពីនេះទៅ ការខ្មាសនឹងមានដល់ពួកយើង ៗ បណ្ឌិតទាំង ៤ ធ្លាក់ទៅក្នុងរណ្ដៅលាមកអស់មួយយប់ នាងអមរាញុំាងអាចារ្យទាំង ៤ នាក់ ឲ្យធ្លាក់ក្នុងរណ្ដៅលាមកដ៏ស្មោកគ្រោក គួរខ្ពើមយ៉ាងនេះ កាលអរុណរះឡើង ឲ្យជនទាំង ៤ នាក់នោះតោងខ្សែឡើងមកអំពីរណ្ដៅលាមក ឲ្យងូតទឹក ឲ្យយកកាំបិតកោរសក់ និងពុកមាត់ អាចារ្យទាំង ៤ នោះ ឲ្យត្រងោល ហើយជុសដោយឥដ្ឋរហូតឈាមហូរវិញៗ ហើយឲ្យយកអង្ករមួយនាឡិទៅត្រាំទឹកបុកឲ្យល្អិន ដាក់ក្នុងភាជនៈ កូរឲ្យស្អិតដូចបាយម៉ាន ឲ្យលាបពេញខ្លួនអាចារ្យទាំង ៤ តាំងអំពីក្បាលរហូតដល់ចុងជើង ហើយឲ្យយកប៉ុយគរោយពេញខ្លួន តាំងអំពីក្បាលដល់ចុងជើង ឲ្យជនទាំង ៤ លំបាកពន់ពេក ឲ្យដេកក្នុងរមូរកន្ទេលផែនបិទយ៉ាងជិត រុំដោយខ្សែប្រថាប់ត្រា ហើយឲ្យនាំរតនៈ ៤ យ៉ាង មួយអន្លើដោយអាចារ្យទាំង ៤ ទៅគាល់ព្រះបាទវិទេហរាជ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ទទួលបណ្ណាការទាំងឡាយ ក្រាបទូលដូច្នេះហើយ ឲ្យដាក់រមូរកន្ទេលផែនទាំង ៤ ទៀបបាទមូលនៃព្រះរាជា លំដាប់នោះ ព្រះរាជាឲ្យបើកកន្ទេលផែននោះចេញ ទតឃើញបណ្ឌិតទាំង ៤ មានសេនកៈជាដើម ដូចគ្នានឹងស្វាស ទ្រង់ក៏តុណ្ហីភាព

ចំណែកមហាជនឃើញអាចារ្យទាំង ៤ នោះ ក៏ពោលថា ឱស្វាសនេះស្អាត ណាស់តើហ្ន៎ យើងទាំងឡាយមិនធ្លាប់ឃើញ ឥឡូវបានឃើញហើយ ក៏នាំគ្នា សើចអឹងកង អាចារ្យទាំង ៤ បាននូវការខ្មាស ។ លំដាប់នោះ នាងអមរា ថ្វាយរតនៈ ៤ យ៉ាង មួយអន្លើដោយអាចារ្យទាំង ៤ ដល់ព្រះរាជា កាល ប្រកាសភាពដែលមហោសថស្វាមីរបស់ខ្លួនមិនមានកំហុស ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព មហោសថបណ្ឌិតមិនមែនជាចោរ តែអាចារ្យទាំង ៤ របស់ទ្រង់ជាចោរ គឺសេនកៈលួចចូឡាមណី បុក្កុសៈលួចសុវណ្ណមាលា កាមិន្ទៈលួចសំពត់កម្ពលកម្រាលទីបន្ទំ ទេវិន្ទៈលួចបាទុកាមាស រតនៈទាំង ៤ យ៉ាងនេះ អាចារ្យទាំង ៤ ឲ្យទាសីឈ្មោះនេះ ដែលជាកូនរបស់ទាសីឈ្មោះ នេះ បញ្ជូនទៅលក់ឲ្យខ្ញុំម្ចាស់ក្នុងថ្ងៃឈ្មោះនោះ ខែនោះ សូមទ្រង់ទតអក្សរ ជាសម្គាល់នេះ ហើយសូមទ្រង់ទទួលយកជារបស់ទ្រង់ និងសូមទ្រង់ទទួល ចោរ និងរតនៈនេះ ញុំាងជនទាំង ៤ ឲ្យដល់មហាវិបការៈយ៉ាងនេះ ហើយ ថ្វាយបង្គំលាត្រឡប់ទៅផ្ទះ ។ លំដាប់នោះ ព្រះរាជាទ្រង់មិនត្រាស់ពាក្យណា មួយនឹងជនទាំងនោះ ព្រោះរង្កៀសក្នុងព្រះពោធិសត្វ ព្រោះព្រះពោធិសត្វ គេចទៅហើយ និងព្រោះមិនមានជនដទៃជាមន្ត្រីបណ្ឌិត បានត្រឹមតែត្រាស់ថា អ្នកទាំង ៤ ចូរងូតទឹកត្រឡប់ទៅផ្ទះចុះ ។

## សព្វរតនថេនា ចប់

ក្នុងកាលនោះ ទេវតាដែលអាស្រ័យនៅត្រង់ស្វេតច្ឆត្ររបស់បរមក្សត្រ មិនបានស្តាប់ធម្មទេសនានៃព្រះពោធិសត្វ ទើបពិចារណាមើលថា មានហេតុ

អ្វីហ្ន៎ ក៏ជ្រាបហេតុនោះ ទើបគិតថា អញនឹងធ្វើឲ្យព្រះពោធិសត្វបានត្រឡប់មកកាន់ស្រុកវិញ ក្នុងពេលរាត្រី ក៏ជ្រែកឡូតឆត្រ ចេញមកសួរបញ្ហានឹងព្រះបាទវិទេហរាជ ៤ ចំណុច មានពាក្យថា **ហន្តិ ហត្ថេហិ បាទេហិ** ជាដើម ដែលជាបញ្ហារបស់ទេវតាក្នុងចតុក្កនិបាត ។ ព្រះរាជាបានស្តាប់ទេវប្បញ្ហានោះ ទ្រង់មិនជ្រាប ទើបតបនឹងទេវតានោះថា យើងមិនដឹង យើងនឹងសួរបណ្ឌិតដទៃៗ សិន ហើយត្រាស់សូមទេវបរិហារត្រឹមមួយថ្ងៃ ។ ស្អែកឡើង ទើបបញ្ជូនរាជសារទៅប្រាប់បណ្ឌិតទាំង ៤ ឲ្យចូលគាល់ កាលអាចារ្យទាំង ៤ ទូលថា ពួកទូលបង្គំមានក្បាលត្រងោលដោយកាំបិតកោរ ដើរតាមផ្លូវមានសេចក្តីខ្មាស ទើបព្រះរាជាឲ្យធ្វើនាឡិកបដ: គឺសំពត់ធ្វើរូបរាងដូចនាឡិបញ្ជូនទៅឲ្យ ដើម្បីពាក់ត្រង់ក្បាល ចូលមកគាល់ ។ បានឮថា នាឡិកបដ: កើតឡើងតាំងពីកាលនោះ រហូតមកដល់កាលឥឡូវនេះ អាចារ្យទាំង ៤ ក៏មកចូលគាល់ក្នុងអាសនៈដែលក្រាល ។ លំដាប់នោះ ព្រះរាជាត្រាស់ថា លោកអាចារ្យសេនកៈ យប់មិញ ទេវតាអាស្រ័យនៅត្រង់ស្វេតច្ឆត្រ សួរបញ្ហា ៤ យ៉ាង យើងសូមពន្យាថា យើងមិនទាន់ដឹងឡើយ ចាំសួរពួកលោកសិន នៃសេនកៈ ចូរលោកឆ្លើយបញ្ហានោះដល់យើង ត្រាស់ដូច្នេះហើយ ក៏ពោលបឋមគាថាដូច្នេះថា

បុគ្គលណា ប្រហារដោយដៃទាំង ២ ផង ដោយជើងទាំង ២
ផង ប្រហារនូវមាត់ផង បពិត្រមហារាជ បុគ្គលនោះ ជាទី
ស្រឡាញ់នៃគេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ដូច្នេះ ។

សេនកៈបានស្តាប់ទេវបញ្ហានោះ ក៏មិនដឹងសេចក្តី គិតស្មានៗ ក្នុងបញ្ហានោះថា អ្នកណាវាយអ្នកណា មិនឃើញទីបំផុត និងកំណួចនៃទេវបញ្ហានោះ សូម្បីអាចារ្យ ៣ នាក់ក៏ទាល់តម្រិះ ។ ព្រះរាជាទ្រង់មានវិប្បដិសារៈក្នុងចំណែកនៃរាត្រី ទេវតាសួរទៀតថា ទ្រង់ជ្រាបបញ្ហាហើយឬ ក៏ត្រាស់ឆ្លើយថា យើងបានសួរបណ្ឌិតទាំង ៤ ហើយ គេក៏មិនដឹង ទេវតាក៏ពោលសម្តុតព្រះរាជាថា អាចារ្យទាំង ៤ នាក់នោះដឹងខ្យល់អ្វី វៀរមហោសថ-បណ្ឌិតហើយ អ្នកដទៃ ដែលអាចស្រាយនូវបញ្ហាទាំងនេះ មិនមានឡើយ បើទ្រង់ហៅមហោសថឲ្យមកដោះស្រាយបញ្ហានេះជាការល្អ បើមិនហៅមក យើងនឹងទម្លាយសីសៈរបស់ទ្រង់ដោយដំបងដែកដ៏រុងរឿងនេះ ពោលសម្តុតដូច្នេះហើយ ក៏ទូលជាស់តឿនថា បពិត្រមហារាជ បើត្រូវការភ្លើង មិនគួរផ្លុំអំពិលអំពែក បើត្រូវការទឹកដោះ មិនគួររីតស្នែងគោ ក៏លើកយកខជ្ជោ-បនកបញ្ហា ក្នុងបញ្ចកនិបាតនេះមក ពោលជាគាថាដូច្នេះថា

នរណាហ្ន៎ កាលបើពន្លឺមាន ត្រាច់ទៅស្វែងរកភ្លើង បានឃើញ
នូវអំពិលអំពែកក្នុងវេលាយប់ ក៏សម្គាល់ថា ភ្លើង ។
បុរសនោះ ក៏ប្របាច់ឈ្លីនូវលម្អិតនៃអាចម៍គោ និងស្មៅ ដោយ
សេចក្តីសម្គាល់ខុស មិនអាចនឹងបង្កាត់ភ្លើងឲ្យឆេះឡើងបានទេ ។
បុគ្គលកាលរីតទឹកដោះមេគោ អំពីស្នែង រមែងមិនបាននូវទឹក
ដោះ យ៉ាងណា បុគ្គលអន្ធពាល ក៏មិនបាននូវប្រយោជន៍
ដោយហេតុមិនមែនឧបាយ យ៉ាងនោះដែរ ។
ជនទាំងឡាយ តែងបាននូវប្រយោជន៍ ដោយឧបាយទាំងឡាយ

ផ្សេងៗ គឺការផ្ចាញ់ផ្ចាល់សត្រូវទាំងឡាយផង គឺការទំនុកបម្រុង
ចំពោះមិត្តទាំងឡាយផង ។

ពួកអ្នករក្សាផែនដី រមែងគ្រប់គ្រងនូវផែនដី ដែលទ្រទ្រង់នូវ
ទ្រព្យសម្បត្តិ ដោយការបំពេញបំបាន ចំពោះសេនាជាប្រធាន
ផង ដោយការណែនាំរបស់ពួកមន្ត្រី ដែលជាអ្នកស្និទ្ធស្នាលផង
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តម្ហិ បជ្ជោតេ** សេចក្តីថា កាលភ្លើងមាន ។ បទថា **អគ្គិបរិយេសនំ ចរំ** សេចក្តីថា ដើររកដោយមិនមែនឧបាយ ។ បទថា **អទ្ទក្ខិ** បានដល់ ឃើញហើយ ។ កាលឃើញហើយ ក៏សម្គាល់អំពិលអំពែកនោះយ៉ាងនេះថា នេះជាភ្លើង ព្រោះមានពន្លឺដូចគ្នា ។ បទថា **ស្វាស្ស** សេចក្តីថា បុរសនោះយកលម្អិតអាចម៍គោ និងស្មៅដាក់លើអំពិលអំពែកនោះ ។ បទថា **អភិមត្ថំ** សេចក្តីថា បុគ្គលនេះឈ្មោះអ្វី យកដៃប្របាច់លម្អិតអាចម៍គោ និងស្មៅ អង្គុយលុតជង្គង់លើផែនដី សូម្បីព្យាយាមដោយការសម្គាល់ខុសថា អញនឹងយកមាត់ផ្លុំវាឲ្យឆេះ ក៏មិនអាចឲ្យឆេះបាន ។ បទថា **ម្ចគោ** សេចក្តីថា បុគ្គលអន្ធពាលដូចមនុស្សគ សូម្បីស្វែងរកដោយមិនមែនឧបាយយ៉ាងនេះ រមែងមិនបាននូវប្រយោជន៍នោះ ។ បទថា **យត្ថ** សេចក្តីថា រមែងមិនបាននូវវត្ថុដែលត្រូវការ ដូចមនុស្សដែលរីតទឹកដោះគោត្រង់ស្នែងគោ ដែលមិនមានទឹកដោះ ។ បទថា **សេណិមោក្ខូបលាភេន** បានដល់ ព្រោះបានពួកអមាត្យដែលមានសេនីជាប្រមុខ ។ បទថា **វល្លភានំ**

**ឆយោជ** ៥ បានដល់ ដោយការណែនាំរបស់ពួកអមាត្យដែលមានសេចក្ដីស្និទ្ធស្នាល ដែលជាទីស្រឡាញ់ ជាទីចម្រើនចិត្ត ។ បទថា **ជគតីបាលា** បានដល់ ព្រះរាជាទាំងឡាយ រមែងគ្រប់គ្រងផែនដីនេះឯង ដែលបានឈ្មោះថា **ពសុន្ធ** ព្រោះទ្រទ្រង់ទុកនូវរតនៈទាំងឡាយ គឺកែវ ។

ទេវតាពោលសម្ដុតព្រះរាជាថា ជនទាំងឡាយក្នុងកាលភ្លើងមាន ក៏មិនផ្ដុំអំពិលអំពែកដូចព្រះអង្គ បពិត្រព្រះរាជា ទ្រង់ត្រាស់សួរអាចារ្យទាំង ៤ មានសេនកៈជាដើម ក៏ដូចជាកាលភ្លើងមាន ទ្រង់ផ្ដុំអំពិលអំពែក ដូចមនុស្សបោលជញ្ជីង ហើយថ្លឹងដោយដៃ និងដូចត្រូវការទឹកដោះ ក៏រឹតទឹកដោះត្រង់ស្នែងគោដូច្នោះ អាចារ្យទាំង ៤ នោះដឹងអ្វី ព្រោះគេទាំងនោះដូចគ្នានឹងអំពិលអំពែក មហោសថបណ្ឌិត ដូចគ្នានឹងគំនរភ្លើងធំ រមែងរុងរឿងដោយបញ្ញា សូមទ្រង់ឲ្យគេតាមរកមហោសថ ហើយត្រាស់សួរចុះ បើទ្រង់មិនដឹងបញ្ហាទាំងនេះ ព្រះជន្មរបស់ទ្រង់មិនមាន គំរាមដូច្នេះហើយ ក៏អន្តរធានទៅ ។

**ខជ្ជោបនកបញ្ហា ចប់**

ព្រះរាជាត្រូវមរណភ័យគំរាម ស្អែកឡើង ឲ្យហៅអមាត្យ ៤ នាក់មកត្រាស់ថា អ្នកទាំងឡាយទាំង ៤ នាក់ ចូរឡើងរថ ៤ ចេញអំពីទ្វារនគរទាំង ៤ ស្វែងរកមហោសថកូនរបស់យើង តើគេនៅឯណា ចូរធ្វើសក្ការៈដល់គេក្នុងទីនោះ ហើយនាំគេមកដោយរហ័ស ។ អមាត្យទាំង ៤ ចេញតាមទ្វារម្នាក់ ១ អមាត្យ ៣ នាក់ មិនជួបមហោសថបណ្ឌិត តែអមាត្យមួយចេញតាមទ្វារទិសខាងត្បូង ជួបព្រះមហាសត្វត្រង់ទក្ខិណយវមជ្ឈគាម ជញ្ជូនដី

ឥដ្ឋមក មានរាងកាយប្រឡាក់ដី អង្គុយលើតាំងស្លឹកឈើ បង្ហិលក្ខារយន្ត ក្នុងសម្នាក់អាចារ្យ សូនដីឥដ្ឋជាដុំៗ បរិភោគបាយដំណើបមិនមានសម្ល ។

សួរថា ព្រោះហេតុអ្វី ទើបមហោសថធ្វើយ៉ាងនេះ ឆ្លើយថា បានឮថា ព្រះរាជាទ្រង់រង្កៀសថា មហោសថបណ្ឌិត នឹងដណ្តើមរាជសម្បត្តិរបស់ទ្រង់ ដោយឥតសង្ស័យ មហោសថគិតថា កាលព្រះរាជាជ្រាបថា មហោសថ ចិញ្ចឹមជីវិតដោយការធ្វើឆ្នាំងលក់ ទ្រង់ក៏អស់សង្ស័យ ទើបធ្វើយ៉ាងនេះ ។

មហោសថឃើញអមាត្យ ក៏ដឹងថា នឹងមករកខ្លួន ទើបត្រិះរិះថា ថ្ងៃនេះ យសរបស់អញនឹងមានជាប្រក្រតីទៀត អញនឹងបរិភោគភោជនាហារ មាន រសដ៏ប្រសើរផ្សេងៗ ដែលនាងអមរាទេវីរៀបចំទទួល គិតដូច្នោះ ក៏បោះ ដុំបាយដែលកំពុងកាន់ ក្រោកឡើងខ្ពុរមាត់ ។ អមាត្យនោះ ចូលទៅរក មហោសថក្នុងខណៈនោះ តែអមាត្យនោះ ជាគ្នីគ្នាអាចារ្យសេនកៈ ព្រោះ ដូច្នោះ កាលនឹងបន្តសេចក្តីដែលសេនកៈពោលអំពីខាងដើមថា ទ្រព្យប្រសើរ ជាងបញ្ញានោះ ទើបពោលថា នែលោកបណ្ឌិត ពាក្យរបស់អាចារ្យសេនកៈ ជាពាក្យពិត ក្នុងកាលយសរបស់លោកវិនាស លោកជាអ្នកមានបញ្ញាច្រើន ដល់ម៉្លេះ ក៏មិនអាចជាទីពឹងដល់លោក ឥឡូវនេះ លោកមានរាងកាយប្រឡាក់ ដោយដីស្អិត អង្គុយត្រង់តាំងស្លឹកឈើ បរិភោគបាយបែបនេះ ពោលដូច្នេះ ហើយ បានពោលគាថាទី ១ ក្នុងកូរិប្បញ្ហា ទសនិបាតនេះថា

បពិត្រអ្នកមានបញ្ញាក្រាស់ដូចផែនដី សិរី សេចក្តីព្យាយាម និង ប្រាជ្ញាប្រាកដដូច្នោះ រមែងមិនរក្សានូវអ្នកដែលជាមនុស្សធ្លាក់ចុះ

ទៅកាន់អំណាចនៃសេចក្តីមិនចម្រើន ព្រោះហេតុតែអ្នកបរិភោគនូវបាយដំណើបមានសម្ងួតិច តើការណ៍នោះពិតមែនឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សច្ចំ កិរ** សេចក្តីថា បពិត្រលោកអាចារ្យ អាចារ្យសេនកៈពោលពាក្យណា បានឮថា ពាក្យនោះជាពាក្យពិត ។ បទថា **សិរី** បានដល់ ភាពជាធំ ។ បទថា **ធិតិ** បានដល់ មានសេចក្តីព្យាយាមជានិច្ច ។ បទថា **ន តាយតេ ភាវវស្សូបនីតំ** សេចក្តីថា មិនរក្សា គឺមិនគ្រប់គ្រងបុគ្គលដែលចូលដល់អំណាចនៃសេចក្តីវិនាស គឺការមិនចម្រើន គឺមិនអាចជាទីពឹងរបស់ពួកអ្នកបាន ។ បទថា **យាវកំ** សេចក្តីថា បរិភោគកត្តាហារអំពីបាយដំណើបបែបនេះ ។

លំដាប់នោះ ព្រះមហាសត្វពោលតបនឹងអមាត្យនោះថា នែអន្ទពាល យើងបំណងនឹងធ្វើយសនោះឲ្យជាប្រក្រតីដោយបញ្ញារបស់ខ្លួន ទើបធ្វើយ៉ាងនេះ ហើយពោលគាថានេះថា

ខ្ញុំញ៉ាំងសេចក្តីសុខ ( ចាស់របស់ខ្លួន ) ឲ្យចម្រើនដោយសេចក្តីទុក្ខ ពិនិត្យមើលនូវកាលគួរ និងកាលមិនគួរ ហើយបិទបាំងតាមសេចក្តីពេញចិត្ត ( របស់ខ្លួន ) បើកនូវទ្វារនៃប្រយោជន៍ ព្រោះហេតុនោះ ទើបត្រេកអរដោយបាយដំណើប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧក្កេន** សេចក្តីថា ញ៉ាំងសេចក្តីសុខចាស់របស់ខ្លួនឲ្យដុះដាល គឺចម្រើន ដោយធ្វើឲ្យត្រឡប់ជាប្រក្រតី ដោយសេចក្តីទុក្ខផ្លូវកាយ និងចិត្ត ។ បទថា **កាលាកាលំ** សេចក្តីថា យើងកាលពិចា-

វេលាកាល និងមិនមែនកាលយ៉ាងនេះថា នេះជាកាលដែលត្រូវលបលួចត្រាច់ទៅ កាលនេះ មិនចាំបាច់លបលួចគេចទៅ ដឹងថា ក្នុងពេលដែលព្រះរាជាក្រោធ ត្រូវលបលួចគេចទៅ ជាអ្នកលបលួច គឺបិទបាំងតាមការគាប់ចិត្ត គឺការគាប់ចិត្តរបស់ខ្លួន ចិញ្ចឹមជីវិតដោយការងារស្មុទផ្ទាំង មិនបិទបាំង គឺបើក ពោល គឺហេតុនៃប្រយោជន៍របស់ខ្លួន ដោយហេតុនោះ ទើបខ្ញុំត្រេកអរដោយការបរិភោគបាយដំណើប ។ បទថា **អភិជិច្ឆតាយ** បានដល់ ដើម្បីការអង់អាច គឺដើម្បីធ្វើសេចក្ដីព្យាយាមក្រៃលែង ។ បទថា **មន្តេហិ អត្តំ បរិចាចយិត្វា** សេចក្ដីថា យើងនឹងញ៉ាំងយសរបស់យើងឲ្យចម្រើនទៀតដោយការដឹងរបស់ខ្លួន អង់អាចដូចរាជសីហ៍អង់អាចត្រង់មនោសិលាដូច្នោះ អ្នកនឹងឃើញយើងដោយការសម្រេចនោះវិញ ។

លំដាប់នោះ អមាត្យពោលនឹងមហោសថថា នៃបណ្ឌិត ទេវតាអាស្រ័យនៅក្នុងស្វេតច្ឆត្រ សួរបញ្ហានឹងព្រះរាជាៗ ត្រាស់សួរបណ្ឌិតទាំង ៤ ក្នុងជនទាំង ៤ នាក់នោះ បុគ្គលសូម្បីតែម្នាក់ក៏មិនអាចឆ្លើយបញ្ហាបាន ព្រោះហេតុនោះ ទើបព្រះរាជាត្រាស់ឲ្យខ្ញុំមករកលោក ។ មហាសត្វក៏ពោលសរសើរអានុភាពរបស់បញ្ញាថា កាលបើដូច្នេះ ចូរអ្នកឃើញអានុភាពនៃបញ្ញារបស់ខ្លួន ព្រោះថា ឥស្សរិយយសមិនជាទីពឹងក្នុងកាលបែបនេះ បុគ្គលដែលបរិបូណ៌ដោយបញ្ញាប៉ុណ្ណោះ រមែងជាទីពឹងបាន ។ អមាត្យបានទទួលព្រះរាជបញ្ជាមកថា ចូរឲ្យមហោសថបណ្ឌិតផ្លូតទឹក ស្លៀកដណ្ដប់ក្នុងទីដែលជួបហើយនាំមក ក៏បានធ្វើតាមបញ្ជា ហើយឲ្យកហាបណៈមួយពាន់ និងសំពត់

មួយសម្រាប់ ដែលព្រះរាជាប្រទានដល់ព្រះមហាសត្វ ។ បានឮថា នាយស្នូនធ្នាំងកើតការភ័យខ្លាច ដោយគិតឃើញថា អញប្រើមហោសថដែលជារាជបណ្ឌិត មហាសត្វឃើញកិរិយារបស់ស្នូនធ្នាំង ទើបនិយាយថា សូមលោកអាចារ្យកុំខ្លាចឡើយ លោកជាបុគ្គលមានឧបការៈដល់ខ្ញុំ ពោលដូច្នេះហើយ ឲ្យកហាបណៈមួយពាន់ដល់ស្នូនធ្នាំង ហើយអង្គុយក្នុងរថ ទាំងខ្លួនប្រឡាក់ដី ចូលទៅកាន់ព្រះនគរ អមាត្យទូលដំណឹងនៃការមករបស់មហោសថដល់ព្រះរាជាៗ ត្រាស់សួរថា តើអ្នកជួបមហោសថនៅឯណា ក៏ក្រាបទូលថា មហោសថធ្វើធ្នាំងលក់ចិញ្ចឹមជីវិត ក្នុងស្រុកទក្ខិណយវមជ្ឈគាម ដឹងថា មានរាជបញ្ជាឲ្យចូលមកគាល់ ក៏មិនងូតទឹក មានរាងកាយប្រឡាក់ដីនោះឯង ។ ព្រះបាទវិទេហរាជទ្រង់ព្រះតម្រិះថា បើមហោសថជាសត្រូវរបស់អញ គប្បីត្រាច់ទៅដោយបែបនៃឥស្សរិយយស មហោសថនេះ មិនមែនជាសត្រូវរបស់យើងឡើយ ទ្រង់ត្រិះរិះដូច្នេះហើយ ត្រាស់ថា ចូរលោកប្រាប់ដល់មហោសថកូនយើងថា ចូរទៅកាន់ផ្ទះរបស់ខ្លួន ងូតទឹកតាក់តែងកាយហើយមកតាមទំនងកិត្តិយសដែលយើងឲ្យ មហោសថបានស្ដាប់ព្រះរាជតម្រាស់ ក៏ធ្វើយ៉ាងនោះ ហើយមកគាល់ បានព្រះរាជានុញ្ញាតឲ្យចូលគាល់ហើយ ក៏ចូលទៅថ្វាយបង្គំព្រះរាជា ហើយបានឈរក្នុងទីសមគួរនាចំណែកម្ខាង ព្រះបាទវិទេហរាជទ្រង់ធ្វើបដិសណ្ឋារៈមហោសថបណ្ឌិត កាលទ្រង់ពិសោធមហោសថបណ្ឌិត ទើបត្រាស់គាថានេះថា

ជនពួកខ្លះ ជាអ្នកមានសេចក្ដីសុខ ទើបមិនធ្វើបាប ជនពួកខ្លះ

ទៀត ( មិនធ្វើបាប ) ព្រោះខ្លាចអំពីការជាប់ជំពាក់ដោយតំណិះដំនៀល អ្នកជាបុគ្គលអាចមានគំនិត គិតនូវប្រយោជន៍ដ៏ទូលាយបាន ហេតុអ្វី ក៏មិនធ្វើសេចក្ដីលំបាកដល់យើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុខី ហិ** សេចក្ដីថា នែបណ្ឌិត បុគ្គលពួកខ្លះ មិនធ្វើអាក្រក់ព្រោះហេតុជាអ្នកមានឥស្សរៈក្រៃលែងដោយគិតថា ពួកយើងមានសេចក្ដីសុខ សម្បូរដោយឥស្សរិយយស ពួកយើងមិនគួរធ្វើអាក្រក់ដោយហេតុប៉ុណ្ណេះ បុគ្គលពួកខ្លះមិនធ្វើអាក្រក់ ព្រោះខ្លាចក្រែងនូវការតិះដៀលដោយគិតថា បុគ្គលប្រាថ្នាអាក្រក់ ពោលតិះដៀល និងពោលដល់ចៅហ្វាយដែលឲ្យនូវយសដល់អញបែបនេះ បុគ្គលខ្លះមានបញ្ញាតិច តែខ្លួនអ្នកជាអ្នកមានសមត្ថភាព មានការគិតបរិបូណ៌ បើត្រូវការក៏គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូលបាន ហេតុអ្វីទើបមិនដណ្ដើមរាជសម្បត្តិ មិនធ្វើសេចក្ដីទុក្ខដល់យើង ។

លំដាប់នោះ ព្រះពោធិសត្វក្រាបទូលព្រះរាជាថា

បណ្ឌិតទាំងឡាយ រមែងមិនប្រព្រឹត្តនូវអំពើដ៏លាមក ព្រោះ
ហេតុនៃសេចក្ដីសុខផ្ទាល់ខ្លួនទេ ទោះបីត្រូវសេចក្ដីទុក្ខប៉ះពាល់
ឬឃ្លាតចាក ( សម្បត្តិ ) ក៏រមែងមិនលះបង់នូវធម៌ ព្រោះ
សេចក្ដីស្រឡាញ់ និងសេចក្ដីស្អប់ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ខលិតាបិ** សេចក្ដីថា ជាអ្នកមានសភាពដែលភ្លាត់ចាកសម្បត្តិ ហើយតាំងនៅក្នុងវិបត្តិ ។ បទថា **ន ជហន្តិ ធម្មំ** សេចក្ដីថា រមែងមិនលះបង់នូវធម៌ គឺបវេណី សុម្បីនូវធម៌ គឺសុចរិត ។

ព្រះរាជា កាលត្រាស់ខត្តិយមាយា ដើម្បីសាកល្បងមហោសថទៀត ទើបទ្រង់ត្រាស់គាថានេះថា

បុគ្គលគប្បីលើកតម្កើងនូវខ្ជួនដ៏ក្រខ្សត់ ( ឲ្យតាំងនៅក្នុងសម្បត្តិ )
ដោយពាក្យសរសើរ ឬដោយពាក្យដ៏ទន់ ឬក៏ដោយពាក្យទ្រគោះ
ណានីមួយ ហើយសឹមប្រព្រឹត្តធម៌ដោយប្រពៃ ក្នុងកាលជាខាង
ក្រោយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហរិណំ** សេចក្តីថា គប្បីរើខ្ជួនដែលថោកទាប គឺក្រីក្រឡើង ឲ្យតាំងនៅក្នុងសម្បត្តិ ។

លំដាប់នោះ ព្រះមហាសត្វកាលនឹងសម្តែងឧបមាដោយដើមឈើដល់ព្រះរាជា ទើបពោលគាថានេះថា

បុគ្គលអង្គុយ ឬដេកក្នុងម្លប់នៃឈើណា មិនត្រូវកាច់នូវមែកនៃ
ឈើនោះទេ ព្រោះបុគ្គលអ្នកទ្រុស្តមិត្ត ជាមនុស្សអាក្រក់ ដូច្នេះ ។

កាលពោលយ៉ាងនេះហើយ កាលនឹងសម្តែងភាពដែលខ្ជួនមិនមែនជាបុគ្គលទ្រុស្តមិត្រក្នុងទីទាំងពួងថា បពិត្រមហារាជ បើបុគ្គលកាច់នូវមែកឈើដែលខ្ជួនបានបរិភោគ ឈ្មោះថា ជាអ្នកទ្រុស្តមិត្រសោត នឹងពោលថ្វីដល់មនុស្សសម្លាប់មនុស្ស បិតារបស់ទូលបង្គំ ទ្រង់ឲ្យតាំងនៅក្នុងឥស្សរិយយសដ៏ឧឡារ ហើយទូលបង្គំ ទ្រង់ក៏អនុគ្រោះដោយការអនុគ្រោះច្រើន កាលទូលបង្គំប្រទូស្តក្នុងទ្រង់ នឹងមិនគប្បីឈ្មោះថាជាបុគ្គលទ្រុស្តមិត្តបានដូចម្តេច កាលនឹងទូលទោសនៃព្រះរាជា ទើបពោលគាថាដូច្នេះថា

បុរសចេះដឹងនូវធម៌ ( អំពីសម្នាក់ ) នៃអាចារ្យណាមួយទៀត សប្បុរសទាំងឡាយណា បន្ទោបង់នូវសេចក្ដីសង្ស័យរបស់អ្នកនោះ ការដឹង និងការបន្ទោបង់នោះ ឈ្មោះថា ជាទីពឹង ជាទីប្រព្រឹត្តទៅរបស់បុរសនោះ បុគ្គលអ្នកមានប្រាជ្ញា មិនត្រូវញុំាងមេត្រីចិត្តឲ្យសាបសូន្យ អំពីអាចារ្យនោះទេ ដូច្នេះ ។

គាថានោះ មានអត្ថថា បពិត្រមហារាជ បុរសគប្បីស្គាល់ធម៌ គឺហេតុមានប្រមាណតិចតួច អំពីសម្នាក់របស់អាចារ្យណា សប្បុរសពួកណា បានបន្ទោបង់នូវសេចក្ដីសង្ស័យដែលកើតដល់នរជននោះ ការធ្វើរបស់បុគ្គលនោះ ដូចកោះ និងជាទីពឹង ព្រោះអត្ថថា ជាទីពឹងរបស់នរជននោះ បណ្ឌិតមិនគប្បីលះ គឺមិនគប្បីញុំាងមិត្តភាពជាមួយអាចារ្យបែបនោះឲ្យវិនាស ។

ឥឡូវនេះ កាលនឹងថ្វាយឱវាទព្រះរាជា មហោសថបណ្ឌិតក៏ពោល ២ គាថាថា

គ្រហស្ថអ្នកបរិភោគកាម ខ្ជិលច្រអូស មិនល្អ បព្វជិត មិនសង្រួម មិនល្អ ព្រះរាជាធ្វើការមិនពិចារណាមិនល្អ នរណាជាបណ្ឌិត ច្រើនក្រោធ សេចក្ដីក្រោធនោះ មិនល្អ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន សាធុ** បានដល់ មិនបរិសុទ្ធ គឺមិនស្អាត ។ បទថា **អនិសម្មការី** បានដល់ បុគ្គលធ្វើនូវការងារឯណានីមួយមិនពិចារណា គឺមិនធ្វើឲ្យប្រចក្សដល់ខ្លួន ហើយធ្វើ ។ បទថា **តំ ន សាធុ** សេចក្ដីថា សេចក្ដីក្រោធ ពោល គឺការកម្រើកនៃអាជ្ញាដោយអំណាចការទាញ

យកវត្ថុដែលមិនមែនឋានៈរបស់បុគ្គលដែលជាបណ្ឌិត គឺអ្នកមានបញ្ញានោះមិនល្អ ។ បទថា **យសោ កិត្តិញ្ច** សេចក្តីថា ឥស្សរិយយស បរិវារយស និងកិត្តិគុណ រមែងចម្រើនដោយចំណែកមួយ ។

## ភូរិប្បញ្ហា ចប់

កាលព្រះមហាសត្វពោលយ៉ាងនេះហើយ ព្រះបាទវិទេហរាជ ក៏ឲ្យព្រះមហាសត្វអង្គុយត្រង់រាជបល្ល័ង្ក ខាងក្រោមស្វេតច្ឆត្រ ទ្រង់ប្រថាប់គង់នៅក្នុងអាសនៈទាបត្រាស់ថា នែបណ្ឌិត ទេវតាដែលអាស្រ័យត្រង់ស្វេតច្ឆត្រ សួរប្រស្នា ៤ ដល់យើង តែយើងមិនដឹងបញ្ហា ៤ នោះ អាចារ្យទាំង ៤ ក៏មិនដឹង ព្រោះដូច្នោះ ចូរអ្នកពោលដោះស្រាយប្រស្នា ៤ នោះដល់យើង ។ មហោសថក្រាបទូលថា បពិត្រមហារាជ ទេវតាដែលអាស្រ័យត្រង់ស្វេតច្ឆត្រក៏ចូរស្ទេះទុកចុះ ទោះបីទេវតាក្នុងជាន់ចាតុម្មហារាជិកាជាដើម ក៏ចូរស្ទេះទុកចុះ ទូលបង្គំអាចឆ្លើយនូវប្រស្នាដែលអ្នកឯណាមួយសួរ សូមទ្រង់ត្រាស់បញ្ហា ៤ ដែលទេវតាសួរចុះ ។ លំដាប់នោះ ព្រះរាជាកាលត្រាស់សួរ ក៏សួរតាមទំនងដែលទេវតាសួរ ទើបត្រាស់គាថាទី ១ ថា

បុគ្គលណា ប្រហារដោយដៃទាំង ២ ផង ដោយជើងទាំង ២
ផង ប្រហារនូវមាត់ផង បពិត្រមហារាជ បុគ្គលនោះ ជាទី
ស្រឡាញ់នៃគេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហន្តិ** បានដល់ រមែងវាយ ។ បទថា **បរិសុម្ភតិ** ប្រែថា រមែងវាយដូចគ្នា ។ បទថា **សវេ រាជ បិយោ ហោតិ** សេចក្តី

ថា បុគ្គលនោះ កាលធ្វើយ៉ាងនោះ រមែងជាទីស្រឡាញ់ ។ បទថា **កាឡេន-មភិបស្សសិ** សេចក្តីថា ព្រោះហេតុនោះ ទ្រង់ឃើញបុគ្គលដែលជាទីស្រឡាញ់ បានដល់បុគ្គលណា ទេវតាសួរបញ្ហានោះយ៉ាងនេះ ។

លុះព្រះមហាសត្វបានស្តាប់បញ្ហាប៉ុណ្ណោះ អត្ថនៃបញ្ហានោះ ក៏ប្រាកដដូចព្រះចន្ទពេញវង់ត្រង់កណ្តាលលម្ហ ។ លំដាប់នោះ ព្រះមហាសត្វជាស់តឿនព្រះរាជាឲ្យទ្រង់ចាំស្តាប់ហើយ ទើបពោលស្រាយទេវប្បញ្ហាធ្វើឲ្យប្រាកដដូចបុគ្គលមានឫទ្ធិ លើកព្រះអាទិត្យឡើងដាក់ត្រង់កណ្តាលលម្ហដូច្នោះ យ៉ាងនេះថា បពិត្រព្រះសម្មតិទេព កាលណាក្មេងតូចដេកលើភ្លៅ មាតាក៏សប្បាយរីករាយ លេងវាយមាតាដោយដៃ និងជើង ដកសក់មាតា យកដៃវាយមាត់មាតា កាលនោះ មាតាក៏ពោលពាក្យដូច្នេះជាដើមជាមួយកូននោះ ដោយអំណាចសេចក្តីស្រឡាញ់ថា នែអាកូនអាក្រក់ អាចោរ ឯងវាយអញយ៉ាងនេះបានឬ ពោលដូច្នេះហើយ មិនអាចអត់សង្កត់សេចក្តីស្រឡាញ់បាន ក៏ឱបក្រសោបត្រង់រវាងដោះ ថើបក្បាល កូននោះ ជាទីស្រឡាញ់នៃមាតាក្នុងកាលនោះ យ៉ាងណា ក៏ជាទីស្រឡាញ់នៃបិតាក្នុងកាលនោះដូច្នោះ ទេវតាបានស្តាប់អធិប្បាយរបស់ព្រះពោធិសត្វ ក៏ជ្រែកឡូតធត្រចេញមក ក៏សម្តែងកាយពាក់កណ្តាលឲ្យប្រាកដ ឲ្យសាធុការដោយសំឡេងដ៏ពីរោះថា ឱបណ្ឌិតពោលឆ្លើយបញ្ហាត្រូវល្អហើយហ្ន៎ ហើយបូជាមហាសត្វដោយផ្កា និងគ្រឿងក្រអូបដែលជាទិព្វ ដែលសម្រេចពេញក្នុងប្រអប់កែវ ហើយអន្តរធានទៅ សូម្បីព្រះបាទវិទេហរាជក៏ទ្រង់បូជាព្រះមហាសត្វ ដោយបុប្ផជាតិជាដើម រួច

ត្រាស់អង្វរឲ្យពោលបញ្ហាដទៃជាបន្ត កាលព្រះមហោសថប្រទានឱកាស ទើបត្រាស់គាថាទី ២ ថា

បុគ្គលណា ជេរប្រទេច តាមសេចក្តីប្រាថ្នា តែមិនប្រាថ្នានូវការ
មកដល់បុគ្គលនោះ បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់
របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វអធិប្បាយបញ្ហាទី ២ នោះថា បពិត្រមហារាជ មាតាប្រើកូនអាយុ ៧-៨ ឆ្នាំ ដែលអាចធ្វើតាមពាក្យប្រើបានថា នែបា ចូរទៅស្រែ ចូរទៅផ្សារ ដូច្នេះជាដើម កុមារពោលថា ម៉ែ បើឲ្យរបស់ទំពា របស់ស៊ីនេះៗ ដល់កូន កូននឹងទៅ កាលមាតាពោលថា យកចុះបា ក៏ទំពាស៊ី ហើយខ្ទរមាត់ឈរត្រង់ទ្វារ មិនទៅស្រែ លេងជាមួយពួកក្មេងៗ មិនធ្វើតាមពាក្យប្រើរបស់ម្តាយឡើយ កាលម្តាយប្រាប់ឲ្យទៅ ក៏ពោលថា នែម៉ែ ម៉ែអង្គុយ ឬឈរត្រង់ម្លប់ផ្ទះ ខ្ញុំត្រូវធ្វើតាមពាក្យរបស់ម៉ែខាងក្រៅដូចម្តេចបាន ដូច្នេះជាដើម កាលមាតាពោលថា ឯងបោកបញ្ឆោតអញ បង្ហាញដៃ និងមាត់ប្លែកៗ ហើយរត់ទៅ មាតាឃើញបុត្ររត់ទៅ ក៏អាក់អន់ កាន់រំពាត់ដេញតាម កាលដេញមិនទាន់ ក៏គំរាមថា អាមនុស្សអាក្រក់ អាចោរ អាស៊ីរបស់អញ ហើយមិនធ្វើអ្វីត្រង់ស្រែ ឈប់សិន ឈប់សិន ហើយជេរថា ឯងទៅចុះ អាថោកទាប ពួកចោរចូរកាត់អាឲ្យដាច់ជាកំណាត់តូចធំ ជេរបរិភាសតាមគាប់ចិត្ត តាមអធ្យាស្រ័យ តែកាលមាត់ពោលពាក្យណាចេញទៅ កាលនោះ ចិត្តក៏មិនប្រាថ្នានូវអន្តរាយសូម្បីតិចតួចដល់កូន ឯទារកលេង

ជាមួយពួកទារកអស់មួយថ្ងៃ មិនហ៊ានចូលផ្ទះក្នុងពេលល្ងាច ក៏ទៅកាន់សម្នាក់ពួកញាតិ ចំណែកមាតាកាលចាំមើលផ្លូវកូនត្រឡប់មក មិនឃើញកូនត្រឡប់មកផ្ទះ ក៏មានហទយៈពេញដោយសេចក្ដីសោកថា ប្រហែលជាកូនរបស់អញមិនហ៊ានចូលផ្ទះ មានទឹកភ្នែកហូរជោកមុខ ដើរស្វែងរកត្រង់ផ្ទះញាតិ ជួបកូនជាទីស្រឡាញ់ ក៏ឱបក្រសោប ថើបត្រង់ក្បាល យកដៃទាំងពីរចាប់កូនយ៉ាងមាំ ពោលថា នែកូនសម្លាញ់ កុំយកពាក្យម៉ែទុកក្នុងចិត្តឡើយ ពោលដូច្នេះហើយ ក៏ញ៉ាំងសេចក្ដីស្រឡាញ់ឲ្យកើតឡើងពន់ពេក បពិត្រមហារាជ កូនឈ្មោះថា ជាទីស្រឡាញ់ក្នុងកាលមាតាក្រោធ ដោយប្រការដូច្នេះ ទេវតាបានបូជាព្រះមហាសត្វ ដូចលើកទីមួយ ចំណែកព្រះបាទវិទេហរាជ ទ្រង់ក៏បូជាមហាសត្វ ដូចលើកទីមួយដែរ ហើយត្រាស់អារាធនាឲ្យស្រាយប្រស្នាទី ៣ កាលទ្រង់បានឱកាស ទើបត្រាស់គាថាទី ៣ ថា

បុគ្គលណា ពោលបន្ទាប់ដោយពាក្យមិនពិត ប្រកាសប្រាប់ឲ្យឮ
ដោយពាក្យឡូឡា បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់
របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ដូច្នេះ ។

លំដាប់នោះ មហាសត្វទូលស្រាយបញ្ហានោះដល់ព្រះរាជាថា បពិត្រមហារាជ កាលណាប្ដីប្រពន្ធពីរនាក់នៅក្នុងទីកំបាំង លូកលាន់គ្នាដោយសេចក្ដីស្នេហា តាមការត្រេកអររបស់លោក ហើយពោលចោទគ្នានិងគ្នាដោយពាក្យមិនពិតយ៉ាងនេះថា សេចក្ដីស្រឡាញ់របស់ខ្ញុំមិនមានដល់អ្នក បានឮថា ចិត្តរបស់អ្នកបែកទៅខាងក្រៅហើយ ហើយចោទគ្នាដោយពាក្យឡេះឡោះ កាល

នោះភរិយា និងស្វាមីទាំងពីរនោះ ក៏ស្រឡាញ់គ្នាពន់ពេក សូមទ្រង់ជ្រាបសេចក្ដីនៃបញ្ហានោះ ដោយប្រការដូច្នេះ ទេវតាបានស្ដាប់ហើយ ក៏បូជាព្រះពោធិសត្វដូចមុនទៀត ចំណែកព្រះរាជាក៏ទ្រង់បូជាមហាសត្វដោយន័យខាងដើម ហើយត្រាស់អារាធនាឲ្យឆ្លើយបញ្ហាជាបន្តទៀត កាលមហាសត្វបើកឱកាស ទើបត្រាស់គាថាទី ៤ ថា

ពួកអ្នកនាំយកទៅ បាននាំយកបាយផង ទឹកផង សំពត់ និងសេនាសនៈទាំងឡាយផង ដោយពិត បពិត្រមហារាជ ពួកអ្នកនាំយកទៅនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វអធិប្បាយអត្ថនៃបញ្ហាថ្វាយព្រះរាជាថា បពិត្រមហារាជ បញ្ហានេះ ទេវតាពោលសំដៅយកសមណៈ និងព្រាហ្មណ៍ដែលប្រព្រឹត្តធម៌ ។ ពិតហើយ ត្រកូលទាំងឡាយដែលមានសទ្ធា ជឿនូវលោកនេះ និងលោកខាងមុខ ទើបបរិច្ចាគទាន និងប្រាថ្នានឹងឲ្យទៀត ត្រកូលទាំងនោះឃើញសមណៈ និងព្រាហ្មណ៍ដែលមានសភាពដូច្នោះ សូមបាយទឹកជាដើមទៅក្ដី នាំយកបាយ និងទឹកជាដើមដែលបានហើយទៅបរិភោគក្ដី ក៏ជ្រះថ្លាក្នុងសមណៈ និងព្រាហ្មណ៍ទាំងនោះពន់ពេក ដោយឃើញថា សមណៈ និងព្រាហ្មណ៍ទាំងនេះ សូមបាយ និងទឹករបស់អញ បរិភោគបាយ និងទឹកជាដើមរបស់អញ កាលបើដូច្នេះ សមណៈ និងព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា ជាអ្នកនាំទៅ គឺជាអ្នកសូមដោយចំណែកមួយ កាលបុគ្គលនាំបាយ និងទឹក

ជាដើម ដែលបានហើយទៅដោយពិត ឈ្មោះថា ជាបុគ្គលជាទីស្រឡាញ់របស់ម្ចាស់ទានជាដើម ក្នុងបញ្ហានេះ មហោសថពោលឆ្លើយហើយ ទេវតាក៏បូជាយ៉ាងនេះ ហើយធ្វើសាធុការ បូជាប្រអប់កែវដែលពេញដោយរតនៈ ៧ ប្រការ ទៀបបាតជើងនៃមហោសថ ប្រាប់ថា ហៃមហោសថបណ្ឌិត ចូរអ្នកទទួលប្រអប់ ដែលពេញដោយរតនៈ ៧ ប្រការ ចំណែកព្រះបាទវិទេហរាជ ទ្រង់ព្រោសប្រាណ ជ្រះថ្លាក្នុងមហោសថក្រៃលែង បានព្រះរាជទានតំណែងសេនាបតីដល់មហោសថ ចាប់តាំងពីថ្ងៃនោះមក ព្រះមហាសត្វមានយសធំ ។

## ទេវប្បញ្ហា ចប់

បណ្ឌិតទាំង ៤ ប្រឹក្សាគ្នាទៀតថា ឥឡូវនេះ មហោសថគហបតីមានយសធំ នឹងធ្វើដូចម្ដេចល្អ លំដាប់នោះ សេនកៈក៏ពោលនឹងបណ្ឌិតទាំង ៣ ថា ការដែលគេមានយសធំនោះស្ទះទុកចុះ យើងឃើញឧបាយហើយ យើងទាំង ៤ នឹងទៅឃាត់មហោសថសួរថា យើងគួរប្រាប់អាថ៌កំបាំងដល់អ្នកណា បើគេឆ្លើយថា មិនគួរប្រាប់ដល់អ្នកណា យើងនឹងទូលញុះញង់ព្រះរាជាថា គហបតីបុត្រដែលមានឈ្មោះថា មហោសថ ជាសត្រូវរបស់ព្រះអង្គ បណ្ឌិតទាំង ៣ យល់ថាប្រពៃ ទើបបណ្ឌិតទាំង ៤ ទៅផ្ទះមហោសថ ធ្វើបដិសណ្ឋារៈ ហើយពោលថា នែបណ្ឌិត យើងទាំង ៤ ប្រាថ្នានឹងសួរបញ្ហា កាលមហោសថបើកឱកាសឲ្យសួរ សេនកៈក៏សួរថា បុគ្គលជាបណ្ឌិតគួរតាំងនៅក្នុងធម៌ដូចម្ដេច មហោសថឆ្លើយថា គួរតាំងនៅក្នុងសេចក្ដីពិត សេនកៈសួរថា តាំង

នៅក្នុងសេចក្តីពិតហើយគួរធ្វើអ្វី មហោសថឆ្លើយថា គួរឲ្យទ្រព្យសម្បត្តិកើតឡើង សេនកៈសួរថា ឲ្យទ្រព្យសម្បត្តិកើតឡើងហើយគួរធ្វើអ្វី មហោសថឆ្លើយថា គួរគប់មិត្រ សេនកៈសួរថា គប់មិត្រហើយ គួរធ្វើអ្វីបន្តទៅទៀត មហោសថឆ្លើយថា គួរប្រឹក្សាជាមួយមិត្រ សេនកៈសួរថា ប្រឹក្សាជាមួយមិត្រហើយ គួរធ្វើអ្វីទៀត មហោសថឆ្លើយថា ការបាននូវការវែកញែកអំពីមិត្រនោះ បើអាថ៌កំបាំង មិនគួរប្រាប់អាថ៌កំបាំងដល់បុគ្គលណាឡើយ បណ្ឌិតទាំង ៤ ក៏ទទួលថា សាធុ ហើយលាត្រឡប់ ជាអ្នកមានចិត្តត្រេកអរ គិតថា ឥឡូវនេះ យើងទាំង ៤ ឃើញខ្នងមហោសថហើយ ទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ មហោសថជាសត្រូវចំពោះព្រះអង្គ ព្រះបាទវិទេហរាជត្រាស់សួរថា យើងមិនជឿអ្នកទាំងឡាយ មហោសថមិនជាសត្រូវរបស់យើងឡើយ បណ្ឌិតទាំង ៤ ក៏ក្រាបទូលថា ពិតហើយ សូមទ្រង់ជឿចុះ បើទ្រង់មិនជឿ ចូរត្រាស់សួរមហោសថថា អាថ៌កំបាំងរបស់គេ គេគួរប្រាប់ដល់អ្នកណា បើមិនជាសត្រូវចំពោះព្រះអង្គ គេនឹងទូលថា គួរប្រាប់ដល់បុគ្គលឈ្មោះនោះ បើគេក្បត់ចំពោះព្រះអង្គ គេនឹងទូលថា មិនគួរប្រាប់ដល់បុគ្គលណាម្នាក់ ក្នុងកាលសេចក្តីប្រាថ្នាសម្រេច ទើបគួរប្រាប់ក្នុងកាលនោះ ទ្រង់នឹងជឿទូលបង្គំ ហើយអស់សេចក្តីសង្ស័យ ព្រះរាជាទ្រង់ទទួលដើម្បីនឹងសាកល្បង ។ ថ្ងៃមួយ កាលបណ្ឌិតទាំង ៥ មកជួបជុំគ្នា ទើបត្រាស់គាថានេះ ក្នុងបញ្ចបណ្ឌិតប្បញ្ហា វីសតិនិបាតថា

អ្នកប្រាជ្ញទាំង ៥ នាក់ មកជួបជុំគ្នាហើយ ប្រស្នាក្លីច្បាស់ដល់យើង
អ្នកទាំងឡាយ ចូរស្តាប់ប្រស្នានោះ អ្នកផងគួរសម្តែង ( ប្រាប់ )

នូវសេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់

នរណា ដូច្នេះ ។

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ សេនកៈគិតថា យើងនឹងឲ្យព្រះរាជានៅខាងយើង ទើបពោលគាថានេះថា

បពិត្រព្រះភូមិបាល សូមព្រះអង្គធ្វើឲ្យជាក់ច្បាស់ដល់ទូលព្រះបង្គំ

ជាខ្ញុំទាំងឡាយ ព្រះអង្គជាអ្នកចិញ្ចឹម ជាអ្នកអត់ធន់នូវរាជកិច្ច

ដ៏ធ្ងន់ សូមព្រះអង្គទ្រង់ពោលប្រស្នាទុំ៎ះមុន បពិត្រព្រះជនិន្ទ អ្នក

ប្រាជ្ញទាំង ៥ នាក់ ពិចារណានូវរបស់ជាទីស្រឡាញ់ និងជាទី

គាប់ព្រះហឫទ័យរបស់ព្រះអង្គ ហើយនឹងក្រាបទូលក្នុងកាល

ជាខាងក្រោយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភត្តា** សេចក្ដីថា ទ្រង់ជាអ្នកចិញ្ចឹមពួកទូលបង្គំ ហើយទ្រង់ជាអ្នកអត់ធន់ចំពោះរាជការកិច្ច ដែលកើតឡើង សូមទ្រង់ត្រាស់សេចក្ដីនោះមុនចុះ ។ បទថា **តវ ឆន្ទរុចីនិ** សេចក្ដីថា បណ្ឌិតទាំង ៥ នាក់នោះ ពិចារណាវត្ថុដែលទ្រង់ពេញព្រះរាជហឫទ័យ និងហេតុដែលពេញចិត្តដោយព្រះអធ្យាស្រ័យហើយ នឹងក្រាបទូលក្នុងកាលជាក្រោយ ។

លំដាប់នោះ ព្រះរាជាក៏ត្រាស់គាថានេះ ដោយភាពជាបុគ្គលប្រព្រឹត្តទៅក្នុងអំណាចកិលេសរបស់ទ្រង់ថា

ភរិយាណា មានសីលពិត ដែលបុរសជាទៃល្មួច ( សម្ពស្ស )

មិនបាន ជាស្រីប្រព្រឹត្តតាមអំណាចនៃសេចក្ដីប្រាថ្នារបស់កស្តា

ជាទីស្រឡាញ់ ជាទីពេញចិត្តនៃកស្ដា បុគ្គលគួរប្រាប់នូវសេចក្ដី ដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់ភរិយា ( នោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនញ្ញាជេយ្យា** សេចក្ដីថា ដែលបុគ្គលដទៃមិនគប្បីពាល់ត្រូវដោយអំណាចកិលេស ។

បន្ទាប់អំពីនោះ សេនកៈត្រេកអរថា ឥឡូវនេះ យើងទាំងឡាយនឹងញុំាងព្រះរាជាឲ្យនៅខាងពួកយើងបានហើយ កាលសម្ដែងហេតុការណ៍ដែលខ្លួនធ្វើ ទើបពោលគាថានេះថា

សម្លាញ់ណាជាទីរឭក ជាគតិ ជាទីពឹង របស់អ្នកដែលដល់នូវសេចក្ដីលំបាក អ្នកដែលក្ដៅក្រហាយ បុគ្គលគួរប្រាប់នូវសេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់សម្លាញ់ ( នោះ ) ដូច្នេះ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរបុក្កុសៈថា នែអាចារ្យបុក្កុសៈ លោកឃើញអ្វី អាថ៌កំបាំងរបស់ខ្លួន គួរប្រាប់ដល់អ្នកណា បុក្កុសៈកាលក្រាបទូលទើបពោលគាថានេះថា

បងប្អូនណា ទោះបីជាបងបង្អស់ក្ដី កណ្ដាលក្ដី ជាប្អូនពៅក្ដី បើបងប្អូននោះតម្កល់នៅស៊ប់ក្នុងសីល មានចិត្តនឹងនួន បុគ្គលគួរប្រាប់នូវសេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់បងប្អូន ( នោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឋិតត្តោ** សេចក្ដីថា តាំងសភាវៈបាន គឺជាអ្នកមានការសេពខុស ( ប្រាស ) ចេញហើយ ។

បន្ទាប់អំពីនោះ ព្រះរាជាត្រាស់សួរកាមិន្ទៈថា នែអាចារ្យកាមិន្ទៈ លោកឃើញដូចម្ដេច អាថ៌កំបាំងគួរប្រាប់ដល់អ្នកណា កាមិន្ទៈកាលនឹងក្រាបទូល ទើបពោលគាថានេះថា

កូនប្រុស អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហឫទ័យរបស់បិតា ជា
អ្នកធ្វើតាមពាក្យ ជាអនុជាតបុត្រ មានប្រាជ្ញាមិនឱនថយជាង
បិតា បុគ្គលគួរប្រាប់នូវសេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែល
ជាអាថ៌កំបាំង ដល់កូនប្រុស ( នោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បត្តគូ** បានដល់ ដែលធ្វើតាមពាក្យ អធិប្បាយថា កូនដែលធ្វើតាមចិត្តរបស់យើង គឺជាអ្នកប្រព្រឹត្តទៅក្នុងអំណាចចិត្តរបស់បិតា ជាអ្នកអត់ធន់ចំពោះឱវាទ ។ បទថា **អនុជាតោ** សេចក្ដីថា កូនមាន ៣ ប្រភេទ គឺអភិជាត ១ អនុជាត ១ អវជាត ១ កូនដែលញុំាងយសមិនទាន់កើតឲ្យកើតឡើង ឈ្មោះថាអភិជាត កូនដែលជាខ្សែស្រឡាយរបស់ត្រកូល ជាអ្នកកាត់នូវវង្សត្រកូល ធ្វើទ្រព្យឲ្យវិនាស ឈ្មោះថាអវជាត កូនដែលរក្សាបែបផែនរបស់ត្រកូល ប្រពៃណីរបស់ត្រកូលបាន ឈ្មោះថាអនុជាត អាចារ្យកាមិន្ទៈពោលយ៉ាងនេះ សំដៅដល់អនុជាតបុត្រនោះ ។

បន្ទាប់អំពីនោះ ព្រះរាជាត្រាស់សួរទេវិន្ទៈថា នែអាចារ្យទេវិន្ទៈ លោកឃើញដូចម្ដេច អាថ៌កំបាំងគួរប្រាប់ដល់អ្នកណា ទេវិន្ទៈកាលក្រាបទូលហេតុ

ការណ៍ដែលខ្លួនធ្វើ ទើបពោលគាថានេះថា

បពិត្រព្រះអង្គជាធំជាងជន ដ៏ប្រសើរជាងមនុស្ស មាតាណាចិញ្ចឹម កូននោះ ដោយសេចក្ដីស្រឡាញ់ពេញចិត្ត បុគ្គលគួរប្រាប់នូវ សេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់ មាតា ( នោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទ្វិបទជនិន្ទសេដ្ឋ** បានដល់ កំពូលជាង ជន ប្រសើរជាងមនុស្សទាំងឡាយ ។ បទថា **ឆន្ទសា បិយេន** បានដល់ ដោយការពេញចិត្ត និងដោយសេចក្ដីស្រឡាញ់ ។

ព្រះរាជាត្រាស់សួរអាចារ្យទាំង ៤ នោះ ដែលពោលតបទៅយ៉ាងនេះ ហើយ ទើបត្រាស់សួរមហោសថបណ្ឌិតថា នែបណ្ឌិត អ្នកឃើញដូចម្ដេច អាថ៌កំបាំងគួរប្រាប់ដល់អ្នកណា មហោសថបណ្ឌិត កាលនឹងក្រាបទូលហេតុ នៃអាថ៌កំបាំង ទើបពោលគាថានេះថា

សេចក្ដីពិតថា ការលាក់ នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់ នូវអាថ៌កំបាំង គេមិនសរសើរទេ អ្នកប្រាជ្ញ កាលបើសេចក្ដី ប្រាថ្នាមិនទាន់សម្រេចនៅឡើយ ត្រូវអត់សង្កត់ទុក លុះសម្រេច ប្រយោជន៍ហើយ ទើបគួរនិយាយតាមសប្បាយចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនិប្ផន្នាយ** សេចក្ដីថា បពិត្រព្រះរាជា វត្ថុដែលខ្លួនប្រាថ្នាមិនទាន់សម្រេចដរាបណា បណ្ឌិតគប្បីអត់សង្កត់ មិនគប្បី ប្រាប់ដល់អ្នកណាដរាបនោះ ។

កាលមហោសថបណ្ឌិតក្រាបទូលយ៉ាងនេះហើយ ព្រះរាជាទ្រង់ខកព្រះហឫទ័យ សេនកៈសម្លឹងព្រះភក្ត្រព្រះរាជាៗ ក៏ទតមុខសេនកៈ មហោសថ-បណ្ឌិត ឃើញកិរិយានៃសេនកៈ និងព្រះរាជា ក៏ដឹងថា អាចារ្យទាំង ៤ នេះបានញុះញង់ក្នុងរវាងយើងនឹងព្រះរាជាជាមុនហើយ ព្រះរាជាត្រាស់សួរបញ្ហាដើម្បីសាកល្បងអញ កាលព្រះរាជា និងរាជបរិស័ទចរចាគ្នា ព្រះអាទិត្យក៏អស្តង្គត ភ្នាក់ងារក៏អុជប្រទីប មហោសថត្រិះរិះថា ឈ្មោះថា រាជការ ជារបស់ធ្ងន់ រមែងមិនប្រាកដ អ្នកណានឹងដឹងរឿងថា អ្វីនឹងកើតមាន អញគួរប្រញាប់ត្រឡប់សិន ត្រិះរិះដូច្នេះ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះរាជាចេញទៅ គិតថា បុគ្គលម្នាក់ពោលថា គួរប្រាប់អាថ៌កំបាំងដល់សម្លាញ់ បុគ្គលម្នាក់ពោលថា គួរប្រាប់អាថ៌កំបាំងដល់ប្អូនប្រុស បុគ្គលម្នាក់ពោលថា គួរប្រាប់អាថ៌កំបាំងដល់បុត្រ បុគ្គលម្នាក់ពោលថា គួរប្រាប់អាថ៌កំបាំងដល់មាតា អញសម្គាល់ថា កិច្ចនេះ នឹងជារបស់បុគ្គលទាំងនេះបានធ្វើហើយពិត បុគ្គលទាំងនេះគង់ពោលដល់កិច្ចដែលខ្លួនឃើញហើយ ចូរលើកទុកចុះ អញនឹងដឹងហេតុនេះក្នុងថ្ងៃនេះ ។ ចំណែករាជបណ្ឌិតទាំង ៤ ចេញអំពីរាជ-សម្នាក់ហើយ ក្នុងថ្ងៃដទៃៗ ធ្លាប់អង្គុយលើធុងកត្តមួយ ក្បែរទ្វាររាជនិវេសន៍ ប្រឹក្សាគ្នាដល់ករណីយកិច្ច ហើយត្រឡប់ទៅផ្ទះ ព្រោះហេតុនោះ មហោសថត្រិះរិះថា ថ្ងៃនេះ អញនឹងដេកខាងក្រោមធុងកត្ត ក៏អាចដឹងអាថ៌កំបាំងរបស់អាចារ្យទាំង ៤ នោះ ទើបឲ្យមនុស្សលើកធុងកត្តនោះ ហើយឲ្យក្រាលកម្រាលហើយចូលខាងក្រោមធុងកត្តនោះ ហើយឲ្យសញ្ញាដល់អ្នកបម្រើថា កាល

អាចារ្យទាំង ៤ មកអង្គុយប្រឹក្សាគ្នា ក្រោកទៅហើយ ចូរពួកអ្នកមកនាំយើងចេញ អ្នកបម្រើនោះ ទទួលពាក្យនុ៎ះ ហើយចៀសចេញទៅ ចំណែកអាចារ្យសេនកៈ ទូលនឹងព្រះបាទវិទេហរាជថា ព្រះអង្គទ្រង់មិនជឿទូលបង្គំឬឥឡូវនេះ សេចក្តីនោះដូចម្តេច ព្រះរាជាស្តាប់ពាក្យរបស់អាចារ្យដែលញុះញង់ ក៏ទ្រង់មិនពិចារណា ជាអ្នកខ្លាចផង តក់ស្លុតផង ទើបត្រាស់សួរថា នែលោកសេនកបណ្ឌិត ឥឡូវនេះ យើងគួរធ្វើដូចម្តេច សេនកៈក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំបង្អង់ កុំទាន់ឲ្យមហោសថដឹងខ្លួន ហើយសម្លាប់ចោល ព្រះរាជាត្រាស់ថា នែអាចារ្យសេនកៈ វៀរអ្នកហើយ អ្នកដទៃឈ្មោះថា ជាអ្នកប្រាថ្នាសេចក្តីចម្រើនដល់យើង មិនមាន សូមលោកបបួលសម្លាញ់របស់លោករង់ចាំខាងក្នុងទ្វារ កាលមហោសថកូនគហបតីមកកាន់រាជសម្នាក់អំពីព្រលឹម ចូរកាត់ក្បាលដោយដាវ ត្រាស់ដូច្នេះហើយ ព្រះរាជទានព្រះខ័នរតនៈ ។ អាចារ្យទាំង ៤ នោះ ក្រាបទូលថា សាធុ សូមទ្រង់កុំខ្លាចឡើយ ពួកទូលបង្គំនឹងសម្លាប់មហោសថនោះឲ្យខាងតែបាន ទូលដូច្នេះហើយ ចេញមកអង្គុយលើធុងកត្តត្រិះរិះប្តូរយោបល់គ្នាថា ពួកយើងឃើញខ្នងបច្ចាមិត្តហើយ បន្ទាប់អំពីនោះ សេនកៈក៏លូកមាត់ឡើងថា អ្នកណានឹងសម្លាប់មហោសថ អាចារ្យទាំង ៣ ក៏ឆ្លើយថា លោកអាចារ្យនោះឯង នឹងសម្លាប់បាន ហើយធ្វើកិច្ចនោះឲ្យជាភារៈរបស់សេនកៈនោះឯង គ្រានោះ សេនកៈក៏សួរអាចារ្យទាំង ៣ ថា លោកទាំង ៣ ពោលថា ឈ្មោះថាអាថ៌កំបាំងគួរប្រាប់ដល់បុគ្គលឈ្មោះនោះៗ ដូច្នេះ កិច្ចនោះ លោកទាំង ៣ បានធ្វើហើយ ឬឃើញហើយ ឬបានស្តាប់ហើយដូចម្តេច លំដាប់នោះ

អាចារ្យទាំង ៣ ពោលនឹងសេនកៈថា បពិត្រលោកអាចារ្យ កិច្ចដែលលោកពោលថា អាថ៌កំបាំងគួរប្រាប់ដល់សម្លាញ់នោះ ជារបស់ប្រាកដហើយ កិច្ចនោះលោកធ្វើហើយ ឬឃើញហើយ ឬបានស្តាប់ហើយដូចម្តេច អាចារ្យសេនកៈពោលថា កិច្ចនោះយើងបានធ្វើឯង អាចារ្យទាំង ៣ សួរថា បពិត្រអាចារ្យ បើដូច្នោះ សូមលោកពោលឲ្យជ្រាប អាចារ្យសេនកៈពោលថា អាថ៌កំបាំងនេះ បើព្រះរាជាដឹងហើយ ជីវិតរបស់យើងនឹងមិនមាន អាចារ្យទាំង ៣ សួរថា បពិត្រអាចារ្យលោកកុំខ្លាចឡើយ បុគ្គលទម្លាយអាថ៌កំបាំងរបស់យើងទាំងឡាយក្នុងទីនេះ មិនមាន សូមលោកពោលឲ្យពួកយើងដឹងចុះ សេនកៈយកក្រចកគោះថុងកត្តថា មហោសថនៅក្រោមថុងកត្តនេះទេដឹង អាចារ្យ ទាំង ៣ ឆ្លើយថា មហោសថជាមនុស្សស្រវឹងក្នុងឥស្សរិយយស គង់មិនចូលទៅក្នុងទីដូច្នេះ ឥឡូវនេះ ជាមនុស្សស្រវឹងក្រៃលែងដោយឥស្សរិយយស ដូចលោកឃើញស្រាប់ ។

ចំណែកសេនកៈ កាលនឹងប្រាប់អាថ៌កំបាំងរបស់ខ្លួន ទើបពោលថា លោកទាំង ៣ ស្គាល់ស្រីពេស្យាឈ្មោះនោះ ក្នុងនគរនេះដែរឬ អាចារ្យទាំង ៣ ពោលថា ខ្ញុំទាំង ៣ ស្គាល់ អាចារ្យសេនកៈ សួរថា ឥឡូវនេះស្រីនោះ នៅប្រាកដ ឬក៏បាត់ទៅ អាចារ្យទាំង ៣ ពោលថា មិនប្រាកដឡើយ សេនកៈក៏ប្រាប់ថា យើងធ្វើកិច្ចរបស់បុរសជាមួយស្រីនោះ ក្នុងឧទ្យានដើមរាំង ហើយញ៉ាំងស្រីនោះឲ្យស្លាប់ ព្រោះចង់បានគ្រឿងអលង្ការ ហើយនាំគ្រឿងប្រដាប់របស់ស្រីនោះខ្ចប់ដោយសំពត់សាដក ហើយព្យួរលើ

ដៃកែវក្នុងផ្ទះរបស់ខ្ញុំ ខ្ញុំមិនអាចប្រើប្រាស់គ្រឿងប្រដាប់នោះ ឃើញភាពដែលគ្រឿងប្រដាប់នោះជារបស់បុរាណ ខ្ញុំធ្វើខុសនឹងព្រះរាជបញ្ញត្តិយ៉ាងនេះ បានប្រាប់ដល់សម្លាញ់ម្នាក់ សម្លាញ់នោះ មិនប្រាប់ដល់បុគ្គលណាម្នាក់ ហេតុនោះ ទើបខ្ញុំពោលថា ខ្ញុំបានប្រាប់អាថ៌កំបាំងដល់សម្លាញ់មហោសថតាំងចិត្តកំណត់អាថ៌កំបាំងរបស់សេនកៈយ៉ាងល្អ ។ ចំណែកបុក្កុសៈ កាលប្រាប់អាថ៌កំបាំងរបស់ខ្លួន ទើបពោលថា រោគឃ្លង់ដែលមានត្រង់ភ្លៅរបស់ខ្ញុំ ប្អូនប្រុសពៅរបស់ខ្ញុំប៉ុណ្ណោះដឹង គេមិនឲ្យបុគ្គលណាដឹង គេលាងដំបៅនោះលាបថ្នាំ រុំដំបៅ ព្រះរាជាមានព្រះហឫទ័យករុណាក្នុងខ្ញុំ ត្រាស់ហៅខ្ញុំមកថា បុក្កុសៈចូរមក ហើយផ្ទំកើយភ្លៅរបស់ខ្ញុំរឿយៗ បើព្រះរាជាទ្រង់ដឹងរឿងនេះ គប្បីប្រហារជីវិតខ្ញុំ វៀរប្អូនប្រុសនោះ របស់ខ្ញុំចេញ អ្នកដទៃមិនដឹងឡើយ ដោយហេតុនេះ ទើបខ្ញុំពោលថា ខ្ញុំប្រាប់អាថ៌កំបាំងដល់ប្អូនប្រុសពៅ ។ ឯកាមិន្ទៈ កាលនឹងប្រាប់អាថ៌កំបាំងរបស់ខ្លួន ទើបពោលថា ក្នុងថ្ងៃឧបោសថខាងរនោច យក្ខឈ្មោះនរទេវៈមកចូលសណ្ឋិតខ្ញុំ ខ្ញុំក៏លូដូចឆ្កែព្រៃ ខ្ញុំក៏បានប្រាប់សេចក្តីនោះដល់កូន កូនរបស់ខ្ញុំដឹងថា យក្ខចូលសណ្ឋិតខ្ញុំ ក៏ឲ្យខ្ញុំដេកក្នុងបន្ទប់ខាងក្នុង បិទទ្វារ ចេញទៅក្នុងទីមានមហោស្រពត្រង់ទ្វារ ដើម្បីបន្ទប់សំឡេងរបស់ខ្ញុំ ដោយហេតុនោះ ទើបខ្ញុំពោលថា ខ្ញុំប្រាប់អាថ៌កំបាំងដល់កូន បន្ទាប់អំពីនោះ អាចារ្យទាំង ៣ ក៏សួរទេវិន្ទៈៗ កាលនឹងពោលអាថ៌កំបាំងរបស់ខ្លួន ទើបពោលថា ខ្ញុំធ្វើការខាត់កែវមណី បានលួចកែវមណីជាមង្គល ជាទីចូលនៅនៃសិរី ជារបស់ព្រះរាជា ដែលសក្កទេវរាជ

ប្រទានដល់ព្រះបាទកុសរាជមកឲ្យមាតា ម្ដាយនោះ មិនឲ្យអ្នកណាដឹង ដល់ពេលខ្ញុំចូលគាល់ព្រះរាជា ក៏ឲ្យមណ្ឌលមណីរតនៈដល់ខ្ញុំ ខ្ញុំញ៉ាំងសិរីឲ្យនៅក្នុងខ្លួនខ្ញុំ ដោយអំណាចមណ្ឌលមណីរតនៈនោះ ទើបចូលទៅកាន់រាជសម្នាក់ ព្រះរាជាមិនត្រាស់ដល់អ្នកទាំងឡាយ ត្រាស់ជាមួយខ្ញុំមុនអ្នកណាទាំងអស់ ហើយព្រះរាជទានកហាបណៈ ៨ ខ្ទះ ១៦ ខ្ទះ ៣២ ខ្ទះ ៦៤ ខ្ទះ ដល់ខ្ញុំជាស្បៀងចិញ្ចឹមជីវិតសព្វថ្ងៃ បើព្រះរាជាទ្រង់ជ្រាបអានុភាពមណីរតនៈនោះសោត ជីវិតរបស់ខ្ញុំនឹងមិនតាំងនៅ ដោយហេតុនោះ ទើបខ្ញុំពោលថា ខ្ញុំប្រាប់អាថ៌កំបាំងដល់មាតា ។

ព្រះមហាសត្វបានធ្វើអាថ៌កំបាំងរបស់អាចារ្យទាំង ៤ ឲ្យប្រចក្ស ។ អាចារ្យទាំង ៤ នោះប្រាប់អាថ៌កំបាំងដល់គ្នានិងគ្នា ដូចបុគ្គលពុះទ្រូងរបស់ខ្លួន ពន្លាត់អាវយវៈខាងក្នុងចេញមកខាងក្រៅ ហើយជាស់តឿនគ្នាថា អ្នកទាំងឡាយកុំប្រមាទ ជួយគ្នាសម្លាប់មហោសថកូនគហបតីអំពីព្រលឹម ណាត់គ្នាដូច្នេះហើយ ក្រោកឡើងចៀសចេញទៅ ក្នុងកាលអាចារ្យទាំង ៤ ទៅហើយ អ្នកបម្រើរបស់មហោសថដែលបានណាត់គ្នា ក៏មកលើកធុងកត្ត នាំមហាសត្វចៀសចេញទៅ ។ មហាសត្វដល់គេហដ្ឋាន ងូតទឹក តែងខ្លួន បរិភោគអាហារហើយ ដឹងថា ថ្ងៃនេះ ព្រះនាងឧទុម្ពរទេវីបងស្រីរបស់អញ គង់ឲ្យដំណឹងមកអំពីព្រះរាជវាំង ទើបដាក់មនុស្សពិសេសត្រង់ទ្វារ ប្រាប់ថា ចូរអ្នកឲ្យមនុស្សអំពីព្រះរាជវាំងចូលមក ហើយប្រាប់ដល់យើងឲ្យរហ័ស កាលប្រាប់ដូច្នេះហើយ ក៏ដេកក្នុងដំណេកដ៏មានសិរី ។

ខណៈនោះ ព្រះបាទវិទេហរាជផ្ទុំត្រង់ទីបន្ទំដ៏មានសិរី ទ្រង់អនុស្សរណៈដល់គុណរបស់មហោសថថា មហោសថបណ្ឌិតបម្រើអញមកតាំងអំពីអាយុ ៧ ឆ្នាំ មិនបានធ្វើសេចក្ដីវិនាសសូម្បីតែតិចតួចដល់អញ កាលទេវតាសួរបញ្ហា បើមិនមានមហោសថសោត ជីវិតរបស់អញក៏មិនមាន អញបែរជាមកកាន់យកពាក្យរបស់បច្ចាមិត្តដែលជាអ្នកមានពៀរ ហើយពោលថា អ្នកទាំងឡាយ ចូរសម្លាប់មហោសថដែលជាបុគ្គលមានធុរៈ រកបុគ្គលប្រៀបគ្មានដូច្នេះហើយ ឲ្យព្រះខ័ន អញធ្វើវត្ថុដែលមិនគួរធ្វើ ឥឡូវនេះ ចាប់ពីព្រឹកនេះទៅ អញនឹងមិនបានឃើញមហោសថទៀត ទ្រង់អាវជ្ជនៈដូច្នេះ ក៏ញុំាងសេចក្ដីសោកឲ្យកើតឡើង ញើសក៏ហូរជោកកាយ ព្រះរាជាពេញទៅដោយសេចក្ដីសោក ទ្រង់មានព្រះហឫទ័យមិនធូរផង់ ។ ព្រះនាងឧទុម្ពរទេវីយាងទៅផ្ទុំជាមួយព្រះរាជស្វាមី ទតឃើញព្រះអាការរបស់ព្រះរាជស្វាមី ព្រះនាងត្រិះរិះថា ហេតុអ្វីហ្ន៎ កំហុសណាមួយរបស់អញមានឬហ្ន៎ ឬហេតុការណ៍នៃសេចក្ដីសោកអ្វីដទៃ កើតឡើងដល់ព្រះអង្គ អញនឹងទូលសួរទ្រង់ កាលនឹងទូលសួរ ទើបពោលគាថានេះថា

បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គទ្រង់មានព្រះហឫទ័យប្រែប្រួល ឬ បពិត្រព្រះអង្គជាធំជាងមនុស្ស ខ្ញុំម្ចាស់ស្ដាប់ព្រះតម្រាស់របស់ព្រះអង្គនោះហើយ តើព្រះអង្គទ្រង់ព្រះចិន្ដាដូចម្ដេច បានជាទ្រង់តូចព្រះហឫទ័យ បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មិនមានកំហុសទេឬ ដូច្នេះ ។

គ្រានោះ ព្រះរាជាកាលនឹងត្រាស់តបជាមួយព្រះនាង ទើបត្រាស់ថា មហោសថត្រូវគេសម្លាប់ព្រោះតែប្រស្នា មហោសថជាអ្នកមានប្រាជ្ញាដូចផែនដី ខ្ញុំបង្គាប់គេឲ្យសម្លាប់ហើយ ខ្ញុំគិតរឿងនោះ បានជាតូចចិត្ត ម្នាលនាងទេវី កំហុសរបស់នាងមិនមានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាណាត្តោ មេ** សេចក្ដីថា នែនាងដ៏ចម្រើន បណ្ឌិតទាំង ៤ ប្រាប់ដល់យើងថា មហោសថបណ្ឌិតជាសត្រូវរបស់យើង យើងមិនបានពិចារណាឲ្យជាក់ច្បាស់ បញ្ជាឲ្យសម្លាប់មហោសថដែលជាអ្នកមានបញ្ញាដូចផែនដីថា ចូរពួកអ្នកសម្លាប់គេចោល កាលយើងគិតដល់ហេតុការណ៍នោះ ទើបមានទោមនស្សថា អញស្លាប់ល្អជាងមហោសថបណ្ឌិតស្លាប់ ។

សេចក្ដីសោកប៉ុនភ្នំ កើតឡើងដល់ព្រះនាងឧទុម្ពរ ដោយសេចក្ដីស្រឡាញ់ក្នុងព្រះមហាសត្វ ព្រោះបានស្ដាប់ព្រះរាជតម្រាស់នោះ បន្ទាប់អំពីនោះ ទើបព្រះនាងទ្រង់គិតថា អញនឹងញ៉ាំងព្រះរាជាឲ្យទ្រង់កក់ក្ដៅដោយឧបាយមួយ ក្នុងកាលព្រះរាជាផ្ទំលក់ អញនឹងបញ្ជូនដំណឹងទៅឲ្យមហោសថប្អូនប្រុសរបស់អញ ។ លំដាប់នោះ ព្រះនាងក៏ក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះអង្គញ៉ាំងមហោសថឲ្យតាំងនៅក្នុងឥស្សរិយយសធំ ក្រោយមក ទ្រង់ធ្វើការដូច្នេះដល់មហោសថ មិនជាការអ្វីឡើយ ហើយទូលលួងលោមព្រះរាជាឲ្យស្បើយព្រះហឫទ័យថា ព្រះអង្គទ្រង់ស្ថាបនាមហោសថក្នុងតំណែងសេនាបតី បានឮថា ឥឡូវនេះ គេគិតក្បត់ចំពោះព្រះអង្គ បុគ្គល

ដែលជាបច្ចាមិត្ត មិនមែនជាបុគ្គលតូចតាចឡើយ ទ្រង់គួរប្រហារជីវិតគេចោល សូមទ្រង់កុំបរិវិតក្កឡើយ ព្រះរាជាទ្រង់មានសេចក្ដីសោកធូរស្រាលក៏ចុះកាន់និទ្រា ខណៈនោះ ព្រះរាជទេវីក្រោកឡើង ចូលទៅកាន់បន្ទប់ព្រះនាងរចនាបុតហ្វាយថា នែមហោសថ បណ្ឌិតទាំង ៤ បំបែកអ្នកឲ្យបែកពីព្រះរាជាៗ ទ្រង់ព្រះពិរោធ ត្រាស់នឹងបណ្ឌិតទាំង ៤ ឲ្យសម្លាប់អ្នកត្រង់ទ្វារព្រះរាជវាំង ក្នុងថ្ងៃស្អែកនេះ ។ ស្អែកនេះ អ្នកកុំមកកាន់រាជសម្នាក់ បើនឹងមក គប្បីជាអ្នកអាចធ្វើអ្នកនគរឲ្យនៅក្នុងកណ្ដាប់ដៃរបស់អ្នកហើយ គប្បីមក ។ ព្រះនាងចារអក្ខរា មានសេចក្ដីដូច្នេះហើយ ស៊កចូលក្នុងកញ្ចប់យកអំបោះចងកញ្ចប់ហើយ ដាក់ក្នុងសុវណ្ណភាជន៍ថ្មី បិទគម្រប ប្រថាប់ត្រាប្រទានដល់ស្រីបម្រើ ដែលប្រព្រឹត្តប្រយោជន៍ ត្រាស់ថា ចូរនាងនាំកញ្ចប់នេះទៅឲ្យដល់មហោសថបណ្ឌិត ដែលជាប្អូនប្រុសរបស់យើង ស្រីបម្រើបានធ្វើតាមពាក្យប្រាប់ ដែលបុគ្គលណាម្នាក់មិនគួរគិតថា ហេតុអ្វី ទើបស្រីបម្រើចេញអំពីដំណាក់ខាងក្នុង ទៅក្នុងពេលរាត្រីបាន ព្រោះព្រះរាជាប្រទានពរដល់នាងហើយ ឲ្យព្រះនាងប្រើអ្នកណានាំរបស់សោយ មានរសចេញទៅឲ្យមហោសថបានតាមបំណង ព្រោះដូច្នោះ បុគ្គលណាក៏មិនឃាត់ស្រីបម្រើនោះ ។ ព្រះពោធិសត្វទទួលព្រះសុវណ្ណភាជន៍ហើយ ឲ្យស្រីបម្រើនោះត្រឡប់ ស្រីបម្រើក៏លាត្រឡប់ មកទូលសេចក្ដីដែលខ្លួនឲ្យភាជន៍មាសដល់មហោសថដល់ព្រះនាង ។ ខណៈនោះ ទើបព្រះនាងយាងមកផ្ទំជាមួយព្រះរាជស្វាមី ចំណែកព្រះពោធិសត្វស្រាយប្រអប់សំបុត្រចេញ អានអក្សរដឹង

នូវសេចក្តីនោះហើយ រៀបចំកិច្ចដែលគប្បីធ្វើហើយ ចូលដេក ។ ចំណែកអាចារ្យទាំង ៤ កាន់ដាវឈរខាងក្នុងទ្វារព្រះរាជវាំងអំពីព្រលឹម កាលមិនឃើញមហោសថមក ក៏ទោមនស្ស ចូលគាល់ព្រះរាជា កាលព្រះរាជាត្រាស់សួរថា តើមានរឿងអ្វី អ្នកទាំងឡាយសម្លាប់មហោសថហើយឬ ទើបក្រាបទូលថា បពិត្រព្រះអង្គ មិនឃើញមហោសថមកឡើយ ។ ចំណែកព្រះមហាសត្វលុះអរុណរះឡើង ក៏ងូតទឹកក្រអូប ប្រដាប់កាយដោយគ្រឿងអលង្ការទាំងពួង បរិភោគភោជនដ៏ប្រសើរ ជម្រះសរីរកិច្ចហើយ ធ្វើអ្នកនគរឲ្យនៅក្នុងកណ្តាប់ដៃ រៀបចំការរក្សាក្នុងទីនោះៗ កាលមហាជនចោមរោមក៏ឡើងរថទៅកាន់ទ្វារព្រះរាជវាំងដោយយសធំ ចំណែកព្រះបាទវិទេហរាជឲ្យបើកបង្អួច ប្រថាប់ឈរទត ។ លំដាប់នោះ ព្រះពោធិសត្វ ចុះអំពីរថមកថ្វាយបង្គំបរមក្សត្រ ហើយឈរ ព្រះរាជាទតឃើញកិរិយារបស់មហោសថទ្រង់ព្រះតម្រិះថា មហោសថជាសត្រូវដល់អញ ហេតុអ្វី ទើបគេថ្វាយបង្គំអញ លំដាប់នោះ ក៏ត្រាស់ឲ្យហៅមហោសថមកគាល់ ហើយទ្រង់យាងប្រថាប់ក្នុងព្រះរាជអាសនៈ ចំណែកមហោសថថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង បណ្ឌិតទាំង ៤ ក៏អង្គុយនៅក្នុងទីនោះ លំដាប់នោះ ព្រះរាជាទ្រង់ធ្វើដូចជាមិនជ្រាបរឿងអ្វី ត្រាស់សួរមហោសថថា នែមហោសថ ម្សិលមិញនេះ អ្នកត្រឡប់ទៅផ្ទះតាំងពីយាមដំបូង អ្នកទើបតែមកអម្បាញ់មិញនេះ អ្នកខុសប្លែកយ៉ាងនេះ ព្រោះហេតុអ្វី ត្រាស់ដូច្នេះហើយ បានត្រាស់គាថានេះថា

អ្នកឯង ទើបតែទៅផ្ទះក្នុងពេលព្រលប់សោះ ឥឡូវនេះ ស្រាប់តែមកវិញភ្លាម[1] អ្នកឯងឮដំណឹងដូចម្ដេច ចិត្តរបស់អ្នកឯងរង្កៀសដូចម្ដេច ម្នាលអ្នកមានប្រាជ្ញាដូចផែនដី នរណា បានប្រាប់ដំណឹងដូចម្ដេច ដល់អ្នក យើងចង់ស្ដាប់ពាក្យនោះ អ្នកចូរប្រាប់ពាក្យនោះ ដល់យើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិទោសគតោ** សេចក្ដីថា នៃបាមហោសថ ម្សិលមិញ អ្នកទៅផ្ទះតាំងអំពីល្ងាច គឺបឋមយាម ។ បទថា **ឥទានិ ឯសិ** សេចក្ដីថា ឥឡូវនេះ មកដោយឥស្សរិយយស ។ បទថា **កិមាសង្កិតេ** បានដល់ រង្កៀសក្នុងអ្វី ។ បទថា **កិមវោច** សេចក្ដីថា អ្នកណាបានពោលនឹងឯងថា កុំទៅគាល់ព្រះរាជាឬ ពួកយើងនឹងស្ដាប់ពាក្យរបស់អ្នក ចូរអ្នកប្រាប់ការណ៍នោះដល់យើង ។

លំដាប់នោះ ព្រះមហាសត្វទូលព្រះរាជាថា បពិត្រមហារាជ ទ្រង់កាន់យកពាក្យបណ្ឌិតទាំង ៤ ហើយមានព្រះរាជបញ្ជាឲ្យសម្លាប់ទូលបង្គំ ដោយហេតុនោះ ទើបទូលបង្គំមិនមក ទូលដូច្នេះហើយ បានពោលគាថានេះថា

បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គស្ដេចទៅក្នុងទីស្ងាត់ បានប្រាប់នូវអាថ៌កំបាំង ដែលព្រះអង្គប្រឹក្សាហើយក្នុងពេលព្រលប់ ដល់ព្រះអគ្គមហេសីថា មហោសធ ត្រូវគេសម្លាប់ ព្រោះតែប្រស្នា

---

១- សេចក្ដីនេះ ស្ដាប់ទៅ ហាក់ដូចជាទៅភ្លាមមកភ្លាម បណ្ឌិតគប្បីកាន់យកតាមភាសាបាលីចុះ ។

ក្នុងកាលណា សេចក្តីកំបាំង ឈ្មោះថា ព្រះអង្គធ្វើឲ្យប្រាកដ ហើយ ក្នុងកាលនោះ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំ បានឮ ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យមិ តេ** បានដល់ អំពីកាលណា ព្រះអង្គ ។ បទថា **មន្តយិតំ** បានដល់ ត្រាស់ហើយ ។ បទថា **ទេសំ** សេចក្តីថា ពេលយប់ គឺពេលកណ្តាលយប់ សួរថា ត្រាស់ដល់អ្នកណា ឆ្លើយថា ដល់ព្រះមហេសី ដ្បិតថា ទ្រង់ប្រថាប់នៅក្នុងទីកំបាំង បានត្រាស់ សេចក្តីនោះ ដល់អគ្គមហេសីនោះ ។ បទថា **គុយ្ហំ ចាតុកតំ** សេចក្តីថា អាថ៌កំបាំងរបស់ទ្រង់បែបនេះ ទ្រង់ធ្វើឲ្យប្រាកដហើយ ។ បទថា **សុតំ មមេតំ** សេចក្តីថា មហោសថពោធិសត្វទូលថា បពិត្រព្រះអង្គ អាថ៌កំបាំង នោះ ទូលបង្គំបានស្តាប់ហើយ ក្នុងខណៈនោះឯង ។

ព្រះបាទវិទេហរាជ ទ្រង់ស្តាប់ពាក្យរបស់មហោសថ ទ្រង់ព្រះពិរោធ ដោយទ្រង់ឃើញថា ព្រះនាងឧទុម្ពរបញ្ជូនដំណឹងទៅខណៈនោះឯង ទើបទត មើលព្រះរាជទេវី មហោសថដឹងកិរិយានោះក៏ក្រាបទូលថា បពិត្រព្រះ សម្មតិទេព ទ្រង់ពិរោធព្រះរាជទេវីធ្វើអ្វី ទូលបង្គំជ្រាបហេតុការណ៍អតីត អនាគត និងបច្ចុប្បន្នទាំងអស់ ព្រះនាងត្រាស់អាថ៌កំបាំងរបស់ទ្រង់ ដល់ ទូលបង្គំ ចូរលើកទុកចុះ អាថ៌កំបាំងសេនកៈ និងបុក្កុសៈជាដើម អ្នកណា ប្រាប់ដល់ទូលបង្គំ បញ្ហារបស់បក្កួយ អ្នកណាប្រាប់ដល់ទូលបង្គំ បញ្ហា របស់ទេវតា អ្នកណាប្រាប់ដល់ទូលបង្គំៗ ជ្រាបអាថ៌កំបាំងរបស់ជនទាំងនេះ

ហើយនោះឯង កាលនឹងទូលអាថ៌កំបាំងរបស់អាចារ្យសេនកៈ បានពោលគាថានេះថា

អាចារ្យសេនកៈ បានធ្វើអំពើអាក្រក់ ជាអំពើមានសភាពមិនល្អ ក្នុងឱទ្យាន ដ៏ដេរដាសដោយដើមសាលព្រឹក្ស បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់សម្លាញ់ សេចក្តីកំបាំងណា ដែលអាចារ្យសេនកៈ ធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំ បានឮហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសព្ភិរូបំ** សេចក្តីថា សេនកៈបានធ្វើអកុសលកម្មដ៏លាមក មិនមែនជាកម្មល្អ គឺសម្លាប់ស្រីពេស្យាឈ្មោះនោះក្នុងឧទ្យាន ដើមរាំងក្នុងនគរនេះឯង ហើយកាន់យកគ្រឿងប្រដាប់ខ្ចប់ដោយសំពត់សាដករបស់ស្រីនោះ រក្សាទុកក្នុងទីនោះក្នុងផ្ទះរបស់ខ្លួន ។ បទថា **សខិនោវ រហោគតោ អសំសិ** សេចក្តីថា បពិត្រមហារាជ កាលនោះសេនកៈនៅក្នុងទីកំបាំង បានប្រាប់រឿងនោះដល់សម្លាញ់ម្នាក់ សូម្បីរឿងនោះទូលបង្គំក៏បានស្តាប់ហើយ ទូលបង្គំមិនបានគិតក្បត់ចំពោះព្រះសម្មតិទេពទេ សេនកៈនោះឯងជាអ្នកគិតក្បត់ បើទ្រង់មានរាជបំណងចាត់ការមនុស្សក្បត់ សូមទ្រង់ឲ្យចាប់សេនកៈចុះ ព្រះរាជាទតមើលសេនកៈ ហើយមានរាជបន្ទូលសួរថា ពិតឬសេនកៈ ក៏បានទូវពាក្យទូលតបថា ពិតព្រះអង្គ ទើបទ្រង់ត្រាស់ឲ្យយកសេនកៈទៅដាក់គុក ។ ចំណែកមហោសថ កាលក្រាបទូលអាថ៌កំបាំងរបស់បុក្កុសៈ ទើបពោលគាថានេះថា

បពិត្រព្រះអង្គជាធំជាងជន រោគ ( ឃ្លង់ ) កើតឡើង ដល់
បុក្កុសបុរស របស់ព្រះអង្គ រោគនោះ មិនសមគួរដល់ព្រះរាជា
ទេ គាត់បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់បងប្អូនប្រុស សេចក្តី
កំបាំងណា ដែលអាចារ្យបុក្កុសៈធ្វើឲ្យប្រាកដហើយ សេចក្តី
កំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរាជយុត្តោ** សេចក្តីថា បពិត្រមហារាជ រោគឃ្លង់កើតឡើងដល់បុក្កុសៈនោះ ជារោគដែលមិនសមគួរនឹងជិតស្និទ្ធ គឺមិនគួរពាល់ត្រូវព្រះរាជា ទ្រង់ផ្ទុំកើយភ្លៅរបស់បុក្កុសៈរឿយៗ ដោយយល់ថា ភ្លៅរបស់បុក្កុសៈទន់ តែសេចក្តីពិត ភ្លៅរបស់បុក្កុសៈនោះ មានសម្ផស្សទន់ ព្រោះសំពត់រុំជំបៅ ។

ព្រះរាជាទតមើលបុក្កុសៈហើយ ត្រាស់សួរថា ពិតឬបុក្កុសៈ កាលទ្រង់បានព្រះសណ្តាប់ការសារភាពថាពិត ទើបត្រាស់ឲ្យគេនាំខ្លួនទៅដាក់គុក ។ មហោសថបណ្ឌិត កាលក្រាបទូលអាថ៌កំបាំងរបស់អាចារ្យកាមិន្ទៈ ទើបពោលគាថានេះថា

អាចារ្យកាមិន្ទនេះ មានអាពាធដ៏អាក្រក់ គឺត្រូវនរទេវយក្ខចូល
បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់កូនប្រុស សេចក្តីកំបាំងណា
ដែលអាចារ្យកាមិន្ទ ធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូល
ព្រះបង្គំជាខ្ញុំ បានឮហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសព្ភិរូបោ** សេចក្តីថា កាមិន្ទៈនោះ កាល

អាពាធណាពាល់ត្រូវហើយលូដូចផ្កៃព្រៃ អាពាធនោះ គឺយក្ខឈ្មោះនរទេវៈ ចូលសណ្ឋិត ជាអាពាធលាមក កាមិន្ទៈកាលអាពាធនោះពាល់ត្រូវហើយ មិនគួរចូលទៅកាន់រាជត្រកូល ។

ព្រះរាជាទតមើលកាមិន្ទៈហើយត្រាស់សួរថា ពិតឬ កាមិន្ទៈៗ ទូលសារភាព ទើបត្រាស់ឲ្យនាំកាមិន្ទៈចូលក្នុងគុក ។ ចំណែកមហោសថបណ្ឌិតកាលក្រាបទូលអាថ៌កំបាំងរបស់ទេវិន្ទៈ ទើបពោលគាថានេះថា

ព្រះឥន្ទ្របានថ្វាយមណិរតន៍មានជ្រុង ៨ ដ៏ថ្លៃថ្លា ( ដល់ព្រះបាទកុសរាជ ) ជាព្រះអយ្យកោរបស់ព្រះអង្គ ថ្ងៃនេះ មណិរតន៍នោះទៅនៅក្នុងកណ្ដាប់ដៃ នៃអាចារ្យទេវិន្ទហើយ អាចារ្យទេវិន្ទទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់មាតា សេចក្ដីកំបាំងណា ដែលអាចារ្យទេវិន្ទធ្វើឲ្យប្រាកដហើយ សេចក្ដីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំ បានឮហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បិតាមហស្ស** បានដល់ ព្រះបាទកុសរាជដែលជាព្រះអយ្យកោរបស់ទ្រង់ ។ បទថា **តទជ្ជ ហត្ថំ** សេចក្ដីថា បពិត្រមហារាជ កែវមណីដែលសន្មតថាជាមង្គលនោះ ឥឡូវនេះ ធ្លាក់ក្នុងដៃរបស់ទេវិន្ទៈហើយ ព្រះរាជាត្រាស់សួរទេវិន្ទៈថា ពិតឬទេវិន្ទៈ កាលទេវិន្ទៈក្រាបទូលសារភាពថាពិត ទើបត្រាស់ឲ្យបញ្ជូនទេវិន្ទៈចូលគុក ។ អាចារ្យទាំង ៤ តាំងចិត្តសម្លាប់មហោសថ បែរជាត្រូវចូលគុកខ្លួនឯងទាំងអស់ ដោយប្រការដូច្នេះ ។

ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទូលបង្គំក្រាបទូលថា បុគ្គលមិនគួរប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់អ្នកដទៃព្រោះហេតុនេះឯង អាចារ្យទាំង ៤ ទូលថា គួរប្រាប់ ក៏ដល់នូវសេចក្ដីវិនាសធំ កាលសម្ដែងធម៌ឲ្យក្រៃលែងឡើង បានពោលគាថាទាំងនេះថា

សេចក្ដីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំង គេមិនសរសើរទេ អ្នកប្រាជ្ញ កាលបើសេចក្ដីប្រាថ្នាមិនទាន់សម្រេច ត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយតាមសប្បាយចុះ ។

បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំង គប្បីរក្សានូវអាថ៌កំបាំងនោះដូចជារក្សានូវកំណប់ ដ្បិតថា អាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនធ្វើឲ្យប្រាកដ ជាការប្រពៃ ។ អ្នកប្រាជ្ញ មិនគប្បីនិយាយប្រាប់នូវអាថ៌កំបាំង ដល់ស្រី ដល់ជនជាសត្រូវ ដល់ជនលើបរឡប់ដោយអាមិស ដល់ជនលួចគំនិតគ្នា ជនណា តែងញ៉ាំងអាថ៌កំបាំង ដែលមិនទាន់មានគេដឹង ឲ្យគេដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចជាមនុស្សខ្ញុំគេ ។ ជនទាំងឡាយប៉ុន្មាននាក់ ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្ដីតក់ស្លុតប៉ុណ្ណោះ តែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញ មិនគប្បីផ្សាយនូវអាថ៌កំបាំង ។

ក្នុងវេលាថ្ងៃ អ្នកប្រាជ្ញ គប្បីនិយាយអាថ៌កំបាំងក្នុងទីស្ងាត់ មិនគប្បីបញ្ចេញសំឡេងក្នុងវេលាយប់ឲ្យហួសកម្រិត ព្រោះថា ពួកអ្នកឈ្លបស្តាប់ រមែងឮនូវអាថ៌កំបាំង ដែលប្រឹក្សាគ្នា ព្រោះហេតុនោះ គំនិតនឹងដល់នូវការបែកធ្លាយយ៉ាងឆាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឋិយា** ប្រែថា ដល់ស្ត្រី ។ បទថា **អមិត្តស្ស ច** សេចក្តីថា មិនគួរប្រាប់ដល់សត្រូវ ។ បទថា **សំហីរោ** សេចក្តីថា បុគ្គលណា ត្រូវអាមិសណាមួយអូសទាញទៅ គឺដល់នូវការពោលបបួល និងសង្គ្រោះ មិនគប្បីប្រាប់អាថ៌កំបាំងដល់បុគ្គលនោះ ។ បទថា **ហាទយត្ថេ នោ** សេចក្តីថា បុគ្គលណាមិនមែនមិត្ត ជាមិត្តក្លែងក្លាយ មាត់និយាយផ្សេង ចិត្តគិតផ្សេង មិនគប្បីប្រាប់ដល់បុគ្គលនោះ ។ បទថា **អសម្ពុទ្ធំ** បានដល់ ដែលអ្នកដទៃមិនដឹង បាឋៈថា **អសម្ពោធំ** ដូច្នេះក៏មាន សេចក្តីថា មិនគួរឲ្យអ្នកដទៃដឹង ។ បទថា **អតិក្ខតិ** សេចក្តីថា រមែងអត់សង្កត់នូវពាក្យជេរខ្លះ នូវពាក្យប្រទេចខ្លះ នូវការប្រហារខ្លះ ដូចទាសៈ ។ បទថា **មន្តិធំ** សេចក្តីថា ជាអ្នកមានការដឹងទាំងឡាយ រមែងដឹងគោលដែលប្រឹក្សាគ្នាក្នុងរវាងអ្នកប្រាជ្ញទាំងឡាយដរាបណា ។ បទថា **តាវន្តោ** សេចក្តីថា ការតក់ស្លុតរបស់បុគ្គលនោះ ប្រមាណត្រឹមនោះ រមែងកើតឡើង ព្រោះអាស្រ័យបុគ្គលដឹងនូវអាថ៌កំបាំងទាំងនោះ ។ បទថា **ន វិសជេ** សេចក្តីថា មិនគប្បីលះបង់ គឺមិនគួរឲ្យអ្នកដទៃដឹង ។ បទថា **ទិវា** សេចក្តីថា បើត្រូវការប្រឹក្សាអាថ៌កំបាំងក្នុងពេលថ្ងៃ គប្បីប្រឹក្សាក្នុងទីបិទបាំង ឲ្យធ្វើឱកាស

ឲ្យស្វាត់ ។ បទថា **ឆាតិវេលំ** សេចក្តីថា កាលពោលនូវសេចក្តីកំបាំងក្នុងរាត្រី មិនគប្បីធ្វើសំឡេងហួសវេលា គឺហួសព្រំដែន ។ បទថា **ឧបស្សុតិកា** បានដល់ ជនដែលគប្បីចូលទៅកាន់ទីដែលប្រឹក្សា ឈរក្នុងទីក្រៅជញ្ជាំងជាដើម ហើយស្តាប់សេចក្តី ។ បទថា **តស្មា** សេចក្តីថា បពិត្រមហារាជ ដោយហេតុនោះ អាថ៌កំបាំងដែលប្រឹក្សាគ្នានោះ គប្បីដល់នូវការដឹងឮសុសសាយ មួយរំពេចនោះឯង ។

ព្រះបាទវិទេហរាជបានស្តាប់ពាក្យរបស់មហោសថ ទ្រង់ពិរោធថា អាចារ្យទាំងនេះប្រទូស្តគ្នាឯង មកចោទមហោសថថាជាអ្នកប្រទូស្តនឹងអញ ទើបមានព្រះរាជតម្រាស់បញ្ជារាជបុរសថា ពួកអ្នកចូរទៅ ចូរនាំអាចារ្យទាំង ៤ នោះ ចេញអំពីព្រះនគរ ឲ្យដេកផ្ងារលើលំពែង ហើយកាត់ក្បាលចោល ។ កាលអាចារ្យទាំង ៤ ត្រូវរាជបុរសចងដៃទៅក្រោយ វាយដោយរំពាត់ម្តង ៤ ហើយនាំទៅកាន់ទីប្រហារជីវិត មហោសថក្រាបទូលថា បពិត្រព្រះសម្មតិទេព អាចារ្យទាំងនេះ ជាអមាត្យចាស់របស់ព្រះអង្គ សូមទ្រង់អត់ទោសដល់អាចារ្យទាំងនេះចុះ ព្រះរាជាក៏អនុញ្ញាត ហើយឲ្យហៅអាចារ្យទាំង ៤ មក ដកយសឲ្យធ្វើជាទាសៈរបស់មហោសថ តែមហោសថដោះឲ្យជាអ្នកជាក្នុងវេលានោះឯង ព្រះរាជាត្រាស់ឲ្យបណ្តេញអាចារ្យទាំង ៤ ចេញអំពីព្រះរាជអាណាចក្រ មហោសថទូលសូមព្រះរាជទានទោសថា សូមទ្រង់អត់ទោសដល់អន្ធពាលទាំងនោះ សូមទ្រង់លើកទុកក្នុងឋានន្តរដើម ព្រះរាជាទ្រង់ជ្រះថ្លាក្នុងមហោសថពន់ប្រមាណ ដោយទ្រង់ព្រះតម្រិះថា មហោសថ

មានមេត្តាបែបនេះក្នុងពួកបច្ចាមិត្ត មហោសថនឹងមិនមានមេត្តាបែបនេះ ក្នុងជនដទៃបានដូចម្តេច ចាប់តាំងពីកាលនោះ អ្នកប្រាជ្ញទាំង ៤ ជាអ្នកអស់ព្យសន៍ ដូចពស់ដកជន្លូមចេញហើយ មិនអាចពោលអ្វីទៀត ។

**បញ្ចបណ្ឌិតបញ្ហា ចប់**

**បរិកិន្នកថា ចប់**

ចាប់តាំងពីកាលនោះ មហោសថបណ្ឌិតថ្វាយអនុសាសន៍ អត្ថ និងធម៌ដល់ព្រះបាទក្រុងមិថិលាម មហោសថគិតថាអញនឹងមើលថែស្វេតច្ឆត្រ ជារាជសម្បត្តិរបស់ព្រះរាជា អញគួរតែមិនប្រមាទ ត្រិះរិះដូច្នេះ ទើបធ្វើមហាកំពែងក្នុងព្រះនគរ និងឲ្យធ្វើកំពែងតូចយ៉ាងនោះ ត្រង់ខឿនជុំវិញ ត្រង់ទ្វារ និងទីចន្លោះៗ ឲ្យជីកគូ ៣ គឺគូទឹក គូភក់ និងគូស្ងួត ឲ្យលាក់របស់បុរាណខាងក្នុងព្រះនគរ ឲ្យជីកស្រះបោក្ខរណីធំ ឲ្យកប់លូទឹកក្នុងស្រះនោះ ធ្វើជង្រុកទាំងពួងក្នុងព្រះនគរឲ្យពេញដោយធញ្ញាហារ ឲ្យនាំពូជស្មៅគែលលក និងកុមុទអំពីពួកតាបសដែលស្និទ្ធស្នាលក្នុងត្រកូល ដែលមកអំពីហិមវន្តប្បទេស យកមកដាំ ឲ្យជម្រះលាងលូទឹក ឲ្យទឹកហូរចូលមកស្រួល ឲ្យជួសជុលទីទាំងឡាយ មានសាលាចាស់ខាងក្រៅព្រះនគរជាដើម ព្រោះហេតុការណ៍ដូចម្តេចទើបមហោសថឲ្យតាក់តែងព្រះនគរដូច្នេះ ព្រោះដើម្បីការពារភ័យ ដែលមកដល់ក្នុងអនាគត ។ មហោសថសាកសួរពួកពាណិជ្ជ ដែលមកអំពីប្រទេសនោះៗ ថា ពួកអ្នកមកអំពីណា កាលបានទទួលនូវចម្លើយថា មកអំពីទីឈ្មោះនោះ ទើបសាកសួរថា អ្វីជាទីពេញចិត្តព្រះរាជារបស់ពួកអ្នក បាន

សេចក្តីហើយ ក៏ធ្វើការរាប់អានចំពោះជនទាំងនោះ ហើយបញ្ជូនត្រឡប់ទៅ ហើយហៅយោធា ១០១ របស់ខ្លួនមកប្រាប់ថា ចូរអ្នកទាំងឡាយទទួលគ្រឿងបណ្ណាការ ដែលយើងនឹងឲ្យហើយ ទៅកាន់រាជធានីទាំង ១០១ ថ្វាយបណ្ណាការទាំងនេះដល់ព្រះរាជាទាំងនោះ ដើម្បីឲ្យព្រះរាជាទាំងនោះស្រឡាញ់ ហើយនៅបម្រើព្រះរាជាទាំងនោះ មើលកិរិយាការគិតរបស់ព្រះរាជាទាំងនោះ បញ្ជូនដំណឹងមកឲ្យយើងដឹង ហើយនៅក្នុងទីនោះចុះ យើងនឹងចិញ្ចឹមបុត្រ និងភរិយារបស់ពួកអ្នក ដូច្នេះហើយ ចារឹកកុណ្ឌលបាទុកា ព្រះខ័ន និងសុវណ្ណមាលា ឲ្យជាអក្សរក្នុងព្រះរាជករណៈនោះៗ ដើម្បីព្រះរាជាទាំងនោះ ហើយតាំងសច្ចាធិដ្ឋានថា កិច្ចរបស់ខ្ញុំរមែងមានក្នុងកាលណា អក្សរទាំងនេះ ចូរប្រាកដក្នុងកាលនោះ ហើយប្រគល់ឲ្យយោធាទាំង ១០១ នោះទៅ ។ យោធាទាំងនោះ ទៅក្នុងប្រទេសនោះៗ ថ្វាយបណ្ណាការដល់ព្រះរាជាទាំងនោះ កាលព្រះរាជាទាំងនោះត្រាស់សួរថា មកមានធុរៈអ្វី ក៏ទូលថា មកបម្រើទ្រង់ កាលត្រាស់សួរថា មកអំពីណា ក៏មិនទូលតាមត្រង់ ទូលថា មកអំពីទីដទៃ កាលទ្រង់ទទួល ក៏នៅទទួលរាជការខាងក្នុង ។

កាលនោះ ព្រះរាជាមួយអង្គ ព្រះនាមសង្ខពលកៈ ក្នុងកម្ពលរដ្ឋ ឲ្យត្រៀមសស្ត្រាវុធ និងប្រមូលកងទ័ព ។ ទាហានរបស់មហោសថដែលបន្តប់ឲ្យស្តាប់ដំណឹង និងរាំងនូវហេតុការណ៍ ដែលបញ្ជូនទៅក្នុងរាជសម្នាក់នៃព្រះបាទសង្ខពលករាជនោះ បានបញ្ជូនដំណឹងមកដល់មហោសថថា ខ្ញុំមិនជ្រាបការប្រព្រឹត្តក្នុងនគរនេះថា ព្រះបាទសង្ខពលករាជ ទ្រង់ធ្វើរាជកិច្ចឈ្មោះ

នេះ សូមលោកបញ្ជូនសុវបណ្ឌិត គឺសត្វសេកទៅ នឹងជ្រាបសេចក្តីឯង ដោយពិត ។ លំដាប់នោះ មហាសត្វបានស្តាប់ដំណឹងនោះ ទើបហៅសុវបោតកៈមកពោលថា ចូរឯងទៅស៊ើបដំណឹងមើលថា ព្រះរាជាមួយអង្គ ព្រះនាមសព្វទត្តពលកៈ ក្នុងកម្ពលរដ្ឋ ធ្វើរាជកិច្ចឈ្មោះនេះ ហើយចូរត្រាច់ទៅក្នុងសកលជម្ពូទ្វីប នាំហេតុការណ៍មកដើម្បីយើង ពោលដូច្នេះហើយ ឲ្យសុវបោតកៈបរិភោគលាជ ដែលលាយដោយទឹកឃ្មុំ ឲ្យផឹកនូវទឹកឃ្មុំ ហើយយកប្រេងដែលចម្រាញ់រាប់រយ រាប់ពាន់ដង លាបស្លាបបក្សី ហើយឲ្យទំត្រង់បង្អួចនាទិសខាងកើត រួចលែងទៅ ។ សុវបណ្ឌិតនោះ ទៅក្នុងទីនោះ ដឹងព្រឹត្តិហេតុនៃព្រះបាទសព្វទត្តពលករាជ អំពីសម្នាក់ទាហានរបស់មហោសថនោះដោយពិតប្រាកដហើយ កាលនឹងត្រួតមើលនូវជម្ពូទ្វីបទាំងមូល ក៏ទៅដល់ឧត្តរបញ្ចាលនគរ ក្នុងកបិលរដ្ឋ ។

កាលនោះ ព្រះរាជាព្រះនាមចូឡនីព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងឧត្តរបញ្ចាលនគរនោះ ព្រាហ្មណ៍ឈ្មោះកេវដ្ដៈ ជាអ្នកប្រាជ្ញ ជាអ្នកឈ្លាសថ្វាយអត្ថ និងធម៌ដល់ព្រះរាជានោះ ។ ក្នុងពេលទៀបភ្លឺថ្ងៃមួយ បុរោហិតនោះភ្ញាក់ឡើង សម្លឹងមើលបន្ទប់ដែលប្រកបដោយសិរីដែលប្រដាប់តាក់តែងហើយ ឃើញយសធំរបស់ខ្លួនដោយពន្លឺនៃប្រទីប ទើបគិតថា យសរបស់អញនេះ ជារបស់អ្នកណា ក៏គិតបានថា មិនមែនរបស់អ្នកដទៃ ជារបស់ព្រះបាទចូឡនីព្រហ្មទត្តព្រះរាជទានដល់អញ អញគួរចាត់ចែងឲ្យព្រះរាជាដែលព្រះរាជទានយសបែបនេះដល់អញ ឲ្យជាអគ្គរាជាក្នុងសកលជម្ពូទ្វីប អញ

នឹងបានជាអគ្គបុរោហិតរបស់ព្រះអង្គ គិតដូច្នេះហើយ ចូលគាល់ព្រះរាជា អំពីព្រលឹម ទូលសួរដល់សុខក្នុងព្រះបន្ទំតាមទំនៀមហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព សេចក្តីដែលទូលបង្គំគប្បីទូលប្រឹក្សាមាន កាលព្រះរាជាអនុញ្ញាត ទើបក្រាបទូលថា បពិត្រមហារាជ ស្ថានទីកំបាំងក្នុងព្រះនគរមិនមាន សូមទ្រង់យាងទៅព្រះរាជឧទ្យាន ។ ព្រះរាជាទ្រង់ឃើញប្រពៃដែរ ទើបយាងទៅព្រះរាជឧទ្យានជាមួយបុរោហិត ទុកពលនិកាយខាងក្រៅឲ្យរក្សា ហើយចូលទៅកាន់ព្រះរាជឧទ្យាន ជាមួយព្រាហ្មណ៍ប៉ុណ្ណោះ ប្រថាប់គង់ត្រង់ផ្ទាំងថ្មជាមង្គល ។ កាលនោះ សុវបោតកៈឃើញកិរិយារបស់ព្រះរាជា និងព្រាហ្មណ៍ ទើបគិតថា ហេតុការណ៍ គប្បីមានក្នុងកិរិយារបស់ព្រះរាជាជាមួយព្រាហ្មណ៍នេះ ថ្ងៃនេះ អញនឹងស្តាប់រឿងរ៉ាវដែលគួរប្រាប់ដល់មហោសថ គិតដូច្នេះហើយ ហើរចូលទៅកាន់ព្រះរាជឧទ្យាន ពួនត្រង់ស្លឹករាំងដែលជាមង្គល ព្រះរាជាត្រាស់ឲ្យកេវដ្តៈទូលរឿង ព្រាហ្មណ៍ក៏ក្រាបទូលយ៉ាងនោះថា សូមទ្រង់ធ្វើទុកក្នុងព្រះកាណ៌របស់ព្រះអង្គ តែទីនេះ ការគិតនេះនឹងឈ្មោះថា ដឹងដោយត្រចៀក ៤ បើទ្រង់ធ្វើតាមពាក្យរបស់ទូលបង្គំ ទូលបង្គំនឹងធ្វើព្រះអង្គឲ្យជាអគ្គរាជក្នុងសកលជម្ពូទ្វីប ព្រះបាទចូឡនីទ្រង់បានស្តាប់ពាក្យរបស់កេវដ្តៈ ទ្រង់ក៏សោមនស្ស ដោយភាពជាអ្នកមានសេចក្តីប្រាថ្នាធំ ទើបត្រាស់ថា ពោលចុះអាចារ្យ យើងនឹងធ្វើតាមពាក្យរបស់លោក ទើបកេវដ្តព្រាហ្មណ៍ទូលបរិយាយការគិតថា បពិត្រព្រះសម្មតិទេព យើងទាំងឡាយនឹងហៅ គឺប្រមូលផ្តុំកងទ័ព ហើយព័ទ្ធនគរតូចៗ ធ្វើជានគរបំណុះ

សិន ទូលបង្គំនឹងចូលទៅកាន់នគរតាមទ្វារតូច ហើយប្រាប់ដល់ព្រះរាជាទាំង នោះថា កិច្ចដោយការច្បាំងរបស់ព្រះអង្គមិនមាន ភោគសម្បត្តិជារបស់ពួកខ្ញុំ ទាំងអស់ ទ្រង់គង់នៅជាព្រះរាជាយ៉ាងនោះ បើទ្រង់ច្បាំង ទ្រង់នឹងចាញ់ ដោយចំណែកមួយ ព្រោះទ្រង់មានពល និងពាហនៈតិច ឯពួកទូលបង្គំ មានច្រើន បើព្រះរាជាទាំងនោះ ធ្វើតាមពាក្យរបស់ពួកយើង ពួកយើងនឹង ចាប់ព្រះរាជាទាំងនោះទុក បើព្រះរាជាទាំងនោះ មិនធ្វើតាមពាក្យរបស់យើង សោត ពួកយើងនឹងច្បាំង ហើយឲ្យព្រះរាជាទាំងនោះអស់ព្រះជន្ម ហើយ កាន់យកកងទ័ពក្នុងនគរនោះ បានជាកម្លាំងពីរ ហើយទៅដណ្តើមនគរតទៅ កាន់យករាជសម្បត្តិក្នុងសកលជម្ពូទ្វីបដោយឧបាយនេះ ហើយផឹកនូវជយ-បានៈ ។ ពួកយើងនាំព្រះរាជាទាំង ១០១ មកកាន់នគរយើង ហើយឲ្យផឹក សុរាដែលលាយដោយថ្នាំពិស ក្នុងឧទ្យានហើយ នឹងញ៉ាំងព្រះរាជាទាំងនោះ ឲ្យអស់នូវព្រះជន្ម ហើយបោលសាកសពព្រះរាជាទាំងនោះក្នុងស្ទឹងគង្គា ហើយនឹងធ្វើរាជសម្បត្តិក្នុងរាជធានីទាំង ១០១ ឲ្យនៅក្នុងកណ្តាប់ព្រះហស្ត របស់ព្រះអង្គ ទ្រង់នឹងជាអគ្គរាជក្នុងជម្ពូទ្វីបទាំងមូល ដោយប្រការដូច្នេះ ។ ព្រះរាជាទ្រង់ត្រេកអរ ត្រាស់ថា សាធុ អាចារ្យ យើងនឹងធ្វើយ៉ាងនោះ កេវដ្តព្រាហ្មណ៍ក្រាបទូលថា ការគិតនេះ ឈ្មោះថា ការគិតដឹងត្រឹមតែត្រចៀក ៤ ព្រោះថា បុគ្គលដទៃមិនអាចដឹង ហេតុនោះ សូមទ្រង់កុំយឺតយ៉ាវ ប្រញាប់ លើកកងទ័ពចេញតែម្តង ព្រះរាជាបានស្តាប់ពាក្យនោះ ទ្រង់ក៏សោមនស្ស ត្រេកអរថា សាធុ ។

សុវបោតកៈបានស្តាប់រឿងទាំងអស់នោះ ក្នុងកាលព្រាហ្មណ៍ និងព្រះរាជាគិតការនេះចប់ ទើបហើរទំត្រង់មែករាំងដែលសំយុង ញុំាងលាមកឲ្យធ្លាក់ចុះលើក្បាលកេវដ្តៈៗ ពោលថា នេះអ្វីហ្ន៎ ក៏ងើយឡើងលើ សេកក៏ទម្លាក់លាមកដាក់ក្នុងមាត់ យំកិរិ កិរិ ហើរឡើងអំពីមែករាំងពោលថា នែកេវដ្តៈ លោកសម្គាល់ថា គំនិតរបស់លោកដឹងតែត្រចៀក ៤ ឬ ឥឡូវនេះ ដឹងត្រចៀក ៦ ហើយនឹងដឹងត្រចៀក ៨ ទៀត ហើយនឹងដឹងច្រើនរយត្រចៀកនោះឯង កាលជនទាំងឡាយពោលថា ជួយគ្នាចាប់ ចាប់ឲ្យបានដូច្នេះ ក៏ហើរទៅកាន់ក្រុងមិថិលាដោយកម្លាំងរហ័សដូចខ្យល់ ចូលទៅកាន់ផ្ទះរបស់មហោសថបណ្ឌិត ឯការប្រព្រឹត្តនេះជាវត្តរបស់សុវបោតកៈ គឺបើនាំដំណឹងមកអំពីណា គួរប្រាប់ដល់មហោសថតែម្នាក់ ពេលនោះ សុវបោតកៈ ក៏ទំត្រង់ចង្កួយស្មានៃមហោសថ បើគួរស្តាប់ទាំងនាងអមរាទេវី សុវបោតកៈក៏ទំត្រង់ភ្លៅ បើមហាជនគួរស្តាប់ សុវបោតកៈទំត្រង់ផែនដី កាលនោះ សុវបោតកៈទំត្រង់ចង្កួយស្មានៃមហោសថ ដោយសញ្ញានោះ មហាជនក៏ចៀសចេញទៅដោយដឹងថា អាថ៌កំបាំងគប្បីមាន មហោសថនាំសុវបោតកៈ ឡើងទៅលើប្រាសាទជាន់លើ ហើយសួរថា បាបានឃើញ បានស្តាប់អ្វីមកឬ គ្រានោះ សុវបោតកៈក៏ពោលនឹងមហោសថថា បពិត្រលោកម្ចាស់ ខ្ញុំមិនឃើញភ័យឯណាមួយក្នុងសម្នាក់ព្រះរាជាដទៃក្នុងសកលជម្ពូទ្វីប តែព្រាហ្មណ៍ឈ្មោះកេវដ្តៈ ដែលជាបុរោហិតរបស់ព្រះបាទចូឡនីព្រហ្មទត្ត ក្នុងឧត្តរបញ្ចាលនគរនាំព្រះរាជាទៅឧទ្យាន ហើយទូលនូវគំនិតដែលដឹងតែត្រចៀក ៤ ខ្ញុំទំត្រង់

វវាងមែកវាំង ញុំាងលាមកឲ្យធ្លាក់ក្នុងមាត់ព្រាហ្មណ៍កេវដ្ដៈហើយមក ពោលដូច្នេះហើយ ប្រាប់កិច្ចដែលបានឃើញ ដែលបានស្ដាប់ទាំងពួងដល់មហោសថៗ សួរថា ព្រះបាទចូឡនីទទួលធ្វើតាមដែរឬទេ សុវបោតកៈឆ្លើយថា ទទួលធ្វើតាម ទើបមហោសថធ្វើសក្ការៈដែលគួរធ្វើដល់បក្សីនោះ ហើយឲ្យដេកក្នុងទ្រុងមាស ដែលមានកម្រាលទន់ ហើយគិតថា ប្រហែលជាកេវដ្ដៈមិនស្គាល់ភាពដែលអញឈ្មោះមហោសថបណ្ឌិត អញនឹងមិនឲ្យការគិតដែលកេវដ្ដព្រាហ្មណ៍គិតនោះ សម្រេចបានក្នុងកាលឥឡូវនេះ ទើបបញ្ជូនត្រកូលក្រីក្រក្នុងក្រុងចេញ ឲ្យមកនៅខាងក្រៅ នាំត្រកូលមានឥស្សរិយយសមានទ្រព្យសម្បត្តិ ដែលនៅជិតទ្វារជនបទក្នុងដែន ឲ្យចូលមកខាងក្នុងនគរ ហើយឲ្យសន្សំធញ្ញាហារជាច្រើន ។

ចំណែកព្រះបាទចូឡនីព្រហ្មទត្តជឿពាក្យកេវដ្ដៈ ញុំាងពួកសេនាឲ្យចោមរោមហើយ យាងទៅព័ទ្ធនគរមួយ ចំណែកកេវដ្ដៈ ក៏ចូលទៅក្នុងនគរនោះដោយន័យដែលពោលហើយ ញុំាងព្រះរាជាក្នុងនគរនោះឲ្យយល់ព្រមហើយ ធ្វើនគរនោះឲ្យជារបស់ខ្លួន ធ្វើកងទ័ពទាំងពីរឲ្យជាកងទ័ពតែមួយ ហើយព័ទ្ធនគរដទៃ ដណ្ដើមនគរទាំងពួងបានដោយលំដាប់ ព្រះបាទចូឡនីតាំងនៅក្នុងឱវាទរបស់កេវដ្ដព្រាហ្មណ៍ វៀរលែងតែព្រះបាទវិទេហរាជ ក្រៅអំពីនោះក៏បានព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីបដ៏សេស ឲ្យជារបស់ព្រះអង្គដោយប្រការដូច្នេះ ។

បុរសដែលមហោសថបន្កប់ ក៏បញ្ជូនដំណឹងដល់មហោសថជានិច្ចថា

នគរទាំងឡាយមានប្រមាណប៉ុណ្ណេះ ព្រះបាទចូឡនីព្រហ្មទត្ត ដណ្តើមបាន ហើយ សូមលោកកុំជាបុគ្គលប្រមាទ ចំណែកមហោសថបណ្ឌិត បញ្ជូនដំណឹង ទៅកាន់ចារបុរសដែលបន្តប់នោះថា យើងជាបុគ្គលមិនបានប្រមាទក្នុងទីនេះ ហើយ សូមឲ្យអ្នកទាំងឡាយក៏កុំវិតក្កដល់យើង ចូរជាបុគ្គលមិនប្រមាទចុះ ។

ចំណែកព្រះបាទចូឡនីព្រហ្មទត្ត លើកទ័ពទៅដណ្តើមនគរនោះៗ អស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ក៏បានរាជសម្បត្តិក្នុងសកលជម្ពូទ្វីប វៀរលែងតែ វិទេហរដ្ឋ ទើបត្រាស់នឹងកេវដ្តបុរោហិតថា នគរទាំងឡាយប៉ុណ្ណេះយើងបាន ហើយ យើងនឹងដណ្តើមយករាជសម្បត្តិរបស់ព្រះបាទវិទេហរាជ ក្នុងក្រុង មិថិលា បុរោហិតទូលជំទាស់ថា បពិត្រមហារាជ ពួកយើងមិនគួរដណ្តើម រាជសម្បត្តិក្នុងនគរដែលមហោសថរស់នៅ ព្រោះថាមហោសថនោះ ជាអ្នក បរិបូណ៌ដោយប្រាជ្ញា និងជាអ្នកឈ្លាសក្នុងឧបាយយ៉ាងនេះៗ បុរោហិតឃាត់ ព្រះបាទចូឡនី ពណ៌នាគុណរបស់មហោសថ ដូចបុគ្គលលើកមណ្ឌលព្រះ ចន្ទឡើងពោល ព្រោះថា បុរោហិតនេះ ជាអ្នកឈ្លាសក្នុងឧបាយឯង ដូច្នោះ ទើបញ៉ាំងព្រះរាជាឲ្យកំណត់ដោយឧបាយថា បពិត្រព្រះសម្មតិទេព រាជ- សម្បត្តិក្នុងមិថិលានគរជារបស់តូចតាច រាជសម្បត្តិក្នុងសកលជម្ពូទ្វីប ជា របស់គ្រប់គ្រាន់ដល់យើងទាំងឡាយ ប្រយោជន៍អ្វីដោយរាជសម្បត្តិក្នុងនគរ មិថិលាដល់យើងទាំងឡាយនោះ ចំណែកព្រះរាជាទាំងឡាយដ៏សេសក៏ពោល ថា យើងទាំងឡាយនឹងដណ្តើមរាជសម្បត្តិក្នុងនគរមិថិលា ហើយផឹកជយ- បានៈ ចំណែកកេវដ្តៈទទួលឃាត់ព្រះរាជាទាំងនោះ ហើយឲ្យព្រះរាជាទាំង

នោះដឹងដោយឧបាយថា យើងទាំងឡាយនឹងដណ្តើមរាជសម្បត្តិក្នុងវិទេហរដ្ឋធ្វើអ្វី ព្រះរាជានោះក៏ដូចជារបស់យើងទាំងឡាយ សូមទ្រង់ទាំងឡាយយាងត្រឡប់ចុះ ព្រះរាជាទាំងនោះបានស្តាប់ពាក្យរបស់កេវដ្តៈ ក៏យាងត្រឡប់ទៅកាន់នគររៀងៗ ខ្លួន ពួកចារបុរសដែលបង្កប់ស្តាប់ហេតុការណ៍ ក៏បញ្ជូនដំណឹងដល់មហោសថថា ព្រះបាទចូឡនីព្រហ្មទត្ត កាលព្រះរាជា ១០១ ចោមរោមមកកាន់ក្រុងមិថិលា តែក៏ត្រឡប់ទៅកាន់នគររៀងៗ ខ្លួន ចំណែកព្រះមហាសត្វបញ្ជូនដំណឹងតបទៅពួកបុរស ដែលបង្កប់ខ្លួនថា ចាប់ពីពេលនេះចូរពួកអ្នកចាំមើលកិរិយារបស់ព្រះបាទចូឡនី ។ ចំណែកព្រះបាទចូឡនីទ្រង់ប្រឹក្សានឹងអាចារ្យកេវដ្តៈថា ឥឡូវនេះ យើងនឹងធ្វើកិច្ចដូចម្តេច កាលកេវដ្តៈទូលថា យើងនឹងផឹកជយបានៈ ទើបឲ្យរៀបចំឧទ្យាន ហើយត្រាស់នឹងពួករាជសេវកៈថា ចូរពួកអ្នកត្រៀមសុរាក្នុងក្រឡ ១០០ រំមាត់ក្រឡឲ្យជិត ត្រៀមគ្រឿងបរិភោគដែលមានរស គឺត្រី និងសាច់ជាដើម មានបែបផ្សេងៗ ឲ្យគ្រប់គ្រាន់ ។

កាលនោះ បុរសដែលមហោសថបង្កប់ ក៏បញ្ជូនព្រឹត្តិហេតុនោះឲ្យមហោសថជ្រាប តែបុរសដែលមហោសថឲ្យបង្កប់ខ្លួននោះ មិនដឹងថា ព្រះបាទចូឡនីប្រកបស្រាដោយថ្នាំពិស ប្រាថ្នានឹងសម្លាប់ព្រះរាជា ១០១ ឲ្យអស់ព្រះជន្ម ចំណែកព្រះពោធិសត្វដឹងសេចក្តីនោះ អំពីសុវបោតកៈក៏បញ្ជូនដំណឹងតបទឹងពួកបុរសដែលបង្កប់នោះថា អ្នកទាំងឡាយដឹងថ្ងៃដែលផឹកស្រាពិតប្រាកដ ចូរប្រាប់ដល់យើង បុរសដែលបង្កប់នោះ ក៏ធ្វើតាមពាក្យប្រាប់

មហោសថត្រិះរិះថា កាលបណ្ឌិតដូចយើងមាន ព្រះរាជាមានប្រមាណ ប៉ុណ្ណេះ មិនគួរអស់ព្រះជន្មឡើយ យើងនឹងជាទីពឹងរបស់ព្រះរាជាទាំងនោះ គិតដូច្នេះហើយ ហៅពួកទាហានដែលជាបរិវារសហជាត ១០០០ នាក់នោះ មកប្រាប់ថា នែសម្លាញ់ទាំងឡាយ បានឮថា ព្រះរាជាចូឡនីឲ្យតាក់តែងព្រះ រាជឧទ្យាន ហើយចោមរោមទៅដោយព្រះរាជា ១០១ បំណងនឹងផឹកស្រា ចូរអ្នកទាំងឡាយទៅក្នុងទីនោះ ក្នុងកាលអាសនៈរបស់ព្រះរាជាទាំងឡាយ ដែលគេតែងតាំងហើយ ក្នុងកាលព្រះរាជាមួយអង្គមិនទាន់អង្គុយ អ្នកទាំង ឡាយ ចូរដណ្តើមយកអាសនៈដែលតាំងនៅក្នុងលំដាប់ បន្ទាប់អំពីអាសនៈនៃ ព្រះបាទចូឡនី ប្រកាសថា នេះជារាជអាសនៈដែលមានតម្លៃច្រើន នៃព្រះ រាជារបស់ពួកយើង ដូច្នេះ ក្នុងកាលពួករាជការនោះពោលថា លោកទាំង ឡាយជាមនុស្សរបស់អ្នកណា គប្បីឆ្លើយថា ជាមនុស្សរបស់ព្រះបាទ វិទេហរាជ កាលពួករាជការទាំងនោះពោលនឹងអ្នកថា យើងទាំងឡាយ កាល ទៅព័ទ្ធដណ្តើមយកនគរនោះៗ អស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ក៏មិនឃើញព្រះ រាជាដែលមានឈ្មោះវិទេហៈត្រឹមតែមួយថ្ងៃ ព្រះរាជាដែលពួកអ្នកអាងនោះ ឈ្មោះថាជាព្រះរាជាដូចម្តេចបាន ចូរអ្នកទាំងឡាយទៅ ចូរកាន់យកអាសនៈ ក្នុងទីបំផុតនៃអាសនៈ កាលពោលដូច្នេះហើយ ក៏នឹងប្រកែកគ្នា ពួកអ្នក ក៏ចូរប្រកែកថា ព្រះរាជាដទៃ វៀរព្រះបាទចូឡនីព្រហ្មទត្តចេញហើយ អ្នក ដទៃដែលអស្ចារ្យជាងព្រះរាជារបស់ពួកយើងក្នុងទីនេះ មិនមាន ពោលដូច្នេះ ហើយ ចូរប្រកែកឲ្យខ្លាំងឡើង ហើយពោលថា បើពួកយើងមិនបានសូម្បី

ត្រឹមតែអាសនៈដើម្បីព្រះរាជាពួកយើងៗ នឹងមិនឲ្យអ្នកទាំងឡាយផឹកស្រា និង ទំពាស៊ីត្រី និងសាច់ក្នុងឥឡូវនេះ ហើយស្រែកសន្ធាប់ ញ៉ាំងការតក់ស្លុតឲ្យកើតដល់អ្នករាជការទាំងនោះ ដោយសំឡេងខ្លាំង ហើយវាយបំបែកឪទិនស្រាទាំងពួងដោយដំបង ហើយចាក់អាហារដែលធ្វើអំពីត្រី និងសាច់ចោល ធ្វើឲ្យបរិភោគមិនបាន ហើយចូលទៅកាន់វាំងពួកសេនាដោយរហ័ស ដូចពួកអសុរចូលទៅកាន់ទេវនគរ ហើយធ្វើសំឡេងឲ្យគឹកកងប្រកាសថា យើងទាំងឡាយជាមនុស្សរបស់មហោសថបណ្ឌិត ក្នុងក្រុងមិថិលា បើអ្នកទាំងឡាយអាច ក៏ចូរចាប់ពួកយើង ឲ្យខ្ញុំរាជការទាំងនោះដឹងភាពដែលពួកអ្នកមកហើយ ចូរត្រឡប់មកវិញ មហោសថប្រាប់ឲ្យសហជាតយោធារបស់ខ្លួនដឹងដូច្នេះហើយ បញ្ជូនទៅពួកទាហានដែលជាសហជាតបរិវាររបស់មហោសថ ទទួលពាក្យ ធ្វើអញ្ជលីមហោសថហើយ សៀតអាវុធទាំង ៥ ចេញអំពីនគរមិថិលា ទៅកាន់រាជឧទ្យាននៃព្រះបាទចូឡនី ចូលទៅកាន់រាជឧទ្យានដែលតាក់តែងហើយ ដូចនន្ទនវនទេវឧទ្យានដូច្នោះ ឃើញសិរីរាជសម្បត្តិដែលប្រដាប់ហើយ តាំងអំពីព្រះរាជបល្ល័ង្កព្រះរាជា ១០១ ដែលមានស្វេតច្ឆត្រលើកហើយ បានធ្វើកិច្ចទាំងពួងដោយន័យដែលព្រះពោធិសត្វពោលហើយ ញ៉ាំងមហាជនឲ្យជ្រួលច្របល់ ហើយបែរមុខត្រឡប់មកកាន់ក្រុងមិថិលា ។

ចំណែករាជបរិស័ទក្នុងក្រុងបញ្ចាល ក៏ក្រាបទូលព្រឹត្តិហេតុដល់ព្រះរាជាទាំងនោះ ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់ព្រះពិរោធថា ពួកអ្នកក្រុងមិថិលាមកធ្វើអន្តរាយដល់សុរាដែលដាក់ថ្នាំពិសបែបនេះរបស់យើង ។ ចំណែកព្រះ

រាជា ១០១ ក៏ខឹងក្រោធថា ពួកនគរមិថិលាមកធ្វើឲ្យពួកយើងខានបានផឹកជយបានៈ ចំណែកពលនិកាយក៏អាក់អន់ថា យើងទាំងឡាយមិនបានផឹកស្រាដ៏មានតម្លៃ ចំណែកព្រះបាទចូឡនីព្រហ្មទត្ត ត្រាស់ហៅព្រះរាជាទាំងនោះមកត្រាស់ថា នែលោកដ៏ចម្រើនទាំងឡាយ ចូរលោកទាំងឡាយមក យើងទាំងឡាយនឹងទៅកាន់ក្រុងមិថិលា កាត់ក្បាលព្រះបាទវិទេហរាជដោយដាវ ហើយជាន់ដោយជើង សឹមប្រជុំគ្នាផឹកជយបានៈ ចូរលោកទាំងឡាយត្រៀមកងទ័ពចេញទៅ ត្រាស់ដូច្នេះហើយ ក៏យាងទៅកាន់ទីស្ងាត់ ត្រាស់សេចក្តីនេះដល់កេវដ្ដៈទៀតថា យើងទាំងឡាយនឹងចាប់បច្ចាមិត្ត ដែលធ្វើអន្តរាយដល់ផែនការបែបនេះរបស់ពួកយើង ពួកយើងនឹងជាបុគ្គលដែលសេនា ១៨ អក្ខោភិនីមួយអន្ទើដោយព្រះរាជា ១០១ ចោមរោមទៅ សូមលោកអាចារ្យទៅផង ។ កេវដ្ដព្រាហ្មណ៍ត្រិះរិះដោយភាពដែលខ្លួនជាបុគ្គលឈ្លាសវៃថា ការដែលយើងមិនអាចយកជ័យជម្នះលើមហោសថបណ្ឌិត ការខ្មាសនឹងមានដល់ពួកយើងពិត យើងនឹងញុំាងព្រះរាជាឲ្យត្រឡប់ព្រះតម្រិះ លំដាប់នោះ កេវដ្ដៈក៏ទូលព្រះរាជាថា បពិត្រមហារាជ នុ៎ះមិនមែនជាកម្លាំងរបស់ព្រះបាទវិទេហរាជទេ នុ៎ះជាការរៀបចំ នុ៎ះជាអានុភាពរបស់មហោសថបណ្ឌិត ក្រុងមិថិលាដែលគេរក្សាហើយ ដូចរាជសីហ៍រក្សាហើយ ដែលបុគ្គលណាម្នាក់មិនអាចដណ្តើមការខ្មាសនឹងមានដល់ពួកយើងតែម្យ៉ាង យើងមិនគួរទៅក្នុងក្រុងមិថិលា ឯព្រះរាជាចូឡនីជាអ្នកស្រវឹង ដោយការស្រវឹងក្នុងរាជឥស្សរិយយស ដោយប្រកាន់ខ្លួនថាជាក្សត្រ ទើបត្រាស់ថា មហោសថនឹងធ្វើអ្វីយើងបាន ត្រាស់

ដូច្នេះហើយ ជាបុគ្គលដែលព្រះរាជា ១០១ ចោមរោម យាងទៅដោយសេនាកំណត់ ១៨ អក្ខោភនី ។ ចំណែកកេវដ្ដអាចារ្យ កាលមិនអាចឲ្យព្រះរាជាចូឡនីជឿពាក្យរបស់ខ្លួន ព្រោះទ្រង់យាងទៅផង ដោយគិតឃើញថា អញមិនគួរប្រព្រឹត្តឲ្យជាសត្រូវចំពោះព្រះរាជាឡើយ ។

ចំណែកសហជាតយោធារបស់មហោសថ ត្រឡប់ដល់នគរមិថិលាដោយមួយរាត្រី ប្រាប់កិច្ចដែលខ្លួនធ្វើដល់មហោសថ ចំណែកពួកបុរសដែលមហោសថបង្កប់ ក៏បញ្ជូនដំណឹងមកថា ព្រះបាទចូឡនីមានព្រះរាជា ១០១ ចោមរោមជារាជបរិវារ យាងមកដោយទ្រង់ប្រាថ្នានឹងចាប់ព្រះបាទវិទេហរាជ សូមបណ្ឌិតកុំប្រមាទ ។ មហោសថបានស្ដាប់ដំណឹងពីពួកបុរសដែលបង្កប់ជានិច្ចថា ថ្ងៃនេះ ព្រះបាទចូឡនីយាងដល់ទីនោះ ថ្ងៃនេះ យាងដល់ទីនោះ ថ្ងៃនេះ នឹងដល់ក្រុងមិថិលា ព្រះមហាសត្វបានជ្រាបដំណឹងនោះ ក៏រឹងរឹតតែជាអ្នកមិនប្រមាទ ចំណែកព្រះបាទវិទេហរាជទ្រង់ជ្រាបថា ព្រះបាទចូឡនី-ព្រហ្មទត្តនឹងកែនទ័ពមកដណ្ដើមនគរយើង ក៏បានស្ដាប់សំឡេងគនរំពងមិនដាច់ ។ លំដាប់នោះ ព្រះបាទចូឡនីព្រហ្មទត្ត មួយអន្លើដោយពលនិកាយកាន់គប់ភ្លើងរាប់ដោយសែន ឈ្លបមាគ៌ាធ្វើដំណើរមកដល់ក្នុងពេលព្រលប់ហើយឲ្យព័ទ្ធនូវនគរមិថិលាទាំងមូល ។ លំដាប់នោះ មេទ័ពក៏តាំងពួកពលក្នុងទីនោះៗ ព័ទ្ធនគរមិថិលាដោយកំពែងដំរី ដោយកំពែងរថ ដោយកំពែងសេះ ពួកពលនិកាយបានឈរបន្លឺសំឡេងគឹកកង ទះដៃ ហួច ស្រែកហ៊ោជុំវិញនគរមិថិលា កម្រាស់ ៧ យោជន៍ ក៏មានពន្លឺតែមួយ ដោយពន្លឺប្រទីប

និងពន្ទឺគ្រឿងប្រដាប់ ។ សម័យនោះ ហាក់បីដូចជាប្រឹថពីបែកដោយសំឡេងដំរី សំឡេងសេះ សំឡេងរថ និងតូរ្យតន្ត្រីជាដើម អ្នកប្រាជ្ញទាំង ៤ គឺសេនកៈ បុក្កុសៈ កាមិន្ទៈ ទេវិន្ទៈ បានឮសំឡេងកោលាហល មិនដឹងរឿងក៏ទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ សំឡេងហ៊ោអឺងកងសន្ធឹកសន្ធាប់ បពិត្រព្រះអង្គ ទ្រង់មិនជ្រាបសំឡេងនោះ ជាសំឡេងអ្វីទេឬ ទ្រង់គួរពិចារណាឲ្យជ្រាបរឿង ព្រះបាទវិទេហរាជទ្រង់បានស្តាប់ពាក្យរបស់អាចារ្យទាំង ៤ ក៏ទ្រង់គិតថា ព្រះបាទព្រហ្មទត្តយាងមកហើយ ទើបបើកសីហបញ្ជរទតមើល ទ្រង់ដឹងថា ព្រះរាជាយាងមក ក៏តក់ស្លុត ទ្រង់ឃើញច្បាស់ថា ជីវិតរបស់អញនឹងមិនមានក្នុងថ្ងៃស្អែកនេះ ស្តេចព្រហ្មទត្តនឹងញ៉ាំងពួកយើងឲ្យដល់នូវការអស់ជីវិត ទ្រង់ឃើញដូច្នេះ ក៏ប្រថាប់គង់ត្រាស់នឹងអាចារ្យទាំង ៤ ចំណែកព្រះពោធិសត្វដឹងថា ព្រះបាទចូឡនីព្រហ្មទត្តយាងមកដល់ហើយ ជាអ្នកមិនញាប់ញ័រ ដូចរាជសីហ៍ ចាត់ការរក្សាក្នុងព្រះនគរទាំងមូល ហើយគិតថា អញនឹងលួងលោមព្រះរាជា ទើបឡើងកាន់រាជនិវេសន៍ ថ្វាយបង្គំព្រះរាជា ហើយឈរក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះបាទវិទេហរាជទតឃើញមហោសថមកគាល់ ក៏សប្បាយព្រះហឫទ័យ ទ្រង់ត្រិះរិះថា អ្នកដទៃវៀរមហោសថបណ្ឌិតកូនរបស់អញ ឈ្មោះថា អាចដោះអញចាកទុក្ខរមែងមិនមាន កាលត្រាស់នឹងមហោសថ បានពោលគាថាដំបូងក្នុងមហាឧម្មង្គជាតកនេះថា

ម្នាលមហោសធ ព្រះរាជាចូឡនីព្រហ្មទត្ត ជាម្ចាស់ក្រុងបញ្ចាល យាងមកជាមួយនឹងសេនាទាំងពួង សេនារបស់ព្រះរាជាក្រុងបញ្ចាលនោះ បុគ្គលប្រមាណមិនបាន ។ ( សេនាទាំងនោះ ) មានពលជាងឈើ និងពលថ្មើរជើង អ្នកឈ្លាសក្នុងសង្គ្រាមទាំងពួង អាចនឹងលុកចូលទៅក្នុងពួក ជាសេនាមានសំឡេង ( មិនស្ងាត់ចាកសំឡេងទាំង ១០ យ៉ាង ) ញ៉ាំងគ្នានិងគ្នាឲ្យដឹងដោយសំឡេងស្គរ និងស័ង្ខ ។ ( ពួកសេនាទាំងនោះ ) មានវិទ្យាក្នុងផ្លូវលោហធាតុ និងមានគ្រឿងប្រដាប់ មានទង់ជ័យ មានមនុស្សអ្នកឡើងកាន់ពាហនៈខាងច្រើន ទាំងបរិបូណ៌ល្អ ដោយពួកមនុស្សអ្នកមានសិល្បៈ ដែលពួកយោធាដ៏ក្លៀវក្លា ( មានព្យាយាមស្មើដោយសត្វសីហៈ ) តាំងទុកដោយល្អហើយ ។ ក្នុងចំណោមសេនាទាំងនុ៎ះ មាននាយពល ១០ នាក់ ជាអ្នកឈ្លាសមានប្រាជ្ញាដូចផែនដី ច្រើនទៅប្រជុំប្រឹក្សាក្នុងទីស្ងាត់ និងមាតារបស់ព្រះរាជាជាគម្រប់ ១១ រមែងទ្រង់ប្រៀនប្រដៅសេនាក្នុងក្រុងបញ្ចាល ។ បណ្ដាជនទាំងនុ៎ះ មានក្សត្រិយ៍ ១០១ សុទ្ធតែមានយស ជាចំណុះ ដែលត្រូវព្រះបាទចូឡនីព្រហ្មទត្តដណ្ដើមយកដែនហើយ មានសេចក្ដីភ័យអំពីមរណៈ ក៏លុះក្នុងអំណាចនៃព្រះបាទបញ្ចាល ។ ( ស្ដេចទាំង ១០១ នោះ ) ជាអ្នកធ្វើតាមព្រះរាជតម្រាស់ មិនមានប្រាថ្នា ក៏ពោលពាក្យជាទីស្រឡាញ់ មិនមានប្រាថ្នា ក៏លុះ

អំណាច ចុះចូលព្រះបាទបញ្ចាល ។ មិថិលារាជធានីរបស់ពួកអ្នកវិទេហៈ ត្រូវពួកសេនានោះចោមព័ទ្ធជា ៣ ជាន់ ( ដូចជា ) ជីកគាស់ដោយជុំវិញ ។ ( ក្រុងមិថិលា ) ត្រូវសេនាចោមព័ទ្ធជុំវិញ ( ប្រាកដដោយសស្ត្រាវុធ ) ដូចជាផ្កាយដែលប្រាកដក្នុងខាងលើ ម្នាលមហោសថ អ្នកឯងចូរដឹងថា សេចក្ដីរួច ( ចាកទុក្ខនេះ ) នឹងមានដល់ពួកយើង ដោយប្រការដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វសេណាយ** សេចក្ដីថា នៃមហោសថបានឮថា ស្ដេចចូឡនីលើកទ័ពមក មួយអន្លើដោយកងទ័ពសព្វយ៉ាង រាប់បាន ១៨ អក្ខោភិនី មានស្ដេច ១០១ ជាអ្នកនាំ ។ បទថា **បញ្ចាលិយា** បានដល់ ជារបស់មាននៃព្រះបាទបញ្ចាលរាជ ។ បទថា **វិទ្ធិមតី** សេចក្ដីថា ប្រកបដោយកម្លាំងរបស់ជាងឈើ ដែលរៃកទព្វសម្ភារៈ នាំមកដើម្បីការងារជាង ។ បទថា **បត្តិមតី** បានដល់ ដែលបុរសកាន់យកនូវវត្ថុដ៏ប្រសើរតូចធំរក្សាហើយ ។ បទថា **សព្វសង្គាមកោវិទា** បានដល់ ឈ្លាសក្នុងសង្គ្រាមទាំងពួង ។ បទថា **ឱហារិនី** សេចក្ដីថា អាចចូលទៅក្នុងកងទ័ព មិនមានអ្នកណាឃើញ កាត់នូវក្បាលសត្រូវនាំមកបាន ។ បទថា **សទ្ទវតី** បានដល់ មិនស្ងាត់ចាកសំឡេង ១០ ប្រការ ។ បទថា **ភេរីសង្ខប្បពោធនា** សេចក្ដីថា ក្នុងទីនោះ មិនអាចឲ្យដឹងដោយពាក្យប្រាប់ថា ចូរមក ចូរទៅមុខ ចូរច្បាំង ចូរកុំទៅជាដើម តែកិច្ចបែបនោះនឹងឲ្យដឹងបានក្នុងទីនេះ ដោយសំឡេងស្គរ និងដោយសំឡេងស័ង្ខ ដូច្នោះ ទើបឈ្មោះថា ញុំាងគ្នានិងគ្នាឲ្យដឹងដោយសំឡេងស្គរ និង

សំឡេងស័ព្ទ ។ បទថា **លោហាវិជ្ជា** ក្នុងបាទគាថាថា **លោហាវិជ្ជាលង្ការា** នេះ គឺជាសិប្បៈទាក់ទងដោយលោហៈ ជាឈ្មោះរបស់ខែល ដូចជាអាវក្រោះ មួកក្រោះជាដើម ដែលប្រដាប់ដោយរតនៈ ៧ ប្រការ ។ បទថា **អលង្ការា** បានដល់ ជាគ្រឿងប្រដាប់របស់ព្រះរាជា និងមហាមាត្យរបស់ព្រះរាជាជាដើម ព្រោះដូច្នោះ ក្នុងបាទគាថានេះ ទើបមានអត្ថដូច្នេះថា ឈ្មោះថា វិជ្ជាខាង លោហធាតុ មានគ្រឿងប្រដាប់ ព្រោះភ្លឺរន្ទាលទៅដោយវិជ្ជាខាងលោហធាតុ និងដោយគ្រឿងប្រដាប់ ។ បទថា **ធជនី** សេចក្តីថា ប្រកបដោយទង់ទាំង ឡាយ ដែលលើកឡើងលើរថជាដើម ដែលប្រដាប់ដោយមាសជាដើម រុង រឿងដោយវត្ថុផ្សេងៗ ។ បទថា **វាមរោហិនី** សេចក្តីថា ទាហានទាំងនោះ លោកហៅថា **វាមរោហិនី** ព្រោះកាលឡើងដំរីមក រមែងឡើងខាងឆ្វេង ប្រកបដោយទាហានទាំងនោះ គឺជេរជាសទៅដោយដំរី និងសេះមានប្រមាណ មិនបាន ។ បទថា **សិប្បិយេហិ** សេចក្តីថា សម្បូរដោយល្អ គឺជេរជាស ដោយពួកទាហានដែលដល់នូវសេចក្តីសម្រេចក្នុងសិប្បៈ ១៨ យ៉ាង មាន សិប្បៈដំរី និងសិប្បៈសេះជាដើម ។ បទថា **សូរេហិ** សេចក្តីថា នៃបា បាន ឮថា កងទ័ពនេះតាំងមាំដោយល្អ ដោយពួកទាហាន ដែលមានការព្យាយាម ជានិច្ចដូចរាជសីហ៍ ។ បទថា **អាហុ** សេចក្តីថា បានឮថា ក្នុងកងទ័ពនេះ មានបណ្ឌិត ១០ នាក់ ។ បទថា **រហោគតា** សេចក្តីថា មានប្រក្រតីទៅ ក្នុងទីស្ងាត់ គឺមានប្រក្រតីអង្គុយប្រឹក្សាក្នុងទីស្ងាត់ បានឮថា បណ្ឌិតទាំងនោះ កាលបានគិតគ្នា ១ ថ្ងៃ ២ ថ្ងៃ ក៏អាចត្រឡប់ផែនដីឡើងទុកក្នុងអាកាសបាន ។

បទថា **ឯកាទសី** សេចក្តីថា បានឮថា ព្រះជននីរបស់ព្រះបាទចូឡនីនោះ ប្រកបដោយបញ្ញាក្រៃលែងជាងបណ្ឌិត ១០ នាក់នោះ ព្រះជននីនោះ ជាមនុស្សឈ្លាសទី ១១ របស់បណ្ឌិតទាំងនោះ ទូន្មានប្រៀនប្រដៅនូវកងទាហានបញ្ចាល ។

បានឮថា ថ្ងៃមួយ បុរសម្នាក់កាន់អង្ករមួយនាឡិ បាយមួយកញ្ចប់ និងកហាបណៈមួយពាន់ គិតនឹងឆ្លងស្ទឹង ក៏ចុះដល់កណ្តាលស្ទឹង មិនអាចឆ្លងបាន ទើបពោលនឹងជនទាំងឡាយ ដែលឈរត្រង់ច្រាំងយ៉ាងនេះថា អ្នកដ៏ចម្រើនទាំងឡាយ អង្ករមួយនាឡិ បាយមួយកញ្ចប់ កហាបណៈមួយពាន់របស់ខ្ញុំមានក្នុងដៃ អ្នកណាអាចចម្លងខ្ញុំឲ្យឆ្លងត្រើយនេះ ខ្ញុំនឹងឲ្យវត្ថុដែលខ្ញុំគាប់ចិត្តមាននៅក្នុងដៃ ។ លំដាប់នោះ មានបុរសម្នាក់ដល់ព្រមដោយកម្លាំង ស្លៀកសំពត់យ៉ាងតឹង ហើយលោតចូលទៅក្នុងទឹក ចាប់ដើមដៃបុរសនោះឲ្យឆ្លងទៅហើយ ពោលថា សូមលោកឲ្យរបស់ដែលគួរដល់ខ្ញុំ បុរសនោះពោលថា លោកយកអង្ករមួយនាឡិ ឬបាយមួយកញ្ចប់ បុរសអ្នកនាំឆ្លងត្រើយពោលថា ខ្ញុំមិនស្តាយជីវិត នាំលោកឆ្លងត្រើយ ខ្ញុំមិនត្រូវការដោយរបស់ទាំងពីរនោះ សូមលោកឲ្យកហាបណៈដល់ខ្ញុំ បុរសដែលថានឹងឲ្យរបស់គាប់ចិត្ត ក៏ពោលថា ខ្ញុំបាននិយាយថា ខ្ញុំនឹងឲ្យរបស់ដែលគាប់ចិត្តអំពីរបស់ ៣ យ៉ាង ដល់លោកដូច្នេះ ខ្ញុំក៏ឲ្យវត្ថុដែលខ្ញុំគាប់ចិត្តដល់លោក បើលោកចង់បាន ក៏ចូរកាន់យក បុរសដែលនាំឆ្លងត្រើយ ក៏ពោលដល់បុគ្គលម្នាក់ដែលឈរជិត បុរសនោះក៏ពោលតបថា បុរសដែលពោលថា ឲ្យរបស់គាប់

ចិត្ត ឲ្យរបស់ដែលគាប់ចិត្តដល់លោក លោកទទួលយកចុះ បុរសអ្នកនាំធ្វងត្រីយពោលថា ខ្ញុំមិនយក ហើយនាំបុរសនោះទៅកាន់ទីវិនិច្ឆ័យ ប្រាប់ដល់អមាត្យអ្នកវិនិច្ឆ័យទាំងឡាយ ។ ចំណែកអមាត្យអ្នកវិនិច្ឆ័យនោះ បានស្តាប់សេចក្តីទាំងពួង ក៏វិនិច្ឆ័យយ៉ាងនោះ បុរសនោះមិនត្រេកអរដោយការវិនិច្ឆ័យនៃពួកអមាត្យ ទើបក្រាបទូលព្រះរាជា ចំណែកព្រះបាទចូឡនីឲ្យហៅអមាត្យអ្នកវិនិច្ឆ័យនោះមក ទ្រង់ស្តាប់ពាក្យជនទាំងពីរ អំពីសម្នាក់អមាត្យអ្នកវិនិច្ឆ័យ កាលទ្រង់មិនជ្រាបនឹងវិនិច្ឆ័យដទៃ ទើបទ្រង់វិនិច្ឆ័យលុបនូវសច្ចៈ បុរសដែលនាំធ្វងត្រីយ បានស្តាប់ព្រះរាជវិនិច្ឆ័យដូច្នោះ ក៏ពោលឡើងត្រង់ព្រះទីន័ងថា ទ្រង់ធ្វើទូលបង្គំដែលលះបង់ជីវិត ចុះកាន់ស្ទឹង ឲ្យមានទោសខណៈនោះ ព្រះជននីនៃព្រះបាទចូឡនី ព្រះនាមសលាកទេវី ប្រថាប់គង់ក្បែរនោះ ព្រះនាងជ្រាបភាពដែលព្រះរាជាវិនិច្ឆ័យខុស ទើបត្រាស់ថា បាវិនិច្ឆ័យក្តីត្រូវល្អហើយឬ ព្រះបាទចូឡនីទូលព្រះមាតាថា ទូលបង្គំដឹងតែប៉ុណ្ណេះ បើព្រះមាតាជ្រាបក្រៃលែងជាងនេះសោតសូមវិនិច្ឆ័យទៀតចុះព្រះនាងសលាកទេវីក៏ត្រាស់ថា សាធុ មាតានឹងវិនិច្ឆ័យ ទើបហៅបុរសដែលត្រូវគេជួយមកហើយត្រាស់ថា ចូរអ្នកមក ចូរដាក់របស់ ៣ យ៉ាង ដែលអ្នកកាន់ទុកលើផែនដីហើយត្រាស់សួរថា កាលអ្នកនៅក្នុងទឹក អ្នកពោលដូចម្តេចនឹងបុរសនេះ កាលបុរសនោះពោលថា នឹងឲ្យរបស់ដែលគាប់ចិត្ត ទើបព្រះនាងត្រាស់ថា បើដូច្នោះ ចូរអ្នកកាន់យករបស់ដែលអ្នកគាប់ចិត្តក្នុងកាលឥឡូវនេះ បុរសនោះក៏កាន់យកថង់កហាបណៈមួយពាន់ លំដាប់នោះ ព្រះនាងក៏ហៅបុរសនោះ

មកក្នុងកាលដែលដើរទៅបានបន្តិច ត្រាស់ថា អ្នកគាប់ចិត្តក្នុងកហាបណៈ ១ ពាន់ឬ កាលបានស្តាប់ព្រះសវនីយ៍ ក៏តបថា ទូលបង្គំគាប់ចិត្តកហាបណៈ ១ ពាន់ ព្រះនាងក៏ត្រាស់ថា អ្នកនិយាយនឹងបុរសនេះថា ខ្ញុំនឹងឲ្យរបស់ដែលខ្ញុំគាប់ចិត្តអំពីរបស់ទាំង ៣ យ៉ាងនេះមិនមែនឬ កាលព្រះនាងបានស្តាប់ថា ទូលបង្គំនិយាយយ៉ាងនោះ ទើបត្រាស់ថា បើដូច្នោះ ចូរអ្នកឲ្យកហាបណៈ ១ ពាន់នោះ ដល់បុរសដែលជួយចម្ងងនេះឯង បុរសនោះ បានស្តាប់ព្រះវិនិច្ឆ័យនោះ ក៏ស្រែកយំ ហើយឲ្យកហាបណៈមួយពាន់ដល់បុរសដែលជួយចម្ងងនោះ ។ ខណៈនោះ ព្រះបាទចូឡនីព្រហ្មទត្ត និងអមាត្យទាំងឡាយត្រេកអរក្នុងព្រះវិនិច្ឆ័យនោះ ក៏ឲ្យសាធុការ ចាប់តាំងពីកាលនោះ ភាពដែលព្រះនាងសលាកទេវី ព្រះជននីរបស់ព្រះបាទចូឡនី ជាអ្នកប្រព្រឹត្តទៅដោយបញ្ញា ក៏ប្រាកដទៅក្នុងទីទាំងពួង ព្រះបាទវិទេហរាជទ្រង់សំដៅយកព្រះនាងសលាកទេវីអង្គនេះ ទើបត្រាស់ថា **មាតា ឯកាធសី** ជាដើម ។

បទថា **ខត្យា** បានដល់ ក្សត្រទាំងឡាយ ។ បទថា **អច្ឆិន្នរដ្ឋា** សេចក្តីថា ត្រូវព្រះបាទចូឡនីព្រហ្មទត្ត ដណ្តើមនូវដែនគ្រប់គ្រង ។ បទថា **ព្យថិតា** សេចក្តីថា ខ្លាចចំពោះមរណភ័យ ទ្រង់មិនឃើញវត្ថុដទៃដែលគប្បីកាន់យក ។ បទថា **បញ្ចាលីនំ វសំ គតា** សេចក្តីថា ធ្លាក់នៅក្នុងអំណាចរបស់ព្រះបាទបញ្ចាលរាជនេះ បទនេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។ បទថា **យំ វទា តក្ករា** សេចក្តីថា អាចធ្វើតាមព្រះរាជតម្រាស់ ។ បទថា **វសិនោ គតា** សេចក្តីថា កាលមុនមានអំណាចឯង តែឥឡូវនេះ នៅក្នុងអំណាចរបស់ព្រះ

បាទចូឡនី ។ បទថា **តិសន្ធិ** សេចក្តីថា ព័ទ្ធកំពែង ៤ ជាន់ទាំងនេះ គឺព័ទ្ធដោយកំពែង គឺដីរឹជាជាន់ទី ១ បន្ទាប់ពីនោះ ព័ទ្ធដោយកំពែង គឺរថ បន្ទាប់ពីនោះ ព័ទ្ធដោយកំពែង គឺសេះ បន្ទាប់អំពីនោះ ព័ទ្ធដោយកំពែង គឺពលថ្មើរជើង ឈ្មោះថា ព័ទ្ធ ៣ ជាន់ គឺរវាងទ័ពដីរី និងទ័ពរថជា ១ ជាន់ រវាងទ័ពរថ និងទ័ពសេះជា ១ ជាន់ រវាងទ័ពសេះ និងទ័ពថ្មើរជើងជា ១ ជាន់ ។ បទថា **បរិខញ្ញាតិ** សេចក្តីថា ឥឡូវនេះ នគរនេះត្រូវជីកដោយជុំវិញ ដូចគេបំណងនឹងលើកឡើងកាន់យកទៅ ។ បទថា **ឧទ្ធំ តារកជាតាវ** សេចក្តីថា កងទ័ពដែលព័ទ្ធជុំវិញក្រុងមិថិលានោះ ប្រាកដដោយអាវុធទាំងឡាយមានដំបងជាដើម ច្រើនរយ ច្រើនពាន់ ដូចផ្កាយក្នុងលម្ហ ។ បទថា **វិជា-នាហិ** សេចក្តីថា នៃបាមហោសថ តាំងអំពីអវិចីរហូតដល់ភវគ្គព្រហ្ម បុគ្គលដទៃដែលឈ្មោះថាបណ្ឌិត ឈ្លាសក្នុងឧបាយដូចអ្នកមិនមាន ម្យ៉ាងទៀត ឈ្មោះថា ភាពជាបណ្ឌិត រមែងដឹងបានក្នុងឋានៈបែបនេះ ព្រោះអ្នកដទៃដូចអ្នកមិនមាន ដូច្នោះ អ្នកប៉ុណ្ណោះ ចូរដឹងថា ពួកយើងនឹងផុតសេចក្តីទុក្ខនេះបានដូចម្តេច ។

ព្រះមហាសត្វ បានស្តាប់ព្រះតម្រាស់របស់ព្រះបាទវិទេហរាជ ដូច្នេះហើយ ត្រិះរិះថា ព្រះរាជានេះទ្រង់ខ្លាចមរណភ័យពន់ពេក គ្រូពេទ្យជាទីពឹងអាស្រ័យរបស់អ្នកជំងឺ ភោជនាហារ ជាទីពឹងអាស្រ័យរបស់អ្នកឃ្លាន ទឹកជាទីពឹងអាស្រ័យរបស់អ្នកស្រេក វៀរអាត្មាអញចេញហើយ អ្នកដទៃជាទីពឹងអាស្រ័យរបស់ព្រះរាជានេះមិនមាន អញនឹងលួងលោមព្រះរាជាឲ្យទ្រង់ស្រាក

ស្រាន្ត ។ កាលនោះ ព្រះពោធិសត្វមិនតក់ស្លុត ដូចរាជសីហ៍បន្លឺសីហនាទ ត្រង់ផ្ទាំងមនោសិលា ក្រាបទូលព្រះបាទវិទេហរាជថា បពិត្រមហារាជ សូមទ្រង់កុំខ្លាចឡើយ សូមទ្រង់សោយរាជសម្បត្តិជាសុខចុះ ទូលបង្គំនឹងធ្វើកងទ័ព ១៨ អក្ខោភិនីនេះ ឲ្យមិនមែនជាម្ចាស់របស់សំពត់សាដក ដែលស្លៀកជាប់នឹងខ្លួន ហើយរត់ទៅ ដូចបុគ្គលឆាដុំដីឲ្យក្អែកគេចទៅ និងដូចបុគ្គលយឹតធ្នូឲ្យស្វាគេចទៅ ដូច្នោះ ក្រាបទូលដូច្នោះហើយ ក៏ពោលគាថាទី ៩ ថា

បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់សណ្ដូកព្រះបាទ ( ឲ្យស្រួលចុះ ) សូមព្រះអង្គ ទ្រង់ក្រសាលរីករាយក្នុងកាមចុះ ព្រះបាទចូឡនី ព្រហ្មទត្ត មុខជានឹងលះបង់សេនាក្នុងក្រុងបញ្ចាល ហើយរត់ទៅ ដូច្នេះ ។

អត្ថរបស់គាថានោះ មានន័យថា បពិត្រព្រះសម្មតិទេព សូមទ្រង់សណ្ដូកព្រះបាទាទាំងគូ ពោល គឺការសោយរាជសម្បត្តិរបស់ព្រះអង្គតាមសប្បាយចុះ កាលទ្រង់សណ្ដូក កុំគិតដល់រឿងសង្គ្រាម សូមទ្រង់សោយនិងត្រេកអរក្នុងកាមសម្បត្តិចុះ ព្រះបាទចូឡនីព្រហ្មទត្ត នឹងលះបង់កងទ័ពហើយរត់ទៅ ។

មហោសថបណ្ឌិត ញុំាងព្រះរាជាឲ្យកក់ក្ដៅហើយ ចេញមកឲ្យវាយស្គរប្រកាសមហោស្រពក្នុងព្រះនគរ ពោលនឹងអ្នកនគរថា អ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយកុំភិតភ័យឡើយ ចូរញុំាងវត្ថុទាំងឡាយ មានផ្កា គ្រឿងក្រអូប គ្រឿងលាប ទឹកផឹក និងភោជនជាដើមឲ្យដល់ព្រម ហើយនាំគ្នាលេងមហោ-

ស្រវឹងអស់ ៧ ថ្ងៃ មហោសថពោលនឹងអ្នកនគរថា ជនទាំងឡាយក្នុងទីនោះៗ ចូរផឹក ចូរលេង ចូរដេញដំ ចូរផ្ទុំ ចូរប្រគំតន្ត្រី ចូរច្រៀងរាំ ចូរស្រែកហ៊ោ ចូរបន្លឺសំឡេងឲ្យបានខ្លាំង ចូរទះដៃឲ្យសប្បាយ ចូរច្រៀងតាមសប្បាយ តម្លៃសម្រាប់ចាយរបស់ពួកលោកទាំងឡាយ ជារបស់យើងឲ្យទាំងអស់ យើងឈ្មោះថាមហោសថបណ្ឌិត ពួកអ្នកនឹងឃើញអានុភាពរបស់យើង ។ ញុំាងអ្នកនគរឲ្យស្រោកស្រាន្តចិត្តហើយ អ្នកនគរបានធ្វើតាមនោះ ជនទាំងឡាយនៅខាងក្រៅនគរ រមែងបានឮសំឡេង មានសំឡេងច្រៀង និងសំឡេងប្រគំជាដើម ក៏នាំគ្នាចូលទៅខាងក្នុងតាមទ្វារតូច អ្នករក្សាទាំងឡាយមិនចាប់បុគ្គលដែលខ្លួនឃើញហើយ ក្រៅអំពីពួកសត្រូវ ព្រោះដូច្នោះ អ្នកដើរចេញចូលក៏មានមិនដាច់ បុគ្គលចូលទៅខាងក្នុង រមែងឃើញមនុស្សលេងមហោស្រព ។

ចំណែកព្រះបាទចូឡនីព្រហ្មទត្ត ស្តាប់សំឡេងកោលាហល ក្នុងនគរមិថិលា ទើបត្រាស់សួរអមាត្យទាំងឡាយថា អ្នកដ៏ចម្រើនទាំងឡាយ ក្នុងកាលពួកយើងព័ទ្ធព្រះនគរដោយកងទ័ព ១៨ អក្ខោភិនី ការខ្វាចត្រឹមតែព្រឺព្រួច មិនមានដល់អ្នកនគរៗ មានបីតិសោមនស្ស ច្រៀងរាំ ហ៊ោកញ្ជ្រៀវទះដៃ មានហេតុការណ៍ដូចម្តេច លំដាប់នោះ បុរសដែលមហោសថបង្កប់ក៏ទូលមុសាដល់ព្រះរាជាថា បពិត្រព្រះអង្គ ពួកយើងមានកិច្ចមួយចូលទៅក្នុងនគរតាមទ្វារតូច ឃើញមហាជនលេងមហោស្រព បានសាកសួរថា ព្រះរាជាក្នុងសកលជម្ពូទ្វីប មកព័ទ្ធនគររបស់អ្នកទាំងឡាយជុំជិតហើយ តែពួក

អ្នកជាអ្នកប្រមាទពន់ពេក ហេតុការណ៍នេះដូចម្ដេច អ្នកនគរទាំងនោះក៏ពោលថា ព្រះរាជារបស់យើងទាំងឡាយប្រាថ្នាមួយ មានក្នុងកាលដែលទ្រង់នៅក្មេងថា ក្នុងកាលនគរយើងដែលព្រះរាជាក្នុងសកលជម្ពូទ្វីបឡោមព័ទ្ធ ពួកយើងនឹងលេងមហោស្រព ថ្ងៃនេះ សេចក្ដីប្រាថ្នារបស់ព្រះរាជារបស់ពួកយើងដល់ទីផុតហើយ ព្រោះដូច្នោះ ទើបអ្នករាជការប្រកាសឲ្យអ្នកនគរលេងមហោស្រព ស៊ីផឹកក្នុងទីកន្លែងរៀងៗ ខ្លួន ។ ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់បានស្ដាប់ពាក្យរបស់ពួកបុរសដែលមហោសថបង្កប់ ក៏ទ្រង់អាក់អន់ ត្រាស់នឹងសេនាថា ចូរលោកទាំងឡាយទៅ ចូរប្រញាប់ត្រួតពិនិត្យមើលនគរក្នុងទីផ្សេងៗ ចូរប្រញាប់ទម្លាយនគរខាងនេះផង ខាងនោះផង ចូរទម្លាយគូទឹក ចូរទម្លាយកំពែង ចូរទម្លាយទ្វារ ចូលទៅខាងក្នុងនគរ យកក្បាលអ្នកនគរមកដោយរទេះមួយរយ ដូចយកផ្លែត្រឡាចមក ដូច្នោះ ចូរកាត់សីសៈរបស់ព្រះបាទវិទេហៈ នាំមក ។ យោធាដែលក្លៀវក្លាទាំងឡាយ បានស្ដាប់ព្រះរាជ-តម្រាស់ ក៏ផ្គងអាវុធមានប្រការផ្សេងៗ ទៅកាន់ទីក្បែរទ្វារ ត្រូវពួកទាហានរបស់មហោសថប្រទូស្តដោយការបាចកក់ លាយដោយដុំក្រួស និងដីខ្សាច់ និងការបោលដុំថ្ម ក៏ត្រឡប់ថយក្រោយ ចុះកាន់គូ ដោយគិតថា ទម្លាយកំពែង ពួកយោធាដែលតាំងនៅលើទ្វារខាងក្នុង ក៏ធ្វើឲ្យសត្រូវដល់ការវិនាសធំ ដោយគ្រឿងប្រហារ មានព្រួញ លំពែង និងលំពែងស្នែងក្របីជាដើម យោធារបស់មហោសថ រមែងបៀតបៀនយោធារបស់ព្រះបាទចូឡនី ដោយសម្ដែងវិការនៃដៃជាដើម និងជេរបរិភាសដោយប្រការផ្សេងៗ ញុះញង់ឲ្យក្រោធថា ពួកឯងនឿយហត់អស់កម្លាំងមិនបានអាហារ ចូរមកស៊ីផឹកបន្តិចសិន ហើយ

ធ្វើជាបញ្ជូនឪទិនស្រា និងឈើសម្រាប់ដោតត្រីសាច់ទៅឲ្យ ហើយទំពាស៊ីខ្លួនឯង ដើរទៅដើរមកលើកំពែង យោធាក្រុងបញ្ចាលមិនអាចធ្វើអ្វីបាន ក៏ចូលទៅគាល់ព្រះបាទព្រហ្មទត្ត ក្រាបទូលថា បពិត្រព្រះសម្មតិទេព បុគ្គលដទៃវៀរអ្នកមានអានុភាព ( ឫទ្ធិ ) ហើយ មិនអាចយកជ័យជម្នះបាន ព្រះបាទចូឡនីស្នាក់នៅ ៤-៥ រាត្រី កាលមិនឃើញឧបាយដណ្តើមយកនគរមិថិលាបាន ក៏សួរអាចារ្យកេវដ្តៈថា លោកអាចារ្យ ពួកយើងមិនអាចកាន់យកព្រះនគរបាន សូម្បីតែមនុស្សម្នាក់ ក៏មិនអាចចូលជិត គួរធ្វើដូចម្តេច កេវដ្តៈទូលថា ណ្ហើយចុះព្រះអង្គ ធម្មតានគរដែលមានទឹកខាងក្រៅ យើងនឹងយកនគរបានដោយការអស់ទឹក ពួកខាងក្នុងនគរលំបាកដោយទឹក នឹងបើកទ្វារចេញមក ព្រះរាជាទ្រង់ឃើញប្រពៃ ព្រោះថា ឧបាយនេះល្អ ចាប់តាំងអំពីនោះមក ពួកកងទ័ពក៏មិនឲ្យអ្នកណានាំទឹកចូលទៅក្នុងនគរ បុរសដែលមហោសថបង្គប់ ក៏សរសេរអក្សរចងត្រង់ចុងព្រួញ បាញ់ចូលទៅខាងក្នុងនគរ ព្រោះមហោសថបានផ្តាំថា អ្នកណាឃើញសំបុត្រត្រង់ចុងព្រួញ ចូរនាំមកឲ្យយើង ដូច្នេះ កាលនោះ បុរសម្នាក់ ឃើញសំបុត្រត្រង់ចុងព្រួញ ក៏យកទៅឲ្យមហោសថៗ ដឹងដំណឹងនោះ ទើបគិតថា ព្រះបាទចូឡនី មិនដឹងភាពដែលអញជាមហោសថបណ្ឌិត ទើបឲ្យពុះឫស្សីវែង ៦០ ហត្ថ ជាពីរចម្រៀក លួសថ្នាំងខាងក្នុងអស់ហើយ ដាក់ចូលគ្នាវិញ យកខ្សែស្បែកចងពីខាងក្រៅ លាបកក់ខាងលើ ឲ្យដាំឈូកក្រហម និងឈូកសដែលបានមកអំពីតាបសដែលមានឫទ្ធិនាំមកអំពីហិមវន្តប្បទេស ក្នុងកក់ក្បែរប្រាំងស្រះបោក្ខរណី

ដាក់ដើមឫស្សីបញ្ឈរ ( លើពន្លកឈូក ) ចាក់ទឹកចូលទៅឲ្យពេញ តែមួយយប់ប៉ុណ្ណោះ ពន្លកក៏ដុះឡើងរហូតផុតចុងឫស្សី ១ ហត្ថ ។ លំដាប់នោះ មហោសថឲ្យបុរសទាំងឡាយរបស់ខ្លួន ដកឈូកដែលលូតក្នុងបំពង់ឫស្សីនោះបោះទៅឲ្យសត្រូវដោយពាក្យថា ចូរពួកអ្នកថ្វាយឈូកនេះដល់ព្រះបាទចូឡនី ពួកបុរសរបស់មហោសថ ធ្វើឈូកនោះឲ្យជារង្វេល ហើយប្រាប់ថា នែពួកអ្នកទាំងឡាយដែលជារាជការរបស់ព្រះបាទចូឡនីព្រហ្មទត្ត ពួកអ្នកកុំស្លាប់ដោយការអត់ឃ្លានឡើយ ចូរទទួលយកផ្កាឈូកនេះប្រដាប់ ទំពាស៊ីដើមឈូកឲ្យឆ្អែតស្កប់ស្កល់ ស្រែកប្រាប់ដូច្នេះហើយ ក៏បោះចុះទៅ បុរសម្នាក់ដែលមហោសថបង្គប់ ក៏កាន់យករង្វេលឈូកនោះ ។

គ្រានោះ បុរសនោះនាំទៅថ្វាយព្រះបាទចូឡនី ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ទតដើមឈូកនេះ ដើមឈូកវែងដល់ម្ល៉េះ យើងមិនធ្លាប់ឃើញមកអំពីមុន រហូតដល់ឥឡូវនេះ កាលព្រះរាជាត្រាស់ថា ចូរអ្នកទាំងឡាយវាស់មើល ក៏វាស់ដើមឈូក ៦០ ហត្ថ តែទូលថា ៨០ ហត្ថ ក្នុងកាលព្រះរាជាត្រាស់សួរទៀតថា ឈូកនោះដុះក្នុងទីណា បុរសដែលព្រះមហោសថបង្គប់ ក៏ក្រាបទូលកុហកថា ថ្ងៃមួយ ទូលបង្គំស្រេកទឹក ចូលទៅក្នុងនគរតាមទ្វារតូច ដោយគិតថា នឹងផឹកសុរា បានឃើញស្រះបោក្ខរណីធំទាំងឡាយ ដែលជីកដើម្បីប្រយោជន៍ដល់អ្នកនគរលេងទឹក មហាជនអង្គុយក្នុងទូកបេះផ្កា ឈូកនេះកើតត្រង់មាត់ច្រាំងស្រះបោក្ខរណីនោះ តែឈូកដែលដុះត្រង់កណ្តាលស្រះប្រវែង ១០០ ហត្ថឯណោះ ព្រះបាទចូឡនីព្រហ្មទត្តបាន

ស្តាប់សេចក្តីនោះ ទើបត្រាស់ដល់កេវដ្តៈថា លោកអាចារ្យ ពួកយើងមិនអាចដណ្តើមយកនគរនេះ ដោយបង្អត់ទឹកបានទេ សូមលោកប្តូរគំនិតនេះចុះ កេវដ្តព្រាហ្មណ៍ក្រាបទូលថា បើយ៉ាងនោះ ចូរដណ្តើមយកនគរនេះដោយឲ្យអស់បាយ ព្រោះធម្មតានគរត្រូវមានស្រូវខាងក្រៅ ព្រះរាជាក៏ឲ្យធ្វើយ៉ាងនោះ ។ មហោសថបណ្ឌិតដឹងដំណឹងនោះ ដូចន័យដែលពោលមកហើយ គិតថា កេវដ្តព្រាហ្មណ៍ មិនស្គាល់កាលដែលអញជាមហោសថបណ្ឌិត ទើបឲ្យគេលាបភក់តាមកំពែងនគរ ហើយឲ្យព្រោះស្រូវក្នុងទីនោះ ធម្មតាបំណងរបស់ព្រះពោធិសត្វ រមែងសម្រេចត្រឹមមួយយប់ប៉ុណ្ណោះ ស្រូវក៏ដុះឡើងលើកំពែងនគរ ព្រះបាទចូឡនីទតឃើញដើមស្រូវនេះ ទើបត្រាស់សួរថា រុក្ខជាតិខៀវនោះប្រាកដលើកំពែង ជាអ្វី បុរសដែលមហោសថបង្កប់ បានស្តាប់ព្រះតម្រាស់ក្លាម ក៏ទូលស្នងក្លាមថា បពិត្រព្រះសម្មតិទេព បានឮថា កូនគហបតីឈ្មោះមហោសថបណ្ឌិត គិតឃើញភ័យក្នុងអនាគត ទើបឲ្យព្រោះស្រូវសាលីក្នុងដែន ហើយប្រមូលដាក់ពេញជង្រុកព្រះរាជា ហើយទុកដាក់ស្រូវដ៏សេសក្បែរកំពែង បានឮថា ស្រូវទាំងនោះ ស្ងួតទៅដោយកម្តៅថ្ងៃ សើមដោយភ្លៀង សម្ទូងទាំងឡាយក៏កើតឡើងព្រមក្នុងទីនោះ ថ្ងៃមួយ ទូលបង្គំចូលទៅតាមទ្វារតូច ដោយកិច្ចឯណានីមួយ ឃើញគំនរស្រូវព្រៀបកំពែង ក៏ចាប់យកស្រូវមកអំពីគំនរនោះ បាចទៅត្រង់មាត់ផ្លូវ ពេលនោះ ពួកជនកាលនិយាយនឹងខ្ញុំថា អ្នកប្រហែលជាឃ្លាន ទើបប្រាប់ថា ចូរអ្នកយកជាយសំពត់ខ្ចប់ស្រូវទៅផ្ទះរបស់អ្នក បុកចម្អិនបរិភោគចុះ ។ ព្រះបាទក្រុងបញ្ចាល

បានស្តាប់ដូច្នោះ ទើបត្រាស់នឹងកេវដ្តព្រាហ្មណ៍ថា យើងមិនអាចដណ្តើមយក ដោយធ្វើនគរនេះឲ្យអស់ធញ្ញាហារបានឡើយ ឧបាយដទៃនៅមានទៀតឬ ។ កេវដ្តព្រាហ្មណ៍ទូលថា បើដូច្នោះ យើងនឹងដណ្តើមយក ដោយការធ្វើឲ្យអស់ឧស ឈ្មោះថា នគរមិនមានឧសខាងក្រៅ នឹងចុះចាញ់ ។ ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះ ។ ចំណែកមហោសថដឹងដំណឹងនោះ ដូចបានពណ៌នាខាងដើម បានឲ្យធ្វើគំនរឧសប្រមាណប៉ុនភ្នំ ឲ្យប្រាកដខ្ពស់ជាងស្រូវ ពីលើកំពែង ពួកយោធារបស់មហោសថ កាលពោលចំអកនឹងយោធារបស់ព្រះបាទចូឡនី ក៏ពោលថា បើពួកអ្នកឃ្លានបាយ ចូរដាំបាយបរិភោគ ហើយបោះឧសធំៗ ទៅឲ្យទាហានទាំងនោះ ។ ព្រះបាទចូឡនីទតឃើញឧសជាច្រើន ផុតកំពែងនគរ ទើបត្រាស់សួរថា នុ៎ះជាអ្វី បុរសដែលមហោសថបង្កប់ ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព បានឮថា កូនគហបតីឈ្មោះមហោសថ ឃើញភ័យក្នុងអនាគត ទើបឲ្យជញ្ជូនឧសមកគរទុកក្នុងផ្ទះពួករាជត្រកូល និងគរទុកត្រង់ក្បែរកំពែងនគរ ក៏មិនមែនតិច ។

ព្រះបាទក្រុងបញ្ចាលបានស្តាប់ដូច្នោះ ទើបត្រាស់នឹងកេវដ្តៈថា យើងមិនអាចដណ្តើមយក ដោយធ្វើនគរនេះឲ្យអស់ឧសបានឡើយ ចូរអ្នកលើកឧបាយនេះចោល ។ កេវដ្តព្រាហ្មណ៍ទូលថា សូមទ្រង់កុំវិតក្កឡើយ ឧបាយដទៃនៅមាន ព្រះបាទចូឡនីត្រាស់សួរថា ឧបាយដូចម្តេចទៀត យើងមិនឃើញឧបាយរបស់លោកបានសម្រេច យើងមិនអាចកាន់យកនគរវិទេហៈបានទេ យើងនឹងត្រឡប់ទៅនគររបស់យើង កេវដ្តៈក៏ទូលថា ការខ្មាសថា ព្រះបាទ

ចូឡនីព្រហ្មទត្ត និងព្រះរាជា ១០១ មិនអាចដណ្តើមវិទេហរដ្ឋបាន នឹងមាន ដល់ពួកយើង មហោសថនឹងជាបណ្ឌិតអ្វី ឯទូលបង្គំក៏ជាបណ្ឌិត ពួកយើង នឹងធ្វើលេសឯណានីមួយ ។ ព្រះរាជាត្រាស់សួរថា តើឧបាយកលដូចម្តេច កេវដ្តៈក៏ទូលថា ពួកយើងនឹងធ្វើធម្មយុទ្ធ ព្រះរាជាត្រាស់សួរថា អ្វីហៅថា ធម្មយុទ្ធ កេវដ្តៈទូលថា សេនាមិនចាំបាច់ច្បាំង តែបណ្ឌិតទាំងពីររបស់ព្រះ រាជា នឹងនៅក្នុងទីជាមួយគ្នា ក្នុងបណ្ឌិតទាំងពីរនោះ បណ្ឌិតណាថ្វាយបង្គំ បណ្ឌិតនោះនឹងចាញ់ មហោសថមិនដឹងការគិតនេះ ឯទូលបង្គំក៏ចាស់ជាង មហោសថនៅក្មេង ឃើញទូលបង្គំនឹងថ្វាយបង្គំ មហោសថថ្វាយបង្គំទូលបង្គំ កាលណា អ្នកដែនវិទេហៈក៏ឈ្មោះថា ពួកយើងឈ្នះហើយ ពេលនោះ ពួក យើងនឹងញាំងវិទេហរដ្ឋឲ្យបរាជ័យ ហើយដណ្តើមយកជានគររបស់ខ្លួន ឯការ ខ្មាស នឹងមិនមានដល់ពួកយើង ដោយប្រការដូច្នេះ ច្បាំងដោយលេស នេះ ឈ្មោះថា ធម្មយុទ្ធ ។ ចំណែកមហោសថ បានជ្រាបហេតុរហ័សដូច ខាងដើម ទើបគិតថា បើអញចាញ់កេវដ្តៈ អញមិនមែនជាបណ្ឌិត ។ ឯព្រះ បាទចូឡនីព្រហ្មទត្តត្រាស់ថា ឧបាយនេះល្អណាស់អាចារ្យ ឲ្យសរសេររាជ-សាសន៍ថា ស្អែកនេះ ធម្មយុទ្ធនឹងមាន ឈ្នះ ឬចាញ់ដោយធម៌ នឹងមាន ដល់បណ្ឌិតទាំងពីរ អ្នកណាមិនធ្វើធម្មយុទ្ធ អ្នកនោះឈ្មោះថា ចាញ់ ដូច្នេះ ហើយ បញ្ជូនទៅថ្វាយព្រះបាទវិទេហរដ្ឋតាមទ្វារតូច ព្រះបាទក្រុងមិថិលាបាន ស្តាប់រាជសាសន៍នោះ ឲ្យហៅមហោសថមកប្រាប់សេចក្តីនោះ មហោសថ ក្រាបទូលថា សាធុ ព្រះអង្គ សូមទ្រង់ព្រះរាជទានរាជសាសន៍តបទៅថា ពួក

អ្នកក្រុងមិថិលានឹងត្រៀមសន្ទនាធម្មយុទ្ធ ត្រង់ទ្វារទិសខាងលិច កងទ័ពក្រុងបញ្ចាល ចូរមកកាន់ទីលានធម្មយុទ្ធក្នុងថ្ងៃស្អែកនេះ ព្រះបាទវិទេហៈបានស្តាប់ពាក្យរបស់មហោសថ ទើបប្រទានរាជសាសន៍ដល់ទូតដែលមកហើយនោះឯង មហោសថបានត្រៀមទីលានធម្មយុទ្ធត្រង់ទិសខាងលិច ដោយគិតថា បរាជ័យនឹងមានដល់កេវដ្ដៈក្នុងថ្ងៃស្អែកនេះ ចំណែកពួកបុរសដែលមហោសថបង្គប់ ១០១ នាក់ ក៏ចោមរោមកេវដ្ដៈ ដើម្បីរក្សាមហោសថ ដោយគិតថា អ្នកណានឹងដឹងហេតុ ហេតុការណ៍អ្វីនឹងកើតមាន ចំណែកព្រះរាជា ១០១ ក៏ទៅកាន់ទីលានធម្មយុទ្ធ ឈរវង់ចាំមើលផ្លូវ ត្រង់ទ្វារទិសខាងលិច ។ កេវដ្ដៈក៏ទៅដូច្នោះដូចគ្នា ។

ចំណែកព្រះមហោសថពោធិសត្វ កក់សក់ ស្រោះព្រំទឹកក្រអូបអំពីប្រលឹមហើយ ស្លៀកសំពត់ដែលកើតក្នុងដែនកាសី ដែលមានតម្លៃរាប់សែនកហាបណៈ ហើយប្រដាប់ដោយគ្រឿងអលង្ការទាំងពួង បរិភោគភោជនាហារមានរសដ៏ប្រសើរផ្សេងៗ ទៅកាន់ទ្វារដោយបរិវារធំ កាលបានព្រះរាជានុញ្ញាតឲ្យចូលគាល់ថា កូនរបស់យើងចូលមកដូច្នេះ ក៏ចូលទៅថ្វាយបង្គំព្រះរាជា ឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង កាលបានស្តាប់ព្រះរាជតម្រាស់សួរដល់ហេតុដែលមកគាល់ ទើបក្រាបទូលថា នឹងទៅកាន់ទីលានធម្មយុទ្ធ កាលព្រះរាជាត្រាស់សួរថា ត្រូវការអ្វី ទើបក្រាបទូលថា ទូលបង្គំបំណងនឹងបញ្ឆោតកេវដ្ដព្រាហ្មណ៍ដោយកែវមណី ទូលបង្គំគួរបានមណីរតនៈ ដែលមានជ្រុង ៨ ព្រះរាជាក៏ទ្រង់អនុញ្ញាត ។ មហោសថទទួលកែវមណីនោះហើយ ថ្វាយ

បង្គំព្រះរាជា ចុះអំពីព្រះរាជនិវេសន៍ មានយោធាដែលជាសហជាតមួយពាន់ ចោមរោម ឡើងកាន់រថដ៏ប្រសើរ ទឹមសេះសិន្ធពអស្សតរ ដែលមានតម្លៃ ៩ សែនកហាបណៈ ដល់ទ្វារក្នុងពេលបរិភោគអាហារព្រឹក ។ ចំណែកកេវដ្ដៈ ឈរចាំមើលការមកនៃមហោសថ ដោយគិតថា មហោសថនឹងមកដល់ក្នុងឥឡូវនេះ មហោសថនឹងមកដល់ក្នុងឥឡូវនេះ ហាក់ដូចអើតកសម្លឹងរកញើសក៏ហូរជោកខ្លួនដោយកម្ដៅនៃព្រះអាទិត្យ ។ ចំណែកមហោសថពេញទៅដោយភាពជាអ្នកមានបរិវារច្រើន ដូចមហាសមុទ្រជោរជន់ ជាអ្នកមិនបានតក់ស្លុត មិនមានការព្រឺរោមព្រឺស្បែក ដូចកេសរសីហរាជ ឲ្យបើកទ្វារចេញអំពីព្រះនគរ ចុះអំពីរថ ដើរទៅយ៉ាងអង់អាច ដូចស្ដេចរាជសីហ៍ ព្រះរាជា ១០១ ឃើញសិរីរូបនៃព្រះពោធិសត្វ ក៏បន្លឺសំឡេងអឺអរសរសើរព្រះពោធិ-សត្វ ប្រព្រឹត្តទៅថា បានឮថា កូនសិរិវឌ្ឍកសេដ្ឋី មានឈ្មោះថាមហោសថ-បណ្ឌិត ជាបុគ្គលមិនមានពីរ មិនមានអ្នកណាប្រៀបដោយបដិភាណក្នុងសកលជម្ពូទ្វីប ។

ចំណែកមហោសថ ហាក់បីដូចសក្កៈដែលគណៈទេវតាចោមរោម មានសិរីសម្បត្តិមិនមានបុគ្គលប្រៀប បានកាន់មណីរតនៈ ដើរតម្រង់ទៅរកកេវដ្ដ-ព្រាហ្មណ៍ ។ ចំណែកកេវដ្ដបុរោហិត ឃើញមហោសថបរមពោធិសត្វ ក៏មិនអាចតម្កល់ខ្លួនបាន ក្រោកឡើងទទួលពោលថា មហោសថបណ្ឌិត យើងទាំងពីរជាបណ្ឌិតដូចគ្នា កាលពួកខ្ញុំមកទីនេះយូរព្រោះលោក លោកមិនបញ្ជូនត្រឹមតែគ្រឿងបណ្ណាការមកខ្លះ ព្រោះហេតុអ្វី ទើបលោកធ្វើយ៉ាងនេះ ។ គ្រា

នោះ មហោសថឆ្លើយនឹងកេវដ្ដៈថា លោកបណ្ឌិត ខ្ញុំរកបណ្ណាការដែលសមគួរដល់លោក ទើបតែបានកែវមណីក្នុងថ្ងៃនេះឯង សូមលោកទទួលយកមណីរតនៈនេះ មណីរតនៈដទៃយ៉ាងនេះ មិនមានឡើយ កេវដ្ដៈឃើញកែវមណីដ៏រុងរឿងក្នុងដៃមហោសថ ក៏គិតថា មហោសថបំណងនឹងឲ្យអញ ទើបពោលថា បើដូច្នោះ សូមលោកឲ្យមកចុះ រួចលាដៃចេញទទួល មហោសថក៏ពោលថា សូមលោកចាំទទួលចុះ ក៏បោះទៅឲ្យធ្លាក់ក្នុងម្រាមដៃដែលលាទទួល ។ លំដាប់នោះ កេវដ្ដៈមិនអាចទ្រទ្រង់កែវមណីដែលមានទម្ងន់ដោយម្រាមដៃ កែវមណីក៏ធ្លាក់ក្បែរជើងមហោសថ កេវដ្ដៈក៏បន្ទោនកាយចុះទៀបបាតជើងមហោសថ ដោយប្រាថ្នានឹងកាន់យក ព្រោះសេចក្ដីលោភ ។ គ្រានោះ មហោសថមិនឲ្យកេវដ្ដៈក្រោកឡើងបាន ចាប់កកេវដ្ដៈដោយដៃម្ខាង ចាប់ជាយក្បិនដោយដៃម្ខាង ពោលថា លោកអាចារ្យក្រោកឡើង ខ្ញុំក្មេងស្មើនឹងចៅរបស់លោក លោកកុំថ្វាយបង្គំខ្ញុំឡើយ ហើយញ៉ាំងមុខរបស់កេវដ្ដៈឲ្យកូតត្រង់ផែនដីត្រឡប់ទៅត្រឡប់មក របូតមុខរបស់គាត់ប្រឡាក់ដោយឈាម ហើយពោលថា នែអន្ធពាល ឯងចង់បានការថ្វាយបង្គំអំពីយើងឬ ពោលដូច្នេះហើយ ចាប់ករបស់កេវដ្ដៈបោះទៅក្នុងទី ១ ឧសភៈ ក្រោកឡើង ចៀសចេញទៅ ។ យោធារបស់មហោសថ ក៏ចាប់យកកែវមណី សំឡេងមហោសថស្រែកថា ក្រោកឡើងចុះ ក្រោកឡើងចុះ កុំថ្វាយបង្គំខ្ញុំឡើយ ដូច្នេះបានឮគ្រប់បរិស័ទ ។ ចំណែកបរិស័ទមហោសថក៏ពោលថា កេវដ្ដៈថ្វាយបង្គំបាតជើងមហោសថ ហើយស្រែកហ៊ោដោយសំឡេងតែមួយ ព្រះរាជា ១០១

មួយអន្ទើយដោយព្រះបាទចូឡនី ក៏បានឃើញកេវដ្ដៈឱនកាយទៀបបាតជើង របស់មហោសថ ព្រះរាជាទាំងនោះ គិតថា បណ្ឌិតរបស់ពួកយើងថ្វាយបង្គំ មហោសថហើយ ឥឡូវនេះ ពួកយើងនឹងចាញ់ មហោសថនឹងមិនឲ្យជីវិតដល់ ពួកយើង គិតដូច្នេះហើយ ក៏ឡើងសេះរៀងៗ ខ្លួន ប្រារព្ធដើម្បីគេចតម្រង់ ទៅឧត្តរបញ្ចាល បរិស័ទរបស់ព្រះពោធិសត្វឃើញព្រះរាជាទាំងនោះគេចទៅ ហើយ ទើបប្រាប់គ្នាថា ព្រះបាទចូឡនីព្រហ្មទត្ត នាំព្រះរាជា ១០១ រត់ទៅ ហើយ ហើយស្រែកដូចគ្នាទៀត ។ ព្រះរាជាទាំងពួងបានស្ដាប់សំឡេងនោះ ខ្លាចចំពោះមរណភ័យ ក៏នាំកងទ័ពរត់ទៅ បរិស័ទព្រះពោធិសត្វក៏បន្លឺសំឡេង ដោយកោលាហលធំ មហោសថមានសេនាទិករចោមរោម ត្រឡប់ចូល មិថិលានគរ ។

ចំណែកកងទ័ពរបស់ព្រះបាទចូឡនីព្រហ្មទត្ត គេចទៅបាន ៣ យោជន៍ ឯកេវដ្ដៈក៏ឡើងជិះសេះមក ជូតឈាមត្រង់ថ្ងាស ទៅដល់កងទ័ព អង្គុយលើ ខ្នងសេះ ពោលថា នែអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយកុំរត់ទៅឡើយ យើងមិនបានថ្វាយបង្គំបុត្រគហបតី ឈ្មោះថាមហោសថនោះទេ អ្នកទាំងឡាយ ឈប់ចុះ សេនាមិនជឿ មិនឈប់ ហើយធ្វើដំណើរទៅ នាំគ្នាជេរកេវដ្ដ-ព្រាហ្មណ៍ ពោលថា រ៉ឺយ ព្រាហ្មណ៍អាក្រក់ មានធម៌ដ៏លាមក លោកពោល ថា យើងនឹងធ្វើធម្មយុទ្ធ ហើយមកថ្វាយបង្គំមហោសថ ដែលស្មើនឹងចៅ ដែលមិនគួរថ្វាយបង្គំ កិច្ចដែលពួកខ្ញុំគប្បីធ្វើដល់លោកមិនមាន ដូច្នេះហើយ មិនស្ដាប់ពាក្យរបស់កេវដ្ដៈ នាំគ្នាធ្វើដំណើរទៅនោះឯង ។ កេវដ្ដៈទៅដោយ

របស់ទាន់កងទ័ព ទើបពោលថា នែអ្នកដ៏ចម្រើនទាំងឡាយ ចូរពួកអ្នកជឿយើងចុះ យើងមិនបានថ្វាយបង្គំមហោសថៗ បញ្ឆោតយើងដោយកែវមណី ញ៉ាំងព្រះរាជាទាំងពួងឲ្យដឹងដោយអាការផ្សេងៗ ឲ្យជឿពាក្យរបស់ខ្លួន ញ៉ាំងកងទ័ពដែលបែកខ្ចាត់ខ្ចាយហើយនោះឲ្យជួបជុំគ្នាជាប្រក្រតី សេនាធំដល់ម៉្លោះ បើកាន់យកធូលី ឬដុំដីត្រឹមតែមួយដុំគ្រវែងទៅសោត គំនរធូលី និងដីនឹងធ្វើកំពែងនគរឲ្យពេញព្រៀប តែបំណងនៃព្រះពោធិសត្វទាំងឡាយ រមែងសម្រេច ព្រោះហេតុនោះ បុគ្គលដែលបែរមុខចំពោះនគរ បាចធូលី ឬដុំដី មិនមានឡើយ កងទ័ពទាំងពួងត្រឡប់ដល់ទីតាំងបន្ទាយរបស់ខ្លួន ។ ព្រះរាជាចូឡនីត្រាស់សួរកេវដ្ដៈថា យើងនឹងធ្វើដូចម្ដេច កេវដ្ដៈទូលតបថា យើងទាំងឡាយកុំឲ្យអ្នកណាចេញចូលតាមទ្វារតូច កាត់ផ្ដាច់នូវការចេញចូល អ្នកនគរចេញចូលមិនបាន ក៏នឹងក្ដៅក្រហាយ បើកទ្វារ ពេលនោះ ពួកយើងនឹងចាប់ពួកបច្ចាមិត្តបាន ព្រះរាជាទូលថា ឧបាយនេះល្អ ។ ចំណែកមហោសថដឹងដំណឹងនោះដោយន័យមុន ទើបគិតថា កាលកងទ័ពនគរបញ្ចាលហ៊ុមទ័ពទីនេះយូរ ពួកយើងនឹងមិនមានផាសុក គួរឲ្យកងទ័ពនេះ រត់ទៅដោយឧបាយ នឹងឲ្យគេចទៅដោយការគិត ។ មហោសថពិចារណារកមនុស្សដែលឈ្លាសក្នុងការគិតម្នាក់ ឃើញព្រាហ្មណ៍ម្នាក់ឈ្មោះអនុកេវដ្ដៈ ទើបឲ្យហៅមកប្រាប់ថា នែអាចារ្យ អ្នកគួរជួយធ្វើការងារមួយរបស់ពួកយើង អនុកេវដ្ដៈសួរថា ខ្ញុំនឹងធ្វើអ្វី សូមលោកប្រាប់មកចុះ ទើបមហោសថបណ្ឌិតប្រាប់ឲ្យអនុកេវដ្ដៈជ្រាបថា សូមលោកអាចារ្យឡើងទៅតាមកំពែងនគរ កាលឃើញកងរក្សាខាង

យើងប្រមាទ ចូរបោះនំ និងត្រីសាច់ជាដើម ដើម្បីពួកកងទ័ពរបស់ព្រះបាទចូឡនីក្នុងចន្លោះៗ ហើយស្រែកប្រាប់ថា អ្នកដ៏ចម្រើនទាំងឡាយ ចូរពួកលោកទំពាស៊ីរបស់នេះៗ កុំអផ្សុក កុំក្តៅក្រហាយឡើយ ចូរព្យាយាមត្រឹម ២-៣ ថ្ងៃចុះ ។ អ្នកក្រុងមិថិលា ក៏ក្តៅ និងក្រហាយ ដូចមាន់ក្តៅក្រហាយស្លាប់ក្នុងទ្រុងដូច្នោះ មិនយូរប៉ុន្មានទីងបើកទ្វារនគរដើម្បីពួកលោក បន្ទាប់ពីនោះ ពួកលោកនឹងចាប់ព្រះបាទក្រុងមិថិលា និងមហោសថអាក្រក់ កងរក្សារបស់ពួកយើងបានស្តាប់ពាក្យរបស់អ្នក នឹងគំរាមអ្នកធ្វើដូចជាចាប់ដៃ និងចាប់ជើងអ្នក វាយដោយបន្ទះឫស្សី ឲ្យកងទ័ពរបស់ព្រះបាទចូឡនីឃើញ ហើយឲ្យអ្នកចុះអំពីកំពែង កួចសក់អ្នកឲ្យជាជុក ៥ ហើយរោយកម្ទេចឥដ្ឋលើក្បាល ហើយឲ្យអ្នកទ្រទ្រង់នូវផ្កាឃីថោ ហើយវាយអ្នកបន្តិចបន្តួច លុះឃើញស្នាមត្រង់ខ្នងហើយ ឲ្យអ្នកឡើងលើកំពែង ឲ្យអ្នកអង្គុយក្នុងសង្រែកយកខ្សែចងទម្លាក់ទៅក្រៅកំពែងនគរ ហើយបង្ហាញឲ្យកងទ័ពរបស់ព្រះបាទចូឡនី បានឮថា នែអាចោរទម្លាយគំនិត ចូរឯងទៅ ពួកកងទ័ពរបស់ព្រះបាទចូឡនី នឹងនាំអ្នកទៅគាល់ព្រះបាទចូឡនីៗ ទតឃើញអ្នក នឹងត្រាស់សួរថា ឯងមានកំហុសអ្វី ពេលនោះ អ្នកគួរទូលយ៉ាងនេះដល់ព្រះបាទចូឡនីថា បពិត្រមហារាជ ពីមុន ទូលបង្គំមានយសធំ មហោសថក្រោធនឹងទូលបង្គំថាជាអ្នកទម្លាយការគិត ទើបទូលព្រះបាទវិទេហរាជ ហើយដណ្តើមយកយសរបស់ទូលបង្គំទាំងអស់ ទូលបង្គំគិតថា នឹងសូមឲ្យពួកពលរបស់ព្រះអង្គកាត់ក្បាលរបស់កូនគហបតីដែលដណ្តើមយសរបស់ទូលបង្គំទៅ គិតដូច្នេះហើយ

បានឃើញយោធារបស់ទ្រង់ក្តៅក្រហាយ ទើបឲ្យរបស់គួរទំពា គួរបរិភោគ ដល់យោធាទាំងនោះ មហោសថដាក់ចិត្តនឹងទូលបង្គំ ដែលមានពៀរស្រោប់ ដោយហេតុមានប្រមាណប៉ុណ្ណេះ ទើបឲ្យទូលបង្គំដល់នូវសេចក្តីវិនាសនេះ ជនទាំងពួងរបស់ព្រះអង្គដឹងហេតុទាំងអស់ ។ ចូរអ្នកញ៉ាំងព្រះបាទចូឡនីព្រហ្ម-ទត្តឲ្យជឿដោយប្រការផ្សេងៗ កាលកើតសេចក្តីស្និទ្ធស្នាលគ្នាហើយ សឹមទូលថា បពិត្រមហារាជ តាំងពីទ្រង់បានទូលបង្គំមកហើយ ទ្រង់កុំវិតក្កឡើយឥឡូវនេះ ព្រះជន្មរបស់ព្រះបាទវិទេហរាជ និងជីវិតរបស់មហោសថ នឹងមិនមាន ព្រោះទូលបង្គំដឹងទីមាំទាំ និងទីមិនមានកម្លាំង និងទីដែលមាន ឬមិនមានសត្វកាច មានក្រពើជាដើម ក្នុងគូនៃកំពែងក្នុងនគរនេះ ទូលបង្គំនឹងដណ្តើមយកនគរថ្វាយទ្រង់ ដោយកាលមិនយូរឡើយ កាលទូលយ៉ាងនេះ ព្រះបាទចូឡនីទ្រង់នឹងជឿ ប្រទានរង្វាន់ដល់អ្នក បន្ទាប់អំពីនោះ នឹងឲ្យអ្នកគ្រប់គ្រងកងទ័ព និងពាហនៈរបស់ព្រះអង្គ ពេលនោះ ចូរអ្នកគ្រប់គ្រងកងទ័ពរបស់ព្រះបាទចូឡនី ឲ្យចុះក្នុងគូទឹកដែលមានក្រពើកាច កងទ័ពរបស់ព្រះបាទចូឡនីនឹងមិនចុះ ដោយខ្លាចក្រពើ កាលនោះ ចូរអ្នកទូលថា បពិត្រព្រះសម្មតិទេព មហោសថញុះញង់ឲ្យកងទ័ពបែកបាក់គ្នា កងទ័ពទាំងនេះក្បត់នឹងព្រះអង្គហើយ បុគ្គលណាម្នាក់ តាំងពីព្រះរាជា ១០១ និងកេវដ្ត-ព្រាហ្មណ៍ មិនទទួលសំណូកមហោសថមិនមាន ជនទាំងនោះ ដែលចោមរោមទ្រង់ទាំងអស់ សុទ្ធតែជាបក្ខពួករបស់មហោសថ សេវកាមាត្យរបស់ព្រះអង្គ មានតែទូលបង្គំម្នាក់ប៉ុណ្ណោះ បើទ្រង់មិនជឿ សូមទ្រង់មានព្រះរាជ-

ឱង្ការដល់ព្រះរាជាទាំងអស់ថា ចូរអ្នកទាំងឡាយតែងខ្លួនមករកយើង ដូច្នេះ ពេលនោះ ទ្រង់នឹងទតឃើញអក្សរក្នុងព្រះរាជាករណៈ មានសំពត់ គ្រឿងប្រដាប់ និងព្រះខ័នជាដើម ដែលមហោសថចារឹកឈ្មោះរបស់ខ្លួន ថ្វាយដល់ព្រះរាជាទាំងនោះ ទ្រង់នឹងជឿ អ្នកទូលដូច្នេះ ព្រះបាទចូឡនីព្រហ្មទត្តនឹងធ្វើតាមយ៉ាងនោះ នឹងទតឃើញអក្សរដែលចារឹកឈ្មោះមហោសថ ក្នុងរាជាករណៈទាំងនោះ កាលទ្រង់ជឿ ទ្រង់នឹងភ័យខ្លាច បញ្ជូនព្រះរាជាទាំងនោះត្រឡប់ទៅ ហើយនឹងត្រាស់ជាមួយអ្នកថា ឥឡូវនេះ ពួកយើងនឹងធ្វើអ្វីល្អ អ្នកគួរក្រាបទូលព្រះរាជាអង្គនេះថា មហោសថជាមនុស្សមានមាយាច្រើន បើទ្រង់ប្រថាប់នៅអស់ថ្ងៃបន្តិចបន្តួច មហោសថនឹងធ្វើអន្ទាក់សេនារបស់ព្រះអង្គឲ្យនៅក្នុងកណ្ដាប់ដៃខ្លួន ហើយចាប់ព្រះអង្គ យើងទាំងឡាយកុំយឺតយូរ ប្រញាប់ឡើងសេះគេចទៅ ក្នុងវេលាមជ្ឈិមយាមថ្ងៃនេះ សូមមរណភ័យរបស់ពួកយើង កុំបីមានក្នុងបុគ្គលដទៃឡើយ ។ ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់បានស្ដាប់ពាក្យរបស់អ្នកដូច្នោះ ទ្រង់នឹងធ្វើតាម ចូរអ្នកត្រឡប់ទៅក្នុងកាលដែលព្រះបាទចូឡនីគេចទៅ ហើយញ៉ាំងពួកយោធារបស់ពួកយើងឲ្យដឹង ។ អនុកេវដ្ដព្រាហ្មណ៍ ស្ដាប់ពាក្យប្រាប់នោះក៏ពោលថា បពិត្របណ្ឌិត ប្រពៃហើយ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោក មហោសថក៏ពោលថា បើយ៉ាងនោះ លោកគួរអត់ធន់ចំពោះការវាយបន្តិចបន្តួច ។ អនុកេវដ្ដៈពោលតបថា បពិត្របណ្ឌិត វៀរតែជីវិត ដៃ ជើងរបស់ខ្ញុំ អ្វីដទៃក្រៅអំពីនោះ សូមលោកធ្វើតាមគាប់ចិត្តរបស់លោក មហោសថក៏ឲ្យទ្រព្យ ដល់មនុស្សក្នុងផ្ទះរបស់អនុកេវដ្ដៈហើយ

ធ្វើព្រាហ្មណ៍ឲ្យដល់នូវប្រការចម្លែកដូចពោលហើយ ហើយឲ្យអង្គុយក្នុងសង្រែក ចងខ្សែទម្លាក់ចុះឲ្យដល់ពួកសេវកៈរបស់ព្រះបាទចូឡនីព្រហ្មទត្ត ។

លំដាប់នោះ ពួកសេនាក៏ចាប់អនុកេវដ្ដៈ នាំទៅថ្វាយព្រះបាទព្រហ្មទត្ត ព្រះរាជាទ្រង់សាកសួរហើយ ក៏ជឿព្រាហ្មណ៍អនុកេវដ្ដៈ ទ្រង់ក៏ប្រទានរង្វាន់ដល់អនុកេវដ្ដៈ ហើយឲ្យគ្រប់គ្រងពួកទាហាន ។ ចំណែកអនុកេវដ្ដៈ ក៏ញុំាងសេនាឲ្យចុះត្រង់ទីដែលមានក្រពើកាច ពលនិកាយត្រូវក្រពើទាំងឡាយខាំ ត្រូវកងរក្សាដែលនៅត្រង់សសរខឿន បាញ់ដោយសរ លំពែង និងលំពែងស្នែងក្របីក៏ដល់នូវសេចក្ដីវិនាសធំ ចាប់តាំងអំពីនោះក៏មិនអាចចូលទៅជិតដោយការខ្លាចអន្តរាយបែបនោះ លំដាប់នោះ អនុកេវដ្ដៈចូលគាល់ព្រះបាទចូឡនីព្រហ្មទត្តទូលថា បពិត្រព្រះសម្មតិទេព ពួកអ្នកចម្បាំងដើម្បីប្រយោជន៍ដល់ព្រះអង្គមិនមាន មានតែពួកទទួលសំណូកទាំងអស់ បើទ្រង់មិនជឿ សូមហៅឲ្យជនទាំងនោះមក ទ្រង់នឹងទតឃើញអក្សរចារឹកឈ្មោះមហោសថ ក្នុងគ្រឿងឧបភោគ មានសំពត់ស្លៀកជាដើម ។ ព្រះបាទក្រុងឧត្តរបញ្ចាលឲ្យធ្វើយ៉ាងនោះ ក៏ទតឃើញអក្សរក្នុងសំពត់ជាដើម នៃជនទាំងអស់នោះ ក៏យល់ពិតថាជនទាំងនេះ ទទួលសំណូក ទើបត្រាស់សួរអនុកេវដ្ដៈថា ឥឡូវនេះ យើងគួរធ្វើដូចម្ដេច កាលអនុកេវដ្ដៈឆ្លើយថា កិច្ចដទៃដែលគួរធ្វើមិនមាន បើទ្រង់បង្អែបង្អង់ មហោសថកូនគហបតីនឹងចាប់ព្រះអង្គ ចំណែកអាចារ្យកេវដ្ដៈ ក៏សំកុកព្រោះដំបៅត្រង់មុខប៉ុណ្ណោះ ទោះបីអាចារ្យកេវដ្ដៈនោះ ក៏ទទួលសំណូកដូចគ្នាព្រោះទទួលមណីរតនៈ ហើយញុំាងទ្រង់ឲ្យរត់ទៅអស់ ៣ យោជន៍ ឲ្យទ្រង់

ជឿហើយឲ្យត្រឡប់ គាត់នេះឯងញុះញង់កងទ័ពឲ្យបែកគ្នា ទូលបង្គំមិនស្ម័គ្រនៅជាមួយ សូម្បីត្រឹមតែមួយយប់ គួរចៀសចេញទៅក្នុងកណ្តាលយប់នេះ វៀរទូលបង្គំហើយ បុគ្គលដទៃ ឈ្មោះថា មានបំណងល្អមិនមាន កាលអនុកេវដ្ដៈទូលដូច្នេះ ក៏ត្រាស់ថា បើយ៉ាងនោះ ចូរលោកអាចារ្យចងសេះព្រះទីន័ង ហើយត្រៀមយានដើម្បីយើង អនុកេវដ្ដៈដឹងភាពដែលព្រះបាទចូឡនីគេច ដោយទ្រង់វិនិច្ឆ័យពិត ទើបទូលឲ្យទ្រង់កក់ក្ដៅថា សូមទ្រង់កុំខ្លាចឡើយ ហើយចេញទៅខាងក្រៅ ប្រាប់ពួកបុរសដែលមហោសថបង្គាប់ថា ថ្ងៃនេះព្រះបាទឧត្តរបញ្ចាលគេចទៅ អ្នកទាំងឡាយកុំត្រឡប់ឡើយ ប្រាប់ដូច្នេះហើយចងសេះព្រះទីន័ងដែលជាសេះកាច ហើយនាំមក ក្នុងវេលាមជ្ឈិមយាម ក្រាបទូលថា សេះព្រះទីន័ងបានត្រៀមហើយ សូមទ្រង់ជ្រាបកាលយាង ព្រះរាជាក៏ឡើងសេះគេចទៅ ចំណែកអនុកេវដ្ដៈ ក៏ឡើងសេះធ្វើដូចជាទៅដែរ ហើយក៏គេចត្រឡប់ សេះព្រះទីន័ងដែលចងយ៉ាងជាប់ សូម្បីព្រះរាជាទាញឲ្យឈប់ក៏នៅតែនាំព្រះរាជាគេចទៅតែម្យ៉ាង ចំណែកអនុកេវដ្ដៈ ចូលទៅក្នុងពួកសេនាក៏ស្រែកឡើងថា ព្រះរាជាចូឡនីព្រហ្មទត្តគេចទៅហើយ បុរសដែលមហោសថបង្គាប់ ក៏ស្រែកជាមួយពួករបស់ខ្លួន ចំណែកព្រះរាជា ១០១ បានស្ដាប់សំឡេងនោះ ក៏សម្គាល់ថា មហោសថបើកទ្វារចេញមក ឥឡូវនេះ គេនឹងមិនទុកជីវិតពួកយើង ក៏ខ្លាច មិនសម្លឹងមើលគ្រឿងឧបភោគបរិភោគ នាំគ្នាគេចទៅអំពីទីនោះៗ ជនទាំងឡាយ ក៏ស្រែកឡើងថា ព្រះរាជា ១០១ គេចទៅហើយ ទាហានរក្សាក្បែរកំពែងឮសំឡេងនោះ ក៏ស្រែកទះដៃឡើង ខណៈនោះ ព្រះ

នគរមិថិលាទាំងមូល ទាំងខាងក្នុង ទាំងខាងក្រៅ ក៏បន្លឺសំឡេងញាប់ញ័រតែមួយ ដូចគ្នានឹងផែនដីបែក ដូចផ្ទៃសមុទ្រវំជួយដូច្នោះ ពលនិកាយ ១៨ អក្ខោភិណីខ្លាចចំពោះមរណភ័យ ក៏យល់ថាព្រះបាទចូឡនី និងព្រះរាជា ១០១ ត្រូវមហោសថចាប់បានហើយ ក៏ចោលសំពត់សាដកដែលរុំត្រង់ពោះរបស់ខ្លួនរត់ទៅ ទីដែលកងទ័ពបោះជំរំក៏ទទេ ។ ព្រះបាទចូឡនីព្រហ្មទត្ត នាំព្រះរាជា ១០១ ទៅកាន់ នគររបស់ខ្លួន ។ ស្អែកឡើង ពលនិកាយក្រុងមិថិលា បើកទ្វារនគរ ចេញអំពីព្រលឹម ឃើញគំនរទ្រព្យជាច្រើន ទើបប្រាប់ដល់មហោសថថា បពិត្របណ្ឌិត ពួកយើងនឹងធ្វើដូចម្តេច មហោសថពោលថា ទ្រព្យដែលពួកសត្រូវចោល គឺជារបស់ពួកអ្នក ចូរពួកអ្នកថ្វាយទ្រព្យដែលជារបស់ព្រះរាជាទាំងនោះ ដល់ព្រះរាជារបស់យើងទាំងឡាយ ចូរនាំរបស់ដែលជារបស់សេដ្ឋី និងរបស់កេវដ្ដៈមកឲ្យដល់យើង ចូរអ្នកនគរកាន់យកទ្រព្យដទៃក្រៅពីនេះ កាលជនទាំងឡាយនាំរតនភណ្ឌ ដែលមានតម្លៃច្រើនទៅអស់វេលាកន្លះខែ ជនទាំងឡាយនាំរបស់ដ៏សេសអំពីនោះទៅ អស់ពេល ៤ ខែ ព្រះពោធិសត្វឲ្យរង្វាន់ជាច្រើនដល់ព្រាហ្មណ៍អនុកេវដ្ដៈ ។ បានឮថា ចាប់តាំងពីនោះមក អ្នកក្រុងមិថិលា ក៏ស្ដុកស្ដម្ភដោយមាស និងប្រាក់ រតនៈដែលមានតម្លៃច្រើន ក៏កើតមានសន្ធឹកសន្ធាប់ ។

ព្រះបាទចូឡនីព្រហ្មទត្ត ប្រថាប់ក្នុងនគរឧត្តរបញ្ចាល ជាមួយព្រះរាជា ១០១ នោះអស់កាលមួយឆ្នាំ ។

ព្រហ្មទត្តយុទ្ធបរាជយកណ្ឌ ចប់

ថ្ងៃមួយ កេវដ្តព្រាហ្មណ៍ធ្មុះមុខដោយកញ្ចក់ ក៏ឃើញស្នាមត្រង់ថ្ងាស គិតថា ស្នាមនេះ មហោសថធ្វើអញឲ្យខ្មាសដល់ព្រះរាជាទាំងឡាយ មានប្រមាណប៉ុណ្ណេះ គិតដូច្នេះ ក៏ក្រោធ ទើបគិតសាជាថ្មីថា កាលណាហ្ន៎ ទើបអញអាចឃើញខ្នងមហោសថ ក៏នឹកបានថា ឧបាយមាន ក៏សន្និដ្ឋានថា ព្រះរាជធីតាព្រះរាជារបស់អញមាន ព្រះនាងមានឈ្មោះបញ្ចាលចន្ទី មានព្រះរូបដ៏ឧត្តម ប្រៀបដោយទេពអប្សរ អញនឹងឲ្យព្រះនាងដល់ព្រះបាទវិទេហរាជ ប្រលោមទ្រង់ដោយកាម ហើយនាំទ្រង់ដែលដូចជាត្រីជាប់សន្ទូច មួយអន្ទើដោយមហោសថមក សម្លាប់ទាំងពីរនាក់ ហើយផឹកជយបានៈ គិតដូច្នេះហើយ ទើបចូលគាល់ក្រាបទូលដល់ព្រះបាទចូឡនីថា បពិត្រព្រះសម្មតិទេព ទូលបង្គំមានគំនិតម្យ៉ាង ព្រះបាទចូឡនីបានស្ដាប់ពាក្យរបស់កេវដ្ដៈ ទើបត្រាស់ថា នែលោកអាចារ្យ ពួកយើងមិនជាម្ចាស់សូម្បីសំពត់សាដកដែលរុំពោះ ព្រោះអាស្រ័យការគិតរបស់លោក ឥឡូវនេះ លោកគិតធ្វើអ្វីទៀត សូមអង្គុយឲ្យស្ងៀមចុះ កេវដ្តព្រាហ្មណ៍ក៏ទូលថា បពិត្រមហារាជ ឧបាយដទៃដូចឧបាយនេះមិនមាន ព្រះរាជាត្រាស់ថា បើដូច្នេះ ចូរលោកពោលមកមើល កេវដ្ដៈក៏ទូលថា គួរនៅតែពីរនាក់ ព្រះរាជាទ្រង់ក៏ឃើញប្រពៃដូច្នោះ ទើបព្រាហ្មណ៍យាងព្រះរាជាឡើងលើប្រាសាទ ចូលទៅកាន់បន្ទប់សម្រាប់ផ្ទំហើយទូលថា យើងទាំងឡាយនឹងលួងព្រះបាទវិទេហរាជដោយកិលេស ហើយនាំខ្ទួនមកសម្លាប់ មួយអន្ទើដោយមហោសថ ព្រះរាជាត្រាស់ថា ឧបាយនេះល្អ តែយើងនឹងលួងលោមនាំគេមកបានដូចម្ដេច កេវដ្ដៈទូលថា បពិត្រមហារាជ

ព្រះរាជធីតារបស់ទ្រង់ព្រះនាមបញ្ចាលចន្ទី ទ្រទ្រង់រូបឆោម ដ៏ស្រស់ត្រកាល ពួកយើងនឹងឲ្យចិន្តកវី និពន្ធអំពីរូបសម្បត្តិដ៏មានសិរី និងលម្អនៃឥរិយាបថ ៤ នៃព្រះរាជធីតានោះចងជាចម្រៀង ហើយឲ្យអ្នកជំនាញច្រៀងនូវពាក្យកាព្យនោះ ក្នុងនគរមិថិលា ដោយសេចក្តីថា កាលព្រះរាជាដែនវិទេហរដ្ឋ មិនបានស្រីកែវបែបនេះ ព្រះរាជសម្បត្តិក៏មិនមានប្រយោជន៍ដូច្នេះ ដឹងថា ព្រះបាទវិទេហរាជប្រតិព័ទ្ធដោយការស្តាប់នោះឯង ទូលបង្គំនឹងទៅនគរមិថិលា កំណត់ថ្ងៃមកនាំព្រះរាជធីតាទៅអភិសេក កាលព្រះអង្គកំណត់ថ្ងៃ ត្រឡប់មកហើយ ព្រះបាទវិទេហរាជ ក៏ដូចជាត្រីលេបសន្ទូច នាំមហោសថមក ពេលនោះ យើងទាំងឡាយនឹងសម្លាប់ព្រះបាទវិទេហរាជ និងមហោសថចោល ព្រះបាទចូឡនីស្តាប់ពាក្យរបស់កេវដ្តៈហើយ ទ្រង់ត្រេកអរ ពោលថា ឧបាយរបស់លោកល្អ យើងទាំងឡាយនឹងធ្វើយ៉ាងនោះ ។ ឯសារិកាញីដែលចិញ្ចឹមក្នុងទីបន្ទំនៃព្រះបាទ ចូឡនីព្រហ្មទត្ត បានស្តាប់ការគិតនោះហើយ បានធ្វើឲ្យប្រចក្ស ។ ព្រះបាទចូឡនីឲ្យហៅពួកចិន្តកវីមក ព្រះរាជទានទ្រព្យជាច្រើន ហើយបង្ហាញព្រះរាជធីតាដល់ជនទាំងនោះ ត្រាស់ថា ចូរអ្នកទាំងឡាយចងកាព្យអាស្រ័យរូបសម្បត្តិរបស់ព្រះរាជធីតា ។ ពួកចិន្តកវីទាំងនោះ ក៏តែងបទចម្រៀងពីរោះ ចាប់ចិត្តក្រៃលែង ហើយច្រៀងថ្វាយព្រះរាជា ព្រះរាជាទ្រង់ព្រះរាជទានទ្រព្យជាច្រើនដល់ជនទាំងនោះទៀត អ្នកចម្រៀងទាំងឡាយរៀនបទចម្រៀងអំពីសម្នាក់ចិន្តកវីទាំងឡាយ ហើយទៅច្រៀងក្នុងមណ្ឌលមហោស្រព បទចម្រៀងនោះ បានផ្សព្វផ្សាយទៅដោយប្រការដូច្នេះ កាល

ចម្រៀងទាំងនោះ បានផ្សព្វផ្សាយទៅក្នុងពួកមហាជន ព្រះបាទចូឡនីត្រាស់ហៅពួកអ្នកចម្រៀងទាំងឡាយ មកត្រាស់ថា ចូរអ្នកទាំងឡាយចាប់បក្សីធំមកដាក់លើដើមឈើក្នុងរាត្រី អង្គុយច្រៀងលើដើមឈើនោះ ក្នុងពេលទៀបភ្លឺ ចូរចងកណ្ដឹងត្រង់កសត្វទាំងនោះ ហើយលែងទៅ សឹមចុះពីលើដើមឈើ ។ ព្រះបាទចូឡនីឲ្យធ្វើដូច្នេះ ដើម្បីហេតុឲ្យជារបស់ប្រាកដថា សូម្បីទេវតាទាំងឡាយ ក៏ច្រៀងពណ៌នាព្រះរូបឆោមនៃព្រះរាជធីតារបស់ព្រះបាទបញ្ចាល ។ ព្រះបាទចូឡនីត្រាស់ហៅពួកចិន្តកវីនោះមកទៀត ត្រាស់ថា ឥឡូវនេះ អ្នកទាំងឡាយចូរពណ៌នាសរសើរថា កុមារិកាបែបនេះ មិនសមគួរដល់ព្រះរាជាដទៃក្នុងជម្ពូទ្វីបឡើយ នាងសមគួរដល់ព្រះបាទវិទេហរាជនគរមិថិលា ឥស្សរិយយសរបស់ព្រះបាទវិទេហរាជ គួរដល់ព្រះរាជធីតានេះមួយអង្គប៉ុណ្ណោះ ដូច្នេះហើយ ឲ្យចងជាចម្រៀង ។ ចិន្តកវីទាំងនោះ បានធ្វើតាមព្រះរាជបញ្ជាហើយ ច្រៀងថ្វាយទ្រង់ព្រះសណ្ដាប់ ព្រះបាទចូឡនីក៏ព្រះរាជប្រទានទ្រព្យដល់ជនទាំងនោះ ហើយត្រាស់ថា ចូរអ្នកទាំងឡាយទៅកាន់ក្រុងមិថិលាហើយច្រៀងដោយឧបាយនេះឯង ក្នុងនគរមិថិលានោះទៀត ចិន្តកវីទាំងនោះកាលច្រៀងចម្រៀងទាំងនោះ ទៅដល់ក្រុងមិថិលាដោយលំដាប់ ក៏ច្រៀងក្នុងរោងមហោស្រព មហាជនបានស្ដាប់ចម្រៀងទាំងនោះ ក៏ញ៉ាំងសំឡេងឲ្យកក្រើករំពើក បានឲ្យទ្រព្យជាច្រើនដល់ជនទាំងនោះ ជនទាំងនោះ ក៏ច្រៀងលើដើមឈើក្នុងពេលរាត្រី លុះពេលទៀបភ្លឺ ក៏ចងកណ្ដឹងត្រង់កបក្សីទាំងឡាយ ហើយក៏ចុះអំពីដើមឈើ សំឡេងកោលាហលតែមួយថា សូម្បីទេវតា

ទាំងឡាយ ក៏ច្រៀងពណ៌នាព្រះរូបឆោមរបស់ព្រះរាជធីតានៃព្រះបាទបញ្ចាល ដូច្នេះ ក៏លាន់ឮក្នុងព្រះនគរទាំងមូល ព្រោះបានឮសំឡេងកណ្តឹងក្នុងអាកាស ព្រះបាទវិទេហរាជទ្រង់បានស្តាប់សំឡេងនោះ ទើបឲ្យហៅពួកអ្នកនិពន្ធមក លេងមហោស្រពក្នុងព្រះរាជនិវេសន៍ ហើយទ្រង់ត្រិះរិះថា បានឮថា ព្រះបាទចូឡនី មានព្រះរាជបំណងប្រទានព្រះរាជធីតា ដែលទេវទ្រង់នូវរូបឆោមដ៏ឧត្តមបែបនេះដល់អញ ទ្រង់ត្រិះរិះដូច្នេះ ក៏ត្រេកអរ បានព្រះរាជទានទ្រព្យជាច្រើនដល់អ្នកនិពន្ធទាំងនោះ ជនទាំងនោះក៏ត្រឡប់ នាំសេចក្តីមកក្រាបទូលដល់ព្រះបាទចូឡនីព្រហ្មទត្ត ។ គ្រានោះ កេវដ្តៈអាចារ្យក៏ក្រាបទូលព្រះបាទចូឡនីថា ឥឡូវនេះ ទូលបង្គំនឹងទៅដើម្បីដាក់ថ្ងៃ ព្រះរាជាត្រាស់ថា សាធុ លោកគួរកាន់យកអ្វីទៅខ្លះ កេវដ្តៈក្រាបទូលថា គួរយកបណ្ណាការបន្តិចបន្តួចទៅ ទ្រង់ក៏អនុញ្ញាត កេវដ្តៈក៏កាន់យកគ្រឿងបណ្ណាការទៅដោយបរិវារធំដល់វិទេហរដ្ឋ សំឡេងកោលាហលតែមួយ បានកើតឡើងក្នុងក្រុងមិថិលា ព្រោះបានស្តាប់ការមករបស់កេវដ្តៈថា បានឮថា ព្រះបាទចូឡនី និងព្រះបាទវិទេហរាជ ធ្វើនូវសម្ពន្ធមេត្រីចំពោះគ្នា ចំណែកព្រះបាទចូឡនីនឹងប្រទានព្រះរាជធីតារបស់ព្រះអង្គ ដល់ព្រះរាជារបស់ពួកយើង ។ បានឮថា កេវដ្តព្រាហ្មណ៍មកគាល់ដើម្បីកំណត់ថ្ងៃយាងទៅអភិសេក ព្រះបាទវិទេហរាជទ្រង់បានស្តាប់ពាក្យនោះ សូម្បីព្រះមហាសត្វក៏បានស្តាប់ដូចគ្នា សេចក្តីត្រិះរិះមានដល់មហាសត្វថា ការដែលកេវដ្តៈមក រមែងមិនពេញចិត្តអញ អញនឹងដឹងហេតុនោះតាមសេចក្តីពិតដូច្នេះ ព្រោះបានឮពាក្យនោះ ទើបមហោសថបញ្ជូន

ដំណឹងទៅកាន់បុរសដែលបង្កប់ ក្នុងសម្នាក់របស់ព្រះបាទចូឡនីថា ចូរអ្នកដឹងសេចក្ដីនេះតាមសេចក្ដីពិត ហើយឲ្យដំណឹងមកយើង ។ លំដាប់នោះ ពួកបុរសដែលដាក់បង្កប់ក៏ឲ្យដំណឹងមកថា ពួកខ្ញុំមិនដឹងសេចក្ដីនេះឡើយ ព្រះបាទចូឡនី និងកេវដ្ដៈ អង្គុយប្រឹក្សាគ្នាក្នុងបន្ទប់សម្រាប់ផ្ទំ តែសារិកាដែលចិញ្ចឹមត្រង់ទីបន្ទំរបស់ព្រះបាទចូឡនី ដឹងនូវផែនការនេះ មហាសត្វបានស្ដាប់ដូច្នោះហើយ គិតថា អញនឹងមិនឲ្យកេវដ្ដៈ ឃើញនគរដែលរៀបចំល្អហើយ ចែកល្អហើយ ដូចបច្ចាមិត្តមិនមានឱកាស ទើបមហោសថឲ្យព័ទ្ធទីដែលមកទាំងសងខាង និងខាងលើដោយកន្ទេលផែង តាំងអំពីទ្វារនគរ រហូតដល់ព្រះរាជនិវេសន៍ តាំងអំពីព្រះរាជនិវេសន៍ រហូតដល់ផ្ទះរបស់ខ្លួន ឲ្យគូរក្រវិល្លិ៍លើផែនដី ឲ្យតម្កល់ក្អមទឹកពេញ និងឲ្យបញ្ឈរដើមចេកចងទង់ ។ កេវដ្ដៈចូលកាន់ព្រះនគរ កាលមិនឃើញក្រុងដែលចែកល្អ ហើយគិតថា ព្រះរាជាឲ្យតាក់តែងផ្លូវសម្រាប់អញ មិនដឹងថា គេធ្វើដើម្បីមិនឲ្យឃើញក្នុងព្រះនគរ ។ កេវដ្ដៈចូលគាល់ថ្វាយបង្គំព្រះបាទវិទេហរាជ ថ្វាយគ្រឿងបណ្ណាការ ទូលបដិសណ្ឋារៈហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ព្រះបាទវិទេហរាជទ្រង់ធ្វើសក្ការៈរាប់អានហើយ កាលនឹងទូលដល់ហេតុការណ៍ដែលមក បានពោលគាថានេះថា

> ព្រះរាជាចូឡនីប្រាថ្នា ដើម្បីធ្វើសម្ពន្ធមិត្ត ( នឹងព្រះអង្គ ) ទាំងទ្រង់ថ្វាយកែវទាំងឡាយ មានស្រីកែវជាដើមដល់ព្រះអង្គ ( ចាប់ដើម ) ពីថ្ងៃនេះទៅ សូមឲ្យពួករាជទូតមានវាចាពីរោះ ពោល

ពាក្យជាទីស្រឡាញ់មក ( ក្នុងក្រុងមិថិលានេះបាន ) សូមឲ្យពួករាជទូតទាំងនេះ ពោលវាចាដ៏ទន់ភ្លន់ ជាវាចាគួរត្រេកអរ សូមព្រះបាទបញ្ចាល និងព្រះបាទវិទេហៈទាំងពីរអង្គនោះ រួបរួមគ្នាតែមួយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្ថវកាមោ តេ** សេចក្តីថា បពិត្រមហារាជ ព្រះរាជារបស់ទូលបង្គំទាំងឡាយ មានព្រះរាជបំណងនឹងធ្វើសម្ពន្ធមេត្រីជាមួយទ្រង់ ។ បទថា **រតនានិ** សេចក្តីថា នឹងប្រទានរតនៈទាំងឡាយចាប់តាំងអំពីព្រះរាជធីតា ដែលជាឥត្ថីរតនៈដល់ព្រះអង្គ ។ បទថា **អាគច្ឆន្តុ** សេចក្តីថា បានឮថា តាំងអំពីនេះទៅ ទូតទាំងឡាយមានវាចាពីរោះ ពោលពាក្យជាទីស្រឡាញ់ នាំនូវគ្រឿងបណ្ណាការអំពីឧត្តរបញ្ចាលនគរមកក្នុងមិថិលានគរនេះ និងពីមិថិលានគរនេះទៅក្នុងឧត្តរបញ្ចាលនគរនោះ ។ បទថា **ឯកា ភវន្តុ** សេចក្តីថា សូមរដ្ឋទាំងពីររួបរួមគ្នាតែមួយ ដូចទឹកគង្គាហូររួមជាមួយទឹកយមុនា ដូច្នោះ ។

កាលក្រាបទូលដូច្នេះហើយ កេវដ្តៈបានក្រាបទូលបន្តថា បពិត្រមហារាជ ព្រះរាជារបស់ទូលបង្គំ ប្រាថ្នានឹងបញ្ជូនអមាត្យដទៃមក ក៏មិនអាចប្រាប់ដំណឹងឲ្យជាទីគាប់ព្រះរាជហឫទ័យ ព្រោះដូច្នោះ ទើបបញ្ជូនទូលបង្គំមកដោយព្រះរាជឱង្ការថា លោកអាចារ្យ សូមលោកញ៉ាំងព្រះបាទវិទេហរាជឲ្យទ្រង់ជ្រាបល្អ ហើយនាំទ្រង់មក ដូច្នេះ បពិត្រព្រះរាជាដ៏ប្រសើរ សូមទ្រង់ធ្វើព្រះរាជដំណើរទៅ នឹងបានព្រះរាជធីតាមានរូបស្អាតពន់ពេក ហើយ

ចំណងមេត្រីរវាងទ្រង់ និងព្រះរាជារបស់ទូលបង្គំទាំងឡាយ នឹងតាំងមាំដល់ព្រះអង្គ ។ ព្រះបាទវិទេហរាជ បានស្តាប់ពាក្យរបស់កេវដ្ដៈហើយ ទ្រង់សោមនស្ស ជាប់ជំពាក់ ដោយទ្រង់បានស្ដាប់ថា នឹងបានព្រះរាជធីតារូបស្អាត ទើបត្រាស់ថា នែអាចារ្យ បានឮថា ការវិវាទព្រោះរឿងធម្មយុទ្ធមានដល់លោក និងមហោសថ សូមលោកទៅរកមហោសថកូនរបស់យើង លោកទាំងពីរជាបណ្ឌិត ចូរញ៉ាំងគ្នានិងគ្នាឲ្យខមាទោស ប្រឹក្សាគ្នាហើយ សឹមត្រឡប់មក កេវដ្ដៈបានស្ដាប់ព្រះរាជតម្រាស់ ក៏ទៅដោយគិតថា អញនឹងជួបមហោសថ ។ ចំណែកមហាសត្វ ដឹងថា កេវដ្ដៈមកកាន់សម្នាក់របស់ខ្លួនក្នុងថ្ងៃនោះ គិតថា ការដែលអញចរចាជាមួយកេវដ្ដៈដែលមានកម្មដ៏លាមកជាធម្មតា ចូរកុំមានឡើយ គិតដូច្នេះហើយ ទើបផឹកសប្បិបន្តិចអំពីព្រលឹម ។ អ្នករក្សាផ្ទះយកគោម័យស្រស់ជាច្រើនមកលាបត្រង់ផ្ទះមហោសថ និងយកប្រេងលាបសសរទាំងឡាយ ទុកតែគ្រែមួយដែលជាទីដេករបស់មហោសថក្រៅអំពីនេះ ឲ្យទុកដាក់ទាំងអស់ មិនថាតែគ្រែ ឬតាំង មហោសថបានឲ្យសញ្ញាដល់ជនជាបរិវារថា បើព្រាហ្មណ៍ប្រាថ្នានឹងនិយាយជាមួយពួកអ្នក អ្នកគប្បីពោលយ៉ាងនេះថា នែព្រាហ្មណ៍ លោកកុំគប្បីពោលជាមួយបណ្ឌិតព្រោះថ្ងៃនេះ បណ្ឌិតផឹកសប្បិ កាលយើងធ្វើអាការនិយាយជាមួយកេវដ្ដៈ ពួកអ្នកគប្បីឃាត់ថា លោកផឹកសប្បិយ៉ាងច្រើន លោកកុំនិយាយ ។ មហោសថប្រាប់យ៉ាងនេះហើយ ស្លៀកសំពត់ពណ៌ក្រហម ដាក់អ្នកយាមត្រង់ខ្លោងទ្វារទាំង ៧ ហើយដេកលើគ្រែសំពត់ ។ ចំណែកកេវដ្ដៈ ឈរត្រង់

ទ្វារទីមួយរបស់ផ្ទះមហោសថ សួរថា បណ្ឌិតនៅឯណា លំដាប់នោះ ជនទាំងឡាយក៏ឃាត់ព្រាហ្មណ៍កេវដ្ដៈថា នែព្រាហ្មណ៍ លោកកុំធ្វើមាត់ បើលោកចង់មក ចូរមកស្ងាត់ៗ ព្រោះថ្ងៃនេះ បណ្ឌិតផឹកសប្បិយ៉ាងច្រើន លោកមិនត្រូវធ្វើសំឡេងខ្លាំង ជនទាំងឡាយត្រង់ខ្លោងទ្វារក្រៅអំពីនេះ ក៏ឃាត់ព្រាហ្មណ៍យ៉ាងនោះ កេវដ្ដៈកន្លងខ្លោងទ្វារទី ៧ ក៏ដល់សម្នាក់មហោសថ ។ មហោសថសម្ដែងអាការទើងនិយាយ លំដាប់នោះ ជនទាំងឡាយក៏ឃាត់ថា លោកកុំនិយាយ ព្រោះលោកផឹកសប្បិយ៉ាងច្រើន ប្រយោជន៍អ្វីដោយការនិយាយជាមួយព្រាហ្មណ៍អាក្រក់នេះ ។ កេវដ្ដៈទៅកាន់សម្នាក់មហោសថបណ្ឌិត មិនបានអង្គុយ មិនបានសូម្បីទីឈរ អាស្រ័យអាសនៈ ត្រូវឈរជាន់គោម័យស្រស់ ។ លំដាប់នោះ អ្នកបម្រើរបស់មហោសថម្នាក់ សម្លឹងមើលកេវដ្ដៈហើយ បើកភ្នែកធំៗ ម្នាក់ទៀតសម្លឹងមើលហើយ លើកចិញ្ចើមឡើង ម្នាក់ទៀតសម្លឹងមើលហើយ បត់ជុំដៃ មនុស្សពួកខ្លះ សម្ដែងអាការមានកាយវិការ មានដៃ និងជើងជាដើម កេវដ្ដៈឃើញកិរិយាមនុស្សរបស់មហោសថ ក៏ខ្មាសអៀន ពោលថា នែលោកបណ្ឌិត ខ្ញុំសូមលាសិនហើយ កាលមនុស្សដទៃៗ ពោលថា នែព្រាហ្មណ៍កំណាច អ្នកកុំបន្លឺសំឡេង បើអ្នកបចេសយើងនឹងទម្លាយឆ្អឹងរបស់អ្នក ជាអ្នកកិតក័យ ត្រឡប់ទៅមិនមើលក្រោយ ។ លំដាប់នោះ បុរសម្នាក់ ក្រោកឡើងវាយខ្នងកេវដ្ដៈដោយបន្ទះឫស្សី ម្នាក់ប្រហារដោយបាតដៃ ម្នាក់ចាប់ត្រង់កច្រានទៅ កេវដ្ដៈខ្លាចផងភ័យផង ចេញទៅកាន់ព្រះរាជវាំង ដូចម្រឹគផុតចាកមាត់រាជសីហ៍ ។ ព្រះបាទ

វិទេហរាជទ្រង់ត្រិះរិះថា ថ្ងៃនេះ កូនរបស់អញបានស្តាប់ព្រឹត្តិហេតុនេះហើយ នឹងជាអ្នកត្រេកអរ ជម្នះសាកច្ចាធំ គប្បីមានដល់បណ្ឌិតទាំងពីរ ថ្ងៃនេះ បណ្ឌិតទាំងពីរ នឹងញ៉ាំងគ្នានិងគ្នាឲ្យអត់ទោស ជាលាភរបស់អញហ្ន៎ ព្រះអង្គទតឃើញកេវដ្ដៈ កាលនឹងត្រាស់សួរអាការជួបនឹងមហោសថបណ្ឌិត ទើបត្រាស់គាថានេះថា

នៃកេវដ្ដៈ អ្នកបានជួបនឹងមហោសធដែរឬ អ្នកចូរពោលសេចក្តីនោះ អ្នកបានឲ្យមហោសធ អត់ទោសហើយឬ មហោសធត្រេកអរហើយឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិនិជ្ឈត្តោ** សេចក្តីថា ដើម្បីរម្ងាប់នូវការឈ្លោះទាស់ទែងគ្នាដែលប្រព្រឹត្តទៅក្នុងលានធម្មយុទ្ធ មហោសថបានអត់ទោសឲ្យលោក ឯលោកបានអត់ទោសឲ្យមហោសថហើយឬ ។ បទថា **កច្ចិ តុដ្ឋោ** សេចក្តីថា មហោសថបានស្តាប់ព្រឹត្តិហេតុ ដែលព្រះរាជារបស់ពួកលោកបញ្ជូនមក ត្រេកអរហើយឬ ។

លំដាប់នោះ កេវដ្ដៈទូលថា ទ្រង់កុំកាន់យកមហោសថថាជាបណ្ឌិតឡើយ មនុស្សដែលជាអសប្បុរសក្រៃលែងជាងមហោសថមិនមាន ហើយពោលគាថានេះថា

បពិត្រព្រះអង្គជាធំជាងជន មហោសធហៅពេញជាបុរសថោកទាប ពុំមានសេចក្តីសោះស្មើ ជាមនុស្សរឹងរូស ជាអសប្បុរស ពុំបានពោលសេចក្តីអ្វីតិចតួចសោះ ដូចជាមនុស្សគ ឬដូចជា

មនុស្សប្រុង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសត្ថិរេចោ** បានដល់ មិនមែនជាតិបណ្ឌិត ។ បទថា **ន កិញ្ចិត្តំ** សេចក្តីថា មហោសថមិនពោលសេចក្តីណាមួយ ជាមួយនឹងទូលបង្គំ ដោយហេតុនោះឯង ទើបទូលបង្គំយល់ថា មិនមែនបណ្ឌិត កេវដ្ដៈពោលទោសរបស់ព្រះពោធិសត្វ ដោយប្រការដូច្នេះ ។

ព្រះបាទវិទេហរាជបានស្តាប់ពាក្យរបស់កេវដ្ដៈហើយ ទ្រង់មិនត្រេកអរ ទ្រង់មិនជំទាស់ ទ្រង់ព្រះរាជទានស្បៀង និងផ្ទះស្នាក់អាស្រ័យដល់កេវដ្ដៈ និងពួកបរិវារដែលមក ទ្រង់បញ្ជូនកេវដ្ដៈទៅដោយត្រាស់ថា អញ្ជើញលោកអាចារ្យទៅសម្រាកចុះ ដូច្នេះហើយ ទ្រង់ត្រិះរិះថា មហោសថកូនអញជាអ្នកឈ្លាសក្នុងបដិសណ្ឋារៈ បានឮថា គេមិនបានធ្វើបដិសណ្ឋារៈជាមួយកេវដ្ដៈឡើយ មិនសម្តែងអាការត្រេកអរ គេឃើញភ័យណាមួយក្នុងអនាគត ត្រិះរិះដូច្នេះហើយ ទ្រង់ក៏ផ្តើមកថាឡើងឯងថា

ចំណែកការដែលគិតនេះ បុរសផ្តេសផ្តាសឃើញបានក្រណាស់
ដោយពិត សេចក្តីបរិសុទ្ធ នរជនអ្នកមានព្យាយាម មុខជានឹង
ឃើញ ហេតុនោះ កាយរបស់អញញាប់ញ័រ អ្នកណានឹងលះបង់
នូវដៃនរបស់ខ្លួន ហើយលុះក្នុងកណ្តាប់ដៃជនដទៃវិញកើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទំ** សេចក្តីថា បទមន្តនេះ ដែលកូនរបស់យើងឃើញហើយ អ្នកដទៃក្រៅអំពីនេះ ឃើញបានដោយក្រពិត ។ បទថា **នរវីរយេន** សេចក្តីថា បំណងដែលពិតដែលនរៈមានសេចក្តីព្យាយាមឃើញ

ហើយ ។ បទថា **សយំ** សេចក្តីថា អ្នកណានឹងរៀវដៃនរបស់ខ្លួន ទៅកាន់កណ្តាប់ដៃរបស់អ្នកដទៃ ។

ព្រះបាទវិទេហរាជគិតដល់សេចក្តីនោះថា កូនរបស់អញនឹងឃើញទោសក្នុងការមករបស់កេវដ្ដៈ ដ្បិតថា កេវដ្ដៈនេះ កាលមក មិនមែនមកដើម្បីសម្ពន្ធមេត្រី គេនឹងមកដើម្បីលួងលោមអញដោយកាមគុណ ហើយនាំទៅនគររបស់ខ្លួន ចាប់ខ្លួនអញ កូនរបស់អញឃើញភ័យក្នុងអនាគតនោះហើយ ទ្រង់គិតយ៉ាងនេះខ្លាចផង តក់ស្លុតផង ហើយគង់នៅ ។ ចំណែកបណ្ឌិតទាំង ៤ នាក់ចូលគាល់ ព្រះរាជាត្រាស់សួរសេនកៈថា កាលដែលយើងទៅឧត្តរ-បញ្ចាលនគរ នាំព្រះរាជធីតាព្រះបាទចូឡនីមក លោកគាប់ចិត្តដែរឬ សេនកៈក្រាបទូលថា ទ្រង់មានព្រះបន្ទូលអ្វី ព្រោះថា ទ្រង់គួរនាំសិរីដែលមកដល់កុំឲ្យគេចទៅបាន បើទ្រង់ទៅនគរបញ្ចាលនឹងបានទទួលព្រះរាជធីតាមក ក្សត្រអង្គដទៃ វៀរតែព្រះបាទចូឡនីព្រហ្មទត្ត នឹងជាអ្នកស្មើដោយព្រះអង្គ រមែងមិនមានក្នុងផ្ទៃសកលជម្ពូទ្វីប ព្រោះអ្វី ព្រោះទ្រង់បានព្រះរាជធីតារបស់ព្រះរាជាដែលជាធំ ជាមហេសី ។ ពិតហើយ ព្រះបាទចូឡនីព្រហ្មទត្ត ជាព្រះរាជាដ៏កំពូលក្នុងសកលជម្ពូទ្វីប ប្រាថ្នានឹងលើកព្រះរាជធីតា ដែលទ្រទ្រង់នូវរូបឆោមដ៏ឧត្តម ថ្វាយដល់ទ្រង់ ដោយទ្រង់ឃើញថា ព្រះរាជាក្រៅអំពីនេះជាមនុស្សរបស់អញ ព្រះបាទវិទេហរាជមួយអង្គ ស្មើគ្នានឹងអញ សូមទ្រង់ធ្វើតាមពាក្យរបស់ព្រះបាទចូឡនីចុះ សូម្បីពួកទូលបង្គំក៏នឹងបានសំពត់ និងគ្រឿងប្រដាប់ទាំងឡាយ ព្រោះអាស្រ័យព្រះអង្គ ព្រះបាទវិទេហរាជត្រាស់

សួរអាចារ្យ ៣ នាក់ទៀត អាចារ្យទាំងនោះក៏ក្រាបទូលដូចគ្នា កាលព្រះរាជាកំពុងត្រាស់នឹងអាចារ្យទាំង ៤ កេវដ្តៈចេញអំពីផ្ទះសម្រាក មកថ្វាយបង្គំព្រះរាជា ដោយគិតថា អញនឹងទូលលាព្រះរាជាត្រឡប់ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំមិនអាចបង្អែបង្អង់បាន នឹងទូលលាត្រឡប់ ព្រះរាជាទ្រង់ធ្វើសក្ការៈដល់កេវដ្តៈហើយ ទ្រង់បញ្ជូនត្រឡប់ ។ ព្រះមហាសត្វដឹងថា កេវដ្តៈត្រឡប់ហើយ ទើបងូតទឹកតាក់តែងកាយ ចូលទៅគាល់ព្រះរាជា ថ្វាយបង្គំព្រះរាជាហើយ អង្គុយក្នុងទីសមគួរខាងចំណែកម្ខាង ព្រះរាជាទ្រង់ត្រិះរិះថា មហោសថបណ្ឌិតកូនរបស់អញ ជាអ្នកមានការគិតច្រើន ជាអ្នកដល់ត្រើយនៃមន្ត្រ រមែងដឹងអត្ថទាំងឡាយ ទាំងក្នុងអតីត អនាគត និងបច្ចុប្បន្ន ជាអ្នកប្រាជ្ញ នឹងដឹងថា គួរ ឬមិនគួរ ដែលអញនឹងទៅក្នុងនគរបញ្ចាល ទ្រង់មិនបានត្រាស់រឿងរបស់ទ្រង់ដែលគិតមុន ជាអ្នកត្រេកអរដោយតម្រេក ព្រោះរាគៈ វង្វេងព្រោះមោហៈ កាលនឹងត្រាស់សួរ ទើបត្រាស់គាថានេះថា

> គំនិតរបស់យើងទាំង ៦ នាក់ ដែលជាអ្នកឈ្លាស មានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ផុតដូចផែនដី ស្មើគ្នាជាឯកច្ឆន្ទ ម្នាលមហោសធ អ្នកចូរគិតមើល ទៅ ឬកុំទៅ ឬក៏ឈប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆន្នំ** សេចក្តីថា នៃបណ្ឌិត ពួកយើងទាំង ៦ នាក់ គឺកេវដ្តព្រាហ្មណ៍ ១ យើង ១ និងអាចារ្យទាំង ៤ ។ បទថា **ឯកាវមតី** សេចក្តីថា មានអធ្យាស្រ័យតែមួយរួមគ្នា ដូចទឹកស៊ីងគង្គាហូររួមជាមួយ

ទឹកស៊ីងយមុនា ដូច្នោះ ។ បទថា **យេ** សេចក្ដីថា ព្រះបាទវិទេហរាជត្រាស់ថា ពួកយើងទាំង ៦ ជាបណ្ឌិតដ៏ឧត្ដម មានបញ្ញាខ្ពង់ខ្ពស់ដូចផែនដី រមែងគាប់ចិត្តក្នុងការដែលព្រះបាទចូឡនីនាំព្រះរាជធីតាមក ។ បទថា **ឋានំ** បានដល់ នៅក្នុងទីនេះប៉ុណ្ណោះ ។ បទថា **មតី ករោហិ** សេចក្ដីថា ឈ្មោះថាការគាប់ចិត្តរបស់ពួកយើង យកជាប្រមាណមិនបាន សូមអ្នកក៏ចូរសម្ដែងការគិតថា ការដែលពួកយើងទៅបញ្ចាលនគរ ដើម្បីប្រយោជន៍អាវាហមង្គល ឬមិនទៅ ឬនៅទីនេះប៉ុណ្ណោះ អ្នកគាប់ចិត្តដូចម្ដេច ។

ព្រះមហាសត្វបានស្ដាប់ព្រះតម្រាស់ដូច្នោះ ទើបគិតថា ព្រះរាជាអង្គនេះ លោភក្នុងកាមារម្មណ៍ កាន់យកពាក្យរបស់អាចារ្យ ៤ នាក់នេះ ដោយភាពជាអន្ធពាល ទ្រង់រមែងមិនជ្រាបទោសនៃការយាងទៅ អញនឹងចង្អុលទោសក្នុងការយាងទៅ ហើយឲ្យទ្រង់បែរព្រះហឫទ័យ គិតដូច្នេះហើយទើបពោល ៤ គាថាថា

> បពិត្រព្រះរាជា សូមព្រះអង្គទ្រង់ជ្រាបថា ព្រះបាទចូឡនីព្រហ្មទត្ត ជាអ្នកមានអានុភាពធំ មានពលច្រើន ឥឡូវ ប្រាថ្នាដើម្បីនឹងសម្លាប់ព្រះអង្គ ដូចនាយព្រានដែលសម្លាប់ម្រឹគដោយផ្អាក់ ។
>
> ត្រីជាសត្វជាប់ចិត្តក្នុងនុយស្រស់ ( លេប ) ផ្លែសន្ទូចដែលគេបិទបាំងដោយសាច់ មិនដឹងសេចក្ដីស្លាប់ខ្លួនយ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកជាប់ក្នុងកាម ចង់បានធីតារបស់ព្រះបាទ

ចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គដូចត្រីនោះឯង ។ បើព្រះអង្គ ស្ដេចយាងទៅកាន់ក្រុងបញ្ចាល ព្រះអង្គមុខជានឹងលះបោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគដែលដើរទៅតាមផ្លូវ ( ទៀបទ្វារនៃស្រុកដែរ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ ព្រះមហាសត្វទូលហៅព្រះបាទវិទេហរាជ ដោយពាក្យថា **រាជ** ។ បទថា **មហានុភាវោ** បានដល់ មានយសធំ ។ បទថា **មហាពលោ** បានដល់ ប្រកបដោយពល ១៨ អក្ខោភិនី ។ បទថា **មារណត្ថំ** បានដល់ ដើម្បីប្រយោជន៍ដល់ការស្លាប់ ។ បទថា **មិគាបរេន** បានដល់ មេម្រឹគផ្ទាក់ នាយព្រានបង្ហឹកមេម្រឹគមួយ ហើយយកខ្សែបង់នាំទៅព្រៃបញ្ឈប់ត្រង់ទីដែលពួកម្រឹគមករកស៊ី មេម្រឹគនោះ ត្រូវការនាំម្រឹគល្ងង់ មកកាន់សម្នាក់ខ្លួន ទើបស្រែកដោយសំឡេងខ្លាំង ប្រកបដោយរាគៈ ដោយសញ្ញារបស់ខ្លួន ម្រឹគល្ងង់ចោមរោមដោយហ្វូងម្រឹគ ដេកត្រង់គុម្ពឈើក្នុងព្រៃ ឲ្យសញ្ញាក្នុងមេម្រឹគដ៏សេស បានស្ដាប់សំឡេងមេម្រឹគនោះ មានចិត្តប្រតិព័ទ្ធ ព្រោះជាប់ជំពាក់ដោយស្ដាប់សំឡេងរបស់មេម្រឹគនោះ ក្រោកចេញទៅ អើតកចូលទៅរកមេម្រឹគនោះ ឈរឲ្យនូវការងាយស្រួល ដល់នាយព្រានៗ ប្រើលំពែងដ៏មុត ចាក់ម្រឹគនោះឲ្យអស់ជីវិតក្នុងទីនោះឯង ក្នុងរឿងនេះ ព្រះបាទចូឡនីដូចនាយព្រាន ព្រះរាជទានធីតារបស់ព្រះអង្គ ដូចមេម្រឹគផ្ទាក់ ព្រាហ្មណ៍កេវដ្ដៈ ដូចអាវុធក្នុងដៃរបស់ព្រាន អធិប្បាយថា នាយព្រាន

ត្រូវការសម្លាប់ម្រឹគដោយម្រឹគធ្នាក់ យ៉ាងណា ព្រះបាទចូឡនីត្រូវការសម្លាប់ព្រះបាទវិទេហរាជ ដោយព្រះរាជធីតា ដូច្នោះ ។ បទថា **អាមគិទ្ធោ** សេចក្តីថា ត្រីរមែងនៅក្នុងទឹកជ្រៅជាង ១០០ ព្យាម ត្រូវការនុយ គឺរបស់ស្រស់ដែលគេបិទត្រង់ផ្លែសន្ទូច លេបសន្ទូចចូលទៅ រមែងមិនដឹងការស្លាប់របស់ខ្លួន ។ បទថា **ជីនរាំ** សេចក្តីថា ព្រះអង្គទ្រង់ប្រាថ្នាកាម ទ្រង់រមែងមិនជ្រាបព្រះរាជធីតារបស់ព្រះបាទចូឡនីនោះ ដូចត្នានឹងនុយដែលព្រានសន្ទូច គឺព្រះបាទចូឡនីបិទ គឺធ្វើពាក្យរបស់កេវដ្តព្រាហ្មណ៍ទុក ដូចត្រីមិនដឹងនុយ គឺការស្លាប់របស់ខ្លួន ។ បទថា **បញ្ចាលំ** បានដល់ ឧត្តរបញ្ចាលនគរ ។

បទថា **អត្តំ** បានដល់ ខ្លួន ។ បទថា **បច្ចានុបច្ឆំ** សេចក្តីថា ភ័យធំនឹងមកដល់ម្រឹគដែលដើរទៅតាមទ្វារស្រុក កាលពួកមនុស្សកាន់អាវុធចេញអំពីស្រុក ដើម្បីសាច់ ជនដែលឃើញនោះៗ រមែងសម្លាប់ម្រឹគនោះ បង់យ៉ាងណា មរណភ័យធំនឹងមកដល់ គឺចូលដល់ព្រះអង្គ កាលទ្រង់យាងទៅឧត្តរបញ្ចាលនគរ ដូច្នោះ ព្រះមហាសត្វទូលសង្កត់ព្រះរាជាដោយ ៤ គាថា ដូច្នេះ ។

ព្រះបាទវិទេហរាជ ត្រូវមហាសត្វផ្ចញ់ផ្ចាល់យ៉ាងនេះ ក៏ទ្រង់ពិរោធថា មហោសថនេះ មើលងាយអញដូចជាទាសៈរបស់ខ្លួន មិនទុកអញថា ជាព្រះរាជា ដឹងរាជសាសន៍ ដែលអគ្គរាជបញ្ជូនមកកាន់សម្នាក់របស់អញថា នឹងប្រទានព្រះរាជធីតា ដូច្នេះហើយ មិនពោលពាក្យប្រកបដោយមង្គលសូម្បីមួយមាត់ ហើយមកពោលនឹងអញថា ដូចជាម្រឹគល្ងង់ ដូចជាត្រីលេប

សន្ធច និងដូចម្រឹគដើរតាមផ្លូវក្នុងស្រុក នឹងដល់នូវសេចក្តីស្លាប់ កាលទ្រង់ពិរោធហើយ បានត្រាស់គាថាជាលំដាប់ថា

យើងដែលបានពោល នូវប្រយោជន៍ដ៏ឧត្តម ក្នុងសម្នាក់នៃអ្នក
ត្រឡប់ទៅជាមនុស្សល្ងង់លីលាវិញ អ្នកឯងជាអ្នកចម្រើនដោយ
ចុងនង្គ័ល ម្តេចនឹងដឹងសេចក្តីចម្រើន ដូចអ្នកដទៃកើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពាលាទ្ធសេ** សេចក្តីថា ជាបុគ្គលល្ងង់ខ្លៅ ។ បទថា **ឯលម្ងគា** បានដល់ ពួកយើងនេះឯង មានមាត់ពេញដោយទឹកមាត់ ។ បទថា **ឧត្តមត្ថានិ** បានដល់ ហេតុឲ្យបានស្រីកែវដ៏ឧត្តម ។ បទថា **តយី លបិម្ហា** សេចក្តីថា ពួកយើងបានពោលក្នុងសម្នាក់របស់អ្នក ។ បទថា **កិមេវ** សេចក្តីថា កាលតិះដៀល ទើបគេពោលយ៉ាងនេះ ។ បទថា **នង្គល–កោដិវឌ្ឍោ** សេចក្តីថា ព្រះបាទវិទេហរាជទ្រង់បំណងថា កូនគហបតី រមែងចម្រើនដោយចុងនង្គ័លតាំងអំពីក្មេងប៉ុណ្ណោះ ទើបត្រាស់ដោយព្រះរាជបំណងនេះថា ឯងរមែងដឹងការងាររបស់គហបតីបុត្រប៉ុណ្ណោះ មិនដឹងការងារដែលជាមង្គលរបស់ក្សត្រទាំងឡាយ ។ បទថា **អញ្ញោ** សេចក្តីថា បុគ្គលដទៃៗ គឺអាចារ្យកេវដ្ដៈ ឬអាចារ្យសេនកៈជាដើម ស្គាល់សេចក្តីចម្រើន គឺមង្គលរបស់ក្សត្រទាំងនេះ យ៉ាងណា ឯងនឹងស្គាល់សេចក្តីចម្រើនទាំងនោះដែរឬ ការស្គាល់កិច្ចការរបស់គហបតីនោះឯង សមគួរដល់ឯង ។

ព្រះបាទវិទេហរាជជេរបរិភាសមហោសថហើយ ត្រាស់ថា កូនគហបតីធ្វើអន្តរាយនៃមង្គលដល់យើង លោកទាំងឡាយ ចូរនាំគេចេញទៅ ហើយ

ត្រាស់គាថាដើម្បីឲ្យនាំមហោសថចេញទៅថា

អ្នកទាំងឡាយ ចូរចាប់អ្នកនេះឰដ៏ក ហើយឲ្យវិនាសចាកដែន
របស់អញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបាន
ស្រីកែវ ដូច្នេះ ។

មហោសថដឹងថា ព្រះរាជាទ្រង់ពិរោធ ទើបគិតថា បើអ្នកដទៃធ្វើតាមព្រះរាជតម្រាស់ ចាប់ដៃ ឬចាប់ករបស់អញនោះ មិនគួរដល់អញ អញនឹងខ្មាសមួយជីវិត ព្រោះដូច្នោះ អញនឹងចេញទៅឯង គិតដូច្នោះហើយ ទើបថ្វាយបង្គំព្រះរាជា ក្រោកចាកទីអង្គុយ ត្រឡប់ទៅកាន់គេហដ្ឋានរបស់ខ្លួន ។ ឯព្រះបាទវិទេហរាជ ត្រាស់ដូច្នោះ ដោយអំណាចកំហឹងប៉ុណ្ណោះ មិនបានត្រាស់បញ្ជាបុគ្គលណាម្នាក់ឲ្យធ្វើដូច្នោះឡើយ ព្រោះទ្រង់មានព្រះហឫទ័យគោរពក្នុងព្រះពោធិសត្វ ។ លំដាប់នោះ ព្រះមហាសត្វគិតថា ព្រះរាជាអង្គនេះ ជាអន្ធពាល មិនជ្រាបប្រយោជន៍ ឬមិនមែនប្រយោជន៍ ទ្រង់ជាអ្នកប្រាថ្នាកាម ទ្រង់ជ្រាបតែខាងបានព្រះរាជធីតារបស់ព្រះបាទចូឡនី ទ្រង់មិនជ្រាបភ័យក្នុងអនាគតឡើយ កាលទ្រង់យាងទៅកាន់ក្រុងបញ្ចាល ក៏នឹងដល់នូវសេចក្តីវិនាសធំ អញមិនគួរធ្វើព្រះរាជតម្រាស់ទុកក្នុងចិត្តឡើយ ព្រោះទ្រង់មានឧបការៈច្រើនដល់អញ ព្រះរាជទានយសធំដល់អញ អញនឹងជាបច្ច័យនៃព្រះអង្គ ហើយត្រិះរិះតទៅថា អញនឹងបញ្ជូនសុវបោតកៈទៅមុន ដឹងសេចក្តីពិតហើយ សឹមទៅឯងក្នុងកាលជាក្រោយ ត្រិះរិះដូច្នេះហើយ ទើបហៅសុវបោតកៈមកបញ្ជូនទៅក្នុងក្រុងបញ្ចាលនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

លំដាប់នោះ មហោសធពោធិសត្វ ក៏ចៀសចេញអំពីសម្នាក់នៃព្រះបាទវិទេហៈហើយ ទើបហៅសុវបណ្ឌិត ឈ្មោះមាធុរៈជាទូតមកប្រាប់ថា ម្នាលសម្លាញ់មានស្លាបខៀវ អ្នកចូរមកធ្វើការបម្រើអញ ដ្បិតមានសាលិកាញីមួយ ដែលគេចិញ្ចឹមទុកជិតទីក្រឡាបន្ទំនៃព្រះបាទបញ្ចាល ។ ឯងចូរទៅសួរសាលិកានោះដោយសន្ទវកិច្ច ព្រោះវាជាសត្វឈ្លាស ក្នុងកិច្ចទាំងពួង វាដឹងការណ៍អាថ៌កំបាំងទាំងពួងរបស់ជនទាំងពីរ គឺព្រះរាជា និងកោសិយព្រាហ្មណ៍ ។ មាធុរសុវបណ្ឌិតមានស្លាបខៀវនោះ បានទទួលស្តាប់ថា បាទ ដូច្នេះហើយ ក៏ហើរទៅកាន់សម្នាក់នៃនាងសាលិកា ។ មាធុរសុវបណ្ឌិត លុះហើរទៅដល់ហើយ ទើបហៅនាងសាលិកាមានទ្រុងល្អ ពោលពាក្យពីរោះថា នែនាងមានទ្រុងល្អ នាងល្មមអត់ទ្រាំបានដែរឬ នែនាងជាវេសជាតិ នាងមិនមានជំងឺតម្កាត់ទេឬ នែនាងមានទ្រុងល្អ នាងបានលាជលាយដោយទឹកឃ្មុំដែរឬ ។

ម្នាលសម្លាញ់ សេចក្តីសុខស្រួលមានដល់ខ្ញុំ ម្នាលសម្លាញ់មួយទៀត ខ្ញុំមិនមានជំងឺតម្កាត់ទេ ម្នាលសុវបណ្ឌិត ទាំងលាជ

លាយដោយទឹកឃ្មុំ ខ្ញុំក៏បានដែរ ។ នែសម្លាញ់ អ្នកមកអំពីណាហ្ន៎ ឬអ្នកណាប្រើមក មួយវិញទៀត អ្នកជាសត្វដែលខ្ញុំមិនធ្លាប់ឃើញ មិនធ្លាប់ឮក្នុងកាលមុនអំពីកាលនេះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហរិតបក្ខ** បានដល់ មានស្លាបដូចស្លឹកឈើពណ៌ខៀវ ។ បទថា **វេយ្យាវច្ចំ** សេចក្តីថា មហោសថពោលនឹងសុវបណ្ឌិត ដែលមកទំរត្រង់ភ្លៅ ក្នុងកាលខ្លួនពោលថា មកសម្លាញ់ ចូរអ្នកធ្វើការខ្វល់ខ្វាយរបស់យើងយ៉ាងក្រៃលែង ដែលអ្នកដទៃ ជាមនុស្សមិនអាចធ្វើបាន កាលសុវបណ្ឌិតសួរថា ខ្ញុំនឹងធ្វើអ្វីលោកម្ចាស់ មហោសថក៏ពោលថា អើសម្លាញ់ អ្នកដទៃ វៀរព្រះបាទចូឡនី និងកេវដ្តព្រាហ្មណ៍ រមែងមិនដឹងហេតុដែលកេវដ្តព្រាហ្មណ៍មកដោយភាពជាទូត មនុស្សពីរនាក់ប៉ុណ្ណោះអង្គុយប្រឹក្សាគ្នាក្នុងទីបន្ទំរបស់ព្រះបាទចូឡនីមានតែសាលិកាញីដែលព្រះបាទបញ្ចាលរាជនោះ ចិញ្ចឹមទុកត្រង់ទីបន្ទំ បានឮថា សាលិកាញីនោះដឹងអាថ៌កំបាំងនោះ ចូរអ្នកទៅក្នុងទីនោះ ធ្វើនូវការស្និទ្ធស្នាលប្រកបដោយមេថុនជាមួយសាលិកាញីនោះ សួរនូវអាថ៌កំបាំងរបស់ព្រះបាទចូឡនី និងកេវដ្តព្រាហ្មណ៍ ជាមួយនឹងសាលិកាញីនោះឲ្យបានពិស្តារ ចូរសួរសាលិកាញីនោះក្នុងប្រទេសដែលស្ងាត់ កុំឲ្យអ្នកដទៃដឹងរឿងនោះ បើអ្នកណាបានឮសំឡេងរបស់អ្នក ជីវិតរបស់អ្នក នឹងមិនមាន ដូច្នោះ ចូរអ្នកសួរតិចៗ ក្នុងទីកំបាំង ។ បទថា **សាធេសំ សព្វំ** សេចក្តីថា សាលិកាញីនោះ ដឹងនូវអាថ៌កំបាំងសព្វយ៉ាងរបស់ជនទាំងពីរនោះ គឺព្រះបាទចូឡនី និងកេវដ្តព្រាហ្មណ៍កោសិយគោត្រ ។ បទថា

**អាមោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សុវបោតកៈនោះ ដែលមហោសថបណ្ឌិតធ្វើសក្ការៈដោយន័យមុននោះឯង បញ្ជូនទៅហើយ ទទួលពាក្យរបស់មហោសថថា បាទ ថ្វាយបង្គំមហាសត្វ ហើរប្រទក្សិណ ហើយចេញតាមបង្អួចដែលបើក ទៅកាន់នគរឈ្មោះអរិដ្ឋបុរៈ ក្នុងដែនសិវិ ដោយសម្ទុះដូចខ្យល់ កំណត់ព្រឹត្តិការណ៍ក្នុងប្រទេសនោះហើយ ទៅកាន់សម្នាក់របស់សាលិកាញី ។ ទៅបានដូចម្តេច សុវបោតកៈនោះ ទំព្រន់កំពូលស្រួច ដែលធ្វើអំពីមាសនៃព្រះរាជនិវេសន៍ យំដោយសំឡេងពីរោះ អាស្រ័យរាគៈ សាលិកាញីបានស្តាប់សំឡេងនោះហើយ ក៏យំទទួលជាសញ្ញាឲ្យដឹងថា ខ្ញុំនឹងទៅរកដោយសញ្ញានោះ សូម្បីសាលិកាញីនោះ បានស្តាប់សំឡេងរបស់សុវបោតកៈហើយ ក៏ទំព្រន់សុវណ្ណបញ្ជរ ជិតទីបន្ទំរបស់ព្រះរាជា មានចិត្តត្រេកអរដោយរាគៈ បន្ទឺសំឡេង ៣ ដង សុវបោតកៈ ហើរទៅបន្តិច បន្ទឺសំឡេងរឿយៗ ទំព្រន់ធរណីសីហបញ្ជរដោយលំដាប់ តាមក្រសែសំឡេងដែលសាលិកាញីធ្វើ ត្រួតមើលមិនឃើញមានអន្តរាយ ហើរទៅកាន់សម្នាក់សាលិកាញីនោះ សាលិកាញីបានពោលនឹងសុវបោតកៈក្នុងទីនោះថា មកសម្លាញ់ ចូរទំព្រន់សុវណ្ណបញ្ជរ សុវបោតកៈក៏ហើរទៅទំ ។ បទថា **អាមន្តយិ** សេចក្តីថា សុវបោតកៈនោះ ហើរទៅយ៉ាងនេះហើយ បំណងនឹងធ្វើសេចក្តីស្និទ្ធស្នាល ប្រកបដោយមេថុន ទើបហៅសាលិកាញីនោះ ។ បទថា **សុឃរំ** បានដល់ ទ្រុងស្អាត ព្រោះនៅក្នុងទ្រុងមាស ។ បទថា **វេសេ** បានដល់ ប្រកបដោយភេទ គឺមានជាតិ តាមភេទ បានឮថា សាលិកា ឈ្មោះថា មាន

ជាតិតាមភេទក្នុងពួកបក្សីទាំងឡាយ ហេតុនោះ ទើបហៅសត្វសាលិកានោះ យ៉ាងនេះ ។ បទថា **តុវំ** សេចក្តីថា យើងពោលក្នុងទ្រុងស្អាតរបស់នាង ។ បទថា **កច្ចិ តេ មធុកា លាជា** សេចក្តីថា សុវបោតកៈសួរថា នាងបាន លាជ និងទឹកឃ្មុំដែរឬ ។ បទថា **កុតោ នុ សម្ម អាគម្ម** សេចក្តីថា សាលិកាសួរថា នែសម្លាញ់ អ្នកមកអំពីណាចូលមកក្នុងទីនេះ ។ បទថា **កស្ស វា** សេចក្តីថា ឬអ្នកណា បញ្ជូនអ្នកមកក្នុងទីនេះ ។

សុវបោតកៈបានស្តាប់ពាក្យរបស់សាលិកាហើយ គិតថា បើអញប្រាប់ ថា មកអំពីមិថិលា សាលិកាញីនេះទោះបីដល់នូវសេចក្តីស្លាប់ ក៏មិនធ្វើ សេចក្តីស្និទ្ធស្នាលជាមួយអញ អញកំណាត់នគរអរិដ្ឋបុរៈក្នុងដែនសិវិ មក ហើយ ដូច្នោះ អញនឹងធ្វើមុសាវាទថា ព្រះបាទសិវិរាជទ្រង់បញ្ជូនមកទីនេះ គិតដូច្នេះហើយ ទើបពោលថា

ខ្ញុំគេចិញ្ចឹមទុកនៅទីបន្ទំក្នុងប្រាសាទ នៃព្រះបាទសិវិ ព្រះរាជានោះ
ទ្រង់ឋិតនៅក្នុងធម៌ តែងទ្រង់ដោះលែងនូវសត្វទាំងឡាយ ដែល
ជាប់ចំណង ចាកចំណងអំពីទីនោះៗ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពន្ធេ** សេចក្តីថា ព្រះរាជាអង្គនោះ ឲ្យដោះ លែងសត្វទាំងពួងអំពីទីដែលត្រូវឃុំឃាំង ព្រោះភាពដែលទ្រង់តាំងនៅក្នុងធម៌ កាលឲ្យដោះលែងយ៉ាងនេះ ទ្រង់ត្រាស់ថា ពួកលោកជឿយើង ចូរដោះលែង វាទៅ ខ្ញុំនោះចេញអំពីទ្រុងមាសដែលបើក កាន់យកអាហារក្នុងទីនោះៗ តាម ប្រាថ្នាខាងក្រៅប្រាសាទ ហើយនៅក្នុងទ្រុងមាសនោះឯង មិនដូចនាងនៅតែ

ក្នុងទ្រុងប៉ុណ្ណោះ អស់កាលជានិច្ចយ៉ាងនេះ ។

លំដាប់នោះ សាលិកាញីឲ្យលាជដែលលាយដោយទឹកឃ្មុំ ដែលដាក់ក្នុងភាជនមាស និងទឹកឃ្មុំដើម្បីខ្លួនដល់សុវបោតកៈ ហើយសួរថា នែសម្លាញ់ អ្នកមកអំពីទីឆ្ងាយ មកក្នុងទីនេះដើម្បីប្រយោជន៍អ្វី សុវបោតកៈបានស្តាប់ពាក្យរបស់សាលិកា ប្រាថ្នានឹងស្តាប់អាថ៌កំបាំង ទើបពោលមុសាវាទថា

មាននាងសាលិកាមួយពោលពាក្យពីរោះ ជាភរិយារបស់ខ្ញុំ ម្នាលនាងមានទ្រុងល្អ កាលខ្ញុំកំពុងតែសម្ងំងជាប់ចិត្ត ស្រាប់តែ ខ្លែងសម្លាប់នាងសាលិកានោះទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្ស មេកា** សេចក្តីថា សាលិកាញីមួយជាភរិយារបស់ខ្ញុំ ។ បទថា **ទុតិយាសិ** សេចក្តីថា បានជាភរិយាចាស់ ។ បទថា **មញ្ជុភាណិកា** បានដល់ ពោលពាក្យពីរោះ ។

លំដាប់នោះ សាលិកាញីសួរសុវបោតកៈថា ហេតុអ្វី ទើបខ្លែងសម្លាប់ភរិយារបស់អ្នក សុវបោតកៈកាលប្រាប់ដល់សាលិកា ទើបពោលថា ចូរនាងស្តាប់ ថ្ងៃមួយ ព្រះរាជារបស់ខ្ញុំទៅស្រង់ទឹក ត្រាស់ហៅខ្ញុំទៅតាម ខ្ញុំក៏នាំភរិយាទៅតាមព្រះរាជាលេងទឹក ត្រឡប់មកជាមួយព្រះរាជានោះ ក្នុងពេលល្ងាចឡើងប្រាសាទជាមួយព្រះអង្គ នាំភរិយាចេញមកអំពីទ្រុងទំត្រង់ទីវាល គឺកំពូលព្រះដំណាក់ដើម្បីសំងិលខ្លួន ខណៈនោះ មានខ្លែងមួយហើរមកចាបយើងទាំងពីរចេញអំពីកំពូលដំណាក់ ខ្ញុំខ្លាចចំពោះមរណភ័យ ក៏ហើរគេចទៅដោយរហ័ស តែសាលិកានោះមានគភ៌ចាស់ខែ ព្រោះដូច្នោះ នាងមិនអាច

គេច ពេលនោះ ខ្ញុំងក៏ញ៉ាំងនាងឲ្យស្លាប់ នៅនឹងមុខខ្ញុំដែលកំពុងឃើញ ហើយនាំគេចទៅ ពេលនោះ ព្រះរាជារបស់ខ្ញុំ ឃើញខ្ញុំយំដោយសេចក្តីសោកដល់សាលិកាញី ទើបត្រាស់សួរថា ឯងយំធ្វើអ្វី ទ្រង់បានស្តាប់សេចក្តីនោះហើយ ទើបត្រាស់ថា នែបា ឯងកុំយំឡើយ ចូរស្វែងរកកិរិយាដទៃ កាលខ្ញុំបានស្តាប់ព្រះតម្រាស់ ទើបក្រាបទូលថា ប្រយោជន៍អ្វីដោយកិរិយាដទៃ ដែលមិនមានអាចារមារយាទ មិនមានសីលដែលនាំមកហើយ ម្នាក់ឯងត្រាច់ទៅល្អជាង ។ ព្រះរាជាត្រាស់ថា នែសម្លាញ់ យើងបានឃើញសាលិកាញីមួយ ដល់ព្រមដោយសីលាចារវត្តដូចកិរិយារបស់អ្នក ឯសាលិកាញីបែបនេះ គេចិញ្ចឹមត្រង់ទីបន្ទំរបស់ព្រះបាទចូឡនី ចូរឯងទៅក្នុងទីនោះ សួរចិត្តរបស់សាលិកាញីនោះមើល ឲ្យសាលិកាញីធ្វើឱកាស បើឯងគាប់ចិត្ត ចូរមកប្រាប់ដល់យើង ក្នុងកាលជាក្រោយ យើងក្តី ព្រះទេវីក្តី នឹងនាំសាលិកាញីនោះមកដោយបរិវារធំ ត្រាស់ដូច្នេះហើយ បញ្ជូនខ្ញុំមកទីនេះ ទើបខ្ញុំមកដោយហេតុនោះ ពោលដូច្នេះហើយ សុវបោតកៈក៏ពោលថា

ខ្ញុំបរិបូណ៌ដោយសេចក្តីប្រាថ្នាចំពោះភរិយានោះ បានជាមកក្នុងសម្នាក់នៃនាង ប្រសិនបើនាងបើកឱកាស យើងទាំងពីរនាក់នឹងនៅក្នុងទីជាមួយគ្នា ដូច្នេះ ។

សាលិកាញីបានស្តាប់ពាក្យរបស់សុវបោតកៈ ក៏ត្រេកអរ តែមិនឲ្យសុវបោតកៈដឹងថា ខ្លួនប្រាថ្នា ធ្វើជាមិនប្រាថ្នា ពោលថា

ធម្មតាសេកឈ្មោល គួរតែប្រាថ្នា រកសេកញី សាលិកាឈ្មោល

គួរតែប្រាថ្នារកសាលិកាញី ចុះការនៅរួមដោយសេកឈ្មោល
នឹងសាលិកាញីដូចម្តេចកើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុវោ** សេចក្តីថា នៃសម្លាញ់សុវបណ្ឌិត សេកនោះ គប្បីស្រឡាញ់សេកញី ដែលមានជាតិស្មើគ្នានឹងខ្លួន ។ បទថា **កឹធិសោ** សេចក្តីថា ឈ្មោះថាការនៅរួមរបស់សេកដែលមានជាតិមិនស្មើគ្នា ដូចម្តេចកើត ព្រោះសេកឈ្មោលឃើញសេកញីដែលមានជាតិស្មើគ្នា ក៏នឹងបោះបង់សាលិកាញី ដែលធ្លាប់ស្និទ្ធស្នាលគ្នាមកអស់កាលយូរ ការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់នោះ នឹងប្រព្រឹត្តទៅដើម្បីទុក្ខធំ ដូច្នោះ តាំងពីកាលណាមក ឈ្មោះថាការនៅរួមរបស់បក្សីដែលមានជាតិមិនស្មើគ្នា រមែងមិនសមគួរឡើយ ។

សុវបោតកៈបានស្តាប់ដូច្នោះ ក៏គិតថា សាលិកានេះមិនឃាត់អញ ថែមទាំងធ្វើការបរិហារទៀត គង់ប្រាថ្នាអញពិត អញនឹងឲ្យសាលិកាញីនេះជឿអញដោយឧបមាផ្សេងៗ គិតដូច្នេះហើយ ទើបពោលថា

បុគ្គលណាប្រាថ្នាស្ត្រីណាក្នុងកាម សូម្បីស្ត្រីនោះ ជាចណ្ឌាល
ក៏ដោយ ព្រោះថា ការនៅរួមទាំងអស់ ដូចៗ គ្នា ដែលមិនដូច
គ្នា ក្នុងកាមមិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចណ្ឌាលិកាមបិ** បានដល់ នូវស្រីចណ្ឌាល ។ បទថា **សធិសោ** សេចក្តីថា ការនៅរួមគ្នាគ្រប់យ៉ាង រមែងដូចគ្នាទាំងអស់ ព្រោះមានចិត្តតែមួយ ។ បទថា **កាមេ** សេចក្តីថា ព្រោះក្នុងរឿងកាម ចិត្ត

ប៉ុណ្ណោះជាប្រមាណ ជាតិមិនជាប្រមាណឡើយ កាលពោលយ៉ាងនេះហើយ សុវបណ្ឌិត ក៏នាំរឿងអតីតមកសបញ្ជាក់ ដើម្បីសម្តែងការផ្សេងគ្នានៃជាតិមិនជាប្រមាណក្នុងពួកមនុស្សជាមុន ទើបពោលពាក្យជាលំដាប់ថា

ព្រះមាតានៃព្រះបាទសិវិ ព្រះនាមជម្ពាវតី ( ជាចណ្ឌាលសោះ )
តែបានជាអគ្គមហេសី ជាទីស្រឡាញ់របស់ព្រះបាទវាសុទេវ-
កណ្ហាយនគោត្រ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជម្ពាវតី** សេចក្តីថា ព្រះមាតារបស់ព្រះបាទសិវិរាជព្រះនាមថា ជម្ពាវតី ជាស្រីចណ្ឌាល ព្រះនាងបានជាអគ្គមហេសី ជាទីស្រឡាញ់របស់ព្រះបាទវាសុទេព ដែលជាបងប្រុសនៃក្សត្រ ១០ អង្គរបស់កណ្ហាយនគោត្រ ។

បានឮថា ថ្ងៃមួយ ព្រះបាទវាសុទេពចេញអំពីនគរទ្វារវតី ប្រពាសព្រះរាជឧទ្យាន ទតឃើញកុមារិការូបស្អាតម្នាក់ជាចណ្ឌាល ចេញអំពីស្រុកចណ្ឌាល ចូលកាន់ព្រះនគរដោយធុរៈណាមួយ ឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង ទ្រង់មានចិត្តប្រតិព័ទ្ធ មានព្រះតម្រាស់សួរថា នាងមានជាតិអ្វី សូម្បីបានដឹងថា មានជាតិជាចណ្ឌាល ក៏ត្រាស់សួរទៀតថា នាងមានប្តីឬនៅ ទ្រង់ស្តាប់ថា មិនទាន់មានប្តី ទើបនាំកុមារិកានោះត្រឡប់អំពីទីនោះ ទៅកាន់ព្រះរាជនិវេសន៍ ទ្រង់តាំងឲ្យជាអគ្គមហេសី ព្រះនាងប្រសូតព្រះឱរសព្រះនាមសិវិ កាលព្រះរាជបិតាសោយទិវង្គតហើយ ព្រះបាទសិវិ ក៏គ្រងរាជសម្បត្តិក្នុងនគរទ្វារវតី សុវបោតកៈពោលពាក្យនេះ សំដៅយកព្រះបាទសិវិនោះ ។

សុវបណ្ឌិត នាំឧទាហរណ៍យ៉ាងនេះមកហើយ ពោលថា ក្សត្រសូម្បី មានសភាពបែបនេះ គង់សម្រេចសំវាសជាមួយស្រីចណ្ឌាល នឹងពោលថ្វី ក្នុងយើងទាំងពីរ ដែលជាសត្វតិរច្ឆាននោះ ការគាប់ចិត្តក្នុងការរួមបវេណីគ្នា និងគ្នាឯណោះទេតើ ជាការសំខាន់ ពោលដូច្នេះហើយ កាលនឹងលើក ឧទាហរណ៍ដទៃមកទៀត ទើបពោលថា

សូម្បីនាងកិន្នរី ឈ្មោះរតនវតី ញុំាងតាបសឈ្មោះវច្ឆៈឲ្យប្រាថ្នា ដែរ ។ មនុស្សរួមសង្វាសជាមួយនឹងមេម្រឹគក៏មាន ការនៅរួមក្នុង កាម មិនដូចគ្នាមិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វច្ឆំ** សេចក្តីថា តាបសមានឈ្មោះយ៉ាងនោះ កិន្នរីនោះ បានរួមរ័កនឹងតាបសនោះដូចម្តេច ។ បានឮថា ក្នុងអតីតកាល មាន ព្រាហ្មណ៍ម្នាក់ ឃើញទោសក្នុងកាមទាំងឡាយ ទើបលះបង់នូវយសធំចេញ បួសជាឥសី សាងបណ្ណសាលាក្នុងហិមវន្តប្បទេស កិន្នរជាច្រើននៅក្នុងគុហា មួយកន្លែង ក្បែរបណ្ណសាលារបស់ឥសីនោះ ពីងពាងមួយនៅត្រង់មាត់គុហា នោះ ពីងពាងនោះបានខាំក្បាលរបស់កិន្នរទាំងនោះបឺតឈាម ធម្មតាកិន្នរទាំង ឡាយជាសត្វមិនមានកម្លាំង មានជាតិខ្លាច សូម្បីពីងពាងនោះក៏ធំ កិន្នរទាំង ឡាយមិនអាចធ្វើអ្វីពីងពាងបាន ទើបចូលទៅរកតាបសនោះ ធ្វើបដិសណ្ឋារៈ ហើយ តាបសសួរដល់ហេតុដែលមក ទើបនាំគ្នាប្រាប់ថា មានពីងពាងមួយ ប្រហារជីវិតរបស់ពួកខ្ញុំ ពួកខ្ញុំមិនឃើញអ្នកដទៃជាទីពឹងបាន សូមលោកម្ចាស់ សម្លាប់ពីងពាង ធ្វើសួស្តីដល់ពួកខ្ញុំ តាបសបានស្តាប់ពាក្យដូច្នោះ ក៏បៀតបៀន

ថា ពួកហង់ទៅចុះ បព្វជិតទាំងឡាយដូចយើងមិនធ្វើបាណាតិបាត ។ បណ្ដាកិន្នរទាំងនោះ មានកិន្នរីមួយឈ្មោះរតនវតី មិនទាន់មានប្ដី កិន្នរទាំងនោះ ក៏តាក់តែងកិន្នរីរតនវតីនោះ ហើយនាំទៅរកតាបសពោលថា កិន្នរីនេះចូរជាអ្នកបម្រើបាតជើងលោកម្ចាស់ សូមលោកម្ចាស់សម្លាប់បច្ចាមិត្តរបស់ពួកយើង តាបសឃើញកិន្នរីរតនវតី ក៏មានចិត្តប្រតិព័ទ្ធ ទើបសម្រេចការរួមអភិរម្យនឹងកិន្នរីនោះ ហើយទៅឈរត្រង់ទ្វារគុហា វាយពីងពាងដែលចេញមករកស៊ីដោយដំបងឲ្យអស់ជីវិត តាបសនោះនៅរួមជាមួយកិន្នរីនោះ មានកូនប្រុសស្រីហើយ ធ្វើកាលកិរិយាក្នុងទីនោះឯង ។ កិន្នរីរតនវតីនោះ ស្រឡាញ់តាបសឈ្មោះវច្ឆៈ ដោយប្រការដូច្នេះ ។ សុវបោតកៈនាំឧទាហរណ៍នេះមកកាលនឹងសម្ដែងថា វច្ឆតាបសជាមនុស្ស គង់សម្រេចសង្វាសជាមួយកិន្នរីនោះដែលជាសត្វតិរច្ឆានបាន នឹងពោលថ្វីដល់យើងទាំងពីរដែលជាបក្សី ជាតិរច្ឆានដូចគ្នា នឹងរួមសង្វាសមិនបាននោះ ទើបពោលពាក្យជាដើមថា មនុស្សរួមសង្វាសជាមួយនឹងមេម្រឹគក៏មាន ដូច្នេះ មនុស្សទាំងឡាយនៅរួមជាមួយសត្វតិរច្ឆានមាន គឺប្រាកដដោយប្រការដូច្នេះ ។

សាលិកាញីនោះ បានស្ដាប់ពាក្យរបស់សុវបោតកៈហើយពោលថា នែអ្នក ឈ្មោះថាចិត្តប្រព្រឹត្តទៅមួយសព្វកាលរមែងមិនមាន ខ្ញុំខ្លាចអំពីការព្រាត់ប្រាសចាកអ្នកជាទីស្រឡាញ់ ។ សុវបណ្ឌិតនោះ ជាសត្វឈ្លាសក្នុងមាយាស្ត្រី ដូច្នោះ កាលនឹងសាកល្បងសាលិកា ទើបពោលគាថាទៀតថា

នៃនាងសាលិកាពោលពាក្យពីរោះ បើដូច្នោះ យើងនឹងទៅវិញ
ព្រោះពាក្យនាងនុ៎ះ ទុកជាពាក្យប្រកែក នាងមើលងាយខ្ញុំពិត
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បច្ចក្ខានុបទំ ហោតំ** សេចក្តីថា ពាក្យនាងពោលទាំងអស់នោះ ជាគន្លងឲ្យដឹងប្រចក្ស គឺជាហេតុឲ្យដឹងប្រចក្ស ។ បទថា **អតិមញ្ញសិ** សេចក្តីថា នាងមើលងាយខ្ញុំពិតថា សេកនេះ រមែងប្រាថ្នាប៉ុណ្ណោះ នាងមិនដឹងសារសំខាន់របស់ខ្ញុំ ព្រះរាជាក៏បូជាខ្ញុំ ខ្ញុំរកកិរិយាបានមិនលំបាក ខ្ញុំនឹងស្វែងរកបក្សីដទៃជាភរិយា ខ្ញុំនឹងទៅ ។

សាលិកាញីបានស្តាប់ពាក្យរបស់សុវបោតកៈ ហទយៈស្ទើរបែក ត្រូវកាមរតិកើតឡើង មួយអន្លើដោយការឃើញសុវបោតកៈនោះ ធ្វើជាមិនប្រាថ្នាដោយមាយាស្ត្រីរបស់ខ្លួន បានពោលមួយគាថាកន្លះថា

នែមាធុរសុវបណ្ឌិត សិរីរមែងមិនមានដល់អ្នកប្រញាប់ទេ អ្នក
ចូរឈប់នៅទីនេះ ដរាបបានឃើញព្រះរាជាសិន អ្នកនឹងបាន
ស្តាប់សំឡេងសម្ភោរ បានឃើញអានុភាពព្រះរាជា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន សិរី** សេចក្តីថា នែសម្លាញ់សុវបណ្ឌិត សិរីរមែងមិនមានដល់អ្នករួសរាន់ ការងារដែលរួសរាន់រមែងធ្វើមិនល្អ ឈ្មោះថា ការគ្រប់គ្រងផ្ទះនោះ ជាភារៈធ្ងន់ក្រៃលែង ត្រូវគិតពិចារណាសិនសឹមធ្វើ សូមអញ្ជើញអ្នកនៅក្នុងទីនេះ ទម្រាំបានឃើញព្រះរាជារបស់យើងដែលប្រកបដោយយសធំ ។ បទថា **សោសិ** សេចក្តីថា អ្នកនឹងបានស្តាប់សំឡេងសម្ភោរ

សំឡេងច្រៀង និងសំឡេងប្រគំតន្ត្រីផ្សេងៗ ដែលពួកនារីមានរូបឆោមឧត្តម មានលីលាស្មើដោយកិន្នរី ប្រគំក្នុងពេលសាយណ្ហ នឹងបានឃើញអានុភាព និងសិរីដ៏ក្រៃលែងរបស់ព្រះរាជា អ្នកប្រញាប់ទៅធ្វើអ្វីសម្លាញ់ សូម្បីគោលអាង ( លេស ) អ្នកក៏មិនទាន់ដឹង នៅសិនចុះ ខ្ញុំនឹងឲ្យដឹងក្នុងកាលខាងក្រោយ ។

លំដាប់នោះ បក្សីទាំងពីរក៏ធ្វើមេថុនសង្វាស ក្នុងសាយណ្ហសម័យនោះឯង មានការសាមគ្គី ត្រេកអររួមសេចក្ដីស្រឡាញ់ដល់គ្នានិងគ្នា ។ គ្រានោះ សុវបោតកៈគិតថា ឥឡូវនេះ សាលិកាញីនឹងមិនលាក់អាថ៌កំបាំងដល់អញ អញគួរសាកសួរនាងហើយ ទៅក្នុងទំនងនេះ ទើបពោលថា នែសាលិកា សាលិកាពោលថា មានការអ្វីឬអ្នក សេកពោលថា ខ្ញុំចង់សួររឿងបន្តិចបន្តួច សាលិកាពោលថា សួរមកចុះ សេកពោលថា រឿងនោះទុកសិនចុះ ថ្ងៃនេះជាថ្ងៃមង្គលរបស់យើង ថ្ងៃដទៃខ្ញុំនឹងដឹង សាលិកាពោលថា បើពាក្យដែលសួរប្រកបដោយមង្គលក៏ចូរសួរ បើមិនមែនក៏កុំសួរ សុវបណ្ឌិតឆ្លើយថា កថានោះជាមង្គលកថា សាលិកាញីពោលថា បើដូច្នោះ ចូរសួរចុះ ។ លំដាប់នោះ សុវបណ្ឌិតពោលថា បើនាងចង់ស្ដាប់រឿងនោះ ខ្ញុំនឹងពោលដល់នាង កាលនឹងសួរអាថ៌កំបាំងនោះ ទើបពោលមួយគាថាកន្លះថា

សំឡេងអឺងកងនេះ ឮល្បីប្រាកដ ទៅជនបទខាងក្រៅថា ព្រះ
រាជធីតារបស់ព្រះបាទបញ្ចាល មានវណ្ណៈដូចជាផ្កាយព្រឹក ព្រះអង្គ
នឹងប្រទានព្រះរាជធីតានោះ ដល់ព្រះបាទវិទេហៈ ឯវិវាហមង្គល

នោះ ក៏នឹងមានដែរ ( តើពិតឬទេ ) ដូច្នេះ ។

អត្ថរបស់គាថានោះថា សំឡេងខ្ទរខ្ទាយនេះច្រើន ។ បទថា **តិរោ-ជនបទេ សុតោ** សេចក្តីថា ប្រាកដ គឺដឹងទូទៅ គឺផ្សាយទៅក្នុងរដ្ឋដទៃ ក្នុងជនបទដទៃ ផ្សាយទៅដូចម្តេច គឺព្រះរាជធីតារបស់ព្រះបាទបញ្ចាលរាជ រុងរឿងដូចផ្កាយព្រឹក មានព្រះឆវីវណ្ណស្មើដោយផ្កាយព្រឹកនោះមាន ព្រះបាទបញ្ចាលរាជ នឹងប្រទានព្រះរាជធីតានោះដល់អ្នកវិទេហរដ្ឋ ។ បទថា **សោ វិវាហោ ភវិស្សតិ** សេចក្តីថា ខ្ញុំបានស្តាប់សំឡេងដែលល្បីទៅយ៉ាងនោះ ទើបគិតថា កុមារិកានេះ ទ្រទ្រង់នូវរូបឆោមដ៏ប្រសើរ ហើយព្រះបាទវិទេហ-រាជ ក៏ជាសត្រូវរបស់ព្រះបាទចូឡនី ព្រះរាជាដទៃៗ ដែលនៅក្នុងអំណាចរបស់ព្រះបាទចូឡនីព្រហ្មទត្ត ក៏មាននៅជាច្រើន ព្រះបាទចូឡនី មិនប្រទានដល់ព្រះរាជាទាំងនោះ ហេតុអ្វី ទើបប្រទានព្រះរាជធីតាដល់ព្រះបាទវិទេហរាជ ។

សាលិកាញីបានស្តាប់ពាក្យរបស់សុវបោតកៈនោះហើយ ទើបពោលយ៉ាងនេះថា នែអ្នក ព្រោះហេតុអ្វី ទើបអ្នកពោលអវមង្គលក្នុងថ្ងៃមង្គល សុវបណ្ឌិតក៏សាកសួរថា ខ្ញុំពោលថា មង្គល នាងពោលថា អវមង្គល តើរឿងនេះដូចម្តេច សាលិកាញីពោលថា អ្នកនិយាយថ្វី ការធ្វើមង្គលបែបនេះ កុំមានដល់ជនទាំងនោះ សូម្បីជាអមិត្ត ។ សុវបោតកៈឲ្យសាលិកាញីប្រាប់រឿង តែនាងមិនហ៊ាននិយាយ ទើបសុវបោតកៈពោលថា នែនាងចាប់តាំងពីកាលដែលនាងប្រាប់អាថ៌កំបាំង ដែលនាងដឹងដល់ខ្ញុំមិនបាន ការរួមអភិរម្យគ្នា ជាប្តីប្រពន្ធ ឈ្មោះថា មិនមាន ។ សាលិកាញីត្រូវសុវបោតកៈរំអុក ក៏

ពោលថា បើយ៉ាងនោះ ចូរអ្នកស្តាប់ ហើយពោលថា

នៃមាធុរៈ ការរៀបចំវិវាហមង្គល ប្រាកដដូចនេះ របស់ពួកសត្រូវ ដូចជាវិវាហមង្គលរបស់ព្រះបាទបញ្ចាល ជាមួយនឹងព្រះបាទវិទេហៈរបស់អ្នកចូរលើកទុកចុះ ដូច្នេះ ។

កាលសាលិកាញីពោលយ៉ាងនេះហើយ សុវបោតកៈសួរទៀតថា ព្រោះហេតុអ្វី ទើបនាងពោលពាក្យបែបនេះ ទើបសាលិកាញីពោលថា បើដូច្នេះ ចូរអ្នកស្តាប់ ខ្ញុំនឹងពោលទោសក្នុងរឿងនេះដល់អ្នកទៀត ទើបពោលគាថានេះថា

ព្រះរាជាដ៏ប្រសើរលើរថ របស់អ្នកក្រុងបញ្ចាល នឹងនាំព្រះបាទវិទេហៈមក ហើយនឹងសម្លាប់ព្រះបាទវិទេហៈនោះ ក្នុងវេលានោះ ( ព្រះបាទចូឡនី ) មិនមែនជាសម្លាញ់របស់ព្រះបាទវិទេហៈនោះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តតោ ធំ ឃាតយិស្សតិ** សេចក្តីថា ព្រះបាទវិទេហរាជ នឹងយាងមកព្រះនគរនេះក្នុងកាលណា ព្រះបាទចូឡនីទ្រង់នឹងធ្វើជាសម្លាញ់ គឺមិត្តជាមួយព្រះបាទវិទេហរាជក្នុងកាលនោះ នឹងមិនប្រទានព្រះរាជធីតាដល់ព្រះបាទវិទេហរាជនោះ សូម្បីដើម្បីទត បានឮថា ព្រះបាទវិទេហរាជនោះ មានអត្តធម្មានុសាសន៍ជាមួយមនុស្សម្នាក់ ឈ្មោះមហោសថ-

បណ្ឌិត ព្រះបាទចូឡនីនឹងសម្លាប់មហោសថនោះ មួយអន្លើដោយព្រះបាទវិទេហរាជ កេវដ្តព្រាហ្មណ៍ប្រឹក្សាជាមួយព្រះបាទចូឡនីថា យើងនឹងសម្លាប់ជនទាំងពីរនោះហើយ ផឹកជយបានៈ ទើបទៅនគរមិថិលាដើម្បីចាប់មហោសថនោះមក ។

សាលិកាញីប្រាប់អាថ៌កំបាំងសុវបណ្ឌិតមិនមានសេសសល់ដោយប្រការដូច្នេះ ។ សុវបណ្ឌិតបានស្តាប់ដូច្នោះហើយ ទើបពោលសរសើរកេវដ្ដៈនោះថា អាចារ្យកេវដ្ដៈ ជាមនុស្សឈ្លាសក្នុងឧបាយ ការសម្លាប់ព្រះបាទវិទេហរាជដោយឧបាយបែបនេះគួរអស្ចារ្យ ហើយពោលថា ប្រយោជន៍អ្វីដោយអវមង្គលបែបនេះដល់យើង ចូរនាំគ្នាស្ងៀមហើយដេកចុះ ដឹងការសម្រេចនៃកិច្ចដែលមកនៅជាមួយសាលិកានោះក្នុងរាត្រីនោះហើយ ពោលថា នៃនាង ខ្ញុំនឹងទៅដែនសិវិទូលភាពដែលខ្ញុំបានករិយាគាប់ចិត្ត ដល់ព្រះបាទសិវិ និងព្រះទេវី ហើយពោលដើម្បីឲ្យសាលិកាញីអនុញ្ញាតឲ្យខ្លួនទៅថា

> សូមនាងអនុញ្ញាតឲ្យបងទៅត្រឹម ៧ រាត្រី ទម្រាំបងទូលព្រះបាទ
> សិវិ និងព្រះមហេសីថា ខ្ញុំបាននៅរួមក្នុងសម្នាក់នាងសាលិកា
> ហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មហេសិនោ** បានដល់ មហេសីរបស់ព្រះបាទសិវិរាជនោះ ។ បទថា **អាវសថោ** បានដល់ ដែលជាលំនៅ ។ បទថា **ឧបដ្ឋិតំ** សេចក្ដីថា កាលនោះ សុវបោតកៈពោលថា ខ្ញុំនឹងប្រាប់ព្រះរាជា និងព្រះទេវីទាំងពីរនោះថា សូមទ្រង់ទៅកាន់សម្នាក់របស់សាលិកានោះ ដូច្នេះ

ក្នុងថ្ងៃទី ៨ នឹងនាំមកទីនេះ ហើយនាំនាងទៅដោយបរិវារធំ នាងកុំក្រវល់ក្រវាយ ទម្រាំខ្ញុំមក ។

សាលិកាបានស្តាប់ដូច្នោះ មិនចង់បែកអំពីសុវបោតកៈឡើយ តែមិនអាចបដិសេធពាក្យរបស់សុវបោតកៈបាន ទើបពោលគាថាជាលំដាប់ថា

អើ ! ខ្ញុំអនុញ្ញាតឲ្យអ្នកទៅត្រឹម ៧ រាត្រី បើអ្នកមិនត្រឡប់មកកាន់សម្នាក់ខ្ញុំក្នុងរវាង ៧ រាត្រីវិញទេ ខ្ញុំសម្គាល់ខ្លួនខ្ញុំថា អស់ជីវិត កាលបើខ្ញុំស្លាប់ហួសទៅហើយ ទើបអ្នកនឹងមកដល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មញ្ញោ ឱក្កន្តសន្តំ មំ** សេចក្តីថា កាលបើដូច្នេះ ខ្ញុំនឹងកំណត់ខ្លួនខ្ញុំថា ប្រាសចាកជីវិតហើយ បើអ្នកមិនមក ក្នុងថ្ងៃទី ៨ ទើបមក ឈ្មោះថា ខ្ញុំស្លាប់ហើយ ព្រោះដូច្នោះ អ្នកកុំបង្អែបង្អង់ ។

ចំណែកសុវបណ្ឌិត ពោលដោយវាចាថា នែនាង នាងនិយាយអ្វី បើខ្ញុំមិនបានឃើញនាងក្នុងថ្ងៃទី ៨ ជីវិតនឹងមានអំពីណា តែចិត្តគិតថា នាងនឹងរស់ ឬស្លាប់ ក៏មិនជាប្រយោជន៍អ្វីដល់អញ ហើរឡើងទៅបែរមុខទៅកាន់សិវិរដ្ឋ ទៅបានបន្តិចក៏ត្រឡប់មកកាន់សម្នាក់របស់សាលិកានោះទៀត ពោលថា នែនាង ខ្ញុំមិនឃើញរូបរបស់នាង មិនអាចចោលនាងទៅបាន ដូច្នោះ ទើបខ្ញុំត្រឡប់មក ពោលដូច្នេះហើយ ក៏ហើរទៅម្តងទៀត ទៅកាន់ក្រុងមិថិលា ទំត្រង់ចង្ក្រុយស្មារបស់មហោសថបណ្ឌិត ព្រះមហាសត្វបីសេកឡើងទៅកាន់ប្រាសាទ ដោយសញ្ញានោះ ហើយសាកសួរ ទើបប្រាប់ព្រឹត្តិការណ៍នោះដល់មហោសថទាំងអស់ ចំណែកមហោសថក៏បានឲ្យរង្វាន់តាមគាប់ចិត្ត ដល់សុវ-

បោតកៈដោយន័យខាងដើមនោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួរប្រសានូវព្រះគាថាដូច្នេះថា

លំដាប់នោះ មាធុរសុវបណ្ឌិតនោះ ក៏ហើរទៅប្រាប់មហោសធថា

ពាក្យនេះ ជាពាក្យរបស់នាងសាលិកា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាលិកាយ វចនំ ឥទំ** សេចក្ដីថា សុវបោតកៈបានប្រាប់សេចក្ដីទាំងពួងដោយពិស្ដារថា ពាក្យនេះ ជាពាក្យរបស់សាលិកាញី ។

ព្រះមហាសត្វបានស្ដាប់ដូច្នោះ ទើបត្រិះរិះថា កាលអញមិនចង់ឲ្យយាងព្រះរាជានឹងយាង កាលយាងទៅហើយ ក៏នឹងដល់នូវសេចក្ដីវិនាសធំ កាលបើដូច្នោះ អញនឹងកាន់យកព្រះរាជតម្រាស់របស់ព្រះរាជា ដែលព្រះរាជទានយសបែបនេះដល់អញទុកក្នុងចិត្តហើយ មិនស្នងព្រះគុណរបស់ទ្រង់ ការនិន្ទានឹងមានដល់អញ បណ្ឌិតដូចអញនៅមាន ព្រោះហេតុអ្វី បណ្ដាយឲ្យព្រះរាជាវិនាស ព្រោះដូច្នោះ អញនឹងទៅមុនទ្រង់ ហើយគាល់ព្រះបាទចូឡនីសាងនគរជាទីប្រថាប់នៃព្រះបាទវិទេហរាជ ធ្វើឲ្យជានគរ ដែលចែកល្អហើយ ធ្វើឧម្មង្គ គឺផ្លូវក្រោមដីប្រវែងមួយគាវុត ឧម្មង្គធំកន្លះយោជន៍ ហើយអភិសេកព្រះនាងបញ្ចាលចន្ទី រាជធីតាព្រះបាទចូឡនីព្រហ្មទត្ត ឲ្យជាបាទបរិចារិកានៃព្រះរាជារបស់អញ ក្នុងកាលព្រះរាជា ១០១ មួយអន្ទើដោយពលនិកាយ ១៨

អក្ខោភិនីចោមរោម អញនឹងដោះព្រះរាជារបស់អញឲ្យផុត ដូចដោះព្រះចន្ទអំពីមាត់រាហុអសុរិន្ទ ដូច្នោះ ហើយនាំព្រះរាជាមកកាន់មិថិលានគរ ឈ្មោះថាព្រះរាជករណីយកិច្ចដែលនឹងមានមករបស់ព្រះរាជា ត្រូវជាធុរៈនៃអញ ។ កាលមហោសថត្រិះរិះយ៉ាងនេះ ក៏កើតបីតិក្នុងសរីរៈ ដោយកម្លាំងនៃបីតិមហោសថ កាលនឹងបន្លឺឧទាន ទើបពោលកន្លះគាថាដូច្នេះថា

បុរសគប្បីបរិភោគនូវភោគសម្បត្តិ ក្នុងផ្ទះរបស់បុគ្គលណា គប្បីធ្វើប្រយោជន៍ដល់បុគ្គលនោះឯង ដូច្នេះ ។

អត្ថនៃកន្លះគាថានោះដូច្នេះថា បុរសដែលជាបណ្ឌិត បានឥស្សរិយយសធំ បរិភោគសម្បត្តិអំពីសម្នាក់របស់ព្រះរាជាណា គប្បីប្រព្រឹត្តវត្តដែលជាប្រយោជន៍ ដែលជាសេចក្តីចម្រើនដល់ព្រះរាជានោះ សូម្បីទ្រង់ជេរបរិភាសប្រហារ ចាប់កអូសទៅក៏ដោយ ដោយទ្វារទាំង ៣ មានកាយទ្វារជាដើម បណ្ឌិតទាំងឡាយ មិនគប្បីធ្វើកម្ម គឺការទ្រុស្តមិត្តឡើយ ។

កាលត្រិះរិះដូច្នេះហើយ ក៏ងូតទឹក តែងខ្លួនទៅគាល់ព្រះបាទវិទេហរាជថ្វាយបង្គំហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់នឹងយាងទៅឧត្តរបញ្ចាលនគរឬ ព្រះរាជាតបថា អើ យើងនឹងទៅ បើយើងមិនបានទាងបញ្ចាលចន្ទី នឹងត្រូវការអ្វីដោយរាជសម្បត្តិ អ្នកកុំបោះបង់យើង ចូរទៅជាមួយយើង ប្រយោជន៍ពីរប្រការ គឺយើងបាននារីរតនៈ និងរាជមេត្រីនៃព្រះបាទចូឡនី ជាមួយយើងនឹងតាំងមាំ នឹងសម្រេចព្រោះយើងទាំងពីរទៅនគរបញ្ចាលនោះ ។ លំដាប់នោះ មហោសថ កាល

នឹងទូលថា បើយ៉ាងនោះ ទូលបង្គំនឹងទៅមុន សាងព្រះរាជនិវេសន៍ដើម្បីព្រះអង្គ ទ្រង់គួរយាងទៅក្នុងកាលដែលទូលបង្គំបញ្ជូនដំណឹងមកក្រាបទូល កាលទូលដូច្នេះហើយ បានពោល ២ គាថាថា

បពិត្រព្រះជនិន្ទ ខ្ញុំព្រះអង្គនឹងសូមទៅកាន់បុរី គួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បម្រុងព្រះអង្គ មានយសធំក្នុងដែនវិទេហៈ ។ បពិត្រក្សត្រិយ៍ លុះខ្ញុំព្រះអង្គសាងនិវេសន៍ដើម្បីព្រះអង្គ មានយសធំ ក្នុងដែនវិទេហៈស្រេចហើយ នឹងបញ្ជូនទូតមកទូលព្រះអង្គក្នុងវេលាណា ព្រះអង្គគប្បីយាងទៅក្នុងវេលានោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វេទេហស្ស** បានដល់ ដល់ព្រះអង្គដែលជាព្រះបាទវិទេហរាជ ។ បទថា **ឃយ្យាសិ** បានដល់ គប្បីយាងមក ។

ព្រះបាទវិទេហរាជបានស្ដាប់ដូច្នោះ ទ្រង់ត្រេកអរផង ត្រង់សោមនស្សផង ដោយយល់ថា មហោសថមិនបោះបង់អញ ទើបត្រាស់ថា នែបាមហោសថ បើបាទៅមុន គួរបានអ្វីទៅខ្លះ កាលមហោសថក្រាបទូលថា គួរបានពល និងពាហនៈ ទើបត្រាស់ថា បាប្រាថ្នារបស់ណា ចូរយករបស់នោះចុះ ទើបមហោសថក្រាបទូលថា សូមទ្រង់ឲ្យបើកគុក ៤ ខែ ឲ្យដោះនូវចំណង គឺខ្នោះនៃចោរទាំងឡាយ បញ្ជូនទៅជាមួយទូលបង្គំ កាលព្រះរាជានុញ្ញាតឲ្យធ្វើតាមគាប់ចិត្ត ទើបទៅបើកគុកឲ្យពួកចោរដែលក្លាហាន ជាទាហានធំ ដែលអាចញុំាងកិច្ចការក្នុងទីដែលទៅហើយឲ្យសម្រេច ហើយពោលថា ឯងទាំង

ឡាយ ចូរបម្រើយើង ហើយឲ្យរបស់ដល់ជនទាំងនោះ ហើយនាំសេនា ១៨ ពួក ដែលជាអ្នកឈ្លាសក្នុងសិប្បៈផ្សេងៗ មានជាងឈើ ជាងដែក ជាងស្បែក ជាងថ្ម ជាងគំនូរ ជាងឥដ្ឋជាដើមទៅ ឲ្យយកគ្រឿងឧបករណ៍ជាច្រើន មានកាំបិត ប៉ូវថៅ ចប ចបជីកជាដើមទៅ ជាអ្នកមានកងពលធំចោមរោម ចេញអំពីព្រះនគរ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាធូវព្រះគាថាដូច្នេះថា

លំដាប់នោះឯង ព្រះមហោសធ ក៏បានទៅកាន់បុរី គួរជាទីរីករាយ

របស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បម្រុងព្រះបាទ

វិទេហៈមានយស ដូច្នេះ ។

ចំណែកមហាសត្វ កាលទៅក្នុងទីទាំងឡាយនោះ ក៏សាងស្រុកមួយក្នុងរវាងផ្លូវមួយយោជន៍ ស្រុកមួយក្នុងរវាងផ្លូវមួយយោជន៍ ហើយពោលនឹងអមាត្យម្នាក់ៗ ថា ចូរអ្នកទាំងឡាយត្រៀមដំរី សេះ និងរថទុកក្នុងកាលព្រះបាទវិទេហរាជទទួលព្រះនាងបញ្ចាលចន្ទីត្រឡប់ទៅ ហើយនាំព្រះរាជាទៅឃាត់នូវបច្ចាមិត្តកុំឲ្យប្រទូស្តបាន ឲ្យយាងដល់ក្រុងមិថិលាដោយរហ័ស បញ្ជាដូច្នេះហើយ ដាក់អមាត្យម្នាក់ៗ កាលមហោសថទៅដល់ច្រាំងគង្គា ទើបហៅអមាត្យម្នាក់ ឈ្មោះអានន្ទកុមារមកប្រាប់ថា នែបាអានន្ទ ចូរអ្នកនាំជាងឈើ ៣០០ នាក់ ទៅខាងលើស្ទឹងគង្គា ឲ្យកាន់យកឈើខ្លឹមធ្វើទូកប្រមាណ ៣០០

ហើយចាំងឈើក្នុងទីនោះឯង ដឹកឈើស្រាលៗ ក្នុងទូកមកដោយរហ័ស ដើម្បីសាងនគរ ចំណែកមហោសថ ឡើងទូកចូងត្រើយទៅកាន់ត្រើយនាយ រាប់ផ្លូវដោយជំហាន ចាប់អំពីទីឡើងអំពីទូកកំណត់ថា ទីនេះ កន្ទះយោជន៍ ឧមង្គធំនឹងមានក្នុងទីនេះ នគរដែលតាំងព្រះរាជនិវេសន៍នៃព្រះបាទវិទេហរាជ នឹងមានក្នុងទីនេះ ចាប់តាំងអំពីព្រះរាជនិវេសន៍នេះ ឧមង្គជាផ្លូវដើរ នឹងមានក្នុងទីមួយគាវុត រហូតដល់ព្រះរាជមន្ទីរ កំណត់ដូច្នេះហើយ ចូលទៅកាន់ឧត្តរ-បញ្ចាលនគរ ព្រះបាទចូឡនីទ្រង់ស្តាប់ថា មហោសថមកដល់ ទ្រង់ក៏សោមនស្សក្រៃលែងថា ឥឡូវនេះ សេចក្តីប្រាថ្នារបស់យើងនឹងសម្រេច យើងនឹងឃើញខ្នងនៃពួកបច្ចាមិត្ត កាលមហោសថមក ព្រះបាទវិទេហរាជនឹងមកក្នុងកាលមិនយូរ ពេលនោះ អញនឹងសម្លាប់សត្រូវទាំងពីរ សោយរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ។ នគរឧត្តរបញ្ចាលទាំងមូល កក្រើករំពើកដោយកោលាហលថា បានឮថា បុរសនេះ ឈ្មោះមហោសថបណ្ឌិត បានឮថាព្រះរាជា ១០១ ដែលមហោសថនេះឲ្យរត់ទៅ ដូចបុគ្គលដេញក្អែកឲ្យគេចទៅដោយដុំដី ។ ព្រះមហាសត្វចូលទៅកាន់ទ្វារ ក្នុងខណៈដែលអ្នកនគរសរសើររូបសម្បត្តិរបស់ខ្លួន ឲ្យក្រាបទូលព្រះបាទចូឡនីឲ្យទ្រង់ជ្រាប កាលបានទទួលព្រះរាជានុញ្ញាតឲ្យចូលគាល់ ទើបចូលទៅថ្វាយបង្គំព្រះរាជា ឈរក្នុងទីសមគួរ នាចំណែកម្ខាង ។

លំដាប់នោះ ព្រះបាទចូឡនីទ្រង់ធ្វើបដិសណ្ឋារៈ ត្រាស់សួរមហោសថថា ព្រះរាជារបស់អ្នកនឹងយាងមកក្នុងកាលណា មហោសថទូលថា នឹងយាង

មកក្នុងកាលដែលទូលបង្គំបញ្ជូនដំណឹងទៅ ព្រះបាទចូឡនីត្រាស់សួរថា ចុះខ្លួនអ្នកមកដើម្បីអ្វី មហោសថទូលថា មកដើម្បីសាងព្រះរាជនិវេសន៍សម្រាប់ព្រះរាជារបស់ទូលបង្គំ ព្រះបាទចូឡនីត្រាស់ថា សាធុ បន្ទាប់អំពីនោះ ក៏ឲ្យព្រះរាជទានស្បៀង ដល់សេនារបស់មហោសថ ព្រះរាជទានទ្រព្យជាច្រើន និងផ្ទះដែលជាលំនៅដល់មហោសថ ហើយត្រាស់ថា នែបា បាកុំក្តៅក្រហាយ ចូរធ្វើរាជការដែលគួរធ្វើជាមួយខ្ញុំ ទម្រាំព្រះរាជារបស់អ្នកយាងមក ។ បានឮថា មហោសថឡើងកាន់ព្រះរាជនិវេសន៍ ឈរក្បែរជើងជណ្តើរ កំណត់ថា ទ្វារឧមង្គនឹងមានក្នុងទីនេះ បរិវិតក្កមានដល់មហោសថថា ព្រះបាទចូឡនីត្រាស់ថា ចូរអ្នកធ្វើកិច្ចដែលគួរធ្វើដល់ពួកយើងខ្លះ ដូច្នេះ ក្នុងកាលជីកឧមង្គ ក៏គួរធ្វើដោយកុំឲ្យជណ្តើរនេះស្រុត លំដាប់នោះ ទើបមហោសថក្រាបទូលព្រះបាទចូឡនីយ៉ាងនេះថា បពិត្រព្រះសម្មតិទេព កាលទូលបង្គំចូលមកគាល់ ឈរត្រង់ជណ្តើរណា ត្រួតមើលនវកម្មក្នុងទីនេះ ឃើញទោសត្រង់ជណ្តើរធំ បើសេចក្តីដែលក្រាបទូលនេះ ប្រពៃដោយព្រះរាជតម្រិះ ទូលបង្គំនឹងយកឈើទាំងឡាយមកក្រាលឲ្យជាទីពេញចិត្ត ព្រះបាទចូឡនីទ្រង់អនុញ្ញាត មហោសថកំណត់ល្អហើយថា ទ្វារឧមង្គនឹងមានក្នុងទីនេះ ទើបនាំជណ្តើរចេញ ឲ្យក្រាលបន្ទះក្តារ ដើម្បីកុំឲ្យមានធូលីក្នុងទីដែលជាទ្វារឧមង្គ ហើយដាក់ជណ្តើរដូចដើម មិនឲ្យកម្រើក មិនឲ្យស្រុតចុះបាន កាលព្រះរាជាមិនជ្រាបទោសដែលគប្បីមាន ទើបទ្រង់យល់ថា មហោសថធ្វើដោយភក្តីចំពោះយើង ។

មហោសថឲ្យធ្វើនវកម្មអស់ ១ ថ្ងៃយ៉ាងនេះហើយ ស្អែកឡើង ទើប

ក្រាបទូលព្រះបាទចូឡនីថា បពិត្រព្រះសម្មតិទេព បើទ្រង់ជ្រើសរើសរកទី ប្រថាប់នៃព្រះរាជារបស់ទូលបង្គំៗ គប្បីបដិបត្តិធ្វើឲ្យពេញចិត្ត ព្រះបាទចូឡនី ត្រាស់ថា ប្រពៃហើយបណ្ឌិត វៀរតែព្រះរាជនិវេសន៍របស់យើង ក្រៅអំពី នេះ ក្នុងនគរទាំងមូល អ្នកប្រាថ្នាទីណា ជាព្រះរាជនិវេសន៍របស់ព្រះបាទ វិទេហរាជ ចូរយកទីនោះចុះ ។ មហោសថក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំជាភ្ញៀវ ទាហាន និងអ្នកជិតស្និទ្ធរបស់ព្រះអង្គមានច្រើន មនុស្ស ទាំងនោះ កាលទូលបង្គំយកផ្ទះរបស់គេ ក៏នឹងកើតជម្លោះ ព្រោះហេតុនោះ ទូលបង្គំនឹងធ្វើអ្វីជាមួយជនទាំងនោះបាន ។ ព្រះបាទចូឡនីត្រាស់ថា នែបណ្ឌិត អ្នកកុំកាន់យកពាក្យរបស់ជនទាំងនោះ ទីណាអ្នកគាប់ចិត្ត ចូរអ្នកកាន់យក ទីនោះឯង មហោសថក៏ក្រាបទូលបន្តថា បពិត្រព្រះសម្មតិទេព ជនទាំងនោះ នឹងមកក្រាបទូលទ្រង់រឿយៗ សេចក្តីសុខនៃព្រះរាជហឫទ័យរបស់ព្រះអង្គ និង ចិត្តរបស់ទូលបង្គំនឹងមិនមាន បើទ្រង់ប្រាថ្នា អ្នករក្សាទ្វារគួរជាមនុស្សរបស់ ទូលបង្គំ ទម្រាំទូលបង្គំរកទីកន្លែង ដែលជាព្រះរាជនិវេសន៍នៃព្រះរាជារបស់ ទូលបង្គំបាន បន្ទាប់អំពីនោះ ជនទាំងនោះ ចូលទ្វារមិនបាន ក៏នឹងមិនមក កាលបើដូច្នេះ ទ្រង់នឹងសុខស្រួល ឯទូលបង្គំក៏នឹងសប្បាយចិត្ត ព្រះបាទ ចូឡនីក៏ទ្រង់អនុញ្ញាត ។ មហាសត្វតាំងមនុស្សរបស់ខ្លួនក្នុងទីទាំងពួង គឺត្រង់ ជើងជណ្តើរ ក្បាលជណ្តើរ ទ្វារធំ ប្រាប់ថា ពួកអ្នកកុំឲ្យអ្នកណាចូលទៅ ។

លំដាប់នោះ មហាសត្វទៅកាន់សម្នាក់ព្រះរាជមាតារបស់ព្រះបាទចូឡនី មុន ហើយប្រាប់មនុស្សទាំងឡាយថា សូមអ្នកទាំងឡាយរើព្រះដំណាក់ អ្នក

បម្រើទាំងនោះក៏ប្រារព្ធដើម្បីរើឥដ្ឋ និងជីកដីតាំងអំពីខ្លោងទ្វារ ។ ព្រះរាជ-មាតារបស់ព្រះបាទចូឡនី បានស្តាប់ដំណឹងនោះ យាងមកត្រាស់ថា ពួកអ្នកឲ្យរើដំណាក់របស់យើងដើម្បីអ្វី ទើបជនទាំងនោះទូលតបថា មហោសថឲ្យរើប្រាថ្នាឲ្យសាងព្រះរាជនិវេសន៍នៃព្រះរាជារបស់ខ្លួន ទើបព្រះរាជមាតាត្រាស់ថា បើយ៉ាងនោះ នៅជាមួយគ្នាក្នុងដំណាក់នេះក៏ជាការស្រេច ។ ជនទាំងនោះទូលតបថា ពលពាហនៈរបស់ព្រះរាជានៃទូលបង្គំមានច្រើន ដំណាក់នេះរមែងមិនគ្រប់គ្រាន់ ទូលបង្គំនឹងសាងព្រះរាជដំណាក់ថ្មីឲ្យធំ ព្រះរាជជននីក៏ត្រាស់ថា ពួកអ្នកមិនស្គាល់យើង យើងជាព្រះរាជមាតារបស់ព្រះបាទចូឡនី យើងនឹងទៅរកកូនយើង នឹងដឹងគ្នាក្នុងកាលឥឡូវនេះ ជនទាំងនោះក៏ក្រាបទូលថា ទូលបង្គំនឹងរើតាមព្រះរាជតម្រាស់ បើព្រះនាងអាច ក៏ចូរឃាត់ ។ ព្រះនាងសលាកទេវីខ្ញាល់ត្រាស់ថា យើងនឹងដឹងកិច្ចដែលយើងគប្បីធ្វើដល់ពួកឯងក្នុងកាលឥឡូវនេះ ត្រាស់ហើយ យាងទៅកាន់ទ្វារព្រះរាជនិវេសន៍ ។ លំដាប់នោះ អ្នកយាមទ្វារក៏ឃាត់ព្រះរាជមាតាថា ព្រះនាងកុំចូលទៅ ព្រះរាជមាតាត្រាស់ថា យើងជាព្រះរាជជននី ជនទាំងនោះក៏ទូលថា ពួកទូលបង្គំមិនដឹង ព្រះបាទចូឡនីត្រាស់ថា កុំឲ្យអ្នកណាចូលទៅ ព្រោះដូច្នោះ សូមព្រះនាងយាងត្រឡប់ចុះ ។ ព្រះនាងសលាកទេវី កាលមិនទតឃើញទីពឹងក៏យាងត្រឡប់មកប្រថាប់ឈរទតព្រះរាជដំណាក់របស់ព្រះនាង ។ លំដាប់នោះបុរសម្នាក់ក៏ទូលព្រះនាងថា នាងមកធ្វើអ្វីក្នុងទីនេះ ចូរទៅ ថាហើយ ក្រោកឡើងចាប់ត្រង់ក ធ្វើឲ្យដួលចុះត្រង់ផែនដី ព្រះនាងត្រិះរិះថា ជនទាំងនេះ ព្រះ

រាជាកូនរបស់អញបញ្ជាដោយពិត អ្នកណាមិនអាចធ្វើយ៉ាងនេះ ដោយប្រការដទៃ អញនឹងទៅហាមមហោសថ ទើបយាងទៅរកមហោសថ ត្រាស់ថា នែបាមហោសថ អ្នកឲ្យរើដំណាក់របស់យើងព្រោះហេតុអ្វី មហោសថមិននិយាយជាមួយព្រះនាង តែបុរសដែលឈរនៅជិតទូលថា ព្រះនាងត្រាស់អ្វី ព្រះនាងក៏ត្រាស់ថា មហោសថឲ្យរើដំណាក់យើងដើម្បីអ្វី បុរសនោះទូលថា ដើម្បីធ្វើទីប្រថាប់របស់ព្រះបាទវិទេហរាជ ព្រះរាជមាតាក៏ត្រាស់ថា នគរធំដល់ម្ល៉េះ ហេតុអ្វីរកទីធ្វើព្រះរាជនិវេសន៍ក្នុងទីដទៃមិនបាន ចូរអ្នកទទួលសំណូក ១ សែនកហាបណៈនេះហើយ ឲ្យធ្វើព្រះរាជដំណាក់ក្នុងទីដទៃចុះ បុរសនោះទូលថា ប្រពៃហើយព្រះនាង ទូលបង្គំនឹងលះដំណាក់របស់ព្រះនាង តែព្រះនាងកុំប្រាប់កាលដែលទូលបង្គំស៊ីសំណូកដល់អ្នកណាមួយ ព្រោះថា ជនដទៃនឹងនាំគ្នាឲ្យសំណូកដល់ពួកទូលបង្គំហើយ មិនចង់លះបង់ផ្ទះរបស់ខ្លួន ព្រះនាងសលាកទេវីត្រាស់តបថា ការដែលយើងនិយាយឲ្យអ្នកណាដឹងនោះ ជាទីគួរខ្មាសដល់យើងថា ព្រះរាជមាតាបានឲ្យសំណូកដូច្នេះ ព្រោះដូច្នោះ យើងមិនប្រាប់ដល់អ្នកណាឡើយ បុរសនោះទទួលថា សាធុ ហើយទទួលយកកហាបណៈ ១ សែនអំពីព្រះនាង ក៏លះដំណាក់នោះ ទៅផ្ទះកេវដ្ដៈ ឲ្យធ្វើដូចធ្វើដល់ដំណាក់របស់ព្រះនាងសលាកទេវីនោះ ។ កេវដ្ដៈក្រោធទៅកាន់ព្រះរាជទ្វារ ពួកអ្នករក្សាទ្វារក៏វាយត្រង់ខ្នងកេវដ្ដៈ ដោយបន្ទះឫស្សី ស្បែកខ្នងរបស់កេវដ្ដៈក៏របក កេវដ្ដៈមិនឃើញទីពឹង ក៏ត្រឡប់មកផ្ទះ ឲ្យកហាបណៈ ១ សែនដល់បុរសនោះ មហោសថកាន់យកទីតាំងផ្ទះ ក្នុងនគរទាំងមូល

ដោយឧបាយនេះ ទទួលសំណូកបានកហាបណៈ ក្នុងទីនោះៗ ប្រមាណ ៩ កោដិ ព្រះពោធិសត្វពិចារណាក្នុងនគរទាំងមូល ហើយទៅគាល់ព្រះបាទចូឡនី ព្រះរាជាត្រាស់សួរថា មានរឿងអ្វីបណ្ឌិត កន្លែងធ្វើព្រះរាជនិវេសន៍ អ្នករកបានហើយឬ មហោសថក្រាបទូលថា ឈ្មោះថា បុគ្គលណាមិនឲ្យ រមែងមិនមាន តែកាលផ្ទះដែលទូលបង្គំកាន់យក ជនជាម្ចាស់ ក៏រមែងលំបាក ការធ្វើភាពដែលជនទាំងនោះ ព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ មិនសមគួរដល់ទូលបង្គំ ព្រោះដូច្នោះ ទូលបង្គំនឹងសាងព្រះនគរ ឲ្យជាទីប្រថាប់នៃព្រះរាជារបស់ទូលបង្គំក្នុងទីនោះ រវាងស្ទឹងគង្គា និងនគរនេះ ក្នុងទីមួយគាវុតអំពីទីនេះ ខាងក្រៅព្រះនគរនេះ ។

ព្រះបាទចូឡនីទ្រង់បានស្តាប់ក៏ត្រេកអរ ដោយទ្រង់យល់ឃើញថា ការច្បាំងខាងក្នុងនគរជាការលំបាក សេនាខាងយើង ឬសេនាខាងអ្នកដទៃក៏ដឹងលំបាក ការធ្វើយុទ្ធនាការខាងក្រៅនគរជាការងាយ នឹងមិនកាប់សម្លាប់គ្នាខាងក្នុងនគរ ទ្រង់ឃើញដូច្នេះក៏ត្រាស់ថា ប្រពៃហើយបា ចូរបាសាងក្នុងទីដែលបាកំណត់ចុះ មហោសថក្រាបទូលថា ទូលបង្គំនឹងឲ្យធ្វើក្នុងទីដែលក្រាបទូល សូមទ្រង់អនុញ្ញាត អ្នកនគរមិនគប្បីទៅកាន់ទីនវកម្មរបស់ទូលបង្គំ ដើម្បីរកឧស និងស្លឹកឈើ ព្រោះថា កាលអ្នកនគរទៅ នឹងកើតជម្លោះ វិវាទគ្នា ដោយហេតុនោះឯង ការសុខស្រួលព្រះរាជហឫទ័យ នឹងមិនមានដល់ព្រះអង្គ ហើយការសប្បាយចិត្ត ក៏នឹងមិនមានដល់ទូលបង្គំ ព្រះបាទចូឡនីត្រាស់ថា សាធុ ចូរអ្នកឃាត់កុំឲ្យអ្នកណាទៅកាន់ទីនោះ មហោសថទូលថា បពិត្រព្រះ

សម្មតិទេព ដំរីទាំងឡាយរបស់ទូលបង្គំ ចូលចិត្តលេងទឹក កាលទឹកល្អក់កើតឡើង បើអ្នកនគរអាក់អន់នឹងពួកទូលបង្គំថា តាំងពីមហោសថមក ពួកយើងមិនបានផឹកទឹកថ្លា សូមទ្រង់ករុណាអត់ធ្មត់ក្នុងរឿងនេះ កុំពិរោធនឹងពួកទូលបង្គំ ព្រះបាទចូឡនីត្រាស់ថា ដំរីទាំងឡាយរបស់អ្នក ចូរឲ្យលេងទឹកចុះ ត្រាស់ដូច្នេះហើយ ទ្រង់ប្រកាសថា អ្នកណាចេញអំពីទីនេះ ទៅកាន់ទីសាងនគររបស់មហោសថ នឹងត្រូវពិន័យ ១ ពាន់កហាបណៈ ។ មហោសថក្រាបថ្វាយបង្គំលាព្រះបាទចូឡនី នាំគ្នីគ្នារបស់ខ្លួនចេញអំពីព្រះនគរ ផ្តើមសាងព្រះនគរក្នុងទីដែលបានកំណត់ ឲ្យសាងស្រុកឈ្មោះគគ្គលិ ត្រង់ត្រើយស្ទឹងគង្គា ត្រើយនាយ ឲ្យដំរី សេះ រថ ពាហនៈ គោ មានកម្លាំងនៅក្នុងស្រុកនោះ ពិចារណាការសាងព្រះនគរ បែងចែកការងារទាំងពួងថា ជនប៉ុណ្ណោះធ្វើកិច្ចឈ្មោះនេះជាដើម ហើយបានផ្តើមធ្វើការងារក្នុងឧម្មង្គ ទ្វារឧម្មង្គធំនៅត្រង់ត្រើយស្ទឹងគង្គា ជនទាំងឡាយ ៦ ពាន់នាក់ជីកឧម្មង្គធំ យកថង់ស្បែកធំនាំក្រួសខ្សាច់ធូលីចាក់ក្នុងស្ទឹងគង្គា ដំរីទាំងឡាយក៏ជាន់ត្រង់ទីដែលចាក់នោះៗ ទឹកល្អក់ក៏ហូរទៅ អ្នកនគរនាំគ្នាពោលថា តាំងពីមហោសថមក ពួកយើងមិនបានផឹកទឹកថ្លា ទឹកល្អក់ហូរទៅ ព្រោះហេតុអ្វីហ្ន៎ ។ លំដាប់នោះបុរសដែលមហោសថបង្កប់ ក៏ប្រាប់ដល់អ្នកនគរថា បានឮថា ហ្វូងដំរីរបស់មហោសថលេងទឹក ធ្វើឲ្យទឹកក្នុងស្ទឹងគង្គាល្អក់ជាកក់ ព្រោះដូច្នោះ ទើបទឹកល្អក់ហូរមក ។ ធម្មតាបំណងរបស់ព្រះពោធិសត្វទាំងឡាយ រមែងសម្រេច ព្រោះដូច្នោះ ឫសឈើ ថ្ម ក្រួសទាំងពួងក្នុងឧម្មង្គ រមែងលិចចុះទៅក្នុងផែនដី

ទ្វារនៃឧមង្គជាផ្លូវដើរក្នុងនគរនោះ ជនទាំងឡាយ ៣ ពាន់នាក់ ជីកឧមង្គដែលជាផ្លូវដើរ ឲ្យដាក់ក្រួសដោយថង់ស្បែកទៅចាក់បំពេញក្នុងនគរនោះ ឲ្យលាយដី និងខ្សាច់ដែលចាក់ជាមួយទឹក ធ្វើជាកំពែង និងធ្វើកិច្ចដទៃៗ ផងដែរ ទ្វារផ្លូវមហាឧមង្គក៏មានក្នុងនគរ ប្រកបដោយទ្វារជាគូ មានគន្លឹះយន្តកម្ពស់ ១៨ ហត្ថ ។ ក្នុងកាលជាន់គន្លឹះមួយ ទ្វារទាំងនោះក៏បិទ ជាន់គន្លឹះមួយទៀត ទ្វារនោះក៏បើក កឥដ្ឋសងខាងនៃមហាឧមង្គហើយ បូកបាយ-អ ក្រាលឈើអំពីខាងលើ យកដីឥដ្ឋបំពេញតាមប្រហោង ហើយបូកបាយ-អ ។ ក្នុងឧមង្គនោះមានទ្វារទាំងអស់ គឺទ្វារធំ ៨០ ទ្វារតូច ៦៤ គ្រប់ទ្វារប្រកបដោយយន្ត ក្នុងកាលជាន់គន្លឹះមួយ ទ្វារទាំងអស់ក៏បិទ ក្នុងកាលជាន់គន្លឹះមួយ ទ្វារទាំងអស់ក៏បើក ប្រើដោយពន្លឺភ្លើងច្រើនជាងមួយរយ សងខាងមហាឧមង្គ មានគោមភ្លើងប្រកបដោយយន្ត កាលបើកយន្តមួយ គោមភ្លើងក៏បើកពន្លឺព្រមគ្នា កាលបិទយន្តមួយ គោមភ្លើងក៏បិទព្រមគ្នាទាំងអស់ ឯបន្ទប់ធំ ១០១ បន្ទប់សម្រាប់ព្រះរាជា ១០១ មានសងខាងនៃមហាឧមង្គ ដាក់កម្រាលផ្សេងៗ ក្នុងបន្ទប់ធំគ្រប់បន្ទប់ មានទីប្រថាប់គង់មួយៗ លើកស្វេតច្ឆត្រគ្រប់កន្លែង រូបស្ត្រីធ្វើអំពីដីឥដ្ឋ មួយរូបៗ ស្អាតក្រៃលែង តាំងទុកអាស្រ័យព្រះរាជសីហាសនៈ និងព្រះរាជមហាសេយ្យាសនៈ ១ អង្គមួយរូប ១ អង្គមួយរូប ប្រតិស្ឋានហើយ បើបុគ្គលមិនចាប់ពាល់រូបនោះ ក៏មិនអាចដឹងថា មិនមែនរូបមនុស្សយ៉ាងទៀត ពួកជាងគំនូរអ្នកឈ្លាស បានធ្វើចិត្តកម្មយ៉ាងវិចិត្រផ្សេងៗ ទាំងសងខាងនៃមហាឧមង្គ សម្តែងរូបភាពទាំងពួងក្នុងឧមង្គ មានរូបសក្កទេវរាជ

មានពួកទេវតាចោមរោម និងភ្នំសិនេរុ ភ្នំសត្តបរិភណ្ឌ សាគរ មហាសាគរ ទ្វីប ៤ ព្រៃហិមពាន្ត អនោតត្តស្រះ ផ្ទាំងមនោសិលា ព្រះចន្ទ ព្រះអាទិត្យ ស្ថានសួគ៌ជាន់កាមាវចរ មានចាតុម្មហារាជិកាជាដើម និងសម្បត្តិ ៧ ប្រការ រោយដោយខ្សាច់ដែលមានពណ៌ដូចប្រាក់ត្រង់ផែនដី គួរផ្កាឈូកសំយុងតាម ប្រហោងខាងលើ គួររានផ្សារមានប្រការផ្សេងៗ ទាំងសងខាង សំយុងកម្រង គ្រឿងក្រអូប និងបុប្ផជាតិជាដើម ក្នុងទីនោះៗ ប្រដាប់ឧម្មង្គដូចសុធម្មា-ទេវសភា ចំណែកជាង ៣០០ នាក់ ដែលមហោសថឲ្យទៅធ្វើទព្វសម្ភារៈនៃ ព្រះរាជនិវេសន៍ និងឲ្យធ្វើទូកដឹកមកនោះ ក៏បានធ្វើទូក ៣០០ ទព្វសម្ភារៈ ដែលធ្វើស្រេចហើយតាមស្នឹងគន្លា ប្រាប់ដល់មហោសថៗ នាំទព្វសម្ភារៈ ទាំងនោះ ទៅជាគ្រឿងប្រកបប្រើការក្នុងព្រះនគរ និងឲ្យនាំទូកទាំងឡាយទៅ រក្សាក្នុងទីកំបាំង ប្រាប់ថា ចូរពួកអ្នកនាំមកក្នុងថ្ងៃដែលយើងប្រាប់ ។ ការ កសាងទាំងពួងក្នុងព្រះនគរដែលហើយស្រេច គឺគូទឹក គូភក់ គូស្ងួត កំពែង កម្ពស់ ១៨ ហត្ថ ប៉ម ទ្វារ ខ្លោងទ្វារ និងព្រះរាជនិវេសន៍ រោងដំរី ស្រះ បោក្ខរណី មហាឧម្មង្គ ជង្ឃឧម្មង្គ ( ឧម្មង្គដែលដើរដោយជើង ) ព្រះនគរ ទាំងអស់នេះហើយស្រេច ក្នុងកាល ៤ ខែ ដោយប្រការដូច្នេះ ។

បន្ទាប់អំពីនោះ កន្លងមកបាន ៤ ខែ មហាសត្វបានបញ្ជូនទូតទៅដើម្បី យាងព្រះបាទវិទេហរាជមក ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិជមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះ

បន្ទូលសួធ្យសាន្ទូវព្រះគាថាដូច្នេះថា

ព្រះមហោសធ លុះសាងនិវេសន៍ដើម្បីព្រះបាទវិទេហៈ មាន
យសស្រេចហើយ ទើបបញ្ជូនទូតមកទូលព្រះបាទវិទេហៈ គ្រប់
គ្រងមិថិលាថា បពិត្រមហារាជ និវេសន៍ខ្ញុំព្រះអង្គសាងដើម្បី
ព្រះអង្គហើយ សូមព្រះអង្គស្តេចមកក្នុងកាលឥឡូវនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាហិណិ** បានដល់ បញ្ជូនទៅហើយ ។
ព្រះបាទវិទេហរាជ បានស្តាប់ពាក្យរបស់ទូត ទ្រង់ក៏សោមនស្ស យាងទៅ
ដោយព្រះរាជបរិវារដ៏ច្រើន ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទ
ព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល
សួធ្យសាន្ទូវព្រះគាថាដូច្នេះថា

លំដាប់នោះឯង ព្រះរាជា ព្រមដោយសេនាមានអង្គ ៤ យាង
ទៅដើម្បីទតបុរីដ៏ធំទូលាយ ដែលមហោសថបណ្ឌិតសាងទុក ក្នុង
ដែនកប្បិលៈ មានពាហនៈមិនមានទីបំផុត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនន្តវាហានំ** បានដល់ ពាហនៈ មានដំរី
និងសេះជាដើមប្រមាណមិនបាន ។ បទថា **កប្បិលិយំ បុរំ** បានដល់ នគរ
ដែលមហោសថបណ្ឌិតសាងក្នុងដែនកប្បិលៈ ។

ព្រះបាទវិទេហរាជយាងទៅដោយលំដាប់ ដល់ច្រាំងស្ទឹងគង្គា លំដាប់
នោះ ព្រះមហាសត្វក៏ទៅទទួលឲ្យទ្រង់យាងចូលព្រះនគរដែលខ្លួនសាង ព្រះ

រាជាយាងទៅកាន់ប្រាសាទដ៏ប្រសើរក្នុងនគរនោះ ស្រង់ទឹក តាក់តែងព្រះកាយហើយ សោយភោជនាហារមានរសដ៏ប្រសើរ ទ្រង់សម្រាកបន្តិចហើយ ពេលល្ងាច ទ្រង់បញ្ជារាជទូតឲ្យទៅកាន់សម្នាក់ព្រះបាទចូឡនី ដើម្បីឲ្យទ្រង់ជ្រាបថា ព្រះអង្គយាងមកហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាចិធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះឯង ព្រះបាទវិទេហៈនោះ លុះស្តេចយាងទៅដល់ ( ដែនកប្បិលៈ ) ហើយ ទើបបញ្ជូនរាជសាសន៍ទៅថ្វាយព្រះបាទចូឡនីព្រហ្មទត្តថា បពិត្រមហារាជ ខ្ញុំមកដើម្បីថ្វាយបង្គំព្រះបាទទាំងឡាយរបស់ព្រះអង្គ ។ សូមព្រះអង្គទ្រង់ប្រទាននាងនារីដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការ ជាវិការនៃមាស មានពួកទាសីជាបរិវារ ឲ្យជាករិយា ( របស់ខ្ញុំ ) ក្នុងកាលឥឡូវនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វន្ទិតុំ** សេចក្តីថា ព្រះបាទវិទេហរាជ មានព្រះជន្មចាស់ជាងព្រះបាទចូឡនី ព្រះបាទចូឡនីមិនគប់គ្រាន់ សូម្បីស្មើនឹងព្រះរាជឱរសរបស់ព្រះបាទវិទេហរាជ តែព្រះបាទវិទេហរាជវង្វេងដោយកិលេស ទើបទ្រង់ព្រះតម្រិះថា ព្រះបាទចូឡនីជាបិតាក្មេក ដែលអញជាកូនប្រសាគួរថ្វាយបង្គំ ទ្រង់មិនជ្រាបការគិតរបស់ព្រះបាទចូឡនី ទើបទ្រង់បញ្ជូនសាសន៍

ថ្វាយបង្គំទៅ ។ បទថា **ធនាហិធានិ** សេចក្ដីថា ព្រះបាទវិទេហរាជទ្រង់បញ្ជូនសាសន៍ទៅថា ទ្រង់ហៅទូលបង្គំមកថា នឹងប្រទានរាជធីតា សូមប្រោសប្រទានរាជធីតានោះ ដល់ទូលបង្គំឥឡូវនេះចុះ ។ បទថា **សុវណ្ណេន បដិច្ឆន្នំ** បានដល់ ប្រដាប់ដោយគ្រឿងអលង្ការដែលធ្វើអំពីមាស ។

ចំណែកព្រះបាទចូឡនី ទ្រង់ស្ដាប់ពាក្យព្រះរាជទូត ក៏ទ្រង់សោមនស្សព្រះតម្រិះថា ឥឡូវនេះ បច្ចាមិត្តរបស់អញនឹងទៅខាងណាផុត អញនឹងកាត់ក្បាលជនទាំងពីរ ហើយផឹកជយបានៈ កាលទ្រង់សម្ដែងព្រះសោមនស្សឲ្យប្រាកដ ទើបព្រះរាជទានរង្វាន់ដល់រាជទូត ហើយត្រាស់គាថាជាលំដាប់ថា

បពិត្រព្រះបាទវិទេហៈ ព្រះអង្គស្ដេចមកល្អហើយ មួយទៀត
ព្រះអង្គស្ដេចមកមិនអាក្រក់ទេ សូមព្រះអង្គសាកសួររកនក្ខត្តឫក្ស
ចុះ ខ្ញុំនឹងថ្វាយនាងកញ្ញា ដ៏ប្រដាប់ដោយគ្រឿងអលង្ការ ជាវិការ
នៃមាស មានពួកទាសីជាបរិវារដល់ព្រះអង្គ ដូច្នេះ ។

ក្នុងគាថានោះ ព្រះបាទចូឡនីបានស្ដាប់សាសន៍របស់ព្រះបាទវិទេហរាជហើយ ត្រាស់ហៅព្រះបាទវិទេហរាជនោះ ដូចនៅចំពោះព្រះភក្ត្រថា **វេទេហ** ន័យម្យ៉ាងទៀត ទ្រង់ឲ្យរាជទូតទៅទូលថា ព្រះបាទព្រហ្មទត្តចូឡនីត្រាស់យ៉ាងនេះ ទើបត្រាស់យ៉ាងនេះ ។

រាជទូតបានស្ដាប់ដូច្នោះ ទើបទៅគាល់ព្រះបាទវិទេហរាជ ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់រកឫក្សដែលសមគួរដល់ព្រះរាជពិធីអាវាហ-មង្គល ព្រះបាទចូឡនីថ្វាយព្រះរាជធីតាដល់ព្រះអង្គ ទើបព្រះបាទវិទេហរាជ

បញ្ជូនរាជទូតទៅទៀតថា ថ្ងៃនេះឯងឫក្សល្អ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសុបស្រាន្តនូវព្រះគាថាដូច្នេះថា

លំដាប់នោះឯង ព្រះបាទវិទេហៈ សួររកនក្ខត្តឫក្ស លុះសួររកនក្ខត្តឫក្សរួចហើយ ទើបបញ្ជូនរាជសាសន៍ ទៅថ្វាយព្រះបាទព្រហ្មទត្តថា សូមព្រះអង្គទ្រង់ប្រទាននារី ដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការ ជាវិការនៃមាស មានពួកទាសីជាបរិវារឲ្យជាកិរិយារបស់ខ្ញុំ ក្នុងកាលឥឡូវនេះ ដូច្នេះ ។

ចំណែកព្រះបាទចូឡនីត្រាស់តបថា

ខ្ញុំថ្វាយនាងនារីដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការនៃមាស មានពួកទាសីជាបរិវារឲ្យជាកិរិយារបស់ព្រះអង្គក្នុងកាលឥឡូវនេះ ដូច្នេះ ។

កាលព្រះបាទចូឡនីត្រាស់គាថានេះហើយ ត្រាស់បញ្ឆោតថា នឹងបញ្ជូនទៅឥឡូវនេះ នឹងបញ្ជូនទៅឥឡូវនេះ ដូច្នេះ បានប្រទានសញ្ញាដល់ព្រះរាជា ១០១ ថា អ្នកទាំងពួង អន្ទើដោយសេនា ១៨ អក្ខោភិនី ចូរត្រៀមចេញច្បាំង ថ្ងៃនេះ យើងនឹងកាត់ក្បាលសត្រូវទាំងពីរ ស្អែកនេះ នឹងបានផឹកជយបានៈ ព្រះរាជាទាំង ១០១ នោះ ក៏ចេញក្នុងខណៈនោះឯង ចំណែកព្រះបាទក្រុងបញ្ចាល កាលនឹងយាងចេញធ្វើចម្បាំង ក៏ញុំាងព្រះនាងសលាកទេវី

ដែលជាព្រះរាជមាតា ព្រះនាងនន្ទាទេវីដែលជាមហេសី ព្រះបាទបញ្ចាលចន្ទៈជារាជឱរស ព្រះនាងបញ្ចាលចន្ទីជារាជធីតា រួមជា ៤ អង្គ ឲ្យនៅក្នុងដំណាក់ជាមួយគ្នានឹងស្រីស្នំទាំងឡាយ ទើបយាងចេញធ្វើសង្គ្រាម ។

ចំណែកមហោសថបរមពោធិសត្វ ធ្វើរាជសក្ការៈជាច្រើនដល់ព្រះបាទវិទេហរាជ មួយអន្ទើដោយសេនា និងជនពួកខ្លះផឹកស្រា ពួកខ្លះទំពាស៊ីមច្ឆ-មំសាហារ ពួកខ្លះហត់នឿយក៏ដេកព្រោះមកអំពីឆ្ងាយ ចំណែកព្រះបាទវិទេហរាជទ្រង់នាំអាចារ្យទាំង ៤ មានសេនកៈជាដើម ប្រថាប់គង់ក្នុងព្រះរាជមន្ទីរ ដែលបានតាក់តែងហើយកណ្តាលរាជបរិវារ ។ ចំណែកព្រះបាទចូឡនី ព័ទ្ធនគរដែលព្រះបាទវិទេហរាជ ប្រថាប់ឲ្យជាប់តគ្នា ៣ ជាន់ ដោយកងទ័ព ១៨ អក្ខោភិនី មានអ្នកកាន់គប់ភ្លើងរាប់សែន ។ កាលអរុណរះឡើង ក៏ត្រៀមដណ្តើមនគរ ។

មហោសថក៏បញ្ជូនយោធា ៣០០ នាក់របស់ខ្លួនទៅថា អ្នកទាំងឡាយចូរទៅតាមជង្ឃឧមង្គ ចាប់រាជមាតា មហេសី រាជបុត្រ និងរាជធីតារបស់ព្រះបាទចូឡនីមកតាមជង្ឃឧមង្គ កុំឲ្យនៅខាងក្រៅទ្វារឧមង្គ ឲ្យនៅខាងក្នុងឧមង្គធ្វើការរក្សា ទម្រាំយើងមក សឹមនាំចេញអំពីឧមង្គ ឲ្យនៅក្នុងរោងធំ ក្បែរឧមង្គ ក្នុងកាលយើងទៅ ។ ជនទាំងនោះទទួលពាក្យរបស់មហោសថ ក៏ធ្វើដំណើរទៅតាមជង្ឃឧមង្គ បើកឈើដែលក្រាលត្រង់ជណ្តើរ ហើយចងមនុស្សដែលរក្សាត្រង់ជើងជណ្តើរ ក្បាលជណ្តើរ និងផ្ទៃដំណាក់ និងស្រីបម្រើ មានស្រីគម ស្រីតឿជាដើម ហើយបិទមាត់ជនទាំងនោះ ឲ្យនៅទីកំបាំង ទំពាស៊ី

ព្រះស្នោយដែលគេត្រៀមថ្វាយព្រះបាទចូឡនី បោះរបស់ទាំងឡាយចោលទម្លាយភាជនៈធ្វើខ្ទិចខ្ទីហើយ ឡើងទៅខាងលើប្រាសាទ ។ កាលនោះព្រះនាងសលាកទេវីសម្គាល់ថា តើមានអ្នកណាស្គាល់ព្រះនាងនន្ទាទេវី កូនប្រុសនិងកូនស្រី តើនឹងមានរឿងអ្វីកើតឡើង ទើបឲ្យផ្ទំក្នុងទីបន្ទំជាមួយព្រះនាង ។ យោធាទាំងនោះ ឈរហៅត្រង់ទ្វារបន្ទប់ ព្រះនាងក៏ចេញមកត្រាស់សួរថា មានរឿងអ្វីបា យោធាទាំងនោះក៏ទូលថា បពិត្រព្រះនាង ព្រះរាជារបស់ពួកយើងញុំាងព្រះបាទវិទេហរាជ និងមហោសថឲ្យដល់នូវការអស់ជីវិតហើយ ចោមរោមដោយព្រះរាជា ១០១ ជាស្តេចឯករាជ្យក្នុងសកលជម្ពូទ្វីប ផឹកជយបានៈដោយព្រះកិត្តិយសធំ បញ្ជូនទូលបង្គំមកដើម្បីនាំទ្រង់ទាំង ៤ អង្គយាងទៅ ។ ព្រះរាជមាតាទ្រង់ជឿ ក៏ចុះអំពីប្រាសាទ ដល់ជើងជណ្តើរ យោធាទាំងនោះក៏នាំព្រះរាជមាតាជាដើមទៅតាមឧម្មង្គ ព្រះរាជមាតាជាដើមត្រាស់ថា យើងនៅទីនេះអស់កាលប៉ុណ្ណេះ មិនធ្លាប់ស្គាល់ផ្លូវនេះ ។ យោធាទាំងនោះទូលថា បពិត្រព្រះទេវី ជនទាំងពួងមិនធ្លាប់មកតាមផ្លូវនេះឡើយ ព្រោះនេះជាផ្លូវមង្គល ថ្ងៃនេះ ព្រះរាជានឹងត្រាស់ឲ្យនាំយាងតាមផ្លូវនេះ ព្រោះជាថ្ងៃមង្គល ។ ព្រះរាជមាតាជាដើមទ្រង់ជឿ ។ លំដាប់នោះ យោធាពួកខ្លះនាំព្រះរាជមាតាជាដើមមក ពួកខ្លះត្រឡប់ទៅបើកឃ្លាំងរតនៈក្នុងរាជនិវេសន៍ កាន់យកទ្រព្យតាមប្រាថ្នាមកខ្លះ ចំណែកព្រះរាជមាតាជាដើម ខាងមុខអំពីការដល់មហាឧម្មង្គ ឃើញឧម្មង្គហាក់បីដូចទេវសភាដែលប្រដាប់ហើយ ព្រះនាងក៏សម្គាល់ថា គេរៀបចំទុកដើម្បីប្រយោជន៍ដល់ព្រះរាជា ។ លំដាប់នោះ យោធា

ទាំងនោះ នាំព្រះរាជមាតាជាដើមទៅកាន់ទីជិតគង្គា ឲ្យប្រថាប់នៅក្នុងបន្ទប់ដែលតាក់តែងហើយខាងក្នុងឧម្មង្គ ជនពួកមួយនៅរក្សា ពួកមួយទៅប្រាប់ការដែលបាននាំព្រះរាជមាតាជាដើមមកហើយ ដល់មហោសថពោធិសត្វ មហោសថបានស្តាប់ពាក្យរបស់យោធាទាំងនោះ ក៏សោមនស្សថា ឥឡូវនេះសេចក្តីប្រាថ្នារបស់អញនឹងដល់ទីបំផុត ទើបចូលទៅគាល់ព្រះបាទវិទេហរាជឈរក្នុងទីសមគួរនាចំណែកម្ខាង ចំណែកព្រះបាទវិទេហរាជ ព្រោះទ្រង់អផ្សុកដោយអំណាចកិលេស ទើបទ្រង់ព្រះតម្រិះថា ព្រះបាទចូឡនីនឹងនាំព្រះរាជ-ធីតាមកឲ្យអញក្នុងកាលឥឡូវនេះ ក៏ក្រោកចាករាជបល្ល័ង្ក ទតព្រះនគរតាមបង្អួច ឃើញព្រះនគរមានពន្លឺតែមួយ ដោយគប់ភ្លើងរាប់ដោយសែន មិនមែនមួយសែន គំនរកងទ័ពធំចោមរោមជុំវិញហើយ ទ្រង់ងឿងឆ្ងល់ ត្រិះរិះថា នុ៎ះជាអ្វីហ្ន៎ កាលទ្រង់សាកសួរអាចារ្យ ដែលជាបណ្ឌិតទាំងឡាយ ទើបត្រាស់គាថានេះថា

ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែល
ឈរនៅ ( ត្រៀបត្រា ) គប់ភ្លើងឆេះភ្លឺសន្ធោសន្ធៅ តើពួក
បណ្ឌិតសម្គាល់ដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្នុ មញ្ញន្តិ** សេចក្តីថា ព្រះបាទវិទេហរាជត្រាស់សួរថា ព្រះបាទចូឡនីប្រោសប្រាណ ឬក្រោធពួកយើង បណ្ឌិតទាំងឡាយ យល់យ៉ាងណាហ្ន៎ ។

អាចារ្យសេនកៈ បានស្តាប់ព្រះតម្រាស់ ទើបក្រាបទូលថា បពិត្រ

មហារាជ សូមទ្រង់កុំវិតក្កឡើយ គប់ភ្លើងច្រើនពន់ពេកកំពុងប្រាកដ ប្រហែលជាព្រះបាទចូឡនី នាំព្រះរាជធីតាមកថ្វាយព្រះអង្គ ចំណែកអាចារ្យបុក្កុសៈ ក្រាបទូលថា ព្រះបាទចូឡនីទ្រង់នឹងរក្សាដើម្បីធ្វើអាគន្តុកសក្ការៈដល់ព្រះអង្គ ។ បណ្ឌិតទាំង ៤ នោះ គាប់ចិត្តយ៉ាងណា ក៏ក្រាបទូលយ៉ាងនោះដោយប្រការដូច្នេះ ចំណែកព្រះបាទវិទេហរាជ កាលទ្រង់បានស្តាប់សំឡេងមនុស្សក្នុងកងទ័ពស្រែកប្រាប់គ្នាថា សេនាទាំងឡាយ ចូរតាំងនៅក្នុងទីនោះ អ្នកទាំងឡាយ ចូររក្សាក្នុងទីនោះ កុំប្រមាទ នឹងទតឃើញសេនាដែលចងក្រោះ ក៏ជាបុគ្គលដែលមរណភ័យគំរាម កាលទ្រង់បំណងនឹងស្តាប់ពាក្យនៃមហាសត្វ ទើបត្រាស់គាថាក្រៅបន្តថា

ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែល
ឈរនៅ ( ត្រៀបត្រា ) គប់ភ្លើងឆេះសន្ធោសន្ធៅ នៃបណ្ឌិត
ពួកសេនាទាំងនោះ នឹងធ្វើអ្វីហ្ន៎ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្នុ កាហន្តិ បណ្ឌិត** សេចក្តីថា នៃបណ្ឌិតអ្នកគិតដូចម្តេចហ្ន៎ សេនាទាំងនេះនឹងធ្វើអ្វីដល់ពួកយើង ។

ព្រះមហាសត្វបានស្តាប់ព្រះតម្រាស់ដូច្នោះ ក៏គិតក្នុងចិត្តថា អញនឹងធ្វើព្រះរាជាអន្ធពាលឲ្យតក់ស្លុតបន្តិច ខាងក្រោយសឹមសម្តែងកម្លាំងបញ្ញារបស់អញឲ្យប្រាកដ ធ្វើឲ្យព្រះអង្គស្រាលព្រះហឫទ័យ គិតដូច្នេះហើយ ក្រាបទូលថា

បពិត្រមហារាជ ព្រះបាទចូឡនី ព្រហ្មទត្តមានពលច្រើន ប្រទូស-

រាយដល់ព្រះអង្គ រក្សាព្រះអង្គទុក នឹងសម្លាប់ព្រះអង្គ អំពីព្រឹក ដូច្នេះ ។

មនុស្សទាំងអស់នោះ មានព្រះបាទវិទេហរាជជាដើម ក៏គិតភ័យក្នុងសេចក្តីស្លាប់ ព្រះរាជាទ្រង់ស្ងួតក មិនមានទឹកមាត់ក្នុងព្រះឱស្ឋ កើតក្តៅក្រហាយក្នុងព្រះសរីរៈ ទ្រង់ខ្លាចចំពោះមរណភ័យ កន្ទក់កន្ទេញត្រាស់ ២ គាថាថា

ហឫទ័យរបស់យើងញ័ររន្ធត់ ទាំងមាត់របស់យើងក៏សោះស្ងួត
យើងមិនបានសេចក្តីរលត់ ដូចជាឈើត្រូវភ្លើងឆេះក្នុងកណ្តាល
កម្តៅថ្ងៃ ។ ចង្ក្រានរបស់ជាង មាសឆេះតែខាងក្នុង មិនឆេះ
ខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើង ក៏ឆេះតែខាងក្នុង
មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧព្វេធតិ** សេចក្តីថា នៃបាមហោសថ ចិត្តរបស់ខ្ញុំរមែងញាប់ញ័រ ហាក់បីដូចស្លឹកពោធិ៍ត្រូវខ្យល់ធំ ដូច្នោះ ។ បទថា **អន្តោ ឈាយតិ នោ ពហិ** សេចក្តីថា ព្រះបាទវិទេហរាជខ្សឹកខ្សួលថា បេះដូងរបស់យើង រមែងក្តៅក្រហាយខាងក្នុង តែមិនប្រាកដខាងក្រៅ ដូចចង្ក្រានជាងដែក ដូច្នោះ ។

ចំណែកមហាសត្វបានស្តាប់ព្រះបាទវិទេហរាជ ទ្រង់កន្ទក់កន្ទេញ គិតថា ព្រះរាជានេះ ជាអន្ធពាល មិនធ្វើតាមពាក្យរបស់អញក្នុងថ្ងៃដទៃៗ អញនឹងសម្លុតព្រះអង្គឲ្យក្រៃលែងឡើង ទើបទូលថា

បពិត្រក្សត្រ ព្រះអង្គស្រវឹង ( ដោយកាម ) ទើបប្រព្រឹត្តកន្លង
ការប្រឹក្សា ទម្លាយការប្រឹក្សាចោល ឥឡូវនេះ សូមឲ្យបណ្ឌិត

( ទាំង ៤ នាក់ ) ដែលជាអ្នកមានប្រាជ្ញា រក្សាព្រះអង្គចុះ ។ បពិត្រព្រះរាជា ព្រះអង្គមិនធ្វើតាមពាក្យរបស់ទូលបង្គំជាអាមាត្យ ជាអ្នកប្រាថ្នាសេចក្ដីចម្រើន និងស្វែងរកប្រយោជន៍ ទ្រង់ត្រេកអរ ដោយបីតិដ៏សៅហ្មងរបស់ព្រះអង្គ ដូចម្រឹគជាប់អន្ទាក់ ។ ( ទូលបង្គំបានក្រាបទូលហើយថា ) ត្រីជាសត្វល្មោភក្នុងនុយស្រស់ លេបនូវផ្លែសន្ទូចដ៏វៀច ដែលគេបិទដោយសាច់ ត្រីមិនដឹងសេចក្ដីស្លាប់របស់ខ្លួន យ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកល្មោភក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គ ដូចត្រីយ៉ាងនោះឯង ។ បើទ្រង់ស្ដេចទៅកាន់ក្រុងបញ្ចាល ទ្រង់មុខជានឹងលះបោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគដែលដើរទៅតាមផ្លូវ ( ទៀបទ្វារនៃស្រុក ) ។ បពិត្រព្រះជនិន្ទ បុរសមានសភាពមិនថ្លៃថ្នូរ ដូចពស់នៅក្នុងថ្នក់ គប្បីចឹកបុរសមានប្រាជ្ញា មិនគប្បីធ្វើនូវមេត្រីភាព ដោយបុរសនោះទេ ព្រោះថា ការគប់រកដោយបុរសអាក្រក់ រមែងនាំមកនូវសេចក្ដីទុក្ខដោយពិត ។ បពិត្រព្រះជនិន្ទ បណ្ឌិតបុរស ស្គាល់នូវបុគ្គលណាថា អ្នកនេះមានសីល មានការចេះដឹងច្រើន ដូច្នេះ បណ្ឌិតបុរសនោះ គួរធ្វើមេត្រីភាព ជាមួយនឹងបុគ្គលនោះ ព្រោះថា ការសេពគប់ដោយសប្បុរសទាំងឡាយ រមែងនាំមកនូវសេចក្ដីសុខពិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បមត្តោ** សេចក្ដីថា បពិត្រមហារាជ ទ្រង់ជាអ្នកប្រមាទព្រោះសេចក្ដីប្រាថ្នា ។ បទថា **មន្តជាតីនោ** សេចក្ដីថា ជាអ្នកឈានកន្លងនូវការគិត ដែលទូលបង្គំឃើញភ័យក្នុងអនាគត គិតកំណត់ទុកដោយបញ្ញា ។ បទថា **ភិន្នមន្តោ** សេចក្ដីថា ជាបុគ្គលមានការគិត ទម្លាយហើយ គឺការគិតណាដែលទ្រង់ប្រកាន់រួមជាមួយអាចារ្យសេនកៈជាដើម ការគិតនោះ ទ្រង់ទម្លាយហើយ ទើបឈ្មោះថា ជាអ្នកមានការគិតទម្លាយហើយ ព្រោះភាពជាអ្នកឈានកន្លងនូវការគិតនោះឯង ។ បទថា **បណ្ឌិតា** សេចក្ដីថា មហោសថសម្ដែងថា អាចារ្យ ៤ នាក់ មានសេនកៈជាដើមនេះ ចូររក្សាព្រះអង្គក្នុងកាលឥឡូវនេះចុះ ទូលបង្គំនឹងឃើញកម្លាំងរបស់អាចារ្យទាំងនោះ ។ បទថា **អកត្វាមច្ចស្ស** សេចក្ដីថា ទ្រង់មិនធ្វើតាមពាក្យរបស់ទូលបង្គំ ដែលជាអមាត្យដ៏ប្រសើរ ។ បទថា **អត្តបីតិរតោ** សេចក្ដីថា ជាអ្នកទ្រទ្រង់នូវសេចក្ដីត្រេកអរក្រៃលែងហើយ ដោយបីតិដែលសៅហ្មងរបស់ព្រះអង្គ ។ បទថា **មិគោ ក្ុដេវ ឱហិតោ** សេចក្ដីថា ម្រឹគមកដោយសេចក្ដីលោភក្នុងចំណីជាប់ក្នុងអន្ទាក់ឬ រណ្ដៅ យ៉ាងណា ព្រះអង្គទ្រង់មិនជឿពាក្យរបស់ទូលបង្គំយាងមកដោយសេចក្ដីលោភថា នឹងបានព្រះរាជធីតាបញ្ចាលចន្ទី ឥឡូវនេះទ្រង់ដូចជាម្រឹគដែលជាប់ក្នុងអន្ទាក់ ឬរណ្ដៅដូច្នោះ ។ ២ គាថាថា **យថាបិមច្ឆោ** ជាដើម មហោសថបណ្ឌិតពោលដើម្បីសម្ដែងថា ឧបមានេះរបស់ទូលបង្គំនាំមកហើយក្នុងកាលនោះ សូម្បីគាថាថា **សចេ គច្ឆសិ** ជាដើម មហោសថបណ្ឌិតក៏ពោលដើម្បីសម្ដែងថា ទូលបង្គំនាំឧបមានេះមកថ្វាយដល់

ព្រះអង្គ មិនមែនត្រឹមប៉ុណ្ណេះតែម្យ៉ាងប៉ុណ្ណោះឡើយ ។ បទថា **អនរិយរូបោ** បានដល់ បុរសដែលឥតខ្មាស មានជាតិជាមនុស្សអាក្រក់ ដូចកេវដ្ដព្រាហ្មណ៍ ។ បទថា **ន តេន មិត្តឹ** សេចក្ដីថា ទ្រង់មិនគួរធ្វើមិត្តធម៌ជាមួយបុគ្គលបែបនោះ តែព្រះអង្គទ្រង់មានមេត្តាក្នុងកេវដ្ដព្រាហ្មណ៍ កាន់យកនូវពាក្យរបស់កេវដ្ដៈនោះ ។ បទថា **ទុក្ខោ** សេចក្ដីថា ឈ្មោះថា ការសមាគមជាមួយបុគ្គលបែបនេះ ធ្វើតែម្ដងក៏ជាទុក្ខ ព្រោះនាំទុក្ខធំមកទាំងក្នុងលោកនេះទាំងក្នុងលោកខាងមុខ ។ បទថា **យំ ត្វេវ** កាត់បទជា **យំ តុ ឯវ** ម្យ៉ាងទៀតបាឋៈក៏យ៉ាងនេះឯង ។ បទថា **សុខោ** សេចក្ដីថា ជាសុខទាំងក្នុងលោកនេះទាំងក្នុងលោកខាងមុខ ។

លំដាប់នោះ មហោសថសង្កត់សង្កិនព្រះបាទវិទេហរាជក្រៃលែងឡើង ដោយបំណងថា ទ្រង់នឹងមិនធ្វើយ៉ាងនេះទៀត កាលនាំព្រះតម្រាស់ដែលត្រាស់ក្នុងកាលមុនមកសម្ដែង ទើបទូលថា

បពិត្រព្រះរាជា ព្រះអង្គជាមនុស្សល្ងង់លីលា បានពោលនូវសេចក្ដីចម្រើនដ៏ឧត្ដម ក្នុងសម្នាក់នៃខ្ញុំព្រះអង្គថា ខ្ញុំព្រះអង្គជាអ្នកចម្រើនដោយចុងនង្គ័ល ធ្វើម្ដេចនឹងដឹងសេចក្ដីចម្រើនដូចអ្នកដទៃ ។ អ្នកទាំងឡាយ ចូរចាប់មហោសថនេះត្រង់ក ហើយឲ្យវិនាសចាកដែនរបស់អញចេញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ ដូច្នេះ ។

កាលមហោសថពោល ២ គាថានេះហើយ ទើបសង្កត់សង្កិនយ៉ាងនេះ

ថា បពិត្រមហារាជ ទូលបង្គំជាបុត្រគហបតី នឹងស្គាល់សេចក្ដីចម្រើនដូចអ្នកដទៃៗ មានសេនកៈជាដើមដែលជាបណ្ឌិតរបស់ព្រះអង្គ ដែលដឹងនូវសេចក្ដីចម្រើនដូច្នោះបានដូចម្ដេច វាទៈនោះ មិនមែនគោចររបស់ទូលបង្គំៗ ដឹងសិប្បៈនៃគហបតីពិត សេចក្ដីនេះ ប្រាកដដល់សេនកៈជាដើម មនុស្សទាំងនោះជាបណ្ឌិត ថ្ងៃនេះ ព្រះអង្គត្រូវកងទ័ព ១៨ អក្ខោភិនីចោមរោម មនុស្សទាំងឡាយ មានសេនកៈជាដើម ចូរជាទីពឹងរបស់ព្រះអង្គៗ ក៏ត្រាស់ឲ្យអូសកទូលបង្គំចេញទៅ ដូច្នេះ ឥឡូវនេះ ទ្រង់ត្រាស់សួរទូលបង្គំធ្វើអ្វី ព្រះបាទវិទេហរាជបានស្ដាប់ដូច្នោះ ទ្រង់ព្រះតម្រិះថា មហោសថបណ្ឌិតពោលទោសដែលអញធ្វើប៉ុណ្ណោះ ព្រោះគេដឹងភ័យក្នុងអនាគតនេះមកពីមុននោះឯង ព្រោះហេតុនោះ ទើបគេពោលសង្កត់សង្កិនអញពន់ពេក តែគេក៏មិនបញ្ឈប់ការងារអស់កាលមានប្រមាណប៉ុណ្ណោះឡើយ មហោសថនេះ នឹងធ្វើសួស្ដីដល់អញពិត លំដាប់នោះ ព្រះបាទវិទេហរាជ កាលកាន់មហោសថជាទីពឹង ទើបត្រាស់ ២ គាថាថា

ម្នាលមហោសធ បណ្ឌិតទាំងឡាយ រមែងមិនចាក់ដោតដោយទោសដែលកន្លងទៅហើយទេ អ្នកចាក់ដោតយើង ដូចគេយកជន្ទួញចាក់សេះ ដែលចងទុកហើយធ្វើអ្វី ។ ប្រសិនបើអ្នកឃើញសេចក្ដីរួចរបស់យើង ឬឃើញសេចក្ដីក្សេមរបស់យើង អ្នកចូរពន្យល់យើងដោយសោត្ថិភាពនោះចុះ អ្នកចាំបាច់ចាក់ដោតយើងដោយទោស ដែលកន្លងទៅហើយធ្វើអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆាទយិស្សន្តិ** សេចក្ដីថា បណ្ឌិតទាំងឡាយ រមែងមិនកាន់យកទោសដែលកន្លងទៅហើយ មកចាក់ដោតគ្នាដោយលំពែង គឺមាត់ ។ បទថា **អស្សាវ សមុត្ថិតំ** សេចក្ដីថា អ្នកចាក់ដោតយើងដូចសេះដែលគេចងទុកយ៉ាងល្អ ព្រោះត្រូវសេនាសត្រូវចោមរោមធ្វើអ្វី ។ បទថា **តោសេវ មំ** សេចក្ដីថា ចូរអ្នកទូន្មានយើង គឺចូរឲ្យយើងសប្បាយចិត្ត ដោយធ្វើសួស្ដីនោះថា ទ្រង់នឹងផុតភ័យដោយអាការយ៉ាងនេះ ទ្រង់នឹងផុតភ័យដោយអាការយ៉ាងនេះ ដ្បិតថា វៀរអ្នកហើយ អ្នកដទៃជាទីពឹងអាស្រ័យរបស់យើងមិនមាន ។

លំដាប់នោះ មហាសត្វត្រិះរិះថា ព្រះរាជាអង្គនេះល្ងង់ខ្លៅពន់ពេក មិនស្គាល់បុរសវិសេស អញនឹងឲ្យទ្រង់លំបាកបន្តិច ហើយសឹមធ្វើជាទីពឹងរបស់ព្រះអង្គក្នុងកាលជាក្រោយ ត្រិះរិះដូច្នេះហើយ ក្រាបទូលថា

អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើដែលគេកែបានដោយក្រ សម្រួលវិញ បានដោយក្រ ខ្ញុំព្រះអង្គមិនអាចនឹងដោះព្រះអង្គបានទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបចុះ ។ ដំរីទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន ដំរីបែបនោះរបស់ព្រះរាជាណា សូមឲ្យដំរីទាំងនោះនាំព្រះរាជានោះទៅចុះ ។ សេះទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន សេះបែបនោះ របស់ព្រះរាជាណា សូមឲ្យសេះទាំងនោះ នាំព្រះរាជានោះទៅចុះ ។ បក្សីទាំងឡាយមានឫទ្ធិ

មានយស អាចទៅតាមអាកាសបាន បក្សីបែបនោះ របស់ព្រះរាជាណា សូមឲ្យបក្សីទាំងនោះ នាំព្រះរាជានោះទៅចុះ ។ យក្ខទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន យក្ខបែបនោះ របស់ព្រះរាជាណា សូមឲ្យយក្ខទាំងនោះ នាំព្រះរាជានោះទៅចុះ ។ អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ បពិត្រក្សត្រិយ៍ ខ្ញុំព្រះអង្គមិនអាចដោះព្រះអង្គទៅតាមអាកាសបានទេដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កម្មំ** សេចក្តីថា បពិត្រមហារាជ កម្មឈ្មោះថា ដោះទ្រង់អំពីភ័យនេះ ដែលពួកមនុស្សជាមនុស្សក្នុងអតីតគប្បីធ្វើនេះ ឈ្មោះថា ប្រព្រឹត្តទៅកន្លងហើយ ។ បទថា **ទុក្ករំ ទុរភិសម្ភវំ** សេចក្តីថា ដែលបុគ្គលណាម្នាក់មិនអាចកែខៃ មិនអាចច្បាំង ។ បទថា **ន តំ សក្កោមិ** សេចក្តីថា ទូលបង្គំមិនអាចដោះទ្រង់ចាកភ័យនេះ ។ បទថា **ត្វំ បជានស្សុ ខត្តិយ** សេចក្តីថា បពិត្រមហារាជ សូមទ្រង់ជ្រាបវត្ថុដែលគួរធ្វើក្នុងរឿងនេះឯងចុះ ។ បទថា **វេហាយសា** បានដល់ ដំរីដែលអាចទៅតាមអាកាស ។ បទថា **យស្ស** បានដល់ ព្រះរាជាអង្គណា ។ បទថា **តជាតិជា** សេចក្តីថា ដំរីទាំងឡាយដែលកើតក្នុងត្រកូលឆទ្ទន្ត ឬត្រកូលឧបោសថមាន ដំរីទាំងនោះគប្បីនាំព្រះរាជានោះទៅ ។ បទថា **អស្សា** សេចក្តីថា សេះទាំងឡាយដែលកើតក្នុងត្រកូលសេះវលាហក ។ បទថា **បក្ខី** ពោលសំដៅយកគ្រុឌ ។ បទ

ថា **យក្ខា** បានដល់ ពួកយក្ខ មានសាតាគិរយក្ខជាដើម ។ បទថា **អន្ត-លិក្ខេន** សេចក្តីថា ទូលបង្គំមិនអាចដោះព្រះអង្គតាមផ្លូវអាកាស គឺមិនអាចនាំព្រះអង្គទៅដល់ក្រុងមិថិលា តាមអាកាសបានឡើយ ។

ព្រះបាទវិទេហរាជ ទ្រង់ស្តាប់ពាក្យរបស់មហោសថដូច្នោះ ក៏នៅស្ងៀមប្រថាប់គង់ លំដាប់នោះ អាចារ្យសេនកៈគិតថា ឥឡូវនេះ វៀរមហោសថបណ្ឌិតចេញ ទីពឹងដទៃរបស់ព្រះរាជា និងរបស់ពួកយើងមិនមាន ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់មហោសថ ទ្រង់ភ័យខ្លាចចំពោះមរណៈ ទ្រង់មិនអាចត្រាស់អ្វីបាន អញនឹងអង្វរមហោសថបណ្ឌិតឲ្យជួយ កាលសេនកៈអង្វរបានពោល ២ គាថាថា

បុរសជាអ្នកមិនឃើញត្រើយ ក្នុងមហាសមុទ្រ បុរសនោះ បានទីពំនាក់ក្នុងប្រទេសណា គេក៏បានសេចក្តីសុខ ក្នុងប្រទេសនោះ ( យ៉ាងណាមិញ ) ។ បពិត្រមហោសធ អ្នកជាទីពឹងរបស់ពួកយើង និងព្រះរាជាក៏យ៉ាងនោះដែរ ព្រោះអ្នកជាបុគ្គលប្រសើរជាងពួកយើង និងពួកមន្ត្រី សូមអ្នកដោះពួកយើងអំពីទុក្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតីរទស្សី** សេចក្តីថា បុគ្គលដែលលិចទូកកណ្តាលសមុទ្រ កាលមិនឃើញត្រើយ ។ បទថា **យត្ថ** សេចក្តីថា កាលត្រូវកម្លាំងរលកបន្សាត់ទៅ បានទីពឹងក្នុងប្រទេសណា ។ បទថា **បមោចយ** សេចក្តីថា អាចារ្យសេនកៈអង្វរថា កាលមុន កាលកងទ័ពព័ទ្ធក្រុងមិថិលា អ្នកបានដោះពួកយើងឲ្យផុតភ័យ សូម្បីឥឡូវនេះ លោកនេះឯង នឹងជួយដោះ

ពួកយើងឲ្យផុតចាកទុក្ខ ។

លំដាប់នោះ ព្រះមហាសត្វកាលនឹងសង្កត់សង្កិនអាចារ្យសេនកៈ ទើបពោលគាថានេះថា

អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ ខ្ញុំមិនអាចនឹងដោះអ្នកបានទេ នែសេនកៈ អ្នកចូរដឹងចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ត្វំ បជានស្សុ សេនក** សេចក្ដីថា លោកអាចារ្យសេនកៈ ខ្ញុំមិនអាច ចូរលោកនាំព្រះរាជានេះ មកកាន់ក្រុងមិថិលាតាមអាកាសចុះ ។

ព្រះបាទវិទេហរាជ កាលទ្រង់មិនឃើញគ្រឿងកាន់យក ដែលទ្រង់គប្បីកាន់យក ទ្រង់តក់ស្លុតចំពោះមរណភ័យ មិនអាចត្រាស់អ្វីជាមួយមហាសត្វបាន ទ្រង់ត្រិះរិះថា ពេលខ្លះ សូម្បីសេនកៈក៏ដឹងឧបាយណាមួយ អញនឹងសួរគេមើល កាលត្រាស់សួរ ទើបពោលគាថាដូច្នេះថា

អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំទុំ ( ស្រាប់ហើយ ) ម្នាលអាចារ្យសេនកៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្ដេច ក្នុងរឿងនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កឹ កិច្ចំ** សេចក្ដីថា លោកសម្គាល់វត្ថុដែលគួរធ្វើដូចម្ដេចក្នុងកាលនេះ ពួកយើងត្រូវមហោសថលះបង់ហើយ បើអ្នកដឹងក៏ចូរប្រាប់ដល់យើង ។

អាចារ្យសេនកៈបានស្តាប់ដូច្នោះហើយ គិតថា ព្រះរាជាត្រាស់សួរឧបាយនឹងអញ ល្អ ឬមិនល្អលើកទុកមួយឡែកចុះ អញនឹងពោលឧបាយមួយនឹងព្រះអង្គ គិតដូច្នេះហើយ ទើបពោលគាថានេះថា

ពួកយើងគួរដុតភ្លើងត្រង់ទ្វារ ឬកាន់កាំបិតសម្លាប់គ្នានិងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្ត សម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទ្វារតោ** សេចក្តីថា ពួកយើងចូរបិទទ្វារបង្កាត់ភ្លើងត្រង់ទ្វារនោះ ។ បទថា **វិកន្តនំ** សេចក្តីថា ចូរចាប់សស្ត្រាប្រហារគ្នានិងគ្នា ។ បទថា **ហិស្សាម** សេចក្តីថា ពួកយើងនឹងឆាប់ស្លាប់ ប្រាសាទដែលតាក់តែងហើយនោះឯង ជាជើងថ្ករបស់ពួកយើង ។

ព្រះបាទវិទេហរាជទ្រង់ស្តាប់ដូច្នោះ ក៏ទ្រង់ទោមនស្សត្រាស់ថា អាចារ្យសេនកៈ ចូរធ្វើជើងថ្ករបែបនោះដល់កូន និងប្រពន្ធរបស់ខ្លួនចុះ ហើយត្រាស់សួរបុក្កុសៈជាដើម ជនទាំងនោះ ក៏ក្រាបទូលដោយពាក្យសម្តែងកាពល្ងង់ខ្លៅតាមសមគួរដល់ខ្លួន ព្រោះហេតុនោះ ទើបលោកពោលថា ព្រះរាជាត្រាស់សួរបុក្កុសៈថា

អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំទុំះ ( ស្រាប់ហើយ ) ម្នាលអាចារ្យបុក្កុសៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ដូច្នេះ ។

បុក្កុសៈក្រាបទូលថា

ពួកយើងគួរស៊ីថ្នាំពិសឲ្យស្លាប់ នឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ ដូច្នេះ ។

ព្រះរាជាត្រាស់សួរកាមិន្ទៈថា

អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យជំនុំះ ( ស្រាប់ហើយ ) ម្នាលអាចារ្យកាមិន្ទៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ដូច្នេះ ។

កាមិន្ទៈក្រាបទូលថា

ពួកយើងគប្បីយកខ្សែចងឲ្យស្លាប់ ឬលោតចុះទៅក្នុងអណ្តូង ( ឲ្យស្លាប់ ) កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ ដូច្នេះ ។

ព្រះរាជាត្រាស់សួរទេវិន្ទៈថា

អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យជំនុំះ ( ស្រាប់ហើយ ) ម្នាលអាចារ្យទេវិន្ទៈ ឥឡូវនេះ អញសួរ តើអ្នកសម្គាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ដូច្នេះ ។

អាចារ្យទេវិន្ទៈក្រាបទូលថា

ពួកយើង ( បិទទ្វារ ) ដុតភ្លើង ហើយកាន់កាំបិតសម្លាប់គ្នានិងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ ( បើ ) មហោសថមិនអាចនឹងដោះពួកយើងឲ្យរួចដោយងាយទេ ដូច្នេះ ។

ម្យ៉ាងទៀត បណ្តាអាចារ្យទាំង ៤ ទេវិន្ទៈគិតថា ព្រះរាជានេះទ្រង់ធ្វើអ្វី

មកត្រាស់សួរពួកយើង ក្នុងកាលភ្លើងមាន ទ្រង់មកផ្លុំអំពិលអំពែក វៀរនូវមហោសថចោលហើយ អ្នកដទៃអាចធ្វើសួស្តីដល់ពួកយើងក្នុងពេលនេះរមែងមិនមាន ទ្រង់មិនត្រាស់សួរមហោសថ មកត្រាស់សួរពួកយើងៗ ដឹងអ្វី គិតដូច្នេះហើយ កាលមិនឃើញឧបាយដទៃ ទើបពោលពាក្យដែលសេនកៈពោលហើយនោះឯង កាលនឹងសរសើរមហោសថ ទើបពោលបទទាំងពីរថា បពិត្រមហារាជ សេចក្តីបំណងក្នុងរឿងនោះដូច្នេះ ពួកយើងទាំងអស់ នឹងអង្វរមហោសថនោះឯង កាលអង្វរមហោសថៗ ក៏មិនអាចដោះពួកយើងបានដោយងាយ ខាងក្រោយ ពួកយើងនឹងធ្វើតាមពាក្យសេនកៈ ។

ព្រះបាទវិទេហរាជ បានស្តាប់ពាក្យរបស់ទេវិន្ទៈដូច្នោះ ទ្រង់រឭកដល់ទោស ដែលទ្រង់បានធ្វើដល់ព្រះពោធិសត្វក្នុងកាលមុន ក៏ទ្រង់មិនអាចត្រាស់នឹងមហោសថ ទ្រង់កន្ទក់កន្ទេញរហូតមហោសថបានឮ ដោយព្រះតម្រាស់ថា

បុគ្គលស្វែងរកខ្លឹមនៃដើមចេក រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរក ( ឧបាយជាគ្រឿងរួចចាកទុក្ខ ) ក៏មិនបានប្រស្នានោះក៏យ៉ាងនោះដែរ ។ បុគ្គលស្វែងរកខ្លឹមនៃដើមរកា រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរកក៏មិនបានប្រស្នានោះ ក៏យ៉ាងនោះដែរ ។ ការនៅនៃដំរីទាំងឡាយក្នុងទីមិនមានទឹក ឈ្មោះថា នៅក្នុងទីមិនមែនប្រទេស ( យ៉ាងណាមិញ ) កាលបើយើងនៅក្នុងទីជិតនៃពួកមនុស្សអាក្រក់ល្ងង់ខ្លៅ មិនចេះមិនដឹង ( ឈ្មោះថានៅក្នុងទីមិនមែនជាប្រទេសក៏ដូច្នោះឯង ) ។ ហឫទ័យរបស់យើង

ញ៉ាំវរទ្ធត់ ទាំងមាត់របស់យើងក៏ស្ងោះស្ងួត យើងមិនបានសេចក្តីរលត់ ដូចឈើត្រូវភ្លើងឆេះក្នុងកណ្តាលកម្តៅថ្ងៃ ។ ចង្ក្រានជាងមាសឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើងឆេះតែខាងក្នុង មិនឆេះខាងក្រៅក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កតលិនោ** សេចក្តីថា បុរសដែលត្រូវការដោយខ្លឹម រមែងស្វែងរក ក៏មិនបានខ្លឹមអំពីដើមចេកនោះ ព្រោះដើមចេកមិនមានខ្លឹមយ៉ាងណា យើងទាំងឡាយ សូម្បីស្វែងរកឧបាយជាគ្រឿងផុតទុក្ខនេះសួរបណ្ឌិត ៥ នាក់ ក៏មិនជួបនូវប្រស្នានោះ ។ បទថា **ឆាជ្ឈគមាមសេ** សេចក្តីថា យើងទាំងឡាយមិនជួបនូវបញ្ហានោះ ដូចបុគ្គលមិនបានស្តាប់ឧបាយដែលយើងទាំងឡាយសួរ សូម្បីក្នុងគាថាទី ២ ក៏ន័យនេះឯង ។ បទថា **កុញ្ជរានំ វនូទកេ** សេចក្តីថា ការនៅរបស់ដំរីទាំងឡាយ ក្នុងទីដែលមិនមានទឹក ឈ្មោះថា នៅក្នុងទីដែលមិនមែនប្រទេស ព្រោះថា ដំរីទាំងនោះ កាលនៅក្នុងព្រៃដែលមិនមានទឹកបែបនោះ ឈ្មោះថា មិនមែនប្រទេស រមែងធ្លាក់នៅក្នុងអំណាចរបស់បច្ចាមិត្តដោយឆាប់រហ័ស យ៉ាងណា សូម្បីកាលដែលយើងទាំងឡាយ នៅក្នុងទីជិតរបស់មនុស្សអាក្រក់ ជាបុគ្គលពាលមិនមានការចេះដឹង ឈ្មោះថា នៅក្នុងទីដែលមិនមែនប្រទេស យ៉ាងនោះ បណ្តាបណ្ឌិតមានប្រមាណប៉ុណ្ណេះ សូម្បីម្នាក់ដែលជាទីពឹងអាស្រ័យរបស់យើងក្នុងកាល ឥឡូវនេះ ក៏មិនមាន ព្រះបាទវិទេហរាជ ទ្រង់រវើរវាយដោយប្រការផ្សេងៗ ដោយប្រការដូច្នេះ ។

មហោសថបានស្តាប់ដូច្នោះ គិតថា ព្រះរាជាអង្គនេះទ្រង់លំបាកពន់ពេក បើអញមិនលួងលោមទ្រង់ឲ្យសប្បាយព្រះហឫទ័យ ទ្រង់នឹងមានហឫទ័យបែកអស់ព្រះជន្ម ទើបក្រាបទូលលួងលោម ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

វេលានោះ មហោសធជាអ្នកប្រាជ្ញ មានប្រាជ្ញាឃើញប្រយោជន៍ ជាប្រក្រតីនោះ បានឃើញព្រះបាទវិទេហៈ ទ្រង់មានសេចក្តីទុក្ខ ទើបក្រាបបង្គំទូលថា បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គដូចគេដោះព្រះចន្ទ ដែលរាហូចាប់ហើយ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះអាទិត្យដែលរាហូចាប់ហើយ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះដំរីផុងក្នុងភក់ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះពស់ដែលជាប់នៅក្នុងកំប្រោង ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ

បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះបក្សីដែលជាប់នៅក្នុងទ្រុង ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះត្រីទាំងឡាយដែលជាប់នៅក្នុងសំណាញ់ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គចេញ ព្រមទាំងយាន រេហ៍ពល និងពាហនៈ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដេញព្រះបាទបញ្ចាលឲ្យរត់ទៅ ដូចជាគេដេញក្អែក និងខ្វែង ដោយដុំដី ។ បុគ្គលណាមិនជួយព្រះអង្គ ដែលមានសេចក្តីចង្អៀត ( ព្រោះមរណៈ ) ឲ្យរួចចាកទុក្ខបានទេ ប្រាជ្ញា ( របស់បុគ្គលនោះ ) មានប្រយោជន៍អ្វី ឬអាមាត្យបែបនោះ ( មានប្រយោជន៍អ្វី ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធំ** សេចក្តីថា មហោសថកាលលួងលោមព្រះបាទវិទេហរាជឲ្យសប្បាយព្រះហឫទ័យ ដូចធ្វើភ្លៀងឲ្យធ្លាក់ក្នុងព្រៃភ្លើងឆេះ បានក្រាបទូលពាក្យនេះថា **មា ត្វំ ភាយិ មហារាជ** ជាដើម ។ បទថា **សន្ធំ** ក្នុងគាថានោះ ប្រែថា ជាប់ ។ បទថា **បេឡពទ្ធំ** បានដល់ ពស់ដែលនៅក្នុងកំប្រោង ។ បទថា **បញ្ចាលំ** បានដល់ គំនរកងទ័ពបញ្ចាល ដែលជា

*កងទ័ពរបស់ព្រះបាទបញ្ចាលរាជ សូម្បីធំយ៉ាងនេះ ។ បទថា* **ពាហាយិស្សាមិ** *បានដល់ នឹងឲ្យគេចទៅ ។ បទថា* **អាធូ** *ជានិបាត ចុះក្នុងអត្ថថា ឈ្មោះថា បញ្ញារបស់អមាត្យនឹងមានប្រយោជន៍អ្វី ។ បទថា* **អមច្ចោ វាបិ តាទិសោ** *សេចក្តីថា ឬអមាត្យសម្បូរដោយបញ្ញាបែបនោះ ព្រោះជាអ្នកប្រកបដោយបញ្ញា ដែលដោះព្រះអង្គ ដែលត្រូវសេចក្តីស្លាប់បៀតបៀនយ៉ាងនេះ ឲ្យផុតទុក្ខមិនបាន នឹងមានប្រយោជន៍អ្វី បពិត្រមហារាជ ព្រះអង្គសម្គាល់ថា មហោសថនេះមកមុន មកដើម្បីប្រយោជន៍អ្វី បពិត្រមហារាជ សូមទ្រង់កុំព្រួយឡើយ ទូលបង្គំនឹងដោះព្រះអង្គឲ្យផុតចាកទុក្ខនេះ ។ មហោសថបណ្ឌិតលួងលោមព្រះបាទវិទេហរាជឲ្យសប្បាយព្រះហឫទ័យ ដោយប្រការដូច្នេះ ។*

*ចំណែកព្រះបាទវិទេហរាជ បានស្តាប់ពាក្យរបស់មហោសថ ក៏ត្រឡប់បាននូវភាពកក់ក្តៅក្នុងព្រះហឫទ័យថា ឥឡូវនេះ អញបានជីវិតហើយ ។ កាលមហោសថបន្លឺសីហនាទ ជនទាំងពួងនោះ ក៏នាំគ្នាត្រេកអរ ។ លំដាប់នោះ សេនកៈសួរព្រះពោធិសត្វថា នែបណ្ឌិត អ្នកកាលនាំពួកយើងទាំងអស់ទៅនឹងទៅបានដោយឧបាយដូចម្តេច មហោសថប្រាប់ថា ខ្ញុំនឹងនាំទៅដោយផ្លូវក្រោមដីដែលបានរៀបចំ ចូរពួកលោកត្រៀមដំណើរចុះ កាលប្រាប់យោធាឲ្យបើកទ្វារឧម្មង្គ ទើបពោលថា*

> *នែមាណពទាំងឡាយ អ្នកទាំងឡាយចូរមក ចូរក្រោកឡើង*
> *អ្នកទាំងឡាយចូរបើកមាត់នៃគន្លឹះយន្ត ព្រះបាទវិទេហៈ មួយអន្លើ*
> *ដោយពួកអាមាត្យ និងស្តេចទៅតាមឧម្មង្គ ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **មាណវា** ជាឈ្មោះរបស់មនុស្សកំលោះ ។ បទថា **មុខំ សោធេថ** សេចក្ដីថា ចូរបើកនូវទ្វារឧម្មង្គ ។ បទថា **សន្ធិនោ** សេចក្ដីថា ចូរបើកទ្វារបន្ទប់ដែលជាប់បន្ទគ្នានៃគ្រឿងយន្ត គឺចូរបើកទ្វារបន្ទប់ ១០១ បន្ទប់ ចូរបើកទ្វារគោម និងប្រទីបទាំង ១០១ ។

អ្នកបម្រើរបស់មហោសថទាំងនោះ ក្រោកទៅបើកទ្វារឧម្មង្គៗ ទាំងមូលក៏មានពន្លឺទូទៅ ពន្លឺហាក់បីដូចទេវសភាពដែលបានប្រដាប់ហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួត្យសានូវព្រះគាថាដូច្នេះថា

ពួកជនអ្នកធ្វើការបម្រើរបស់មហោសធបណ្ឌិត ស្ដាប់ពាក្យរបស់លោកហើយ ទើបបើកទ្វារនៃឧម្មង្គ និងគន្លឹះទ្វារ ដែលប្រកបដោយគ្រឿងយន្ត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុសារិនោ** បានដល់ ដែលធ្វើនូវសេចក្ដីខ្វល់ខ្វាយជួយស្រោចស្រង់ ។ បទថា **យន្តយុត្តេ ច អគ្គឡេ** សេចក្ដីថា ទ្វារដែលជល់ព្រមដោយគន្លឹះ ។

ជនទាំងនោះ បើកទ្វារឧម្មង្គ ហើយប្រាប់ឲ្យមហោសថជ្រាប មហោសធក៏ក្រាបទូលព្រះរាជាថា ពេលវេលាបានហើយ សូមទ្រង់យាងចុះអំពីប្រាសាទ ព្រះរាជាក៏យាងចុះ សេនកៈដោះគ្រឿងប្រដាប់ក្បាល ហើយយកសំពត់ជូតក្បាលយ៉ាងធំ លំដាប់នោះ មហោសថឃើញកិរិយានៃសេនកៈ ក៏សួរថា

*លោកអាចារ្យធ្វើអ្វី សេនកៈឆ្លើយថា នែបណ្ឌិត ធម្មតាមនុស្សទាំងឡាយទៅដោយផ្លូវក្រោមដី ត្រូវដោះសំពត់ជួតក្បាលឲ្យធំ មហោសថក៏ប្រាប់ថា នែអាចារ្យសេនកៈ អ្នកកុំសម្គាល់ថា អ្នកចូលឧម្មង្គត្រូវដើរទីងក្បាលជង្គង់ បើអ្នកប្រាថ្នាទៅដោយដំរី ក៏ចូរឡើងដំរីទៅ បើប្រាថ្នាដោយសេះ ក៏ចូរទៅដោយសេះ ព្រោះឧម្មង្គខ្ពស់ មានទ្វារ ១៨ ហត្ថ ចូរលោកប្រដាប់តាក់តែងខ្លួនតាមគាប់ចិត្តទៅមុនព្រះរាជា ចំណែកព្រះពោធិសត្វ ចាត់ឲ្យសេនកៈទៅមុន ឲ្យព្រះរាជាទៅត្រង់កណ្តាល ខ្លួនឯងទៅខាងក្រោយ ហេតុអ្វី ទើបមហោសថរៀបចំយ៉ាងនេះ ព្រោះព្រះបាទវិទេហរាជ មិនទតឧម្មង្គដែលតាក់តែងហើយរឿយៗ យាងទៅ បបរ បាយ របស់ទំពាជាដើមប្រមាណមិនបាន មានសម្រាប់មហាជនក្នុងឧម្មង្គ ជនទាំងនោះ ទំពាស៊ី ផឹកបណ្តើរសរសើរឧម្មង្គហើយទៅ ចំណែកព្រះមហាសត្វ ទូលព្រះបាទវិទេហរាជថា សូមទ្រង់យាងទៅ សូមទ្រង់យាងទៅ ហើយទៅតាមក្រោយ ។ ព្រះបាទវិទេហរាជទតឧម្មង្គដែលដូចជាទេវសភា ដែលតាក់តែងបណ្តើរ ហើយយាងទៅបណ្តើរ ។*

**តមគ្គំ បក្កាសេន្តោ សត្ថា អាហ** *វីអាថិធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាន្ទូវព្រះគាថាដូច្នេះថា*

*អាចារ្យសេនកៈដើរមុន មហោសថដើរក្រោយ ព្រះបាទវិទេហៈ*
*មានអាមាត្យហែហម ស្តេចយាងត្រង់កណ្តាល ដូច្នេះ ។*

មាណពកំលោះ អ្នកបម្រើរបស់មហោសថទាំងនោះ ដឹងថា ព្រះបាទវិទេហរាជយាងមក ទើបនាំនាងសលាកទេវី ព្រះរាជមាតាព្រះបាទចូឡនី ព្រះនាងនន្ទាទេវីមហេសីព្រះបាទចូឡនី និងបញ្ចាលចន្ទរាជកុមារ បញ្ចាល-ចន្ទីរាជកុមារី ដែលជាបុត្រាបុត្រីរបស់ព្រះបាទចូឡនី ចេញអំពីឧមង្គ ទៅប្រថាប់នៅត្រង់ព្រះពន្លាធំ ចំណែកព្រះបាទវិទេហរាជ យាងចេញអំពីឧមង្គជាមួយមហោសថ ក្សត្រទាំង ៤ គឺព្រះនាងសលាកទេវី ព្រះនាងនន្ទាទេវី បញ្ចាលចន្ទកុមារ បញ្ចាលចន្ទីកុមារី បានទតឃើញព្រះបាទវិទេហរាជ និងមហោសថ ក៏ជ្រាបថា ពួកយើងធ្លាក់នៅក្នុងកណ្ដាប់ដៃអ្នកដទៃ ដោយឥតសង្ស័យ ពួកមនុស្សរបស់មហោសថចាប់ពួកយើងមក ក៏ខ្សឹកខ្សួលចំពោះមរណភ័យ តក់ស្លុត ស្រែកខ្ញៀវខ្ញារ ។ បានឮថា ព្រះបាទចូឡនីយាងទៅរក្សាក្នុងទីមួយគាវុត ក្បែរស្ទឹងគង្គា ព្រោះទ្រង់ខ្លាចព្រះបាទវិទេហរាជគេចព្រះបាទចូឡនីកាលរាត្រីស្ងប់ស្ងាត់ ទ្រង់បានឮសំឡេងយំរបស់ស្ដេចទាំង ៤ ជាបុគ្គលជាទីស្រឡាញ់ ត្រាស់ថា សំឡេងនុ៎ះជាសំឡេងនាងនន្ទាទេវី តែក៏មិនត្រាស់អ្វីឡើយ ដោយទ្រង់ខ្លាចក្រែងពាក្យចំអកថា ទ្រង់ទតឃើញព្រះនាងនន្ទាទេវីក្នុងទីណា ។ ព្រះមហាសត្វយាងព្រះនាងបញ្ចាលចន្ទីរាជកុមារី ប្រថាប់លើគំនររតនៈ ហើយអភិសេកក្នុងទីនោះ ក្រាបទូលដល់ព្រះបាទវិទេហរាជថា ទ្រង់យាងមកព្រោះហេតុការណ៍នេះ ព្រះរាជកុមារី ចូរជាមហេសីរបស់ព្រះអង្គ ទូក ៣០០ បានត្រៀមជាស្រេច ព្រះបាទវិទេហរាជយាងចុះអំពីព្រះពន្លា ឡើងកាន់ទូកដែលតាក់តែងហើយ សូម្បីក្សត្រទាំង ៤ ក៏ឡើងកាន់ទូកដូចគ្នា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថិធម៌ឯណាពុំទាន់ប្រាកដ បទ

ព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្យសាទូវព្រះគាថាដូច្នេះថា

ព្រះបាទវិទេហៈ ស្តេចទ្រង់ចេញអំពីឧម្មង្គ ហើយឡើងគង់លើព្រះទីន័ងនាវា មហោសថដឹងថា ព្រះរាជាឡើងគង់ហើយ ក៏ប្រៀនប្រដៅថា បពិត្រព្រះសម្មតិទេព ព្រះបាទចូឡនីព្រហ្មទត្តនេះ ជាព្រះបិតាក្មេករបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងជនព្រះនាងនន្ទាទេវីនេះ ជាព្រះមាតាក្មេករបស់ព្រះអង្គ ការប្រតិបត្តិព្រះវររាជមាតា ( របស់ព្រះអង្គ ) យ៉ាងណា ការប្រតិបត្តិព្រះមាតាក្មេក ចូរមានដល់ព្រះអង្គ ក៏យ៉ាងនោះដែរ ។ ព្រះរាជបុត្របង្កើតរួមឧទរ មានព្រះមាតាជាមួយគ្នា យ៉ាងណា បពិត្រព្រះអង្គប្រសើរលើរថ បញ្ចាលចន្ទរាជកុមារ ព្រះអង្គគប្បីស្រឡាញ់យ៉ាងនោះដែរ ។ បពិត្រព្រះអង្គប្រសើរលើរថ ព្រះនាងបញ្ចាល-ចន្ទីទេវីនេះ ជាព្រះរាជបុត្រី ( របស់ព្រះបាទចូឡនីព្រហ្មទត្ត ) ដែលព្រះអង្គទ្រង់ប្រាថ្នា សូមព្រះអង្គធ្វើសេចក្តីប្រាថ្នារបស់ព្រះអង្គចំពោះព្រះនាងនោះ ព្រះនាងជាកិរិយារបស់ព្រះអង្គហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុសាសិ** សេចក្តីថា បានឮថា មហោសថនោះ មានគំនិតយ៉ាងនេះថា ក្នុងកាលខ្លះ ព្រះបាទវិទេហរាជអាចខឹងក្រោធហើយសម្លាប់ព្រះជននីរបស់ព្រះបាទចូឡនីចោល គប្បីសម្រេចសង្វាសជាមួយព្រះនាងនន្ទាទេវីដែលមានរូបល្អ គប្បីសម្លាប់ព្រះរាជកុមារក៏បាន អញនឹងកាន់

យកប្តេជ្ញារបស់ព្រះបាទវិទេហរាជ ព្រោះដូច្នោះ ទើបពោលថ្វាយអនុសាសន៍ ដោយពាក្យថា **អយំ តេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អយំ តេ សស្សុរោ** សេចក្តីថា ព្រះបាទបញ្ចាលចន្ទកុមារនេះ ជាព្រះឱរសរបស់ព្រះបាទចូឡនី ដែលជាព្រះសស្សុរះរបស់ព្រះអង្គ ជាព្រះអង្គកនិដ្ឋភាតារបស់ព្រះនាងបញ្ចាលចន្ទី ឥឡូវនេះ ព្រះបាទចូឡនីជាបិតាក្មេករបស់ទ្រង់ ។ បទថា **អយំ សស្សុ** សេចក្តីថា ព្រះមាតារបស់ព្រះនាងបញ្ចាលចន្ទីនេះ ព្រះនាមនន្ទាទេវី ជាមាតាក្មេករបស់ព្រះអង្គ ។ បទថា **យថា មាតុ** សេចក្តីថា កូនរមែងធ្វើវត្តបដិបត្តិដល់មាតា យ៉ាងណា សូមព្រះអង្គមានការធ្វើវត្តបដិបត្តិដល់ព្រះនាងនន្ទាទេវី យ៉ាងនោះ ញុំាងមាតុសញ្ញា ដែលមានកម្លាំងជាងឲ្យប្រាកដ ទ្រង់កុំសម្លឹងមើលព្រះនាងនន្ទាទេវីដោយលោភចិត្ត មិនថា ក្នុងកាលណាឡើយ ។ បទថា **ឯិយកោ** សេចក្តីថា ជាអ្នកកើតខាងក្នុង គឺកើតដោយមាតាបិតាតែមួយ ។ បទថា **ឧយិតព្វោ** បានដល់ គប្បីប្រព្រឹត្តជាទីស្រឡាញ់ ។ បទថា **ភរិយា** សេចក្តីថា ព្រះនាងបញ្ចាលចន្ទីនេះ នឹងជាមហេសីរបស់ព្រះអង្គ ទ្រង់កុំមើលងាយព្រះនាង មហោសថបណ្ឌិតបានកាន់យកប្តេជ្ញារបស់ព្រះបាទវិទេហរាជយ៉ាងនេះ ។

ព្រះបាទវិទេហរាជទ្រង់ទទួលពាក្យថា សាធុ ឯមហោសថមិនពោលអ្វីឡើយ ប្រារព្ធដល់ព្រះរាជជននីរបស់ព្រះបាទចូឡនី ព្រោះហេតុអ្វី ទើបមិនពោលប្រារព្ធដល់ ព្រោះព្រះរាជជននីនោះ ទ្រង់ព្រះជរាហើយ ព្រះពោធិសត្វឈរពោលរឿងទាំងពួងត្រង់មាត់ស្ទឹងគង្គា ។ លំដាប់នោះ ព្រះបាទវិទេហរាជ

ប្រាថ្នានឹងយានទៅដោយការផុតចាកទុក្ខធំ ទើបត្រាស់នឹងមហោសថថា នែបា អ្នកឈរត្រង់មាត់ស្ទឹងគង្គាធ្វើអ្វី ហើយត្រាស់គាថាដូច្នេះថា

ម្នាលមហោសធ អ្នកចូរប្រញាប់ប្រញាល់ឡើងជិះទូកមក នៅឈរលើច្រាំងធ្វើអ្វី យើងទាំងឡាយ រួចចាកទុក្ខដោយលំបាក យើងនឹងទៅឥឡូវនេះ ដូច្នេះ ។

មហាសត្វបានស្តាប់ព្រះតម្រាស់ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ការទៅជាមួយព្រះអង្គ មិនគួរដល់ទូលបង្គំឡើយ ហើយទូលថា

បពិត្រមហារាជ ខ្ញុំព្រះអង្គដែលជានាយកនៃសេនា លះបង់ចោលនូវអង្គនៃសេនា ហើយដោះយកតែខ្លួន នេះមិនមែនជាទំនៀមទេ ។ បពិត្រព្រះសម្មតិទេពប្រសើរលើរថ ខ្ញុំព្រះអង្គនឹងដឹកនាំនូវអង្គនៃសេនា ដែលព្រះអង្គបោះបង់ចោល ក្នុងរាជ-និវេសន៍ និងរបស់ដែលព្រះបាទព្រហ្មទត្តថ្វាយហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មោ** បានដល់ សភាវៈ ។ បទថា **និវេ-សនម្ហិ** លោកពោលសំដៅយកព្រះនគរ ។ បទថា **បរិមោចយេ** បានដល់ គប្បីដោះ ។ បទថា **បរិហាបិតំ** បានដល់ ទុកចោល ។

មហោសថពោលគាថាដូច្នេះហើយ ក្រាបទូលថា កាលពួកជនមកអំពីចម្ងាយ ពួកខ្លះទំពាស៊ី ពួកខ្លះផឹក ពួកខ្លះហត់នឿយ ក៏ដេកលក់ មិនដឹងការដែលពួកយើងមកអំពីឧម្មង្គហើយ ពួកខ្លះឈឺថ្កាត់ ធ្វើការងារមកជាមួយទូលបង្គំអស់ ៤ ខែ ជាអ្នកមានឧបការៈច្រើនដល់ទូលបង្គំ បណ្តាជនទាំងនោះមានច្រើន ទូលបង្គំមិនអាចបោះបង់ សូម្បីតែម្នាក់ហើយទៅ បពិត្រព្រះអង្គ

ទូលបង្គំនឹងត្រឡប់ នាំមកនូវសេនាទាំងពួងរបស់ព្រះអង្គ និងទ្រព្យដែលព្រះបាទចូឡនីប្រទានមិនឲ្យសេសសល់ សូមទ្រង់កុំបង្អែបង្អង់ ប្រញាប់យាងទៅចុះ សូមទ្រង់លះបង់ដំរី សេះ ពាហនៈជាដើម ដែលហត់នឿយ ដែលទូលបង្គំបណ្ដាក់តាមផ្លូវជារយៈ ហើយយាងឡើងយានមាសដែលអាចទៅកាន់ក្រុងមិថិលាដោយឆាប់រួសរាន់ ។

លំដាប់នោះ ព្រះរាជាបានត្រាស់គាថាដូច្នេះថា

ម្នាលបណ្ឌិត អ្នកឯងជាអ្នកមានសេនាតិច នឹងសង្កត់សង្កិន ទប់ទល់ព្រះបាទចូឡនីព្រហ្មទត្ត ដែលមានសេនាច្រើនដូចម្ដេចបាន អ្នកឯងជាអ្នកមានកម្លាំងខ្សោយ មុខជាលំបាកដោយព្រះបាទចូឡនីព្រហ្មទត្ត ដែលមានកម្លាំង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និគ្គយ្ហ** បានដល់ គ្របសង្កត់ ។ បទថា **វិហញ្ញិស្សសិ** បានដល់ នឹងលំបាក គឺក្ដៅក្រហាយ ។

លំដាប់នោះ ព្រះពោធិសត្វពោលគាថាដូច្នេះថា

បុគ្គលមានប្រាជ្ញា សូម្បីមានសេនាតិច រមែងឈ្នះបុគ្គលមិនមានប្រាជ្ញា ដែលមានសេនាច្រើន ព្រះរាជាតែមួយព្រះអង្គ ( ជាអ្នកឈ្លាសក្នុងឧបាយ ) រមែងឈ្នះព្រះរាជាទាំងឡាយ ( ជាអ្នកល្ងង់ក្នុងឧបាយ ) ដូចព្រះអាទិត្យ ដែលរះឡើង ( រមែងឈ្នះ ) ងងឹតដូច្នោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មន្តី** បានដល់ ប្រកបដោយការគិត គឺមាន

បញ្ញាឈ្លាសក្នុងឧបាយ ។ បទថា **អមន្តិតំ** បានដល់ មិនឈ្លាសក្នុងឧបាយ ។ បទថា **និធាតិ** សេចក្តីថា អ្នកមានបញ្ញា រមែងឈ្នះអ្នកមានបញ្ញាតិច ។ បទថា **រាជា រាជានោ** សេចក្តីថា ព្រះរាជាបែបនេះ សូម្បីមួយព្រះអង្គ ក៏រមែងឈ្នះព្រះរាជាទាំងឡាយ ដែលមានបញ្ញាថោកថយសូម្បីដោយច្រើន សួរថា ដូចអ្វី ឆ្លើយថា ដូចព្រះអាទិត្យរះឡើងកម្ចាត់នូវងងឹត សេចក្តីថា ព្រះអាទិត្យបញ្ចេញពន្លឺកម្ចាត់នូវងងឹត យ៉ាងណា បុគ្គលមានបញ្ញា រមែងឈ្នះ និងរមែងរុងរឿងដូចព្រះអាទិត្យ ក៏យ៉ាងនោះ ។

កាលទូលដូច្នេះហើយ ព្រះមហាសត្វថ្វាយបង្គំព្រះបាទវិទេហរាជក្រាបទូលថា សូមទ្រង់យាងទៅចុះ ហើយបញ្ជូនព្រះរាជាទៅ ។ ព្រះបាទវិទេហរាជទ្រង់រឭកដល់គុណរបស់ព្រះពោធិសត្វថា អញផុតចាកកណ្តាប់ដៃសត្រូវហើយហ្ន៎ បំណងរបស់អញក៏ដល់ទីបំផុតហើយ ព្រោះបាននាងបញ្ចាលចន្ទីរាជធីតារបស់ព្រះបាទព្រហ្មទត្តហើយ ក៏កើតបីតិបាមោជ្ជ ក៏ត្រាស់សរសើរគុណរបស់មហោសថដល់សេនកៈថា

នែអាចារ្យសេនកៈ ការនៅរួមជាមួយនឹងពួកបណ្ឌិត នាំមកនូវសេចក្តីសុខស្រួលណាស់ហ្ន៎ ព្រោះថា មហោសធបានដោះពួកយើង ដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រីដែលជាប់នៅក្នុងសំណាញ់ ដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **សុសុខំ វត** សេចក្ដីថា ការនៅរួមដោយបណ្ឌិតទាំងឡាយ នេះជាសុខក្រៃលែង ជាសុខក្រៃលែងជាងហ្ន៎ ។ បទថា **វត** ត្រឹមតែជានិបាត ចុះក្នុងអត្ថថា ហេតុ មានពាក្យអធិប្បាយថា នែអាចារ្យសេនកៈ ព្រោះមហោសថដោះពួកយើង ដែលធ្លាក់ក្នុងកណ្ដាប់ដៃសត្រូវដូច្នោះ យើងគប្បីពោលថា ការនៅរួមដោយពួកបណ្ឌិតយ៉ាងនេះ ជាសុខហ្ន៎ ។

អាចារ្យសេនកៈ បានស្ដាប់ព្រះរាជតម្រាស់ដូច្នោះ កាលនឹងសរសើរគុណរបស់ព្រះមហោសថ ទើបពោលថា

បពិត្រមហារាជ ពិតមែនហើយ បណ្ឌិតទាំងឡាយ នាំមក
សេចក្ដីសុខយ៉ាងនោះឯង មហោសធបានដោះពួកយើង ដែលនៅ
ក្នុងកណ្ដាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់
នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រី ដែលជាប់នៅក្នុងសំណាញ់
ដូច្នោះ ។

លំដាប់នោះ ព្រះបាទវិទេហរាជយាងឡើងអំពីស្ទឹង មកដល់ស្រុកដែលមហោសថឲ្យសាងគ្រប់ៗ មួយយោជន៍ ជនទាំងឡាយដែលមហោសថដាក់ក្នុងទីនោះៗ ក៏រៀបចំដំរី ពាហនៈ បាយ ទឹកជាដើម ថ្វាយព្រះរាជាៗ ញ៉ាំងដំរី សេះ រថ ដែលហត់នឿយហើយឲ្យត្រឡប់ ឡើងកាន់ពាហនៈក្រៅអំពីនេះ ដល់ស្រុកដទៃដោយសត្វពាហនៈទាំងនោះ កន្លងមាគ៌ាមួយរយយោជន៍ដោយឧបាយនេះ ស្អែកឡើង ក៏ចូលដល់នគរមិថិលា ។

ចំណែកព្រះពោធិសត្វ ទៅកាន់ទ្វារឧម្មង្គ ដោះដាវដែលខ្លួនសៀតចេញកាយខ្សាច់ត្រង់ទ្វារឧម្មង្គ កប់ដាវនោះក្នុងខ្សាច់នោះ កាលកប់ដាវហើយ ក៏ចូល

*ទៅក្នុងឧម្មង្គ ចេញអំពីឧម្មង្គ ទៅកាន់ទីដែលបានសាង ឡើងប្រាសាទ ងូតទឹក ក្រអូបហើយ បរិភោគភោជនមានរសប្រសើរផ្សេងៗ ហើយទៅកាន់ទីដេកដ៏ប្រសើរ កាលនឹកថា មនោរថរបស់អញដល់ទីបំផុតហើយ ក៏ដេកលក់ទៅ ។ ចំណែកព្រះបាទចូឡនី ត្រួតមើលសេនានិករហើយ យាងដល់នគរនោះដោយកាលកន្លងទៅនៃរាត្រីនោះ ។*

**តមត្ថំ បកាសេន្តោ សត្ថា អាហ** *វីអាថិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា*

*ព្រះបាទចូឡនីព្រហ្មទត្តមានកម្លាំងច្រើន ទ្រង់រក្សាអស់រាត្រីទាំងមូល កាលអរុណរះឡើង ក៏ស្តេចចូលទៅដល់ក្រុងឧបការៈ ។ ព្រះបាទចូឡនី គ្រប់គ្រងក្រុងបញ្ចាល មានកម្លាំងច្រើន ស្តេចឡើងគង់លើដំរីប្រសើរ ដ៏មានកម្លាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ បានត្រាច់ទៅ ( នឹងសេនារបស់ព្រះអង្គ ) ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់សៀតគ្រឿងក្រោះ ជាវិការនៃកែវមណី ព្រះហស្តចាប់សរ បានត្រាស់ទៅនឹងរេហ៍ពល អ្នកទទួលបម្រើ ( របស់ព្រះអង្គ ) ជាអ្នកមានសិល្បៈច្រើន ដែលមកជួបជុំគ្នាដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **កសិណំ** *បានដល់ អស់រាត្រីទាំងមូលមិនមានសេសសល់ ។ បទថា* **ឧគ្គន្តំ** *បានដល់ ឡើងទៅ ។ បទថា* **ឧបការំ**

សេចក្តីថា យានដល់នគរដែលបានឈ្មោះថា ឧបការៈ ព្រោះមហាសត្វធ្វើទន្ទឹមនឹងបញ្ចាលនគរ ។ បទថា **អជោច** សេចក្តីថា បានត្រាស់នឹងសេនារបស់ព្រះអង្គ ។ បទថា **បេសិយេ** បានដល់ ដែលធ្វើការទទួលបម្រើរបស់ព្រះអង្គ ។ បទថា **អជ្ឈភាសិត្ថ** សេចក្តីថា ត្រាស់ក្រៃលែងហើយ គឺបានត្រាស់មុននោះឯង ។ បទថា **បុថុគុម្ពា** សេចក្តីថា តាំងនៅក្នុងសិប្បៈជាច្រើន គឺដឹងនូវសិប្បៈជាអនេក ។

ឥឡូវនេះ កាលទ្រង់សម្តែងសេចក្តីនោះដោយសង្ខេប ទើបព្រះសាស្តាត្រាស់ថា

( ព្រះបាទចូឡនីត្រាស់ទៅ ) នឹងពលដំរី ពលសេះ ពលរថ
ពលថ្មើរជើង និងខ្មាន់ធ្នូដែលមានដៃដ៏ស្ទាត់ក្នុងសិល្បៈធ្នូ អាច
បាញ់រោមត្រូវ ដែលមកជួបជុំគ្នា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបាសនម្ហិ** សេចក្តីថា ជាអ្នកជំនាញក្នុងការបាញ់ធ្នូ ។ បទថា **កតហត្ថា** បានដល់ ដែលបាញ់ស្ទាត់ ព្រោះបាញ់មិនខុស ។

ឥឡូវនេះ ព្រះបាទចូឡនី កាលត្រាស់ឲ្យចាប់ព្រះបាទវិទេហរាជ ទើបត្រាស់ថា

អ្នកទាំងឡាយ ចូរបញ្ជូនដំរី មានភ្លុកដ៏មានកម្លាំង ជាដំរីមាន
អាយុប្រមាណ ៦០ ឆ្នាំ ចូរឲ្យដំរីទាំងឡាយញាំញីទីក្រុង ដែល
ព្រះបាទវិទេហៈសាងទុកហើយ ។ ( ពួកព្រួញ ) មានសម្បុរស

មានមុខដូចពន្លាក មានចុងដ៏មុត អាចចាក់ទម្លាយនូវធ្នឹង ដែលបាញ់ដោយកម្លាំងធ្នូ ឲ្យធ្លាក់ចុះព្រមគ្នា អំពីខាងនេះ ខាងនោះ ។ ពួកសេនាក្មេងៗ ក្លៀវក្លា ពាក់គ្រឿងក្រោះ មានអាវុធប្រកបដោយដងដ៏វិចិត្រ កាលបើពួកដំរីធំស្ទុះចូលមក ចូរអ្នកនាំគ្នា ( តស៊ូ ) ចំពោះមុខដំរីទាំងឡាយ ។ លំពែងទាំងឡាយ ដែលគេលាងជម្រះដោយប្រេង មានរស្មីភ្លឺផ្លេក រុងរឿង ដូចជាផ្កាយព្រឹក មានរស្មីច្រើន ។ កាលបើពួកយោធា ( របស់យើង ) មានគ្រឿងអាវុធជាកម្លាំង ទ្រទ្រង់សង្វារ គឺគ្រឿងក្រោះប្រាកដដូច្នេះ មិនបានរត់ក្នុងសង្គ្រាមទេ ព្រះបាទវិទេហៈ នឹងរួចពីដៃយើងអំពីណា បើក្រែងតែព្រះបាទវិទេហៈ នឹងធ្វើដូចបក្សី ( ទើបរួច ) ។ ពួកយោធារបស់យើងទាំងអស់ មានចំនួន ៣៩០០០ អាចកាត់ក្បាលសត្រូវ ហើយរើសយកក្បាលមួយៗ មក យើងបានដើរសព្វលើផែនដី មិនឃើញពួកយោធាណាស្មើឡើយ ។ ដំរីទាំងឡាយ មានភ្លុកប្រដាប់ហើយ មានកម្លាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ ពួកយោធានៅក្មេងៗ មានសម្បុរដូចមាសរមែងល្អលើកនៃដំរីទាំងឡាយ ។ យោធាទាំងឡាយ មានគ្រឿងអលង្ការ មានពណ៌លឿង ស្លៀកសំពត់មានពណ៌លឿង ដណ្តប់សំពត់មានពណ៌លឿង រមែងល្អលើកនៃដំរីទាំងឡាយ ដូចទេវបុត្តទាំងឡាយ ក្នុងនន្ទវ័ន ។ ព្រះខ័នទាំងឡាយ មានសម្បុរដូចត្រី

ស្ពាត ដែលលាងជម្រះដោយប្រេង មានរស្មីភ្លឺផ្លេក ដែលបុរសអ្នកមានព្យាយាម ធ្វើសម្រេចហើយ មានមុខស្មើ ដែលគេសំលៀងល្អហើយ ។ ព្រះខ័នទាំងឡាយ មិនមានស្នឹម រុងរឿងដូចជាព្រះអាទិត្យ ស្ថិតនៅក្នុងទីពាក់កណ្តាល ដែលគេធ្វើដោយដែកថែបដ៏មាំ ដែលពួកយោធា អ្នកមានកម្លាំងជំនាញក្នុងវិធីប្រហារមាំ កាន់យកហើយ ។ ព្រះខ័នទាំងឡាយ បរិបូណ៌ដោយដងជាវិការនៃមាស ទ្រទ្រង់ដោយស្រោម មានពណ៌ក្រហម កាលបើគេគ្រវីឡើង រមែងល្អ ដូចជាផ្លេកបន្ទោរ ភ្លឺផ្លេកក្នុងចន្លោះនៃពពក ។ ពួកខ្មាន់ធ្នូអ្នកក្លៀវក្លា ពាក់គ្រឿងក្រោះ អាចប្រព្រឹត្តទៅក្នុងអាកាសបាន អ្នកឈ្លាសក្នុងការកាន់ដាវ និងខែល ជាអ្នកហាត់ក្នុងការកាន់ធ្នូដ៏ក្រៃលែង អាចកាត់នូវកនៃដំរីឲ្យធ្លាក់ចុះបាន ។ អ្នកឯងត្រូវពួកយោធា ប្រាកដដូច្នេះព័ទ្ធហើយ អ្នកឯងមិនរួចអំពីទីនេះទេ អ្នកនឹងទៅកាន់ក្រុងមិថិលា ដោយរាជានុភាពណា យើងមិនបានឃើញរាជានុភាពនោះ របស់អ្នកទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្តិ** បានដល់ មានក្លុកសម្បូរ ។ បទថា **វជ្ជឧត្តមុខា** បានដល់ មានមុខដូចពន្លាក ។ បទថា **បន្ទុណ្ណា** បានដល់ រលោង ។ បទថា **សម្បតន្តុតីរតា** សេចក្តីថា ព្រួញទាំងនេះ ចូរធ្លាក់ចុះ គឺចូរមកព្រមគ្នាហើយព្រមគ្នាទៀត ព្រះបាទចូឡនីមានព្រះតម្រាស់ថា ចូរពួកអ្នកញុំាងភ្លៀង គឺព្រួញ ឲ្យដូចជាភ្លៀងពេលធ្លាក់ចុះ ។ បទថា **មាឈរា** បាន

ដល់ ទាហានកំលោះ ។ បទថា **ចម្មិនោ** បានដល់ កាន់ខែល ។ បទថា **ចិត្តធណ្ហយុធាវុធា** សេចក្តីថា ប្រកបដោយអាវុធដែលមានជនដ៏វិចិត្រ ។ បទថា **បក្ខន្ទិនោ** បានដល់ ជាអ្នកស្ទុះចូលទៅកាន់សង្គ្រាម ។ បទថា **មហានាគា** សេចក្តីថា សូម្បីដំរីធំទាំងឡាយ ធ្វើកោញ្ចនាទស្ទុះមក យោធាទាំងឡាយក៏អាចឈរស្ងៀម ចាប់ភ្លុកទាំងពីររបស់ដំរីនោះដកចេញបាន ។ បទថា **សតរំសីវ តារកា** សេចក្តីថា មានរស្មីច្រើន បីដូចផ្កាយព្រឹក ។ បទថា **អាវុធពលវន្តានំ** បានដល់ ប្រកបដោយកម្លាំងអាវុធ ។ បទថា **គុណិកា-យុរធារិនំ** សេចក្តីថា ក្រោះ លោកហៅថា **គុណី** អ្នកទ្រទ្រង់នូវក្រោះទាំងឡាយផង ទ្រទ្រង់នូវគ្រឿងប្រដាប់ គឺសង្វារទាំងឡាយផង ឬជាបុគ្គលទ្រទ្រង់នូវសង្វារ ពោល គឺក្រោះ ។ បទថា **សចេ បក្ខីវ កាហិតិ** សេចក្តីថា ព្រះបាទចូឡនីត្រាស់ថា បើនឹងហើរទៅបានតាមអាកាសដូចបក្សី សូម្បីយ៉ាងនោះ ក៏នឹងផុតទៅបានដូចម្តេច ។ បទថា **តឹស មេ បុរិសនាវុត្យោ** សេចក្តីថា លោកហៅបុរស ៣៩០០០ ថា **តឹសនាវុត្យោ** ដូច្នេះ ។ បទថា **សព្វេ ឯកេកនិច្ចិតា** សេចក្តីថា ព្រះបាទចូឡនីទ្រង់សម្តែងថា យោធារបស់យើងអាចដណ្តើមអាវុធអំពីដៃអ្នកដទៃ កាត់ក្បាលបច្ចាមិត្តទាំងឡាយបាន ជាយោធាដែលជ្រើសរើសជាប្រចាំ ។ បទថា **កេវលំ មហិមំ ចរំ** សេចក្តីថា ត្រាច់ទៅពេញផែនដីទាំងមូល ។ បទថា **យេសំ សមំ ន បស្សាមិ** សេចក្តីថា ព្រះបាទចូឡនីទ្រង់សម្តែងថា យើងមិនឃើញយោធាទាំងនោះដែលដូចយោធារបស់យើង ដែលមានសមត្ថភាពប៉ុណ្ណោះ ។ មាស លោកហៅថា **ចារុ ក្នុង**

បទថា **ចារុទស្សនា** សេចក្ដីថា មានពណ៌ដូចមាស ។ បទថា **បីតាលង្ការា** បានដល់ មានគ្រឿងប្រដាប់ពណ៌លឿង ។ បទថា **បីតវសនា** បានដល់ ស្លៀកសំពត់ពណ៌លឿង ។ បទថា **បីតុត្តរនិវាសនា** បានដល់ មានសំពត់ដណ្ដប់លឿង ។ បទថា **ចាមីនវណ្ណា** បានដល់ ដូចគ្នានឹងត្រីស្វាត ។ បទថា **នេត្តឹសា** បានដល់ ព្រះខ័ន ។ បទថា **នរវីរេហិ** បានដល់ បុរសដែលជាបណ្ឌិត អ្នកមានសេចក្ដីព្យាយាម ។ បទថា **សុនិស្សិតា** បានដល់ សំលៀងយ៉ាងល្អ មុត ។ បទថា **វេល្លាឡិនោ** សេចក្ដីថា រុងរឿងដូចព្រះអាទិត្យក្នុងពេលថ្ងៃ ។ បទថា **សិក្កាយសមយា** សេចក្ដីថា ធ្វើដោយដែកថែបដែលលាយចំណីឲ្យសត្វក្រៀលស៊ីអស់ ៧ ដង កាន់យក ។ បទថា **សុប្បហា-រប្បហារិភិ** បានដល់ យោធាមានដៃស្ទាត់ជំនាញ ។ បទថា **លោហិត-កញ្ចុបធារិតា** សេចក្ដីថា ប្រកបដោយអាវពណ៌ក្រហម ។ បទថា **បជកា** បានដល់ អាចរលាស់ទង់ក្នុងអាកាស ។ បទថា **អសិចម្មស្ស កោវិទា** បានដល់ ឈ្លាសក្នុងការប្រើដាវ និងខែល ។ បទថា **ធនុគ្គហា** បានដល់ អ្នកកាន់ធ្នូ ។ បទថា **សិក្ខិតរា** បានដល់ បង្វឹកយ៉ាងល្អក្នុងការកាន់ធ្នូនោះ ។ បទថា **នាគក្ខន្ធនិចាតិនោ** សេចក្ដីថា អាចប្រើព្រះខ័នកាត់នូវកដំរីឲ្យធ្លាក់ចុះ ។ បទថា **នត្ថិ មោក្ខោ** សេចក្ដីថា ព្រះបាទចូឡនីត្រាស់ថា រុឺយ វិទេហៈ កាលមុនឯងរត់រួចផុតបាន ដោយអានុភាពរបស់មហោសថកូនគហបតី តែឥឡូវនេះ អ្នកមិនមានការរួចផុតឡើយ ។ បទថា **បភាវន្តេ** សេចក្ដីថា ឥឡូវនេះ យើងមិនឃើញរាជានុភាពរបស់អ្នក ដែលជាគ្រឿងឲ្យត្រឡប់ទៅ

ក្រុងមិថិលាបាន ថ្ងៃនេះ អ្នកដូចជាត្រីចូលសំណាញ់ដែលបង់ ។

ព្រះបាទចូឡនី ត្រាស់គំរាមព្រះបាទវិទេហរាជយ៉ាងនេះហើយ ទ្រង់ធ្វើក្នុងព្រះហឫទ័យថា អញនឹងចាប់ព្រះបាទវិទេហរាជឲ្យបានក្នុងកាលឥឡូវនេះ ទើបទ្រង់បញ្ជាដំរីព្រះទីន័ងដោយកន្ទ្រេវពេជ្រ ហើយត្រាស់បញ្ជាសេនាថា ពួកឯង ចូរចាប់ ចូរទម្លាយ ចូរចាក់ យាងដល់ឧបការនគរ ដូចទឹកជំនន់ ។ លំដាប់នោះ បុរសទាំងឡាយដែលមហោសថរៀបចំ ក៏នាំគ្នីគ្នាចោមរោមមហោសថ ដោយគិតថា អ្នកណានឹងដឹងអ្វីកើតមាន ។ ខណៈនោះ ព្រះពោធិសត្វក្រោកចាកដំណេកដ៏មានសិរី ជម្រះរាងកាយហើយ បរិភោគអាហារព្រឹក ប្រដាប់តាក់តែងខ្លួន ស្លៀកសំពត់មកអំពីដែនកាសីដែលមានតម្លៃមួយសែន ដណ្តប់សំពត់កម្ពលចៀងស្មា កាន់ឈើច្រត់មាស ដែលវិលេចដោយរតនៈ ៧ ប្រការ សម្រាប់ប្រើមួយ ពាក់ស្បែកជើងមាស ពួកស្រីដែលតាក់តែង ដូចទេពអប្សរបក់ដោយផ្លិតវាលវីជនី បើកបង្អួចលើប្រាសាទដែលតាក់តែងហើយ បង្ហាញខ្លួនដល់ព្រះបាទចូឡនី ដើរត្រឡប់ទៅត្រឡប់មក ដោយលីលាដូចសក្កទេវរាជ ។

ចំណែកព្រះបាទចូឡនីទតឃើញសិរីរូប ដ៏ឧត្តមរបស់ព្រះពោធិសត្វ ក៏មិនអាចញ៉ាំងចិត្តឲ្យជ្រះថ្លា ទ្រង់បរដំរីព្រះទីន័ងចូលទៅដោយគិតថា អញនឹងចាប់មហោសថឲ្យបានក្នុងកាលឥឡូវនេះ ។ មហោសថពោធិសត្វគិតថា ព្រះបាទចូឡនីនេះ ប្រញាប់មកដោយទ្រង់សម្គាល់ថា អញនឹងចាប់ខ្លួនព្រះបាទវិទេហៈក្នុងទីនេះឯង ទ្រង់ប្រហែលជាមិនបានដឹងថា អញចាប់បុត្រាបុត្រី និង

មហេសីរបស់ព្រះអង្គ ថ្វាយដល់ព្រះរាជារបស់អញ អញនឹងបង្ហាញមុខរបស់អញឲ្យដូចគ្នានឹងកញ្ចក់មាស ហើយពោលនឹងព្រះបាទចូឡនី ព្រះពោធិសត្វឈរត្រង់មាត់បង្អួច បន្លឺសំឡេងដ៏ពីរោះ កាលនឹងពោលចំអកព្រះបាទចូឡនី ទើបទូលថា

ព្រះអង្គទ្រង់ប្រញាប់ប្រញាល់ បញ្ជូនដំរីដ៏ប្រសើរមក ព្រះអង្គមានព្រះហឫទ័យរីករាយ យាងមកហើយ ទ្រង់សម្គាល់ថា អាត្មាអញនឹងបានសម្រេចប្រយោជន៍ដូច្នេះឬហ្ន៎ ។ សូមព្រះអង្គដាក់ធ្នូ និងបំពង់ព្រួញនុ៎ះចេញ សូមព្រះអង្គដាក់កូនសរនោះចេញ សូមព្រះអង្គដាក់គ្រឿងក្រោះដ៏ល្អ ប្រហែលដោយកែវពៃទូរ្យ និងកែវមណីនុ៎ះចេញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុញ្ជរំ** បានដល់ ដំរីដ៏ប្រសើរ ។ បទថា **បហដ្ឋរូបោ** សេចក្ដីថា មានព្រះហឫទ័យត្រេកអរហើយ គឺទ្រង់សោមនស្ស ។ បទថា **អាគមសិ** បានដល់ យាងមក ។ បទថា **លទ្ធត្ថោស្មិ** សេចក្ដីថា ព្រះអង្គយល់ក្នុងព្រះហឫទ័យថា អញមានប្រយោជន៍ដែលសម្រេចហើយ គឺសេចក្ដីប្រាថ្នារបស់អញដល់ទីបំផុតហើយ ។ បទថា **ឱហារេតំ** សេចក្ដីថា សូមទ្រង់ដាក់ចុះនូវធ្នូ ពោល គឺបំពង់ព្រួញនោះចេញ ប្រយោជន៍អ្វីដោយធ្នូនោះដល់ព្រះអង្គ ។ បទថា **បដិសំហារ** សេចក្ដីថា ចូរប្រទានដល់អ្នកដទៃ ឬទុកដាក់ក្នុងទីដែលគត់មត់ ទ្រង់នឹងប្រើព្រួញធ្វើអ្វី ។ បទថា **ចម្មំ** សេចក្ដីថា សូម្បីក្រោះនោះ ក៏ចូរនាំចេញ ព្រោះក្រោះនេះ ទ្រង់ពាក់តាំងពីម្សិលមិញ

សូមដោះចោលចុះ កុំឲ្យក្រោះបៀតបៀនព្រះកាយរបស់ព្រះអង្គឡើយ កុំធ្វើព្រះកាយរបស់ព្រះអង្គឲ្យលំបាកឡើយ សូមទ្រង់យាងចូលព្រះនគររបស់ទូលបង្គំអំពីព្រឹកចុះ ព្រះពោធិសត្វបានធ្វើការចំអកដល់ព្រះបាទចូឡនី ដូច្នេះ ។

ព្រះបាទចូឡនី បានស្តាប់ពាក្យមហោសថហើយត្រាស់ថា កូនគហបតីនេះធ្វើការចំអកអញ ថ្ងៃនេះ អញនឹងដឹងកិច្ចដែលគប្បីធ្វើដល់គេ កាលទ្រង់គំរាមមហោសថ ទើបត្រាស់ថា

អ្នកឯងជាអ្នកមានសម្បុរមុខស្រស់បស់ ទាំងនិយាយ ក៏ញញឹមញញែមជាប់ ឯការបរិបូណ៌ដោយសម្បុរបែបនេះ រមែងមានប្រាកដក្នុងមរណកាល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិហិតបុព្វញ្ច ភាសសិ** សេចក្តីថា អ្នកញញឹមញញែមមុនហើយ ទើបពោលជាក្រោយ ឈ្មោះថា ពោលនូវពាក្យញញឹម អ្នកមិនរាប់យើងក្នុងរឿងណាមួយ ។ បទថា **ហោតិ ខោ** សេចក្តីថា ធម្មតាការដល់ព្រមនៃពណ៌សម្បុរបែបនេះ រមែងមានដល់បុគ្គលក្នុងពេលជិតស្លាប់ប៉ុណ្ណោះ ព្រោះដូច្នោះ អ្នកផូរផង់ថ្ងៃនេះ យើងនឹងកាត់ក្បាលរបស់អ្នក ហើយផឹកជយបានៈ ។

ក្នុងពេលដែលមហោសថទូលនឹងព្រះបាទចូឡនីយ៉ាងនេះ ចំណែកពលនិកាយជាច្រើន បានឃើញរូបដ៏ល្អរបស់មហាសត្វ ទើបទៅកាន់សម្នាក់របស់ព្រះបាទព្រហ្មទត្តដោយគិតថា ព្រះរាជារបស់ពួកយើង ទ្រង់ប្រឹក្សានឹងមហោសថដោយពាក្យអ្វីហ្ន៎ ពួកយើងនឹងស្តាប់ពាក្យនៃព្រះរាជា និងមហោសថ ឯ

មហោសថបានស្តាប់ព្រះតម្រាស់ព្រះបាទចូឡនីហើយ គិតថា ព្រះបាទចូឡនី ទ្រង់មិនដឹងអញថា មហោសថបណ្ឌិត អញនឹងមិនឲ្យសម្លាប់អញបាន គិតដូច្នេះ ទើបទូលថា ការគិតរបស់ព្រះអង្គវិនាសហើយ រឿងដែលព្រះអង្គនិងកេវដ្ដៈគិតដោយចិត្តមិនកើតហើយ តែរឿងដែលពោលដោយមាត់កើតហើយ កាលប្រកាសសេចក្ដីនោះ ទើបទូលថា

បពិត្រក្សត្រជាព្រះរាជា ពាក្យដែលព្រះអង្គគំរាមហើយ ជាពាក្យសោះសូន្យទទេ ព្រះអង្គមានការប្រឹក្សាថ្លាយហើយ ឯព្រះរាជា ( របស់យើង ) ព្រះអង្គមិនងាយនឹងចាប់យកបានទេ ដូចសេះសិន្ធព និងសេះខ្វក ។ ( ព្រះរាជាក្រុងមិថិលា ) ព្រមដោយអាមាត្យ និងរាជបរិស័ទ ចូលស្ទឹងគង្គាតាំងពីថ្ងៃម្សិលទៅហើយ ម៉្លេះ ក្អែកស៊ុះតាមរាជហង្ស នឹងធ្លាក់ចុះក្នុងពាក់កណ្ដាលផ្លូវយ៉ាងណាមិញ ( បើព្រះអង្គនឹងតាមព្រះរាជានោះ នឹងដល់សេចក្ដីវិនាស ក្នុងពាក់កណ្ដាលផ្លូវ ក៏យ៉ាងនោះដែរ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភិន្នមន្តោសិ** សេចក្ដីថា មហោសថពោលថា ទ្រង់កុំយល់ថា ការគិតរបស់អញ ដែលប្រឹក្សាជាមួយកេវដ្ដៈ ក្នុងបន្ទប់ដ៏មានសិរីនោះ មិនមានអ្នកណាដឹង ការគិតនោះ ទូលបង្គំដឹងមុនហើយនោះឯង ដូច្នោះ ទ្រង់នឹងជាអ្នកមានការត្រិះរិះបែកធ្លាយហើយ ។ បទថា **ទុគ្គណ្ហោ ហិ តយា** សេចក្ដីថា បពិត្រមហារាជ ព្រះរាជារបស់ពួកទូលបង្គំ ទ្រង់ចាប់បានលំបាក ដូចសេះសិន្ធព និងសេះខ្វក ទ្រង់ដូចជាសេះខ្វក

មិនអាចនឹងចាប់ព្រះរាជារបស់ទូលបង្គំ ដែលដូចជាសេះអាជានេយ្យ មានសម្ផុះរហ័ស ។ មហោសថសម្ដែងថា កេវដ្ដៈដូចសេះខ្ចក ទ្រង់ដូចសេះខ្ចក ទូលបង្គំដូចសេះសិន្ធព មានកម្លាំងខ្លាំង ព្រះរាជារបស់ទូលបង្គំ ដូចមនុស្សជិះសេះសិន្ធព ។ បទថា **តិណ្ណោ ហិយ្យោ** សេចក្ដីថា ព្រះបាទវិទេហរាជមួយអន្លើដោយពួកអមាត្យរាជបរិវារ យាងឆ្លងទឹកទៅតាំងពីម្សិលមិញនោះហើយ មិនបានគេចទៅតែមួយអង្គឯង ។ បទថា **អនុជ្ជវំ** សេចក្ដីថា បើទ្រង់ដេញតាម គឺនឹងដេញតាមព្រះបាទវិទេហរាជ ដូចក្អែកដេញស្ដេចហង្ស នឹងត្រូវធ្លាក់កណ្ដាលចន្លោះនោះឯង យ៉ាងណា ទ្រង់នឹងធ្លាក់ គឺនឹងដល់នូវសេចក្ដីវិនាសក្នុងវវាំងនោះឯង ដូច្នោះ មហោសថទូលដោយប្រការដូច្នេះ ។

ឥឡូវនេះ មហាសត្វមិនបានតក់ស្លុត ដូចកេសរសីហរាជ កាលនឹងនាំឧទាហរណ៍មក ទើបទូលថា

ក្ងែចចកទាំងឡាយ ជាម្រឹគថោកទាបឃើញផ្កាចារ ដែលរីកក្នុងចំណែកនៃរាត្រី ក៏សម្គាល់ថាដុំសាច់ ហើយនាំគ្នាចោមរោម ។ ( ក្ងែចចកទាំងនោះ ) ជាម្រឹគថោកទាប កាលបើរាត្រីកន្លងទៅហើយ ព្រះអាទិត្យក៏រះឡើង ទើបឃើញច្បាស់ថា ជាផ្កាចាររីក ក៏ដាច់សេចក្ដីប្រាថ្នា ( រត់ទៅ ) យ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គចោមព័ទ្ធព្រះបាទវិទេហៈ នឹងដាច់សេចក្ដីប្រាថ្នាហើយទៅ ដូចពួកក្ងែចចក ( ចោមរោម ) នូវផ្កាចារដូច្នោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធិស្វាន** បានដល់ ឃើញដោយពន្លឺព្រះចន្ទ ។

បទថា **បរិយុដ្ឋា** សេចក្តីថា ឈរចោមរោមដោយបំណងថា នឹងទំពាស៊ី ដុំសាច់អំពីព្រលឹមនោះឯង ហើយនឹងទៅ ។ បទថា **វីតិវត្តាសុ** សេចក្តីថា ឆ្កែចចកទាំងនោះ បានឈរយ៉ាងនោះ ក្នុងរាត្រីណាៗ កាលរាត្រីនោះៗ អស់ទៅហើយ ។ បទថា **ទិស្វា** សេចក្តីថា ចចកទាំងឡាយ ឃើញផ្កាចារ អំពីព្រឹក ដឹងថា នេះមិនមែនសាច់ក៏អស់ប្រាថ្នា នាំគ្នាគេចទៅ ។ បទថា **សិង្គាលា** សេចក្តីថា ចចកទាំងឡាយចោមរោមដើមចារហើយ អស់សង្ឃឹម ក៏ទៅ យ៉ាងណា សូម្បីព្រះអង្គក៏ដូច្នោះ ទ្រង់ជ្រាបថា ព្រះបាទវិទេហរាជ មិនមានក្នុងទីនេះ ក៏នឹងអស់សង្ឃឹមយាងទៅ ក៏នឹងនាំសេនាគេចទៅ មហោសថពោលដូច្នេះ ។

ព្រះបាទចូឡនី ទ្រង់ស្តាប់ពាក្យដ៏គួរភ្ញាក់ផ្អើលរបស់មហោសថនោះ គិតថា គហបតីបុត្រនេះ ជាមនុស្សក្លាហានពោលហើយ គេពិតជាឲ្យព្រះបាទវិទេហរាជគេចទៅហើយដោយឥតសង្ស័យ ទ្រង់ព្រះពិរោធពន់ពេក ទ្រង់គិតថា កាលមុន ពួកយើងមិនជាម្ចាស់នៃសំពត់សាដកដែលស្លៀក ព្រោះមហោសថ ឥឡូវនេះ បច្ចាមិត្តនៅក្នុងកណ្តាប់ដៃរបស់ពួកយើងហើយ មហោសថក៏ឲ្យគេចទៅ មហោសថជាមនុស្សធ្វើសេចក្តីវិនាសដល់ពួកយើងច្រើនហ្ន៎ យើងនឹងធ្វើទោសដែលគួរធ្វើដល់ជនពីរនាក់ ដល់មហោសថនេះតែម្នាក់ កាលទ្រង់ដាក់ទោសដល់មហោសថ ទើបត្រាស់ថា

អ្នកទាំងឡាយ ចូរកាត់ដៃ និងជើង ត្រចៀក និងច្រមុះ នៃ
មហោសថនេះ ព្រោះវាធ្វើព្រះបាទវិទេហៈ ជាសត្រូវដែលនៅក្នុង

កណ្តាប់ដៃយើង ឲ្យរួចទៅវិញ ។ សេនាទាំងឡាយ ចូលដោត គហបតីបុត្តនេះ ដោយឈើស្រួច ហើយចម្អិនវា ដូចគេចម្អិនសាច់ ដែលគួរចម្អិន ព្រោះវាធ្វើស្តេចវិទេហៈ ជាសត្រូវដែលនៅក្នុង កណ្តាប់ដៃយើង ឲ្យរួចទៅវិញ ។ បុគ្គលដោតសន្ទឹងស្បែកគោ លើផែនដី ពុំនោះសោត ពួកស្បែកសីហៈ ឬខ្លាធំដោយកង្វេរ យ៉ាងណា ។ យើងនឹងចាក់ដោតវាដោយលំពែង យ៉ាងនោះ ព្រោះវាធ្វើព្រះបាទវិទេហៈ ជាសត្រូវដែលនៅក្នុងកណ្តាប់ដៃយើង ឲ្យរួចទៅវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាតប្បំ** សេចក្តីថា ចូរដោតគហបតីបុត្តនេះដោយលំពែង យកទៅអាំងលើភ្លើង ដូចដោតម្រឹគជាដើម ដែលគួរអាំង ដូច្នោះ ។ បទថា **សីហស្ស អថោ ព្យគ្ឃស្ស** សេចក្តីថា ដូចបុគ្គលយកកង្វេរថ្កក់ស្បែករាជសីហ៍ជាដើមទាញមក យ៉ាងណា ចូរធ្វើដល់មហោសថ ដូច្នោះ ។ បទថា **វេធយិស្សាមិ** បានដល់ នឹងឲ្យចាក់ ។

ព្រះមហាសត្វបានស្តាប់ព្រះតម្រាស់ដូច្នោះក៏សើច គិតថា ព្រះរាជានេះ មិនដឹងថា អញបញ្ជូនមហេសី និងវង្សានុវង្សរបស់ព្រះអង្គ ទៅក្រុងមិថិលាឡើយ ព្រោះដូច្នោះ ទើបគិតដាក់កម្មករណៈដល់អញ តែអាចបាញ់អញដោយព្រួញ ធ្វើទោសដទៃតាមគាប់ចិត្តរបស់ទ្រង់ដោយសេចក្តីពិរោធ ណ្ហើយចុះ អញនឹងប្រាប់ហេតុការណ៍ ដើម្បីឲ្យទ្រង់សោយសោក ដល់នូវសេចក្តីទុក្ខ សន្ធប់លើខ្នងដំរីព្រះទីន័ងនោះឯង គិតដូច្នេះហើយ ទើបទូលថា

បើព្រះអង្គកាត់នូវដៃ ជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( ដៃ ជើង ត្រចៀក និងច្រមុះ ) របស់ព្រះរាជបុត្ត ឈ្មោះបញ្ចាលចន្ទៈ យ៉ាងហ្នឹងដែរ បើព្រះអង្គកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( នូវដៃ ជើង ត្រចៀក និងច្រមុះ ) របស់ព្រះរាជធីតាឈ្មោះបញ្ចាលចន្ទី យ៉ាងហ្នឹងដែរ ។ បើព្រះអង្គកាត់ដៃ និងជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( នូវដៃ ជើង ត្រចៀក និងច្រមុះ ) របស់អគ្គ-មហេសីឈ្មោះនន្ទាទេវី យ៉ាងហ្នឹងដែរ ។ បើព្រះអង្គកាត់ដៃ និងជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ ( នូវដៃ និងជើង ត្រចៀក និងច្រមុះ ) របស់ព្រះរាជបុត្ត និងព្រះមហេសីរបស់ព្រះអង្គ យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំដោយឈើអណ្ដោត ហើយចម្អិន ដូចគេចម្អិនសាច់ដែលគួរចម្អិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជបុត្តឈ្មោះបញ្ចាលចន្ទៈ ( ដោយឈើអណ្ដោត ) ហើយចម្អិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំ ដោយឈើអណ្ដោត ហើយចម្អិន ដូចគេចម្អិនសាច់ ដែលគួរចម្អិន ព្រះបាទវិទេហៈ មុខជានឹងប្រើគេឲ្យដោតព្រះរាជធីតាឈ្មោះបញ្ចាលចន្ទី ( ដោយឈើអណ្ដោត ) ហើយចម្អិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្ដោត

ហើយចម្អិនដូចគេចម្អិនសាច់ ដែលគួរចម្អិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោត អគ្គមហេសីឈ្មោះនន្ទាទេវី ( ដោយឈើអណ្តាត ) ហើយចម្អិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្តាត ហើយចម្អិន ដូចគេចម្អិនសាច់ ដែលគួរចម្អិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជបុត្ត និងព្រះមហេសីរបស់ព្រះអង្គ ( ដោយឈើអណ្តាត ) ហើយចម្អិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងដោតព្រះរាជបុត្តឈ្មោះបញ្ចាលចន្ទៈ ( ដោយលំពែង ) យ៉ាងហ្នឹងដែរ ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតព្រះរាជធីតាឈ្មោះបញ្ចាលចន្ទី ( ដោយលំពែង ) យ៉ាងនោះដែរ ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតអគ្គមហេសីឈ្មោះនន្ទាទេវី ( ដោយលំពែង ) យ៉ាងនោះដែរ ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតព្រះរាជបុត្ត និងព្រះមហេសីរបស់ព្រះអង្គ ( ដោយលំពែង ) យ៉ាងនោះដែរ ។ យើងទាំងពីរនាក់ គឺស្តេចវិទេហៈ និងទូលព្រះបង្គំជាខ្ញុំ ប្រឹក្សាគ្នារួចស្រេច ក្នុងទីស្ងាត់យ៉ាងនេះហើយ ខែលស្បែកមានទម្ងន់ ១០០ បលៈ ដែលជាងស្បែកឲ្យសម្រេចហើយ ដោយសស្ត្រារបស់ជាងស្បែក រមែងជួយការពារខ្លួន ដើម្បីទប់រងនូវកូនសរទាំងឡាយ យ៉ាងណា ។ ទូល

ព្រះបង្គំជាខ្ញុំ ជាអ្នកនាំសេចក្តីសុខមក ជួយបន្ទោបង់សេចក្តីទុក្ខនៃព្រះបាទវិទេហៈដ៏មានយស តែងទប់រងនូវកូនសរ គឺព្រះតម្រិះរបស់ព្រះអង្គ ដោយខែលស្បែកមានទម្ងន់ ១០០ បលៈ ( សេចក្តីគិតរបស់ទូលព្រះបង្គំជាខ្ញុំ ក៏ដូច្នោះឯង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆេទយិស្សតិ** សេចក្តីថា ព្រះបាទវិទេហរាជទ្រង់ស្តាប់ថា បានឮថា ព្រះបាទចូឡនីកាត់ដៃជើងរបស់មហោសថបណ្ឌិតហើយ ក៏នឹងឲ្យគេកាត់ ។ បទថា **បុត្តទារស្ស** សេចក្តីថា ព្រះរាជារបស់ពួកទូលបង្គំនឹងឲ្យគេកាត់ដៃជើងរបស់ជន ៣ នាក់ គឺព្រះរាជឱរស ព្រះរាជធីតា និងអគ្គមហេសី ព្រោះកាត់ដៃជើងរបស់ទូលបង្គំតែម្នាក់ជាហេតុ ។ បទថា **ឯវំ នោ មន្តិតំ រហោ** សេចក្តីថា បពិត្រមហារាជ ទូលបង្គំ និងព្រះបាទវិទេហរាជ បានប្រឹក្សាគ្នាក្នុងទីកំបាំងយ៉ាងនេះថា បើព្រះបាទចូឡនីឲ្យគេធ្វើកម្មណាមួយ ដល់ទូលបង្គំក្នុងនគរបញ្ចាលនេះ ព្រះបាទវិទេហរាជគប្បីធ្វើកម្មនោះៗ ដល់ព្រះរាជឱរស ព្រះរាជធីតា និងព្រះមហេសីរបស់ព្រះអង្គក្នុងនគរមិថិលានោះ ។ បទថា **បលសតំ** សេចក្តីថា ស្បែកទម្ងន់ប្រមាណ ១០០ បលៈ ដែលពេលភ្លើងឲ្យទន់ កាត់ដោយកាំបិតរបស់ជាងស្បែកលោកហៅថា **កោន្តិមន្តា** ក្នុងបទថា **កោន្តិមន្តាសុធិដ្ឋិតំ** បានដល់ ខែលស្បែកសម្រេចដោយល្អ ព្រោះស្នាមកាត់ទាំងឡាយ ធ្វើដោយកាំបិតរបស់ជាងស្បែកនោះ ។ បទថា **តន្ទុតាណាយ** សេចក្តីថា ខែលស្បែកនោះចូលដល់នូវការការពារសរីរៈ ដើម្បីការពារព្រួញទាំងឡាយ គឺការពារកូនសរ

ទាំងឡាយ រក្សាសិរីៈបាន យ៉ាងណា ។ បទថា **សុខាវហោ** សេចក្តីថា បពិត្រមហារាជ សូមទ្រង់ទូលបង្គំ ក៏នឹងជាអ្នកនាំសេចក្តីសុខមកថ្វាយដល់ព្រះរាជារបស់ពួកទូលបង្គំ ដោយហាមនូវបច្ចាមិត្តទាំងឡាយ ដូចខែលស្បែកសម្រាប់ការពារនូវព្រួញរបស់ព្រះអង្គ ។ បទថា **ទុក្ខនុទោ** សេចក្តីថា ទូលបង្គំនាំមកនូវសេចក្តីសុខផ្លូវកាយ និងសុខផ្លូវចិត្ត បន្ទោបង់នូវសេចក្តីទុក្ខ ។ បទថា **មតិន្តេ** សេចក្តីថា ព្រោះដូច្នោះ ទូលបង្គំនឹងត្រូវទម្លាយការគិត គឺបញ្ញារបស់ព្រះអង្គ ដោយការគិតរបស់ទូលបង្គំ ដូចការពារព្រួញដោយខែលស្បែកទម្ងន់ ១០០ បលៈនោះ ។

ព្រះបាទចូឡនី បានស្តាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា បុត្រគហបតីពោលយ៉ាងនេះធ្វើអ្វី បានឮថា អញធ្វើកម្មករណៈដល់គេយ៉ាងណា ព្រះបាទវិទេហរាជ ទ្រង់នឹងធ្វើកម្មករណៈដល់កូនប្រុស និងមហេសីរបស់អញយ៉ាងនោះ កូនគហបតីមិនដឹងថា អញចាត់ការរក្សាព្រះឱរស និងមហេសីយ៉ាងល្អឥឡូវនេះ គេនឹងស្លាប់ ទើបរវើរវាយដោយខ្លាចមរណភ័យនោះឯង អញមិនជឿពាក្យរបស់គេឡើយ ។ មហោសថគិតថា ព្រះរាជាសម្គាល់អញថានិយាយព្រោះខ្លាចស្លាប់ អញនឹងឲ្យព្រះអង្គទ្រង់ជ្រាប ទើបទូលថា

បពិត្រមហារាជ សូមអញ្ជើញព្រះអង្គ ទតព្រះនេត្រមើលព្រះរាជវាំង របស់ព្រះអង្គដែលសូន្យឈឹងចុះ បពិត្រព្រះមហាក្សត្រិយ៍ ស្រីស្នំ និងកុមារទាំងឡាយ និងព្រះវររាជមាតារបស់ព្រះអង្គ ខ្ញុំឲ្យនាំចេញចាកឧម្មង្គ នាំទៅថ្វាយព្រះបាទវិទេហៈហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧម្មង្គា** បានដល់ ខ្ញុំប្រាប់មាណពរបស់ខ្ញុំទៅនាំវង្សានុវង្សទាំងនោះ ចុះអំពីប្រាសាទ នាំមកតាមឧម្មង្គនោះឯង ហើយនាំចេញអំពីមហាឧម្មង្គ ថ្វាយដល់ព្រះបាទវិទេហរាជទៅហើយ ។

ព្រះបាទចូឡនី ទ្រង់បានស្តាប់ដូច្នោះ ទើបទ្រង់គិតថា កូនគហបតីនេះនិយាយធូទ់ពន់ពេក ម្យ៉ាងទៀត កាលពីយប់មិញនេះ អញបានឮសំឡេងដូចសំឡេងនាងនន្ទាទេវី ក្សេរឆ្នេរស្ទឹងគង្គា មហោសថនេះជាបណ្ឌិត មានបញ្ញាច្រើន ជួនកាល គប្បីពោលពិត ទ្រង់គិតដូច្នេះហើយ កើតសេចក្តីសោកដ៏មានកម្លាំង តាំងនូវសតិធ្វើជាមិនសោក កាលត្រាស់ហៅអមាត្យម្នាក់មកបញ្ជូនទៅឲ្យដឹងសេចក្តី ទើបត្រាស់គាថានេះថា

*បើដូច្នោះ អ្នកទាំងឡាយ ចូរទៅឯព្រះរាជវាំងរបស់អញ ហើយ*
*ពិចារណាមើលហេតុនោះ តើសមដូចពាក្យរបស់មហោសធនេះ*
*ពិត ឬកុហកទេ ដូច្នេះ ។*

អមាត្យនោះ មួយអន្ទើដោយបរិវារទៅកាន់ព្រះរាជនិវេសន៍ បើកទ្វារចូលទៅខាងក្នុង បានឃើញពួកមនុស្សរក្សាព្រះរាជនិវេសន៍ និងពួកបរិចារិកានារីដែលគមក្រិសជាដើម ត្រូវចងដៃ និងជើង បិទមាត់ជាប់នឹងដៃកែវទាំងឡាយ ភាជនៈក្នុងបន្ទប់បែកធ្លាយ ខាទនិយៈរាត់រាយក្នុងទីនោះ បន្ទប់ប្រកបដោយសិរី មានទ្វារបើក មានការប្លន់រតនៈ ដែលពួកបច្ចាមិត្តបើកទ្វារឃ្លាំងរតនៈធ្វើហើយ បានឃើញហ្វូងក្អែកចូលទៅតាមទ្វារ និងបង្អួចដែលបើកចំហ ។ ព្រះរាជនិវេសន៍មិនមានសិរី ដូចគ្នានឹងស្រុកដែលគេបោះបង់ចោល ឬដូចព្រៃ

ស្មសាន ទើបត្រឡប់មក កាលក្រាបទូលដល់ព្រះរាជា ទើបពោលគាថា នេះថា

បពិត្រមហារាជ មហោសធទូលយ៉ាងណា សេចក្តីនុ៎ះក៏យ៉ាង នោះឯង ព្រះរាជវាំងទាំងមូល សូន្យឈឹង ដូចស្ថានជាទីប្រជុំចុះ នៃពួកក្អែក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាកបតនកំ យថា** សេចក្តីថា ហាក់បី ដូចជាស្រុកដែលគេបោះបង់ក្បែរមាត់សមុទ្រ ដេរដាសទៅដោយហ្វូងក្អែក ដែលមកដោយក្លិនរបស់ត្រី ។

ព្រះបាទចូឡនីបានស្តាប់ដូច្នោះ ក៏ទ្រង់លះបង់សេចក្តីសោក ដែលកើត អំពីការព្រាត់ប្រាសចាកក្សត្រទាំង ៤ អង្គ ទ្រង់ក៏ក្រោធព្រះពោធិសត្វពន់ពេក ដូចពស់ត្រូវវាយដោយដំបង គិតថា សេចក្តីទុក្ខរបស់អញនេះ កើតព្រោះ អាស្រ័យកូនគហបតី ។ មហោសថឃើញអាការពិរោធរបស់ព្រះបាទចូឡនី ទើបគិតថា ព្រះរាជាមានយសធំអង្គនេះ គប្បីបៀតបៀនអញដោយខត្តិយមានះ ដោយអំណាចនៃសេចក្តីក្រោធ ក្នុងកាលខ្លះក៏ថាបាន អញនឹងត្រូវការដោយ ក្សត្រទាំង ៤ ធ្វើអ្វី បើដូច្នោះអញនឹងធ្វើព្រះនាងនន្ទាទេវី ឲ្យដូចជាព្រះរាជា នេះ មិនធ្លាប់ឃើញ ទើបសរសើរវណ្ណៈនៃព្រះនាងនោះ ពេលនោះ ព្រះរាជា ទ្រង់នឹងរឭកដល់ព្រះនាង ហើយមិនបៀតបៀនអញ ដោយទ្រង់ស្រឡាញ់ ក្នុងមហេសីរបស់ព្រះអង្គ ដោយទ្រង់គិតថា បើអញសម្លាប់មហោសថ អញ នឹងមិនបាននារីរ័តន៍បែបនេះ មហោសថគិតដូច្នេះហើយ ឈរលើប្រាសាទ

ដើម្បីរក្សាខ្លួន បានលាដៃដែលមានពណ៌ដូចមាសចេញ ក្នុងវាំងវត្ថកម្ពល ( សំពត់កម្ពលក្រហម ) កាលទឹងសរសើរព្រះទេវី ដោយអំណាចនៃការក្រាបទូលផ្លូវ ដែលព្រះនាងយាងទៅ ទើបទូលថា

បពិត្រមហារាជ ព្រះនាងនារីនន្ទាទេវី ព្រះសរីរកាយដ៏ល្អ មានព្រះសោណីដ៏ល្អ ដូចដំបារមាស មានប្រក្រតីពោលពាក្យពីរោះ ដូចជាសំឡេងនៃហង្ស បានចេញទៅអំពីឧម្មង្គនេះហើយ ។ បពិត្រមហារាជ ព្រះនាងនារីមានសរីរកាយដ៏ល្អ ទ្រទ្រង់កោសេយ្យពស្ត្រ មានសរីរៈដូចមាស មានខ្សែរឹតព្រះអង្គនោះក៏ល្អវិចិត្រដោយមាស ។ ព្រះនាងនារី មានព្រះបាទដ៏ក្រហមល្អ ប្រកបដោយលម្អ ( ៥ យ៉ាង ) មានខ្សែរឹតជាវិការនៃមាស និងកែវមណី មានដួងព្រះនេត្រប្រាកដស្មើ ដោយភ្នែកសត្វព្រាប មានសរីរៈដ៏ល្អ មានរីមព្រះឱស្ឋរលីងល្អ ដូចជាផ្លែទន្លាប់ មានចង្កេះរៀវ ។ ព្រះនាងនារីមានចង្កេះរៀវ ដូចវល្លិ៍នាគលតា ដែលលូតលាស់ល្អ ឬដូចក្តារហឹង ( ជាវិការនៃមាស ) ព្រះកេសរបស់ព្រះនាងនារីនោះ វែងមានចុងខ្មៅងបន្តិច ដូចចុងកាំបិត ។ ព្រះនាងនន្ទាទេវី មានដួងព្រះនេត្រថ្លាយង់ ដូចជាភ្នែកនៃកូនម្រឹគកើត ( បានមួយខួប ) ឬដូចជាអណ្តាតភ្លើង ក្នុងហេមន្តរដូវ ពុំនោះសោត ដូចជាស្ទឹងដ៏ដេរដាសដោយដើមឫស្សីតូចៗ ទាំងឡាយទៀបជ្រោះភ្នំ ។ ព្រះនាងនន្ទាទេវី មានព្រះឱរុល្អដូចប្រមោយដំរី

មានស្តនទាំងគូ ល្អដូចផ្លែទន្លាប់ ដ៏ប្រសើរ មិនខ្ពស់ពេក មិនទាប ពេក មិនមែនឥតព្រះលោមា មិនមែនមានព្រះលោមាច្រើនពេក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតោ** សំដៅដល់ឧម្មន្តី ។ បទថា **កោសុម្ភផលកសុស្សោណី** សេចក្តីថា មានព្រះសោណីស្អាតដូចជំពូរមាស ដ៏វិសាល ។ បទថា **ហំសគគ្គរភាណិនី** សេចក្តីថា ប្រកបដោយការបន្លឺ សំឡេងដ៏ពីរោះជាប់ចិត្ត ដូចសំឡេងកូនហង្ស ដែលត្រាច់រកស៊ី ។ បទថា **កោសេយ្យវសនា** បានដល់ ទ្រទ្រង់នូវសំពត់ថ្មី រំលេចដោយមាស ។ បទ ថា **សាមា** បានដល់ មានសរីរៈដូចមាស ។ បទថា **ចារុនេត្តិ** សេចក្តីថា មានភ្នែកដូចសត្វព្រាប ក្នុងឋានៈដ៏ប្រសើរទាំងឡាយ ក្នុងបសាទទាំង ៥ ។ បទថា **សុតនូ** បានដល់ មានព្រះសរីរៈស្អាត ។ បទថា **ពិម្ពោដ្ឋា** បានដល់ មានបបូរមាត់ក្រហមដូចផ្លែបាសទុំ ។ បទថា **តនុមជ្ឈិមា** សេចក្តីថា មាន ចង្កេះរៀវដោយជុំវិញ ។ បទថា **សុជាតា ភុជលដ្ឋីវ** សេចក្តីថា មានចង្កេះ ល្អដូចពន្លកឈើ មានពណ៌ក្រហម ត្រូវខ្យល់បក់ ក្នុងកាលព្រះនាងយាង យាស ល្អរុងរឿងដូចវល្លិ៍នាគលតាដែលដុះល្អហើយ ។ បទថា **វេទីវ** សេចក្តី ថា មានចង្កេះដូចគ្នានឹងក្តារហឹងមាស ។ បទថា **ទីឃស្សា វេល្លិតគ្គា** សេចក្តី ថា ព្រះកេសារបស់នាងត្រង់ចុងបន្តិច ឈ្មោះថា ចុងរបស់នាងបន្តិចដូចចុងកាំបិត ។ បទថា **មិគច្ឆាបីវ** សេចក្តីថា ប្រកបដោយកែវភ្នែកល្អ ដូចកូនម្រឹគមួយខួប ដែល កើតត្រង់ជើងភ្នំ ។ បទថា **ហេមន្តគ្គិសិខារិវ** សេចក្តីថា ដូចអណ្តាតភ្លើងក្នុង

វដ្ដវង្សា ព្រោះមានពន្លឺ ។

បទថា **ខុទ្ទវេទ្ឋកិ** សេចក្ដីថា ស្អាតដោយជួរនៃរោមជាតិស្ដើងៗ ដូចស្មៅដែលដេរដាសដោយដើមឫស្សីតូចៗ រមែងស្អាតដូច្នោះ ។ បទថា **កល្យាណី** សេចក្ដីថា ប្រកបដោយលម្អ ៥ យ៉ាង គឺលម្អស្បែក លម្អសាច់ លម្អសក់ លម្អវ័យ និងលម្អធ្មេញ ។ បទថា **បឋមា តិម្ពរុត្ថនី** សេចក្ដីថា ព្រះនាងនន្ទាទេវីនោះ មានព្រះស្ដនជិតគ្នាបរិបូណ៌ដោយសណ្ឋាន ដូចគូនៃផ្លែទន្លាប់មាស ដែលដាក់លើបន្ទះមាសដូច្នោះ ល្អឯក គឺឧត្ដម ។

កាលព្រះមហាសត្វ ពណ៌នានូវរូបសិរីរបស់ព្រះនាងនន្ទាទេវីយ៉ាងនេះហើយ ព្រះនាងហាក់ដូចព្រះបាទចូឡនី មិនធ្លាប់បានឃើញមកអំពីមុន ទ្រង់កើតសេចក្ដីស្នេហាមានកម្លាំង ។

លំដាប់នោះ ព្រះមហាសត្វទ្រង់ជ្រាបថា ព្រះបាទចូឡនីមានសេចក្ដីស្នេហាកើតឡើង ទើបពោលគាថាជាលំដាប់ថា

បពិត្រព្រះអង្គមានពាហនៈ បរិបូណ៌ដោយសិរី ព្រះអង្គត្រេកអរ
ដោយមរណៈ នៃព្រះនាងនន្ទាទេវីដោយពិត ឯខ្ញុំព្រះអង្គ និង
ព្រះនាងនន្ទា នឹងទៅកាន់សម្នាក់យមរាជដោយពិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សិរិវាហន** សេចក្ដីថា មហោសថពោលថា បពិត្រមហារាជដែលមានពាហនៈដល់ព្រមដោយសិរី ទ្រង់រមែងត្រេកអរដោយការសោយព្រះវិលាល័យរបស់ព្រះនាងនន្ទាទេវី ដែលទ្រទ្រង់នូវព្រះរូបដ៏ប្រសើរយ៉ាងនេះពិត ។ បទថា **គច្ឆាម** សេចក្ដីថា បើទ្រង់សម្លាប់ទូលបង្គំ

ព្រះរាជារបស់ទូលបង្គំក៏សម្លាប់ព្រះនាងនន្ទាទេវីដូចគ្នា ព្រោះដូច្នោះ ព្រះនាងនន្ទាទេវី ជាមួយទូលបង្គំ នឹងទៅកាន់សម្នាក់របស់យមរាជៗ ឃើញទូលបង្គំទាំងពីរហើយ នឹងឲ្យព្រះនាងនន្ទាទេវីដល់ទូលបង្គំប៉ុណ្ណោះ កាលទូលបង្គំស្លាប់ហើយ ក៏គង់បានស្រីកែវបែបនោះ នឹងខាតបង់អ្វីហ្ន៎ ទូលបង្គំមិនឃើញការវិនាស ព្រោះត្រូវស្លាប់ ។ បានឮថា មហោសថក្រាបទូលព្រះបាទចូឡនីយ៉ាងនេះ ដោយប្រការដូច្នេះ ។

ព្រះមហោសថសរសើរព្រះនាងនន្ទាទេវីដោយឋានៈប៉ុណ្ណោះ មិនសរសើរក្សត្រទាំង ៣ អង្គឡើយ ដោយប្រការដូច្នេះ ព្រោះហេតុអ្វី ព្រោះសត្វទាំងឡាយ មិនធ្វើសេចក្តីស្នេហាក្នុងជនដទៃ ដូចក្នុងកិរិយាជាទីស្រឡាញ់ ឬថា ជនទាំងឡាយ កាលមិនរឭកដល់មាតា ក៏មិនរឭកដល់បុត្រ និងធីតា ព្រោះហេតុនោះ ទើបព្រះពោធិសត្វសរសើរព្រះនាងនន្ទាទេវីប៉ុណ្ណោះ ទ្រង់មិនសរសើរព្រះរាជមាតា ព្រោះទ្រង់ជរាហើយ ។ ក្នុងកាលមហាសត្វសរសើរព្រះនាងនន្ទាទេវីដោយសំឡេងពីរោះ ព្រះនាងនន្ទាទេវី ក៏ហាក់បីដូចជាមកប្រថាប់នៅត្រង់ព្រះកក្ត្រារបស់ព្រះបាទចូឡនី បន្ទាប់អំពីនោះ ព្រះបាទចូឡនីទ្រង់គិតថា វៀរមហោសថបណ្ឌិតចេញ បុគ្គលដទៃដែលអាចនាំកិរិយាជាទីស្រឡាញ់របស់អញ មកឲ្យដល់អញ មិនមាន ។ លំដាប់នោះ កាលព្រះបាទចូឡនីរឭកដល់ព្រះនាង សេចក្តីសោកក៏កើតឡើង ។ ទើបព្រះពោធិសត្វលួងលោមព្រះបាទចូឡនីថា ទ្រង់កុំវិតក្កឡើយ ព្រះរាជទេវី ព្រះរាជឱរស និងព្រះរាជធីតារបស់ព្រះអង្គទាំង ៣ អង្គ នឹងយាងត្រឡប់មក ទូលបង្គំត្រឡប់

ទៅនោះឯង ជាការកំណត់នៃការយាងមករបស់ក្សត្រទាំង ៣ អង្គនោះ ព្រោះដូច្នោះ សូមទ្រង់ទុកព្រះហឫទ័យចុះ ។

លំដាប់នោះ ព្រះបាទចូឡនីគិតថា អញឲ្យធ្វើការរក្សានគររបស់អញយ៉ាងល្អ ហើយមកចោមព័ទ្ធឧបការនគរនេះ ដោយពលពាហនៈដល់ម៉្លេះ មហោសថនៅតែនាំព្រះទេវី បុត្រា បុត្រី និងព្រះមាតារបស់អញ អំពីនគរអញ ដែលរក្សាល្អហើយយ៉ាងនេះ ទៅឲ្យព្រះបាទវិទេហរាជបាន ហើយកាលពួកយើងកំពុងព័ទ្ធយ៉ាងនេះ មហោសថញុំាងព្រះបាទវិទេហរាជ មួយអន្លើដោយពលពាហនៈឲ្យគេចទៅ សូម្បីតែម្នាក់ក៏មិនមានអ្នកណាដឹង មហោសថចេះមាយាដែលជាទិព្វឬ ឬជាឧបាយបំបាំងភ្នែក កាលនឹងត្រាស់សួរសេចក្ដីនោះនឹងព្រះមហោសថ ទើបត្រាស់ថា

អ្នកបានរៀនកលមាយាជាទិព្វ ហើយបានធ្វើឧបាយបំបាំងភ្នែកឬ
បានជាអ្នកដោះលែងព្រះបាទវិទេហៈជាសត្រូវ នៅក្នុងកណ្ដាប់នៃ
យើងបាន ដូច្នេះ ។

មហោសថបានស្ដាប់ព្រះតម្រាស់ក៏ទូលថា ទូលបង្គំចេះមាយាដែលជាទិព្វ មែនពិត បណ្ឌិតទាំងឡាយ រមែងរៀនមាយាដែលជាទិព្វ កាលមានភ័យមកដល់ ក៏ដោះខ្លួនឯងផង ដោះអ្នកដទៃផងឲ្យផុតទុក្ខ ដូច្នេះហើយ ក៏ទូលថា

បពិត្រមហារាជ បណ្ឌិតទាំងឡាយ ក្នុងលោកនេះ រមែងរៀននូវ
កលមាយាជាទិព្វដោយពិត ពួកបណ្ឌិតជន អ្នកមានសេចក្ដីដឹង

នោះ ទើបដោះខ្លួន (ចាកទុក្ខបាន ) ពួកយោធាក្មេងៗ អ្នកបម្រើ របស់ទូលព្រះបង្គំ ជាអ្នកឈ្លាស ជាអ្នកកាត់ផ្តាច់នូវទីត ព្រះបាទវិទេហៈ យាងទៅកាន់ក្រុងមិថិលា តាមផ្លូវដែលពួកជនទាំងនេះ ធ្វើទុកហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធិតាមាយីធ** កាត់បទជា **ធិតាមាយំ ឥធ** ។ បទថា **មាណវបុត្តា** បានដល់ ពួកយោធាកំលោះដែលជាអ្នកបម្រើ ។ បទថា **យេសំ កតេន** បានដល់ ដែលពួកគេធ្វើ ។ បទថា **មគ្គេន** បានដល់ ដោយឧមង្គដែលគាត់តែង ។

ព្រះបាទចូឡនីបានស្តាប់ពាក្យនេះហើយ ប្រាថ្នាចង់ឃើញឧមង្គ ដោយទ្រង់គិតថា មហោសថប្រាប់ថា ព្រះបាទវិទេហរាជបានយាងទៅដោយឧមង្គដែលគេបានតាក់តែង ឧមង្គដូចម្តេចហ្ន៎ ។ លំដាប់នោះ ព្រះពោធិសត្វដឹងថា ព្រះបាទចូឡនីមានព្រះរាជបំណងនឹងទតឧមង្គ ទើបគិតថា ព្រះរាជាប្រាថ្នានឹងទតឧមង្គ អញនឹងបង្ហាញឧមង្គដល់ព្រះអង្គ កាលនឹងបង្ហាញ ទើបពោលគាថាដូច្នេះថា

បពិត្រមហារាជ សូមព្រះអង្គស្តេចទតឧមង្គ ដែលពួកជាងសាងទុកល្អហើយ សូមព្រះអង្គទតឧមង្គដ៏ល្អរុងរឿង ( ដោយរបៀប ) នៃដំរី សេះ រថ និងពលថ្មើរជើង ដែលគេធ្វើឲ្យសម្រេចហើយដោយល្អ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហត្ថីនំ** សេចក្តីថា សូមទ្រង់ទតឧមង្គដែលល្អ

រុងរឿងដោយរបៀបនៃពលដ៏វីជាដើមនេះ ដែលទាយជាងធ្វើដោយបោត្ថកម្ម គឺការច្នាក់ និងចិត្តកម្ម គឺការគូរ មានពន្លឺតែមួយ ដូចគ្នានឹងទេវសភាដែលតាក់តែងហើយ ។

កាលពោលយ៉ាងនេះហើយ មហោសថបានទូលបន្តថា ឧមង្គដែលតាក់តែងហើយ ទូលបង្គំបានសាងដោយបញ្ញារបស់ទូលបង្គំ ដែលហាក់បីដូចជាប្រាកដហើយ ក្នុងទីរះឡើងនៃព្រះចន្ទ និងព្រះអាទិត្យ សូមទ្រង់ទតទ្វារធំ ៨០ ទ្វារតូច ៦៤ បន្ទប់ដេក ១០១ គោមប្រទីបច្រើនរយ សូមទ្រង់ព្រមព្រៀងត្រេកអរជាមួយទូលបង្គំ យាងចូលទៅកាន់ឧបការនគរជាមួយរាជបរិវារ ទូលដូច្នេះហើយ ឲ្យបើកទ្វារនគរ ។ ព្រះបាទចូឡនី និងព្រះរាជា ១០១ ចោមរោមចូលកាន់នគរ មហោសថចុះអំពីប្រាសាទ ថ្វាយបង្គំព្រះបាទចូឡនី នាំព្រះរាជា និងរាជបរិវារចូលកាន់ឧមង្គ ព្រះបាទចូឡនីទតឃើញឧមង្គ ហាក់បីដូចទេវសភា កាលទ្រង់ពណ៌នាគុណនៃព្រះពោធិសត្វ ទើបត្រាស់ថា

ម្នាលមហោសធ ជាលាភរបស់អ្នកដែនវិទេហៈដោយពិត បណ្ឌិតទាំងឡាយ បែបដូចជាអ្នកនេះ នៅក្នុងដំណាក់ក្នុងដែនរបស់ព្រះរាជាណា ( ជាលាភរបស់ព្រះរាជានោះពិត ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិទេហានំ** សេចក្តីថា ជាលាភរបស់អ្នកវិទេហៈ គឺរបស់ជនបទដែលជាទីកើត គឺជាទីតាំងឡើងនៃពួកបណ្ឌិតបែបនេះហ្ន៎ ។ បទថា **យស្សិមេ ឯទិសា** សេចក្តីថា បណ្ឌិតទាំងឡាយដែលឈ្លាសក្នុងឧបាយទាំងនេះ គឺបែបនេះ នៅក្នុងផ្ទះតែមួយ ក្នុងប្រទេសតែមួយ ឬក្នុង

ដែនតែមួយរបស់បុគ្គលណា ជាលាភរបស់បុគ្គលនោះហ្ន៎ ។ បទថា **យេសំ ភូមសិ** សេចក្តីថា ជនទាំងឡាយរមែងបាន ដើម្បីនៅក្នុងរដ្ឋតែមួយ ក្នុងជនបទតែមួយ ក្នុងនគរតែមួយ ក្នុងផ្ទះតែមួយជាមួយនឹងបណ្ឌិតបែបនោះ ដូចអ្នកនុ៎ះឯង ជាលាភរបស់ជនទាំងនោះ គឺរបស់អ្នកវិទេហរដ្ឋ និងអ្នកក្រុងមិថិលា ដែលបាននៅរួមជាមួយអ្នក ព្រះបាទចូឡនីព្រហ្មទត្ត មានព្រះតម្រាស់ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វបានបង្ហាញបន្ទប់ ១០១ ដល់ព្រះបាទចូឡនី កាលទ្វារបន្ទប់មួយបើក ទ្វារទាំងអស់ក៏បើក កាលបន្ទប់មួយបិទ ទ្វារទាំងអស់ក៏បិទ កាលព្រះរាជាទតទៅខាងមុខ មហោសថទៅឯក្រោយ សេនាទាំងពួងក៏ចូលកាន់ឧមង្គ ព្រះរាជាយាងចេញចាកឧមង្គ មហោសថដឹងថា ទ្រង់យាងចេញ ទើបចេញមកដែរ មិនឲ្យជនទាំងឡាយចេញ បិទទ្វារឧមង្គដោយជាន់គន្លឹះយន្ត ទ្វារធំ ៨០ ទ្វារតូច ៦៤ ទ្វារបន្ទប់ ១០១ និងគោមប្រើនរយ ក៏បិទព្រមគ្នា ឧមង្គទាំងមូល ក៏ងងឹតហាក់បីដូចលោកន្តរនរក មហាជនខ្លាចផង តក់ស្លុតចំពោះមរណភ័យផង ព្រះមហាសត្វចាប់យកដាវដែលខ្ទនកប់ក្នុងខ្សាច់ កាលពីម្សិលមិញ ហើយលោតទៅក្នុងអាកាសកម្ពស់ ១៨ ហត្ថ ចុះមកអំពីអាកាស ចាប់ព្រះហស្តព្រះបាទចូឡនីព្រហ្មទត្ត ងាដាវឲ្យទ្រង់តក់ស្លុត សួរថា រាជសម្បត្តិក្នុងសកលជម្ពូទ្វីបជារបស់អ្នកណា ព្រះរាជាកិតភ័យត្រាស់តបថា ជារបស់អ្នក ហើយត្រាស់ថា ចូរអ្នកឲ្យអភ័យដល់យើង ។ មហោសថទូលថា សូមទ្រង់កុំតក់ស្លុតឡើយ ទូលបង្គំចាប់ដាវដោយប្រាថ្នានឹងផ្តាច់ព្រះជន្មក៏មិនមែន ទូលបង្គំចាប់ដើម្បីសម្តែងបញ្ញានុភាពរបស់ទូលបង្គំ

ទូលដូច្នេះហើយ ថ្វាយដាវនោះចំពោះព្រះហស្តព្រះរាជា ។ លំដាប់នោះ មហោសថទូលនឹងព្រះរាជា ដែលទ្រង់កាន់ដាវប្រថាប់ឈរថា បពិត្រមហារាជ បើទ្រង់ប្រាថ្នានឹងសម្លាប់ទូលបង្គំ ក៏ចូរសម្លាប់ដោយដាវនេះ បើទ្រង់ប្រាថ្នាប្រទានអភ័យ ក៏ចូរព្រះរាជទាន ព្រះរាជាត្រាស់តបថា នែបណ្ឌិត យើងឲ្យអភ័យដល់អ្នក អ្នកកុំគិតថ្វីឡើយ ។ ព្រះបាទចូឡនីព្រហ្មទត្ត និងមហោសថ-ពោធិសត្វទាំងពីរ ចាប់ដាវ ធ្វើសម្បថ មិនប្រទូស្តដល់គ្នានិងគ្នា ។ លំដាប់នោះ ព្រះបាទចូឡនីត្រាស់នឹងព្រះពោធិសត្វថា នែបណ្ឌិត អ្នកជាបុគ្គលដល់ព្រមដោយកម្លាំងបញ្ញាយ៉ាងនេះ ហេតុអ្វីមិនយករាជសម្បត្តិ មហោសថទូលថា បើទូលបង្គំចង់បាន ក៏នឹងសម្លាប់ព្រះរាជាក្នុងសកលជម្ពូទ្វីបក្នុងថ្ងៃនេះ ហើយយករាជសម្បត្តិ តែការសម្លាប់អ្នកដទៃ ហើយកាន់យកយស អ្នកប្រាជ្ញទាំងឡាយ មិនសរសើរឡើយ លំដាប់នោះ ព្រះរាជាត្រាស់ថា នែបណ្ឌិត មហាជនចេញអំពីឧម្មង្គមិនបាន ក៏នឹងខ្សឹកខ្សួល ចូរអ្នកបើកឧម្មង្គឲ្យជីវិតដល់មហាជន ។ មហោសថបើកទ្វារឧម្មង្គទាំងមូល ឲ្យមានពន្លឺដូចគ្នា មហាជនក៏បានទូវសេចក្ដីត្រេកអរ ។ ព្រះរាជាទាំងពួងចេញពីឧម្មង្គជាមួយសេនា ទៅកាន់សម្នាក់មហោសថៗ ស្ថិតនៅត្រង់មហាព្រះពន្លា ជាមួយនឹងព្រះបាទចូឡនី ។ លំដាប់នោះ ព្រះរាជាទាំងនោះត្រាស់នឹងមហោសថថា ពួកយើងបានជីវិតព្រោះអាស្រ័យអ្នក បើអ្នកមិនបើកទ្វារឧម្មង្គមួយសន្ទុះទៀត ពួកយើងទាំងឡាយក៏នឹងស្លាប់ក្នុងឧម្មង្គនោះឯង ។ មហោសថទូលថា បពិត្រមហារាជទាំងឡាយ ទ្រង់មិនអស់ព្រះជន្ម ព្រោះអាស្រ័យទូលបង្គំតែក្នុង

កាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ទ្រង់ក៏បានអាស្រ័យទូលបង្គំ ទើបតម្កល់ព្រះជន្មនៅបាន ព្រះរាជាទាំងនោះត្រាស់សួរថា នែបណ្ឌិត តើក្នុងកាលណា មហោសថក៏ទូលថា បើយ៉ាងនោះ សូមទ្រង់ស្តាប់ ទ្រង់រឭកដល់កាលព្រះបាទចូឡនីដណ្តើមរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូលបាន វៀរលែងតែនគររបស់ទូលបង្គំ ហើយត្រឡប់ទៅឧត្តរបញ្ចាលរាជធានី ហើយរៀបចំស្រាជយបានៈដើម្បីផឹក ក្នុងឧទ្យានបានដែរឬទេ ព្រះរាជាទាំងនោះទទួលថា រឭកបាន មហោសថក៏ទូលថា ក្នុងកាលនោះ ព្រះបាទចូឡនី និងកេវដ្ដៈ មានគំនិតអាក្រក់ ដាក់ថ្នាំពុលដើម្បីផ្តាច់ព្រះជន្មទ្រង់ទាំងឡាយដោយសុរា ដែលប្រកបដោយថ្នាំពិស និងត្រី សាច់ជាដើម ពេលនោះ ទូលបង្គំគិតថា បើអញនៅមានជីវិត សូមស្តេចទាំងឡាយកុំបាត់បង់ព្រះជន្ម មិនមានទីពឹងឡើយ គិតដូច្នេះ ទើបបញ្ជូនមនុស្សរបស់ទូលបង្គំទៅ ឲ្យវាយបំបែកភាជនៈទាំងពួង ទម្លាយគំនិតជនទាំងនោះ បានឲ្យជីវិតដល់ទ្រង់ទាំងឡាយ ។ ព្រះរាជាទាំងនោះបានស្តាប់ពាក្យរបស់មហោសថ ក៏មានព្រះហឫទ័យស្រៀវខ្លាច ទើបទូលសួរព្រះបាទចូឡនីថា បពិត្រព្រះអង្គ ពិត ឬមិនពិត ព្រះបាទចូឡនីត្រាស់ថា ពិត ខ្ញុំជឿពាក្យអាចារ្យកេវដ្ដៈបានធ្វើយ៉ាងនោះ មហោសថបណ្ឌិតពោលពិតនោះឯង ព្រះរាជាទាំងនោះ ក៏នាំគ្នាឱបក្រសោបព្រះមហាសត្វ ត្រាស់ថា នែបណ្ឌិត អ្នកបានជាទីពឹងរបស់ខ្ញុំ ពួកខ្ញុំបានរួចជីវិតព្រោះអ្នក ត្រាស់ដូច្នេះហើយ បូជាព្រះមហាសត្វដោយរាជាភរណៈទាំងពួង ។ មហោសថទូលព្រះបាទចូឡនីយ៉ាងនេះថា បពិត្រមហារាជ ទ្រង់កុំគិតឡើយ នុ៎ះជាទោសនៃការ

សេពមិត្តអាក្រក់នោះឯង សូមទ្រង់ញ៉ាំងព្រះរាជាទាំងនោះ ឲ្យអត់ទោស ព្រះរាជាព្រហ្មទត្តត្រាស់ថា ខ្ញុំបានធ្វើកម្មបែបនេះដល់ពួកទ្រង់ព្រោះអាស្រ័យមិត្តអាក្រក់ នុ៎ះជាកំហុសរបស់ខ្ញុំ សូមទ្រង់ទាំងឡាយអត់នូវទោសដល់ខ្ញុំ ខ្ញុំនឹងមិនធ្វើកម្មបែបនេះទៀតឡើយ ត្រាស់ដូច្នេះហើយ ឲ្យព្រះរាជាទាំងនោះអត់ទោស ព្រះរាជាទាំងនោះសម្តែងទោសដល់គ្នានិងគ្នា ហើយជាអ្នកព្រមព្រៀងត្រេកអរចំពោះគ្នានិងគ្នា ។ លំដាប់នោះ ព្រះបាទចូឡនីឲ្យនាំខាទនីយៈ និងភោជនីយៈជាច្រើន និងតន្ត្រី គ្រឿងក្រអូប ផ្កាជាដើមមក លេងក្នុងឧទ្យានជាមួយក្សត្រទាំងពួងអស់ ១ សប្តាហ៍ហើយ ចូលកាន់ព្រះនគរ ឲ្យធ្វើសក្ការៈធំដល់មហាសត្វ ហោមរោមទៅដោយព្រះរាជា ១០១ ប្រថាប់គង់ក្នុងផ្ទៃព្រះរាជមន្ទីរ ត្រាស់ដោយមានព្រះរាជបំណងនឹងឲ្យមហោសថបណ្ឌិត នៅក្នុងរាជសម្នាក់របស់ព្រះអង្គថា

យើងនឹងឲ្យគ្រឿងចិញ្ចឹមជីវិត និងវត្ថុគ្រឿងរក្សា គឺស្រុក និងនិគម ទាំងបាយ និងថ្លៃឈ្នួល ជាទ្វេគុណដល់អ្នក ទាំងឲ្យភោគសម្បត្តិដ៏ធំទូលាយទៀត អ្នកចូរបរិភោគ ចូររីករាយតាមប្រាថ្នាចុះ អ្នកកុំទៅរកព្រះបាទវិទេហៈឡើយ ព្រះបាទវិទេហៈនឹងធ្វើអ្វីដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វុត្តឹ** បានដល់ គ្រឿងប្រព្រឹត្តទៅនៃជីវិតដែលអាស្រ័យបាន ។ បទថា **បរិហារំ** បានដល់ ឲ្យគាម និងនិគម ។ បទថា **ភត្តំ** បានដល់ អាហារ ។ បទថា **វេតនំ** បានដល់ ស្បៀង ។ បទថា **ភោគេ**

សេចក្តីថា យើងនឹងឲ្យភោគសម្បត្តិដែលបរិបូណ៌ដទៃៗ ដល់អ្នក ។

ចំណែកមហោសថបណ្ឌិត កាលទូលឃាត់ព្រះបាទចូឡនី បានទូលថា បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គលអ្នកចិញ្ចឹមព្រោះហេតុនៃទ្រព្យ បុគ្គលនោះ ត្រូវជនទាំងពីរ គឺខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់គង់ព្រះជន្មាយុដរាបណា ខ្ញុំក៏មិនគប្បីនៅក្នុងដែននៃព្រះរាជាដទៃ ( ដរាបនោះ ) ។ បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គល អ្នកចិញ្ចឹមព្រោះហេតុនៃទ្រព្យ បុគ្គលនោះ ត្រូវជនទាំងពីរ គឺខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់ស្ថិតនៅដរាបណា ខ្ញុំមិនត្រូវជាបុរសរបស់បុគ្គលដទៃ ( ដរាបនោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្តនោ ច បរស្ស ច** សេចក្តីថា បុគ្គលរមែងតិះដៀលខ្លួនថា បាបបែបនេះដែលអញលះបុគ្គល ដែលចិញ្ចឹមខ្លួនព្រោះហេតុនៃទ្រព្យធ្វើហើយ សូម្បីបុគ្គលដទៃ ក៏រមែងតិះដៀលដោយហេតុនេះថា បុគ្គលនេះមានធម៌លាមក លះបង់បុគ្គលអ្នកចិញ្ចឹមខ្លួនមក ព្រោះហេតុនៃទ្រព្យ ព្រោះហេតុនោះ កាលព្រះបាទវិទេហរាជតាំងព្រះជន្មនៅ ទូលបង្គំមិនអាចនៅក្នុងដែនរបស់ព្រះរាជាដទៃបានឡើយ ។

គ្រានោះ ព្រះបាទចូឡនីត្រាស់នឹងមហោសថថា នែបណ្ឌិត បើដូច្នោះ ចូរអ្នកឲ្យបដិញ្ញាថា នឹងមកក្នុងនគរនេះ ក្នុងកាលដែលព្រះរាជារបស់អ្នកសោយទិវង្គតហើយ ។ មហោសថទូលថា សាធុ បើទូលបង្គំនៅមានជីវិត នឹងមក ។

លំដាប់នោះ ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់ធ្វើមហាសក្ការៈដល់ព្រះពោធិសត្វ អស់ ១ សប្តាហ៍ កាលកន្លងទៅ ១ សប្តាហ៍ទៀត ពេលដែលមហោសថទូលលា កាលនឹងត្រាស់ថា នែបណ្ឌិត យើងឲ្យវត្ថុនេះៗ ដល់អ្នក ទើបពោលគាថានេះថា

ម្នាលមហោសធ យើងឲ្យមាសនេក្ខារ ១០០០ និងស្រុកចំនួន ៨០ ក្នុងដែនកាសីដល់អ្នក យើងឲ្យទាសី ៤០០ និងភរិយា ១០០ ដល់អ្នក អ្នកចូរនាំអង្គនៃសេនាទាំងពួងទៅដោយសួស្តីចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និក្ខសហស្សំ** សេចក្តីថា ៥ សុវណ្ណៈ ជា ១ និក្ខៈ ឲ្យមាស ១ ពាន់និក្ខៈ ។ បទថា **គាមា** សេចក្តីថា ស្រុកពួកណាទារនូវសួយបានមួយឆ្នាំ ១ សែនកហាបណៈ យើងឲ្យស្រុកទាំងនោះដល់អ្នក ។ បទថា **កាសិសុ** បានដល់ ក្នុងដែនរបស់អ្នកកាសី ។

កាសិរដ្ឋនោះ នៅក្បែរវិទេហរដ្ឋ ព្រោះដូច្នោះ ទើបព្រះបាទចូឡនីប្រទានស្រុក ៨០ ក្នុងកាសិករដ្ឋនោះដល់មហោសថ ចំណែកមហោសថទូលដល់ព្រះបាទចូឡនីថា ព្រះអង្គទ្រង់កុំវិតក្កដល់ព្រះរាជវង្សឡើយ ទូលបង្គំបានផ្តាំព្រះរាជារបស់ទូលបង្គំ ក្នុងកាលទ្រង់យាងទៅដល់ក្រុងមិថិលាថា សូមទ្រង់តាំងព្រះនាងនន្ទាទេវី ក្នុងតំណែងជាព្រះរាជមាតា សូមតាំងបញ្ចាលចន្ទកុមារ ក្នុងតំណែងព្រះកនិដ្ឋភាតា ទូលដូច្នោះហើយ បានអភិសេកព្រះនាងបញ្ចាលចន្ទីរាជធីតារបស់ព្រះអង្គ និងព្រះបាទវិទេហរាជ ហើយទើបបញ្ជូនព្រះបាទវិទេហរាជទៅ ទូលបង្គំនឹងនាំព្រះរាជមាតា ព្រះនាងនន្ទាទេវី

និងព្រះរាជឱរសរបស់ព្រះអង្គមកដោយឆាប់នោះឯង ព្រះបាទចូឡនីព្រហ្មទត្ត ត្រាស់ថា សាធុ បណ្ឌិត ហើយញុំាងមហោសថឲ្យទទួលរង្វាន់ អ្នកបម្រើ ប្រុស ស្រី គោ ក្របី និងគ្រឿងប្រដាប់ និងមាសប្រាក់ ដំរី សេះ រថ ដែលតាក់តែងហើយជាដើម ដែលគប្បីព្រះរាជទានដល់ព្រះរាជធីតាដោយ ព្រះតម្រាស់ថា អ្នកគប្បីឲ្យទ្រព្យទាំងនេះ ដល់បញ្ចាលចន្ទីរាជបុត្ររបស់ យើង កាលទ្រង់ពិចារណាកិច្ចដែលគួរធ្វើដល់សេនា ពាហនៈ ទើបត្រាស់ថា

ជនទាំងឡាយ ចូរឲ្យវត្ថុផ្សេងៗ ជាទេយ្យគុណ ដល់ពួកដំរី ពួក សេះជាកំណត់ ចូរញុំាងពលរថ និងពលថ្មើរជើង ឲ្យឆ្អែតស្កប់ ស្កល់ ដោយបាយ និងទឹកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាវ** សេចក្តីថា មិនមែនបន្ថែមត្រឹមតែពីរ ដងតែម្យ៉ាងប៉ុណ្ណោះឡើយ ព្រះបាទចូឡនីត្រាស់ថា ចូរឲ្យអាហារ មានបាយ ដំណើប និងស្រូវសាលីជាដើមដល់ដំរី និងសេះទាំងឡាយរហូតគ្រប់គ្រាន់ ។ បទថា **តប្បេន្តុ** សេចក្តីថា ចូរឲ្យតាមដែលទៅមិនលំបាកក្នុងរវាងផ្លូវឲ្យឆ្អែត ស្កប់ស្កល់ ។

កាលត្រាស់យ៉ាងនេះហើយ កាលទ្រង់បញ្ជូនមហោសថបណ្ឌិតទៅ ទើប ត្រាស់ថា

ម្នាលបណ្ឌិត អ្នកចូរនាំយកពួកដំរី ពួកសេះ ពួករថ និងពួក ពលថ្មើរជើងទៅ ព្រះបាទវិទេហមហារាជ ចូរទតឃើញអ្នក ដែលទៅដល់ក្រុងមិថិលាចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិថិលំ គតំ** សេចក្តីថា សូមព្រះបាទវិទេហរាជ ទតឃើញអ្នកដល់ក្រុងមិថិលាដោយសួស្តី ។

ព្រះបាទចូឡនីទ្រង់ធ្វើសក្ការៈធំ ដល់មហោសថបណ្ឌិត ហើយបញ្ជូនទៅដោយប្រការដូច្នេះ សូម្បីព្រះរាជា ១០១ នោះ ក៏ធ្វើមហាសក្ការៈប្រទានបណ្ណាការជាច្រើន ចំណែកពួកបុរសដែលមហោសថបន្កប់ក្នុងសម្នាក់របស់ព្រះរាជា ១០១ ក៏ចោមរោមមហោសថៗ ធ្វើដំណើរទៅដោយបរិវារច្រើនក្នុងរវាងផ្លូវ បានបញ្ជូនមនុស្សទៅទារសួយត្រង់ស្រុកដែលព្រះបាទចូឡនីប្រទានដល់វិទេហរដ្ឋហើយ ។ ចំណែកអាចារ្យសេនកៈ បានដាក់មនុស្សក្នុងរវាងផ្លូវប្រាប់ថា ចូរអ្នកមើលព្រះបាទចូឡនីយាងមក ឬមិនយាងមក ហើយបុគ្គលណាមក ក៏ចូរប្រាប់យើង ចំណែកបុគ្គលដែលទទួលពាក្យរបស់អាចារ្យសេនកៈ ឃើញមហោសថមកអំពីចម្ងាយ ប្រមាណ ៣ យោជន៍ ក៏មកប្រាប់ដល់សេនកៈថា មហោសថ និងបរិវារជាច្រើននាំគ្នាមក ។ សេនកៈបានស្តាប់ព្រឹត្តិហេតុ ទើបទៅកាន់រាជសម្នាក់ ។ ចំណែកព្រះបាទវិទេហរាជប្រថាប់នៅក្នុងផ្ទៃប្រាសាទ ទតខាងក្រៅតាមបង្អួចឃើញទ័ពធំ ទ្រង់ត្រិះរិះថា សេនារបស់មហោសថតិច សេនានេះប្រាកដច្រើនពន់ពេក ព្រះបាទចូឡនីយាងមកទេដឹងហ្ន៎ ទ្រង់គិតដូច្នេះ ក៏ទ្រង់ភ័យខ្លាច កាលត្រាស់សួរអាចារ្យទាំង ៤ ទើបត្រាស់ថា

សេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ
និងសេនាថ្មើរជើងនោះ ប្រាកដជាមានច្រើន មានសភាពគួរខ្លាច

តើបណ្ឌិតទាំងឡាយ សម្គាល់ដូចម្ដេចហ្ន៎ ដូច្នេះ ។

លំដាប់នោះ សេនកៈកាលក្រាបទូលសេចក្ដីនោះ ទើបពោលថា

បពិត្រមហារាជ សេចក្ដីត្រេកអរ យ៉ាងខ្ពង់ខ្ពស់ រមែងប្រាកដដល់

ព្រះអង្គ មហោសធនាំយកអង្គនៃសេនាទាំងពួង មកដល់ហើយ

ដោយសួស្ដី ដូច្នេះ ។

ព្រះបាទវិទេហរាជទ្រង់បានស្ដាប់ពាក្យរបស់សេនកៈ ទើបត្រាស់ថា នែសេនកៈ សេនារបស់មហោសថបណ្ឌិតមានតិច តែសេនានេះច្រើន ។ សេនកៈទូលថា មហោសថនឹងធ្វើឲ្យព្រះបាទចូឡនីជ្រះថ្លា ព្រះបាទចូឡនីទ្រង់ជ្រះថ្លាហើយ នឹងព្រះរាជទានសេនាដល់មហោសថ ព្រះបាទវិទេហរាជ ទើបឲ្យយកស្គរវាយប្រកាសក្នុងព្រះនគរថា អ្នកនគរទាំងឡាយ ចូរតាក់តែងព្រះនគរទទួលមហោសថបណ្ឌិត អ្នកនគរក៏ធ្វើតាមប្រកាស ។ មហោសថចូលព្រះនគរទៅកាន់រាជសម្នាក់ ថ្វាយបង្គំព្រះបាទវិទេហរាជ ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះ ព្រះបាទវិទេហរាជ ទ្រង់ក្រោកឡើង ឱបក្រសោបមហោសថ ហើយប្រថាប់លើបល្ល័ង្កដ៏ប្រសើរ កាលទ្រង់ធ្វើបដិសណ្ឋារៈ ទើបត្រាស់ថា

ម្នាលមហោសធ ជនទាំង ៤ នាក់ នាំមនុស្សស្លាប់ ទៅចោលក្នុង

ព្រៃស្មសាន ( ហើយត្រឡប់មក ) យ៉ាងណា ពួកយើងបោះបង់

អ្នកចោលក្នុងដែនកប្បិលៈ ហើយត្រឡប់មកក្នុងទីនេះ ក៏ដូច្នោះ ។

កាលបើដូច្នេះ អ្នកចេះដោះខ្លួនឲ្យរួចមក ដោយហេតុដូចម្ដេច

ដោយបច្ច័យដូចម្តេច ដោយដំណើរដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុរោ ជនា** សេចក្តីថា នែបណ្ឌិត មនុស្ស ៤ នាក់ នាំអ្នកស្លាប់ទៅព្រៃខ្មោចដោយគ្រែ បោលសាកសពក្នុងព្រៃខ្មោច នោះ មិនក្រឡេកមើលហើយទៅ យ៉ាងណា ពួកយើងបោះបង់អ្នកក្នុង កបិលរដ្ឋ មកក្នុងទីនេះ ក៏ដូច្នោះ ។ បទថា **វណ្ណេន** បានដល់ ដោយហេតុ ។ បទថា **ហេតុនា** បានដល់ ដោយបច្ច័យ ។ បទថា **អត្ថជាតេន** បានដល់ ដោយផល ។ បទថា **បរិមោចយិ** សេចក្តីថា ព្រះបាទវិទេហរាជត្រាស់សួរ មហោសថថា អ្នកធ្លាក់ក្នុងកណ្តាប់ដៃរបស់សត្រូវ ដោះខ្លួនមកបានដោយ ហេតុអ្វី ដោយបច្ច័យអ្វី ដោយផលអ្វី ។

លំដាប់នោះ មហាសត្វទូលថា

បពិត្រក្សត្រព្រះនាមវិទេហៈ ទូលព្រះបង្គំបានការពារនូវសេចក្តី
ដោយសេចក្តី នូវការប្រឹក្សាដោយប្រឹក្សា ទូលព្រះបង្គំបាន
ការពារស្តេច ដូចជាសាគរការពារជម្ពូទ្វីប ដូច្នោះ ។

អត្ថនៃគាថានោះថា បពិត្រមហារាជ ទូលបង្គំការពារសេចក្តីដែលជន ទាំងនោះគិត ដោយសេចក្តីដែលទូលបង្គំគិតហើយ ទូលបង្គំការពារការគិត ដែលជនទាំងនោះគិត ដោយការគិតរបស់ទូលបង្គំ មិនតែប៉ុណ្ណោះ ទូលបង្គំ បានការពារព្រះរាជាទាំងនោះ មានព្រះរាជា ១០១ ជាបរិវារដល់ម៉្លោះ នោះឯង ដូចសមុទ្រព័ទ្ធជម្ពូទ្វីប ដូច្នោះ មហោសថពោលកម្មដែលខ្លួនធ្វើ ទាំងអស់ដោយពិស្តារ ។

ព្រះបាទវិទេហរាជបានស្តាប់ដូច្នោះហើយ ទ្រង់សោមនស្ស ។ លំដាប់នោះ មហោសថបណ្ឌិត កាលនឹងទូលដល់បណ្ណាការ ដែលព្រះបាទចូឡនីប្រទានដល់ខ្លួនឲ្យទ្រង់ជ្រាប ទើបទូលថា

ព្រះបាទចូឡនី បានប្រទានមាសគ្គោរ ១០០០ និងស្រុកចំនួន ៨០
ក្នុងដែនកាសី ដល់ទូលព្រះបង្គំ ប្រទានទាសី ៤០០ និងភរិយា
១០០ ដល់ទូលព្រះបង្គំ ទូលព្រះបង្គំ ជាអ្នកនាំអង្គនៃសេនាទាំង
ពួង មកក្នុងទីនេះដោយសួស្តី ដូច្នេះ ។

បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ត្រេកអរពន់ពេក កាលត្រាស់សរសើរគុណរបស់មហាសត្វ ទើបទ្រង់បន្លឺឧទានថា

នៃអាចារ្យសេនកៈ កាលនៅរួមជាមួយនឹងអ្នកប្រាជ្ញ នាំមកនូវ
សេចក្តីសុខស្រួលណាស់ហ្ន៎ មហោសធ បានដោះពួកយើង
ដែលតាំងនៅក្នុងសេចក្តីវិនាស គឺដៃនៃសត្រូវ ដូចជាគេដោះ
ហ្វូងបក្សី ដែលជាប់នៅក្នុងទ្រុង ឬដូចជាគេដោះត្រី ដែលជាប់
នៅក្នុងសំណាញ់ ដូច្នេះ ។

ចំណែកសេនកបណ្ឌិត កាលទទួលព្រះរាជតម្រាស់ បានពោលគាថាដូច្នេះថា

បពិត្រមហារាជ មែនពិត ពួកបណ្ឌិត រមែងនាំមកនូវសេចក្តីសុខ
យ៉ាងនេះឯង មហោសធបានដោះពួកយើង ដែលតាំងនៅក្នុង
សេចក្តីវិនាស គឺដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សី ដែលជាប់

ក្នុងទ្រុង ឬដូចជាគេដោះត្រី ដែលជាប់ក្នុងសំណាញ់ ដូច្នេះ ។

លំដាប់នោះ ព្រះបាទវិទេហរាជឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា អ្នកក្រុងចូរលេងមហោស្រពធំអស់មួយសប្តាហ៍ មនុស្សពួកណាមានសេចក្តីស្រឡាញ់ក្នុងខ្ញុំយើង មនុស្សទាំងនោះ ចូរធ្វើសក្ការៈដល់មហោសថបណ្ឌិតចុះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វិសេដ្ឋិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសាទូវព្រះគាថាដូច្នេះថា

ពួកជន ចូរដេញពិណា ចូរវាយស្គរតូច និងស្គរធំ ផ្លុំស័ង្ខ ដែល
កើតក្នុងដែនមគធៈ និងទូងស្គរធំ មានសំឡេងពីរោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាហញ្ញន្តុ** បានដល់ ចូរប្រគំតន្ត្រី ។ បទថា **មាគធា សង្ខា** សេចក្តីថា រាប់ថា កើតក្នុងមគធរដ្ឋ ។ បទថា **ទុន្ទុភី** បានដល់ ស្គរធំ ។

លំដាប់នោះ អ្នកនគរ និងអ្នកជនបទទាំងនោះ តាមប្រក្រតីក៏ប្រាថ្នានឹងធ្វើសក្ការៈដល់មហោសថបណ្ឌិតស្រាប់ហើយ កាលបានឮសំឡេងប្រកាសក៏បានធ្វើសក្ការៈដូចគ្នា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វិសេដ្ឋិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសាទូវព្រះគាថាដូច្នេះថា

ពួកស្រីស្នំ ពួកកុមារ ពួកវេស្សៈ និងពួកព្រាហ្មណ៍ នាំបាយ និងទឹកជាច្រើន មកជូន ( មហោសធបណ្ឌិត ) ។ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត ។ ពួកអ្នកជនបទប្រជុំគ្នា ទាំងពួកអ្នកនិគម ក៏មកប្រជុំគ្នា នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត ។ ជនជាច្រើន កាលបើបានឃើញបណ្ឌិតមកដល់ហើយ ក៏មានសេចក្តីជ្រះថ្លា កាលបើបណ្ឌិតមកដល់ហើយ ការលើកឡើងនូវទង់ក៏ប្រព្រឹត្តទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱរោធា ច** សេចក្តីថា ពួកស្រីស្នំ មានព្រះនាងឧទុម្ពរទេវីជាដើម ។ បទថា **អភិហារយុំ** សេចក្តីថា ឲ្យនាំទៅក្រៃលែង គឺបញ្ជូនទៅ ។ បទថា **ពហុជ្ជនោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ជនជាច្រើន ទាំងអ្នកនគរ ទាំងអ្នកស្រុកក្នុងទ្វារទាំង ៤ ទាំងអ្នកជនបទបានជ្រះថ្លាហើយ ។ បទថា **ទិស្វា បណ្ឌិតមាគតំ** សេចក្តីថា កាលមហោសថបណ្ឌិតមកក្រុងមិថិលា ឃើញមហោសថបណ្ឌិតនោះ ។ បទថា **បវត្តថ** សេចក្តីថា កាលមហោសថបណ្ឌិតដល់ក្រុងមិថិលា មហាជនត្រេកអរពោលថា មហោ-សថបណ្ឌិតនេះ ដោះព្រះរាជារបស់ពួកយើង ដែលធ្លាក់នៅក្នុងអំណាចរបស់បច្ចាមិត្តឲ្យផុតភ័យមុន ខាងក្រោយញុំាងព្រះរាជា ១០១ ឲ្យខមាទោសដល់គ្នានិងគ្នា ធ្វើឲ្យមានសាមគ្គី ញុំាងព្រះបាទចូឡនីឲ្យជ្រះថ្លា នាំយកយសធំដែលព្រះបាទចូឡនីប្រទានមកហើយ បានត្រឡប់ទៅវិញ ។

លំដាប់នោះ មហាសត្វទៅកាន់រាជសម្នាក់ ក្នុងថ្ងៃមហោស្រពក្រាបទូលថា បពិត្រព្រះសម្មតិទេព គួរទ្រង់បញ្ជូនព្រះរាជមាតា និងព្រះរាជទេវី និងព្រះរាជឱរសរបស់ព្រះបាទចូឡនីទៅដោយរហ័ស ព្រះបាទវិទេហរាជ ទ្រង់បានស្តាប់មហោសថ ក៏ត្រាស់ថា ប្រពៃហើយបា ចូរអ្នកបញ្ជូនទៅ ។ មហោសថធ្វើសក្ការៈធំដល់ក្សត្រទាំង ៣ និងធ្វើសក្ការសមានៈ ដល់សេនាដែលមកជាមួយខ្លួន បញ្ជូនក្សត្រទាំង ៣ នោះ មួយអន្ទើដោយពួកជនរបស់ខ្លួន ទៅដោយបរិវារច្រើន បញ្ជូនករិយា ១០០ និងទាសី ៤០០ ដែលព្រះបាទចូឡនីប្រទានដល់ខ្លួន ប្រគល់ថ្វាយទៅជាមួយព្រះនាងនន្ទាទេវី ហើយបញ្ជូនសូម្បីពួកសេនា ដែលមកជាមួយខ្លួនឲ្យទៅជាមួយជនទាំងនោះ ។

ព្រះនាងនន្ទាទេវីឱបក្រសោបព្រះរាជធីតា ថើបត្រង់សីសៈហើយត្រាស់ថា មាតាលាកូនទៅហើយ មាតាលាកូនទៅហើយ ត្រាស់ដូច្នេះហើយទ្រង់ព្រះកន្សែងដោយសព្ទសំនៀងដ៏ខ្លាំង ។ ចំណែកព្រះនាងបញ្ចាលចន្ទីដែលជាព្រះរាជធីតា ថ្វាយបង្គំព្រះរាជមាតាហើយ ព្រះនាងទ្រង់សោកសង្រេងថា សូមព្រះមាតាកុំបោះបង់កូន ក្សត្រទាំង ៣ ចេញអំពីព្រះនគរដោយបរិវារជាច្រើន ដល់ឧត្តរបញ្ចាលនគរដោយលំដាប់ ។ លំដាប់នោះព្រះបាទចូឡនីព្រហ្មទត្ត ត្រាស់សួរព្រះរាជមាតាថា បពិត្រព្រះមាតា ព្រះបាទវិទេហរាជទ្រង់ធ្វើអនុគ្រោះដល់ព្រះអង្គដូចម្តេច ព្រះនាងសលាករាជជននីត្រាស់តបថា បានិយាយអ្វី ព្រះបាទវិទេហរាជតាំងមាតាក្នុងឋានៈជាទេវតាបានធ្វើសក្ការៈដល់យើង តាំងនាងនន្ទាទេវីក្នុងឋានៈជាមាតា តាំងបញ្ចាល-

រាជកុមារក្នុងឋានៈជារាជកនិដ្ឋភាតា ព្រះបាទចូឡនីបានស្តាប់ព្រះរាជជននី ត្រាស់ ទ្រង់ក៏ត្រេកអរពន់ពេក ហើយបញ្ជូនព្រះរាជបណ្ណាការជាច្រើន ទៅថ្វាយព្រះបាទវិទេហរាជ ចាប់តាំងអំពីនោះ ស្តេចក្នុងនគរទាំងពីរ ក៏ព្រមព្រៀងគ្នានោះឯង ។

## មហាឧម្មង្គកណ្ឌ ចប់

ព្រះនាងបញ្ចាលចន្ទី បានជាទីស្រឡាញ់ ជាទីប្រោសប្រាណរបស់ព្រះបាទវិទេហរាជ ក្នុងឆ្នាំទី ២ ព្រះនាងក៏ប្រសូតព្រះរាជឱរស កាលព្រះរាជ-ឱរសនោះ ព្រះជន្មបាន ១០ ឆ្នាំ ព្រះបាទវិទេហរាជក៏សោយទិវង្គត ។ មហោសថពោធិសត្វ បានថ្វាយរាជសម្បត្តិ ដល់ព្រះរាជកុមារនោះ ហើយទូលលាថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងទៅកាន់រាជសម្នាក់របស់ព្រះបាទចូឡនី ព្រះអយ្យការបស់ព្រះអង្គ ព្រះរាជាត្រាស់ថា នែបណ្ឌិត អ្នកកុំបោះបង់យើងដែលជាកុមារឡើយ យើងតាំងអ្នកក្នុងតំណែងជាបិតា នឹងធ្វើសក្ការៈបូជា សូម្បីព្រះនាងបញ្ចាលចន្ទី ដែលជាព្រះជននី ក៏ត្រាស់អង្វរព្រះពោធិសត្វថា នែបណ្ឌិត ក្នុងកាលអ្នកទៅហើយ ទីពឹងដទៃរបស់យើងមិនមាន អ្នកកុំទៅឡើយ មហោសថទូលថា ទូលបង្គំបានថ្វាយប្តេជ្ញាដល់ព្រះបាទចូឡនី ទូលបង្គំមិនអាចនឹងមិនទៅបានទេ កាលមហាជនកំពុងយំ ដ៏គួរអាណោច មហោសថក៏នាំពួកឧបដ្ឋាករបស់ខ្លួនចេញអំពីព្រះនគរ ដល់ឧត្តរ-បញ្ចាលរាជធានី ព្រះបាទចូឡនីជ្រាបថា មហោសថមកដល់ ក៏យាងទៅទទួលឲ្យមហោសថចូលព្រះនគរដោយបរិវារច្រើន ប្រទានឋានៈធំដល់មហោសថ

ហើយប្រទានស្រុក ៨០ ដែលប្រទានហើយកាលពីដំបូង និងភោគសម្បត្តិដទៃៗ មហោសថក៏ទទួលរាជការក្នុងរាជសម្នាក់នោះ ។

ក្នុងកាលនោះ មានបរិព្វាជិកាម្នាក់ ឈ្មោះភេរី ចូលទៅឆាន់ក្នុងព្រះរាជនិវេសន៍ នាងជាបណ្ឌិតឈ្លាសវៃ នាងមិនធ្លាប់ឃើញមហោសថ បានឮតែកិត្តិសព្ទថា មហោសថអ្នកបម្រើព្រះរាជា សូម្បីមហោសថ ក៏មិនធ្លាប់ឃើញបរិព្វាជិកា បានឮតែកិត្តិសព្ទថា បរិព្វាជិកាឈ្មោះភេរីឆាន់ក្នុងព្រះរាជដ្ឋាន ។

ចំណែកព្រះនាងនន្ទាទេវី មិនពេញព្រះហឫទ័យក្នុងព្រះពោធិសត្វថា មហោសថធ្វើបិយវិប្បយោគឲ្យអញលំបាក ទើបព្រះនាងត្រាស់នឹងស្រ្តីដែលជិតស្និទ្ធ ៥០០ ថា នាងទាំងឡាយ ចូរព្យាយាមរកទោសរបស់មហោសថណាមួយ ហើយញុះញង់រវាងព្រះរាជាឲ្យបែកគ្នា ស្រ្តីទាំងនោះត្រាច់ស្វែងរកទោសរបស់មហោសថ ថ្ងៃមួយ បរិព្វាជិកានោះឆាន់ហើយចេញទៅ បានឃើញព្រះពោធិសត្វមកកាន់រាជឧបដ្ឋាកត្រង់ព្រះលាន ព្រះពោធិសត្វថ្វាយបង្គំបរិព្វាជិកាហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង បរិព្វាជិកាគិតថា បានឮថា មហោសថនេះជាបណ្ឌិត អញនឹងដឹងភាពដែលគេជាបណ្ឌិត ឬមិនមែនបណ្ឌិតសិន កាលនឹងសួរបញ្ហាដោយសញ្ញាដៃ ទើបសម្លឹងមើលមហោសថហើយលាដៃចេញ បានឮថា នាងសួរបញ្ហាដោយចិត្តថា ព្រះបាទចូឡនីនាំមហោសថមកអំពីប្រទេសដទៃ ឥឡូវនេះ ទ្រង់ឲ្យតំណែងអ្វី ឬមិនបានឲ្យទេ ព្រះពោធិសត្វដឹងថា នាងភេរីបរិព្វាជិកាសួរបញ្ហាដោយសញ្ញានៃដៃ កាលនឹង

ឆ្លើយបញ្ហា ទើបក្ដាប់ដៃតប បានឮថា មហោសធ ឆ្លើយបញ្ហាដោយចិត្តថា បពិត្រអ្នកនាងម្ចាស់ ព្រះរាជាទ្រង់ទទួលប្ដេជ្ញារបស់ខ្ញុំ ហើយឲ្យហៅមកឥឡូវនេះ ជាបុគ្គលដូចគ្នានឹងក្ដាប់ដៃយ៉ាងមាំ មិនព្រះរាជទានតំណែងអ្វីមួយ ដែលទ្រង់មិនធ្លាប់ព្រះរាជទានដល់ខ្ញុំ នាងកេរីដឹងកាសារបស់មហោសថ ទើបលើកដៃឡើង អង្អែលក្បាលរបស់ខ្លួន នាងចង់សម្ដែងបញ្ហានោះ ដោយកិរិយានោះថា នៃបណ្ឌិត បើអ្នកលំបាក ហេតុអ្វីក៏មិនបួសដូចយើង មហាសត្វដឹងសេចក្ដីនោះ ក៏អង្អែលពោះរបស់ខ្លួន បង្ហាញសេចក្ដីនោះដោយកិរិយាថា បពិត្រអ្នកនាងម្ចាស់ កូន និងប្រពន្ធរបស់ខ្ញុំ ត្រូវការអ្នកចិញ្ចឹម ព្រោះហេតុនោះ ទើបខ្ញុំមិនទាន់បួស នាងកេរីសួរបញ្ហាដោយសញ្ញានៃដៃ ហើយ ទៅកាន់អាវាសរបស់ខ្លួន ចំណែកមហោសធថ្វាយបង្គំនាងហើយទៅកាន់រាជុបដ្ឋាន ។

ចំណែកស្ត្រីជិតស្និទ្ធរបស់ព្រះនាងនន្ទាទេវី ឈរត្រង់មាត់បង្អួច ឃើញកិរិយានោះ ទើបចូលទៅគាល់ព្រះបាទចូឡនី ទូលញុះញង់ថា បពិត្រព្រះសម្មតិទេព មហោសថ និងនាងកេរីបរិព្វាជិកា ជាអ្នកប្រាថ្នានឹងដណ្ដើមរាជសម្បត្តិ រមែងជាសត្រូវរបស់ព្រះអង្គ ព្រះរាជាបានស្ដាប់ពាក្យនោះ ទើបត្រាស់ថា ពួកនាងបានឃើញ ឬបានឮអ្វី ស្ត្រីទាំងនោះទូលថា បពិត្រមហារាជ បរិព្វាជិកាឆាន់ហើយចុះអំពីប្រាសាទ ឃើញមហោសថលាដៃចេញឲ្យសញ្ញាថា លោកអាចធ្វើព្រះរាជាឲ្យដូចជាបាតដៃ ឬឲ្យដូចជាលានស្រូវ ហើយធ្វើរាជសម្បត្តិឲ្យដល់កណ្ដាប់ដៃរបស់ខ្លួន ចំណែកមហោសថ កាល

សម្តែងអាការចាប់ដាវ បានក្តាប់ដៃបញ្ជាក់ថា យើងនឹងកាត់ក្បាលព្រះរាជា ដោយថ្ងៃកន្ទង់ទៅបន្តិចបន្តួច ហើយធ្វើរាជសម្បត្តិឲ្យដល់កណ្តាប់ដៃរបស់ខ្លួន បរិព្វាជិកាលើកដៃរបស់ខ្លួនឡើងអង្អែលក្បាលឲ្យដឹងថា អ្នកកាត់តែក្បាលរបស់ព្រះរាជាប៉ុណ្ណោះឬ មហោសថអង្អែលពោះ ចង់ឲ្យដឹងថា យើងនឹងកាត់ត្រង់ពាក់កណ្តាលខ្លួនផង បពិត្រមហារាជ សូមទ្រង់កុំប្រមាទ ទ្រង់គួរសម្លាប់មហោសថជាមុន ព្រះបាទចូឡនីបានស្តាប់ពាក្យរបស់ស្រីទាំងនោះ ទើបទ្រង់ត្រិះរិះថា មហោសថមិនអាចប្រទូស្តក្នុងអញ អញនឹងសួរបរិព្វាជិកានឹងដឹងសេចក្តី ក្នុងថ្ងៃមួយទៀត ក្នុងកាលបរិព្វាជិកាឆាន់ហើយ ព្រះរាជាចូលទៅរកនាង ត្រាស់សួរថា បពិត្រអ្នកនាងម្ចាស់ៗ ជួបមហោសថដែរឬ នាងទូលថា ម្សិលមិញនេះ អាត្មាឆាន់ហើយ ចេញទៅអំពីទីនេះបានជួបមហោសថ ព្រះរាជាត្រាស់ថា អ្នកនាងម្ចាស់បានចរចា សន្ទនាអ្វីដែរឬទេ នាងទូលថា មិនបាននិយាយគ្នាឡើយ តែអាត្មាបានឮថា គេជាអ្នកប្រាជ្ញ ទើបសួរបញ្ហាដោយសញ្ញាដៃ ដោយមនសិការថា បើគេជាអ្នកប្រាជ្ញ គេនឹងដឹងបញ្ហានេះ ទើបលាដៃចេញឲ្យសញ្ញាថា ព្រះរាជារបស់អ្នកមានព្រះហស្តលា ឬមានព្រះហស្តក្តាប់ គឺបានសង្គ្រោះអ្វីដល់អ្នកខ្លះ ឬមិនបានសង្គ្រោះទេ មហោសថបានក្តាប់ដៃឲ្យដឹងថា ព្រះរាជាទទួលបដិញ្ញារបស់ខ្ញុំ ហើយហៅមកឥឡូវនេះ មិនបានព្រះរាជទានអ្វី ពេលនោះ អាត្មាក៏ស្ទាបក្បាលជាសញ្ញាថា បើអ្នកលំបាក ហេតុអ្វី ទើបមិនបួសដូចអាត្មា មហោសថអង្អែលពោះរបស់ខ្លួនឲ្យដឹងថា ខ្ញុំត្រូវចិញ្ចឹមករិយា និងកូនច្រើន និងត្រូវឲ្យពេញពោះមិនមែន

តិច ហេតុនេះ ទើបបួសមិនបាន ។ ព្រះរាជាត្រាស់សួរថា បពិត្រអ្នកនាងម្ចាស់ មហោសថជាអ្នកប្រាជ្ញឬ នាងភេរីទូលថា បុគ្គលដទៃលើផែនដីឈ្មោះថា អ្នកប្រាជ្ញដូចមហោសថ មិនមាន ព្រះរាជាបានស្តាប់ពាក្យព្រះនាងភេរីហើយ ទ្រង់ថ្វាយបង្គំអាពធនាឲ្យត្រឡប់ ក្នុងកាលព្រះនាងភេរីទៅហើយ មហោសថបានចូលទៅកាន់រាជុបដ្ឋាន ។

លំដាប់នោះ ព្រះរាជាត្រាស់សួរមហោសថថា នែបណ្ឌិត អ្នកបានជួបនាងភេរីបរិព្វាជិកាដែរឬ មហោសថក្រាបទូលដោយនិយាមនៃសេចក្តីដែលនាងទូលហើយថា ម្សិលមិញនេះ នាងចេញអំពីព្រះរាជនិវេសន៍ ទូលបង្គំបានជួបនាង នាងសួរបញ្ហាដល់ទូលបង្គំ ដោយហត្ថសញ្ញានោះ ទូលបង្គំក៏បានឆ្លើយបញ្ហារបស់នាងយ៉ាងនោះ ព្រះរាជាទ្រង់ជ្រះថ្លា ព្រះរាជទានតំណែងជាសេនាបតីដល់មហោសថក្នុងថ្ងៃនោះ ឲ្យមហោសថទទួលរាជកិច្ចទាំងពួង ។ មហោសថក៏មានកិត្តិយសធំ ក្នុងរវាងឥស្សរិយយសដែលបានទទួលព្រះរាជ-ទាន មហោសថគិតថា ព្រះរាជាព្រះរាជទានឥស្សរិយយសធំក្រៃលែង តែព្រះរាជាទាំងឡាយ បើទ្រង់ប្រាថ្នាញុំាងអញឲ្យស្លាប់ ក៏ទ្រង់ធ្វើយ៉ាងនេះឯង បើដូច្នោះ អញនឹងពិសោធព្រះរាជាថា ទ្រង់មានព្រះហឫទ័យល្អចំពោះអញដែរឬទេ តែបុគ្គលដទៃមិនអាចនឹងដឹងបាន នាងភេរីបរិព្វាជិកាដល់ព្រមដោយបញ្ញានោះឯងនឹងដឹងបានដោយឧបាយ កាលគិតដូច្នេះហើយ ទើបកាន់យកគ្រឿងក្រអូប មានផ្កាជាដើមជាច្រើន ទៅកាន់អាវាសបរិព្វាជិកា បូជា ថ្វាយបង្គំនាងហើយ ទើបពោលថា បពិត្រអ្នកនាងម្ចាស់ តាំងអំពីថ្ងៃដែលអ្នកនាងម្ចាស់ពោលគុណកថារបស់ខ្ញុំដល់ព្រះរាជាៗ ប្រទានយសធំក្រៃលែងដល់ខ្ញុំ តែ

ខ្ញុំមិនជ្រាបយសដែលទ្រង់ព្រះរាជទាននោះទេថា ព្រះរាជទានដោយប្រក្រតី ឬដោយពិសេសល្អហើយ អ្នកនាងម្ចាស់គប្បីដឹងភាពដែលព្រះរាជាប្រោស ប្រាណខ្ញុំដែរឬ ដោយឧបាយណាមួយ នាងភេរីក៏ទទួលពាក្យ ។

ថ្ងៃមួយ កាលចូលទៅកាន់ព្រះរាជនិវេសន៍ បានគិតបញ្ហាឈ្មោះថា ទករក្ខសបញ្ហា ។ បានឮមកថា សេចក្តីត្រិះរិះយ៉ាងនេះ បានកើតមានដល់ នាងភេរីថា អញដូចជាចារបុរស នឹងទូលសួរព្រះរាជាដោយឧបាយ ក៏នឹងដឹង ថា ព្រះអង្គមានព្រះហឫទ័យល្អចំពោះមហោសថដែរឬទេ នាងធ្វើកត្តកិច្ច ហើយ ក៏អង្គុយ ។ ព្រះរាជាទ្រង់ក៏នមស្ការនាងភេរីហើយ ប្រថាប់គង់ ។ សេចក្តីត្រិះរិះ បានកើតដល់នាងភេរីថា បើព្រះរាជាមានព្រះហឫទ័យអាក្រក់ ចំពោះមហោសថ អញទូលសួរបញ្ហា នឹងត្រាស់ភាពដែលទ្រង់មានព្រះ ហឫទ័យអាក្រក់ក្នុងកណ្តាលមហាជន ទ្រង់មិនហ៊ានត្រាស់ឡើយ អញត្រូវ ទូលសួរព្រះរាជាក្នុងទីដែលសមគួរមួយ ទើបនាងទូលថា អាត្មាប្រាថ្នាទីស្ងាត់ ទើបព្រះរាជាឲ្យជនទាំងឡាយត្រឡប់ទៅ ។ លំដាប់នោះ នាងភេរីទូលសូម ឱកាសដល់ព្រះរាជាថា អាត្មានឹងទូលសួរបញ្ហាជាមួយទ្រង់ ព្រះរាជាអនុញ្ញាត ថា សូមអ្នកនាងម្ចាស់សាកសួរចុះ ខ្ញុំដឹង ខ្ញុំនឹងឆ្លើយ ។ លំដាប់នោះ នាង ភេរីបរិញ្វជិកា កាលនឹងទូលសួរទករក្ខសបញ្ហា ទើបពោលគាថាទី ១ ក្នុង ( ទករក្ខសជាតត ) ថា

កាលពួកជនទាំង ៧ នាក់ របស់ព្រះអង្គ រសាត់ទៅក្នុងអន្លង់ទឹក
ជ្រៅ អារក្សទឹក កាលស្វែងរកគ្រឿងបូជារបស់មនុស្ស គប្បីចាប់

ទុក ( ព្រះអគ្គព្រះរាជទានទូវជន ) តាមលំដាប់ដូចម្តេច ទើបរួចអំពីអារក្សទឹកបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សត្តន្នំ** សេចក្តីថា របស់មនុស្ស ៧ នាក់ គឺព្រះមាតារបស់ព្រះអគ្គ ១ ព្រះនាងនន្ទាទេវី ១ តិខិណមន្តិកុមារ ១ ធនុសេក្ខសម្លាញ់របស់ព្រះអគ្គ ១ បុរោហិត ១ មហោសថ ១ និងព្រះអគ្គ ១ ។ បទថា **ឧទកណ្ណវេ** បានដល់ ក្នុងទឹកជ្រៅផង ធំល្វឹងល្វើយផង ។ បទថា **មនុស្សពលិមេសានោ** សេចក្តីថា ស្វែងរកគ្រឿងបូជា គឺសាច់មនុស្ស ។ បទថា **គណ្ហេយ្យ** សេចក្តីថា អារក្សទឹកដល់ព្រមដោយកម្លាំង ផុសឡើងអំពីទឹក ចាប់សំពៅនោះ កាលចាប់ហើយ ពោលថា ចូរអ្នកឲ្យមនុស្ស ៦ នាក់ ដល់ខ្ញុំតាមលំដាប់ ខ្ញុំនឹងលែងអ្នកទៅ កាលបើយ៉ាងនេះ ទ្រង់នឹងចាត់លំដាប់ដូចម្តេច ។ បទថា **មុញ្ចេសិ ឧទករក្ខសោ** សេចក្តីថា គប្បីចាត់លំដាប់ម្តងម្នាក់ ក្នុងបណ្តាមនុស្សទាំង ៦ ឲ្យដល់អារក្សទឹកដូចម្តេច ។

ព្រះបាទចូឡនីទ្រង់ស្តាប់ដូច្នោះ កាលទ្រង់សម្តែងតាមព្រះរាជអធ្យាស្រ័យ ទើបត្រាស់គាថានេះថា

ខ្ញុំឲ្យមាតាជាមុន រួចឲ្យភរិយា ឲ្យប្អូន លំដាប់អំពីនោះ ឲ្យ
សម្លាញ់ និងឲ្យព្រាហ្មណ៍ជាគម្រប់ ៥ ទើបឲ្យខ្លួនជាគម្រប់ ៦
មិនឲ្យមហោសថទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆជ្ជាហំ** សេចក្តីថា កាលអារក្សទឹកទំពាស៊ី

ព្រាហ្មណ៍ជាគម្រប់ ៥ ហើយ លំដាប់នោះ ខ្ញុំនឹងពោលថា នែបាអារក្សទឹក ចូរអ្នកហារមាត់ កាលអារក្សទឹកហារមាត់ហើយ ខ្ញុំនឹងឲ្យខ្ទុនដល់អារក្សទឹក មិនគិតដល់សិរីរាជសម្បត្តិ ពោលថា ចូរទំពាស៊ីខ្ញុំក្នុងឥឡូវនេះ ហើយ លោតចូលមាត់ បើខ្ញុំនៅមានជីវិត នឹងមិនឲ្យមហោសថបណ្ឌិតដល់អារក្សទឹក ដោយពិត ។

## ឯត្តកេន អយំ បញ្ហា ចប់

ការដែលព្រះរាជាមានព្រះហឫទ័យល្អក្នុងព្រះមហាសត្វ កាលបរិញ្ញជិកា ដឹងហើយដោយប្រការដូច្នេះ តែគុណរបស់មហោសថបណ្ឌិត បានប្រាកដ ដោយកថាមគ្គត្រឹមប៉ុណ្ណោះក៏មិនមែន ព្រោះហេតុនោះ បរិវិតក្កបានមានដល់ នាងភេរីថា អញនឹងពោលគុណរបស់ជនទាំង ៥ នោះ ក្នុងកណ្ដាលមហាជន ព្រះរាជានឹងសម្ដែងទោសរបស់ជនទាំងនោះ ហើយទ្រង់សរសើរគុណរបស់ មហោសថបណ្ឌិត គុណរបស់មហោសថបណ្ឌិត ក៏នឹងប្រាកដដូចព្រះចន្ទក្នុង ថ្ងៃ ១៥ កើត អណ្ដែតក្នុងលម្ហ ដូច្នេះ ដោយប្រការដូច្នេះ ទើបនាងញុំាង មហាជនក្នុងនគរទាំងអស់ឲ្យប្រជុំគ្នា ហើយទូលសួរបញ្ហានោះនឹងព្រះរាជា ទៀត ចាប់តាំងអំពីខាងដើមរៀងមក កាលព្រះរាជាទ្រង់សម្ដែងយ៉ាងនោះ ហើយ ទើបទូលថា បពិត្រមហារាជ ទ្រង់ត្រាស់ថា នឹងប្រទានព្រះរាជមាតា មុន ធម្មតាមាតាជាអ្នកមានគុណច្រើន ព្រះរាជមាតារបស់ព្រះអង្គ ដូចគ្នានឹង មាតារបស់ជនដទៃក៏មិនមែន ព្រះរាជមាតារបស់ព្រះអង្គមានឧបការៈច្រើន កាលនឹងសម្ដែងគុណរបស់រាជមាតា ទើបពោល ២ គាថាថា

ព្រះមាតាជាអ្នកចិញ្ចឹមព្រះអង្គផង ជាអ្នកបង្កើតផង អនុគ្រោះព្រះអង្គ អស់កាលដ៏យូរផង កាលបើធត្តិព្រាហ្មណ៍ប្រទូស្តចំពោះព្រះអង្គ ព្រះមាតាជាបណ្ឌិត ជាអ្នកស្គាល់ឧបាយ ធ្វើនូវរបស់ដទៃជាគ្រឿងបន្ទំ ហើយដោះព្រះអង្គឲ្យរួចអំពីការសម្លាប់ ព្រះអង្គព្រះរាជទានដល់អារក្សទឹកនូវព្រះមាតា ដែលមានព្រះគុណប្រាកដដូច្នោះ ជាអ្នកឲ្យនូវជីវិត ជាអ្នកឲ្យព្រះអង្គកើតអំពីឱរា ជាអ្នកទ្រទ្រង់នូវគភ៌នោះ តើព្រោះទោសដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធោសេតា** សេចក្តីថា ព្រះនាងឲ្យងូត ឲ្យផឹក ឲ្យបរិភោគមួយថ្ងៃ ២-៣ ដង ចិញ្ចឹមទ្រង់ក្នុងកាលដែលទ្រង់នៅក្មេង ។ បទថា **ឌីឃរត្តានុកម្បិកា** សេចក្តីថា ព្រះនាងអនុគ្រោះដោយព្រះហឫទ័យទន់ អស់កាលយូរ ។ បទថា **ធត្តិ តយិ បទុដ្ឋាសិ** សេចក្តីថា ព្រាហ្មណ៍ឈ្មោះថា ធត្តិប្រទូស្តព្រះអង្គក្នុងកាលណា កាលព្រាហ្មណ៍នោះប្រទូស្តក្នុងព្រះអង្គ ព្រះរាជមាតានោះ ជាអ្នកឈ្លាស ឃើញប្រយោជន៍ជាប្រក្រតី បានធ្វើរូបសិប្បនិមិត្តរបស់ព្រះអង្គ ដោះព្រះអង្គចាកការផ្តាច់ព្រះជន្ម ។

បានឮមកថា ព្រះបិតារបស់ព្រះបាទចូឡនីព្រះនាមថា មហាចូឡនី ព្រះនាងសលាកទេវីជាព្រះមហេសី បានសាហាយស្មន់ជាមួយព្រាហ្មណ៍ ឈ្មោះធត្តិនោះ បានផ្តាច់ព្រះជន្មព្រះបាទមហាចូឡនីដោយថ្នាំពិស លើករាជសម្បត្តិឲ្យព្រាហ្មណ៍ ធ្វើជាមហេសីព្រាហ្មណ៍នោះ ក្នុងកាលព្រះបាទចូឡនីនៅក្មេងថ្ងៃមួយ ចូឡនីរាជកុមារទូលថា បពិត្រព្រះមាតា ទូលបង្គំឃ្លាន ទើបឲ្យរបស់

គួរទំពា មួយអន្ទើដោយទឹកអំពៅដល់ព្រះឱរស ។ រុយទាំងឡាយចោមរោម ព្រះរាជកុមារនោះ ព្រះរាជកុមារគិតថា អញនឹងទំពាស៊ីរបស់ទំពានេះ មិនឲ្យមានរុយ ទើបផ្ទៀងបន្តិច ញុំាងតំណក់ទឹកអំពៅឲ្យធ្លាក់ចុះលើផែនដី ហើយដេញរុយដែលទំត្រង់ខ្លួនឲ្យគេចទៅ រុយទាំងនោះ ក៏នាំគ្នាទៅរោមទឹកអំពៅត្រង់ផែនដីនោះ ព្រះរាជកុមារសោយរបស់ទំពា មិនឲ្យមានរុយ ហើយលាងព្រះហស្តទាំងពីរ ខ្ពុរព្រះឱស្ឋហើយ គេចទៅ ព្រាហ្មណ៍បានឃើញកិរិយានៃរាជកុមារនោះ ទើបគិតថា កុមារនេះ បរិភោគទឹកអំពៅមិនមានរុយក្នុងកាលឥឡូវនេះ ជាំឡើងនឹងមិនឲ្យរាជសម្បត្តិដល់អញ អញនឹងញុំាងកុមារនោះឲ្យស្លាប់ក្នុងកាលឥឡូវនេះ ទើបព្រាហ្មណ៍ប្រាប់សេចក្តីនោះ ដល់ព្រះនាងសលាកទេវី ព្រះនាងត្រាស់ថា សាធុ ព្រះសម្មតិទេព ខ្ញុំម្ចាស់ញុំាងកស្តារបស់ខ្លួនឲ្យអស់ព្រះជន្ម ព្រោះស្រឡាញ់ទ្រង់ នឹងត្រូវការអ្វីដោយកុមារនេះឥឡូវនេះ ខ្ញុំម្ចាស់នឹងមិនឲ្យមហាជនដឹង នឹងញុំាងកុមារឲ្យស្លាប់ដោយសម្ងាត់ ត្រាស់ដូច្នេះហើយ បញ្ជោតព្រាហ្មណ៍ថា ឧបាយនេះមាន ។

ព្រះនាងសលាកទេវីជាអ្នកមានប្រាជ្ញា ឈ្លាសក្នុងឧបាយ ទើបហៅអ្នកវិសេសមកត្រាស់ថា កូនរបស់យើងចូឡនីកុមារ និងកូនរបស់អ្នក ឈ្មោះធនុសេក្ខកុមារ កើតក្នុងថ្ងៃតែមួយ ចម្រើនដោយកុមារចោមរោមជាសម្លាញ់នឹងគ្នា ឥឡូវនេះ ឆព្តិព្រាហ្មណ៍ ប្រាថ្នានឹងញុំាងកូនរបស់យើងឲ្យស្លាប់ ចូរអ្នកឲ្យជីវិតដល់កូនរបស់យើង ។ កាលអ្នកវិសេសទូលថា សាធុ ទូលបង្គំនឹងធ្វើដូចម្តេច ទើបត្រាស់ថា កូនរបស់យើងចូរនៅក្នុងផ្ទះរបស់អ្នករាល់ថ្ងៃ

អ្នក និងកូនរបស់យើង មួយអន្លើដោយកូនរបស់អ្នក ចូរដេកក្នុងផ្ទះបាយ ដើម្បីកុំឲ្យអ្នកណាសង្ស័យ ២-៣ ថ្ងៃទៀត បន្ទាប់អំពីថ្ងៃនោះ ដឹងថា មិនមានអ្នកណាសង្ស័យហើយ ចូរអ្នកដាក់ធ្យូងពពៃក្នុងដំណេករបស់ជនទាំង ៣ ហើយដុតភ្លើងត្រង់រោងចុងភៅ ក្នុងកាលមហាជនដេកលក់ កុំឲ្យអ្នកណាដឹង ចូរអ្នកនាំកូនរបស់យើង និងកូនរបស់អ្នកចេញតាមទ្វារតូច ទៅខាងក្រៅដែន កុំប្រាប់ភាពដែលកូនរបស់យើងថាជាកូនស្តេច ហើយតាមរក្សាជីវិតកូនរបស់យើង អ្នកវិសេសទទួលព្រះសវនីយ៍ថា សាធុ លំដាប់នោះ ព្រះនាងប្រទានទ្រព្យសម្បត្តិល្អៗ ដល់អ្នកវិសេសនោះ អ្នកវិសេសបានធ្វើយ៉ាងនោះ នាំកូនរបស់ខ្លួន និងព្រះរាជកុមារទៅកាន់សាគលនគរក្នុងមទ្ទរដ្ឋ ហើយនៅបម្រើព្រះបាទមទ្ទរាជ ។ ព្រះបាទមទ្ទរាជ ឲ្យចុងភៅបុរាណចេញ ប្រទានតំណែងនោះដល់អ្នកវិសេសដែលមកថ្មីនោះ សូម្បីកុមារទាំងពីរក៏ទៅកាន់ព្រះរាជ-និវេសន៍ជាមួយអ្នកវិសេសនោះ ព្រះរាជាត្រាស់សួរថា កុមារទាំងពីរនេះ ជាកូនរបស់អ្នកណា អ្នកវិសេសទូលថា ជាកូនរបស់ទូលបង្គំ ព្រះបាទសាគល-នគរត្រាស់ថា ហេតុអ្វីមុខមាត់មិនដូចគ្នា អ្នកវិសេសទូលថា បពិត្រព្រះអង្គម្តាយផ្សេងគ្នា ។ ក្នុងកាលកន្លងទៅ ចូឡនីរាជកុមារ និងធនុសេក្ខកុមារទាំងពីរ អ្នកស្និទ្ធស្នាលលេងជាមួយព្រះធីតារបស់ព្រះរាជា ក្នុងព្រះរាជ-និវេសន៍នោះឯង ។ លំដាប់នោះ ចូឡនីរាជកុមារ និងនន្ទារាជធីតារបស់ព្រះបាទមទ្ទរាជ មានចិត្តប្រតិព័ទ្ធគ្នានិងគ្នា ព្រោះឃើញគ្នារាល់ថ្ងៃ ចូឡនីរាជកុមារឲ្យរាជធីតានាំរូវ និងខ្សែមកក្នុងទីលេង ព្រះរាជកុមារវាយសីសៈព្រះរាជធីតា

ដែលមិននាំមក ព្រះរាជធីតាក៏យំ លំដាប់នោះ ព្រះរាជាទ្រង់ស្តាប់សំឡេងព្រះរាជធីតា ទើបត្រាស់សួរថា អ្នកណាវាយកូនរបស់យើង ស្រីស្នំទាំងឡាយមក សួរថា អ្នកណាវាយព្រះនាង កុមារិកាគិតថា បើអញប្រាប់ថាកុមារនេះវាយ បិតារបស់អញនឹងដាក់រាជទណ្ឌដល់គេ គិតដូច្នេះ ទើបមិនប្រាប់ថាកុមារវាយ ព្រោះសេចក្តីស្នេហាក្នុងកុមារនោះ ទើបត្រាស់ថា មិនមានអ្នកណាវាយខ្ញុំឡើយ ។ លំដាប់នោះ ព្រះបាទមទ្ទរាជបានឃើញចូឡនីរាជកុមារវាយ ព្រោះទ្រង់បានទតឃើញឯង សេចក្តីត្រិះរិះក៏មានដល់ព្រះរាជាថា កុមារនេះមុខមាត់មិនដូចអ្នកវិសេស ជាអ្នកមានរូបស្អាតគួរជ្រះថ្លា ជាអ្នកមិនចេះខ្លាចរអែង កុមារនេះមិនមែនកូនអ្នកវិសេសនោះឡើយ ចាប់តាំងពីនោះមកព្រះរាជាក៏ទ្រង់សង្កេតកុមារនោះ ស្នំទាំងឡាយនាំរបស់ទំពាមកក្នុងទីលេងថ្វាយព្រះរាជធីតាៗ ក៏ប្រទានដល់កុមារដទៃៗ ក្មេងទាំងនោះ លុតជង្គង់បង្អោនខ្នងទទួល ចំណែកចូឡនីរាជកុមារ ឈរដណ្តើមយកអំពីព្រះហស្តនៃព្រះរាជកុមារី សូម្បីព្រះរាជាក៏បានទតឃើញកិរិយានោះ ។ ថ្ងៃមួយ វូរបស់ចូឡនីកុមារ ចូលទៅក្រោមគ្រែបន្ទប់របស់ព្រះរាជា ចូឡនីរាជកុមារ កាលនឹងចាប់យកវូនោះ ក៏យកឈើច្រត់ចេញមក កាន់យកដោយគិតថា អញមិនចូលក្រោមគ្រែរបស់ព្រះរាជាក្នុងបច្ចុប្បន្នទេសនេះ ចំណែកព្រះរាជាទតឃើញកិរិយានោះ សន្និដ្ឋានថា កុមារនេះមិនមែនកូនរបស់អ្នកវិសេសដោយពិត ទើបហៅអ្នកវិសេសមកត្រាស់សួរថា កុមារទាំងពីរនេះ ជាកូនរបស់អ្នកណា អ្នកវិសេសទូលថា ជាកូនរបស់ទូលបង្គំទាំងពីរនាក់ ព្រះរាជាសម្តេចថា យើងដឹងថា កូនរបស់ឯង ឬមិនមែនកូនរបស់ឯង ចូរឯងប្រាប់ការពិត បើមិនប្រាប់

ជីវិតរបស់ឯងមិនមាន ដូច្នេះហើយ ក៏នាំព្រះវ៉ន អ្នកវិសេសខ្លាចមរណភ័យ ទើបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំត្រូវការទីស្ងាត់ កាលព្រះរាជាប្រទានឱកាសហើយ ទើបសូមព្រះរាជទានអភ័យ ហើយទូលការពិត ព្រះរាជាទ្រង់ជ្រាបសេចក្តីពិតហើយ ក៏ឲ្យតាក់តែងព្រះរាជធីតារបស់ព្រះអគ្គប្រទានជាបាទបរិចារិកាដល់ចូឡនីរាជកុមារនោះ ។

ក្នុងថ្ងៃដែលអ្នកវិសេស ចូឡនីរាជកុមារ និងកូនរបស់អ្នកវិសេសគេចខ្លួន កោលាហលតែមួយមានក្នុងឧត្តរបញ្ចាលទាំងមូលថា អ្នកវិសេស ចូឡនីរាជកុមារ និងកូនរបស់គាត់ កាលភ្លើងឆេះរោងចុងភៅ បានឆេះស្លាប់ហើយជាមួយគ្នា ព្រះនាងសលាកទេវីទ្រង់ជ្រាបព្រឹត្តិហេតុនោះ ទើបប្រាប់ដល់ព្រាហ្មណ៍ថា បពិត្រព្រះសម្មតិទេព សេចក្តីប្រាថ្នារបស់ទ្រង់ដល់ទីបំផុតហើយ បានឮថា ជនទាំង ៣ គឺអ្នកវិសេស ចូឡនីរាជកុមារ និងកូនរបស់គេ ឆេះស្លាប់ក្នុងរោងចុងភៅនោះឯង ព្រាហ្មណ៍ត្រេកអរក្រៃលែង ចំណែកព្រះនាងសលាកទេវីឲ្យនាំឆ្អឹងពពែ មកបង្ហាញដល់ព្រាហ្មណ៍ថា នេះឆ្អឹងចូឡនីកុមារ ហើយឲ្យបោះចោល ។ នាងភេរីបរិព្វាជិកាសំដៅយកសេចក្តីនេះ ទើបពោលថា ព្រះមាតារបស់ទ្រង់ ធ្វើរូបសិប្បនិមិត្តដទៃ ដោះទ្រង់ចាកការផ្តាច់ព្រះជន្ម ព្រះរាជមាតាទ្រង់បង្ហាញឆ្អឹងពពែថាជាឆ្អឹងរបស់មនុស្ស ដោះទ្រង់ចាកការផ្តាច់ព្រះជន្ម ។ បទថា **ឱរសំ** សេចក្តីថា ធ្វើទ្រង់ទុកក្នុងទ្រូងឲ្យចម្រើនហើយ ជាទីស្រឡាញ់ ជាទីប្រោសប្រាណ ។ បទថា **គព្ភធារិនី** សេចក្តីថា ទ្រង់នឹងប្រទានរាជមាតា ដែលទ្រទ្រង់ព្រះអង្គក្នុងព្រះគភ៌បែបនេះ ដល់អារក្សទឹក

ដោយទោសអ្វី ។

ព្រះបាទចូឡនីព្រហ្មទត្ត បានស្តាប់ពាក្យរបស់នាងភេរីបរិព្វាជិកាដូច្នោះហើយ ត្រាស់ថា បពិត្រអ្នកនាងម្ចាស់ គុណរបស់មាតាមានច្រើន ខ្ញុំក៏ដឹងភាពដែលព្រះមាតាមានឧបការៈដល់ខ្ញុំ តែគុណរបស់ខ្ញុំនេះឯង មានច្រើនជាងនោះ កាលទ្រង់ពណ៌នាទោសរបស់ព្រះមាតា ទើបត្រាស់ ២ គាថា ថា

ព្រះមាតាខ្ញុំ ទ្រទ្រង់គ្រឿងអលង្ការ ដែលមិនគួរតាក់តែង ដូចស្ត្រីក្មេង សើចក្អាកក្អាយហួសវេលា ( ជាមួយ ) នឹងនាយឆ្មាំទ្វារ និងពពួកពលសេនា មិនតែប៉ុណ្ណោះ ថែមទាំងបញ្ជូនទូវទូតទាំងឡាយ ដល់ពួកបដិរាជ ( ព្រះរាជានៅក្រោមអំណាច ) ដោយខ្លួនឯង ខ្ញុំឲ្យព្រះមាតាដល់អារក្សទឹក ព្រោះទោសនោះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥត្ថិរូបា វិយ** សេចក្តីថា សូម្បីទ្រង់ជរាហើយក៏នៅទ្រទ្រង់គ្រឿងប្រដាប់ គឺតែងព្រះកាយដូចក្រមុំ ។ បទថា **អបិលន្ធនំ** បានដល់ ទ្រទ្រង់នូវគ្រឿងប្រដាប់មិនសមគួរ បានឮថា ព្រះនាងសលាកទេវីនោះប្រដាប់ខ្សែក្រវាត់មាសដែលដាំដោយពេជ្រ យាងទៅយាងមក ក្នុងកាលដែលព្រះរាជាប្រថាប់ ក្នុងមហាប្រាសាទ ជាមួយពួកអមាត្យពេញព្រះរាជនិវេសន៍ បានពពាក់ពពួនគ្នាដោយសំឡេងតែមួយរបស់ខ្សែក្រវាត់ ។ បទថា **បជគ្ឃតិ** សេចក្តីថា ទ្រង់ហៅពួកអ្នកយាមទ្វារ និងពួកអ្នកបង្ហឹកដំរី បង្ហឹកសេះជាដើម ដែលជាបុគ្គលមិនគួរបរិភោគ សូម្បីអាហារ ដែលជាសំណល់របស់ព្រះនាង មកសើចជាមួយជនទាំងនោះ ហួសកាលវេលា ។ បទថា

**បដិភាជានំ** បានដល់ ពួកព្រះរាជាគ្រប់គ្រងនគរ ។ បទថា **សយំ ទូតានិ សាសតិ** សេចក្តីថា ព្រះនាងប្រថាប់អក្សរឯងថា ជាពាក្យរបស់ខ្ញុំ ហើយបញ្ជូនទូតទៅថា ព្រះជនទីរបស់យើងតាំងនៅក្នុងវ័យដែលបុគ្គលគួរប្រាថ្នា ស្តេចនោះៗ ចូរមកនាំព្រះជននីទៅ ពួកស្តេចគ្រប់គ្រងនគរទាំងនោះ បញ្ជូនរាជសាសន៍តបមកថា ពួកទូលបង្គំជាឧបដ្ឋាករបស់ព្រះអង្គ ហេតុអ្វី ទើបទ្រង់ត្រាស់ដល់ពួកទូលបង្គំយ៉ាងនេះ កាលស្តេចទាំងនោះ អានរាជសាស៍នោះ ក្នុងកណ្តាលទីប្រជុំ ហាក់ដូចជាកាត់ក្បាលរបស់ខ្ញុំ ខ្ញុំនឹងឲ្យព្រះមាតានោះដល់អារក្សទឹក ដោយទោសនោះ ។

នាងភេរីបានស្តាប់ព្រះរាជាត្រាស់ហើយ ទូលថា បពិត្រមហារាជ ទ្រង់ប្រទានមាតាដោយទោសនេះក៏សមគួរ តែព្រះមហេសីរបស់ព្រះអង្គ ជាអ្នកមានគុណ កាលនឹងពណ៌នាគុណរបស់ព្រះនាងនន្ទាទេវីមហេសីនោះ បានពោល ២ គាថាថា

អគ្គមហេសី ជាស្ត្រីប្រសើរជាងពួកស្ត្រី ពោលពាក្យជាទីស្រឡាញ់ដ៏ក្រៃលែង ជាស្ត្រីមានសណ្តាប់ធ្នាប់ មានសីលធម៌ ធ្លាប់ជាប់តាម ( ព្រះអង្គ ) ដូចជាស្រមោល ជាស្ត្រីមិនក្រេវក្រោធ ជាអ្នកមានបុណ្យ ជាបណ្ឌិតឃើញនូវប្រយោជន៍ ព្រះអង្គព្រះរាជទាននាងឧព្វរី ដល់អារក្សទឹក តើព្រោះទោសដូចម្តេចដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥត្ថីគុម្ពស្ស** បានដល់ ពួកស្ត្រី ។ បទថា

**អនុព្ពតា** សេចក្តីថា ចាប់តាំងពីពេលដែលព្រះនាងនៅក្មេង ជាអ្នកប្រព្រឹត្ត តាមចិត្ត គឺទៅតាមគួរ ជាអ្នកមានសីល ជាអ្នកយាងតាមព្រះអង្គដូចស្រមោល អន្ទោលតាមប្រាណ ។ នាងភេរីបរិព្វាជិកា កាលនឹងពោលគុណរបស់ព្រះនាង នន្ទាទេវីនោះ ដោយបទថា **អក្កោធនា** ជាដើម ទើបពោលពាក្យនេះថា ក្នុង ពេលប្រថាប់នៅក្នុងសាគលនគរ ក្នុងមទ្ទរដ្ឋ ព្រះនាងនន្ទាទេវីសូម្បីទ្រង់វាយ ក៏មិនទូលដល់ព្រះមាតាបិតា ព្រោះសេចក្តីស្រឡាញ់ក្នុងព្រះអង្គ ព្រោះខ្លាច ព្រះអង្គត្រូវអាជ្ញា ព្រះនាងជាអ្នកមិនក្រោធ ជាស្រីមានបុណ្យ ជាបណ្ឌិតឃើញ ប្រយោជន៍យ៉ាងនេះដូច្នេះ សំដៅយកការមិនក្រោធជាដើម ក្នុងពេលដែល ព្រះនាងនៅក្មេង ។ បទថា **ឧត្តរឹ** បានដល់ ព្រះមហេសី នាងភេរីពោលថា ទ្រង់នឹងប្រទានព្រះនាងនន្ទាទេវីដែលសម្បូរដោយគុណយ៉ាងនេះ ដល់អារក្ស-ទឹក ដោយទោសអ្វី ។

ព្រះបាទចូឡនី កាលទ្រង់សម្តែងទោសរបស់ព្រះនាងនន្ទាទេវី ដែលជា មហេសីនោះ បានត្រាស់គាថានេះថា

នាងនន្ទាទេវីនោះ ( បានដឹងច្បាស់ ) នូវខ្ញុំ ថាជាអ្នកប្រកបដោយ
សេចក្តីត្រេកអរក្នុងល្បែង ទាំងជាអ្នកលុះអំណាចនៃកិលេស
ដែលមិនមានប្រយោជន៍ នាងបានសូមចំពោះខ្ញុំ នូវទ្រព្យនៃកូន
ទាំងឡាយរបស់ខ្លួន ដែលជាទ្រព្យមិនគួរសូម ខ្ញុំនោះ កំពុង
ត្រេកត្រអាល ក៏បានឲ្យទ្រព្យប្រសើរ និងថោកទាប ច្រើនយ៉ាង
លុះខ្ញុំលះបង់នូវទ្រព្យដែលគេលះបង់បាន ដោយក្រហើយ ក៏មាន

ចិត្តអាក់អន់ សោកស្តាយក្នុងកាលជាខាងក្រោយ ខ្ញុំឲ្យនាងឧព្វរី ដល់អារក្សទឹក ព្រោះទោសនោះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនត្ថវសមាគតំ** សេចក្តីថា ដឹងថាខ្ញុំធ្លាក់ក្នុងអំណាចរបស់កិលេស ដែលធ្វើសេចក្តីវិនាស ព្រោះត្រេកអរក្នុងការលេងគឺកាមកីឡានោះ ។ បទថា **សា មំ** សេចក្តីថា ព្រះនាងនន្ទាទេវីនោះ ដឹងខ្ញុំ ។ បទថា **សកានំ បុត្តានំ** សេចក្តីថា គ្រឿងប្រដាប់ដែលខ្ញុំឲ្យដល់កូនប្រុសកូនស្រី និងកិរិយាទាំងឡាយរបស់ខ្ញុំ នាងសូមគ្រឿងប្រដាប់នោះ ដែលមិនគួរសូមថា ចូរឲ្យដល់ខ្ញុំម្ចាស់ ។ បទថា **បច្ឆា សោចាមិ** សេចក្តីថា ក្នុងថ្ងៃទី ២ ព្រះនាងពោលនឹងបុត្រជាដើមរបស់ខ្ញុំថា គ្រឿងប្រដាប់ទាំងនេះ ព្រះរាជាប្រទានដល់យើងហើយ ចូរអ្នកទាំងឡាយនាំមកឲ្យយើងដូច្នេះ កាលបុត្រជាដើមរបស់ខ្ញុំយំក៏នៅតែដោះយក បន្ទាប់មក ខ្ញុំឃើញបុត្រជាដើមនោះយំមករក ខ្ញុំក៏សោយសោកខាងក្រោយ ព្រះនាងនន្ទាទេវីនេះ ធ្វើទោសយ៉ាងនេះ ខ្ញុំឲ្យនាងដល់អារក្សទឹក ដោយទោសនេះ ។

លំដាប់នោះ បរិញ្ជិកាភេរីកាលទូលសួរព្រះបាទចូឡនីថា ទ្រង់ប្រទានព្រះមហេសីដោយទោសនេះក៏សមគួរ តែតិរិណកុមារដែលជាប្អូនប្រុស មានឧបការៈដល់ព្រះអង្គ ទ្រង់ប្រទានកុមារដោយទោសដូចម្តេច ដូច្នេះ ទើបពោលគាថាថា

ពួកអ្នកជនបទចម្រើនហើយ ព្រោះព្រះកនិដ្ឋភាតាណា ទាំងព្រះអង្គដែលព្រះកនិដ្ឋភាតាណា នាំមកកាន់ព្រះរាជដំណាក់វិញ ព្រះ

រាជទ្រព្យជាច្រើនយ៉ាង ដែលព្រះកនិដ្ឋភាតាណា រឹបជាន់នាំមក អំពីពួកស្តេចដទៃ ព្រះអង្គព្រះរាជទានព្រះកនិដ្ឋភាតា ជាបុគ្គល ប្រសើរជាងពួកខ្មាន់ធ្នូ ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ( នោះ ) ដល់អារក្សទឹក តើព្រោះទោសដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោធោចិតា** បានដល់ ដែលឲ្យចម្រើន ហើយ ។ បទថា **បដិគ្គហំ** សេចក្តីថា ដែលនាំព្រះអង្គឲ្យប្រថាប់នៅក្នុង ប្រទេសដទៃ ត្រឡប់មកកាន់ព្រះរាជមន្ទីរ ។ បទថា **អភិជ្ឈាយ** បានដល់ គ្របសង្កត់ហើយ ។ បទថា **តិខិណាមន្តិធំ** បានដល់ ជាអ្នកមានបញ្ញាមុត ស្រួច ។

បានឮថា តិខិណរាជកុមារនោះ ប្រសូតក្នុងកាលដែលព្រះរាជមាតានៅ រួមជាមួយព្រាហ្មណ៍ កាលព្រះរាជកុមារទ្រង់ចម្រើនហើយ ព្រាហ្មណ៍បានឲ្យ ដាវ ប្រាប់ថា ចូរឯងកាន់យកដាវនេះចូលមករកយើងបាន ព្រះរាជកុមារនោះ បម្រើព្រាហ្មណ៍ដោយសម្គាល់ថាជាព្រះបិតារបស់ខ្លួន ។ លំដាប់នោះ អមាត្យ ម្នាក់ បានទូលព្រះរាជកុមារថា បពិត្រព្រះរាជកុមារ ទ្រង់មិនមែនជាកូន ព្រាហ្មណ៍នេះទេ ក្នុងកាលទ្រង់នៅក្នុងផ្ទៃ ព្រះនាងសលាកទេវីជាព្រះមាតា ឲ្យផ្តាច់ព្រះជន្មព្រះរាជបិតា ហើយប្រគល់រាជសម្បត្តិដល់ព្រាហ្មណ៍នេះ ទ្រង់ ជារាជបុត្ររបស់ព្រះបាទមហាចូឡនី ។ ព្រះរាជកុមារបានស្តាប់ព្រឹត្តិហេតុនោះ ក៏ពិរោធ គិតថា ណ្ហើយចុះ អញនឹងសម្លាប់ព្រាហ្មណ៍នេះ ដោយឧបាយណា មួយ ហើយចូលទៅកាន់រាជសម្នាក់ ប្រទានដាវដល់មហាតលិកជិតស្និទ្ធម្នាក់

ហើយត្រាស់នឹងមហាតលិកម្នាក់ទៀតថា ចូរអ្នកឈរទៀបទ្វារព្រះរាជនិវេសន៍ ពោលនឹងមហាតលិកដែលកាន់ដាវនោះថា នុ៎ះជាដាវរបស់យើង ហើយបន្លូវជម្លោះនឹងមហាតលិកនោះ ត្រាស់ដូច្នេះហើយ ក៏ចូលទៅខាងក្នុង មហាតលិកទាំង ២ នោះ បានទាស់ទែងគ្នា ព្រះរាជកុមារបញ្ជូនបុរសម្នាក់ទៅ ដើម្បីឲ្យដឹងថា ជនទាំងនោះឈ្លោះគ្នា រឿងអ្វី បុរសនោះមកវិញក្រាបទូលថា ឈ្លោះគ្នាដោយត្រូវការដាវ ។ លំដាប់នោះ ព្រាហ្មណ៍បានស្តាប់ដូច្នោះ ទើបសួរព្រះរាជកុមារថា រឿងនុ៎ះដូចម្តេច ព្រះរាជកុមារពោលថា បានឮថា ដាវដែលទ្រង់ព្រះរាជទានដល់ទូលបង្គំជារបស់អ្នកដទៃ ព្រាហ្មណ៍ពោលថា នែបា ឯងនិយាយអ្វី បើយ៉ាងនោះ ចូរឲ្យគេនាំមក យើងនឹងស្គាល់ព្រះខ័ននោះបាន ព្រះរាជកុមារឲ្យនាំព្រះខ័ននោះមក ហើយដកចេញអំពីស្រោម ធ្វើជាឲ្យចាំបានដោយពាក្យថា សូមទ្រង់ទតចុះ ចូលទៅជិតព្រាហ្មណ៍នោះហើយ កាត់ក្បាលព្រាហ្មណ៍នោះ ឲ្យធ្លាក់ចុះទៀបជើងរបស់ខ្លួន ដោយកាប់ត្រឹមមួយដាវប៉ុណ្ណោះ កាលនាំសពព្រាហ្មណ៍ចេញអំពីព្រះរាជនិវេសន៍ បានរៀបចំព្រះរាជ-និវេសន៍ តាក់តែងព្រះនគរអភិសេកព្រះរាជកុមារនោះ ។ ព្រះជននីប្រាប់ថា ចូឡនីរាជកុមារនៅក្នុងមទ្ទរដ្ឋ ព្រះរាជកុមារទ្រង់ស្តាប់ដូច្នោះ ចោមរោមដោយអង្គនៃសេនាយាងទៅកាន់មទ្ទរដ្ឋ នាំព្រះជេដ្ឋាធិរាជមកឲ្យគ្រប់គ្រងរាជសម្បត្តិ ចាប់តាំងពីកាលនោះមក ជនទាំងឡាយ ក៏ស្គាល់ព្រះអង្គថា តិខិណមន្តិ បរិញ្ញជិកាទូលសួរថា ទ្រង់ប្រទានប្អូនប្រុសបែបនេះ ដល់អារក្សទឹក ដោយទោសដូចម្តេច ។

ព្រះរាជាកាលត្រាស់ទោសរបស់តិរិណកុមារ ទើបត្រាស់ថា

ពួកអ្នកជនបទចម្រើនហើយ ព្រោះកនិដ្ឋភាតាណា ទាំងខ្ញុំ ( ដែល កនិដ្ឋភាតាណា ) នាំមកកាន់ដំណាក់វិញ ព្រះរាជទ្រព្យជាច្រើន យ៉ាង ( ដែលកនិដ្ឋភាតាណា ) រឹបជាន់ ហើយនាំមកអំពីពួក ស្តេចដទៃ កនិដ្ឋភាតានោះ មើលងាយថា អញប្រសើរជាងពួក ខ្ទាន់ធ្នូ ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ឯព្រះរាជានេះដូចជាក្មេង បានសេចក្តីសុខ ព្រោះតែអញ បពិត្រនាងជាម្ចាស់ មិនតែប៉ុណ្ណោះ កនិដ្ឋភាតានោះ មិនមកកាន់ទីបម្រើខ្ញុំ ដូចក្នុងកាលពីដើមទេ ខ្ញុំឲ្យ កនិដ្ឋភាតា ( នោះ ) ដល់អារក្សទឹក ព្រោះទោសនោះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បររជ្ជេភិ** សេចក្តីថា តិរិណរាជកុមារនិយាយ ស្មើថា យើងនាំទ្រព្យជាច្រើនមកអំពីរាជសម្បត្តិដទៃ មកថ្វាយដល់ព្រះរាជា នេះ កាលព្រះអង្គប្រថាប់នៅក្នុងរាជសម្បត្តិដទៃ យើងក៏នាំត្រឡប់មកកាន់ រាជធានីនេះ យើងបានប្រតិស្ឋានព្រះរាជានេះក្នុងយសធំ ។ បទថា **យថាបុរេ** សេចក្តីថា កាលមុនគេមកគាល់ខ្ញុំអំពីព្រលឹម តែឥឡូវនេះ គេមិនមកយ៉ាង នោះ ខ្ញុំឲ្យគេដល់អារក្សទឹក ដោយទោសនោះ ។

បរិព្វាជិកាទូលថា បពិត្រមហារាជ ទោសរបស់ព្រះកនិដ្ឋភាតា ចូរលើក ទុកចុះ តែធនុសេខកុមារប្រកបដោយគុណ មានសេចក្តីស្មោះស្ម័គ្រក្នុងព្រះ អង្គ ជាអ្នកមានឧបការៈច្រើន កាលពោលគុណរបស់ធនុសេខកុមារ ទើប ទូលថា

ជនទាំងពីរនាក់ គឺព្រះអង្គ និងធនុសេខកុមារ ជាសម្លាញ់មានវ័យស្មើគ្នា ធ្លាប់នៅក្នុងបញ្ចាលនគរ ជាបុគ្គលពីរនាក់កើតក្នុងបញ្ចាលនគរនេះ ក្នុងរាត្រីតែមួយ ធនុសេខកុមារ មានទុក្ខសុខជាមួយគ្នានឹងព្រះអង្គ ជាប់តាមព្រះអង្គ ក្នុងការត្រាច់ទៅកាន់ ( ជនបទ ) ជាអ្នកខ្មីឃ្មាតខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ដើម្បីព្រះអង្គ ទាំងថ្ងៃទាំងយប់ ព្រះអង្គព្រះរាជទានសម្លាញ់នេះ ដល់អារក្សទឹក តើព្រោះហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធនុសេខវា** សេចក្តីថា ឈ្មោះថា ធនុសេខកុមារ ព្រោះជាអ្នករៀនខាងសិប្បៈធ្នូ ។ បទថា **ឯត្ថ** បានដល់ ក្នុងព្រះនគរនេះឯង ។ បទថា **បញ្ចាលា** សេចក្តីថា ដែលហៅយ៉ាងនេះ ព្រោះកើតក្នុងឧត្តរបញ្ចាលនគរ ។ បទថា **សុសមាវយា** បានដល់ មានវ័យស្មើគ្នាដោយល្អ ។ បទថា **ចរិយា តំ អនុពន្ធិត្ថោ** សេចក្តីថា បានជាប់តាមព្រះអង្គដែលចៀសចេញទៅ ត្រាច់តាមជនបទក្នុងកាលទ្រង់នៅក្មេង ។ សេចក្តីនេះដូចអ្វី ដូចស្រមោលមិនលះបង់ព្រះអង្គ ។ បទថា **ឧស្សុក្កោ តេ** សេចក្តីថា ជាអ្នកឧស្សាហ៍ខ្មីឃ្មាត គឺកើតនូវការពេញចិត្តក្នុងកិច្ចទាំងឡាយរបស់ព្រះអង្គ ទាំងពេលយប់ និងពេលថ្ងៃ ខ្វល់ខ្វាយជានិច្ច ទ្រង់ឲ្យសម្លាញ់នោះដល់អារក្សទឹក ដោយទោសអ្វី ។

លំដាប់នោះ ព្រះបាទចូឡនីកាលពោលទោសរបស់ធនុសេខកុមារនោះ ទើបត្រាស់ថា

បពិត្រនាងម្ចាស់ ធនុសេខកុមារនេះ ( ជាប់តាម ) ខ្ញុំ ក្នុងការត្រាច់ទៅ ( កាន់ជនបទ ) សើចក្អាកក្អាយជាមួយនឹងខ្ញុំ ក្នុងកាលមុន សូម្បីក្នុងថ្ងៃនេះ ក៏នៅតែសើចក្អាកក្អាយ ហួសវេលាតាមទំនងនោះដែរ បពិត្រនាងម្ចាស់ ខ្ញុំនៅក្នុងទីស្ងាត់ កំពុងប្រឹក្សាជាមួយនឹងនាងឧត្តរី ឯសេខកុមារខ្ញុំមិនបានហៅ មិនបានឲ្យដំណឹងខ្ញុំជាមុនទេ ស្រាប់តែចូលមក ជាបុគ្គលមានទ្វារបានហើយ មានឱកាសធ្វើឲ្យហើយ ខ្ញុំឲ្យនូវសម្មាញ់ ជាមនុស្សមិនមានសេចក្ដីអៀនខ្មាស មិនអើពើ ដល់អារក្សទឹក ព្រោះទោសនោះឯងដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អដ្ឋាបិ តេន វណ្ណេន** សេចក្ដីថា សម្មាញ់ធនុសេខៈនេះ កាលមុនដើរតាមខ្ញុំ បរិភោគរួម ដេករួមជាមួយខ្ញុំ ក្នុងកាលក្រីក្រ ជាអ្នកទះដៃសើច យ៉ាងណា សូម្បីថ្ងៃនេះ គេក៏នៅតែសើចយ៉ាងនោះឯង នៅសម្លឹងមើលខ្ញុំដូចកាលនៅក្រីក្រ ។ បទថា **អនាមន្តោ** សេចក្ដីថា កាលខ្ញុំកំពុងនិយាយជាមួយនាងនន្ទាទេវីក្នុងទីស្ងាត់ គេមិនគោះទ្វារជាមុនដើរចូលទៅ ខ្ញុំឲ្យគេដែលមិនមានការកោតក្រែង មិនមានការអើពើដល់អារក្សទឹក ដោយទោសនេះ ។

លំដាប់នោះ បរិព្វាជិកាទូលព្រះបាទចូឡនីថា បពិត្រមហារាជ ទោសរបស់ធនុសេខៈនេះស្តេះចុះ តែបុរោហិតកេវដ្ដៈ ជាអ្នកមានឧបការៈដល់ព្រះអង្គច្រើន កាលពោលគុណរបស់បុរោហិតនោះ ទើបទូលថា

ព្រាហ្មណ៍បុរោហិត ជាអ្នកឈ្លាសវៃក្នុងនិមិត្តទាំងពួង ជាអ្នកដឹងនូវសំឡេងស្រែក ជាអ្នកឈ្លាសក្នុងឧត្បាត ជាអ្នកបេះកាត់សុបិន ជាអ្នកឈ្លាសវៃក្នុងការចេញ និងការចូលផង លើផែនដី និងលើអាកាសផង ជាអ្នកឈ្លាសវៃក្នុងចំណែកនក្ខត្តឫក្ស ព្រះអង្គព្រះរាជទានព្រាហ្មណ៍បុរោហិត ដល់អារក្សទឹក តើព្រោះទោសដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វនិមិត្តានំ** សេចក្តីថា ជាអ្នកឈ្លាសក្នុងនិមិត្តទាំងពួងយ៉ាងនេះថា ដោយនិមិត្តនេះវត្ថុនេះនឹងមាន ដោយនិមិត្តនេះវត្ថុនេះនឹងមាន ។ បទថា **រុតញ្ញូ** សេចក្តីថា សំឡេងស្រែករបស់សត្វទាំងពួង ។ បទថា **ឧប្បាតេ** បានដល់ រឿងឧត្បាត មានចន្ទគ្រាស សុរិយគ្រាស ឧត្បាតនិងវិជ្ជាមើលឫក្សយាមជាដើម ។ បទថា **សុបិនេ យុត្តោ** ដឹងក្នុងរឿងសុបិនថា យល់សប្តិយ៉ាងនេះ នឹងមានផលយ៉ាងនេះ ។ បទថា **និយ្យានេ ច បវេសនេ** សេចក្តីថា ដឹងថា ដោយនក្ខត្តឫក្សនេះគប្បីលើកទ័ព ដោយនក្ខត្តឫក្សនេះគប្បីចូលច្បាំង ។ បទថា **បដ្ឋោ ភុម្មន្តលិក្ខស្មឹ** សេចក្តីថា ជាបុគ្គលឈ្លាស គឺអាច បានដល់ អាចដឹងទោស និងគុណក្នុងផែនដី និងក្នុងអាកាស ។ បទថា **នក្ខត្តបទកោវិទោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងចំណែកនៃនក្ខត្តឫក្ស ២៨ ទ្រង់ឲ្យកេវដ្តបុរោហិតនោះដល់អារក្សទឹក ដោយទោសអ្វី ។

ព្រះរាជា កាលត្រាស់ទោសរបស់កេវដ្តបុរោហិតនោះ ទើបត្រាស់ថា

បពិត្រនាងម្ចាស់ ព្រាហ្មណ៍បុរោហិត បើកភ្នែកសម្លក់ចំពោះខ្ញុំ ក្នុងកណ្តាលបរិស័ទ ព្រោះហេតុនោះ ទើបខ្ញុំឲ្យបុរោហិតអាក្រក់ មានចិញ្ចើមក្រញូវ ដល់អារក្សទឹក ដូច្នេះ ។

អត្ថនៃគាថានោះថា បពិត្រអ្នកនាងម្ចាស់ កេវដ្ដបុរោហិតនេះ សម្លឹងមើលខ្ញុំក្នុងកណ្តាលបរិស័ទ ក៏បើកភ្នែកមើលដូចមនុស្សក្រោធ ព្រោះដូច្នោះ ទើបខ្ញុំឲ្យនាយព្រាន គឺអ្នកបាញ់សត្វ ដែលធ្វើការញ្ញាក់ចិញ្ចើម ព្រោះទោសដែលញ្ញាក់ចិញ្ចើមនោះ ដល់អារក្សទឹក ។

បន្ទាប់អំពីនោះ បរិញ្វជិកាក្រាបទូលសួរថា បពិត្រមហារាជ ទ្រង់ត្រាស់ថា នឹងឲ្យជនទាំង ៥ នេះ មានព្រះរាជមាតាជាដើមដល់អារក្សទឹក និងត្រាស់ថា ប្រទានជីវិតរបស់ព្រះអង្គដល់មហោសថបណ្ឌិត ដោយមិនអាឡោះអាល័យរាជសម្បត្តិបែបនេះ ទ្រង់ឃើញគុណរបស់មហោសថបណ្ឌិតដូចម្តេច ដូច្នេះ ទើបពោលគាថាទាំងនេះថា

ព្រះអង្គគ្រប់គ្រងនូវផែនដីដ៏ធំ មានសមុទ្រព័ទ្ធជុំវិញ ជាកុណ្ឌលរបស់សាគរ ព្រះអង្គមានអាមាត្យចោមរោម ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានដែនដ៏ច្រើន ជាអ្នកឈ្នះសង្គ្រាម មានពលច្រើន ជាព្រះរាជាឯកលើផែនដី យសរបស់ព្រះអង្គក៏ដល់នូវភាពដ៏ធំធ្ញើង មានពួកនារី មកអំពីជនបទផ្សេងៗ ជាស្ត្រីស្នំ ១៦ ពាន់ ពាក់គ្រឿងកុណ្ឌល ជាវិការនៃកែវមណី ល្អល្អះដូចស្រីទេពកញ្ញា បពិត្រក្សត្រ អ្នកប្រាជ្ញទាំងឡាយ បាន

ពោលចំពោះជីវិតដែលវែង បរិបូណ៌ដោយអង្គទាំងពួង សម្រេចនូវសេចក្ដីប្រាថ្នាទាំងពួងថា ជាទីស្រឡាញ់ របស់សត្វទាំងឡាយអ្នកដល់នូវសេចក្ដីសុខយ៉ាងនេះ កាលបើដូច្នោះ ព្រះអង្គរក្សាទុកនូវបណ្ឌិត ត្រឡប់ជាលះបង់ព្រះជន្ម ដែលគេលះបង់បានដោយកម្រ តើដោយដំណើរដូចម្ដេច ឬក៏ដោយហេតុដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សសមុទ្ទបរិយាសំ** បានដល់ ប្រកបដោយគ្រឿងចោមរោម គឺសមុទ្រ ពោល គឺមានសមុទ្រជាគូជុំវិញ ។ បទថា **សាគរកុណ្ឌលំ** សេចក្ដីថា ជាកុណ្ឌលនៃសាគរព័ទ្ធផែនដីនោះ ។ បទថា **វិជិតាវី** បានដល់ ទ្រង់ឈ្នះនូវសង្គ្រាម ។ បទថា **ឯករាជា** សេចក្ដីថា ជាព្រះរាជាឯកនោះឯង ព្រោះមិនមានព្រះរាជាដទៃដែលដូចគ្នានឹងព្រះអង្គ ។ បទថា **សព្វកាមសមិទ្ធិនំ** សេចក្ដីថា ប្រកបដោយការសម្រេចនៃវត្ថុកាម និងកិលេសកាមសព្វយ៉ាង ។ បទថា **សុខិតានំ** សេចក្ដីថា បណ្ឌិតទាំងឡាយពោលថា ពួកសត្វដែលមានសេចក្ដីសុខបែបនេះ រមែងប្រាថ្នាជីវិតដែលសម្បូរដោយអង្គប្រកបគ្រប់យ៉ាង យ៉ាងនេះ ដែលជាទីស្រឡាញ់ឲ្យរស់នៅបានយូរ មិនត្រូវការជីវិត គឺការរស់នៅតិចឡើយ ។ បទថា **ចាគំ** សេចក្ដីថា ទ្រង់ការពារមហោសថបណ្ឌិត លះបង់ជីវិតព្រះអង្គបែបនេះ ព្រោះហេតុអ្វី ។

ព្រះបាទចូឡនីស្ដាប់ពាក្យរបស់បរិព្វាជិកានោះហើយ កាលត្រាស់គុណរបស់មហោសថបណ្ឌិត ទើបពោលគាថាទាំងនេះថា

បពិត្រនាងម្ចាស់ តាំងអំពីកាលដែលមហោសធបណ្ឌិត មកតាំងនៅក្នុងកណ្ដាប់ដៃនៃខ្ញុំ ខ្ញុំនខ្ញុំក៏មិនដែលឃើញនូវអំពើអាក្រក់សូម្បីបន្តិចបន្តួចរបស់មហោសធបណ្ឌិត ជាអ្នកប្រាជ្ញទេ ថាបើសេចក្ដីស្លាប់គប្បីមានដល់ខ្ញុំមុនក្នុងកាលណាមួយ មហោសធ-បណ្ឌិត គប្បីញុំាងបុត្រទាំងឡាយ និងចៅទាំងឡាយ របស់ខ្ញុំឲ្យសុខ មហោសធបណ្ឌិត តែងពិចារណាឃើញនូវប្រយោជន៍ទាំងពួងក្នុងអនាគត និងបច្ចុប្បន្ន ( ព្រោះហេតុនោះ ) ខ្ញុំមិនឲ្យនូវមហោសធបណ្ឌិត ជាអ្នកមានការងារមិនដែលមានកំហុស ( ដល់អារក្សទឹកទេ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិម្ហិចិ កាលេ** ប្រែថា ក្នុងកាលណាមួយ ។ បទថា **សុខាបេយ្យ** សេចក្ដីថា គប្បីឲ្យតាំងនៅក្នុងសុខនោះឯង ។ បទថា **សព្វមត្ថំ** សេចក្ដីថា មហោសថរមែងឃើញច្បាស់នូវសេចក្ដីចម្រើនគ្រប់យ៉ាងទាំងអនាគត និងបច្ចុប្បន្ន ឬអតីត ហាក់បីដូចសព្វញ្ញុពុទ្ធ ។ បទថា **អនា-បរាធកម្មន្តំ** សេចក្ដីថា វៀរចាកការខុសតាមកាយកម្មជាដើម ។ បទថា **ន ទជ្ជំ** សេចក្ដីថា បពិត្រអ្នកនាងម្ចាស់ ខ្ញុំនឹងមិនឲ្យបណ្ឌិតដែលមានធុរៈមិនមានបុគ្គលស្មើបែបនេះ ដល់អារក្សទឹកឡើយ ។

ព្រះបាទចូឡនី ទ្រង់លើកកិត្តិគុណរបស់ព្រះមហាសត្វឡើងប្រកាសហាក់បីដូចទ្រង់លើកព្រះចន្ទឡើងដូច្នោះ ដោយប្រការដូច្នេះ ជាតកនេះ មានអត្ថជាប់តគ្នា ដោយប្រការដូច្នេះ ។

លំដាប់នោះ នាងភេរីបរិព្វាជិកាគិតថា កិត្តិគុណរបស់មហោសថបណ្ឌិត ប្រាកដត្រឹមប៉ុណ្ណេះ មិនទាន់គ្រប់គ្រាន់នៅឡើយ អញនឹងធ្វើនូវកិត្តិគុណរបស់មហោសថបណ្ឌិតឲ្យប្រាកដក្នុងកណ្តាលអ្នកនគរទាំងមូល ឲ្យដូចជាចាក់ប្រេងលើផ្ទៃទឹក ឲ្យប្រេងផ្សាយទៅដូច្នោះ គិតដូច្នេះហើយ ទើបយាងព្រះបាទចូឡនីចុះអំពីប្រាសាទ ឲ្យក្រាលអាសនៈត្រង់លានព្រះរាជវាំង អង្គុយលើអាសនៈនោះ ហើយប្រកាសឲ្យអ្នកនគរមកប្រជុំគ្នា ហើយទូលសួរព្រះបាទចូឡនីដល់បញ្ហាអារក្សទឹកសាថ្មីម្តងទៀត ក្នុងពេលដែលព្រះបាទចូឡនីត្រាស់ហើយខាងដើម នាងភេរីបរិព្វាជិកាបានពោលប្រកាសដល់អ្នកនគរថា

ពួកអ្នកនគរបញ្ចាលទាំងឡាយ ចូរស្តាប់នូវភាសិតនេះ របស់ព្រះបាទចូឡនីចុះ ព្រះរាជាទ្រង់រក្សានូវបណ្ឌិត ស៊ូលះបង់នូវព្រះជន្ម ដែលគេលះបានដោយក្រ ព្រះរាជាក្នុងបញ្ចាលនគរលះបង់នូវជីវិតរបស់ជន ៦ រូប គឺព្រះមាតា ១ ព្រះមហេសី ១ ព្រះកនិដ្ឋភាតា ១ សម្លាញ់ ១ ព្រាហ្មណ៍ ១ ព្រះអង្គ ១ បញ្ញាជាគុណជាតិដ៏ល្អិត សម្រាប់គិតនូវប្រយោជន៍ដ៏ល្អ មានឫទ្ធិច្រើនយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ននេះផង ដើម្បីសេចក្តីសុខក្នុងបរលោកផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហត្ថិយា** សេចក្តីថា កាន់យកប្រយោជន៍ធំតាំងនៅ ។ បទថា **ទិដ្ឋធម្មហិតត្ថាយ** សេចក្តីថា រមែងមានដើម្បីប្រយោជន៍ក្នុងអត្តភាពនេះឯង និងដើម្បីប្រយោជន៍ និងសេចក្តីសុខក្នុងបរលោក ។

នាងភេរីបរិព្វាជិកា កាន់យកកំពូលនៃធម្មទេសនាដោយគុណទាំងឡាយរបស់មហាសត្វ ដូចចាប់ត្រង់ជុំកែវមណីដែលជាកំពូលនៃផ្ទះកែវដូច្នោះ ដោយប្រការដូច្នេះ ។

## ទករក្ខសបញ្ហា ចប់

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងដោយប្រការយ៉ាងនេះហើយ កាលទ្រង់ប្រកាសអរិយសច្ច ៤ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតមានបញ្ញា ញាំញីនូវវាទៈរបស់អ្នកដទៃ សូម្បីក្នុងអតីតកាល កាលញាណមិនទាន់ចាស់ក្លា តថាគតនៅបំពេញចរិយាដើម្បីប្រយោជន៍ក្នុងពោធិញ្ញាណ ក៏មានបញ្ញាដូចគ្នា ត្រាស់ដូច្នេះហើយ ទើបទ្រង់សមោធានជាតកថា

សេនកបណ្ឌិតក្នុងកាលនោះ បានមកជាកស្សបភិក្ខុក្នុងកាលឥឡូវនេះ កាមិន្ទៈក្នុងកាលនោះ បានមកជាអម្ពដ្ឋភិក្ខុ បុក្កុសៈក្នុងកាលនោះ បានមកជាបោដ្ឋបាទភិក្ខុ បញ្ចាលចន្ទកុមារក្នុងកាលនោះ បានមកជាអនុរុទ្ធភិក្ខុ ទេវិន្ទៈក្នុងកាលនោះ បានមកជាសោណទណ្ឌកភិក្ខុ ព្រាហ្មណ៍កេវដ្ដៈក្នុងកាលនោះ បានមកជាទេវទត្តភិក្ខុ ព្រះនាងសលាកទេវីក្នុងកាលនោះ បានមកជាថុលនន្ទិកាភិក្ខុនី អនុកេវដ្ដព្រាហ្មណ៍ក្នុងកាលនោះ បានមកជាមោគ្គល្លានភិក្ខុ ព្រះនាងបញ្ចាលចន្ទីក្នុងកាលនោះ បានមកជាសុន្ទរីភិក្ខុនី សាលិកាញីក្នុងកាលនោះ បានមកជាព្រះនាងមល្លិកាទេវី ព្រះនាងឧទុម្ពរទេវីក្នុងកាលនោះ បានមកជាគោតមីភិក្ខុនី ព្រះបាទវិទេហរាជក្នុងកាលនោះ បានមកជាកាឡុទាយិភិក្ខុ

នាងភេរីបរិញ្វជិកា ក្នុងកាលនោះ បានមកជាឧប្បលវណ្ណាភិក្ខុនី គហបតីបិតា ក្នុងកាលនោះ បានមកជាសុទ្ធោទនមហារាជ គហបតានីដែលជាមាតាក្នុង កាលនោះ បានមកជាព្រះនាងសិរិមហាមាយា នាងអមរាក្នុងកាលនោះ បាន មកជាពិម្ពាសុន្ទរី ( រាហុលមាតា ) តិរិណាកុមារក្នុងកាលនោះ បានមកជា ឆន្នភិក្ខុ ជនុសេខៈក្នុងកាលនោះ បានមកជារាហុលភិក្ខុ សេកស្សុវបណ្ឌិត ក្នុងកាលនោះ បានមកជាអានន្ទភិក្ខុ ព្រះបាទចូឡនីក្នុងកាលនោះ បានមក ជាសារីបុត្ត មហោសថបណ្ឌិតក្នុងកាលនោះ គឺតថាគតដែលជាលោកនាថ អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះឯង ។

## អដ្ឋកថាមហោសថបណ្ឌិត ចប់

# សុត្តន្តបិដក

## ភូរិទត្តជាតក

[ ២៩៤ ] ( នាគទាំង ៤ ក្រាបបង្គំទូលថា ) រតនៈណាមួយ មានក្នុងនិវេសន៍របស់នាគរាជ ព្រះនាមធតរដ្ឋ រតនៈទាំងអស់នោះ ចូរមកដល់ព្រះអង្គ សូមព្រះអង្គទ្រង់ប្រទានធីតាដល់ព្រះរាជាយើង ។

[ ២៩៥ ] ( ព្រះបាទព្រហ្មទត្តត្រាស់ថា ) វិវាហៈជាមួយនឹងពួកនាគ យើងមិនធ្លាប់ធ្វើ ក្នុងកាលណាម្តងទេ យើងនឹងធ្វើវិវាហៈមិនសមគួរនោះ ដូចម្តេចកើត ។

[ ២៩៦ ] ( នាគទាំង ៤ ... ) បពិត្រព្រះអង្គ ជាធំជាងមនុស្ស ជីវិតក្តី ដែនក្តី ព្រះអង្គនឹងលះបង់ដោយពិត កាលបើនាគខឹងហើយ ព្រះរាជាទាំងឡាយ ប្រហែលនឹងព្រះអង្គមិនគង់ព្រះជន្មនៅយូរទេ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គណាជាមនុស្ស ព្រះអង្គនោះ មិនមានឫទ្ធិ មើលងាយព្រះរាជាដែលមានឫទ្ធិ ជាកូនបង្កើតនៃព្រះបាទវរុណៈ ដែលកើតក្នុងទន្លេយមុនា ។

[ ២៩៧ ] ( ព្រះរាជា ... ) យើងមិនមើលងាយព្រះបាទធតរដ្ឋ ដ៏មានយសទេ ព្រោះថា ព្រះបាទធតរដ្ឋ ជាធំជាងនាគទាំងឡាយដ៏ច្រើន ។ ពស់ ទុកជាមានអានុភាពច្រើន ក៏មិនសមគួរនឹងធីតារបស់យើងទេ ចំណែកខាងយើង ជាក្សត្រ

របស់អ្នកដែនវិទេហៈ ធីតា ( របស់យើង ) ឈ្មោះសមុទ្ទជា មានជាតិដ៏ប្រសើរ ។

[ ២៩៨ ] ( ព្រះបាទធតរដ្ឋ ... ) ពួកនាគឈ្មោះកម្ពលស្សតរា ចូរក្រោកឡើង អ្នកចូរប្រាប់នាគទាំងអស់ថា នាគទាំងឡាយ ចូរទៅកាន់ក្រុងពារាណសី តែកុំបៀតបៀនបុគ្គលណាមួយឡើយ ។

[ ២៩៩ ] នាគទាំងឡាយ ដែលមានសរីរៈធំ ចូរសំយុងខ្លួនក្នុងនិវេសនដ្ឋានទាំងឡាយក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើខ្លោងទ្វារ ។ ចំណែកខាងខ្ញុំ មានកាយធំសសុទ្ធ នឹងព័ទ្ធបុរីដែលធំទូលាយ ដោយភ្នែនទាំងឡាយ នឹងញុំាងភ័យឲ្យកើតឡើងដល់ពួកអ្នកដែនកាសី ។

[ ៣០០ ] នាគទាំងឡាយ មានសម្បុរដ៏ច្រើន បានស្តាប់ពាក្យព្រះបាទធតរដ្ឋនោះហើយ ក៏ចូលទៅកាន់ក្រុងពារាណសី តែមិនបៀតបៀនបុគ្គលណាមួយឡើយ ។ នាគទាំងឡាយដែលមានសរីរៈធំ ក៏សំយុងខ្លួនក្នុងនិវេសនដ្ឋាន ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើខ្លោងទ្វារ ។ នារីទាំងឡាយជាច្រើន បានឃើញនាគទាំងនុ៎ះ កំពុងសំយុងខ្លួនលុះឃើញពួកនាគបើកពពារ កំពុងឲ្យសំឡេងរឿយៗ ក៏កន្ទក់កន្ទេញ ។ ពួកជនក្នុងពារាណសី តក់ស្លុត ក្តៅក្រហាយ ក៏

លើកដៃកន្ទក់កន្ទេញថា សូមព្រះអង្គប្រទានជីតាដល់នាគរាជ ។

[ ៣០១ ] ( ព្រាហ្មណ៍នេសាទ ... ) អ្នកជាអ្វី មានភ្នែកក្រហម មានចន្លោះស្មាទូលាយ ( អង្គុយ ) ក្នុងកណ្តាលនៃព្រៃ ជាទីនាំមកបូជា ដោយផ្កាឈើ ស្រីទាំង ១០ នាក់ជាអ្វី ដែលទ្រទ្រង់នូវសង្វារ ជាវិការនៃមាស មានសំពត់ដ៏ល្អ កំពុងឈរសំពះ ។ អ្នកជាអ្វី មានដៃធំ រុងរឿងក្នុងកណ្តាលព្រៃ ដូចភ្លើងឆេះនូវឆ្នាំងខ្លាញ់ អ្នកជាយក្ខណាមួយ ដែលមានសក្តិធំឬ ឬជានាគមានអានុភាពធំ ។

[ ៣០២ ] ( ភូរិទត្តនាគរាជ ... ) ខ្ញុំជានាគមានឫទ្ធិ មានតេជះ ដែលគេកន្លងមិនបាន ប្រសិនជាខ្ញុំក្រោធ អាចចឹកសម្លាប់នូវអ្នកជនបទ ដែលបរិបូណ៌ ( ដោយភោគៈ ) ដោយតេជះបាន ។ ឯមាតារបស់ខ្ញុំ ឈ្មោះសមុទ្ទជា បិតារបស់ខ្ញុំឈ្មោះធតរដ្ឋ ខ្ញុំជាប្អូននៃនាគរាជឈ្មោះសុទស្សនៈ ជនទាំងឡាយស្គាល់ខ្ញុំថា ភូរិទត្ត ។

[ ៣០៣ ] លោក រមែងឃើញអន្លង់ទឹកណាដ៏ជ្រៅ ដែលហូរកួចសព្វកាល ជាអន្លង់ទឹកគួរខ្លាច អន្លង់ទឹកនោះ ជាទិព្វ ជាលំនៅរបស់ខ្ញុំ មានជម្រៅច្រើនរយនៃជួរបុរស ។ អ្នកកុំខ្លាច ចូរចូលទៅកាន់ស្ទឹងយមុនា មានទឹកខៀវ ( ដែលហូរមក ) អំពីកណ្តាលព្រៃ ជាកន្លែងដែលក្ងោក និងក្រៀលយំ ជាស្ទឹង

ត្រជាក់ ក្រៀមក្សាន្ត ជាលំនៅរបស់ពួកអ្នកមានវត្ត ។
[ ៣០៤ ] ម្នាលព្រាហ្មណ៍ អ្នក ព្រមទាំងកូន មកដល់កពទាគនោះហើយ នឹងបានប្រពន្ធ ម្នាលព្រាហ្មណ៍ យើងនឹងបូជាអ្នកដោយកាមទាំងឡាយរបស់យើង អ្នកចូរនៅឲ្យសុខចុះ ។
[ ៣០៥ ] ( ព្រាហ្មណ៍នេសាទ ... ) ផែនដីមានផ្ទៃរាបស្មើដោយជុំវិញ មានដើមក្រស្នាច្រើន ដេរដាសដោយមេភ្លៀង មានស្មៅខៀវដ៏ឧត្តមល្អ ។ ព្រៃជ្រុំគួររីករាយ ស្រះបោក្ខរណីទាំងឡាយ ដែលបុញ្ញកម្មរបស់ព្រះអង្គនិម្មិតល្អហើយ ជាទីរីករាយ ដែលហង្សយំហើយ មានផ្កាឈូកធ្លាក់ចុះ ។ សសរមានជ្រុង ៨ ដែលគេធ្វើល្អហើយ ជាវិការនៃកែវពៃទូរ្យទាំងអស់ ប្រាសាទទាំងឡាយ មានសសរ ១ ពាន់ ដ៏ពេញដោយនាងកញ្ញា ភ្លឺរុងរឿង ។ ព្រះអង្គបានដល់នូវវិមានជាទិព្វ ដោយបុណ្យរបស់ព្រះអង្គ ជាវិមានមិនចង្អៀត ជាទីក្សេម គួររីករាយ ប្រកបដោយសេចក្តីសុខយ៉ាងក្រៃលែង ។ ខ្ញុំសម្គាល់ថា ព្រះអង្គ មិនប្រាថ្នាវិមានរបស់ព្រះឥន្ទ្រ ជាសហស្សនេត្តទេ ព្រោះថា ឫទ្ធិរបស់ព្រះអង្គនេះ ដ៏ធំដូចជាឫទ្ធិនៃព្រះឥន្ទ្រដ៏រុងរឿងដែរ ។
[ ៣០៦ ] ( ភូរិទត្តនាគរាជ ... ) អានុភាពរបស់ព្រះឥន្ទ្រ

អានុភាពរបស់លោកបាលទាំង ៤ ញុំាំងអំណាចឲ្យប្រព្រឹត្តទៅ ជាអ្នកបម្រើព្រះឥន្ទ្រក្តី អ្នកមិនគប្បីដឹងដោយចិត្តបានទេ ។

[ ៣០៧ ] ខ្ញុំប្រាថ្នាវិមាននោះ របស់ទេវតាទាំងឡាយ អ្នកស្វែងរកសេចក្តីសុខ បានជារក្សាឧបោសថ ហើយដេកលើក្បាលដំបូក ។

[ ៣០៨ ] ( ព្រាហ្មណ៍នេសាទ ... ) ឯខ្ញុំ ព្រមទាំងកូនស្វែងរកម្រឹគ បានចូលទៅកាន់ព្រៃ ញាតិទាំងនោះ មិនដឹងខ្ញុំថាស្លាប់ ឬរស់ទេ ។ ខ្ញុំសូមលាព្រះភូរិទត្ត ជាបុត្តព្រះរាជធីតាក្នុងដែនកាសី ព្រះអង្គមានយស យើងខ្ញុំ បើព្រះអង្គព្រមអនុញ្ញាតហើយ គប្បីឃើញពួកញាតិ ។

[ ៣០៩ ] ( ភូរិទត្តនាគរាជ ... ) ឱន៎ុះពិតជាសេចក្តីពេញចិត្តរបស់ខ្ញុំហើយ ត្រង់ដែលអ្នកនៅក្នុងសម្នាក់នៃខ្ញុំ ព្រោះថាកាមទាំងឡាយប្រាកដដូច្នេះ អ្នកមិនងាយបានក្នុងពួកមនុស្សទេ ។ អ្នកដែលខ្ញុំបូជាដោយកាមទាំងឡាយរបស់ខ្ញុំ បើមិនចង់នៅទេ ខ្ញុំនឹងអនុញ្ញាតអ្នក សូមអ្នកទៅជួបពួកញាតិដោយសួស្តីចុះ ។

[ ៣១០ ] អ្នក កាលទ្រទ្រង់កែវមណីជាទិព្វនេះ រមែងបានសត្វចិញ្ចឹម និងបុត្ត អ្នកចូរមិនមានរោគ បានសេចក្តីសុខ ម្នាលព្រាហ្មណ៍ អ្នកចូរយក ( នូវកែវមណីនេះ ) ហើយ

ទៅចុះ ។

[ ៣១១ ] ( ព្រាហ្មណ៍នេសាទ ... ) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ខ្ញុំនឹងបួស ព្រោះខ្ញុំចាស់ហើយ ខ្ញុំមិនប្រាថ្នាកាមទេ ។

[ ៣១២ ] ( ភូរិទត្តនាគរាជ ... ) បើមានការបែកធ្លាយព្រហ្មចរិយៈ កិច្ចការដែលត្រូវធ្វើដោយភោគៈទាំងឡាយ ( រមែងមាន ) អ្នកកុំមានសេចក្តីរង្កៀសឡើយ គប្បីមកយើងនឹងឲ្យទ្រព្យដ៏ច្រើនដល់អ្នក ។

[ ៣១៣ ] ( ព្រាហ្មណ៍នេសាទ ... ) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ប្រសិនបើមានសេចក្តីត្រូវការ ខ្ញុំនឹងមកម្តងទៀត ។

[ ៣១៤ ] ( អភិសម្ពុទ្ធគាថា ) ព្រះភូរិទត្ត លុះពោលពាក្យនេះហើយ ក៏បញ្ជូននូវនាគទាំង ៤ ថា អ្នកទាំងឡាយមកនេះ ចូរទៅ ចូរក្រោកឡើង ចូរញ៉ាំងព្រាហ្មណ៍ឲ្យដល់ ( នូវផ្លូវជាទីទៅកាន់ក្រុងពារាណសី ) ជាឆាប់ ។ នាគទាំង ៤ ត្រូវភូរិទត្តប្រើទៅហើយ បានស្តាប់ពាក្យនោះរបស់ភូរិទត្តនោះ ក៏ក្រោកឡើង ហើយបានញ៉ាំងព្រាហ្មណ៍ឲ្យដល់ឆាប់ ។

[ ៣១៥ ] ( ព្រាហ្មណ៍នេសាទ ... ) អ្នកកាន់យកនូវកែវមណីជាមង្គល ជាទ្រព្យដ៏ប្រសើរ ជាទីរីករាយនៃចិត្ត ជា

ថ្មបរិបូណ៌ដោយទ្រង់ទ្រាយ អ្នកបានកែវមណីនេះអំពីទីណា ។

[ ៣១៦ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) ថ្ងៃនេះ ខ្ញុំទៅកាន់ផ្លូវពីព្រឹក បានកែវមណីនេះ ដែលពួកនាងនាគក្មេកក្រហមមួយពាន់ ថែរក្សាហើយ ។

[ ៣១៧ ] ( ព្រាហ្មណ៍នេសាទ ... ) កែវមណីនេះ បើបុគ្គលសន្សំទុកល្អ ថែទាំបូជាគ្រប់គ្រងល្អ ទុកដាក់ល្អ ហើយសព្វកាល គប្បីញុំាងប្រយោជន៍ទាំងពួងឲ្យសម្រេចបាន ។ តែកាលបើបុគ្គល ជាអ្នកប្រាសចាកការថែទាំក្នុងការទុកដាក់ ឬក្នុងការប្រើប្រាស់វិញ កែវមណីនេះ ដែលគេសន្សំទុក ដោយមិនត្រូវទំនង នឹងដល់សេចក្តីវិនាស ។ អ្នកជាបុគ្គលមិនឈ្លាស មិនគួរគ្រប់គ្រងកែវមណីជាទិព្វនេះទេ អ្នកចូរគ្រប់គ្រងមាសគ្រឿងមួយរយចុះ ចូរឲ្យកែវមណីនេះដល់ខ្ញុំ ។

[ ៣១៨ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) កែវមណីនេះ ខ្ញុំមិនគប្បីលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ កែវមណីរបស់ខ្ញុំដែលកើតអំពីថ្ម បរិបូណ៌ដោយទ្រង់ទ្រាយ ខ្ញុំមិនគប្បីលក់ទេ ។

[ ៣១៩ ] ( ព្រាហ្មណ៍នេសាទ ... ) បើកែវមណី អ្នកមិនលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ ចុះកែវមណី អ្នក

នឹងលក់ដោយវត្ថុអ្វី ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនោះ ។

[ ៣២០ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) បុគ្គលណាគប្បី បង្ហាញនាគដ៏ធំ មានតេជះ ដែលគេកន្ទន់បានដោយក្រដល់ខ្ញុំ ខ្ញុំនឹងឲ្យកែវមណី ដ៏រុងរឿងដោយតេជះដល់បុគ្គលនោះ ។

[ ៣២១ ] ( ព្រាហ្មណ៍នេសាទ ... ) អ្នកជាអ្វី ជាគ្រុឌដ៏ប្រសើរជាងសត្វស្លាបទាំងឡាយ កាលស្វែងរកចំណីដើម្បីខ្លួន ទើបចាប់យកនាគដោយភេទជាព្រាហ្មណ៍ទេឬ ។

[ ៣២២ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) ខ្ញុំមិនមែនជាស្តេចសត្វស្លាបទេ គ្រុឌខ្ញុំមិនដែលឃើញទេ ខ្ញុំជាអ្នកត្រេកអរដោយអាសិរពិស ម្នាលព្រាហ្មណ៍ ជនទាំងឡាយដឹងថា ខ្ញុំជាហ្មពស់ ។

[ ៣២៣ ] ( ព្រាហ្មណ៍នេសាទ ... ) កម្លាំងរបស់អ្នកដូចម្តេច សិល្បៈរបស់អ្នកដូចម្តេច ទាំងអ្នករឹងប៉ឹង ព្រោះហេតុអ្វី បានជាមិនកោតខ្លាចនាគ ។

[ ៣២៤ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) គ្រុឌបានប្រាប់វិជ្ជាពិសដ៏ប្រសើរដល់ឥសីមួយអង្គ ជាកោសិយគោត្រនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌អស់រាត្រីយូរ ។ ខ្ញុំជាអ្នកមិនខ្ជិលប្រអូសទាំងយប់ ទាំងថ្ងៃ បានបម្រើឥសីមួយអង្គនោះ ដែលមានខ្លួនចម្រើនហើយ កាលគង់នៅក្នុងចន្លោះភ្នំដោយសេចក្តីគោរព ។

ឥសីនោះ ដែលខ្ញុំបានបម្រើនហើយ ក្នុងកាលនោះ វត្តក្តី ព្រហ្មចរិយៈក្តី ឥសីនោះ បានប្រព្រឹត្តហើយ ឥសីមានជោគ នោះ ក៏បង្រៀនមន្តទិព្វដល់ខ្ញុំ តាមសេចក្តីប្រាថ្នា ។ ខ្ញុំជាអ្នក រឹងប៉ឹងព្រោះមន្តនោះ បានជាមិនខ្លាចនាគទាំងឡាយ ខ្ញុំជា អាចារ្យរបស់ពួកអ្នកសម្លាប់សត្វមានពិសទាំងឡាយ ជនទាំង ឡាយ ស្គាល់ខ្ញុំថា អាលម្ពាយន៍ ។

[ ៣២៥ ] ( ព្រាហ្មណ៍នេសាទ ... ) ម្នាលសោមទត្ត កូន យើង នឹងកាន់យកកែវមណី ចូរអ្នកដឹងចុះ យើងកុំយកជំបង ទាត់ចោលសិរីដែលមកដល់ហើយតាមសេចក្តីប្រាថ្នាឡើយ ។

[ ៣២៦ ] ( សោមទត្តកុមារ ... ) បពិត្រព្រាហ្មណ៍ ភូរិទត្តណា បានបូជាលោក ដែលដល់នូវនិវេសន៍របស់ខ្លួន លោកប្រាថ្នានឹងប្រទូស្តចំពោះព្រះភូរិទត្តនោះ ដែលធ្វើអំពើ ល្អយ៉ាងនេះ ព្រោះសេចក្តីវង្វេងធ្វើអ្វី ។ បើលោកឪពុកចង់ បានទ្រព្យ ព្រះភូរិទត្តនឹងប្រទាន ចូរលោកឪពុកទៅសុំលោក ចុះ លោកនឹងប្រទានទ្រព្យច្រើនដល់លោកឪពុក ។

[ ៣២៧ ] ( ព្រាហ្មណ៍នេសាទ ... ) ម្នាលសោមទត្ត យើង គួរស៊ីរបស់ឆ្អិនដែលមកដល់ដៃ ឬដល់ភាជន៍ ប្រសើរជាង កុំឲ្យប្រយោជន៍ដែលឃើញច្បាស់នឹងភ្នែក កន្លងផុតពីយើង ទៅបាន ។

[ ៣២៨ ] ( សោមទត្តកុមារ ... ) បុគ្គលជាអ្នកទ្រុស្តមិត្ត ជាអ្នកលះបង់ប្រយោជន៍ រមែងដេះក្នុងនរកដ៏គួរខ្លាច ផែនដីក៏ស្រូបបុគ្គលទ្រុស្តមិត្តនោះ បុគ្គលទ្រុស្តមិត្ត សូម្បីរស់នៅក៏រីងស្ងួត ( ដូចជាប្រេត ) បើឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទានមិនខាន ខ្ញុំសម្គាល់ថា មិនយូរប៉ុន្មាន ឪពុកនឹងដឹងច្បាស់នូវពៀរ ដែលខ្លួនធ្វើហើយ ។

[ ៣២៩ ] ( ព្រាហ្មណ៍នេសាទ ... ) ព្រាហ្មណ៍ទាំងឡាយបូជាមហាយញ្ញហើយ រមែងបរិសុទ្ធយ៉ាងនេះ យើងនឹងបូជាមហាយញ្ញ គង់នឹងរួចចាកបាប ដោយអាការយ៉ាងនេះ ។

[ ៣៣០ ] ( សោមទត្ត ... ) ណ្ហើយចុះ ឥឡូវនេះ ខ្ញុំនឹងគេចចេញថ្ងៃនេះ ខ្ញុំមិននៅជាមួយនឹងឪពុកទេ ខ្ញុំមិនដើរជាមួយនឹងឪពុក ដែលធ្វើអំពើអាក្រក់យ៉ាងនេះអស់មួយជំហានទេ ។

[ ៣៣១ ]( អភិសម្ពុទ្ធគាថា ) សោមទត្តកុមារ ជាពហុស្សូតបានពោលពាក្យនេះនឹងបិតាហើយ ក៏ប្រកាសទេវតាទាំងឡាយហើយគេចចេញចាកទីនោះ ។

[ ៣៣២ ] ( ព្រាហ្មណ៍នេសាទ ... ) នាគណា មានពន្លឺដូចជាសម្បុរនៃសត្វមេភ្លៀង មានក្បាលក្រហម អ្នកចូរចាប់នាគធំទុំះចុះ ហើយចូរនាំកែវមណីទុំះដល់ខ្ញុំ ។ កាយរបស់

នាគនុ៎ះ រមែងប្រាកដដូចជាគំនរប៉ុយកប្បាស នាគនេះ ដេក លើដំបូក ម្នាលព្រាហ្មណ៍ អ្នកចូរចាប់យកនាគនោះចុះ ។

[ ៣៣៣ ] ( អភិសម្ពុទ្ធគាថា ) គ្រានោះ អាលម្ពាយនព្រាហ្មណ៍ កាលជប់បទនៃមន្តទាំងឡាយ ធ្វើជាគ្រឿងការពារខ្លួនដោយឱសថទិព្វទាំងឡាយហើយ ទើបអាចចាប់នាគនោះដោយវិធីយ៉ាងនេះ ។

[ ៣៣៤ ] ( សុទស្សននាគរាជ ... ) ឥន្ទ្រិយរបស់លោកមិនស្រស់បស់ ព្រះភក្ត្ររបស់លោកក៏ខ្មៅ ព្រោះឃើញខ្ញុំ ដែលសម្រេចសេចក្តីប្រាថ្នាទាំងពួង កំពុងមកគាល់ឬ ។ ព្រះភក្ត្ររបស់លោកខ្មៅ ដូចជាផ្កាឈូកដែលស្ថិតនៅក្នុងដៃ ដែលគេប្របាច់ដោយដៃ ព្រោះតែឃើញខ្ញុំប្រាកដដូច្នេះឬ ។

[ ៣៣៥ ] ក្រែងបុគ្គលណាមួយ មិនរាប់អានលោកខ្លះឬ វេទនារបស់លោកមានខ្លះឬ ព្រះភក្ត្ររបស់លោកខ្មៅ ព្រោះឃើញខ្ញុំមក ដោយហេតុណា ( សូមលោកប្រាប់នូវហេតុនោះដល់ខ្ញុំចុះ ) ។

[ ៣៣៦ ] ( នាងសមុទ្ទជា ... ) ម្នាលកូន ក្រោយមួយខែមកហើយអំពីថ្ងៃនេះ យើងបានឃើញសុបិនថា ហាក់ដូចជាបុរសកាត់ដៃខាងស្តាំរបស់យើង ហើយនាំយកដៃដែលប្រឡាក់ដោយឈាម ដើរចេញទៅ ក្នុងកាលដែលយើងកំពុង

យំ ។ ម្នាលសុទស្សនៈ កាលណាយើងបានឃើញសុបិន អ្នកចូរដឹងចុះថា កាលណោះ យើងមិនបានសេចក្តីសុខ ទាំងថ្ងៃទាំងយប់ ។

[ ៣៣៧ ] នាងកញ្ញាទាំងឡាយ មានរាងកាយដ៏រុងរឿងពាក់បណ្តាញមាស បានចោមរោមកូរិទត្តណាពីក្នុងកាលមុន ( ឥឡូវនេះ ) កូរិទត្តនោះ យើងមិនឃើញទេ ។ នាគទាំងឡាយដែលកាន់ព្រះខ័នដ៏ប្រសើរ ដូចជាផ្កាកណិការរីកចោមរោមកូរិទត្តណាពីក្នុងកាលមុន ( ឥឡូវនេះ ) កូរិទត្តនោះយើងមិនឃើញទេ ។ ណ្ហើយចុះ ឥឡូវនេះ យើងនឹងទៅកាន់លំនៅរបស់កូរិទត្ត យើងគង់នឹងឃើញប្អូនរបស់អ្នក ដែលតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីល ។

[ ៣៣៨ ] ( អភិសម្ពុទ្ធគាថា ) ឯករិយាទាំងឡាយរបស់កូរិទត្តបានឃើញព្រះមាតានៃកូរិទត្តនោះកំពុងដើរមក ក៏ផ្គងដៃឡើងកន្ទក់កន្ទេញថា បពិត្រលោកម្តាយជាម្ចាស់ ក្រោយមួយខែមកហើយ អំពីថ្ងៃនេះ យើងមិនដឹងកូរិទត្តដ៏មានយស ជាបុត្ររបស់លោក ជា ស្លាប់ ឬរស់នៅទេ ។

[ ៣៣៩ ] ( នាងសមុទ្ទជា ... ) យើងកាលមិនឃើញកូរិទត្តទេ នឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរ ដូចជាមេសត្វស្លាបបាត់កូន ឃើញតែសម្បុកទទេដូច្នោះ ។ យើងកាល

មិនឃើញភូរិទត្ត នឹងឆេះដោយសេចក្ដីទុក្ខអស់កាលយូរ ដូចជាមេអកបាត់កូន ឃើញតែសម្បុកទទេដូច្នោះ ។ យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្ដីទុក្ខ អស់កាលយូរ ដូចជាមេសត្វចាក្រពាកនោះ នៅលើកក់ ដែលមិនមានទឹកដោយពិត ។ ជើងក្រានៃពួកជាងមាស ឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណា យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្ដីសោក យ៉ាងនោះ ។

[ ៣៤០ ] ( អភិសម្ពុទ្ធគាថា ) កូន និងប្រពន្ធទាំងឡាយ ដួលដេកក្នុងនិវេសន៍របស់ព្រះភូរិទត្ត ដូចជាដើមឈើដែលត្រូវខ្យល់ញាំញីបំបាក់ ដូច្នោះ ។

[ ៣៤១ ] អរិដ្ឋ និងសុភោគនាគរាជ បានឮសំឡេងគឹងកងនៃនាគទាំងនោះ ក្នុងនិវេសន៍របស់ព្រះភូរិទត្ត ក៏ស្ទុះទៅតាមលំដាប់ ហើយពោលថា បពិត្រលោកម្ដាយ សូមលោកជកដង្ហើមស្រួលចុះ កុំសោយសោកឡើយ ព្រោះថាសត្វទាំងឡាយមានសភាពយ៉ាងនេះជាធម្មតា តែងច្យុត តែងកើតឡើងវិញ នេះជាការប្រែប្រួលនៃលោក ។

[ ៣៤២ ] ( នាងសមុទ្ទជា ... ) ម្នាលកូន យើងក៏ដឹងថាសត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតាដែរ តែថាយើងកាលមិនឃើញភូរិទត្តទេ ត្រូវសេចក្ដីសោកគ្របសង្កត់

ហើយប្រសិនបើ ( ភូរិទត្ត ) មិនបាន ( មកជួប ) នឹង យើងក្នុងថ្ងៃនេះយប់នេះទេ ម្នាលសុទស្សនៈ អ្នកចូរដឹងចុះ យើងកាលមិនឃើញភូរិទត្តទេ យើងមុខជានឹងលះបង់នូវជីវិតពុំខាន ។

[ ៣៤៣ ] ( កូនទាំងឡាយ ... ) បពិត្រព្រះមាតា សូមលោកជកជង្រើមស្រួលចុះ កុំសោយសោកឡើយ យើងទាំងឡាយនឹងនាំបងមក យើងទាំងឡាយ ត្រាច់ទៅកាន់ទីស្វែងរកបង នឹងទៅកាន់ទិសតូចធំ លើភ្នំ ជ្រោះភ្នំ ក្នុងស្រុក និងនិគមទាំងឡាយ លោកចូរឃើញបងដែលមកក្នុងវាំងខាងក្នុង ៧ រាត្រី ។

[ ៣៤៤ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) នាគដែលរួចអំពីដៃ ( របស់យើង ) ក្រាបចុះលើជើងលោកយ៉ាងខ្លាំង លោកត្រូវពស់ចឹកឬ លោកកុំខ្លាចឡើយ ចូរដល់សេចក្ដីសុខចុះ ។

[ ៣៤៥ ] ( សុទស្សនទាគរាជ ... ) នាគនេះ មិនអាចឲ្យទុក្ខណាមួយដល់អាត្មាទេ អ្នកចាប់ពស់ មានទាំងប៉ុន្មានមិនមែនមានច្រើនជាងអាត្មាទេ ។

[ ៣៤៦ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) អ្នកណាហ្ន៎ ភ្លឺភ្លៃមានភេទដូចជាភេទនៃព្រាហ្មណ៍ មកកាន់បរិស័ទ ហើយហៅ ( អញ ) ច្បាំង បរិស័ទចូរស្ដាប់ពាក្យរបស់យើងចុះ ។

[ ៣៤៧ ] ( សុទស្សនទាគរាជ ... ) ម្នាលអាលម្ពាយន៍ អ្នកច្បាំងនឹងយើងដោយនាគ យើងក៏ច្បាំងនឹងអ្នកដោយកូនកង្កែបដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើង ដោយកហាបណៈ ៥០០០ ជាកំណត់ ។

[ ៣៤៨ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) ម្នាលមាណព យើងជាអ្នកមានទ្រព្យស្តុកស្តម្ភ អ្នកឯងជាអ្នកទាល់ក្រ តើបុគ្គលណា ជាអ្នកធានាអ្នក ម្យ៉ាងទៀត ទ្រព្យតម្កល់ទុកក្នុងការភ្នាល់មានដែរឬ ។ ទ្រព្យតម្កល់ទុកក្នុងការភ្នាល់របស់យើងមាន ទាំងបុគ្គលជាអ្នកធានាប្រាកដដូច្នោះ ក៏មានដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ ៥០០០ ជាកំណត់ ។

[ ៣៤៩ ] ( សុទស្សនទាគរាជ ... ) បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យអាត្មាភាព សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ ព្រះអង្គមានកិត្តិគុណ សូមព្រះអង្គធានាដោយកហាបណៈ ៥០០០ របស់អាត្មាភាព ។

[ ៣៥០ ] ( ព្រះរាជា ... ) នៃព្រាហ្មណ៍ បំណុលជារបស់នៃបិតា ឬថា ខ្ញុំជំពាក់ដោយខ្លួនឯង បានជាអ្នកទារយកទ្រព្យរបស់យើងច្រើន តើព្រោះហេតុអ្វី ។

[ ៣៥១ ] ( សុទស្សនទាគរាជ ... ) ត្បិតអាលម្ពាយន-

ព្រាហ្មណ៍ ផ្ចាញ់អាត្មាភាពដោយនាគ អាត្មាកពនឹងញ៉ាំងកូន កន្ដែបឲ្យខាំព្រាហ្មណ៍ ។ បពិត្រមហារាជ ញ៉ាំងដែនឲ្យចម្រើន ព្រោះហេតុនោះ សូមព្រះអង្គមានពួកអ្នកកាន់ព្រះខ័នហែហម យាងទៅដើម្បីទតពស់ដែលគួរទត ។

[ ៣៥២ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) ម្នាលមាណព ខ្ញុំ មិនមើលងាយអ្នកដោយសិប្បៈទេ ចំណែកអ្នកមើលងាយ ដោយសិប្បៈ បានជាមិនកោតក្រែងនាគ ។

[ ៣៥៣ ] ( សុទស្សននាគរាជ ... ) នៃព្រាហ្មណ៍ អាត្មា ក៏មិនមើលងាយអ្នកដោយសិប្បៈទេ តែអ្នកបញ្ឆោតជន ច្រើនដោយនាគ ដែលមិនមានពិស ។ អាត្មាដឹង អ្នក យ៉ាង ណា ជនក៏ត្រូវដឹងអ្នកយ៉ាងនោះដែរ ម្នាលអាលម្ពាយន៍ អ្នក មិនបានអង្ករ ១ ក្ដាប់ នឹងបានទ្រព្យអំពីណា ។

[ ៣៥៤ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) អ្នកស្លៀកដណ្ដប់ ស្បែកខ្លាទាំងក្រចក មានផ្នួងសក់ ជាមនុស្សក្រខ្វក់ ភ្លីភ្លើ មក កាន់បរិស័ទ ហើយមើលងាយនាគបែបនេះថា មិនមានពិស អ្នកចូរមកយើង គង់នឹងដឹងនាគនោះ ដែលពេញដោយតេជះ របស់នាគដ៏ខ្ពង់ខ្ពស់ ខ្ញុំសម្គាល់ថា នាគនុ៎ះ នឹងធ្វើអ្នកឲ្យដូច ជាគំនរផេះយ៉ាងឆាប់ ។

[ ៣៥៥ ] ( សុទស្សននាគរាជ ... ) ពិសនៃពស់ផ្ទះ ពស់ទឹក

ពស់ខៀវគ្រាន់មានខ្វះ ឯពិសនៃនាគមានក្បាលក្រហម មិនមានសោះឡើយ ។

[ ៣៥៦ ] ( អាលម្ពាយនព្រាហ្មណ៍ ... ) ខ្ញុំបានស្តាប់ពាក្យនេះ របស់ពួកព្រះអរហន្តដែលសង្រួមហើយ មានតបៈថា ទាយកទាំងឡាយ ក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌ ថាបើអ្នកមានវត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ ។ នាគនេះមានឫទ្ធិច្រើន មានតេជះដែលគេកន្លងបានដោយក្រ ខ្ញុំនឹងប្រើនាគនេះឲ្យចឹកអ្នក នាគនោះនឹងធ្វើអ្នកឲ្យទៅជាផេះ ។

[ ៣៥៧ ] ( សុទស្សននាគរាជ ... ) ម្នាលសម្លាញ់ ខ្ញុំក៏បានស្តាប់ពាក្យនេះរបស់ពួកព្រះអរហន្ត ដែលសង្រួមហើយ មានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌ ថាបើអ្នកមានវត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ ។ កូនកង្កែបនេះឈ្មោះអច្ចិមុខី ពេញដោយតេជះរបស់ពស់ដ៏ខ្លាំងខ្លាស់ អាត្មានឹងប្រើនាងអច្ចិមុខីនោះ ឲ្យខាំអ្នក នាងអច្ចិមុខីនោះ នឹងធ្វើអ្នកឲ្យទៅជាផេះ ។ នាងអច្ចិមុខីនោះ ជាធីតារបស់ព្រះបាទធតរដ្ឋ មានមាតាផ្សេងគ្នាជាប្អូនស្រីរបស់អាត្មា ដ៏ពេញដោយតេជះរបស់ពស់ដ៏ខ្លាំងខ្លាស់ ចូរខាំចុះ ។

[ ៣៥៨ ] បពិត្រព្រះអង្គព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅលើផែនដី ស្មៅ វល្លិ៍ ពួកឈើជាឱសថ នឹងស្វិតស្រពោនគ្មានសល់ ។

[ ៣៥៩ ] បពិត្រព្រះអង្គព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅខាងលើ ភ្លៀងនឹងមិនបង្អុរចុះ ទឹកសន្សើមនឹងមិនធ្លាក់ចុះអស់ ៧ ឆ្នាំ ។

[ ៣៦០ ] បពិត្រព្រះអង្គព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅក្នុងទឹក ត្រី និងអណ្ដើក ដែលជាសត្វកើតក្នុងទឹកទាំងប៉ុន្មាន នឹងស្លាប់ទាំងអស់ ។

[ ៣៦១ ] ( ព្រាហ្មណ៍នេសាទ ... ) ទឹកដែលតាំងនៅក្នុងកំពង់បយាគៈ ដែលអញកំពុងស្រោច ជាទឹកដែលលោកសន្មតថា សម្រាប់លាងបាប ចុះខ្មោចអ្វី ជ្រមុជអញចុះទៅក្នុងស្ទឹងយមុនាដ៏ជ្រៅ ។

[ ៣៦២ ] ( សុភោគនាគរាជ ... ) នាគណាជាធំក្នុងលោកមានយស បានមកព័ទ្ធក្រុងពារាណសីដោយជុំវិញ អញជាកូននាគដ៏ប្រសើរនោះ ម្នាលព្រាហ្មណ៍ នាគទាំងឡាយហៅអញថា សុភោគៈ ដូច្នេះ ។

[ ៣៦៣ ] ( ព្រាហ្មណ៍នេសាទ ... ) បើអ្នកជាកូននៃនាគដ៏ប្រសើរ ជាព្រះរាជាក្នុងដែនកាសី ជាធំជាងនាគដែលមាន

អាយុវែង បិតារបស់អ្នកជានាគមានសក្តិធំមួយដែរ បណ្តាសត្វទាំងឡាយ មាតារបស់អ្នកក៏មិនមានស្ត្រីណាផ្ទឹមបានឡើយ បុគ្គលមានអានុភាពច្រើន ដូចអ្នកមិនគួរចាប់ជ្រមុជ បុគ្គលសូម្បីជាទាសៈនៃព្រាហ្មណ៍ទេ ។

[ ៣៦៤ ] ( សុភោគនាគរាជ ... ) ឯងអែបដើមឈើ ហើយបាញ់ទ្រាយដែលមកផឹក ( ទឹក ) ទ្រាយនោះ ដែលឯងបាញ់ហើយ ក៏ងាកមើលដោយកម្លាំងនៃសរ ក៏ស្ទុះទៅកាន់ទីឆ្ងាយ ។ ឯងបានឃើញទ្រាយនោះដួលក្នុងព្រៃធំហើយ ក៏នាំសាច់មួយអម្រែក ចូលទៅកាន់ដើមជ្រៃក្នុងវេលាល្ងាច ជាឈើដែលគឹងកងដោយសត្វ សេក និងសាលិកា មានស្លឹកលឿង ដេរដាសដោយពួរ ដែលសត្វតាវៅទំយំ ជាទីគួររីករាយ មានផែនដីដុះស្មៅខៀវជានិច្ច បងរបស់អញដែលមានអានុភាពច្រើន រុងរឿងដោយឫទ្ធិ និងយស ដែលពួកនាគកញ្ញាចោមរោមហើយ ក៏ប្រាកដដល់ឯងក្នុងទីនោះ ។ ឯងនោះ ដែលបងរបស់អញនោះផ្គាប់ហើយ ឲ្យស្កប់ស្កល់ដោយកាមទាំងពួង ឯងបានប្រទូស្តចំពោះបងដែលមិនប្រទូស្ត ពៀរនោះមកដល់ឯងក្នុងទីនេះហើយ ។ ឯងចូរដកកយ៉ាងឆាប់ អញនឹងមិនឲ្យជីវិតដល់ឯងទេ អញរឭកឃើញនូវពៀរ ( ដែលឯងធ្វើ ) ចំពោះបង អញនឹងកាត់ក្បាលឯងឥឡូវនេះ ។

[ ៣៦៥ ] ( ព្រាហ្មណ៍នៃសាទ ... ) ព្រាហ្មណ៍ជាអ្នករៀនមន្ត ១ ជាអ្នកប្រកបដោយការសូម ១ ជាអ្នកបូជាភ្លើង ១ ព្រាហ្មណ៍ប្រកបដោយហេតុទាំង ៣ នេះ អ្នកមិនគួរសម្លាប់ទេ ។

[ ៣៦៦ ] ( សុភោគនាគរាជ ... ) បុរីណារបស់ព្រះបាទធតរដ្ឋ ជាវិការនៃមាសទាំងអស់ ដែលចូលទៅកាន់ស្ទឹងយមុនា ទល់នឹងភ្នំហិមពាន្ត ដែលនៅជិតស្ទឹងយមុនា រមែងរុងរឿង ។ បងប្អូនរបស់អញទាំងនោះ ជាបុរសក្លៀវក្លា ជាអ្នករួមផ្ទៃនៅក្នុងបុរីនោះ បងប្អូនទាំងនោះ ក្នុងបុរីនោះ និយាយយ៉ាងណា ឯងនឹងទៅជាយ៉ាងនោះ ។

[ ៣៦៧ ] ( កាណារិដ្ឋនាគរាជ ... ) បពិត្រសុភោគ យញ្ញនិងវេទទាំងឡាយក្នុងលោកនេះ ដែលព្រាហ្មណ៍ឯទៀតប្រកបហើយ មិនមែនជារបស់ផ្តេសផ្តាសទេ ព្រោះហេតុនោះ បុគ្គលកាលតិះដៀលព្រាហ្មណ៍ដែលមិនគួរតិះដៀល ឈ្មោះថា លះបង់ទ្រព្យ និងធម៌របស់ពួកសប្បុរស ។

[ ៣៦៨ ] ពួកអ្នកប្រសើរ ( ព្រាហ្មណ៍ ) ប្រកាន់ខាងការរៀនមន្ត ពួកជាធំជាងជន ( ក្សត្រិយ៍ ) ប្រកាន់ខាងការផែនដី ពួកវេស្សៈ ប្រកាន់ខាងការភ្ជួររាស់ ពួកសូទ្រៈ ប្រកាន់ខាងការបម្រើ ផ្សេងៗ គ្នា តាមសមគួរដល់ប្រទេស ជនទាំង

ឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែង ហើយ ។

[ ៣៦៩ ] ទេវរាជព្រះនាមធាតុ វិធាតុ វរុណៈ កុវេរៈ សោមៈ យមៈ ចន្ទិមៈ វាយុ សុរិយៈ ស្តេចទាំងនេះ បាន បូជាយញ្ញដ៏ច្រើន ទាំង ( បានឲ្យ ) វត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ពួកព្រាហ្មណ៍អ្នករៀនមន្ត្រ ។ ព្រះបាទអជ្ជុនណា មាន កម្លាំង មានសេនាគួរខ្លាច មានដៃមួយពាន់ មិនមានបុគ្គល ណាស្មើលើផែនដី ជាអ្នកឃឹតធ្នូ ៥០០ បាន ព្រះបាទអជ្ជុន នោះឯង ក៏បូជាភ្លើងក្នុងកាលនោះដែរ ។

[ ៣៧០ ] បុគ្គលណា មានចិត្តជ្រះថ្លារីករាយ បានញ៉ាំង ព្រាហ្មណ៍ឲ្យបរិភោគបាយ និងទឹកអស់កាលយូរ ដ៏សមគួរ តាមអានុភាព បពិត្រសុភោគ បុគ្គលនោះ នឹងបានជាទេវតា មួយអង្គ ។

[ ៣៧១ ] ព្រះបាទមុជលិន្ទ អាចញ៉ាំងទេវតាភ្លើង ជាអ្នក ស៊ីច្រើន មានពន្លឺមិនថោកទាប ឲ្យស្កប់ស្កល់ដោយសប្បិ បាន បូជាវិធីយញ្ញ ចំពោះទេវតាភ្លើងដ៏ប្រសើរ ទ្រង់បានទៅកាន់ គតិជាទិព្វ ។

[ ៣៧២ ] ព្រះរាជាព្រះនាមទុទីបៈ មានអានុភាពច្រើន មាន ព្រះជន្ម ១០០០ ឆ្នាំ បានលះបង់ដែន ព្រមទាំងសេនាមិនមាន

ទីបំផុត ហើយបួស បានជាទក្ខិណេយ្យបុគ្គល គួររមិល មើលដ៏លើសលុប ទ្រង់បានទៅកាន់ស្ថានសួគ៌ ។

[ ៣៧៣ ] បពិត្រសុភោគ ព្រះបាទសាគរឈ្មោះផែនដី មានសាគរជាទីបំផុត បានលើកសសរយញ្ញដ៏ល្អ ជាវិការនៃមាស ដ៏លើសលុប បូជាភ្លើង ទ្រង់បានជាទេវតាមួយអង្គ ។ បពិត្រសុភោគ ទន្លេគង្គា ប្រព្រឹត្តទៅដោយអានុភាពនៃព្រះរាជាណា ទឹកដោះដូរដែលស្ងប់ស្ងៀម ទៅជាសមុទ្រ ដោយអានុភាពនៃព្រះរាជាណា ព្រះរាជានោះ គឺព្រះបាទអង្គៈ មានរោមត្រង់ព្រះបាទ បម្រើភ្លើង ក៏ទ្រង់បានទៅកាន់បុរីនៃព្រះឥន្ទ ។

[ ៣៧៤ ] បពិត្រសុភោគ ទេវតាដ៏ប្រសើរមានឫទ្ធិច្រើន មានយស ជាសេនាបតីនៃព្រះបាទវាសវៈក្នុងស្ថានត្រៃត្រឹង្ស ព្រោះតែបានកម្ចាត់បង់នូវមន្ទិល ដោយសោមយាគវិធី ក៏បានជាទេវតាមួយអង្គ ។

[ ៣៧៥ ] ទេវតាដ៏ប្រសើរ ព្រហ្មមានឫទ្ធិច្រើន មានយសបាន សាងលោកនេះ និងលោកដទៃ និងស៊ឹងភាគីរថីផង ភ្នំហិមពាន្តផង ភ្នំវិជ្ឈៈផង ព្រហ្មនោះឯង ក៏បានបូជាភ្លើងក្នុងកាលនោះដែរ ។ ម្យ៉ាងទៀត ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ពួកព្រាហ្មណ៍ពោលថា ភ្នំទាំងនេះក្តី ភ្នំដទៃធំៗ ក្តី ពួកព្រាហ្មណ៍

អ្នកបូជាយញ្ញ បានធ្វើឲ្យវិចិត្រហើយ ។

[ ៣៧៦ ] ជនទាំងឡាយ បានពោលចំពោះព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈក្នុងលោកនេះថា ជាអ្នកប្រកបដោយការសូម សាគរបានពន្លិចព្រាហ្មណ៍នោះ ដែលស្ថិតនៅលើត្រើយ កំពុងសាចទឹកសមុទ្រ ហេតុនោះបានជាសមុទ្រមានទឹកប្រៃ ផឹកមិនបាន ។

[ ៣៧៧ ] ព្រាហ្មណ៍ទាំងឡាយ ជាវត្ថុសម្រាប់បូជា មានច្រើនលើផែនដី មានក្នុងទិសខាងកើត ទិសខាងលិច ទិសខាងត្បូង និងទិសខាងជើង តែងញុំាងសេចក្តីត្រេកអរឲ្យកើតដល់វាសវៈ ។

[ ៣៧៨ ] ( កូវិទត្ថនាគរាជ ... ) ម្នាលអរិដ្ឋ ការរៀនយកនូវវេទទាំងឡាយ ជាទោសរបស់អ្នកប្រាជ្ញទាំងឡាយ តែជាអំពើរបស់បុគ្គលពាលទាំងឡាយ ( ត្រៃវេទ ) ជាធម៌ដូចថ្ងៃបណ្តើរកូន ព្រោះសម្លឹងមើលទៅ មិនស្មើវេទទាំងឡាយជាចំណែកនៃកលឧបាយ ទង់ទាញអ្នកមានបញ្ញាមិនបានទេ ការពារជនអ្នកទ្រុស្តមិត្ត បំផ្លាញសេចក្តីចម្រើននោះ ក៏មិនបានទេ ភ្លើងដែលបុគ្គលបម្រើហើយ រមែងមិនការពារនូវសត្វមានកម្មបានទេ ជារបស់មិនប្រសើរ ប្រកបដោយទោស ។ មួយទៀត សត្វទាំងឡាយ មានទ្រព្យ មានភោគៈ យកទ្រព្យ

ទាំងអស់លាយដោយខស និងស្មៅ ហើយដុតភ្លើង មាន តេជះមិនមានអ្វីស្មើ កាលនេះវត្ថុដែលគេដុតហើយ ក៏មិន គប្បីឆ្អែត ម្នាលអ្នកដ៏ងរសដោយអណ្តាតទាំងពីរ ចុះបុគ្គល ណា គប្បីធ្វើភ្លើងនោះឲ្យឆ្អែតបាន ។ ទឹកៈមានការប្រែប្រួល ជាធម្មតា ក្លាយទៅជាទធិ ហើយទៅជានវនីត យ៉ាងណា ភ្លើងជាតេជោធាតុ មានការប្រែប្រួលជាធម្មតាយ៉ាងនោះដែរ លុះតែប្រកបដោយគ្រឿងពួត ទើបឆេះ ។ ភ្លើងដែលចូលទៅ ក្នុងឈើស្ងួត ឬឈើស្រស់ក៏មិនប្រាកដ ភ្លើងដែលនរជន មានឈើពំនូតក្នុងដៃមិនបានពួត ក៏មិនឆេះ ភ្លើងមិនមែនឆេះ ដោយការមិនធ្វើទេ ។ ប្រសិនបើភ្លើងនៅក្នុងឈើស្ងួត ឬឈើ ស្រស់នៅខាងក្នុង នៅក្នុងព្រៃទាំងអស់ ក្នុងលោក គប្បីស្ងួត ក្រៀម ឯឈើស្ងួតទាំងឡាយ គប្បីឆេះ ។ ថាបើនរជនញុំាង ភ្លើងដ៏ក្តៅ ប្រកបដោយផ្សែង និងអណ្តាត ឲ្យស៊ីដោយខស និងស្មៅ ឈ្មោះថា ធ្វើបុណ្យឬ ជនអ្នកធ្វើធ្យូង អ្នកធ្វើ អំបិល អ្នកធ្វើអាហារ និងអ្នកដុតសរីរៈនៃបុគ្គលស្លាប់ ឈ្មោះ ថា ធ្វើបុណ្យដែរឬ ។ ប្រសិនបើព្រាហ្មណ៍ទាំងនុ៎ះ ញុំាងការ រៀនមន្ត និងភ្លើង ឲ្យឆ្អែតក្នុងលោកនេះ ទើបឈ្មោះថា ធ្វើ បុណ្យ នរជនណាមួយក្នុងលោក កាលញុំាងភ្លើងមានកម្តៅ ប្រកបដោយផ្សែង និងអណ្តាតឲ្យស៊ី មិនឈ្មោះថា ធ្វើបុណ្យ

ទេ ។ ម្នាលអ្នកដឹងរសដោយអណ្តាតពីរ ( អគ្គិទេពរបស់អ្នក ) ដែលលោកគោរពហើយ ម្តេចក៏ស៊ីវត្ថុមានក្លិនមិនជាទីគាប់ចិត្ត មិនជាទីត្រេកអរនៃជនដ៏ច្រើន ដែលពួកមនុស្សតែងវៀរ ជាវត្ថុមិនប្រសើរនោះ ។ ពួកមនុស្សខ្លះពោលថា ភ្លើង ( ជាទេវតាមួយអង្គ ) ក្នុងពួកទេវតា ឯពួកមិលក្ខុជនពោលថា ទឹកជាទេវតា ជនទាំងអស់នុ៎ះពោលខុស ភ្លើងមិនមែនជាទេវតាណាមួយទេ ទឹកក៏មិនមែនដែរ ។ ភ្លើងមិនមានឥន្ទ្រិយ ជាពួកមិនមានចេតនា សម្រាប់ធ្វើការងាររបស់ពួកមនុស្ស អ្នកធ្វើបាបកម្មទាំងឡាយ កាលបម្រើភ្លើង គប្បីទៅកាន់សុគតិដូចម្តេចកើត ។ ពួកព្រាហ្មណ៍ ជាអ្នកត្រូវការដោយជីវិត ក្នុងលោកនេះ ពោលថា ( មហាព្រហ្ម ) ជាអ្នកគ្របសង្កត់លោកទាំងអស់ ហើយពោលថា ព្រហ្មជាអ្នកបម្រើភ្លើងដូច្នេះ បើ ( មហាព្រហ្ម ) មានអានុភាពជាងលោកទាំងអស់ មានអំណាចមិនមានអ្នកណាសាង ហេតុអ្វី ក៏សំពះភ្លើង ដែលខ្លួននិម្មិតវិញ ។ ពាក្យព្រាហ្មណ៍ជាពាក្យគួរសើច មិនគួរដល់ការពិនិត្យ ជាពាក្យមិនពិត ពួកព្រាហ្មណ៍ក្នុងកាលមុន តាក់តែង ( ពាក្យមិនពិត ) ព្រោះហេតុនៃសក្ការៈ ព្រាហ្មណ៍ទាំងនោះ កាលបើលាភសក្ការៈមិនកើតឡើងទេ ក៏តទូវសន្តិធម៌ពោល គឺលទ្ធិរបស់ខ្លួន ជាមួយនឹងពួកសត្វ ។ ពួកអ្នកប្រសើរ

( ព្រាហ្មណ៍ ) ប្រកាន់ការរៀនមន្ត ពួកជាធំជាងជន ( ក្សត្រិយ៍ ) ប្រកាន់ផែនដី ពួកវេស្សៈប្រកាន់ការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ការបម្រើ ផ្សេងៗ គ្នា សមគួរតាមប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបាន តាក់តែងហើយ ។ ប្រសិនបើពាក្យនុ៎ះ ជាពាក្យពិត ដូច យ៉ាងពាក្យដែលព្រាហ្មណ៍ទាំងឡាយពោលហើយនេះ បុគ្គល មិនមែនជាក្សត្រ មិនត្រូវបានរាជ្យដោយដាច់ខាត បុគ្គលមិន មែនជាព្រាហ្មណ៍ មិនគប្បីសិក្សានូវបទនៃមន្ត បុគ្គលវៀរ ចាកពួកវេស្សៈ មិនគប្បីធ្វើការភ្ជួររាស់ ពួកសូទ្រៈ មិនគប្បី រួចអំពីការប្រើនៃជនដទៃ ។ ពាក្យនេះ ជាពាក្យមិនពិត ព្រោះ ហេតុណា ( ហេតុនោះ ) ព្រាហ្មណ៍ទាំងនេះ ពោលពាក្យ កុហក ដើម្បីការបំពេញផ្ទៃ បុគ្គលអ្នកមិនមានប្រាជ្ញាទាំង ឡាយ រមែងជឿស៊ប់នូវពាក្យនោះ ចំណែកខាងពួកបណ្ឌិត រមែងឃើញហេតុនោះដោយខ្លួនឯង ។ ពួកក្សត្រិយ៍នាំយកពលី ( ហូតពន្ធ ) របស់ពួកវេស្សៈ ពួកព្រាហ្មណ៍កាន់យកគ្រឿង សស្ត្រាទាំងឡាយ ហើយដើរទៅ ( សម្លាប់សត្វ ) ហេតុអ្វី ព្រហ្មមិនធ្វើលោក ដែលជ្រួលជ្រើម បែកខ្ញែកបែបនោះ ឲ្យ ត្រង់ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះជាប្រធាន ជាម្ចាស់ លើកូតរបស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វី ក៏ចាត់ចែង

លោកទាំងអស់ឲ្យមានទុក្ខ ហេតុអ្វី មិនធ្វើលោកទាំងអស់ឲ្យបានសេចក្ដីសុខ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធានជាម្ចាស់លើកូតរបស់ពួកសត្វ ក្នុងលោកទាំងអស់ ហេតុអ្វីក៏ធ្វើលោកឲ្យវិនាស ដោយកលឧបាយ និងការញ៉ាំញី ដោយការពោលពាក្យកុហក ដែលមិនមែនជាធម៌ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើកូតរបស់ពួកសត្វក្នុងលោកទាំងអស់ ម្នាលអរិដ្ឋ ព្រហ្មជាម្ចាស់លើកូត មិនប្រកបដោយធម៌ទេ ព្រោះកាលបើធម៌មាន បែរជាចាត់ចែងអធម៌វិញ ។ បុគ្គលសម្លាប់កណ្ដូប កន្ទុំរុយ ពស់ កង្កែប ដង្កូវរុយ ទើបឈ្មោះថា បរិសុទ្ធ ឯធម៌ទាំងនេះ ជាធម៌របស់ពួកជនអ្នកនៅក្នុងដែនកម្ពុជៈដ៏ច្រើន ជាធម៌មានសភាពមិនប្រសើរ ជាធម៌មិនពិត ។

[ ៣៧៩ ] ប្រសិនបើអ្នកសម្លាប់នោះ បរិសុទ្ធ ឬអ្នកដែលត្រូវសម្លាប់នោះ ទៅកាន់ស្ថានសួគ៌បាន ពួកព្រាហ្មណ៍ គប្បីសម្លាប់ពួកព្រាហ្មណ៍ ឬសម្លាប់ពួកជនអ្នកជឿពាក្យព្រាហ្មណ៍នោះ ( មុន ) ។ មិនមានពួកម្រឹគ មិនមានពួកសត្វចិញ្ចឹមពួកគោណាមួយ អង្វរឲ្យសម្លាប់ខ្លួនទេ សត្វទាំងឡាយ ក្នុងលោកនេះ សុទ្ធតែញាប់ញ័រ ត្រូវការដោយជីវិត ( ព្រោះថា ) ជនទាំងឡាយ ប្រារព្ធនឹងសម្លាប់ សត្វទាំងឡាយ និង

សត្វចិញ្ចឹមក្នុងយញ្ញទាំងឡាយ ។ ពួកបុគ្គលពាល រមែង បើកមាត់និយាយ ដោយហេតុទាំងឡាយដ៏វិចិត្ត ក្នុងការលើកឡើងនូវសសរយញ្ញ និងទីចងនៃសត្វចិញ្ចឹមថា សសរយញ្ញនេះ បង្ករសេចក្តីប្រាថ្នាដល់អ្នកក្នុងបរលោក នឹងឲ្យសេចក្តីទៀងទាត់ក្នុងបរលោក ។ ប្រសិនបើបុគ្គលគប្បីបានកែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ និងមាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ ម្យ៉ាងទៀត ប្រសិនបើសសរយញ្ញ គប្បីបង្ករសេចក្តីប្រាថ្នាគ្រប់យ៉ាងក្នុងស្ថានសួគ៌ ពួកជនអ្នកចេះត្រៃវេទដ៏ច្រើន គប្បីបូជាបុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីបូជាតិចតួចទេ ។ កែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ មាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ នឹងមានពីណា សសរយញ្ញនឹងបង្ករសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងស្ថានសួគ៌ដូចម្តេចកើត ។ ពួកព្រាហ្មណ៍ជាអ្នកបោកប្រាស ចិត្តអាក្រក់ ជាពួកពាល ប្រលោមលោក តែងបើកមាត់និយាយ ដោយហេតុដ៏វិចិត្រថា អ្នកឯងចូរយកភ្លើងចុះ ហើយឲ្យទ្រព្យដល់យើង លំដាប់នោះ អ្នកឯងនឹងបាននូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយនឹងដល់នូវសេចក្តីសុខ ។ ពួកព្រាហ្មណ៍ នាំបុគ្គលជាសរណៈ ( ព្រះរាជា និងមហាមាត្យ ) ចូលទៅកាន់រោងសម្រាប់បូជាភ្លើងនោះ ក៏បើកមាត់

និយាយ ដោយហេតុដ៏វិចិត្រ ឲ្យកោរសក់ ពុកមាត់ កាត់ក្រចក ហើយគាបយកទ្រព្យ ដោយវេទទាំងឡាយ ។ ពួកព្រាហ្មណ៍ជាអ្នកកុហកដ៏ច្រើន បានទាយកម្នាក់ហើយ ក៏ចោមស៊ីបាយ ដូចជាក្អែកទាំងឡាយ ចោមចាប់មៀមក្នុងទីស្ងាត់ កុហកធ្វើឲ្យលើងហើយ ដាក់ចុះទៅក្នុងផ្លូវនៃយញ្ញ ។ ទាយកតែម្នាក់នោះ ត្រូវពួកព្រាហ្មណ៍បញ្ឆោតហើយ ដោយអាការយ៉ាងនេះឯង ព្រាហ្មណ៍ទាំងនោះជាច្រើន ចោមប្ចូន់ដោយការប្រកបដោយឧបាយ ក៏នាំយកទ្រព្យដែលឃើញ ដោយទេវលោក ដែលមិនឃើញសោះ ។ ដូចយ៉ាងពួករាជបុរសដែលព្រះរាជាប្រើទៅហើយ ក៏នាំយកទ្រព្យនោះរបស់គេ ម្នាលអរិដ្ឋ ពួកព្រាហ្មណ៍ប្រាកដដូច្នោះ ប្រហែលគ្នានឹងពួកចោរជាអសប្បុរស ជាបុគ្គលគួរសម្លាប់ តែគេមិនសម្លាប់ក្នុងលោក ។ ពួកព្រាហ្មណ៍បានកាត់ដើមចារ មកប្រើក្នុងវិធីយញ្ញ ( ប្រាប់ថា នេះ ) ជាដៃស្តាំរបស់ព្រះឥន្ទ្រ បើពាក្យនោះពិត ព្រះឥន្ទ្រទៅជាដាច់ដៃ ចុះព្រះឥន្ទ្រឈ្នះពួកអសុរដោយកម្លាំងដៃដូចម្តេច ។ ពាក្យនោះ ទទេសោះ ព្រះឥន្ទ្រនៅមានដើមដៃគ្រប់គ្រាន់ ជាទេវតាដ៏ប្រសើរ មិនមានអ្នកណាសម្លាប់បាន បានកម្ចាត់ពួកអសុរ មន្តទាំងឡាយនេះរបស់ពួកព្រាហ្មណ៍ មានសភាពជារបស់ទទេ នេះជាការ

បញ្ចោត ដែលគេឃើញច្បាស់ក្នុងលោក ។ ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ភ្នំទាំងនុ៎ះក្តី ភ្នំធំៗ ឯទៀតក្តី ព្រាហ្មណ៍ទាំងឡាយពោលថា ពួកព្រាហ្មណ៍អ្នកបូជាយញ្ញ កសាងហើយដ៏វិចិត្រ ដូច្នោះ ។ ព្រាហ្មណ៍ទាំងឡាយពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ កាន់យកឥដ្ឋទាំងឡាយ មានបការយ៉ាងណា ធ្វើវិចិត្រហើយ ភ្នំទាំងឡាយមិនមែនមានបការដូច្នោះទេ ឯភ្នំទាំងឡាយ មិនដូចរបស់ដទៃទេ ជារបស់មិនកម្រើក ជាថ្មសុទ្ធ ដែលគេឃើញច្បាស់ ។ ភ្នំទាំងឡាយ មិនមែនជាឥដ្ឋទេ ជាថ្មយូរយារហើយ ដែកមិនមែនកើតក្នុងឥដ្ឋនោះទេ លោហៈក៏មិនមែនកើតក្នុងឥដ្ឋនោះដែរ ពួកព្រាហ្មណ៍ កាលសរសើរនូវយញ្ញនេះ បានពោលថា ភ្នំទាំងឡាយដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ ធ្វើវិចិត្រហើយ ។ ព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ បានពោលនូវព្រាហ្មណ៍អ្នករៀនមន្ត្រ បរិបូណ៌ដោយគុណនៃមន្ត្រ មានតបៈថា ជាអ្នកប្រកបដោយការស្មូម សាគរពន្លិចព្រាហ្មណ៍នោះ ដែលកំពុងសាចទឹកនៃសមុទ្រលើប្រាំង ព្រោះហេតុនោះ បានជាទឹកសមុទ្រនោះប្រៃ ផឹកមិនបាន ។ ស្ទឹងទាំងឡាយ ក្ជួចយកពួកព្រាហ្មណ៍ អ្នកបរិបូណ៌ដោយវេទ បរិបូណ៌ដោយមន្ត្រ ច្រើន

ជាងពាន់នាក់ ទឹកទាំងឡាយមិនខូចរស ព្រោះហេតុនោះទេ សមុទ្ទមិនមានអ្វីស្មើ មានរសប្រៃ ផឹកមិនបាន តើព្រោះហេតុអ្វី ។ អណ្ដូងខ្លះ ក្នុងជីវលោកនេះ មានទឹកប្រៃ ដែលពួកជនអ្នកផឹកអណ្ដូង បានផឹកហើយ ម្នាលអ្នកជីងរសដោយអណ្ដាតទាំងពីរ ជនទាំងឡាយមិនពោលថា ទឹកក្នុងអណ្ដូងទាំងនេះ មានរសប្រៃផឹកមិនបាន ព្រោះតែក្ដួចយកព្រាហ្មណ៍ទេ ។ តាំងពីមុនដំបូងមក ស្ត្រីណាជាភរិយារបស់បុរសណា មានោបានញ៉ាំងមនុស្ស ឲ្យកើតឡើងក្នុងកាលមុន មិនមានអ្នកណាមួយ ថោកទាបជាងគ្នាដោយធម៌នោះ ព្រាហ្មណ៍ទាំងឡាយបានពោលនូវការចែក ( វណ្ណៈ ) ដោយការលះបង់ ( ធម៌នោះ ) យ៉ាងនេះឯង ។ សូម្បីកូនចណ្ឌាល ជាអ្នកឈ្លាសវៃមានប្រាជ្ញា បានរៀនវេទទាំងឡាយ ពោលមន្តទាំងឡាយ ក្បាលនៃកូនជនចណ្ឌាលនោះ មិនបែកជា ៧ ភាគទេ មន្តទាំងនេះ ពួកព្រាហ្មណ៍ធ្វើហើយ ដើម្បីសម្លាប់ខ្លួន ។ វាចាកុហក ពួកព្រាហ្មណ៍បានតាក់តែងហើយ ការចង់បាន ពួកព្រាហ្មណ៍បានតាក់តែង កាន់យកហើយ ការកើតឡើងតាមគន្លងនៃកាព្យឃ្លោង ដែលគេស្រោយបានដោយក្រ ចិត្តរបស់បុគ្គលពាលទាំងឡាយ ជឿស៊ប់ក្នុងអំពើមិនស្មើ បុគ្គលឥតប្រាជ្ញា រមែងជឿពាក្យនោះ ។ ព្រាហ្មណ៍មិន ( ប្រកប )

ដោយកម្លាំងដ៏មាំ ដូចកម្លាំងនៃរាជសីហ៍ ខ្វាធំ និងខ្វាដំបង មនុស្សភាព ( របស់ព្រាហ្មណ៍ទាំងនោះ ) ត្រូវយល់ថា ដូចគោដែរ ព្រោះជាតិរបស់ព្រាហ្មណ៍ទាំងនោះ ស្មើ ( ដោយគោ ) ស្មើដោយសីហៈជាដើម ។ ប្រសិនបើព្រះរាជាឈ្នះផែនដី ប្រកបដោយអាមាត្យ មានអ្នកស្តាប់បង្គាប់ មានបរិស័ទ ព្រះរាជានោះ គប្បីឈ្នះពួកសត្រូវដោយព្រះអង្គឯង ប្រជាជនរបស់ព្រះរាជានោះ គប្បីបានសេចក្តីសុខជានិច្ច ។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ ( តែក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី ) មិនបានវិនិច្ឆ័យនូវអត្ថនៃមន្ត និងវេទទាំងនោះទេ ទាំងមិនដឹង ដូចបុគ្គលកាលមិនដឹងផ្លូវដែលកំបាំងដោយទឹក ។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ លាភ ឥតលាភ យស និងឥតយស ទាំងអស់នេះ ជាធម៌របស់វណ្ណៈទាំង ៤ នោះ ។ ពួកគហបតីជាច្រើនលើផែនដី ញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ព្រោះហេតុតែទ្រព្យ និងស្រូវ យ៉ាងណា សូម្បីពួកអ្នកមានត្រៃវេទជាច្រើនលើផែនដី ក៏ញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ក្នុងថ្ងៃនេះ យ៉ាងនោះដែរ ។ ព្រាហ្មណ៍ទាំងនោះ ស្មើគ្នានឹងគហបតី ព្រាហ្មណ៍ទាំងឡាយជាច្រើនលើផែនដី ជាអ្នកខ្វល់ខ្វាយជានិច្ច ប្រកបក្នុងកាមគុណទាំងឡាយ តែងញុំាងបុគ្គល

ឲ្យធ្វើការងារទាំងឡាយ ម្នាលអរិដ្ឋ អ្នកជីនរសេដោយអណ្តាត ទាំងពីរ ព្រោះហេតុនោះ ព្រាហ្មណ៍ទាំងនោះ ជាអ្នកឥតបញ្ញា ។

[ ៣៨០ ] ( ព្រះបាទសាគរព្រហ្មទត្ត ... ) ស្គរធំ សម្ភោរ សង្ខ ស្គរជ័យ និងស្គរទ័ព របស់អ្នកណាដែលដើរខាងមុខ ហើយញុំាងព្រះរាជាដ៏ប្រសើរ ក្នុងរថឲ្យរីករាយ ។ ( សម្បុរមុខ ) របស់អ្នកណា ( ដ៏រុងរឿង ) ដោយដំបារមាសដ៏ក្រាស់ មានពន្លឺដូចផ្លេកបន្ទោរ អ្នកណានៅកំលោះ ប្រដាប់ដោយបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក ។ មុខអ្នកណា ស្រស់បស់ដូចមាសឆ្អិន លើមាត់ជើងក្រាន ឬប្រាកដស្មើដោយរងើកនៃឧសគគីរ អ្នកណារុងរឿងដោយសិរី ហើយដើរមក ។ ឆត្ររបស់បុគ្គលណា ជាវិការនៃមាសជម្ពូនទ ប្រកបដោយឆ្អឹង ជាទីរីករាយនៃចិត្ត ជាគ្រឿងបិទបាំងរស្មីនៃព្រះអាទិត្យ អ្នកណារុងរឿងដោយសិរី ហើយដើរមក ។ អង្គ ( អ្នកកាន់ផ្ចិត ) បានកាន់យកវាលវីជនីដ៏ឧត្តមខាងលើក្បាលទាំងពីរខាង នៃបុគ្គលមានបញ្ញាដ៏ប្រសើរណា ។ បាច់នៃកន្ទុយក្ងោកដ៏វិចិត្រផង ទន់ផង មានដងជាវិការនៃមាស និងកែវមណី ប្រព្រឹត្តទៅទាំងពីរ ខាងមុខរបស់បុគ្គលណា ។ កុណ្ឌលទាំងឡាយនេះ ដ៏ល្អ មានពន្លឺដូចជាពណ៌រងើកភ្លើងនៃឧសគគីរ ដ៏ភ្លឺលើមាត់ជើងក្រាន រមែងរុងរឿង

ទាំងពីរខាងមុខ របស់បុគ្គលណា ។ សក់របស់បុគ្គលណា មានចុងដ៏ស្និទ្ធ ទន់ ខ្មៅ ត្រូវខ្យល់បក់ហើយ ក៏ញុំាងទីបំផុតនៃថ្ងាសឲ្យល្អ ដូចជាផ្លេកបន្ទោរ ដែលចេញអំពីមេឃ ។ ភ្នែកទាំងនេះ វែង ធំ របស់អ្នកណា អ្នកណាមានភ្នែកទូលាយសម មុខនេះរបស់អ្នកណា ភ្លឺថ្លះដូចកញ្ចក់មាស មាត់នេះរបស់អ្នកណា ដ៏ស្អាត ដូចជាស័ង្ខដ៏ប្រសើរ ធ្មេញរបស់បុគ្គលណា កាលនិយាយឡើង ដូចជាផ្កាមណ្ឌាក្រពុំ ។ ដៃនិងជើងទាំងឡាយរបស់អ្នកណា ដូចជាទឹកល័ក្ត តាំងនៅក្នុងសេចក្តីសុខ អ្នកណាមានរីមបបូរមាត់ ដូចផ្លែបាស ដ៏ល្អ ដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ ។ អ្នកណា មានសំពត់បាវារៈដ៏សដូចដើមរាំងដ៏ធំមានផ្ការីកហើយ ក្នុងព្រៃហិមពាន្ត ក្នុងកាលដែលកន្ទងទៅនៃទឹកសន្សើម ល្អដូចព្រះឥន្ទ្រ ដែលមានជ័យជម្នះ ។ អ្នកណានៅក្នុងបរិស័ទ ដោះដាវនៅលើស្មា ដែលមានដងដ៏វិចិត្រដោយកែវមណី ដ៏ដេរដាសដោយពក ជាវិការនៃមាស ។ អ្នកណាដោះស្បែកជើង ដែលប៉ាក់ដោយមាសវិចិត្រដោយកែវ ៧ ប្រការ ដេរដោយសូត្រដ៏វិចិត្រ រចនាល្អហើយ ក៏ថ្វាយបង្គំតាបស អ្នកស្វែងរកគុណដ៏ធំ ។

[ ៣៨១ ] ( តាបសជាបិតា ... ) នាគទាំងនោះ ជានាគមានឫទ្ធិ មានយស ជាកូននៃព្រះបាទធតរដ្ឋ កើតអំពីនាងសមុទ្ទជា នាគទាំងនេះ សុទ្ធតែជានាគមានឫទ្ធិច្រើន ។

## ភូរិទត្តជាតកទី ៦ ចប់

# អដ្ឋកថា

# ខុទ្ទកនិកាយ ជាតក

# ឯកាទសមភាគ

## មហានិបាតជាតក

### ភូរិទត្តជាតក

[ ២៩៤-៣៨១ ] ព្រះសាស្តា កាលទ្រង់អាស្រ័យក្រុងសាវត្ថី គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកអ្នករក្សាឧបោសថទាំងឡាយ ហើយត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យង្កិញ្ចិ រតនមត្ថិ** ដូច្នេះ ។

បានឮថា ក្នុងថ្ងៃឧបោសថ ឧបាសកទាំងនោះ អធិដ្ឋានឧបោសថអំពីព្រលឹម ថ្វាយទាន ខាងក្រោយភត្ត កាន់យកគ្រឿងក្រអូប និងផ្កាជាដើមទៅកាន់វត្តជេតពន ក្នុងវេលាស្តាប់ធម៌ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ក្នុងកាលនោះ ព្រះសាស្តាយាងមកកាន់ធម្មសភា គង់លើធម្មាសនៈដែលគេតាក់តែង ទ្រង់ទតភិក្ខុសង្ឃ គិតថា ធម្មកថាតាំងឡើង ប្រារព្ធបុគ្គលពួកណាក្នុងបណ្តាភិក្ខុជាដើម ព្រះតថាគតទាំងឡាយ ទ្រង់ចរចាប្រាស្រ័យជាមួយបុគ្គលទាំងនោះ ព្រោះហេតុនោះ ថ្ងៃនេះ ទ្រង់ជ្រាបថា ធម្មកថាដែលទាក់ទងនឹងបុព្វចរិយាតាំងឡើង ប្រារព្ធឧបាសកទាំងឡាយ ដូច្នេះហើយ ទើបទ្រង់ចរចាជាមួយឧបាសកទាំងនោះ ហើយត្រាស់សួរថា ម្នាលឧបាសកទាំងឡាយ

ពួកអ្នករក្សានូវឧបោសថឬ កាលឧបាសកទាំងឡាយទូលឲ្យទ្រង់ជ្រាប ទើបត្រាស់ថា សាធុ ឧបាសកទាំងឡាយ ការដែលអ្នកបានព្រះពុទ្ធដូចតថាគតជាអ្នកឲ្យឱវាទ គប្បីធ្វើឧបោសថ រាប់ថា អ្នកធ្វើកម្មស្អាត មិនគួរអស្ចារ្យឡើយ បុរាណកបណ្ឌិត មិនមានអាចារ្យលះនូវយសធំ ធ្វើឧបោសថបានដូចគ្នា ដូច្នេះហើយ ទ្រង់ក៏នៅស្ងៀម កាលឧបាសកទាំងឡាយទូលអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល មានព្រះរាជាមួយអង្គ ព្រះនាមព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់ប្រទានតំណែងឧបរាជដល់ព្រះរាជបុត្រ ទតឃើញយសធំរបស់ព្រះរាជបុត្រនោះ ទ្រង់កើតសេចក្ដីសង្ស័យឡើងថា ព្រះរាជឱរសអាចដណ្ដើមរាជសម្បត្តិរបស់អញក៏ថាបាន ទើបត្រាស់ឲ្យហៅព្រះរាជឱរសនោះមក ត្រាស់ថា នែបា ឯងមិនអាចនៅទីនេះ ចូរឯងចេញទៅអំពីទីនេះ ហើយនៅក្នុងទីដែលឯងគាប់ចិត្ត អំណឹះតតពីបិតាទៅ សឹមមកកាន់យករាជសម្បត្តិ ដែលជារបស់ត្រកូល ។ ព្រះរាជឱរសទទួលព្រះរាជតម្រាស់ហើយថ្វាយបង្គំលាព្រះរាជបិតា ចេញអំពីព្រះនគរ ទៅកាន់ស្ទឹងយមុនាដោយលំដាប់ ហើយឲ្យសាងបណ្ណសាលាក្នុងរវាងស្ទឹងយមុនា សមុទ្រ និងភ្នំ មានឫសឈើ និងផ្លែឈើជាអាហារ អាស្រ័យនៅក្នុងទីនោះ ។ កាលនោះ នាគមាណវិកាដែលមានប្ដីស្លាប់ក្នុងនាគពិភព ស្ថិតនៅត្រង់ប្រាំងសមុទ្រ សម្លឹងមើលយសអ្នកដទៃដែលមានប្ដី អាស្រ័យកិលេសក៏អផ្សុក ទើបចេញពីនាគពិភព ត្រាច់ទៅតាមឆ្នេរសមុទ្រ ឃើញស្នាមជើងព្រះរាជឱរស ក៏ដើរ

តាមស្នាមជើង បានឃើញបណ្ណសាលានោះ ។ កាលនោះ ព្រះរាជឱរសបាន ចេញទៅព្រៃ ដើម្បីរកផ្លែឈើ ។ នាងចូលទៅកាន់បណ្ណសាលា ឃើញកម្រាល ធ្វើដោយស្បែកឈើ និងបរិក្ខារផ្សេងៗ ទៀត ទើបគិតថា នេះប្រហែលជា លំនៅរបស់បព្វជិតណាមួយ អញនឹងសាកល្បងមើលថា តើគេបួសដោយ សទ្ធាដែរឬហ្ន៎ បើបួសដោយសទ្ធា និងបង្អោនទៅក្នុងនេក្ខម្មៈ គេមិនត្រេកអរ ក្នុងការដេកលើដំណេកដែលអញតាក់តែង បើគេមានចិត្តត្រេកអរក្នុងកាម មិនបួសដោយសទ្ធា នឹងដេកលើដំណេកដែលអញរៀបចំ បើដូច្នេះ អញនឹង ចាប់យកធ្វើជាប្ដីរបស់អញ ហើយនៅក្នុងទីនេះឯង ។ នាងទៅកាន់ភពនាគ នាំយកផ្កាទិព្វ និងគ្រឿងក្រអូបទិព្វមកចាត់ចែងទីដេក ដែលសម្រេចដោយ ផ្កា បាននាំផ្កាមកទុកត្រង់បណ្ណសាលា រោយនូវគ្រឿងក្រអូប ប្រដាប់តាក់ តែងបណ្ណសាលា ហើយទៅកាន់នាគពិភព ។

ព្រះរាជឱរសយាងមកក្នុងពេលល្ងាច ចូលទៅកាន់បណ្ណសាលា ទ្រង់ ឃើញការប្រព្រឹត្តទៅនោះ ក៏គិតថា អ្នកណាហ្ន៎រៀបចំទីដេក ដូច្នេះហើយ ទើបសោយផ្លែឈើតូចធំ គិតថា គួរអស្ចារ្យ ផ្កាមានក្លិនក្រអូប គួរអស្ចារ្យ ផ្កាមានក្លិនក្រអូប អ្នកណារៀបចំទីដេក ឲ្យជាទីគាប់ចិត្តរបស់អញ កើត សោមនស្សឡើង ព្រោះមិនមែនបួសដោយសទ្ធា ទើបដេកបម្រះននៀលទៅ មកលើសយនាផ្កា ឈានចុះកាន់និទ្រា ។

ស្អែកឡើង កាលព្រះអាទិត្យរះ ក្រោកឡើងមិនបោសបណ្ណសាលា ចេញទៅព្រៃ ដើម្បីរកឫសឈើ និងផ្លែឈើតូចធំក្នុងព្រៃ ។ ក្នុងខណៈនោះ

នាគមាណវិកាឃើញផ្កាស្វិតស្រពោន ដឹងថា បុរសនេះ បង្អោនចិត្តទៅក្នុងកាម មិនមែនបួសដោយសទ្ធា អញអាចចាប់បុរសនេះបាន ដូច្នេះហើយ នាំយកផ្កាចាស់ៗចេញទៅ យកផ្កាដទៃៗ មករៀបចំដំណេកយ៉ាងនោះឯង រៀបចំបណ្ណសាលា រោយនូវផ្កាក្នុងទីចង្ក្រម ហើយទៅកាន់នាគពិភពវិញ ។ សូម្បីក្នុងថ្ងៃនោះ ព្រះរាជឱរសក៏ដេកលើដំណេកផ្កា ស្អែកឡើង ក៏គិតថា អ្នកណាហ្ន៎ ប្រដាប់បណ្ណសាលានេះ ។ ទ្រង់មិនទៅរកផ្លែឈើតូចធំ បានឈរក្នុងទីកំបាំងមិនឆ្ងាយអំពីបណ្ណសាលា ។ ឯនាគមាណវិកា កាន់យកគ្រឿងក្រអូបនិងផ្កាជាច្រើន មកកាន់អាស្រមបទ ។ ព្រះរាជឱរស កាលឃើញនាងនាគ-មាណវិកាទ្រទ្រង់នូវរូបឆោមដ៏ត្រកាល មានចិត្តប្រតិព័ទ្ធ មិនបង្ហាញខ្លួន ចូលទៅកាន់បណ្ណសាលា ក្នុងកាលដែលនាងរៀបចំផ្កា ហើយសួរថា នាងជានរណា នាងឆ្លើយថា ខ្ញុំឈ្មោះនាគមាណវិកា ។ ព្រះរាជឱរស សួរថា នាងមានប្ដីហើយឬនៅ ។ នាងឆ្លើយថា ពីមុនខ្ញុំមាន តែឥឡូវនេះ ខ្ញុំមិនមាន ជាស្រីមេម៉ាយ ចុះអ្នកវិញនៅឯណា ព្រះឱរសឆ្លើយថា ខ្ញុំឈ្មោះព្រហ្មទត្តកុមារជាបុត្ររបស់ព្រះបាទពារាណសី ចុះនាង ព្រោះហេតុអ្វី ទើបលះនូវនាគ-ពិភព មកក្នុងទីនេះ ។ នាងឆ្លើយថា ខ្ញុំសម្លឹងមើលយសរបស់នាគមាណវិកាដែលមានប្ដីក្នុងទីនោះ អាស្រ័យកិលេស ទើបអផ្សុក ក៏ចេញអំពីភពនាគស្វែងរកស្វាមី ព្រះរាជឱរសត្រាស់ថា នែនាង ខ្ញុំក៏មិនមែនបួសដោយសទ្ធាព្រោះត្រូវបិតាបណ្ដេញ ទើបមកក្នុងទីនេះ នាងកុំគិតថ្វី ខ្ញុំនឹងជាប្ដីរបស់នាងជនទាំង ២ ក៏បាននៅរួមសង្វាសគ្នាក្នុងទីនោះឯង ។ នាងសាងដំណាក់ដែល

មានតម្លៃច្រើន ដោយអានុភាពរបស់ខ្លួន ហើយនាំបល្ល័ង្កដែលមានតម្លៃច្រើន តាក់តែងទីដេក ។ ចាប់ពីនោះមក ព្រះរាជឱរសនោះ មិនបានសោយឫសឈើ និងផ្លែឈើតូចធំ សោយតែបាយ និងទឹកដែលជាទិព្វប៉ុណ្ណោះរស់នៅ ។

ក្នុងកាលតមក នាគមាណវិកាក៏តាំងគភ៌ ប្រសូតរាជបុត្រ ពួកញាតិបានដាក់ឈ្មោះថា សាគរព្រហ្មទត្ត ព្រោះប្រសូតត្រង់ឆ្នេរសមុទ្រ ក្នុងពេលចេះដើរ នាគមាណវិកាក៏ប្រសូតព្រះរាជបុត្រី ពួកញាតិបានដាក់ឈ្មោះថា សមុទ្ទជា ព្រោះកើតត្រង់ឆ្នេរសមុទ្រ ។ ពេលវេលាកន្លងទៅ កាលនោះ ព្រានព្រៃអ្នកក្រុងពារាណសីម្នាក់ មកដល់ទីនោះហើយ បានធ្វើបដិសណ្ឋារៈក៏ស្គាល់ព្រះឱរស នៅក្នុងទីនោះ ២-៣ ថ្ងៃ ហើយពោលថា បពិត្រសម្មតិទេព ទូលបង្គំនឹងប្រាប់ភាពដែលទ្រង់នៅទីនេះដល់រាជត្រកូល ថ្វាយបង្គំហើយក៏ចេញពីទីនោះ ចូលទៅកាន់ព្រះនគរ ។ ក្នុងកាលនោះ ព្រះរាជាក៏សោយទិវង្គត ពួកអមាត្យបានធ្វើសរីរកិច្ចដល់ទ្រង់ ហើយប្រជុំគ្នាក្នុងថ្ងៃទី ៧ ប្រឹក្សាគ្នាថា ឈ្មោះថា រាជសម្បត្តិដែលមិនមានព្រះរាជា រមែងតាំងនៅមិនមាន ពួកយើងមិនដឹងលំនៅរបស់ព្រះរាជឱរស តើទ្រង់នៅមានជីវិត ឬក៏មិនមាន ទើបផ្សងបុស្សរថ ស្វែងរកព្រះរាជា ។ ខណៈនោះ ព្រានព្រៃចូលទៅកាន់ព្រះនគរ ដឹងរឿងនោះរបស់អមាត្យទាំងនោះ ទើបទៅកាន់សម្នាក់របស់អមាត្យ ហើយប្រាប់រឿងនោះថា ខ្ញុំនៅក្នុងសម្នាក់របស់ព្រះរាជឱរស ៣-៤ ថ្ងៃហើយ ទើបមក ។ លំដាប់នោះ អមាត្យទាំងឡាយបានស្តាប់ដូច្នោះហើយ បានធ្វើសក្ការៈដល់ព្រានព្រៃ មានព្រានព្រៃជាមគ្គុទ្ទេសក៍ទៅកាន់ទីនោះ បាន

ធ្វើបដិសណ្ឋារៈ ហើយប្រាប់កាលដែលព្រះរាជាសោយទិវង្គត ទូលថា សូមទ្រង់គ្រងរាជសម្បត្តិចុះ ។ ព្រះរាជឱរសទ្រង់ព្រះតម្រិះថា អញនឹងដឹងចិត្តរបស់នាគមាណវិកា ដូច្នេះហើយ ចូលទៅរកនាង សួរថា នែនាងដ៏ចម្រើន បិតារបស់យើងសោយទិវង្គតហើយ អមាត្យទាំងឡាយមកក្នុងទីនេះ ដើម្បីលើកនូវស្វេតច្ឆត្រឲ្យយើង មកយើងទៅទាំងអស់គ្នា យើងទាំង ២ នឹងគ្រងរាជសម្បត្តិក្នុងនគរពារាណសីប្រមាណ ១២ យោជន៍ នាងជាធំជាងស្រី ១ ម៉ឺន ៦ ពាន់នាក់ ។ នាងពោលថា បពិត្រព្រះស្វាមី ខ្ញុំម្ចាស់មិនអាចទៅជាមួយទ្រង់បាន ព្រះរាជឱរសសួរថា ព្រោះហេតុអ្វី នាងពោលថា ខ្ញុំម្ចាស់ជាអាសិរពិសកាច ក្រោធរហ័ស ខឹងក្រោធដោយហេតុត្រឹមតែតិចតួច ឈ្មោះថា ការមានស្រីរួមប្តីជាការៈធ្ងន់ បើខ្ញុំឃើញ ឬបានឮសំឡេងណាមួយហើយមានចិត្តខឹងក្រោធ សម្លឹងមើលអ្នកណាមួយ នឹងឆេះជាផេះផង់ធូលី ព្រោះហេតុនោះ ខ្ញុំមិនអាចទៅជាមួយទ្រង់បានទេ ស្អែកឡើង ព្រះរាជឱរសក៏នៅតែអង្វរនោះឯង លំដាប់នោះ ទើបនាងពោលនឹងព្រះរាជាថា ខ្ញុំម្ចាស់នឹងមិនទៅដោយបរិយាយណាមួយឡើយ ឯនាគកុមារកូនរបស់យើងនេះ មានជាតិជាមនុស្ស ព្រោះកើតដោយការសម្ពាធជាមួយទ្រង់ បើបុត្រទាំងនោះ មានសេចក្តីស្រឡាញ់ក្នុងខ្ញុំម្ចាស់ សូមទ្រង់កុំប្រមាទក្នុងបុត្រទាំងនោះ តែបុត្រទាំងនេះជាសុខុមាលជាតិ កាលធ្វើដំណើរត្រូវលំបាកដោយខ្យល់ និងកម្ដៅថ្ងៃ គប្បីស្លាប់ ហើយទើបឲ្យធ្វើទូកមួយ ដាក់ទឹកឲ្យពេញ ឲ្យកូនលេងទឹកហើយធ្វើដំណើរទៅ គប្បីជីកស្រះបោក្ខរណីក្នុងទីជិតព្រះនគរ ដើម្បីកូនទាំង

នោះ កាលនាងពោលយ៉ាងនេះហើយ ថ្វាយបង្គំព្រះរាជឱរស ធ្វើប្រទក្សិណ ឱបព្រះរាជបុត្រាបុត្រីទាំង ២ ទុកក្នុងរវាងទ្រូង ថើបក្បាល ប្រគល់ឲ្យដល់ព្រះស្វាមី ទូលលាហើយ ហើយអន្តរធានទៅក្នុងទីនោះឯង បានទៅប្រាកដក្នុងនាគពិភពវិញ ។ ឯព្រះរាជាដល់នូវទោមនស្ស មានមុខជោកដោយទឹកភ្នែក ចេញអំពីនិវេស ជូតព្រះនេត្រហើយ ទៅរកពួកអមាត្យ ។ ពួកអមាត្យទាំងនោះអភិសេកព្រះរាជាក្នុងទីនោះឯង ក៏ទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំនឹងទៅកាន់នគររបស់ពួកយើង ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរពួកអ្នកប្រញាប់ធ្វើទូក ហើយលើកដាក់រទេះ ចាក់ទឹកឲ្យពេញ ហើយរោយនូវផ្កាផ្សេងៗ ដែលសម្បូរដោយពណ៌ និងក្លិនលើផ្ទៃទឹក ព្រោះកូនទាំង ២ របស់យើង មានពូជកើតអំពីទឹក កូនទាំងនោះនឹងលេងទឹកក្នុងទីនោះ ទើបទៅសប្បាយ ។ ពួកអមាត្យបានធ្វើយ៉ាងនោះ ។ ព្រះរាជាយាងដល់នគរពារាណសី ចូលកាន់ព្រះនគរដែលតាក់តែង ចោមរោមទៅដោយអ្នករបាំ និងអមាត្យជាដើមប្រមាណ ១ ម៉ឺន ៦ ពាន់នាក់ ប្រថាប់គង់ក្នុងមហាប្រាសាទ សោយនូវទឹកមហាបានអស់ ៧ ថ្ងៃ ហើយសាងស្រះបោក្ខរណី ដើម្បីជាប្រយោជន៍ដល់បុត្រ ។ ពួកបុត្រទាំងនោះបានលេងក្នុងទីនោះជានិច្ចកាល ។ សម័យក្រោយមក កាលបុត្រទាំង ២ នាំគ្នាលេងទឹកក្នុងស្រះបោក្ខរណី អណ្តើកមួយចូលទៅកាន់ព្រះរាជវាំង រកកន្លែងចេញមិនឃើញ ក៏ចុះទៅកាន់ស្រះបោក្ខរណី ក្នុងពេលដែលព្រះរាជកុមារទាំង ២ លេងទឹក ក៏ផុសអំពីទឹកអើតក្បាលឡើង ឃើញពួកក្មេងទាំងនោះ ក៏មុជចុះទៅក្នុងទឹកវិញ ។ ពួក

ក្មេងទាំងនោះ ឃើញអណ្តើកនោះ ភ័យខ្លាច ទៅកាន់សម្នាក់របស់ព្រះបិតា ក្រាបទូលថា បពិត្រព្រះបិតា ក្នុងស្រះបោក្ខរណីមានយក្ខមួយ ធ្វើពួកខ្ញុំឲ្យខ្លាច ។ ព្រះរាជាបញ្ជាពួករាជបុរសថា ពួកអ្នកចូរទៅចាប់យក្ខនោះមក ។ ពួករាជបុរសក៏យកសំណាញ់ទៅបង់ក្នុងទឹក ហើយនាំយកអណ្តើកមកថ្វាយព្រះរាជា ។ ព្រះរាជកុមារឃើញអណ្តើកនោះហើយ ស្រែកថា បពិត្របិតា នេះឯងបិសាច បពិត្របិតា នេះឯងបិសាច ។ ព្រះរាជាទ្រង់ខ្ញាល់នឹងអណ្តើក ព្រោះស្រឡាញ់ក្នុងបុត្រ ក៏ត្រាស់ថា ចូរពួកអ្នកធ្វើកម្មករណ៍ដល់អណ្តើកនេះ ។ បណ្តារាជបុរសទាំងនោះ រាជបុរសម្នាក់ពោលថា អណ្តើកនេះ បង្កពៀរវេរាដល់ព្រះរាជា ខ្ញុំនឹងយកវាដាក់ក្នុងត្បាល់ ហើយបុកដោយអង្រែ ឲ្យទៅជាលម្អិត ។ អមាត្យមួយពួកទៀតពោលថា ខ្ញុំនឹងអាំងឲ្យឆ្អិនក្នុងភ្លើង អស់វារៈ ៣ ដងហើយ សឹមបរិភោគ ។ អមាត្យពួកខ្លះពោលថា យើងគួរចាប់វាឲ្យដេកផ្ងារ ហើយដុតវាលើរងើកភ្លើង ។ អមាត្យពួកខ្លះពោលថា យើងគួរស្ងោរវាក្នុងខ្ទះ ។ អមាត្យម្នាក់ទៀត ដែលជាអ្នកខ្លាចទឹកពោលថា យើងគួរបោះវាត្រង់កន្លែងទឹកកួចត្រង់ស្ទឹងយមុនា វានឹងដល់សេចក្តីវិនាសធំក្នុងទីនោះ ព្រោះការដាក់ទោសរបស់អណ្តើកនេះ ឲ្យខ្លាំងក្លាជាងនេះ មិនមាន ។ អណ្តើកស្តាប់ពាក្យរបស់អមាត្យនោះ ក៏អើតក្បាលឡើងពោលថា បពិត្រលោកម្ចាស់ ខ្ញុំធ្វើអ្វីខុស បានជាលោកនឹកឃើញដល់កម្មករណ៍ គឺយកខ្ញុំទៅបោះក្នុងទឹកកួចបែបនេះ ខ្ញុំអាចអត់ទ្រាំនឹងកម្មករណ៍ដទៃបាន តែកម្មករណ៍មួយនេះឃោរឃៅណាស់ លោកកុំធ្វើបែបនេះឡើយ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ គិត

ថា អញគួរធ្វើសេចក្តីទុក្ខដល់អណ្តើកនេះ ដូច្នេះហើយ ទើបឲ្យយកទៅបោះក្នុងទីដែលទឹកក្តួចខ្លាំងក្នុងស្ទឹងយមុនា ។ អណ្តើកកាលធ្លាក់ដល់ក្នុងទឹក ទឹកនោះក៏ក្តួចរហូតទៅដល់ពិភពនាគ ។ គ្រានោះ ពួកនាគកំលោះជាកូនរបស់ស្តេចនាគ ឈ្មោះធតរដ្ឋ កំពុងលេងក្នុងទីទឹកក្តួច ឃើញអណ្តើកនោះ ក៏ពោលថា ចូរពួកលោកចាប់អណ្តើកនេះធ្វើជាទាសៈ អណ្តើកគិតថា អញផុតអំពីកណ្តាប់ដៃស្តេចពារាណសី ឥឡូវនេះ មកធ្លាក់ដល់កណ្តាប់ដៃរបស់ពួកនាគដែលឃោរឃៅបែបនេះ អញគប្បីផុតដោយឧបាយដូចម្តេចហ្ន៎ អណ្តើកនោះគិតថា ឧបាយនេះប្រើការបាន អញគប្បីពោលមុសាវាទ ទើបរួចខ្លួនហើយពោលថា ពួកលោកមកពីសម្នាក់របស់ស្តេចឈ្មោះធតរដ្ឋ ហេតុអ្វីមកពោលទឹងយើងយ៉ាងនេះ យើងឈ្មោះចិត្តចូឡៈ ជាទូតនៃព្រះបាទពារាណសីមកកាន់សម្នាក់របស់នាគឈ្មោះធតរដ្ឋ ព្រះរាជារបស់យើងបំណងនឹងឲ្យព្រះធីតាដល់ស្តេចនាគឈ្មោះធតរដ្ឋ ទើបបញ្ជូនយើងមក ចូរពួកលោកបង្ហាញយើងដល់ស្តេចនាគនោះចុះ ។ នាគមាណពទាំងនោះជឿហើយ កើតសោមនស្ស នាំអណ្តើកនោះទៅកាន់សម្នាក់ព្រះរាជា ក្រាបទូលសេចក្តីនោះហើយ ។ ព្រះរាជាត្រាស់ឲ្យហៅអណ្តើកនោះមកដោយពាក្យថា ចូរនាំគេមកចុះ លុះឃើញអណ្តើកនោះ ក៏មិនពេញព្រះហឫទ័យ ត្រាស់ថា ឯងមានរូបរាងអាក្រក់បែបនេះ មិនអាចធ្វើទូតកម្មបានទេ អណ្តើកស្តាប់ពាក្យនោះហើយក្រាបទូលថា បពិត្រមហារាជ ឈ្មោះថា ទូត ទាល់តែមានរាងកាយប៉ុនដើមត្នោតឬ សេចក្តីពិត រាងកាយតូច ឬធំ មិនជាប្រមាណឡើយ ការធ្វើកម្ម

ក្នុងទីដែលទៅហើយឲ្យសម្រេចបាននោះឯង ទើបជាប្រមាណ ។ ទូតជាច្រើនរបស់ព្រះរាជានៃមនុស្ស រមែងធ្វើកម្មលើគោក បក្សីធ្វើកម្មលើអាកាស ឯទូលបង្គំចិត្តបូឡៈ ដល់នូវឋាននន្តរ ជាទីប្រោសប្រាណរបស់ព្រះរាជា ជាអ្នកគ្រប់គ្រងស្រុក រមែងធ្វើកម្មក្នុងទឹក សូមទ្រង់កុំសម្លុត ឬមើលងាយទូលបង្គំឡើយ ដូច្នេះហើយ ទើបសរសើរគុណរបស់ខ្លួន ។ លំដាប់នោះ ស្តេចនាគធតរដ្ឋ ត្រាស់សួរអណ្តើកនោះថា អ្នកជាបុគ្គលដែលព្រះរាជាបញ្ជូនមកដើម្បីអ្វី អណ្តើកពោលថា បពិត្រមហារាជ ព្រះរាជារបស់ខ្ញុំត្រាស់នឹងខ្ញុំយ៉ាងនេះថា យើងនឹងធ្វើមិត្តធម៌ជាមួយព្រះរាជាទាំងអស់ក្នុងជម្ពូទ្វីប ឥឡូវនេះ យើងគួរធ្វើមិត្តធម៌ជាមួយស្តេចនាគធតរដ្ឋ យើងនឹងលើកនាងសមុទ្ទជាដែលជាធីតាដល់ស្តេចនាគធតរដ្ឋ ទើបបញ្ជូនខ្ញុំមក សូមទ្រង់កុំបង្អែបង្អង់ សូមបញ្ជូនបុរសទាំងឡាយទៅ និងកំណត់ថ្ងៃទទួលនាងទារិកាចុះ ។ ស្តេចនាគនោះត្រេកអរ ឲ្យធ្វើសក្ការៈហើយ បញ្ជូននាគមាណព ៤ នាក់ទៅជាមួយអណ្តើកនោះ ដោយពាក្យថា ពួកលោកទៅចុះ ចូរស្តាប់ពាក្យរបស់ព្រះរាជាកំណត់ថ្ងៃហើយចូរមក ។ នាគមាណពទាំងនោះទទួលពាក្យហើយ ក៏នាំអណ្តើកចេញពីនាគពិភព ។

អណ្តើកឃើញស្រះឈូកមួយ ក្នុងរវាងស្ទឹងយមុនា និងនគរពារាណសី មានបំណងនឹងគេចខ្លួនដោយឧបាយណាមួយ ទើបពោលថា នៃនាគមាណពទាំងឡាយដ៏ចម្រើន ព្រះរាជារបស់យើង មួយអន្ទើដោយបុត្រ កិរិយារបស់ទ្រង់ ឃើញយើងត្រាច់ទៅក្នុងទឹក ទៅកាន់រាជនិវេសន៍ផ្តាំផ្ញើថា ចូរលោក

កាច់ផ្កាឈូកមកថ្វាយដល់យើង ចូរឲ្យក្រអៅឈូក យើងនឹងកាន់យកក្រអៅឈូកទាំងនោះ ដើម្បីជាប្រយោជន៍ដល់ព្រះរាជាអង្គនោះ ។ ចូរពួកលោកលែងខ្ញុំក្នុងទីនេះ បើពួកលោកមិនឃើញយើង ក៏ចូរទៅកាន់សម្នាក់ព្រះរាជាមុនចុះ យើងនឹងជួបគ្នាក្នុងទីនោះ ។ នាគមាណពទាំងនោះ ជឿពាក្យរបស់អណ្ដើក បានលែងអណ្ដើកនោះទៅ អណ្ដើកបានពួនក្នុងចំណែកម្ខាងក្នុងទីនោះ ។ ឯនាគមាណពមិនឃើញអណ្ដើក ក៏ទៅគាល់ព្រះរាជា ដោយភេទនៃមាណពតាមសញ្ញាថា យើងនឹងទៅកានរាជសម្នាក់ ។

**កច្ឆបកណ្ឌ ចប់**

ព្រះរាជាទ្រង់ធ្វើបដិសណ្ឋារៈ ហើយត្រាស់សួរថា ពួកលោកមកអំពីណា នាគមាណពក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំមកអំពីសម្នាក់របស់ស្ដេចនាគឈ្មោះធតរដ្ឋ ។ ព្រះរាជាសួរថា ព្រោះហេតុអ្វី ទើបពួកលោកមកទីនេះ នាគមាណពទាំងឡាយទូលថា បពិត្រមហារាជ ពួកខ្ញុំព្រះអង្គជាទូតរបស់ស្ដេចនាគធតរដ្ឋនោះ ស្ដេចនាគធតរដ្ឋសួរដល់ការមិនមានរោគរបស់ព្រះអង្គ បើទ្រង់ប្រាថ្នាវត្ថុណា សូមទ្រង់ប្រទានរបស់នោះដល់ខ្ញុំ បានឮថា ទ្រង់នឹងប្រទាននាងសមុទ្ទជាដែលជាធីតារបស់ទ្រង់ ឲ្យធ្វើជាបាទបរិចារិការបស់ព្រះរាជាពួកខ្ញុំ ដូច្នេះហើយ កាលប្រកាសសេចក្ដីនោះ ទើបពោលគាថាទី ១ ថា

រតនៈណាមួយ មានក្នុងនិវេសន៍របស់នាគរាជ ព្រះនាមធតរដ្ឋ
រតនៈទាំងអស់នោះ ចូរមកដល់ព្រះអង្គ សូមព្រះអង្គទ្រង់
ប្រទានធីតាដល់ព្រះរាជាយើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វានិ តេ ឧបយន្តុ** សេចក្ដីថា រតនៈទាំងអស់ក្នុងនិវេសន៍ស្ដេចធតរដ្ឋនោះ ចូរមក គឺចូរចូលមកកាន់និវេសន៍របស់ទ្រង់ ។

ព្រះរាជាកាលបានស្ដាប់ ទើបត្រាស់គាថាទី ២ ថា

វិវាហៈជាមួយនឹងពួកនាគ យើងមិនធ្លាប់ធ្វើ ក្នុងកាលណាម្ដងទេ យើងនឹងធ្វើវិវាហៈ មិនសមគួរនោះ ដូចម្ដេចកើតដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសំយុត្តំ** សេចក្ដីថា មិនសមគួរ គឺមិនសមជាមួយសត្វតិរច្ឆាន ។ បទថា **អម្ហេ** សេចក្ដីថា ពួកយើងជាជាតិមនុស្សនឹងធ្វើសម្ពន្ធជាមួយសត្វតិរច្ឆានដូចម្ដេចកើត ។ ពួកនាគមាណព បានស្ដាប់ពាក្យនោះហើយ ទើបពោលថា បើការសម្ពន្ធជាមួយស្ដេចនាគធតរដ្ឋ មិនសមគួរជាមួយទ្រង់ ចុះហេតុអ្វី ទើបបញ្ជូនចិត្តចូឡៈ ដែលជាឧបដ្ឋាករបស់ខ្លួន ទៅជាទូតដល់ព្រះរាជារបស់ពួកយើងថា យើងនឹងឲ្យធីតារបស់យើងឈ្មោះ សមុទ្ទា ដល់ព្រះអង្គទៅវិញ កាលបញ្ជូនសាសន៍យ៉ាងនេះហើយឥឡូវនេះ ទ្រង់ធ្វើនូវការមើលងាយព្រះរាជារបស់ពួកយើងៗ ឈ្មោះថា ជានាគមាណព នឹងដឹងកម្មដែលគួរធ្វើដល់ទ្រង់ កាលគំរាមព្រះរាជា ទើបពោលគាថាដូច្នេះថា

បពិត្រព្រះអង្គ ជាធំជាងមនុស្ស ជីវិតក្ដី ដែនក្ដី ព្រះអង្គនឹង

លះបង់ដោយពិត កាលបើនាគខឹងហើយ ព្រះរាជាទាំងឡាយ
ប្រហែលនឹងព្រះអង្គ មិនគង់ព្រះជន្មនៅយូរទេ ។ បពិត្រព្រះ
សម្មតិទេព ព្រះអង្គណាជាមនុស្ស ព្រះអង្គនោះ មិនមានឫទ្ធិ
មើលងាយព្រះរាជាដែលមានឫទ្ធិ ជាកូនបង្កើតនៃព្រះបាទវរុណៈ
ដែលកើតក្នុងទន្លេយមុនា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រដ្ឋំ វា** សេចក្តីថា ជីវិតក្តី រដ្ឋក្តី ទ្រង់នឹងលះបង់ដោយចំណែកមួយ ។ បទថា **តាធិសា** សេចក្តីថា ព្រះរាជាទាំងឡាយដូចទ្រង់ ត្រូវនាគមានអានុភាពច្រើនក្រោធហើយយ៉ាងនេះ មិនអាចធ្វើជីវិតឲ្យស្ថិតនៅបានយូរឡើយ រមែងអន្តរធានទៅក្នុងរវាងនោះឯង ។ បទថា **យោ ត្វំ ទេវ** សេចក្តីថា បពិត្រព្រះសម្មតិទេព ទ្រង់សូម្បីជាមនុស្ស ។ បទថា **វរុណស្ស** បានដល់ ស្តេចនាគឈ្មោះវរុណៈ ។ បទថា **និយំ បុត្តំ** បានដល់ កូនដែលកើតក្នុងខ្លួន ។ បទថា **យាមុនំ** បានដល់ កើតខាងក្រោមស្ទឹងយមុនា ។

លំដាប់នោះ ព្រះរាជាបានត្រាស់ ២ គាថាថា

យើងមិនមើលងាយ ព្រះបាទធតរដ្ឋ ដ៏មានយសទេ ព្រោះថា
ព្រះបាទធតរដ្ឋ ជាធំជាងនាគទាំងឡាយដ៏ច្រើន ។ ពស់ទុកជា
មានអានុភាពច្រើន ក៏មិនសមគួរនឹងធីតារបស់យើងទេ ចំណែក
ខាងយើង ជាក្សត្ររបស់អ្នកដែនវិទេហៈ ធីតា ( របស់យើង )
ឈ្មោះសមុទ្ទជា មានជាតិដ៏ប្រសើរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពហុយោជនេ** នេះ ព្រះរាជាពោលសំដៅយកភាពជាធំនៃកពនាគប្រមាណ ៥០០ យោជន៍ ។ បទថា **ន មេ ធីតរមរហោ** សេចក្ដីថា ទោះបីទ្រង់មានអានុភាពច្រើនយ៉ាងនេះ ក៏មិនសមគួរដល់ធីតានៃយើង ព្រោះទ្រង់ជាអហិជាតិ គឺមានពូជជាពស់ ។ ព្រះរាជាកាលសម្ដែងដល់បុគ្គលជាញាតិចំណែកខាងមាតា ទើបត្រាស់ថា **ខត្តិយោ ច វិទេហានំ** ដូច្នេះ ។ បទថា **សមុទ្ទជា** នេះ ព្រះរាជាត្រាស់ថា ក្សត្រដែលជាព្រះរាជឱរសរបស់ព្រះបាទវិទេហៈនោះ និងនាងសមុទ្ទជាដែលជាធីតារបស់យើង សូម្បីទាំងពីរនោះ ជាអភិជាតិ សមគួរដល់សង្វាសដល់គ្នានិងគ្នា ព្រោះនាងមិនគួរដល់ពស់ដែលមានកង្កែបជាអាហារឡើយ ។

ពួកនាគមាណព បានស្ដាប់ដូច្នោះហើយ គិតនឹងសម្លាប់ព្រះរាជាដោយខ្យល់ក្នុងច្រមុះក្នុងទីនោះឯង តែគិតថា បើពួកយើងត្រូវព្រះរាជាបញ្ជូនមកដើម្បីកំណត់ថ្ងៃ កាលបើសម្លាប់ព្រះរាជានេះ មិនសមគួរឡើយ ពួកយើងនឹងក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ដូច្នេះហើយ ទើបក្រោកចាកទីនោះ ចេញពីព្រះរាជនិវេសន៍ មុជផែនដីទៅកាន់ទីនោះ ត្រូវស្ដេចនាគសួរថា នៃបាទាំងឡាយ ពួកលោកបានព្រះរាជធីតាហើយឬ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់បញ្ជូនពួកខ្ញុំទៅក្នុងទីណាមួយ ព្រោះហេតុដែលមិនសមគួរសោះឡើយ បើទ្រង់ប្រាថ្នាសម្លាប់ សូមទ្រង់សម្លាប់ពួកខ្ញុំក្នុងទីនេះឯង ព្រះរាជានោះ ជេរបរិភាសទ្រង់ ដោយលើកនូវមានះក្នុងជាតិ ដូច្នេះហើយ ក្រាបទូលដល់ភាពដែលព្រះរាជានោះពោល និងមិនបានពោល ធ្វើការក្រោធឲ្យ

កើតឡើងដល់ស្តេចនាគៗ កាលបញ្ជាឲ្យប្រជុំបរិស័ទ ទើបត្រាស់ថា

ពួកនាគឈ្មោះកម្ពលស្សតរា ចូរក្រោកឡើង អ្នកចូរប្រាប់នាគ ទាំងអស់ថា នាគទាំងឡាយ ចូរទៅកាន់ក្រុងពារាណសី តែកុំ បៀតបៀនបុគ្គលណាមួយឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កម្ពលស្សតរា** ស្តេចនាគ កាលបញ្ជាថា នាគឈ្មោះកម្ពលស្សតរ ដែលជាចំណែកខាងមាតារបស់យើង ដែលនៅត្រង់ជើងភ្នំសិនេរុ នាគទាំងនោះ ចូរក្រោកឡើង និងនាគដទៃដែលធ្វើតាមពាក្យរបស់យើងក្នុងទិសធំទាំង ៤ ក្នុងទិសតូចទាំង ៤ មានប្រមាណប៉ុនណា ចូរទៅប្រាប់នាគទាំងអស់នោះឲ្យជ្រាបដំណឹងថា ចូរពួកអ្នកប្រញាប់ប្រជុំគ្នា ទើបបានត្រាស់យ៉ាងនោះ ។ លំដាប់នោះ ពួកនាគទាំងអស់នោះ ប្រជុំគ្នាយ៉ាងប្រញាប់ ទូលថា ពួកខ្ញុំនឹងធ្វើដូចម្តេច ស្តេចនាគត្រាស់ថា នាគរបស់យើងទាំងអស់ ចូរប្រញាប់ទៅកាន់ក្រុងពារាណសី កាលពួកនាគទាំងនោះពោលថា ពួកខ្ញុំទៅក្នុងទីនោះគប្បីធ្វើអ្វី ពួកខ្ញុំធ្វើនគរនោះ ឲ្យក្លាយជាផេះដោយខ្យល់ក្នុងប្រមុះឬ ។ ស្តេចនាគមិនប្រាថ្នាសេចក្តីវិនាសដល់នាងសមុទ្ទជា ព្រោះមានចិត្តប្រតិព័ទ្ធក្នុងព្រះរាជធីតា ទើបត្រាស់ថា ពួកនាគមិនគប្បីបៀតបៀនអ្នកណាម្នាក់ឡើយ អធិប្បាយថា បណ្តាពួកលោកមិនគប្បីបៀតបៀនអ្នកណាម្នាក់ឡើយ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។

លំដាប់នោះ ទើបពួកនាគពោលនឹងស្តេចនាគថា បពិត្រមហារាជ បើមិនបៀតបៀនមនុស្សខ្វះ ពួកយើងទៅក្នុងទីនោះធ្វើអ្វី ។ លំដាប់នោះ ទើប

ព្រះរាជាត្រាស់នឹងពួកនាគនោះថា ចូរពួកលោកធ្វើវត្ថុនេះ និងវត្ថុនេះ យើងក៏នឹងធ្វើវត្ថុឈ្មោះនេះ ដូច្នេះហើយ ទើបត្រាស់ប្រាប់ ២ គាថាថា

នាគទាំងឡាយ ដែលមានសរីរៈធំ ចូលសំយុងខ្លួនក្នុងនិវេស-
នដ្ឋានទាំងឡាយ ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុង
ឈើ និងលើខ្លោងទ្វារ ។ ចំណែកខាងខ្ញុំ មានកាយធំសសុទ្ធ នឹង
ព័ទ្ធបុរីដែលធំទូលាយ ដោយភ្នែនទាំងឡាយ នឹងញុំាងភ័យឲ្យ
កើតឡើង ដល់ពួកអ្នកដែនកាសី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោព្ភេសុ** បានដល់ ក្នុងស្រះបោក្ខរណី ។ បទថា **រថិយា** បានដល់ ត្រង់ផ្លូវដើរ ។ បទថា **លម្ពន្តុ** បានដល់ សំយុងចុះ ។ បទថា **វិតតា** សេចក្ដីថា ស្ដេចនាគបញ្ជាថា ចូរនាគទាំងឡាយបើកពពារធ្វើរាងកាយឲ្យធំ សំយុងត្រង់ផ្ទះជាដើមនោះ និងត្រង់ខ្លោងទ្វារ ត្រង់សសរទាំងឡាយ ចូរធ្វើត្រឹមប៉ុណ្ណោះ កាលនឹងធ្វើ ជាដំបូងត្រូវនិម្មិតកាយឲ្យធំ និងបើកពពារឲ្យធំ ខាងក្នុងបន្ទប់ និងខាងក្រៅបន្ទប់ជាដើម ខាងក្រោម និងខាងលើគ្រែ ឬតាំង ត្រង់ផ្ទះ ត្រង់ផ្លូវដើរជាដើម លើទឹក ក្នុងស្រះបោក្ខរណី និងលើគោកត្រង់ផ្ទះ បង្អួយផ្សែង ដូចស្នប់របស់ជាងលោហៈ ចូរធ្វើសំឡេង **សុសុ** សំយុងខ្លួន ហើយដេក តែកុំបង្ហាញខ្លួនដល់ជន ៤ ពួក គឺកុមារ មនុស្សចាស់ជរា ស្រីមានទម្ងន់ និងនាងសមុទ្ទជា ឯខ្ញុំក៏ទៅដោយរាងកាយដ៏ធំដែលមានពណ៌សសុទ្ធ ព័ទ្ធដែនកាសីជុំវិញ ៧ ជាន់ គ្របដោយពពារធំ ធ្វើឲ្យងងឹត ឲ្យកើតការខ្លាចដល់អ្នកកាសី ខ្ញុំនឹងបន្លឺសំឡេងថា

**សុសុ** ដូច្នេះ ។ នាគទាំងឡាយបានធ្វើយ៉ាងនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

នាគទាំងឡាយ មានសម្បុរដ៏ច្រើន បានស្តាប់ពាក្យព្រះបាទធតរដ្ឋ នោះហើយ ក៏ចូលទៅកាន់ក្រុងពារាណសី តែមិនបៀតបៀន បុគ្គលណាមួយឡើយ ។ នាគទាំងឡាយ ដែលមានសរីរៈធំ ក៏ សំយុងខ្លួន ក្នុងនិវេសនដ្ឋាន ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើខ្លោងទ្វារ ។ នារីទាំងឡាយជាច្រើន បាន ឃើញនាគទាំងនុ៎ះ កំពុងសំយុងខ្លួន លុះឃើញពួកនាគបើកពពារ កំពុងឲ្យសំឡេងរឿយៗ ក៏កន្ទក់កន្ទេញ ។ ពួកជនក្នុងពារាណសី តក់ស្លុតក្តៅក្រហាយ ក៏លើកដៃកន្ទក់កន្ទេញថា សូមព្រះអង្គ ប្រទានធីតាដល់នាគរាជ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនេកវណ្ណា នោ** សេចក្តីថា នាគទាំងនោះ កាឡាខ្លួនច្រើនយ៉ាង ដោយអំណាចនៃពណ៌ មានពណ៌ខៀវជាដើម និម្មិតរូប បែបនោះ ។ បទថា **បវដ្ឋិំសុ** សេចក្តីថា នាគទាំងនោះ ចូលទៅក្នុងពេល យប់ ។ បទថា **លម្ពឹសុ** សេចក្តីថា ដោយទំនងដែលស្តេចធតរដ្ឋពោលហើយ នោះឯង នាគទាំងអស់សំយុងខ្លួន ផ្តាច់ការទៅមករបស់ពួកមនុស្ស ក្នុងទី នោះៗ ឯនាគមាណពទាំង ៤ ដែលជាទូត មករុំជើងព្រះទែនបន្ទំរបស់ព្រះ

រាជា បើកពពារធំលើព្រះសិរសា បានបញ្ចេញចង្អូម ហាក់ដូចចង់ខាំសីសៈដោយមាត់ ។ ព្រះបាទធតរដ្ឋត្រាស់ឲ្យបិទព្រះនគរ ដោយទំនងដែលខ្លួនពោលហើយនោះឯង បុរសទាំងឡាយកាលភ្ញាក់ឡើង សណ្ដូកដៃ-ជើង ទៅកាន់ទីណា ក៏ប៉ះពស់ក្នុងទីនោះៗ ហើយស្រែកថា ពស់ ពស់ ដូច្នេះ ។ បទថា **បុព្វំ កន្ទិំសុ** សេចក្ដីថា ប្រទីបដែលអុជក្នុងផ្ទះណាៗ ស្រីទាំងឡាយក្នុងផ្ទះនោះៗ ភ្ញាក់ឡើងហើយ សម្លឹងមើលសសរ ធ្នឹម ឃើញនាគសំយុងស្រែកព្រមៗ គ្នានោះឯង ព្រះនគរទាំងមូល បានកើតកោលាហលតែមួយដោយប្រការដូច្នេះ ។ បទថា **សោណ្ឌិកតេ** បានដល់ បើកពពារ ។ បទថា **បក្ខន្ទុំ** សេចក្ដីថា កាលរាត្រីអស់ហើយ កាលនគរទាំងមូល និងព្រះរាជ-និវេសន៍ ត្រូវគ្របសង្កត់ដោយខ្យល់ដង្ហើមរបស់ពួកនាគ មនុស្សទាំងឡាយនាំគ្នាខ្លាច ទើបពោលនឹងនាគរាជទាំងឡាយថា ពួកលោកបៀតបៀនពួកយើងដើម្បីអ្វី ពួកនាគទាំងឡាយប្រាប់ថា ព្រះរាជារបស់ពួកអ្នក បញ្ជូនទូតទៅដល់ស្ដេចធតរដ្ឋថា ទ្រង់នឹងលើកព្រះរាជធីតាឲ្យដល់ព្រះរាជារបស់យើង កាលទូតរបស់ស្ដេចនាគមកក្រាបទូលថា សូមទ្រង់ព្រះរាជទាន ( ធីតា )ចុះក៏បែរជាជេរបរិភាសព្រះរាជារបស់ពួកយើង ពួកទូតដែលជានាគពោលថា បើមិនឲ្យធីតាដល់ព្រះរាជារបស់ពួកយើង ជីវិតរបស់អ្នកនគរទាំងមូលនឹងមិនមាន ពួកអ្នកស្រុកអង្វរថា បើដូច្នោះ សូមពួកលោកឲ្យឱកាស ដល់ព្រះរាជារបស់យើង ពួកយើងនឹងទៅអង្វរព្រះរាជា ។ បានឱកាសហើយទៅកាន់ ទ្វារនគរ នាំគ្នាស្រែកដោយសំឡេងខ្លាំង ។ ឯមហេសីរបស់ព្រះរាជា

ផ្ទំក្នុងបន្ទប់រៀងៗ ខ្លួន ស្រែកយំពោលថា សូមទ្រង់ឲ្យធីតាដល់ស្តេចធតរដ្ឋចុះ ។

ចំណែកនាគមាណពទាំង ៤ នោះ បានបញ្ឈរខ្លួន ហាក់ដូចជាយកមាត់ ត្របាក់សីសៈថា ចូរឲ្យ ចូរឲ្យ ព្រះរាជាកំពុងផ្ទំ បានស្តាប់សំឡេងអ្នកនគរ និងព្រះមហេសីរបស់ព្រះអង្គកំពុងយំស្រែក ហើយទ្រង់ត្រូវនាគ-មាណពគំរាម ក៏តក់ស្លុតចំពោះមរណភ័យ ទើបត្រាស់ឡើង ៣ ដងថា យើងនឹងឲ្យនាងសមុទ្ទជា ជាធីតារបស់យើងដល់ស្តេចធតរដ្ឋ ។

នាគរាជទាំងអស់ កាលបានស្តាប់ព្រះតម្រាស់នោះហើយ ក៏ត្រឡប់ទៅកាន់ទីប្រមាណមួយគាវុត សាងនគរឡើងមួយកន្លែង ដូចទេវនគរ បាននៅក្នុងទីនោះ ទើបបញ្ជូនបណ្ណាការទៅថា បានឮថា ទ្រង់បញ្ជូនព្រះធីតា ព្រះរាជាកាន់យកគ្រឿងបណ្ណាការដែលពួកនាគនាំមក ទើបបញ្ជូនពួកនាគទាំងនោះទៅថា ពួកលោកទៅចុះ យើងនឹងបញ្ជូនធីតាទៅក្នុងការគ្រប់គ្រងរបស់ពួកអមាត្យនៃយើង ហើយត្រាស់ឲ្យហៅធីតាមក ឡើងកាន់ប្រាសាទខាងលើ ឲ្យបើកសីហបញ្ជរ ហើយឲ្យសញ្ញាថា នែបុត្រី ចូរកូនមើលនគរដែលគេតាក់តែងហើយនេះ កូននឹងជាអគ្គមហេសីរបស់ព្រះរាជាក្នុងទីនេះ នគរនោះ មិនឆ្ងាយអំពីនេះ បើកូនកើតអផ្សុកក្នុងនគរនោះ កូនអាចមកក្នុងទីនេះបាន ហើយគប្បីមកក្នុងទីនេះ ហើយឲ្យស្រេពស្រង់ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ឲ្យអង្គុយលើវែដលបិទបាំងហើយ បានបញ្ជូនទៅក្នុងការគ្រប់គ្រងនៃអមាត្យរបស់ ព្រះអង្គ ។ ស្តេចនាគទាំងឡាយ ធ្វើការទទួលព្រះរាជធីតា

ហើយបានធ្វើមហាសក្ការៈ អមាត្យទាំងឡាយចូលទៅកាន់ព្រះនគរ ថ្វាយព្រះធីតានោះដល់ស្តេចនាគ បានកាន់យកទ្រព្យជាច្រើន ហើយត្រឡប់មក ។ ស្តេចនាគឲ្យព្រះធីតាឡើងកាន់ប្រាសាទ ឲ្យផ្ទុំលើបន្ទំដែលជាទិព្វ ដែលប្រដាប់តាក់តែង ។ ក្នុងខណៈនោះឯង ពួកនាគមាណវិកា កាឡាខ្លួនជាមនុស្សគមមនុស្សតឿជាដើម ចោមរោមព្រះធីតា ដូចពួកបរិចារិការបស់ពួកមនុស្ស ព្រះធីតាផ្ទុំលើព្រះបន្ទំដ៏ជាទិព្វ ត្រូវសម្ផស្សដែលជាទិព្វប៉ុណ្ណោះ ក៏ឈានចុះកាន់និទ្រា ។ ព្រះបាទធតរដ្ឋនាំព្រះធីតា មួយអន្លើដោយនាគបរិស័ទបាត់អំពីទីនោះ បានប្រាកដក្នុងភពនាគ ។ ព្រះរាជធីតាទ្រង់តើនឡើង ទតឃើញទីបន្ទំដែលជាទិព្វ ដែលតាក់តែង និងទីដទៃ ដូចជាប្រាសាទដែលសម្រេចដោយមាស និងសម្រេចដោយកែវមណី ព្រះរាជឧទ្យាន ស្រះបោក្ខរណី និងភពនាគ ដូចទេវនគរ ដែលតាក់តែង ទើបត្រាស់សួរស្រីបម្រើ មានស្រីគមជាដើមថា នគរនេះ ជាងរចនាស្អាតពន់ពេក មិនដូចនគររបស់យើង នគរនេះ ជានគររបស់អ្នកណា ពួកស្រីបម្រើទូលថា បពិត្រព្រះទេវី នេះជានគររបស់ស្វាមីព្រះនាង អ្នកមានបុណ្យតិច មិនបានសម្បត្តិបែបនេះឡើយ នាងបានសម្បត្តិនេះ ព្រោះនាងមានបុណ្យច្រើន ចំណែកព្រះបាទធតរដ្ឋត្រាស់ឲ្យវាយស្គរ ប្រកាសក្នុងនាគពិភព ប្រមាណ ៥០០ យោជន៍ថា អ្នកណាបង្ហាញភេទជាពស់ឲ្យព្រះនាងសមុទ្ទជាឃើញ អ្នកនោះ នឹងត្រូវរាជទណ្ឌ ។ ព្រោះហេតុនោះ ឈ្មោះថា បុគ្គលអាចបង្ហាញភេទជាពស់ដល់ព្រះនាងសូម្បីតែមួយមិនមានឡើយ ព្រោះសម្គាល់ថា ជាមនុស្សលោក ព្រះនាងក៏ត្រេកអរ

ជាមួយព្រះបាទធតរដ្ឋនោះ ក្នុងទីនោះឯង នូវសង្វាសដោយសេចក្តីស្រឡាញ់ ដោយអាការយ៉ាងនេះ ។

នគរកណ្ឌ ចប់

សម័យក្រោយមក ព្រះនាងអាស្រ័យស្តេចធរតដ្ឋ ក៏មានព្រះគភ៌ ប្រសូតព្រះឱរស ពួកញាតិបានដាក់ឈ្មោះថា **សុទស្សនៈ** ព្រោះមើលហើយ នាំឲ្យកើតសេចក្តីស្រឡាញ់ ក្នុងកាលព្រះរាជឱរសដើរបាន ព្រះនាងក៏ប្រសូត្រ ព្រះរាជឱរសមួយអង្គទៀត ព្រះញាតិបានដាក់ឈ្មោះថា **ទត្តៈ** ជាតួអង្គព្រះ ពោធិសត្វ ។ ព្រះនាងប្រសូតឱរសមួយអង្គទៀត ពួកញាតិបានដាក់ឈ្មោះថា សុ **ភោគៈ** ។ ព្រះនាងប្រសូតព្រះឱរសមួយអង្គទៀត ពួកញាតិបានដាក់ ឈ្មោះថា **អរិដ្ឋៈ** ដូច្នោះ ព្រះនាងសូម្បីប្រសូតព្រះរាជឱរស ៤ អង្គហើយ ក៏នៅតែមិនដឹងថា ជាកពរបស់នាគ ។ ថ្ងៃមួយ ពួកនាគកំលោះប្រាប់ដល់ ព្រះរាជឱរសឈ្មោះអរិដ្ឋៈថា មាតារបស់ទ្រង់ជាមនុស្ស មិនមែនជានាគ ព្រះ រាជឱរសព្រះនាមអរិដ្ឋៈគិតថា អញនឹងពិសោធមាតានោះ ថ្ងៃមួយ ពេល សោយទឹកដោះ ទើបនិម្មិតខ្លួនជាពស់ យកកន្ទុយគ្ពឹះខ្នងជើងមាតា ព្រះនាង ឃើញសរីរៈពស់របស់ព្រះរាជឱរសព្រះនាមអរិដ្ឋៈ មានព្រះហឫទ័យភ័យខ្លាច ស្រែក ហើយបោះព្រះរាជឱរសទៅលើផែនដី ព្រះនេត្ររបស់ព្រះរាជឱរស នោះ ក៏បែកព្រោះក្រចក បន្ទាប់អំពីនោះ ឈាមក៏ហូរ ព្រះរាជាទ្រង់ស្តាប់ សំឡេងរបស់ព្រះនាង ទើបត្រាស់សួរថា នុ៎ះជាសំឡេងស្រែករបស់អ្នកណា ទ្រង់ស្តាប់កិរិយាដែលព្រះរាជឱរសអរិដ្ឋៈធ្វើ ទើបទ្រង់ដាក់អាជ្ញាថា ពួកលោក

ចូរនាំអរិដ្ឋៈទៅសម្លាប់ចោល ព្រះរាជធីតាទ្រង់ជ្រាបថា ព្រះរាជាទ្រង់ព្រះពិរោធ ទើបត្រាស់ដោយសេចក្ដីស្នេហាក្នុងបុត្រថា បពិត្រព្រះអង្គ នេត្រាកូនរបស់ខ្ញុំបែកទៅហើយ សូមទ្រង់អត់ទោសដល់បុត្ររបស់ខ្ញុំចុះ ព្រះរាជាកាលព្រះនាងត្រាស់យ៉ាងនោះ ក៏ត្រាស់ថា យើងមិនអាចធ្វើអ្វីបាន ទើបអត់ទោសឲ្យ ក្នុងថ្ងៃនោះ ព្រះនាងបានជ្រាបថា នេះជាស្ថាននាគ ចាប់តាំងពីនោះមក ព្រះរាជឱរសព្រះនាមអរិដ្ឋៈ ក៏បានឈ្មោះបន្ថែមថា កាណារិដ្ឋៈ ( អារិដ្ឋៈខ្វាក់ ) ។ ឯព្រះរាជឱរសទាំង ៤ ដល់នូវការដឹងក្ដីហើយ ។ លំដាប់នោះ ព្រះបិតានៃព្រះរាជឱរសទាំងនោះ ទ្រង់បានប្រទានរាជសម្បត្តិមួយកន្លែង ១០០ យោជន៍យសធំមានហើយ ។ ពួកនាគកញ្ញានាំគ្នាចោមរោម មួយកន្លែង ១៦០០០ ព្រះរាជាសោយរាជសម្បត្តិត្រឹមតែ ១០១ យោជន៍ប៉ុណ្ណោះ ។ ព្រះរាជឱរសទាំង ៣ មកគាល់ព្រះរាជមាតាបិតាមួយខែម្ដង ឯព្រះពោធិសត្វ កន្លះខែមកម្ដង ព្រះពោធិសត្វនោះឯង បានពោលដល់បញ្ហាដែលកើតឡើងក្នុងកពនាគមួយអន្ទើដោយព្រះបិតា ទើបទៅកាន់ទីឧបដ្ឋាករបស់ព្រះបាទវិរូបក្ខមហារាជ ទ្រង់បានពោលបញ្ហាដែលតាំងឡើងក្នុងសម្នាក់របស់កពនាគនោះ ។ ក្រោយមក កាលមហារាជវិរូបក្ខៈ មួយអន្ទើដោយនាគបរិវារ ទៅកាន់ត្រៃត្រិង្សបុរីអង្គុយចោមរោមសក្កទេវរាជ បានដាក់បញ្ហាឡើងក្នុងរវាងពួកទេវតាទាំងឡាយ ។ បុគ្គលណាម្នាក់ មិនអាចឆ្លើយបញ្ហានោះបាន ព្រះពោធិសត្វជាអ្នកអង្គុយលើបល្ល័ង្កដ៏ប្រសើរប៉ុណ្ណោះ ទើបស្រាយនូវប្រស្នានោះបាន ។

លំដាប់នោះ ទេវរាជទ្រង់បូជាព្រះពោធិសត្វដោយគ្រឿងក្រអូប និងផ្កា

ដែលជាទិព្វ ហើយត្រាស់ថា នែបាទត្ត: ទ្រង់ប្រកបដោយបញ្ញាបរិបូណ៌ស្មើដោយផែនដី តាំងអំពីនេះទៅ សូមទ្រង់មានឈ្មោះថា **ភូរិទត្ត** ព្រោះហេតុនោះ ទើបបានឈ្មោះភូរិទត្តរហូតមក ។ តាំងអំពីនោះមក ព្រះពោធិសត្វបានទៅកាន់ទីបម្រើរបស់សក្កៈ ឃើញវេជយន្តប្រាសាទ ដែលប្រដាប់តាក់តែងនិងសម្បត្តិរបស់សក្កៈ ដែលគួរត្រេកអរក្រៃលែង ដេរដាសទៅដោយទេព-អប្សរ ធ្វើនូវសេចក្តីប្រាថ្នាក្នុងទេវលោក ហើយគិតថា ប្រយោជន៍អ្វីដោយអត្តភាពនេះ ដែលមានកង្កែបជាអាហារ អញទៅកាន់នាគពិភព រក្សាឧបោ-សថ នឹងធ្វើហេតុឲ្យកើតក្នុងទេវលោកនេះ ។ ដូច្នេះហើយ ទើបត្រឡប់មកកាន់ភពនាគ ទូលលាព្រះមាតា និងព្រះបិតាថា បពិត្រមាតាបិតា ខ្ញុំនឹងធ្វើឧបោសថកម្ម ។ ព្រះមាតាបិតាត្រាស់ថា សាធុ ចូរបាធ្វើចុះ កាលនឹងធ្វើឯងកុំទៅខាងក្រៅ ចូរធ្វើក្នុងវិមានស្ងាត់ណាមួយ ក្នុងភពនាគនេះឯង ព្រោះពួកនាគបើទៅខាងក្រៅ ភ័យធំរមែងកើតឡើង ។ ព្រះពោធិសត្វទទួលថាសាធុ ហើយរក្សាឧបោសថក្នុងឧទ្យាន ក្នុងវិមានស្ងាត់នោះឯង ។ លំដាប់នោះ នាគកញ្ញាទាំងឡាយនាំគ្នាកាន់តន្ត្រីផ្សេងៗ ចោមរោមព្រះពោធិសត្វ ។ ព្រះពោធិសត្វគិតថា បើអញនៅក្នុងទីនេះ ឧបោសថនឹងមិនដល់ទីបំផុត អញនឹងទៅកាន់ទឹកដីមនុស្ស ធ្វើឧបោសថ មិនបានប្រាប់ដល់មាតា និងបិតា ព្រោះខ្លាចទ្រង់ឃាត់ ទើបហៅភរិយាទាំងឡាយរបស់ខ្លួនមកពោលថា នែនាងដ៏ចម្រើន អញនឹងទៅមនុស្សលោក ពត់ភ្នែនលើដំបូក មិនឆ្ងាយអំពីដើមជ្រៃធំត្រង់ច្នេរស្ទឹងយមុនា នឹងអធិដ្ឋានឧបោសថដែលប្រកបដោយអង្គ ៤ ដេកធ្វើ

ឧបោសថកម្ម កាលអញសម្ងំធ្វើឧបោសថកម្មអស់យប់ និងថ្ងៃ ក្នុងថ្ងៃស្អែកឡើងនោះឯង ពួកនាគកញ្ញាកាន់តន្ត្រីទាំង ១០ នាក់ ចូរផ្លាស់វេនគ្នាទៅកាន់សម្នាក់របស់អញ បូជាដោយផ្កា និងគ្រឿងក្រអូប ប្រគំ ហើយត្រឡប់មកកាន់ពិភពនាគវិញ ដូច្នេះហើយ ក៏ទៅក្នុងទីនោះ ពត់ភ្នែនលើដំបូក ហើយអធិដ្ឋានឧបោសថ ដែលប្រកបដោយអង្គ ៤ ថា បុគ្គលណា ប្រាថ្នាស្បែក សរសៃ ឆ្អឹង ឬឈាមរបស់អញ បុគ្គលនោះ ចូរនាំទៅចុះ ហើយនិម្មិតរាងកាយប្រមាណប៉ុនយាមនង្គ័ល ដេកធ្វើឧបោសថកម្ម លុះអរុណរះឡើង នាគមាណវិកា មកបដិបត្តិព្រះពោធិសត្វ តាមពាក្យប្រៀនប្រដៅ ហើយនាំមកកាន់ភពនាគ ព្រះពោធិសត្វធ្វើឧបោសថកម្មតាមទំនងនេះ អស់កាលកន្លងទៅដ៏យូរ ។

## ឧបោសថកម្ម ចប់

ក្នុងកាលនោះ មានព្រានទេសាទម្នាក់ អាស្រ័យនៅក្បែរទ្វារនគរពារាណសី ជាមួយសោមទត្តដែលជាកូនប្រុសទៅកាន់ព្រៃ ដើម្បីដាក់អន្ទាក់សត្វ ដោយលំពែងយន្ត និងអន្ទាក់ជាដើម សម្លាប់ម្រឹគហើយ រែកសាច់មកលក់ចិញ្ចឹមជីវិត ។ ថ្ងៃមួយ ព្រាននោះ មិនបានសត្វណាមួយសោះ ដោយហោចសូម្បីតែទន្សោងមួយ ក៏មិនបាន ទើបពោលថា នែបាសោមទត្ត បើយើងទៅដៃទទេ មាតាឯងនឹងក្រោធអញ អញនឹងនាំសត្វណាមួយទៅឲ្យបាន ដូច្នេះហើយ ទើបបែរមុខទៅកាន់ដំបូក ដែលព្រះពោធិសត្វដេក ឃើញស្នាមជើងម្រឹគទាំងឡាយ ដែលចុះទៅផឹកទឹកស្ទឹងយមុនា ទើបពោលថា នែបា ផ្លូវ

ម្រឹគប្រាកដ ចូរបាថយចេញទៅ អញនឹងបាញ់ម្រឹគដែលចុះមកផឹកទឹក ដូច្នេះហើយ ទើបទាញធ្នូ ពួនក្បែរគល់ឈើមួយ ឃ្លាំចាំមើលម្រឹគ ។ ក្នុងពេលល្ងាច ម្រឹគមួយក៏មកផឹកទឹក ព្រានទោះបាញ់ម្រឹគនោះ ។ ម្រឹគមិនមែនដួលក្នុងទីនោះឡើយ ភិតភ័យដោយកម្លាំងសរ មានឈាមហូរ ហើយរត់ទៅ ។ ចំណែកឪពុក និងកូន ក៏នាំគ្នាដេញម្រឹគនោះទៅ ចាប់យកម្រឹគនោះក្នុងទីដែលម្រឹគដួល ហើយចេញអំពីព្រៃ ដល់ដើមជ្រៃនោះ ក្នុងពេលព្រះអាទិត្យអស្តង្គត ទើបប្រឹក្សាគ្នាថា ឥឡូវនេះ មិនមែនជាពេលដែលអាចទៅបានយើងនឹងសម្រាកក្នុងទីនេះឯង ដូច្នេះហើយ ទើបយកសាច់ដាក់ក្នុងទីសមគួរនាចំណែកម្ខាង នាំគ្នាឡើងដើមឈើ ដេកក្នុងចន្លោះប្រគាបឈើ ។ ក្នុងពេលទៀបភ្លឺ ព្រានភ្ញាក់ឡើង ផ្ទៀងត្រចៀកចាំស្តាប់សំឡេងម្រឹគយំ ។

ខណៈនោះ នាគមាណវិកាទាំងឡាយ នាំគ្នាតាក់តែងអាសនៈផ្កាដើម្បីព្រះពោធិសត្វ ។ ព្រះពោធិសត្វរំសាយរាងកាយពីពស់ និម្មិតជាសរីរៈទិព្វប្រដាប់ដោយគ្រឿងអលង្ការទាំងពួង គង់ប្រថាប់លើអាសនៈផ្កា ដោយលីលាដូចសក្កទេវរាជ ឯនាងនាគមាណវិកាក៏បូជាព្រះពោធិសត្វដោយគ្រឿងក្រអូបនិងផ្កាជាដើម ហើយលេងនូវទិព្វតន្ត្រីអមដោយការរាំច្រៀង ។ ព្រានបានស្តាប់សំឡេងនោះហើយ គិតថា នុ៎ះជាអ្វីហ្ន៎ អញនឹងដឹងសំឡេងនោះ ដូច្នេះហើយ ទើបពោលថា នែបា កាលមិនអាចដាស់បុត្រឲ្យភ្ញាក់បាន ទើបគិតថាកូននេះ ប្រហែលជាហត់នឿយ ឲ្យវាដេកទៅចុះ អញនឹងទៅម្នាក់ឯង គិតហើយ ក៏ចុះអំពីដើមឈើ ចូលទៅរកព្រះពោធិសត្វ ពួកនាគមាណវិកា

ឃើញព្រានទោះ ក៏មុជក្នុងផែនដី មួយអន្ទើដោយគ្រឿងតន្ត្រី ទៅកាន់នាគពិភពវិញ ។ ឯព្រះពោធិសត្វគង់នៅម្នាក់ឯងប៉ុណ្ណោះ ។ ព្រានឈរក្នុងសម្នាក់របស់ព្រះពោធិសត្វ កាលនឹងសួរ ទើបពោល ២ គាថាថា

អ្នកជាអ្វី មានភ្នែកក្រហម មានចន្លោះស្មាទូលាយ ( អង្គុយ ) ក្នុងកណ្ដាលនៃព្រៃ ជាទីនាំមកបូជា ដោយផ្កាឈើ ស្រីទាំង ១០ នាក់ជាអ្វី ដែលទ្រទ្រង់នូវសង្វារ ជាវិការនៃមាស មានសំពត់ដ៏ល្អ កំពុងឈរសំពះ ។ អ្នកជាអ្វី មានដៃធំ រុងរឿងក្នុងកណ្ដាលព្រៃ ដូចភ្លើងឆេះនូវផ្ទាំងខ្លាញ់ អ្នកជាយក្ខណាមួយដែលមានសក្តិធំឬ ឬជានាគមានអានុភាពធំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុប្ផាភិហារស្ស** សេចក្ដីថា ដែលប្រកបដោយការនាំទៅចំពោះនូវផ្កាទិព្វ ដែលគេនាំមកបូជា ដើម្បីព្រះពោធិសត្វ ។

បទថា **កោ** បានដល់ អ្នក គឺនរណា ។ បទថា **លោហិតក្ខោ** បានដល់ មានភ្នែកក្រហម ។ បទថា **វិហតន្តរំសោ** បានដល់ មានទ្រូងទូលាយ ។ បទថា **កា កម្ពុកាយូរធរា** បានដល់ ទ្រទ្រង់នូវគ្រឿងដែលសម្រេចហើយដោយមាស ។ បទថា **ព្រហាពាហុ** បានដល់ មានដើមដៃធំ អធិប្បាយថា មានដៃធំ ។ បទថា **វនស្សមជ្ឈេ** សេចក្ដីថា អ្នកមានដើមដៃធំ គឺនរណា មានអានុភាពច្រើនក្នុងកណ្ដាលនៃព្រៃធំ គឺអ្នកជានរណាហ្ន៎ មានសក្ដិធំក្នុងកណ្ដាលនៃនាងនាគ ដែលសៀតផ្កាលើក្បាលប្រដាប់នូវសំពត់ល្អ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះហើយ ត្រិះរិះថា បើអញប្រាប់ថា អញជានរណា ក្នុងបណ្តាបុគ្គលដែលមានឫទ្ធិ មានសក្កទេវរាជជាដើម ព្រាហ្មណ៍នេះ នឹងជឿពិត តែថ្ងៃនេះ អញគួរពោលតាមពិតនោះឯង កាលប្រាប់ថា ខ្លួនជានាគ ទើបពោលថា

ខ្ញុំជានាគមានឫទ្ធិ មានតេជះ ដែលគេកន្លងមិនបាន ប្រសិនជាខ្ញុំក្រោធ អាចចឹកសូម្បីនូវអ្នកជនបទ ដែលបរិបូណ៌ ( ដោយភោគៈ ) ដោយតេជះបាន ។ ឯមាតារបស់ខ្ញុំឈ្មោះសមុទ្ទជា បិតារបស់ខ្ញុំឈ្មោះធតរដ្ឋ ខ្ញុំជាប្អូននៃនាគរាជឈ្មោះសុទស្សនៈ ជនទាំងឡាយស្គាល់ខ្ញុំថា ភូរិទត្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេជសី** សេចក្តីថា ឈ្មោះថា **តេជសី** ព្រោះមានតេជះ គឺពិស ។ បទថា **ទុរតិក្កមោ** សេចក្តីថា អ្នកដទៃមិនអាចកន្លងបាន ។ បទថា **ឌំសេយ្យំ** សេចក្តីថា បើខ្ញុំក្រោធហើយ គប្បីបំផ្លាញជនបទដែលធំទូលាយបាន ។ បើចន្ទុមរបស់ខ្ញុំធ្លាក់លើផែនដី ដោយតេជះរបស់ខ្ញុំ អ្នកជនបទទាំងអស់ មួយអន្លើដោយផែនដី គប្បីឆេះជាផេះ ។ បទថា **សុទស្សនកនិដ្ឋោស្មិ** សេចក្តីថា ខ្ញុំជាប្អូនប្រុសរបស់សុទស្សនទនាគ ដែលជាបងប្រុសរបស់ខ្ញុំ ។ បទថា **វិទូ** សេចក្តីថា ជនទាំងអស់ រមែងស្គាល់ខ្ញុំក្នុងនាគពិភព ដែលមានទំហំ ៥០០ យោជន៍យ៉ាងនេះ ។

កាលព្រះមហាសត្វពោលយ៉ាងនេះហើយ ទើបគិតថា ព្រាហ្មណ៍នេះជាបុគ្គលគ្រោតគ្រាត បើគេប្រាប់ដល់អាលម្ពាយហើយ គប្បីធ្វើអន្តរាយ

ដល់ឧបោសថកម្មរបស់អញ បើដូច្នោះ អញនឹងនាំព្រាហ្មណ៍នេះទៅកាន់នាគ-ពិភព គប្បីឲ្យយសដល់គេ ហើយគប្បីធ្វើឧបោសថកម្មរបស់អញឲ្យស្ថិតស្ថេរយូរលង់បាន លំដាប់នោះ ព្រះពោធិសត្វក៏ពោលនឹងព្រាហ្មណ៍នោះយ៉ាងនេះថា នែព្រាហ្មណ៍ ខ្ញុំនឹងឲ្យយសធំដល់លោក នាគពិភព ជាទីគួរត្រេកអរក្រៃលែង មកយើងទៅក្នុងនាគពិភពនោះជាមួយគ្នា ។ ព្រាហ្មណ៍ពោលថា កូនរបស់ខ្ញុំមានម្នាក់ បើកូននោះ មកខ្ញុំនឹងទៅ ។ លំដាប់នោះ ព្រះមហា-សត្វក៏ពោលនឹងព្រាហ្មណ៍នោះថា នែព្រាហ្មណ៍ ចូរអ្នកទៅនាំកូនរបស់អ្នកមកចុះ កាលនឹងប្រាប់លំនៅរបស់ព្រះអង្គ ទើបពោលថា

លោក រមែងឃើញអន្លង់ទឹកណាដ៏ជ្រៅ ដែលហូរក្ដួចសព្វកាល
ជាអន្លង់ទឹកគួរខ្លាច អន្លង់ទឹកនោះ ជាទិព្វ ជាលំនៅរបស់ខ្ញុំ មាន
ជម្រៅច្រើនរយនៃជួរបុរស ។ អ្នកកុំខ្លាច ចូរចូលទៅកាន់ស្ទឹង
យមុនា មានទឹកខៀវ ( ដែលហូរមក ) អំពីកណ្ដាលព្រៃ ជា
កន្លែងដែលក្ងោក និងក្រៀលយំ ជាស្ទឹងត្រជាក់ក្សេមក្សាន្ត ជា
លំនៅរបស់ពួកអ្នកមានវត្ត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សទាវដ្ដំ** បានដល់ វិលវល់ ប្រព្រឹត្តទៅសព្វកាល ។ បទថា **ភេស្មំ** បានដល់ គប្បីខ្លាច ។ បទថា **បេក្ខសិ** សេចក្ដីថា អ្នកសម្លឹងមើលអន្លង់ទឹកបែបនេះ ។ បទថា **មយូរកោញ្ចាភិរុទំ** សេចក្ដីថា គឹកកងដោយសំឡេងរបស់ក្ងោក និងក្រៀល ដែលនៅត្រង់ច្រាំងទាំង ២ នៃស្ទឹងយមុនា ។ បទថា **នីលោទក** បានដល់ មានទឹកពណ៌ខៀវ ។ បទ

ថា **វនមជ្ឈតោ** បានដល់ ហួរមកអំពីកណ្តាលព្រៃ ។ បទថា **បវិស មា ភីតោ** សេចក្តីថា លោកកុំខ្លាចឡើយ សូមចូលទៅកាន់ស្ទឹងយមុនាមានសភាពបែបនោះ ។ បទថា **វត្តវតំ** សេចក្តីថា សូមចូលទៅកាន់ភូមិដែលជាលំនៅរបស់លោក ដែលដល់ព្រមដោយវត្ត គឺអ្នកមានអាចារវត្ត ។

កាលព្រះមហាសត្វពោលយ៉ាងនេះហើយ ក៏ពោលថា ទៅចុះព្រាហ្មណ៍ ទៅនាំបុត្រមក ។ ព្រាហ្មណ៍ក៏ទៅប្រាប់សេចក្តីនោះដល់បុត្រ ហើយនាំបុត្រនោះមក ។ ព្រះមហាសត្វនាំព្រាហ្មណ៍ និងបុត្រទៅកាន់ស្ទឹងយមុនា ឈរត្រង់ច្រាំងស្ទឹង ហើយពោលថា

ម្នាលព្រាហ្មណ៍ អ្នក ព្រមទាំងកូន មកដល់ភពនាគនោះហើយ
នឹងបានប្រពន្ធ ម្នាលព្រាហ្មណ៍ យើងនឹងបូជាអ្នកដោយកាមទាំង
ឡាយរបស់យើង អ្នកចូរនៅឲ្យសុខចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បត្តោ** សេចក្តីថា អ្នកដល់នាគពិភពរបស់ខ្ញុំហើយ ។ បទថា **សានុចរោ** បានដល់ មួយអន្លើដោយករិយា ។ បទថា **មយ្ហំ** សេចក្តីថា ព្រោះខ្ញុំនឹងបូជាដោយកាមទាំងឡាយដែលជារបស់ខ្ញុំ ។ បទថា **វច្ឆសិ** សេចក្តីថា អ្នកនឹងនៅជាសុខក្នុងនាគពិភពនោះ ។

ព្រះមហាសត្វកាលពោលយ៉ាងនេះហើយ ទើបនាំជនទាំងពីរ គឺបិតា និងបុត្រ ទៅកាន់នាគពិភពដោយអានុភាពរបស់ខ្លួន កាលបិតា និងបុត្រទៅដល់នាគពិភព អត្តភាពក៏ប្រាកដជាទិព្វ ។ លំដាប់នោះ ព្រះពោធិសត្វ ក៏លើកសម្បត្តិទិព្វឲ្យដល់បិតា និងបុត្រនោះសន្ធឹកសន្ធាប់ ហើយបានឲ្យនាគ-

កញ្ញាម្នាក់ ៤០០ ។ ជនទាំង ២ នាក់នោះ ក៏បរិភោគសម្បត្តិក្នុងនាគពិភព នោះ ។

ឯព្រះពោធិសត្វក៏មិនប្រមាទ រក្សាឧបោសថ បានទៅធ្វើឧបដ្ឋាកព្រះជនក ព្រះជននីរៀងរាល់កន្លះខែ សម្ដែងធម្មកថាថ្វាយ បន្ទាប់អំពីនោះ ក៏ទៅកាន់សម្នាក់របស់ព្រាហ្មណ៍ សួរដល់ការមិនមានរោគ ហើយពោលថា លោកត្រូវការវត្ថុណា គប្បីប្រាប់ចុះ កុំនឿយណាយ ចូរត្រេកអរ ដូច្នេះហើយ បានធ្វើបដិសណ្ឋារៈជាមួយសោមទត្ត ហើយទៅកាន់និវេសន៍របស់ព្រះអង្គ ។ ព្រាហ្មណ៍នៅក្នុងនាគពិភពបានមួយឆ្នាំ ព្រោះខ្លួនជាអ្នកមានបុណ្យតិច ក៏កើតនូវការអផ្សុក ប្រាថ្នានឹងមកកាន់មនុស្សលោក ឃើញនាគពិភព ដូចលោកន្តរនរក ប្រាសាទដែលប្រដាប់យ៉ាងល្អ ប្រាកដដូចគុក នាងនាគកញ្ញាដែលតាក់តែងស្អាតបាត ប្រាកដដូចយក្ខិនី ទើបព្រាហ្មណ៍គិតថា អញនឿយណាយមុន អញនឹងដឹងការគិតរបស់សោមទត្តខ្លះ ដូច្នេះហើយ ទើបទៅកាន់សម្នាក់សោមទត្តកុមារ ហើយសួរថា នែបាសោមទត្ត ឯងអផ្សុកដែរឬ ។ សោម-ទត្តសួរថា បពិត្រលោកឪពុក ខ្ញុំអផ្សុកព្រោះហេតុអ្វី ខ្ញុំមិនអផ្សុកទេ លោកឪពុក អផ្សុកឬ ។ ព្រាហ្មណ៍ឆ្លើយថា អើ អញអផ្សុក សោមទត្តសួរថា អផ្សុកព្រោះហេតុអ្វី ព្រាហ្មណ៍ឆ្លើយថា នែបា អញអផ្សុកព្រោះមិនបានឃើញម្ដាយ និងបងប្អូនរបស់ឯង សោមទត្ត មកយើងទៅទាំងអស់គ្នា សោមទត្តទោះបីពោលថា មិនទៅ តែកាលឪពុកអង្វររឿយៗ ក៏យល់ព្រម ។ ព្រាហ្មណ៍គិតថា អញបាននូវការសម្រេចចិត្តរបស់កូនជាដំបូង តែបើអញប្រាប់ភូរិទត្ត

ថា អញធុនទ្រាន់ កុរិទត្តនឹងបន្ថែមយសក្រៃលែងថែមទៀត បើដូច្នោះ អញនឹងមិនបានទៅ អញត្រូវពណ៌នាសរសើរសម្បត្តិរបស់កុរិទត្ត ដោយឧបាយណាមួយ ទើបសួរថា កុរិទត្តលះសម្បត្តិបែបនេះ ទៅធ្វើឧបោសថកម្ម ត្រង់មនុស្សលោក ព្រោះហេតុណា បើឆ្លើយថា ត្រូវការទៅស្ថានសួគ៌ អញនឹងទូលឲ្យជ្រាបសញ្ញារបស់អញថា សម្បត្តិមានដល់ម៉្លេះហើយ ទ្រង់នៅតែលះបង់ទៅធ្វើឧបោសថកម្ម ដើម្បីទៅស្ថានសួគ៌ ចុះរឿងអ្វីមនុស្សដូចខ្ញុំ មកចិញ្ចឹមជីវិតដោយទ្រព្យរបស់អ្នកដទៃ ខ្ញុំនឹងទៅមនុស្សលោក សួរសុខទុក្ខញាតិ ហើយបួសបំពេញសមណធម៌ ដូច្នេះ កុរិទត្តគង់នឹងអនុញ្ញាតឲ្យអញទៅ ។ ថ្ងៃមួយ កាលព្រះពោធិសត្វមកសួរសុខទុក្ខ និងសួរថា អ្នកអផ្សុកដែរឬទេ ក៏ឆ្លើយថា ខ្ញុំអផ្សុក ព្រោះហេតុអ្វី ទ្រព្យ និងគ្រឿងបរិភោគដែលបានអំពីសម្នាក់ព្រះអង្គមិនខ្វះខាត ត្រឹមតែរបស់មួយក្នុងរយៈនេះ ព្រាហ្មណ៍មិនបានពោលដល់រឿងដែលទាក់ទងដល់ការទៅ ក៏ផ្តើមពណ៌នាដល់សម្បត្តិរបស់ព្រះពោធិសត្វថា

ផែនដីមានផ្កាបស្មើ ដោយជុំវិញ មានដើមក្រស្នាច្រើន ដេរដាសដោយមេភ្លៀង មានស្មៅខៀវដ៏ឧត្តមល្អ ។ ព្រៃជ្រំគួររីករាយ ស្រះបោក្ខរណីទាំងឡាយ ដែលបុញ្ញកម្មរបស់ព្រះអង្គ និម្មិតល្អហើយ ជាទីរីករាយ ដែលហង្សយំហើយ មានផ្កាឈូកធ្លាក់ចុះ ។ សសរមានជ្រុង ៨ ដែលគេធ្វើល្អហើយ ជាវិការនៃកែវពៃទូរ្យទាំងអស់ ប្រាសាទទាំងឡាយ មានសសរ ១ ពាន់ ដ៏ពេញដោយនាង

កញ្ញាក្តីរុងរឿង ។ ព្រះអង្គបានដល់នូវវិមានជាទិព្វ ដោយបុណ្យរបស់ព្រះអង្គ ជាវិមានមិនចង្អៀត ជាទីក្សេម គួរីកកាយ ប្រកបដោយសេចក្តីសុខយ៉ាងក្រៃលែង ។ ខ្ញុំសម្គាល់ថា ព្រះអង្គមិនប្រាថ្នាវិមានរបស់ព្រះឥន្ទ្រ ជាសហស្សនេត្តទេ ព្រោះថា ឫទ្ធិរបស់ព្រះអង្គនេះ ដ៏ធំដូចជាឫទ្ធិនៃព្រះឥន្ទ្រដ៏រុងរឿងដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមា សមន្តបរិតោ** សេចក្តីថា ផែនដីក្នុងនាគពិភពរបស់ទ្រង់នេះ ក្នុងទិសាភាគទាំងពួង មានផ្ទៃរាបស្មើ ដេរដាសដោយមាស ប្រាក់ កែវមណី កែវមុក្តា និងខ្សាច់ ។ បទថា **សមា** បានដល់ ផែនដីមានផ្ទៃរាបស្មើ ។ បទថា **បហូតតគរា មហី** សេចក្តីថា ប្រកបដោយដើមក្រស្នាជាច្រើន ។ បទថា **ឥន្ទគោបកសញ្ឆន្នា** សេចក្តីថា ដេរដាសទៅដោយពួកមេភ្លៀង ។ បទថា **សោភតិ ហរិតុត្តមា** សេចក្តីថា ដេរដាសទៅដោយស្បូវក្ខាំង មានពណ៌ខៀវស្រងាត់ ។ បទថា **វនចេត្យានិ** បានដល់ ពួកឈើក្នុងព្រៃ ។ បទថា **ឱបុប្ផាបទុមា** សេចក្តីថា លើផ្ទៃទឹកដេរដាសទៅដោយផ្កាឈូកដែលរុះរោយ ។ បទថា **សុនិម្មិតា** សេចក្តីថា សាងឡើងដោយល្អ ដោយបុញ្ញសម្បត្តិរបស់ទ្រង់ ។ បទថា **អដ្ឋំសា** សេចក្តីថា ក្នុងប្រាសាទដែលជាលំនៅរបស់ទ្រង់ ។ មានសសរសម្រេចដោយកែវពៃទូរ្យ បានសាងល្អហើយ មានជ្រុង ៨ ប្រាសាទរបស់ទ្រង់មានសសរ ១០០០ រុងរឿង បរិបូណ៌ដោយនាគកញ្ញា ។ បទថា **ឧបបន្នោសិ** សេចក្តីថា កើតក្នុងវិមានបែបនេះ ។ បទថា **សហស្សនេត្តស្ស វិមានំ** បាន

ដល់ វេជយន្តប្បសាទ ។ បទថា **ឥទ្ធិ ហិ ត្យាយំ វិបុលា** សេចក្ដីថា ព្រោះឫទ្ធិធំក្រៃលែង បរិបូណ៌របស់ទ្រង់នេះ ដោយឧបោសថកម្មនោះ ទើបទ្រង់មិនប្រាថ្នាវិមាននៃសក្កទេវរាជ ខ្ញុំសម្គាល់ថា ទ្រង់ប្រាថ្នាតំណែងដទៃក្រៃលែងជាងនោះ ។

ព្រះមហាសត្វ កាលបានស្ដាប់ដូច្នោះហើយ ក៏ពោលថា នែព្រាហ្មណ៍ អ្នកកុំពោលដូច្នោះឡើយ យសសក្ដិរបស់ខ្ញុំ បើប្រៀបធៀបនឹងយសរបស់សក្កទេវរាជហើយ ឈ្មោះថា តិចតួចពេក ដូចគ្រាប់ស្ពៃធៀបនឹងភ្នំសិនេរុ ពួកយើងមានតម្លៃមិនស្មើនឹងអ្នកបម្រើរបស់ទ្រង់ឡើយ ដូច្នេះហើយ ទើបពោលគាថានេះថា

អានុភាពរបស់ព្រះឥន្ទ្រ អានុភាពរបស់លោកបាលទាំង ៤ ញុំាង
អំណាចឲ្យប្រព្រឹត្តទៅ ជាអ្នកបម្រើព្រះឥន្ទ្រក្ដី អ្នកមិនគប្បីដឹង
ដោយចិត្តបានទេ ដូច្នេះ ។

សេចក្ដីនៃពាក្យជាគាថានោះ ដូច្នេះថា នែព្រាហ្មណ៍ បុគ្គលណាមិនគប្បីដល់ដោយចិត្ត គឺស្មូម្បីដោយចិត្តថា ឈ្មោះថា យសសក្ដិរបស់សក្កទេវរាជ មានត្រឹមប៉ុណ្ណោះ គឺ ១-២-៣-៤ ថ្ងៃប៉ុណ្ណោះ យសសក្ដិរបស់សត្តិច្ចានដូចយើង មិនដល់ចម្រៀកទី ១៦ នៃយសសក្ដិរបស់មហារាជទាំង ៤ ដែលជាអ្នកបម្រើរបស់ព្រះឥន្ទ្រ គឺត្រាច់ធ្វើសក្កទេវរាជឲ្យជាធំ ឲ្យជានាយកជាអ្នកនៅក្នុងអំណាចរបស់សក្កទេវរាជ ។

កាលព្រះពោធិសត្វពោលយ៉ាងនេះហើយ ទើបពោលបន្តថា យើងបាន

ឮអ្នកនិយាយថា នេះជាវិមានរបស់ស្តេចសហស្សនេត្ត យើងក៏ឮកបានថា យើងប្រាថ្នាវេជយន្តប្រាសាទ ទើបធ្វើឧបោសថកម្ម កាលនឹងប្រាប់សេចក្តីប្រាថ្នារបស់ខ្លួនដល់ព្រាហ្មណ៍ ទើបពោលគាថានេះថា

ខ្ញុំប្រាថ្នាវិមាននោះ របស់ទេវតាទាំងឡាយ អ្នកស្វែងរកសេចក្តីសុខ បានជារក្សាឧបោសថ ហើយដេកលើក្បាលដំបូក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភិជ្ឈាយ** បានដល់ ប្រាថ្នា ។ បទថា **អមរានំ** បានដល់ ទេវតាដែលមានអាយុវែង ។ បទថា **សុខេសិនំ** បានដល់ អ្នកស្វែងរកសេចក្តីសុខ គឺប្រាថ្នាសេចក្តីសុខ ។

ព្រាហ្មណ៍កាលបានស្តាប់ដូច្នោះហើយ ដល់នូវសោមនស្សថា ឥឡូវនេះ អញបានឱកាសហើយ កាលនឹងលាទៅ ទើបពោល ២ គាថាថា

ឯខ្ញុំ ព្រមទាំងកូន ស្វែងរកម្រឹគ បានចូលទៅកាន់ព្រៃ ញាតិទាំងនោះ មិនដឹងខ្ញុំថា ស្លាប់ ឬរស់ទេ ។ ខ្ញុំសូមលាព្រះភូរិទត្ត ជាបុត្តព្រះរាជធីតាក្នុងដែនកាសី ព្រះអង្គមានយស យើងខ្ញុំ បើព្រះអង្គព្រមអនុញ្ញាតហើយ គប្បីឃើញពួកញាតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ញាភិវេទេន្តិ** បានដល់ រមែងមិនដឹង គឺអ្នកដែលទៅប្រាប់ពួកញាតិទាំងនោះ ក៏មិនមាន ។ បទថា **មិគមេសានោ** កាត់បទជា **មិគំ ឯសានោ** ប្រែថា អ្នកស្វែងរកម្រឹគ ។ បទថា **អាមន្តយេ** បានដល់ ខ្ញុំសូមទូលលា ។ បទថា **កាសិបុត្តំ** បានដល់ ជាបុត្រនៃព្រះរាជធីតារបស់ស្តេចកាសី ។

លំដាប់នោះ ព្រះពោធិសត្វពោល ២ គាថាថា

ឱ ទុំះពិតជាសេចក្តីពេញចិត្តរបស់ខ្ញុំ ហើយត្រង់ដែលអ្នកនៅក្នុងសម្នាក់នៃខ្ញុំ ព្រោះថា កាមទាំងឡាយប្រាកដដូច្នេះ អ្នកមិនងាយបានក្នុងពួកមនុស្សទេ ។ អ្នក ដែលខ្ញុំបូជាដោយកាមទាំងឡាយរបស់ខ្ញុំ បើមិនចង់នៅទេ ខ្ញុំនឹងអនុញ្ញាតអ្នក សូមអ្នកទៅជួបពួកញាតិ ដោយសួស្តីចុះ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វ កាលពោល ២ គាថាហើយ ទើបគិតថា ព្រាហ្មណ៍នេះ កាលបានអាស្រ័យយើងចិញ្ចឹមជីវិតជាសុខ គង់មិនប្រាប់អ្នកណា អញនឹងឲ្យកែវមណី ដែលឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ព្រាហ្មណ៍នេះ លំដាប់នោះ កាលនឹងឲ្យកែវមណីដល់ព្រាហ្មណ៍ ទើបពោលថា

អ្នក កាលទ្រទ្រង់កែវមណីជាទិព្វនេះ រមែងបានសត្វចិញ្ចឹម និងបុត្ត អ្នកចូរមិនមានរោគ បានសេចក្តីសុខ ម្នាលព្រាហ្មណ៍ អ្នកចូរយក ( នូវកែវមណីនេះ ) ហើយទៅចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បសុំ បុត្តេ ច វិន្ទសិ** សេចក្តីថា កាលអ្នកទ្រទ្រង់នូវកែវមណីនេះ ដោយអានុភាពរបស់កែវមណីនេះ អ្នករមែងបាននូវវត្ថុដែលអ្នកប្រាថ្នាទាំងអស់ គឺជាបសុសត្វ បុត្រ និងវត្ថុដទៃតាមបំណង ។ លំដាប់នោះ ព្រាហ្មណ៍ក៏ពោលគាថានេះថា

បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ខ្ញុំនឹងបួស ព្រោះខ្ញុំចាស់ហើយ ខ្ញុំមិនប្រាថ្នាកាមទេ

ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បពិត្រកុរិទត្ត ព្រះតម្រាស់របស់ទ្រង់ជាកុសល មិនមានទោស ខ្ញុំត្រេកអរនឹងព្រះតម្រាស់នោះដ៏ក្រៃលែង មិនបដិសេធ តែខ្ញុំចាស់ហើយ ព្រោះដូច្នោះ ខ្ញុំនឹងបួស ។ បទថា **ឆ កាមេ អភិបត្ថយេ** សេចក្តីថា ខ្ញុំមិនប្រាថ្នាកាមទាំងឡាយ ប្រយោជន៍អ្វីដោយកែវមណីដល់ខ្ញុំ ។

ព្រះមហាសត្វក៏ពោលថា

បើមានការបែកធ្លាយព្រហ្មចរិយៈ កិច្ចការដែលត្រូវធ្វើដោយភោគៈទាំងឡាយ ( រមែងមាន ) អ្នកកុំមានសេចក្តីរង្កៀសឡើយ គប្បីមក យើងនឹងឲ្យទ្រព្យដ៏ច្រើនដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចេ ភង្គោ** សេចក្តីថា នែព្រាហ្មណ៍ ឈ្មោះថា ការប្រព្រឹត្តព្រហ្មចរិយៈ ជាការធ្វើបានលំបាកក្រៃលែង បើក្នុងកាលណាព្រហ្មចរិយៈដែលអ្នកមិនត្រេកអរ មានការត្រូវលះបង់ ក្នុងកាលនោះ កិច្ចដែលត្រូវធ្វើដោយភោគទ្រព្យទាំងឡាយរបស់គ្រហស្ថ មានក្នុងកាលបែបនេះ អ្នកកុំញ្ញាប់ញ៉័រឡើយ គួរមកកាន់សម្នាក់ខ្ញុំ ខ្ញុំនឹងឲ្យទ្រព្យច្រើនដល់អ្នក ។

ព្រាហ្មណ៍ពោលថា

បពិត្រព្រះកុរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ប្រសិនបើមានសេចក្តីត្រូវការ ខ្ញុំនឹងមកម្តងទៀត ដូច្នេះ ។

សព្ទថា **បុនបិ** ក្នុងគាថានោះ គឺជា **បុនអបិ** ។ មយ៉ាងទៀត បាលី

ក៏យ៉ាងនេះដូចគ្នា ។

លំដាប់នោះ ព្រះមហាសត្វដឹងថា ព្រាហ្មណ៍នោះមិនប្រាថ្នានៅក្នុងទីនោះ ទើបហៅនាគមាណពទាំងឡាយមក ហើយបញ្ជូនទៅថា ចូរពួកអ្នកនាំព្រាហ្មណ៍ ទៅឲ្យដល់មនុស្សលោក ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រស្វាធ្យាយនូវព្រះគាថាដូច្នេះថា

ព្រះភូរិទត្ត លុះពោលពាក្យនេះហើយ ក៏បញ្ជូននូវនាគទាំង ៤ ថា អ្នកទាំងឡាយមកនេះ ចូរទៅ ចូរក្រោកឡើង ចូរញ៉ាំងព្រាហ្មណ៍ឲ្យដល់ ( នូវផ្លូវជាទីទៅកាន់ក្រុងពារាណសី ) ជាឆាប់ ។ នាគទាំង ៤ ត្រូវភូរិទត្តប្រើទៅហើយ បានស្តាប់ពាក្យនោះរបស់ភូរិទត្តនោះ ក៏ក្រោកឡើង ហើយបានញ៉ាំងព្រាហ្មណ៍ឲ្យដល់ឆាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធាបេសុំ** សេចក្តីថា នាគមាណពទាំង ៤ ឡើងអំពីស្ទឹងយមុនាជូនព្រាហ្មណ៍ឲ្យដល់ផ្លូវទៅកាន់ក្រុងពាណាសី កាលជូនឲ្យដល់ហើយ ទើបពោលថា សូមលោកទៅចុះ ដូច្នេះហើយ ក៏ត្រឡប់មកកាន់នាគពិភពវិញ។

ឯព្រាហ្មណ៍ កាលប្រាប់ដល់បុត្រថា នែបាសោមទត្ត អញបាញ់ម្រឹគក្នុងទីនេះ បាញ់ជ្រូកក្នុងទីនេះ ដូច្នេះហើយ ដើរទៅ ឃើញស្រះបោក្ខរណីក្នុង

វាងផ្លូវហើយ ពោលថា នែបាសោមទត្ត យើងងូតទឹកទាំងអស់គ្នាចុះ កាល សោមទត្តពោលថា សាធុ ជនទាំង ២ ក៏ដោះគ្រឿងអាភរណៈដែលជាទិព្វ និងសំពត់ទិព្វ ហើយខ្ចប់ពាក់ត្រង់មាត់ស្រះបោក្ខរណី ហើយចុះងូតទឹក ។ ក្នុងខណៈនោះ គ្រឿងអាភរណៈទាំងនោះ បានទៅកាន់នាគពិភពវិញ សំពត់ចាស់ក៏មកដល់ជនទាំង ២ នោះ ធ្នូ និងលំពែងក៏បានប្រាកដដូចមុន ។ ចំណែកសោមទត្តស្រែកយំថា លោកឪពុកធ្វើខ្ញុំឲ្យវិនាសហើយ ។ លំដាប់នោះ បិតាក៏លួងលោមថា នែសោមទត្ត ឯងកុំវិតក្កឡើយ ឲ្យតែម្រឹគនៅមាន យើងនឹងសម្លាប់ម្រឹគចិញ្ចឹមជីវិត ។ មាតារបស់សោមទត្ត ជ្រាបការមករបស់ជនទាំង ២ ទើបចេញមកទទួល នាំចូលទៅកាន់ផ្ទះ រៀបចំបាយទឹក អង្គាសឲ្យឆ្អែតស្កប់ស្កល់ ។ ព្រាហ្មណ៍បរិភោគអាហារហើយ ក៏ដេកលក់ទៅ ចំណែកភរិយាក៏សួរបុត្រថា អើ សោមទត្ត ឯងទាំង ២ បាត់ទៅឯណាអស់កាលមានប្រមាណប៉ុណ្ណេះ សោមទត្តឆ្លើយថា បពិត្រអ្នកម៉ែ ភូរិទត្តនាគរាជនាំខ្ញុំនិងពុក ទៅកាន់ពិភពនាគ ព្រោះហេតុនោះ ទើបយើងទាំង ២ នឹកដល់ម៉ែក៏ត្រឡប់មកក្នុងកាលឥឡូវនេះ ។ មាតាសួរថា ឯងបានកែវកងអ្វីមកខ្លះដែរឬទេ សោមទត្តឆ្លើយថា មិនបានទេម៉ែ មាតាសួរថា ចុះភូរិទត្តមិនឲ្យអ្វីខ្លះទេឬ សោមទត្តឆ្លើយថា ព្រះភូរិទត្តឲ្យកែវដែលសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាងដល់ពុក តែពុកមិនយក មាតាសួរថា ហេតុអ្វី ទើបពុកឯងមិនទទួល សោមទត្តឆ្លើយថា បានឮថា គាត់នឹងបួស ។ ព្រាហ្មណីខឹងក្រោធ គិតថា ប្ដីរបស់អញ ទុកកូនចោល ឲ្យជាភារៈដល់អញអស់កាលមានប្រមាណប៉ុណ្ណេះ

ទៅកពនាគបាត់ ឥឡូវនេះ ឮថា ចង់បួស ដូច្នេះហើយ ទើបវាយខ្នង ព្រាហ្មណ៍ដោយវែកជ្រួយបាយ ហើយសម្លុតគំរាមថា វ៉ឺយ ព្រាហ្មណ៍អាក្រក់ ឮថា ឯងនឹងបួស ក្ងរទត្តឲ្យកែវមណីក៏មិនទទួល ហេតុអ្វីក៏មិនបួស ត្រឡប់ មកទីនេះធ្វើអ្វីទៀត ចូរប្រញាប់ចេញទៅឲ្យផុតពីផ្ទះអញ ។ លំដាប់នោះ ព្រាហ្មណ៍ក៏លួងលោមព្រាហ្មណីថា នាងកុំខឹងនឹងអញឡើយ ឲ្យតែម្រឹគក្នុង ព្រៃនៅមាន អញនឹងសម្លាប់ មកចិញ្ចឹមនាង ដូច្នេះហើយ ក៏ចេញអំពីទីនោះ ទៅព្រៃជាមួយបុត្រ រកស៊ីចិញ្ចឹមជីវិតតាមទំនងមុននោះឯង ។

## នេសាទកណ្ឌ ចប់

ក្នុងកាលនោះ មានគ្រុឌមួយទំគ្រង់ដើមរកា នាមាត់សមុទ្រភាគខាង ត្បូង ទទះស្លាបឲ្យទឹកសមុទ្រខ្វង ចាប់នាគរាជត្រង់ក្បាលបានមួយ ។ ពិត ហើយ ក្នុងកាលនោះ គ្រុឌទាំងឡាយមិនចេះវិធីចាប់នាគ ក្រោយមក ទើប ចេះវិធីចាប់នាគ ដូចក្នុងបណ្ឌរកជាតក ។ តែគ្រុឌនោះ កាលចាប់នាគត្រង់ ក្បាល ផុសមកវិញមិនទាន់ទឹក ទឹកក៏រួមមកវិញ ក៏ពាំនាគឡើងបាន កន្ទុយ នាគក៏សំយុងចុះ នាំទៅខាងលើព្រៃហិមពាន្ត ។ កាលនោះ មានព្រាហ្មណ៍ អ្នកកាសិករដ្ឋម្នាក់ បួសជាឥសី សាងបណ្ណសាលា អាស្រ័យក្នុងហិមវន្ត-បទេស ត្រង់ទីបំផុតទីចង្ក្រមរបស់ឥសីនោះ មានដើមជ្រៃធំមួយ ។ ឥសីនោះ ធ្វើទីសម្រាកក្នុងពេលថ្ងៃត្រង់គល់ជ្រៃនោះ គ្រុឌពាំនាគទៅដល់ចុងជ្រៃ នាគ ក៏ទម្លាក់កន្ទុយរុំដើមជ្រៃ ប្រាថ្នាឲ្យរួចខ្លួន គ្រុឌមិនចាប់ភ្ញីក ក៏ប្រញាប់ទៅតាម អាកាស ព្រោះជាសត្វមានកម្លាំងច្រើន ដើមជ្រៃ ព្រមទាំងឫស ក៏សណ្តក

ទៅជាមួយកន្ទុយនាគ កាលគ្រុឌពាំនាគទៅដល់ដើមរកា ក៏ចឹកដោយចំពុះ ហែកពោះនាគ ស៊ីកន្សោមខ្លាញ់ ទម្លាក់សរីរៈទៅក្នុងសមុទ្រ ដើមជ្រៃក៏ធ្លាក់ លាន់ដោយសំឡេងខ្លាំង ។ គ្រុឌស្តាប់សំឡេង សង្ស័យថា នេះជាសំឡេងអ្វី មើលទៅខាងក្រោម ឃើញដើមជ្រៃ គិតថា ជ្រៃនេះ អញដកមកពីកន្លែង ណា ក៏គិតបានដោយប្រាកដថា ដើមជ្រៃនោះ នៅខាងចុងទីចង្ក្រមរបស់ តាបស ក៏គិតបន្តថា ដើមជ្រៃនេះមានឧបការៈច្រើនដល់តាបសនោះ ខ្លួនអញ ប្រាកដថា ធ្វើនូវអកុសលឬហ្ន៎ អញនឹងទៅសួរតាបស ក៏នឹងដឹងបាន ដូច្នេះ ហើយ ក៏កាឡាខ្លួនជាមាណពទៅកាន់សម្នាក់តាបស ។ ខណៈនោះ តាបស កំពុងធ្វើទីនោះឲ្យស្មើ ស្តេចគ្រុឌថ្វាយបង្គំតាបសហើយ ក៏អង្គុយក្នុងទីសមគួរ ធ្វើហាក់ដូចមិនដឹង សាកសួរថា បពិត្រលោកម្ចាស់ ទីត្រង់នេះ ជាលំនៅ របស់អ្នកណា តាបសឆ្លើយថា អាវុសោ ស្តេចគ្រុឌមួយ ចាប់នាគមកដើម្បី ជាអាហារ កាលនាគយកកន្ទុយរុំដើមជ្រៃ ដោយបំណងយករូចខ្លួន គ្រុឌ នោះមិនដឹង ហើរទៅដោយរហ័ស ព្រោះភាពដែលខ្លួនមានកម្លាំងច្រើន កាល បើដូច្នេះ ដើមជ្រៃក្នុងទីនេះ ក៏ត្រូវសណ្តកទាំងឫស ត្រង់នេះឯង ជាកន្លែង ដើមជ្រៃដែលដកឡើងនោះ ។ គ្រុឌសួរថា បពិត្រលោកម្ចាស់ អកុសលកម្ម មានដល់ស្តេចគ្រុឌឬ តាបសឆ្លើយថា បើស្តេចគ្រុឌនោះមិនដឹង អកុសល-កម្មក៏មិនមាន ព្រោះមិនមានចេតនា ។ ស្តេចគ្រុឌសួរថា អកុសលកម្មនឹង មានដល់នាគនោះ ឬមិនមាន តាបសឆ្លើយថា នាគក៏មិនបានយកកន្ទុយចាប់ ដើម្បីឲ្យដើមជ្រៃវិនាស ចាប់ដើម្បីទាញឲ្យផុតភ័យ ព្រោះហេតុនោះ អកុសល

រមែងមិន មានដល់នាគ នោះដូចគ្នា ។

ស្តេចគ្រុឌបានស្តាប់ពាក្យរបស់តាបសក៏ត្រេកអរ ពោលថា បពិត្រលោកម្ចាស់ ខ្ញុំនេះឯង គឺស្តេចគ្រុឌ ខ្ញុំត្រេកអរដោយពាក្យជាសុភាសិតរបស់លោកម្ចាស់ដែលដោះស្រាយបញ្ហា លោកម្ចាស់អាស្រ័យនៅក្នុងព្រៃ ខ្ញុំចេះមន្តឈ្មោះអាលម្ពាយនៈមួយបទ ដែលមានតម្លៃកាត់ថ្លៃមិនបាន ខ្ញុំនឹងប្រគេនដល់លោកម្ចាស់ ឲ្យជាចំណែកបូជាអាចារ្យ សូមលោកម្ចាស់ទទួលយកចុះ ។ តាបសពោលថា នែបា យើងមិនត្រូវការដោយមន្ត ចូរអ្នកទៅចុះ ។ ស្តេចគ្រុឌអង្វររឿយៗ រហូតតាបសទទួលហើយ ទើបប្រគេនមន្ត ប្រាប់ថ្នាំដល់តាបស ហើយចៀសចេញទៅ ។

គរុឡកណ្ឌ ចប់

ក្នុងកាលនោះ មានព្រាហ្មណ៍ក្រីក្រម្នាក់ ក្នុងនគរពារាណសី ខ្ចីបុលបំណុលគេច្រើន ត្រូវម្ចាស់បំណុលទាំងឡាយតឹងទារ គិតថា អញនៅក្នុងនគរនេះធ្វើអ្វីទៀត ចូលទៅស្លាប់ក្នុងព្រៃល្អជាង ដូច្នេះហើយ ទើបចេញអំពីស្រុក ចូលទៅកាន់ព្រៃ រហូតដល់អាស្រមរបស់ឥសី បដិបត្តិតាបសឲ្យត្រេកអរដោយវត្តសម្បទាគុណ ។ តាបសគិតថា ព្រាហ្មណ៍នេះ ជាអ្នកមានឧបការៈដល់អញក្រៃលែង អញនឹងឲ្យទិព្វមន្ត ដែលស្តេចគ្រុឌឲ្យដល់អញ ដល់ព្រាហ្មណ៍នេះ ដូច្នេះហើយ ក៏ប្រាប់ព្រាហ្មណ៍ថា នែព្រាហ្មណ៍ យើងចេះមន្តឈ្មោះអាលម្ពាយ យើងនឹងឲ្យមន្តនោះដល់ឯង ចូរឯងរៀនមន្តនោះ ។ សូម្បីកាលព្រាហ្មណ៍នោះឃាត់ថា កុំឡើយ ខ្ញុំមិនត្រូវការមន្ត ក៏អង្វរហើយ

អង្វរទៀត រហូតព្រាហ្មណ៍ទទួលពាក្យហើយ ទើបឲ្យមន្ត និងប្រាប់ថ្នាំដែលប្រកបជាមួយមន្ត និងឧបចារៈរបស់មន្ត ។ ព្រាហ្មណ៍នោះគិតថា អញបានឧបាយចិញ្ចឹមជីវិត ក៏សម្រាក ២-៣ ថ្ងៃ ហើយអាងលេសថា បពិត្រលោកម្ចាស់ រោគខ្យល់បៀតបៀនខ្ញុំ រហូតដល់តាបសឲ្យទៅ ទើបថ្វាយបង្គំតាបសសូមខមាទោស ចេញអំពីព្រៃ ទៅរហូតដល់ឆ្នេរស្ទឹងយមុនាដោយលំដាប់ ដើរស្វាធ្យាយមន្តនោះទៅតាមផ្លូវធំ ។

ខណៈនោះ នាគមាណវិកាជាបាទបរិចារិការបស់ព្រះភូរិទត្តប្រមាណ ១ ពាន់នាក់ កាន់យកកែវមណីដែលឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាងនោះចេញអំពីនាគពិភព បានដាក់កែវមណីនោះលើគំនរខ្សាច់ ត្រង់ឆ្នេរស្ទឹងយមុនា ហើយនាំគ្នាលេងទឹកអស់មួយយប់ ដោយប្រើពន្លឺកែវមណីនោះ ។ កាលអរុណរះ ទើបនាំគ្នាតាក់តែងកាយ ដោយគ្រឿងអាភរណៈទាំងពួង អង្គុយជុំវិញកែវមណីឲ្យសិរីចូលក្នុងកាយ ។ ឯព្រាហ្មណ៍ក៏ដើរស្វាធ្យាយមន្តមកដល់ទីនោះ នាគមាណវិកាទាំងនោះបានឮសំឡេងមន្ត សម្គាល់សំឡេងព្រាហ្មណ៍នោះថាជាគ្រុឌ តក់ស្លុតចំពោះមរណភ័យ មិនកាន់យកកែវមណី នាំគ្នាមុជក្នុងផែនដី ទៅកាន់នាគពិភពវិញ ព្រាហ្មណ៍ឃើញកែវមណីត្រេកអរថា មន្តរបស់អញសម្រេចផល ឥឡូវនេះហើយ ទើបកាន់យកកែវមណីនោះទៅ ។

សម័យនោះ ព្រាហ្មណ៍នេសាទ និងសោមទត្តទៅកាន់ព្រៃ ដើម្បីបរបាញ់ម្រឹគ ឃើញកែវមណីនោះក្នុងដៃរបស់ព្រាហ្មណ៍ ទើបពោលនឹងកូនថា អើ សោមទត្ត កែវមណីនេះ ព្រះភូរិទត្តឲ្យដល់យើងមិនមែនឬ សោមទត្ត

ពោលថា ពិតហើយ បិតាពោលថា បើដូច្នោះ យើងពោលទោសកែវមណី នោះ បញ្ឆោតព្រាហ្មណ៍យកកែវមណីនេះ សោមទត្តពោលថា បពិត្រលោក ឪពុក កាលព្រះភូរិទត្តឲ្យ ម៉េចក៏ពុកមិនទទួល ឥឡូវនេះ បែរជាមកកុហក ព្រាហ្មណ៍ទៅវិញ ពុកកុំធ្វើយ៉ាងនេះឡើយ ហើយក៏នៅស្ងៀម ។

ព្រាហ្មណ៍នេសាទក៏ពោលថា រឿងនោះលើកទុកសិន ឯងចាំមើលអញ បោកតានេះចុះ ថាហើយ កាលនឹងប្រាស្រ័យជាមួយអាលម្ពាយទើបពោលថា

អ្នកកាន់យកនូវកែវមណី ជាមង្គល ជាទ្រព្យដ៏ប្រសើរ ជាទី រីករាយនៃចិត្ត ជាថ្មបរិបូណ៌ដោយទ្រង់ទ្រាយ អ្នកបានកែវមណី នេះអំពីទីណា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មង្គល្យំ** សេចក្ដីថា កែវមណីដែលសន្មត ថា ជាមង្គល ឲ្យនូវសម្បត្តិដែលគួរប្រាថ្នាទាំងពួង ។ បទថា **កោ មំ** សេចក្ដីថា អ្នកបានកែវមណីនេះអំពីណា ។

លំដាប់នោះ អាលម្ពាយពោលគាថានេះថា

ថ្ងៃនេះ ខ្ញុំទៅកាន់ផ្លូវពីព្រឹក បានកែវមណីនេះ ដែលពួកនាងនាគ ភ្នែកក្រហមមួយពាន់ ថែរក្សាហើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា ថ្ងៃនេះ ខ្ញុំដើរតាមផ្លូវធំអំពី ព្រលឹម បានជួបកែវមណី ចោមរោមដោយជុំវិញដោយនាងនាគមាណវិកា ដែលភ្នែកក្រហម ១០០០ នាក់ ឯនាងនាគមាណវិកាទាំងអស់នោះ ឃើញខ្ញុំ ក៏ភិតភ័យ នាំគ្នាចោលកែវមណីនេះគេចទៅ ។

ព្រាហ្មណ៍នេសាទបំណងនឹងបោកអាលម្ពាយនោះ ក៏ប្រកាសទោសនៃកែវមណី បំណងនឹងកាន់យកជារបស់ខ្លួន ទើបពោលគាថានេះថា

កែវមណីនេះ បើបុគ្គលសន្សំទុកល្អ ថែទាំបូជាគ្រប់គ្រងល្អ ទុកដាក់ល្អហើយសព្វកាល គប្បីញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេចបាន ។ តែកាលបើបុគ្គល ជាអ្នកប្រាសចាកការថែទាំក្នុងការទុកដាក់ ឬក្នុងការប្រើប្រាស់វិញ កែវមណីនេះ ដែលគេសន្សំទុកដោយមិនត្រូវទំនង នឹងដល់សេចក្ដីវិនាស ។ អ្នកជាបុគ្គលមិនឈ្លាស មិនគួរគ្រប់គ្រងកែវមណីជាទិព្វនេះទេ អ្នកចូរគ្រប់គ្រងមាសរត្តាមួយរយចុះ ចូរឲ្យកែវមណីនេះដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វត្តំ** សេចក្ដីថា បុគ្គលណានឹងទុកដាក់នូវកែវមណីនេះ គឺរក្សាទុកដោយល្អ កាន់យកថាជារបស់អញ ដូចជាជីវិតនៃខ្លួន បុគ្គលនោះទុកដាក់ដោយល្អ បូជារក្សាដោយល្អ រមែងញ៉ាំងប្រយោជន៍ឲ្យសម្រេច ។ បទថា **ឧបចារវិបន្នស្ស** សេចក្ដីថា បុគ្គលដែលប្រាសចាកការរក្សាដោយឧបាយ ដែលមិនមែនឧបាយនូវកែវមណីដែលកើតអំពីថ្ម រមែងនាំមកតែសេចក្ដីវិនាសប៉ុណ្ណោះ ។ បទថា **ធារេតុមារហោ** បានដល់ មិនគួរប្រដាប់ ។ បទថា **បដិបជ្ជ សតំ និក្ខំ** សេចក្ដីថា ក្នុងផ្ទះរបស់យើង មានកែវមណីច្រើន ពួកយើងទើបចេះរក្សាកែវមណី យើងនឹងឲ្យមាសរត្តារ ១០០ ដល់អ្នក ចូរអ្នកគ្រប់គ្រងដុំមាសនោះ ហើយឲ្យកែវមណីនេះដល់យើង ។ មាសរត្តារក្នុងផ្ទះរបស់ព្រាហ្មណ៍ ត្រឹមតែមួយដុំក៏មិនមាន តែគាត់ដឹងថា កែវ

មណីនោះ ឲ្យសម្រេចតាមការប្រាថ្នា អញនឹងផ្ងូតទឹក ជ្រមុជក្បាល ហើយយកទឹកប្រោះកែវមណី ទើបពោលថា សូមអ្នកឲ្យមាស ១០០ ដល់ខ្ញុំ កាលបើដូច្នេះ កែវមណីនឹងឲ្យមាសផ្កា ១០០ ដល់អញ នឹងឲ្យមាសផ្ការនោះដល់អាយលម្ពាយ ព្រោះហេតុនោះ ទើបគាត់ពោលយ៉ាងនេះ ។

លំដាប់នោះ អាលម្ពាយពោលគាថានេះថា

កែវមណីនេះ ខ្ញុំមិនគប្បីលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ កែវមណីរបស់ខ្ញុំដែលកើតអំពីថ្ម បរិបូណ៌ដោយទ្រព្យទ្រាយ ខ្ញុំមិនគប្បីលក់ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នេវ មាយំ** សេចក្តីថា កែវមណីរបស់យើងនេះ ឈ្មោះថា មិនគួរដោះដូរដោយវត្ថុណាទេ ។ បទថា **នេវ កោយេ្យា** សេចក្តីថា កែវមណីរបស់ខ្ញុំនេះ សម្បូរដោយលក្ខណៈ ព្រោះដូច្នោះ ឈ្មោះថា ជារបស់មិនគួរទិញលក់ដោយវត្ថុណាឡើយ ។ ព្រាហ្មណ៍នេសាទពោលថា

បើកែវមណី អ្នកមិនលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ ចុះកែវមណីអ្នកនឹងលក់ដោយវត្ថុអ្វី ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនោះ ដូច្នេះ ។

អាលម្ពាយពោលថា

បុគ្គលណា គប្បីបង្ហាញនាគដ៏ធំ មានតេជៈ ដែលគេកន្ទងបានដោយក្រដល់ខ្ញុំ ខ្ញុំនឹងឲ្យកែវមណីដ៏រុងរឿង ដោយតេជៈ ដល់បុគ្គលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជលន្តិវ តេជសា** បានដល់ រុងរឿងដោយរស្មី ។ ព្រាហ្មណ៍នេសាទពោលថា

អ្នកជាអ្វី ជាគ្រុឌដ៏ប្រសើរ ជាងសត្វស្លាបទាំងឡាយ កាលស្វែងរកចំណីដើម្បីខ្លួន ទើបចាប់យកនាគ ដោយភេទជាព្រាហ្មណ៍ទេឬ ដូច្នេះ ។

បទថា **កោ នុ** ក្នុងគាថានោះ ព្រាហ្មណ៍នេសាទគិតថា ប្រហែលជាបុគ្គលនោះជាគ្រុឌ ដេញតាមអាហាររបស់ខ្លួន ទើបពោលយ៉ាងនេះ ។

អាលម្ពាយពោលថា

ខ្ញុំមិនមែនជាស្តេចសត្វស្លាបទេ គ្រុឌ ខ្ញុំមិនដែលឃើញទេ ខ្ញុំជាអ្នកត្រេកអរដោយអាសិរពិស ម្នាលព្រាហ្មណ៍ ជនទាំងឡាយដឹងថា ខ្ញុំជាហ្មពស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មំ វិទូ** សេចក្តីថា ជនទាំងឡាយស្គាល់យើងថា បុគ្គលនេះជាអ្នកស្វែងរកពស់ពិស ឈ្មោះថា អាលម្ពាយ ។

ព្រាហ្មណ៍នេសាទពោលថា

កម្លាំងរបស់អ្នកដូចម្តេច សិល្បៈរបស់អ្នកដូចម្តេច ទាំងអ្នករឹងប៉ឹង ព្រោះហេតុអ្វី បានជាមិនកោតខ្លាចនាគ ដូច្នេះ ។

បណ្តាបទទាំងនោះ ដោយពាក្យថា **កិស្មឹ វា ត្វំ បរត្ថទ្ធោ** ព្រាហ្មណ៍សួរថា អ្នកជាបុគ្គលទ្រទ្រង់នូវផលដ៏វិសេសក្នុងអ្វី នឹងធ្វើអ្វីឲ្យជាទីអាស្រ័យ ទើបមិនកោតក្រែងនាគ គឺអាសិរពិស គឺមើលងាយ មិនធ្វើនូវការកោតក្រែង

ដល់បុគ្គលប្រសើរ ។

អាលម្ពាយនោះ កាលសម្តែងកម្លាំងរបស់ខ្លួន ទើបពោលថា គ្រុឌបានប្រាប់វិជ្ជាពិសដ៏ប្រសើរ ដល់ឥសីមួយអង្គ ជាកោសិយគោត្រ នៅក្នុងព្រៃ ប្រព្រឹត្តតបធម៌អស់រាត្រីយូរ ។ ខ្ញុំជាអ្នកមិនខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃ បានបម្រើឥសីមួយអង្គនោះ ដែលមានខ្លួនចម្រើនហើយ កាលគង់នៅក្នុងចន្លោះភ្នំ ដោយសេចក្តីគោរព ។ ឥសីនោះ ដែលខ្ញុំបានបម្រើហើយ ក្នុងកាលនោះ វត្តក្តី ព្រហ្មចរិយៈក្តី ឥសីនោះបានប្រព្រឹត្តហើយ ឥសីមានជោគនោះ ក៏បង្រៀនមន្តទិព្វដល់ខ្ញុំ តាមសេចក្តីប្រាថ្នា ។ ខ្ញុំជាអ្នករឹងប៉ឹងព្រោះមន្តនោះ បានជាមិនខ្លាចនាគទាំងឡាយ ខ្ញុំជាអាចារ្យរបស់ពួកអ្នកសម្លាប់សត្វមានពិសទាំងឡាយ ជនទាំងឡាយស្គាល់ខ្ញុំថា អាលម្ពាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោសិយស្សក្ខា** សេចក្តីថា គ្រុឌមកប្រាប់ឥសីកោសិយគោត្រ ហេតុដែលគ្រុឌនោះប្រាប់ទាំងអស់ គប្បីពោលឲ្យពិស្តារ ។ បទថា **ភាវិតត្តញ្ញតរំ** សេចក្តីថា ខ្ញុំចូលទៅរកឥសីម្នាក់ បណ្តាអ្នកបំពេញខ្លួន ។ បទថា **សម្មន្នំ** បានដល់ អាស្រ័យនៅ ។ បទថា **កាមសា** បានដល់ ដោយសេចក្តីប្រាថ្នារបស់ខ្លួន ។ បទថា **មមំ** សេចក្តីថា រមែងប្រកាសមន្តដល់ខ្ញុំ ។ បទថា **ត្យាហំ មន្តេ បរត្ថទ្ធោ** សេចក្តីថា ខ្ញុំទ្រទ្រង់នូវផលដ៏វិសេស គឺអាស្រ័យមន្តទាំងនោះ ។ បទថា **ភោគិនំ** បានដល់

ចំពោះនាគទាំងឡាយ ។ បទថា **វិសឃាតានំ** សេចក្តីថា ជាអាចារ្យរបស់ពួកគ្រូដែលសម្លាប់អាសិរពិស ។

ព្រាហ្មណ៍នេសាទបានស្តាប់ដូច្នោះ ទើបគិតថា អាលម្ពាយនេះឲ្យកែវមណីដល់បុគ្គលដែលបង្ហាញលំនៅរបស់ព្រះភូរិទត្តដល់គេ កាលបង្ហាញភូរិទត្តដល់គេហើយ ទើបបានទទួលកែវមណី កាលប្រឹក្សាជាមួយបុត្រ ទើបពោលថា

ម្នាលសោមទត្តកូន យើងនឹងកាន់យកកែវមណី ចូរអ្នកដឹងចុះ យើងកុំយកដំបងទាត់ចោលសិរីដែលមកដល់ហើយ តាមសេចក្តីប្រាថ្នាឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គណ្ហាមសេ** បានដល់ គួរទទួលយក ។ បទថា **កាមសា** សេចក្តីថា កុំច្រឹះដោយកំណាត់ឈើ ហើយលះសិរីតាមគាប់ចិត្តរបស់ខ្លួន ។

សោមទត្តពោលថា

បពិត្រព្រាហ្មណ៍ ភូរិទត្តណា បានបូជាលោក ដែលដល់នូវនិវេសន៍របស់ខ្លួន លោកប្រាថ្នានឹងប្រទូស្តចំពោះព្រះភូរិទត្តនោះ ដែលធ្វើអំពើល្អយ៉ាងនេះ ព្រោះសេចក្តីវង្វេងធ្វើអ្វី ។ បើលោកឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទាន ចូរលោកឪពុកទៅសុំលោកចុះ លោកនឹងប្រទានទ្រព្យច្រើនដល់លោកឪពុក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បូជយិ** សេចក្តីថា បូជាហើយដោយកាម

ដែលជាទិព្វ ។ បទថា **ទុត្តិមិច្ឆសិ** សេចក្តីថា បពិត្រលោកឪពុក លោកប្រាថ្នាធ្វើនូវកម្ម គឺការប្រទូស្តចំពោះមិត្របែបនោះព្រោះហេតុអ្វី ។

ព្រាហ្មណ៍ពោលថា

ម្នាលសោមទត្ត យើងគួរស៊ីរបស់ឆ្អិនដែលមកដល់ដៃ ឬដល់ភាជន៍ ប្រសើរជាង កុំឲ្យប្រយោជន៍ដែលឃើញច្បាស់នឹងក្អែកកន្ទុងផុតពីយើងទៅបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហត្ថគតំ** សេចក្តីថា នែបាសោមទត្ត ឯងនៅក្មេង មិនដឹងការប្រព្រឹត្តទៅរបស់លោកសន្និវាស ការទំពាស៊ីរបស់ដែលនៅក្នុងដៃ នៅក្នុងភាជន៍ ឬដែលទុកត្រង់ចំពោះមុខនោះឯងប្រសើរ ការទំពាស៊ីរបស់ដែលនៅឆ្ងាយ មិនប្រសើរឡើយ ។

សោមនទត្តពោលថា

បុគ្គលជាអ្នកទ្រុស្តមិត្ត ជាអ្នកលះបង់ប្រយោជន៍ រមែងឆេះក្នុងនរកដ៏គួរខ្លាច ផែនដីក៏ស្រូបបុគ្គលទ្រុស្តមិត្តនោះ បុគ្គលទ្រុស្តមិត្តសូម្បីរស់នៅ ក៏រីងស្ងួត ( ដូចជាប្រេត ) បើឪពុកចង់បានទ្រព្យព្រះភូរិទត្តនឹងប្រទានមិនខាន ខ្ញុំសម្គាល់ថា មិនយូរប៉ុន្មាន ឪពុកនឹងដឹងច្បាស់នូវពៀរ ដែលខ្លួនធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិមស្ស វិវរិយតិ** សេចក្តីថា បពិត្រលោកឪពុក ផែនដីរមែងបើកនូវឱកាសឲ្យដល់អ្នកទ្រុស្តមិត្ត ទាំងនៅរស់នោះឯង ។ បទថា **ហិតច្ចាគី** បានដល់ ដែលលះបង់នូវប្រយោជន៍របស់ខ្លួន ។

បទថា **ជីវេ វាបិ សុស្សតិ** សេចក្តីថា ទោះមានជីវិត ក៏រមែងស្គាំងស្គម ដូចមនុស្សប្រេត ដូច្នោះ ។ បទថា **អត្តកតំ វេរំ** បានដល់ បាបដែលខ្លួនធ្វើ ។ បទថា **ឆ ចិរំ** សេចក្តីថា កូនយល់ថា មិនយូរ លោកនឹងជួបនូវពៀរ ។

ព្រាហ្មណ៍ពោលថា

ព្រាហ្មណ៍ទាំងឡាយ បូជាមហាយញ្ញហើយ រមែងបរិសុទ្ធយ៉ាង នេះ យើងនឹងបូជាមហាយញ្ញ គង់នឹងរួចចាកបាប ដោយអាការ យ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុជ្ឈន្តិ** សេចក្តីថា នែសោមទត្ត បុគ្គល នៅកំលោះមិនដឹងអ្វី ធម្មតាព្រាហ្មណ៍ទាំងឡាយ កាលធ្វើនូវបាបឯណាមួយ ហើយ រមែងបរិសុទ្ធបានដោយយញ្ញ ទើបពោលយ៉ាងនេះ ។

សោមទត្តពោលថា

ណ្ហើយចុះ ឥឡូវនេះ ខ្ញុំនឹងគេចចេញថ្ងៃនេះ ខ្ញុំមិននៅជាមួយ នឹងឪពុកទេ ខ្ញុំមិនដើរជាមួយនឹងឪពុក ដែលធ្វើអំពើអាក្រក់យ៉ាង នេះ អស់មួយជំហានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបាយាមិ** សេចក្តីថា អញ្ជើញចុះ ខ្ញុំសូម បែកទៅ គឺគេចទៅ ។ ឯបណ្ឌិតមាណពកាលពោលយ៉ាងនេះហើយ កាល មិនអាចឲ្យបិតាស្តាប់ពាក្យរបស់ខ្លួន ទើបពោលឲ្យទេវតាជ្រាបដោយសំឡេង ខ្លាំងថា ខ្ញុំនឹងមិនទៅជាមួយអ្នកធ្វើបាបបែបនេះ កាលប្រកាសហើយ ក៏គេច ទៅទាំងបិតាឃើញនោះឯង ហើយចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី

ញ៉ាំងអភិញ្ញា និងសមាបត្តិឲ្យកើតហើយ មានឈានមិនសាបសូន្យ កើតក្នុងព្រហ្មលោក ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

សោមទត្តកុមារជាពហុស្សូត បានពោលពាក្យនេះ នឹងបិតាហើយ
ក៏ប្រកាសទេវតាទាំងឡាយ ហើយគេចចេញចាកទីនោះ ដូច្នេះ ។

***សោមទត្តកណ្ឌ ចប់***

ព្រាហ្មណ៍នេសាទគិតថា សោមទត្តនឹងទៅណា ក្រៅពីផ្ទះរបស់ខ្លួន ឃើញអាលម្ពាយមិនពេញចិត្តបន្តិច ទើបលួងលោមថា នែអាលម្ពាយ អ្នកកុំវិតក្កឡើយ ខ្ញុំនឹងបង្ហាញភូរិទត្តដល់អ្នក ដូច្នេះហើយ ក៏នាំអាលម្ពាយទៅកាន់ទីរក្សាឧបោសថនៃស្តេចនាគ ឃើញស្តេចនាគព័ទ្ធវង្វេលត្រង់កំពូលដំបូកឈរក្នុងទីមិនឆ្ងាយ លាដៃចេញហើយ ពោល ២ គាថាថា

នាគណា មានពន្លឺដូចជាសម្បុរនៃសត្វមេភ្លៀង មានក្បាលក្រហម អ្នកចូរចាប់នាគធំនុ៎ះចុះ ហើយចូរនាំកែវមណីនុ៎ះដល់ខ្ញុំ ។
កាយរបស់នាគនុ៎ះ រមែងប្រាកដដូចជាគំនរប៉ុយកប្បាស នាគនេះដេកលើដំបូក ម្នាលព្រាហ្មណ៍ អ្នកចូរចាប់យកនាគនោះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥន្ទគោបកវណ្ណាភា** សេចក្ដីថា មានរស្មី

ដូចរស្មីនៃពណ៌មេឃ្លៀង ។ បទថា **កប្បាសបិចុរាសិវ** សេចក្ដីថា ដូចគំនរនៃកប្បាសដែលចាត់ចែងល្អហើយ ។

ព្រះមហាសត្វបើកភ្នែកឡើង ឃើញព្រាហ្មណ៍នេសាទគិតថា អញបាន គិតហើយថា ព្រាហ្មណ៍នេះធ្វើអន្តរាយដល់ឧបោសថរបស់អញ ទើបអញនាំ ទៅកាន់ស្ថាននាគឲ្យសោយនូវសម្បត្តិដ៏ច្រើន មិនប្រាថ្នាទទួលកែវដែលអញ ឲ្យ តែឥឡូវនេះ បែរជាទទួលយកអំពីអាលម្ពាយ បើអញក្រោធដល់បុគ្គល ទ្រុស្តមិត្ត សីលរបស់អញនឹងដាច់ អញបានអធិដ្ឋានឧបោសថដែលប្រកប ដោយអង្គ ៤ ហើយត្រូវឲ្យឧបោសថនោះមាំទាំ ទោះអាលម្ពាយកាត់ ដុត សម្លាប់ ចាក់ដោយលំពែងក៏ដោយចុះ អញនឹងមិនក្រោធឡើយ បើអញ សម្លឹងមើលគេដោយសេចក្ដីក្រោធ គេក៏នឹងខ្ទេចជាផេះ ណ្ហើយចុះ ទោះបីគេ បៀតបៀនអញ អញមិនត្រូវខឹងក្រោធឡើយ ដូច្នេះហើយ ក៏បិទភ្នែក បំពេញ អធិដ្ឋានបារមីទុកខាងមុខ ដាក់ក្បាលចូលក្នុងរង្វែល ដេកស្ងៀមមិនកម្រើក ឡើយ ។

## សីលកណ្ឌ ចប់

ឯព្រាហ្មណ៍នេសាទពោលថា នែអាលម្ពាយដ៏ចម្រើន អញ្ជើញអ្នក ចាប់នាគនេះ ហើយចូរឲ្យកែវមណីដល់ខ្ញុំចុះ អាលម្ពាយឃើញនាគរាជហើយ ត្រេកអរ មិនបានគិតដល់កែវមណីថា មានតម្លៃអ្វី ប្រៀបដូចជាស្មៅ បោះ កែវមណីទៅឲ្យព្រាហ្មណ៍នេសាទ ដោយពាក្យថា យកចុះព្រាហ្មណ៍ កែវ មណីក៏ធ្លាក់អំពីដៃព្រាហ្មណ៍នេសាទ ចូលទៅកាន់ផែនដី ហើយទៅកាន់

ពិភពនាគវិញ ។ ព្រាហ្មណ៍នេសាទប្រាសចាកឋានៈ ៣ ប្រការ គឺប្រាសចាកកែវមណី ប្រាសចាកមិត្តភាពជាមួយព្រះភូរិទត្ត និងសាបសូន្យចាកបុត្រ ។ គាត់ក៏ស្រែកយំ រៀបរាប់ថា អញអស់ទីពឹងអាស្រ័យហើយ ព្រោះអញមិនជឿពាក្យរបស់បុត្រ ហើយក៏ត្រឡប់ទៅផ្ទះ ។

ឯអាលម្ពាយ លាបរាងកាយរបស់ខ្លួនដោយទិព្វឱសថ ទំពាស៊ីបន្តិចប្រោះព្រំរាងកាយរបស់ខ្លួន ក៏រាយទិព្វមន្ត ចូលទៅរកព្រះពោធិសត្វ ចាប់កន្ទុយទាញមក ចាប់ក្បាលយ៉ាងតឹង ប្របាច់មាត់ព្រះមហាសត្វ ទំពាថ្នាំស្តោះដាក់ទាំងស្ដេស្មចូលទៅក្នុងមាត់ព្រះមហាសត្វ ស្ដេចនាគជាសត្វមានជាតិស្អាត មិនក្រោធ មិនបើកភ្នែក ព្រោះខ្លាចសីលដាច់ ។ លំដាប់នោះអាលម្ពាយក៏ប្រើថ្នាំ និងមន្តចាប់ព្រះពោធិសត្វសំយុងឲ្យក្បាលចុះក្រោម រលាក់ឲ្យអាហារចេញតាមមាត់ ហើយឲ្យដេកស្តូកលើផែនដី ដើរជាន់ដោយជើង ដូចមនុស្សបែនសណ្ដែក ឆ្អឹងហាក់ដូចជាបែកជាលម្អិតតូចធំ ។ ចាប់កន្ទុយព្រះមហាសត្វ ឲ្យមានក្បាលចុះក្រោមម្ដងទៀត បោកដូចបោកសំពត់ ព្រះមហាសត្វសោយទុក្ខវេទនាមានប្រមាណប៉ុណ្ណោះ ក៏មិនក្រោធឡើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាចិធម៌ឯណាពុំទាន់ប្រាកដបទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

គ្រានោះ អាលម្ពាយនព្រាហ្មណ៍ កាលជប់បទនៃមន្តទាំងឡាយ
ធ្វើជាគ្រឿងការពារខ្លួន ដោយឱសថទិព្វទាំងឡាយហើយ ទើប

អាចចាប់នាគនោះ ដោយវិធីយ៉ាងនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសក្ខិ** ប្រែថា អាច ។ បទថា **ដុដ្ឋុំ** បាន ដល់ ដើម្បីចាប់ ។

អាលម្ពាយកាលធ្វើព្រះមហាសត្វឲ្យថយកម្លាំងដូច្នោះហើយ ទើបយកវល្លិចាក់ធ្វើកំប្រោង ហើយយកព្រះមហាសត្វដាក់ក្នុងកំប្រោងនោះ តែសរីរៈរបស់ព្រះមហាសត្វធំ ចូលក្នុងកំប្រោងនោះមិនបាន ។ លំដាប់នោះ អាលម្ពាយក៏ប្រើកែងជើងជាក់ញាត់ព្រះពោធិសត្វឲ្យចូលទៅ ហើយពុនទៅដល់ស្រុកមួយ ទើបដាក់កំប្រោងចុះត្រង់កណ្ដាលស្រុក ស្រែកប្រកាសថា អ្នកណាចង់មើលការរាំរបស់នាគ ចូរនាំគ្នាមក អ្នកស្រុកទាំងអស់ នាំគ្នាមកប្រជុំគ្នា ។ ខណៈនោះ អាលម្ពាយក៏ពោលថា មហានាគ ចូរអ្នកចេញមក មហាសត្វគិតថា ថ្ងៃនេះ អញនឹងលេងឲ្យបរិស័ទត្រេកអរ ទើបគួរ អាលម្ពាយកាលបានទ្រព្យច្រើនយ៉ាងនេះ ត្រេកអរហើយ នឹងលែងអញទៅ អាលម្ពាយឲ្យអញធ្វើយ៉ាងណា អញនឹងធ្វើយ៉ាងនោះ ។ លំដាប់នោះ អាលម្ពាយក៏នាំព្រះមហាសត្វចេញអំពីកំប្រោង ហើយពោលថា ចូរឯងធ្វើខ្លួនឲ្យធំ ។ ព្រះមហាសត្វធ្វើខ្លួនឲ្យធំ អាលម្ពាយប្រាប់ឲ្យធ្វើខ្លួនឲ្យតូច ឲ្យខ្វី ឲ្យវែង ឲ្យបើកពពារមួយ ឲ្យបើកពពារ ២-៣-៤-៥-៦-៧-៨-៩-១០-២០-៣០-៤០-៥០-៦០-៧០-៨០-៩០-១០០ ឲ្យខ្ពស់ ឲ្យទាប ឲ្យឃើញខ្លួន ឲ្យបាត់ខ្លួន ឲ្យឃើញពាក់កណ្ដាលខ្លួន ឲ្យមានពណ៌ខៀវ លឿងក្រហម ស ហង្សបាទ ឲ្យព្រួសអណ្ដាតភ្លើង ឲ្យព្រួសទឹក ឲ្យព្រួសផ្សែង ។ ក្នុងអាការទាំងនេះ

អាលម្ពាយប្រាប់ឲ្យធ្វើអាការណាមួយ ព្រះមហាសត្វក៏និម្មិតអត្តភាព សម្តែងអាការនោះៗ សព្វយ៉ាង បុគ្គលណាឃើញមហាសត្វនោះហើយ ក៏មិនអាចទប់ទឹកភ្នែកបាន ។ មនុស្សជាច្រើននាំគ្នាឲ្យវត្ថុផ្សេងៗ មានប្រាក់ មាស សំពត់ និងគ្រឿងប្រដាប់ជាដើម អាលម្ពាយក៏បានទ្រព្យក្នុងស្រុកនោះរាប់ពាន់ ដោយប្រការដូច្នេះ ។ អាលម្ពាយនោះ ចាប់ព្រះមហាសត្វបានទ្រព្យ ១០០០ ទើបពោលនឹងព្រះមហាសត្វថា យើងនឹងលែងក៏ពិត តែទោះជាដូច្នោះ កាលបាន ១០០០ ហើយ ក៏គិតថា ក្នុងស្រុកតូច អញគង់បានទ្រព្យប្រមាណប៉ុណ្ណេះ បើក្នុងព្រះនគរនឹងបានទ្រព្យច្រើន ព្រោះសេចក្តីលោភក្នុងទ្រព្យ ទើបមិនលែងមហាសត្វ ។ អាលម្ពាយនោះ មានទ្រព្យចម្រើនឡើងក្នុងស្រុកនោះហើយ ឲ្យជាងធ្វើកំប្រោងកែវ ដាក់មហាសត្វក្នុងកំប្រោងកែវនោះ ហើយឡើងកាន់យានតូចជាទីសប្បាយ ចេញទៅដោយបរិវារច្រើន ឲ្យព្រះមហាសត្វទៅក្នុងស្រុក និងនិគមជាដើម រហូតដល់នគរពារាណសី ដោយលំដាប់ តែអាលម្ពាយមិនឲ្យទឹកឃ្មុំ និងលាជដល់ស្តេចនាគ ចាប់កង្កែបមកឲ្យបរិភោគ ព្រះមហាសត្វក៏មិនបានបរិភោគអាហារ ព្រះមហាសត្វអត់អាហារ ព្រោះខ្លាចអាលម្ពាយមិនលែង អាលម្ពាយក៏ឲ្យមហាសត្វលេងក្នុងស្រុកនោះ តាំងអំពីស្រុកជិតទ្វារទាំង ៤ ចូលទៅ ។ លុះដល់ថ្ងៃឧបោសថទី ១៥ អាលម្ពាយ ក៏ក្រាបទូលដល់ព្រះរាជាថា ថ្ងៃនេះ នឹងឲ្យនាគលេងថ្វាយទ្រង់ ព្រះរាជាក៏ត្រាស់ឲ្យវាយស្គរប្រកាសឲ្យមហាជនប្រជុំគ្នា

ជនទាំងនោះក៏នាំគ្នាមកប្រជុំ លើកគ្រែដាក់លើគ្នា ត្រង់លានព្រះរាជវាំង ។

អាលម្ពាយកណ្ឌ ចប់

ក្នុងថ្ងៃដែលអាលម្ពាយចាប់ព្រះមហាសត្វទៅនោះ ព្រះមាតារបស់ព្រះមហាសត្វបានឃើញក្នុងសុបិនថា ព្រះនាងត្រូវបុរសម្នាក់សម្បុរខ្មៅ ភ្នែកក្រហម យកដាវកាត់ដៃស្តាំរបស់ព្រះនាងដាច់ ហើយនាំយកទៅទាំងដែលមានឈាមហូរ ។ កាលព្រះនាងភ្ញាក់ឡើង ក៏តក់ស្លុត ទ្រង់ស្ទាបដៃស្តាំ ក៏ជ្រាបថា នុ៎ះជាយល់សប្តិ លំដាប់នោះ ព្រះនាងទ្រង់ត្រិះរិះថា អញយល់សប្តិអាក្រក់ណាស់ កូនរបស់អញទាំង ៤ ឬស្តេចធតរដ្ឋ ខ្ញុំនអញឯងគង់នឹងមានអន្តរាយ ម្យ៉ាងទៀត ព្រះនាងនឹកក្នុកដល់ព្រះមហាសត្វជាងអ្នកដទៃ ព្រោះហេតុអ្វី ព្រោះថា នាគក្រៅពីនោះ នៅក្នុងស្ថានរបស់ខ្លួន ចំណែកព្រះមហាសត្វ ព្រោះជាអ្នកមានសីលជាអធ្យាស្រ័យ ទៅកាន់មនុស្សលោកធ្វើឧបោសថកម្ម ព្រោះហេតុនោះ ទើបព្រះនាងគិតដល់ភូរិទត្តក្រៃលែងជាងអ្នកណាទាំងអស់ថា គ្រូពស់ ឬគ្រូឧចាប់យកកូនរបស់អញទៅទេដឹងហ្ន៎ លុះកន្លងទៅបានកន្លះខែ ព្រះនាងទោមនស្ស គិតថា កូនរបស់អញ មិនអាចព្រាត់ប្រាសអំពីអញលើសកន្លះខែឡើយ ភ័យណាមួយនឹងកើតឡើងដល់កូនរបស់អញពិត ។ លុះកន្លងទៅបានមួយខែ ព្រះនាងសមុទ្ទជាក៏សោកសង្រេងទឹកព្រះនេត្រហូរមិនដាច់ ដួងហឫទ័យក៏ស្វិតស្រពោន ព្រះនេត្រទាំង ២ ក៏ហើម ព្រះនាងសមុទ្ទជាអង្គុយទន្ទឹងមើលផ្លូវ ដែលព្រះមហាសត្វនឹងត្រឡប់មកដល់ប៉ុណ្ណោះ ដោយព្រះនាងរំពឹងថា ភូរិទត្តនឹងមកក្នុងឥឡូវនេះ ភូរិទត្ត

នឹងមកក្នុងឥឡូវនេះ ។

គ្រានោះ សុទស្សនៈជាកូនច្បងរបស់ព្រះនាង លុះកន្លងទៅបានមួយខែហើយ មួយអន្ទើដោយបរិស័ទជាច្រើន បានចូលគាល់ព្រះរាជមាតា ឲ្យបរិស័ទនៅខាងក្រៅ ហើយឡើងកាន់ប្រាសាទ ថ្វាយបង្គំព្រះមាតា ហើយឈរក្នុងទីសមគួរ នាចំណែកម្ខាង ព្រះនាងសមុទ្ទជានោះ កំពុងសោកដល់ព្រះភូរិទត្ត មិនបានចរចាប្រាស្រ័យជាមួយសុទស្សនៈ ។ សុទស្សនៈនោះគិតថា ព្រះមាតារបស់យើង កាលយើងមកពីមុនៗ ឃើញអញហើយ រមែងត្រេកអររាក់ទាក់ ថ្ងៃនេះ ព្រះមាតាទោមនស្ស អាក់អន់ព្រះហឫទ័យដោយរឿងអ្វីមួយពិតប្រាកដ ។ លំដាប់នោះ កាលនឹងទូលសួរព្រះជននី ក៏ពោលថា

> ឥន្ទ្រិយរបស់លោក មិនស្រស់បស់ ព្រះភក្ត្ររបស់លោក ក៏ខ្មៅ
> ព្រោះឃើញខ្ញុំ ដែលសម្រេចសេចក្តីប្រាថ្នាទាំងពួង កំពុងមក
> គាល់ឬ ។ ព្រះភក្ត្ររបស់លោកខ្មៅ ដូចជាផ្កាឈូកដែលឋិតនៅ
> ក្នុងដៃ ដែលគេច្របាច់ដោយដៃ ព្រោះតែឃើញខ្ញុំប្រាកដដូច្នេះឬ
> ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហាដ្ឋាធិ** បានដល់ មិនផូរផង់ ។ បទថា **សាវំ** សេចក្តីថា ថ្ងៃនេះ សូម្បីព្រះភក្ត្ររបស់ព្រះមាតាក៏ក្រៀមស្រពោន ដូចពណ៌នៃកញ្ចក់ដែលធ្វើដោយមាស ។ បទថា **ហត្ថគតំ** សេចក្តីថា ច្របាច់ដោយដៃ ។ បទថា **ឯទិសំ** សេចក្តីថា ព្រោះបានឃើញខ្ញុំបែបនេះសូម្បីមកគាល់ដោយសិរីដ៏ធំ ។

កាលសុទស្សនៈពោលយ៉ាងនេះហើយ ព្រះនាងសមុទ្ទជាក៏មិនបាន ត្រាស់ប្រាស្រ័យឡើយ សុទស្សនៈក៏គិតថា អ្នកណាធ្វើឲ្យព្រះមាតាខឹង ក្រោធឬហ្ន៎ ឬគប្បីមានអន្តរាយ ។ លំដាប់នោះ សុទស្សនៈកាលទូលសួរ ព្រះមាតានោះ ទើបពោលគាថាទៀតថា

ក្រែងបុគ្គលណាមួយ មិនរាប់អានលោកខ្វះឬ វេទនារបស់លោក មានខ្វះឬ ព្រះភក្ត្ររបស់លោកខ្មៅ ព្រោះឃើញខ្ញុំមកដោយ ហេតុណា ( សូមលោកប្រាប់នូវហេតុនោះដល់ខ្ញុំចុះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កច្ចិ នុ តេ ឆាភិស្សសិ** នេះ សុទស្សនៈ សួរថា អ្នកណាពោលលុបលើក្នុងព្រះមាតាឬ ឬមួយអ្នកណាបៀតបៀន ដោយការជេរ ដោយការបរិភាស ។ បទថា **តុយ្ហំ** សេចក្ដីថា ព្រោះទត ឃើញខ្ញុំដែលមកគាល់ក្នុងកាលមុនៗ ព្រះភក្ត្ររបស់ព្រះមាតា មិនមែនបែប នេះ ។ បទថា **យេន** នេះ សុទស្សនៈសួរថា ព្រោះហេតុអ្វី ថ្ងៃនេះ ព្រះភក្ត្ររបស់ព្រះមាតាស្វិតក្រៀម សូមព្រះមាតាប្រាប់រឿងនោះដល់ខ្ញុំ ។

លំដាប់នោះ ព្រះនាងសមុទ្ទជា កាលត្រាស់ប្រាប់ដល់សុទស្សនៈនោះ ទើបត្រាស់ថា

ម្នាលកូន ក្រោយមួយខែមកហើយអំពីថ្ងៃនេះ យើងបានឃើញ សុបិនថា ហាក់ដូចជាបុរសកាត់ដៃខាងស្ដាំរបស់យើង ហើយនាំ យកដៃដែលប្រឡាក់ដោយឈាម ដើរចេញទៅក្នុងកាលដែល យើងកំពុងយំ ។ ម្នាលសុទស្សនៈ កាលណាយើងបានឃើញ

សុបិន អ្នកចូរដឹងចុះថា កាលនោះ យើងមិនបានសេចក្តីសុខ
ទាំងថ្ងៃ ទាំងយប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតោ មាសំ អធោគតំ** នេះ ព្រះនាងសមុទ្ទជាសម្តែងថា តាំងពីមាតាយល់សប្តិរហូតមកដល់ថ្ងៃនេះ បានមួយខែហើយ ។ បទថា **បុរិសោ** សេចក្តីថា យល់សប្តិឃើញថា មានបុរសម្នាក់មានសម្បុរខ្មៅ ក្អែកក្រហម ។ បទថា **រោទន្តិយា សតិ** សេចក្តីថា កាលមាតាកំពុងយំ ។ បទថា **សុខំ មេ នោបលព្ភតិ** សេចក្តីថា ឈ្មោះថាសេចក្តីសុខរបស់មាតាមិនមានឡើយ ។

កាលព្រះនាងសមុទ្ទជាត្រាស់យ៉ាងនេះហើយ ទើបត្រាស់បន្តថា នែកូនជាទីស្រឡាញ់ ប្អូនរបស់ឯង បាត់ទៅមិនឃើញ ភ័យប្រហែលជាកើតឡើងដល់ប្អូនរបស់ឯង ដូច្នេះហើយ ព្រះនាងយំរៀបរាប់ថា

នាងកញ្ញាទាំងឡាយ មានរាងកាយដ៏រុងរឿង ពាក់បណ្តាញមាស បានចោមរោមភូរិទត្តណាពីក្នុងកាលមុន ( ឥឡូវនេះ ) ភូរិទត្តនោះ យើងមិនឃើញទេ ។ នាគទាំងឡាយ ដែលកាន់ព្រះខ័នដ៏ប្រសើរ ដូចជាផ្កាកណិការ រឹកចោមរោមភូរិទត្តណាពីក្នុងកាលមុន ( ឥឡូវនេះ ) ភូរិទត្តនោះ យើងមិនឃើញទេ ។ ណ្ហើយចុះ ឥឡូវនេះ យើងនឹងទៅកាន់លំនៅរបស់ភូរិទត្ត យើងគង់នឹងឃើញប្អូនរបស់អ្នកដែលតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីលដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្ពុល្លា** សេចក្តីថា ដូចផ្កាកណិការដែលរីកស្គុសស្គាយ ព្រោះទ្រទ្រង់នូវគ្រឿងប្រដាប់ ដែលធ្វើអំពីមាស ។ សព្ទថា **ហន្ទ** ត្រឹមតែជានិបាត ប្រើក្នុងអត្ថនៃឧបសគ្គ ។ ព្រះនាងសមុទ្ទជាត្រាស់ថា មកពួកយើងនឹងទៅកាន់និវេសន៍របស់កុរិទត្ត ។

កាលព្រះនាងសមុទ្ទជាត្រាស់យ៉ាងនេះហើយ ទើបយាងទៅកាន់និវេសន៍របស់កុរិទ្ត មួយអន្លើដោយបរិស័ទរបស់សុទស្សនៈ និងបរិស័ទរបស់ព្រះនាង ឯពួកភរិយារបស់ព្រះមហាសត្វ កាលមិនឃើញភូរិទត្តត្រង់ជំបូកហើយ គិតថា ប្រហែលជានៅក្នុងនិវេសន៍របស់មាតា ទើបមិនបាននាំគ្នាខ្វល់ខ្វាយស្វែងរក ភរិយាទាំងនោះ កាលដឹងថា បានឮថា ព្រះមាតាមិនឃើញបុត្ររបស់ខ្លួន ទើបនាំគ្នាទទួល ហើយទូលថា បពិត្រព្រះមាតា ព្រះរាជបុត្ររបស់ព្រះមាតា បាត់ទៅមួយខែថ្ងៃនេះហើយ ហើយក៏នាំគ្នាយំសោក ក្រាបចុះទៀបបាទារបស់ព្រះនាង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វិអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ឯភរិយាទាំងឡាយរបស់ភូរិទត្ត បានឃើញព្រះមាតានៃភូរិទត្តនោះ
កំពុងដើរមក ក៏ផ្គងដៃឡើងកន្ទក់កន្ទេញថា បពិត្រលោកម្តាយ
ជាម្ចាស់ ក្រោយមួយខែមកហើយ អំពីថ្ងៃនេះ យើងមិនដឹងភូរិទត្ត
ដ៏មានយស ជាបុត្ររបស់លោក ជាស្លាប់ឬរស់នៅទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុត្តន្តេយ្យេ** កាត់បទជា **បុត្តំ តេ អយ្យេ ។** បទតទៅ ជាពាក្យយំសោករបស់ស្រីទាំងនោះ ដូច្នេះ ។ ព្រះមាតារបស់ព្រះភូរិទត្ត មួយអន្លើដោយស្រីជាកូនប្រសា នាំគ្នាយំសោកក្នុងវាំងផ្ទៃ ព្រះនាងនាំស្រីទាំងនោះឡើងកាន់ប្រាសាទនៃភូរិទត្តនោះ ត្រួតមើលទីដេក និងទីអង្គុយរបស់បុត្រហើយ កន្ទក់កន្ទេញដោយគាថាទាំងនេះថា

យើងកាលមិនឃើញភូរិទត្តទេ នឹងចេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេសត្វស្លាបបាត់កូន ឃើញតែសម្បុកទទេ ដូច្នោះ ។ យើងកាលមិនឃើញភូរិទត្ត នឹងចេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេអកបាត់កូន ឃើញតែសំបុកទទេ ដូច្នោះ ។ យើងកាលមិនឃើញភូរិទត្តទេ នឹងចេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេសត្វចាក្រពាកនោះ នៅលើកក់ដែលមិនមានទឹកដោយពិត ។ ជើងក្រាននៃពួកជាងមាស ចេះតែខាងក្នុង មិនចេះខាងក្រៅយ៉ាងណា យើងកាលមិនឃើញភូរិទត្ត នឹងចេះដោយសេចក្តីសោកយ៉ាងនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបស្សន្តី** បានដល់ មិនឃើញ ។ បទថា **ហតច្ឆាទា** សេចក្តីថា ដូចហង្សស[1] ព្រាត់ប្រាសចាកកូនខ្ចី ។

កាលព្រះមាតាព្រះភូរិទត្តយំរៀបរាប់យ៉ាងនេះ និវេសន៍របស់ភូរិទត្ត ក៏មានសំឡេងយំតែមួយ ហាក់បីដូចសំឡេងរលកក្នុងមហាសមុទ្រ ដូច្នោះ ។

---

១- បិដកខ្មែរ ជាអក ) ។

សូម្បីនាគតែមួយ ក៏មិនអាចគ្រប់គ្រងការៈរបស់ខ្លួន ទូទាំងនិវេសន៍ ដូចព្រៃរាំងត្រូវខ្យល់យុគន្ធរវាតបក់បោក ដូច្នោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

កូន និងប្រពន្ធទាំងឡាយ ដួលដេកក្នុងនិវេសន៍របស់ព្រះភូរិទត្ត
ដូចជាដើមឈើដែលត្រូវខ្យល់ ញាំញីបំបាក់ ដូច្នោះ ។

ក្នុងកាលនោះ អរិដ្ឋៈ និងសុភោគៈ ២ នាក់បងប្អូន ទៅកាន់ទីឧបដ្ឋាករបស់ព្រះមាតាបិតា បានឮសំឡេងនោះ ទើបចូលទៅកាន់និវេសន៍នៃភូរិទត្ត នាំគ្នាលួងលោមព្រះមាតា ។

**តមត្ថំ បកាសេន្តោ សត្ថា** អាហ វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

អរិដ្ឋ និងសុភោគនាគរាជ បានឮសំឡេងគឹងកងនៃនាគទាំងនោះ
ក្នុងនិវេសន៍របស់ព្រះភូរិទត្ត ក៏ស្ទុះទៅតាមលំដាប់ ហើយពោល
ថា បពិត្រលោកម្តាយ សូមលោកដកដង្ហើមស្រួលចុះ កុំសោយ
សោកឡើយ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះ
ជាធម្មតា តែងច្យុត តែងកើតឡើងវិញ នេះជាការប្រែប្រួល
នៃលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯសាស្ស បរិណាមតា** នេះ អរិដ្ឋៈ និង សុភោគៈពោលថា ចុតិ និងបដិសន្ធិនេះ ជាការប្រែប្រួលរបស់សត្វលោក- សត្វ លោករមែងប្រែប្រួលទៅដោយអាការយ៉ាងនេះឯង បុគ្គលណាមួយ ឈ្មោះថា នឹងផុតទៅអំពីអន្តធម៌ ២ យ៉ាងនេះ រមែងមិនមាន ។ ព្រះនាង សមុទ្ទជាត្រាស់ថា

ម្នាលកូន យើងក៏ដឹងថា សត្វទាំងឡាយ មានសភាពយ៉ាងនេះ ជាធម្មតាដែរ តែថា យើងកាលមិនឃើញភូរិទត្តទេ ត្រូវសេចក្តី សោកគ្របសង្កត់ហើយ ប្រសិនបើ ( ភូរិទត្ត ) មិនបាន ( មក ជួប ) នឹងយើងក្នុងថ្ងៃនេះយប់នេះទេ ម្នាលសុទស្សនៈ អ្នកចូរ ដឹងចុះ យើងកាលមិនឃើញភូរិទត្តទេ យើងមុខជានឹងលះបង់នូវ ជីវិតពុំខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ជ ចេ មេ** សេចក្តីថា នែបាសុទស្សនៈ បើភូរិទត្តមិនមកឲ្យម្តាយឃើញក្នុងថ្ងៃនេះសោត កាលម្តាយមិនឃើញភូរិទត្ត មាតាយល់ថា មាតានឹងលះបង់ជីវិតពិត ។ បុត្រទាំងឡាយពោលថា

បពិត្រព្រះមាតា សូមលោកដកដង្ហើមស្រួលចុះ កុំសោយសោក ឡើយ យើងទាំងឡាយនឹងនាំបងមក យើងទាំងឡាយត្រាច់ទៅ កាន់ទីស្វែងរកបង នឹងទៅកាន់ទិសតូចធំ លើភ្នំ ជ្រោះភ្នំ ក្នុង ស្រុក និងនិគមទាំងឡាយ លោកចូរឃើញបងដែលមកក្នុងរវាង ខាងក្នុង ៧ រាត្រី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចរំ** សេចក្ដីថា កូនទាំង ៣ លួងលោមព្រះមាតាថា បពិត្រព្រះមាតា ពួកកូននឹងស្វែងរកបងប្រុស ក្នុងទិសតូចធំ ។

បន្ទាប់អំពីនោះ សុទស្សនៈក៏គិតថា យើងទាំង ៣ ទៅរួមគ្នា ក៏នឹងយឺតយូរ គួរបែកគ្នាជា ៣ ផ្លូវ គឺម្នាក់ទៅទេវលោក ម្នាក់ទៅក្នុងហិមពាន្ត ម្នាក់ទៅក្នុងមនុស្សលោក តែបើឲ្យកាណារិដ្ឋៈទៅក្នុងមនុស្សលោក បើជួបភូរិទត្តក្នុងស្រុក ឬនិគមណា នឹងធ្វើស្រុក និងនិគមនោះឲ្យឆេះអស់ ព្រោះកាណារិដ្ឋៈកាចខ្លាំងណាស់ មិនគួរឲ្យទៅក្នុងមនុស្សលោកឡើយ ដូច្នេះហើយ ទើបបញ្ជូនអរិដ្ឋៈទៅទេវលោកថា នែអរិដ្ឋៈ ចូរឯងទៅកាន់ទេវលោក បើទេវតាត្រូវការស្ដាប់ធម៌ នាំភូរិទត្តទៅទេវលោកសោត ចូរឯងនាំគេត្រឡប់មក ។ រួចហើយ បញ្ជូនសុភោគៈទៅកាន់ព្រៃហិមពាន្តថា នែសុភោគៈ ចូរឯងទៅកាន់ហិមពាន្ត ស្វែងរកភូរិទត្តក្នុងស្ទឹងទាំង ៥ បើជួបភូរិទត្តហើយ ចូរនាំមក ឯសុទស្សនៈខ្លួនឯង មកកាន់មនុស្សលោក តែមកដោយគិតថា អញនឹងទៅដោយភេទជាបុរសកំលោះ ពួកមនុស្សមិនសូវរាប់អាន អញគួរទៅដោយភេទតាបស ព្រោះបព្វជិតជាទីស្រឡាញ់របស់ពួកមនុស្ស ទើបគេកាឡាខ្លួនជាតាបស លាព្រះមាតា ហើយចៀសចេញទៅ ។

ភូរិទត្តពោធិសត្វនោះ មាននាគកញ្ញាជាប្អូនស្រី មាតាដទៃម្នាក់ ឈ្មោះអច្ចិមុខី ។ នាងអច្ចិមុខីនោះស្រឡាញ់ព្រះពោធិសត្វពន់ពេក នាងឃើញសុទស្សនៈចេញទៅ ក៏សូមខ្លួនថា បពិត្រម្ចាស់បង ខ្ញុំលំបាកចិត្តពន់ពេក ខ្ញុំសូមទៅជាមួយផង ។ សុទស្សនៈពោលថា នែប្អូនស្រី នាងមិនអាចទៅជា

មួយបងបានឡើយ ព្រោះបងទៅដោយភេទបព្វជិត អច្ចិមុខីពោលថា បពិត្រម្ចាស់បង ខ្ញុំនឹងធ្វើជាកូនកង្កែបដេកក្នុងផ្នួងសក់ម្ចាស់បង ។ សុទស្សនៈពោលថា បើដូច្នោះ មកយើងទៅជាមួយគ្នា ។ នាងអច្ចិមុខីក៏កាឡាខ្លួនជាកូនកង្កែប ដេកក្នុងជដារបស់សុទស្សនៈ ។ សុទស្សនៈគិតថា អញនឹងពិនិត្យមើលតាំងពីទីដើម ដូច្នេះហើយ ទើបសួរដល់ទីដែលព្រះកូរិទត្តទៅរក្សាឧបោសថនឹងកិរិយាកូរិទត្តជាមុន ហើយទើបទៅក្នុងទីនោះឯង ឃើញឈាមនិងស្នាមកំប្រោងដែលធ្វើដោយវល្លិ ក្នុងទីដែលអាលម្ពាយចាប់ ក៏ដឹងច្បាស់ថា គ្រូពស់នឹងចាប់កូរិទត្ត ក៏កើតសេចក្តីសោកឡើង មានមុខជោកដោយទឹកភ្នែក ទើបដើរតាមស្នាមជើងអាកម្ពាយ ទៅដល់ស្រុកដែលអាលម្ពាយឲ្យព្រះមហាសត្វលេងនូវកីឡាក្នុងគ្រាដំបូង ហើយសួរពួកមនុស្សថា តើមានគ្រូពស់យកនាគរាជឈ្មោះនេះមកលេងក្នុងស្រុកនេះដែរឬទេ ពួកមនុស្សឆ្លើយថា អាលម្ពាយយកនាគរាជ ដែលមានសភាពបែបនេះមកលេង តាំងពីកន្លះខែមុនម៉្លេះ ។ សុទស្សនៈសួរថា គ្រូពស់នោះ បានទ្រព្យអ្វីខ្លះដែរឬទេ មនុស្សឆ្លើយថា ត្រង់ស្រុកនេះ គ្រូពស់បានទ្រព្យប្រមាណ ១០០០ សុទស្សនៈសួរថា ឥឡូវនេះ គ្រូពស់ទៅឯណា ពួកមនុស្សឆ្លើយថា គ្រូពស់ទៅស្រុកឈ្មោះនោះ ទៅស្រុកឈ្មោះនោះ សុទស្សនៈសួររឿយៗ ទៅ តាំងអំពីស្រុកនោះ រហូតដល់ទ្វារព្រះរាជដ្ឋាន ។

**វិលាបកណ្ឌ ចប់**

ខណៈនោះ អាលម្ពាយន៍ងូតទឹក ប្រោះព្រំក្បាល លាបនូវគ្រឿងក្រអូប ស្លៀកសំពត់សាច់ល្អ ឲ្យមនុស្សលើកកំប្រោងរតនៈទៅកាន់ទ្វារព្រះរាជដ្ឋាន មហាជនប្រជុំគ្នាហើយ ព្រះរាជអាសនៈក៏រៀបចំស្រេចបាច់ ។ ព្រះរាជាទ្រង់នៅខាងក្នុងនិវេសន៍បញ្ជូនដំណឹងទៅថា យើងនឹងទៅមើល ចូរអាលម្ពាយឲ្យពស់លេងកីឡាចុះ ។ អាលម្ពាយក៏ដាក់កំប្រោងរតនៈចុះលើកម្រាលដ៏វិចិត្រ បើកកំប្រោងចេញ ហើយឲ្យសញ្ញាថា ចូរមហានាគចេញមកចុះ ។ គ្រានោះ សុទស្សនៈក៏ទៅឈរខាងចុងបរិស័ទទាំងពួង ។ ព្រះមហាសត្វអើតក្បាលមើលបរិស័ទទូទៅ ។ នាគទាំងឡាយមើលបរិស័ទដោយអាការ ២ យ៉ាង គឺ ដើម្បីមើលអន្តរាយអំពីគ្រុឌ ១ ដើម្បីមើលពួកញាតិ ១ ។ នាគទាំងនោះ បើឃើញគ្រុឌ ក៏មិនរាំ បើឃើញពួកញាតិក៏ខ្មាស មិនរាំដូចគ្នា ។ ចំណែកព្រះមហាសត្វសម្លឹងទៅ ឃើញបងប្រុសក្នុងរវាងបរិស័ទ ក៏លូនចេញអំពីកំប្រោង ទៅរកបងប្រុស ទាំងទឹកភ្នែក ។

មហាជនឃើញព្រះភូរិទត្តលូន នាំគ្នាភិតភ័យរត់ចេញទៅ ។ សុទស្សនៈឈរតែម្នាក់ឯង ព្រះភូរិទត្តឱនសីសៈ យំត្រង់ខ្នងជើងរបស់សុទស្សនៈ ឯសុទស្សនៈក៏យំដូចគ្នា ។ ព្រះមហាសត្វយំហើយ ក៏ត្រឡប់មកចូលកំប្រោងវិញ អាលម្ពាយយល់ថា តាបសត្រូវនាគនេះចឹក គិតនឹងលួងលោម ទើបចូលទៅរកសុទស្សនៈ ហើយពោលថា

នាគដែលរួចអំពីដៃ ( របស់យើង ) ក្រាបចុះលើជើងលោក
យ៉ាងខ្លាំង លោកត្រូវពស់ចឹកឬ លោកកុំខ្លាចឡើយ ចូរដល់

សេចក្ដីសុខចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មា ភាយិ** សេចក្ដីថា បពិត្រតាបស ខ្ញុំឈ្មោះអាលម្ពាយ សូមលោកកុំខ្លាចឡើយ ឈ្មោះថា ការព្យាបាលនោះ ជានាទីរបស់ខ្ញុំ ។ សុទស្សនៈ ព្រោះមានបំណងនឹងពោលជាមួយអាលម្ពាយ ក៏ពោលថា

នាគនេះ មិនអាចឲ្យទុក្ខណាមួយដល់អាត្មាទេ អ្នកចាប់ពស់មានទាំងប៉ុន្មាន មិនមែនមានច្រើនជាងអាត្មាទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាយចិ** សេចក្ដីថា នាគនេះ មិនមានសមត្ថភាពក្នុងការញុំាងទុក្ខណាមួយ សូម្បីមានប្រមាណតិច ឲ្យកើតឡើងដល់យើងបានឡើយ ព្រោះគ្រូពស់ដែលក្រៃលែងជាងយើងមិនមាន ។ អាលម្ពាយមិនស្គាល់ថា សុទស្សនៈជានរណា ក៏ក្រោធថា

អ្នកណាហ្ន៎ ភ្លីភ្លើ មានភេទដូចជាភេទនៃព្រាហ្មណ៍ មកកាន់បរិស័ទ ហើយហៅ ( អញ ) ច្បាំង បរិស័ទចូរស្ដាប់ពាក្យរបស់យើងចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧគ្គោ** បានដល់ ឃោរឃៅ អាក្រក់លាមក អន្ធពាល ។ បទថា **អវ្ហាយតុ** បានដល់ មកបបួលយើងច្បាំង ។ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ លោកអធិប្បាយថា បុគ្គលនោះជានរណា ជាមនុស្សល្ងង់ខ្លៅ ឬជាមនុស្សឆ្កួត មកបបួលយើងដោយសង្គ្រាម

លើកខ្លួនស្មើនឹងយើង មកកាន់បរិស័ទ ។ បទថា **បរិសា មម** សេចក្តីថា សូមបរិស័ទស្តាប់យើង ទោសរបស់យើងមិនមាន សូមពួកអ្នកកុំក្រោធនឹងខ្ញុំឡើយ ។ លំដាប់នោះ សុទស្សនៈបានពោលនឹងគ្រុតស់ថា

ម្នាលអាលម្ពាយ អ្នកច្បាំងនឹងយើងដោយនាគ យើងក៏ច្បាំងនឹងអ្នកដោយកូនកង្កែបដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាណៈ ៥០០០ ជាកំណត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នាគេន** សេចក្តីថា អ្នកចង់ច្បាំងជាមួយយើងដោយនាគ យើងក៏នឹងច្បាំងជាមួយអ្នកដោយកូនកង្កែប ។ បទថា **អាសហាស្ស្រហិ បញ្ចហិ** សេចក្តីថា ណ្ហើយចុះ ក្នុងការច្បាំងរបស់យើងនោះ ចូរយើងភ្នាល់គ្នាដោយដាក់ ៥០០០ កហាបណៈ ។

អាលម្ពាយពោលថា

ម្នាលមាណព យើងជាអ្នកមានទ្រព្យស្តុកស្តម្ភ អ្នកឯងជាអ្នកទាល់ក្រ តើបុគ្គលណា ជាអ្នកធានាអ្នក ម្យ៉ាងទៀត ទ្រព្យតម្កល់ទុកក្នុងការភ្នាល់មានដែរឬ ។ ទ្រព្យតម្កល់ទុកក្នុងការភ្នាល់របស់យើងមាន ទាំងបុគ្គលជាអ្នកធានាប្រាកដដូច្នោះ ក៏មានដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ ៥០០០ ជាកំណត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ នុ តេ** សេចក្តីថា អ្នកជាអ្នកធានារបស់អ្នក ដែលជាបព្វជិតមានឬ ។ បទថា **ឧបជូតញ្ច** នេះ អាលម្ពាយ

ពោលថា ម្យ៉ាងទៀត ទ្រព្យណាមួយ ឈ្មោះថា ជារបស់អ្នកដែលតម្កល់ទុកក្នុងការភ្នាល់មានឬ ចូរអ្នកបង្ហាញដល់ខ្ញុំ ។ បទថា **ឧបជូតញ្ច មេ** សេចក្តីថា ឯទ្រព្យដែលគប្បីឲ្យដល់ខ្ញុំ ឬដែលគប្បីដាក់ភ្នាល់ ឬអ្នកជាអ្នកធានាបែបនេះមាន ព្រោះដូច្នោះ ក្នុងការច្បាំងរបស់យើងទាំង ២ នោះ យើងទាំង ២ នឹងត្រូវមានទ្រព្យសម្រាប់ដាក់ ៥០០០ កហាបណៈ ។

សុទស្សនៈ កាលបានស្តាប់ពាក្យរបស់អាលម្ពាយនោះហើយ មិនខ្លាចអះអាងថា ណ្ហើយចុះ ភ្នាល់គ្នាដោយទ្រព្យ ៥០០០ កហាបណៈដូច្នេះ ក៏ឡើងកាន់ព្រះរាជនិវេសន៍ គាល់ព្រះបាទកាសីដែលជាអ៊ំហើយ ពោលគាថានេះថា

បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យអាត្មាភាព
សេចក្តីចម្រើនចូរមានដល់ព្រះអង្គ ព្រះអង្គមានកិត្តិគុណ សូម
ព្រះអង្គធានាដោយកហាបណៈ ៥០០០ របស់អាត្មាភាព
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិត្តិមា** បានដល់ ជាអ្នកសម្បូរដោយកិត្តិគុណ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា តាបសនេះ សុំទ្រព្យអញច្រើនម្ល៉េះ មានហេតុអ្វីហ្ន៎ ទើបត្រាស់គាថានេះថា

នៃព្រាហ្មណ៍ បំណុលជារបស់នៃបិតា ឬថា ខ្ញុំជំពាក់ដោយ
ខ្លួនឯង បានជាអ្នកទារយកទ្រព្យរបស់យើងច្រើន តើព្រោះ
ហេតុអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បេត្តិកំ វា** សេចក្ដីថា ឈ្មោះថា បំណុល នេះ ជារបស់បិតា យកប្រើបរិភោគឬ ឬខ្លួនឯងធ្វើទ្រព្យណាមួយដែលបិតា របស់យើងកាន់យកអំពីដៃរបស់អ្នក ឬអ្វីយើងកាន់យករបស់អ្នកមាន ព្រោះ ហេតុអ្វី ទើបអ្នកសូមទ្រព្យច្រើនដល់ម្ល៉េះនឹងយើង ។

កាលព្រះរាជាត្រាស់យ៉ាងនេះ សុទស្សនៈក៏បានពោល ២ គាថាថា

ដ្បិតអាលម្ពាយព្រាហ្មណ៍ ផ្ចាញ់អាត្មាភាពដោយនាគ អាត្មា
ភាពនឹងញុំាងកូនកង្កែបឲ្យខាំព្រាហ្មណ៍ ។ បពិត្រមហារាជ
ញុំាងដែនឲ្យចម្រើន ព្រោះហេតុនោះ សូមព្រះអង្គមានពួកអ្នក
កាន់ព្រះខ័នហែហម យាងទៅដើម្បីទតពស់ដែលគួរទត
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិជិគីសតិ** សេចក្ដីថា ក្នុងសង្គ្រាមដែល បុគ្គលប្រាថ្នានឹងឈ្នះ បើអាលម្ពាយឈ្នះអាត្មាៗ នឹងឲ្យទ្រព្យ ៥០០០ កហាបណៈដល់គេ បើអាត្មាឈ្នះ ក៏នឹងឲ្យដល់អាត្មាដូចគ្នា ព្រោះដូច្នោះ ទើបអាត្មាសូមទ្រព្យរបស់ទ្រង់ជាច្រើន ។ បទថា **តំ** សេចក្ដីថា មហាបពិត្រ សូមទ្រង់ទតនាគក្នុងថ្ងៃនេះ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ យើងនឹងទៅ ទើបយាងទៅជាមួយ តាបសនោះឯង ។ អាលម្ពាយឃើញព្រះរាជាយាងមកជាមួយតាបស កិត ភ័យ ខ្លាចថា តាបសនេះ ទៅអញ្ជើញព្រះរាជាមក ប្រហែលជាបព្វជិតក្នុង ព្រះរាជវាំង កាលនឹងចាក់ស្រេប ទើបពោលថា

ម្នាលមាណព ខ្ញុំមិនមើលងាយអ្នកដោយសិប្បវាទទេ ចំណែកអ្នកមើលងាយដោយសិប្បៈ បានជាមិនកោតក្រែងនាគដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សិប្បវាទេន** អាលម្ពាយពោលថា នៃមាណព យើងមិនបានមើលងាយអ្នកដោយសិប្បសាស្ត្ររបស់ខ្លួនឡើយ តែអ្នកស្រវឹងដោយសិប្បសាស្ត្ររបស់ខ្លួន មិនបូជានាគនេះ គឺមិនធ្វើការកោតក្រែងនាគនោះ ។

លំដាប់នោះ សុទស្សនៈបានពោល ២ គាថាថា

នៃព្រាហ្មណ៍ អាត្មាក៏មិនមើលងាយអ្នកដោយសិប្បវាទទេ តែអ្នកបញ្ឆោតជនច្រើនដោយនាគ ដែលមិនមានពិស ។ អាត្មាដឹងអ្នកយ៉ាងណា ជនក៏ត្រូវដឹងអ្នកយ៉ាងនោះដែរ ម្នាលអាលម្ពាយ អ្នកមិនបានអង្កាម ១ ក្ដាប់ នឹងបានទ្រព្យអំពីណាដូច្នេះ ។

លំដាប់នោះ អាលម្ពាយខឹងក្រោធចំពោះសុទស្សនៈ ទើបពោលថា

អ្នកស្លៀកដណ្ដប់ស្បែកខ្លាទាំងក្រចក មានផ្នួងសក់ ជាមនុស្សកខ្វក់ ក្ជីក្ជើ មកកាន់បរិស័ទ ហើយមើលងាយនាគបែបនេះថាមិនមានពិស អ្នកចូរមក យើងគង់នឹងដឹងនាគនោះ ដែលពេញដោយតេជៈរបស់នាគដ៏ខ្ពង់ខ្ពស់ ខ្ញុំសម្គាល់ថា នាគនុ៎ះនឹងធ្វើអ្នកឲ្យដូចជាគំនរផេះយ៉ាងឆាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រុម្មី** សេចក្ដីថា លោកស្លៀកសំពត់ស្បែកខ្លាទាំងក្រចក ។ បទថា **អវិសោ អតិមញ្ញសិ** សេចក្ដីថា អ្នកមើលងាយនាគនេះថា មិនមានពិស ។ បទថា **អាសជ្ជ** សេចក្ដីថា ចូលមកជិត ។ បទថា **ជញ្ញាសិ** បានដល់ លោកនឹងដឹង ។

លំដាប់នោះ សុទស្សនៈកាលធ្វើនូវការចំអក ទើបពោលថា

ពិសនៃពស់ផ្ទះ ពស់ទឹក ពស់ខៀវ គ្រាន់មានខ្លះ ឯពិស
នៃនាគមានក្បាលក្រហម មិនមានសោះឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សិលុត្តស្ស** បានដល់ ពស់ផ្ទះ ។ បទថា **ឧទ្ទុភស្ស** បានដល់ ពស់ទឹក ។ បទថា **សិលាភុនោ** បានដល់ ពស់ដែលមានខៀវ ។

សុទស្សនៈ កាលសម្ដែងពស់មិនមានពិសដូច្នេះហើយ ទើបពោលថា ពិសរបស់ពស់ទាំងនោះគប្បីមាន តែពិសរបស់ពស់ដែលមានក្បាលក្រហមមិនមានឡើយ ។

លំដាប់នោះ អាលម្ពាយបានពោលនឹងសុទស្សនៈគាថា ២ ថា

ខ្ញុំបានស្ដាប់ពាក្យនេះរបស់ពួកព្រះអរហន្ត ដែលសង្រួមហើយ
មានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ
រមែងទៅកាន់ស្ថានសួគ៌ ថាបើអ្នកមានវត្ថុតិចតួចដែលគួរឲ្យ
អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ ។ នាគនេះ មានឫទ្ធិ
ច្រើន មានតេជះដែលគេកន្លងបានដោយក្រ ខ្ញុំនឹងប្រើនាគនេះ

ឲ្យចឹកអ្នក នាគនោះ នឹងធ្វើអ្នកឲ្យទៅជាផេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធាតវេ** សេចក្ដីថា បើលោកមានវត្ថុណាមួយដែលគួរឲ្យ ចូរឲ្យទានចុះ ។

លំដាប់នោះ សុទស្សនៈពោលថា

ម្នាលសម្លាញ់ ខ្ញុំក៏បានស្ដាប់ពាក្យនេះ របស់ពួកព្រះអរហន្ត
ដែលសង្រួមហើយ មានតបៈថា ទាយកទាំងឡាយក្នុងលោក
នេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌ ថាបើអ្នកមាន
វត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយ
ចុះ ។ កូនកង្កែបនេះ ឈ្មោះអច្ចិមុខី ពេញដោយតេជះរបស់
ពស់ដ៏ខ្ពង់ខ្ពស់ អាត្មានឹងប្រើនាងអច្ចិមុខីនោះ ឲ្យខាំអ្នក នាង
អច្ចិមុខីនោះ នឹងធ្វើអ្នកឲ្យទៅជាផេះ ។ នាងអច្ចិមុខីនោះ ជា
ធីតារបស់ព្រះបាទធតរដ្ឋ មានមាតាផ្សេងគ្នា ជាប្អូនស្រីរបស់
អាត្មា ដ៏ពេញដោយតេជះរបស់ពស់ដ៏ខ្ពង់ខ្ពស់ ចូរខាំចុះ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧគ្គស្ស តេជសា** សេចក្ដីថា ពេញទៅដោយពិសដ៏ឧត្ដម ។

កាលសុទស្សនៈពោលយ៉ាងនេះហើយ ទើបលាដៃហៅប្អូនស្រីក្នុងកណ្ដាលមហាជននោះឯង ដោយពាក្យថា ចូរនាងអច្ចិមុខីចេញអំពីផ្នួងសក់របស់យើង មកឈរលើបាតដៃរបស់បង ។

នាងអច្ចិមុខីដេកក្នុងជជានោះឯង បានឮសំឡេងហៅរបស់សុទស្សនៈ បងប្រុស បន្ទឺសំឡេងកន្ត្តែប ៣ ដងហើយ ទើបចេញពីក្នុងជជា ទំត្រង់ចន្ទយស្មា លោតអំពីនោះ ក៏ទំលើបាតដៃរបស់សុទស្សនៈដែលជាបងប្រុស ហើយធ្វើតំណក់ពិស ៣ តំណក់ ឲ្យធ្លាក់ចុះ ហើយចូលទៅក្នុងជជារបស់សុទស្សនៈវិញ ។ សុទស្សនៈឈរកាន់ពិស ហើយប្រកាសដោយសំឡេងខ្លាំង ៣ ដងថា អ្នកជនបទនឹងវិនាសហ្ន៎ ។ សំឡេងរបស់សុទស្សនៈ បានលាន់ឮពេញនគរពារាណសីទាំង ១២ យោជន៍ ។ លំដាប់នោះ ព្រះរាជាត្រាស់សួរថា អ្នកជនបទនឹងវិនាសដូចម្តេច សុទស្សនៈទូលថា បពិត្រមហារាជ អាត្មាមិនឃើញទីដែលគួរទម្លាក់ពិសនេះ ព្រះរាជាត្រាស់ថា ចូរលោកទម្លាក់ត្រង់ផែនដីចុះ លំដាប់នោះ សុទស្សនៈ កាលនឹងឃាត់ព្រះរាជា ទើបពោលថា អាត្មាមិនអាចចោលពិសលើផែនដីធំនោះ ទើបពោលគាថានេះថា

> បពិត្រព្រះអង្គព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មា
> កាពសាចពិសទៅលើផែនដី ស្មៅ វល្លិ៍ ពួកឈើជាឱសថ
> នឹងស្វិតស្រពោនគ្មានសល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តិណលតានិ** សេចក្តីថា ស្មៅ វល្លិ និងដើមឈើជាឱសថទាំងពួងដែលអាស្រ័យផែនដី ក៏គប្បីស្វិតស្រពោនទៅ ព្រោះដូច្នោះ ទើបអាត្មាមិនអាចបន្តក់ពិសលើផែនដីបាន ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរគ្រវែងទៅលើអាកាស សុទស្សនៈកាលនឹងសម្តែងថា សូម្បីក្នុងអាកាស ក៏មិនអាចគ្រវែងពិសនេះទៅបាន ទើបពោលគាថានេះថា

បពិត្រព្រះអង្គព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មា
ភាពសាចពិសទៅខាងលើ ភ្លៀងនឹងមិនបង្អុរចុះ ទឹកសន្សើម
នឹងមិនធ្លាក់ចុះអស់ ៧ ឆ្នាំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ហិមំ បតេ** សេចក្ដីថា សូម្បីត្រឹមតែ
តំណក់ទឹកសន្សើមក៏មិនធ្លាក់អស់ ៧ ឆ្នាំ ព្រះរាជាត្រាស់ថា បើដូច្នោះ សូម
លោកបាចសាចពិសនោះទៅក្នុងទឹក សុទស្សនៈកាលសម្ដែងថា សូម្បីទឹក
នោះ ក៏ពិសមិនអាចធ្លាក់ទៅបាន ទើបពោលថា

បពិត្រព្រះអង្គព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មា
ភាពសាចពិសទៅក្នុងទឹក ត្រី និងអណ្ដើកដែលជាសត្វកើត
ក្នុងទឹកទាំងប៉ុន្មាន នឹងស្លាប់ទាំងអស់ ដូច្នេះ ។

លំដាប់នោះ ព្រះរាជាត្រាស់ថា ខ្ញុំមិនដឹងធ្វើដូចម្ដេច សូមលោកជួយ
រកឧបាយ កុំឲ្យដែនរបស់យើងវិនាសផងចុះ សុទស្សនៈទូលថា មហាបពិត្រ
បើដូច្នោះ សូមមហាបពិត្រជីកអណ្ដូង ៣ ជង្រ្គាក្នុងទីនេះ ។ ព្រះរាជាឲ្យ
ជីកអណ្ដូងហើយ ។ សុទស្សនៈឲ្យដាក់អណ្ដូងទី ១ ពេញដោយឱសថ
ផ្សេងៗ អណ្ដូងទី ២ ពេញដោយគោម័យ អណ្ដូងទី ៣ ពេញដោយថ្នាំទិព្វ
ហើយក៏ដាក់ពិសក្នុងអណ្ដូងទី ១ ខណៈនោះឯង ផ្សែងក៏កើតឡើង ឆេះជា
អណ្ដាតភ្លើង រាលទៅឆេះអណ្ដូងគោម័យ ហើយរាលទៅដល់អណ្ដូងដែល
ដាក់ថ្នាំទិព្វ ឆេះថ្នាំទិព្វអស់ហើយ ទើបរលត់ អាលម្ពាយឈរក្បែរអណ្ដូង
នោះ ចំហាយផ្សែងពិសប៉ះពាល់រាងកាយ ក៏កើតជារោគឃ្លង់ ។ អាលម្ពាយ

កិតភ័យ ទើបស្រែកឡើង ៣ ដងថា ខ្ញុំលែងនាគរាជ ។ ព្រះពោធិសត្វបាន ឮដូច្នោះ ទើបចេញអំពីកំប្រោងរតនៈ និម្មិតអត្តភាពដោយគ្រឿងអលង្ការ ទាំងពួង ឈរដោយអាកប្បកិរិយាដូចទេវរាជ ។ សុទស្សនៈក្តី អច្ចមុខីក្តី មកឈរដូចព្រះពោធិសត្វនោះឯង គ្រានោះ សុទស្សនៈ ក៏ទូលសួរព្រះបាទ ពារាណសីថា បពិត្រមហារាជ ទ្រង់ស្គាល់ថា ទូលបង្គំទាំង ៣ ជាកូនចៅ នរណាដែរឬ ព្រះរាជាត្រាស់ថា អើបា យើងមិនស្គាល់ឡើយ សុទស្សនៈ ទូលថា ទ្រង់មិនស្គាល់ខ្ញុំទាំង ៣ ក៏លើកទុកសិនចុះ តែទ្រង់បានដឹងរឿង ដែលនាងសមុទ្ទជារាជធីតាព្រះបាទកាសី ដែលប្រទានដល់ព្រះបាទធតរដ្ឋខ្លះ ដែរឬ ព្រះរាជាត្រាស់ថា អើ យើងដឹង នាងសមុទ្ទជាជាប្អូនស្រីរបស់យើង សុទស្សនៈទូលថា បពិត្រមហារាជ យើងខ្ញុំទាំង ៣ ជាកូនរបស់នាងសមុទ្ទជា ទ្រង់ជាម្ចាស់អ៊ំរបស់ពួកយើង ព្រះរាជាបានស្តាប់ដូច្នោះ ទ្រង់ក៏ឱបថើបក្មួយ ទាំង ៣ ទ្រង់ព្រះកន្សែង ហើយនាំឡើងកាន់ប្រាសាទ ទ្រង់ធ្វើសក្ការៈច្រើន ហើយ លុះទ្រង់ធ្វើសក្ការៈហើយ ក៏សួរថា នែភូរិទត្ត ឯងមានឫទ្ធិដល់ម្ល៉េះ ហេតុអ្វីក៏អាលម្ពាយចាប់បាន ភូរិទត្តក៏ទូលរឿងនោះដោយពិស្តារ ហើយក៏ ថ្វាយឱវាទដល់ព្រះរាជា ទើបសម្តែងធម៌ដល់ម្ចាស់អ៊ំ ដោយន័យជាដើមថា សូមព្រះរាជទានវោកាស ទំនៀមរបស់ព្រះរាជា ដែលគ្រងរាជសម្បត្តិ ដោយទំនងយ៉ាងនេះ ។

លំដាប់នោះ សុទស្សនៈក៏ទូលព្រះរាជាថា បពិត្រម្ចាស់អ៊ំ មាតា របស់ខ្ញុំ មិនទាន់ជួបភូរិទត្តនៅឡើយ ខ្ញុំមិនអាចបង្អែបង្អង់នៅយូរបានឡើយ

ព្រះរាជាត្រាស់ថា សាធុ ចូរនាំគ្នាទៅចុះ តែអ៊ំចង់ជួបប្អូនស្រីខ្លះ ធ្វើដូចម្ដេច ទើបបានជួបហ្ន៎ សុទស្សនៈពោលថា បពិត្រម្ចាស់អ៊ំ ព្រះបាទកាសិករាជ ដែលជាព្រះអយ្យកោរបស់ខ្ញុំ ឥឡូវនេះ ទ្រង់នៅឯណា ព្រះរាជាត្រាស់ថា នែបា ព្រះបាទកាសិករាជ ក្រោយពីព្រាត់ប្រាសចាកប្អូនស្រីរបស់អ៊ំ មិនអាចសោយរាជសម្បត្តិបាន ក៏លះរាជសម្បត្តិចេញបួសជាឥសី ក្នុងដងព្រៃមួយកន្លែង ។ សុទស្សនៈពោលថា បពិត្រម្ចាស់អ៊ំ មាតារបស់ខ្ញុំបំណាងនឹងជួបម្ចាស់អ៊ំ និងព្រះអយ្យកោដែរ សូមទ្រង់យាងទៅកាន់សម្នាក់ព្រះអយ្យកោ ខ្ញុំនឹងនាំព្រះមាតាទៅកាន់អាស្រមព្រះអយ្យកោ ម្ចាស់អ៊ំនឹងជួបព្រះមាតារបស់ខ្ញុំក្នុងទីនោះឯង ។

ជនទាំង ៣ ណាត់គ្នាជាមួយម្ចាស់អ៊ំហើយ ចេញអំពីព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់បញ្ជូនក្មួយទៅហើយ ទ្រង់ព្រះកន្សែង ហើយក៏យាងត្រឡប់ ។ ក្មួយទាំង ៣ នាក់ មុជផែនដីទៅកាន់ពិភពនាគ ។

**នាគវេសនកណ្ឌ ចប់**

កាលព្រះមហាសត្វដល់នាគពិភពហើយ សំឡេងខ្សឹកខ្សួលក៏កើតព្រមគ្នា ព្រះភូរិទត្តហត់នឿយ ព្រោះចូលទៅក្នុងកំប្រោងអស់មួយខែ ទើបដេកឈឺ មានពួកនាគមកសួរសុខទុក្ខរាប់មិនអស់ ព្រះភូរិទត្តនោះហត់នឿយ ព្រោះប្រាស្រ័យជាមួយនាគទាំងនោះ ។

កាណារិដ្ឋៈទៅកាន់ទេវលោក កាលមិនជួបមហាសត្វ ក៏ត្រឡប់មកមុនគ្រានោះ ញាតិមិត្តរបស់ព្រះមហាសត្វឃើញថា កាណារិដ្ឋៈនោះកាច អាច

ហាមនាគបរិស័ទបាន ទើបឲ្យកាណារិដ្ឋៈជាអ្នកយាមទ្វារបន្ទប់របស់ព្រះមហាសត្វ ។ ឯសុភោគៈរកទូទៅពេញព្រៃហិមពាន្ត បន្ទាប់អំពីនោះ ក៏ពិចារណាបន្តថា នឹងតាមរកក្នុងមហាសមុទ្រ និងស្ទឹងក្រៅអំពីនោះ ហើយក៏ធ្វើដំណើរមកដល់ស្ទឹងយមុនា ។

ឯព្រាហ្មណ៍នេសាទឃើញអាលម្ពាយកើតឃ្លង់ គិតថា បុរសនេះឯងធ្វើភូរិទត្តឲ្យលំបាក ទើបកើតឃ្លង់ ឯអញក៏ជាអ្នកចង្អុលបង្ហាញភូរិទត្តដែលមានគុណដល់អញច្រើនដល់អាលម្ពាយ ដោយចង់បានកែវ កម្មអាក្រក់នេះនឹងមកដល់អញដែរ អញនឹងទៅកាន់ស្ទឹងយមុនាទាន់កម្មនោះមិនទាន់មកដល់អញនឹងធ្វើពិធីបន្សាត់បាបត្រង់កំពង់បយាគៈ ទើបទៅកាន់កំពង់ទឹកឈ្មោះបយាគៈ ហើយពោលថា ខ្ញុំបានធ្វើកម្ម គឺទ្រុស្តមិត្រក្នុងព្រះភូរិទត្ត ខ្ញុំនឹងបន្សាត់បាបនេះចោល ដូច្នេះហើយ ទើបធ្វើពិធីចុះទឹក ។

ខណៈនោះ សុភោគៈទៅដល់ទីនោះ បានឮពាក្យរបស់ព្រាហ្មណ៍-នេសាទ ក៏គិតថា បានឮថា តាចាស់នេះបាបធ្ងន់ បងប្រុសរបស់អញបានឲ្យយសសក្តិជាច្រើន បែរជាចង្អុលប្រាប់គ្រូពស់ ព្រោះចង់បានកែវ អញនឹងយកជីវិតវាចុះ ដូច្នេះហើយ ទើបយកកន្ទុយចងកជើងព្រាហ្មណ៍ទាំងសងខាងទាញឲ្យលិចទឹក ជិតដាច់ខ្យល់ ទើបបន្ធូរបន្តិច ព្រាហ្មណ៍បានផុសឡើង ក៏ទាញពន្លិចសាជាថ្មីទៀត ទូន្មានឲ្យលំបាកយ៉ាងនេះច្រើនដង ព្រាហ្មណ៍-នេសាទងើបក្បាលឡើងបាន ក៏ពោលគាថានេះថា

ទឹកដែលតាំងនៅក្នុងកំពង់បយាគៈ ដែលអញកំពុងស្រោច ជា

ទឹកដែលលោកសន្មតថា សម្រាប់លាងបាប ចុះខ្មោចអ្វី ជ្រមុជ
អញចុះទៅក្នុងស្ទឹងយមុនាដ៏ជ្រៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លោក្យំ** សេចក្តីថា ទឹកដែលសត្វលោកសន្មតថា អាចបន្សាត់បាបបានយ៉ាងនេះ ។ បទថា **សជ្ជន្តំ** សេចក្តីថា ទឹកបែបនេះដែលចាត់ទុកសម្រាប់ងូតបន្សាតបាប ។ បទថា **បយាគស្មឹ** បានដល់មានត្រង់កំពង់បយាគៈ ។

លំដាប់នោះ សុភោគៈបានពោលនឹងព្រាហ្មណ៍នេសាទនោះ ដោយគាថាដូច្នេះថា

នាគណា ជាធំក្នុងលោក មានយស បានមកព័ទ្ធក្រុងពារាណសី
ដោយជុំវិញ អញជាកូននាគដ៏ប្រសើរនោះ ម្នាលព្រាហ្មណ៍
នាគទាំងឡាយហៅអញថា សុភោគៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេនេស** កាត់បទជា **យោ ឯសោ** ។ បទថា **បរិហារី សមន្តតោ** សេចក្តីថា ព័ទ្ធក្រុងពារាណសី ដោយរង្វេលជុំវិញ បើកពពារអំពីខាងលើ ដោយអាចនាំទុក្ខចូលទៅដល់អ្នកដែលជាសត្រូវ ។

លំដាប់នោះ ព្រាហ្មណ៍នេសាទក៏គិតថា នាគនេះ ជាបងប្អូនរបស់ព្រះភូរិទត្ត នឹងមិនទុកជីវិតឲ្យអញ បើដូច្នោះ អញនឹងសរសើរកិត្តិគុណរបស់នាគ ទាំងមាតាបិតារបស់គេឲ្យចិត្តទន់ ហើយលែងជីវិតអញ ដូច្នេះហើយទើបពោលគាថានេះថា

បើអ្នកជាកូននៃនាគដ៏ប្រសើរ ជាព្រះរាជាក្នុងដែនកាសី ជាធំ
ជាងនាគដែលមានអាយុវែង បិតារបស់អ្នក ជានាគមានសក្តិធំ
មួយដែរ បណ្តាសត្វទាំងឡាយ មាតារបស់អ្នក ក៏មិនមានស្រ្តី
ណាផ្ទឹមបានឡើយ បុគ្គលមានអានុភាពច្រើនដូចអ្នក មិនគួរ
ចាប់ជ្រមុជបុគ្គលសូម្បីជាទាសៈនៃព្រាហ្មណ៍ទេ ដូច្នេះ ។

ក្នុងគាថានោះ បទថា **កាសិស្ស** បានដល់ ជនទាំងឡាយពោលថា ព្រះរាជាជាឥស្សរៈក្នុងដែនកាសី ដែលមានឈ្មោះយ៉ាងនេះ សូម្បីមានឈ្មោះដទៃ ព្រាហ្មណ៍ពណ៌នារាជសម្បត្តិដែនកាសីឲ្យជារបស់នាគរាជធតរដ្ឋ ព្រោះបានព្រះរាជធីតារបស់ព្រះបាទកាសី ។ បទថា **អមរាធិបស្ស** សេចក្តីថា ជាធំនៃនាគទាំងឡាយ ពោល គឺ **អមរ** ព្រោះមានអាយុវែង ។ បទថា **មហេសក្ខោ** សេចក្តីថា ជាអ្នកមានសក្តិធំ ។ បទថា **ធាសំបិ** សេចក្តីថា ពិតហើយ អានុភាពរបស់អ្នកច្រើនយ៉ាងនេះ មិនគួរធ្វើអ្នកមិនមានអានុភាពសូម្បីជាទាសៈរបស់ព្រាហ្មណ៍ឲ្យលិចទឹក នឹងពោលថ្វីដល់ព្រាហ្មណ៍ដែលមានអានុភាពច្រើននោះ ។

លំដាប់នោះ សុភោគៈក៏ពោលនឹងព្រាហ្មណ៍នោះថា នែព្រាហ្មណ៍អាក្រក់ ឯងសម្គាល់ថា នឹងបោកបញ្ឆោតអញឲ្យលែងឬ អញមិនឲ្យជីវិតឯងទេ កាលនឹងប្រកាសកម្មដែលព្រាហ្មណ៍នោះធ្វើ ទើបពោលថា

ឯងអែបដើមឈើ ហើយបាញ់ទ្រាយដែលមកផឹក ( ទឹក )
ទ្រាយនោះ ដែលឯងបាញ់ហើយ ក៏ងាកមើល ដោយកម្លាំងនៃ
សរ ក៏ស្ទុះទៅកាន់ទីឆ្ងាយ ។ ឯងបានឃើញទ្រាយនោះ ដួល

ក្នុងព្រៃធំហើយ ក៏នាំសាច់មួយអម្រែក ចូលទៅកាន់ដើមជ្រៃ ក្នុងវេលាល្ងាច ជាឈើដែលគឹងកងដោយសត្វសេក និង សាលិកា មានស្លឹកល្មើង ដេរដាសដោយពួរ ដែលសត្វ តាវៅទំយំ ជាទីគួររីករាយ មានផែនដីដុះស្មៅខៀវជានិច្ច បង របស់អញដែលមានអានុភាពច្រើន រុងរឿងដោយឫទ្ធិ និង យស ដែលពួកនាគកញ្ញាចោមរោមហើយ ក៏ប្រាកដដល់ឯង ក្នុងទីនោះ ។ ឯងនោះដែលបងរបស់អញនោះផ្គាប់ហើយ ឲ្យ ស្កប់ស្កល់ដោយកាមទាំងពួង ឯងបានប្រទូស្តចំពោះបងដែល មិនប្រទូស្ត ពៀរនោះ មកដល់ឯងក្នុងទីនេះហើយ ។ ឯងចូរ ដកកយ៉ាងឆាប់ អញនឹងមិនឲ្យជីវិតដល់ឯងទេ អញរឭក ឃើញនូវពៀរ ( ដែលឯងធ្វើ ) ចំពោះបង អញនឹងកាត់ ក្បាលឯងឥឡូវនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាយំ និគ្រោធុបាគមិ** សេចក្ដីថា អ្នក ចូលទៅកាន់ដើមជ្រៃក្នុងពេលវិកាល ។ បទថា **បិន្ទិយំ** សេចក្ដីថា មានស្លឹក ពណ៌ល្មើង ។ បទថា **សណ្ឌតាយុតំ** បានដល់ ដេរដាសដោយពួរជ្រៃ ។ បទថា **កោកិលាភិរុទំ** សេចក្ដីថា មានហ្វូងតាវៅយំល្វេងល្វើយ ។ បទថា **ធុវំ ហរិតសទ្ទលំ** សេចក្ដីថា ភូមិភាគខៀវទៅដោយស្មៅភ្លាំងជានិច្ច ព្រោះ កើតក្នុងទីជិតទឹក ។ បទថា **ឆាតុរហុ** សេចក្ដីថា បងប្រុសរបស់យើងនោះ បានប្រាកដ គឺប្រាកដច្បាស់ដល់ឯងត្រង់ដើមជ្រៃនោះ ។ បទថា **ឥទ្ធិយា** បានដល់ ដោយតេជះនៃបុណ្យ ។ បទថា **សោ តេន** សេចក្ដីថា ឯងកាល

បងប្រុសរបស់យើង នាំទៅកាន់ភពរបស់នាគ ហើយទំនុកបម្រុង ។ បទថា **បរិសរំ** សេចក្តីថា យើងរឭកដល់ពារ គឺកម្មអាក្រក់ដែលឯងធ្វើដល់បងប្រុសរបស់យើង ។ បទថា **ឆេទយិស្សាមិ** បានដល់ យើងនឹងកាត់ ( ក្បាល ) ។

លំដាប់នោះ ព្រាហ្មណ៍នេសាទគិតថា នាគនេះប្រហែលជាមិនទុកជីវិតឲ្យអញពិត តែអញក៏គួរព្យាយាមពោលនូវពាក្យណាមួយ ដើម្បីឲ្យរួចខ្លួនបាន ទើបពោលគាថានេះថា

ព្រាហ្មណ៍ជាអ្នករៀនមន្ត ១ ជាអ្នកប្រកបដោយការសូម ១
ជាអ្នកបូជាភ្លើង ១ ព្រាហ្មណ៍ប្រកបដោយហេតុទាំង ៣ នេះ
អ្នកមិនគួរសម្លាប់ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អវេជ្ឈោ** សេចក្តីថា ព្រាហ្មណ៍ជាបុគ្គលដែលគេមិនគួរសម្លាប់ គឺសម្លាប់មិនបានដោយហេតុ ៣ ប្រការនេះ មានព្រាហ្មណ៍ដែលទ្រទ្រង់នូវវេទជាដើម ព្រោះអ្នកណាសម្លាប់ព្រាហ្មណ៍ អ្នកនោះ រមែងកើតក្នុងនរក ។

សុភោគៈបានស្តាប់ដូច្នោះហើយ ទើបរារែកចិត្ត គិតថា អញនឹងនាំព្រាហ្មណ៍នេះទៅកាន់ភពនាគ សាកសួរបងប្អូនអញមើល ក្រែងដឹងបានដូច្នេះហើយ ទើបពោល ២ គាថាថា

បុរីណារបស់ព្រះបាទធតរដ្ឋ ជាវិការនៃមាសទាំងអស់ ដែល
ចូលទៅកាន់ស្ទឹងយមុនា ទល់នឹងភ្នំហិមពាន្ត ដែលនៅជិតស្ទឹង

យមុនា រមែងរុងរឿង ។ បងប្អូនរបស់អញទាំងនោះ ជាបុរស ក្លៀវក្លា ជាអ្នករួមផ្ទៃនៅក្នុងបុរីនោះ បងប្អូនទាំងនោះ ក្នុងបុរី នោះ និយាយយ៉ាងណា ឯងនឹងទៅជាយ៉ាងនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យំ បុរំ** បានដល់ នគរណា ។ បទថា **ឱគាឡ្ហំ** សេចក្ដីថា នៅជ្រៅខាងក្រោមស្ទឹងយមុនា ។ បទថា **គិរិមាហច្ច យមុនំ** សេចក្ដីថា តាំងនៅមិនឆ្ងាយអំពីស្ទឹងយមុនា ទៅទល់នឹងភ្នំហិមពាន្ត ។ បទថា **ជោតតេ** បានដល់ រុងរឿង ។ បទថា **តត្ថ តេ** សេចក្ដីថា បងប្អូនប្រុសរបស់យើងនោះនៅក្នុងនគរនោះ អធិប្បាយថា កាលឯងត្រូវនាំទៅក្នុងទីនោះ បងប្អូនប្រុសទាំងនោះថាយ៉ាងណា យើងនឹងធ្វើយ៉ាងនោះ បើឯងពោលពាក្យពិត ជីវិតរបស់ឯងនឹងមាន បើឯងនិយាយមិនពិត អញនឹងកាត់ក្បាលរបស់ឯងក្នុងទីនោះ ។

សុភោគៈកាលពោលដូច្នេះហើយ ក៏ចាប់កព្រាហ្មណ៍ គ្រវីបណ្ដើរ ជេរបណ្ដើរ រហូតដល់ប្រាសាទព្រះពោធិសត្វ ។

### សុភោគកណ្ឌ ចប់

លំដាប់នោះ កាលណារិដ្ឋៈអង្គុយយាមទ្វារ ឃើញសុភោគៈនាំព្រាហ្មណ៍ធ្វើទារុណកម្មមកដូច្នោះ ទើបដើរបញ្ច្រាស់ផ្លូវទៅប្រាប់ នែបងសុភោគៈ បងកុំបៀតបៀនព្រាហ្មណ៍នោះ ព្រោះបុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ក្នុងលោកនេះ ជាកូនរបស់មហាព្រហ្ម បើមហាព្រហ្មដឹង ទ្រង់នឹងក្រោធ ពោលថា នាគទាំងនេះ បៀតបៀនកូនទាំងឡាយរបស់អញ អញនឹងធ្វើស្ថាននាគឲ្យ

វិនាស ព្រោះបុគ្គលឈ្មោះថា ព្រាហ្មណ៍ ជាបុគ្គលប្រសើរ និងមានអានុភាព ច្រើនក្នុងលោក បងមិនស្គាល់អានុភាពរបស់ព្រហ្មទាំងនោះ ឯខ្ញុំ ទើបដឹង ។ បានឮមកថា កាលណារិដ្ឋៈក្នុងភពកន្លងមក បានកើតជាព្រាហ្មណ៍ បូជាយញ្ញ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ កាលពោលហើយ ដោយអំណាចដែលខ្លួនធ្លាប់សោយមកអំពីមុន ទើបមានប្រក្រតីស្តាប់ក្នុងការបូជាយញ្ញ ក៏ហៅសុភោគៈ និងនាគបរិស័ទមកប្រាប់ថា នែអ្នកដ៏ចម្រើនទាំងឡាយ ចូរមក ខ្ញុំនឹងពណ៌នាគុណរបស់ព្រាហ្មណ៍ ដែលធ្វើការបូជាយញ្ញ ដូច្នេះហើយ ទើបផ្តើមពណ៌នាយញ្ញដូច្នេះថា

បពិត្រសុភោគៈ យញ្ញ និងវេទទាំងឡាយ ក្នុងលោកនេះ ដែលព្រាហ្មណ៍ឯទៀតប្រកបហើយ មិនមែនជារបស់ផ្តេសផ្តាស ទេ ព្រោះហេតុនោះ បុគ្គលកាលតិះដៀលព្រាហ្មណ៍ ដែលមិនគួរតិះដៀល ឈ្មោះថា លះបង់ទ្រព្យ និងធម៌របស់ពួកសប្បុរស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អផិត្តរា** សេចក្តីថា នែសុភោគៈ យញ្ញ និងវេទទាំងឡាយក្នុងលោកនេះ ដែលពួកព្រាហ្មណ៍ប្រកបឡើង មិនមែនតូចតាច មិនមែនថោកថយ មានអានុភាពច្រើន យញ្ញ និងវេទទាំងនោះ ដែលពួកព្រាហ្មណ៍ក្រៅអំពីនេះប្រកបឡើង ព្រោះដូច្នោះ សូម្បីព្រាហ្មណ៍ទាំងឡាយ ក៏ជាបុគ្គលមិនតូចតាចឡើយ ។ បទថា **តឧគ្គរយ្ហំ** សេចក្តីថា ព្រោះហេតុនោះ បុគ្គលតិះដៀលព្រាហ្មណ៍ដែលមិនគួរតិះដៀល ឈ្មោះថា រមែងលះបង់

នូវទ្រព្យ និងធម៌របស់សប្បុរស គឺរបស់បណ្ឌិតទាំងឡាយ ។

បានឮមកថា អរិដ្ឋៈពោលថា នាគបរិស័ទទាំងឡាយ កុំពោលថា ព្រាហ្មណ៍នេះ ធ្វើកម្មទ្រុស្តមិត្រ គឺក្នុងព្រះភូរិទត្តឡើយ ។

លំដាប់នោះ កាណារិដ្ឋៈបានពោលនឹងសុភោគៈនោះថា នែសុភោគៈ បងដឹងឬទេថា លោកនេះ អ្នកណាសាង កាលសុភោគៈឆ្លើយថា យើងមិនដឹង ដើម្បីនឹងសម្តែងថា លោកនេះ មហាព្រហ្មជីតារបស់ពួកព្រាហ្មណ៍សាង ទើបពោលគាថាបន្តថា

ពួកអ្នកប្រសើរ ( ព្រាហ្មណ៍ ) ប្រកាន់ខាងការរៀនមន្ត ពួកជាធំជាងជន ( ក្សត្រិយ៍ ) ប្រកាន់ខាងការផែនដី ពួកវេស្សៈប្រកាន់ខាងការភ្ជួររាស់ ពួកសូទ្រៈ ប្រកាន់ខាងការបម្រើផ្សេងៗគ្នា តាមសមគួរដល់ប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបាគូ** បានដល់ ចូលដល់ហើយ ។ បានឮថា ព្រហ្មនិម្មិតវណ្ណៈទាំង ៤ មានវណ្ណៈព្រាហ្មណ៍ជាដើម ពោលនឹងព្រាហ្មណ៍ទាំងឡាយដ៏ប្រសើរ ជាលំដាប់ដំបូងថា ចូរពួកអ្នកទាញយកនូវការសិក្សាត្រៃវេទប៉ុណ្ណោះ កុំធ្វើវត្តុដទៃ ។ ពោលនឹងព្រះរាជាថា ចូរពួកអ្នកគ្រប់គ្រងផែនដីតែម្យ៉ាង កុំធ្វើវត្តុដទៃ ពោលនឹងពួកវេស្សៈថា ចូរពួកអ្នកភ្ជួរស្រែតែម្យ៉ាង ពោលនឹងពួកសូទ្រៈថា ចូរពួកអ្នកបម្រើវណ្ណៈទាំង ៣ តែម្យ៉ាង ។

តាំងពីនោះមក ក៏ពោលថា ព្រាហ្មណ៍ប្រសើរ កាន់យកនូវការសិក្សាត្រៃវេទ ព្រះរាជាកាន់យកនូវការគ្រប់គ្រង វេស្សៈកាន់យកនូវការភ្ជួររាស់ស្រែ សូទ្រៈកាន់យកនូវការបម្រើ ។ បទថា **បច្ចេកំ យថាបទេសំ** សេចក្ដីថា កាលនឹងចូលទៅកាន់យកអាជីព គឺកាន់យកការងាររៀងៗ ខ្លួន តាមទំនងដែលព្រាហ្មណ៍ពោលហើយដោយសមគួរតាមត្រកូល និងប្រទេសរបស់ខ្លួន ។ បទថា **កតាហុ ឯតេ វសិនាតិ អាហុ** សេចក្ដីថា លោកសម្ដែងថា ព្រាហ្មណ៍ទាំងនោះ ជាបុគ្គលដែលមហាព្រហ្មអ្នកមានអំណាចបានសាងយ៉ាងនេះ ។

កាណារិដ្ឋៈពោលថា ឈ្មោះថា ព្រាហណ៍ ជាអ្នកមានអានុភាពច្រើនយ៉ាងនេះ បុគ្គលណាធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រាហ្មណ៍ទាំងនោះ ហើយឲ្យទាន បុគ្គលនោះមិនមានបដិសន្ធិក្នុងទីដទៃ រមែងទៅកាន់ទេវលោកតែម្យ៉ាង ទើបពោលថា

> ទេវរាជព្រះនាមធាតុ វិធាតុ វរុណៈ កុវេរៈ សោមៈ យមៈ
> ចន្ទិមៈ វាយុ សុរិយៈ ស្ដេចទាំងនេះ បានបូជាយញ្ញដ៏ច្រើន
> ទាំង ( បានឲ្យ ) វត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ពួកព្រាហ្មណ៍
> អ្នករៀនមន្ត ។ ព្រះបាទអជ្ជុនណាមានកម្លាំង មានសេនាគួរ
> ខ្លាច មានដៃមួយពាន់ មិនមានបុគ្គលណាស្មើលើផែនដី ជាអ្នក
> យឹតធ្នូ ៥០០ បាន ព្រះបាទអជ្ជុននោះឯង ក៏បូជាភ្លើងក្នុង
> កាលនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯតេបិ** បានដល់ ទេវរាជទាំងឡាយ មាន

ព្រះបាទធាតាទាំងនោះជាដើម ។ បទថា **បុថុសោ** សេចក្តីថា បូជាយញ្ញជាច្រើន ។ ដោយបទថា **អថ សត្ថកាមេ** នេះ លោកសម្តែងថា ម្យ៉ាងទៀត ឲ្យនូវវត្ថុដែលគួរត្រេកអរទាំងពួងដល់ព្រាហ្មណ៍ ដែលជាអ្នករៀននូវមន្ត ទើបដល់នូវឋានៈទាំងនេះ ។ បទថា **វិកាសិតា** បានដល់ ទាញមក ។ បទថា **ចាបសតានិ បញ្ច** សេចក្តីថា មិនមែនត្រឹមតែធ្នូ ៥០០ សូម្បីធ្នូធំ ៥០០ ក៏ទាញមកបានដោយខ្លួនឯង ។ បទថា **ភីមសេនោ** បានដល់ មានកងទ័ពដែលគួរខ្លាច ។ បទថា **សហស្សពាហុ** សេចក្តីថា មិនមែនទ្រង់មានដៃ ១០០០ តែសេចក្តីថា លោកអាចលើកធ្នូធំ ដែលត្រូវលើកដោយដៃចំនួន ១០០០ គឺកម្លាំងបុរស ៥០០ ទើបអាចលើកបាន ព្រោះហេតុនោះទើបពោលយ៉ាងនេះ ។ បទថា **អាធហិ ជាតវេទំ** សេចក្តីថា ក្នុងកាលនោះ ព្រះរាជាទាំងនោះឲ្យព្រាហ្មណ៍ទាំងឡាយ ស្កប់ស្កល់ដោយកាមទាំងពួង ឲ្យដុតភ្លើង ហើយបម្រើភ្លើង ព្រោះហេតុនោះ ទើបកើតក្នុងទេវលោក ព្រោះហេតុនោះ ទើបលោកពោលថា ព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា ជាធំក្នុងលោកនេះ ។

កាណារិដ្ឋៈកាលសរសើរពួកព្រាហ្មណ៍ឲ្យក្រៃលែងឡើង បានពោលគាថានេះថា

បុគ្គលណា មានចិត្តជ្រះថ្លា រីករាយ បានញ៉ាំងព្រាហ្មណ៍ឲ្យ
បរិភោគបាយ និងទឹកអស់កាលយូរដ៏សមគួរ តាមអានុភាព
បពិត្រសុភោគៈ បុគ្គលនោះនឹងបានជាទេវតាមួយអន្ថ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យោ** ជាបទសម្ដែងមិនចំពោះ គឺលោកសម្ដែងថា អ្នកណាក៏បានដូចគ្នានឹងព្រះបាទពារាណសីអំពីបុរាណ ។ បទថា **យថានុភាវំ** សេចក្ដីថា បរិច្ចាគទ្រព្យទាំងអស់ ដែលមានដល់បុគ្គលនោះតាមកម្លាំង ហើយឲ្យបរិភោគ ។ បទថា **ទេវញ្ញតរោ** សេចក្ដីថា នៃសុភោគៈ គេបានជាទេវរាជមានសក្ដិធំម្នាក់ ។ ព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរយ៉ាងនេះ ។

លំដាប់នោះ កាណារិដ្ឋៈកាលនាំហេតុដទៃមកសម្ដែង ទើបពោលគាថាបន្ដថា

> ព្រះបាទមុជលិន្ទ អាចញុំាំងទេវតាភ្លើង ជាអ្នកស៊ីច្រើន មាន
> ពន្លឺមិនថោកទាប ឲ្យស្កប់ស្កល់ដោយសប្បិ បានបូជាវិធីយញ្ញ
> ចំពោះទេវតាភ្លើងដ៏ប្រសើរ ទ្រង់បានទៅកាន់គតិជាទិព្វ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មហាសនំ** បានដល់ ជាអ្នកស៊ីច្រើន ។ បទថា **ភោជេត្វា** បានដល់ ដើម្បីឲ្យឆ្អែតស្កប់ស្កល់ ។ បទថា **យញ្ញតន្តំ** បានដល់ វិធីបូជាយញ្ញ ។ បទថា **វរតោ** បានដល់ បូជាទេវតា គឺភ្លើងដ៏ប្រសើរ ។ បទថា **មុចលិន្ទជ្ឈគច្ឆិ** សេចក្ដីថា ព្រះបាទមុចលិន្ទទ្រង់បានចូលដល់ហើយ ។

បានឮមកថា ព្រះរាជាមួយអង្គព្រះនាមមុជលិន្ទ ក្នុងក្រុងពារាណសីក្នុងកាលមុន ត្រាស់ឲ្យព្រាហ្មណ៍ទាំងឡាយមក ហើយសួរដល់ផ្លូវដែលទៅស្ថានសួគ៌ ។

លំដាប់នោះ ព្រាហ្មណ៍ទាំងនោះ ទូលព្រះរាជាថា សូមទ្រង់ធ្វើសក្ការៈដល់ពួកព្រាហ្មណ៍ និងដល់ពួទេវតាដែលជាព្រាហ្មណ៍ កាលព្រះរាជាត្រាស់សួរថា ទេវតាដែលជាព្រាហ្មណ៍ពួកណា ក៏ទូលថា ទេវតា គឺភ្លើង ដូច្នេះហើយ ទើបទូលព្រះរាជាថា សូមទ្រង់ឲ្យភ្លើងនោះឆ្អែតដោយសប្បិ និងនវនីត ព្រះរាជានោះបានធ្វើយ៉ាងនោះ ។

កាលព្រះសាស្តា... កាលណារិដ្ឋៈនោះ កាលនឹងប្រកាសសេចក្តីនោះ ទើបពោលគាថានេះថា

ព្រះរាជាព្រះនាមទុទីបៈ មានអានុភាពច្រើន មានព្រះជន្ម
១០០០ ឆ្នាំ បានលះបង់ដែន ព្រមទាំងសេនា មិនមានទីបំផុត
ហើយបួស បានជាទក្ខិណេយ្យបុគ្គល គួរមិលមើលដ៏លើស
លុប ទ្រង់បានទៅកាន់ស្ថានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បព្វជិ** សេចក្តីថា ដែលគ្រប់គ្រងរាជសម្បត្តិអស់ ៥០០ ឆ្នាំ ធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងឡាយ ហើយលះរាជសម្បត្តិដែលមិនមានទីបំផុត មួយអន្លើដោយសេនា ហើយចេញបួស ទ្រង់ធ្វើនូវសមណធម៌ ៥០០ ឆ្នាំ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ គួរមើល គួរសរសើរ ។ បទថា **ឧុធីចោបិ** លោកពោលថា ព្រះរាជាព្រះនាមទុទីបៈនោះបូជាព្រាហ្មណ៍ទាំងឡាយប៉ុណ្ណោះ ក៏យាងទៅកាន់ស្ថានសួគ៌ បាលីថា **ឧុធិប** ដូច្នេះក៏មាន ។

កាលណារិដ្ឋៈ កាលសម្តែងឧទាហរណ៍ដទៃទៀតដល់សុភោគៈនោះ បានពោលគាថានេះថា

បពិត្រសុភោគៈ ព្រះបាទសាគរឈ្មះផែនដី មានសាគរជាទីបំផុត បានលើកសសរយញ្ញដ៏ល្អ ជាវិការនៃមាសដ៏លើសលុបបូជាភ្លើង ទ្រង់បានជាទេវតាមួយអន្ត ។ បពិត្រសុភោគៈ ទន្លេគង្គា ប្រព្រឹត្តទៅដោយអានុភាពនៃព្រះរាជាណា ទឹកដោះជូរដែលស្ងប់ស្ងៀមទៅជាសមុទ្រ ដោយអានុភាពនៃព្រះរាជាណា ព្រះរាជានោះ គឺព្រះបាទអង្គៈ មានរោមត្រង់ព្រះបាទ បម្រើភ្លើង ក៏ទ្រង់បានទៅកាន់បុរីនៃព្រះឥន្ទ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាគរន្តំ** បានដល់ ផែនដី មានសាគរជាទីបំផុត ។ បទថា **ឧស្សេសិ** សេចក្ដីថា កាលលោកសួរដល់ផ្លូវទៅស្ថានសួគ៌នឹងពួកព្រាហ្មណ៍ កាលពួកព្រាហ្មណ៍ពោលថា ចូរលើកសសរមាសបូជាយញ្ញ ទើបឲ្យលើកសសរឡើង ដើម្បីចងសត្វចិញ្ចឹមសម្រាប់សម្លាប់ ។ បទថា **វេស្សានរមាទហានោ** សេចក្ដីថា ចាប់ផ្ដើមបូជាភ្លើងដល់ទេវតា ម្យ៉ាងទៀត បាលីថា **វេស្សានរី** ដូច្នេះក៏មាន ។ បទថា **ទេវញ្ញតរោ** កាលណាវិជ្ជៈពោលថា នៃសុភោគៈ ព្រះរាជាអង្គនោះ បូជាភ្លើងហើយ បានជាទេវតាមានសក្ដិធំមួយអង្គ ។ បទថា **យស្សានុភាវេន** សេចក្ដីថា នៃសុភោគៈ ស្ទឹងគង្គា និងមហាសមុទ្រ ដឹងទេ អ្នកណាសាង ។ សុភោគៈពោលថា យើងមិនដឹង ។ កាលណាវិជ្ជៈពោលថា បងមិនដឹងអ្វី ដឹងតែវាយព្រាហ្មណ៍ប៉ុណ្ណោះ ក្នុងអតីតកាល ព្រះបាទពារាណសី ព្រះនាមថាអង្គលោមបាទ ត្រាស់សួរផ្លូវទៅស្ថានសួគ៌នឹងពួកព្រាហ្មណ៍ កាលពួកព្រាហ្មណ៍

ក្រាបទូលថា សូមទ្រង់ចូលទៅកាន់ហិមវន្ត ធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងឡាយ ហើយបម្រើភ្លើង ទើបទ្រង់នាំមេគោទឹកដោះ និងព្រះមហេសី ប្រមាណមិនបាន ចូលទៅកាន់ហិមវន្ត បានធ្វើយ៉ាងនោះ ។ កាលព្រះរាជាត្រាស់សួរថា ទីរៈ និងទធិដ៏សេសអំពីពួកព្រាហ្មណ៍បរិភោគហើយ គប្បីធ្វើដូចម្ដេច ទើបពោលថា ចូរចាក់ចោលចុះ ។ ក្នុងទីដែលទឹកដោះបន្តិចបន្តួចដែលចាក់ចោលនោះ បានក្លាយជាស្ទឹងតូច ។ ក្នុងទីដែលទឹកដោះជាច្រើនត្រូវចាក់ចោល បានហូរទៅក្លាយជាស្ទឹងគង្គា ។ ចំណែកទឹកដោះនោះ ក្លាយជាទឹកដោះជូរ ហូរទៅដក់ក្នុងទីណា ទីនោះ ក៏ក្លាយជាសមុទ្រ ។ ព្រះបាទពារាណសី ទ្រង់ធ្វើសក្ការៈបែបនេះ យាងទៅកាន់បុរីសក្កទេវរាជ ដែលបម្រើភ្លើងតាមវិធីដែលព្រាហ្មណ៍ពោល ដោយប្រការដូច្នេះ ។

កាណារិដ្ឋៈ លុះនាំអតីតនិទាននេះ មកសបញ្ជាក់ដល់សុភោគៈដូច្នេះហើយ ទើបពោលគាថាដូច្នេះថា

បពិត្រសុភោគៈ ទេវតាដ៏ប្រសើរមានឫទ្ធិច្រើន មានយស ជាសេនាបតីនៃព្រះបាទវាសវៈ ក្នុងស្ថានត្រៃត្រិង្ស ព្រោះតែបានកម្ចាត់បង់នូវមន្ទិល ដោយសោមយាគវិធី ក៏បានជាទេវតាមួយអង្គ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោ សោមយាគេន មលំ វិហន្ត្វា** សេចក្ដីថា បពិត្រសុភោគៈដ៏ចម្រើន ឥឡូវនេះ បុគ្គលដែលជាសេនាបតីរបស់សក្កទេវរាជ មានយសច្រើន ជាទេវបុត្រ សូម្បីបុគ្គលនោះ ក្នុងកាលមុនជា

ស្ដេចពារាណសី សួរដល់ផ្លូវទៅកាន់ស្ថានសួគ៌ជាមួយពួកព្រាហ្មណ៍ កាលពួកព្រាហ្មណ៍ពោលថា សូមព្រះអង្គបណ្ដែតមន្ទិលរបស់ខ្លួនដោយសោម-យាគវិធី ហើយនឹងទៅកាន់ទេវលោក ទើបទ្រង់ធ្វើសក្ការៈធំដល់ព្រាហ្មណ៍ទាំងឡាយ ការធ្វើការបូជាសោមយាគៈ តាមវិធីដែលពួកព្រាហ្មណ៍ទាំងនោះពោលហើយ ទើបទ្រង់កម្ចាត់មន្ទិលដោយវិធីនោះ ហើយកើតជាទេវតាមួយអង្គ កាលប្រកាសសេចក្ដីនេះ ទើបពោលយ៉ាងនេះ ។

កាណារិដ្ឋៈកាលសម្ដែងឧទាហរណ៍ដទៃទៀតដល់សុភោគៈ ក៏ពោលថា

ទេវតាដ៏ប្រសើរ ព្រហ្មមានឫទ្ធិច្រើន មានយស បានសាង
លោកនេះ និងលោកដទៃ និងស្ទឹងភាគីរថីផង ភ្នំហិមពាន្តផង
ភ្នំវិជ្ឈៈផង ព្រហ្មនោះឯង ក៏បានបូជាភ្លើងក្នុងកាលនោះដែរ ។
ម្យ៉ាងទៀត ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំ
សុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ពួកព្រាហ្មណ៍
ពោលថា ភ្នំទាំងនេះក្ដី ភ្នំដទៃធំៗ ក្ដី ពួកព្រាហ្មណ៍អ្នកបូជា
យញ្ញ បានធ្វើឲ្យវិចិត្រហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោបិ តថា អាឧហិ ជាតវេធំ** លោកសម្ដែងថា បពិត្រសុភោគៈ មហាព្រហ្មណាបានសាងលោកនេះ និងលោកខាងមុខ ស្ទឹងភាគីរថី ស្ទឹងគង្គា ភ្នំហិមពាន្ត ភ្នំវិជ្ឈៈ និងភ្នំកាកវេរុ ក្នុងកាលណាមហាព្រហ្មនោះ បានជាមាណពមុនព្រហ្មឧប្បត្តិ ក្នុងកាលនោះ គេផ្ដើមបូជាភ្លើង កើតជាមហាព្រហ្ម បានសាងវត្ថុគ្រប់យ៉ាង ព្រាហ្មណ៍អ្នកមានឫទ្ធិក៏យ៉ាងនោះ ។ បទថា **ចិត្យា កតា** សេចក្ដីថា បានឮមកថា ក្នុងកាលមុន

ព្រះបាទក្រុងពារាណសីមួយអន្លើ ត្រាស់សួរផ្លូវទៅកាន់ស្ថានសួគ៌នឹងពួកព្រាហ្មណ៍ កាលពួកព្រាហ្មណ៍ទូលថា សូមទ្រង់ធ្វើសក្ការៈដល់ពួកព្រាហ្មណ៍ ទ្រង់បានថ្វាយមហាទានដល់ព្រាហ្មណ៍ទាំងនោះ ហើយត្រាស់សួរថា ក្នុងការឲ្យទានរបស់ខ្ញុំនេះ នៅខ្វះខាតអ្វីឬ កាលពួកព្រាហ្មណ៍ទូលថា មានទាំងអស់ តែអាសនៈមិនគ្រប់គ្រាន់ ដល់ពួកព្រាហ្មណ៍ ទើបត្រាស់ឲ្យកឥដ្ឋ សាងនូវអាសនៈទាំងឡាយ ។ ទីដេក និងតាំងដែលទ្រង់បានឲ្យសាងឡើងនោះចម្រើនដោយអានុភាពរបស់ពួកព្រាហ្មណ៍ ក្លាយជាភ្នំមាលាគិរីជាដើម ភ្នំទាំងនោះគេតែងហៅថា ពួកព្រាហ្មណ៍បូជាយញ្ញបានសាង ដោយប្រការដូច្នេះ ។

លំដាប់នោះ កាណារិដ្ឋៈក៏ពោលនឹងសុភោគៈនោះថា បពិត្រសុភោគៈ បងដឹងឬថា ព្រោះហេតុអ្វី សមុទ្រនេះមានទឹកប្រៃ ផឹកមិនកើត ។ សុភោគៈពោលថា អើ អរិដ្ឋៈ យើងមិនដឹងឡើយ ។ កាណារិដ្ឋៈក៏ពោលនឹងសុភោគៈថា បងដឹងតែបៀតបៀនពួកព្រាហ្មណ៍ប៉ុណ្ណោះ មិនដឹងអ្វីដទៃឡើយ ចាំស្តាប់ចុះ ហើយក៏ពោលគាថាដូច្នេះថា

> ជនទាំងឡាយ បានពោលចំពោះព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌
> ដោយគុណនៃមន្ត មានតបៈក្នុងលោកនេះ ថាជាអ្នកប្រកប
> ដោយការសូម សាគរបានពន្លិចព្រាហ្មណ៍នោះ ដែលស្ថិតនៅ
> លើត្រើយ កំពុងសាចទឹកសមុទ្រ ហេតុនោះ បានជាសមុទ្រ
> មានទឹកប្រៃ ផឹកមិនបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាចយោគីតិធាហុ** សេចក្តីថា ជនទាំង

ឡាយក្នុងលោកនេះ ហៅព្រាហ្មណ៍នោះថា **យាចយោគី** ( ជាអ្នកប្រកប ក្នុងការសូម ) ។ បទថា **ឧទកំ សជន្តំ** សេចក្ដីថា បានឮថា ថ្ងៃមួយ ព្រាហ្មណ៍ នោះធ្វើនូវកម្ម គឺការបណ្ដែតនូវបាប ឈរត្រង់មាត់ប្រាំង ដងទឹកអំពីសមុទ្រ ធ្វើនូវការលោបស្រឡាបខ្លួន ខណៈនោះ សាគរក៏ជន់លិចព្រាហ្មណ៍នោះ ដែល ធ្វើយ៉ាងនោះ មហាព្រហ្មទ្រង់បានដឹងហេតុនោះ ទើបក្រោធ គិតថា បានឮថា សមុទ្រនេះសម្លាប់កូនរបស់អញ ទើបផ្ដាសាថា នៃសមុទ្រ ចូរឯងមានទឹកប្រៃ គេផឹកមិនកើត ដោយហេតុនោះឯង ទើបគេផឹកមិនបាន ក្លាយជាទឹកប្រៃ ។ ឈ្មោះថា ព្រាហ្មណ៍ទាំងនេះ មានគុណច្រើនបែបនេះ ។ កាណារិដ្ឋៈពោល បន្តថា

ព្រាហ្មណ៍ទាំងឡាយ ជាវត្ថុសម្រាប់បូជា មានច្រើនលើផែនដី
មានក្នុងទិសខាងកើត ទិសខាងលិច ទិសខាងត្បូង និងទិស
ខាងជើង តែងញុំាងសេចក្ដីត្រេកអរឲ្យកើតដល់វាសវៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាសវស្ស** សេចក្ដីថា របស់ស្ដេចវាសវៈ គឺរបស់សក្កទេវរាជ ដែលជាអ្នកឲ្យទានដល់ពួកព្រាហ្មណ៍ក្នុងកាលមុនហើយ ទើបដល់នូវភាពជាស្ដេចវាសវៈ ។ បទថា **អាយាគវត្ថូនិ** សេចក្ដីថា ព្រាហ្មណ៍ជាច្រើនក្នុងបឋពី គឺផែនដី ដែលជាបុញ្ញក្ខេត្ត ដែលជាទក្ខិណេយ្យ-បុគ្គលដ៏ប្រសើរ មានក្នុងកាលមុន ។ បទថា **បុរិមំ ទិសំ** សេចក្ដីថា ឥឡូវ នេះ ព្រាហ្មណ៍ទាំងនោះ មានក្នុងទិសទាំង ៤ នេះ រមែងឲ្យកើតបីតិដ៏ច្រើន គឺនាំមកនូវបីតិ និងសោមនស្សដល់ស្ដេចវាសវៈនោះ ។

អរិដ្ឋៈពណ៌នាដល់ព្រាហ្មណ៍ យញ្ញ និងវេទ ១៤ គាថា ដោយប្រការដូច្នេះ ។

## ការពណ៌នាយញ្ញ ចប់

នាគជាច្រើន ដែលមកសួរសុខទុក្ខព្រះមហាសត្វ ស្តាប់ពាក្យកាណារិដ្ឋៈនោះហើយ ក៏កាន់យកខុសតាម ដោយគិតថា កាណារិដ្ឋៈពោលតែពាក្យពិតប៉ុណ្ណោះ ។ ព្រះមហាសត្វផ្ទំដោយការឈឺចាប់ បានស្តាប់ពាក្យទាំងអស់នោះហើយ ទាំងពួកនាគក៏មកប្រាប់ឲ្យទ្រង់ជ្រាបទៀត ។ លំដាប់នោះ មហាសត្វគិតថា អរិដ្ឋៈពណ៌នាផ្លូវខុស ណ្ហើយចុះ អញនឹងទម្លាយវាទៈរបស់កាណារិដ្ឋៈនោះ ហើយនឹងធ្វើបរិស័ទឲ្យជាសម្មាទិដ្ឋិ ក្រោកឡើង ងូតទឹក ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង អង្គុយលើធម្មាសនៈ ឲ្យនាគបរិស័ទទាំងអស់ប្រជុំគ្នា ឲ្យហៅកាណារិដ្ឋៈមក ហើយពោលថា នែអារិដ្ឋៈ ឯងពោលសរសើរវត្ថុដែលមិនពិត គឺវេទ យញ្ញ និងព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា ការបូជាយញ្ញដោយវេទនៃព្រាហ្មណ៍ទាំងឡាយ មិនឈ្មោះថា ជាវត្ថុប្រសើរឡើយ មិនមែនជាផ្លូវនៃស្ថានសួគ៌ យើងនឹងបង្អួលក្នុងភាពមិនពិតក្នុងវាទៈរបស់ឯង ដូច្នេះហើយ កាលផ្តើមនូវវាទៈ ដែលពោលអំពីប្រភេទនៃយញ្ញ ទើបពោលថា

ម្នាលអរិដ្ឋៈ ការរៀនយកនូវវេទទាំងឡាយ ជាទោសរបស់អ្នកប្រាជ្ញទាំងឡាយ តែជាអំពើរបស់បុគ្គលពាលទាំងឡាយ ( ត្រៃវេទ ) ជាធម៌ដូចថ្ងៃបណ្តើរកូន ព្រោះសម្លឹងមើលទៅ មិនស្មើវេទទាំងឡាយ ជាចំណែកនៃកលឧបាយ ទង់ទាញអ្នកមាន

បញ្ញាមិនបានទេ ការពារជនអ្នកទ្រុស្តមិត្ត បំផ្លាញសេចក្តីចម្រើននោះក៏មិនបានទេ ភ្លើងដែលបុគ្គលបម្រើហើយ រមែងមិនការពារនូវសត្វមានកម្មបានទេ ជារបស់មិនប្រសើរ ប្រកបដោយទោស ។ មួយទៀត សត្វទាំងឡាយមានទ្រព្យ មានភោគៈ យកទ្រព្យទាំងអស់លាយដោយឧស និងស្មៅ ហើយដុតភ្លើង មានតេជះ មិនមានអ្វីស្មើ កាលឆេះវត្ថុដែលគេដុតហើយ ក៏មិនគប្បីឆ្អែត ម្នាលអ្នកដឹងរសដោយអណ្តាតទាំងពីរ ចុះបុគ្គលណាគប្បីធ្វើភ្លើងនោះ ឲ្យឆ្អែតបាន ។ ទឹកៈ មានការប្រែប្រួលជាធម្មតា ក្លាយទៅជាទធិ ហើយទៅជានវនីត យ៉ាងណា ភ្លើងជាតេជោធាតុ មានការប្រែប្រួលជាធម្មតា យ៉ាងនោះដែរ លុះតែប្រកបដោយគ្រឿងពួត ទើបឆេះ ។ ភ្លើងដែលចូលទៅក្នុងឈើស្ងួត ឬឈើស្រស់ក៏មិនប្រាកដ ភ្លើងដែលនរជន មានឈើពំនួតក្នុងដៃមិនបានពួត ក៏មិនឆេះ ភ្លើងមិនមែនឆេះដោយការមិនធ្វើទេ ។ ប្រសិនបើភ្លើង នៅក្នុងឈើស្ងួត ឬឈើស្រស់នៅខាងក្នុង នៅក្នុងព្រៃទាំងអស់ ក្នុងលោក គប្បីស្ងួតក្រៀម ឯឈើស្ងួតទាំងឡាយ គប្បីឆេះ ។ ថាបើនរជនញ៉ាំងភ្លើងដ៏ក្តៅ ប្រកបដោយផ្សែង និងអណ្តាតឲ្យស៊ីដោយឧស និងស្មៅ ឈ្មោះថា ធ្វើបុណ្យឬ ជនអ្នកធ្វើធ្យូង អ្នកធ្វើអំបិល អ្នកធ្វើអាហារ និងអ្នកដុតសរីរៈនៃបុគ្គល

ស្លាប់ ឈ្មោះថា ធ្វើបុណ្យដែរឬ ។ ប្រសិនបើព្រាហ្មណ៍ទាំងនុ៎ះ ញុំាងការរៀនមន្ត និងភ្លើង ឲ្យឆ្អែតក្នុងលោកនេះ ទើបឈ្មោះថា ធ្វើបុណ្យ នរជនណាមួយក្នុងលោក កាលញុំាងភ្លើងមានកម្ដៅ ប្រកបដោយផ្សែង និងអណ្ដាត ឲ្យស៊ី មិនឈ្មោះថា ធ្វើបុណ្យទេ ។ ម្នាលអ្នកដ៏ងរសេដោយអណ្ដាតពីរ ( អគ្គិទេពរបស់អ្នក ) ដែលលោកគោរពហើយ ម្ដេចក៏ស៊ីវត្ថុមានក្លិនមិនជាទីគាប់ចិត្ត មិនជាទីត្រេកអរនៃជនដ៏ច្រើន ដែលពួកមនុស្សតែងវៀរ ជាវត្ថុមិនប្រសើរនោះ ។ ពួកមនុស្សខ្លះពោលថា ភ្លើង ( ជាទេវតាមួយអង្គ ) ក្នុងពួកទេវតា ឯពួកមិលក្ខុជន ពោលថា ទឹកជាទេវតា ជនទាំងអស់នុ៎ះពោលខុស ភ្លើងមិនមែនជាទេវតាណាមួយទេ ទឹកក៏មិនមែនដែរ ។ ភ្លើងមិនមានឥន្ទ្រិយ ជាពួកមិនមានចេតនា សម្រាប់ធ្វើការងាររបស់ពួកមនុស្ស អ្នកធ្វើបាបកម្មទាំងឡាយ កាលបម្រើភ្លើងគប្បីទៅកាន់សុគតិដូចម្ដេចកើត ។ ពួកព្រាហ្មណ៍ ជាអ្នកត្រូវការដោយជីវិត ក្នុងលោកនេះ ពោលថា ( មហាព្រហ្ម ) ជាអ្នកគ្របសង្កត់លោកទាំងអស់ ហើយពោលថា ព្រហ្មជាអ្នកបម្រើភ្លើង ដូច្នេះ បើ ( មហាព្រហ្ម ) មានអានុភាពជាងលោកទាំងអស់ មានអំណាចមិនមានអ្នកណាស្មាន ហេតុអ្វីក៏សំពះភ្លើងដែលខ្លួននិម្មិតវិញ ។ ពាក្យព្រាហ្មណ៍ ជាពាក្យគួរ

សើច មិនគួរដល់ការពិនិត្យ ជាពាក្យមិនពិត ពួកព្រាហ្មណ៍ក្នុងកាលមុន តាក់តែង ( ពាក្យមិនពិត ) ព្រោះហេតុនៃសក្ការៈ ព្រាហ្មណ៍ទាំងនោះ កាលបើលាភសក្ការៈមិនកើតឡើងទេ ក៏តនូវសន្និធមិ ពោល គឺលទ្ធិរបស់ខ្លួន ជាមួយនឹងពួកសត្វ ។ ពួកអ្នកប្រសើរ ( ព្រាហ្មណ៍ ) ប្រកាន់ការរៀនមន្ត ពួកជាធំជាងជន ( ក្សត្រិយ៍ ) ប្រកាន់ផែនដី ពួកវេស្សៈប្រកាន់ការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ការបម្រើផ្សេងៗ គ្នាសមគួរតាមប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែងហើយ ។ ប្រសិនបើពាក្យនុ៎ះ ជាពាក្យពិត ដូចយ៉ាងពាក្យដែលព្រាហ្មណ៍ទាំងឡាយពោលហើយនេះ បុគ្គលមិនមែនជាក្សត្រ មិនត្រូវបានរាជ្យដោយដាច់ខាត បុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីសិក្សានូវបទនៃមន្ត បុគ្គលវៀរចាកពួកវេស្សៈ មិនគប្បីធ្វើការភ្ជួររាស់ ពួកសូទ្រៈមិនគប្បីរួចអំពីការប្រើនៃជនដទៃ ។ ពាក្យនេះ ជាពាក្យមិនពិត ព្រោះហេតុណា ( ហេតុនោះ ) ព្រាហ្មណ៍ទាំងនេះ ពោលពាក្យកុហក ដើម្បីការបំពេញផ្ទៃ បុគ្គលអ្នកមិនមានប្រាជ្ញាទាំងឡាយ រមែងជឿស៊ប់នូវពាក្យនោះ ចំណែកខាងពួកបណ្ឌិត រមែងឃើញហេតុនោះ ដោយខ្លួនឯង ។ ពួកក្សត្រិយ៍ នាំយកពលី ( ហូតពន្ធ ) របស់ពួកវេស្សៈ ពួកព្រាហ្មណ៍ កាន់យកគ្រឿងសស្ត្រាទាំងឡាយ ហើយដើរទៅ ( សម្លាប់សត្វ )

ហេតុអ្វី ព្រហ្មមិនធ្វើលោក ដែលជ្រួលជ្រើម បែកខ្ញែកបែប នោះ ឲ្យត្រង់ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះជាប្រធាន ជាម្ចាស់លើកួត របស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វីក៏ចាត់ចែងលោកទាំងអស់ ឲ្យមានទុក្ខ ហេតុអ្វីមិនធ្វើលោកទាំងអស់ ឲ្យបានសេចក្ដីសុខ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើកួតរបស់ពួកសត្វ ក្នុងលោកទាំងអស់ ហេតុអ្វី ក៏ធ្វើលោកឲ្យវិនាស ដោយកលឧបាយ និងការញ៉ាំញី ដោយការពោលពាក្យកុហក ដែលមិនមែនជាធម៌ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើកួតរបស់ពួកសត្វក្នុងលោកទាំងអស់ ម្នាលអរិដ្ឋៈ ព្រហ្មជាម្ចាស់លើកួត មិនប្រកបដោយធម៌ទេ ព្រោះកាលបើធម៌មាន បែរជាចាត់ចែងអធម៌វិញ ។ បុគ្គលសម្លាប់កណ្ដូប កន្ទុំរុយ ពស់ កង្កែប ដង្កូវរុយ ទើបឈ្មោះថា បរិសុទ្ធ ឯធម៌ទាំងនេះ ជាធម៌របស់ពួកជនអ្នកនៅក្នុងដែនកម្ពុជៈដ៏ច្រើន ជាធម៌មានសភាពមិនប្រសើរ ជាធម៌មិនពិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វេឧជ្ឈគតារិដ្ឋ** សេចក្ដីថា នែអរិដ្ឋៈ ឈ្មោះថា ការសម្រេចត្រៃវេទក្នុងឥឡូវនេះ ជាការកាន់យកឧបទ្រព ឈ្មោះថា ការបរាជ័យរបស់អ្នកប្រាជ្ញ តែបែរជាការមានជ័យជម្នះរបស់បុគ្គលល្ងង់ខ្លៅ អប្បប្រាជ្ញា ។ បទថា **មរីចិធម្មំ** សេចក្ដីថា ពិតហើយ ត្រៃវេទនេះ

ជាអាការធម្មតារបស់ថ្ងៃបណ្តើរកូន បុគ្គលពាលទាំងឡាយ មិនដឹងនូវធម្មតារបស់ថ្ងៃបណ្តើរកូននេះ ដែលមិនមានពិតប្រាកដ ព្រោះជារបស់មិនស្មើ ទើបនាំខ្លួនចូលដល់សេចក្តីវិនាស ព្រោះសម្គាល់ថា មានពិត និងមិនមានទោស តែហាក់ដូចជាមាន ព្រោះការឃើញមិនជាប់តគ្នា ដូចពួកម្រឹគមើលឃើញថ្ងៃបណ្តើរកូន ដោយសម្គាល់ថាជាទឹក ។ បទថា **ឆាតិវហាត្តិ បញ្ញំ** សេចក្តីថា ឯមាយាបែបនេះ ជាចំណែកមួយ រមែងនាំយកទៅមិនបាន គឺបោកបញ្ឆោតបុរសអ្នកមានបញ្ញា បរិបូណ៌ដោយបញ្ញាមិនបាន ។ **រ** អក្ខរៈ ក្នុងបទថា **ភវត្តិរស្ស** នេះ ជាព្យញ្ជនៈសន្ធិ ។ បទថា **ភូតហុនោ** សេចក្តីថា វេទទាំងឡាយរបស់បុគ្គលទ្រុស្តមិត្រ ជាអ្នកសម្លាប់សេចក្តីចម្រើន រមែងមិនមានទីពឹង អធិប្បាយថា មិនអាចជាទីពឹងបាន ។ បទថា **បរិចិណ្ណោវ អគ្គិ** សេចក្តីថា ម្យ៉ាងទៀត ភ្លើងដែលគេបម្រើបូជា ។ បទថា **នោសន្តរំ** សេចក្តីថា ភ្លើង រមែងមិនជាទីពឹង គឺមិនរក្សាបុរសដែលមានចិត្តប្រកបដោយទោស ជាអ្នកមានកម្មដ៏លាមក ព្រោះទោសនៃទុច្ចរិតទាំង ៣ បានឡើយ ។ បទថា **សព្វញ្ចេ មច្ចា** សេចក្តីថា មនុស្សទាំងឡាយ ដែលជាអ្នកមានទ្រព្យ មានភោគៈ នឹងយកឈើដែលមាននៅក្នុងលោកទាំងអស់ ព្រមទាំងទ្រព្យសម្បត្តិរបស់ខ្លួន លាយជាមួយស្មៅ ហើយយកភ្លើងដុត ភ្លើងរបស់ជនទាំងនេះ ដែលមានតេជះ មិនមានគេប្រៀប មានតេជះមិនមានគេស្មើ កាលដុតវត្ថុទាំងអស់នោះ ដែលជនទាំងនោះឲ្យដុតហើយ ក៏មិនគប្បីឆ្អែតបាន កាលបើដូច្នោះ ភ្លើងក៏ដុតឲ្យឆ្អែតមិនបានឡើយ ។ បទថា **ធិរសញ្ញា**

សេចក្តីថា បុគ្គលដែលអាចដឹងសេចបានដោយអណ្តាតពីរ អ្នកណាគប្បីធ្វើភ្លើងនោះឲ្យឆ្អែតស្កប់ស្កល់ ដោយសប្បិជាដើមបាន គឺអ្នកណាអាចធ្វើបានឈ្មោះថា បុគ្គលណា ឲ្យភ្លើងដែលមិនឆ្អែតយ៉ាងនេះ ដែលស៊ីច្រើនយ៉ាងនេះឲ្យឆ្អែត ហើយទៅកាន់ស្ថានសួគ៌ មើលចុះ សេចក្តីនោះ អ្នកពោលខុសសព្វកាល ។ បទថា **យោគយុត្តោ** សេចក្តីថា ជាអ្នកប្រកបដោយឈើកួតភ្លើងលុះបានវត្ថុនោះជាបច្ច័យ ក៏កើតឡើង គឺឧប្បត្តិឡើង ។ លោកពោលនឹងភ្លើងនោះ ដែលមិនមានចិត្តកើតឡើង ព្រោះសេចក្តីព្យាយាមរបស់អ្នកដទៃយ៉ាងនេះ ថាជាទេវតា ។ អ្នកពោលតែវត្ថុដែលមិនពិតនេះប៉ុណ្ណោះ ។ បទថា **អគ្គិមនុប្បវិដ្ឋោ** សេចក្តីថា មិនធ្លាប់បានឃើញភ្លើងចូលទៅក្នុងឈើស្ងួត ។ បទថា **ឆាមត្តមាណោ** សេចក្តីថា ទោះបីឈើស្ងួត តែអ្នកកួតមិនកួត ភ្លើងក៏មិនកើតឡើង ។ បទថា **ឆាកម្មុនា ជាយតិ ជាតវេទោ** សេចក្តីថា បើបុរសដែលត្រូវការភ្លើង មិនបង្កាត់ភ្លើង ភ្លើងក៏កើតឡើងឯងមិនបាន ។ បទថា **សុស្សេយ្យុំ** សេចក្តីថា ព្រៃឈើដែលកំពុងក្រៀមស្ងួតដោយភ្លើងខាងក្នុង គប្បីស្ងួត សូម្បីព្រៃឈើដែលនៅស្រស់នោះឯង ក៏គប្បីស្ងួត ។ បទថា **ភោជំ** បានដល់ ឲ្យបរិភោគ ។ បទថា **ធូមសិខី បតាបវា** សេចក្តីថា ប្រកបដោយផ្សែង និងអណ្តាតភ្លើង ។ បទថា **អង្គារិកា** បានដល់ អ្នកដុតធ្យូង ។ បទថា **លោណករា** បានដល់ អ្នកម្ចាស់ទឹកប្រៃធ្វើអំបិល ។ បទថា **សូទា** បានដល់ អ្នកដាំស្ល ។ បទថា **សរីរទាហា** បានដល់ អ្នកដុតខ្មោច ។ បទថា **បុញ្ញំ** សេចក្តីថា អ្នកទាំងអស់នោះ សុទ្ធតែប្រកបដោយ

បុណ្យប៉ុណ្ណោះ ។ បទថា **អជ្ឈេនមគ្គី** សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយ ទោះជាអ្នកបម្រើភ្លើង ឬរៀនមន្ដក៏ដោយ ។ បុគ្គលខ្លះឲ្យភ្លើងមានផ្សែង មានអណ្ដាតស៊ីរហូតស្ងប់ស្ងាត់ ក៏មិនឈ្មោះថា ធ្វើបុណ្យ ។ បទថា **លោកា-បចិតោ សមានោ** សេចក្ដីថា ទេវតារបស់អ្នក ឈ្មោះថា សត្វលោកគោរពក្រែង សត្វលោកគួរបូជា ។ បទថា **យទេវ** សេចក្ដីថា មនុស្សគប្បីវៀរវត្ថុដែលបដិកូលគួរខ្ពើម មានសាកសពសត្វជាដើម ចៀសចេញឆ្ងាយ ។ បទថា **តទប្បសដ្ឋំ** សេចក្ដីថា ភ្លើងនោះជារបស់មិនប្រសើរ នៃសម្មាញ់អ្នកដឹងរសដោយអណ្ដាត ២ គប្បីបរិភោគបានដូចម្ដេច គឺព្រោះហេតុអ្វី ។ បទថា **ទេវេសុ** សេចក្ដីថា បុគ្គលពួកខ្លះរាប់អានភ្លើង ទេវតាអង្គណាមួយ បណ្ដាទេវតាទាំងឡាយ ។ បទថា **មិលក្ខុ បន** សេចក្ដីថា ចំណែកពួកមិលក្ខុៈដែលមិនដឹង រាប់អានទឹក ថាជាទេវតា ។ បទថា **អសញ្ញកាយំ** សេចក្ដីថា សត្វលោក បម្រើភ្លើង ដែលបានឈ្មោះថា **វេស្សានរ** ដែលមិនមានឥន្ទ្រិយ មានកាយមិនមានចិត្តដឹងបាន មិនមានចេតនា ធ្វើកិច្ច មានការចម្អិនជាដើមដល់មហាជនហើយ ធ្វើកម្មអាក្រក់ នឹងទៅកាន់សុគតិបានដូចម្ដេច ។ ពាក្យនេះ លោកពោលខុសក្រៃលែង ។

បទថា **សព្វាភិភូតាហុធ ជីវិកត្ថា** សេចក្ដីថា ពួកព្រាហ្មណ៍ទាំងនេះពោលថា មហាព្រហ្មគ្របសង្កត់បានទាំងអស់ ដើម្បីការរស់នៅរបស់ខ្លួន ។ និងពោលថា លោកទាំងអស់ មហាព្រហ្មនោះឯងសាងឡើង ។ ពោលទៀតថា ព្រះព្រហ្មបម្រើភ្លើង ។ បានឮថា ព្រហ្មនោះឯង បូជាភ្លើង ។ បទថា

**សច្ចានុភាវី ច វសី** សេចក្តីថា ព្រហ្មនោះ បើមានអានុភាពគ្រប់យ៉ាង និង មានការស្ទាត់ក្នុងឫទ្ធិសោត កាលបើដូច្នេះ ព្រោះហេតុអ្វី ខ្លួនឯងមិនប្រើឲ្យ អ្នកដទៃសាង ខ្លួនឯងប៉ុណ្ណោះសាងឡើង ។ បទថា **វញ្ចិតស្ស** សេចក្តីថា ព្រហ្មនោះ គប្បីជាបុគ្គលដែលគេថ្វាយបង្គំ សូម្បីពាក្យនេះ អ្នកពោលមិន ត្រូវដូចគ្នា ។ បទថា **ហាសំ** សេចក្តីថា នៃអវិជ្ជៈ ឈ្មោះថា ពាក្យរបស់ ព្រាហ្មណ៍ ជាពាក្យដែលគួរសើច មិនគួរសម្លឹងមើលសម្រាប់បណ្ឌិតទាំង ឡាយ ។ បទថា **បរិការីសុ** សេចក្តីថា ព្រាហ្មណ៍ទាំងនេះ សាងរឿង មុសាវាទបែបនេះឡើងក្នុងកាលមុន ព្រោះហេតុនៃសក្ការៈដើម្បីខ្លួន ។ បទថា **សន្ធាភិតា ជន្តុភិ សន្តិធម្មំ** សេចក្តីថា ព្រាហ្មណ៍ទាំងនោះ កាលលាភ និងសក្ការៈមានប្រមាណប៉ុណ្ណោះ មិនទាន់ប្រាកដ ទើបចងសន្តិធម៌ គឺលទ្ធិធម៌ របស់ខ្លួន ដែលទាក់ទងដោយការសម្លាប់សត្វ ទើបចងក្រងយញ្ញពិធី ឈ្មោះ ថា យញ្ញសូត្រ ។ បទថា **ឯតញ្ច សច្ចំ** សេចក្តីថា បើពាក្យដែលអ្នក ពោលជាដើមថា ពួកអ្នកប្រសើរ ( ព្រាហ្មណ៍ ) ប្រកាន់ខាងការរៀនមន្ត គប្បីជាសេចក្តីពិតសោត ។ បទថា **ឆាខត្តិយោ** សេចក្តីថា កាលបើដូច្នោះ អ្នកដែលមិនមែនក្សត្រ នឹងគ្រប់គ្រងរដ្ឋមិនបាន អ្នកដែលមិនមែនព្រាហ្មណ៍ ក៏សិក្សាមន្តមិនបាន ។ បទថា **មុសាវិមេ** កាត់បទជា **មុសាវ ឥមេ**។ បទ ថា **ឱទរិយា** សេចក្តីថា ពួកអ្នករកបំពេញផ្ទៃ គឺព្រោះហេតុឲ្យពេញផ្ទៃ ។ បទថា **តទប្បបញ្ញា** សេចក្តីថា បុគ្គលមានបញ្ញាតិចជឿពាក្យរបស់ជនទាំង នោះ ។ បទថា **អត្តនាវ** សេចក្តីថា ចំណែកបណ្ឌិតទាំងឡាយ តែងឃើញ

ដោយខ្លួនឯងថា ពាក្យរបស់ជននោះ ជាពាក្យមានទោស ទើបមិនជឿ ។ បទថា **តំ តាទិសំ** បានដល់ ពាក្យនោះ គឺបែបនោះ ។ បទថា **សង្គុភិតំ** សេចក្តីថា ព្រោះហេតុអ្វី ព្រហ្មរបស់អ្នកឯងនោះ មិនធ្វើលោកដែលកម្រើកផ្សេងគ្នាដែលកម្រើកហើយ ទម្លាយច្បាប់ដែលព្រហ្មតាំងទុកហើយឲ្យត្រង់ ។ បទថា **អលក្ខិ** សេចក្តីថា ព្រោះហេតុអ្វី ទើបព្រហ្មរបស់អ្នកសាងលោកទាំងពួងឲ្យជាទុក្ខ ។ បទថា **សុខី** សេចក្តីថា ព្រោះហេតុអ្វី ព្រហ្មរបស់ពួកអ្នក មិនសាងលោកទាំងពួង ឲ្យទទួលសេចក្តីសុខតែម្យ៉ាង ព្រះព្រហ្មរបស់អ្នក ប្រហែលជាចោរ ធ្វើលោកឲ្យវិនាស ។

បទថា **មាយា** បានដល់ ដោយមាយា ។ បទថា **អធម្មេន កិមត្ថការី** សេចក្តីថា ព្រោះហេតុអ្វី ទើបព្រហ្មរបស់អ្នកធ្វើលោកទាំងពួងឲ្យវិនាស គឺប្រកបក្នុងផ្លូវឥតប្រយោជន៍ ដោយអធម៌ មានមាយាជាដើមនេះ ។ បទថា **អរិដ្ឋ** សេចក្តីថា នៃអរិដ្ឋៈ ព្រះរបស់អ្នក មិនប្រកបដោយធម៌កាលកុសលធម៌ ១០ ប្រការ មានមិនចាត់ចែងធម៌ឡើយ ចាត់ចែងតែអធម៌ ។ ក្នុងបទថា **កីដា** ជាដើម ជាបឋមាវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ អ្នកសម្លាប់កណ្តូបជាដើមនោះ រមែងបរិសុទ្ធ រមែងទៅកាន់ស្ថានសួគ៌ ឯធម៌ទាំងនោះ ក៏ជារបស់ជនច្រើនគ្នា មិនមែនរបស់ព្រះអរិយៈ មានអ្នកដែនកម្ពុជៈជាដើម តែធម៌ទាំងនោះមិនពិត មិនជាធម៌ ពោលថា ជាធម៌ ធម៌ទាំងនោះជារបស់ដែលពួកព្រហ្មរបស់អ្នកសាងឡើង ។

ឥឡូវនេះ ព្រះភូរិទត្ត កាលសម្តែងធម៌ដែលមិនពិតនៃធម៌ទាំងនោះ ក៏

បានគាថានេះថា

ប្រសិនបើអ្នកសម្លាប់នោះ បរិសុទ្ធ ឬអ្នកដែលត្រូវសម្លាប់នោះ ទៅកាន់ស្ថានសួគ៌បាន ពួកព្រាហ្មណ៍ គប្បីសម្លាប់ពួកព្រាហ្មណ៍ ឬសម្លាប់ពួកជន អ្នកជឿពាក្យព្រាហ្មណ៍នោះ ( មុន ) ។ មិនមាន ពួកម្រឹគ មិនមានពួកសត្វចិញ្ចឹម ពួកគោណាមួយ អង្វរឲ្យសម្លាប់ ខ្លួនទេ សត្វទាំងឡាយ ក្នុងលោកនេះ សុទ្ធតែញាប់ញ័រ ត្រូវការ ដោយជីវិត ( ព្រោះថា ) ជនទាំងឡាយ ប្រារព្ធនឹងសម្លាប់សត្វ ទាំងឡាយ និងសត្វចិញ្ចឹមក្នុងយញ្ញទាំងឡាយ ។ ពួកបុគ្គល ពាល រមែងបើកមាត់និយាយ ដោយហេតុទាំងឡាយដ៏វិចិត្ត ក្នុង ការលើកឡើងនូវសសរយញ្ញ និងទីចងនៃសត្វចិញ្ចឹមថា សសរ យញ្ញនេះ បង្ហូរសេចក្តីប្រាថ្នាដល់អ្នក ក្នុងបរលោក នឹងឲ្យសេចក្តី ទៀងទាត់ក្នុងបរលោក ។ ប្រសិនបើ បុគ្គលគប្បីបានកែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ និងមាស ក្នុងសសរ យញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ ម្យ៉ាងទៀត ប្រសិនបើ សសរយញ្ញ គប្បីបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ ពួក ជនអ្នកចេះត្រៃវេទដ៏ច្រើន គប្បីបូជាបុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីបូជាតិចតួចទេ ។ កែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ មាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ នឹង មានពីណា សសរយញ្ញនឹងបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុង

ស្ថានសួគ៌ដូចម្ដេចកើត ។ ពួកព្រាហ្មណ៍ ជាអ្នកបោកប្រាស ចិត្តអាក្រក់ ជាពួកពាល ប្រលោមលោក តែងបើកមាត់និយាយដោយហេតុដ៏វិចិត្រថា អ្នកឯងចូរយកភ្លើងចុះ ហើយឲ្យទ្រព្យដល់យើង លំដាប់នោះ អ្នកឯងនឹងបាននូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង ហើយនឹងដល់នូវសេចក្ដីសុខ ។ ពួកព្រាហ្មណ៍ នាំបុគ្គលជាសរណៈ ( ព្រះរាជា និងមហាមាត្យ ) ចូលទៅកាន់រោងសម្រាប់បូជាភ្លើងនោះ ក៏បើកមាត់និយាយ ដោយហេតុដ៏វិចិត្រ ឲ្យកោរសក់ ពុកមាត់ កាត់ក្រចក ហើយគាបយកទ្រព្យដោយវេទទាំងឡាយ ។ ពួកព្រាហ្មណ៍ ជាអ្នកកុហកដ៏ច្រើន បានទាយកម្នាក់ហើយ ក៏ចោមស៊ីបាយ ដូចជាក្អែកទាំងឡាយ ចោមចាប់មៀមក្នុងទីស្ងាត់ កុហកធ្វើឲ្យលើងហើយ ដាក់ចុះទៅក្នុងផ្លូវនៃយញ្ញ ។ ទាយកតែម្នាក់នោះ ត្រូវពួកព្រាហ្មណ៍បញ្ឆោតហើយ ដោយអាការយ៉ាងនេះឯង ព្រាហ្មណ៍ទាំងនោះជាច្រើន ចោមប្លន់ដោយការប្រកបដោយឧបាយ ក៏នាំយកទ្រព្យដែលឃើញដោយទេវលោក ដែលមិនឃើញសោះ ។ ដូចយ៉ាងពួករាជបុរស ដែលព្រះរាជាប្រើទៅហើយ ក៏នាំយកទ្រព្យនោះរបស់គេ ម្នាលអរិដ្ឋៈ ពួកព្រាហ្មណ៍ប្រាកដដូច្នោះ ប្រហែលគ្នានឹងពួកចោរ ជាអសប្បុរស ជាបុគ្គលគួរសម្លាប់ តែគេមិនសម្លាប់ក្នុងលោក ។ ពួកព្រាហ្មណ៍បានកាត់ដើមចារ មកប្រើក្នុងវិធីយញ្ញ ( ប្រាប់ថា នេះ ) ជាដៃស្ដាំរបស់

ព្រះឥន្ទ្រ បើពាក្យនោះពិត ព្រះឥន្ទ្រទៅជាដាច់ដៃ ចុះព្រះឥន្ទ្រ ឈ្នះពួកអសុរ ដោយកម្លាំងដៃដូចម្តេច ។ ពាក្យនោះ ទទេសោះ ព្រះឥន្ទ្រនៅមានដើមដៃគ្រប់គ្រាន់ ជាទេវតាដ៏ប្រសើរ មិនមានអ្នកណាសម្លាប់បាន បានកម្ចាត់ពួកអសុរ មន្តទាំងឡាយនេះ របស់ពួកព្រាហ្មណ៍ មានសភាពជារបស់ទទេ នេះជាការបញ្ឆោត ដែលគេឃើញច្បាស់ក្នុងលោក ។ ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ភ្នំទាំងនុ៎ះក្តី ភ្នំធំៗឯទៀតក្តី ព្រាហ្មណ៍ទាំងឡាយពោលថា ពួកព្រាហ្មណ៍អ្នកបូជាយញ្ញកសាងហើយដ៏វិចិត្រ ដូច្នោះ ។ ព្រាហ្មណ៍ទាំងឡាយពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ កាន់យកឥដ្ឋទាំងឡាយ មានបការយ៉ាងណា ធ្វើវិចិត្រហើយ ភ្នំទាំងឡាយ មិនមែនមានបការដូច្នោះទេ ឯភ្នំទាំងឡាយ មិនដូចរបស់ដទៃទេ ជារបស់មិនកម្រើក ជាថ្មសុទ្ធដែលគេឃើញច្បាស់ ។ ភ្នំទាំងឡាយ មិនមែនជាឥដ្ឋទេ ជាថ្មយូរយារហើយ ដែកមិនមែនកើតក្នុងឥដ្ឋនោះទេ លោហៈក៏មិនមែនកើតក្នុងឥដ្ឋនោះដែរ ពួកព្រាហ្មណ៍ កាលសរសើរនូវយញ្ញនេះ បានពោលថា ភ្នំទាំងឡាយដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ ធ្វើវិចិត្រហើយ ។ ព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ បានពោលនូវព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈ ថាជាអ្នកប្រកបដោយការសូម សាគរពន្ទិចព្រាហ្មណ៍នោះ

ដែលកំពុងសាចទឹក នៃសមុទ្រលើប្រាំង ព្រោះហេតុនោះ បាន ជាទឹកសមុទ្រនោះ ប្រៃផឹកមិនបាន ។ ស៊ីងទាំងឡាយ កួចយក ពួកព្រាហ្មណ៍ អ្នកបរិបូណ៌ដោយវេទ បរិបូណ៌ដោយមន្ត ច្រើនជាង ពាន់នាក់ ទឹកទាំងឡាយ មិនខូចរសព្រោះហេតុនោះទេ សមុទ្រមិន មានអ្វីស្មើ មានរសប្រៃផឹកមិនបាន តើព្រោះហេតុអ្វី ។ អណ្ដូងខ្លះ ក្នុងជីវលោកនេះ មានទឹកប្រៃ ដែលពួកជនអ្នកផឹកអណ្ដូង បានផឹក ហើយ ម្នាលអ្នកដឹងរសដោយអណ្ដាតទាំងពីរ ជនទាំងឡាយមិន ពោលថា ទឹកក្នុងអណ្ដូងទាំងនេះ មានរសប្រៃផឹកមិនបាន ព្រោះ តែកួចយកព្រាហ្មណ៍ទេ ។ តាំងពីមុនដំបូងមក ស្រ្តីណា ជាកិរិយា របស់បុរសណា មនោបានញ៉ាំងមនុស្ស ឲ្យកើតឡើងក្នុងកាលមុន មិនមានអ្នកណាមួយ ថោកទាបជាងគ្នាដោយធម៌នោះ ព្រាហ្មណ៍ ទាំងឡាយ បានពោលនូវការចែក ( វណ្ណៈ ) ដោយការលះបង់ ( ធម៌នោះ ) យ៉ាងនេះឯង ។ សូម្បីកូនចណ្ឌាល ជាអ្នកឈ្លាស វៃ មានប្រាជ្ញា បានរៀនវេទទាំងឡាយ ពោលមន្តទាំងឡាយ ក្បាលនៃកូនជនចណ្ឌាលនោះ មិនបែកជា ៧ ភាគទេ មន្តទាំងនេះ ពួកព្រាហ្មណ៍ធ្វើហើយ ដើម្បីសម្លាប់ខ្លួន ។ វាចាកុហក ពួក ព្រាហ្មណ៍បានតាក់តែងហើយ ការចង់បាន ពួកព្រាហ្មណ៍បានតាក់តែង កាន់យកហើយការកើតឡើងតាមគន្លងនៃកាព្យឃ្លោងដែលគេស្រោយ បានដោយក្រ ចិត្តរបស់បុគ្គលពាលទាំងឡាយ ជឿស៊ប់ក្នុងអំពើ

មិនស្មើ បុគ្គលឥតប្រាជ្ញា រមែងជឿពាក្យនោះ ។ ព្រាហ្មណ៍មិន ( ប្រកប ) ដោយកម្លាំងដ៏មាំ ដូចកម្លាំងនៃរាជសីហ៍ ខ្លាធំ និងខ្លាដំបង មនុស្សភាព ( របស់ព្រាហ្មណ៍ទាំងនោះ ) ត្រូវយល់ថាដូចគោដែរ ព្រោះជាតិរបស់ព្រាហ្មណ៍ទាំងនោះ ស្មើ ( ដោយគោ ) ស្មើដោយសីហៈជាដើម ។ ប្រសិនបើព្រះរាជាឈ្នះផែនដី ប្រកបដោយអាមាត្យ មានអ្នកស្តាប់បង្គាប់ មានបរិស័ទ ព្រះរាជានោះគប្បីឈ្នះពួកសត្រូវ ដោយព្រះអង្គឯង ប្រជាជនរបស់ព្រះរាជានោះគប្បីបានសេចក្តីសុខជានិច្ច ។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ ( តែក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី ) មិនបានវិនិច្ឆ័យនូវអត្ថនៃមន្ត និងវេទទាំងនោះទេ ទាំងមិនដឹង ដូចបុគ្គលកាលមិនដឹងផ្លូវ ដែលកំបាំងដោយទឹក ។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ លាភ ឥតលាភ យស និងឥតយស ទាំងអស់នេះ ជាធម៌របស់វណ្ណៈទាំង ៤ នោះ ។ ពួកគហបតីជាច្រើន លើផែនដី ញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ព្រោះហេតុតែទ្រព្យ និងស្រូវយ៉ាងណា សូម្បី ពួកអ្នកមានត្រៃវេទជាច្រើនលើផែនដី ក៏ញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ក្នុងថ្ងៃនេះយ៉ាងនោះដែរ ។ ព្រាហ្មណ៍ទាំងនោះ ស្មើគ្នានឹងគហបតី ព្រាហ្មណ៍ទាំងឡាយជាច្រើន លើផែនដី ជាអ្នកខ្វល់ខ្វាយជានិច្ច ប្រកបក្នុងកាមគុណទាំងឡាយ តែងញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ម្នាល

អរិដ្ឋៈ អ្នកជីងរសេដោយអណ្តាតទាំងពីរ ព្រោះហេតុនោះ ព្រាហ្មណ៍ទាំងនោះ ជាអ្នកឥតបញ្ញា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភោវាទិ** បានដល់ ពួកព្រាហ្មណ៍ ។ បទថា **ភោវាទិនមារយេយ្យុំ** សេចក្តីថា គប្បីសម្លាប់តែពួកព្រាហ្មណ៍ប៉ុណ្ណោះ ។ បទថា **យេ វាបិ** សេចក្តីថា ឬសម្លាប់ជនពួកណាដែលជឿនូវពាក្យរបស់ព្រាហ្មណ៍ ពួកព្រាហ្មណ៍គប្បីសម្លាប់ពួកឧបដ្ឋាករបស់ខ្លួនប៉ុណ្ណោះ ឯព្រាហ្មណ៍មិនសម្លាប់ព្រាហ្មណ៍ និងពួកឧបដ្ឋាក សម្លាប់តែសត្វតិរច្ឆាន មានប្រការផ្សេងៗ ប៉ុណ្ណោះ ដូច្នោះ ទើបពាក្យរបស់ពួកព្រាហ្មណ៍ទាំងនោះ ខុស ។ បទថា **កេចិ** សេចក្តីថា ជនពួកណាដែលសំណូមពរថា សូមសម្លាប់ពួកយើងចុះ ពួកយើងនឹងទៅកាន់ស្ថានសួគ៌ រមែងមិនមានក្នុងយញ្ញទាំងឡាយ ។ បទថា **ចាណេ បសុមារភន្តិ** សេចក្តីថា រមែងសម្លាប់ពួកម្រឹគជាដើម និងបសុសត្វដែលកំពុងអន្ទះអន្ទែងចិញ្ចឹមជីវិត ។ បទថា **មុខំ នយន្តិ** សេចក្តីថា បុគ្គលពាលទាំងឡាយ រមែងនាំយកសត្វ និងបសុសត្វ ទ្រព្យទាំងអស់ ដូចជាកែវមណី ស័ង្ខ កែវមុក្តា ទ្រព្យ ស្រូវ ប្រាក់ មាស ដែលចាត់ចែងទាំងអស់ បែរមុខទៅពោលពាក្យនោះៗ ប្រកាន់ខុសដោយឃើញថា វត្ថុនេះនឹងឲ្យរបស់ដែលគាប់ចិត្តដល់អ្នកក្នុងបរលោក នឹងនាំមកនូវភាពជារបស់ទៀងពិតប្រាកដ ។ បទថា **សចេ ច** សេចក្តីថា បើបានកែវមណីជាដើមនេះត្រង់សសរយញ្ញ ឬត្រង់ឈើក្រៅអំពីនោះ ឬសសរជាដើមនោះ គប្បីឲ្យនូវស្ថានត្រៃត្រិង្ស ឬវត្ថុដែលគួរប្រាថ្នាទាំងពួង ព្រាហ្មណ៍ជាច្រើនដែលទ្រទ្រង់

ត្រៃវេទ គប្បីបូជាយញ្ញ ព្រោះមានទ្រព្យច្រើន និងប្រាថ្នាចំពោះស្ថានសួគ៌ មិនគប្បីឲ្យអ្នកដទៃដែលមិនមែនជាព្រាហ្មណ៍បូជាយញ្ញ ព្រោះហេតុប្រាថ្នាតែទ្រព្យដើម្បីខ្លួន ទើបឲ្យអ្នកដទៃបូជា ដូច្នោះ គប្បីជ្រាបថា ពួកព្រាហ្មណ៍ជាអ្នកមានប្រក្រតីពោលមិនពិត ។ បទថា **កុតោ ច** សេចក្តីថា វត្ថុទាំងពួង មានកែវមណីជាដើមនេះ មិនមានត្រង់សសរ ឬត្រង់ឈើក្រៅអំពីនោះឡើយ និងចម្រាញ់យកស្ថានតាវត្តិង្ស ដែលជាវត្ថុឲ្យនូវសេចក្តីប្រាថ្នាទាំងពួងបានអំពីណា ពាក្យរបស់ជនទាំងនោះ មិនពិតទាំងអស់ ដោយប្រការទាំងពួង ។ បទថា **សឋា ច លុទ្ធា ច បលុទ្ធពាលា** សេចក្តីថា នៃអវិជ្ជៈ ឈ្មោះថា ព្រាហ្មណ៍ទាំងនេះ ជាអ្នកបោកបញ្ឆោត គ្មានករុណា ។ បុគ្គលពាលទាំងនោះ រមែងបោកបញ្ឆោត ( សត្វ ) លោក ត្រឡប់ត្រឡិនផ្តេសផ្តាសដោយហេតុផ្សេងៗ ។ បទថា **សព្ពកាមេ** សេចក្តីថា ចូរអ្នកយកភ្លើងបូជា នឹងឲ្យវត្ថុជាគ្រឿងត្រេកអរដល់យើង ។ បទថា **តតោ សុខី** សេចក្តីថា ចូរអ្នកឲ្យវត្ថុដែលគួរប្រាថ្នាទាំងពួងដល់យើង ហើយចូរមានសេចក្តីសុខ ។ បទថា **តមគ្គិហុត្តំ សរណំ បវិស្ស** សេចក្តីថា ចូរនាំព្រះរាជា ឬមហាមាត្យនៃព្រះរាជា ចូលទៅកាន់រោងបូជាភ្លើង។ បទថា **ឱរោបយិត្វា** សេចក្តីថា ពណ៌នាហេតុផ្សេងៗ មានកោរសក់ កោរពុកមាត់ កាត់ក្រចក ( ជាដើម ) ។ បទថា **អតិគាឡ្ហយន្តិ** សេចក្តីថា អាស្រ័យវេទ ៣ តាមដែលពោលហើយ ពោលបណ្តើរៗ ថា វត្ថុនេះគួរឲ្យ វត្ថុនេះគួរធ្វើ បង្ក្រាបធ្វើឲ្យវិនាស គឺកម្ចាត់ទ្រព្យជាគ្រឿងត្រេកអរដែលជារបស់បុគ្គលនោះ ។ បទថា

**អន្នានិ កុត្វា កុហកា កុហិត្វា** សេចក្តីថា អ្នកបោកបញ្ឆោតទាំងនោះ ធ្វើនូវកម្ម គឺការបោកបញ្ឆោត មានប្រការផ្សេងៗ មកប្រជុំរួមគ្នាពណ៌នាយញ្ញ បោកបញ្ឆោតអ្នកឲ្យបរិភោគភោជនល្អៗ មានរសប្រសើររបស់បុគ្គលនោះស្រេចហើយ ធ្វើបុគ្គលនោះ ឲ្យជាបុគ្គលក្បាលត្រងោល ហើយលែងចូលទៅក្នុងផ្លូវយញ្ញ អធិប្បាយថា នាំទៅកាន់រណ្តៅយញ្ញខាងក្រៅ ។ បទថា **យោគយោគេន** សេចក្តីថា ព្រាហ្មណ៍ទាំងនោះ ប្រជុំគ្នាជាច្រើនហើយ បោកបញ្ឆោតបុគ្គលនោះបានម្នាក់ ដោយសេចក្តីព្យាយាមនោះៗ គឺការប្រកបនោះៗ ពណ៌នាការបោកបញ្ឆោតទ្រព្យរបស់បុគ្គលនោះ ដែលឃើញប្រចក្សនិងទេវលោកដែលមិនឃើញ ដោយទេវលោកដែលមិនឃើញ ធ្វើឲ្យជាស្ថានទេវតា ។ បទថា **អកាសិយា រាជូហិ វានុសិដ្ឋា** សេចក្តីថា ដូចរាជបុរសពោល គឺបុគ្គលអ្នកទារពន្ធដារ ត្រូវព្រះរាជា ឬអមាត្យរបស់ព្រះរាជាទូន្មានថា ចូរពួកអ្នកកាន់យកសួយរបស់យើងនេះឯង ។ បទថា **តទស្ស** សេចក្តីថា បានកាន់យកទ្រព្យរបស់ព្រះរាជាទៅ ។ បទថា **ចោរសមា** សេចក្តីថា ជាអ្នកកាន់យកពលីដែលមិនពិត ដូចចោរកាត់ទីត ។ បទថា **វជ្ឈា** សេចក្តីថា ជាអ្នកគួរកម្ចាត់បាបធម៌ ព្រាហ្មណ៍ទាំងនោះ មានបាបធម៌បែបនេះ មិនត្រូវសម្លាប់ក្នុងលោក ។

បទថា **ពាហារសិ** កាត់បទជា **ពាហា អសិ** លោកពោលអធិប្បាយថា នៃអរិដ្ឋៈ ចូរអ្នកមើលមុសាវាទរបស់ព្រាហ្មណ៍នេះ បានឮមកថា ព្រាហ្មណ៍ទាំងនោះ ពោលមែកឈើដែលមានស្លឹកជុំក្នុងយញ្ញទាំងឡាយ ថាជា

ដៃស្តាំរបស់ព្រះឥន្ទ្រ ដច្នេះហើយ ទើបកាត់ ( មែកឈើនោះ ) បើពាក្យរបស់ព្រាហ្មណ៍ទាំងនោះ ជាពាក្យពិត កាលបើដូច្នោះ ព្រះឥន្ទ្រនឹងជាអ្នកមានដៃដាច់ តើនឹងឈ្នះអសុរព្រោះកម្លាំងដើមដៃបានដូចម្តេច ។ បទថា **សមង្គី** សេចក្តីថា ដល់ព្រមដោយដើមដៃ មិនដាច់ដៃ មិនមានរោគឡើយ ។ បទថា **ហន្តា** បានដល់ សម្លាប់ពួកអសុរ ។ បទថា **បរមោ** សេចក្តីថា ជាបុគ្គលឧត្តម គឺប្រកបដោយឫទ្ធិ មិនសម្លាប់អ្នកដទៃ ។ បទថា **ព្រាហ្មណា** បានដល់ មន្តរបស់ព្រាហ្មណ៍ទាំងឡាយ ។ បទថា **តុច្ឆរូបា** បានដល់ ភាពទទេ គឺមិនមានផល ។ បទថា **វញ្ចនា** បានដល់ ការបោកបញ្ឆោតដែលឃើញបានក្នុងលោកនេះ ឈ្មោះថា ជាមន្តរបស់ព្រាហ្មណ៍ទាំងនោះ ។ បទថា **យថាបការានិ** សេចក្តីថា ពួកព្រាហ្មណ៍ពោលថា ព្រាហ្មណ៍បូជាយញ្ញកាន់យកឥដ្ឋណាមួយសាងទុក ។ បទថា **ចិដ្ឋសេលា** សេចក្តីថា ពិតហើយ ភ្នំទាំងឡាយ មិនញាប់ញ័រ ឃើញបានឯង មិនមានអ្នកណាសាងឡើង ជារបស់តាន់ សម្រេចហើយដោយថ្ម មិនក្លាយជាដទៃឡើយ ឥដ្ឋទាំងឡាយញាប់ញ័រ មិនតាន់ មិនសម្រេចអំពីថ្ម ។ បទថា **បរិវណ្ណយន្តា** សេចក្តីថា ព្រាហ្មណ៍ទាំងឡាយ ពណ៌នាដល់យញ្ញនេះ ។ បទថា **សមត្តវេទេ** បានដល់ ពួកព្រាហ្មណ៍ដែលមានវេទបរិបូណ៌ ។ បទថា **វហន្តិ** សេចក្តីថា រមែងបក់ផាត់បុគ្គលដែលធ្លាក់ទៅក្នុងក្រសែទឹកក្តី ក្នុងទឹកវល់ក្តី ទៅកាន់ស្ទឹងឲ្យលិចចុះ ឲ្យដល់នូវការអស់ជីវិត ។ **ឧ** អក្ខរៈ ក្នុងបទ ថា **ឧ តេឧ ព្យាបន្នរូ-ស្វូឧកានិ** នេះ ជានិបាត ប្រើក្នុងអត្ថថា សួរ ។ ពិតហើយ កាលសួរលោក

ថា ស៊ឹងមានទឹកមានរសវិបត្តិ ព្រោះហេតុនោះ មិនមែនឬ ទើបពោលយ៉ាង នោះ ។ បទថា **កស្មា** សេចក្តីថា នៃអារិដ្ឋៈ ព្រោះហេតុអ្វី ទឹកក្នុង មហាសមុទ្រ ព្រហ្មធ្វើឲ្យផឹកមិនបាន ចុះហេតុអ្វី ទើបមហាព្រហ្មមិនអាចធ្វើ ទឹកក្នុងស៊ឹងទាំងឡាយ មានស៊ឹងយមុនាជាដើម ឲ្យផឹកមិនបាន ឬថា អាច តែក្នុងមហាសមុទ្រប៉ុណ្ណោះ ។ បទថា **ទ្វិរសញ្ញុរាហុ** សេចក្តីថា ជាទឹកដឹង រស ២ យ៉ាង ។

បទថា **បុរេ បុរត្ថា** សេចក្តីថា មុនអំពីនេះ គឺមុនដំបូង បានដល់ ក្នុងកាលនៃបឋមកប្ប ។ បទថា **កា កស្ស ភរិយា** សេចក្តីថា ជាភរិយា របស់បុគ្គលណា ។ ពិតហើយ ក្នុងកាលនោះ មិនមានភេទស្រី និងភេទ ប្រុសឡើយ ក្រោយមក ទើបមានឈ្មោះថា មាតា និងបិតា ដោយអំណាច មេថុនធម្ម ។ បទថា **មនោ មនុស្សំ** សេចក្តីថា ក្នុងកាលនោះ មនោនោះ ឯង បានឲ្យមនុស្សកើតឡើង អធិប្បាយថា សត្វទាំងឡាយ សម្រេចដោយ ចិត្តកើតឡើង ។ បទថា **តេនាបិ ធម្មេន** សេចក្តីថា ដោយហេតុនោះ គឺ ដោយសភាវៈនោះ បុគ្គលណាម្នាក់ ឈ្មោះថា អាក្រក់ដោយជាតិមិនមាន ។ ពិតហើយ ក្នុងកាលនោះ ការផ្សេងគ្នានៃក្សត្រជាដើម មិនមានឡើយ ព្រោះ ហេតុនោះ ព្រាហ្មណ៍ទាំងឡាយពោលពាក្យណាថា ព្រាហ្មណ៍ប៉ុណ្ណោះ ប្រសើរដោយជាតិ មនុស្សក្រៅអំពីនោះ អាក្រក់ ព្រោះហេតុនោះ ពាក្យ នោះ ឈ្មោះថា ខុស ។ បទថា **ឯវម្បិ** សេចក្តីថា កាលលោកប្រព្រឹត្តទៅ យ៉ាងនេះ ទើបបុគ្គលទាំងឡាយ មានក្សត្រជាដើមចែកចេញជា ៤ ចំណែក

ដោយអំណាចលះវត្តដែលជារបស់បុរាណ ខាងក្រោយទើបកំណត់ធ្វើដោយខ្លួនឯង ។ បទថា **ឯវម្បិ លោកស្មិ វិភង្គមាហុ** សេចក្តីថា ព្រាហ្មណ៍ពោលចែកយ៉ាងនេះថា ដោយការលះកម្មដែលខ្លួនធ្វើ បណ្តាសត្វទាំងនោះ ពួកខ្លះកើតជាក្សត្រ ពួកខ្លះកើតជាព្រាហ្មណ៍ជាដើម ព្រោះហេតុនោះ ពាក្យថាព្រាហ្មណ៍ទាំងនោះប្រសើរ ទើបខុសនោះឯង ។ បទថា **សច្ចជា** សេចក្តីថាបើមហាព្រហ្មឲ្យត្រៃវេទដល់ពួកព្រាហ្មណ៍ប៉ុណ្ណោះ មិនឲ្យដល់អ្នកដទៃ ក្បាលរបស់ចណ្ឌាល ដែលពោលមន្ត គប្បីបែកជា ៧ ភាគ តែក៏មិនបែក ព្រោះដូច្នោះ ព្រាហ្មណ៍ទាំងនេះ សាងមន្តឡើងដើម្បីសម្លាប់ខ្លួនឯង គឺកាល ( មន្ត ) ប្រាប់ឲ្យដឹងថា ព្រាហ្មណ៍ទាំងនោះឯងពោលមុសា ទើបឈ្មោះថា ធ្វើនូវការសម្លាប់គុណ ។ បទថា **វាចា កតា** សេចក្តីថា ឈ្មោះថា មន្តទាំងនេះដែលពួកព្រាហ្មណ៍គិតធ្វើដោយមុសាវាទ ។ បទថា **គិទ្ធិ កតា គហិតា** សេចក្តីថា ឈ្មោះថា ដែលពួកព្រាហ្មណ៍កាន់យក ដោយភាពជាអ្នកជាប់នៅក្នុងលាភ ។ បទថា **ទុម្មោចយា** សេចក្តីថា ដោះបានលំបាក ដូចត្រីដែលជាប់សន្ទូច ដូច្នោះ ។ បទថា **កាព្យាបថានុបន្នា** សេចក្តីថា ដើរតាម គឺចូលដល់ផ្លូវនៃពាក្យរបស់ពួកព្រាហ្មណ៍ អ្នកតែងកាព្យឃ្លោង ពួកព្រាហ្មណ៍ទាំងនោះពោលមុសា ចងគាថាឡើងតាមដែលខ្លួនប្រាថ្នា ។ បទថា **ពាលាន** សេចក្តីថា ចិត្តនៃបុគ្គលល្ងង់ទាំងនោះ គង់តម្កល់ខុស ម្តងខ្ពស់ ម្តងទាបជនដទៃដែលមិនមានបញ្ញា រមែងជឿពាក្យបុគ្គលដែលល្ងង់ខ្លៅនោះ ។ បទថា **ចោរិសិយំពលេន** សេចក្តីថា ដោយកម្លាំង ពោល គឺភាពជាបុរស លោក

អធិប្បាយថា ឈ្មោះថា ព្រាហ្មណ៍ ជាអ្នកប្រកបដោយកម្លាំងរបស់បុរសពោល គឺកម្លាំងនៃសីហបុរសជាដើមនោះ រមែងមិនមាន ។ មនុស្សទាំងអស់អាក្រក់ជាង គឺអាក្រក់ជាងសត្វតិរច្ឆានទាំងនេះទៅទៀត ។ បទថា **មនុស្ស-ភាវោ ច គវំវ បេក្ខោ** សេចក្តីថា ម្យ៉ាងទៀត ភាវៈនៃភាពជាមនុស្សរបស់ពួកព្រាហ្មណ៍ទាំងនោះ គប្បីឃើញដូចហ្វូងគោ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាតិរបស់ព្រាហ្មណ៍ទាំងនោះ មិនស្មើគ្នា អធិប្បាយថា ជាតិរបស់អ្នកស្មើជាមួយពួកព្រាហ្មណ៍ទាំងនោះមិនស្មើគ្នា ព្រោះពួកព្រាហ្មណ៍ទាំងនោះមានបញ្ញាថោកថយ សេចក្តីពិត សណ្ឋានរបស់ពួកគោម្យ៉ាង របស់ពួកព្រាហ្មណ៍ទាំងនោះក៏ម្យ៉ាង ព្រោះហេតុនោះ ទើបលោកមិនប្រៀបធៀបព្រាហ្មណ៍ទាំងនោះឲ្យស្មើគ្នា នឹងសត្វតិរច្ឆាន មានសីហៈជាដើម តែប្រៀបធៀបឲ្យស្មើគ្នាជាមួយគោប៉ុណ្ណោះ ។

បទថា **សចេ ច រាជា** សេចក្តីថា នៃអរិដ្ឋៈ បើក្សត្រប៉ុណ្ណោះគ្រប់គ្រងផែនដី ដោយការៈដែលមហាព្រហ្មឲ្យសោត ។ បទថា **សជីវវា** សេចក្តីថា ប្រកបដោយអមាត្យដែលនៅរួមគ្នា ។ បទថា **អស្សវា ចារិសដ្ឋោ** សេចក្តីថា គប្បីជាបុគ្គលដែលប្រើមនុស្សអ្នកធ្វើតាមឱវាទរបស់ខ្លួន កាលបើដូច្នោះបរិស័ទរបស់ព្រះរាជា ឈ្មោះថា គប្បីច្បាំង ហើយឲ្យរាជសម្បត្តិដល់ព្រះរាជា មិនគប្បីមាន ។ ព្រះរាជាអង្គនោះ មួយអង្គប៉ុណ្ណោះ គប្បីឈ្នះពួកសត្រូវដោយព្រះអង្គឯង ។ កាលការច្បាំងមានយ៉ាងនេះ ប្រជារាស្ត្ររបស់ព្រះអង្គ គប្បីមានសេចក្តីសុខជានិច្ច ព្រោះមិនមានសេចក្តីទុក្ខ សេចក្តីនោះ

មិនជាការពិត ព្រោះហេតុនោះ ពាក្យរបស់ពួកព្រាហ្មណ៍ទាំងនោះ រមែង មិនពិត ។

បទថា **ខត្តិយមន្តា** សេចក្តីថា រាជសាសន៍ និងត្រៃវេទទាំងនោះ ប្រព្រឹត្តទៅតាមអំណាចរាជអាណា តាមគប់ចិត្តរបស់ខ្លួន ថាវត្ថុនេះប៉ុណ្ណោះ គួរធ្វើ រមែងមានអត្ថស្មើគ្នា ។ បទថា **អវិនិច្ឆិនិត្វា** សេចក្តីថា ក្សត្រមិន វិនិច្ឆ័យអត្ថរបស់មន្តនៃក្សត្រទាំងនោះ ឯព្រាហ្មណ៍ក៏មិនវិនិច្ឆ័យអត្ថរបស់វេទ ទាំងឡាយ កាន់យកដោយអំណាចអាជ្ញាប៉ុណ្ណោះ រមែងឈមចុះដល់អត្ថនោះ ដូចផ្លូវដែលត្រូវជំនន់ទឹកកាត់ផ្តាច់ ដូច្នោះ ។ បទថា **អត្ថេន ឯតេ** សេចក្តី ថា រាជសាសន៍ និងវេទទាំងនោះ រមែងស្មើគ្នា ដោយអត្ថថា បោកបញ្ឆោត ។ ព្រោះហេតុអ្វី ព្រោះពួកព្រាហ្មណ៍ពោលថា ពួកព្រាហ្មណ៍ប៉ុណ្ណោះជាបុគ្គល ប្រសើរ វណ្ណៈដទៃថោកទាប ឯលោកធម៌ មានលាភទាំងអស់ជាដើម ជា ធម៌របស់វណ្ណៈទាំង ៤ ពិតហើយ សត្វសូម្បីតែមួយ ឈ្មោះថា ផុតទៅអំពី លោកធម៌ទាំងនោះ រមែងមិនមាន ។ ដូច្នោះ ទើបពួកព្រាហ្មណ៍ពោល មុសាវាទថា យើងជាបុគ្គលមិនផុតអំពីលោកធម៌នោះឯង ប្រសើរ ។ បទថា **ឥត្ថា** បានដល់ អ្នកជាធំក្នុងផ្ទះ ។ បទថា **តេវិជ្ជសង្ឃាបិ** សេចក្តីថា ឯពួក ព្រាហ្មណ៍ រមែងធ្វើកម្មជាច្រើន មានកសិកម្ម និងគោរក្ខកម្មជាដើមយ៉ាង នោះដូចគ្នា ។ បទថា **និច្ចុស្សុក្កា** សេចក្តីថា កើតនូវការខ្វល់ខ្វាយពេញចិត្ត ជានិច្ច ។ បទថា **តឧប្បបញ្ញា និរសញ្ញាភា តេ** សេចក្តីថា នែប្អូនប្រុស អ្នកដឹងរសដោយអណ្តាតទាំង ២ ព្រោះហេតុនោះ ពួកព្រាហ្មណ៍ ជាអ្នកមិន

មានបញ្ញា ព្រាហ្មណ៍ទាំងនោះ ជាអ្នកឆ្ងាយចាកធម៌ គឺធម៌របស់ពួកព្រាហ្មណ៍ អំពីបុរាណ រមែងប្រាកដក្នុងសុនខក្នុងកាលឥឡូវនេះ ។

ព្រះមហាសត្វ កាលទម្លាយនូវវាទៈរបស់ព្រាហ្មណ៍ទាំងនោះហើយ តាំងទុកនូវវាទៈរបស់ព្រះអង្គ ដោយប្រការដូច្នេះ ។ នាគបរិស័ទទាំងអស់នោះ បានស្តាប់ធម្មកថារបស់ព្រះមហាសត្វហើយ ក៏នាំគ្នាកើតសោមនស្ស ឯព្រះមហាសត្វឲ្យហៅនាគបរិស័ទ នាំព្រាហ្មណ៍នេសាទចេញអំពីនាគពិភព សូម្បីត្រឹមតែការបរិភាស ក៏មិនបានធ្វើដល់ព្រាហ្មណ៍នោះ ។

## យញ្ញភេទកណ្ឌ ចប់

ចំណែកព្រះបាទសាគរព្រហ្មទត្ត មិនបានកន្លងថ្ងៃដែលទ្រង់សន្យា យាងទៅកាន់ដំណាក់របស់ព្រះរាជបិតា មួយអន្លើដោយចតុរង្គសេនា ឯព្រះមហាសត្វ ក៏ឲ្យវាយស្គរប្រកាសថា យើងនឹងទៅគាល់ម្ចាស់អុំ និងព្រះអយ្យកោរបស់យើង ហើយក៏ឡើងអំពីស្ទឹងយមុនាដោយសិរីដ៏ល្អ ឆ្ពោះទៅកាន់អាស្រមនោះ បងប្អូនក្រៅអំពីនោះ មួយអន្លើដោយព្រះជននី ក៏ជាប់តាមទៅអំពីខាងក្រោយ ក្នុងខណៈនោះ ព្រះបាទសាគរព្រហ្មទត្តទតឃើញព្រះមហាសត្វ មកជាមួយនាគបរិស័ទជាច្រើន ទ្រង់ចាំមិនបាន កាលនឹងទូលសួរព្រះរាជបិតា ទើបត្រាស់ថា

ស្គរធំ សម្ភោរ ស័ង្ខ ស្គរជ័យ និងស្គរទ័ព របស់អ្នកណាដែល
ដើរខាងមុខ ហើយញ៉ាំងព្រះរាជាដ៏ប្រសើរ ក្នុងរថ ឲ្យរីករាយ ។
( សម្បុរមុខ ) របស់អ្នកណា ( ដ៏រុងរឿង ) ដោយដំបារមាស

ដ៏ក្រាស់ មានពន្លឺដូចផ្លេកបន្ទោរ អ្នកណានៅកំលោះ ប្រដាប់ដោយបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក ។ មុខអ្នកណាស្រស់បស់ដូចមាសឆ្អិន លើមាត់ជើងក្រាន ឬប្រាកដស្មើដោយរងើកនៃឧសគគីរ អ្នកណា រុងរឿងដោយសិរី ហើយដើរមក ។ ឆត្ររបស់បុគ្គលណា ជាវិការនៃមាសជម្ពូនទ ប្រកបដោយឆ្អឹងជាទីរីករាយនៃចិត្ត ជាគ្រឿងបិទបាំងរស្មីនៃព្រះអាទិត្យ អ្នកណារុងរឿងដោយសិរី ហើយដើរមក ។ អង្គ ( អ្នកកាន់ផ្ចិត ) បានកាន់យកវាលវីជនីដ៏ឧត្តម ខាងលើក្បាល ទាំងពីរខាងនៃបុគ្គលមានបញ្ញាដ៏ប្រសើរណា ។ បាច់នៃកន្ទុយក្ងោកដ៏វិចិត្រផង ទន់ផង មានដងជាវិការនៃមាស និងកែវមណី ប្រព្រឹត្តទៅទាំងពីរខាងមុខរបស់បុគ្គលណា ។ កុណ្ឌលទាំងឡាយនេះដ៏ល្អ មានពន្លឺដូចជាពណ៌រងើកភ្លើង នៃឧសគគីរ ដ៏ភ្លឺលើមាត់ជើងក្រានរមែងរុងរឿងទាំងពីរខាងមុខរបស់បុគ្គលណា ។ សក់របស់បុគ្គលណា មានចុងដ៏ស្និទ្ធ ទន់ ខ្មៅ ត្រូវខ្យល់បក់ហើយ ក៏ញ៉ាំងទីបំផុតនៃថ្ងាសឲ្យល្អ ដូចជាផ្លេកបន្ទោរ ដែលចេញអំពីមេឃ ។ ភ្នែកទាំងនេះវែងធំ របស់អ្នកណា អ្នកណា មានភ្នែកទូលាយសម មុខនេះរបស់អ្នកណា ភ្លឺថ្លះដូចកញ្ចក់មាស មាត់នេះរបស់អ្នកណាដ៏ស្អាត ដូចជាស័ង្ខដ៏ប្រសើរ ធ្មេញរបស់បុគ្គលណាកាលនិយាយឡើង ដូចជាផ្កាមណ្ឌាក្រពុំ ។ ដៃ និងជើងទាំង

ឡាយ របស់អ្នកណា ដូចជាទឹកល័ក្ត តាំងនៅក្នុងសេចក្តីសុខ អ្នកណា មានរិមបបូរមាត់ ដូចផ្លែបាសដ៏ល្អ ដូចជាព្រះអាទិត្យ ក្នុងវេលាថ្ងៃ ។ អ្នកណា មានសំពត់បាវារៈដ៏ស ដូចដើមរាំងដ៏ធំ មានផ្ការីកហើយ ក្នុងព្រៃហិមពាន្ត ក្នុងកាលដែលកន្ទងទៅនៃ ទឹកសន្សើម ល្អដូចព្រះឥន្ទ្រ ដែលមានជ័យជម្នះ ។ អ្នកណា នៅក្នុងបរិស័ទ ដោះដាវនៅលើស្មា ដែលមានដងដ៏វិចិត្រ ដោយ កែវមណី ដ៏ដេរដាសដោយពក ជាវិការនៃមាស ។ អ្នកណា ដោះស្បែកជើង ដែលប៉ាក់ដោយមាស វិចិត្រដោយកែវ ៧ ប្រការ ដេរដោយសូត្រដ៏វិចិត្រ រចនាល្អហើយ ក៏ថ្វាយបង្គំតាបស អ្នក ស្វែងរកគុណដ៏ធំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិបន្នានិ** សេចក្តីថា តន្ត្រីទាំងនេះជារបស់ អ្នកណា ដើរមកខាងមុខ ។ បទថា **ហាសយន្តា** សេចក្តីថា ធ្វើឲ្យព្រះរាជា នេះ ទ្រង់ត្រេកអរ ។ បទថា **កស្ស កាញ្ចនបដ្ដេន** សេចក្តីថា ព្រះរាជា ត្រាស់សួរថា អ្នកណាមានពណ៌សម្បុរមុខរុងរឿង ដោយអំណាចក្បាំងមុខ ត្រង់ថ្ងាស ដូចដុំពពករុងរឿងដោយផ្លេកបន្ទោរ ដូច្នោះ ។ បទថា **យុវា កលាបសន្នទ្ធោ** ប្រែថា នៅកំលោះ ស្ពាយទូវបំពង់ព្រួញ ។ បទថា **ឧក្កា-មុខេ បហដ្ឋំវ** សេចក្តីថា ដូចមាសឆ្អិនឆ្អៅត្រង់ជើងប្រានរបស់ជាងមាស ។ បទថា **ខទិរង្គារសន្និភំ** បានដល់ ដូចរងើកគគីរដែលឆេះសន្ធោសន្ធៅ ។ បទថា **ជម្ពោនទំ** សេចក្តីថា សម្រេចហើយដោយមាស ដែលមានពណ៌

រុងរឿង ។ បទថា **អគ្គិ បរិគ្គយ្ហ** សេចក្តីថា ដែលអ្នកបម្រើកាន់ស៊ែ និង លាំពែងស្នែងក្របី កំពុងមក ។ បទថា **វាលវីជនី** បានដល់ បក់នូវផ្លិតវាល វីជនីដែលសម្រេចដោយកែវមណី ។ បទថា **ឧត្តមំ** ប្រែថា ដ៏កំពូល ។ បទថា **បេក្ខុណហត្ថានិ** បានដល់ អ្នកខ្វះកាន់បាច់អង្កាំកន្ទុយក្ងោក ។ បទថា **ចិត្រានិ** បានដល់ វិចិត្រដោយកែវ ៧ ប្រការ ។ បទថា **សុវណ្ណ-មណិទណ្ឌានិ** សេចក្តីថា មានដងរំលេចដោយមាសទឹកដប់ និងដោយកែវ មណី ។ បទថា **ឧភតោ មុខំ** សេចក្តីថា ត្រាច់ទៅខាងមុខទាំងពីរខាង ។ បទថា **វាតេន ធុបិតា** បានដល់ ដែលខ្យល់បក់រំភើយ ។ បទថា **សិនិទ្ធគ្គា** ប្រែថា មានចុងស្និទ្ធទន់ ។ បទថា **ឥលាតង្គំ** សេចក្តីថា សរសៃសក់បែប នេះរបស់អ្នកណាស្អាត មកទល់ត្រង់ថ្ងាស ។ បទថា **ឥភា វិជ្ជុរិវុគ្គតា** សេចក្តីថា ដូចផ្លេកបន្ទោរក្នុងលម្អមេឃ ដូច្នោះ ។ បទថា **ឧណ្ណជំ** សេចក្តី ថា បរិសុទ្ធដូចកញ្ចក់មាស ។ បទថា **លបនជាតា** ប្រែថា មាត់ ។ បទថា **កុប្បិលសាទិសា** បានដល់ ដូចផ្កាមណ្ឌារវៈក្រពុំ ។ បទថា **សុខេ ឋិតា** សេចក្តីថា បរិហារបានងាយ ។ បទថា **ជយំ ឥន្ទោវ** សេចក្តីថា ដូច ព្រះឥន្ទ្របាននូវជ័យជម្នះ ។ បទថា **សុវណ្ណបីឡកាកិណ្ណំ** បានដល់ ដេរដាសទៅដោយពកមាស ។ បទថា **មណិទណ្ឌវិចិត្តកំ** សេចក្តីថា វិចិត្រ ទៅដោយកែវមណីត្រង់ដង ។ បទថា **សុវណ្ណវិកតា** បានដល់ រំលេច ដោយមាស ។ បទថា **ចិត្រា** បានដល់ វិចិត្រទៅដោយកែវ ៧ ប្រការ ។

បទថា **សុកតា** សេចក្តីថា សម្រេចរៀបរយហើយ ។ បទថា **ចិត្រសិព្វិនី** បានដល់ ដេរយ៉ាងស្អាត ។ ដោយបទថា **ទានា** នេះ លោកសួរថា អ្នកណា ដោះស្បែកជើងមាសមានសភាពបែបនេះ ។

តាបសដែលមានឫទ្ធិបាននូវអភិញ្ញា ត្រូវព្រះបាទសាគរព្រហ្មទត្តជាឱរសទូលសួរយ៉ាងនេះ កាលនឹងប្រាប់ថា នែបា អ្នកដែលមកទាំងនេះ គឺជានាគកូនរបស់ធតរដ្ឋ ក្មួយរបស់ឯង ទើបពោលគាថានេះថា

នាគទាំងនោះ ជានាគមានឫទ្ធិ មានយស ជាកូននៃព្រះបាទធតរដ្ឋ
កើតអំពីនាងសមុទ្ទជា នាគទាំងនេះ សុទ្ធតែជានាគមានឫទ្ធិច្រើន
ដូច្នេះ ។

កាលរាជឥសី និងព្រះបាទសាគរព្រហ្មទត្តត្រាស់យ៉ាងនេះ នាគបរិស័ទទាំងឡាយ ក៏នាំគ្នាថ្វាយបង្គំបាទារបស់តាបស ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ឯនាងសមុទ្ទជា ក៏ថ្វាយបង្គំព្រះរាជបិតា និងព្រះរាជភាតា ហើយបរិទេវនាកា ហើយក៏នាំនាគបរិស័ទ ត្រឡប់ទៅកាន់នាគពិភព ឯព្រះបាទសាគរព្រហ្មទត្ត ប្រថាប់នៅក្នុងទីនោះឯង ២-៣ ថ្ងៃ ទើបថ្វាយបង្គំលា ខមាទោសព្រះរាជបិតា ហើយត្រឡប់ទៅកាន់ក្រុងពារាណសី ។ ព្រះនាងសមុទ្ទជាទេវី ក៏អស់ព្រះជន្មក្នុងនាគពិភពនោះឯង ឯព្រះពោធិសត្វរក្សាសីលរហូតអស់ជីវិត ក្នុងទីបំផុតនៃព្រះជន្មាយុ ក៏បានទៅកាន់ស្ថានសួគ៌មួយអន្លើដោយនាគបរិស័ទ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបត្រាស់ថា ម្នាលឧបាសកទាំងឡាយ បុរាណកបណ្ឌិត ទោះព្រះពុទ្ធមិនទាន់កើតឡើង ក៏គង់លះនាគសម្បត្តិបែបនេះ ធ្វើឧបោសថកម្ម ដូច្នេះហើយ ទើបទ្រង់ប្រជុំជាតកថា មាតាបិតារបស់ភូរិទត្តក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ ព្រាហ្មណ៍នេសាទបានមកជាទេវទត្ត សោមទត្តក្នុងកាលនោះ បានមកជាអានន្ទ នាងអច្ចិមុខីក្នុងកាលនោះ បានមកជាឧប្បលវណ្ណា សុទស្សនៈក្នុងកាលនោះ បានមកជាសារីបុត្រ សុភោគៈក្នុងកាលនោះ បានមកជាមោគ្គល្លាន កាណារិដ្ឋៈក្នុងកាលនោះ បានមកជាសុនក្ខត្តលិច្ឆវី ភូរិទត្តក្នុងកាលនោះ គឺតថាគតដ៏ជាសម្មាសម្ពុទ្ធនេះឯង ។ល។

**ភូរិទត្តជាតកទី ៦ ចប់**

# សុត្តន្តបិដក

## ចន្ទកុមារជាតក

[ ៣៨២ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទឯករាជ អ្នកមានអំពើអាក្រក់ នៅក្នុងក្រុងបុប្ផវតីនោះ សួររកផ្លូវទៅព្រហ្មលោក នឹងបរោហិតឈ្មោះខណ្ឌហាល ជាពូជពង្សព្រហ្ម ជាមនុស្សល្ងង់វង្វេងថា ម្នាលព្រាហ្មណ៍ អ្នកជាមនុស្សឈ្លាសក្នុងធម៌វិន័យ សូមអ្នកប្រាប់ផ្លូវស្ថានសួគ៌ តាមទំនងដែលពួកជន ធ្វើបុណ្យទាំងឡាយហើយចេញចាកលោកនេះ ទៅកាន់សុគតិ ដូចម្តេច ។

[ ៣៨៣ ] ( ខណ្ឌហាលព្រាហ្មណ៍បុរោហិតទូលថា ) បពិត្រព្រះទេវៈ ពួកជនធ្វើបុណ្យទាំងឡាយ ឲ្យទានដ៏ក្រៃលែង សម្លាប់បុគ្គល ដែលមិនគួរសម្លាប់ទាំងឡាយ ហើយទៅកាន់សុគតិយ៉ាងនេះ ។

[ ៣៨៤ ] ( ព្រះបាទឯករាជ... ) ទានដ៏ក្រៃលែងនុ៎ះដូចម្តេចក្នុងលោកនេះ បុគ្គលទាំងឡាយដូចម្តេច ដែលមិនគួរសម្លាប់ ចូរអ្នកប្រាប់សេចក្តីនុ៎ះដល់យើង យើងនឹងបូជា នឹងឲ្យទានទាំងឡាយ ។

[ ៣៨៥ ] ( ខណ្ឌហាលព្រាហ្មណ៍ ... ) បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយព្រះរាជបុត្តទាំងឡាយផង ដោយព្រះអគ្គមហេសីទាំងឡាយផង ដោយអ្នកនិគម ( សេដ្ឋី ) ទាំងឡាយផង បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយគោឧសភ សេះអាជា-

នេយ្យ បួនៗ ដោយពួកសត្វ បួនៗ ទាំងអស់ ។

[ ៣៨៦ ] សំឡេងគឹកកង់តែមួយ សំឡេងគួរខ្លាច លាន់ឮឡើងក្នុងវាំង ព្រោះឮព្រះរាជឱង្ការនោះថា ព្រះកុមារទាំងឡាយ និងព្រះអគ្គមហេសីទាំងឡាយ ត្រូវសម្លាប់ ។

[ ៣៨៧ ] ( ព្រះរាជា ... ) អ្នកទាំងឡាយ ចូរទៅប្រាប់កុមារទាំងឡាយ គឺចន្ទកុមារ ១ សុរិយកុមារ ១ ភទ្ទសេនកុមារ ១ សុរកុមារ ១ វាមគោត្តកុមារ ១ ថា អ្នកទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។

[ ៣៨៨ ] អ្នកទាំងឡាយ ចូរប្រាប់កុមារីទាំងឡាយ គឺកុមារីឈ្មោះឧបសេនា ១ កោកិលា ១ មុទិតា ១ នន្ទា ១ ថា នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។

[ ៣៨៩ ] អ្នកទាំងឡាយ ចូរប្រាប់មហេសីអញ គឺនាងវិជយា ១ នាងឯរាវតី ១ នាងកេសិនី ១ នាងសុនន្ទា ១ ដែលជាស្រ្តីបរិបូណ៌ដោយលក្ខណៈដ៏ប្រសើរថា នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។

[ ៣៩០ ] អ្នកទាំងឡាយ ចូរប្រាប់គហបតីទាំងឡាយ គឺគហបតីឈ្មោះបុណ្ណមុខៈ ១ ភទ្ទិយៈ ១ សិង្គាលៈ ១ វឌ្ឍៈ ១ ថា ចូរអ្នកទាំងឡាយមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។

[ ៣៩១ ] ( អភិសម្ពុទ្ធគាថា ) ពួកគហបតីទាំងនោះ មកជួបជុំគ្នា ដេរដាសដោយកូន និងប្រពន្ធក្នុងទីនោះ ក្រាបបង្គំទូលថា បពិត្រព្រះទេវៈ សូមព្រះអង្គធ្វើយើងខ្ញុំទាំងអស់ ឲ្យមានជុកលើក្បាលវិញ ពុំនោះសោត សូមព្រះអង្គប្រកាសនូវយើងខ្ញុំថាជាទាសៈ ។

[ ៣៩២ ] ( ព្រះរាជា ... ) អ្នកទាំងឡាយ ចូរនាំមកនូវដំរីរបស់អញ ឈ្មោះអភយង្ការៈ ១ នាឡាគិរី ១ អច្ចុគ្គតៈ ១ ( ឈ្មោះវរុណទន្តៈ ) ១ ដំរីទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងឆាប់ ។ អ្នកទាំងឡាយ ចូរនាំមកនូវសេះកែវរបស់អញ គឺសេះឈ្មោះកេសី ១ សុរាមុខៈ ១ បុណ្ណកៈ ១ វិនតកៈ ១ សេះទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងឆាប់ ។ អ្នកទាំងឡាយ ចូរនាំយកគោឧសភទាំងនោះរបស់អញ គឺគោឧសភឈ្មោះយូថបតិ ១ អនោជៈ ១ និសភៈ ១ គវម្បតិ ១ មកដល់អញ ជនទាំងឡាយ ចូរធ្វើកិច្ចការទាំងពួង ក្នុងទីចំពោះមុខអញ នឹងបូជា នឹងឲ្យទានទាំងឡាយ ។ អ្នកទាំងឡាយ ចូរតាក់តែងគ្រឿងបូជាគ្រប់មុខ កាលបើព្រះអាទិត្យរះឡើងហើយ អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់ពួកកុមារមានចន្ទកុមារជាដើមថា កុមារទាំងឡាយ ចូររីករាយអស់ ១ យប់នេះចុះ ។ អ្នកទាំងឡាយចូរតម្កល់ទុក នូវគ្រឿងយញ្ញគ្រប់មុខ កាលព្រះអាទិត្យរះឡើង អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់

កុមារទាំងឡាយ ក្នុងកាលឥឡូវនេះថា រាត្រីថ្ងៃនេះឯង ជារាត្រីបំផុត ។

[ ៣៩៣ ] ( អភិសម្ពុទ្ធគាថា ) ព្រះរាជាមាតា ( ព្រះបាទឯករាជ ) ទ្រង់ព្រះកន្សែង ទ្រង់ស្តេចមកអំពីវិមាន ទ្រង់មានព្រះរាជ-សវនីយ៍ សួរនូវសេក្តីនោះ នឹងព្រះរាជានោះថា នែកូន ឮថា កូនឯងនឹងបូជាយញ្ញ ដោយព្រះរាជបុត្តទាំង ៤ នាក់មែនឬ ។

[ ៣៩៤ ] ( ព្រះបាទឯករាជ ... ) កាលបើខ្ញុំសម្លាប់ចន្ទកុមារហើយ បុត្តរបស់ខ្ញុំទាំងអស់ ក៏ខ្ញុំលះបង់ដើម្បីបូជាយញ្ញដែរ លុះខ្ញុំបូជាដោយបុត្តទាំងឡាយហើយ ខ្ញុំនឹងទៅកាន់សុគតិសួគ៌ ។

[ ៣៩៥ ] ( ព្រះរាជាមាតា ... ) ម្នាលកូន អ្នកកុំជឿខណ្ឌហាល-ព្រាហ្មណ៍នោះថា សុគតិបានដោយការបូជាបុត្តឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរក មិនមែនជាផ្លូវទៅកាន់ស្ថានសួគ៌ទេ ។ ម្នាលកូនកោណ្ឌញ្ញគោត្ត ចូរអ្នកឲ្យទានទាំងឡាយ ( អ្នក ) កុំបៀតបៀនសព្វសត្វដែលកើតហើយ នឹងត្រូវកើតឡើយ នេះជាផ្លូវនៃសុគតិផ្លូវ ( នៃសុគតិ ) មិនមែនបានដោយការបូជាបុត្តទេ ។

[ ៣៩៦ ] ( ព្រះបាទឯករាជ ... ) ខ្ញុំនឹងសម្លាប់ចន្ទកុមារផងសុរិយកុមារផង តាមពាក្យខណ្ឌហាលអាចារ្យ បូជាបុត្តទាំងឡាយដែលគេលះបង់បានដោយកម្រហើយ នឹងទៅកាន់សុគតិសួគ៌ ។

[ ៣៩៧ ] ( អភិសម្ពុទ្ធគាថា ) ចំណែកខាងព្រះវេសវត្តី ជាព្រះ

រាជបិតាត្រាស់សួរហេតុនោះ ចំពោះព្រះបាទឯករាជ ជារាជបុត្តកើតអំពីឱរានោះថា ម្នាលកូន ឮថា អ្នកនឹងបូជាយញ្ញ ដោយបុត្តទាំង ៤ មែនឬ ។

[ ៣៩៨ ] ( ព្រះបាទឯករាជ ... ) កាលបើខ្ញុំសម្លាប់ចន្ទកុមារ ( បូជា ) ហើយ បុត្តទាំងឡាយទាំងអស់ ក៏ខ្ញុំលះបង់ដែរ ខ្ញុំបូជាយញ្ញដោយបុត្តទាំងឡាយហើយ នឹងទៅកាន់សុគតិសួគ៌ ។

[ ៣៩៩ ] ( ព្រះរាជបិតា ... ) ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍ថា សុគតិមាន ដោយការបូជាបុត្តឡើយ ផ្លូវហ្នឹងជាផ្លូវទៅកាន់នរកទេ មិនមែនជាផ្លូវទៅកាន់ស្ថានសួគ៌ទេ ។ ម្នាលកូនកោណ្ឌញ្ញគោត្ត ចូរអ្នកឲ្យទានទាំងឡាយ ( អ្នក ) កុំបៀតបៀនសព្វសត្វទាំងឡាយដែលកើតហើយ នឹងត្រូវកើត នេះជាផ្លូវនៃសុគតិ ផ្លូវ ( នៃសុគតិ ) មិនមែនបានដោយការបូជាបុត្តទេ ។

[ ៤០០ ] ( ព្រះបាទឯករាជ ... ) ខ្ញុំនឹងសម្លាប់ចន្ទកុមារផងសុរិយកុមារផង តាមពាក្យនៃខណ្ឌហាលអាចារ្យ ខ្ញុំបូជាបុត្តទាំងឡាយ ដែលគេលះបង់បានដោយកម្រ ហើយនឹងទៅកើតក្នុងសុគតិសួគ៌ ។

[ ៤០១ ] ( ព្រះរាជបិតា ... ) ម្នាលកូន កោណ្ឌញ្ញគោត្ត អ្នកចូរឲ្យទានទាំងឡាយ ( អ្នក ) កុំបៀតបៀនសព្វសត្វដែលកើតហើយ នឹងត្រូវកើតទាំងឡាយឡើយ អ្នកចូរជាមនុស្សដែលកូនទាំង

ឡាយចោមរោមហើយ រក្សាដែន និងជនបទចុះ ។

[ ៤០២ ] ( ចន្ទកុមារ ... ) បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយឃ្វាលដំរី និងសេះ ។ បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គ ព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយនឹងចោលអាចម៍ដំរី ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គ ព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយនឹងចោលអាចម៍សេះ ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជាទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ព្រះអង្គមានប្រាថ្នា ( ដើម្បីព្រះរាជទាន ) ដល់ខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានទូលបង្គំ ជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោតនឹងសូមព្រះអង្គ បំបរបង់ទូលបង្គំជាខ្ញុំទាំងឡាយ ចេញចាកដែន

ក៏ទូលបង្គំជាខ្ញុំទាំងឡាយ នឹងត្រាច់ទៅកាន់កិក្ខាចារ ។

[ ៤០៣ ] ( ព្រះបាទឯករាជ ... ) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយយំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ អ្នកទាំងឡាយលែងកុមារទាំងឡាយទៅ ការបូជាយញ្ញ ដោយកូនរបស់អញ ល្មមលើកលែងចុះ ។

[ ៤០៤ ] ( ខណ្ឌហាលព្រាហ្មណ៍ ... ) ទូលព្រះបង្គំជាខ្ញុំ ក្រាបទូលព្រះអង្គ តាំងពីដើមមកថា ការបូជាយញ្ញនុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងធ្វើឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញ ដែលទូលព្រះបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វី ព្រះអង្គធ្វើឲ្យខានទៅវិញ ។ ជនទាំងឡាយណា ឲ្យគេបូជាយញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផងកំពុងបូជា ប្រាកដដូច្នេះក្តី ជនទាំងឡាយទាំងអស់នោះ រមែងទៅកាន់សុគតិ ។

[ ៤០៥ ] ( ចន្ទកុមារ ... ) ចុះព្រះអង្គ ឲ្យពួកព្រាហ្មណ៍ទាយសួស្តីរបស់ទូលព្រះបង្គំជាខ្ញុំ ពីមុនមកដើម្បីអ្វី បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គឲ្យគេសម្លាប់ ពួកទូលបង្គំជាខ្ញុំ ដើម្បីប្រយោជន៍ដល់យញ្ញ ដោយឥតហេតុ ។ ពីដើម កាលដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយ នៅក្មេងនៅឡើយ ( ម្តេចក៏ ) ព្រះអង្គ

មិនសម្លាប់ មិនឲ្យគេសម្លាប់ទៅ បពិត្រព្រះបិតា ឥឡូវនេះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាក្មេងពេញកំលោះ ជាអ្នកឥតប្រទូស្ត ក៏ស្រាប់តែព្រះអង្គឲ្យគេសម្លាប់ ។ បពិត្រមហារាជ សូមព្រះអង្គទតមើលទូលបង្គំជាខ្ញុំទាំងឡាយ ដែលពាក់គ្រឿងក្រោះ ជិះដំរី ជិះសេះ ច្បាំងហើយ និងកំពុងច្បាំង មនុស្សទាំងឡាយបែបខ្ញុំនេះ មិនមែនជាមនុស្សសម្រាប់បូជាយញ្ញទេ ។ ជនទាំងឡាយ តែងបញ្ជូនពួកមនុស្ស ដូចទូលបង្គំជាខ្ញុំ ទៅក្នុងបច្ចន្តគ្រាម ដែលបះបោរឡើងហើយ ឬក្នុងដងព្រៃ បពិត្រព្រះបិតា កាលបើដូច្នោះ ទូលបង្គំជាខ្ញុំទាំងឡាយ មិនត្រូវព្រះអង្គឲ្យគេសម្លាប់ ក្នុងទីមិនជាឱកាស ដោយឥតហេតុទេ ។ មេសត្វស្លាបទាំងឡាយណានីមួយធ្វើសម្បុកដោយស្មៅទាំងឡាយ ហើយនៅ កូនទាំងឡាយជាទីស្រឡាញ់របស់មេសត្វស្លាបទាំងនោះ បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គនៅតែឲ្យគេសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយ ។ ព្រះអង្គកុំជឿពាក្យខណ្ឌហាលព្រាហ្មណ៍នោះថា ខណ្ឌហាលព្រាហ្មណ៍មិនគប្បីសម្លាប់អញខ្ញុំ ដូច្នេះឡើយ បពិត្រព្រះទេវៈ ព្រោះខណ្ឌហាលព្រាហ្មណ៍នោះ សម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយហើយគប្បីសម្លាប់ព្រះអង្គ ក្នុងកាលជាលំដាប់ ។ បពិត្រមហារាជ ព្រះរាជាទាំងឡាយ តែងព្រះរាជទានស្រុកដ៏ប្រសើរផង និគមដ៏ប្រសើរផង ភោគៈផង ដល់ព្រាហ្មណ៍នោះ កាលបើដូច្នោះ ពួកព្រាហ្មណ៍

ទាំងនោះ ជាអ្នកបរិភោគ រាល់ៗ ដុំបាយដ៏ថ្លៃថ្លា តែងបាន បរិភោគ រាល់ៗ ត្រកូល ។ បពិត្រមហារាជ ព្រាហ្មណ៍ទុះ ប្រាថ្នាដើម្បីប្រទូស្ត ចំពោះជនអ្នកឲ្យទាំងនោះ ដូចជាព្រះអង្គ បពិត្រព្រះទេវៈ ពួកព្រាហ្មណ៍ទាំងនុ៎ះ ជាមនុស្សអកតញ្ញូដោយ ច្រើន ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំង ឡាយឡើយ សូមព្រះអង្គ ព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណង ហើយនឹងឃ្វាលដំរី និងសេះ ។ បពិត្រព្រះ សម្មតិទេព សូមព្រះអង្គកុំសម្លាប់ ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទាន នូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈ នៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយជាប់ចំណង ហើយនឹងចាក់អាចម៍ដំរី ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទាន ទូលបង្គំ ជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូល បង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណង នឹងចាក់អាចម៍សេះ ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ នូវទូលបង្គំជាខ្ញុំទាំង ឡាយឡើយ ព្រះអង្គសព្វព្រះរាជហឫទ័យ ចំពោះខណ្ឌហាល- ព្រាហ្មណ៍ណា សូមព្រះរាជទាននូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជា ទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះវិញចុះ ពុំនោះសោត ទូលបង្គំ

ជាខ្ញុំទាំងឡាយ បើព្រះអង្គបំបរបង់ចេញចាកដែន នឹងត្រាច់ទៅកាន់ភិក្ខាចារ ។

[ ៤០៦ ] ( ព្រះបាទឯករាជ ... ) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយយំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយ លែងកុមារទាំងឡាយទៅ ការបូជាយញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ ។

[ ៤០៧ ] ( ខណ្ឌហាលព្រាហ្មណ៍ ... ) ទូលបង្គំជាខ្ញុំ បានក្រាបទូលតាំងពីដើមមកថា ការបូជាយញ្ញនុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញដែលទូលបង្គំជាខ្ញុំ ប្រុងប្រៀបស្រេចហើយ ហេតុអ្វីក៏ព្រះអង្គ ធ្វើឲ្យអាក់ខានទៅវិញ ។ ជនទាំងឡាយណា បូជាយញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផងកំពុងបូជា ប្រាកដដូច្នេះក្តី ជនទាំងអស់ ( នោះ ) រមែងទៅកាន់សុគតិ ។

[ ៤០៨ ] ( ចន្ទកុមារ ... ) បើប្រាកដជាបុគ្គលទាំងឡាយបូជាយញ្ញ ដោយបុត្រទាំងឡាយហើយ ច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់ទេវលោក បពិត្រមហារាជ ចូរព្រាហ្មណ៍បូជាមុនចុះ សឹមព្រះអង្គបូជាជាខាងក្រោយ ។ ឮថា បើប្រាកដជាបុគ្គលទាំងឡាយ បូជាយញ្ញដោយបុត្តទាំងឡាយហើយ ច្យុតអំពីមនុស្ស-

លោកនេះ រមែងទៅកាន់ទេវលោក ចូរខណ្ឌហាលព្រាហ្មណ៍ហ្នឹង ឯង បូជាដោយកូនទាំងឡាយរបស់ខ្លួនចុះ ។ បើខណ្ឌហាល-ព្រាហ្មណ៍ដឹងយ៉ាងនេះហើយ ហេតុអ្វីក៏មិនសម្លាប់កូនតូចៗ ទាំងឡាយផង មិនសម្លាប់ជនជាញាតិទាំងអស់ផង មិនសម្លាប់ខ្លួនឯងផង ។ ជនទាំងឡាយណា បូជាយញ្ញដោយខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញប្រាកដដូច្នេះក្តី ជនទាំងអស់ ( នោះ ) រមែងទៅកាន់នរក ។

[ ៤០៩ ] ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា កុំទ្រង់សម្លាប់បុត្រដែលកើតអំពីទ្រូងឡើយ ។ ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា កុំទ្រង់សម្លាប់បុត្រដែលកើតអំពីខ្លួនឡើយ ។ ខ្ញុំជាអ្នកប្រាថ្នាប្រយោជន៍ចំពោះព្រះរាជា ប្រយោជន៍ចំពោះអ្នកជនបទទាំងអស់ ឥតមាននរណាមួយថ្នាំងថ្នាក់ចិត្តនឹងខ្ញុំឡើយ ( ហេតុអីក៏ ) អ្នកជនបទមិនក្រាបទូលឲ្យទ្រង់ជ្រាប ។

[ ៤១០ ] ម្នាលនាងយរណីទាំងឡាយ ( ស្រីមេផ្ទះ ) ចូរនាងទាំងឡាយទៅអង្វរព្រះរាជបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំងឡាយ ដូចជាសីហៈ ជាអ្នកមិន

ប្រទូស្ត ម្នាលនាងយរណីទាំងឡាយ ចូរនាងទាំងឡាយទៅនិយាយអង្វរព្រះបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំងឡាយ ជាទីអាល័យរបស់សត្វលោកទាំងអស់ ។

[ ៤១១ ] បើដូច្នោះ គួរតែអញកើតក្នុងត្រកូលអ្នកធ្វើរថ ឬអ្នកបោលសំរាម ឬកើតក្នុងត្រកូលវេស្សៈ ទើបព្រះរាជានឹងមិនសម្លាប់អញ ដើម្បីយញ្ញក្នុងថ្ងៃនេះ ។

[ ៤១២ ] ម្នាលពួកស្រីអ្នកមានគំនិតទាំងឡាយ ចូរនាងទាំងអស់ទៅក្រាបទៀបបាទា នៃខណ្ឌហាលព្រាហ្មណ៍ជាម្ចាស់ហើយ ( ប្រាប់ថា ) ខ្ញុំមិនឃើញកំហុសសោះ ។ ម្នាលពួកស្រីជាមេផ្ទះទាំងអស់គ្នា ចូរនាងទាំងឡាយទៅក្រាបទៀបបាទានៃខណ្ឌហាល-ព្រាហ្មណ៍ជាម្ចាស់ ហើយ ( និយាយថា ) បពិត្រលោកខណ្ឌ-ហាលដ៏ចម្រើន យើងទាំងឡាយ បានប្រទូស្តអ្វីដល់លោក ។

[ ៤១៣ ] លំដាប់នោះ ព្រះនាងសេលា ជាព្រះរាជធីតាគួរអាណិត បានឃើញព្រះភាតាទាំងឡាយ ដែលគេនាំខ្លួនទៅហើយ ទ្រង់ព្រះកន្សែងថា ឮថា យញ្ញ ព្រះរាជបិតាអញ ទ្រង់ប្រាថ្នាស្ថានសួគ៌ ឲ្យប្រព្រឹត្តទៅហើយ ។

[ ៤១៤ ] ( លំដាប់នោះ ) វសុលរាជកុមារ បម្រះនទៀលក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ទ្រង់ព្រះកន្សែងអង្វរថា បពិត្រព្រះ

ទេវៈ សូមព្រះអង្គកុំសម្លាប់បិតារបស់ទូលបង្គំជាខ្ញុំឡើយ ព្រោះទូលបង្គំជាខ្ញុំនៅក្មេង ពុំទាន់ធំនៅឡើយ ។

[ ៨១៥ ] ( ព្រះរាជា ... ) ម្នាលវសុលកុមារ ន៎ះបិតារបស់ឯង ចូរឯងស្ងប់រម្ងាប់ជាមួយនឹងបិតារបស់ឯងចុះ ឯងយំស្រែកក្នុងព្រះរាជវាំង ឈ្មោះថា ញុំាំងទុក្ខយ៉ាងខ្លាំង ឲ្យកើតឡើងដល់អញ អ្នកទាំងឡាយ ចូរលែងពួកកុមារក្នុងកាលឥឡូវនេះចុះ ការបូជាយញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ ។

[ ៨១៦ ] ( ខណ្ឌហាលព្រាហ្មណ៍ ... ) ទូលបង្គំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយញ្ញនេះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញដែលទូលបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីក៏ព្រះអង្គធ្វើឲ្យអាក់ខានទៅវិញ ។ ជនទាំងឡាយណា បូជាយញ្ញដោយខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងអស់នោះ រមែងទៅកើតក្នុងសុគតិ ។

[ ៨១៧ ] បពិត្រព្រះឯករាជ យញ្ញទូលបង្គំជាខ្ញុំចាត់ចែងរៀបចំដើម្បីព្រះអង្គដោយរតនៈទាំងពួងហើយ បពិត្រព្រះទេវៈ សូមព្រះអង្គយាងចេញទៅ ព្រះអង្គនឹងទៅរីករាយក្នុងស្ថានសួគ៌ ។

[ ៨១៨ ] ( អភិសម្ពុទ្ធគាថា ) ពួកស្ត្រីទាំង ៧០០ ន៎ះ នៅ

ក្មេងៗ ដែលជាកិរិយាចន្ទកុមារ រំសាយកេសា ទួញយំដើរតាមផ្លូវទៅ ។ ចំណែកពួកស្ត្រីឯទៀត ក៏ចេញទៅដោយសេចក្តីសោកស្តាយ រំសាយកេសា ទួញយំដើរតាមផ្លូវទៅ ដូចជាទេវតា ( ហោមរោមទេវបុត្រដែលរៀបច្យុត ) ក្នុងនន្ទវនឧទ្យាន ។

[ ៤១៩ ] ចន្ទកុមារ និងសុរិយកុមារ ទ្រទ្រង់សំពត់ដ៏ស្អាតដែលកើតក្នុងដែនកាសី ជាអ្នកទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យញ្ញនៃព្រះបាទឯករាជ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ ។ ចន្ទកុមារ និងសុរិយកុមារ ដែលជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្ពាន់ព្រះកេសផ្លូតៗ ស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យញ្ញ នៃព្រះបាទឯករាជ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគនូវសាច់ដ៏មានរស ជាអ្នកដែលខ្ពាន់ព្រះកេសផ្លូតៗ ស្អាតហើយ ទ្រទ្រង់

កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្នាន់ព្រះកេសផ្តិតៗ ស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ ។ កាលពីមុន ពួកពលដំរី តែងតាមហែហម នូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងដំរីដ៏ប្រសើរ ថ្ងៃនេះចន្ទកុមារ និងសុរិយកុមារ ទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ពួកពលសេះ តែងតាមហែនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងសេះដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ពួករថ តែងតាមហែនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់ក្នុងកណ្តាលរថដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារ ទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ចន្ទកុមារ និងសុរិយកុមារណា ស្តេចទៅដោយព្រះទីន័ងអស្សតរ ដែលតាក់តែងដោយគ្រឿងមាស ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។

[ ៤២០ ] ( មហាជន ... ) ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរ

អ្នកហើរទៅតាមទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកព្រះរាជបុត្រ ៤ ព្រះអង្គ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកព្រះរាជកញ្ញាទាំង ៤ ព្រះអង្គបូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជកាន់ស្មារតី ទ្រង់យកព្រះមហេសីទាំង ៤ ព្រះអង្គបូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជកាន់ស្មារតី ទ្រង់យកគហបតីទាំង ៤ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកដំរីទាំង ៤ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកសេះទាំង ៤ បូជាយញ្ញ ក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកគោឧសភ ៤ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះ

ព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកសត្វបួនៗ គ្រប់មុខ បូជាយញ្ញក្នុងទីនុ៎ះ ។

[ ៨២១ ] ប្រាសាទនេះជាវិការនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ផ្ទះកំពូលនេះ ជាវិការនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ឧទ្យាននេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃអសោកនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃកណិការនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃប្រទៀងនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃស្វាយនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ស្រះបោក្ខរណីនេះ ដេរដាសពាសពេញដោយផ្កាឈូកស ឈូកក្រហម ទាំងទូកដែលរចនាដោយមាស វិចិត្រដោយភ្ញីវល្លិ៍ជាទីរីករាយចិត្តដោយក្រៃលែង ឥឡូវនេះ ព្រះអយ្យបុត្រ

ទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។

[ ៤២២ ] ដំរីរ័តន៍នេះ ជាដំរីឈ្មោះឯករាវ័ណ មានកម្លាំង មានភ្លុក ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ សេះរ័តន៍នេះ ជាសេះមានក្រចកមួយ មានសម្ទុះរហ័ស ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ រថសេះនេះ មានសូរសព្ទដូចសំឡេងនៃស្រូវសាលី ជារថដ៏ស្អាត វិចិត្រដោយរតនវត្ថុ ជាលម្អរបស់ពួកអយ្យបុត្រ ដូចជាពួកទេវតាក្នុងនន្ទនវ័ន ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ម្តេចក៏ព្រះរាជាកាន់ប្រទ្បំ នឹងបូជាយញ្ញដោយព្រះរាជបុត្រទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ( ឥតទោស ) ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍ ។ ម្តេចក៏ព្រះរាជាកាន់ប្រទ្បំ នឹងបូជាយញ្ញដោយព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍ ។ ម្តេចក៏ព្រះរាជាកាន់ប្រទ្បំ នឹងបូជាយញ្ញដោយព្រះមហេសីទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍ ។ ម្តេចក៏ព្រះរាជាកាន់ប្រទ្បំ នឹងបូជាយញ្ញដោយគហបតីទាំង ៤ នាក់ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត

ដែលមានខ្លួនលាបដោយខ្លឹមចន្ទន៍ ។ ស្រុក និងនិគមទាំងឡាយ សូន្យ ឥតមនុស្ស ក្លាយទៅជាព្រៃធំ យ៉ាងណាមិញ កាលបើចន្ទកុមារ និងសុរិយកុមារ ត្រូវព្រះរាជាយកទៅបូជាយញ្ញហើយ ក្រុងបុប្ផវតី ក៏នឹង ( ស្ងាត់សូន្យឈឹង ) យ៉ាងនោះដែរ ។

[ ៤២៣ ] ( ព្រះនាងគោតមីទេវី ... ) ខ្ញុំម្ចាស់នឹងឆ្កួតសាបសូន្យចាកសេចក្ដីចម្រើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើជនសម្លាប់ចន្ទកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងបែកធ្លាយ ។ ខ្ញុំម្ចាស់នឹងឆ្កួតសាបសូន្យ ចាកសេចក្ដីចម្រើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើជនសម្លាប់សុរិយកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងបែកធ្លាយ ។

[ ៤២៤ ] ស្ត្រីទាំងឡាយនេះ គឺនាងយដ្ឋិកា នាងឧបរិក្ខី នាងបោក្ខរណី នាងគាយិកា ជាអ្នកពោលពាក្យជាទីស្រឡាញ់ទៅរកគ្នានិងគ្នា ម្ដេចក៏មិនរាំ ឲ្យចន្ទកុមារ និងសុរិយកុមារសប្បាយរីករាយ ( ព្រោះស្ត្រីដទៃ ) ស្មើដោយស្ត្រីទាំងនោះមិនមានទេ ។

[ ៤២៥ ] សេចក្ដីសោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្ដាយអ្នកឯង ចូរទទួលយកសេចក្ដីសោក ក្នុងហឫទ័យនៃអញនេះទៅចុះ ។ សេចក្ដីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្ដាយ

អ្នកឯង ចូរទទួលយកសេចក្តីសោក ក្នុងហឫទ័យនៃអញនេះទៅចុះ ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង ចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារដែលគេនាំយកទៅសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធរបស់អ្នកចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯងកុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារដែលសត្វលោកទាំងអស់ អាឡោះអាល័យ នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសត្វលោកទាំងអស់ អាឡោះអាល័យ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ ។

[ ៤២៦ ] ( ចន្ទកុមារ ... ) បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះ

អន្តទាំងឡាយឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយឃ្វាលដំរី និងសេះ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយចោលអាចម៍ដំរី ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាល-ព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយចោលអាចម៍សេះ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំឡើយ បើព្រះអង្គសព្វព្រះហឫទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌាលព្រាហ្មណ៍នោះចុះ ពុំនោះសោតសូមព្រះអង្គបំបរបង់ឲ្យចេញចាកដែន ខ្ញុំព្រះអង្គនឹងត្រាច់ទៅកាន់ភិក្ខាចារ ។ បពិត្រព្រះសម្មតិទេព នារីពួកខ្លះ សូមឲ្យជាស្ត្រីកម្សត់ នៅតែចង់បានកូន ហើយបន់ស្រន់ទេព្តា ស៊ូលះបង់ចំណង់ប្លែក នៅតែមិនបានកូនទាំងឡាយ ក៏មាន ។ នារីពួកខ្លះ ធ្វើពាក្យប្រកបដោយសេចក្ដីប៉ុនប៉ងថា កូនទាំងឡាយរបស់យើង ចូរកើតបន្ទាប់ពីនោះ ចៅទាំងឡាយ ចូរកើតទៀត បពិត្រព្រះសម្មតិទេព កាល

បើដូច្នេះ ( ហេតុអ្វីក៏ ) ព្រះអង្គសម្លាប់ទូលព្រះបង្គំទាំងឡាយ ដើម្បីបូជាយញ្ញ ដោយមិនសមហេតុ ។ ពួកស្ត្រី តែងបានកូន ដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំ ទាំងឡាយឡើយ ព្រះអង្គកុំបូជាយញ្ញនេះ ដោយបុត្រទាំងឡាយ ដែលបានដោយលំបាកឡើយ ។ ពួកស្ត្រី តែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមព្រះអង្គកុំញ៉ាំង ទូលព្រះបង្គំទាំងឡាយ ឲ្យព្រាត់ប្រាសចាកមាតា និងបុត្រទាំងឡាយ ដែលបានដោយលំបាក ។

[ ៤២៧ ] បពិត្រព្រះមាតា ព្រះអង្គបានបង្កើតបុត្រ គឺចន្ទកុមារមក មានទុក្ខព្រួយច្រើនណាស់ ព្រោះតែការចិញ្ចឹម ខ្ញុំជាកូនសូមក្រាបថ្វាយបង្គំព្រះបាទានៃព្រះមាតា សូមឲ្យព្រះរាជបិតាបានទៅបរលោក ( ដែលបរិបូណ៌ដោយសម្បត្តិ ) ចុះ ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងទៅកាន់ទីព្រាត់ប្រាស ដើម្បីប្រយោជន៍ដល់យញ្ញរបស់ព្រះបាទឯករាជ ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្តីសោកក្នុងហឫទ័យនៃព្រះមាតា ហើយទៅកាន់ទីព្រាត់ប្រាស ។ បពិត្រ

ព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាត ឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្ដីសោក ក្នុងហឫទ័យនៃជន ហើយទៅកាន់ទីព្រាត់ប្រាស ។

[ ៤២៨ ] ( ព្រះមាតា ... ) ម្នាលគោតមីបុត្រ ណ្ហើយចុះ បាឯង ចូរបួងមោលីដោយស្លឹកឈូក បាឯងចូរប្រដាប់ផ្កាកម្រង ដែល លាយដោយត្របកផ្កាចម្ប៉ា នេះជាប្រក្រតីពីដើមរបស់បា ។ ហក បាឯងធ្លាប់លាបស្រឡាប ដោយខ្លឹមចន្ទន៍ទាំងឡាយណា ហើយ ល្អរុងរឿងក្នុងរាជបរិស័ទ ( នេះ ) ជាគ្រឿងលាបរបស់បា បា ចូរលាបខ្លឹមចន្ទន៍ជាទីបំផុតចុះ ។ ហក បាឯងស្លៀកដណ្ដប់សំពត់ ទាំងឡាយណា មានសាច់ទន់ៗ រមែងល្អរុងរឿងក្នុងរាជបរិស័ទ ( នេះ ) ជាសំពត់មានសាច់ទន់ បាចូរស្លៀកសំពត់ដែលកើតក្នុង ដែនកាសី មានក្នុងទីបំផុតចុះ ។ បាឯងល្អរុងរឿងដោយហត្ថា- ករណៈណាក្នុងរាជបរិស័ទ បាចូរពាក់នូវហត្ថាករណៈដ៏ហើយ ដោយកែវមុក្តា កែវមណី និងមាស ( នោះ ) ចុះ ។

[ ៤២៩ ] ( នាងចន្ទាទេវី ... ) ព្រះបាទឯករាជនេះ ជាអ្នករក្សា ដែន ជាម្ចាស់ផែនដី ជាអ្នកទទួលមត៌ករបស់អ្នកជនបទ ជាឥស្សរៈ លើលោក ទ្រង់ជាធំ តែមិនញុំាងសេចក្ដីស្នេហាឲ្យកើតក្នុងព្រះ រាជបុត្រដោយពិត ។

[ ៤៣០ ] ( ព្រះបាទឯករាជ ... ) បុត្រប្រុសទាំងឡាយជាទី

ស្រឡាញ់របស់អញ ម្យ៉ាងទៀត នាងឯងក្តី កិរិយាទាំងឡាយ ( ឯទៀត ) ក្តី ក៏ជាទីស្រឡាញ់របស់អញ ប៉ុន្តែអញចង់បាន ស្ថានសួគ៌ទេតើ បានជាអញឲ្យគេសម្លាប់ដោយហេតុនោះ ។

[ ៤៣១ ] ( នាងចន្ទាទេវី ... ) បពិត្រព្រះសម្មតិទេព សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់មុន កុំឲ្យសេចក្តីទុក្ខបំបែកហឫទ័យខ្ញុំម្ចាស់ឡើយ បពិត្រព្រះសម្មតិទេព បុត្ររបស់ព្រះអង្គជាអ្នកមានគ្រឿងអលង្ការប្រដាប់ហើយ ជាបុត្រល្អល្អះ ជាសុខុមាលជាតិ ។ បពិត្រព្រះអង្គជាម្ចាស់គេ ណ្ហើយចុះ សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់ជាស្ត្រីមានសេចក្តីសោកជាមួយគ្នានឹងចន្ទកុមារ សូមព្រះអង្គធ្វើបុណ្យឲ្យបរិបូណ៌ចុះ យើងខ្ញុំទាំងពីរនាក់នឹងត្រាច់ទៅក្នុងបរលោក ។

[ ៤៣២ ] ( ព្រះបាទឯករាជ ... ) ម្នាលនាងចន្ទា មានភ្នែកវិសេសវិសាល នាងកុំយំឡើយ ជនទាំងឡាយជាបងប្អូនខាងប្តីរបស់នាងជាច្រើន ជនទាំងនោះ នឹងញុំាងនាងឲ្យត្រេកអរ ព្រោះគោតមីបុត្រ ត្រូវគេបូជាយញ្ញហើយ ។

[ ៤៣៣ ] ( អភិសម្ពុទ្ធគាថា ) កាលបើព្រះបាទឯករាជ ទ្រង់ត្រាស់យ៉ាងនេះហើយ នាងចន្ទាទេវី ប្រហារខ្លួនឯងដោយបាតដៃទាំងឡាយ ( ទ្រង់ពិលាបថា ) ការរស់នៅក្នុងលោកនេះ ល្មមប៉ុណ្ណឹងហើយ អញនឹងផឹកថ្នាំពិសឲ្យស្លាប់ ។ ព្រោះថា ជនទាំង

ឡាយជាញាតិមិត្រ ជាសម្លាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយ ហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រទាំងឡាយ ដែលកើតអំពីព្រះឱរសដូច្នេះឡើយ ។ ជនទាំងឡាយជាញាតិមិត្រ ជាសម្លាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយ ហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រ ដែលកើតអំពីព្រះអង្គដូច្នេះឡើយ ។ បុត្ររបស់ខ្ញុំម្ចាស់ទាំងឡាយនេះ ពាក់កម្រងផ្កា ទ្រទ្រង់គ្រឿងប្រដាប់ ជាវិការនៃមាស សូមព្រះរាជាបូជាយញ្ញ ដោយរាជបុត្រទាំងឡាយចុះ ប៉ុន្តែសូមព្រះអង្គលែងគោតមីបុត្ត ។ បពិត្រមហារាជ សូមព្រះអង្គកាប់ខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បងដែលជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត ។ បពិត្រមហារាជ សូមព្រះអង្គចិញ្ច្រាំខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បង ដែលសត្វលោកទាំងអស់អាឡោះអាល័យឡើយ ។

[ ៤៣៤ ] ( ចន្ទកុមារ ... ) គ្រឿងអាភរណៈច្រើនយ៉ាង គឺកែវមុក្តា កែវមណី កែវពៃទូរ្យដែលប្រសើរ និងមិនប្រសើរ យើងឲ្យហើយដល់នាង ក្នុងរឿងដែលនាងនិយាយល្អហើយ នេះជាអំណោយទីបំផុត ចូរមានដល់នាងចុះ ។

[ ៤៣៥ ] ( នាងចន្ទាទេវី ... ) កាលពីដើម រាជបុត្រទាំងឡាយណា ដែលមានកម្រងផ្កាកិសំពោង ពាក់ហើយលើកទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវដែលគេសំលៀងមុត នឹងធ្លាក់លើកទាំងឡាយវិញ ។ ពីដើមព្រះរាជបុត្រទាំងឡាយណា ដែលមានកម្រងផ្កាដ៏វិចិត្រហើយ ពាក់លើកទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្តទាំងនោះ ត្រឡប់ទៅជាមានដាវដែលគេសំលៀងមុត នឹងធ្លាក់លើកទាំងឡាយវិញ ។ មិនយូរប៉ុន្មានទេ មុខតែដាវនឹងធ្លាក់លើកនៃរាជបុត្រទាំងឡាយពុំខាន ហឫទ័យរបស់ខ្ញុំម្ចាស់ ខានបែកធ្លាយឯណាបាន ព្រោះចំណងយ៉ាងមាំមានដល់ខ្ញុំម្ចាស់ហើយ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់សាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅដើម្បីយញ្ញនៃព្រះបាទឯករាជចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់ មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរចេញទៅចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តី

សោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជន ដែលលាយដោយសាច់ មានរស ជាអ្នកដែលពួកអ្នកផ្លូតៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅដើម្បីយញ្ញរបស់ព្រះបាទឯករាជចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជន ដែលលាយដោយសាច់ មានរស ជាអ្នកដែលពួកអ្នកផ្លូតៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរស្តេចចេញទៅចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជន ដែលលាយដោយសាច់ មានរស ជាអ្នកដែលពួកអ្នកផ្លូតៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ ។

[ ៤៣៦ ] ( អភិសម្ពុទ្ធគាថា ) កាលបើគ្រឿងប្រដាប់បូជាយញ្ញគ្រប់យ៉ាង ដែលគេចាត់ចែងហើយ កាលបើចន្ទកុមារ និងសុរិយកុមារ អន្ទុយដើម្បីប្រយោជន៍ដល់យញ្ញហើយ នាងបញ្ចាលរាជធីតា លើកកម្បង់អញ្ជលី ដើរចូលទៅត្រង់ចន្លោះពួកបរិស័ទទាំងពួង ( ប្រកាសថា ) ខណ្ឌហាលព្រាហ្មណ៍ ជាមនុស្សយល់ខុស ធ្វើបាបកម្ម ដោយពាក្យសច្ចៈណា ខ្ញុំម្ចាស់

ព្រមព្រៀងជាមួយនឹងព្រះស្វាមីតាមពាក្យសច្ចៈនុ៎ះ ។ ពួកអមនុស្ស ពួកទេវតា និងពួកសត្វកើតហើយ និងសត្វដែលត្រូវកើតមាន ក្នុងទីនេះ ចូរធ្វើនូវសេចក្តីខ្វល់ខ្វាយចំពោះខ្ញុំ ខ្ញុំសូមព្រមព្រៀង ( ជាមួយ ) នឹងព្រះស្វាមីហើយ ។ ពួកទេវតា ពួកសត្វកើត ហើយ និងសត្វដែលត្រូវកើតទាំងអស់ ដែលមកក្នុងទីនេះ សូម អ្នកទាំងឡាយរក្សាខ្ញុំ ជាមនុស្សអនាថា ដែលស្វែងរកទីពឹង ខ្ញុំ សូមអង្វរព្រះស្វាមី ដែលពួកបច្ចាមិត្តផ្ចាញ់មិនបានចំពោះលោក ទាំងឡាយ ។

[ ៤៣៧ ] អមនុស្ស ( សក្កទេវរាជ ) ឮពាក្យនោះហើយ ក៏ គ្រវីដំបងដែកបំភ័យព្រះរាជានោះ ហើយនិយាយនឹងព្រះរាជា ដូច្នេះថា ម្នាលស្តេចកាឡកិណី ព្រះអង្គចូរដឹងចុះ កុំឲ្យខ្ញុំសំពង ក្បាលព្រះអង្គឡើយ ព្រះអង្គកុំសម្លាប់បុត្រច្បង ជាអ្នកអង់អាច ដូចសីហៈ ជាអ្នកមិនប្រទូស្ត ។ ម្នាលស្តេចកាឡកិណី ព្រះអង្គ ធ្លាប់ឃើញអ្នកណាដែលសម្លាប់បុត្រភរិយា និងសេដ្ឋីគហបតី ជា អ្នកមិនប្រទូស្ត ព្រោះប្រាថ្នាស្ថានសួគ៌ ។

[ ៤៣៨ ] ខណ្ឌហាលព្រាហ្មណ៍បានឮពាក្យនោះ ទាំងព្រះរាជា ក៏ឃើញសក្កទេវរាជ ដែលព្រះអង្គមិនធ្លាប់ឃើញនេះ ទើបឲ្យ ស្រាយចំណងអំពីជនទាំងពួង ឲ្យដូចជាមិនមានសេចក្តីបៀតបៀន ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួក

ជនដែលមកប្រជុំក្នុងកន្លែងនោះ ក៏នាំគ្នាគប់មួយដុំដីៗ ម្នាក់ នេះជាការសម្លាប់ខណ្ឌហាលព្រាហ្មណ៍ ។

[ ៤៣៩ ] ពួកជនទាំងពួង ធ្វើបាបកម្មហើយ ទៅកាន់នរកយ៉ាងណា ពួកជនមិនធ្វើបាបកម្មហើយ ទៅអំពីលោកនេះទៅ គប្បីបាននូវសុគតិយ៉ាងនោះឯង ។

[ ៤៤០ ] កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបុរស មកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិ-សេកចន្ទកុមារ ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបរិស័ទដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំ

គ្នាលើកទង់សំពត់ ។ កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នា លើកទង់សំពត់ ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ពួកជនជាច្រើន ត្រេកអររីករាយ ប៉ាវគងទូងអានន្ទភេរី ក្នុងកាល ដែលចន្ទកុមារចូលទៅក្នុងនគរ ពួកជនបានប្រកាសការរួចចាក ចំណង ( របស់ពួកសត្វ ) ។

**ចន្ទកុមារជាតកទី ៧ ចប់**

# អដ្ឋកថា

## ចន្ទកុមារជាតក

[ ៣៨២-៤៤០ ] ព្រះសាស្តា កាលគង់នៅត្រង់ភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធ ភិក្ខុទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **រាជាសិ លុទ្ទកកម្មោ** ដូច្នេះជាដើម ។

រឿងរបស់ទេវទត្តនោះ មកហើយក្នុងសង្ឃភេទក្ខន្ធកៈនោះឯង ។ រឿងនោះ ចាប់តាំងពីពេលដែលលោកចេញបួសហើយ ដរាបដល់ការសោយទិវង្គតរបស់ព្រះបាទពិម្ពិសារ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងទីនោះៗ ឯង ។

ឯទេវទត្ត កាលឲ្យផ្តាច់ព្រះជន្មព្រះបាទពិម្ពិសារហើយ ក៏ទៅគាល់ព្រះបាទអជាតសត្តុ ទូលថា បពិត្រមហារាជ មនោរថរបស់ទ្រង់ ដល់ទីបំផុតហើយ ចំណែកមនោរថរបស់អាត្មា មិនទាន់ដល់ទីបំផុតឡើយ ។ ព្រះរាជាបានស្តាប់ដូច្នោះ ទើបត្រាស់សួរថា បពិត្រលោកម្ចាស់ មនោរថរបស់លោកម្ចាស់ដូចម្តេច ទេវទត្តទូលថា បពិត្រមហារាជ បើសម្លាប់ព្រះទសពលហើយ អាត្មានឹងធ្វើជាព្រះពុទ្ធ មិនមែនឬ ព្រះរាជាត្រាស់សួរថា ក្នុងរឿងនេះ ខ្ញុំគួរធ្វើដូចម្តេច ទេវទត្តទូលថា បពិត្រមហារាជ គួរឲ្យនាយខ្មាន់ធ្នូទាំងឡាយប្រជុំគ្នា ។ ព្រះរាជាទ្រង់ទទួលថា សាធុ ទើបឲ្យប្រជុំនាយខ្មាន់ធ្នូ ដែលជាអ្នកបាញ់មិនខុសទាំង ៥០០ ត្រកូល ហើយទ្រង់ចម្រាញ់យកតែ ៣១ នាក់ ត្រាស់ថា នែបាទាំងឡាយ ចូរពួកអ្នកធ្វើតាមពាក្យរបស់ព្រះថេរៈ ដូច្នេះហើយ ទើបបញ្ជូនទៅកាន់សម្នាក់ទេវទត្ត ។ ទេវទត្តហៅខ្មាន់ធ្នូដែលជាធំ ក្នុងបណ្តា

ខ្មាន់ធ្នូទាំងនោះមកហើយ ប្រាប់យ៉ាងនេះថា អាវុសោ ព្រះសមណគោតម គង់នៅត្រង់ភ្នំគិជ្ឈកូដ ទ្រង់ចង្រ្កមក្នុងទីសម្រាកពេលថ្ងៃក្នុងទីនោះ ចូរឯង ទៅក្នុងទីនោះ បាញ់ព្រះសមណគោតមដោយព្រួញដែលលាបដោយថ្នាំពិស ឲ្យអស់ព្រះជន្មហើយ ចូរត្រឡប់មកតាមផ្លូវឈ្មោះនោះ កាលទេវទត្តបញ្ជូន នាយខ្មាន់ធ្នូដែលជាធំទៅហើយ ទើបប្រាប់ខ្មាន់ធ្នូ ២ នាក់ ឲ្យទៅពួនត្រង់ផ្លូវ នោះ ប្រាប់ថា មានបុរសម្នាក់ចុះមកតាមផ្លូវដែលពួកឯងឈរ ចូរពួកឯង បាញ់បុរសនោះសម្លាប់ចោល ហើយចុះមកតាមផ្លូវឈ្មោះនោះ ។ ទេវទត្ត បញ្ជូនបុរស ៤ នាក់ ទៅត្រង់ផ្លូវនោះ ប្រាប់ថា ក្នុងផ្លូវដែលពួកឯងឈរ នឹង មានបុរស ២ នាក់ដើរមក ចូរឯងផ្តាច់ជីវិតបុរស ២ នាក់នោះ ហើយចុះ មកតាមផ្លូវឈ្មោះនោះ រួចហើយបញ្ជូនខ្មាន់ធ្នូ ៨ នាក់ទៅ ដោយប្រាប់ថា ក្នុងផ្លូវដែលពួកឯងឈរស្កាត់នោះ មានបុរស ៤ នាក់ចុះមក ចូរពួកឯង សម្លាប់បុរសទាំង ៤ នាក់នោះចោល ហើយចុះមកតាមផ្លូវឈ្មោះនោះ ។ ក្នុង ផ្លូវនោះ ទេវទត្តបញ្ជូនខ្មាន់ធ្នូ ១៦ នាក់ទៅចាំស្កាត់ ហើយប្រាប់ថា ផ្លូវដែល ពួកឯងឈរចាំនោះ នឹងមានមនុស្ស ៨ នាក់ចុះមក ចូរពួកឯងផ្តាច់ជីវិត បុរស ៨ នាក់នោះ ហើយចុះមកតាមផ្លូវឈ្មោះនោះ ។ សួរថា ព្រោះហេតុអ្វី ទើបទេវទត្តធ្វើយ៉ាងនោះ ឆ្លើយថា ព្រោះដើម្បីបិទបាំងកម្មអាក្រក់របស់ខ្លួន បានឮថា ទេវទត្តបានធ្វើដូច្នោះ ដើម្បីបិទបាំងអំពើលាមករបស់ខ្លួន ។

លំដាប់នោះ ខ្មាន់ធ្នូដែលជាធំ ស្ពាយដាវខាងឆ្វេង ស្ពាយបំពង់ព្រួញ ខាងខ្នង ចាប់ធ្នូធំដែលធ្វើដោយស្នែងកែះ ទៅកាន់សម្នាក់ព្រះតថាគត ហើយ

លើកធ្នូឡើងដោយសញ្ញាថា អញនឹងបាញ់ព្រះសមណគោតម ដូច្នេះ ទើបផ្ទាប់នូវកាំស ទាញខ្សែដើម្បីបាញ់ ក៏មិនអាចបាញ់បាន ។ ព្រះសាស្ដាឲ្យខ្មាន់ធ្នូយឹតធ្នូបាន តែមិនឲ្យបាញ់បាន ។ នាយខ្មាន់ធ្នូជាធំនោះ កាលមិនអាចបាញ់បានក្ដី មិនអាចទម្លាក់ចុះក្ដី ក៏ដល់នូវសេចក្ដីលំបាក ព្រោះឆ្អឹងជំនីរទាំង ២ ហាក់ដូចជាបាក់ ទឹកមាត់ក៏ហូរចេញអំពីមាត់ ។ រាងកាយទាំងមូលក៏រឹង ដល់នូវអាការដូចគ្រឿងយន្តកៀប នាយខ្មាន់ធ្នូនោះ ត្រូវមរណភ័យគំរាម ហើយឈរ ។

លំដាប់នោះ ព្រះសាស្ដាទតឃើញដូច្នេះហើយ ទ្រង់បន្លឺដោយសំឡេងពីរោះ ត្រាស់លួងលោមនាយខ្មាន់ធ្នូថា នែបុរសល្ងង់ខ្លៅ អ្នកកុំខ្លាចឡើយ ចូរមកទីនេះចុះ ។ ខណៈនោះ ខ្មាន់ធ្នូក៏ទម្លាក់អាវុធ ក្រាបចុះដោយសិរសាទៀបព្រះបាទាព្រះសាស្ដា ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទោសបានគន្លងខ្ញុំព្រះអង្គហើយ ព្រោះជាអ្នកល្ងង់ខ្លៅ ជាអ្នកវង្វេង ជាបុគ្គលបាប ខ្ញុំព្រះអង្គមិនបានស្គាល់គុណរបស់ទ្រង់ ទើបមកហើយ ដើម្បីផ្ដាច់ព្រះជន្មរបស់ព្រះអង្គ តាមពាក្យប្រៀនប្រដៅរបស់ទេវទត្តដែលជាអន្ធពាល បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់អត់ទោសដល់ខ្ញុំព្រះអង្គ បពិត្រព្រះសុគត សូមទ្រង់អត់ទោសដល់ខ្ញុំព្រះអង្គ បពិត្រព្រះលោកវិទូ សូមទ្រង់អត់ទោសដល់ខ្ញុំព្រះអង្គ ។ កាលព្រះសាស្ដាទ្រង់អត់ទោសឲ្យហើយ ក៏អង្គុយក្នុងទីបំផុតនាចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្ដាកាលទ្រង់ប្រកាសសច្ចៈទាំងឡាយ ញុំាងនាយខ្មាន់ធ្នូឲ្យតាំងនៅក្នុងសោតាបត្តិផល ហើយទូន្មានថា ម្នាលឧបាសក អ្នកកុំចុះទៅ

តាមផ្លូវដែលទេវទត្តប្រាប់ឡើយ ចូរចុះទៅតាមផ្លូវដទៃ ហើយទ្រង់បញ្ជូននាយខ្មាន់ធ្នូនោះទៅ ។ កាលទ្រង់បញ្ជូននាយខ្មាន់ធ្នូទៅហើយ ទ្រង់យាងចុះអំពីទីចង្ក្រម គង់ត្រង់គល់ឈើមួយដើម ។

លំដាប់នោះ កាលខ្មាន់ធ្នូជាធំ មិនបានត្រឡប់មក ខ្មាន់ធ្នូដែលរង់ចាំ ២ នាក់ទៀត គិតថា ហេតុអ្វី ទើបមិនឃើញហ្ន៎ ក៏ធ្វើដំណើរឡើងទៅ កាលឃើញព្រះទសពល ក៏ចូលទៅថ្វាយបង្គំ ហើយអង្គុយក្នុងទីបំផុតនាចំណែកម្ខាង ។ ព្រះសាស្តា ទ្រង់ប្រកាសអរិយសច្ចដល់ជនទាំង ២ ឲ្យតាំងនៅក្នុងសោតាបត្តិផល ហើយត្រាស់ទូន្មានថា ម្នាលឧបាសក ចូរអ្នកកុំទៅតាមផ្លូវដែលទេវទត្តប្រាប់ ចូរទៅតាមផ្លូវនេះ ហើយទ្រង់បញ្ជូនទៅ ដោយឧបាយនេះទ្រង់ប្រកាសអរិយសច្ចដល់នាយខ្មាន់ធ្នូក្រៅអំពីនេះដែលមកដល់ ឲ្យតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់បញ្ជូនទៅកាន់ផ្លូវដទៃទាំងអស់ ។

លំដាប់នោះ ខ្មាន់ធ្នូដែលជាធំនោះ ត្រឡប់មកដល់មុន ក៏ចូលទៅរកទេវទត្ត ពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនអាចផ្តាច់ព្រះជន្មព្រះសម្មាសម្ពុទ្ធបានឡើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់មានឫទ្ធិធំក្រៃលែង ទ្រង់មានអានុភាពធំក្រៃលែង ចំណែកនាយខ្មាន់ធ្នូទាំងនោះ គិតថា យើងទាំងអស់អាស្រ័យព្រះសម្មាសម្ពុទ្ធ ទើបរស់រានមានជីវិត ក៏ចេញបួសក្នុងសម្នាក់ព្រះសាស្តា សម្រេចអរហត្តគ្រប់អង្គ ។

រឿងនេះ បានប្រាកដក្នុងភិក្ខុសង្ឃ ភិក្ខុទាំងឡាយអង្គុយសន្ទនាក្នុងធម្មសភាថា អាវុសោ បានឮថា ទេវទត្តធ្វើនូវសេចក្តីព្យាយាមដើម្បីផ្តាច់

ជីវិតជនច្រើនគ្នា ព្រោះចងពៀរក្នុងព្រះសាស្ដាតែមួយអង្គ តែជនទាំងនោះអាស្រ័យព្រះសាស្ដា បានរួចជីវិតទាំងអស់ ។ ចំណែកព្រះសាស្ដាយាងមកចាកទីផ្ទុំដ៏ប្រសើរ ទ្រង់បានឮពាក្យរបស់ភិក្ខុទាំងឡាយនោះ ដោយព្រះសោតធាតុដ៏ជាទិព្វ យាងមកកាន់ធម្មសភា ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ធ្វើសេចក្ដីព្យាយាម ដើម្បីសម្លាប់មហាជន ព្រោះអាស្រ័យតថាគតម្នាក់ ព្រោះចិត្តមានពៀរក្នុងតថាគត ដូច្នេះហើយ ទ្រង់ក៏គង់ស្ងៀម កាលភិក្ខុទាំងនោះអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅ

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ក្រុងពារាណសីនេះ មានឈ្មោះថា បុប្ផវតី ព្រះរាជឱរសរបស់ព្រះបាទវសវតី ព្រះនាមឯករាជ បានគ្រងរាជសម្បត្តិក្នុងនគរនោះ ។ ព្រះរាជឱរសរបស់ព្រះអង្គ ព្រះនាមចន្ទកុមារ តាំងនៅក្នុងតំណែងជាឧបរាជ ។ ព្រាហ្មណ៍ឈ្មោះខណ្ឌហាល ជាបុរោហិត ។ ព្រាហ្មណ៍ថ្វាយអនុសាសន៍ អត្ថ និងធម៌ដល់ព្រះរាជា បានឮថា ព្រះរាជាកាលទ្រង់ស្ដាប់ថា ខណ្ឌហាលជាបណ្ឌិត ក៏ទ្រង់ឲ្យតាំងនៅក្នុងនាទីជាអ្នកវិនិច្ឆ័យក្ដី ។ ខណ្ឌហាលព្រាហ្មណ៍នោះ ជាអ្នកមានចិត្តប្រាថ្នាក្នុងសំណូក កាលទទួលសំណូកហើយ ក៏កាត់ក្ដីឲ្យបុគ្គលដែលមិនមែនជាម្ចាស់ទ្រព្យ ឲ្យបានជាម្ចាស់ទ្រព្យ បុគ្គលជាម្ចាស់ទ្រព្យ ឲ្យមិនមែនជាម្ចាស់ទ្រព្យ ។ ថ្ងៃមួយ

មានបុរសចាញ់ក្តីម្នាក់ដើរប្រទេចក្នុងទីវិនិច្ឆ័យក្តី កាលចេញមកខាងក្រៅ ឃើញព្រះចន្ទកុមារចេញមកកាន់ទីគាល់ព្រះរាជា ក្រាបចុះទៀបបាទា ហើយយំ ព្រះចន្ទកុមារសួរថា នែបុរស តើមានរឿងអ្វី ។ បុរសនោះទូលថា ខណ្ឌហាលនេះប្លន់ខ្ញុំដោយការកាត់ក្តី កាលគេទទួលសំណូកហើយ ធ្វើឲ្យខ្ញុំចាញ់ក្តី ។ ព្រះចន្ទកុមារត្រាស់ថា កុំខ្លាចឡើយ ដូច្នេះហើយ ក៏ទ្រង់នាំបុរសនោះទៅកាន់ទីវិនិច្ឆ័យក្តី ធ្វើអ្នកជាម្ចាស់ទ្រព្យនោះឯង ឲ្យជាម្ចាស់ទ្រព្យ បុគ្គលមិនមែនម្ចាស់ទ្រព្យ ឲ្យមិនមែនជាម្ចាស់ទ្រព្យ ។ មហាជននាំគ្នាឲ្យសាធុការ ដោយសំឡេងខ្លាំង ។ ព្រះរាជាទ្រង់បានស្តាប់សំឡេងនោះ ទើបត្រាស់សួរថា នុ៎ះជាសំឡេងអ្វី មានអ្នកប្រាប់ថា បពិត្រសម្មតិទេព បានឮថា ក្តីដែលព្រះចន្ទកុមារកាត់ហើយ ប្រកបដោយធម៌ សំឡេងនោះ គឺសំឡេងសាធុការរបស់មហាជន ។ ព្រោះសំឡេងនោះ ព្រះរាជាក៏មានបីតិ ។

ព្រះចន្ទកុមារយាងមកថ្វាយបង្គំព្រះរាជបិតាហើយ ក៏គង់ប្រថាប់ក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះ ព្រះរាជាក៏ត្រាស់នឹងព្រះចន្ទកុមារថា នែបា បានឮថា ឯងកាត់ក្តីរឿងមួយឬ ព្រះចន្ទកុមារទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំកាត់រឿងមួយ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ តាំងអំពីនេះទៅ ចូរបាញ៉ាំងការកាត់ក្តីឲ្យប្រព្រឹត្តទៅចុះ ហើយទ្រង់ប្រទាននាទីវិនិច្ឆ័យដល់ព្រះរាជកុមារ ។ ផលប្រយោជន៍របស់ខណ្ឌហាលព្រាហ្មណ៍ ក៏ដាច់ទៅ គាត់ចងអាឃាត ជាអ្នកសម្លឹងទោស ចាប់កំហុសក្នុងព្រះចន្ទកុមារតាំងអំពីនោះមក ។

ព្រះរាជាជាអ្នកមានបញ្ញាទន់ខ្សោយ ថ្ងៃមួយ ក្នុងវេលាទៀបភ្លឺ ទ្រង់បានសុបិនឃើញថា បានឃើញតាវត្តិង្សពិភព មានខ្លោងទ្វារប្រដាប់ហើយ មានកំពែងសម្រេចដោយកែវ ៧ ប្រការ ប្រកបដោយវិថី មានខ្សាច់មាស ទំហំប្រមាណ ៦០ យោជន៍ ប្រដាប់ដោយវេជយន្តប្រាសាទ កម្ពស់ ១០០០ យោជន៍ ជាទីត្រេកអរទៅដោយសួនច្បារ មាននន្ទវនឧទ្យានជាដើម មានស្រះបោក្ខរណីជាទីត្រេកអរ មាននន្ទបោក្ខរណីជាដើម មានពួកទេវតាកុះករ និងទេពអប្សរជាច្រើន រាំ ច្រៀង ប្រគំតន្ត្រី ក្នុងវេជយន្តប្រាសាទ ក្នុងស្ថានតាវត្តិង្សនោះ ។ ព្រះរាជាបានឃើញដូច្នោះ កាលទ្រង់ភ្ញាក់ពីបន្ទំ ប្រាថ្នានឹងចូលទៅកាន់កពនោះ ទើបទ្រង់ព្រះតម្រិះថា ថ្ងៃនេះ ក្នុងពេលដែលអាចារ្យខណ្ឌហាលមកគាល់ អញនឹងសួរដល់ផ្លូវ ដែលជាទីទៅកាន់ទេវលោក ហើយអញនឹងទៅកាន់ទេវលោក ដោយផ្លូវដែលអាចារ្យប្រាប់នោះ ។ ព្រះរាជាទ្រង់ស្រពស្រង់អំពីព្រលឹម ទ្រង់ជណ្តប់ព្រះកូសា ទ្រង់សោយភោជនីយាហារមានរសដ៏ប្រសើរផ្សេងៗ ទ្រង់លាបនូវគ្រឿងក្រអូប ហើយប្រថាប់គង់ ចំណែកខណ្ឌហាលព្រាហ្មណ៍ ងូតទឹកពីព្រលឹម ស្លៀកសំពត់ បរិភោគអាហារ បានលាបនូវគ្រឿងក្រអូប ហើយទៅកាន់ទីបម្រើព្រះរាជា ចូលទៅកាន់ព្រះរាជនិវេសន៍ ហើយទូលសួរដល់ការផ្ទំជាសុខរបស់ព្រះរាជា ។ គ្រានោះ ព្រះរាជាប្រទានអាសនៈដល់ខណ្ឌហាលព្រាហ្មណ៍នោះហើយ ទើបទ្រង់សួរបញ្ហា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ

បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួចសួរនូវព្រះគាថាដូច្នេះថា

ព្រះបាទឯករាជ អ្នកមានអំពើអាក្រក់ នៅក្នុងក្រុងបុប្ផវតីនោះ សួរកផ្លូវទៅព្រហ្មលោក នឹងបុរោហិតឈ្មោះខណ្ឌហាល ជាពូជពង្សព្រហ្ម ជាមនុស្សល្ងង់វង្វេងថា ម្នាលព្រាហ្មណ៍ អ្នកជាមនុស្សឈ្លាសក្នុងធម៌វិន័យ សូមអ្នកប្រាប់ផ្លូវស្ថានសួគ៌ តាមទំនងដែលពួកជនធ្វើបុណ្យទាំងឡាយ ហើយចេញចាកលោកនេះ ទៅកាន់សុគតិ ដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **រាជាសិ** កាត់បទជា **រាជា អាសិ**។ បទថា **លុទ្ទកកម្មោ** បានដល់ ជាអ្នកមានកម្មគ្រោតគ្រាត ។ បទថា **សគ្គានមគ្គំ** សេចក្ដីថា ផ្លូវនៃស្ថានសួគ៌ ។ បទថា **ធម្មវិនយកុសលោ** សេចក្ដីថា ជាអ្នកឈ្លាសក្នុងធម៌ គឺសុចរិត និងវិន័យ គឺមារយាទ ។ ដោយបទថា **យថា** នេះ ព្រះរាជាត្រាស់សួរថា ដូចមនុស្សទាំងឡាយធ្វើនូវបុណ្យហើយ ចាកលោកនេះ ទៅកាន់សុគតិ ដោយប្រការណា ចូរអ្នកប្រាប់ផ្លូវសុគតិដល់ខ្ញុំ ដោយប្រការនោះ ។ បញ្ហានេះ ព្រះរាជាគួរសួរព្រះសម្មាសម្ពុទ្ធ ឬសាវ័កនៃព្រះសព្វញ្ញុពុទ្ធ បើមិនបានព្រះសព្វញ្ញុពុទ្ធ ឬសាវ័ករបស់ព្រះសព្វញ្ញុពុទ្ធ គួរសួរព្រះពោធិសត្វ តែព្រះរាជាបែរជាសួរខណ្ឌហាលព្រាហ្មណ៍ ដែលមិនដឹងអ្វីសោះ ដូចបុរសវង្វេងផ្លូវ ៧ ថ្ងៃ សួរកផ្លូវនឹងអ្នកដែលវង្វេងផ្លូវកន្លះថ្ងៃ ដូច្នោះ ។

ខណ្ឌហាលព្រាហ្មណ៍គិតថា ពេលនេះ ជាពេលដែលអញបានឃើញខ្នងសត្រូវរបស់អញរបស់ហើយ ឥឡូវនេះ អញនឹងធ្វើចន្ទកុមារឲ្យដល់នូវការអស់ជីវិត ធ្វើមនោរថរបស់អញឲ្យសម្រេច ។ កាលនោះ ខណ្ឌហាលព្រាហ្មណ៍ កាលក្រាបទូលព្រះរាជា ទើបពោលគាថាទី ៣ ថា

បពិត្រព្រះទេវៈ ពួកជនធ្វើបុណ្យទាំងឡាយ ឲ្យទានដ៏ក្រៃលែង
សម្លាប់បុគ្គល ដែលមិនគួរសម្លាប់ទាំងឡាយ ហើយទៅកាន់
សុគតិយ៉ាងនេះ ដូច្នេះ ។

សេចក្ដីនៃគាថានោះ មានដូច្នេះថា បពិត្រមហារាជ ឈ្មោះថា បុគ្គលទៅកាន់ស្ថានសួគ៌ រមែងឲ្យទានដែលក្រៃលែងជាងទាន គឺសម្លាប់បុគ្គលដែលមិនគួរសម្លាប់ បើទ្រង់ប្រាថ្នាសុគតិលោក សូមទ្រង់ធ្វើយ៉ាងនោះឯង ។

លំដាប់នោះ ព្រះរាជាក៏ត្រាស់សួរដល់អត្ថនៃបញ្ហាជាមួយខណ្ឌហាលព្រាហ្មណ៍ថា

ទានដ៏ក្រៃលែងនុ៎ះដូចម្ដេច ក្នុងលោកនេះ បុគ្គលទាំងឡាយដូច
ម្ដេច ដែលមិនគួរសម្លាប់ ចូរអ្នកប្រាប់សេចក្ដីនុ៎ះដល់យើង យើង
នឹងបូជា នឹងឲ្យទានទាំងឡាយ ដូច្នេះ ។

ខណ្ឌហាលព្រាហ្មណ៍ទូលឆ្លើយបញ្ហានឹងព្រះរាជាថា

បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយព្រះរាជបុត្តទាំងឡាយផង
ដោយព្រះអគ្គមហេសីទាំងឡាយផង ដោយអ្នកនិគម ( សេដ្ឋី )
ទាំងឡាយផង បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយគោឧសភ

សេះអាជានេយ្យបួនៗ ដោយពួកសត្វបួនៗ ទាំងអស់ ដូច្នេះ ។

ខណ្ឌហាលព្រាហ្មណ៍នោះ កាលនឹងថ្វាយព្យាករដល់ព្រះរាជានោះ ត្រូវព្រះរាជានោះទ្រង់សួរដល់ផ្លូវទៅកាន់ស្ថានសួគ៌ តែត្រឡប់ជាព្យាករផ្លូវទៅនរក ។

បណ្ដាបទទាំងនោះ បទថា **បុត្តេហិ** សេចក្ដីថា ដោយព្រះរាជបុត្រ និងព្រះរាជធីតា ដែលជាទីស្រឡាញ់ទាំងឡាយ ដែលកើតហើយអំពីព្រះអង្គផង ។ បទថា **មហេសីហិ** បានដល់ ដោយព្រះជាយាជាទីស្រឡាញ់ទាំងឡាយ ។ បទថា **នេគមេហិ** បានដល់ ដោយសេដ្ឋីទាំងឡាយ ។ បទថា **ឧសភេហិ** សេចក្ដីថា ដោយគោឧសភរាជទាំងឡាយដែលមានពណ៌សសុទ្ធ ។ បទថា **អាជានិយេហិ** សេចក្ដីថា ដោយសេះដែលជាមង្គលទាំងឡាយ ។ បទថា **ចតូហិ** សេចក្ដីថា បពិត្រព្រះសម្មតិទេព ទ្រង់គប្បីបូជាយញ្ញដោយពួក ៤ នៃបុគ្គល និងសត្វទាំងពួងយ៉ាងនេះ គឺដោយបុគ្គលទាំងអស់ និងសត្វពួកដទៃមួយមុខបួន មានដំរីជាដើម ។ ខណ្ឌហាលព្រាហ្មណ៍ឲ្យព្រះរាជាយល់ថា ព្រះរាជាទាំងឡាយដែលទ្រង់បូជាយញ្ញ កាលបានកាត់សីសៈនៃសត្វទាំងឡាយ មានព្រះរាជបុត្រជាដើមនោះដោយព្រះខ័ន កាន់យកឈាមក្នុងបំពង់ក ដោយថាសមាស ដាក់ក្នុងរណ្ដៅយញ្ញហើយ រមែងយាងទៅកាន់ទេវលោក ព្រមទាំងព្រះសរីរកាយនោះឯង បពិត្រមហារាជ ការឲ្យទាន មានឲ្យរបស់បរិភោគ និងគ្រឿងស្លៀកដណ្ដប់ជាដើមដល់សមណព្រាហ្មណ៍ អ្នកកម្សត់ក្រីក្រ អ្នកដំណើរ ស្មូម និងយាចក មិនបានជាអតិទានឡើយ ឯការ

សម្លាប់បុគ្គលដែលមិនគួរសម្លាប់ មានបុត្រ និងធីតាជាដើម ហើយធ្វើការបូជាយញ្ញដោយឈាមក្នុងបំពង់ករបស់បុគ្គលពួកនោះ ទើបឈ្មោះថា អតិទាន ។ ខណ្ឌហាលព្រាហ្មណ៍នោះគិតដូច្នេះថា បើអញឲ្យចាប់តែចន្ទកុមារម្នាក់ មនុស្សទាំងឡាយនឹងដឹងដល់ហេតុនៃការចងពៀរ ព្រោះដូច្នោះ ទើបបញ្ចូលចន្ទកុមារក្នុងរវាងមហាជន ។

ឯអ្នករាជវាំងបានស្តាប់រឿងដែលព្រះរាជា និងខណ្ឌហាលពោលយ៉ាងនេះ ក៏តក់ស្លុត ស្រែកដោយសំឡេងខ្លាំងតែមួយដូចគ្នា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

សំឡេងគឹកកងតែមួយ សំឡេងគួរខ្លាច លាន់ឮឡើងក្នុងវាំង

ព្រោះឮព្រះរាជឱង្ការនោះថា ព្រះកុមារទាំងឡាយ និងព្រះអគ្គមហេសីទាំងឡាយ ត្រូវសម្លាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ** សេចក្តីថា ព្រោះបានឮថា ព្រះរាជកុមារ ព្រះរាជកុមារី និងអគ្គមហេសីទាំងឡាយត្រូវសម្លាប់ ។ បទថា **ឯកោ** សេចក្តីថា មានសំឡេងកងរំពងតែមួយ ពេញព្រះរាជនិវេសន៍ ។ បទថា **ភេស្មា** ប្រែថា គួរខ្លាច ។ បទថា **អច្ចុគ្គតោ** សេចក្តីថា បានកើតឡើងអឺងកង ។

ក្នុងកាលនោះ ព្រះរាជត្រកូលទាំងអស់ ដូចព្រៃវាំងដែលខ្យល់

យុគន្ធរវាតបោកបក់ ឲ្យដួលចុះហើយ ។

ចំណែកព្រាហ្មណ៍ ទូលសួរព្រះរាជាថា បពិត្រមហារាជ ទ្រង់ហ៊ានធ្វើការបូជាយញ្ញនេះ ឬក៏មិនហ៊ាន ព្រះរាជាត្រាស់ថា នែលោកអាចារ្យ លោកពោលអ្វី យើងបូជាហើយ នឹងទៅកាន់ទេវលោក ។ ខណ្ឌហាលព្រាហ្មណ៍ទូលថា បពិត្រមហារាជ បុរសទាំងឡាយកើតមកជាមនុស្សខ្លាច មានអធ្យាស្រ័យទន់ខ្សោយ មិនអាចបូជាយញ្ញបានឡើយ សូមទ្រង់ឲ្យប្រជុំសត្វដែលមានជីវិតទាំងឡាយក្នុងទីនេះ ទូលបង្គំនឹងធ្វើកម្មក្នុងរណ្ដៅយញ្ញ ដូច្នេះហើយ ទើបនាំបក្ខពួកដែលមានកម្លាំងរបស់ខ្លួនចេញអំពីព្រះនគរ ទៅធ្វើរណ្ដៅយញ្ញត្រង់ផែនដីដែលរាបស្មើ ហើយព័ទ្ធរបង ព្រោះហេតុអ្វី ព្រោះថា សមណៈ ឬព្រាហ្មណ៍ដែលទ្រទ្រង់នូវធម៌ គប្បីរារាំងនូវការធ្វើយញ្ញនោះ ព្រោះហេតុនោះ ព្រាហ្មណ៍ក្នុងសម័យបុរាណបញ្ញត្តថា រណ្ដៅយញ្ញត្រូវតែព័ទ្ធដោយរបង ។

ឯព្រះរាជាទ្រង់ត្រាស់ឲ្យហៅរាជបុរសទាំងឡាយមក ហើយប្រាប់ថា នែបាទាំងឡាយ យើងត្រូវការសម្លាប់បុត្រ ធីតា និងភរិយាទាំងឡាយរបស់យើងបូជាយញ្ញ ហើយនឹងទៅកាន់ទេវលោក ចូរឯងទៅទូលព្រះរាជបុត្រ ព្រះរាជធីតា និងអគ្គមហេសីទាំងនោះ ហើយនាំមកកាន់ទីនេះទាំងអស់ ដូច្នេះហើយ ដើម្បីឲ្យរាជបុរសនាំព្រះរាជបុត្រទាំងឡាយមកមុន ទើបត្រាស់ថា

អ្នកទាំងឡាយ ចូរទៅប្រាប់កុមារទាំងឡាយ គឺចន្ទកុមារ ១ សុរិយកុមារ ១ ភទ្ទសេនកុមារ ១ សុរកុមារ ១ វាមគោត្តកុមារ

១ ថា អ្នកទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចន្ទញ្ច សុរិយញ្ច** សេចក្ដីថា ព្រះចន្ទកុមារ និងសុរិយកុមារទាំង ២ ជាព្រះរាជបុត្ររបស់ព្រះនាងគោតមីទេវីអគ្គមហេសី ចំណែកកន្ទសេនកុមារ សុរកុមារ វាមគោត្តកុមារ ជាព្រះភាតាមាតាផ្សេងនៃចន្ទកុមារ និងសុរិយកុមារនោះ ។ បទថា **បច្ចុភា គិរ ហោថ** សេចក្ដីថា ចូរអ្នកប្រមូលឲ្យមូលជាមួយគ្នា អធិប្បាយថា កុំឲ្យបែកគ្នា ។

រាជបុរសទាំងនោះ បានទៅកាន់សម្នាក់ព្រះចន្ទកុមារមុន ហើយទូលថា បពិត្រចន្ទកុមារ បានឮមកថា ព្រះបិតារបស់ព្រះអង្គ បំណងនឹងសម្លាប់ទ្រង់យាងទៅទេវលោក ទ្រង់ឲ្យពួកទូលបង្គំមក ដើម្បីចាប់ទ្រង់ទៅ ។

ព្រះចន្ទកុមារត្រាស់ថា ព្រះរាជាប្រើអ្នកឲ្យមកចាប់យើងតាមពាក្យរបស់អ្នកណា រាជបុរសទូលថា តាមពាក្យរបស់ខណ្ឌហាលព្រាហ្មណ៍ ។ ចន្ទកុមារត្រាស់សួរថា ទ្រង់មកឲ្យចាប់យើងតែម្នាក់ ឬឲ្យចាប់អ្នកដទៃដែរ រាជបុរសទូលថា ទ្រង់ឲ្យចាប់អ្នកដទៃដែរ បានឮថា ទ្រង់ប្រាថ្នាបូជាយញ្ញ ដោយសត្វមួយមុខបួន ។ ព្រះចន្ទកុមារគិតថា ខណ្ឌហាលព្រាហ្មណ៍នេះ មិនបានចងពៀរជាមួយអ្នកដទៃ ព្រោះធ្វើការកាត់ក្ដីកោងក្នុងការវិនិច្ឆ័យក្ដីមិនបាន ក៏សម្លាប់អ្នកដទៃជាច្រើន ព្រោះតែចងពៀរក្នុងអញម្នាក់ បើអញបានឱកាសគាល់ព្រះរាជបិតា ជនទាំងអស់នេះ នឹងផុតភ័យ នេះជាភារៈរបស់អញពិត ។ លំដាប់នោះ ចន្ទកុមារក៏ត្រាស់នឹងរាជបុរសថា បើដូច្នោះ ចូរអ្នកធ្វើតាមបញ្ជា

របស់ព្រះបិតាចុះ ។ រាជបុរសទាំងនោះ នាំព្រះចន្ទកុមារមកឲ្យប្រថាប់ត្រង់ លានព្រះរាជវាំង ក្នុងទិសមគ្គុនខាងចំណែកម្ខាង ហើយនាំកុមារដទៃ ៣ អង្គ មកទៀត ឲ្យប្រថាប់ក្បែរគ្នាហើយ ទូលដល់ព្រះរាជាថា បពិត្រសម្មតិទេព ទូលបង្គំបាននាំព្រះរាជឱរសទាំងឡាយរបស់ព្រះអង្គមកហើយ ។ ព្រះរាជា នោះបានស្តាប់ពាក្យរបស់រាជបុរសទាំងនោះហើយ ត្រាស់ថា នែបាទាំងឡាយ ឥឡូវនេះ ចូរឯងនាំព្រះរាជធីតាទាំងឡាយរបស់យើងមក ហើយឲ្យប្រថាប់ ក្នុងទីជិតនៃបងប្រុសរបស់គេ ។ កាលឲ្យមនុស្សនាំព្រះរាជធីតាទាំង ៤ អង្គ មក ទើបត្រាស់ដូច្នេះថា

អ្នកទាំងឡាយ ចូរប្រាប់កុមារីទាំងឡាយ គឺកុមារីឈ្មោះឧបសេនា ១ កោកិលា ១ មុទិតា ១ នន្ទា ១ ថា នាងទាំងឡាយ ចូរមក ជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ដូច្នេះ ។

រាជបុរសទាំងនោះ ទៅកាន់សម្នាក់ព្រះរាជធីតាទាំងឡាយ ដោយគិត ថា យើងនឹងធ្វើដោយអាការយ៉ាងនេះ ដូច្នេះហើយ នាំព្រះរាជធីតាទាំងនោះ ដែលកំពុងយំសោក ឲ្យមកប្រថាប់ក្នុងទីជិតព្រះភាតា ។ បន្ទាប់អំពីនោះ ព្រះ រាជាកាលឲ្យព្រះរាជបុរសទៅប្រមូលមហេសីទាំងឡាយរបស់ទ្រង់មក ទើប ត្រាស់គាថានេះថា

អ្នកទាំងឡាយ ចូរប្រាប់មហេសីអញ គឺនាងវិជយា ១ នាង ឯរាវតី ១ នាងកេសិនី ១ នាងសុនន្ទា ១ ដែលជាស្ត្រីបរិបូណ៌ ដោយលក្ខណៈដ៏ប្រសើរថា នាងទាំងឡាយ ចូរមកជួបជុំគ្នា

ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លក្ខណារូបបន្នា** សេចក្ដីថា ចូរអ្នកទាំងឡាយទូលមហេសីទាំងនេះ ដែលជាស្រីមានរូបល្អ សម្បូរដោយលក្ខណៈដ៏ឧត្ដម ៦៤ ប្រការ ។

រាជបុរសទាំងនោះ ក៏នាំព្រះនាងទាំង ៤ ដែលកំពុងបរិទេវនាការទាំងនោះមក ឲ្យប្រថាប់នៅក្នុងទីជិតព្រះរាជកុមារ ។ លំដាប់នោះ ព្រះរាជាកាលទ្រង់ឲ្យរាជបុរសនាំសេដ្ឋីទាំង ៤ មក ទើបត្រាស់គាថានេះថា

អ្នកទាំងឡាយ ចូរប្រាប់គហបតីទាំងឡាយ គឺគហបតីឈ្មោះ
បុណ្ណមុខៈ ១ កទ្ធិយៈ ១ សិង្គាលៈ ១ វឌ្ឍៈ ១ ថា ចូរអ្នកទាំង
ឡាយមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ដូច្នេះ ។

រាជបុរសទាំងឡាយ ក៏ទៅនាំគហបតីទាំងនោះមក កាលព្រះរាជាឲ្យចាប់ព្រះរាជកុមារ និងព្រះមហេសីទាំងឡាយ អ្នកនគរមិនមានអ្នកណាពោលពាក្យអ្វីឡើយ តែត្រកូលនៃសេដ្ឋីទាំងឡាយ មានពួកញាតិរាប់ពាន់ ព្រោះដូច្នោះ កាលសេដ្ឋីទាំងនោះត្រូវចាប់ មហាជនក៏នាំគ្នាបះបោរពេញព្រះនគរ ។ ជនទាំងនោះនាំគ្នាពោលថា យើងមិនឲ្យព្រះរាជាសម្លាប់សេដ្ឋីបូជាយញ្ញ ដូច្នេះហើយ នាំគ្នាចោមរោមសេដ្ឋី នាំគ្នាទៅកាន់រាជត្រកូលជាមួយពួកញាតិរបស់សេដ្ឋីទាំងនោះ ។ លំដាប់នោះ សេដ្ឋីទាំងនោះ មានពួកញាតិចោមរោមជុំវិញថ្វាយបង្គំព្រះរាជាហើយ សូមព្រះរាជទានជីវិតរបស់ខ្លួន ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ

បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្បសានូវព្រះគាថាដូច្នេះថា

ពួកគហបតីទាំងនោះ មកជួបជុំគ្នា ដេរដាសដោយកូន និងប្រពន្ធក្នុងទីនោះ ក្រាបបង្គំទូលថា បពិត្រព្រះទេវៈ សូមព្រះអង្គធ្វើយើងខ្ញុំទាំងអស់ ឲ្យមានជុកលើក្បាលវិញ ពុំនោះសោត សូមព្រះអង្គប្រកាសនូវយើងខ្ញុំ ថាជាទាសៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វេ សិខិនោ** សេចក្ដីថា សូមទ្រង់ធ្វើទូលបង្គំគ្រប់គ្នាឲ្យមានជុកលើក្បាល ហើយឲ្យទូលបង្គំ ធ្វើជាអ្នកបម្រើរបស់ព្រះអង្គ ទូលបង្គំនឹងធ្វើកិច្ចជាអ្នកបម្រើរបស់ព្រះអង្គ ។ បទថា **អថ វា នោ ទាសេ សាវេហិ** សេចក្ដីថា កាលមិនយកចិត្តទុកដាក់ជឿទូលបង្គំ សូមប្រជុំកងទ័ពទាំងអស់ ហើយទ្រង់ប្រកាសក្នុងកណ្ដាលកងទ័ពទាំងនោះ ឲ្យពួកទូលបង្គំជាទាសៈ ទូលបង្គំទាំងឡាយនឹងធ្វើវត្តជាទាសៈដល់ទ្រង់ ។

គហបតីទាំងនោះ កាលទូលសូមជីវិតយ៉ាងនេះ ក៏នៅតែមិនបាន ។ រាជបុរសទាំងឡាយ បានឲ្យគហបតីទាំងអស់នោះត្រឡប់ទៅហើយ បណ្ដើរយកសេដ្ឋីទាំង ៤ ឲ្យចូលទៅអង្គុយជិតព្រះរាជកុមារនោះឯង ។

ក្រោយមក ព្រះរាជាកាលទ្រង់បញ្ជារាជបុរស ដើម្បីឲ្យនាំសត្វទាំងឡាយ មានដំរីជាដើមមក ទើបត្រាស់ថា

អ្នកទាំងឡាយ ចូរនាំមកនូវដំរីរបស់អញ ឈ្មោះអភយង្ការៈ ១ នាឡាគិរី ១ អច្ចុគ្គតៈ ១ ( ឈ្មោះវរុណទន្តៈ ) ១ ដំរីទាំងឡាយ

នោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងឆាប់ ។ អ្នកទាំងឡាយ ចូរនាំមកនូវសេះកែវរបស់អញ គឺសេះឈ្មោះ កេសី ១ សុរាមុខៈ ១ បុណ្ណកៈ ១ វិនតកៈ ១ សេះទាំងឡាយ នោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងឆាប់ ។ អ្នកទាំងឡាយ ចូរនាំយកគោឧសភទាំងនោះរបស់អញ គឺគោ ឧសភឈ្មោះយូថបតិ ១ អនោជៈ ១ និសភៈ ១ គវម្បតិ ១ មកដល់អញ ជនទាំងឡាយ ចូរធ្វើកិច្ចការទាំងពួង ក្នុងទីចំពោះ មុខ អញនឹងបូជា នឹងឲ្យទានទាំងឡាយ ។ អ្នកទាំងឡាយ ចូរ តាក់តែងគ្រឿងបូជាគ្រប់មុខ កាលបើព្រះអាទិត្យរះឡើងហើយ អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់ពួកកុមារ មានចន្ទកុមារ ជាដើមថា កុមារទាំងឡាយ ចូររីករាយអស់ ១ យប់ នេះចុះ ។ អ្នកទាំងឡាយ ចូរតម្កល់ទុកនូវគ្រឿងយញ្ញគ្រប់មុខ កាលព្រះ អាទិត្យរះឡើង អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់កុមារទាំង ឡាយ ក្នុងកាលឥឡូវនេះថា រាត្រីថ្ងៃនេះឯង ជារាត្រីបំផុត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វហា ករោន្តុ សព្វំ** សេចក្តីថា ចូរធ្វើឲ្យ ជាពួកៗ មិនមែនតែសត្វទាំងអស់មានប្រមាណប៉ុណ្ណោះទេ សូម្បីសត្វទាំងពួង ក្រៅអំពីនេះ ប្រភេទសត្វជើង ៤ ក្តី បក្សីក្តី ចូរធ្វើឲ្យជាមួយពួកបួនៗ រួច គរជាគំនរ យើងនឹងបូជាយញ្ញ ដែលប្រកបដោយពួក ៤ នៃសត្វគ្រប់ប្រភេទ

យើងនឹងឲ្យទានដល់យាចកទាំងឡាយ និងសមណព្រាហ្មណ៍ទាំងឡាយ ។ បទថា **សព្វំបិ បដិយាទេថ** សេចក្តីថា ចូររៀបចំវត្ថុដ៏សេសដែលយើងពោលហើយនោះ ។ បទថា **ឧគ្គតម្ហិ** សេចក្តីថា ចំណែកយើងនឹងបូជាយញ្ញក្នុងថ្ងៃស្អែកនេះអំពីព្រលឹម ក្នុងកាលព្រះអាទិត្យរះឡើង ។ បទថា **សព្វំបិ ឧបដ្ឋ-បេថ** សេចក្តីថា ចូររៀបចំគ្រឿងឧបករណ៍ដល់យញ្ញដ៏សេសទាំងអស់ ។

ចំណែកព្រះរាជមាតា និងព្រះរាជបិតារបស់ព្រះរាជានោះ នៅមានព្រះជន្មទាំង ២ អង្គ ។ លំដាប់នោះ ពួកអមាត្យក៏ទៅទូលព្រះរាជមាតាថា បពិត្រព្រះនាង អយ្យបុត្រព្រះនាងប្រាថ្នានឹងសម្លាប់ព្រះរាជបុត្រ និងព្រះជាយា រួចបូជាយញ្ញ ។ ព្រះរាជមាតាត្រាស់ថា នែបា ឯងនិយាយអ្វីយ៉ាងនេះ ហើយទះព្រះឧរៈដោយព្រះហស្តព្រះកន្សែងយាងមក ត្រាស់សួរថា នែកូន បានឮថាឯងបូជាយញ្ញបែបនេះឬ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះរាជមាតា ( ព្រះបាទឯករាជ ) ទ្រង់ព្រះកន្សែង ទ្រង់ស្តេចមក
អំពីវិមាន ទ្រង់មានព្រះរាជសវនីយ៍ សួរនូវសេក្តីនោះ នឹងព្រះ
រាជានោះថា នែកូន ឮថា កូនឯងនឹងបូជាយញ្ញ ដោយព្រះ
រាជបុត្តទាំង ៤ នាក់ មែនឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ តំ** បានដល់ ព្រះបាទឯករាជនោះ ។

បទថា **សព្វិមានតោ** បានដល់ អំពីព្រះរាជដំណាក់របស់ព្រះនាង ។

ព្រះរាជាក្រាបទូលថា

កាលបើខ្ញុំសម្លាប់ចន្ទកុមារហើយ បុត្តរបស់ខ្ញុំទាំងអស់ ក៏ខ្ញុំលះបង់ដើម្បីបូជាយញ្ញដែរ លុះខ្ញុំបូជាដោយបុត្តទាំងឡាយហើយ ខ្ញុំនឹងទៅកាន់សុគតិសួគ៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចន្ទា** សេចក្ដីថា កាលសម្លាប់ចន្ទកុមារនោះឯង បុត្តទាំងអស់ ខ្ញុំក៏លះបង់ដើម្បីបូជាយញ្ញ ។

លំដាប់នោះ ព្រះរាជមាតារបស់ព្រះរាជា ត្រាស់នឹងព្រះរាជានោះថា

ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍នោះថា សុគតិបានដោយការបូជាបុត្តឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរក មិនមែនជាផ្លូវទៅកាន់ស្ថានសួគ៌ទេ ។ ម្នាលកូនកោណ្ឌញ្ញគោត្ត ចូរអ្នកឲ្យទានទាំងឡាយ ( អ្នក ) កុំបៀតបៀនសព្វសត្វដែលកើតហើយ នឹងត្រូវកើតឡើយ នេះជាផ្លូវនៃសុគតិ ផ្លូវ ( នៃសុគតិ ) មិនមែនបានដោយការបូជាបុត្តទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និរយានេសោ** សេចក្ដីថា នុ៎ះជាផ្លូវនៃអបាយ ៤ ដែលឈ្មោះថា នរក ព្រោះមិនមានសេចក្ដីចម្រើន ។ ព្រះរាជមាតាហៅព្រះរាជាដោយគោត្រថា កោណ្ឌញ្ញ ។ បទថា **ភូតភព្យានំ** សេចក្ដីថា ដល់សត្វទាំងឡាយដែលកើតមកហើយ និងដល់សត្វដែលគប្បីកើត ។ បទថា **បុត្តយញ្ញេន** សេចក្ដីថា ឈ្មោះថា ផ្លូវទៅកាន់ស្ថានសួគ៌ មិនមាន

ដោយការសម្លាប់កូនប្រុស និងកូនស្រី បូជាយញ្ញបែបនេះឡើយ ។

ព្រះរាជាទូលថា

ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យខណ្ឌ-

ហាលអាចារ្យ បូជាបុត្តទាំងឡាយ ដែលគេលះបង់បានដោយកម្រ

ហើយ នឹងទៅកាន់សុគតិសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាចរិយានំ វចនា** សេចក្តីថា បពិត្រព្រះមាតា មតិនេះជារបស់ខ្ញុំក៏មិនមែន ពាក្យទូន្មាននេះជារបស់ខណ្ឌហាលាចារ្យ ដែលញុំាងខ្ញុំឲ្យសិក្សានូវវត្តប្រពៃ ព្រោះដូច្នោះ ខ្ញុំនឹងសម្លាប់កូនទាំងឡាយនេះ កាលបូជាយញ្ញហើយដោយកូនដែលគេលះបង់បានដោយក្រ ខ្ញុំនឹងទៅកាន់ស្ថានសួគ៌ លំដាប់នោះ ព្រះរាជមាតា កាលមិនអាចញុំាងព្រះរាជាឲ្យស្តាប់វាចារបស់ព្រះនាងបាន ក៏ចៀសចេញទៅ ។ ព្រះរាជបិតារបស់ព្រះរាជាបានឮដំណឹងនោះហើយ ក៏យាងមកសាកសួរព្រះបាទឯករាជនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្បសានូវព្រះគាថាដូច្នេះថា

ចំណែកខាងព្រះវេសវត្តី ជាព្រះរាជបិតា ត្រាស់សួរហេតុនោះ

ចំពោះព្រះបាទឯករាជ ជារាជបុត្តកើតអំពីឱរានោះថា ម្នាលកូន

ឮថា អ្នកនឹងបូជាយញ្ញដោយបុត្តទាំង ៤ មែនឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេសវត្តិ**នេះ ជាឈ្មោះរបស់ព្រះរាជានោះ ។

ព្រះបាទឯករាជទូលថា

កាលបើខ្ញុំសម្លាប់ចន្ទកុមារ ( បូជា ) ហើយ បុត្តទាំងឡាយទាំងអស់ ក៏ខ្ញុំលះបង់ដែរ ខ្ញុំបូជាយញ្ញដោយបុត្តទាំងឡាយហើយ នឹងទៅកាន់សុគតិសួគ៌ ដូច្នេះ ។

លំដាប់នោះ ព្រះរាជបិតាត្រាស់ថា

ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍ថា សុគតិមាន ដោយការបូជាបុត្តឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរកទេ មិនមែនជាផ្លូវទៅកាន់ស្ថានសួគ៌ទេ ។ ម្នាលកូនកោណ្ឌញ្ញគោត្ត ចូរអ្នកឲ្យទានទាំងឡាយ ( អ្នក ) កុំបៀតបៀនសព្វសត្វទាំងឡាយ ដែលកើតហើយ នឹងត្រូវកើត នេះជាផ្លូវនៃសុគតិ ផ្លូវ ( នៃសុគតិ ) មិនមែនបានដោយការបូជាបុត្តទេ ដូច្នេះ ។

ព្រះបាទឯករាជត្រាស់ថា

ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យនៃខណ្ឌហាលអាចារ្យ ខ្ញុំបូជាបុត្តទាំងឡាយ ដែលគេលះបង់បានដោយកម្រ ហើយនឹងទៅកើតក្នុងសុគតិសួគ៌ ដូច្នេះ ។

លំដាប់នោះ ព្រះរាជបិតាក៏ត្រាស់នឹងព្រះរាជាថា

ម្នាលកូន កោណ្ឌញ្ញគោត្ត អ្នកចូរឲ្យទានទាំងឡាយ ( អ្នក ) កុំបៀតបៀនសព្វសត្វដែលកើតហើយ នឹងត្រូវកើតទាំងឡាយឡើយ អ្នកចូរជាមនុស្ស ដែលកូនទាំងឡាយចោមរោមហើយ

រក្សាដែន និងជនបទចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុត្តបរិវុតោ** បានដល់ ដែលកូនទាំងឡាយចោមរោមហើយ ។ បទថា **រដ្ឋំ ជនបទញ្ច** សេចក្ដីថា កូនអាចរក្សាកាសិករដ្ឋទាំងមូល និងជនបទ ដែលជាចំណែកនោះៗ របស់កាសិករដ្ឋនោះឯង ។

គ្រានោះ ព្រះរាជបិតាក៏មិនអាចធ្វើឲ្យព្រះបាទឯករាជទ្រង់ស្ដាប់ព្រះរាជតម្រាស់នៃទ្រង់ឡើយ លំដាប់នោះ ព្រះចន្ទកុមារទ្រង់ត្រិះរិះថា អាស្រ័យអាត្មាអញម្នាក់ឯង ទុក្ខកើតឡើងហើយដល់មនុស្សមានប្រមាណប៉ុណ្ណេះ អញនឹងទូលអង្វរព្រះរាជបិតារបស់អញហើយ នឹងដោះលែងជនមានប្រមាណប៉ុណ្ណេះឲ្យផុតទុក្ខ គឺសេចក្ដីស្លាប់ កាលទ្រង់ចរចាជាមួយព្រះរាជបិតា ទើបត្រាស់ថា

បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយឃ្វាលដំរី និងសេះ ។ បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយនឹងចោលអាចម៍ដំរី ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំ

សម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទាន ទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយ នឹងចោលអាចម៍សេះ ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជាទានទូលបង្គំ ជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ព្រះអង្គ មានប្រាថ្នា ( ដើម្បីព្រះរាជទាន ) ដល់ខណ្ឌហាលព្រាហ្មណ៍ ណា សូមទ្រង់ព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃ ខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត នឹងសូមព្រះអង្គបំបរ បង់ទូលបង្គំជាខ្ញុំទាំងឡាយ ចេញចាកដែន ក៏ទូលបង្គំជាខ្ញុំទាំង ឡាយ នឹងត្រាច់ទៅកាន់ភិក្ខាចារ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និគឡពន្ធកាបិ** សេចក្ដីថា ទោះបីទូលបង្គំ ទាំងឡាយត្រូវចងដោយច្រវាក់ ។ បទថា **យស្ស ហោន្តិ តវ កាមា** សេចក្ដី ថា បើទ្រង់ប្រាថ្នាឲ្យដល់ខណ្ឌហាលបុរោហិត សូមទ្រង់ធ្វើពួកខ្ញុំឲ្យជាទាសៈ ហើយឲ្យដល់ខណ្ឌហាលបុរោហិត ពួកយើងនឹងធ្វើកម្ម គឺភាពជាទាសៈដល់ ខណ្ឌហាលបុរោហិត ។ ដោយបទថា **អបិ រដ្ឋា** នេះ លោករៀបរាប់ថា បើពួកខ្ញុំមានទោសណាមួយ សូមទ្រង់បំបរបង់ពួកខ្ញុំចេញអំពីដែន ម្យ៉ាងទៀត ពួកខ្ញុំត្រូវបណ្ដេញអំពីនគរហើយ នឹងកាន់អំបែងដើរសូមទាន ដូចអ្នកកំព្រា សូមទ្រង់កុំសម្លាប់ខ្ញុំឡើយ សូមឲ្យជីវិតដល់ខ្ញុំទាំងឡាយចុះ ។

ព្រះរាជាបានស្តាប់ពាក្យរៀបរាប់មានប្រការផ្សេងៗ នោះរបស់ព្រះរាជកុមារហើយ ដល់នូវសេចក្តីទុក្ខ ហាក់ដូចដើមទ្រូងត្រូវបែក មានព្រះនេត្រពេញដោយព្រះអស្សុជល ប្រកាសថា អ្នកណាក៏ដោយកុំសម្លាប់កូនរបស់យើង សេចក្តីត្រូវការដោយទេវលោក មិនមានដល់យើងឡើយ ដើម្បីដោះលែងមនុស្សទាំងពួង ទើបត្រាស់គាថានេះថា

អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយ
យំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ អ្នកទាំងឡាយលែង
កុមារទាំងឡាយទៅ ការបូជាយញ្ញ ដោយកូនរបស់អញ ល្មម
លើកលែងចុះ ដូច្នេះ ។

រាជបុរសទាំងឡាយនោះ កាលបានស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក៏លែងសត្វដែលចងជាក្រុមៗ ទាំងអស់ ចាប់តាំងពីព្រះរាជបុត្ររហូតដល់ពួកបក្សីជាទីបំផុត ។

ចំណែកខណ្ឌហាលព្រាហ្មណ៍ កំពុងចាត់ចែងកម្មក្នុងរណ្តៅយញ្ញ គ្រានោះ បុរសម្នាក់ពោលនឹងខណ្ឌហាលនោះថា អើ ខណ្ឌហាលអាក្រក់ដូជាតិពួករាជបុត្រ និងរាជធីតាទាំងឡាយនោះ ព្រះរាជាដោះលែងអស់ទៅហើយ ឯងសម្លាប់កូនប្រពន្ធរបស់ឯង យកឈាមក្នុងបំពង់ករបស់មនុស្សទាំងនោះបូជាយញ្ញចុះ ខណ្ឌហាលព្រាហ្មណ៍គិតថា ព្រះរាជាទ្រង់ធ្វើអ្វីហ្ន៎ ក្រោកឡើង ស្ទុះមកដោយកម្លាំងដ៏រហ័ស បីដូចត្រូវភ្លើងប្រល័យកប្បជុត ដូច្នោះ ទើបពោលថា

ទូលព្រះបង្គំជាខ្ញុំក្រាបទូលព្រះអង្គ តាំងពីដើមមកថា ការបូជាយញ្ញទុំះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងធ្វើឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញ ដែលទូលព្រះបង្គំជាខ្ញុំ ប្រុងប្រៀបស្រេចហើយ ហេតុអ្វី ព្រះអង្គធ្វើឲ្យវិនាសទៅវិញ ។ ជនទាំងឡាយណា ឲ្យគេបូជាយញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងឡាយទាំងអស់នោះ រមែងទៅកាន់សុគតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វេវ** សេចក្តីថា ទូលបង្គំបានទូលហើយក្នុងកាលមុនមិនមែនឬថា បុគ្គលមានជាតិខ្វាចដូចទ្រង់ មិនអាចបូជាយញ្ញឈ្មោះថា ការបូជាយញ្ញនេះ ធ្វើបានដោយលំបាក ឲ្យនូវការត្រេកអរបានដោយលំបាក កាលបើដូច្នេះ ទ្រង់ឈ្មោះថា ធ្វើនូវការកាត់ផ្តាច់នូវយញ្ញដែលត្រៀមក្នុងឥឡូវនេះរបស់យើង ។ បាលីថា **វិឡុម្ភំ** ដូច្នេះក៏មាន អធិប្បាយថា បដិសេធ ។ ខណ្ឌហាលព្រាហ្មណ៍សម្តែងថា បពិត្រមហារាជ ព្រោះហេតុអ្វីទើបទ្រង់ធ្វើយ៉ាងនេះ ជនប្រមាណប៉ុនណាបូជាយញ្ញដោយខ្លួនឯងក្តី ឲ្យអ្នកដទៃបូជាក្តី អនុមោទនាយញ្ញដែលអ្នកដទៃបូជាហើយក្តី ជនទាំងអស់នោះរមែងទៅកាន់សុគតិតែម្យ៉ាង ។

ព្រះរាជាល្ងង់ខ្លៅ ទ្រង់កាន់យកពាក្យរបស់ខណ្ឌហាលព្រាហ្មណ៍ ជាអ្នកប្រព្រឹត្តទៅក្នុងអំណាចសេចក្តីក្រោធ ទ្រង់សម្គាល់ថា ប្រកបដោយធម៌ ក៏

ឲ្យរាជបុរសចាប់ព្រះរាជកុមារមកសាជាថ្មី ។

ព្រោះហេតុនោះ ព្រះចន្ទកុមារ កាលញុំាងព្រះបិតាឲ្យទ្រង់ជ្រាប ទើបក្រាបទូលថា

ចុះព្រះអង្គ ឲ្យពួកព្រាហ្មណ៍ទាយ សួស្តីរបស់ទូលព្រះបង្គំជាខ្ញុំពីមុនមកដើម្បីអ្វី បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គឲ្យគេសម្លាប់ពួកទូលបង្គំជាខ្ញុំ ដើម្បីប្រយោជន៍ដល់យញ្ញ ដោយឥតហេតុ ។ ពីដើម កាលដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយ នៅក្មេងនៅឡើយ ( ម្តេចក៏ ) ព្រះអង្គមិនសម្លាប់ មិនឲ្យគេសម្លាប់ទៅ បពិត្រព្រះបិតា ឥឡូវនេះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាក្មេងពេញកំលោះ ជាអ្នកឥតប្រទូស្ត ក៏ស្រាប់តែព្រះអង្គឲ្យគេសម្លាប់ ។ បពិត្រមហារាជ សូមព្រះអង្គទតមើល ទូលបង្គំជាខ្ញុំទាំងឡាយដែលពាក់គ្រឿងក្រោះ ជិះដំរី ជិះសេះ ច្បាំងហើយ និងកំពុងច្បាំង មនុស្សទាំងឡាយបែបខ្ញុំនេះ មិនមែនជាមនុស្សសម្រាប់បូជាយញ្ញទេ ។ ជនទាំងឡាយ តែងបញ្ជូនពួកមនុស្ស ដូចទូលបង្គំជាខ្ញុំ ទៅក្នុងបច្ចន្តគ្រាម ដែលបះបោរឡើងហើយ ឬក្នុងដងព្រៃ បពិត្រព្រះបិតា កាលបើដូច្នោះ ទូលបង្គំជាខ្ញុំទាំងឡាយមិនត្រូវព្រះអង្គឲ្យគេសម្លាប់ ក្នុងទីមិនជាឱកាស ដោយឥតហេតុទេ ។ មេសត្វស្លាបទាំងឡាយណានីមួយ ធ្វើសម្បុកដោយស្មៅទាំងឡាយ ហើយនៅ កូនទាំងឡាយជាទីស្រឡាញ់របស់មេសត្វ

ស្ដាប់ទាំងនោះ បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គនៅតែឲ្យគេសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយ ។ ព្រះអង្គកុំជឿពាក្យខណ្ឌហាលព្រាហ្មណ៍នោះថា ខណ្ឌហាលព្រាហ្មណ៍ មិនគប្បីសម្លាប់អញខ្ញុំ ដូច្នេះឡើយ បពិត្រព្រះទេវៈ ព្រោះខណ្ឌហាលព្រាហ្មណ៍នោះ សម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយហើយ គប្បីសម្លាប់ព្រះអង្គក្នុងកាលជាលំដាប់ ។ បពិត្រមហារាជ ព្រះរាជាទាំងឡាយតែងព្រះរាជទានស្រុកដ៏ប្រសើរផង និគមដ៏ប្រសើរផង ភោគៈផងដល់ព្រាហ្មណ៍នោះ កាលបើដូច្នោះ ពួកព្រាហ្មណ៍ទាំងនោះជាអ្នកបរិភោគ រាល់ៗ ដុំបាយដ៏ថ្លៃថ្លាង តែងបានបរិភោគ រាល់ៗត្រកូល ។ បពិត្រមហារាជ ព្រាហ្មណ៍ទុំះ ប្រាថ្នាដើម្បីប្រទូស្តចំពោះជនអ្នកឲ្យទាំងនោះ ដូចជាព្រះអង្គ បពិត្រព្រះទេវៈ ពួកព្រាហ្មណ៍ទាំងនុ៎ះ ជាមនុស្សអកតញ្ញូដោយច្រើន ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណងហើយ នឹងឃ្វាលដំរី និងសេះ ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទាននូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាប់ចំណងហើយ

នឹងចាក់អាចម៍ដីវ ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណង នឹងចាក់អាចម៍សេះ ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់នូវទូលបង្គំជាខ្ញុំទាំងឡាយឡើយ ព្រះអង្គសព្វព្រះរាជហឫទ័យ ចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមព្រះរាជទាននូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះវិញចុះ ពុំនោះសោត ទូលបង្គំជាខ្ញុំទាំងឡាយ បើព្រះអង្គបំបរបង់ចេញចាកដែន នឹងត្រាច់ទៅកាន់ភិក្ខាចារដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុត្តេ** សេចក្ដីថា បពិត្រព្រះបិតា បើខ្ញុំជាកូនដែលទ្រង់គប្បីសម្លាប់សោត បើដូច្នេះ ហេតុអ្វីក្នុងកាលមុន គឺក្នុងកាលដែលខ្ញុំកើតហើយ ជនដែលជាញាតិរបស់យើងខ្ញុំទាំងឡាយ ទើបបានឲ្យពួកព្រាហ្មណ៍ទាំងឡាយពោលពាក្យជាសុវត្ថិមង្គល បានឮមកថា ក្នុងកាលនោះខណ្ឌហាលព្រាហ្មណ៍នោះឯង បានពិនិត្យលក្ខណៈទាំងឡាយរបស់ខ្ញុំមកហើយ បានទាយថា ភ័យដែលមកក្នុងចន្លោះណាមួយ មិនមានដល់ព្រះរាជកុមារអង្គនេះ ក្នុងកាលជាទីបំផុតរបស់ទ្រង់ ព្រះរាជកុមារអង្គនេះ នឹងញុំាងរដ្ឋឲ្យប្រព្រឹត្តទៅ ពាក្យក្រោយរបស់ខណ្ឌហាលព្រាហ្មណ៍ ស្ដាប់ទៅ មិនសមគ្នានឹងពាក្យមុន ដូច្នេះ ព្រាហ្មណ៍នេះ រមែងជាមនុស្សពោលកុហក តែឥឡូវ

នេះ ទ្រង់កាន់យកពាក្យរបស់ខណ្ឌហាលព្រាហ្មណ៍ សម្លាប់យើងខ្ញុំទាំងឡាយ ដើម្បីបូជាយញ្ញ ដោយហេតុដែលមិនគួរ បពិត្រព្រះសម្មតិទេព សូមទ្រង់កុំសម្លាប់យើងខ្ញុំទាំងឡាយ បពិត្រព្រះអង្គជាធំជាងនរៈ សូមទ្រង់កំណត់ឲ្យល្អថា ខណ្ឌហាលព្រាហ្មណ៍នេះ ជាអ្នកប្រាថ្នាសម្លាប់ជនជាច្រើន ព្រោះចងពៀរនឹងខ្ញុំតែម្នាក់ ។ បទថា **បុព្វេវ នោ** សេចក្តីថា បពិត្រមហារាជ បើទ្រង់ប្រាថ្នានឹងសម្លាប់យើងខ្ញុំទាំងឡាយ ព្រោះហេតុអ្វី ក្នុងកាលមុន គឺក្នុងកាលដែលយើងខ្ញុំទាំងឡាយនៅក្មេង ព្រះអង្គមិនសម្លាប់ឯង ឬឲ្យអ្នកដទៃសម្លាប់យើងខ្ញុំទាំងឡាយ តែឥឡូវនេះ យើងខ្ញុំទាំងឡាយកំលោះ តាំងនៅក្នុងបឋមវ័យ ចម្រើនដោយបុត្រ និងធីតាទាំងឡាយ កាលបើដូច្នេះ ខ្ញុំកើតមក មិនបានគិតប្រទូស្តចំពោះទ្រង់ឡើយ ព្រះអង្គសម្លាប់យើងខ្ញុំទាំងឡាយ ព្រោះហេតុអ្វី ។ បទថា **បស្ស នោ** សេចក្តីថា សូមទ្រង់ពិចារណាមើលនូវយើងខ្ញុំទាំង ៤ នាក់បងប្អូន ។ បទថា **យុជ្ឈមានេ** សេចក្តីថា ក្នុងកាលដែលសត្រូវទាំងឡាយចោមរោមនគរហើយ សូមទ្រង់ទតនូវព្រះរាជបុត្រទាំងឡាយដូចខ្ញុំ ច្បាំងនឹងសត្រូវទាំងនោះ ព្រះរាជាទាំងឡាយដែលឥតព្រះរាជ-បុត្រ ឈ្មោះថា ជាបុគ្គលគ្មានទីពឹង ។ បទថា **មាធិសា** សេចក្តីថា រាជបុត្រទាំងឡាយជាអ្នកក្លាហាន បរិបូណ៌ដោយកម្លាំង ទើបមិនមែនជាបុគ្គលដែលគួរសម្លាប់ដើម្បីយញ្ញ ។ បទថា **និយោជេន្តិ** សេចក្តីថា ទ្រង់រមែងប្រើដើម្បីជាប្រយោជន៍ដល់ការបង្ក្រាបបច្ចាមិត្រទាំងឡាយ ។ បទថា **អថ នោ** កែជា **អថ អម្ហេ**។ បទថា **អការណស្មា** សេចក្តីថា ព្រោះហេតុដែលមិនសមគួរ ។

បទថា **អភូមិយំ** សេចក្តីថា ក្នុងឱកាសដែលមិនសមគួរឡើយ អធិប្បាយថា បពិត្រព្រះបិតា ព្រោះហេតុអ្វី ទើបពួកខ្ញុំត្រូវសម្លាប់ ។ បទថា **មា តស្ស សទ្ទហេសិ** សេចក្តីថា បពិត្រមហារាជ ខណ្ឌហាលព្រាហ្មណ៍មិនគួរឲ្យសម្លាប់ខ្ញុំ សូមទ្រង់កុំជឿខណ្ឌហាលព្រាហ្មណ៍នោះ ។ បទថា **ភោគំ ចិស្ស** សេចក្តីថា ព្រះរាជាទាំងឡាយមិនឲ្យនូវភោគៈដល់ព្រាហ្មណ៍នោះ ។ បទថា **អជគ្គបិណ្ឌិកាបិ** សេចក្តីថា ព្រាហ្មណ៍ទាំងនោះ កាលបាននូវទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ទើបឈ្មោះថា បាននូវដុំបាយ និងទឹកដ៏ប្រសើរ ។ បទថា **តេសំបិ** សេចក្តីថា ពួកគេបរិភោគក្នុងត្រកូលរបស់មនុស្សពួកណា ពួកគេប្រទូស្តសូម្បីបុគ្គលដែលឲ្យនូវដុំបាយបែបនេះទាំងនោះ ។

ព្រះរាជា កាលទ្រង់ស្តាប់ពាក្យប្រៀនប្រដៅរបស់កុមារនោះ ទើបត្រាស់ថា

អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយយំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយលែងកុមារទាំងឡាយទៅ ការបូជាយញ្ញដោយកូនរបស់អញល្មមលើកលែងចុះ ដូច្នេះ ។

ព្រះរាជា កាលទ្រង់ពោលដូច្នេះហើយ ក៏ឲ្យលែងកុមារទាំងឡាយម្តងទៀត ។ ខណ្ឌហាលព្រាហ្មណ៍មកហើយ ពោលទៀតថា

ទូលបង្គំជាខ្ញុំ បានក្រាបទូលតាំងពីដើមមកថា ការបូជាយញ្ញនុ៎ះជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងឲ្យកើតឡើងបានផង

កាលបើគ្រឿងយញ្ញ ដែលទូលបង្គំជាខ្ញុំ ប្រុងប្រៀបស្រេចហើយ ហេតុអ្វី ក៏ព្រះអង្គធ្វើឲ្យអាក់ខានទៅវិញ ។ ជនទាំងឡាយណា បូជាយញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផង កំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងអស់ ( នោះ ) រមែងទៅកាន់ សុគតិ ដូច្នេះ ។

កាលពោលដូច្នេះហើយ ក៏ឲ្យចាប់ព្រះរាជកុមារម្តងទៀត លំដាប់នោះ កុមារកាលពោលទៅតាមក្រសែសេចក្តីរបស់ខណ្ឌហាលព្រាហ្មណ៍ ទើប ក្រាបទូលថា

បើប្រាកដជាបុគ្គលទាំងឡាយបូជាយញ្ញ ដោយបុត្រទាំងឡាយ ហើយ ច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់ទេវលោក បពិត្រ មហារាជ ចូរព្រាហ្មណ៍បូជាមុនចុះ សឹមព្រះអង្គបូជាជាខាង ក្រោយ ។ ពួថា បើប្រាកដជាបុគ្គលទាំងឡាយ បូជាយញ្ញដោយ បុត្តទាំងឡាយហើយ ច្យុតអំពីមនុស្សលោកនេះ រមែងទៅកាន់ ទេវលោក ចូរខណ្ឌហាលព្រាហ្មណ៍ហ្នឹងឯង បូជាដោយកូនទាំង ឡាយរបស់ខ្លួនចុះ ។ បើខណ្ឌហាលព្រាហ្មណ៍ដឹងយ៉ាងនេះហើយ ហេតុអ្វី ក៏មិនសម្លាប់កូនតូចៗ ទាំងឡាយផង មិនសម្លាប់ជន ជាញាតិទាំងអស់ផង មិនសម្លាប់ខ្លួនឯងផង ។ ជនទាំងឡាយ ណា បូជាយញ្ញដោយខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជា

យញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ប្រាកដដូច្នេះក្តី ជនទាំងអស់ ( នោះ ) រមែងទៅកាន់នរក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្រាហ្មណោ តាវ** សេចក្តីថា ខណ្ឌ-ហាលព្រាហ្មណ៍ ចូរបូជាយញ្ញមុន ។ បទថា **សកេហិ** សេចក្តីថា ចូរបូជាដោយកូនទាំងឡាយរបស់ខ្លួន ។ លំដាប់នោះ ព្រះចន្ទកុមារ កាលនឹងសម្តែងក៏បានទូលយ៉ាងនេះថា បពិត្រសម្មតិទេព កាលខណ្ឌហាលព្រាហ្មណ៍បូជាយញ្ញយ៉ាងនេះហើយ ទៅកាន់ទេវលោក សឹមទ្រង់បូជាយញ្ញជាខាងក្រោយ សូម្បីភោជនដែលមានរសឆ្ងាញ់ កាលទ្រង់សោយ លុះតែអ្នកដទៃភ្លក្សមុនហើយ តែនេះជាការស្លាប់របស់បុត្រ ហេតុអ្វី ទើបទ្រង់មិនឲ្យអ្នកដទៃសាកល្បងជាមុនហើយ សឹមទ្រង់ធ្វើ ។ បទថា **ឯវំ ជានំ** សេចក្តីថា ខណ្ឌ-ហាលព្រាហ្មណ៍កាលបើដឹងយ៉ាងនេះថា មនុស្សទាំងឡាយសម្លាប់បុត្រធីតាហើយ ទៅកាន់ទេវលោក ព្រោះហេតុអ្វី ខណ្ឌហាលព្រាហ្មណ៍ មិនសម្លាប់កូនទាំងឡាយ និងពួកញាតិរបស់ខ្លួន និងខ្លួនឯងផង បើបុគ្គលណាដឹងគុណនៃការបូជាយញ្ញយ៉ាងនេះថា បើសម្លាប់អ្នកដទៃហើយ ទៅកាន់ទេវលោក បើសម្លាប់ខ្លួនឯងហើយ នឹងទៅដល់ព្រហ្មលោកដូច្នេះសោត ក៏មិនគប្បីសម្លាប់អ្នកដទៃ គប្បីសម្លាប់ខ្លួនឯងនោះឯង តែខណ្ឌហាលព្រាហ្មណ៍នេះ មិនធ្វើយ៉ាងនោះ បែរជាញុំាងទ្រង់ឲ្យសម្លាប់ខ្ញុំ បពិត្រមហារាជ សូមទ្រង់ជ្រាបការធ្វើរបស់ខណ្ឌហាលព្រាហ្មណ៍ដោយហេតុនេះ បពិត្រមហារាជ ខណ្ឌហាល-

ព្រាហ្មណ៍នេះ កាលប្រជែងជាមួយទូលបង្គំក្នុងការកាត់ក្តីមិនបាន ទើបធ្វើ ដូច្នេះ ។ បទថា **ឯធិសំ** បានដល់ យញ្ញដែលសម្លាប់បុត្របែបនេះ ។

ព្រះរាជកុមារ កាលនឹងទូលសេចក្តីមានប្រមាណប៉ុណ្ណេះ ក៏មិនអាចធ្វើឲ្យព្រះរាជបិតា ទ្រង់កាន់យកពាក្យរបស់ខ្លួនបាន ទើបប្រាប់ពួករាជបរិស័ទដែលចោមរោមព្រះរាជានោះ ត្រាស់ថា

ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជថា កុំទ្រង់សម្លាប់បុត្រដែលកើតអំពីទ្រូងឡើយ ។ ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា កុំទ្រង់សម្លាប់បុត្រដែលកើតអំពីខ្លួនឡើយ ។ ខ្ញុំជាអ្នកប្រាថ្នាប្រយោជន៍ចំពោះព្រះរាជា ប្រយោជន៍ចំពោះអ្នកជនបទទាំងអស់ ឥតមាននរណាមួយថ្នាំងថ្នាក់ចិត្តនឹងខ្ញុំឡើយ ( ហេតុអីក៏ ) អ្នកជនបទមិនក្រាបទូលឲ្យទ្រង់ជ្រាប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុត្តកាមាយោ** លោកពោលសំដៅយកស្រីមេផ្ទះប៉ុណ្ណោះ ។ ម្យ៉ាងទៀត ឪពុកដែលជាម្ចាស់ផ្ទះ ក៏ឈ្មោះថា **បុត្ត-កាមាយោ** ។ បទថា **ន ឧបវទន្តិ** សេចក្តីថា មិនចូលទៅពោលទោស គឺមិនពោលជំទាស់ ។ បទថា **អត្រជំ** ប្រែថា កើតអំពីខ្លួន ។ កាលចន្ទកុមារពោលយ៉ាងនេះ បុគ្គលណាម្នាក់ ឈ្មោះថា ជាអ្នកអាចនឹងទូលជាមួយព្រះរាជា មិនមានឡើយ ។ បទថា **ន កោចិ អស្ស បដិឃំ មយា** សេចក្តីថា

បុគ្គលណា សូម្បីត្រឹមតែម្នាក់ ឈ្មោះថា ធ្វើនូវការអាក់អន់ជាមួយយើងថា ព្រះរាជកុមារអង្គនេះ ទទួលសំណូករបស់យើង ឬថា ធ្វើទុក្ខឈ្មោះនេះឲ្យដល់យើង ព្រោះការស្រេវឹងដោយភាពជាធំ ដូច្នេះមិនមានឡើយ ។ បទថា **ជនបទោ ន បវេទេតិ** សេចក្តីថា អ្នកជនបទមិនជួយនាំគ្នាប្រកាស គឺក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាបថា យើងជាបុគ្គលប្រាថ្នាប្រយោជន៍របស់ព្រះរាជានិងរបស់អ្នកជនបទ ដោយប្រការដូច្នេះ ហេតុអ្វី ទើបអ្នកជនបទនេះ មិនក្រាបទូលព្រះរាជបិតារបស់យើងថា ព្រះរាជបុត្ររបស់ព្រះអង្គ ជាអ្នកសម្បូរដោយគុណ ។

កាលចន្ទកុមារត្រាស់យ៉ាងនេះហើយ បុគ្គលណាម្នាក់ មិនបានពោលអ្វីឡើយ ព្រោះហេតុនោះ ទើបព្រះរាជកុមារបញ្ជូនព្រះជាយារបស់ព្រះអង្គ ៧០០ នាក់ ឲ្យទៅអង្វរ ទើបត្រាស់ថា

ម្នាលនាងយរណីទាំងឡាយ ( ស្រីមេផ្ទះ ) ចូរនាងទាំងឡាយ
ទៅអង្វរព្រះរាជបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គ
កុំសម្លាប់កុមារទាំងឡាយ ដូចជាសីហៈ ជាអ្នកមិនប្រទូស្ត ម្នាល
នាងយរណីទាំងឡាយ ចូរនាងទាំងឡាយទៅនិយាយអង្វរព្រះ
បិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារ
ទាំងឡាយ ជាទីអាល័យរបស់សត្វលោកទាំងអស់ ដូច្នេះ ។

មេផ្ទះទាំងនោះទៅក្រាបទូលអង្វរហើយ ព្រះរាជាមិនទតមើលឡើយ ព្រោះដូច្នោះ ព្រះរាជកុមារឥតទីពឹងហើយ ទើបរៀបរាប់ជាគាថានេះថា

បើដូច្នោះ គួរតែអញកើតក្នុងត្រកូលអ្នកធ្វើរថ ឬអ្នកចោលសំរាម ឬកើតក្នុងត្រកូលវេស្សៈ ទើបព្រះរាជានឹងមិនសម្លាប់អញ ដើម្បីយញ្ញក្នុងថ្ងៃនេះ ដូច្នេះ ។

កាលពោលដូច្នេះហើយ ព្រះរាជកុមារ កាលបញ្ជូនព្រះជាយាទាំងឡាយទៅម្តងទៀត ទើបត្រាស់ថា

ម្នាលពួកស្រីអ្នកមានគំនិតទាំងឡាយ ចូរនាងទាំងអស់ ទៅក្រាបទៀបបាទានៃខណ្ឌហាលព្រាហ្មណ៍ជាម្ចាស់ហើយ ( ប្រាប់ថា ) ខ្ញុំមិនឃើញកំហុសសោះ ។ ម្នាលពួកស្រីជាមេផ្ទះទាំងអស់គ្នា ចូរនាងទាំងឡាយទៅក្រាបទៀបបាទា នៃខណ្ឌហាលព្រាហ្មណ៍ជាម្ចាស់ ហើយ ( និយាយថា ) បពិត្រលោកខណ្ឌហាលដ៏ចម្រើន យើងទាំងឡាយ បានប្រទូស្តអ្វីដល់លោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបរាធាហំ ន បស្សាមិ** សេចក្តីថា បពិត្រអាចារ្យខណ្ឌហាល ខ្ញុំមិនឃើញកំហុសរបស់ខ្លួន ។ បទថា **កិំភន្តេ ភន្តេ** សេចក្តីថា បពិត្រលោកម្ចាស់ខណ្ឌហាល ពួកយើងបានប្រទូស្តអ្វីដល់លោក បើចន្ទកុមារមានទោសសោត សូមលោកអត់ទោសផងចុះ ។

លំដាប់នោះ ព្រះកនិដ្ឋកតិនីរបស់ចន្ទកុមារ ព្រះនាមសេលាកុមារី កាលមិនអាចអត់សង្កត់នូវសេចក្តីសោកបាន ក៏ក្រាបចុះទៀបបាទមូលរបស់ព្រះបិតា ហើយកន្ទក់កន្ទេញ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទ

ព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះ ព្រះនាងសេលា ជាព្រះរាជធីតាគួរអាណិត បានឃើញព្រះភាតាទាំងឡាយដែលគេនាំខ្លួនទៅហើយទ្រង់ព្រះកន្សែងថា ឮថា យញ្ញ ព្រះរាជបិតាអញ ទ្រង់ប្រាថ្នាស្ថានសួគ៌ ឲ្យប្រព្រឹត្តទៅហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបនីតត្តេ** បានដល់ មានសភាវៈដែលគេនាំមកដើម្បីបូជាយញ្ញ ។ បទថា **ឧក្ខិបិតោ** សេចក្តីថា ព្រះរាជបិតាត្រាស់ឲ្យលើកឡើងតាំងទុក គឺឲ្យប្រព្រឹត្តទៅ ។ ដោយបទថា **សគ្គកាមេន** នេះព្រះនាងសេលារាជកុមារីខ្សឹកខ្សួលថា ព្រះរាជបិតាសម្លាប់បងប្រុសទាំងឡាយរបស់ខ្ញុំប្រាថ្នាស្ថានសួគ៌ ព្រះអង្គសម្លាប់បងប្រុសទាំងនេះហើយ ទៅស្ថាន-សួគ៌ឬ ។

ព្រះរាជាទ្រង់មិនកាន់យកពាក្យសម្តីរបស់ព្រះនាង លំដាប់នោះ ឱរសរបស់ចន្ទកុមារ ឈ្មោះវសុល កាលឃើញព្រះបិតាទទួលទុក្ខ ក៏គិតថា អញនឹងចូលទៅទូលអង្វរព្រះអយ្យកោ ឲ្យប្រទានជីវិតដល់បិតារបស់អញ ដូច្នេះហើយ ក្រាបចុះទៀបបាទមូលនៃព្រះរាជា ហើយយំសោក ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្យសានូវព្រះគាថាដូច្នេះថា

វសុលរាជកុមារ បម្រះនទៀល ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ទ្រង់ព្រះកន្សែងអង្វរថា បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់បិតារបស់ទូលបង្គំជាខ្ញុំឡើយ ព្រោះទូលបង្គំជាខ្ញុំនៅក្មេង ពុំទាន់ធំនៅឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧហារម្ហា អយោព្វនប្បត្តា** សេចក្ដីថា បពិត្រព្រះសម្មតិទេព ពួកខ្ញុំនៅក្មេងតូច មិនទាន់ដឹងក្ដី សូមទ្រង់កុំសម្លាប់បិតានៃពួកខ្ញុំ ដោយការអាណិតអាសូរដល់ពួកខ្ញុំចុះ ។

ព្រះរាជា ទ្រង់ស្ដាប់សំឡេងយំសោករបស់វសុលកុមារ មានព្រះឱរាស្ទើរបែកសញ្ចែកទ្រង់ឱបក្រសោបព្រះនត្តា មានព្រះនេត្រជិតជាមដោយព្រះអស្សុជល ហើយត្រាស់ថា ចៅសម្លាញ់ ចូរឯងបាននូវខ្យល់ដង្ហើមចុះ អញនឹងលែងបិតារបស់ឯង ហើយទ្រង់ក៏ពោលគាថានេះថា

ម្នាលវសុលកុមារ នុ៎ះបិតារបស់ឯង ចូរឯងស្ងប់រម្ងាប់ជាមួយនឹងបិតារបស់ឯងចុះ ឯងយំស្រែកក្នុងព្រះរាជវាំង ឈ្មោះថា ញុំាងទុក្ខយ៉ាងខ្លាំង ឲ្យកើតឡើងដល់អញ អ្នកទាំងឡាយ ចូរលែងពួកកុមារក្នុងកាលឥឡូវនេះចុះ ការបូជាយញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះបទថា **អន្តេ បុរស្មឹ** បានដល់ ខាងក្នុងព្រះរាជវាំង ។ ខណ្ឌហាលក៏មកពោលទៀតថា

ទូលបង្គំក្រាបទូលព្រះអង្គ តាំងពីដើមមកថា ការបូជាយញ្ញនេះ

ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញ ដែលទូលបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីក៏ព្រះអង្គធ្វើឲ្យអាក់ខានទៅវិញ ។ ជនទាំងឡាយណា បូជាយញ្ញដោយខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងអស់នោះ រមែងទៅកើតក្នុងសុគតិ ដូច្នេះ ។

ចំណែកព្រះរាជាល្ងង់ខ្លៅ ក៏ឲ្យរាជបុរសចាប់ព្រះរាជបុត្រទាំងឡាយមកម្តងទៀត តាមពាក្យរបស់ខណ្ឌហាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបខណ្ឌ-ហាលព្រាហ្មណ៍គិតថា ព្រះរាជាអង្គនេះចិត្តទន់ ម្តងឲ្យលែង ម្តងឲ្យចាប់ព្រះរាជបុត្រទាំងឡាយ ទ្រង់នឹងលែងរាជបុត្រទាំងឡាយ តាមពាក្យទារកទាំងឡាយទៀត កុំដូច្នោះឡើយ អញនឹងនាំទ្រង់ទៅកាន់រណ្តៅយញ្ញតែម្តង ។ លំដាប់នោះ ទើបពោលគាថា ដើម្បីឲ្យទ្រង់យាងទៅក្នុងទីនោះថា

បពិត្រព្រះឯករាជ យញ្ញទូលបង្គំជាខ្ញុំចាត់ចែងរៀបចំ ដើម្បីព្រះអង្គ ដោយរតនៈទាំងពួងហើយ បពិត្រព្រះទេវៈ សូមព្រះអង្គយាងចេញទៅ ព្រះអង្គនឹងទៅរីករាយក្នុងស្ថានសួគ៌ ដូច្នេះ ។

សេចក្តីនៃពាក្យជាគាថានោះថា បពិត្រមហារាជ ទូលបង្គំត្រៀមហើយដោយកែវគ្រប់ប្រការ ដើម្បីព្រះអង្គ ឥឡូវនេះ ជាពេលដែលព្រះអង្គយាងទៅ ព្រោះដូច្នោះ សូមទ្រង់យាងចេញបូជាយញ្ញ ហើយទៅកាន់

ស្ថានសួគ៌ ទ្រង់នឹងត្រេកអរ ។ ក្នុងកាលដែលគេនាំព្រះពោធិសត្វទៅកាន់រណ្តៅ ជាទីបូជាយញ្ញ ស្រីស្នំទាំងឡាយរបស់ព្រះពោធិសត្វនោះក៏បានចេញទៅព្រមគ្នា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាធូវព្រះគាថាដូច្នេះថា

ពួកស្រ្តីទាំង ៧០០ នុ៎ះ នៅក្មេងៗ ដែលជាភរិយាចន្ទកុមារ រំសាយកេសា ទួញយំ ដើរតាមផ្លូវទៅ ។ ចំណែកពួកស្រ្តីឯទៀតក៏ចេញទៅដោយសេចក្តីសោកស្តាយ រំសាយកេសា ទួញយំ ដើរតាមផ្លូវទៅ ដូចជាទេវតា ( ចោមរោមទេវបុត្រ ដែលរៀបច្យុត ) ក្នុងនន្ទវនឧទ្យាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆន្ទនេ វិយ ទេវា** សេចក្តីថា ដូចទេវតាទាំងឡាយចោមរោមទេវបុត្រ ដែលចុតិជាធម្មតា ក្នុងនន្ទនវ័ន ។

បន្ទាប់អំពីនោះ ស្រីស្នំទាំងឡាយយំទួញថា

ចន្ទកុមារ និងសុរិយកុមារ ទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ជាអ្នកទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យញ្ញ នៃព្រះបាទឯករាជ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាប

ដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ ។ ចន្ទកុមារ និងសុរិយកុមារ ដែលជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្ចាន់ព្រះកេសផ្លូតៗ ស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅ ដើម្បីប្រយោជន៍ដល់យញ្ញ នៃព្រះបាទឯករាជ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគនូវសាច់ដ៏មានរស ជាអ្នកដែលខ្ចាន់ព្រះកេសផ្លូតៗ ស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្ចាន់ព្រះកេសផ្លូតៗ ស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ ។ កាលពីមុន ពួកពលដំរី តែងតាមហែហមនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងដំរីដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារ ទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ពួកពលសេះ តែងតាមហែ

នូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងសេះដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារ ទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ពួករថ តែងតាមហែនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់ក្នុងកណ្ដាលរថដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារ ទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ។ កាលពីមុន ចន្ទកុមារ និងសុរិយកុមារណា ស្ដេចទៅដោយព្រះទីនាំងអស្សតរ ដែលតាក់តែដោយគ្រឿងមាស ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារ ទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាសិកសុចិវត្ថធរា** សេចក្ដីថា ចន្ទកុមារ និងសុរិយកុមារទ្រទ្រង់នូវសំពត់សស្អាតរបស់អ្នកដែនកាសី ។ បទថា **ចន្ទសុរិយា** បានដល់ ព្រះចន្ទកុមារ និងសុរិយកុមារ ។ បទថា **ឆ្លាបកសុឆ្លាតា** ឈ្មោះថា ស្រពស្រន់ព្រះកាយល្អ ព្រោះលាបដោយលម្អិតខ្លឹមចន្ទន៍ ហើយធ្វើនូវការប្រោះព្រំដោយគ្រឿងលាបផ្សេងៗ ។ បទថា **យស្សុ** កាត់បទជា **យេ អស្សុ** នេះ ត្រឹមតែជានិបាត អធិប្បាយថា នូវព្រះរាជកុមារពួកណា ។ បទថា **បុព្វេ** បានដល់ ក្នុងកាលមុនអំពីនេះ ។ បទថា **ហត្ថិវរធុរគតេ** បានដល់ យាងឡើងកាន់កដីរដ៏ប្រសើរ គឺឡើងកាន់កដីរដ៏ប្រសើរ ដែលគេប្រដាប់តាក់តែងហើយ ។ បទថា **អស្សវរធុរគតេ** បានដល់ ដែលឡើងកាន់ខ្នងសេះដ៏ប្រសើរ ។ បទថា **រថវរធុរគតេ** បានដល់ ដែលគង់ត្រង់កណ្ដាលរថ

ដ៏ប្រសើរ ។ បទថា **ធីយំសុ** ប្រែថា ចេញទៅហើយ ។ កាលស្រីទាំងនោះ បរិទេវនាការយ៉ាងនេះ រាជបុរសនាំព្រះពោធិសត្វចេញអំពីព្រះនគរ ។ ក្នុងកាលនោះ អ្នកនគរក៏រំជើបរំជួលឡើង ។ អ្នកនគរប្រាថ្នានឹងចេញអំពីព្រះនគរ កាលមហាជនកំពុងចេញទៅ ទ្វារទាំងឡាយក៏មិនគ្រប់គ្រាន់ ព្រាហ្មណ៍ឃើញមនុស្សច្រើនពេក ក៏គិតថា អ្នកណានឹងដឹងថា មានអ្វីកើតឡើង ក៏ប្រើឲ្យបិទទ្វារនគរ កាលមហាជនចេញមកមិនបាន ក៏នាំគ្នាស្រែកយំទ្រហឹងអឺងកងក្នុងទីមួយ ក្បែរទ្វារ ខាងក្នុងព្រះនគរ ហ្វូងបក្សីទាំងឡាយ នាំគ្នាភិតភ័យ ដោយសំឡេងយំនោះ ហើរទៅកាន់អាកាស មហាជនហៅបក្សីនោះហើយ យំរៀបរាប់ថា

ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកព្រះរាជបុត្រ ៤ ព្រះអង្គ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជកាន់ស្មារតី ទ្រង់យកព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកព្រះមហេសីទាំង ៤ ព្រះអង្គ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់

ស្មារតី ទ្រង់យកគហបតីទាំង ៤ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកដំរីទាំង ៤ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតីទ្រង់យកសេះទាំង ៤ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតី ទ្រង់យកគោឧសភ ៤ បូជាយញ្ញក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ កាន់ស្មារតីទ្រង់យកសត្វ បួនៗ គ្រប់មុខ បូជាយញ្ញក្នុងទីនុ៎ះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មំសមិច្ឆសិ** សេចក្តីថា បក្សីដ៏ចម្រើន បើអ្នកប្រាថ្នាសាច់ ។ បទថា **ឧយ្យស្សុ បុរេន បុប្ផវតិយាយំ** សេចក្តីថា ចូរអ្នកហើរទៅក្នុងទីដែលមានការបិទបាំងដើម្បីបូជាយញ្ញ តាមទិសខាងកើតនៃបុប្ផវតីនគរ ។ បទថា **យជតេត្ថ** សេចក្តីថា ក្នុងទីនោះ ព្រះបាទឯករាជដែលជាអ្នកវង្វេង ទ្រង់ជឿនូវពាក្យខណ្ឌហាលព្រាហ្មណ៍ នឹងបូជាដោយព្រះរាជឱរស ៤ អង្គ ក្នុងគាថាដ៏សេស គប្បីជ្រាបដោយន័យនេះដូចគ្នា ។

មហាជននាំគ្នាកន្ទក់កន្ទេញក្នុងទីនោះ ដោយប្រការដូច្នេះ ទើបទៅកាន់ទីលំនៅរបស់ព្រះពោធិសត្វ កាលធ្វើប្រទក្សិណប្រាសាទ ឃើញព្រះដំណាក់

និងផ្ទះកំពូលខាងក្នុងព្រះនគរ និងទីផ្សេងៗ មានឧទ្យានជាដើម ទើបពោលរំរឹកខ្សួលដោយគាថាដូច្នេះថា

ប្រាសាទនេះ ជាវិការនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ផ្ទះកំពូលនេះ ជាវិការនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ឧទ្យាននេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃអសោកនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃកណិការនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃប្រទៀងនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃស្វាយនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ស្រះបោក្ខរណីនេះ ដេរដាសពាសពេញដោយផ្កាឈូកស ឈូកក្រហម ទាំងទូកដែលរចនាដោយមាស វិចិត្រដោយភ្ញីវល្លិ៍ ជាទីរីករាយចិត្តដោយក្រៃលែង ឥឡូវនេះ ព្រះអយ្យបុត្រ

ទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេធានិ** សេចក្ដីថា ឥឡូវនេះ អយ្យបុត្រទាំង ៤ របស់យើង មានចន្ទកុមារជាប្រធាន លះបង់ប្រាសាទបែបនេះ ត្រូវគេនាំទៅសម្លាប់ ។ បទថា **សោវណ្ណាវិកតា** ប្រែថា រំលេចដោយមាស ។

មនុស្សទាំងឡាយ រវើរវាយក្នុងទីមានប្រមាណប៉ុណ្ណេះ ទើបនាំគ្នាទៅកាន់រោងដំរីជាដើម ហើយពោលថា

ដំរីរ័តន៍នេះ ជាដំរីឈ្មោះឯរាវ័ណ មានកម្លាំង មានភ្លុក ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ សេះរ័តន៍នេះ ជាសេះមានក្រចកមួយ មានសម្ទុះរហ័ស ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ រថសេះនេះ មានសូរសព្ទដូចសំឡេងនៃស្រូវសាលី ជារថដ៏ស្អាតវិចិត្រដោយរតនវត្ថុ ជាលម្អរបស់ពួកអយ្យបុត្រ ដូចជាពួកទេវតាក្នុងនន្ទនវ័ន ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ម្ដេចក៏ព្រះរាជាកាន់ប្រទ្បំ និងបូជាយញ្ញដោយព្រះរាជបុត្រទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ( ឥតទោស ) ដែលមានខ្លួនលាបហើយ ដោយខ្លឹមចន្ទន៍ ។ ម្ដេចក៏ព្រះរាជាកាន់ប្រទ្បំ និងបូជាយញ្ញដោយព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹម

ចន្ទន៍ ។ ម្តេចក៏ព្រះរាជាកាន់ប្រឡំ និងបូជាយញ្ញដោយព្រះមហេសី ទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍ ។ ម្តេចក៏ព្រះរាជាកាន់ប្រឡំ និងបូជាយញ្ញដោយគហបតីទាំង ៤ នាក់ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបដោយខ្លឹមចន្ទន៍ ។ ស្រុក និងនិគមទាំងឡាយ សូន្យឥតមនុស្ស ក្លាយទៅជាព្រៃធំ យ៉ាងណាមិញ កាលបើចន្ទកុមារ និងសុរិយកុមារ ត្រូវព្រះរាជាយកទៅបូជាយញ្ញហើយ ក្រុងបុប្ផវតី ក៏នឹង ( ស្ងាត់សូន្យឈឹង ) យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯរាវណោ** នេះ ជាឈ្មោះដំរីនោះ ។ បទថា **ឯកពុន្ទោ** បានដល់ មានក្រចកមិនបែក ។ បទថា **សាលិយា វិយ និគ្ឃោសោ** សេចក្តីថា ក្នុងពេលទៅ ប្រកបដោយសំឡេងពីរោះ ដូចសំឡេងរបស់បក្សីសាលិកាទាំងឡាយ ។ បទថា **កញ្ចនាម សាមសមសុន្ទរេហិ** សេចក្តីថា មានពណ៌សម្បុរលឿងដូចមាស ស្មើគ្នានិងគ្នាដោយកំណើត ឈ្មោះថា **សុន្ទរេហិ** ព្រោះប្រាសចាកទោស ។ បទថា **ចន្ទនមុទុកគត្តេហិ** បានដល់ មានអវយវៈលាបដោយខ្លឹមចន្ទន៍ក្រហម ។ បទថា **ព្រហារញ្ញា** សេចក្តីថា គាម និងនិគម ទាំងនោះទទេ មិនមានមនុស្ស ក្លាយជាព្រៃធំ យ៉ាងណា កាលព្រះរាជាទ្រង់បូជាយញ្ញដោយព្រះឱរសទាំងឡាយ នគរបុប្ផវតី ក៏នឹងស្ងាត់ទទេ ដូចព្រៃធំ ដូច្នោះ ។

មហាជនទាំងនោះ កាលមិនបានចេញទៅខាងក្រៅ ក៏នាំគ្នាកន្ទក់កន្ទេញ ត្រាច់ទៅខាងក្នុងព្រះនគរនោះឯង ឯព្រះពោធិសត្វ ត្រូវនាំទៅកាន់រណ្តៅបូជាយញ្ញ ។ លំដាប់នោះ ព្រះមាតារបស់ព្រះពោធិសត្វ ព្រះនាមគោតមីទេវី ក្រាបចុះទៀបបាទមូលនៃព្រះរាជាទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រទានជីវិតដល់បុត្រទាំងឡាយរបស់ខ្ញុំម្ចាស់ ព្រះនាងព្រះកន្សែងទូលថា

ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាកសេចក្តីចម្រើន ប្រឡាក់ប្រឡូស ដោយអាចម៍ដីពុំខាន បើជនសម្លាប់ចន្ទកុមារ បពិត្រព្រះសម្មតិ-ទេព ជីវិតរបស់ខ្ញុំម្ចាស់ នឹងបែកធ្លាយ ។ ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាកសេចក្តីចម្រើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើជនសម្លាប់សុរិយកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់ នឹងបែកធ្លាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភូនហាតា** បានដល់ មានសេចក្តីចម្រើនត្រូវកម្ចាត់ហើយ ។ បទថា **បំសុនាវ បរិកិណ្ណា** សេចក្តីថា ខ្ញុំមានសរីរៈប្រឡាក់ដោយធូលី នឹងក្លាយជាមនុស្សឆ្កួត ត្រាច់ទៅ ។

ព្រះនាងគោតមីទេវី កាលកន្ទក់កន្ទេញយ៉ាងនេះ មិនបានទទួលព្រះរាជតម្រាស់ណាមួយអំពីសម្នាក់ព្រះរាជា ទើបព្រះនាងពោលដល់កូនប្រសាទាំងឡាយថា ប្រហែលជាកូនរបស់អញក្រោធ ហើយនឹងទៅទេដឹង ហេតុអ្វីមិនឲ្យត្រឡប់មក ព្រះនាងឱបក្រសោបព្រះជាយាទាំង ៤ របស់ព្រះរាជកុមារ ហើយ ក៏ពោលរៀបរាប់ថា

ស្ត្រីទាំងឡាយនេះ គឺនាងយដ្ឋិកា នាងឧបរិក្ខី នាងបោក្ខរណី នាងគាយិកា ជាអ្នកពោលពាក្យជាទីស្រឡាញ់ ទៅរកគ្នានិងគ្នា ម្តេចក៏មិនរាំឲ្យចន្ទកុមារ និងសុរិយកុមារសប្បាយរីករាយ ( ព្រោះស្ត្រីដទៃ ) ស្មើដោយស្ត្រីទាំងនោះមិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្នុមា ន រមាបេយ្យុំ** សេចក្តីថា ព្រោះហេតុអ្វី កូនប្រសាស្រីទាំង ៤ មាននាងយដ្ឋិកាជាដើមនេះ មិនពោលពាក្យគួរជាទីត្រេកអរដល់គ្នានិងគ្នា រាំ ច្រៀង ក្នុងសម្នាក់របស់ចន្ទកុមារ និងសុរិយកុមារ មិនធ្វើឲ្យព្រះរាជឱរសទាំង ២ របស់យើងត្រេកអរ គឺមិនឲ្យអផ្សុក អធិប្បាយថា ពិតហើយ ការរាំ ឬច្រៀង ក្នុងជម្ពូទ្វីបទាំងមូលនេះ អ្នកដទៃដែលស្មើនឹងព្រះនាងទាំង ៤ នេះ មិនមាន ។

ព្រះនាងទ្រង់ខ្សឹកខ្សួលជាមួយព្រះសុណិសា ដូច្នេះហើយ កាលមិនឃើញឧបាយដែលគួរកាន់យកដទៃ ទើបពោល ៨ គាថា ផ្តាសាខណ្ឌហាលថា

សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារ ដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯងចូរទទួលយកសេចក្តីសោក ក្នុងហឫទ័យនៃអញនេះទៅចុះ ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារ ដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯង ចូរទទួលយកសេចក្តីសោក ក្នុងហឫទ័យនៃអញនេះទៅចុះ ។ សេចក្តី

សោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារ ដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង ចូរទទួលយកសេចក្ដីសោក ក្នុងហឫទ័យនៃអញនេះទៅចុះ ។ សេចក្ដីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារ ដែលគេនាំយកទៅសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធរបស់អ្នក ចូរទទួលយកសេចក្ដីសោក ក្នុងហឫទ័យនៃអញនេះទៅចុះ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នៃខណ្ឌហាលព្រាហ្មណ៍ ម្ដាយអ្នកឯងកុំបានឃើញកូនទាំងឡាយផង ប្ដីផងឡើយ។ អ្នកឯងសម្លាប់ពួកកុមារដែលសត្វលោកទាំងអស់ អាឡោះអាល័យ នៃខណ្ឌហាលព្រាហ្មណ៍ ម្ដាយអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្ដីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នៃខណ្ឌហាល-ព្រាហ្មណ៍ ប្រពន្ធអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្ដីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសត្វលោកទាំងអស់ អាឡោះអាល័យ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្ដីផងឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥមំ មយ្ហំ** សេចក្ដីថា សេចក្ដីសោករបស់អញនេះ ចាត់ជាទុក្ខ ។ បទថា **បដិមុញ្ចតុ** សេចក្ដីថា ចូរទៅ គឺចូរដល់ ។ បទថា **យោ ឃាតេសិ** សេចក្ដីថា អ្នកណាឲ្យសម្លាប់ ។ បទថា **អបេក្ខិតេ**

សេចក្តីថា អ្នកណា រមែងសម្លាប់បុគ្គលដែលសត្វលោកទាំងពួងសម្លឹងមើល គឺឃើញ ។

ព្រះពោធិសត្វកាលទូលអង្វរព្រះបិតាត្រង់រណ្តៅយញ្ញ ទើបពោលថា បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយឃ្វាលដំរី និងសេះ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយបោលអាចម៍ដំរី ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយបោលអាចម៍សេះ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំឡើយ បើព្រះអង្គសព្វព្រះហឫទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត សូមព្រះអង្គបំបរបង់ឲ្យចេញចាកដែន ខ្ញុំព្រះអង្គនឹងត្រាច់ទៅកាន់កិក្ខាចារ ។ បពិត្រព្រះសម្មតិទេព នារីពួកខ្លះ

សូម្បីជាស្ត្រីកម្សត់ នៅតែចង់បានកូន ហើយបន់ស្រន់ទេព្តា ស៊ូលះបង់ចំណង់ប្លែក នៅតែមិនបានកូនទាំងឡាយ ក៏មាន ។ នារីពួកខ្លះ ធ្វើពាក្យប្រកបដោយសេចក្តីប៉ុនប៉ងថា កូនទាំងឡាយរបស់យើង ចូរកើត បន្ទាប់ពីនោះ ចៅទាំងឡាយ ចូរកើតទៀត បពិត្រព្រះសម្មតិទេព កាលបើដូច្នេះ ( ហេតុអ្វីក៏ ) ព្រះអង្គសម្លាប់ទូលព្រះបង្គំទាំងឡាយ ដើម្បីបូជាយញ្ញ ដោយមិនសមហេតុ ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ ព្រះអង្គកុំបូជាយញ្ញនេះដោយបុត្រទាំងឡាយ ដែលបានដោយលំបាកឡើយ ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមព្រះអង្គកុំញុំាងទូលព្រះបង្គំទាំងឡាយ ឲ្យព្រាត់ប្រាសចាកមាតា និងបុត្រទាំងឡាយដែលបានដោយលំបាក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឩត្យ** សេចក្តីថា បពិត្រព្រះសម្មតិទេព នារីទាំងឡាយដែលមិនមានកូន សូម្បីក្រីក្រ ក៏ជាអ្នកត្រូវការបុត្រ នាំបណ្ណាការជាច្រើនទៅបន់ស្រន់ទេវតាថា សូមឲ្យខ្ញុំបានកូនស្រី ឬកូនប្រុស ដូច្នេះ ។ បទថា **បដិភាណានិបិ ហិត្វា** សេចក្តីថា សូម្បីលះហើយ គឺមិនបានហើយនូវការតាំងគភ៌ លោកអធិប្បាយថា បពិត្រមហារាជ គភ៌របស់នារីទាំងឡាយដែលមិនបានការតាំងគភ៌កើតឡើង រមែងស្ពាំងស្គម អន្តរធានទៅ ។ ក្នុង

បណ្តាស្រីទាំងនោះ ស្រីពួកខ្លះ កាលមិនបានកូន ក៏សូម ស្រីពួកខ្លះ លះបង់នូវការតាំងគភ៌ ដែលបានហើយ មិនបរិភោគ ( មិនថែរក្សា ) ក៏មិនបាននូវបុត្រ ។ ស្រីខ្លះ កាលមិនបាននូវការតាំងគភ៌ ក៏មិនមាននូវបុត្រ តែមាតារបស់ខ្ញុំ បានហើយនូវការតាំងគភ៌ ហើយបរិភោគ ( ថែរក្សា ) នឹងមិនបានបណ្តោយឲ្យគភ៌ដែលកើតឡើងហើយ វិនាសទៅ ទើបបានកូនទាំងឡាយ ។ ព្រះរាជកុមារទ្រង់អង្វរថា សូមទ្រង់កុំសម្លាប់យើងខ្ញុំទាំងឡាយ ដែលជារាជបុត្រ ដែលបានមកដោយប្រការដូច្នេះ ។ បទថា **អាសាសិកានិ** សេចក្តីថា បពិត្រមហារាជ សត្វទាំងនេះ រមែងធ្វើសេចក្តីសង្ឃឹមថា សូមកូនទាំងឡាយ កើតឡើងដល់អញ ។ បទថា **តតោ បបុត្តា** សេចក្តីថា សូមបុត្រទាំងឡាយ កើតដល់កូនទាំងឡាយរបស់អញ ។ បទថា **អថ នោ អការណស្មា** សេចក្តីថា កាលបើដូច្នេះ ទ្រង់ បានឈ្មោះថា សម្លាប់ពួកខ្ញុំព្រះអង្គដើម្បីជាប្រយោជន៍ដល់ការបូជាយញ្ញ ដោយហេតុមិនសមគួរឡើយ ។ បទថា **ឧបយាចិតកេន** បានដល់ ដោយការអង្វរទេវតាទាំងឡាយ ។ បទថា **កបណាលទ្ធកេហិ** ព្រះរាជឱរសត្រាស់ថា សូមទ្រង់កុំធ្វើនូវការព្រាត់ប្រាសចាកមាតារបស់ទូលព្រះបង្គំនឹងពួកទូលបង្គំដែលជាបុត្រ ដែលម្តាយបានមកដោយលំបាកឡើយ សូមកុំធ្វើនូវការព្រាត់ប្រាសចាកពួកទូលព្រះបង្គំនឹងមាតាឡើយ ។

ចន្ទកុមារកាលទូលអង្វរដោយអាការយ៉ាងនេះ ក៏មិនបានចម្លើយណាមួយអំពីសម្នាក់បិតា ទើបក្រាបចុះទៀបបាទមូលរបស់ព្រះមាតាបណ្តើរ

បរិទេវនាការបណ្ដើរថា

បពិត្រព្រះមាតា ព្រះអង្គបានបង្កើតបុត្រ គឺចន្ទកុមារមក មានទុក្ខព្រួយច្រើនណាស់ ព្រោះតែការចិញ្ចឹម ខ្ញុំជាកូន សូមក្រាបថ្វាយបង្គំព្រះបាទានៃព្រះមាតា សូមឲ្យព្រះរាជបិតាបានទៅបរលោក (ដែលបរិបូណ៌ដោយសម្បត្តិ) ចុះ ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងទៅកាន់ទីព្រាត់ប្រាស ដើម្បីប្រយោជន៍ដល់យញ្ញរបស់ព្រះបាទឯករាជ ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្ដីសោកក្នុងហឫទ័យនៃព្រះមាតា ហើយទៅកាន់ទីព្រាត់ប្រាស ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្ដីសោកក្នុងហឫទ័យនៃជន ហើយទៅកាន់ទីព្រាត់ប្រាស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពហុទុក្ខំ បោសិយា** សេចក្ដីថា ព្រះមាតាទ្រង់ចិញ្ចឹមកូនមកដោយលំបាក ។ បទថា **ចន្ទំ** សេចក្ដីថា បពិត្រព្រះមាតា ទ្រង់ចិញ្ចឹមនូវបុត្រ គឺចន្ទកុមារ ដោយប្រការដូច្នេះ ឥឡូវនេះ ព្រះនាងរមែងទ្រង់ជរា ។ បទថា **លភតំ តាតោ បរលោកំ** សេចក្ដីថា សូមព្រះរាជបិតារបស់ខ្ញុំទៅកាន់បរលោកដែលសម្បូរដោយភោគៈចុះ ។ បទថា **ឧបគូហ**

សេចក្តីថា សូមឪប គឺឪបរឹត ។ បទថា **បវាសំ** សេចក្តីថា ជាការព្រាត់ប្រាសយ៉ាងពិត ដោយមិនបានវិលត្រឡប់មកទៀត ។

លំដាប់នោះ ព្រះមាតារបស់ចន្ទកុមារ កាលទ្រង់បរិទេវនាការ ទើបត្រាស់ ៤ គាថាដូច្នេះថា

ម្នាលគោតមីបុត្រ ណ្ហើយចុះ បាឯងចូរបួងមោលីដោយស្លឹកឈូក បាឯងចូរប្រដាប់ផ្កាកម្រង ដែលលាយដោយត្របកផ្កាចម្ប៉ា នេះជាប្រក្រតីពីដើមរបស់បា ។ ហក បាឯងធ្លាប់លាបស្រឡាបដោយខ្លឹមចន្ទន៍ទាំងឡាយណា ហើយល្អរុងរឿងក្នុងរាជបរិស័ទ ( នេះ ) ជាគ្រឿងលាបរបស់បា បាចូរលាបខ្លឹមចន្ទន៍ជាទីបំផុតចុះ ។ ហក បាឯងស្លៀកដណ្តប់សំពត់ទាំងឡាយណា មានសាច់ទន់ៗ រមែងល្អរុងរឿងក្នុងរាជបរិស័ទ ( នេះ ) ជាសំពត់មានសាច់ទន់ បាចូរស្លៀកសំពត់ដែលកើតក្នុងដែនកាសី មានក្នុងទីបំផុតចុះ ។ បាឯងល្អរុងរឿងដោយហត្ថាភរណៈណា ក្នុងរាជបរិស័ទ បាចូរពាក់នូវហត្ថាភរណៈដ៏ហើយដោយកែវមុក្តា កែវមណី និងមាស ( នោះ ) ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បទុមបត្តាឆំ** សេចក្តីថា នូវគ្រឿងប្រដាប់ម្យ៉ាង ឈ្មោះបទុមបត្តវេឋនៈ សំពត់ជូតក្បាលសម្រាប់ចងមោលី ដែលធ្វើដោយស្លឹកឈូក ។ ព្រះនាងគោតមីទ្រង់បំណាងយកគ្រឿងប្រដាប់នោះឯង ទើបត្រាស់យ៉ាងនោះ អធិប្បាយថា ចូរឯងចងនូវមោលីរបស់ឯង ដែលខ្ចាត់

ខ្លាយហើយ ចូរចងដោយបទុមបត្តវេឋនៈ ។ ព្រះនាងហៅព្រះចន្ទកុមារដោយពាក្យថា **គោតមិបុត្ត**។ បទថា **ចម្បកទលមិស្សាយោ** សេចក្តីថា ចូរឯងប្រដាប់ដោយកម្រងផ្កាច្រើនប្រភេទ ដែលសម្បូរដោយពណ៌ និងក្លិន សៀតដោយត្របកចម្ប៉ា សៀតស្មៀតសក់ខាងក្នុង ។ ដោយបទថា **ឯសា តេ** នេះ ព្រះនាងខ្សឹកខ្សួលថា នេះជាប្រក្រតីរបស់កូនក្នុងកាលមុន ចូរលាបស្រឡាបនូវគ្រឿងលាប និងលម្អិតនោះឯង ។ បទថា **យេហិ ច** សេចក្តីថា ចូរឯងលាបដោយគ្រឿងលាប គឺចន្ទក្រហមទាំងឡាយណា ចូរឯងស្អាតក្នុងរាជ-បរិស័ទ ចូរឯងលាបដោយគ្រឿងក្រអូប គឺលម្អិតចន្ទក្រហមទាំងនេះចុះ ។ បទថា **កាសិកំ** បានដល់ សំពត់កាសិកពស្ត្រដែលមានតម្លៃមួយសែន ។ បទថា **គណ្ហស្សុ** សេចក្តីថា ចូរប្រដាប់ ។

ឥឡូវនេះ ព្រះនាងចន្ទា ដែលជាអគ្គមហេសីរបស់ចន្ទកុមារ ក្រាបចុះទៀបបាទមូលរបស់ព្រះរាជា កន្ទក់កន្ទេញថា

ព្រះបាទឯករាជនេះ ជាអ្នករក្សាដែន ជាម្ចាស់ផែនដី ជាអ្នកទទួល
មតិករបស់អ្នកជនបទ ជាឥស្សរៈលើលោក ទ្រង់ជាធំ តែមិន
ញ៉ាំងសេចក្តីស្នេហាឲ្យកើតក្នុងព្រះរាជបុត្រដោយពិត ដូច្នេះ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ត្រាស់គាថានេះថា

បុត្រប្រុសទាំងឡាយ ជាទីស្រឡាញ់របស់អញ ម្យ៉ាងទៀត នាង
ឯងក្តី ភរិយាទាំងឡាយ ( ឯទៀត ) ក្តី ក៏ជាទីស្រឡាញ់របស់
អញ ប៉ុន្តែ អញចង់បានស្ថានសួគ៌ទេតើ បានជាអញឲ្យគេសម្លាប់

ដោយហេតុនោះ ដូច្នេះ ។

សេចក្តីនៃព្រះតម្រាស់នោះ ដូច្នេះថា ព្រោះហេតុអ្វី ទើបមិនកើតការស្រឡាញ់កូន ពិតហើយ កូនទាំងឡាយជាទីស្រឡាញ់របស់អញ មិនមែនតែគោតមីមួយអង្គប៉ុណ្ណោះទេ សូម្បីអញក៏មានការស្រឡាញ់បុត្រទាំងឡាយ ខ្លួនឯងក្តី ក៏ជាទីស្រឡាញ់ នាងទាំងឡាយជាកូនប្រសាក្តី ករិយាទាំងឡាយក្តី ក៏ជាទីស្រឡាញ់របស់អញដូចគ្នា កាលបើដូច្នោះ អញប្រាថ្នានូវស្ថានសួគ៌នោះ ព្រោះហេតុនោះ អញនឹងសម្លាប់កូនទាំងឡាយនេះ នាងកុំគិតថ្វីឡើយ សូម្បីកូនទាំងឡាយរបស់អញ ក៏ទៅនៅជាមួយអញក្នុងទេវលោក ។

ព្រះនាងចន្ទាទូលថា

បពិត្រព្រះសម្មតិទេព សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់មុន កុំឲ្យសេចក្តីទុក្ខបំបែកហឫទ័យខ្ញុំម្ចាស់ឡើយ បពិត្រព្រះសម្មតិទេព បុត្ររបស់ព្រះអង្គជាអ្នកមានគ្រឿងអលង្ការ ប្រដាប់ហើយ ជាបុត្រល្អល្អះជាសុខុមាលជាតិ ។ បពិត្រព្រះអង្គជាម្ចាស់គេ ណ្ហើយចុះ សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់ជាស្ត្រីមានសេចក្តីសោកជាមួយគ្នានឹងចន្ទកុមារ សូមព្រះអង្គធ្វើបុណ្យឲ្យបរិបូណ៌ចុះ យើងខ្ញុំទាំងពីរនាក់នឹងត្រាច់ទៅក្នុងបរលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បឋមំ** សេចក្តីថា បពិត្រព្រះសម្មតិទេព សូមទ្រង់សម្លាប់ខ្ញុំម្ចាស់មុនស្វាមីរបស់ខ្ញុំម្ចាស់ចុះ ។ បទថា **ទុក្ខំ** សេចក្តីថា ទុក្ខអំពីសេចក្តីស្លាប់របស់ព្រះចន្ទកុមារនោះ សូមកុំញុំាំងហទយៈរបស់ខ្ញុំឲ្យ

បែកឡើយ ។ បទថា **អលង្កតោ** សេចក្តីថា ប្រដាប់ហើយដោយអាការ យ៉ាងនេះ គឺព្រះរាជកុមារអង្គនេះមួយអង្គ គេប្រដាប់តាក់តែងហើយសម្រាប់ ខ្ញុំ ព្រះនាងរមែងសម្តែងថា បពិត្រមហារាជ ទ្រង់មិនស្រឡាញ់ព្រះរាជបុត្រ អង្គនេះ ថាជាកូនរបស់អញ ។ បទថា **ហន្តយ្យ** កាត់បទជា **ហន្ទ អយ្យ** ព្រះនាងរវើរវាយយ៉ាងនេះនឹងព្រះរាជា ។ បទថា **សសោកា** សេចក្តីថា ប្រព្រឹត្តទៅដោយសេចក្តីសោកជាមួយចន្ទកុមារ ។ បទថា **ហេស្សាមិ** ប្រែថា នឹងមាន ។ បទថា **វិចរាម ឧភោ បរលោកេ** សេចក្តីថា ខ្ញុំម្ចាស់ និង ចន្ទកុមារដែលព្រះអង្គឲ្យសម្លាប់រួមគ្នា នឹងសោយសុខត្រាច់ទៅក្នុងបរលោក សូមទ្រង់កុំធ្វើអន្តរាយដល់ស្ថានសួគ៌របស់យើងខ្ញុំទាំង ២ ឡើយ ។

ព្រះរាជាត្រាស់ថា

ម្នាលនាងចន្ទា មានភ្នែកវិសេសវិសាល នាងកុំយំឡើយ ជន ទាំងឡាយជាបងប្អូនខាងប្តី របស់នាងជាច្រើន ជនទាំងនោះ នឹង ញុំាងនាងឲ្យត្រេកអរ ព្រោះគោតមីបុត្រ ត្រូវគេបូជាយញ្ញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា តំ ចន្ទេ រុទិ** សេចក្តីថា នាងកុំគាប់ ចិត្តក្នុងការស្លាប់របស់ខ្លួនឡើយ ។ បាលីថា **មា រុទិ** ដូច្នេះក៏មាន សេចក្តី ថា កុំយំឡើយ ។ បទថា **ទេវរា** សេចក្តីថា បងថ្លៃប្អូនថ្លៃរបស់នាងជាអ្នក ប្រសើរ ។

**តមត្ថំ បកាសេន្តោ សត្ថា ឧបឌ្ឍមាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលកន្លះគាថាដូច្នេះថា

កាលបើព្រះបាទឯករាជ ទ្រង់ត្រាស់យ៉ាងនេះហើយ នាងចន្ទាទេវី ប្រហារខ្លួនឯងដោយបាតដៃទាំងឡាយ ដូច្នេះ ។

បន្ទាប់អំពីនោះ ទ្រង់ពិលាបថា

ការរស់នៅក្នុងលោកនេះ ល្មមប៉ុណ្ណឹងហើយ អញនឹងផឹកថ្នាំពិសឲ្យស្លាប់ ។ ព្រោះថា ជនទាំងឡាយ ជាញាតិមិត្រ ជាសម្លាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយ ហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រទាំងឡាយ ដែលកើតអំពីព្រះឱរា ដូច្នេះឡើយ ។ ជនទាំងឡាយ ជាញាតិមិត្រ ជាសម្លាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយ ហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រ ដែលកើតអំពីព្រះអង្គ ដូច្នេះឡើយ ។ បុត្ររបស់ខ្ញុំម្ចាស់ទាំងឡាយនេះ ពាក់កម្រងផ្កា ទ្រទ្រង់គ្រឿងប្រដាប់ជាវិការនៃមាស សូមព្រះរាជាបូជាយញ្ញដោយរាជបុត្រទាំងឡាយចុះ ប៉ុន្តែសូមព្រះអង្គលែងគោតមីបុត្ត ។ បពិត្រមហារាជ សូមព្រះអង្គកាប់ខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បងដែលជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត ។ បពិត្រ

មហារាជ សូមព្រះអង្គចិញ្ច្រាំខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជា យញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បង ដែល សត្វលោកទាំងអស់អាឡោះអាល័យឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃរំ** សេចក្តីថា កាលព្រះបាទឯករាជល្ងង់ ខ្លៅត្រាស់យ៉ាងនោះ ។ ដោយបទថា **ហន្ទិ** សេចក្តីថា ព្រះនាងទូលថា បពិត្រព្រះសម្មតិទេព ហេតុអ្វី ទើបទ្រង់ត្រាស់ដូច្នោះ ហើយវាយព្រះកាយ ដោយបាតដៃ ។ បទថា **បិសុណាមិ** ប្រែថា នឹងផឹក ។ បទថា **ឥមេ តេបិ** សេចក្តីថា ព្រះនាងចាប់ដៃកុមារដ៏សេសទាំងនេះ តាំងពីវសុលកុមារប្រថាប់ ឈរក្បែរបាទមូលរបស់ព្រះរាជា ហើយបានពោលយ៉ាងនោះ ។ បទថា **គុណរិនោ** សេចក្តីថា ប្រកបដោយអាភរណៈ គឺកម្រងផ្កា ។ បទថា **កាយុរធារិនោ** សេចក្តីថា ទ្រទ្រង់នូវគ្រឿងប្រដាប់ គឺកងដៃមាស ។ បទថា **វិលសតំ** សេចក្តីថា បពិត្រមហារាជ ទ្រង់សម្លាប់ខ្ញុំ ហើយចែកជា ១០០ ចំណែក ។ បទថា **សត្តធា** សេចក្តីថា សូមបូជាយញ្ញក្នុងទី ៧ កន្លែង ។

លំដាប់នោះ ព្រះនាងចន្ទាទេវីនោះ ទ្រង់កន្ទក់កន្ទេញក្នុងសម្នាក់ព្រះរាជា ដោយគាថាទាំងនេះហើយ កាលមិនបាននូវការស្រោកស្រាន្តចិត្ត ទើបយាង ទៅកាន់សម្នាក់ព្រះពោធិសត្វនោះឯង ហើយឈរយំ ។ លំដាប់នោះ ព្រះ ចន្ទកុមារត្រាស់ដល់ព្រះនាងចន្ទាថា នែចន្ទានាងពោលល្អដល់រឿងផ្សេងៗ កាលយើងនៅមានជីវិត យើងឲ្យអាភរណៈដល់នាងសន្ទឹកសន្ធាប់ មានកែវ មុក្តាជាដើម ដែលប្រសើរ និងមិនប្រសើរ តែក្នុងថ្ងៃនេះ យើងនឹងឲ្យ

អាភរណៈដែលប្រដាប់ត្រង់កាយរបស់យើងនេះ ជារបស់យើងក្នុងគ្រាចុងក្រោយ ចូរនាងទទួលនូវអាភរណៈនេះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួរព្យសានូវព្រះគាថាដូច្នេះថា

គ្រឿងអាភរណៈច្រើនយ៉ាង គឺកែវមុក្តា កែវមណី កែវពៃទូរ្យ ដែលប្រសើរ និងមិនប្រសើរ យើងឲ្យហើយដល់នាង ក្នុងរឿងដែលនាងនិយាយល្អហើយ នេះជាអំណោយទីបំផុត ចូរមានដល់នាងចុះ ដូច្នេះ ។

ឯព្រះនាងចន្ទាទេវី កាលស្តាប់ពាក្យព្រះស្វាមីហើយ ពោល ៩ គាថាដទៃអំពីនោះថា

កាលពីដើម រាជបុត្រទាំងឡាយណា ដែលមានកម្រងផ្កាវីកសំពោង ពាក់ហើយលើកទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវដែលគេសំលៀងមុត នឹងធ្លាក់លើ-កទាំងឡាយវិញ ។ ពីដើម ព្រះរាជបុត្រទាំងឡាយណា ដែលមានកម្រងផ្កាដ៏វិចិត្រហើយ ពាក់លើ-កទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្តទាំងនោះ ត្រឡប់ទៅជាមានដាវដែលគេសំលៀងមុត នឹងធ្លាក់លើ-កទាំងឡាយវិញ ។ មិនយូរប៉ុន្មានទេ មុខតែដាវនឹងធ្លាក់លើ-កនៃរាជបុត្រទាំងឡាយពុំខាន ហឫទ័យរបស់ខ្ញុំម្ចាស់ ខាន

បែកធ្លាយឯណាបាន ព្រោះចំណងយ៉ាងមាំមានដល់ខ្ញុំម្ចាស់ហើយ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់សាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅដើម្បីយញ្ញនៃព្រះបាទឯករាជចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយជាអ្នកទ្រទ្រង់សំពត់ មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរចេញទៅចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជន ដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្លូតៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅដើម្បីយញ្ញរបស់ព្រះបាទឯករាជចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជន ដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្លូតៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យ

នៃមាតា ចូរស្តេចចេញទៅចុះ ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជន ដែលលាយដោយសាច់ មានរស ជាអ្នកដែលពួកអ្នកផ្សេងៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ផុល្លា មាលា** បានដល់ កម្រងផ្កា ។ បទថា **តេសជ្ជ** កាត់បទជា **តេសំ អជ្ជ**។ បទថា **នេត្តិំសោ** កែជា **អសិ** ប្រែថា ដាវ ។ បទថា **វិវត្តិស្សតិ** ប្រែថា នឹងធ្លាក់ ។ បទថា **អចិរា វត** បានដល់ មិនយូរទេហ្ន៎ ។ បទថា **ន ផលតិ** ប្រែថា មិនបែក ។ បទថា **តាវ ទឡ្ហ-ពន្ធនញ្ច មេ អាសិ** សេចក្តីថា នឹងមានគ្រឿងចងដែលមាំក្រៃលែង នឹងចងហទយៈនៃយើង ។ បទថា **និយ្យាថ** បានដល់ យាងចេញទៅ ។

កាលព្រះនាងចន្ទាកន្ទក់កន្ទេញយ៉ាងនោះ ការងារគ្រប់យ៉ាងក្នុងរណ្តៅសម្រេចហើយ អមាត្យទាំងឡាយ នាំព្រះរាជបុត្រមកហើយ ឲ្យឱន-ក លុតជង្គង់ចុះ ខណ្ឌហាលព្រាហ្មណ៍ បង្អោនថាសមាសទៅជិតហើយ ដកដាវមកកាន់ ហើយឈរ ដោយបំណងថា អញនឹងកាត់កព្រះរាជកុមារ ។ ព្រះនាងចន្ទាទេវីឃើញដូច្នោះ គិតថា ទីពឹងដទៃរបស់អញមិនមាន អញនឹងធ្វើសួស្តីដល់ព្រះស្វាមី ដោយកម្លាំងសច្ចៈរបស់អញ ទើបផ្គងអញ្ជលី យាងទៅក្នុងរវាងនៃប្រជុំជន ហើយធ្វើសច្ចកិរិយា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួបសានូវព្រះគាថាដូច្នេះថា

កាលបើគ្រឿងប្រដាប់បូជាយញ្ញគ្រប់យ៉ាង ដែលគេចាត់ចែងហើយ កាលបើចន្ទកុមារ និងសុរិយកុមារ អង្គុយដើម្បីប្រយោជន៍ដល់យញ្ញហើយ នាងបញ្ចាលរាជធីតា លើកកម្បង់អញ្ជលី ដើរចូលទៅត្រង់ចន្លោះពួកបរិស័ទទាំងពួង ( ប្រកាសថា ) ខណ្ឌហាល-ព្រាហ្មណ៍ ជាមនុស្សយល់ខុស ធ្វើបាបកម្ម ដោយពាក្យសច្ចៈណា ខ្ញុំម្ចាស់ព្រមព្រៀងជាមួយនឹងព្រះស្វាមីតាមពាក្យសច្ចៈនុ៎ះ ។ ពួកអមនុស្ស ពួកទេវតា និងពួកសត្វកើតហើយ និងសត្វដែលត្រូវកើតមានក្នុងទីនេះ ចូរធ្វើនូវសេចក្តីខ្វល់ខ្វាយចំពោះខ្ញុំ ខ្ញុំសូមព្រមព្រៀង ( ជាមួយ ) នឹងព្រះស្វាមីហើយ ។ ពួកទេវតា ពួកសត្វកើតហើយ និងសត្វដែលត្រូវកើតទាំងអស់ ដែលមកក្នុងទីនេះ សូមអ្នកទាំងឡាយរក្សាខ្ញុំជាមនុស្សអនាថា ដែលស្វែងរកទីពឹង ខ្ញុំសូមអង្វរ ព្រះស្វាមីដែលពួកបច្ចាមិត្តផ្ចាញ់មិនបានចំពោះលោកទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបក្ខតស្មឹ** សេចក្តីថា កាលគេរៀបចំគ្រឿងបូជាយញ្ញ មួយអន្លើដោយវត្ថុគ្រប់យ៉ាង ។ បទថា **សមង្គិនី** សេចក្តីថា ចូរជាអ្នកប្រកបព្រម គឺប្រកបជាមួយគ្នា បានដល់ ជាអ្នកនៅរួមគ្នា ។ បទថា

**យេធ អត្ថិ** កាត់បទជា **យេ ឥធ អត្ថិ** ប្រែថា ជនពួកណាមាននៅក្នុងទីនេះ ។ បទថា **យក្ខភូតភព្យានិ** សេចក្តីថា យក្ខ ពោល គឺទេវតា ភូត គឺសត្វដែលកើតហើយ ពោល គឺសត្វដែលចម្រើនហើយ តាំងនៅ និងពួកសត្វដែលគប្បីកើត ពោល គឺសត្វដែលចម្រើនក្នុងឥឡូវនេះ ។ បទថា **វេយ្យាវដិកំ** សេចក្តីថា ចូរធ្វើសេចក្តីខ្វល់ខ្វាយដើម្បីខ្ញុំ ។ បទថា **តាយថ មំ** សេចក្តីថា សូមរក្សានូវខ្ញុំ ។ បទថា **យាចាមិ វោ** សេចក្តីថា ខ្ញុំសំណូមពរដល់លោកទាំងឡាយ ។ បទថា **បតិមាហំ** កាត់បទជា **បតិ អហំ** ។ បទថា **អជេយ្យំ** សេចក្តីថា សូមសត្រូវកុំឈ្នះ គឺមិនមានជ័យជម្នះ ។

កាលនោះ សក្កទេវរាជទ្រង់ស្តាប់សំឡេងខ្សឹកខ្សួលរបស់ព្រះនាងចន្ទាទេវីនោះ ដឹងរឿងនោះហើយ ក្នុងខណៈនោះឯង កាន់យកដំបងដែក ដែលរុងរឿងហើយ យាងមកសម្លុតព្រះរាជា ឲ្យដោះលែងមនុស្សទាំងអស់ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្យសានូវព្រះគាថាដូច្នេះថា

អមនុស្ស ( សក្កទេវរាជ ) ឮពាក្យនោះហើយ ក៏គ្រវីដំបងដែកបំភ័យព្រះរាជានោះ ហើយនិយាយនឹងព្រះរាជាដូច្នេះថា ម្នាលស្តេចកាឡកិណី ព្រះអង្គចូរដឹងចុះ កុំឲ្យខ្ញុំសំពងក្បាលព្រះអង្គឡើយ ព្រះអង្គកុំសម្លាប់បុត្រច្បង ជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត ។ ម្នាលស្តេចកាឡកិណី ព្រះអង្គធ្លាប់ឃើញអ្នក

ណា ដែលសម្លាប់បុត្រកិរិយា និងសេដ្ឋីគហបតី ជាអ្នកមិនប្រទូស្ត ព្រោះប្រាថ្នាស្ថានសួគ៌ ។

ខណ្ឌហាលព្រាហ្មណ៍បានឮពាក្យនោះ ទាំងព្រះរាជា ក៏ឃើញសក្កទេវរាជ ដែលព្រះអង្គមិនធ្លាប់ឃើញនេះ ទើបឲ្យស្រាយចំណងពីជនទាំងពួង ឲ្យដូចជាមិនមានសេចក្តីបៀតបៀន ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកជនដែលមកប្រជុំក្នុងកន្លែងនោះ ក៏នាំគ្នាគប់មួយដុំដីៗ ម្នាក់ នេះជាការសម្លាប់ខណ្ឌហាលព្រាហ្មណ៍ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អមនុស្សោ** បានដល់ សក្កទេវរាជ ។ បទថា **ពុជ្ឈស្សុ** បានដល់ ទ្រង់ដឹង គឺទ្រង់កំណត់ ។ បទថា **រាជកលិ** សេចក្តីថា នែព្រះរាជាកាឡកិណី ព្រះរាជាលាមក ។ បទថា **មា តេហំ** សេចក្តីថា នែព្រះរាជាអាក្រក់ ចូរទ្រង់ដឹង កុំឲ្យយើងវាយ គឺប្រហារអំបែងក្បាលរបស់ទ្រង់ឡើយ ។ បទថា **កោ តេ ទិដ្ឋោ** សេចក្តីថា ទ្រង់ធ្លាប់ឃើញក្នុងទីណា ។ សព្ទថា **ហិ** ក្នុងបទថា **សគ្គកាមា ហិ** នេះ ត្រឹមតែជានិបាត អធិប្បាយថា អ្នកប្រាថ្នាចំពោះស្ថានសួគ៌ គឺអ្នកប្រាថ្នាស្ថានសួគ៌ ។ បទថា **តំ សុត្វា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ខណ្ឌហាលបុរោហិតស្តាប់ពាក្យនៃសក្កទេវរាជហើយ ។ បទថា **អត្ភុតមិទំ** សេចក្តីថា ម្យ៉ាងទៀត ព្រះរាជាទ្រង់ឃើញហើយនូវការបង្ហាញរូបនៃសក្កទេវរាជ នេះដែលគួរអស្ចារ្យ មិនធ្លាប់មានមកអំពីមុនឡើយ ។ បទថា **យថា តំ** សេចក្តីថា ឲ្យដោះសត្វទាំងពួង

ដូចដោះអ្នកដែលមិនមានសេចក្ដីអាក្រក់ ដូច្នោះ ។ បទថា **យាវន្តោ ឧបទ្ទវា** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយ មានប្រមាណប៉ុណ្ណា ប្រជុំគ្នាទៀបរណ្ដៅយញ្ញនោះ ធ្វើសំឡេងកងរំពង ឲ្យនូវការប្រហារខណ្ឌ-ហាលបុរោហិត ដោយដុំដីម្នាក់មួយដុំ ។ បទថា **វធោ សោ** សេចក្ដីថា នុ៎ះ ឯងជាការសម្លាប់ខណ្ឌហាលបុរោហិត អធិប្បាយថា ឲ្យខណ្ឌហាលបុរោហិត ដល់នូវការអស់ជីវិតក្នុងទីនោះឯង ។

ឯមហាជន កាលសម្លាប់ខណ្ឌហាលព្រាហ្មណ៍នោះហើយ ក៏ផ្ដើមនឹងសម្លាប់ព្រះរាជា ព្រះពោធិសត្វឱបក្រសោបព្រះរាជបិតាហើយ មិនបានប្រទានឲ្យគេសម្លាប់ ។ មហាជនពោលថា ពួកខ្ញុំឲ្យតែជីវិតប៉ុណ្ណោះដល់ព្រះរាជាអាក្រក់នោះ តែពួកយើងមិនព្រមឲ្យឆត្រ និងទីនៅអាស្រ័យក្នុងព្រះនគរ ដល់ព្រះរាជានោះឡើយ ពួកយើងនឹងធ្វើព្រះរាជា ឲ្យជាមនុស្សចណ្ឌាល រួចឲ្យនៅខាងក្រៅព្រះនគរ ហើយក៏ឲ្យនាំចេញនូវគ្រឿងទ្រទ្រង់របស់ព្រះរាជា ឲ្យទ្រទ្រង់នូវសំពត់ដែលជ្រលក់នូវទឹកម្ចត់ ឲ្យដួតក្បាលដោយកំណាត់សំពត់ជ្រលក់ដោយរមៀត ធ្វើឲ្យជាមនុស្សចណ្ឌាល ហើយបញ្ជូនទៅកាន់លំនៅនៃមនុស្សចណ្ឌាល ។ ចំណែកបុគ្គលពួកណាបូជាយញ្ញដែលប្រកបដោយការសម្លាប់បសុសត្វក្ដី ប្រើឲ្យបូជាក្ដី ត្រេកអរតាមក្ដី ជនទាំងនោះ មាននរកជាទីទៅខាងមុខទាំងអស់ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល

សូត្រសាធ្យានូវព្រះគាថាដូច្នេះថា

ពួកជនទាំងពួង ធ្វើបាបកម្មហើយ ទៅកាន់នរក យ៉ាងណា ពួកជនមិនធ្វើបាបកម្មហើយ ទៅអំពីលោកនេះទៅ គប្បីបាននូវសុគតិ យ៉ាងនោះឯង ដូច្នេះ ។

មហាជនទាំងនោះ កាលនាំមនុស្សក្រោឡកិណីទាំង ២ ចេញទៅហើយ ក៏នាំមកនូវគ្រឿងសម្រាប់អភិសេក ហើយអភិសេកចន្ទកុមារក្នុងទីនោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាធ្យានូវព្រះគាថាដូច្នេះថា

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបុរស មកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបរិស័ទដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកជួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ពួកជនជាច្រើនត្រេកអររីករាយ ប៉ាវគងទូងអានន្ទភេរី ក្នុងកាលដែលចន្ទកុមារចូលទៅក្នុងនគរ ពួកជនបានប្រកាសការរួចចាកចំណង ( របស់ពួកសត្វ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រាជបុរិសា ច** សេចក្តីថា ឯបរិស័ទនៃព្រះរាជាទាំងឡាយ ក៏បានថ្វាយទឹកអភិសេកព្រះចន្ទកុមារនោះ ដោយស័ង្ខទាំង ៣ ។ បទថា **រាជកញ្ញាយោ** សេចក្តីថា ខត្តិយរាជធីតាទាំងឡាយ ក៏ថ្វាយទឹកអភិសេកព្រះចន្ទកុមារ ។ បទថា **ទេវបុរិសា** សេចក្តីថា សក្កទេវរាជមួយអន្លើដោយទេវបរិស័ទ ក៏កាន់ស័ង្ខវិជយុត្រ ថ្វាយទឹកអភិសេក ។ បទថា **ទេវកញ្ញាយោ** សេចក្តីថា នាងសុជាតាទេវធីតា មួយអន្លើដោយទេវកញ្ញាទាំងឡាយ ក៏ថ្វាយទឹកអភិសេក ។ បទថា **ចេលុក្ខេបមករុំ** សេចក្តីថា បានឲ្យលើកទង់ទាំងឡាយ មួយអន្លើដោយសំពត់ពណ៌ផ្សេងៗ លើកឡើងនូវសំពត់ដណ្តប់ទាំងឡាយ ធ្វើឲ្យជាផ្ទាំងសំពត់ក្នុងអាកាស ។ បទថា **រាជុបរិសា**

**ច** សេចក្តីថា រាជបរិស័ទទាំងឡាយ ៣ ពួក គឺរាជកញ្ញា ទេវបរិស័ទ និងទេវកញ្ញា ដែលជាអ្នកធ្វើនូវការអភិសេកព្រះចន្ទកុមារ រួមជា ៤ ពួកជាមួយជាគ្នា បានធ្វើនូវការលើកទង់សំពត់នោះឯង ។ បទថា **អានន្ទិនោ អហុវាធីសុ** សេចក្តីថា មនុស្សទាំងឡាយត្រេកអរក្រៃលែងហើយ ។ បទថា **នន្ទិប្បវេសនគរំ** សេចក្តីថា មនុស្សទាំងឡាយត្រេកអរក្រៃលែងហើយ ក្នុងកាលដែលចន្ទកុមារយាងចូលព្រះនគរ បាំងឆត្រឲ្យ ហើយវាយស្គរឈ្មោះអានន្ទភេរី ប្រកាសពេញព្រះនគរ ។ សួរថា ដើម្បីជាប្រយោជន៍អ្វី ឆ្លើយថា ព្រះចន្ទកុមាររបស់យើងទាំងឡាយ ផុតហើយចាកចំណង យ៉ាងណា មនុស្សទាំងពួង ផុតហើយចាកចំណងដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបលោកពោលថា **ពន្ធនាមោក្ខោ អយោសិត្ថ** ដូច្នេះ ។

គ្រានោះឯង ព្រះពោធិសត្វទ្រង់ផ្តើមតាំងវត្តបដិបត្តិចំពោះព្រះរាជបិតា ។ ព្រះរាជបិតាមិនបានយាងចូលកាន់ព្រះនគរ ។ ក្នុងកាលស្បៀងអាហារអស់ទៅ ព្រះពោធិសត្វក៏យាងទៅដើម្បីជាប្រយោជន៍ដល់កិច្ចផ្សេងៗ មានការក្រសាលឧទ្យានជាដើម ក៏ចូលទៅគាល់ព្រះរាជបិតានោះ តែមិនបានថ្វាយបង្គំ ។ ចំណែកព្រះបាទឯករាជធ្វើអញ្ជលី ហើយត្រាស់ថា សូមទ្រង់មានព្រះជន្មយឺនយូរ ។ ព្រះពោធិសត្វត្រាស់សួរថា ព្រះបិតាបំណងដោយវត្ថុណា ។ ព្រះបាទឯករាជក៏ទូលសេចក្តីប្រាថ្នាឲ្យជ្រាប ។ ព្រះពោធិសត្វឲ្យថ្វាយតម្លៃប្រើប្រាស់ដល់ព្រះរាជបិតា ។ ព្រះពោធិសត្វគ្រងរាជសម្បត្តិដោយធម៌ហើយ ក្នុងទីបំផុតនៃអាយុ ក៏បានទៅកាន់ទេវលោក ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសអរិយសច្ចទាំងឡាយ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តព្យាយាមសម្លាប់មនុស្សជាច្រើន ព្រោះអាស្រ័យតថាគតតែម្នាក់ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ខណ្ឌហាលព្រាហ្មណ៍ក្នុងកាលនោះ បានមកជាទេវទត្ត ភិក្ខុក្នុងកាលឥឡូវនេះ ព្រះនាងគោតមីទេវីក្នុងកាលនោះ បានមកជាព្រះនាងមហាមាយា ព្រះនាងចន្ទាទេវីក្នុងកាលនោះ បានមកជារាហុលមាតា វសុលកុមារក្នុងកាលនោះ បានមកជារាហុល ព្រះនាងសេលាកុមារក្នុងកាលនោះ បានមកជាឧប្បលវណ្ណា សុរកុមារក្នុងកាលនោះ បានមកជាអានន្ទ រាមគោត្រក្នុងកាលនោះ បានមកជាកស្សបៈ ភទ្ទសេនក្នុងកាលនោះ បានមកជាមោគ្គល្លាន សុរិយាកុមារក្នុងកាលនោះ បានមកជាសារីបុត្រ សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯចន្ទកុមារក្នុងកាលនោះ គឺតថាគតដ៏ជាសម្មាសម្ពុទ្ធនេះឯង ។

**អដ្ឋកថា ចន្ទកុមារជាតក ចប់**

# ក្បាលទី ៥១

# សុត្តន្តបិដកបាលីប្រែ -៦២

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | | លេខទំព័រ |
|---|---|---|
| តេមិយជាតក | ...... ...... ...... ...... | ២ |
| អដ្ឋកថា តេមិយជាតក | ...... ...... ...... ...... | ២១ |
| ចន្ទកុមារជាតក | ...... ...... ...... ...... | ៨៩៩ |
| អដ្ឋកថា ចន្ទកុមារជាតក | ...... ...... ...... ...... | ៩២៩ |